# ព្រះត្រៃបិដក

## ប្រែរួមនឹងព្រះអដ្ឋកថា

## ភាគ១៨

បាលីប្រែ ២៧ - ២៨

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# បបញ្ចសូទនី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

## មជ្ឈិមនិកាយ ឧបរិបណ្ណាសក

## អដ្ឋមភាគ សុញ្ញតវគ្គ

## នវមភាគ វិភង្គវគ្គ

# ១៨

## បាលីប្រែ ២៧-២៨



*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៤៣*

# ក្បាលទី ១៨

# មជ្ឈិមនិកាយ ឧបរិបណ្ណាសក

# អដ្ឋមភាគ

# សុញ្ញតវគ្គ

## ចូឡសុញ្ញតសូត្រទី ១

[ ១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគគង់ក្នុងប្រាសាទរបស់មិគារមាតា ក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ គ្រានោះ ព្រះអានន្ទមានអាយុ ចេញអំពីទីសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះអានន្ទមានអាយុ គង់ក្នុងទីសមគួរហើយ ក៏ទូលស្នើនឹងព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សម័យមួយ ព្រះមានព្រះភាគគង់ក្នុងនគរតូច ជានិគមរបស់ពួកសក្យៈ ក្នុងសក្កជនបទ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានរៀនក្នុងទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគក្នុងទីនោះថា ម្នាលអានន្ទ ឥឡូវនេះ តថាគតនៅច្រើនដោយការនៅស្ងប់ស្ងាត់ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនុ៎ះ ឈ្មោះថា ខ្ញុំព្រះអង្គបានស្តាប់ដោយប្រពៃ បានរៀនដោយប្រពៃ បានធ្វើទុកក្នុងចិត្តដោយប្រពៃ បានចងចាំដោយប្រពៃហើយឬ ។

[ ២ ] ព្រះមានព្រះភាគត្រាស់ថា អើអានន្ទ ពាក្យនុ៎ះ ឈ្មោះថាអ្នក

បានស្តាប់ដោយប្រពៃ រៀនដោយប្រពៃ ធ្វើទុកក្នុងចិត្តដោយប្រពៃ ចងចាំដោយប្រពៃហើយ ។ ម្នាលអានន្ទ កាលពីដើមក្តី ឥឡូវនេះក្តី តថាគតធ្លាប់នៅច្រើន ដោយការនៅស្ងប់ស្ងាត់ ។ ម្នាលអានន្ទ ប្រាសាទរបស់មិគារមាតានេះ សូន្យចាកដំរី គោ សេះ លា សូន្យចាកមាស និងប្រាក់ សូន្យចាកការជួបជុំស្រី និងប្រុសអស់ហើយ ។ តែទីនេះ មិនមែនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យភិក្ខុសង្ឃ មានឧបមាដូចម្តេចមិញ ម្នាលអានន្ទ មានឧបមេយ្យដូចជាភិក្ខុមិនធ្វើទុកក្នុងចិត្តនូវគាមសញ្ញា ( សេចក្តីសម្គាល់ថាស្រុក ) មិនធ្វើទុកក្នុងចិត្តនូវមនុស្សសញ្ញា ( សេចក្តីសម្គាល់ថាមនុស្ស ) ទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យអរញ្ញសញ្ញា ( សេចក្តីសម្គាល់ថាព្រៃ ) ក៏ដូច្នោះដែរ ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងអរញ្ញសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យគាមសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយ ណានៅមាន ព្រោះអាស្រ័យមនុស្សសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្តីក្រវល់ក្រវាយនេះ បែរជានៅមាន គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យអរញ្ញសញ្ញា ។ ភិក្ខុនោះដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសម្គាល់ថាសូន្យចាកគាមសញ្ញា ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសម្គាល់ថាសូន្យចាកមនុស្សសញ្ញា ។ តែទីនេះ មិនមែនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យអរញ្ញសញ្ញា ។

ព្រោះហេតុនោះ បើសេចក្តីក្រវល់ក្រវាយណា មិនដែលមានត្រង់កន្លែងនោះ ភិក្ខុក៏ពិចារណាឃើញនូវសេចក្តីក្រវល់ក្រវាយនោះ ថាជារបស់សូន្យ ត្រង់កន្លែងនោះ បើសេចក្តីក្រវល់ក្រវាយណាសេសសល់នៅ ត្រង់កន្លែងនោះ ភិក្ខុក៏ដឹងច្បាស់នូវសេចក្តីក្រវល់ក្រវាយដែលនៅមាននោះថា សេចក្តីក្រវល់-ក្រវាយនេះ នៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថា មានការកើតឡើងនៃសេចក្តីសូន្យទុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាត យ៉ាងនេះខ្លះ ។

[ ៣ ] ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្តនូវមនុស្សសញ្ញា មិនធ្វើទុកក្នុងចិត្តនូវអរញ្ញសញ្ញាទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យបឋវីសញ្ញា ( សេចក្តីសម្គាល់ថាដី ) ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងបឋវីសញ្ញា ។ ម្នាលអានន្ទ ស្បែកគោដែលគេកោស គេរុស ដោយខ្នាស មានឧបមាដូចម្តេចមិញ ម្នាលអានន្ទ មានឧបមេយ្យដូចជាទីណាខ្ពស់ ទាប ច្រាំងទឹក ច្រាំងភក់ មានដង្កត់ និងបន្លាច្រេះច្រាង មានភ្នំរដិបរដុប ដែលមាននៅលើផែនដីនេះ ភិក្ខុមិនធ្វើទុកក្នុងចិត្តនូវទីទាំងអស់នោះទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យបឋវីសញ្ញា ក៏ដូច្នោះដែរ ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងបឋវីសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យមនុស្សសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន

ព្រោះអាស្រ័យអរញ្ញសញ្ញា សេចក្ដីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្ដីក្រវល់ក្រវាយនេះ បែរជានៅមាន គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យបឋវីសញ្ញា ។ ភិក្ខុនោះដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្ដីសម្គាល់ថាសូន្យ ចាកមនុស្សសញ្ញា ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្ដីសម្គាល់ថាសូន្យចាកអរញ្ញសញ្ញា ។ តែទីនេះ មិនមែនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យបឋវីសញ្ញា ។ ព្រោះហេតុនោះ បើសេចក្ដីក្រវល់ក្រវាយណា មិនមានត្រង់កន្លែងនោះ ភិក្ខុពិចារណាឃើញនូវសេចក្ដីក្រវល់ក្រវាយនោះ ថាជារបស់សូន្យ ត្រង់កន្លែងនោះ បើសេចក្ដីក្រវល់ក្រវាយណា សេសសល់នៅ ត្រង់កន្លែងនោះ ភិក្ខុក៏ដឹងច្បាស់នូវសេចក្ដីក្រវល់ក្រវាយដែលនៅមាននោះថា សេចក្ដីក្រវល់ក្រវាយនេះ នៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថាមានការកើតឡើងនៃសេចក្ដីសូន្យទុំៈ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាត យ៉ាងនេះឯង ។

[ ៤ ] ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្តនូវអរញ្ញសញ្ញា មិនធ្វើទុកក្នុងចិត្តនូវបឋវីសញ្ញាទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យអាកាសានញ្ចាយតនសញ្ញា ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ក្នុងអាកាសានញ្ចាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្ដីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យអរញ្ញ-សញ្ញា សេចក្ដីក្រវល់ក្រវាយទាំងនោះ មិនមាន ក្នុងទីនេះទេ សេចក្ដីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យបឋវីសញ្ញា សេចក្ដីក្រវល់

ក្រវាយទាំងនោះ មិនមាន ក្នុងទីនេះទេ តែសេចក្ដីក្រវល់ក្រវាយនេះ បែរជានៅមាន គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យអាកាសានញ្ចាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្ដីសម្គាល់ថាសូន្យ ចាកអរញ្ញសញ្ញា ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្ដីសម្គាល់ថាសូន្យ ចាកបឋវីសញ្ញា ។ តែទីនេះ មិនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យអាកាសានញ្ចាយតនសញ្ញា ។ ព្រោះហេតុនោះ បើសេចក្ដីក្រវល់ក្រវាយណា មិនមានត្រង់កន្លែងនោះទេ ភិក្ខុពិចារណាឃើញ នូវសេចក្ដីក្រវល់ក្រវាយនោះ ត្រង់កន្លែងនោះ ថាជារបស់សូន្យ បើសេចក្ដីក្រវល់ក្រវាយណា សេសសល់នៅត្រង់កន្លែងនោះ ភិក្ខុដឹងច្បាស់នូវសេចក្ដីក្រវល់ក្រវាយ ដែលនៅមាននោះថា សេចក្ដីក្រវល់ក្រវាយនេះ នៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថាមានការកើតឡើងនៃសេចក្ដីសូន្យនុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាត យ៉ាងនេះខ្លះ ។

[ ៥ ] ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្តនូវបឋវីសញ្ញា មិនធ្វើទុកក្នុងចិត្តនូវអាកាសានញ្ចាយតនសញ្ញាទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យវិញ្ញាណញ្ចាយតនសញ្ញា ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងវិញ្ញាណញ្ចាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្ដីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យបឋវីសញ្ញា សេចក្ដីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្ដីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យអាកាសានញ្ចាយតន-

សញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្តីក្រវល់ក្រវាយនេះ បែរជានៅមាន គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យវិញ្ញាណញ្ចាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសម្គាល់ថា សូន្យចាកបឋវីសញ្ញា ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសម្គាល់ថា សូន្យចាកអាកាសានញ្ចាយតនសញ្ញា ។ តែទីនេះ មិនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យវិញ្ញាណញ្ចាយតនសញ្ញា ។ ព្រោះហេតុនោះ បើសេចក្តីក្រវល់ក្រវាយណាមិនមាន ត្រង់កន្លែងនោះ ភិក្ខុពិចារណាឃើញនូវសេចក្តីក្រវល់ក្រវាយនោះ ត្រង់កន្លែងនោះ ថាជារបស់សូន្យ បើសេចក្តីក្រវល់ក្រវាយណាសេសសល់នៅ ត្រង់កន្លែងនោះ ភិក្ខុក៏ដឹងច្បាស់នូវសេចក្តីក្រវល់ក្រវាយ ដែលនៅមាននោះថា សេចក្តីក្រវល់ក្រវាយនេះ នៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថា មានការកើតឡើងនៃសេចក្តីសូន្យទុំះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាត យ៉ាងនេះខ្វះ ។

[ ៦ ] ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្តនូវអាកាសានញ្ចាយតនសញ្ញា មិនធ្វើទុកក្នុងចិត្តនូវវិញ្ញាណញ្ចាយតនសញ្ញាទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យអាកិញ្ចញ្ញាយតនសញ្ញា ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងអាកិញ្ចញ្ញាយតនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមានព្រោះអាស្រ័យអាកាសានញ្ចាយតនសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យ

វិញ្ញាណញ្ចាយតនសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្តីក្រវល់ក្រវាយនេះ បែរជានៅមាន គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យអាកិញ្ចញ្ញាយតនសញ្ញា ។ ភិក្ខុនោះដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសម្គាល់ថា សូន្យចាកអាកាសានញ្ចាយតនសញ្ញា ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសម្គាល់ថា សូន្យចាកវិញ្ញាណញ្ចាយតនសញ្ញា ។ តែទីនេះ មិនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យអាកិញ្ចញ្ញាយតន-សញ្ញា ។ ព្រោះហេតុនោះ បើសេចក្តីក្រវល់ក្រវាយណា មិនមានក្នុងទីនោះ ភិក្ខុពិចារណាឃើញនូវសេចក្តីក្រវល់ក្រវាយនោះ ត្រង់កន្លែងនោះ ថាជារបស់សូន្យ បើសេចក្តីក្រវល់ក្រវាយណា សេសសល់នៅត្រង់ទីនោះ ភិក្ខុក៏ដឹងច្បាស់នូវសេចក្តីក្រវល់ក្រវាយ ដែលមាននោះថា សេចក្តីក្រវល់ក្រវាយនេះនៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថាមានការកើតឡើងនៃសេចក្តីសូន្យទុំះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាតយ៉ាងនេះខ្វះ ។

[ ៧ ] ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្តនូវវិញ្ញាណញ្ចា-យតនសញ្ញា មិនធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនសញ្ញាទេ តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យនេវសញ្ញានាសញ្ញាយតនសញ្ញា ។ ភិក្ខុនោះមានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងនេវសញ្ញានាសញ្ញាយ-តនសញ្ញា ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំង-ឡាយណា នៅមាន ព្រោះអាស្រ័យវិញ្ញាណញ្ចាយតនសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយណា

នៅមាន ព្រោះអាស្រ័យអាកិញ្ចញ្ញាយតនសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្តីក្រវល់ក្រវាយនេះ បែរជានៅមាន គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យនេវសញ្ញានាសញ្ញាយតនសញ្ញា ។ ភិក្ខុនោះដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសម្គាល់ថា សូន្យចាកវិញ្ញាណញ្ចាយតនសញ្ញា ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសម្គាល់ថា សូន្យចាកអាកិញ្ចញ្ញាយតនសញ្ញា ។ តែទីនេះ មិនឈ្មោះថាសូន្យទេ គឺនៅមានសភាវៈមួយ ព្រោះអាស្រ័យនេវសញ្ញានាសញ្ញាយតនសញ្ញា ។ ព្រោះហេតុនោះ បើសេចក្តីក្រវល់ក្រវាយណា មិនមានក្នុងទីនោះ ភិក្ខុពិចារណាឃើញនូវសេចក្តីក្រវល់ក្រវាយនោះ ត្រង់ទីនោះ ថាជារបស់សូន្យ បើសេចក្តីក្រវល់ក្រវាយណានៅមានសល់ត្រង់ទីនោះ ភិក្ខុក៏ដឹងច្បាស់ថា សេចក្តីក្រវល់ក្រវាយដែលនៅមាននោះថា សេចក្តីក្រវល់ក្រវាយនេះនៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯងឈ្មោះថា មានការកើតឡើងនៃសេចក្តីសូន្យនុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាត យ៉ាងនេះខ្លះ ។

[ ៨ ] ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនសញ្ញា មិនធ្វើទុកក្នុងចិត្តនូវនេវសញ្ញានាសញ្ញាយតនសញ្ញា តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យអនិមិត្តចេតោសមាធិ ។ ភិក្ខុនោះមានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ ក្នុងអនិមិត្តចេតោសមាធិ ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យអាកិញ្ចញ្ញាយតនសញ្ញា សេចក្តីក្រវល់ក្រវាយទាំងនោះ មិន

មានក្នុងទីនេះទេ សេចក្ដីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យនេវសញ្ញានាសញ្ញាយតនសញ្ញា សេចក្ដីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ តែសេចក្ដីក្រវល់ក្រវាយនេះ បែរជានៅមាន គឺមាន ព្រោះអាស្រ័យនូវកាយដែលប្រកបដោយសឡាយតនៈនេះ ដោយមានជីវិតជាបច្ច័យ ។ ភិក្ខុនោះ ដឹងច្បាស់ថា ទីនេះដល់នូវសេចក្ដីសម្គាល់ថាសូន្យ ចាកអាកិញ្ចញ្ញាយតនសញ្ញា ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្ដីសម្គាល់ថា សូន្យចាកនេវសញ្ញានាសញ្ញាយតនសញ្ញា ។ តែទីនេះ មិនឈ្មោះថាសូន្យទេ គឺនៅមានព្រោះអាស្រ័យកាយ ដែលប្រកបដោយសឡាយតនៈនេះ ដោយមានជីវិតជាបច្ច័យ ។ ព្រោះហេតុនោះ បើសេចក្ដីក្រវល់ក្រវាយណា មិនមានក្នុងទីនោះ ភិក្ខុក៏ពិចារណាឃើញសេចក្ដីក្រវល់ក្រវាយនោះ ត្រង់ទីនោះ ថាជារបស់សូន្យ បើសេចក្ដីក្រវល់ក្រវាយណា សល់នៅក្នុងទីនោះ ភិក្ខុក៏ដឹងច្បាស់នូវសេចក្ដីក្រវល់ក្រវាយដែលមាននោះថា សេចក្ដីក្រវល់ក្រវាយនេះនៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថា មានការកើតឡើងនៃសេចក្ដីសូន្យទុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធស្អាត យ៉ាងនេះខ្ញុំ ។

[ ៩ ] ម្នាលអានន្ទ មួយទៀត ភិក្ខុមិនធ្វើទុកក្នុងចិត្តនូវអាកិញ្ចញ្ញាយតនសញ្ញា មិនធ្វើទុកក្នុងចិត្ត នូវនេវសញ្ញានាសញ្ញាយតនសញ្ញា តែធ្វើទុកក្នុងចិត្តនូវសភាវៈមួយ ព្រោះអាស្រ័យអនិមិត្តចេតោសមាធិ ។ ភិក្ខុនោះ មានចិត្តស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ជឿស៊ប់ក្នុងអនិមិត្តចេតោសមាធិ ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា អនិមិត្តចេតោសមាធិនេះ អាត្មាអញបានតាក់តែង

ហើយ បានរិះគិតសន្សំហើយ ។ ភិក្ខុនោះដឹងទៀតថា បើធម្មជាតណាមួយ ដែលអាត្មាអញតាក់តែងហើយ រិះគិតសន្សំហើយ ធម្មជាតនោះ មិនទៀង មានការរលត់ជាធម្មតា ។ កាលបើភិក្ខុដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តក៏រួច ចាកកាមាសវៈផង ចិត្តក៏រួចចាកភវាសវៈផង ចិត្តក៏រួចចាកអវិជ្ជាសវៈផង កាលបើចិត្តរួចស្រឡះហើយ ញាណក៏កើតឡើងថា អាត្មាអញមានចិត្តរួច ស្រឡះហើយ ភិក្ខុនោះដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចារី អាត្មាអញ បានប្រព្រឹត្តស្រេចហើយ កិច្ចដែលអញត្រូវធ្វើ ក៏ធ្វើស្រេចហើយ មិនមាន កិច្ចដទៃ ក្រៅពីនេះទៀតទេ ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា សេចក្តី ក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យកាមាសវៈ សេចក្តី ក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយ ណានៅមាន ព្រោះអាស្រ័យភវាសវៈ សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមាន ក្នុងទីនេះទេ សេចក្តីក្រវល់ក្រវាយទាំងឡាយណា នៅមាន ព្រោះអាស្រ័យ អវិជ្ជាសវៈ សេចក្តីក្រវល់ក្រវាយទាំងនោះ មិនមានក្នុងទីនេះ តែសេចក្តី ក្រវល់ក្រវាយនេះ បែរជានៅមាន គឺនៅមាន ព្រោះអាស្រ័យកាយ ដែល ប្រកបដោយសឡាយតនៈនេះឯង ដោយមានជីវិតជាបច្ច័យ ។ ភិក្ខុនោះ ដឹង ច្បាស់ថា ទីនេះ ដល់នូវសេចក្តីសម្គាល់ថា សូន្យចាកកាមាសវៈ ដឹងច្បាស់ ថា ទីនេះ ដល់នូវសេចក្តីសម្គាល់ថា សូន្យចាកភវាសវៈ ដឹងច្បាស់ថា ទីនេះ ដល់នូវសេចក្តីសម្គាល់ថា សូន្យចាកអវិជ្ជាសវៈ ។ តែទីនេះ មិនឈ្មោះថា សូន្យទេ គឺនៅមាន ព្រោះអាស្រ័យកាយ ដែលប្រកបដោយសឡាយតនៈ

នេះឯង ដោយមានជីវិតជាបច្ច័យ ។ សេចក្ដីក្រវល់ក្រវាយណា មិនមានក្នុងទីនោះ ភិក្ខុពិចារណាឃើញនូវសេចក្ដីក្រវល់ក្រវាយនោះ ត្រង់ទីនេះ ថាជារបស់សូន្យ ពុំនោះ បើសេចក្ដីក្រវល់ក្រវាយណា សល់នៅក្នុងទីនោះ ភិក្ខុក៏ដឹងច្បាស់នូវសេចក្ដីក្រវល់ក្រវាយដែលមាននោះថា សេចក្ដីក្រវល់ក្រវាយនេះ នៅមាន ។ ម្នាលអានន្ទ ភិក្ខុនោះឯង ឈ្មោះថា មានការកើតឡើងនៃសេចក្ដីសូន្យទុ៎ះ ដែលជារបស់ពិត មិនប្រែប្រួល បរិសុទ្ធ ប្រសើរក្រៃលែងយ៉ាងនេះឯង ។

[ ១០ ] ម្នាលអានន្ទ សមណៈ ឬព្រាហ្មណ៍ណាមួយ ក្នុងអតីតកាល បានចូលកាន់សុញ្ញតៈដ៏បរិសុទ្ធ ប្រសើរក្រៃលែង ពួកសមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ តែងចូលកាន់សុញ្ញតៈ ដ៏បរិសុទ្ធ ប្រសើរក្រៃលែងនេះឯង ។ ម្នាលអានន្ទ បើពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ក្នុងអនាគតកាល នឹងចូលកាន់សុញ្ញតៈដ៏បរិសុទ្ធ ប្រសើរក្រៃលែង ពួកសមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ នឹងចូលកាន់សុញ្ញតៈដ៏បរិសុទ្ធ ប្រសើរក្រៃលែងនេះឯង ។ ម្នាលអានន្ទ បើពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ក្នុងបច្ចុប្បន្នកាល ចូលកាន់សុញ្ញតៈដ៏បរិសុទ្ធ ប្រសើរក្រៃលែង ពួកសមណៈ ឬព្រាហ្មណ៍ទាំងអស់នោះ តែងចូលកាន់សុញ្ញតៈ ដ៏បរិសុទ្ធ ប្រសើរក្រៃលែងនេះឯង ។ ម្នាលអានន្ទ ហេតុនោះ ក្នុងសាសនានេះ ភិក្ខុត្រូវគិតថា យើងរាល់គ្នា នឹងចូលកាន់សុញ្ញតៈដ៏បរិសុទ្ធ ប្រសើរក្រៃលែង ម្នាលអានន្ទ អ្នកទាំងឡាយ គប្បីសិក្សាយ៉ាងនេះឯង ។ លុះព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអានន្ទ

មានអាយុ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះឯង ។

## ចប់ ចូឡសុញ្ញតសូត្រទី ១

# អដ្ឋកថា

# មជ្ឈិមនិកាយ ឈ្មោះ បបញ្ចសូទនី

# ឧបរិបណ្ណាសក

## សុញ្ញតវគ្គ

## ចូឡសុញ្ញតាសូត្រ

[ ១ ] *ចូឡសុញ្ញតាសូត្រ មានបទផ្ដើមថា* **ឯវម្មេ សុតំ** *ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា* **ឯកមិទំ** *សេចក្ដីថា បានឮថា ព្រះថេរៈបានធ្វើវត្តដល់ព្រះមានព្រះភាគ ហើយទៅកាន់ទីសម្រាកពេលថ្ងៃរបស់ខ្លួន កំណត់វេលា ហើយអង្គុយចម្រើនសុញ្ញតាផលសមាបត្តិ មានព្រះនិព្វានជាអារម្មណ៍ហើយ ចេញតាមវេលាដែលកំណត់ ។ លំដាប់នោះ សង្ខាររបស់លោកប្រាកដដោយភាពជារបស់ទទេ លោកពិចារណាសុញ្ញតាកថា ហើយមានការគិតយ៉ាងនេះថា អាត្មាអញមានធុរៈស្មុគស្មាញ មិនអាចទៅក្រាបទូលដល់ព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាត្រាស់សុញ្ញតា-កថាដល់ខ្ញុំព្រះអង្គ ណ្ហើយចុះ អញនឹងឲ្យព្រះអង្គរឭកដល់ការដែលព្រះអង្គចូលទៅអាស្រ័យនិគមឈ្មោះនគរកៈ ត្រាស់កថារឿងមួយនោះ ព្រះមានព្រះភាគនឹងត្រាស់សុញ្ញតាកថា ដល់អាត្មាអញយ៉ាងនេះ កាលព្រះអានន្ទឲ្យព្រះសាស្ដាទ្រង់រឭកបាន ទើបពោលពាក្យថា* **ឯកមិទំ** *ជាដើម ។ បទថា* **ឥទំ** *ក្នុងបទថា* **ឯកមិទំ** *នុ៎ះ ត្រឹមតែជានិបាតប៉ុណ្ណោះ ។ បទថា* **កច្ចិ មេតំ**

**ភន្តេ** សេចក្តីថា ព្រះថេរៈចាំបានត្រឹមតែមួយបទ ក៏អាចពង្រីកនូវការចាំបាន ដល់ទៅ ៦ ម៉ឺនបទ ព្រោះដូច្នោះ លោកនឹងមិនអាចមានសុញ្ញតាវិហារធម៌ ហើយទ្រទ្រង់ចាំត្រឹមតែបទមួយ ដូច្នោះ ការដែលបុគ្គលបំណងនឹងស្តាប់ ធ្វើហាក់ដូចជាបុគ្គលដឹងហើយ សួរ មិនសមគួរ ព្រះថេរៈបំណងនឹងស្តាប់សុញ្ញតាកថាដែលព្រះអង្គទ្រង់សម្តែងយ៉ាងពិស្តារឲ្យជាក់ច្បាស់ ទើបអាពធនាយ៉ាងនេះ ហាក់ដូចជាមិនដឹង បុគ្គលខ្លះមិនដឹង ក៏ធ្វើហាក់ដូចជាអ្នកដឹង ។ ព្រះថេរៈធ្វើការបោកបញ្ឆោតយ៉ាងនេះបានដូចម្តេច ។ ព្រះថេរៈសម្តែងសេចក្តីគោរពចំពោះព្រះមានព្រះភាគ ទើបទូលពាក្យថា **កច្ចិ មេតំ** ដូច្នេះជាដើម ក្នុងឋានៈដែលខ្លួនដឹង ។

[ ២ ] បទថា **បុព្វេ** សេចក្តីថា សូម្បីក្នុងវេលាដែលចូលទៅអាស្រ័យនិគមឈ្មោះនគរកៈ ក្នុងបឋមពោធិកាល ។ បទថា **ឯតរហិ** ប្រែថា ក្នុងឥឡូវនេះ ។ ព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ទើបមានព្រះពុទ្ធតម្រិះថា អានន្ទបំណងនឹងស្តាប់សុញ្ញតាកថា ឯបុគ្គលខ្លះអាចនឹងស្តាប់ តែមិនអាចរៀន បុគ្គលខ្លះអាចស្តាប់ផង រៀនផង តែមិនអាចសម្តែង តែសម្រាប់អានន្ទអាចទាំងស្តាប់ ទាំងរៀន ទាំងសម្តែង តថាគតនឹងពោលសុញ្ញតាកថាដល់អានន្ទ ។ កាលត្រាស់សុញ្ញតាកថានោះ ទើបត្រាស់ពាក្យថា **សេយ្យថាបិ** ដូច្នេះជាដើម ដោយប្រការយ៉ាងនេះ ។

បណ្តាបទទាំងនោះ បទថា **សុញ្ញោ ហត្ថិគវាស្សវឡវេន** នោះ សេចក្តីថា ដំរីជាដើម ដែលធ្វើជាដំរីឈើ ដំរីដី ដំរីគំនូរ មាននៅក្នុងប្រាសាទនោះ

ប្រាក់មាសដែលធ្វើជាចិត្រកម្ម ក្នុងទីតាំងនៃស្តេចវេស្សវ័ណ ស្តេចមន្ធាតុរាជជាដើមខ្លះ ដែលគេប្រកបជាបន្អួច ទ្វារ និងគ្រែតាំង ដែលប្រដាប់ដោយមាសប្រាក់នោះ ក៏រក្សាទុកដើម្បីបដិសន្ខរណៈ គឺជួសជុលរបស់ចាស់ក៏មាន ។ ស្រីប្រុសដែលមកស្តាប់ធម៌ និងសួរបញ្ហាជាដើម ធ្វើដោយរូបឈើជាដើមមាន ដូច្នោះ ទើបប្រាសាទនោះមិនទទេចាកស្រី និងប្រុសទាំងនោះ ។ លោកពោលពាក្យនេះ សំដៅដល់ការមិនមាននៃជីវជាដើម ដែលមានវិញ្ញាណ ទាក់ទងដោយឥន្ទ្រិយ ប្រាក់ និងមាស ដែលប្រើប្រាស់ក្នុងខណៈត្រូវការ និងស្រីប្រុសដែលនៅជានិច្ច ។ បទថា **ភិក្ខុសង្ឃំ បដិច្ច** សេចក្តីថា ព្រោះថាសូម្បីភិក្ខុទាំងឡាយ ចូលទៅបិណ្ឌបាត ប្រាសាទនោះក៏មិនទទេចាកភិក្ខុដែលត្រេកអរដោយកត្ត ក្នុងវិហារ និងភិក្ខុឈឺ ភិក្ខុថែភិក្ខុឈឺ ភិក្ខុអ្នកសិក្សា ភិក្ខុអ្នកខ្វល់ខ្វាយក្នុងចីវរកម្មជាដើម ដោយប្រការដូច្នេះ ។ ទើបលោកពោលយ៉ាងនេះ ។ ព្រោះមានភិក្ខុនៅប្រចាំ ។ បទថា **ឯកត្តំ** ប្រែថា ភាពតែមួយអធិប្បាយថា មិនទំនេរឡើយ ។ លោកអធិប្បាយថា មានការមិនទំនេរតែម្យ៉ាង ។ បទថា **អមនសិការិត្វា** ប្រែថា មិនធ្វើទុកក្នុងចិត្ត ។ បទថា **អនាវជ្ជិត្វា** ប្រែថា មិនពិចារណា ។ បទថា **គាមសញ្ញំ** សេចក្តីថា ការសម្គាល់ថា ស្រុកកើតឡើង ដោយប្រកាន់ថាជាស្រុក ឬដោយជាកិលេស ។ សូម្បីមនុស្សសញ្ញាក៏មានន័យដូចគ្នានេះឯង ។ បទថា **អរញ្ញសញ្ញំ បដិច្ច មនសិការោតិ ឯកត្តំ** សេចក្តីថា ធ្វើទុកក្នុងចិត្តនូវព្រៃនេះថា ជាអរញ្ញសញ្ញាចំពោះព្រៃតែម្យ៉ាងប៉ុណ្ណោះ យ៉ាងនេះថា នេះដើមឈើ នេះភ្នំ នេះជង

ព្រៃពណ៌ខៀវស្រងាត់ ។ បទថា **បក្ខន្ទតិ** ប្រែថា ឈមចុះ ។ បទថា **អធិមុច្ចតិ** ប្រែថា បង្អោនទៅថា យ៉ាងនោះ ។ បទថា **យេ អស្សុ ទរថា** សេចក្តីថា ការក្រវល់ក្រវាយដែលប្រព្រឹត្តទៅហើយក្តី ការក្រវល់ក្រវាយព្រោះកិលេសក្តី ដែលគប្បីមាន ព្រោះអាស្រ័យគាមសញ្ញាទាំងនោះ រមែងមិនមានដោយអារញ្ញសញ្ញាក្នុងព្រៃនេះ ។ ក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ បទថា **អត្ថិ ចេវាយំ** សេចក្តីថា តែមានត្រឹមតែការក្រវល់ក្រវាយដែលប្រព្រឹត្តទៅ ដែលកើតឡើងព្រោះអាស្រ័យអារញ្ញសញ្ញាតែម្យ៉ាង ។ បទថា **យំ ហិ ខោ តត្ថ ន ហោតិ** សេចក្តីថា ការក្រវល់ក្រវាយដែលប្រព្រឹត្តទៅហើយ និងការក្រវល់ក្រវាយព្រោះកិលេស ដែលកើតឡើងដោយគាមសញ្ញានិងមនុស្សសញ្ញានោះ រមែងមិនមានក្នុងអរញ្ញសញ្ញានេះ ដូចដំរីជាដើមមិនមានក្នុងប្រាសាទនៃនាងវិសាខាមិគារមាតា ។ បទថា **យំ បន តត្ថ អវសិដ្ឋំ** សេចក្តីថា ទោះបីមានសល់ ក៏ត្រឹមតែការក្រវល់ក្រវាយដែលប្រព្រឹត្តទៅក្នុងអារញ្ញសញ្ញានោះ ។ ដូចភិក្ខុសង្ឃ ដែលនៅក្នុងប្រាសាទនៃនាងវិសាខាមិគារមាតា ។ បទថា **តំ សន្តមិទំ អត្ថីតិ បជានាតិ** សេចក្តីថា ដឹងច្បាស់នូវវត្ថុនោះដែលមានប៉ុណ្ណោះថា វត្ថុនេះមាន ។ បទថា **សុញ្ញតាវក្កន្តិ** ប្រែថា ការកើតឡើងនៃសុញ្ញតា ។

[ ៣ ] បទថា **អមនសិករិត្វា មនុស្សសញ្ញំ** គឺមិនកាន់យកគាមសញ្ញាក្នុងបទនេះ ។ ព្រោះហេតុអ្វី ព្រោះបានឮថា ភិក្ខុនោះមានការគិតយ៉ាងនេះថា អញនឹងញ៉ាំងគាមសញ្ញាឲ្យកើត ដោយមនុស្សសញ្ញា ញ៉ាំងមនុស្សសញ្ញាឲ្យ

*កើតដោយអរញ្ញសញ្ញា ញុំាងអរញ្ញសញ្ញាឲ្យកើតដោយបឋវីសញ្ញា ញុំាងបឋវីសញ្ញាឲ្យកើតដោយអាកាសានញ្ចាយតនសញ្ញា ។បេ។ ញុំាងអាកិញ្ចញ្ញាយតនសញ្ញាឲ្យកើតដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ញុំាងនេវសញ្ញានាសញ្ញាយតនសញ្ញាឲ្យកើតដោយវិបស្សនា ញុំាងវិបស្សនាឲ្យកើតដោយមគ្គ និងសម្តែងអច្ចន្តសញ្ញាដោយលំដាប់ ដូច្នោះ ទើបផ្តើមទេសនាយ៉ាងនេះ ។*

*ក្នុងបទទាំងនោះ បទថា* **បឋវីសញ្ញំ** *សេចក្តីថា ព្រោះហេតុអ្វី ទើបលះអរញ្ញសញ្ញា ដាក់ចិត្តក្នុងបឋវីសញ្ញា ព្រោះសម្រេចគុណវិសេសដោយអរញ្ញសញ្ញា ប្រៀបដូចបុរសឃើញទីស្រែដែលគួរីករាយ សម្លឹងមើលស្រែអស់ ៧ ដងដោយគិតថា ស្រូវសាលីជាដើម ដែលព្រោះចូលក្នុងស្រែនេះ នឹងបរិបូណ៌ដោយល្អ អញនឹងបានលាភធំ ស្រូវសាលីជាដើមរមែងមិនបរិបូណ៌ឡើយ តែបើបុគ្គលធ្វើទីនោះឲ្យប្រាសចាកជង្គត់ និងបន្លា ហើយភ្ជួរ សាបព្រោះ កាលបើដូច្នេះ ស្រូវសាលីរមែងបរិបូណ៌ យ៉ាងណា ភិក្ខុក៏ដូច្នោះដូចគ្នា មនសិការព្រៃនេះឲ្យជាអរញ្ញសញ្ញាអស់ ៧ ដងថា នេះព្រៃ នេះដើមឈើ នេះភ្នំ នេះដងព្រៃខៀវស្រងាត់ រមែងសម្រេចឧបចារសមាធិ ។ សម្រាប់បឋវីសញ្ញា ភិក្ខុនោះធ្វើបឋវីកសិណ បរិកម្មឲ្យជាកម្មដ្ឋានប្រចាំ ញុំាងឈានឲ្យកើត ចម្រើនវិបស្សនាដែលមានឈានជាបទដ្ឋាន អាចនឹងសម្រេចអរហត្តបាន ព្រោះដូច្នោះ លោករមែងលះអរញ្ញសញ្ញា មនសិការបឋវីសញ្ញា ។ បទថា* **បដិច្ច** *ប្រែថា អាស្រ័យគ្នាកើតឡើង ។*

*ឥឡូវនេះ ដើម្បីសម្តែងការប្រៀបធៀបបឋវីកសិណដែលមានការសម្គាល់*

ថា បឋវីក្នុងបឋវីកសិណ ទើបត្រាស់ពាក្យជាដើមថា **សេយ្យថាបិ** ដូច្នេះ ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **ឧសភ** នោះឯង គឺ **អសភំ** គឺគោដ៏អង់អាច សេចក្ដីថា គោដទៃសូម្បីមានឫសខ្លះ ស្នាមចាក់ខ្លះ ស្បែករបស់គោទាំងនោះ កាលកោសរួសចេញ រមែងមិនមានទូវស្នាមជ្រួញ តំណិះដំណៀលទាំងនោះ រមែងមិនកើតដល់គោឧសភៈ ព្រោះសម្បូរដោយលក្ខណៈ ដូច្នោះ ទើបកាន់យកស្បែករបស់គោឧសភៈនោះ ។ បទថា **សង្កុសតេន** បានដល់ ខ្នាសសម្រាប់កោស ។ បទថា **សុវិហតំ** បានដល់ លាតចេញហើយ កោសទាល់តែរលោង ។ ពិតហើយ ស្បែកគោដែលគេប្រើខ្នាសកោសមិនដល់ ១០០ ដង ឈ្មោះថា មិនទាន់រលោង ប្រើខ្នាសកោសដល់ ១០០ ដង ទើបរលោងដូចផ្ទៃស្គរ ព្រោះដូច្នោះ ទើបត្រាស់យ៉ាងនេះ ។ បទថា **ឧក្កូល-វិក្កុលំ** ប្រែថា ខ្ពស់ទាបៗ គឺជាទីទួលខ្លះ ជាទីទំនាបខ្លះ ។ បទថា **នទីវិទុគ្គំ** បានដល់ ស្ទឹង និងទីទួលដែលមិនស្រួល ។ បទថា **បឋវីសញ្ញំ បដិច្ច មនសិការោតិ ឯកត្តំ** សេចក្ដីថា ដាក់ចិត្តក្នុងសញ្ញាតែម្យ៉ាង ដែលអាស្រ័យគ្នាកើតឡើងក្នុងបឋវីកសិណ ។ បទថា **ធរថមត្តា** សេចក្ដីថា ចាប់អំពីនេះគប្បីជ្រាបការក្រវល់ក្រវាយ ដោយការក្រវល់ក្រវាយដែលប្រព្រឹត្តទៅក្នុងវារៈទាំងពួង ។

[ ៨-៩ ] បទថា **អនិមិត្តំ ចេតោ សមាធឹ** បានដល់ វិបស្សនាចិត្ត-សមាធិ ។ ចេតោសមាធិដែលវៀរចាកនិច្ចនិមិត្តជាដើមនោះ លោកពោលថា អនិមិត្ត ។ បទថា **ឥមមេវកាយំ** លោកសម្ដែងវត្ថុដោយវិបស្សនា ។ ក្នុង

បទទាំងនោះ បទថា **ឥមមេវ** បានដល់ មហាភូតរូបទាំង ៤ នេះ ។ បទថា **សឡាយតនិកំ** ប្រែថា បដិសំយុត្តដោយសឡាយតនៈ ។ បទថា **ជីវិត-បច្ចយា** សេចក្ដីថា ជីវិតនៅប្រព្រឹត្តទៅបាន ជួរជីវិតិន្ទ្រិយនៅប្រព្រឹត្តទៅ អធិប្បាយថា បវិសញ្ញានោះ នៅមានការក្រវល់ក្រវាយដែលប្រព្រឹត្តទៅ ។ ដើម្បីទ្រង់សម្ដែងការឃើញច្បាស់ ដោយចំពោះវិបស្សនា ទើបត្រាស់ថា **អនិមិត្តំ** ទៀត ។ បទថា **កាមាសវំ បដិច្ច** ប្រែថា អាស្រ័យកាមាសវៈ ។ អធិប្បាយថា ការក្រវល់ក្រវាយដែលកើតឡើង និងដែលប្រព្រឹត្តទៅហើយ មិនមានក្នុងទីនេះ គឺមិនមានក្នុងអរិយមគ្គ និងអរិយផល ។ បទថា **ឥមមេវ កាយំ** នេះ ត្រាស់ដើម្បីសម្ដែងការក្រវល់ក្រវាយនៃបញ្ចក្ខន្ធដែលនៅសល់ ។ ដោយប្រការដូច្នេះ ឈ្មោះថា ទ្រង់ផ្លាស់មនុស្សសញ្ញាជាគាមសញ្ញា ។បេ។ មគ្គជាវិបស្សនា ហើយទ្រង់សម្ដែងភាពទទេកន្លងចំណែកដោយលំដាប់ ។

[ ១០ ] បទថា **បរិសុទ្ធំ** បានដល់ ប្រាសចាកឧបក្កិលេស ។ បទថា **អនុត្តរំ** ប្រែថា វៀរចាកវត្ថុដទៃដ៏កំពូល គឺប្រសើរបំផុតជាងគ្រប់យ៉ាង ។ បទថា **សុញ្ញតំ** បានដល់ សុញ្ញតាផលសមាបត្តិ ។ បទថា **តស្មា** សេចក្ដីថា ព្រោះសមណព្រាហ្មណ៍ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវកពុទ្ធ ក្នុងអតីតក្ដី សមណព្រាហ្មណ៍ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ក្នុងអនាគតក្ដី ព្រោះសមណព្រាហ្មណ៍ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះសាវកពុទ្ធ ក្នុងបច្ចុប្បន្នក្ដី ចូលសុញ្ញតៈដ៏បរិសុទ្ធដ៏កំពូលនេះហើយ នឹងនៅ នឹងកំពុងនៅ ដូច្នោះ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ហើយ ។៚

# សុត្តន្តបិដក

## មហាសុញ្ញតសូត្រទី ២

[ ១១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់ក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ នាដែនរបស់ពួកសក្កៈ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រ ចីវរ ក្នុងបុព្វណ្ហសម័យ ហើយស្តេចចូលទៅបិណ្ឌបាត ក្នុងក្រុងកបិលពស្តុ ។ លុះព្រះអង្គចូលទៅបិណ្ឌបាត ក្នុងក្រុងកបិលពស្តុហើយ ត្រឡប់មកពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលទៅកាន់វិហាររបស់សក្កៈឈ្មោះកាឡខេមកៈ ដើម្បីសម្រាកព្រះអង្គក្នុងវេលាថ្ងៃ ។ សម័យនោះឯង ក្នុងវិហាររបស់កាឡខេមកសក្កៈ មានគេក្រាលសេនាសនៈទុកច្រើន ។ លំដាប់នោះ ព្រះមានបុណ្យ ទ្រង់ទតឃើញសេនា-សនៈច្រើន គេរៀបចំទុកក្នុងវិហាររបស់កាឡខេមកសក្កៈ ។ លុះព្រះអង្គទតឃើញហើយ ក៏មានព្រះហឫទ័យត្រិះរិះដូច្នេះថា សេនាសនៈច្រើន គេរៀបចំទុកក្នុងវិហារ របស់កាឡខេមកសក្កៈ ទំនងជាមានពួកភិក្ខុច្រើន នៅក្នុងទីនេះទេដឹង ។

[ ១២ ] សម័យនោះឯង ព្រះអានន្ទមានអាយុ កំពុងចាត់ចែងដេរចីពរ ក្នុងវិហាររបស់ឃដាយសក្កៈ ជាមួយនឹងពួកភិក្ខុច្រើនរូប ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ចេញអំពីផលសមាបត្តិ ក្នុងសាយណ្ហសម័យ ហើយស្តេចចូលទៅកាន់វិហាររបស់ឃដាយសក្កៈ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេរៀបចំទុក ។ លុះព្រះអង្គគង់ស៊ប់ហើយ ក៏ត្រាស់សួរព្រះ

អានន្ទមានអាយុថា ម្នាលអានន្ទ សេនាសនៈច្រើន ដែលគេបានរៀបចំទុកក្នុងវិហាររបស់កាឡខេមកសក្កៈ ហើយមានទាំងពួកភិក្ខុនៅក្នុងទីនុ៎ះ អ៊ីច្រើនម៉េះ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេនាសនៈច្រើនដែលគេរៀបចំទុកក្នុងវិហារ របស់កាឡខេមកសក្កៈ ហើយមានពួកភិក្ខុច្រើននៅក្នុងទីនុ៎ះ បពិត្រព្រះអង្គដ៏ចម្រើន ( ព្រោះ ) ពេលនេះ ជាពេលធ្វើចីវរប្រព្រឹត្តមកដល់យើងខ្ញុំទាំងឡាយ ។

[ ១៣ ] ម្នាលអានន្ទ ភិក្ខុដែលត្រេកអរនឹងពួក ចូលចិត្តនឹងពួក ប្រកបរឿយៗ ក្នុងសេចក្តីត្រេកអរនឹងពួក ត្រេកអរនឹងគ្នីគ្នា ចូលចិត្តនឹងមានគ្នីគ្នា រីករាយនឹងគ្នីគ្នា មិនល្អទេ ម្នាលអានន្ទ ភិក្ខុដែលត្រេកអរនឹងពួក ចូលចិត្តនឹងពួក ប្រកបរឿយៗ ក្នុងសេចក្តីត្រេកអរនឹងពួក ត្រេកអរនឹងគ្នីគ្នា ចូលចិត្តនឹងមានគ្នីគ្នា រីករាយនឹងគ្នីគ្នានោះ ហើយបានមិនបាច់ប្រាថ្នា បានមិនលំបាក បានដោយស្រួល នូវនេក្ខម្មសុខ វិវេកសុខ ឧបសមសុខ សម្ពោធិសុខ ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ម្នាលអានន្ទ បើភិក្ខុណាចេញចាកពួក ហើយទៅនៅតែម្នាក់ឯង ភិក្ខុនោះ នឹងបានមិនបាច់ប្រាថ្នា បានមិនលំបាក បានដោយស្រួលនូវនេក្ខម្មសុខ វិវេកសុខ ឧបសមសុខ សម្ពោធិសុខ ជាប្រាកដ ពាក្យដូច្នេះនេះ ទើបសមហេតុ ។ ម្នាលអានន្ទ ភិក្ខុនោះ ត្រេកអរនឹងពួក ចូលចិត្តនឹងពួក ប្រកបរឿយៗ ក្នុងសេចក្តីត្រេកអរនឹងពួក ត្រេកអរនឹងគ្នីគ្នា ចូលចិត្តនឹងគ្នីគ្នា រីករាយនឹងគ្នីគ្នា អាចនឹងចូលកាន់ចេតោវិមុត្តិ ដែលផុតស្រឡះចាកកិលេស ជាទីរីករាយ ឬនឹងចូលកាន់ចេតោវិមុត្តិ ដែលមិនទាន់

ផុតស្រឡះចាកពួកកិលេស ជាវិមុត្តិមិនកម្រើកដោយកិលេសបាន ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ម្នាលអានន្ទ លុះតែភិក្ខុណាចេញចាកពួក ហើយទៅសម្ងំនៅតែម្នាក់ឯង ភិក្ខុនោះ នឹងចូលកាន់ចេតោវិមុត្តិ ដែលផុតចាកពួកកិលេស ជាទីរីករាយ ឬនឹងចូលកាន់ចេតោវិមុត្តិ ដែលមិនទាន់ផុតចាកពួកកិលេស ជាវិមុត្តិមិនកម្រើកដោយកិលេស ជាប្រាកដ ពាក្យដូច្នេះនេះ ទើបសមហេតុ ។ ម្នាលអានន្ទ តថាគតពិចារណារកមើលមិនឃើញនូវរូប សូម្បីតែមួយដែលបុគ្គលត្រេកអរ ត្រេកត្រអាលយ៉ាងម្ល៉ោះហើយ មិនកើតសេចក្តីសោកខ្សឹកខ្សួល លំបាកកាយ លំបាកចិត្ត និងសេចក្តីតានតឹង ព្រោះមិនមានការប្រែប្រួលទៅជាប្រការដទៃនោះសោះឡើយ ។

[ ១៤ ] ម្នាលអានន្ទ វិហារធម៌ ( ការនៅ ) ក្នុងទីស្ងាត់ តថាគតបានត្រាស់ដឹងហើយ គឺបានសម្រេចនូវសុញ្ញតផលសមាបត្តិក្នុងសន្តាន ព្រោះមិនធ្វើទុកក្នុងចិត្តនូវសង្ខតនិមិត្តទាំងអស់ ( មានរូបជាដើម ) ។ ម្នាលអានន្ទ បើពួកភិក្ខុក្តី ពួកភិក្ខុនីក្តី ពួកឧបាសកក្តី ពួកឧបាសិកាក្តី ពួកព្រះរាជាក្តី ពួករាជមហាមាត្យក្តី ពួកតិរ្ថិយក្តី ពួកសាវ័កនៃតិរ្ថិយក្តី ជាអ្នកចូលមករកតថាគត ជាភគវន្ត ដែលកំពុងនៅដោយវិហារធម៌នេះ ម្នាលអានន្ទ តថាគតឋិតនៅក្នុងកណ្តាលបរិស័ទនោះ ក៏មានចិត្តឈមទៅរកវិវេក បែរទៅរកវិវេក ទោរទន់ទៅរកវិវេក ស្ងាត់ចាកពួកគណៈ ត្រេកអរនឹងនេក្ខម្មៈ ប្រាសចាកធម៌ដែលជាទីតាំងនៃអាសវៈ ជាអ្នកធ្វើនូវពាក្យដែលប្រកបដោយការដាស់តឿន ឲ្យវៀរចាកធម៌ជាទីតាំងនៃអាសវៈ សព្វគ្រប់ដោយពិត ។ ម្នាលអានន្ទ ហេតុនោះ

ភិក្ខុក្នុងសាសនានេះ បើមានសេចក្តីប្រាថ្នាថា អាត្មាអញគប្បីសម្រេចនូវ សុញ្ញតផលសមាបត្តិ ខាងក្នុង គឺបញ្ចក្ខន្ធរបស់ខ្លួន ម្នាលអានន្ទ ភិក្ខុនោះ ត្រូវតាំងចិត្ត ត្រូវញ៉ាំងចិត្តឲ្យរីករាយ ត្រូវធ្វើចិត្តឲ្យស្ងប់ស្ងាត់ ត្រូវធ្វើចិត្តឲ្យ ជ្រះថ្លាខាងក្នុងតែមួយយ៉ាង ។

[ ១៥ ] ម្នាលអានន្ទ ចុះភិក្ខុតាំងចិត្ត ធ្វើចិត្តឲ្យរីករាយ ធ្វើចិត្តឲ្យស្ងប់ ស្ងាត់ ធ្វើចិត្តឲ្យជ្រះថ្លា ខាងក្នុង គឺបញ្ចក្ខន្ធរបស់ខ្លួន តើដូចម្តេច ។ ម្នាល អានន្ទ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ ទាំងឡាយ ចូលកាន់បឋមជ្ឈាន ប្រកបដោយវិតក្ក វិចារ មានបីតិ និងសុខ ដែលកើតអំពីវិវេក ... ចូលកាន់ទុតិយជ្ឈាន ... ចូលកាន់តតិយជ្ឈាន ... ចូលកាន់ចតុត្ថជ្ឈាន ។ ម្នាលអានន្ទ ភិក្ខុតាំងចិត្ត ធ្វើចិត្តឲ្យជ្រះថ្លា ធ្វើចិត្តឲ្យ ស្ងប់ស្ងាត់ ធ្វើចិត្តឲ្យរីករាយ ខាងក្នុង យ៉ាងនេះឯង ។ ភិក្ខុនោះ ឈ្មោះថា ធ្វើទុកក្នុងចិត្តនូវសុញ្ញតផលសមាបត្តិ ខាងក្នុង ។ តែកាលបើភិក្ខុនោះ ធ្វើ ទុកក្នុងចិត្តនូវសុញ្ញតផលសមាបត្តិ ខាងក្នុងហើយ ចិត្តមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនចុះចិត្តស៊ប់ ក្នុងសុញ្ញតផលសមាបត្តិខាងក្នុងទេ ។ ម្នាល អានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុគង់ដឹងច្បាស់យ៉ាងនេះថា កាលអាត្មា អញធ្វើទុកក្នុងចិត្ត នូវសុញ្ញតផលសមាបត្តិ ខាងក្នុង ចិត្តមិនស្ទុះទៅ មិន ជ្រះថ្លា មិនតាំងនៅស៊ប់ មិនចុះចិត្តស៊ប់ ក្នុងសុញ្ញតផលសមាបត្តិ ខាងក្នុង ទេ ។ ភិក្ខុនោះជាអ្នកដឹងច្បាស់ ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ បើភិក្ខុ នោះ ធ្វើទុកក្នុងចិត្តនូវសុញ្ញតផលសមាបត្តិ ខាងក្រៅ គឺបញ្ចក្ខន្ធអ្នកដទៃ ។

បើភិក្ខុនោះ ធ្វើទុកក្នុងចិត្ត នូវសុញ្ញតផលសមាបត្តិ ខាងក្នុងនិងខាងក្រៅ ។ បើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសេចក្តីមិនញាប់ញ័រ គឺអរូបសមាបត្តិ ។ កាលភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសេចក្តីមិនញាប់ញ័រ ចិត្តមិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនចុះចិត្តស៊ប់ ក្នុងសេចក្តីមិនញាប់ញ័រ ។ ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុគង់ដឹងច្បាស់យ៉ាងនេះថា កាលអាត្មាអញធ្វើទុកក្នុងចិត្តនូវសេចក្តីមិនញាប់ញ័រហើយ ចិត្តក៏មិនស្ទុះទៅ មិនជ្រះថ្លា មិនតាំងនៅស៊ប់ មិនចុះចិត្តស៊ប់ ក្នុងសេចក្តីមិនញាប់ញ័រ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ភិក្ខុនោះ ត្រូវតាំងចិត្ត ធ្វើចិត្តឲ្យជ្រះថ្លា ធ្វើចិត្តឲ្យស្ងប់ស្ងាត់ ធ្វើចិត្តឲ្យរីករាយ ខាងក្នុង ក្នុងសមាធិ-និមិត្តពីមុននោះវិញ ។ ភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសុញ្ញតផលសមាបត្តិខាងក្នុង ។ កាលភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវសុញ្ញតផលសមាបត្តិខាងក្នុងហើយ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ចុះចិត្តស៊ប់ ក្នុងសុញ្ញតផលសមាបត្តិខាងក្នុង ។ ម្នាលអានន្ទ កាលបើចិត្តនុ៎ះស្ងប់ស្ងាត់យ៉ាងនេះ ភិក្ខុក៏ដឹងច្បាស់យ៉ាងនេះថា កាលអាត្មាអញ ធ្វើទុកក្នុងចិត្តនូវសុញ្ញតផលសមាបត្តិខាងក្នុងហើយ ចិត្តក៏ស្ទុះទៅ ជ្រះថ្លា តាំងនៅស៊ប់ ចុះចិត្តស៊ប់ ក្នុងសុញ្ញតផល-សមាបត្តិខាងក្នុង ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ បើភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវផលសមាបត្តិខាងក្រៅ ។ បើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសុញ្ញត ផលសមាបត្តិខាងក្នុង និងខាងក្រៅ ។ បើភិក្ខុនោះធ្វើទុកក្នុងចិត្តនូវសេចក្តីមិនញាប់ញ័រ ។ កាលភិក្ខុនោះ ធ្វើទុកក្នុងចិត្តនូវ

សេចក្តីមិនញាប់ញ័រហើយ ចិត្តក៏ស្ងប់ទៅ ជ្រះថ្លា តាំងនៅស៊ប់ ចុះចិត្តស៊ប់ ក្នុងសេចក្តីមិនញាប់ញ័រ ។ ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុគប្បីដឹងច្បាស់យ៉ាងនេះថា កាលអាត្មាអញ ធ្វើទុកក្នុងចិត្តនូវសេចក្តីមិនញាប់ញ័រ ហើយ ចិត្តក៏ស្ងប់ទៅ ជ្រះថ្លា តាំងនៅស៊ប់ ចុះចិត្តស៊ប់ ក្នុងសេចក្តីមិនញាប់ញ័រ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។

[ ១៦ ] ម្នាលអានន្ទ កាលបើភិក្ខុនោះ នៅដោយវិហារធម៌ គឺសមថវិបស្សនានេះ ចិត្តក៏បង្អោនទៅដើម្បីចង្រ្កម ។ ភិក្ខុនោះចង្រ្កមដោយគិតដូច្នេះថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស នឹងមិនជាប់តាមអាត្មាអញដែលកំពុងចង្រ្កម យ៉ាងនេះ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌ គឺសមថវិបស្សនានេះ ចិត្តក៏បង្អោនទៅ ដើម្បីកិរិយាឈរ ។ ភិក្ខុនោះ ឈរដោយគិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងឈរយ៉ាងនេះ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កាលបើភិក្ខុនោះកំពុងនៅដោយវិហារធម៌ គឺសមថវិបស្សនានេះ ចិត្តក៏បង្អោនទៅដើម្បីអង្គុយ ។ ភិក្ខុនោះ ក៏អង្គុយដោយគិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងអង្គុយនៅយ៉ាងនេះ ។ ភិក្ខុនោះ ជាអ្នកដឹងក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កាលបើភិក្ខុនោះនៅដោយវិហារធម៌ គឺសមថវិបស្សនានេះ ចិត្តក៏

បង្អោនទៅដើម្បីដេក ។ ភិក្ខុនោះក៏ដេកដោយគិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈា និងទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងដេកយ៉ាងនេះ ។ ភិក្ខុនោះជាអ្នកដឹងច្បាស់នូវហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កាលបើភិក្ខុនោះ កំពុងនៅដោយវិហារធម៌ គឺសមថវិបស្សនានេះ ចិត្តក៏បង្អោនទៅដើម្បីនិយាយ ។ ភិក្ខុនោះគិតថា កថាណា ថោកទាបជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ មិនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាករាគៈ មិនប្រព្រឹត្តទៅ ដើម្បីរម្ងត់ទុក្ខ មិនប្រព្រឹត្តទៅ ដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីដឹងច្បាស់ មិនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន គឺរាជកថា ( និយាយពីព្រះរាជា ) ចោរកថា ( និយាយពីចោរ ) មហាមត្តកថា ( និយាយពីអាមាត្យធំ ) សេនាកថា ( និយាយពីសេនា ) ភយកថា ( និយាយពីភ័យ ) យុទ្ធកថា ( និយាយពីចម្បាំង ) អន្នកថា ( និយាយពីបាយ ) បានកថា ( និយាយពីទឹក ) វត្ថកថា ( និយាយពីសំពត់ ) សយនកថា ( និយាយពីដំណេក ) មាលាកថា ( និយាយពីកម្រងផ្កា ) គន្ធកថា ( និយាយពីគ្រឿងក្រអូប ) ញាតិកថា ( និយាយពីញាតិ ) យានកថា ( និយាយពីយានជំនិះ ) គាមកថា ( និយាយពីស្រុក ) និគមកថា ( និយាយពីនិគម ) នគរកថា ( និយាយពីក្រុង ) ជនបទកថា ( និយាយពីជនបទ ) ឥត្ថីកថា ( និយាយពីស្ត្រី ) សូរកថា ( និយាយពីមនុស្សក្លៀវក្លា ) វិសិខាកថា ( និយាយពីកំប៉ោយ ) កុម្ភដ្ឋានកថា ( និយាយ

ពីកន្ទែងដាក់ក្អមទឹក ឬកន្ទែងកំណាប់ ) បុព្វបេត្បកថា ( និយាយពីមនុស្ស ដែលស្លាប់ហើយ ) នានត្តកថា ( និយាយពីមនុស្សផ្សេងៗ គ្នា ) លោកក្ខាយិកា ( និយាយពីព្រហ្មកសាងលោក ) សមុទ្ទក្ខាយិកា ( និយាយពីព្រហ្មកសាងសមុទ្រ ) និយាយអំពីកពតូច និងកពធំ ថាដូច្នោះខ្លះ ដូច្នេះខ្លះ អាត្មាអញមិននិយាយនូវកថាមានសភាពយ៉ាងនោះឡើយ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កថាណាផ្លូវផង់ ជាទីសប្បាយដល់ការពិចារណា តាមដំណើរចិត្ត ប្រព្រឹត្តទៅ ដើម្បីនឿយណាយដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីរម្ងត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន គឺអប្បិច្ឆកថា ( និយាយពីសេចក្តីប្រាថ្នាតិច ) សន្តុដ្ឋិកថា ( និយាយពីសេចក្តីសន្តោស ) បវិវេកកថា ( និយាយពីសេចក្តីស្ងប់ស្ងាត់ ) អសំសគ្គកថា ( និយាយពីការមិនជាប់ជំពាក់ ) វីរិយារម្ភកថា ( និយាយពីការប្រារព្ធព្យាយាម ) សីលកថា ( និយាយពីសីល ) សមាធិកថា ( និយាយពីសមាធិ ) បញ្ញាកថា ( និយាយពីប្រាជ្ញា ) វិមុត្តិកថា ( និយាយពីការរួចចាកកិលេស ) វិមុត្តិញ្ញាណទស្សនកថា ( និយាយពីការឃើញដោយបញ្ញា ចំពោះកិរិយារួចចាកកកិលេស ) អាត្មាអញនឹងនិយាយតែកថា មានសភាពយ៉ាងនោះឯង ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ កាលបើភិក្ខុនោះ កំពុងនៅ ដោយវិហារធម៌ គឺសមថវិបស្សនានេះ ចិត្តក៏បង្អោនទៅដើម្បីវិតក្ក ( សេចក្តីត្រិះរិះ ) ។ ភិក្ខុនោះ គិតថា វិតក្កទាំងឡាយ

ណា ដែលថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនប្រសើរ មិនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅ ដើម្បីនឿយណាយ មិនប្រព្រឹត្តទៅដើម្បីប្រាសចាករាគៈ មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីរម្ងត់ទុក្ខ មិនប្រព្រឹត្តទៅដើម្បីស្ងប់រម្ងាប់ មិនប្រព្រឹត្តទៅ ដើម្បីដឹង មិនប្រព្រឹត្តទៅ ដើម្បីត្រាស់ដឹង មិនប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន គឺកាមវិតក្ក ព្យាបាទ វិតក្ក វិហឹសាវិតក្ក អាត្មាអញនឹងមិនត្រិះរិះដោយវិតក្ក មានសភាពយ៉ាងនោះឡើយ ។ ភិក្ខុនោះជាអ្នកដឹងក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ វិតក្កទាំងឡាយណា ដ៏ប្រសើរ ជានិយ្យានិកៈ ដឹកនាំសត្វ តែងដឹកនាំបុគ្គលជាអ្នកធ្វើតាមពុទ្ធវចនៈនោះ ឲ្យអស់ទៅនៃទុក្ខដោយប្រពៃបាន គឺនេក្ខម្មវិតក្ក អព្យាបាទ-វិតក្ក អវិហឹសាវិតក្ក ភិក្ខុគិតថា អាត្មាអញនឹងត្រិះរិះនូវវិតក្កទាំងឡាយ មានសភាពយ៉ាងនោះឯង ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។

[ ១៧ ] ម្នាលអានន្ទ កាមគុណ មាន ៥ ប្រការ កាមគុណ ៥ ប្រការ គឺអ្វីខ្លះ រូបទាំងឡាយ ដែលបុគ្គលដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេក ១ សំឡេងទាំងឡាយ ដែលបុគ្គលដឹងដោយត្រចៀក ... ១ ក្លិនទាំងឡាយ ដែលបុគ្គលដឹងដោយច្រមុះ ... ១ រសទាំងឡាយ ដែលបុគ្គលដឹងដោយអណ្តាត ... ១ ផោដ្ឋព្វៈទាំងឡាយ ដែលបុគ្គលដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរ

ឲ្យកើតតម្រេក ១ ម្នាលអានន្ទ កាមគុណ ៥ ប្រការ នេះឯង ។ ភិក្ខុត្រូវពិចារណាចិត្តរបស់ខ្លួនឲ្យរឿយៗ ថា បណ្តាកាមគុណទាំង ៥ នេះ សេចក្តីជ្រួលច្រាល់ចិត្ត នៃអាត្មាអញកើតឡើង ក្នុងហេតុជាទីកើតនៃកិលេស ចំពោះកាមគុណណាមួយ មានដែរឬទេ ។ ម្នាលអានន្ទ បើភិក្ខុពិចារណាទៅ ដឹងយ៉ាងនេះថា បណ្តាកាមគុណទាំង ៥ នេះ សេចក្តីជ្រួលច្រាល់នៃចិត្តរបស់អាត្មាអញ កើតឡើងក្នុងហេតុ ជាទីកើតនៃកិលេស ចំពោះកាមគុណណាមួយ ។ ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុគង់ដឹងយ៉ាងនេះថា តម្រេកណា ដែលកើតក្នុងកាមគុណទាំង ៥ នេះ តម្រេកនោះ អាត្មាអញមិនទាន់លះបង់បានទេ ។ ម្នាលអានន្ទ មួយទៀត បើភិក្ខុពិចារណាទៅ ដឹងយ៉ាងនេះថា បណ្តាកាមគុណទាំង ៥ នេះ សេចក្តីជ្រួលច្រាល់នៃចិត្តរបស់អាត្មាអញ មិនកើតឡើង ក្នុងហេតុជាទីកើតនៃកិលេស ចំពោះកាមគុណណាមួយទេ ។ ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុក៏ដឹងយ៉ាងនេះថា សេចក្តីប្រាថ្នាណា ក្នុងកាមគុណទាំង ៥ នេះ សេចក្តីប្រាថ្នានោះ អាត្មាអញបានលះបង់ហើយ ។ ភិក្ខុនោះ ជាអ្នកដឹងច្បាស់ ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។

[ ១៨ ] ម្នាលអានន្ទ ឧបាទានក្ខន្ធនេះ មាន ៥ យ៉ាង ។ ភិក្ខុត្រូវប្រព្រឹត្តដោយកិរិយាពិចារណាឃើញ នូវសេចក្តីកើត និងសេចក្តីរលត់ ដូច្នេះថា រូបដូច្នេះ ការកើតឡើងនៃរូប ដូច្នេះ ការវិនាសទៅនៃរូប ដូច្នេះ វេទនាដូច្នេះ ... សញ្ញាដូច្នេះ ... សង្ខារទាំងឡាយដូច្នេះ ... វិញ្ញាណដូច្នេះ ការកើតឡើងនៃ

វិញ្ញាណដូច្នេះ ការវិនាសទៅនៃវិញ្ញាណដូច្នេះ ។ កាលបើភិក្ខុនោះពិចារណា ឃើញច្បាស់នូវការកើតនិងការរលត់ ក្នុងឧបាទានក្ខន្ធទាំង ៥ នេះ ភិក្ខុនោះ រមែងលះបង់អស្មិមានះ ក្នុងឧបាទានក្ខន្ធទាំង ៥ចេញបាន ។ ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ភិក្ខុដឹងយ៉ាងនេះថា អាត្មាអញបានលះបង់អស្មិមានះ ក្នុងឧបាទានក្ខន្ធទាំង ៥ បានហើយ ។ ភិក្ខុនោះជាអ្នកដឹងច្បាស់ក្នុងហេតុនោះ ដោយប្រការដូច្នេះ ។ ម្នាលអានន្ទ ធម៌ទាំងឡាយនេះឯង ជាប់មកតាមកុសលដោយចំណែកមួយ ដ៏បរិសុទ្ធ ប្រសើរក្នុងលោក ដែលមារមានចិត្តបាប មិនអាចគ្របសង្កត់បាន ។ ម្នាលអានន្ទ អ្នកសម្គាល់នូវហេតុនោះថាដូចម្តេច សាវកពិចារណាឃើញនូវអំណាចនៃប្រយោជន៍ដូចម្តេច បានជាមិនហៅរក តែគួរដើរតាមសាស្តា ។ ព្រះអានន្ទ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ មានព្រះមានព្រះភាគជាមូល មានព្រះមានព្រះភាគជាអ្នកណែនាំ មានព្រះមានព្រះភាគជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ សម្តែងសេចក្តីនៃភាសិតនុ៎ះដោយប្រពៃ ដល់យើងខ្ញុំ ពួកភិក្ខុស្តាប់ភាសិតរបស់ព្រះអង្គហើយ នឹងចងចាំទុក ។

[ ១៩ ] ម្នាលអានន្ទ សាវកមិនគួរដើរតាមតែព្រះសាស្តាទេ គឺថា គួរតែស្តាប់នូវសុត្តៈ គេយ្យៈ វេយ្យាករណៈ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះថា ធម៌ទាំងឡាយ អ្នកទាំងឡាយក៏បានស្តាប់ បានទ្រទ្រង់ ចាំរត់មាត់ ស្ទាត់ក្នុងចិត្ត ចាក់ធ្លុះដោយទិដ្ឋិជាយូរយារហើយ ។ ម្នាលអានន្ទ មួយទៀត កថាណា ផ្ទុយផ្ទង់គ្រែលែង ជាទីសប្បាយដល់កិរិយាពិចារណា

ដោយចិត្ត ប្រព្រឹត្តទៅ ដើម្បីនឿយណាយ ដោយចំណែកមួយ ដើម្បីប្រាសចាករាគៈ ដើម្បីរម្ងត់ទុក្ខ ដើម្បីស្ងប់រម្ងាប់ ដើម្បីដឹងច្បាស់ ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន កថានោះ គឺអប្បិច្ឆកថា សន្តុដ្ឋិកថា បវិវេកកថា អសំសគ្គកថា វីរិយារម្ភកថា សីលកថា សមាធិកថា បញ្ញាកថា វិមុត្តិកថា វិមុត្តិញ្ញាណទស្សនកថា ម្នាលអានន្ទ សាវកគួរតែស្តាប់ នូវកថាមានសភាពយ៉ាងនោះ ទើបឈ្មោះថាមិនហៅរក តែគួរដើរតាមសាស្តា ។ ម្នាលអានន្ទ កាលបើមានហេតុយ៉ាងនេះ ឧបទ្រពអាចារ្យក៏មាន កាលបើមានហេតុយ៉ាងនេះ ឧបទ្រពកូនសិស្សក៏មាន កាលបើមានហេតុយ៉ាងនេះ ឧបទ្រពព្រហ្មចារីក៏មាន ។

[ ២០ ] ម្នាលអានន្ទ ឧបទ្រពអាចារ្យ តើដូចម្តេច ។ ម្នាលអានន្ទ សាស្តាខ្លះ ក្នុងលោកនេះ នៅអាស្រ័យ នឹងសេនាសនៈដ៏ស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ញកភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ដងព្រៃ ទីវាល គំនរចំបើង ។ កាលដែលសាស្តានោះ ចៀសចេញចាកពួកគណៈដូច្នោះ ពួកព្រាហ្មណ៍ និងគហបតីក្តី អ្នកនិគមក្តី អ្នកជនបទក្តី ក៏ប្រព្រឹត្តតាម ( បែបផែននោះ ) ។ កាលបើព្រាហ្មណ៍និងគហបតីក្តី អ្នកនិគមក្តី អ្នកជនបទក្តី ប្រព្រឹត្តតាមដូច្នោះហើយ សាស្តានោះ ប្រាថ្នានូវតណ្ហា ជាធម្មជាតជ្រុលជ្រប់ ដល់នូវសេចក្តីត្រេកអរ ក៏ត្រឡប់មកកាន់សេចក្តីល្មោភវិញ ។ ម្នាលអានន្ទ នេះតថាគតហៅថា ឧបទ្រពអាចារ្យ ព្រោះឧបទ្រព គឺកិលេស កើតក្នុងអាចារ្យ ។ អកុសលធម៌ទាំងឡាយ ដ៏លាមក ជាគ្រឿងសៅហ្មង ជាធម៌នាំឲ្យកើតក្នុងភពថ្មី

ទៀត ប្រព្រឹត្តទៅដោយសេចក្តីក្រវល់ក្រវាយ ឲ្យផលជាទុក្ខ ប្រកបដោយជាតិ ជរា និងមរណៈ តទៅមុខ ក៏សម្លាប់នូវសាស្តានោះ ។ ម្នាលអានន្ទ យ៉ាងនេះឯង ជាឧបទ្រពអាចារ្យ ។

[ ២១ ] ម្នាលអានន្ទ ចុះឧបទ្រពសិស្ស តើដូចម្តេច ។ ម្នាលអានន្ទ សាវករបស់សាស្តានោះឯង កាលចម្រើនវិវេក យកតម្រាប់សាស្តានោះ ក៏អាស្រ័យនៅនឹងសេនាសនៈដ៏ស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ញកភ្នំ គុហាក្នុងភ្នំ ព្រៃស្មសាន ជងព្រៃ ទីវាល គំនរចំបើង ។ ពួកព្រាហ្មណ៍ និងគហបតីក្តី អ្នកនិគមក្តី អ្នកជនបទក្តី ក៏ប្រព្រឹត្តតាមសាវក ដែលចេញចាកពួកដូច្នោះ ។ សាវកនោះប្រាថ្នានូវតណ្ហា ជាធម្មជាតជ្រុលជ្រប់ ដល់នូវសេចក្តីត្រេកអរ ក៏ត្រឡប់មកកាន់សេចក្តីល្មោភ ក្នុងពួកព្រាហ្មណ៍ និងគហបតី អ្នកនិគម អ្នកជនបទ ដែលប្រព្រឹត្តតាម ( ទាំងអម្បាលនោះ ) វិញ ។ ម្នាលអានន្ទ នេះតថាគតហៅថា ឧបទ្រពសិស្ស ព្រោះឧបទ្រព គឺកិលេស កើតក្នុងសិស្ស ។ អកុសលធម៌ទាំងឡាយ ដ៏លាមក ជាគ្រឿងសៅហ្មង ជាធម៌នាំឲ្យកើតក្នុងភពថ្មីទៀត ប្រព្រឹត្តទៅដោយសេចក្តីក្រវល់ក្រវាយ ឲ្យផលជាទុក្ខ ប្រកបដោយជាតិ ជរា និងមរណៈតទៅ ក៏សម្លាប់នូវសាវកនោះ ។ ម្នាលអានន្ទ យ៉ាងនេះឯង ជាឧបទ្រព្យសិស្ស ។

[ ២២ ] ម្នាលអានន្ទ ចុះឧបទ្រពព្រហ្មចារី តើដូចម្តេច ។ ម្នាលអានន្ទ ព្រះតថាគតឆ្ងាយចាកសឹកសត្រូវ គឺកិលេស ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ បរិបូណ៌ដោយវិជ្ជា និងចរណៈ មាន

ដំណើរល្អទៅកាន់ព្រះនិព្វាន ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលា-ទិគុណ រកបុគ្គលណាមួយស្មើគ្មាន ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ត្រាស់ដឹងនូវចតុរារិយសច្ច មិនត្រឡប់មកកាន់ត្រៃភព ព្រះអង្គកើតឡើងក្នុងលោកនេះ ។ ព្រះតថាគត នោះ អាស្រ័យនៅនឹងសេនាសនៈដ៏ស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ញកភ្នំ គុហា ក្នុងភ្នំ ព្រៃស្មសាន ដងព្រៃ ទីវាល គំនរចំបើង ។ ពួកព្រាហ្មណ៍ និងគហបតី ក្តី អ្នកនិគមក្តី អ្នកជនបទក្តី ក៏ប្រព្រឹត្តតាមព្រះតថាគត ដែលចេញចាកពួក ដូច្នោះ ។ ព្រះតថាគតនោះ មិនប្រាថ្នានូវតណ្ហាជាធម្មជាតជ្រុលជ្រប់ មិនដល់ នូវសេចក្តីត្រេកអរ មិនត្រឡប់មកកាន់សេចក្តីល្មោភ ក្នុងពួកព្រាហ្មណ៍ និង គហបតីក្តី អ្នកនិគមក្តី អ្នកជនបទក្តី ដែលប្រព្រឹត្តតាម ( នោះ ) ទេ ។ ម្នាលអានន្ទ តែថា សាវ័ករបស់សាស្តានោះឯង ចម្រើនវិវេក យកតម្រាប់ សាស្តានោះ ក៏នៅនឹងសេនាសនៈដ៏ស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ញកភ្នំ គុហា ក្នុងភ្នំ ព្រៃស្មសាន ដងព្រៃ ទីវាល គំនរចំបើង ។ ពួកព្រាហ្មណ៍ និងគហបតី ក្តី អ្នកនិគមក្តី អ្នកជនបទក្តី ក៏ប្រព្រឹត្តតាមសាវ័កដែលចេញចាកពួកដូច្នោះ ។ សាវ័កនោះ បែរជាប្រាថ្នានូវតណ្ហាជាធម្មជាតជ្រុលជ្រប់ ដល់នូវសេចក្តី ត្រេកអរ ក៏ត្រឡប់មកកាន់សេចក្តីល្មោភ ក្នុងពួកព្រាហ្មណ៍ និងគហបតី អ្នក និគមក្តី អ្នកជនបទក្តី ដែលប្រព្រឹត្តតាមនោះវិញ ។ ម្នាលអានន្ទ នេះឯង តថាគតហៅថា ឧបទ្រពព្រហ្មចារី ព្រោះឧបទ្រព គឺកិលេសក្នុងព្រហ្មចារី ។ អកុសលធម៌ទាំងឡាយ ដ៏លាមក ជាគ្រឿងសៅហ្មង ជាធម៌នាំឲ្យកើតក្នុង

ភពថ្មីទៀត ប្រព្រឹត្តទៅដោយសេចក្តីក្រវល់ក្រវាយ ឲ្យផលជាទុក្ខ ប្រកប ដោយ ជាតិ ជរា និងមរណៈតទៅ ក៏សម្លាប់នូវសាវ័កនោះ ។ ម្នាលអានន្ទ យ៉ាងនេះឯង ជាឧបទ្រពព្រហ្មចារី ។ ម្នាលអានន្ទ បណ្តាឧបទ្រពទាំងនោះ ឧបទ្រពអាចារ្យក្តី ឧបទ្រពសិស្សក្តី ឲ្យផលជាទុក្ខល្មមទេ ចំណែកឧបទ្រព ព្រហ្មចារីនេះ ទើបឲ្យផលជាទុក្ខយ៉ាងក្រៃលែង ឲ្យផលផ្សាក្តៅយ៉ាងក្រៃលែង ជាងឧបទ្រពអាចារ្យ និងឧបទ្រពសិស្សទាំងនោះទៅទៀត មិនតែប៉ុណ្ណោះ ប្រព្រឹត្តទៅ ដើម្បីធ្លាក់ចុះទៅកាន់អបាយ ។ ម្នាលអានន្ទ ហេតុនោះ អ្នក ទាំងឡាយ ចូររាប់អានតថាគតដោយសេចក្តីប្រតិបត្តិថាជាមិត្ត កុំរាប់អាន តថាគត ដោយសេចក្តីប្រតិបត្តិថា ជាអ្នកមានពៀរឡើយ សេចក្តីប្រតិបត្តិជា មិត្តនោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកទាំង-ឡាយ អស់កាលជាអង្វែងទៅ ។

[ ២៣ ] ម្នាលអានន្ទ ចុះពួកសាវ័ក រាប់អានសាស្តា ដោយសេចក្តី ប្រតិបត្តិ ជាអ្នកមានពៀរ មិនរាប់អានសាស្តា ដោយសេចក្តីប្រតិបត្តិជាមិត្ត តើដូចម្តេច ។ ម្នាលអានន្ទ សាស្តាក្នុងលោកនេះ ជាអ្នកអនុគ្រោះ ស្វែងរក ប្រយោជន៍ ប្រកបដោយសេចក្តីអនុគ្រោះ ទើបសម្តែងធម៌ដល់ពួកសាវ័កថា ធម្មជាតនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដល់អ្នកទាំងឡាយ ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយ ។ ឯពួកសាវ័ករបស់សាស្តា នោះ មិនស្តាប់ដោយគោរព មិនផ្ទៀងត្រចៀកស្តាប់ មិនញុំាងចិត្តដែលត្រាច់ ទៅក្នុងទីដទៃឲ្យតាំងនៅនឹង លះបង់លែងប្រព្រឹត្តតាមសាសនារបស់សាស្តា ។

ម្នាលអានន្ទ ពួកសាវ័ករាប់អានសាស្តា ដោយប្រតិបត្តិជាអ្នកមានពៀរ មិនរាប់អានដោយសេចក្តីប្រតិបត្តិ ដើម្បីជាមិត្តយ៉ាងនេះឯង ។

[ ២៤ ] ម្នាលអានន្ទ ចុះពួកសាវ័ករាប់អានសាស្តា ដោយសេចក្តីប្រតិបត្តិជាមិត្ត មិនរាប់អានដោយសេចក្តីប្រតិបត្តិជាអ្នកមានពៀរ តើដូចម្តេច ។ ម្នាលអានន្ទ សាស្តាក្នុងលោកនេះ ជាអ្នកអនុគ្រោះ ស្វែងរកប្រយោជន៍ ប្រកបដោយសេចក្តីអនុគ្រោះ ទើបសំដែងធម៌ដល់ពួកសាវ័កថា ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដល់អ្នកទាំងឡាយ ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយ ។ ពួកសាវ័ករបស់សាស្តានោះ ខំប្រឹងស្តាប់ ផ្ទៀងត្រចៀកស្តាប់ ញុំាងចិត្តដែលត្រាច់ទៅក្នុងទីដទៃឲ្យតាំងនៅនឹង ទាំងមិនលះបង់ លែងប្រព្រឹត្តតាមសាសនារបស់សាស្តាឡើយ ។ ម្នាលអានន្ទ ពួកសាវ័ករាប់អានសាស្តា ដោយសេចក្តីប្រតិបត្តិជាមិត្ត មិនរាប់អានដោយសេចក្តីប្រតិបត្តិជាអ្នកមានពៀរ យ៉ាងនេះឯង ។ ម្នាលអានន្ទ ព្រោះហេតុនោះ អ្នកទាំងឡាយ គួររាប់អានតថាគតដោយសេចក្តីប្រតិបត្តិជាមិត្តចុះ កុំរាប់អានតថាគត ដោយសេចក្តីប្រតិបត្តិជាអ្នកមានពៀរឡើយ ការប្រតិបត្តិជាមិត្តនោះ នឹងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់អ្នកទាំងឡាយ អស់កាលជាអង្វែងទៅ ។ ម្នាលអានន្ទ ស្មូនឆ្នាំង កាន់ភាជន៍ទទឹក មិនទាន់ស្ងួត ( ថ្នមមិនឲ្យបែក ) យ៉ាងណា តថាគតមិនបៀតបៀនអ្នកទាំងឡាយ យ៉ាងនោះដែរ ។ ម្នាលអានន្ទ តថាគតសង្កត់សង្កិនហើយ ប្រៀនប្រដៅរឿយៗ ម្នាលអានន្ទ តថាគតបន្សាត់បង់ បំផ្លាញបង់ នូវទោសចេញហើយ ប្រៀន

ប្រដៅថែមទៀត ដោយគិតថា នឹងឲ្យអ្នកទាំងឡាយមានសារៈ គឺមគ្គផល តាំងនៅក្នុងសន្តាន ។ លុះព្រះមានបុណ្យ បានត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏មានសេចក្តីពេញចិត្ត ត្រេកអរនឹងភាសិត របស់ព្រះមានព្រះភាគ ដោយប្រការដូច្នេះ ។

## មហាសុញ្ញតសូត្រទី ២ ចប់

# អដ្ឋកថា

## មហាសុញ្ញតាសូត្រ

[ ១១ ] មហាសុញ្ញតាសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះ ជាដើម ។ ក្នុងបទទាំងនោះ បទថា **កាឡខេមកស្ស** សេចក្ដីថា ស្ដេចសក្យៈនោះមានស្បែកខ្មៅ ។ ឯបទថា **ខេមកោ** ជាឈ្មោះនៃស្ដេចសក្យៈនោះ ។ បទថា **វិហារោ** សំដៅដល់ ទីស្នាក់អាស្រ័យដែលស្ដេចសក្យៈព័ទ្ធរបងក្នុងទីណាមួយ ក្បែរនិគ្រោធារាមនោះឯង ធ្វើខ្លោងទ្វារ ប្រតិស្ឋានសេនាសនៈរូបហង្សជាដើម និងមាលាមណ្ឌល សាងរោងឆាន់ជាដើម ។ បទថា **សម្ពហុលានិ សេនាសនានិ** បានដល់ គ្រែ តាំង ពូក ខ្នើយ កន្ទេលប្រមក្ខណ្ឌ សន្ថ័តដែលធ្វើដោយស្មៅ សន្ថ័តដែលធ្វើដោយស្លឹកឈើ សន្ថ័តដែលធ្វើដោយចំបើងជាដើម ដែលគេក្រាល គឺរៀបគ្រែទល់គ្រែ ។បេ។ ក្រាលសន្ថ័តដែលធ្វើដោយចំបើង ទល់នឹងសន្ថ័តដែលធ្វើដោយចំបើងដូចគ្នា ។ ហាក់ដូចជាលំនៅរបស់ភិក្ខុដែលនៅជាគណៈ ។ បទថា **សម្ពហុលា នុ ខោ** សេចក្ដីថា ដែលឈ្មោះថា ការសង្ស័យ មិនមានដល់ព្រះមានព្រះភាគ ព្រោះព្រះអង្គដកកិលេសទាំងពួងបានហើយ ត្រង់ពោធិបល្ល័ង្កនោះឯង ។ បុច្ឆាដែលមានវិតក្កជាបុព្វភាគក្ដី និង **នុ** អក្ខរៈ ដែលមានវិតក្កជាបុព្វភាគក្ដី ត្រឹមតែជានិបាត កាលដល់វារៈព្រះបាលី ឈ្មោះថា មិនត្រូវវិនិច្ឆ័យ ។

បានឮថា ខាងមុខអំពីនេះ ព្រះមានព្រះភាគ មិនធ្លាប់ទតឃើញភិក្ខុទាំងឡាយនៅក្នុងទីជាមួយគ្នា ១០ រូប ១២ រូប ។

គ្រានោះ ព្រះអង្គមានព្រះតម្រិះដូច្នេះថា ឈ្មោះថា ការនៅជាគណៈនេះ បានប្រព្រឹត្តបដិបត្តិមកក្នុងវដ្តៈហើយ ដូចទឹកដែលហូរចុះកាន់ស្ទឹង ហើយកាលនៅជាគណៈ ក៏បានប្រព្រឹត្តមកហើយក្នុងនរក កំណើតសត្វតិរច្ឆាន បេត-វិស័យ និងអសុរកាយក៏មាន ក្នុងមនុស្សលោក ទេវលោក និងព្រហ្មលោកក៏មាន នរកមួយម៉ឺនយោជន៍ ពេញទៅដោយសត្វទាំងឡាយ ដូចនាឡិពេញទៅដោយកម្ទេចសំណ ពួកសត្វក្នុងទីដែលគេដាក់ទោស ដោយចំណង ៥ ប្រការ នឹងប្រមាណ ឬកំណត់មិនបាន ពួកសត្វដែលនៅជាគណៈ រមែងក្តៅក្រហាយក្នុងទីដែលត្រូវកាំបិតកាត់ជាដើមយ៉ាងនោះ ។ ក្នុងកំណើតសត្វតិរច្ឆាន ពពួកកណ្តៀរក្នុងដំបូក ១ មិនមានប្រមាណ ឬកំណត់មិនបាន ពពួកស្រមោចក្រហមជាដើម សូម្បីតែមួយសម្បុកក៏ដូចគ្នា សូម្បីកំណើតសត្វតិរច្ឆាន ក៏រមែងនៅរួមគ្នាជាគណៈ ។ ឯនគរប្រេតមានមួយគាវុតក៏មាន កន្លះយោជន៍ក៏មាន ពេញទៅដោយប្រេត សូម្បីក្នុងពួកប្រេត ក៏នៅរួមគ្នាជាគណៈយ៉ាងនេះឯង ។ ភពអសុរមានប្រមាណមួយម៉ឺនយោជន៍ ដូចរន្ធត្រចៀកដែលយកម្ជុលដោតត្រង់ត្រចៀក សូម្បីក្នុងអសុរកាយ ក៏រមែងនៅរួមគ្នាជាគណៈយ៉ាងនេះ ។ ក្នុងមនុស្សលោក គ្រាន់តែក្រុងសាវត្ថីមានដល់ទៅ ៥ លាន ៧ សែនត្រកូល ។ ក្នុងក្រុងរាជគ្រឹះ ទាំងខាងក្នុង ខាងក្រៅ មានមនុស្សនៅអាស្រ័យ ១៨ កោដិ ក្នុងឋានៈដទៃៗ ក្នុងមនុស្សលោក ក៏នៅរួមគ្នាជាគណៈដូចគ្នា ។ ក្នុងទេវលោក និងព្រហ្មលោក តាំងអំពីភុម្មទេវតាទៅ ក៏នៅរួមគ្នាជាគណៈ ។ ទេវបុត្រមួយអង្គ មានទេពអប្សរអ្នកកាំ ច្រៀងដល់ទៅ

២ កោដិកន្ទះ ទេវបុត្រខ្លះមានដល់ទៅ ៩ កោដិ សូម្បីព្រហ្ម ចំនួនរាប់ម៉ឺន ក៏រស់នៅក្នុងទីជាមួយគ្នា ។ បន្ទាប់មក ទ្រង់ព្រះតម្រិះថា តថាគតបំពេញបារមី ១០ អស់ ៤ អសង្ខេយ្យ និងមួយសែនកប្ប ក៏ដើម្បីកម្ចាត់ការនៅរួមគ្នាជាគណៈ តែភិក្ខុទាំងនេះ ចាប់ពីពេលនេះទៅ ភិក្ខុទាំងនេះ រមែងជួបជុំគ្នា ត្រេកអរក្នុងគណៈ ធ្វើកម្មមិនសមគួរឡើយ ។ ព្រះមានព្រះភាគ ទ្រង់កើតធម្មសង្វេគ ព្រោះភិក្ខុទាំងឡាយជាហេតុ ទ្រង់ត្រិះរិះថា បើតថាគតបញ្ញត្តសិក្ខាបទថា ភិក្ខុ ២ រូប មិនគប្បីនៅក្នុងទីជាមួយគ្នា តែមិនអាចបញ្ញត្តបានហើយចុះ តថាគតនឹងសម្តែងសូត្រឈ្មោះមហាសុញ្ញតាបដិបត្តិ ក៏ហាក់ដូចជាបញ្ញត្តសិក្ខាបទ សម្រាប់កុលបុត្រដែលប្រាថ្នាចំពោះការសិក្សា និងដូចកញ្ចក់សម្រាប់ឆ្លុះនៃពួកសត្វគ្រប់ជំពូក ដែលដាក់ត្រង់ទ្វារក្រុង បន្ទាប់ពីនោះ ក្សត្រជាដើមឃើញទោសរបស់ខ្លួនក្នុងកញ្ចក់ លះទោសនោះ រមែងមិនមានទោសយ៉ាងណា កាលតថាគតបរិនិព្វានហើយ កន្លងទៅដល់ ៥០០០ ឆ្នាំ កុលបុត្រទាំងឡាយ រមែងរឭកដល់ព្រះសូត្រនេះ នឹងបន្ទោបង់ភាពជាគណៈ ត្រេកអរក្នុងឯកីភាព នឹងធ្វើទីបំផុតនៃវដ្តទុក្ខបាន ។ កុលបុត្រទាំងឡាយ រឭកដល់ព្រះសូត្រនេះហើយ បន្ទោបង់នូវភាពជាគណៈ ញុំាងទុក្ខក្នុងវដ្តៈឲ្យអស់ទៅហើយបរិនិព្វានរាប់មិនអស់ ដូចញុំាងមនោរថរបស់ព្រះមានព្រះភាគ ឲ្យបរិបូណ៌ក្នុងវាលិកបិដ្ឋិវិហារ ព្រះអភយត្ថេរជាអ្នកជំនាញក្នុងព្រះអភិធម្មស្វាធ្យាយព្រះសូត្រនេះជាមួយភិក្ខុទាំងឡាយដ៏ច្រើន ក្នុងវស្សូបនាយិកសម័យពោលថា ព្រះសម្មាសម្ពុទ្ធប្រាសឲ្យធ្វើយ៉ាងនេះ ពួកយើងនឹងធ្វើដូចម្តេច ។

ភិក្ខុទាំងអស់នោះបន្ទោបង់ការនៅរួមគ្នាជាគណៈ ត្រេកអរក្នុងឯកីភាព ហើយសម្រេចអរហត្តខាងក្នុងវស្សា ។ ព្រះសូត្រនេះ ឈ្មោះថា ទម្លាយការនៅរួមគ្នាជាគណៈ ដោយប្រការដូច្នេះ ។

[ ១២ ] បទថា **យេន** បានដល់ ស្តេចសក្យៈដែលមានឈ្មោះយ៉ាងនោះ ។ បទថា **វិហារេ** សេចក្តីថា ក្នុងវិហារនេះ គប្បីជ្រាបថា សាងក្នុងឯកទេសនៃនិគ្រោធារាមនោះឯង ដូចវិហាររបស់ស្តេចសក្យៈ ឈ្មោះកាឡខេមកៈដែរ ។ បទថា **ចីវរកម្មំ** សេចក្តីថា ការចាត់ចែងយកសំពត់ចាស់សៅហ្មងមកប៉ះ និងបោកគក់ជាដើមក្តី សំពត់ដែលកើតឡើងដើម្បីធ្វើចីវរដែលមិនទាន់បានបោកគក់ និងមិនទាន់បានដេរ មកចាត់ចែងក្តី ក៏គួរ ។ តែក្នុងទីនេះ បំណងយកចំណែកដែលមិនទាន់បានរៀបចំធ្វើ ។ មនុស្សទាំងឡាយបានថ្វាយសំពត់ចីវរដល់ព្រះអានន្ទត្ថេរ ។ ព្រោះដូច្នោះ ទើបព្រះថេរៈបបួលភិក្ខុជាច្រើន ទៅធ្វើចីវរកម្មក្នុងវិហារនោះ ។ សូម្បីភិក្ខុទាំងនោះ តាំងអំពីផ្តើមដានអំពីព្រលឹម ក្រោកឡើងក្នុងវេលាមិនប្រាកដ ។ កាលដេរស្រេចហើយ ភិក្ខុទាំងនោះគិតថា នឹងរៀបចំសេនាសនៈដែលមិនទាន់បានរៀបចំ ។ បទថា **ចីវរកាលសមយោ នោ** សេចក្តីថា បានឮថា ព្រះថេរៈគិតថា ព្រះមានព្រះភាគ ទ្រង់ឃើញសេនាសនៈទាំងឡាយ ដែលភិក្ខុទាំងនេះមិនទាន់បានរក្សាទុកពិតប្រាកដ ដោយប្រការដូច្នេះ ព្រះសាស្តា ទ្រង់នឹងមិនពេញព្រះហឫទ័យ បំណងនឹងព្រមាន អញនឹងជួយស្រោចស្រង់ភិក្ខុទាំងនោះ ព្រោះដូច្នោះ ទើបព្រះថេរៈពោលយ៉ាងនេះ ។ ក្នុងសេចក្តីនេះ មានអធិប្បាយដូច្នេះ

ព្រះអានន្ទទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងនេះ មិនមែនបំណងតែការងារតែម្យ៉ាងប៉ុណ្ណោះទេ តែនៅយ៉ាងនេះ ដោយចីវរកិច្ច ។

[ ១៣ ] បទថា **ន ខោ អានន្ទ** សេចក្តីថា ម្នាលអានន្ទ កម្មសម័យក្តី អកម្មសម័យក្តី ចីវរកាលសម័យក្តី អចីវរកាលសម័យក្តី ចូរស្មេះទុកសិនភិក្ខុដែលត្រេកអរដោយការច្រឡូកច្រឡំមិនល្អឡើយ អ្នកកុំជួយស្រោចស្រង់ក្នុងឋានៈ ដែលមិនគួរជួយស្រោចស្រង់ ។ បណ្តាបទទាំងនោះ បទថា **សង្គណិកា** ជាបទរួមបរិស័ទរបស់ខ្លួន ។ បទថា **គណោ** ជាបទរួមជនផ្សេងៗ ។ ដោយប្រការដូច្នេះ ភិក្ខុទោះត្រេកអរដោយការច្រឡូកច្រឡំក៏ដោយ ត្រេកអរក្នុងគណៈក៏ដោយ ត្រេកអរក្នុងការកុះករនៃគណៈ ទាក់ទងដោយគណៈ រមែងមិនល្អដោយប្រការទាំងពួង ។ តែភិក្ខុបោសទីសម្រាកពេលថ្ងៃក្នុងវេលាក្រោយភត្ត ហើយលាងដៃ-ជើងស្អាត ទទួលមូលកម្មដ្ឋានប្រកបរឿយៗ នូវភាពជាបុគ្គលមានឯកគ្គតារម្មណ៍ រមែងស្អាតក្នុងព្រះពុទ្ធ-សាសនា ។

បទថា **នេក្ខម្មសុខំ** សេចក្តីថា សុខរបស់ភិក្ខុដែលចេញចាកកាម ទោះជាសុខដែលកើតអំពីសេចក្តីស្ងប់ ក៏ចាត់ជាសុខកើតអំពីសេចក្តីស្ងប់ចាកកាម ។ ឈ្មោះថា **ឧបសមសុខ** ព្រោះអត្ថថា ប្រព្រឹត្តទៅដើម្បីស្ងប់កិលេស មានរាគៈជាដើម ។ ឈ្មោះថា **សម្ពោធិសុខ** ព្រោះអត្ថថា ប្រព្រឹត្តទៅដើម្បីដឹងព្រមនូវមគ្គ ។ បទថា **និកាមលាភី** ប្រែថា បានតាមដែលត្រូវការ គឺបានតាមប្រាថ្នា ។ បទថា **អកិច្ឆលាភី** ប្រែថា បានដោយមិនលំបាក ។ បទថា

**អកសិរលាភី** ប្រែថា បានដោយងាយ ។ បទថា **សាមាយិកំ** បានដល់ផុតកិលេសជាគ្រាៗ ។ បទថា **កន្តំ** ប្រែថា ជាទីពេញចិត្ត ។ បទថា **ចេតោ-វិមុត្តឹ** បានដល់ ចេតោវិមុត្តិជារូបាវចរនិងអរូបាវចរ ។ សមដូចព្រះតម្រាស់ថា ឈាន ៤ និងអរូបសមាបត្តិ ៤ នេះ ចាត់ជាវិមោក្ខជាខណៈ ជាសម័យ ។ បទថា **អសាមាយិកំ** សេចក្តីថា ផុតចាកកិលេស មិនទាក់ទងដោយសម័យ ។ អច្ចន្តវិមុត្តចាត់ជាលោកុត្តរពិត ។ សមដូចព្រះតម្រាស់ថា អរិយមគ្គ ៤ សាមញ្ញផល ៤ នេះ ចាត់ជាវិមោក្ខដែលមិនប្រព្រឹត្តទៅដោយសម័យ ។ បទថា **អកុប្បំ** ប្រែថា មិនញុំាងកិលេសឲ្យកម្រើក ។ តាមដែលអធិប្បាយមកនេះ លោកពោលសំដៅដល់អ្វី ។ ភិក្ខុដែលចូលចិត្តប្រឡូកប្រឡំជាពួក ជាគណៈ រមែងមិនអាចញុំាងលោកិយគុណ និងលោកុត្តរ-គុណឲ្យកើតឡើងបានឡើយ ។ តែបើបន្ទោបង់នូវការនៅជាគណៈ ត្រេកអរក្នុងឯកីភាព ទើបអាចញុំាងលោកិយគុណ និងលោកុត្តរគុណឲ្យកើតឡើងបានពិតហើយ សូម្បីព្រះវិបស្សីពោធិសត្វហែហមទៅដោយបព្វជិត ៨ ម៉ឺន ៤ ពាន់រូប ត្រាច់ទៅអស់ ៧ ឆ្នាំ ក៏មិនអាចញុំាងពោធិញ្ញាណឲ្យកើតឡើងបាន ។ កាលបន្ទោបង់នូវភាពជាគណៈ ហើយត្រេកអរក្នុងឯកីភាព ឡើងកាន់ពោធិ-មណ្ឌល ៧ ថ្ងៃ ញុំាងសព្វញ្ញុគុណឲ្យកើតហើយ ព្រះពោធិសត្វនៃយើងទាំងឡាយ ត្រាច់ទៅអស់ ៦ ឆ្នាំ ជាមួយបញ្ចវគ្គិយភិក្ខុ ក៏មិនអាចញុំាងគុណនៃសព្វញ្ញុឲ្យកើតបាន កាលបញ្ចវគ្គិយចៀសចេញទៅហើយ ទ្រង់ត្រេកអរក្នុងឯកីភាព ទ្រង់ឡើងកាន់ពោធិមណ្ឌល ញុំាងសព្វញ្ញុគុណឲ្យកើតហើយ ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងថា បុគ្គលដែលពេញចិត្តក្នុងការប្រឡូកប្រឡំ មិនមានផ្លូវដែលអាចសម្រេចគុណវិសេសបានយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្ដែងការកើតទោស ទើបត្រាស់ថា **ឆាហំ អានន្ទ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **រូបំ** បានដល់ សរីរៈ ។ បទថា **យត្ថ រត្តស្ស** បានដល់ ត្រេកអរដោយតម្រេកក្នុងរូបណា ។ បទថា **ន ឧប្បជ្ជេយ្យុំ** សេចក្ដីថា មិនកើតអំពីភិក្ខុដែលត្រេកត្រអាលក្នុងរូបណា តថាគតមិនពិចារណាឃើញរូបនោះឡើយ ដែលពិត រមែងកើតឡើងបាន ដូចកើតឡើងដល់បរិព្វាជកឈ្មោះសញ្ជ័យ ដោយភាពដទៃ កាលព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានចូលទៅជាសាវ័ករបស់ព្រះទសពល និងដូចកើតដល់និគណ្ឋនាដបុត្រ កាលឧបាលិគហបតីប្ដូរចិត្ត និងដូចកើតដល់សេដ្ឋីជាដើម ក្នុងបិយជាតកសូត្រ ។

[ ១៤-១៥ ] បទថា **អយំ ខោ បន អានន្ទ** ជាបទជាប់សេចក្ដីមួយ ។ បើភិក្ខុដែលបួសថ្មី ជាអ្នកមានការចេះដឹងទាបរូបខ្លះ នឹងគប្បីពោលថា ព្រះសម្មាសម្ពុទ្ធ ល្អតែនាំពួកយើងចេញចាកគណៈ ប្រកបក្នុងភាពម្នាក់ឯង ដូចអ្នកស្រែនាំគោដែលចូលទៅកាន់ស្រែចេញមក ឯព្រះអង្គឯង ហែហមទៅដោយព្រះរាជា និងរាជបរិវារជាដើម ព្រោះដូច្នោះ ព្រះតថាគតសូម្បីប្រថាប់គង់កណ្ដាលបរិស័ទ មានចក្រវាលជាទីបំផុត ក៏ទ្រង់ផ្ដើមទេសនានេះ ដើម្បីទ្រង់សម្ដែងថា ជាអ្នកនៅម្នាក់ឯង ដើម្បីមិនឲ្យឱកាសភិក្ខុរូបខ្លះនោះ និយាយលើកទោសបាន ។ បណ្ដាបទទាំងនោះ បទថា **សព្វនិមិត្តានំ** បានដល់និមិត្តដែលតាក់តែងហើយ មានរូបជាដើម ។ បទថា **អជ្ឈត្តំ** សេចក្ដីថា ក្នុង

ខាងក្នុងខ្លួន ។ បទថា **សុញ្ញតំ** បានដល់ សុញ្ញតាផលសមាបត្តិ ។ បទថា **តត្ថ ចេ** ជាសត្តមីវិភត្តិ ចុះក្នុងអត្ថទុតិយាវិភត្តិ អធិប្បាយថា ស្មើគ្នានឹង **តំ ចេ** ។ បទថា **តត្រ** សេចក្តីថា ព្រះតថាគតប្រថាប់កណ្តាលបរិស័ទនោះ ។ បទថា **វិវេកនិន្នេន** បានដល់ បង្អោនទៅក្នុងព្រះនិព្វាន ។ បទថា **ព្យន្តីភូតេន** សេចក្តីថា ប្រាសចាក គឺវលាស់ចេញ បានដល់ ប្រាសចាកធម៌ ជាទីតាំងនៃអាសវៈ ។ បទថា **ឧយ្យោជនិកប្បដិសំយុត្តំ** សេចក្តីថា ប្រកបដោយវាចាដែលដឹកនាំយ៉ាងនេះថា អ្នកទាំងឡាយចូរទៅចុះ ។ សួរថា ព្រះមានព្រះភាគត្រាស់យ៉ាងនេះ វេលាណា ឆ្លើយថា ត្រាស់ក្នុងវេលាក្រោយភត្តកិច្ចក៏មានក្នុងវេលាបំពេញពុទ្ធកិច្ចក្នុងបឋមយាមក៏មាន ។ ព្រះមានព្រះភាគ សម្រេចសីហសេយ្យានៈក្នុងព្រះគន្ធកុដិ ខាងក្រោយភត្តាហារ ចេញអំពីសីហ-សេយ្យានៈហើយ ប្រថាប់គង់ចូលផលសមាបត្តិ ។ ក្នុងសម័យនោះ បរិស័ទទាំងឡាយ រមែងប្រជុំគ្នាដើម្បីស្តាប់ធម៌ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ជ្រាបវេលាហើយ យាងចេញអំពីព្រះគន្ធកុដិ ទ្រង់ទៅកាន់ពុទ្ធាសនៈដ៏ប្រសើរ ទ្រង់សម្តែងធម៌មិនឲ្យវេលាកន្លងទៅ ដូចបុរសកាន់យកប្រេងដែលចម្រាញ់សម្រាប់ធ្វើថ្នាំ ទ្រង់បញ្ជូនបរិស័ទទៅដោយចិត្តដែលបង្អោនទៅក្នុងវិវេក ។ កាលបុរិមយាមកន្លងទៅ ទ្រង់បញ្ជូនបរិស័ទត្រឡប់ ដោយព្រះតម្រាស់យ៉ាងនេះថា ម្នាលវាសេដ្ឋៈ រាត្រីកន្លងទៅហើយ ឥឡូវនេះ ពួកអ្នកចូរសម្គាល់កាលគួរចុះ ។ ចាប់អំពីព្រះពុទ្ធទាំងឡាយ សម្រេចព្រះពោធិញ្ញាណហើយ សព្វញ្ញុតញ្ញាណទាំង ១០ របស់ព្រះអង្គ ក៏បង្អោនទៅ

ដើម្បីព្រះនិព្វានតែម្យ៉ាង ។

បទថា **តស្មាតិហានន្ទ** សេចក្តីថា ព្រោះសុញ្ញតាវិហារ ស្ងប់ ប្រណីត ដូច្នោះ ។ បទថា **អជ្ឈត្តមេវ** បានដល់ ខាងក្នុងគោចរនោះឯង ។ ខាងក្នុងនៃខ្លួនក្នុងបទនេះថា **អជ្ឈត្តំ សុញ្ញតំ** អធិប្បាយថា អាស្រ័យបញ្ចក្ខន្ធរបស់ខ្លួន ។ បទថា **សម្បជានោ ហោតិ** សេចក្តីថា ដឹងខ្លួន ដោយដឹងថា កម្មដ្ឋានមិនទាន់បរិបូណ៌ ។ បទថា **ពហិទ្ធា** បានដល់ ក្នុងបញ្ចក្ខន្ធរបស់អ្នកដទៃ ។ បទថា **អជ្ឈត្តពហិទ្ធា** សេចក្តីថា ជួនកាលខាងក្នុង ជួនកាលខាងក្រៅ ។ បទថា **អនេញ្ជំ** សេចក្តីថា ដាក់ចិត្តក្នុងអនេញ្ជសមាបត្តិ គឺអរូបសមាបត្តិថាអញទឹងជាឧភតោភាគវិមុត្តិ ។ បទថា **តស្មិំយេវ បុរិមស្មិំ** លោកពោលសំដៅដល់ឈានដែលជាបាទ ។ កាលភិក្ខុនោះចេញចាកឈានដែលជាបាទ ដែលនៅមិនទាន់ស្ទាត់ជំនាញ ដាក់ចិត្តក្នុងសុញ្ញតាក្នុងខាងក្នុង ចិត្តរមែងមិនស្ទុះទៅក្នុងសុញ្ញតាសមាបត្តិនោះ ។ បន្ទាប់អំពីនោះ ដាក់ចិត្តទៅខាងក្រៅថា ក្នុងសន្តាននៃអ្នកដទៃដូចម្តេចហ្ន៎ ។ ចិត្តរមែងមិនស្ទុះទៅក្នុងសុញ្ញតាសមាបត្តិនោះ ។ បន្ទាប់អំពីនោះ ដាក់ចិត្តទាំងខាងក្នុងផង ខាងក្រៅផងថា ក្នុងសន្តាននៃខ្លួន ជួនកាលដូចម្តេច ក្នុងសន្តាននៃអ្នកដទៃ ជួនកាលដូចម្តេច ។ ចិត្តរមែងមិនស្ទុះទៅស្ទូប្បីក្នុងសុញ្ញតាសមាធិនោះ ។ បន្ទាប់អំពីនោះ អ្នកបំណងជាឧភតោភាគវិមុត្តិ ដាក់ចិត្តក្នុងអនេញ្ជាសមាបត្តិថា ក្នុងអរូបសមាបត្តិដូចម្តេចហ្ន៎ ដូច្នេះ ។ ចិត្តរមែងមិនស្ទុះទៅស្ទូប្បីក្នុងអនេញ្ជាសមាបត្តិនោះ ។ ភិក្ខុដែលលះសេចក្តីព្យាយាម មិនគប្បីប្រព្រឹត្តតាមក្រោយឧបដ្ឋាករបស់ខ្លួន

ដោយគិតថា ឥឡូវនេះ ចិត្តរបស់អញមិនទាន់ស៊ុះទៅ តែគប្បីដាក់ចិត្តដល់ឈានដែលជាបាទ ឲ្យស្មើដោយល្អតែម្យ៉ាង ។ ដើម្បីទ្រង់សម្តែងថា ការដាក់ចិត្ត កម្មដ្ឋានរមែងស៊ុះទៅស្រួល ដូចបុរសកាប់ដើមឈើ កាលពូថៅរិល ត្រូវសំលៀងពូថៅជាមុនសិន ហើយសឹមកាប់ ទើបពូថៅមុត ដោយប្រការដូច្នោះ ទើបត្រាស់ពាក្យថា **តស្មិញ្ញេវ** ដូច្នេះជាដើម ។

ឥឡូវនេះ កាលទ្រង់សម្តែងថា កាលភិក្ខុនោះបដិបត្តិយ៉ាងនេះ ការដាក់ចិត្តក្នុងសមាបត្តិនោះៗ រមែងបរិបូណ៌ ទើបត្រាស់ថា **បក្ខន្ទតិ**។

[ ១៦ ] បទថា **ឥមិនា វិហារេន** បានដល់ ដោយវិហារធម៌ គឺសមថៈនិងវិបស្សនា ។ បទថា **ឥតិហា តត្ថ សម្បជានោ** សេចក្តីថា កាលកំពុងដើរចង្រ្កម ក៏ដឹងច្បាស់ថា កាលកម្មដ្ឋាននោះបរិបូណ៌ កម្មដ្ឋានរបស់អញក៏បរិបូណ៌ ។ បទថា **សយតិ** ប្រែថា រមែងដេក ។ ក្នុងពាក្យនេះ សេចក្តីថា ភិក្ខុទោះដើរចង្រ្កមក្នុងកាលណា ក៏ដឹងថា ឥឡូវនេះ អញអាចដើរចង្រ្កមបាន អស់កាលមានប្រមាណប៉ុណ្ណោះ មិនសម្រាកឥរិយាបថឡើយ ស្ថិតនៅ ។ ក្នុងវារៈទាំងពួងក៏ន័យនេះ ។ បទថា **ឥតិហា តត្ថ** សេចក្តីថា រមែងដឹងខ្លួនក្នុងឥរិយាបថនោះៗ ដោយដឹងថា អញនឹងមិនពោលយ៉ាងនេះ ។ សូម្បីក្នុងទុតិយវារៈ ភិក្ខុក៏ដឹងខ្លួន ដោយដឹងថា អញនឹងពោលពាក្យបែបនេះ ។ ភិក្ខុនេះនៅមានសមថវិបស្សនាទន់ខ្វីដោយពិត ។ ដើម្បីតាមរក្សាសមថវិបស្សនាទាំងនោះ គប្បីប្រាថ្នាសប្បាយ ៧ យ៉ាង គឺអាវាស ១ គោចរ ១ ការសន្ទនា ១ បុគ្គល ១ ភោជន ១ ឧតុ ១ ឥរិយាបថ ១ ។

ដើម្បីសម្តែងសប្បាយទាំង ៧ នោះ ទើបត្រាស់យ៉ាងនេះ ។ ក្នុងវិតក្ក-វារៈទាំងឡាយ គប្បីជ្រាបតាមភាពជាអ្នកដឹងខ្លួន ទាំងអវិតក្ក និងវិតក្ក ។

[ ១៧ ] ព្រះមានព្រះភាគត្រាស់មគ្គទាំង ២ ដោយការលះនូវវិតក្កដូចពោលមកនេះហើយ ឥឡូវនេះ ដើម្បីត្រាស់ប្រាប់ការឃើញច្បាស់នូវតតិយមគ្គ ទើបត្រាស់ពាក្យជាដើមថា **បញ្ច ខោ ឥមេ អានន្ទ កាមគុណា** ដូច្នេះ ។ បទថា **អាយតនេ** សេចក្តីថា ក្នុងហេតុកើតកិលេសណាមួយក្នុងកាមគុណទាំងនោះ ។ បទថា **សមុទាចារោ** បានដល់ កិលេសដែលនៅមិនទាន់លះបាន ព្រោះនៅរាយមាយ ។ បទថា **ឯវំ សន្តំ** សេចក្តីថា មានយ៉ាងនេះឯង ។ បទថា **សម្បជានោ** បានដល់ ដឹងច្បាស់ ដោយដឹងថា កម្មដ្ឋាននៅមិនទាន់បរិបូណ៌ ។ ក្នុងទុតិយវារៈមានវិនិច្ឆ័យដូចតទៅនេះ បទថា **ឯវំ សន្តំ** ប្រែថា មានយ៉ាងនេះ ។ បទថា **ឯវំ សម្បជានោ** បានដល់ ដឹងច្បាស់ ដោយដឹងថា កម្មដ្ឋានបរិបូណ៌ ។ កាលភិក្ខុនេះពិចារណាថា ឆន្ទរាគៈក្នុងកាមគុណទាំង ៥ អញលះបានហើយ ឬនៅហ្ន៎ ដូច្នេះ ដឹងថា មិនទាន់លះបាន ដោយផ្គងនូវសេចក្តីព្យាយាម ទើបដកឆន្ទរាគៈនោះបាន ដោយអនាគាមិមគ្គ ។ បន្ទាប់ពីនោះ ក៏ពិចារណាផលសមាបត្តិក្នុងលំដាប់នៃមគ្គ ចេញអំពីផលសមាបត្តិ ហើយពិចារណា ទើបដឹងថា លះបានហើយ ។ អធិប្បាយថា រមែងដឹងច្បាស់ ដោយដឹងថា លះឆន្ទរាគៈនោះបានហើយ ។

[ ១៨ ] ឥឡូវនេះ កាលត្រាស់ប្រាប់ការឃើញច្បាស់នូវអរហត្តមគ្គ ទើបត្រាស់ពាក្យថា **បញ្ច ខោ ឥមេ អានន្ទ ឧបាទានក្ខន្ធា** ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា **សោ បជហីយតិ** សេចក្តីថា លះមានះថាមានក្នុងរូប លះឆន្ទៈថាមានក្នុងរូប លះអនុស័យថាមានក្នុងរូប ។ ការដឹងច្បាស់ក្នុងវេទនាជាដើម គប្បីជ្រាបដោយន័យដូចពោលហើយយ៉ាងនោះឯង ។ ព្រះមានព្រះភាគត្រាស់ថា **ឥមេ ខោ តេ អានន្ទ ធម្មា** ដូច្នេះ ទ្រង់សំដៅដល់ធម៌ គឺសមថៈ វិបស្សនា មគ្គ និងផលដែលត្រាស់ហើយខាងដើម ។ បទថា **កុសលាយត្តិកា** ប្រែថា មកអំពីកុសល ។ សេចក្តីពិត កុសលធម៌ទាំងឡាយ ជាកុសលក្តី ជាធម៌ដែលទាក់ទងមកអំពីកុសលក្តី អាកិញ្ចញ្ញា-យតនជ្ឈានជាកុសល នេវសញ្ញានាសញ្ញាយតនជ្ឈានជាកុសលក្តី ធម៌ដែលទាក់ទងមកអំពីកុសលក្តី នេវសញ្ញានាសញ្ញាយតនជ្ឈានជាកុសល សោតា-បត្តិមគ្គជាកុសលក្តី ធម៌ដែលទាក់ទងមកអំពីកុសលក្តី ។បេ។ អនាគាមិមគ្គជាកុសល អរហត្តមគ្គជាកុសលក្តី ជាធម៌ដែលទាក់ទងមកអំពីកុសលក្តី បឋមជ្ឈានក៏ចាត់ជាកុសលដូចគ្នា ធម៌ដែលសម្បយុត្តដោយបឋមជ្ឈាននោះជាកុសលក្តី និងជាធម៌ដែលទាក់ទងមកអំពីកុសលក្តី ។បេ។ អរហត្តមគ្គជាកុសល ធម៌ដែលសម្បយុត្តដោយអរហត្តមគ្គនោះ ជាកុសលក្តី ជាធម៌ដែលទាក់ទងមកអំពីកុសលក្តី ។ បទថា **អរិយា** ប្រែថា មិនមានកិលេស គឺបរិសុទ្ធ ។ បទថា **លោកុត្តរា** ប្រែថា កំពូល គឺបរិសុទ្ធក្នុងលោក ។ បទថា **អនវក្កន្តា បាបិមតា** ប្រែថា ដែលមារមានចិត្តបាបឈមចុះមិនបាន ។ មាររមែងមិនឃើញចិត្តនៃភិក្ខុដែលអង្គុយចូលសមាបត្តិ ៨ មានវិបស្សនាជាបាទ គឺមិនអាចដើម្បីដឹងថា ចិត្តនៃភិក្ខុនោះ អាស្រ័យអារម្មណ៍ឈ្មោះនេះ

ប្រព្រឹត្តទៅ ព្រោះដូច្នោះ ទើបត្រាស់ថា **អនវក្កន្តា** ។ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់បទនេះថា **តំ កឹ មញ្ញសិ** ។ សេចក្តីពិត ក្នុងគណៈក៏មានអានិសង្សម្យ៉ាង ដើម្បីទ្រង់សម្តែងអានិសង្សនោះ ទើបត្រាស់ពាក្យនេះ ។ បទថា **អនុពន្ធិតុំ** ប្រែថា ជាប់តាមទៅ គឺចោមរោម ។

[ ១៩ ] ក្នុងបទថា **ន ខោ អានន្ទ** នេះ មានវិនិច្ឆ័យថា ម្នាលភិក្ខុទាំងឡាយ អរិយសាវកបានស្តាប់ហើយ តែព្រះដ៏មានព្រះភាគ រមែងលះអកុសល ចម្រើនកុសល លះធម៌ដែលមានទោស ចម្រើនធម៌ដែលមិនមានទោស បរិហារខ្លួនឲ្យបរិសុទ្ធ ដូច្នេះ ។ ឈ្មោះថា ធ្វើខ្លួនឲ្យជាពហុសូត ដូចទាហានដែលដល់ព្រមដោយអាវុធ ៥ យ៉ាង ។ ព្រោះភិក្ខុទោះរៀនសុត្តបរិយត្តិ តែមិនរៀនអនុលោមប្បដិបទា សមគួរដល់សុត្តប្បរិយត្តិនោះ លោករមែងឈ្មោះថា មិនមានអាវុធនោះ ឯភិក្ខុណាបដិបត្តិ ទើបភិក្ខុនោះឯង ឈ្មោះថា មានអាវុធ ដូច្នោះ កាលនឹងសម្តែងសេចក្តីនេះថា មិនគួរគិតតាម ទើបត្រាស់ថា **ន ខោ អានន្ទ** ដូច្នេះ ។

ឥឡូវនេះ ដើម្បីទ្រង់សម្តែងរឿងដែលគួរជាប់តាម ទើបត្រាស់ពាក្យថា **យា ច ខោ** ដូច្នេះជាដើម ។ កថាវត្ថុ ១០ ក្នុងឋានៈទាំង ៣ មកក្នុងព្រះសូត្រនេះ ដោយប្រការដូច្នេះ ។ មកដោយអំណាចនៃធម៌ដែលជាសប្បាយ និងធម៌ដែលជាអសប្បាយ ដូចក្នុងប្រយោគជាដើមថា **ឥតិ ឯវរូបំ កថំ កថេស្សាមិ** ទើបតថាគតពោលកថាបែបនេះ ដោយប្រការនេះ ។ មកដោយអំណាចសុត្តបរិយត្តិ ដូចក្នុងប្រយោគជាដើមថា **យទិទំ សុត្តំ គេយ្យំ** តែ

ក្នុងទីនេះមកហើយដោយបរិបូណ៌ ។ ព្រោះដូច្នោះ កាលនឹងត្រាស់កថាវត្ថុ ១០ ក្នុងព្រះសូត្រនេះ ទើបត្រាស់រួមនៅក្នុងឋានៈនេះ ។

ឥឡូវនេះ ព្រោះហេតុដែលភិក្ខុពួកខ្លះ សូម្បីនៅម្នាក់ឯង ក៏មិនកើតប្រយោជន៍ ដូច្នោះ ដើម្បីទ្រង់សម្តែងទោសក្នុងការនៅម្នាក់ឯង ។ ទ្រង់សំដៅដល់ភិក្ខុពួកខ្លះនោះ ទើបត្រាស់ពាក្យជាដើមថា **ឯវំ សន្តេ ខោ អានន្ទ** ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ឯវំ សន្តេ** សេចក្តីថា កាលនៅម្នាក់ឯងយ៉ាងនោះមាន ។

[ ២០-២៤ ] បទថា **សត្ថា** សំដៅយកមេលទ្ធិក្រៅសាសនា ។ បទថា **អន្វាវត្តន្តិ** ប្រែថា ស្របតាម គឺចូលទៅរក ។ បទថា **មុច្ឆំ និកាមយតិ** ប្រែថា ប្រាថ្នាការចង់រួចផុត អធិប្បាយថា ឲ្យប្រព្រឹត្តទៅ ។ បទថា **អាចរិយូបទ្ទវេន** សេចក្តីថា ឈ្មោះថា ឧបទ្រវនៃអាចារ្យ ព្រោះមានអន្តរាយ គឺកិលេសកើតឡើងខាងក្នុងនៃខ្លួន ។ សូម្បីក្នុងឧទ្រវដ៏សេសក៏មានន័យដូចគ្នា ។ បទថា **អវធីសុ នំ** ប្រែថា សម្លាប់សាស្តានោះចោលហើយ ។ លោកពោលដល់ការស្លាប់ចាកសេចក្តីល្អ ដោយបទថា **អវធីសុ នំ** នេះ ។ បទថា **វិនិបាតាយ** ប្រែថា ឲ្យធ្លាក់ទៅដោយល្អ ។ ព្រោះហេតុអ្វី ទើបលោកពោលឧបទ្រវនៃអ្នកប្រព្រឹត្តព្រហ្មចរិយៈថា មានទុក្ខជាវិបាក ថាមានផលផ្សាក្តៅ ជាវិបាកថា ប្រព្រឹត្តទៅដើម្បីការធ្លាក់ចុះ ។ ពិតហើយ ការបួសខាងក្រៅព្រះសាសនា មានលាភតិច ក្នុងការបួសក្រៅសាសនានោះ មិនមានផ្លូវឲ្យកើតគុណធំបានឡើយ មានត្រឹមតែសមាបត្តិ ៨ អភិញ្ញា ៥ ប៉ុណ្ណោះ ។ ប្រៀប

ដូចបុគ្គលធ្លាក់អំពីខ្នងលា រមែងមានទុក្ខច្រើន គឺមានខ្លួនប្រឡាក់ធូលីប៉ុណ្ណោះ យ៉ាងណា ក្នុងលទ្ធិក្រៅសាសនាក៏ដូច្នោះ ទោះសាបសូន្យ ក៏ត្រឹមតែលោកិយ-គុណប៉ុណ្ណោះ ដូច្នោះ ឧបទ្វ ២ យ៉ាងខាងដើម ទើបលោកមិនពោលយ៉ាងនេះ ដោយប្រការដូច្នេះ ។ តែកាលបួសក្នុងព្រះសាសនា មានលាភច្រើន ហើយការបួសក្នុងព្រះសាសនានោះ មានគុណដែលគប្បីបានសម្រេចជំកន្លង គឺមគ្គ ៤ ផល ៤ និព្វាន ១ ។ ខត្តិយកុមារដែលជាឧភតោសុជាតិ ប្រថាប់លើ-កដីរ ប្រពាតព្រះនគរ កាលធ្លាក់អំពីកដីរ ក៏ដល់នូវទុក្ខច្រើន យ៉ាងណា បុគ្គលវិនាសចាកសាសនា ក៏ដូច្នោះ រមែងវិនាសចាកលោកុត្តរគុណ ៩ ប្រការ ដូច្នេះ ។ ព្រោះដូច្នោះ ទើបលោកពោលឧបទ្វនៃអ្នកប្រព្រឹត្តព្រហ្មចរិយៈយ៉ាងនេះ ។

បទថា **តស្មា** សេចក្តីថា ព្រោះឧបទ្វនៃអ្នកប្រព្រឹត្តព្រហ្មចរិយៈ មានទុក្ខជាផលច្រើន ឧបទ្វដ៏សេស ព្រោះបដិបទារបស់បុគ្គលជាសត្រូវ រមែងប្រព្រឹត្តទៅដើម្បីវត្ថុមិនជាប្រយោជន៍ ដើម្បីទុក្ខអស់កាលយូរ បដិបទារបស់បុគ្គលជាមិត្រ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដូច្នោះ គប្បីប្រកបការគប់រកដោយភាពជាមិត្រ និងមិនមែនគប់រកដោយភាពជាសត្រូវ ដោយអត្ថទាំងមុន ទាំងក្រោយយ៉ាងនេះ ដោយប្រការដូច្នេះ ។ បទថា **មិត្តវតាយ** ប្រែថា ដោយកិច្ចបដិបត្តិតថាគតជាមិត្រ ។ បទថា **សបត្តវតាយ** ប្រែថា ដោយបដិបត្តិដូចសត្រូវ ។ បទថា **ឱក្កម្ម ច សត្ថុ សាសនេ** សេចក្តីថា បើដាក់ចិត្តកន្លងអាបត្តិសូម្បីទុក្កដ និងទុព្ភាសិត ឈ្មោះថា ប្រព្រឹត្តឃៀងឃាត បើ

មិនដាក់ចិត្តប្រព្រឹត្តកន្ទង ដូច្នោះ ឈ្មោះថា មិនប្រព្រឹត្តឃ្វៀងឃ្វាត ។ បទថា **ន វោ អហំ អានន្ទ តថា បរក្កមិស្សាមិ** សេចក្តីថា តថាគតមិនបដិបត្តិអ្នកទាំងឡាយយ៉ាងនោះ ។ បទថា **អាមកេ** ប្រែថា មិនទាន់រឹង ។ បទថា **អាមកមត្តេ** ប្រែថា ក្នុងភាជនៈឆៅ គឺមិនទាន់ស្ងួតល្អ ។ ពិតហើយ ស្មូនឆ្នាំងយកដៃទាំង ២ សង្រួមៗ ផ្គងភាជនៈឆៅដែលមិនទាន់ស្ងួតល្អ មិនទាន់ធ្អិន ដោយគិតថា កុំបែកឡើយ ។ ពន្រឹកសេចក្តីថា តថាគតនឹងមិនបដិបត្តិក្នុងអ្នកទាំងឡាយ ដូចស្មូនឆ្នាំងបដិបត្តិក្នុងភាជនៈឆៅនោះ ដោយប្រការដូច្នេះ ។ បទថា **និគ្គយ្ហ និគ្គយ្ហ** សេចក្តីថា តថាគតមិនប្រៀនប្រដៅតែម្តង ហើយនៅស្ងៀម តែតិះដៀលហើយ ប្រៀនប្រដៅរឿយៗ ។ បទថា **បវយ្ហ បវយ្ហ** ប្រែថា តថាគតនឹងសរសើរ នឹងសរសើរ ។ ប្រៀបដូចស្មូនឆ្នាំងជ្រើសយកភាជនៈដែលខូច ក្នុងភាជនៈដែលធ្អិនចេញគរ វាយកម្ទេច គឺយកចំណែកដែលល្អប៉ុណ្ណោះ យ៉ាងណា សូម្បីតថាគតក៏ដូច្នោះ នឹងទំនុកបម្រុង សរសើរពោលដាស់តឿនប្រៀនប្រដៅរឿយៗ ។ បទថា **យោ សារោ សោ ឋស្សតិ** សេចក្តីថា ធម្មតាអ្នកទាំងឡាយដែលតថាគតប្រៀនប្រដៅ បុគ្គលណាមានខ្លឹមសារ គឺមគ្គ ផល បុគ្គលនោះនឹងតាំងនៅបាន ម្យ៉ាងទៀត សូម្បីលោកិយគុណ ក៏បំណាងយកថាជាខ្លឹមក្នុងទីនេះដូចគ្នា ។ ពាក្យដ៏សេស ក្នុងបទទាំងពួង ងាយយល់ទាំងអស់ហើយ ៕

អដ្ឋកថា មហាសុញ្ញតាសូត្រ ចប់

សូត្រទី ២ ចប់

# សុត្តន្តបិដក

## អច្ឆរិយព្ភូតធម្មសូត្រទី ៣

[ ២៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ កាល ពួកភិក្ខុមានចំនួនច្រើន ត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត អង្គុយ ប្រជុំគ្នាក្នុងឧបដ្ឋានសាលា ក្នុងកាលនោះឯង អន្តរាកថានេះ ក៏កើតឡើងថា អស្ចារ្យណាស់ អាវុសោ ចម្លែកណាស់ អាវុសោ ត្រង់ដែលព្រះតថាគត ព្រះអង្គមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះថា ព្រះតថាគតទ្រង់ជ្រាបនូវ ព្រះអតីតពុទ្ធទាំងឡាយ ដែលបរិនិព្វានហើយ ទ្រង់ផ្តាច់ផ្តិលនូវកិលេស ជា គ្រឿងញ៉ាំងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្តាច់ផ្តិលនូវកម្មជាគ្រឿងញ៉ាំង សត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្មជាគ្រឿងញ៉ាំងសត្វឲ្យវិលវល់ ទ្រង់ កន្លងបង់នូវទុក្ខទាំងពួងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានព្រះនាមយ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានព្រះគោត្រយ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានសីលយ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានធម៌យ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានបញ្ញាយ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានវិហារធម៌យ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ ។ លុះភិក្ខុទាំងឡាយនិយាយ យ៉ាងនេះហើយ ព្រះអានន្ទមានអាយុ បានពោលនឹងភិក្ខុទាំងនោះដូច្នេះថា ម្នាលអាវុសោ ព្រះតថាគតទាំងឡាយ ជាបុគ្គលអស្ចារ្យ ទាំងប្រកបដោយ

ធម៌ អស្ចារ្យមែន ម្នាលអាវុសោ ព្រះតថាគតទាំងឡាយ ជាបុគ្គលចម្លែក ទាំងប្រកបដោយធម៌ដ៏ចម្លែកមែន ។ នេះជាអន្តរាកថា របស់ភិក្ខុទាំងនោះ អន្តរាកថានេះ ក៏ដាច់ពាក់កណ្ដាលទៅ ។

[ ២៦ ] លំដាប់នោះ ព្រះមានព្រះភាគទ្រង់ចេញអំពីការសម្ងំ ក្នុងសាយណ្ហសម័យ ហើយចូលសំដៅទៅឧបដ្ឋានសាលា លុះទ្រង់ចូលទៅដល់ហើយ ក៏ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគទ្រង់គង់ហើយ ក៏មានព្រះបន្ទូលនឹងពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ អ្នកទាំងឡាយ អង្គុយប្រជុំគ្នា និយាយដូចម្ដេច ចុះពាក្យដូចម្ដេច ដែលអ្នកទាំងឡាយបញ្ឈប់ទៅ ។ ភិក្ខុទាំងឡាយក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន អម្បាញ់មិញនេះ ខ្ញុំព្រះអង្គទាំងឡាយ ត្រឡប់មកអំពីបិណ្ឌបាតក្នុងវេលាក្រោយភត្ត ក៏អង្គុយប្រជុំគ្នាក្នុងឧបដ្ឋានសាលា អន្តរាកថានេះ កើតឡើងដូច្នេះថា អស្ចារ្យណាស់ អាវុសោ ចម្លែកណាស់ អាវុសោ ត្រង់ដែលព្រះតថាគត ព្រះអង្គមានឫទ្ធិច្រើន មានអានុភាពច្រើន ព្រោះថា ព្រះតថាគតទ្រង់ជ្រាបនូវព្រះអតីតពុទ្ធទាំងឡាយ ដែលបរិនិព្វានហើយ ទ្រង់ផ្ដាច់ផ្ដិលនូវកិលេស ជាគ្រឿងញុំាងសត្វឲ្យមានដំណើរយឺតយូរ ទ្រង់ផ្ដាច់ផ្ដិលនូវកម្ម ជាគ្រឿងញុំាងសត្វឲ្យវិលវល់ ទ្រង់គ្របសង្កត់នូវកម្ម ជាគ្រឿងញុំាងសត្វឲ្យវិលវល់ ទ្រង់កន្លងបង់នូវទុក្ខទាំងពួងថា ព្រះមានព្រះភាគទាំងនោះ មានព្រះជាតិយ៉ាងនេះខ្លះ ... មានព្រះនាមយ៉ាងនេះខ្លះ ... មានព្រះគោត្រយ៉ាងនេះខ្លះ ... មានសីលយ៉ាងនេះខ្លះ ... មានធម៌យ៉ាងនេះខ្លះ ... មានប្រាជ្ញាយ៉ាងនេះខ្លះ ...

មានវិហារធម៌យ៉ាងនេះខ្លះ ព្រះមានព្រះភាគទាំងនោះ មានវិមុត្តិយ៉ាងនេះខ្លះ បពិត្រព្រះអង្គដ៏ចម្រើន លុះខ្ញុំព្រះអង្គទាំងឡាយ និយាយយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏និយាយនឹងខ្ញុំព្រះអង្គទាំងឡាយដូច្នេះថា ម្នាលអាវុសោ ព្រះតថាគតទាំងឡាយ មានសេចក្តីអស្ចារ្យ ទាំងប្រកបដោយធម៌ដ៏អស្ចារ្យមែន ម្នាលអាវុសោ ព្រះតថាគតទាំងឡាយ ជាបុគ្គលចម្លែក ជាបុគ្គលប្រកបដោយធម៌ដ៏ចម្លែកមែន បពិត្រព្រះអង្គដ៏ចម្រើន នេះជាអន្តរាកថា ដែលខ្ញុំព្រះអង្គទាំងឡាយ បញ្ឈប់ក្នុងវេលាដែលព្រះមានព្រះភាគ ទ្រង់ស្តេចមកដល់ ។

[ ២៧ ] លំដាប់នោះ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលនឹងព្រះអានន្ទថា ម្នាលអានន្ទ បើដូច្នោះ ធម៌ណា ដែលអស្ចារ្យ ដែលចម្លែក អ្នកចូរបំភ្លឺនូវធម៌នោះ ចំពោះតថាគត ឲ្យលើសលន់ពន់ប្រមាណ ក្នុងទីនេះចុះ ។

[ ២៨ ] ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនុ៎ះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ ពាក្យនេះ ខ្ញុំព្រះអង្គបានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពោធិសត្វកើតក្នុងពួកទេវតាជាន់តុសិត តែងមានសតិសម្បជញ្ញៈ ។ បពិត្រព្រះអង្គដ៏ចម្រើន ពោធិសត្វកើតក្នុងពួកទេវតាជាន់តុសិត តែងមានសតិសម្បជញ្ញៈ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ ( ធម៌អស្ចារ្យចម្លែក ) របស់ព្រះមានព្រះភាគ ។

[ ២៩ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទី

ចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពោធិសត្វឋិតនៅក្នុងពួកទេវតាជាន់តុសិត តែងមានសតិ-សម្បជញ្ញៈ ។ បពិត្រព្រះអង្គដ៏ចម្រើន ពោធិសត្វឋិតនៅក្នុងពួកទេវតាជាន់តុសិត តែងមានសតិសម្បជញ្ញៈ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៣០ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពោធិសត្វឋិតនៅក្នុងពួកទេវតាជាន់តុសិត ដរាបដល់អស់អាយុ ។ បពិត្រព្រះអង្គដ៏ចម្រើន ពោធិសត្វឋិតនៅក្នុងពួកទេវតាជាន់តុសិត ដរាបដល់អស់ព្រះជន្មាយុ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៣១ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពោធិសត្វ ច្យុតចាកពួកទេវតាជាន់តុសិតចុះមកកាន់ផ្ទៃនៃមាតា តែងមានសតិសម្បជញ្ញៈ ។ បពិត្រព្រះអង្គដ៏ចម្រើន ពោធិសត្វច្យុតចាកពួកទេវតាជាន់តុសិត ទ្រង់ចុះមកកាន់ផ្ទៃព្រះមាតា តែងមានសតិសម្បជញ្ញៈ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ។បេ។

[ ៣២ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលណាពោធិសត្វ ច្យុតចាកពួកទេវតាជាន់តុសិត ចុះមកកាន់ផ្ទៃនៃមាតា កាលនោះពន្លឺដ៏លើសលុបហួសប្រមាណ កើតប្រាកដក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ទាំងសមណព្រាហ្មណ៍ និងពួកសត្វ គឺទេវតា និងមនុស្សដ៏សេស ជាពន្លឺកន្លងនូវទេវានុភាព របស់ទេវតាទាំងឡាយ ទាំងចន្លោះនៃលោកណា ដែលបើកជានិច្ច មិនមានទីតម្កល់នៅខាងក្រោម មានតែងងឹត ប្រកបដោយងងឹត និងអ័ព្ទ ព្រះចន្ទ និងព្រះអាទិត្យនេះ មានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ មិនបានចាំងទៅក្នុងទីណា ពន្លឺដ៏លើសលុបហួសប្រមាណ កន្លងបង់នូវទេវានុភាព របស់ទេវតាទាំងឡាយ ក៏កើតប្រាកដក្នុងទីនោះ មួយទៀត ពួកសត្វណា ដែលកើតក្នុងទីនោះ ពួកសត្វនោះ ក៏ស្គាល់គ្នាច្បាស់ទៅវិញទៅមក ដោយពន្លឺនោះថា យីអើ ពួកសត្វដទៃមានមកកើតក្នុងទីនេះដែរតើ មួយទៀត លោកធាតុទាំងមួយម៉ឺននេះ ក៏រំភើប ញាប់ញ័រ រន្ធត់ ឯពន្លឺដ៏លើសលុបហួសប្រមាណកន្លងបង់នូវទេវានុភាព របស់ទេវតាក៏កើតប្រាកដក្នុងលោក បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៣៣ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា

ម្នាលអានន្ទ កាលណាពោធិសត្វ ចុះកាន់ផ្ទៃព្រះមាតា មានទេវបុត្រ ៤ អង្គ ចូលមករក្សាពោធិសត្វនោះ ក្នុងទិសទាំង ៤ ដោយគិតថា កុំឲ្យមនុស្ស ឬ អមនុស្ស ឬអ្នកណាមួយ បៀតបៀន ពោធិសត្វ និងមាតាពោធិសត្វបាន ឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ ព្រះមានព្រះភាគ ។

[ ៣៤ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទី ចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលណាពោធិសត្វ ចុះកាន់ផ្ទៃមាតា មាតានៃពោធិសត្វ ជាអ្នក មានសីលដោយប្រក្រតី គឺជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមា- ទដ្ឋាន ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ ព្រះមានព្រះភាគ ។

[ ៣៥ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទី ចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចុះកាន់ផ្ទៃមាតា មាតានៃពោធិសត្វ មិន កើតចំណង់ដែលប្រកបដោយកាមគុណ ក្នុងបុរសទាំងឡាយឡើយ ទាំងបុរស ណាមួយ ដែលមានចិត្តត្រេក ក៏មិនគប្បីប្រព្រឹត្តកន្លងមាតាពោធិសត្វបានទេ ។

បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៣៦ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចុះកាន់ផ្ទៃមាតា មាតានៃពោធិសត្វ ជាស្ត្រីបាននូវកាមគុណទាំង ៥ ប្រការ ឆ្អែតស្កប់ស្កល់ មូលមិត្តដោយកាមគុណទាំង ៥ ប្រការ ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៣៧ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលណាពោធិសត្វ ចុះកាន់ផ្ទៃមាតា មាតាពោធិសត្វ ឥតមានអាពាធណាមួយកើតឡើងទេ មាតាពោធិសត្វជាស្ត្រីមានសេចក្តីសុខ ឥតមានលំបាកកាយ មាតាពោធិសត្វ រមែងឃើញពោធិសត្វសព្វអវយវៈតូចធំ មានឥន្ទ្រិយមិនសៅហ្មង ហាក់ដូចជាឋិតនៅខាងក្រៅផ្ទៃ ។ ម្នាលអានន្ទ ដូចកែវមណី និងកែវពៃទូរ្យដ៏ល្អ មានពន្លឺ មានជ្រុង ៨ ដែលគេច្នៃហើយដោយល្អ ។ បុគ្គលយកសូត្រដែលមានពណ៌ខៀវក្តី លឿងក្តី ក្រហមក្តី សក្តី សូត្រដែលមានពណ៌លឿងទុំក្តី ទៅដោតក្នុងកែវនោះ ។ បុរសដែលមានចក្ខុ យកមក

ដាក់ក្នុងដៃហើយ ពិចារណាស្គាល់ច្បាស់នូវកែវនោះថា នេះជាកែវមណី ជាកែវពៃទូរ្យដ៏ល្អ មានពន្លឺ មានជ្រុង ៨ ដែលគេច្នៃដោយប្រពៃ ។ បុគ្គលយកសូត្រ ដែលមានពណ៌ខៀវក្តី លឿងក្តី ក្រហមក្តី សក្តី សូត្រដែលមានពណ៌លឿងទុំក្តី ទៅដោតក្នុងកែវនោះ យ៉ាងណា ម្នាលអានន្ទ កាលណាពោធិសត្វចុះកាន់ផ្ទៃមាតា មាតាពោធិសត្វ មិនដែលមានអាពាធណាមួយកើតឡើងទេ មាតាពោធិសត្វ ជាស្ត្រីមានសេចក្តីសុខ ឥតមានលំបាកកាយ មាតាពោធិសត្វរមែងឃើញពោធិសត្វសព្វអវយវៈតូចធំ មានឥន្ទ្រិយមិនសៅហ្មង ហាក់ដូចជាឋិតនៅខាងក្រៅផ្ទៃ ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៣៨ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលពោធិសត្វប្រសូតហើយ បាន ៧ ថ្ងៃ មាតាពោធិសត្វរមែងធ្វើមរណកាល ទៅកើតក្នុងពួកទេវតាជាន់តុសិត ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៣៩ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពួកស្ត្រីឯទៀត ពគភ៌ដោយផ្ទៃអស់ ៩ ខែខ្លះ ១០ ខែខ្លះ ទើប

ប្រសូតកូនដូចម្តេចមិញ ឯមាតាពោធិសត្វមិនប្រសូតពោធិសត្វដូច្នោះទេ មាតាពោធិសត្វ លុះតែពពោធិសត្វដោយផ្ទៃអស់ ១០ ខែគត់ ទើបប្រសូត ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៤០ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពួកស្ត្រីឯទៀត អង្គុយប្រសូតក៏មាន ដេកប្រសូតក៏មាន ឯមាតាពោធិសត្វមិនប្រសូតពោធិសត្វបែបនេះទេ មាតាពោធិសត្វតែងឈរប្រសូតពោធិសត្វតែមួយយ៉ាង បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិ-យព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៤១ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចេញចាកផ្ទៃមាតា ពួកទេវតាទទួលមុន ទើបពួកមនុស្សទទួលក្រោយ ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៤២ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទី

ចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចេញចាកផ្ទៃមាតា ពោធិសត្វមិនទាន់ដល់ផែនដីនៅឡើយ ទេវបុត្រ ៤ អង្គទទួលពោធិសត្វនោះ មកតម្កល់ទុកនៅទីចំពោះព្រះភក្ត្រមាតា ហើយពោលថា សូមព្រះនាងទេវីមានព្រះទ័យរីករាយចុះ ព្រះរាជបុត្រមានសក្តិធំរបស់ព្រះនាងកើតហើយ ។ បពិត្រព្រះអង្គដ៏ចម្រើនដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៤៣ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចេញចាកផ្ទៃព្រះមាតាក៏ចេញមកស្អាតបាត មិនប្រឡាក់ដោយទឹករំអិល មិនប្រឡាក់ដោយស្លេស្ម មិនប្រឡាក់ដោយឈាម មិនប្រឡាក់ដោយខ្ទុះ មិនប្រឡាក់ដោយវត្ថុមិនស្អាត ណាមួយឡើយ ជាឧិរសបរិសុទ្ធស្អាតវិសេស ។ ម្នាលអានន្ទ ដូចកែវមណី ដែលគេដាក់លើកាសិកពស្ត្រ កែវមណីមិនបានប្រឡាក់កាសិកពស្ត្រ ទាំងកាសិកពស្ត្រក៏មិនប្រឡាក់កែវមណីឡើយ ដំណើរនោះ ព្រោះហេតុអ្វី ព្រោះហេតុវត្ថុទាំងពីរនោះ ជារបស់ស្អាតដូចគ្នា សេចក្តីនេះ យ៉ាងណា ម្នាលអានន្ទ កាលដែលពោធិសត្វចេញចាកផ្ទៃមាតា ក៏ចេញមកស្អាតវិសេស មិនប្រឡាក់ដោយទឹករំអិលមិនប្រឡាក់ដោយស្លេស្ម ។បេ។ មិនប្រឡាក់ដោយវត្ថុមិនស្អាតណាមួយឡើយ ជាឧិរសបរិសុទ្ធស្អាតវិសេស ក៏យ៉ាងនោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន

ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៤៤ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចេញចាកផ្ទៃមាតា មានធារទឹក ២ ហូរមកអំពីអាកាស គឺធារទឹកត្រជាក់ ១ ធារទឹកក្តៅ ១ អ្នកផងក៏ធ្វើឧទកកិច្ចជម្រះពោធិសត្វ និងព្រះមាតា ដោយធារដែលហូរមកនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុកថាជាអច្ឆរិយព្ភូតធម៌របស់ព្រះមានព្រះភាគ ។

[ ៤៥ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ ពោធិសត្វប្រសូតមកភ្លាម ទ្រង់ប្រតិស្ឋានលើផែនដី ដោយព្រះបាទដ៏ស្មើ បែរព្រះភក្ត្រទៅទិសខាងជើង ទ្រង់ស្តេចដោយព្រះបាទបាន ៧ ជំហាន កាលគេកំពុងបាំងស្វេតច្ឆត្រថ្វាយ ទ្រង់ក្រឡេកមើលគ្រប់ទិសទាំងអស់ ទើបបញ្ចេញអាសភិវាចាថា អាត្មាអញ ជាកំពូលរបស់លោក អាត្មាអញ ជាបុគ្គលចម្បងជាងលោក អាត្មាអញ ជាបុគ្គលប្រសើរជាងសត្វលោក ជាតិនេះជាជាតិទីបំផុត ឥឡូវនេះ មិនមានភពថ្មីទៀតឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៤៦ ] បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះ ខ្ញុំព្រះអង្គបានស្តាប់ក្នុងទីចំពោះព្រះភក្ត្រ បានទទួលក្នុងទីចំពោះព្រះភក្ត្រ របស់ព្រះមានព្រះភាគថា ម្នាលអានន្ទ កាលដែលពោធិសត្វ ចេញចាកផ្ទៃមាតា មានពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបាន កើតប្រាកដក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព ព្រមទាំងមនុស្សដ៏សេស ជាពន្លឺកន្លងបង់នូវទេវានុភាពរបស់ទេវតាទាំងឡាយ ឱកាសណាដែលចំហទទេ មានក្នុងចន្លោះលោក ឥតមានអ្វីបាំងរាំង មានតែអ័ព្ទងងឹត មួយទៀត ព្រះចន្ទព្រះអាទិត្យទាំងនេះ សឹងមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ផ្សាយពន្លឺទៅមិនដល់ ក្នុងទីឱកាសណា ពន្លឺភ្លឺស្វាងច្បាស់ រកប្រមាណមិនបាន កន្លងបង់នូវទេវានុភាពរបស់ទេវតាទាំងឡាយ ក៏កើតប្រាកដឡើងក្នុងទីឱកាសទាំងនោះ ពួកសត្វដែលកើតក្នុងទីនោះ ក៏ស្គាល់គ្នាទៅវិញទៅមក ដោយសារពន្លឺនោះថា អើហ្ន៎ មានពួកសត្វដទៃមកកើតក្នុងទីនេះដែរតើ ។ លោកធាតុទាំង ១ ម៉ឺននេះ ក៏កក្រើករំពើកញាប់ញ័រ ឯពន្លឺភ្លឺស្វាងច្បាស់រកប្រមាណមិនបាន ក៏កើតប្រាកដឡើងក្នុងលោក ជាពន្លឺកន្លងបង់នូវទេវានុភាពរបស់ទេវតាទាំងឡាយ ។ បពិត្រព្រះអង្គដ៏ចម្រើន ដោយហេតុណា ។បេ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។

[ ៤៧ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ ព្រោះហេតុនោះ

អ្នកចូរចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះតថាគត ក្នុងសាសនានេះចុះ ។ ម្នាលអានន្ទ តថាគតមានវេទនាកើតប្រាកដ តាំងនៅប្រាកដ ដល់នូវកិរិយាអស់ទៅប្រាកដ សញ្ញា ... វិតក្ក កើតប្រាកដ តាំងនៅប្រាកដ ដល់នូវកិរិយាអស់ទៅប្រាកដ ក្នុងលោកនេះ ។ ម្នាលអានន្ទ ចូរអ្នកចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះតថាគតចុះ ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ មានវេទនាកើតប្រាកដ តាំងនៅប្រាកដ ដល់នូវកិរិយាអស់ទៅប្រាកដ ដោយហេតុណា ។ សញ្ញា ... វិតក្ក កើតប្រាកដ តាំងនៅប្រាកដ ដល់នូវកិរិយាអស់ទៅប្រាកដ ដោយហេតុណា ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុនេះឯង ដែលខ្ញុំព្រះអង្គចំណាំទុក ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះមានព្រះភាគ ។ ព្រះអានន្ទមានអាយុ បានពោលពាក្យនេះ ។ ព្រះសាស្តាទ្រង់ពេញព្រះហឫទ័យ ។ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយ នឹងភាសិតរបស់ព្រះអានន្ទមានអាយុ ។

**អច្ឆរិយព្ភូតធម្មសូត្រទី ៣ ចប់**

# អដ្ឋកថា

## អច្ឆរិយព្ភូតធម្មសូត្រ

[ ២៥ ] អច្ឆរិយព្ភូតធម្មសូត្រ មានបទផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **យត្រ ហិ នាម** ជានិបាត ចុះក្នុងអត្ថថា អស្ចារ្យ អធិប្បាយថា ព្រះតថាគតអង្គណា ។ ឈ្មោះថា **បបញ្ចោ** ក្នុងបទថា **ឆិន្នបបញ្ចេ** នេះ បានដល់ កិលេស ៣ យ៉ាង គឺតណ្ហា មានះ និងទិដ្ឋិ ។ កម្មវដ្ដៈ ជាកុសល និងអកុសល លោកហៅថា **វដ្ដុម** ក្នុងបទថា **ឆិន្នវដ្ដុមេ** នេះ ។ បទថា **បរិយាទិន្នវដ្ដេ** ជាវេវចនៈនៃបទថា **ឆិន្នវដ្ដុមេ** នោះឯង ។ បទថា **សព្វទុក្ខវីតិវត្តេ** សេចក្ដីថា កន្លងនូវទុក្ខ ពោល គឺវិបាកវដ្ដទាំងពួង ។ បទថា **អនុស្សរិស្សតិ** នេះ ជាពាក្យពោលដល់អនាគតកាល ដោយប្រើនិបាតថា **យត្រ** តែក្នុងបទនេះ គប្បីជ្រាបថា លោកប្រើសំដៅដល់អតីត ពិតហើយ ព្រះមានព្រះភាគ ទ្រង់រឭកដល់ព្រះពុទ្ធទាំងនោះហើយ មិនមែនរឭកដល់ក្នុងឥឡូវនេះទេ ។ បទថា **ឯវំ ជច្ចា** សេចក្ដីថា ព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សីជាដើម មានព្រះជាតិជាក្សត្រ ព្រះពុទ្ធទាំងឡាយ មានព្រះកកុសន្ធៈជាដើម មានជាតិជាព្រាហ្មណ៍ ។ បទថា **ឯវំគោត្តា** សេចក្ដីថា ព្រះពុទ្ធទាំងឡាយ មានព្រះវិបស្សីជាដើម ជាកោណ្ឌញ្ញគោត្រ ព្រះពុទ្ធទាំងឡាយ មានព្រះកកុសន្ធៈជាដើម ជាកស្សបគោត្រ ។ បទថា **ឯវំសីលា** សេចក្ដីថា មានសីលយ៉ាងនេះ គឺមានសីល ទាំងជាលោកិយ និងលោកុត្តរ ។ ក្នុងបទថា **ឯវំធម្មា** នេះ លោកសំដៅយកធម៌ដែលប្រព្រឹត្តទៅ ក្នុងចំណែកនៃសមាធិ

*អធិប្បាយថា មានសមាធិយ៉ាងនេះ គឺលោកិយសមាធិផង លោកុត្តរសមាធិផង ។ បទថា* **ឯវំបញ្ញា** *សេចក្តីថា មានបញ្ញាយ៉ាងនេះ គឺលោកិយប្បញ្ញាផង លោកុត្តរប្បញ្ញាផង ។ ក្នុងបទថា* **ឯវំវិហារី** *នេះ ក៏ព្រោះកាន់យកធម៌ដែលប្រព្រឹត្តទៅក្នុងចំណែកសមាធិខាងដើមហើយ ឈ្មោះថា វិហារធម៌ផង បើមានអ្នកចោទសួរថា ហេតុអ្វី ទើបលោកកាន់យកវត្ថុដែលកាន់យកហើយទៀត ។ ឆ្លើយថា សេចក្តីនេះ លោកមិនកាន់យកយ៉ាងនោះឡើយ ដោយពិត ការដែលលោកកាន់វត្ថុដែលកាន់ហើយទៀតនេះ ដើម្បីសម្តែងដល់និរោធសមាបត្តិ ព្រោះដូច្នោះ ក្នុងពាក្យនេះ បានសេចក្តីយ៉ាងនេះថា មានប្រក្រតីនៅដោយនិរោធសមាបត្តិយ៉ាងនេះ ។*

*ក្នុងបទថា* **ឯវំវិមុត្តា** *នេះ បានដល់ វិមុត្តិ ៥ យ៉ាង គឺវិក្ខម្ភនវិមុត្តិ ១ តទង្គវិមុត្តិ ១ សមុច្ឆេទវិមុត្តិ ១ បដិបស្សទ្ធិវិមុត្តិ ១ និស្សរណវិមុត្តិ ១ ក្នុងវិមុត្តិទាំង ៥ នោះ សមាបត្តិ រាប់ជាវិក្ខម្ភនវិមុត្តិ ព្រោះផុតហើយចាកកិលេស មាននីវរណៈជាដើម ដែលខ្លួនសង្កត់ទុកហើយ ។ អនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម រាប់ជាតទង្គវិមុត្តិ ព្រោះរលាស់ផុតហើយចាកនិច្ចសញ្ញាជាដើមដែលខ្លួនលះបង់ហើយ ដោយអំណាចនៃអង្គដែលជាសត្រូវនៃមគ្គនោះៗ ។ អរិយមគ្គ ៤ រាប់ជាសមុច្ឆេទវិមុត្តិ ព្រោះរួចផុតចាកកិលេសទាំងឡាយដែលខ្លួនដកឡើងហើយឯង ។ សាមញ្ញផល ៤ រាប់ជាបដិបស្សទ្ធិវិមុត្តិ ព្រោះកិលេសទាំងឡាយកើតឡើងហើយ ក្នុងទីបំផុតនៃបដិបស្សទ្ធិដោយអានុភាពនៃមគ្គ ។ និព្វានជានិស្សរណវិមុត្តិ ព្រោះជាទីរលាស់ចេញ*

កម្ចាត់ចេញ តាំងនៅក្នុងទីឆ្ងាយអំពីកិលេសទាំងពួង ។ ក្នុងសេចក្ដីនេះ គប្បី ជ្រាបសេចក្ដីយ៉ាងនេះថា រួចផុតហើយយ៉ាងនេះ ដោយអំណាចនៃវិមុត្តិទាំង ៥ នេះ ដោយប្រការដូច្នេះ ។ បទថា **តស្មាតិហ** សេចក្ដីថា ព្រោះហេតុ ដែលលោកពោលថា ព្រះតថាគតទាំងឡាយគួរអស្ចារ្យ ដូច្នោះ ទើបអច្ឆរិ-យព្ភូតធម៌ទាំងឡាយនៃព្រះតថាគត ជាក់ច្បាស់ក្រៃលែងជាងប្រមាណ ។

[ ២៨-២៩ ] ក្នុងបទថា **សតោ សម្បជានោ** នេះ បានដល់ សម្បជញ្ញៈ ២ យ៉ាង គឺទាំងក្នុងមនុស្សលោក និងទេវលោក ។ ក្នុងសម្ប-ជញ្ញៈ ២ នោះ ក្នុងវេស្សន្តរជាតក ព្រះវេស្សន្តរ ឲ្យព្រះឱរសទាំង ២ ដល់ ព្រាហ្មណ៍ហើយ ក្នុងថ្ងៃស្អែកឡើង ឲ្យព្រះមហេសីដល់សក្កទេវរាជ កាល កាន់យកពរ ៨ យ៉ាង ដែលសក្កៈទ្រង់ជ្រះថ្លាប្រទានហើយ បានជ្រើសរើស យកពរថា ខ្ញុំសូមបដិសន្ធិក្នុងស្ថានតុសិតយ៉ាងនេះថា

កាលបើខ្ញុំច្យុតចាកអត្តភាពនេះ សូមឲ្យបានទៅកាន់ឋានសួគ៌ ដល់នូវ ឋានៈដ៏វិសេស គឺកើតក្នុងតុសិតបុរី ( កាលបើខ្ញុំច្យុតចាកតុសិតភពនោះមក ) សូមកុំឲ្យកើត ( ក្នុងភពថ្មីទៀត ) ខ្ញុំសូមពរទី ៨ នេះ ។

ចាប់ផ្ដើមអំពីនោះមក ក៏ដឹងថា អញនឹងកើតក្នុងតុសិតពិភព ។ នេះ ចាត់ជាសម្បជញ្ញៈក្នុងមនុស្សលោក ។ កាលព្រះអង្គចុតិចាកអត្តភាពជាព្រះ វេស្សន្តរហើយ កើតក្នុងតុសិត បានដឹងខ្លួនថា អញកើតហើយ ដូច្នេះ ជា សម្បជញ្ញៈក្នុងទេវលោក ។

សួរថា ទេវតាដ៏សេសទាំងឡាយមិនដឹងឬ ។ ឆ្លើយថា មិនមែនមិនដឹង

ទេ តែទេវតាទាំងនោះត្រូវមើលដើមកល្បព្រឹក្សក្បែរវិមានក្នុងឧទ្យាន ដែលពួកទេពអប្សរអ្នកបាំជាស់តៀនដោយសំឡេងទិព្វតូរ្យតន្ត្រី ឲ្យឮកថា លោកនិទុក្ខ នេះជាទេវលោក លោកកើតក្នុងទេវលោកនេះហើយ ដូច្នេះ ទើបដឹង ។ ព្រះពោធិសត្វមិនដឹងក្នុងបឋមជវនវារៈ រាប់អំពីទុតិយវារៈទៅ ទើបដឹង ។ ការដឹងរបស់ព្រះពោធិសត្វ មិនសាធារណៈទូទៅដល់អ្នកដទៃ ដូចពណ៌នាមក ដូច្នេះ ។ ក្នុងបទថា **អដ្ឋាសិ** នេះ សេចក្តីថា សូម្បីទេវតាដទៃ ទោះបីតាំងនៅក្នុងភពនោះ ក៏រមែងដឹងខ្លួនថា ពួកយើងតាំងនៅហើយក៏ពិត តែទេវតាទាំងនោះត្រូវឥដ្ឋារម្មណ៍ដែលមានកម្លាំងក្នុងទ្វារទាំង ៦ គ្របសង្កត់ មិនមានស្មារតី មិនដឹងសូម្បីវត្ថុដែលខ្លួនបរិភោគហើយ ផឹកហើយ រមែងចុតិ ព្រោះដាច់អាហារ ។

សួរថា ព្រះពោធិសត្វមិនមានអារម្មណ៍យ៉ាងនោះឬ ឆ្លើយថា មិនមែនមិនមានឡើយ ព្រោះថា ព្រះអង្គរមែងនៅដូចទេវតាដ៏សេសទៀតដែរ ដោយឋានៈ ១០ ។ ព្រះអង្គមិនព្រមឲ្យអារម្មណ៍ញាំញីព្រះអង្គ សង្កត់អារម្មណ៍នោះតាំងនៅបាន ។ ព្រោះហេតុនោះ ទើបត្រាស់ថា **សតោ សម្បជានោ អានន្ទ ពោធិសត្តោ តុសិតេ កាយេ អដ្ឋាសិ ។**

[ ៣០-៣១ ] បទថា **យាវតាយុកំ** នេះ សួរថា ក្នុងអត្តភាពដ៏សេសព្រះពោធិសត្វ មិនតាំងនៅរហូតអស់អាយុឬ ឆ្លើយថា ពិតហើយ មិនតាំងនៅរហូតអស់អាយុទេ ។ ក្នុងកាលដទៃៗ ព្រះពោធិសត្វកើតក្នុងទេវលោកដែលទេវតាមានអាយុវែង មិនអាចបំពេញបារមីក្នុងទេវលោកនោះបាន ដូច្នោះ

ព្រះអង្គបើកភ្នែកទាំង ២ ធ្វើអធិមុត្តកាលកិរិយា ( អត់ដង្ហើមឲ្យស្លាប់ ) ហើយកើតក្នុងមនុស្សលោក កាលកិរិយាយ៉ាងនេះ មិនមានដល់ទេវតាដទៃ ។ ក្នុងកាលនោះ មិនមានការលួចទ្រព្យ មិនមានអ្នកមិនរក្សាសីល ព្រះអង្គតាំងនៅរហូតអស់អាយុ ព្រោះទ្រង់បំពេញបារមីគ្រប់យ៉ាងបរិបូណ៌ហើយ ព្រះអង្គមានសតិសម្បជញ្ញៈ ឃ្លាតចាកពួកទេវតាជាន់តុសិត ស្ថិតនៅក្នុងគភ៌ព្រះមាតា ។ ព្រះពោធិសត្វ ទ្រង់បំពេញបារមីគ្រប់សព្វយ៉ាងនេះហើយ បានតាំងនៅរហូតអស់ព្រះជន្មជីព ក្នុងកាលនោះ ដោយប្រការដូចពណ៌នាមកដូច្នេះ ។

បុព្វនិមិត្ត ៥ យ៉ាង គឺផ្កាស្វិតស្រពោន ១ សំពត់សៅហ្មង ១ ញើសហូរចេញអំពីក្លៀក ១ កាយសៅហ្មង ១ ទេវតាមិនតាំងនៅលើអាសនៈនៃទេវតា ១ នេះរមែងកើតដល់ទេវតាទាំងឡាយ ដើម្បីជាសញ្ញាឲ្យដឹងថា ឥឡូវនេះ នៅសល់ត្រឹមតែ ៧ ថ្ងៃ នឹងត្រូវចុតិ ដោយការរាប់ថ្ងៃមនុស្ស ។ បណ្តាបទទាំងនោះ បទថា **មាលា** បានដល់ ផ្កាសម្រាប់ប្រដាប់ ដោយរាប់ថ្ងៃ ចាប់ពីបដិសន្ធិជាកំណត់ ។ បានឮថា ផ្កាទាំងនោះមិនស្វិតស្រពោនអស់កាល ៥៧ កោដិ និង ៦ លានឆ្នាំ តែស្វិតស្រពោនក្នុងកាលនោះ ។ សំពត់ទាំងឡាយក៏ន័យនេះដូចគ្នា ។ ទេវតាទាំងឡាយ មិនស្គាល់រងា មិនស្គាល់ក្តៅអស់កាលមានប្រមាណប៉ុណ្ណេះ ។ តែក្នុងកាលនោះ ញើសនឹងហូរចេញអំពីរាងកាយជាតំណក់ៗ ។ អស់កាលមានប្រមាណប៉ុណ្ណេះ រាងកាយរបស់ទេវតាទាំងនោះ មិនធ្លាប់ប្រាកដជាសៅហ្មង ដូចជាធ្មេញបាក់ ឬសក់

ស្អុវឡើយ ទេពធីតាប្រាកដរាងកាយ ដូចស្រីវ័យ ១៦ ទេវបុត្រប្រាកដរាងកាយ ដូចកំលោះវ័យ ២០ ។ ក្នុងពេលជិតនឹងស្លាប់ ទេវបុត្រទាំងនោះ រមែងមានអត្តភាពសៅហ្មង ម្យ៉ាងទៀត ទេវបុត្រទាំងនោះ មិនមានការអផ្សុកក្នុងទេវលោកអស់កាលប្រមាណប៉ុណ្ណេះ តែក្នុងវេលាជិតស្លាប់ ទេវបុត្ររមែងនឿយណាយ តក់ស្លុត ញាប់ញ័រ មិនត្រេកអរក្នុងអាសនៈរបស់ខ្លួន នេះចាត់ជាបុព្វនិមិត្ត ៥ ប្រការ ។

និមិត្តទាំងឡាយ មានឧកាបាតធ្លាក់ចុះ ផែនដីកម្រើក និងចន្ទ្រគ្រាស ជាដើមប្រាកដចំពោះបុគ្គលដែលមានសក្តិធំក្នុងលោក ដូចជាព្រះរាជា មហាមាត្យជាដើមប៉ុណ្ណោះ មិនប្រាកដដល់សាមញ្ញជនទូទៅ យ៉ាងណា បុព្វនិមិត្តក៏ដូច្នោះ នឹងប្រាកដចំពោះពួកទេវតាសក្តិធំប៉ុណ្ណោះ មិនប្រាកដដល់ទេវតាទូទៅ ។ ក្នុងពួកមនុស្សទាំងឡាយ ហោរាជាដើមប៉ុណ្ណោះ ទើបដឹងបុព្វនិមិត្តទាំងឡាយ ជនទូទៅមិនដឹង យ៉ាងណា ពួកទេវតាទាំងឡាយក៏ដូច្នោះ ទេវតាទូទៅទាំងនោះ រមែងមិនដឹង នឹងដឹងក៏ចំពោះតែទេវតាដែលឈ្លាសប៉ុណ្ណោះ ។ ក្នុងបណ្តាទេវតាទាំងនោះ ទេវបុត្រដែលកើតដោយកុសលកម្មតិច កាលបុព្វនិមិត្តកើតហើយ ប្រាថ្នានឹងដឹងថា ឥឡូវនេះ ពួកអញទៅកើតក្នុងទីណា ទើបភ័យខ្លាច ឯទេវបុត្រដែលមានបុណ្យច្រើន គិតថា ពួកយើងអាស្រ័យទានដែលឲ្យ សីលដែលរក្សា ភាវនាដែលចម្រើនហើយ នឹងសោយសម្បត្តិក្នុងទេវលោកខ្ពស់ឡើងៗ ទៅ ទើបមិនខ្លាច ឯព្រះពោធិសត្វឃើញបុព្វនិមិត្តទាំងនោះហើយ គិតថា ឥឡូវនេះ អញនឹងបានជាព្រះពុទ្ធក្នុងអត្តភាពតទៅ

ទើបមិនខ្វាច ។ គ្រានោះ កាលនិមិត្តទាំងនោះប្រាកដដល់ព្រះពោធិសត្វហើយ ទេវតាក្នុងម៉ឺនចក្រវាលមកប្រជុំគ្នា ហើយទូលអារាធនាថា បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ កាលដែលព្រះអង្គទ្រង់បំពេញទសបារមី បំណាងនូវសម្បត្តិថា នឹងកើតជាសក្កទេវរាជក៏ទេ បំណាងសម្បត្តិថា នឹងកើតជាមារ ជាព្រហ្ម ជាស្តេចចក្រពត្តិក៏ទេ តែទ្រង់បំពេញដោយប្រាថ្នាជាព្រះពុទ្ធ ដើម្បីស្រោចស្រង់សត្វលោក បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ឥឡូវនេះ ជាកាលដ៏សមគួរ ដើម្បីការត្រាស់ដឹងនៃព្រះអង្គ បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ឥឡូវនេះ ជាសម័យដ៏សមគួរ ដើម្បីការត្រាស់ដឹងនៃព្រះអង្គ ។

លំដាប់នោះ ព្រះមហាសត្វ ទ្រង់មិនទាន់ឲ្យពាក្យប្តេជ្ញាដល់ទេវតាទាំង-ឡាយ ទ្រង់ប្រមើលមើល មហាវិលោកនៈទាំង ៥ ប្រការ គឺកាល ទ្វីប ប្រទេស ត្រកូល និងការកំណត់អាយុរបស់មាតា ។ មហាវិលោកនៈ ៥ ប្រការនោះ ទ្រង់ពិចារណាមើលកាលមុនថា ជាវេលាសមគួរ ឬមិនសមគួរ ។ កាលមនុស្សទាំងឡាយមានអាយុវែងជាងមួយសែនឆ្នាំទៅ ឈ្មោះថា កាលដែលមិនសមគួរ ក្នុងមហាវិលោកនៈ ៥ ប្រការនោះ ។

ព្រោះហេតុអ្វី ព្រោះក្នុងវេលានោះ ជាតិ ជរា និងមរណៈ រមែងមិនប្រាកដដល់សត្វទាំងឡាយ ដែលឈ្មោះថា ការសម្តែងធម៌នៃព្រះពុទ្ធទាំង-ឡាយ នឹងផុតទៅអំពីត្រៃលក្ខណ៍ រមែងមិនមាន កាលព្រះអង្គត្រាស់ថា អនិច្ចំ ទុក្ខំ អនត្តា មនុស្សទាំងឡាយគិតថា នេះព្រះអង្គត្រាស់ដល់អ្វី ហើយមិនដាក់ចិត្តស្តាប់ មិនព្រមរាប់អាន ឬស្តាប់ បន្ទាប់អំពីនោះ រមែងមិនមាន

ការត្រាស់ដឹងមគ្គផល កាលមិនមានការត្រាស់ដឹងមគ្គផល ឱវាទរមែងមិនចាត់ជានិយ្យានិកធម៌បានឡើយ ព្រោះដូច្នោះ ទើបវេលានោះ ចាត់ជាវេលាមិនសមគួរ ។ វេលាដែលមនុស្សទាំងឡាយ មានអាយុតិចជាង ១០០ ឆ្នាំ ក៏មិនចាត់ថាជាកាលសមគួរ ព្រោះហេតុអ្វី ព្រោះកាលនោះ មនុស្សទាំង-ឡាយក្រាស់ដោយកិលេស ពាក្យប្រៀនប្រដៅដែលឲ្យដល់មនុស្សដែលមានកិលេសក្រាស់ រមែងមិនតាំងនៅក្នុងឋានៈនៃឱវាទ រមែងសាបសូន្យទៅដោយឆាប់រហ័ស ដូចយកកំណាត់ឈើ គូសក្នុងទឹក ព្រោះដូច្នោះ សូម្បីកាលនោះ ក៏មិនចាត់ជាកាលគួរ តែកំណត់អាយុ រាប់អំពីមួយសែនចុះមក ១០០ ឆ្នាំ ឡើងទៅចាត់ជាកាលសមគួរ ។ ក្នុងគ្រានោះ ជាវេលាដែលសត្វមានអាយុប្រមាណ ១០០ ឆ្នាំ ។ លំដាប់នោះ ព្រះមហាសត្វទ្រង់ពិចារណាឃើញហើយថា ជាកាលសមគួរ ដែលគប្បីមកកើត ។

បន្ទាប់អំពីនោះ កាលទ្រង់ប្រមើលមើលទ្វីប ទ្រង់បានពិចារណាមើលទ្វីបទាំង ៤ និងទ្វីបដែលជាបរិវារ ទ្រង់ឃើញថា ព្រះពុទ្ធទាំងឡាយ មិនមកកើតក្នុងទ្វីបទាំង ៣ កើតក្នុងជម្ពូទ្វីបប៉ុណ្ណោះ បន្ទាប់អំពីនោះ ទ្រង់ប្រមើលមើលប្រទេសថា ដែលឈ្មោះថា ជម្ពូទ្វីប ចាត់ជាទ្វីបធំ មានប្រមាណដល់ទៅមួយម៉ឺនយោជន៍ ព្រះពុទ្ធទាំងឡាយ រមែងមកកើតក្នុងប្រទេសណាហ្ន៎ ទ្រង់ពិចារណាឃើញមជ្ឈិមប្រទេសហើយ ។ ឈ្មោះថា មជ្ឈិមប្រទេស បានដល់ប្រទេសដែលលោកពោលហើយក្នុងព្រះវិន័យ ដោយន័យជាដើមថា មាននិគម ឈ្មោះកជង្គលៈនៅក្នុងទិសបូព៌ ដូច្នេះ មជ្ឈិមប្រទេសនោះ មានកំណត់

បណ្តាយ ៣០០ យោជន៍ ទទឹង ២៥០ យោជន៍ វាស់ដោយជុំវិញ ៩០០ យោជន៍ សម្តេចព្រះសម្មាសម្ពុទ្ធទាំងឡាយ ទ្រង់បំពេញបារមី ៤ អសង្ខេយ្យ និងមួយសែនកប្បខ្លះ ៨ អសង្ខេយ មួយសែនកប្បខ្លះ ១៦ អសង្ខេយ្យ មួយសែនកប្បខ្លះ ហើយស្តេចកើតក្នុងប្រទេសនេះ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ទ្រង់បំពេញបារមី ២ អសង្ខេយ្យ មួយសែនកប្ប ហើយមកកើត ។ មហាសាវកទាំងឡាយ មានព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានជាដើម បំពេញបារមីមួយអសង្ខេយ្យ និងមួយសែនកប្ប ហើយមកកើត ។ ស្តេចចក្រពត្តិទ្រង់អភិសេកលើទ្វីបធំទាំង ៤ មានទ្វីបតូច ២០០០ ជាបរិវារ ស្តេចរមែងមកកើត ។ ខត្តិយមហាសាលក្តី ព្រាហ្មណមហាសាលក្តី គហបតីមហាសាលក្តី អ្នកមានសក្តិធំដទៃក្តី ក៏មកកើតក្នុងប្រទេសនេះ ហើយក្នុងបទេសនេះ មាននគរឈ្មោះថា **កបិលពស្តុ** ជារាជធានី ទើបព្រះអង្គដាក់ព្រះហឫទ័យថា អញគួរកើត ក្នុងនគរកបិលពស្តុនោះ ។

បន្ទាប់អំពីនោះ ទ្រង់ប្រមើលមើលត្រកូល ពិចារណាមើលត្រកូលថា ធម្មតាព្រះពុទ្ធទាំងឡាយ រមែងកើតក្នុងត្រកូលដែលលោកសន្មត ឥឡូវនេះត្រកូលក្សត្រ ជាត្រកូលលោកសន្មត អញនឹងកើតក្នុងត្រកូលក្សត្រនោះ ព្រះរាជាឈ្មោះសុទ្ធោទនៈ នឹងជាបិតារបស់អញ ។ បន្ទាប់អំពីនោះ ទ្រង់ប្រមើលមើលមាតា ទ្រង់ពិចារណាថា ឈ្មោះថា ព្រះពុទ្ធមាតា រមែងមិនជាស្រីឡេះឡោះ មិនជាអ្នកលេងសុរា បំពេញបារមីមកអស់មួយសែនកប្ប រាប់តាំងអំពីកើត មានសីល ៥ មិនដាច់ ឯព្រះទេវីឈ្មោះថាមហាមាយាអង្គនេះ

មានលក្ខណៈដូច្នេះ ព្រះនាងនឹងជាមាតារបស់អញ តែព្រះនាងនឹងមានអាយុប៉ុនណា ហើយទ្រង់ឃើញថា អាយុរបស់ព្រះនាង ក្រោយអំពីទ្រទ្រង់ព្រះគភ៌ ១០ ខែ ប្រសូតហើយ នឹងមាន ៧ ថ្ងៃ ។

ព្រះមហាសត្វ កាលទ្រង់ពិនិត្យមើលមហាវិលោកនៈ ៥ ប្រការនេះ ដូចពោលមកនេះហើយ ត្រាស់ថា នែអ្នកនិទ៌ុក្ខទាំងឡាយ ដល់ពេលដែលខ្ញុំជាព្រះពុទ្ធហើយ កាលធ្វើនូវការសង្គ្រោះ ទើបឲ្យពាក្យប្ដេជ្ញាដល់ទេវតាទាំងឡាយ បញ្ជូនទេវតាទាំងនោះទៅដោយពាក្យថា ចូរត្រឡប់ទៅចុះ លោកទាំងឡាយ ហើយហែហមដោយទេវតាជាន់តុសិត ចូលទៅកាន់នន្ទវ័នក្នុងតុសិត-បុរី ។ ក្នុងទេវលោកគ្រប់ជាន់ក៏មានសួននន្ទនវ័នទាំងអស់ ។ សូម្បីក្នុងសួននន្ទនវ័ននោះ ទេវតាទាំងឡាយឲ្យព្រះពោធិសត្វរឭកដល់ឱកាសនៃកុសលកម្មដែលធ្លាប់ធ្វើក្នុងជាតិមុនថា សូមព្រះអង្គចុតិចាកតុសិតបុរី ទៅកាន់សុគតិ សូមចុតិចាកតុសិតបុរី ទៅកាន់សុគតិ ដូច្នេះ ក៏ត្រាច់ទៅ ។ ព្រះពោធិសត្វហែហមទៅដោយទេវតា ដែលជួយរម្លឹកដល់កុសលកម្មយ៉ាងនេះ ទ្រង់យាងទៅក្នុងនន្ទវ័ន ចុតិហើយ ក៏ដឹងថា អញកំពុងចុតិ មិនមែនដឹងចុតិចិត្ត សូម្បីបដិសន្ធិហើយ ក៏មិនដឹងបដិសន្ធិចិត្ត ។ ព្រះអង្គដឹងច្បាស់យ៉ាងនេះថា អញបដិសន្ធិក្នុងទីនេះ ព្រះថេរៈពួកខ្លះពោលថា គួរនឹងបានអាវជ្ជនបរិយាយ ព្រះមហាសត្វដឹងក្នុងទុតិយចិត្តវារៈ និងតតិយចិត្តវារៈប៉ុណ្ណោះ ។ តែព្រះមហាសិវត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា បដិសន្ធិនៃព្រះមហាសត្វទាំងឡាយមិនដូចបដិសន្ធិនៃសត្វដទៃ សតិសម្បជញ្ញៈរបស់ព្រះមហាសត្វនោះ ដល់ទី

បំផុតហើយ ក៏ព្រោះមិនអាចដឹងចិត្តដួងនោះដោយចិត្តដួងនោះបាន ដូច្នោះ ទើបព្រះមហាសត្វមិនដឹងចុតិចិត្ត សូម្បីក្នុងចុតិក្ខណៈ ក៏ដឹងថា អញកំពុងចុតិ បដិសន្ធិក៏មិនដឹងបដិសន្ធិចិត្ត ដឹងច្បាស់ថា អញបដិសន្ធិក្នុងទីនោះ ក្នុងកាលនោះ មុ៉ីនលោកធាតុរមែងញាប់ញ័រ ដូច្នេះ ។ កាលព្រះមហាសត្វឈានចុះកាន់គភ៌មាតាយ៉ាងនេះ ទ្រង់បដិសន្ធិដោយមហាវិបាកចិត្ត ដូចគ្នានឹងអសង្ខារិកកុសលចិត្ត សហគតៈដោយសោមនស្ស និងសម្បយុត្តដោយបញ្ញា មានមេត្តាជាបុព្វភាគ ក្នុងបណ្តាបដិសន្ធិចិត្ត ១៩ ដួង ។ ឯព្រះមហាសិវត្ថេរពោលថា ដោយមហាវិបាកចិត្តដែលសហគតៈដោយឧបេក្ខា ។ ព្រះមហាសត្វ ទ្រង់បដិសន្ធិក្នុងថ្ងៃពេញបូណ៌មី ខែទុតិយាសាឍ ។

បានឮមកថា គ្រានោះ ព្រះនាងមហាមាយា ក្រសាលដោយការលេងនក្ខត្តឫក្សដ៏សម្បូរទៅដោយគ្រឿងផឹក ដែលប្រាសចាកសុរា កម្រងគ្រឿងក្រអូប និងគ្រឿងប្រដាប់ តាំងអំពីថ្ងៃទី ៧ បន្ទាប់អំពីថ្ងៃពេញបូណ៌មី ខែបឋមាសាឍ ក្នុងថ្ងៃទី ៧ ព្រះនាងតើនអំពីព្រលឹម ស្រពស្រង់ដោយទឹកក្រអូប ប្រដាប់ព្រះវរកាយ ដោយគ្រឿងអលង្ការទាំងពួង សោយព្រះក្រយាហារដ៏ប្រសើរ អធិដ្ឋានអដ្ឋឧបោសថ ហើយយាងចូលបន្ទប់ដ៏មានសិរីផ្ទំលើគ្រែដ៏មានសិរី ព្រះនាងផ្ទំលក់ទៅ បានសុបិនដូច្នេះថា ស្តេចមហារាជទាំង ៤ ទ្រង់លើកព្រះនាងទាំងព្រះក្រឡាបន្ទំ នាំទៅកាន់អនោតត្តស្រះ ហើយដាក់ក្នុងទីមួយ ។ គ្រានោះ ព្រះទេវីរបស់ស្តេចមហារាជទាំង ៤ នោះ បានមកឲ្យព្រះនាងស្រង់ ដើម្បីជម្រះមន្ទិលរបស់មនុស្ស ហើយឲ្យស្លៀកសំពត់

ទិព្វ លាបដោយគ្រឿងក្រអូប ប្រដាប់ដោយសំពត់ទិព្វ ឲ្យព្រះនាងផ្ទំរក្សាសីល នៅក្នុងវិមានមាស ដែលមាននៅក្នុងភ្នំប្រាក់ តាំងនៅមិនឆ្ងាយអំពីអនោតត្តស្រះនោះ ។ គ្រានោះ ព្រះពោធិសត្វជាដំរីសត្រាច់ទៅលើភ្នំមាសមួយ តាំងនៅមិនឆ្ងាយអំពីអនោតត្តស្រះនោះ ចុះអំពីភ្នំមាសនោះហើយ ឡើងកាន់ភ្នំប្រាក់ មកអំពីទិសឧត្តរ ចូលទៅកាន់វិមានមាស ធ្វើប្រទក្សិណព្រះមាតាហើយ ហាក់បីដូចជាញែកឆ្អឹងជំនីរស្តាំ ចូលទៅកាន់ព្រះគភ៌ ។

លំដាប់នោះ ព្រះនាងតើនហើយ បានក្រាបទូលព្រះសុបិននោះដល់ព្រះរាជា ។ កាលអរុណរះច្បាស់ ព្រះរាជាបញ្ជាឲ្យប្រធានព្រាហ្មណ៍ប្រមាណ ៦៤ នាក់ចូលគាល់ ក្រាលអាសនៈមានតម្លៃច្រើនលើភូមិភាគដែលមានតិណជាតិខៀវខ្ចី តាក់តែងហើយដោយគ្រឿងសក្ការៈដែលជាមង្គល ដែលធ្វើដោយលាជជាដើម ហើយនាំមធុបាយាសដ៏ប្រសើរ ចម្អិនដោយសប្បិ ទឹកឃ្មុំ និងទឹកអំពៅ ដាក់ភាជនៈមាស ថ្នាំងប្រាក់ ពេញហើយ បិទដោយភាជនៈមាស ភាជនៈប្រាក់ដូចគ្នា ព្រះរាជទានដល់ព្រាហ្មណ៍ទាំងឡាយ ដែលអង្គុយលើអាសនៈនោះ ។ ញុំាងព្រាហ្មណ៍ទាំងនោះឲ្យឆ្អែតស្កប់ស្កល់ដោយសំពត់ និងមេគោពពាលដែលមនុស្សដទៃនាំមកឲ្យទៀតផង ។ លំដាប់នោះ ព្រះរាជាទ្រង់ប្រាប់ឲ្យព្រាហ្មណ៍ទាំងឡាយ ដែលឆ្អែតស្កប់ស្កល់ហើយ ជ្រាបដល់ព្រះសុបិន ហើយទ្រង់សួរថា នឹងមានអ្វីកើតឡើង ។ ព្រាហ្មណ៍ទាំងឡាយក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គទ្រង់កុំព្រះវិតក្កឡើយ ព្រះទេវីរបស់ព្រះអង្គ ទ្រង់តាំងព្រះគភ៌ ហើយព្រះគភ៌នោះ ជាព្រះឱរស មិនមែនព្រះធីតា

ឡើយ ព្រះអង្គនឹងមានព្រះឱរស បើឱរសនោះ នៅគ្រប់គ្រងផ្ទះ នឹងបានជាស្ដេចចក្រពត្តិ បើចេញបួស នឹងបានជាព្រះពុទ្ធ ។ ដែលដកកិលេសបានហើយក្នុងលោក ។ ព្រះពោធិសត្វមានសតិ និងសម្បជញ្ញៈ ចុតិចាកពួកទេវតាជាន់តុសិត ចូលកាន់ព្រះគភ៌ព្រះមាតា ដោយប្រការដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **សតោ សម្បជានោ** នេះ លោកសំដែងថា ព្រះពោធិសត្វទ្រង់ឈានចុះ ដោយវិធីឈានចុះកាន់ព្រះគភ៌បែបទី ៤ ។ ឯការឈានចុះកាន់ព្រះគភ៌មាន ៤ យ៉ាង ដូចព្រះបាលីក្នុងសម្បសាទនីយសូត្រថា បពិត្រព្រះអង្គដ៏ចម្រើន ដំណើរចុះកាន់គភ៌ទាំងឡាយនេះមាន ៤ យ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតា ក៏មិនដឹងខ្លួន ឋិតនៅក្នុងផ្ទៃមាតា ក៏មិនដឹងខ្លួន ប្រសូតចេញចាកផ្ទៃមាតា ក៏មិនដឹងខ្លួន នេះជាដំណើរចុះកាន់គភ៌ទី ១ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតា ក៏ដឹងខ្លួន តែឋិតនៅក្នុងផ្ទៃមាតា ក៏លែងដឹងខ្លួន ប្រសូតចេញចាកផ្ទៃមាតា ក៏លែងដឹងខ្លួន នេះជាដំណើរចុះកាន់គភ៌ទី ២ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតាក៏ដឹងខ្លួន ឋិតនៅក្នុងផ្ទៃមាតា ក៏ដឹងខ្លួន លុះប្រសូតចេញចាកផ្ទៃមាតា ក៏លែងដឹងខ្លួនទៅវិញ នេះជាដំណើរចុះកាន់គភ៌ទី ៣ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យខាងមុខនៅមានទៀត សត្វពួកខ្លះក្នុងលោកនេះ ចុះកាន់ផ្ទៃមាតា ក៏ដឹងខ្លួន ឋិតនៅក្នុងផ្ទៃមាតា ក៏ដឹងខ្លួន ប្រសូតចេញចាកផ្ទៃមាតា ក៏ដឹងខ្លួន នេះជាដំណើរចុះកាន់គភ៌ទី ៤ ។

ក្នុង ៤ យ៉ាងនេះ ទី ១ ជារបស់ពួកលោកិយមនុស្ស ។ ទី ២ ជារបស់ព្រះអសីតិមហាសាវក ។ ទី ៣ ជារបស់ព្រះអគ្គសាវកទាំង ២ និងព្រះ-បច្ចេកពោធិសត្វទាំងឡាយ បានឮថា បុគ្គល ៣ ពួកនោះ កាលត្រូវកម្មជវាត បក់ជើងឡើងលើ ក្បាលចុះក្រោម ចេញអំពីអន្លកំណើតដ៏ចង្អៀតពន់ពេក រមែងដល់នូវសេចក្តីទុក្ខដ៏ក្រៃលែង ឧបមាដូចគេចាប់បោះចូលទៅក្នុងជ្រោះជ្រៅច្រើនជាងរយជួរបុរស ឬដូចដំរីដែលត្រូវចេញអំពីប្រហោងជុំរទេះ ដូច្នោះ ។ ដោយហេតុនោះ ការដឹងខ្លួនថា អញកំពុងប្រសូត ទើបមិនមានដល់បុគ្គល ៣ ពួកនោះ ។ ការឈានចុះកាន់គភ៌ទី ៤ រមែងមានចំពោះព្រះសព្វញ្ញូពោធិ-សត្វទាំងឡាយប៉ុណ្ណោះ ។ ពិតហើយ ព្រះសព្វញ្ញូពោធិសត្វទាំងឡាយនោះ កាលបដិសន្ធិក្នុងគភ៌ព្រះមាតាក៏ដឹង កាលនៅក្នុងគភ៌ព្រះមាតាក៏ដឹង ។ តែក្នុងវេលាប្រសូត កម្មជវាត មិនអាចបក់យកព្រះបាទរបស់ព្រះសព្វញ្ញូពោធិសត្វទាំងនោះឡើងលើ ធ្វើព្រះសីសៈឲ្យចុះក្រោម ព្រះពោធិសត្វទាំងនោះ ទ្រង់លាព្រះហស្តទាំង ២ បិទព្រះនេត្រហើយ ប្រថាប់ឈរយោងចេញ ។

ក្នុងបទថា **មាតុ កុច្ឆឹ ឱក្កមតិ** នេះ មានអធិប្បាយថា រមែងឈានចុះកាន់គភ៌មាតា ។ ពិតហើយ កាលព្រះពោធិសត្វនោះ ឈានចុះកាន់គភ៌ព្រះមាតា ក៏រមែងមានហេតុអស្ចារ្យយ៉ាងនេះ កាលមិនឈានចុះ ក៏មិនមានហេតុអស្ចារ្យ ។

[ ៣២ ] បទថា **អប្បមាណោ** ប្រែថា មានប្រមាណដ៏ច្រើន អធិប្បាយថា បរិបូណ៌ ។ បទថា **ទេវានំ ទេវានុភាវំ** នេះ មានអធិប្បាយថា អានុភាព

នៃទេវតាទាំងឡាយ មានដូច្នេះ គឺស្មើនៃសំពត់ដែលស្លៀក រមែងផ្សាយទៅបាន ១២ យោជន៍ របស់សរីរៈក៏ផ្សាយទៅយ៉ាងនោះ គ្រឿងប្រដាប់ក៏ផ្សាយទៅយ៉ាងនោះ វិមានក៏ផ្សាយទៅយ៉ាងនោះ ។ កន្លងនូវទេវានុភាពនោះ ។ បទថា **លោកន្តរិកា** សេចក្តីថា លោកន្តរិកនរកមួយរណ្តៅ រមែងមានក្នុងចន្លោះចក្រវាលទាំង ៣ លោកន្តរិកនរកនោះ មានប្រមាណ ៨ ពាន់យោជន៍ ។ ដូចចន្លោះរមែងមានត្រង់កណ្តាលកង់រទេះ ៣ ឬបាត្រ ៣ ដែលដាក់ទល់គ្នា ។ បទថា **អឃា** ប្រែថា បើកហើយជានិច្ច ។ បទថា **អសំវុតា** សេចក្តីថា ខាងក្រោមក៏មិនមានទីអាស្រ័យ ។ បទថា **អន្ធការា** ប្រែថា ងងឹតសូប ។ បទថា **អន្ធការតិមិសា** សេចក្តីថា ប្រកបដោយពពកដែលធ្វើនូវការងងឹត ព្រោះហាមការកើតឡើងនៃចក្ខុវិញ្ញាណ ។ បានឮថា ចក្ខុវិញ្ញាណ រមែងមិនកើតក្នុងលោកន្តរិកនរកនោះ ។ បទថា **ឯវំ មហិទ្ធិកា** សេចក្តីថា មានឫទ្ធិយ៉ាងនេះ គឺបានឮថា ព្រះចន្ទ និងព្រះអាទិត្យរមែងប្រាកដក្នុងទ្វីបទាំង ៣ តែមួយព្រមគ្នា ។ មានអានុភាពច្រើនយ៉ាងនេះ គឺកម្ចាត់ការងងឹត ហើយជះពន្លឺទៅបានមួយទិស ៨ លាន ១ សែនយោជន៍ ។

បទថា **អាភាយ ឆានុភោន្តិ** ប្រែថា ពន្លឺរបស់ខ្លួនមិនគ្រប់គ្រាន់ ។ បានឮថា ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ រមែងមិនជះពន្លឺទៅដល់ភ្នំកណ្តាប់ចក្រវាលឡើយ ។ លោកន្តរិកនរក នៅហួសភ្នំកណ្តាប់ចក្រវាលទៅទៀត ។ ព្រោះដូច្នោះ ទើបលោកសម្តែងថា ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ មិនមានពន្លឺល្មមចាំងទៅដល់លោកន្តរិកនរកនោះឡើយ ។

បទថា **យេបិ តត្ថ សត្តា** សេចក្តីថា សួរថា ពួកសត្វដែលកើតក្នុងលោកន្តរិកនរកនោះ ធ្វើកម្មអ្វីទុក ទើបកើតក្នុងទីនោះ ។ ឆ្លើយថា ធ្វើកម្មគ្រោតគ្រាត ធ្វើទារុណចំពោះមាតាបិតា ចំពោះសមណព្រាហ្មណ៍ដែលតាំងនៅក្នុងធម៌ខ្លះ ធ្វើខុសដទៃខ្ពស់ឡើងទៅទៀតខ្លះ ធ្វើកម្មដ៏ទារុណ ដូចជាសម្លាប់សត្វបំបាត់ជីវិតជាដើមជាប្រចាំរាល់ៗ ថ្ងៃខ្លះ ទើបកើតក្នុងលោកន្តរិក-នរកនោះ ដូចជាអភយចោរ នាគចោរជាដើម ក្នុងតម្ពបណ្ណិទ្វីប ។ អត្តភាពនៃសត្វទាំងនោះ មានប្រមាណ ៣ គាវុត ។ មានក្រចកវែង ដូចក្រចកប្រចៀវ ។ សត្វទាំងនោះប្រើក្រចកតោងត្រង់ជើងភ្នំកណ្តាប់ចក្រវាល ដូចប្រចៀវទំត្រង់ដើមឈើ ដូច្នោះ ។ តែកាលណាវារទៅប៉ះដៃគ្នានឹងគ្នា កាលនោះក៏សម្គាល់ថា អញបានអាហារហើយ ស្ទុះទៅជុំវិញត្រង់ជើងភ្នំកណ្តាប់ចក្រវាលនោះ ហើយធ្លាក់ចុះក្នុងទឹកក្រុត កាលខ្យល់បក់ ក៏បែកធ្លាក់ចូលក្នុងទឹក ដូចផ្លែស្រគំ ។ លុះធ្លាក់ចុះទៅក៏រលួយ ដូចម្សៅដែលធ្លាក់ទៅក្នុងទឹកប្រៃ ។

បទថា **អញ្ញេបិ កិរ ភោ សន្តិ សត្តា** សេចក្តីថា រមែងឃើញប្រចក្សក្នុងថ្ងៃនោះថា សូម្បីសត្វដទៃ កាលសោយទុក្ខនេះ ក៏កើតក្នុងលោកន្តរិកនរកនេះ ដូចពួកយើងដែលកំពុងសោយទុក្ខធំ ដូច្នោះ ឱភាសនេះរមែងមិនតាំងនៅត្រឹមមួយជួរខណៈហុតបបរម្តង ។ មានត្រឹមមួយជួរវេលា ដែលដេកលក់ទៅហើយ ភ្ញាក់ឡើង ទទួលដឹងអារម្មណ៍ប៉ុណ្ណោះ ។ ឯទីឃនិកាយាចារ្យពោលថា ឱភាសនោះប្រាកដចំពោះត្រឹមមួយខណៈផ្ទាត់ម្រាមដៃហើយ ក៏បាត់ទៅ ដូចពន្លឺរបស់ផ្លេកបន្ទោរ លុះបុគ្គលធ្ងល់ថា នេះអ្វី ក៏បាត់ទៅ ។ បទថា

**សង្កម្បតិ** *ប្រែថា ញាប់ញ័រដោយជុំវិញ ។ ២ បទក្រៅអំពីនេះ ជាវេវចនៈនៃបទដំបូងនោះឯង ដើម្បីសរុបសេចក្តី ទើបលោកពោលពាក្យថា* **អប្ប-មាណោ ច** *ជាដើមបន្ថែមទៀត ។*

*[ ៣៣ ] បទថា* **ចត្តារោ** *ក្នុងប្រយោគថា* **ចត្តារោ ធំ ទេវបុត្តា ចតុទ្ទិសំ អារក្ខាយ ឧបគច្ឆន្តិ** *នេះ លោកពោលសំដៅយកស្តេចមហារាជទាំង ៤ ។ ក្នុងម៉ឺនចក្រវាលរមែងមានចតុមហារាជ ៤ ម៉ឺននៅប្រចាំ បែកគ្នានៅមួយចក្រវាល ៤ បណ្តាមហារាជទាំងនោះ មហារាជក្នុងចក្រវាលនេះទ្រង់កាន់ព្រះខ័នយាងមកហើយ ចូលទៅកាន់បន្ទប់ដ៏មានសិរី ដើម្បីរក្សាព្រះពោធិសត្វ មហារាជក្រៅអំពី ៤ អង្គនេះ បែកខ្ញែកគ្នាទៅដេញពួកយក្ខមានបិសាចដែលប្រឡាក់ធូលីជាដើម ដែលគេបង្ខាំងទុកឲ្យចៀសចេញទៅហើយធ្វើការរក្សា តាំងអំពីទ្វារបន្ទប់ រហូតដល់កណ្តាប់ចក្រវាល ។*

*ការថ្វាយនូវអារក្ខានេះ ដើម្បីប្រយោជន៍អ្វី ព្រោះចាប់អំពីពេលដែលជាកលលៈ ក្នុងខណៈបដិសន្ធិ ទោះបីមានមារមួយសែនកោដិ លើកភ្នំព្រះសិនេរុទាំងមួយសែនកោដិមកដើម្បីធ្វើអន្តរាយព្រះពោធិសត្វ ឬព្រះមាតារបស់ព្រះ-ពោធិសត្វ អន្តរាយទាំងពួង ក៏គប្បីអន្តរធានទៅមិនមែនឬ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ក្នុងរឿងដែលទេវទត្តភិក្ខុ ធ្វើលោហិតឲ្យពុះពង ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ការដែលបុគ្គលចង់ផ្តាច់ព្រះជន្មតថាគតដោយសេចក្តីព្យាយាមរបស់បុគ្គលនោះ មិនមែនឋានៈ មិនមែនឱកាស ព្រោះព្រះតថាគតទាំងឡាយ នឹងមិនបរិនិព្វាន ដោយការព្យាយាមរបស់អ្នកដទៃ*

ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរទៅនៅតាមទីដើម ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតទាំងឡាយ មិនចាំបាច់មានការរក្សា ។ ម្នាលភិក្ខុទាំងឡាយ អ្នកណាព្យាយាមសម្លាប់តថាគត សេចក្តីព្យាយាមសម្លាប់របស់អ្នកនោះ មិនមែនជាហេតុ មិនមែនជាឱកាស ( គួរធ្វើបានឡើយ ) ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនដែលបរិនិព្វានដោយសេចក្តីព្យាយាមរបស់បុគ្គលដទៃទេ ម្នាលភិក្ខុទាំងឡាយ ចូរអ្នកទៅកាន់វិហាររាល់គ្នាចុះ ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនបាច់មានបុគ្គលរក្សាទេ ។ ព្រោះហេតុនោះ អន្តរាយនៃជីវិត រមែងមិនមានដល់ព្រះតថាគតទាំងឡាយ ដោយការព្យាយាមអ្នកដទៃឡើយ ។ ពួកអមនុស្សដែលមានរូបវិកល គួរខ្ពើម បក្សីដែលមានរូបគួរខ្លាច ក៏មាន ការខ្លាច ឬការតក់ស្លុត គប្បីកើតដល់ព្រះមាតារបស់ព្រះពោធិសត្វបាន ព្រោះឃើញរូប ឬស្តាប់សំឡេងរបស់អមនុស្សពួកណា ដើម្បីឃាត់អមនុស្សទាំងនោះ ទើបត្រូវដាក់ការរក្សា ។ម្យ៉ាងទៀត មហារាជទាំងនោះ មានសេចក្តីគោរព កើតឡើងដោយតេជះ បុណ្យបារមីរបស់ព្រះពោធិសត្វ ទាំងខ្លួនឯង ក៏មានសេចក្តីគោរពស្រេចស្រាប់ហើយ ទើបធ្វើយ៉ាងនេះ ។

សួរថា ស្តេចមហារាជទាំង ៤ ចូលទៅឈរខាងក្នុងបន្ទប់ហើយ សម្តែងខ្លួន ឲ្យប្រាកដដល់ព្រះមាតារបស់ព្រះពោធិសត្វ ឬមិនសម្តែង ។ ឆ្លើយថា មិនបង្ហាញខ្លួនក្នុងវេលាដែលព្រះមាតារបស់ព្រះពោធិសត្វ ទ្រង់ធ្វើកិច្ចផ្ទាល់ខ្លួន ដូចជាស្រេពស្រង់ ស្អិតស្អាង និងសោយជាដើម ។ តែបង្ហាញខ្លួនក្នុង

វេលាដែលព្រះនាងចូលបន្ទប់ដ៏មានសិរី ហើយផ្ទំលើព្រះទែនបន្ទំ ។ ឈ្មោះថា រាងកាយរបស់អមនុស្សទាំងឡាយ រមែងជាវត្ថុដែលគួរខ្លាចចំពោះមុខនៃមនុស្សទាំងឡាយក្នុងវេលានោះក៏ពិត តែសម្រាប់ព្រះមាតារបស់ព្រះពោធិសត្វ ឃើញអមនុស្សទាំងនោះហើយ រមែងមិនខ្លាច ដោយអានុភាពនៃបុណ្យរបស់ព្រះនាង និងព្រះឱរស ។ ព្រះនាងមានចិត្តក្នុងអមនុស្សទាំងនោះ ដូចភ្នាក់ងារដែលយាមក្នុងព្រះរាជដ្ឋានទូទៅ ។

[ ៣៤ ] បទថា **បកតិយា សីលវតី** សេចក្តីថា ព្រះនាងដល់ព្រមដោយសីល ដោយសភាវៈនោះឯង បានឮថា កាលព្រះពុទ្ធទ្រង់មិនទាន់កើតឡើង មនុស្សទាំងឡាយ នាំគ្នាទៅអង្គុយប្រហោង កាន់សីលក្នុងសម្នាក់របស់តាបស និងបរិព្វាជកទាំងឡាយ សូម្បីមាតារបស់ព្រះពោធិសត្វ ក៏កាន់សីលក្នុងសម្នាក់នៃកាឡទេវិលតាបស ។ តែកាលព្រះពោធិសត្វនៅក្នុងព្រះគភ៌ ព្រះនាងមិនអាចគង់ក្បែរបាទមូលរបស់អ្នកដទៃបាន សូម្បីសីលដែលព្រះនាងប្រថាប់គង់លើអាសនៈស្មើគ្នាទទួល ក៏គ្រាន់តែជាវិធីការប៉ុណ្ណោះ ។ ព្រោះហេតុនោះ ទើបពោលដូច្នេះថា ព្រះមាតារបស់ព្រះពោធិសត្វ បានសមាទានសីល ដោយព្រះអង្គឯងនោះឯង ។

[ ៣៥ ] បទថា **បុរិសេសុ** សេចក្តីថា ចិត្តដែលមានសេចក្តីបំណងក្នុងបុរស រមែងមិនកើតក្នុងមនុស្សទាំងឡាយ រាប់តាំងពីព្រះបិតារបស់ព្រះពោធិសត្វផង ។ ឯសេចក្តីនោះ កើតដោយការគោរពក្នុងព្រះពោធិសត្វ មិនមែនកើតព្រោះលះកិលេសបានឡើយ ។ ឯអ្នកសិប្បៈទាំងឡាយសូម្បីឈ្លាស

អង់អាច ក៏មិនអាចគូររូបព្រះមាតានៃព្រះពោធិសត្វ ក្នុងផ្ទាំងគំនូរជាដើមបាន ឡើយ ។ បុគ្គលណាម្នាក់ មិនអាចពោលបានថា តម្រេករមែងមិនកើតដល់បុរស ព្រោះឃើញរូបព្រះមាតាព្រះពោធិសត្វនោះ បើមានចិត្តតម្រេក បំណងនឹងចូលទៅរកព្រះនាង នឹងឈានជើងមិនរួច ដូចត្រូវចងដោយប្រវ៉ាក់ទិព្វ ។ ព្រោះដូច្នោះ ទើបលោកពោលពាក្យជាដើមថា **អនតិក្កមនីយា** ដូច្នេះ ។

[ ៣៦ ] បទថា **បញ្ចន្នំ កាមគុណានំ** សេចក្តីថា ការហាមវត្ថុដោយអំណាចនៃចំណង់ក្នុងបុរស លោកពោលហើយពីមុន ដោយបទថា **កាមគុណូបសញ្ហិតំ** ។

ក្នុងទីនេះ សម្តែងត្រឹមតែការបានចំពោះនូវអារម្មណ៍ ។ បានឮថា ក្នុងគ្រានោះ ព្រះរាជាដោយទូទៅ ជ្រាបដំណឹងថា ព្រះឱរសដែលមានសភាពបែបនេះ កើតក្នុងព្រះគភ៌របស់ព្រះទេវី ទើបបញ្ជូនបណ្ណាការដែលជាទីតាំងនៃអារម្មណ៍របស់ទ្វារទាំង ៥ ដោយជាគ្រឿងប្រដាប់ដែលមានតម្លៃច្រើន និងគ្រឿងតន្ត្រីជាដើម ។ សម្រាប់ព្រះពោធិសត្វ និងព្រះមាតា រមែងមានលាភសក្ការៈ កំណត់ប្រមាណមិនបាន ព្រោះកុសលសម្ភារៈដែលទ្រង់បំពេញ ។

[ ៣៧ ] បទថា **អកិលន្តកាយា** សេចក្តីថា ស្រីដទៃរមែងលំបាកដោយការៈ ក្នុងការរក្សាគភ៌ ដៃក្តី ជើងក្តី ហើម យ៉ាងណា ព្រះនាងមិនលំបាកដូចស្រីទាំងនោះឡើយ ។ បទថា **តិរោ កុច្ឆិគតំ** ប្រែថា ប្រថាប់នៅខាងក្នុងព្រះឧទរ គឺផុតកាលដែលជាកលលៈជាដើមទៅហើយ ព្រះនាងឃើញព្រះពោធិសត្វមានអង្គអវយវៈបរិបូណ៌ មានឥន្ទ្រិយមិនថោកថយ ។

សួរថា នាងមើលដើម្បីប្រយោជន៍អ្វី ។ ឆ្លើយថា ដើម្បីឲ្យនៅយ៉ាងសប្បាយ ។

បណ្ដាម្ដាយទាំងឡាយ ទោះអង្គុយ ឬដេកជាមួយបុត្រក្ដី ក៏ត្រូវសម្លឹងមើលបុត្រ ដើម្បីឲ្យនៅយ៉ាងសប្បាយថា អញនឹងលើកដៃ-ជើង ដែលសំយុងចុះ ឲ្យតាំងនៅដោយល្អ យ៉ាងណា សូម្បីមាតារបស់ព្រះពោធិសត្វក៏ដូច្នោះ នាងសម្លឹងមើលព្រះពោធិសត្វដើម្បីឲ្យនៅយ៉ាងសប្បាយ ដោយព្រះតម្រិះថា ទុក្ខឯណាដែលកើតឡើងដល់ទារកដែលនៅក្នុងផ្ទៃ ក្នុងវេលាដែលម្ដាយក្រោក ដើរទៅ បង្វិលខ្លួន និងអង្គុយជាដើមក្ដី ក្នុងវេលាដែលម្ដាយលេបអាហារដែលក្ដៅ ត្រជាក់ ប្រៃ ល្វីង និងដែលហឹរ ទុក្ខនោះមានដល់ព្រះឱរសរបស់អញខ្លះដែរឬហ្ន៎ ព្រះនាងឃើញព្រះពោធិសត្វអង្គុយពត់ភ្នែនហើយ ធម្មតាទារកដែលនៅក្នុងផ្ទៃដទៃ អង្គុយសង្កត់លើអាហារចាស់ ទូលអាហារថ្មី បែរខ្នងមកខាងមុខផ្ទៃម្ដាយ អង្គុយចំកោងខ្នង យកដៃទាំង ២ ទល់ចង្កា ដូចស្វាអង្គុយក្នុងប្រហោងឈើ ក្នុងវេលាភ្លៀងធ្លាក់ តែព្រះពោធិសត្វមិនដូច្នោះឡើយ ។ ព្រះអង្គធ្វើឆ្អឹងខ្នងឲ្យត្រង់ អង្គុយពត់ភ្នែន បែរព្រះភក្ត្រទៅទិសបូព៌ា ដូចព្រះធម្មកថិកអង្គុយលើធម្មាសនៈ ។ ឯកម្មដែលព្រះមាតានៃព្រះពោធិសត្វធ្វើក្នុងកាលមុន រមែងញុំាងវត្ថុ គឺទីតាំងនៃព្រះគភ៌របស់ព្រះនាងឲ្យបរិសុទ្ធ កាលវត្ថុបរិសុទ្ធ លក្ខណៈនៃព្រះឆវីដ៏ល្អិតទន់ រមែងកើត គ្រានោះ ស្បែកក៏មិនអាចបិទបាំងព្រះពោធិសត្វដែលនៅក្នុងគភ៌បាន កាលសម្លឹងមើល ប្រាកដដូច ប្រថាប់ឈរនៅខាងក្រៅ ។

ដើម្បីញ៉ាំងសេចក្តីនោះឲ្យជាក់ច្បាស់ដោយឧបមា ទើបលោកពោលពាក្យជាដើមថា **សេយ្យថាបិ** ឯព្រះពោធិសត្វនៅខាងក្នុងព្រះគភ៌ រមែងមើលមិនឃើញព្រះមាតា ព្រោះចក្ខុវិញ្ញាណមិនកើតខាងក្នុងព្រះគភ៌ឡើយ ។

[ ៣៨ ] បទថា **កាលំ ករោតិ** សេចក្តីថា មិនមែនព្រះនាងសោយព្រះទិវង្គតព្រោះប្រសូតឡើយ តែព្រោះអស់ជន្មាយុតែម៉្យាង ។ ពិតហើយ ទីដែលព្រះពោធិសត្វនៅប្រថាប់ រមែងដូចកុដិក្នុងព្រះចេតិយ មិនគួរដល់សត្វពួកដទៃប្រើប្រាស់រួម ហើយបុគ្គលណាម្នាក់ មិនអាចនឹងញែកព្រះមាតារបស់ព្រះពោធិសត្វចេញ ហើយតែងតាំងស្រីដទៃ ទុកក្នុងតំណែងព្រះអគ្គមហេសីបានឡើយ ហេតុដូចពោលមកប្រមាណប៉ុណ្ណេះនោះឯង រមែងជាប្រមាណនៃអាយុរបស់ព្រះមាតាព្រះពោធិសត្វ ព្រោះដូច្នោះ ទើបព្រះនាងសោយព្រះទិវង្គតក្នុងវេលានោះ ។

សួរថា ព្រះនាងសោយព្រះទិវង្គតក្នុងវ័យណា ឆ្លើយថា ក្នុងមជ្ឈិមវ័យ ។ សេចក្តីពិត ក្នុងបឋមវ័យ អត្តភាពរបស់ព្រះពោធិសត្វទាំងឡាយរមែងមានឆន្ទរាគៈខ្លាំងក្លា ។ ដោយហេតុនោះ ស្ត្រីដែលតាំងគភ៌ក្នុងវេលានោះ រមែងមិនអាចថ្នមគភ៌នោះទុកបាន ។ គភ៌រមែងមានរោគច្រើន កាលកន្លងចំណែកទាំង ២ នៃមជ្ឈិមវ័យទៅហើយ វត្ថុ គឺទីតាំងនៃព្រះគភ៌ រមែងបរិសុទ្ធក្នុងចំណែកទី ៣ នៃវ័យ កាលវត្ថុបរិសុទ្ធ ទារកដែលកើតក៏មិនមានរោគ ព្រោះដូច្នោះ សូម្បីព្រះមាតារបស់ព្រះពោធិសត្វ សោយសម្បត្តិក្នុងបឋមវ័យ ក៏ប្រសូតក្នុងចំណែកទី ៣ នៃមជ្ឈិមវ័យ ព្រះនាងសោយព្រះ

វិលាល័យហើយ ដោយប្រការដូច្នេះ ។

[ ៣៩ ] **វា** សព្ទ ក្នុងបទថា **នវ វា ទស វា** នេះ គប្បីជ្រាបថា ត្រូវសង្គ្រោះមាតិកាជាដើមយ៉ាងនេះថា **សត្ត វា អដ្ឋ វា ឯកាទស វា ទ្វាទស វា** ចូលមកផង ដោយជាវិកប្ប ។ បណ្តាកំណត់ទាំងនោះ សត្វដែលនៅក្នុងព្រះគភ៌បាន ៧ ខែប្រសូត សូម្បីរួចផុត ក៏មិនអាចអត់ធន់នឹងរងា អត់ធន់នឹងក្តៅបាន ដែលនៅក្នុងព្រះគភ៌បាន ៨ ខែប្រសូត មិនរួចផុត ក្រៅអំពីនោះ ទើបរួចផុត ។ បទថា **ឋិតា វ** ប្រែថា ប្រថាប់ឈរហើយនោះឯង ។

ព្រះនាងមហាមាយាទេវី ព្រះតម្រិះថា អញនឹងទៅកាន់ផ្ទះនៃត្រកូលព្រះញាតិរបស់អញ ហើយក្រាបទូលព្រះរាជា ។ ព្រះរាជាបញ្ជាឲ្យប្រដាប់តាក់តែងផ្លូវដែលព្រះនាងយាងទៅ តាំងអំពីក្រុងកបិលពស្តុ រហូតដល់ក្រុងទេវទហៈ ហើយឲ្យព្រះទេវីប្រថាប់លើវមាស ។ ស្តេចសក្យៈនៅក្នុងព្រះនគរទាំងមូលហែហមបូជាដោយគ្រឿងក្រអូប និងផ្កាជាដើម នាំព្រះទេវីយាងទៅហើយ ។ ព្រះនាងទតឃើញលុម្ពិនីសាលវនោទ្យាន មិនឆ្ងាយអំពីព្រះនគរទេវទហៈ កើតការពេញព្រះហឫទ័យ ចង់ប្រពាតឧទ្យាន ទើបឲ្យសញ្ញាដល់ព្រះរាជា ។ ព្រះរាជាបញ្ជាឲ្យប្រដាប់តាក់តែងព្រះឧទ្យាន ហើយធ្វើការរក្សា ។ ព្រះទេវីយាងចូលកាន់ឧទ្យាន ក៏មានព្រះកម្លាំងខ្សោយចុះ គ្រានោះ ពួកក្នាក់ងារបានក្រាលទីបន្ទំដ៏មានសិរីត្រង់គល់រាំងដ៏ជាមង្គល ហើយបាំងវាំងននថ្វាយព្រះនាង ព្រះនាងយាងចូលខាងក្នុងហើយ ប្រថាប់ឈរតោងមែកសាលៈ

លំដាប់នោះ ព្រះនាងបានប្រសូតព្រះឱរសក្នុងរំពេចនោះឯង ។

[ ៤១ ] បទថា **ទេវា បឋមំ បដិគ្គណ្ហន្តិ** សេចក្តីថា ពួកព្រហ្មជាន់សុទ្ធាវាសទាំងឡាយដែលជាព្រះខីណាស្រពទទួលមុន ។

ទទួលដូចម្តេច អាចារ្យមួយពួកពោលថា ពួកព្រហ្មជាន់សុទ្ធាវាសកាឡាខ្លួនជាពួកឆ្មាក់ឆ្មារ ថ្វាយការប្រសូតិ ។ លោកបដិសេធសេចក្តីនោះហើយអធិប្បាយដូច្នេះ ។ វេលានោះ ព្រះមាតាព្រះពោធិសត្វ ទ្រង់ស្លៀកសំពត់ដែលរំលេចដោយមាស ទ្រង់ដណ្តប់សំពត់ ២ ជាន់ ស្រដៀងគ្នានឹងភ្នែកត្រីគ្របដណ្តប់ដល់បាតជើង ហើយប្រថាប់ឈរ ការប្រសូតិឱរសរបស់ព្រះនាងក៏ងាយ ដូចទឹកដែលហូរចេញចាកធម្មក្រក ខណៈនោះ ព្រហ្មជាន់សុទ្ធាវាសទាំងនោះ ចូលទៅដោយភេទរបស់ព្រហ្មតាមប្រក្រតី រួចទទួលព្រះឱរសដោយបណ្តាញមាស ។ មនុស្សទាំងឡាយ ទទួលបន្តពីដៃរបស់ព្រហ្មទាំងនោះ ដោយសំពត់ទុកូលយ៉ាងល្អ ដោយហេតុនោះ ទើបលោកពោលថាទេវតាទាំងឡាយទទួលមុន ពួកមនុស្សទទួលឯក្រោយ ។

[ ៤២ ] បទថា **ចត្តារោ នំ ទេវបុត្តា** សំដៅដល់មហារាជទាំង ៤ ។ បទថា **បដិគ្គហេត្វា** បានដល់ ទទួលដោយបណ្តាញដែលធ្វើដោយស្បែកខ្លា ។ បទថា **មហេសក្ខោ** ប្រែថា មានតេជះច្រើន គឺមានយសច្រើន អធិប្បាយថា បរិបូណ៌ដោយលក្ខណៈ ។

[ ៤៣ ] បទថា **វិសុទ្ធោ វ និក្ខមតិ** សេចក្តីថា ធម្មតាសត្វដទៃរមែងនៅជាប់ត្រង់ទ្វារកំណើត តែព្រះមាតាព្រះពោធិសត្វ មិនដូច្នោះឡើយ ។

អធិប្បាយថា ប្រសូតងាយ មិនជាប់អ្វីឡើយ ។ បទថា **ឧទ្ទេន** ប្រែថា ដោយទឹក ។ បទថា **កេនចិ អសុចិនា** សេចក្តីថា ធម្មតាសត្វដទៃមាន ខ្យល់កម្មជវាតបក់យកជើងឡើងខាងលើ យកក្បាលចុះខាងក្រោម ធ្វើទ្វារ កំណើត សោយនូវទុក្ខធំកន្លង ឧបមាដូចធ្លាក់ចុះទៅក្នុងជ្រោះជម្រៅមួយរយ ជួរបុរស ឬដូចដំរីដែលគេទាញចេញពីប្រហោងរនុកទ្វារ ប្រឡាក់ប្រឡូសទៅ ដោយរបស់មិនស្អាតច្រើនប្រការ ទើបចេញបាន យ៉ាងណា ព្រះពោធិសត្វ មិនដូច្នោះឡើយ ព្រោះខ្យល់កម្មជវាត មិនអាចធ្វើព្រះពោធិសត្វឲ្យមានព្រះ បាទឡើងលើ ព្រះសីសៈចុះក្រោមបានឡើយ ។ ព្រះអង្គលាព្រះហស្ត និង ព្រះបាទទាំង ២ ចេញ ហើយប្រថាប់ឈរ ឧបមាដូចព្រះធម្មកថិកឈានចុះ អំពីធម្មាសនៈ ឬដូចបុរសចុះពីជណ្តើរ ដូច្នោះ មិនប្រឡាក់របស់មិនស្អាត ខ្លះៗ ដែលកើតក្នុងព្រះគភ៌របស់ព្រះមាតាឡើយ ហើយប្រសូត ។

[ ៤៤ ] បទថា **ឧទកស្ស ធារា** ប្រែថា ធ្លារទឹក ។ ក្នុងធ្លារទឹកនោះ ធ្លារទឹកត្រជាក់ធ្លាក់ចុះអំពីក្អមមាស ធ្លារទឹកក្តៅធ្លាក់ចុះអំពីក្អមប្រាក់ ។ លោក ពោលសេចក្តីនេះដើម្បីសម្តែងថា ទឹកផឹក ទឹកប្រើប្រាស់ទាំង ២ របស់ព្រះ អង្គ មិនលាយឡំដោយរបស់មិនស្អាតណាមួយលើផែនដី និងទឹកសម្រាប់ លេង ក៏មិនសាធារណៈដល់បុគ្គលទូទៅ ។ ទឹកដទៃដែលគប្បីនាំមកដោយ ក្អមមាស ក្អមប្រាក់ក្តី ទឹកដែលនៅក្នុងស្រះបោក្ខរណី ឈ្មោះហង្សវដ្តៈ ជាដើមក្តី រមែងមិនមានកំណត់ ។

[ ៤៥ ] បទថា **សម្បតិជាតោ** ប្រែថា ប្រសូតហើយមួយប្រសក់ ។

ក្នុងព្រះបាលី លោកសម្ដែងថា ព្រះពោធិសត្វប្រសូតចាកព្រះគភ៌ព្រះមាតា ភ្លាម ក៏ប្រថាប់ព្រះយុគលបាទដ៏ស្មើលើផែនដី តែមិនគួរឃើញយ៉ាងនោះ ។ តាមពិត ព្រះពោធិសត្វយាងចេញ ព្រហ្មទាំងឡាយយកបណ្ដាញមាសទទួល មុន ស្ដេចមហារាជទាំង ៤ ទទួលបន្តពីដៃរបស់ព្រហ្មទាំងនោះ ដោយ បណ្ដាញដែលធ្វើដោយស្បែកខ្លា ដែលមានសម្ផស្សទន់ សប្បាយ ដែល សន្មតថាជាមង្គល ទើបមនុស្សទាំងឡាយ ទទួលអំពីដៃរបស់ស្ដេចមហារាជ ទាំងនោះ ដោយទុកូលពស្ត្រយ៉ាងល្អ លុះផុតអំពីដៃមនុស្ស ក៏ប្រថាប់ឈរ លើផែនដី ។

បទថា **សេតម្ហិ ឆត្តេ អនុហិរមានេ** ប្រែថា កាលទេវបុត្រប៉ាំងស្វេតច្ឆត្រ ជាទិព្វ សូម្បីគ្រឿងរាជកកុធៈទាំង ៥ មានដាវជាដើម ដែលជាបរិវាររបស់ ឆត្រ មកហើយក្នុងទីនោះដូចគ្នា ។ តែក្នុងព្រះបាលីពោលត្រឹមតែឆត្រ ដូច ព្រះរាជាដែលគេប៉ាំងឆត្រថ្វាយ ក្នុងវេលាស្ដេចព្រះរាជដំណើរ ។ ក្នុងរាជ-កកុធភណ្ឌទាំង ៥ នេះ ប្រាកដតែឆត្រប៉ុណ្ណោះ មិនប្រាកដអ្នកកាន់ ។ ព្រះខ័ន ផ្លិតស្លឹកត្នោត ផ្លិតកន្ទុយក្ងោក ផ្លិតវាលវីជនី ក្បាំងមុខក៏ប្រាកដដូចគ្នា ។ មិន ប្រាកដអ្នកកាន់វត្ថុទាំងនោះ ។ បានឮថា ទេវតាទាំងឡាយមិនប្រាកដខ្លួន កាន់ គ្រឿងកកុធភណ្ឌទាំងនេះគ្រប់យ៉ាង ។ សមដូចពាក្យដែលលោកពោលក្នុង សុត្តនិបាតថា

ពួកទេវតាប៉ាំងឆត្រស មានឆ្អឹងច្រើន មានមណ្ឌលមួយពាន់
( សម្រេចអំពីមាសឆ្អិន ) នាកណ្ដាលអាកាស ចាមរ

ទាំងឡាយ មានជនជាវិការនៃមាស សំយុងចុះ ពួកទេវតា
អ្នកកាន់ចាមរ ក៏មិនប្រាកដឡើយ ។

បទថា **សព្វា ច ទិសា** នេះ លោកពោលដល់ការសម្លឹងមើលទិសទាំងពួង ដូចការមើលទិសរបស់បុរសដែលឈរបែរមុខទៅទិសខាងជើង ព្រះ-មហាសត្វឈានព្រះបាទទៅ ៧ ជំហាន តែសេចក្តីនេះ មិនគួរឃើញយ៉ាងនោះ ពិតហើយ ព្រះមហាសត្វផុតអំពីដៃរបស់មនុស្សទាំងឡាយហើយ ទ្រង់សម្លឹងមើលទិសបូព៌ា ចក្រវាលច្រើនពាន់បានប្រាកដជាទួលតែមួយ ។ ទេវតាទាំងឡាយក្នុងចក្រវាលទាំងនោះ នាំគ្នាបូជាដោយគ្រឿងសក្ការៈ មានគ្រឿងក្រអូប និងផ្កាជាដើម ហើយពោលថា បពិត្រមហាបុរស ក្នុងលោកនេះមិនមានបុគ្គលស្មើនឹងព្រះអង្គបាន តើនឹងមានបុគ្គលក្រៃលែងជាង ដូចម្តេច ។ ព្រះមហាសត្វទ្រង់សម្លឹងមើលទិសទាំង ១០ គឺ ទិសធំ ៤ ទិសតូច ៤ ទិសខាងក្រោម ១ ទិសខាងលើ ១ យ៉ាងនេះ មិនឃើញមានអ្នកស្មើព្រះអង្គ ទ្រង់កំណត់ថា នេះជាទិសឧត្តរ ហើយយាងទៅដោយព្រះបាទ ៧ ជំហាន ក្នុងរឿងនេះ គប្បីឃើញកិច្ចពណ៌នាយ៉ាងនេះ ។ បទថា **អាសភឹ** ប្រែថា ឧត្តម ។ បទថា **អគ្គោ** ប្រែថា ប្រសើរបំផុត គឺចម្រើនបំផុត បានដល់ក្រៃលែងជាងមនុស្សទាំងអស់ដោយគុណទាំងឡាយ ។ ២ បទ ក្រៅអំពីនេះ ជាវេវចនៈនៃបទថា **អគ្គោ** នោះឯង ។ លោកព្យាករអរហត្តដែលគប្បីសម្រេចក្នុងអត្តភាពនេះ ដោយបទទាំង ២ ថា **អយមន្តិមា ជាតិ នត្ថិ ទានិ បុនព្ភវោតិ** ។

ក្នុងអធិការនេះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ។ ការដែលព្រះអង្គឈរប្រថាប់លើផែនដី ដោយព្រះបាទដ៏រាបស្មើ ជាបុព្វនិមិត្តនៃការបានចំពោះនូវឥទ្ធិបាទ ៤ ការដែលព្រះអង្គទ្រង់បែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ជាបុព្វនិមិត្តនៃការយាងទៅជាធំ ក្រៃលែងលើមហាជន ។ ការដែលព្រះអង្គឈានទៅ ៧ ជំហានជាបុព្វនិមិត្តនៃការបាននូវរតនៈ គឺ ពោជ្ឈង្គ ៧ ។ ការដែលទ្រង់ស្វេតច្ឆត្រដ៏ជាទិព្វ ជាបុព្វនិមិត្តនៃការបានចំពោះនូវឆត្រ គឺវិមុត្តិ ។ រាជកកុធភណ្ឌទាំង ៥ ជាបុព្វនិមិត្តនៃការរួចផុតដោយវិមុត្តិ ៥ ប្រការ ។ ការដែលទ្រង់សម្លឹងមើលទិស ជាបុព្វនិមិត្តនៃការបានចំពោះនូវអនាវរណញ្ញាណ ។ ការដែលទ្រង់បន្លឺអាសភិវាចា ជាបុព្វនិមិត្តនៃការប្រកាសធម្មចក្រ ដែលមិនមានបុគ្គលបង្វិលបាន ។ សីហនាទដែលទ្រង់បន្លឺថា **អាយមន្តិមា ជាតិ** គប្បីជ្រាបថា ជាបុព្វនិមិត្តនៃបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ វារៈផ្សេងៗ ទាំងនេះ មកហើយក្នុងព្រះបាលី ។ តែសម្ពហុលវារៈមិនទាន់មានមក ទើបគួរនាំមកសម្តែងផងដែរ ។

ក្នុងថ្ងៃដែលព្រះមហាបុរសប្រសូត លោកធាតុទាំងមួយម៉ឺនកម្រើកហើយ ទេវតាទាំងឡាយក្នុងម៉ឺនលោកធាតុប្រជុំគ្នាហើយ ក្នុងចក្រវាលមួយ ។ ទេវតាទាំងឡាយទទួលមុន ពួកមនុស្សទទួលឯក្រោយ ពិណទាំងឡាយដែលសន្ទឹងដោយអំបោះ និងស្គរទាំងឡាយដែលពាសដោយស្បែក មិនមានបុគ្គលណាមួយប្រគំ ក៏ឮឡើងឯង ។ គ្រឿងខ្នោះឃ្នាង និងច្រវាក់ជាដើមរបស់មនុស្សទាំងឡាយ ដាច់ចេញជាកំណាត់តូច-ធំ រោគគ្រប់យ៉ាងជាអស់ ដូចច្រេះដែល

គេខាត់ដោយរបស់ជួរ ។ អ្នកខ្វាក់អំពីកំណើតក៏ឃើញរូបផ្សេងៗ បាន អ្នកថ្លង់អំពីកំណើត ក៏បានឮសំឡេង មនុស្សខ្វិន ក៏ត្រឡប់សម្បូរដោយកម្លាំងកំហែង ។ មនុស្សឆ្កួតជ្រូក និងល្ងង់អំពីកំណើត ក៏ត្រឡប់ជាមានសតិ ទូកដែលចេញដំណើរទៅប្រទេសដទៃ ក៏ដល់កំពង់ដោយស្រួល ។ រតនៈទាំងឡាយ ដែលនៅក្នុងអាកាស និងនៅលើដី ក៏បានចាំងចែងពន្លឺឡើងឯង ។ បុគ្គលដែលជាសត្រូវ បែរជាបាននូវមេត្តាចិត្ត ។ ភ្លើងក្នុងអវិចីនរកក៏រលត់ ។ ពន្លឺកើតឡើងក្នុងលោកន្តរនរក ។ ទឹកក្នុងស្ទឹងទាំងឡាយក៏មិនហូរ ។ ទឹកក្នុងមហាសមុទ្របានក្លាយជាទឹកផ្អែម ។ មហាវាតភ័យ ក៏មិនបក់ បក្សីដែលហើរទៅក្នុងអាកាស និងដែលទំនៅតាមដើមឈើ ភ្នំ ក៏ធ្លាក់ចុះលើផែនដី ។ ព្រះចន្ទមានពន្លឺល្អពន់ពេក ។ ព្រះអាទិត្យក៏មិនក្តៅមិនត្រជាក់ ប្រាសចាកមន្ទិល សម្បូរតាមរដូវកាល ។ ទេវតាទាំងឡាយឈរនៅត្រង់វិមានរៀងៗខ្លួន នាំគ្នាលេងមហាកីឡា មានទះដៃ ស្រែកហ៊ោ និងគ្រវីទង់ ។ មហាមេឃតាំងឡើងក្នុងទិសទាំង ៤ ញ៉ាំងភ្លៀងឲ្យធ្លាក់ ។ ការឃ្លាន និងការស្រេក មិនបៀតបៀនមហាជន ។ ទ្វារបង្អួចក៏បើកឯង ។ ដើមឈើមានផ្កាមានផ្លែ ក៏បានចេញផ្កា ចេញផ្លែរយោនរយាន ។ ទូទាំងម៉ឺនលោកធាតុ មានទង់ផ្កាឈើជាជួរតែមួយ ដូចគ្នាទាំងអស់ ។

ក្នុងសេចក្តីដែលគួរអស្ចារ្យនោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ការញាប់ញ័រនៃម៉ឺនលោកធាតុ ជាបុព្វនិមិត្តនៃការបានចំពោះនូវព្រះសព្វញ្ញុតញ្ញាណរបស់ព្រះមហាបុរស ។ ការដែលទេវតាទាំងឡាយ មកប្រជុំគ្នាក្នុង

ចក្រវាលមួយ ជាបុព្វនិមិត្តនៃការរួមប្រជុំទទួលព្រះសទ្ធម្មជាមួយគ្នា ក្នុងវេលាដែលទ្រង់ប្រកាសធម្មចក្រ ។ ការដែលទេវតាទាំងឡាយ ទទួលព្រះពោធិសត្វមុន ជាបុព្វនិមិត្តនៃការបានចំពោះនូវរូបាវចរជ្ឈានទាំង ៤ ការដែលមនុស្សទាំងឡាយទទួលឯក្រោយ ជាបុព្វនិមិត្តនៃការបានចំពោះនូវអរូបាវចរជ្ឈានទាំង ៤ ។ ការដែលពិណាព្យឡើងឯង ជាបុព្វនិមិត្តនៃការបានចំពោះនូវអនុបុព្វវិហារធម៌ ។ ការដែលស្គរព្យឡើងឯង ជាបុព្វនិមិត្តនៃការទូន្មានដោយធម្មភេរីដ៏ធំក្រៃលែង ។ ការដែលចំណង មានខ្នោះឃ្នាង និងប្រវាក់ជាដើមដាច់ចេញអំពីគ្នា ជាបុព្វនិមិត្តនៃការកាត់នូវអស្មិមានះបានជាសមុច្ឆេទ ។ ការដែលមនុស្សទាំងឡាយជារោគផ្សេងៗ ជាបុព្វនិមិត្តនៃការប្រាសទៅនៃកិលេសទាំងពួង ។ ការដែលមនុស្សខ្វាក់អំពីកំណើតឃើញរូបបាន ជាបុព្វនិមិត្តនៃការបានចំពោះនូវទិព្វចក្ខុ ។ ការដែលមនុស្សថ្លង់អំពីកំណើតបានឮសំឡេង ជាបុព្វនិមិត្តនៃការបានចំពោះនូវទិព្វសោតធាតុ ។ ការដែលមនុស្សខ្វិន សម្បូរដោយកម្លាំង ជាបុព្វនិមិត្តនៃការសម្រេចនូវឥទ្ធិបាទទាំង ៤ ។ ការដែលមនុស្សឆ្កួតជ្រូកត្រឡប់បានសតិ ជាបុព្វនិមិត្តនៃការបានចំពោះនូវសតិប្បដ្ឋាន ៤ ។ ការដែលទូកទាំងឡាយ ដែលស្ទុះចេញទៅប្រទេសដទៃដល់កំពង់ដោយស្រួល ជាបុព្វនិមិត្តនៃការសម្រេចបដិសម្ភិទា ៤ ។ ការដែលរតនៈទាំងឡាយបញ្ចេញពន្លឺបានឯង ជាបុព្វនិមិត្តនៃពន្លឺព្រះធម៌ ដែលព្រះអង្គទ្រង់សម្តែងដល់សត្វលោក ។ ការដែលសត្រូវទាំងឡាយបែរជាបាននូវមេត្តាចិត្ត ជាបុព្វនិមិត្តនៃការបានចំពោះនូវព្រហ្មវិហារ ៤ ។ កាលដែលភ្លើងនរក

អវិចីរលត់ ជាបុព្វនិមិត្តនៃការរម្ងត់ភ្លើង ១១ កង ។ ការដែលលោកន្តរនរក មានពន្លឺ ជាបុព្វនិមិត្តនៃការកម្ចាត់ងងឹត គឺអវិជ្ជា ហើយទ្រង់ឃើញពន្លឺបាន ដោយព្រះញាណ ។ ការដែលទឹកនៃមហាសមុទ្រមានរសផ្អែម ជាបុព្វនិមិត្ត នៃការដែលព្រះសទ្ធម្មមានរសតែមួយ ។ ការដែលមិនកើតវាតភ័យ ជាបុព្វ-និមិត្តនៃការដែលពុទ្ធបរិស័ទមិនបែកខ្ញែកគ្នា ដោយអំណាចទិដ្ឋិ ៦២ ។ ការ ដែលបក្សីទាំងឡាយធ្លាក់ចុះកាន់ផែនដី ជាបុព្វនិមិត្តនៃការដែលមហាជនដល់ នូវសរណៈស្មើដោយជីវិត ។ ការដែលព្រះចន្ទមានពន្លឺល្អក្រៃពេក ជាបុព្វ-និមិត្តនៃការដែលមហាជនដាក់ចិត្តក្នុងព្រះធម៌ ។ ការដែលព្រះអាទិត្យមិនក្តៅ មិនត្រជាក់ ឲ្យនូវភាពសប្បាយតាមរដូវ ជាបុព្វនិមិត្តនៃការដែលមហាជន ដល់នូវសេចក្តីសុខកាយ សុខចិត្ត ។ ការដែលទេវតាទាំងឡាយលេងកីឡា មានទះដៃជាដើមត្រង់ទ្វារវិមាន ជាបុព្វនិមិត្តនៃការដែលព្រះមហាសត្វសម្រេច ដល់ភាពជាព្រះពុទ្ធ ហើយទ្រង់បន្លឺឧទាន ។ ការដែលមហាមេឃ ៤ ទិស ញុំាងភ្លៀងឲ្យធ្លាក់ ជាបុព្វនិមិត្តនៃការដែលធ្លារទឹក គឺព្រះធម៌ ធ្លាក់ចុះជា ច្រើន ។ ការដែលមនុស្សទាំងឡាយមិនត្រូវសេចក្តីឃ្លានបៀតបៀន ជាបុព្វ-និមិត្តនៃការបានចំពោះនូវអមតធម៌ គឺកាយគតាសតិ ។ ការដែលមនុស្សទាំង ឡាយមិនត្រូវសេចក្តីស្រេកបៀតបៀន ជាបុព្វនិមិត្តនៃការដែលពុទ្ធបរិស័ទ ដល់នូវសេចក្តីសុខហើយ ដោយវិមុត្តិសុខ ។ ការដែលទ្វារបង្អួចទាំងឡាយ បើកឯង ជាបុព្វនិមិត្តនៃការបើកទ្វារអដ្ឋង្គិកមគ្គ ។ ការដែលដើមឈើទាំង-ឡាយបញ្ចេញផ្កា និងផ្លែ ជាបុព្វនិមិត្តនៃព្រះធម៌ ដែលរីកដោយផ្កា គឺវិមុត្តិ

និងពេញដេរដាសដោយសាមញ្ញផល ។ ការដែលលោកជាតុទាំងមួយម៉ឺន មានទង់ជារបៀបតែមួយ គប្បីជ្រាបថា ជាបុព្វនិមិត្តដែលពុទ្ធបរិស័ទមាន អរិយទង់ជាមាល័យ ។ នេះឈ្មោះថា សម្ពហុលវារៈ ។

ក្នុងសម្ពហុលវារៈនេះ មានបុគ្គលជាច្រើនសួរជាប្រស្នាថា ក្នុងវេលា ដែលមហាបុរសជាន់ផែនដី ទ្រង់យាងបែរមុខទៅទិសឧត្តរ ហើយទ្រង់បន្លឺ អាសភិវាចានោះ ទ្រង់ប្រថាប់ឈរលើផែនដី ឬនៅក្នុងអាកាស ប្រាកដព្រះ អង្គ ឬមិនប្រាកដ មិនស្លៀកសំពត់ ឬប្រដាប់តាក់តែងហើយយ៉ាងល្អ ជា កំលោះ ឬជាមនុស្សចាស់ សូម្បីខាងក្រោយ ក៏គង់ជាសភាពដូច្នោះ ឬជា កូនង៉ា ។ ក្នុងកាលតមក ព្រះចូឡាភយត្ថេរ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក បាន វិសជ្ជនាប្រស្នានេះហើយ ក្នុងទីប្រជុំនាលោហប្រាសាទ ។ បានឮថា ក្នុង សេចក្តីនេះ ព្រះថេរៈពោលដល់រឿងរ៉ាវដ៏ច្រើន ដោយជានិយតវាទ បុព្វេ- កតកម្មវាទ និងឥស្សរនិម្មានវាទ ចុងក្រោយបានព្យាករយ៉ាងនេះថា ព្រះមហា បុរសឈរលើផែនដី បានប្រាកដដល់មហាជន ដូចយាងទៅដោយអាកាស និងយាងទៅមានមនុស្សឃើញ តែបានប្រាកដដល់មហាជន ដូចមើលមិន ឃើញ ។ មិនមានសំពត់យាងទៅ តែប្រាកដដល់មហាជន ដូចប្រដាប់តាក់ តែងហើយយ៉ាងល្អ នៅជាកុមារ តែប្រាកដដល់មហាជន ដូចមានព្រះជន្ម ១៦ ព្រះវស្សា តែខាងក្រោយ ក៏នៅជាកូនង៉ាធម្មតា មិនបានដូចដែលប្រាកដ នោះទេ ។ កាលព្រះថេរៈពោលចន្លុលបង្ហាញយ៉ាងនេះហើយ បរិស័ទរបស់ លោកនាំគ្នាពេញចិត្ត ដោយពោលថា អ្នកដ៏ចម្រើន ព្រះថេរៈពោលស្រាយ

ប្រស្នាបានជាក់ច្បាស់ ដូចព្រះពុទ្ធហ្ន៎ ។ លោកន្តរិកវារៈ មានន័យដូចពោល ហើយនោះឯង ។

[ ៤៧ ] បទថា **វិទិតា** ប្រែថា ប្រាកដហើយ ។ ពិតហើយ ព្រះអរិយសាវកទាំងឡាយ រមែងមិនអាចរកឱកាសពិចារណាសង្ខារ ដែលជាចំណែកអតីត ក្នុងខណៈដែលមិនមានឱកាស ដូចក្នុងវេលាផ្ទួតទឹក លុបមុខទំពា និងផឹកជាដើមបានឡើយ ពិចារណាបានចំពោះកាលដែលមានឱកាសប៉ុណ្ណោះ យ៉ាងណា ព្រះពុទ្ធទាំងឡាយ មិនដូច្នោះឡើយ ។ ព្រះពុទ្ធទាំងឡាយ ទ្រង់ពិចារណាសង្ខារដែលកន្លងទៅហើយ ខាងក្នុង ៧ ថ្ងៃបាន តាំងអំពីទ្រង់លើកឡើងកាន់ត្រៃលក្ខណ៍ ទ្រង់រមែងចង្អុលបង្ហាញបាន ឈ្មោះថា ធម៌ដែលមិនជាក់ច្បាស់ដល់ព្រះពុទ្ធទាំងនោះមិនមានឡើយ ព្រោះដូច្នោះ ទើបលោកពោលថា **វិទិតា** ទ្រង់ដឹងច្បាស់ហើយ ពាក្យដ៏សេសក្នុងទីទាំងពួងងាយយល់ហើយ ។

**អដ្ឋកថា អច្ឆរិយព្ភូតធម្មសូត្រ ចប់**
**សូត្រទី ៣ ចប់**

# សុត្តន្តបិដក

## ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រទី ៤

[ ៤៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះពក្កុលៈមានអាយុ នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង អចេលក៏ឈ្មោះកស្សប ជាសម្លាញ់របស់ព្រះពក្កុលៈមានអាយុ ក្នុងកាលនៅជាគ្រហស្ថពីដើម បានចូលទៅរកព្រះពក្កុលៈមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយពាក្យរាក់ទាក់សំណេះសំណាល ទៅរកព្រះពក្កុលៈមានអាយុ លុះបញ្ចប់ពាក្យសំណេះសំណាល និងពាក្យដែលគួររឭកហើយ ទើបអង្គុយក្នុងទីសមគួរ ។ លុះអចេលកស្សបអង្គុយ ក្នុងទីសមគួរហើយ ក៏សួរព្រះពក្កុលៈមានអាយុដូច្នេះថា បពិត្រព្រះពក្កុលៈមានអាយុ លោកម្ចាស់បួសយូរប៉ុន្មានឆ្នាំហើយ ។ ព្រះពក្កុលៈឆ្លើយថា អាត្មាបួស ៨០ វស្សាហើយ ។ អចេលកស្សបសួរទៀតថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ លោកសេពមេថុនប៉ុន្មានដង ។

[ ៤៩ ] ម្នាលអាវុសោកស្សប អ្នកកុំសួរអាត្មាថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ លោកសេពមេថុនធម្មប៉ុន្មានដង យ៉ាងនេះឡើយ ម្នាលអាវុសោកស្សប អ្នកត្រូវសួរអាត្មាថា បពិត្រព្រះពក្កុលៈមានអាយុ ចុះ ៨០ វស្សានេះ កាមសញ្ញារបស់លោកធ្លាប់កើតប៉ុន្មានដង យ៉ាងនេះវិញ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានកាមសញ្ញាកើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានកាមសញ្ញា

កើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានព្យាបាទសញ្ញា ... មិនដែលមានវិហឹសាសញ្ញា កើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានវិហឹសាសញ្ញាកើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

[ ៥០ ] ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានកាមវិតក្ក កើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានកាមវិតក្កកើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែលមានព្យាបាទវិតក្ក ... មិនដែលមានវិហឹសាវិតក្ក កើតឡើងទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលមានវិហឹសាវិតក្ក កើតឡើងអស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

[ ៥១ ] ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនធ្លាប់ត្រេកអរនឹងគហបតិចីវរទេ ។ ព្រះពក្កុលៈមានអាយុ មិនធ្លាប់ត្រេកអរនឹងគហបតិចីវរ អស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចំណាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនធ្លាប់កាត់ចីវរ ដោយកាំបិត

ទេ ... អាត្មាមិនធ្លាប់ដេរចីវរដោយម្ជុលទេ ... មិនធ្លាប់ជ្រលក់ចីវរ ដោយគ្រឿងជ្រលក់ទេ ... មិនធ្លាប់ដេរចីវរលើឈើស្ពឹងទេ ... មិនធ្លាប់ចាត់ចែងចីវរកម្ម របស់សព្រហ្មចារីបុគ្គលទាំងឡាយទេ ... មិនធ្លាប់ត្រេកអរនឹងការនិមន្តន៍ទេ ... មិនធ្លាប់មានគំនិតកើតឡើងថា ធ្វើដូចម្តេចហ្ន៎ បុគ្គលណាមួយគប្បីមកនិមន្តអញទេ ។បេ។ អាត្មាមិនដែលអង្គុយក្នុងចន្លោះផ្ទះទេ ... មិនដែលឆាន់ក្នុងចន្លោះផ្ទះទេ ... មិនដែលកាន់យកនិមិត្ត របស់មាតុគ្រាមដោយអនុព្យញ្ជនៈទេ ... មិនដែលសម្តែងធម៌ដល់មាតុគ្រាម ដោយហោចទៅសូម្បីត្រឹមតែគាថា ៤ បទទេ ... មិនដែលចូលទៅកាន់សម្នាក់ភិក្ខុនីទេ ... មិនដែលសម្តែងធម៌ដល់ភិក្ខុនីទេ ... មិនដែលសម្តែងធម៌ ដល់សិក្ខមានាទេ ... មិនដែលសម្តែងធម៌ ដល់សាមណេរីទេ ... មិនដែលបំបួសទេ ... មិនដែលឲ្យឧបសម្បទាទេ ... មិនដែលឲ្យនិស្ស័យទេ ... មិនដែលឲ្យសាមណេរបម្រើទេ ... មិនដែលស្រពកាយ ក្នុងផ្ទះសម្រាប់កម្តៅកាយទេ ... មិនដែលស្រពកាយ ដោយគ្រឿងលម្អិតទេ ... មិនដែលត្រេកអរនូវការគក់ច្របាច់ខ្លួនរបស់សព្រហ្មចារីបុគ្គលទេ ... មិនដែលមានអាពាធកើតឡើង ដោយហោចទៅសូម្បីតែដំណួចពិសទេ ... មិនដែលថែរក្សាថ្នាំទុក ដោយហោចទៅ សូម្បីតែចំណិតផ្លែសម៉ទេ ... មិនដែលផ្អែកបង្អែកទេ ... មិនដែលដេកទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលដេក អស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌របស់ព្រះពក្កុលៈមានអាយុ ។

[ ៥២ ] ម្នាលអាវុសោ អាត្មាបួស ៨០ វស្សាហើយ អាត្មាមិនដែល

ចូលវស្សា ក្នុងទីសេនាសនៈ ក្នុងស្រុកទេ ។ ព្រះពក្កុលៈមានអាយុ មិនដែលចូលវស្សាក្នុងទីសេនាសនៈ ក្នុងស្រុក អស់ ៨០ វស្សាហើយ ដោយហេតុណា យើងខ្ញុំចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។ ម្នាលអាវុសោ អាត្មាប្រកបដោយកិលេស ឆាន់បិណ្ឌបាតរបស់អ្នកដែនតែ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ អរហត្តផលក៏កើតឡើង ។ ព្រះពក្កុលៈមានអាយុ ប្រកបដោយកិលេសឆាន់បិណ្ឌបាតរបស់អ្នកដែនតែ ៧ ថ្ងៃ លុះដល់ថ្ងៃទី ៨ អរហត្តផលក៏កើតឡើង ដោយហេតុណា យើងខ្ញុំចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

[ ៥៣ ] បពិត្រព្រះពក្កុលៈមានអាយុ ខ្ញុំគប្បីបាននូវបព្វជ្ជា គប្បីបាននូវឧបសម្បទា ក្នុងធម្មវិន័យនេះ ។ អចេលកស្សប ក៏បាននូវបព្វជ្ជា បាននូវឧបសម្បទា ក្នុងធម្មវិន័យនេះ ។ លុះព្រះកស្សបមានអាយុ បានឧបសម្បទាមិនយូរប៉ុន្មានក៏ចៀសចេញទៅតែម្នាក់ឯង ជាអ្នកមិនប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន កុលបុត្រទាំងឡាយចេញចាកផ្ទះ ទៅបួសក្នុងផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា ក៏បានធ្វើឲ្យជាក់ច្បាស់ នូវអនុត្តរធម៌នោះ ដែលជាទីបំផុតនៃព្រហ្មចរិយៈ ដោយប្រាជ្ញាដ៏ឧត្តម ចំពោះខ្លួនឯងក្នុងបច្ចុប្បន្ន ហើយសម្រាន្តនៅដោយឥរិយាបថទាំង ៤ រមែងដឹងថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបាននៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បណ្តាព្រះអរហន្ត

ទាំងឡាយ ព្រះកស្សបមានអាយុ ក៏ជាព្រះអរហន្ត ១ រូបដែរ ។

[ ៥៤ ] លុះសម័យជាខាងក្រោយមក ព្រះពក្កុលៈមានអាយុ កាន់យកកូនសោ ចេញអំពីវិហារ ចូលទៅកាន់វិហារ ហើយពោលពាក្យយ៉ាងនេះថា សូមលោកមានអាយុទាំងឡាយ ថយចេញទៅសិន សូមលោកមានអាយុទាំងឡាយ ថយចេញទៅសិន ខ្ញុំនឹងបរិនិព្វានក្នុងថ្ងៃនេះ ។ ព្រះកស្សបពោលថា ព្រះពក្កុលៈមានអាយុ បានកាន់យកកូនសោ ចេញអំពីវិហារ ចូលទៅកាន់វិហារ ហើយពោលយ៉ាងនេះថា សូមលោកមានអាយុទាំងឡាយ ថយចេញទៅសិន សូមលោកមានអាយុទាំងឡាយ ថយចេញទៅសិន ខ្ញុំនឹងបរិនិព្វានក្នុងថ្ងៃនេះ ដោយហេតុណា ខ្ញុំចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

[ ៥៥ ] ឯព្រះពក្កុលៈមានអាយុ អង្គុយបរិនិព្វាន ក្នុងទីកណ្តាលភិក្ខុសង្ឃ ។ ព្រះពក្កុលៈមានអាយុ អង្គុយបរិនិព្វាន ក្នុងទីកណ្តាលភិក្ខុសង្ឃ ដោយហេតុណា ខ្ញុំក៏ចាំទុកនូវហេតុនេះ ថាជាអច្ឆរិយព្ភូតធម៌ របស់ព្រះពក្កុលៈមានអាយុ ។

## ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រទី ៤ ចប់

# អដ្ឋកថា

## ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ

[ ៤៨-៤៩ ] ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ពក្កុលោ** មានអធិប្បាយថា ប្រៀបដូចកាលគួរពោលពាក្យជាដើមថា **ទ្វាវីសតិ ទ្វត្តឹស** មនុស្សទាំងឡាយត្រឡប់ពោលថា **ពាវីសតិ ពត្តឹស** ដូច្នេះជាដើម យ៉ាងណា បទនេះក៏ដូច្នោះដូចគ្នា គឺកាលគួរពោលថា **ទ្វិក្កុលោ** ឬ **ទ្វក្កុលោ** បែរជាពោលថា **ពក្កុលោ** ដូច្នេះ ព្រះថេរៈ មានត្រកូលដល់ទៅ ២ ត្រកូល ។

បានឮថា លោកចុតិអំពីទេវលោក កើតក្នុងត្រកូលមហាសេដ្ឋី ក្នុងនគរឈ្មោះកោសម្ពី ។ ក្នុងថ្ងៃទី ៥ ពួកកីលៀង បាននាំលោកទៅងូតទឹក ហើយចុះលេងក្នុងស្ទឹងគង្គា កាលពួកកីលៀងកំពុងឲ្យទារកលេងមុជងើប មុជហែលត្រីមួយឃើញទារកសម្គាល់ថាជាអាហារ ទើបពាំក្មេងទៅ ។ ពួកកីលៀងក៏បោលក្មេងគេចទៅ ត្រីលេបទារកហើយ ធម្មតាសត្វមានបុណ្យ មិនក្ដៅក្រហាយឡើយ ។ ទារកហាក់ដូចជាចូលទៅកាន់បន្ទប់ដេក ហើយដេកលក់ទៅ ។ ដោយតេជះនៃទារក ត្រីមានសភាពដូចលេបអំបែងដែលក្ដៅចូលទៅត្រូវកម្ដៅដុតរោល មានកម្លាំងហែលទៅបានត្រឹមតែ ៣០ យោជន៍ ហើយចូលទៅជាប់សំណាញ់របស់អ្នកប្រមង់ អ្នកក្រុងពារាណសី ធម្មតាត្រីធំដែលជាប់សំណាញ់ កាលត្រូវនាំទៅ ទើបស្លាប់ តែតេជះនៃទារក ត្រីនេះ គ្រាន់តែនាំចេញអំពីសំណាញ់ក៏ស្លាប់ភ្លាម ។ ធម្មតាអ្នកនេសាទបានត្រីធំៗ ហើយ

រមែងវះបែងចែកជាចំណែក ហើយលក់ តែដោយអានុភាពរបស់ក្មេង អ្នកប្រមង់មិនពុះត្រីនោះ ប្រើដងរែករែកទៅទាំងមូល ស្រែកប្រកាសក្នុងទីក្រុងថា នឹងលក់តម្លៃ ១០០០ បុគ្គលណាម្នាក់ក៏មិនទិញ ។

ក្នុងក្រុងនោះ មានត្រកូលសេដ្ឋី មានសម្បត្តិ ៨០ កោដិ ជាត្រកូលមិនមានបុត្រ កាលដល់ទ្វារផ្ទះសេដ្ឋីនោះ គេសួរថា តម្លៃដូចម្តេច ។ បែរជាឆ្លើយថា តម្លៃមួយកហាបណៈ ។ គាត់ឲ្យប្រាក់មួយកហាបណៈហើយទិញ ។ កិរិយារបស់លោកសេដ្ឋី ក្នុងថ្ងៃដទៃៗ មិនចូលចិត្តធ្វើត្រី តែថ្ងៃនោះ ដាក់ត្រីលើជ្រញ់ ចាប់ផ្តើមវះឯងនោះឯង ។ ធម្មតាត្រីត្រូវវះត្រង់ពោះ តែនាងវះខាងខ្នង ឃើញទារកមានសម្បុរដូចមាសក្នុងពោះត្រី ក៏បន្លឺកគ្នាថា ខ្ញុំបានកូនក្នុងពោះត្រីហើយ ពរទារកទៅកាន់សម្នាក់របស់ស្វាមី លោកសេដ្ឋីឲ្យវាយស្គរប្រកាស ដំណឹងទូទៅក្នុងវេលានោះឯង ហើយពរទារកទៅកាន់រាជដំណាក់ ក្រាបទូលថា បពិត្រព្រះករុណា ទូលបង្គំបានទារកក្នុងពោះត្រី ទូលបង្គំនឹងធ្វើដូចម្តេច ។ ព្រះរាជាត្រាស់ថា ទារកដែលនៅក្នុងពោះត្រីបានដោយមិនមានគ្រោះថ្នាក់ នេះជាមនុស្សមានបុណ្យ លោកចូរចិញ្ចឹមចុះ ។ ត្រកូលម្តាយបង្កើតបានដំណឹងថា ក្នុងនគរពារាណសី មានត្រកូលមួយរើសបានទារកក្នុងពោះត្រី ។ ទើបពួកគាត់នាំគ្នាទៅកាន់ក្រុងនោះ ខណៈនោះ មាតារបស់ទារកឃើញម្តាយចិញ្ចឹមកំពុងតែងខ្លួនទារក ហើយឲ្យលេង ទើបស្ទុះទៅពរដោយគិតថា កុមារនេះគួរស្រឡាញ់ពិតហ្ន៎ ហើយនិទានរឿងរ៉ាវប្រាប់គ្រប់ប្រការ ។ ស្ត្រីអ្នករើសនិយាយថា កុមារនេះជាកូនរបស់ខ្ញុំ ស្រីម្តាយបង្កើត

សួរថា នាងបានអំពីណា ស្រីម្ដាយចិញ្ចឹមពោលថា ខ្ញុំបានក្នុងពោះត្រី ស្រីម្ដាយបង្កើតពោលថា ក្មេងនេះមិនមែនកូនរបស់នាងទេ ជាកូនរបស់ខ្ញុំ ។ ស្រីអ្នករើសបានសួរថា នាងបានក្នុងទីណា ស្រីនោះប្រាប់ថា ខ្ញុំពរផ្ទៃទារកនេះមកអស់ ១០ ខែ គ្រានោះ ត្រីបានលេបក្មេងដែលពួកកីលៀងកំពុងឲ្យលេងទឹក ។ ស្រីនោះជំទាស់ថា កូនរបស់នាងប្រហែលត្រីដទៃលេបទេ តែក្មេងនេះ ខ្ញុំបានក្នុងពោះត្រី ទើបជនទាំង ២ នាំគ្នាទៅកាន់រាជដំណាក់ ។

ព្រះរាជាត្រាស់ថា ស្រីទាំងនេះ បុគ្គលណាម្នាក់ មិនអាចបដិសេធបានថា មិនមែនជាម្ដាយ ព្រោះមានផ្ទៃពោះមកអស់ ១០ ខែ សូម្បីពួកអ្នកប្រមង់ដែលចាប់ត្រីបាន ក៏ធ្វើការលក់ដូរជាដើម សព្វគ្រប់ទៅហើយ ទើបអស់សិទ្ធិ ព្រោះដូច្នោះ សូម្បីស្រីនេះក៏បដិសេធមិនបានថា មិនមែនជាមាតា ព្រោះបានក្មេងនេះក្នុងពោះត្រី សូមឲ្យទាំង ២ ភាគីចិញ្ចឹមក្មេងរួមគ្នាចុះ ។ ត្រកូលទាំង ២ ក៏ចិញ្ចឹមក្មេងរួមគ្នាហើយ កាលទារកចម្រើនវ័យហើយ ទាំង ២ ត្រកូលក៏បានឲ្យគេសាងប្រាសាទក្នុងព្រះនគរទាំង ២ ហើយឲ្យបម្រើដោយពួកស្រីរបាំ កុលបុត្រនៅក្នុងនគរមួយ ៤ ខែ ។ កាលនៅក្នុងនគរមួយគ្រប់ ៤ ខែហើយ ត្រកូលទាំង ២ ឲ្យជាងសាងមណ្ឌបក្នុងទូកដែលតជាផែជាប់គ្នា ហើយឲ្យចូលនៅក្នុងទូកនោះ មួយអន្លើដោយអ្នករបាំទាំងឡាយ គេសោយសម្បត្តិរីករាយ ធ្វើដំណើរទៅក្រុងមួយទៀត ស្រីរបាំអ្នកនគរបានបញ្ជូនកុលបុត្រនោះបានពាក់កណ្ដាលផ្លូវ ស្រីនគរមួយទៀត មកទទួលហែហមនាំទៅកាន់ប្រាសាទរបស់ខ្លួន ។ ស្រីនគរមួយក៏នាំគ្នាត្រឡប់មកនគររបស់

ខ្លួនវិញ ។ កុលបុត្រនោះ នៅក្នុងប្រាសាទអស់ ៤ ខែ ហើយធ្វើដំណើរ ត្រឡប់ទៅកាន់នគរមួយទៀត ដោយទំនងនេះឯង ។ កុលបុត្រនោះសោយសម្បត្តិយ៉ាងនេះគ្រប់ ៨០ ឆ្នាំបរិបូណ៌ ព្រះមានព្រះភាគ ទ្រង់ចារិកទៅដល់នគរពារាណសីហើយ ។ កុលបុត្រនោះស្តាប់ធម៌ក្នុងសម្នាក់ព្រះមានព្រះភាគ កើតសទ្ធា បួសហើយ នៅជាបុថុជ្ជនត្រឹម ៧ ថ្ងៃប៉ុណ្ណោះ ថ្ងៃទី ៨ បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ។ ត្រកូលទាំង ២ ទាក់ទងជាមួយលោកយ៉ាងនេះ ព្រោះដូច្នោះ ទើបលោកបានឈ្មោះថា ពក្កុលៈ ។

បទថា **បុរាណគិហិសហាយោ** ប្រែថា ធ្លាប់ជាសម្លាញ់នឹងគ្នាមកក្នុងវេលាជាគ្រហស្ថ ។ សូម្បីបរិព្វាជកឈ្មោះអចេលកស្សបនេះ ក៏មានអាយុវែងដូចគ្នា កាលទៅសួរសុខទុក្ខព្រះថេរៈដែលបួសហើយ បានទៅក្នុងឆ្នាំទី ៨០ ។ បទថា **មេថុនោ ធម្មោ** សេចក្តីថា បុគ្គលល្ងង់ដែលនៅក្នុងពួកសមណអាក្រាតសួរទៅដោយបែបល្ងង់ មិនបានសួរដោយប្រើវាចាអាស្រ័យសាសនវោហារ ។ គេតាំងនៅក្នុងន័យដែលព្រះថេរៈឲ្យហើយក្នុងឥឡូវនេះ ទើបសួរដោយពាក្យថា **ឥមេហិ បន តេ** ដូច្នេះជាដើម ។ ព្រះធម្ម-សង្គាហកត្ថេរទាំងឡាយកំណត់បទទាំងឡាយថា **យម្បាយស្មា** ដូច្នេះជាដើមតាំងទុកហើយ ក្នុង **សត្តវារ** ទាំងឡាយ ក្នុង **សត្តវារ** ទាំងនោះ សញ្ញាគ្រាន់តែកើតឡើងហើយប៉ុណ្ណោះ វិតក្កក៏ទម្លាយកម្មបថ ព្រោះដូច្នោះ ទើបព្រះថេរៈពោលថា លោកទាំងឡាយបែកអំពីគ្នាធ្វើអ្វី ទាំង ២ យ៉ាងនេះ សុទ្ធតែធ្វើកម្មបថឲ្យបែកទាំងអស់ ។

[ ៥១ ] បទថា **គហបតិចីវរំ** បានដល់ ចីវររបស់ភិក្ខុដែលនៅចាំវស្សា ។ បទថា **សត្ថេន** បានដល់ កន្ត្រៃ ។ បទថា **សូចិយា** អធិប្បាយថា ខ្ញុំមិនរឭកដល់ការដែលចីវរត្រូវដេរដោយម្ជុល ។ បទថា **កឋិនេ ចីវរំ** បានដល់ កឋិនចីវរ ។ ឯកឋិនចីវរមានគតិដូចគ្នានឹងសំពត់ចំណាំវស្សាប៉ុណ្ណោះ ព្រោះដូច្នោះ ក្នុងកឋិនចីវរនោះ ទើបលោកពោលថា **សិព្វេតា ។បេ។ នាភិជានាមិ** ដូច្នេះ ។

កាលព្រះពក្កុលត្ថេរនោះ មិនត្រេកអរក្នុងគហបតិចីវរ មិនធ្វើនវកម្មមានការកាត់ និងការដេរជាដើម អស់កាលមានប្រមាណប៉ុណ្ណោះ ចីវរកើតឡើងអំពីណា ។

ឆ្លើយថា កើតអំពីនគរទាំង ២ ព្រះថេរៈមានយសធំក្រៃលែង ។ កូនប្រុសស្រី ក្មួយ ចៅរបស់លោក ឲ្យមនុស្សធ្វើចីវរ ដោយសំពត់សាដកសាច់ម៉ដ្ឋ ឲ្យជ្រលក់ ហើយដាក់ក្នុងប្រអប់ បញ្ជូនទៅប្រគេន ។ ក្នុងវេលាដែលព្រះថេរៈស្រង់ទឹក គេដាក់ត្រង់ទ្វារបន្ទប់ទឹក ព្រះថេរៈស្លៀក និងដណ្តប់ចីវរទាំងនោះ ។ លោកឲ្យចីវរចាស់ដល់បព្វជិតទាំងឡាយដែលលោកជួប ។ ព្រះថេរៈស្លៀកដណ្តប់ចីវរទាំងនោះហើយ មិនចាំបាច់ធ្វើនវកម្ម ។ កិច្ចកម្មដែលត្រូវបង្រួបបង្រួមណាមួយក៏មិនមាន ។ លោកអង្គុយចូលផលសមាបត្តិកាលគ្រប់ ៨ ខែទៅហើយ រោមក៏ពុកផុយ គ្រានោះ កូនៗ ចៅៗ ក៏បញ្ជូនចីវរទៅប្រគេនលោកដោយទំនងនោះឯង ។ អាចារ្យពួកខ្លះពោលថា លោកផ្លាស់ប្តូរចីវររាល់កន្លះខែម្តង ។

ការដែលព្រះថេរៈមានបុណ្យច្រើន មានអភិញ្ញាច្រើន បំពេញបារមីមកអស់សែនកប្ប ផ្លាស់ប្តូរចីវររាល់កន្ទះខែម្តងនោះ ជារបស់មិនគួរអស្ចារ្យឡើយ ព្រះនិគ្រោធដែលនៅប្រចាំព្រះរាជសម្នាក់របស់ព្រះបាទអសោកធម្ម-រាជផ្លាស់ចីវរមួយថ្ងៃដល់ទៅ ៣ ដង ភ្នាក់ងារដាក់ចីវររបស់លោកលើ-កដំរី នាំមកប្រគេនអំពីព្រលឹម ព្រមទាំងប្រអប់ដាក់គ្រឿងក្រអូប ៥០០ ប្រអប់ដាក់ផ្កា ៥០០ ដល់ពេលថ្ងៃ និងពេលល្ងាច ក៏បដិបត្តិ ដូច្នោះ ។ បានឮថាព្រះរាជា កាលឲ្យលោកផ្លាស់សំពត់មួយថ្ងៃ ៣ ដង នឹងត្រាស់សួរថា ពួកលោកធ្វើចីវរទៅប្រគេនព្រះថេរៈហើយឬ លុះព្រះរាជាទ្រង់ឮថា នាំទៅប្រគេនហើយ ទើបព្រះអង្គឲ្យផ្លាស់ ។ ព្រះថេរៈក៏មិនចងចីវរជាបាច់ទុកឡើយ ។ បានប្រគេនដល់សព្រហ្មចារីដែលលោកជួបហើយ ។

បានឮថា ក្នុងគ្រានោះ ភិក្ខុសង្ឃក្នុងជម្ពូទ្វីបទាំងមូល ដោយច្រើន បានប្រើចីវរប្បច្ច័យដែលជារបស់ព្រះនិគ្រោធត្ថេរនោះ ។ ក្នុងបទថា **អហោ វត មំ កោចិ និមន្តេយ្យ** នេះ មានពាក្យសួរថា ហេតុអ្វី ការមិនឲ្យចិត្តកើតឡើងទើបជារបស់ធ្ងន់ និងចិត្តដែលកើតឡើងហើយ ក៏ត្រូវលះ ។

ឆ្លើយថា ដែលឈ្មោះថា ចិត្ត ជាធម្មជាតផ្លាស់ប្តូររហ័ស ព្រោះដូច្នោះការមិនឲ្យចិត្តកើតឡើង ទើបជារបស់ធ្ងន់ សូម្បីលះចិត្តដែលកើតឡើងហើយក៏ជារបស់ធ្ងន់ដូចគ្នា ។ បទថា **អន្តរឃរេ** សេចក្តីថា ក្នុងមហាសកុល-ទាយិសូត្រ តាំងអំពីធរណីទ្វារទៅ ហៅថា ផ្ទះ តែក្នុងទីនេះ បំណាងយកតាំងអំពីទីដែលទឹកស្រក់អំពីសំយាបផ្ទះ ។

សួរថា ចុះភិក្ខាកើតដល់លោកបានអំពីណា ឆ្លើយថា ព្រះថេរៈស្គាល់មនុស្សទាំង ២ នគរ គ្រាន់តែលោកមកដល់ទ្វារផ្ទះប៉ុណ្ណោះ មនុស្សនាំគ្នារត់មកទទួលបាត្រ ដាក់ភោជនដែលមានរសប្រណីតផ្សេងៗ ប្រគេន ។ លោកត្រឡប់អំពីទីដែលលោកបានទទួលអាហារហើយ ។ តែទីសម្រាប់លោកធ្វើភត្តកិច្ច មានប្រចាំនោះឯង ។ បទថា **អនុព្យញ្ជនសោ** សេចក្តីថា បានឮថា ព្រះថេរៈកាន់យកនិមិត្តក្នុងរូបហើយ មិនធ្លាប់សម្លឹងមើលមាតុគ្រាមឡើយ ។ បទថា **មាតុគាមស្ស ធម្មំ** សេចក្តីថា សម្តែងធម៌ដល់មាតុគ្រាមដោយវាចាត្រឹមតែ ៥-៦ ម៉ាត់ក៏គួរ តែបើគេសួរប្រស្នា ទោះឆ្លើយសូម្បីគាថា ១០០០ ក៏សមគួរពិត ។ ព្រះថេរៈមិនធ្លាប់ធ្វើវត្តដែលជាកប្បិយឲ្យជាអកប្បិយឡើយ ។ ពិតហើយ ការធ្វើនោះ ដោយច្រើន មានដល់ភិក្ខុដែលចូលកាន់ត្រកូល ។ បទថា **ភិក្ខុនុបស្សយំ** ប្រែថា សម្នាក់របស់ភិក្ខុនី ។ បុគ្គលដែលសួរសុខទុក្ខអ្នកជំងឺ ទោះទៅសម្នាក់ភិក្ខុនីនោះក៏គួរ ។ ព្រះថេរៈមិនធ្វើចំពោះវត្តដែលជាកប្បិយ ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ បទថា **ចុណ្ណេន** បានដល់លម្អិតនៃផ្កាប្រទៀងជាដើម ។ បណ្តាបទទាំងនោះ បទថា **បរិកម្មេ** បានដល់ធ្វើការគក់ខ្លួន ។ បទថា **សាធិតា** ប្រែថា ឲ្យប្រកបហើយ ។ បទថា **គទ្ទូហានមត្តំ** សេចក្តីថា សូម្បីមួយជួរខណៈចាប់ដោះគោ ហើយរឹតយកទឹកដោះ ត្រឹមមួយតំណក់ ។

ព្រះថេរៈ មិនធ្លាប់អាពាធដោយហេតុណាមួយឡើយ បានឮថា កាលព្រះមានព្រះភាគ ព្រះនាមថាបទុមុត្តរៈ មានភិក្ខុមួយសែនជាបរិវារ ស្តេច

ចារិកទៅ ដើមឈើមានជាតិពុលក្នុងព្រៃហិមពាន្តរីកហើយ ភិក្ខុទាំង ១ សែន ក៏អាពាធកើតរោគ ទាក់ទងដោយផ្កាស្មៅដែលពុល ។ ក្នុងសម័យនោះ ព្រះថេរៈជាតាបសអ្នកមានឫទ្ធិ លោកហោះទៅឃើញភិក្ខុសង្ឃ ទើបចុះមកសួរដល់រោគដែលកើត ហើយនាំឱសថមកអំពីព្រៃហិមពាន្តថ្វាយ ។ គ្រាន់តែប៉ះថ្នាំប៉ុណ្ណោះ រោគក៏ស្ងប់ភ្លាម ។ សូម្បីក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ព្រះនាមថាកស្សប លោកឈប់ក្ខុរស្រែក្នុងថ្ងៃក្ខុរស្រែដំបូង ឲ្យសាងរោងភត្ត និងវច្ចកុដិ រៀបចំថ្នាំប្រគេនភិក្ខុសង្ឃជាប្រចាំ ដោយកម្មនេះ ទើបលោកជាអ្នកប្រាសចាកអាពាធ ។ និងព្រោះលោកសមាទានការអង្គុយជាវត្តយ៉ាងឧក្រិដ្ឋ និងការនៅព្រៃជាវត្តយ៉ាងឧក្រិដ្ឋ ដូច្នោះ ទើបលោកពោលពាក្យជាដើមថា **នាភិជានាមិ អបស្សយិតា** ។

[ ៥២ ] បទថា **សរណោ** ប្រែថា នៅមានកិលេស ។ បទថា **អញ្ញា ឧទបាទិ** សេចក្តីថា មិនគួរព្យាករអរហត្តដល់អនុបសម្បន្ន ។ សួរថា ព្រោះហេតុអ្វី ទើបព្រះថេរៈបានព្យាករ ឆ្លើយថា ព្រះថេរៈមិនបានពោលថា ខ្ញុំជាព្រះអរហន្ត តែពោលថា អរហត្តផលកើតឡើងហើយ ម្យ៉ាងទៀត ប្រាកដថា ព្រះថេរៈបានជាព្រះអរហន្តហើយ ព្រោះដូច្នោះ ទើបលោកពោលយ៉ាងនេះ ។

[ ៥៣ ] បទថា **បព្វជ្ជំ** សេចក្តីថា ព្រះថេរៈមិនបានឲ្យបរិព្វាជកឈ្មោះអចេលកស្សបបព្វជ្ជា និងឧបសម្បទាដោយខ្លួនឯងឡើយ តែឲ្យភិក្ខុដទៃបំបួស ។ បទថា **អបាបុរណំ អាទាយ** ប្រែថា កាន់ត្រដោកទ្វារ ។ បទថា **និសិន្នកោវ បរិនិព្វាយិ** សេចក្តីថា ព្រះថេរៈត្រិះរិះថា សូម្បីអញមានជីវិត

នៅ កុំបានជាភារៈដល់ភិក្ខុដទៃឡើយ សរីរៈនៃអាត្មាអញ ក្រោយពីបរិនិព្វាន ហើយ កុំឲ្យភិក្ខុសង្ឃកើតកង្វល់ឡើយ ទើបចូលតេជោធាតុបរិនិព្វាន ហើយ អណ្តាតភ្លើងឆេះឡើងពេញសរីរៈ ។ ស្បែក សាច់ និងឈាម ត្រូវឆេះអស់ទៅ ដូចសប្បិដែលឆេះ នៅសល់តែព្រះធាតុដែលមានលក្ខណៈដូចផ្កាម្លិះក្រពុំ ។ ពាក្យដ៏សេសក្នុងបទទាំងពួង ជាក់ច្បាស់ហើយ ។ ឯសូត្រនេះលោកសង្គ្រោះ ចូលក្នុងទុតិយសង្គហវារៈ ។៚

## អដ្ឋកថា ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ ចប់
## សូត្រទី ៤ ចប់

# សុត្តន្តបិដក

## ទន្តភូមិសូត្រទី ៥

[ ៥៦ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះ សមណុទ្ទេស ឈ្មោះអចិរវតៈ នៅក្នុងកុដិជិតព្រៃ ។ គ្រានោះឯង រាជកុមារព្រះនាមជយសេន ស្តេចយាងទៅមកៗ ដើម្បីសម្រួលព្រះជង្ឃា បានចូលទៅរកអចិរវតសមណុទ្ទេស លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលទៅរកអចិរវតសមណុទ្ទេស លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីសមគួរ ។

[ ៥៧ ] លុះជយសេនរាជកុមារ គង់ក្នុងទីសមគួរហើយ បានពោលនឹងអចិរវតសមណុទ្ទេស ដូច្នេះថា បពិត្រអគ្គិវេស្សនៈដ៏ចម្រើន ខ្ញុំបានឮមកថា ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រហែសធ្វេស មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន គប្បីបាននូវចិត្តជាឯកគ្គតា ( ចិត្តដែលមានអារម្មណ៍តែមួយ ) មែនឬ ។ អចិរវតសមណុទ្ទេសតបថា ថ្វាយព្រះពរព្រះរាជកុមារ ការណ៍នុ៎ះយ៉ាងហ្នឹងហើយ ថ្វាយព្រះពរព្រះរាជកុមារ ការណ៍នុ៎ះ យ៉ាងហ្នឹងហើយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រហែសធ្វេស មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន គប្បីបាននូវចិត្តជាឯកគ្គតាមែន ។ ជយសេនរាជកុមារតបថា ខ្ញុំសូមអង្វរ សូមអគ្គិវេស្សនៈដ៏ចម្រើន សម្តែងធម៌តាមទំនងដែលលោកបានស្តាប់ បានរៀនមក ប្រាប់ខ្ញុំផង ។

[ ៥៨ ] អចិរវតសមណុទ្ទេសពោលថា ថ្វាយព្រះពរព្រះរាជកុមារ អាត្មាភាព មិនអាចនឹងសម្តែងធម៌ តាមទំនង ដែលបានស្តាប់ បានរៀនមក ថ្វាយទ្រង់បានទេ ទោះបីអាត្មាភាព សម្តែងធម៌តាមទំនង ដែលបានស្តាប់ បានរៀនមកថ្វាយទ្រង់ ក៏ទ្រង់យល់នូវសេចក្តីនៃភាសិត របស់អាត្មាភាពពុំបាន អាត្មាភាពមុខជានឹងមានសេចក្តីលំបាកនោះ អាត្មាភាព មុខជានឹងមានសេចក្តីនឿយហត់នោះ ( ឥតអំពើ ) ។ សូមអគ្គិវេស្សនៈដ៏ចម្រើន សម្តែងធម៌ តាមទំនងដែលបានស្តាប់ បានរៀនមកប្រាប់ខ្ញុំ ហើយធ្វើដូចម្តេច ឲ្យខាងតែខ្ញុំបាន យល់សេចក្តីនៃភាសិត របស់អគ្គិវេស្សនៈដ៏ចម្រើនផង ។ បពិត្រព្រះរាជ-កុមារ អាត្មាភាពសូមសម្តែងធម៌តាមទំនង ដែលបានស្តាប់ បានរៀនមក ថ្វាយទ្រង់ ប្រសិនបើទ្រង់យល់សេចក្តីនៃភាសិតរបស់អាត្មាភាព ការយល់នុ៎ះ ជាការប្រពៃ តែបើទ្រង់មិនយល់សេចក្តីនៃភាសិតរបស់អាត្មាភាពទេ សូមទ្រង់ឋិតនៅក្នុងការមិនយល់របស់ទ្រង់ដដែលចុះ ទ្រង់មិនគប្បីត្រឡប់សួរ អាត្មាភាព ក្នុងសេចក្តីនោះតទៅទៀតឡើយ ។ សូមអគ្គិវេស្សនៈដ៏ចម្រើន សម្តែងធម៌ តាមទំនង ដែលលោកបានស្តាប់ បានរៀនមក ប្រាប់ខ្ញុំចុះ បើខ្ញុំយល់សេចក្តីនៃភាសិតរបស់អគ្គិវេស្សនៈដ៏ចម្រើន ការដែលយល់នុ៎ះ ជាការប្រពៃ តែបើខ្ញុំមិនយល់សេចក្តីនៃភាសិត របស់អគ្គិវេស្សនៈដ៏ចម្រើនទេ ខ្ញុំនឹងឋិតនៅក្នុងការមិនយល់របស់ខ្លួនដដែល ខ្ញុំមិនត្រឡប់សួរអគ្គិវេស្សនៈដ៏ចម្រើនក្នុងសេចក្តីនោះ តទៅទៀតទេ ។

[ ៥៩ ] លំដាប់នោះ អចិរវតសមណុទ្ទេស ក៏សម្តែងធម៌តាមទំនង

ដែលបានស្តាប់ បានរៀនមក ថ្វាយជយសេនរាជកុមារ ។ កាលបើអចិរវតសមណុទ្ទេស សម្តែងដូច្នោះហើយ ជយសេនរាជកុមារ ក៏ពោលនឹងអចិរវតសមណុទ្ទេស ដូច្នេះថា បពិត្រអគ្គិវេស្សនៈដ៏ចម្រើន ត្រង់ដែលថា ភិក្ខុជាអ្នកមិនប្រហែសធ្វេស មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅរកព្រះនិព្វាន គប្បីបាននូវចិត្ត ជាឯកគ្គតា នុ៎ះមិនទំនង មិនមែនជាឱកាសទេ ។ លុះជយសេនរាជកុមារ ប្រកាសនូវហេតុដែលមិនមែនជាទំនង មិនមែនជាឱកាសរបស់អចិរវតសមណុទ្ទេសហើយ ក៏ក្រោកអំពីអាសនៈស្តេចចេញទៅ ។ កាលដែលជយសេនរាជកុមារ ស្តេចចេញទៅមិនយូរប៉ុន្មាន អចិរវតសមណុទ្ទេសក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះមានព្រះភាគ អង្គុយក្នុងទីសមគួរ ។ លុះអចិរវតសមណុទ្ទេសអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបទូលពាក្យចរចា ដែលខ្លួននិយាយនឹងជយសេនរាជកុមារនោះចំពោះព្រះមានព្រះភាគ ដោយសព្វគ្រប់ ។

[ ៦០ ] កាលអចិរវតសមណុទ្ទេស ក្រាបបង្គំទូលយ៉ាងនេះហើយព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងអចិរវតសមណុទ្ទេសដូច្នេះថា ម្នាលអគ្គិវេស្សនៈគុណជាតណាដែលបុគ្គលគប្បីដឹងដោយនេក្ខម្មៈ គប្បីឃើញដោយនេក្ខម្មៈ គប្បីដល់ដោយនេក្ខម្មៈ គប្បីធ្វើឲ្យជាក់ច្បាស់ដោយនេក្ខម្មៈ តើជយសេនរាជកុមារនឹងបាននូវគុណជាតនោះអំពីទីណា ក្នុងអត្តភាពនេះ ព្រោះថាជយសេនរាជកុមារ កំពុងនៅក្នុងកណ្តាលកាម ដែលកាមវិតក្កកំពុងទំពាស៊ី កំពុងរោលរាលដោយសេចក្តីក្រហល់ក្រហាយព្រោះកាម ជាអ្នកខ្វល់ខ្វាយដើម្បីស្វែងរកកាម

នឹងដឹង នឹងយល់ នឹងធ្វើឲ្យជាក់ច្បាស់នូវគុណជាតនោះ ដូចម្តេចកើត ពាក្យដូច្នេះនេះ មិនសមហេតុទេ ។

[ ៦១ ] ម្នាលអគ្គិវេស្សនៈ ដូចសត្វពាហនៈ ២ ពួក គឺដំរីគួរទូន្មាន សេះគួរទូន្មាន ឬគោគួរទូន្មាន ដែលគេកំពុងទូន្មានជិតបានល្អ ១ ដែលគេទូន្មានបានល្អហើយ ១ ។ សត្វពាហនៈ ២ ពួក គឺដំរីគួរទូន្មាន សេះគួរទូន្មាន ឬគោគួរទូន្មាន ដែលគេមិនទាន់ទូន្មាននៅឡើយ ១ ដែលគេទូន្មានមិនទាន់បាន ១ ។ ម្នាលអគ្គិវេស្សនៈ អ្នកយល់សេចក្តីនោះដូចម្តេច សត្វពាហនៈ ២ ពួកណា គឺដំរីគួរទូន្មាន សេះគួរទូន្មាន ឬគោគួរទូន្មាន ដែលគេកំពុងទូន្មានជិតបានល្អ ១ ទូន្មានបានល្អហើយ ១ ចុះពួកសត្វដែលគេកំពុងទូន្មាននោះ តើនឹងលុះតាមដំបូន្មានដែរឬ កាលបើទូន្មានហើយ តើនឹងដល់ថ្នាក់ ដែលគេធ្លាប់ទូន្មានដែរឬទេ ។ សូមទ្រង់ព្រះមេត្តាប្រោស យ៉ាងហ្នឹងហើយ ។ សត្វពាហនៈ ២ ពួកណា គឺដំរីគួរទូន្មាន សេះគួរទូន្មាន ឬគោគួរទូន្មាន ដែលគេមិនទាន់បានទូន្មាននៅឡើយ ១ ទូន្មានមិនទាន់បាន ១ ចុះសត្វពាហនៈដែលគេមិនទាន់បានទូន្មាននៅឡើយនោះ តើនឹងលុះតាមដំបូន្មានដែរឬ កាលបើមិនបានទូន្មានហើយ តើនឹងដល់ថ្នាក់ ដែលគេធ្លាប់ទូន្មាន ដូចសត្វពាហនៈ ២ ពួក គឺដំរីគួរទូន្មាន សេះគួរទូន្មាន ឬគោគួរទូន្មាន ដែលគេកំពុងទូន្មានជិតបានល្អ នឹងដែលគេទូន្មានបានល្អហើយនោះ ដែរឬទេ ។ សូមទ្រង់ព្រះមេត្តាប្រោស មិនដូច្នោះទេ ។ ម្នាលអគ្គិវេស្សនៈ សេចក្តីនេះមានឧបមេយ្យដូចជាជយសេនរាជកុមារ ដែលកំពុងនៅក្នុងកណ្តាលកាម កំពុងបរិភោគកាម ដែល

កាមវិតក្កកំពុងទំពាស៊ី កំពុងរោលរាលដោយសេចក្តីក្រហល់ក្រហាយព្រោះកាម ជាអ្នកខ្វល់ខ្វាយដើម្បីស្វែងរកកាម នឹងដឹង នឹងយល់ នឹងធ្វើឲ្យជាក់ច្បាស់នូវគុណជាត ដែលបុគ្គលគប្បីដឹងដោយនេក្ខម្មៈ គប្បីយល់ដោយនេក្ខម្មៈ គប្បីដល់ដោយនេក្ខម្មៈ គប្បីធ្វើឲ្យជាក់ច្បាស់ដោយនេក្ខម្មៈ ដូចម្តេចបាន ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។

[ ៦២ ] ម្នាលអគ្គិវេស្សនៈ ដូចភ្នំធំដែលនៅជិតស្រុក ឬនិគម ។ មានបុរស ២ នាក់ ជាសម្លាញ់នឹងគ្នា ចេញអំពីស្រុក ឬនិគមនោះ ដឹកដៃគ្នា ចូលទៅរកភ្នំនោះ លុះចូលទៅដល់ហើយ បុរសជាសម្លាញ់ម្នាក់ ឈរនៅទៀបជើងភ្នំខាងក្រោម បុរសជាសម្លាញ់ម្នាក់ ឡើងទៅខាងលើភ្នំ ។ បុរសជាសម្លាញ់ ដែលឈរក្បែរជើងភ្នំខាងក្រោមសួរសម្លាញ់ ដែលឈរលើភ្នំនោះយ៉ាងនេះថា នែសម្លាញ់ ដែលសម្លាញ់ឯង ឈរលើកំពូលភ្នំ តើបានឃើញអ្វីដែរ ។ បុរសដែលឈរខាងលើភ្នំនោះ ប្រាប់យ៉ាងនេះថា ម្នាលសម្លាញ់ដែលខ្ញុំឈរលើកំពូលភ្នំ បានឃើញសួនច្បារជាទីត្រេកអរ ព្រៃជាទីត្រេកអរ ភូមិជាទីត្រេកអរ ស្រះបោក្ខរណីជាទីត្រេកអរ ។ បុរសជាសម្លាញ់ ដែលឈរទៀបជើងភ្នំនោះ និយាយយ៉ាងនេះថា ម្នាលសម្លាញ់ ដែលសម្លាញ់ឯងឈរលើកំពូលភ្នំ ហើយឃើញសួនច្បារ ជាទីត្រេកអរ ព្រៃ ជាទីត្រេកអរ ភូមិជាទីត្រេកអរ ស្រះបោក្ខរណីជាទីត្រេកអរ នុ៎ះមិនមែនសមហេតុ មិនមែនជាឱកាសទេ ។ បុរសជាសម្លាញ់ ដែលឈរលើភ្នំ ក៏ចុះមកនាជើងភ្នំខាងក្រោមនោះហើយ គៀកបុរសជាសម្លាញ់នោះ ដោយដើមដៃ នាំឡើងទៅលើ

ភ្នំ លួងលោមមួយស្របក់ ក៏សួរយ៉ាងនេះថា នែសម្លាញ់ ដែលសម្លាញ់ឯង ឈរលើភ្នំ បានឃើញអ្វីដែរ ។ បុរសដែលឈរ ទៀបជើងភ្នំនោះ និយាយ តបយ៉ាងនេះថា ម្នាលសម្លាញ់ ខ្ញុំឈរលើភ្នំ ឃើញសួនច្បារជាទីត្រេកអរ ព្រៃជាទីត្រេកអរ ភូមិជាទីត្រេកអរ ស្រះបោក្ខរណីជាទីត្រេកអរ ។ បុរស ដែលឈរលើភ្នំនោះ ពោលយ៉ាងនេះថា ម្នាលសម្លាញ់ ឥឡូវនេះ យើងដឹង ច្បាស់ នូវសម្ដីរបស់សម្លាញ់ឯងហើយ ( ដែលពោល ) យ៉ាងនេះថា ម្នាល សម្លាញ់ ដែលសម្លាញ់ឯងឈរលើភ្នំ ហើយឃើញសួនច្បារជាទីត្រេកអរ ព្រៃជាទីត្រេកអរ ភូមិជាទីត្រេកអរ ស្រះបោក្ខរណីជាទីត្រេកអរ នុ៎ះមិនមែន សមហេតុ មិនមែនជាឱកាសទេ ។ មួយទៀត ឥឡូវនេះ យើងដឹងច្បាស់នូវ សម្ដីរបស់សម្លាញ់ឯងហើយ ( ដែលពោល ) យ៉ាងនេះថា ម្នាលសម្លាញ់ ដែលខ្ញុំឈរលើភ្នំ ឃើញសួនច្បារជាទីត្រេកអរ ព្រៃជាទីត្រេកអរ ភូមិជាទី ត្រេកអរ ស្រះបោក្ខរណីជាទីត្រេកអរ ។ សម្លាញ់ដែលឈរទៀបជើងភ្នំនោះ និយាយយ៉ាងនេះថា ម្នាលសម្លាញ់ ពិតដូច្នោះមែនហើយ ខ្ញុំជាបុគ្គលត្រូវភ្នំធំ នេះបិទបាំង បានជាមិនឃើញនូវរបស់ដែលគួរឃើញ ។ ម្នាលអគ្គិវេស្សនៈ រឿងនេះមានឧបមាដូចម្ដេចមិញ មានឧបមេយ្យដូចជាជយសេនរាជកុមារ ត្រូវគំនរអវិជ្ជាដ៏ធំវិសេសក្រៃលែងជាងភ្នំនោះទៅទៀត គ្របសង្កត់ ដោតក្រង ចាក់ស្រែះ រួបរឹតហើយ ។ ជយសេនរាជកុមារ ដែលកំពុងនៅក្នុងកណ្ដាល កាម កំពុងបរិភោគកាម ដែលកាមវិតក្កកំពុងទំពាស៊ី កំពុងរោលរាលដោយ សេចក្ដីក្រហល់ក្រហាយព្រោះកាម ជាអ្នកខ្វល់ខ្វាយដើម្បីស្វែងរកកាម តើ នឹងដឹង នឹងយល់ នឹងធ្វើឲ្យជាក់ច្បាស់ នូវគុណជាតដែលបុគ្គលគប្បីដឹងដោយ

នេក្ខម្មៈ គប្បីឃើញដោយនេក្ខម្មៈ គប្បីដល់ដោយនេក្ខម្មៈ គប្បីធ្វើឲ្យជាក់ច្បាស់ដោយនេក្ខម្មៈ ដូចម្តេចបាន ពាក្យដូច្នេះនេះ មិនសមហេតុឡើយ ។ ម្នាលអគ្គិវេស្សនៈ ប្រសិនបើអ្នកបំភ្លឺសេចក្តីឧបមាទាំង ២ នេះ ដល់ជយសេនរាជកុមារនោះ ក៏ជាការអស្ចារ្យគ្រាន់បើរបស់អ្នកដែរ ជយសេនរាជកុមារមុខជាជ្រះថ្លា លុះជ្រះថ្លាហើយ មុខជាធ្វើនូវអាការនៃសេចក្តីជ្រះថ្លា ចំពោះអ្នកមិនខាន ។ បពិត្រព្រះអង្គដ៏ចម្រើន ឧបមាទាំងពីរជាទីអស្ចារ្យនេះ ខ្ញុំព្រះអង្គមិនធ្លាប់បានស្តាប់ពីមុនមកសោះ នឹងបំភ្លឺដល់ជយសេនរាជកុមារ ឲ្យដូចជាព្រះមានព្រះភាគ ដូចម្តេចបាន ។

[ ៦៣ ] ម្នាលអគ្គិវេស្សនៈ ដូចក្សត្រិយ៍ជាព្រះរាជា បានមុទ្ធាភិសេកហើយ ត្រាស់នឹងហ្មដំរីថា ម្នាលហ្មដំរីមានចិត្តស្មោះស្មើ ចូរអ្នកមកអាយ ចូរអ្នកឡើងជិះដំរីព្រះរាជទ្រព្យ ចូលទៅឯព្រៃដំរី លុះឃើញដំរីព្រៃច្បាស់លាស់ហើយ ចូរទាម កដំរីព្រះរាជទ្រព្យឲ្យមាំ ។ ម្នាលអគ្គិវេស្សនៈ ហ្មដំរីក៏ទទួលព្រះរាជឱង្ការនៃក្សត្រិយ៍ ជាព្រះរាជាបានមុទ្ធាភិសេកហើយថា ព្រះករុណាថ្លៃវិសេស ហើយក៏ឡើងជិះដំរីព្រះរាជទ្រព្យ ចូលទៅឯព្រៃដំរី ឃើញដំរីច្បាស់លាស់ហើយ ក៏ទាម កដំរីព្រះរាជទ្រព្យ យ៉ាងមាំ ។ ឯដំរីព្រះរាជទ្រព្យ ក៏កៀងដំរីព្រៃនោះទៅរកទីវាល ។ ម្នាលអគ្គិវេស្សនៈ ដោយហេតុប៉ុណ្ណោះឯងដំរីព្រៃក៏ទៅនៅក្នុងទីវាល ។ ម្នាលអគ្គិវេស្សនៈ ទោះបីដូច្នោះ ដំរីព្រៃក៏នៅតែមានចិត្តជាប់ចំពាក់ក្នុងព្រៃដំរីដដែល ។ ហ្មដំរីក៏បានក្រាបបង្គំទូលដំណើរនោះចំពោះក្សត្រិយ៍ ជាព្រះរាជាដែលបានមុទ្ធាភិសេកហើយថា បពិត្រព្រះសម្មតិ-

ទេព ដំរីព្រៃចេញទៅនៅក្នុងទីវាលហើយ ។ ក្សត្រិយ៍ជាព្រះរាជាដែលបាន មុទ្ធាភិសេកហើយ ក៏ទ្រង់ត្រាស់នឹងហ្មដំរីនោះថា ម្នាលហ្មដំរីមានចិត្តស្មោះស្មើ ចូរអ្នកមកអាយ ចូរអ្នកទូន្មានដំរីព្រៃ ចូរអ្នកទៅញ៉ាំញីនូវសណ្តាប់ធ្នាប់ របស់ពួកដំរីព្រៃផង ញ៉ាំញីនូវតម្រិះក្នុងការស្មុះទៅរបស់ពួកដំរីព្រៃផង ញ៉ាំញីនូវសេចក្តីក្រវល់ក្រវាយ សេចក្តីនឿយហត់ សេចក្តីក្តៅក្រហាយ របស់ពួកដំរីព្រៃផង ញ៉ាំងដំរីព្រៃឲ្យត្រេកអរ ចំពោះស្រុកផង ធ្វើឲ្យកាន់យកសណ្តាប់ធ្នាប់ ដែលជាទីត្រេកអររបស់មនុស្សផង ។ ម្នាលអគ្គិវេស្សនៈ ហ្មដំរីក៏ទទួលព្រះបន្ទូលរបស់ក្សត្រិយ៍ ជាព្រះរាជាដែលបានមុទ្ធាភិសេកហើយថា ព្រះករុណាថ្លៃវិសេស ហើយជីកជាំសសរយ៉ាងធំក្នុងផែនដី ចងក្រៀក-កដំរីព្រៃដើម្បីនឹងញ៉ាំញី នូវទម្លាប់របស់ពួកដំរីព្រៃផង ដើម្បីញ៉ាំញីនូវតម្រិះក្នុងការស្មុះទៅរបស់ពួកដំរីព្រៃផង ដើម្បីញ៉ាំញីនូវសេចក្តីក្រវល់ក្រវាយ សេចក្តីនឿយហត់ សេចក្តីក្តៅក្រហាយរបស់ពួកដំរីព្រៃផង ដើម្បីញ៉ាំងដំរីព្រៃឲ្យត្រេកអរចំពោះស្រុកផង ដើម្បីឲ្យកាន់យកសណ្តាប់ធ្នាប់ ដែលជាទីត្រេកអររបស់មនុស្សផង ។ ទម័កដំរី រមែងចរចាដោយវាចាដែលឥតទោស នាំឲ្យសុខដល់ត្រចៀក ជាទីស្រឡាញ់ គួរទុកក្នុងហឫទ័យ ជាវាចាអ្នកបុរី ជាទីត្រេកអរនៃជនច្រើនគ្នា ជាទីគាប់ចិត្ត នៃជនច្រើនគ្នាតែប៉ុណ្ណោះ ។ ម្នាលអគ្គិវេស្សនៈ កាលណាទម័កដំរីចរចា តែវាចាដែលឥតទោស នាំឲ្យសុខដល់ត្រចៀក ជាទីស្រឡាញ់ គួរទុកក្នុងហឫទ័យ ជាវាចាអ្នកបុរី ជាទីត្រេកអរនៃជនច្រើនគ្នា ជាទីគាប់ចិត្តនៃជនច្រើនគ្នាដូច្នោះ ដំរីព្រៃក៏ស្តាប់ដោយស្រួល ផ្ទៀងត្រចៀក តាំងចិត្តបាក

អារម្មណ៍ដទៃ ។ ទម័កដំរីបំប៉នស្មៅដែលដំរីគួរស៊ីបាន និងទឹកឲ្យដំរីនោះតទៅ ។ ម្នាលអគ្គិវេស្សនៈ បើដំរីព្រៃទទួលស្មៅដែលដំរីគួរស៊ីបាន និងទឹករបស់ទម័កដំរីកាលណា ។ កាលនោះ ទម័កដំរីក៏មានសេចក្តីត្រិះរិះថា ឥឡូវនេះ ដំរីព្រៃមុខជានឹងរស់មិនខាន ។ ទម័កដំរីក៏បង្ហាត់ដំរីនោះ តទៅទៀតថា នែដំរីដ៏ចម្រើន ចូរឯងកាន់ នែដំរីដ៏ចម្រើន ចូរឯងដាក់ ។ ម្នាលអគ្គិវេស្សនៈ បើដំរីព្រះរាជទ្រព្យធ្វើតាមពាក្យ ធ្វើតាមឱវាទរបស់ទម័កដំរី ក្នុងការកាន់យក និងការដាក់ហើយ ។ ទម័កដំរីក៏បង្ហាត់តទៅទៀតថា នែដំរីដ៏ចម្រើន ចូរឯងឈានទៅមុខ នែដំរីដ៏ចម្រើន ចូរឯងថយក្រោយ ។ ម្នាលអគ្គិវេស្សនៈ កាលណាបើដំរីព្រះរាជទ្រព្យធ្វើតាមពាក្យ ធ្វើតាមឱវាទរបស់ទម័កដំរី ក្នុងការឈានទៅមុខ និងការឈានថយក្រោយហើយ ។ ទម័កដំរីក៏បង្ហាត់ដំរីនោះ តទៅទៀតថា នែដំរីដ៏ចម្រើន ចូរឯងក្រោកឡើង នែដំរីដ៏ចម្រើន ចូរឯងទ្រោមចុះ ។ ម្នាលអគ្គិវេស្សនៈ កាលណាបើដំរីព្រះរាជទ្រព្យ ធ្វើតាមពាក្យ ធ្វើតាមឱវាទរបស់ទម័កដំរី ក្នុងការក្រោកឡើង និងការទ្រោមចុះហើយ ។ ទម័កដំរីក៏បង្ហាត់ដំរីនោះ ឲ្យជាសត្វមិនញាប់ញ័រតទៅទៀត ក៏យកក្តារយ៉ាងធំ ទៅចងក្រៀកនឹងប្រមោយដំរីនោះផង បុរសមានដៃកាន់លំពែងស្នែងក្របី ក៏អង្គុយលើកដំរីនោះផង បុរសមានដៃកាន់លំពែងស្នែងក្របី នាំគ្នាឈរព័ទ្ធដំរីនោះផង ទម័កដំរីកាន់ដងលំពែងស្នែងក្របីដ៏វែង ឈរចំពីខាងមុខដំរីនោះផង ។ ដំរីនោះកាលដែលទម័ក បង្ហាត់ឲ្យជាដំរីមិនញាប់ញ័រហើយ ក៏មិនកម្រើកជើងមុខ មិនកម្រើកជើងក្រោយ មិនកម្រើកកាយខាងមុខ មិនកម្រើកកាយខាងក្រោយ

មិនកម្រើកក្បាល មិនកម្រើកត្រចៀក មិនកម្រើកភ្លុក មិនកម្រើកកន្ទុយ មិនកម្រើកប្រមោយ ។ ដំរីព្រះរាជទ្រព្យនោះ ជាសត្វចេះអត់ទ្រាំ ចំពោះការប្រហារដោយលំពែង ការប្រហារដោយដាវ ការប្រហារដោយសរ និងការប្រហាររបស់សត្រូវឯទៀត និងសំឡេងរំពងនៃស្គរធំ ស្គរជ័យ ស័ង្ខ និងស្គរទ័ព ជាសត្វកម្ចាត់បង់នូវទោសវៀចគ្រប់យ៉ាង ជាសត្វអស់ពុតកំណាចហើយ គួរដល់ព្រះរាជា គួរជាទីប្រើប្រាស់របស់ព្រះរាជា ដល់នូវការរាប់បញ្ចូលថាជាអង្គរបស់ព្រះរាជាបាន សេចក្តីនេះ មានឧបមាដូចម្តេចមិញ ។

[ ៦៤ ] ម្នាលអគ្គិវេស្សនៈ មានឧបមេយ្យដូចជាព្រះតថាគតបានកើតឡើង ក្នុងលោកនេះ ជាព្រះអរហន្ត ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ បរិបូណ៌ដោយវិជ្ជា និងចរណៈ មានព្រះដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ជាសារថីទូន្មាននូវបុរសដែលគួរទូន្មាន ជាសាស្តានៃទេវតា និងមនុស្សទាំងឡាយ ត្រាស់ដឹងនូវចតុរារិយសច្ច លែងវិលមកកាន់ភពថ្មីទៀត ព្រះតថាគតអង្គនោះ ទ្រង់ធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តម ដោយព្រះអង្គឯង នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ នូវមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយអាចប្រកាសបាន ព្រះអង្គសម្តែងធម៌មានលម្អបទដើម មានលម្អបទកណ្តាល មានលម្អបទចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏បរិបូណ៌បរិសុទ្ធទាំងអស់ ។ គហបតី ឬគហបតិបុត្រ ដែលកើតជាខាងក្រោយ ក្នុងត្រកូល

ណាមួយ បានស្តាប់ធម៌នោះ លុះគហបតី ឬគហបតិបុត្រនោះ បានស្តាប់ធម៌នោះហើយ ក៏បានចំពោះនូវសទ្ធាក្នុងព្រះតថាគត ។ កាលបើគហបតីនោះប្រកបដោយកិរិយាបានចំពោះនូវសទ្ធា ដូច្នេះហើយ រមែងពិចារណាឃើញច្បាស់ថា ឃរាវាសចង្អៀតពេកណាស់ ជាផ្លូវហូរមកនៃធូលី គឺកិលេស បព្វជ្ជាទើបមានពេលទំនេរ បុគ្គលដែលនៅគ្រប់គ្រងផ្ទះ នឹងប្រព្រឹត្តព្រហ្ម-ចរិយធម៌ឲ្យបរិបូណ៌តែមួយយ៉ាង ឲ្យបរិសុទ្ធតែមួយយ៉ាង ឲ្យស្អាតដូចជាស័ង្ខដែលគេខាត់ហើយមិនងាយបានទេ បើដូច្នោះ មានតែអាត្មាអញកោរសក់ និងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ លុះគ្រាក្រោយមក បុគ្គលនោះ ក៏លះបង់នូវគំនរទ្រព្យតិចផង លះបង់នូវគំនរទ្រព្យច្រើនផង លះបង់នូវញាតិវង្សតិចផង លះបង់នូវញាតិវង្សច្រើនផង ហើយកោរសក់និងពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ ម្នាលអគ្គិវេស្សនៈ អរិយសាវ័កដែលទៅនៅក្នុងទីទំនេរបានក៏ដោយសារហេតុមានប្រមាណប៉ុណ្ណោះ ។ ម្នាលអគ្គិវេស្សនៈ ពួកទេវតា និងមនុស្ស រមែងមានសេចក្តីត្រេកអរក្នុងកាមគុណទាំង ៥ ប្រការនេះឯង ។ ព្រះតថាគត ទ្រង់ប្រដៅបុគ្គលនោះ តទៅទៀតថា ម្នាលភិក្ខុ ចូរអ្នកមក ចូរជាអ្នកមានសីល ចូរជាអ្នកសង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារនិងគោចរ ចូរជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ សូម្បីតិចតួច ចូរសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ ម្នាលអគ្គិវេស្សនៈ កាលបើអរិយសាវ័កជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារ និងគោចរ

ជាអ្នកឃើញភ័យក្នុងទោសសូម្បីតិចតួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយហើយ ។ ព្រះតថាគត ក៏ប្រដៅតទៅទៀតថា ម្នាលភិក្ខុ ចូរអ្នកមក ចូរជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ បើឃើញរូបដោយចក្ខុ ក៏មិនបានកាន់យកនិមិត្ត ។បេ។ ភិក្ខុនោះ លះបង់នីវរណៈទាំង ៥ ប្រការ ដែលជាគ្រឿងសៅហ្មងចិត្ត ធ្វើប្រាជ្ញាឲ្យទុព្វល ពិចារណាឃើញច្បាស់នូវកាយក្នុងកាយ ជាអ្នកព្យាយាមដុតកម្តៅកិលេស មានសតិសម្បជញ្ញៈ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។ ពិចារណាឃើញច្បាស់នូវវេទនា ក្នុងវេទនាទាំងឡាយ ... ពិចារណាឃើញច្បាស់នូវចិត្តក្នុងចិត្ត ... ពិចារណាឃើញច្បាស់ នូវធម្មារម្មណ៍ក្នុងធម្មារម្មណ៍ ព្យាយាមដុតកម្តៅកិលេស មានសតិសម្បជញ្ញៈ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ។

[ ៦៥ ] ម្នាលអគ្គិវេស្សនៈ ដូចទម័កដំរី ដែលដាំសសរធំទៅក្នុងផែនដី ហើយចងក្រៀកដំរីព្រៃត្រង់ក ដើម្បីញ៉ាំញីនូវទម្លាប់របស់ពួកដំរីព្រៃផង ដើម្បីញ៉ាំញីនូវតម្រិះជាគ្រឿងស្មុះទៅ របស់ពួកដំរីព្រៃផង ញ៉ាំញីនូវសេចក្តីក្រវល់ក្រវាយ សេចក្តីនឿយហត់ សេចក្តីក្តៅក្រហាយរបស់ពួកដំរីព្រៃផង ដើម្បីញ៉ាំងដំរីព្រៃឲ្យត្រេកអរ ចំពោះស្រុកផង ដើម្បីកាន់យកសណ្តាប់ធ្នាប់ ដែលជាទីស្រឡាញ់របស់មនុស្សផង សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលអគ្គិវេស្សនៈ មានឧបមេយ្យដូចជាអរិយសាវ័ក ដែលចងក្រៀកចិត្តភ្ជាប់នឹងសតិប្បដ្ឋានទាំង ៤ នេះ ដើម្បីញ៉ាំញីនូវទម្លាប់ ដែលអាស្រ័យនឹងបញ្ចកាមគុណផង ដើម្បីញ៉ាំញីតម្រិះជាគ្រឿងស្មុះទៅ ដែលអាស្រ័យនឹងបញ្ចកាមគុណ

ផង ដើម្បីញ៉ាំញីនូវសេចក្តីក្រវល់ក្រវាយ សេចក្តីទៀយហត់ សេចក្តីក្តៅក្រហាយ ដែលអាស្រ័យនឹងបញ្ចកាមគុណផង ដើម្បីត្រាស់ដឹងនូវអដ្ឋង្គិកមគ្គ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

[ ៦៦ ] ព្រះតថាគត ទ្រង់ប្រដៅភិក្ខុនោះតទៅទៀតថា ម្នាលភិក្ខុ អ្នកចូរមក អ្នកចូរពិចារណានូវកាយក្នុងកាយ តែកុំត្រិះរិះនូវតម្រិះដែលប្រកបដោយកាយឡើយ ។ អ្នកចូរពិចារណានូវវេទនា ក្នុងវេទនាទាំងឡាយ ... អ្នកចូរពិចារណានូវចិត្តក្នុងចិត្ត ... អ្នកចូរពិចារណា នូវធម្មារម្មណ៍ក្នុងធម្មារម្មណ៍ តែកុំត្រិះរិះនូវតម្រិះ ដែលប្រកបដោយធម្មារម្មណ៍ឡើយ ។ ភិក្ខុនោះព្រោះរម្ងាប់នូវវិតក្ក និងវិចារ ហើយចូលកាន់ទុតិយជ្ឈាន ដែលមានសេចក្តីជ្រះថ្លាប្រព្រឹត្តទៅខាងក្នុង ជាចិត្តខ្ពស់ឯក ឥតមានវិតក្ក ឥតមាន វិចារ មានតែបីតិនិងសុខដែលកើតអំពីសមាធិ ... ចូលកាន់តតិយជ្ឈាន ... ចូលកាន់ចតុត្ថជ្ឈាន ។

[ ៦៧ ] ភិក្ខុនោះ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ភាវនាកម្ម ជាចិត្តនឹងធឹង ដល់នូវការមិនញាប់ញ័រ យ៉ាងនេះហើយ បង្អោនចិត្តទៅដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ( ញាណដែលរឭកឃើញនូវខន្ធ ដែលធ្លាប់កើតក្នុងភពមុនៗ ) ។ ភិក្ខុនោះ រមែងរឭកឃើញនូវបុព្វេនិវាស មានច្រើនប្រការ គឺរឭកឃើញជាតិ ១ ជាតិ ២ ។បេ។ រឭកឃើញនូវបុព្វេនិវាស មានច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ ។

[ ៦៨ ] ភិក្ខុនោះ កាលបើចិត្តតាំងនៅល្អ បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស ជាចិត្តទន់ គួរដល់ការងារកម្ម ជាចិត្តនឹងធឹង ដល់នូវការមិនញាប់ញ័រ យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណ ( ញាណដែលឆ្លុះឃើញនូវចុតិបដិសន្ធិ ) របស់សត្វទាំងឡាយ ។ ភិក្ខុនោះ មានចក្ខុដូចជាទិព្វ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា រមែងឃើញពួកសត្វ ដែលកំពុងច្យុត កំពុងកើត ដ៏ថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ មានរូបល្អខ្លះ មានរូបអាក្រក់ខ្លះ មានគតិល្អខ្លះ មានគតិអាក្រក់ខ្លះ ។បេ។ រមែងដឹងច្បាស់នូវពួកសត្វ ដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ។

[ ៦៩ ] ភិក្ខុនោះ កាលបើចិត្តខ្ជាប់ខ្ជួន បរិសុទ្ធ ផូរផង់ មិនមានទីទួល គឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការងារកម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ក៏បង្អោនចិត្តទៅដើម្បីអាសវក្ខយញ្ញាណ (ញាណដែលឆ្លុះឃើញនូវកិរិយាក្ស័យនៃអាសវៈ)។ ភិក្ខុនោះ រមែងដឹងច្បាស់ដោយពិតថា នេះជាទុក្ខ ដឹងច្បាស់ដោយពិតថា នេះជាតណ្ហាជាហេតុឲ្យកើតទុក្ខ ដឹងច្បាស់ដោយពិតថា នេះជាព្រះនិព្វានទីរម្ងត់ទុក្ខ ដឹងច្បាស់ដោយពិតថា នេះជាបដិបទាដំណើរទៅកាន់ព្រះនិព្វានទីរលត់ទុក្ខ ។ ភិក្ខុនោះ រមែងដឹងច្បាស់ដោយពិតថា នេះជាពួកអាសវៈ ដឹងច្បាស់ដោយពិតថា នេះជាធម៌នាំឲ្យកើតអាសវៈ ដឹងច្បាស់ដោយពិតថា នេះជាព្រះនិព្វានទីរម្ងត់អាសវៈ ដឹងច្បាស់ដោយពិតថា នេះជាបដិបទា ដំណើរទៅកាន់ព្រះនិព្វានទីរម្ងត់អាសវៈ ។ កាលបើភិក្ខុនោះ ដឹងយ៉ាងនេះ ឃើញ

យ៉ាងនេះហើយ ចិត្តក៏រួចស្រឡះចាកកាមាសវៈផង ចាកភវាសវៈផង ចាកអវិជ្ជាសវៈផង កាលបើចិត្តរួចស្រឡះហើយ ក៏មានសេចក្តីដឹងថា ចិត្តរួចស្រឡះហើយដូច្នេះ ភិក្ខុនោះដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈអាត្មាអញបាននៅរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[ ៧០ ] ភិក្ខុនោះ ជាអ្នកអត់ទ្រាំនឹងត្រជាក់ នឹងក្តៅ នឹងសេចក្តីស្រេក នឹងសេចក្តីឃ្លាន នឹងសម្ផស្សនៃរបោម មូស ខ្យល់ កម្តៅថ្ងៃ និងពស់តូចពស់ធំទាំងឡាយ ប្រកបដោយជាតិជាអ្នកអត់ធ្មត់ចំពោះគន្លងពាក្យ ដែលគេស្តីអាក្រក់ ដែលមានដំណើរមកអាក្រក់ និងវេទនា ដែលអាស្រ័យក្នុងសរីរៈកើតឡើងហើយ ជាទុក្ខដ៏ក្លា ក្តៅផ្សា មិនជាទីត្រេកអរ មិនជាទីគាប់ចិត្ត នាំបង់នូវជីវិត ។ ភិក្ខុនោះ ជាអ្នកមានទឹកចត់ គឺរាគៈ ទោសៈ មោហៈទាំងពួងកម្ចាត់បង់ហើយ ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកអំពីចម្ងាយ គួរទទួលនូវទាន ដែលគេតាក់តែងដើម្បីភ្ញៀវ គួរទទួលនូវទាន របស់បុគ្គលជាអ្នកជឿកម្មផល គួរដល់អញ្ជលីកម្ម ជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោក ។

[ ៧១ ] ម្នាលអគ្គិវេស្សនៈ ប្រសិនបើដំរីព្រះរាជទ្រព្យ ជាសត្វចាស់គេមិនបានទូន្មាន មិនបានប្រៀនប្រដៅ ហើយធ្វើមរណកាលទៅ គឺស្លាប់ទៅទាំងគេមិនទាន់បានទូន្មាន ដំរីព្រះរាជទ្រព្យ ជាសត្វចាស់ដែលស្លាប់ហើយនោះដល់នូវកិរិយារាប់ថា ជាដំរីស្លាប់ហើយ ។ ម្នាលអគ្គិវេស្សនៈ ប្រសិនបើដំរីព្រះរាជទ្រព្យ ជាសត្វកណ្តាល ... ម្នាលអគ្គិវេស្សនៈ ប្រសិនបើដំរីព្រះរាជ-

ទ្រព្យ ជាសត្វនៅក្មេង គេមិនទាន់ទូន្មាន មិនទាន់ប្រៀនប្រដៅទេ ហើយធ្វើមរណកាលទៅ គឺស្លាប់ទៅទាំងគេមិនទាន់ទូន្មាន ដំរីព្រះរាជទ្រព្យ ដែលជាសត្វនៅក្មេងស្លាប់ហើយនោះ ក៏ដល់នូវកិរិយារាប់ថា ជាដំរីស្លាប់ហើយដែរ ។ សេចក្ដីនេះ មានឧបមាដូចម្ដេចមិញ ម្នាលអគ្គិវេស្សនៈ មានឧបមេយ្យដូចភិក្ខុជាថេរៈ ប្រសិនបើមិនមែនជាព្រះខីណាស្រព ធ្វើមរណកាលទៅ គឺស្លាប់ទៅទាំងមិនទាន់បានទូន្មានខ្លួនទេ ភិក្ខុជាថេរៈ ដែលស្លាប់ហើយនោះ ដល់នូវកិរិយារាប់ថា ធ្វើមរណកាល ។ ម្នាលអគ្គិវេស្សនៈ ប្រសិនបើភិក្ខុជាកណ្ដាល ... ម្នាលអគ្គិវេស្សនៈ ប្រសិនបើភិក្ខុបួសថ្មី មិនមែនជាព្រះខីណាស្រព ធ្វើមរណកាលទៅ គឺស្លាប់ទៅទាំងមិនទាន់បានទូន្មានខ្លួនទេ ភិក្ខុបួសថ្មីដែលស្លាប់ហើយនោះ ក៏ដល់នូវកិរិយារាប់ថា ធ្វើមរណកាលដែរ ។

[ ៧២ ] ម្នាលអគ្គិវេស្សនៈ ប្រសិនបើដំរីព្រះរាជទ្រព្យ ជាសត្វចាស់ គេបានទូន្មានប្រៀនប្រដៅ បានបែបបទហើយ ធ្វើមរណកាលទៅ គឺស្លាប់ទៅដោយគេបានទូន្មានហើយ ដំរីព្រះរាជទ្រព្យ ជាសត្វចាស់ ដែលស្លាប់ហើយនោះ ដល់នូវកិរិយារាប់ថា ជាសត្វស្លាប់ ។ ម្នាលអគ្គិវេស្សនៈ ប្រសិនបើដំរីព្រះរាជទ្រព្យ ជាសត្វនៅកណ្ដាល ... ម្នាលអគ្គិវេស្សនៈ ប្រសិនបើដំរីព្រះរាជទ្រព្យ ជាសត្វនៅក្មេង គេបានទូន្មានប្រៀនប្រដៅ បានបែបបទហើយ ធ្វើមរណកាលទៅ គឺស្លាប់ទៅដោយគេបានទូន្មានហើយ ដំរីព្រះរាជទ្រព្យជាសត្វនៅក្មេង ដែលស្លាប់ហើយនោះ ក៏ដល់នូវកិរិយារាប់ថាជាសត្វស្លាប់ដែរ ។ សេចក្ដីនេះមានឧបមាដូចម្ដេចមិញ ម្នាលអគ្គិវេស្សនៈ មានឧបមេយ្យដូចភិក្ខុ

ជាថេរៈ បើជាព្រះនវកៈ... 

ជាថេរៈ បើជាព្រះខីណាស្រព ធ្វើមរណកាលទៅ គឺស្លាប់ទៅដោយបានទូន្មានខ្លួនហើយ ភិក្ខុជាថេរៈដែលស្លាប់ហើយនោះ ដល់នូវកិរិយារាប់ថា ធ្វើមរណកាល ។ ម្នាលអគ្គិវេស្សនៈ ប្រសិនបើភិក្ខុជាកណ្តាល ... ប្រសិនបើភិក្ខុបួសថ្មី ជាព្រះខីណាស្រព ធ្វើមរណកាល គឺស្លាប់ទៅទាំងបានទូន្មានខ្លួនហើយ ភិក្ខុបួសថ្មី ដែលធ្វើមរណកាលហើយនោះ ក៏ដល់នូវកិរិយារាប់ថាធ្វើមរណកាលដែរ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះចប់ហើយ អចិរវតសមណុទ្ទេស ក៏រីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ។

## ទន្តភូមិសូត្រទី ៥ ចប់

# អដ្ឋកថា

## ទន្តភូមិសូត្រ

[ ៥៦ ] ទន្តភូមិសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **អរញ្ញ កុដិកាយំ** បានដល់ សេនាសនៈដែលគេសាងដើម្បីប្រយោជន៍ដល់ភិក្ខុដែលបំពេញព្យាយាម ក្នុងទីស្ងប់ស្ងាត់មួយកន្លែងនៃវេឡុវនវិហារនោះឯង ។ បទថា **រាជកុមារោ** សំដៅដល់ព្រះរាជកុមារ ឈ្មោះជ័យសេន ជាព្រះរាជបុត្ររបស់ព្រះបាទពិម្ពិសារ ។

[ ៥៧ ] បទថា **ផុសេយ្យ** ប្រែថា គប្បីបាន ។ បទថា **ឯកគ្គតំ** សេចក្តីថា ព្រះរាជកុមារត្រាស់ថា ខ្ញុំបានឮមកយ៉ាងនេះថា ភិក្ខុអ្នកបដិបត្តិយ៉ាងនេះ ឈ្មោះថា រមែងបានសមាបត្តិ ឈ្មោះថា រមែងបានឈាន ។

[ ៥៨ ] បទថា **កិលមថោ** បានដល់ លំបាកកាយ ការលំបាកនោះឯង ហៅថា **វិហេសា** ក៏បាន ។ បទថា **យថាសកេ តិដ្ឋេយ្យាសិ** សេចក្តីថា សូមព្រះអង្គតាំងនៅក្នុងចំណែក ដែលមិនដឹងរបស់ព្រះអង្គចុះ ។

[ ៥៩ ] បទថា **ទេសេសិ** សេចក្តីថា រមែងបានយ៉ាងនេះ គឺបានចិត្តេកគ្គតា បានដល់ រមែងញុំាងសមាបត្តិឲ្យកើតយ៉ាងនេះ ព្រោះដូច្នោះ អ្នកដែលដល់អប្បនាសមាធិ និងឧបចារសមាធិហើយ ទើបពោលកសិណបរិកម្មយ៉ាងនេះ ។ បទថា **បវេទេត្វា** ប្រែថា ប្រកាសហើយ ។

[ ៦០ ] បទថា **នេក្ខម្មេន ញាតព្វំ** សេចក្តីថា គប្បីដឹងដោយគុណ គឺបព្វជ្ជាជាគ្រឿងរលាស់ចេញចាកកាម សេចក្តីនោះ លោកអធិប្បាយថា

ឈ្មោះថា ឯកគ្គតាដែលបុគ្គលតាំងនៅក្នុងគុណ គឺបព្វជ្ជា ដែលជាគ្រឿងរលាស់ចេញចាកកាមគប្បីដឹង ។ បទដ៏សេសជាវេវចនៈនៃបទថា **ញាតព្វំ** នោះឯង ។ បទថា **កាមេ បរិភុញ្ជន្តោ** បានដល់ បរិភោគកាមទាំង ២ យ៉ាង ។

[ ៦១ ] បទថា **ហត្ថិទម្មា វា អស្សទម្មា វា គោទម្មា វា** នេះ មានអធិប្បាយថា បុគ្គលដែលវៀរចាកភាពជាអ្នកមានឯកគ្គតាចិត្ត គប្បីឃើញដូចការទូន្មានដំរីដែលមិនធ្លាប់បានទទួលការទូន្មានជាដើម បុគ្គលដែលបរិបូណ៌ដោយភាពជាអ្នកមានឯកគ្គតាចិត្ត គប្បីឃើញដូចការទូន្មានដំរីដែលធ្លាប់ទូន្មានហើយជាដើម ។ ប្រៀបដូចសត្វពាហនៈមានដំរីជាដើម ដែលមិនទាន់បានទទួលការទូន្មាន រមែងមិនសមគួរនឹងចូលកាន់ទីលានបង្ហឹក ឬដល់នូវភូមិភាគដែលសត្វទទួលការបង្ហឹក ហើយគប្បីដល់ ដោយមិនចាំបាច់ធ្វើផ្ទះកំពូល មិនចាំបាច់ដាក់ចុះនូវធុរៈ យ៉ាងណា បុគ្គលដែលប្រាសចាកភាពជាអ្នកមានឯកគ្គតាចិត្ត ក៏ដូច្នោះ រមែងមិនអាចដើម្បីញុំាំងគុណ ដែលបុគ្គលអ្នកបរិបូណ៌ដោយឯកគ្គតាចិត្តឲ្យកើតហើយ ឲ្យកើតឡើងបាន ។

[ ៦២ ] បទថា **ហត្ថវិលង្ឃកេន** ប្រែថា ដឹកដៃទៅ ។ បទថា **ឱលោកេយ្យំ** ប្រែថា គួរមើល ។ បទថា **អាវុដោ** ប្រែថា បិទបាំង ។ បទថា **និវុដោ** ប្រែថា បាំង ។ បទថា **ឱផុដោ** ប្រែថា គ្របដណ្តប់ហើយ ។

[ ៦៣ ] បទថា **នាគវនិកំ** សេចក្តីថា ក្នុងហត្ថិបទោបមសូត្រ លោកហៅបុរសដែលជាអ្នកត្រាច់ទៅក្នុងនាគវនថា **នាគវនិកោ**។ ក្នុងសេចក្តីនេះ

*មានអធិប្បាយថា បុរសដែលឈ្លាសក្នុងការទូន្មានដំរី រមែងអាចទាក់ដំរីបាន ។ បទថា* **អតិបស្សិត្វា** *ប្រែថា ឃើញហើយ ។ បទថា* **ឯត្ថ គេធា** *បានដល់ ការសង្ស័យដែលប្រព្រឹត្តទៅក្នុងនាគវ័ននោះ ។ បទថា* **សរសង្កប្បានំ** *ប្រែថា ការត្រិះរិះស្មុះទៅ ។ ក្នុងបទថា* **មនុស្សកន្តេសុ សីលេសុ សមាទបនាយ** *អធិប្បាយថា ក្នុងវេលាណា ស្ត្រី និងកូន កុមារ កុមារី ចាប់ត្រង់ប្រមោយ ជាដើម លេងក្បាល ដំរីមិនសម្តែងអាការខុសប្រក្រតី គឺនៅយ៉ាងសប្បាយ ក្នុងវេលានោះ ដំរីនោះឈ្មោះថា រមែងរីករាយតាមប្រក្រតីដែលមនុស្សត្រូវ ការ ។*

*បទថា* **បេមនីយា** *បានដល់ ពោលថា នែបា កាលព្រះរាជាពេញចិត្ត បាហើយ និងតែងតាំងបាក្នុងតំណែងហត្ថីមង្គលនោះឯង បានឹងបានបរិភោគ នូវរបស់ល្អៗ មានភោជនជាដើម ដែលគួរដល់ព្រះរាជា ពាក្យពោលបែប នេះ ជាវាចាដែលដំរីស្រឡាញ់ ។ បទថា* **សុស្សូសតិ** *សេចក្តីថា ដំរីរមែង បំណងនឹងស្តាប់ពាក្យដែលជាទីស្រឡាញ់បែបនោះ ។ បទថា* **តិណឃាស-ោទកំ** *បានដល់ ដើម្បីរកអាហារ គឺស្មៅ និងទឹក ។ បទថា* **តិណឃាសំ** *ប្រែថា ស្មៅដែលគប្បីទំពា អធិប្បាយថា ស្មៅដែលគប្បីស៊ី ។*

*បទថា* **បណ្ឌវោ** *ប្រែថា ស្គរជ័យ ។ បទថា* **សព្វវង្កទោសនិហិត-និន្និតកសាវោ** *បានដល់ កម្ចាត់ទោស គឺការកោងគ្រប់យ៉ាងបានផង អស់ ព្យសនៈកំណាចផង ។ បទថា* **អង្គន្តេវ សង្ខំ គច្ឆតិ** *សេចក្តីថា រមែងចាត់ ជាអង្គសម្បត្តិ ។ បទថា* **គេហាសិតសីលានំ** *បានដល់ សីលដែលអាស្រ័យ*

*កាមគុណ ៥ ។*

[ ៦៥ ] *បទថា* **ញាយស្ស** *បានដល់ អដ្ឋង្គិកមគ្គ ។*

[ ៧១ ] *ក្នុងបទថា* **អនន្តមរណំ មហាល្វកោ រញ្ញោ ឆាគោ មគោ កាលគតោ** *នេះ សេចក្តីថា ដំរីចាស់របស់ព្រះរាជាដួលចុះទាំងមិនបានទូន្មាន ។ បទទាំងពួងក៏មានន័យនេះឯង ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ដូច្នេះ ។*

**ទន្តភូមិសូត្រ ចប់**

**សូត្រទី ៥ ចប់**

# សុត្តន្តបិដក

## ភូមិជសូត្រទី ៦

[ ៧៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ គ្រានោះ ព្រះភូមិជៈមានអាយុ ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ដំណាក់ នៃព្រះរាជកុមារព្រះនាមជយសេន លុះចូលទៅដល់ ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុក ។ លំដាប់នោះ ជយសេនរាជ-កុមារ ចូលទៅរកព្រះភូមិជៈមានអាយុ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះភូមិជៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីសមគួរ ។

[ ៧៤ ] លុះជយសេនរាជកុមារ គង់ក្នុងទីសមគួរហើយ ក៏ពោលនឹងព្រះភូមិជៈមានអាយុដូច្នេះថា បពិត្រព្រះភូមិជៈដ៏ចម្រើន មានសមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បើបុគ្គលធ្វើនូវបំណង ( ដើម្បីត្រាស់ដឹងនូវផល ) ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលទេ មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយវិញទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ ចុះក្នុងសាសនានេះ ព្រះជា

គ្រូរបស់កុមិជៈដ៏ចម្រើន តើមានវាទៈដូចម្តេច មានទិដ្ឋិដូចម្តេច បានពោលដូចម្តេច ។

[ ៧៥ ] ថ្វាយព្រះពរព្រះរាជកុមារ ឯដំណើរនុ៎ះ អាត្មាភាពពុំដែលបានស្តាប់មក ក្នុងទីចំពោះព្រះភក្ត្រ ឬបានទទួលមក អំពីទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគទេ ប៉ុន្តែបើហេតុការណ៍នុ៎ះមាន ប្រាកដជាព្រះមានព្រះភាគនឹងទ្រង់ដោះស្រាយយ៉ាងនេះថា បើបុគ្គលធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ទើបគួរដើម្បីត្រាស់ដឹងនូវផលបាន មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ មួយវិញទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បពិត្រព្រះរាជកុមារ ឯដំណើរនុ៎ះ អាត្មាភាពពុំ

ដែលបានស្តាប់មកក្នុងទីចំពោះព្រះភក្ត្រ ឬបានទទួលមក អំពីទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគទេ ប៉ុន្តែបើហេតុការណ៍នុ៎ះមាន ប្រាកដជាព្រះមានព្រះភាគ នឹងទ្រង់ដោះស្រាយយ៉ាងនេះឯង ។ បើព្រះជាគ្រូរបស់ព្រះភូមិជៈដ៏ចម្រើន មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះ បានពោលយ៉ាងនេះមែន ព្រះជាគ្រូរបស់ព្រះភូមិជៈដ៏ចម្រើន ហាក់ដូចជាសំពងអំបែងក្បាល នៃពួកសមណព្រាហ្មណ៍ជាច្រើនទាំងអស់ ដោយពិត ។ គ្រានោះ ជយសេនរាជកុមារ ក៏អង្គាសព្រះភូមិជៈមានអាយុ ដោយសម្រាប់របស់ខ្លួន ។

[ ៧៦ ] លំដាប់នោះ ព្រះភូមិជៈមានអាយុ កាលត្រឡប់អំពីបិណ្ឌបាតមក ក្នុងវេលាក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះភូមិជៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ដំណាក់របស់ជយសេនរាជកុមារ ក្នុងទីឯណោះ លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ជយសេនរាជកុមារ ចូលមករកខ្ញុំព្រះអង្គ លុះចូលមកដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងខ្ញុំព្រះអង្គ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏គង់ក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះជយសេនរាជកុមារ គង់ក្នុងទីសមគួរហើយ ក៏ចោទសួរ ចំពោះខ្ញុំព្រះអង្គដូច្នេះថា បពិត្រព្រះភូមិជៈដ៏ចម្រើន មាន

សមណព្រាហ្មណ៍ពួកមួយ មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះថា បើបុគ្គល ធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលទេ មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ ចុះក្នុងសាសនានេះ ព្រះជាគ្រូរបស់ព្រះភូមិជៈដ៏ចម្រើន តើមានវាទៈដូចម្តេច មានទិដ្ឋិដូចម្តេច បានពោលដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើជយសេនរាជកុមារ ទ្រង់សួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គក៏ពោលតបទៅនឹងជយសេនរាជកុមារ ដូច្នេះថា ថ្វាយព្រះពរព្រះរាជកុមារ ឯដំណើរនុ៎ះ អាត្មាភាពមិនដែលបានស្តាប់ ក្នុងទីចំពោះព្រះភក្ត្រ ឬបានទទួលមកអំពីទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគទេ ប៉ុន្តែ បើហេតុការណ៍នុ៎ះមាន ប្រាកដជាព្រះមានព្រះភាគនឹងទ្រង់ដោះស្រាយ យ៉ាងនេះថា បើបុគ្គលធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិនត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយមិន

ត្រូវទំនង ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ទើបគួរដើម្បីត្រាស់ដឹងនូវផលបាន បើមិនធ្វើនូវបំណង ... បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ដោយត្រូវទំនង ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បពិត្រព្រះរាជកុមារ ឯដំណើរនុ៎ះ អាត្មាភាពមិនដែលបានស្តាប់ ក្នុងទីចំពោះព្រះភក្ត្រ ឬបានទទួលមកអំពីទីចំពោះព្រះភក្ត្រ នៃព្រះមានព្រះភាគទេ ប៉ុន្តែ បើហេតុការណ៍នុ៎ះមានប្រាកដជាព្រះមានព្រះភាគ នឹងទ្រង់ដោះស្រាយយ៉ាងនេះឯង ។ ជយសេនរាជកុមារទ្រង់ត្រាស់ថា បើព្រះជាគ្រូរបស់ព្រះកូមិជៈដ៏ចម្រើន មានវាទៈយ៉ាងនេះ មានទិដ្ឋិយ៉ាងនេះ បានពោលយ៉ាងនេះមែន ព្រះជាគ្រូរបស់ព្រះកូមិជៈដ៏ចម្រើន ហាក់ដូចជាសំពងនូវអំបែងក្បាលនៃពួកសមណព្រាហ្មណ៍ ជាច្រើនទាំងអស់ ដោយពិត ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើរាជកុមារ ទ្រង់សួរយ៉ាងនេះហើយ ខ្ញុំព្រះអង្គក៏បានដោះស្រាយយ៉ាងនេះ តើឈ្មោះថា ខ្ញុំព្រះអង្គពោលត្រូវតាមព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគផង ឈ្មោះថា មិនពោលបង្កាច់ព្រះមានព្រះភាគ ដោយពាក្យមិនពិតផង ឈ្មោះថា សម្តែងនូវធម៌ដ៏សមគួរដល់ធម៌ផងឬទេ មួយទៀត វាទានុវាទបន្តិចបន្តួច ដែលប្រកបដោយធម៌ មិនមកកាន់ទីដែលបណ្ឌិតគួរតិះដៀលទេឬ ។

[ ៧៧ ] ព្រះមានព្រះភាគទ្រង់ត្រាស់ថា អើ កូមិជៈ កាលដែលព្រះរាជកុមារ ទ្រង់ចោទសួរយ៉ាងនុ៎ះ ហើយអ្នកដោះស្រាយយ៉ាងនុ៎ះ ឈ្មោះថា

អ្នកពោលត្រូវតាមពាក្យ របស់តថាគតផង ឈ្មោះថា មិនពោលបង្កាច់តថាគត ដោយពាក្យមិនពិតផង ឈ្មោះថា សម្តែងនូវធម៌ដ៏សមគួរដល់ធម៌ផង មួយទៀត វាទានុវាទបន្តិចបន្តួច ដែលប្រកបដោយធម៌ មិនបានមកកាន់ទីដែលបណ្ឌិតគួរតិះដៀលទេ ។ ម្នាលភូមិជៈ ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិខុស មានសេចក្តីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានព្យាយាមខុស មានសតិខុស មានសមាធិខុស សមណព្រាហ្មណ៍ទាំងនោះ បើធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ មួយទៀត បើមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយទៀត បើធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ មួយវិញទៀត បើមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះគ្មានទំនង ដែលនាំឲ្យត្រាស់ដឹងនូវផល ។

[ ៧៨ ] ម្នាលភូមិជៈ ដូចបុរសដែលត្រូវការដោយប្រេង ស្វែងរកប្រេង ត្រាច់ទៅកាន់ទីស្វែងរកប្រេង ក៏យកដីខ្សាច់មកចាក់ក្នុងស្នូក ហើយយកទឹកមកប្រោះព្រំ ប្របាច់រឿយៗ បើទុកជាធ្វើនូវបំណង ហើយយកដីខ្សាច់មកចាក់ក្នុងស្នូក ហើយយកទឹកមកប្រោះព្រំ ប្របាច់រឿយៗ ក៏មិនគួរដើម្បីបាននូវប្រេងឡើយ បើទុកជាមិនធ្វើនូវបំណង ហើយយកដីខ្សាច់មក

ចាក់ក្នុងស្នូក ហើយយកទឹកមកប្រោះព្រំ ច្របាច់រឿយៗ ក៏មិនគួរដើម្បីបាននូវប្រេងដែរ បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយយកដីខ្សាច់មកចាក់ក្នុងស្នូក ហើយយកទឹកមកប្រោះព្រំ ច្របាច់រឿយៗ ក៏មិនគួរដើម្បីបាននូវប្រេងដែរ បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយយកដីខ្សាច់មកចាក់ក្នុងស្នូក ហើយយកទឹកមកប្រោះព្រំ ច្របាច់រឿយៗ ក៏មិនគួរដើម្បីបាននូវប្រេងដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះគ្មានទំនង ដែលគួរឲ្យបានប្រេងឡើយ សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាងពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិខុស មានសេចក្តីត្រិះរិះខុស មានវាចាខុស មានការងារខុស មានការចិញ្ចឹមជីវិតខុស មានព្យាយាមខុស មានសតិខុស មានសមាធិខុស សមណៈ ឬព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ បើទុកជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះគ្មានទំនង ដែលនាំឲ្យត្រាស់ដឹងនូវផលឡើយ ។

[ ៧៩ ] ម្នាលភូមិជៈ ពុំនោះសោត ដូចបុរសដែលត្រូវការដោយទឹក

ដោះស្រស់ ស្វែងរកទឹកដោះស្រស់ ត្រាច់ទៅកាន់ទីស្វែងរកទឹកដោះស្រស់ ក៏ចាប់មួលស្នែងមេគោដែលមានកូនខ្ចី បើទុកជាធ្វើនូវបំណង ហើយចាប់មួលស្នែងមេគោដែលមានកូនខ្ចី ក៏មិនគួរដើម្បីបាននូវទឹកដោះស្រស់ឡើយ បើទុកជាមិនធ្វើនូវបំណង ។បេ។ បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយចាប់មួលស្នែងមេគោដែលមានកូនខ្ចី ក៏មិនគួរដើម្បីបាននូវទឹកដោះស្រស់ដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះគ្មានទំនងដែលនាំឲ្យបាននូវទឹកដោះស្រស់ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាងពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិខុស ។បេ។ មានសមាធិខុស សមណព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះថា គ្មានទំនងដើម្បីឲ្យត្រាស់ដឹងនូវផលឡើយ ។

[ ៨០ ] ម្នាលភូមិជៈ ពុំនោះសោត ដូចបុរសដែលត្រូវការដោយទឹកដោះខាប់ ស្វែងរកទឹកដោះខាប់ ត្រាច់ទៅកាន់ទីស្វែងរកទឹកដោះខាប់ ហើយយកទឹកមកស្រោចលើភក់ហើយវិត ដោយឈើសម្រាប់វិត បើទុកជាធ្វើនូវបំណង ហើយយកទឹកមកស្រោចលើភក់ ហើយវិតដោយឈើសម្រាប់វិត ក៏មិនគួរដើម្បីបាននូវទឹកដោះខាប់ឡើយ បើទុកជាមិនធ្វើនូវបំណង ... បើទុក

ជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយយកទឹកមកស្រោចលើកក់ ហើយវិត ដោយឈើសម្រាប់វិត ក៏មិនគួរដើម្បីបាននូវទឹកដោះខាប់ដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះគ្មានទំនងដែលគួរឲ្យបានទឹកដោះខាប់ សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាងសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិខុស ។បេ។ មានសមាធិខុស សមណ-ព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈដ៏ចម្រើន ព្រោះគ្មានទំនង ដែលនាំឲ្យត្រាស់ដឹងនូវផលឡើយ ។

[ ៨១ ] ម្នាលភូមិជៈ ពុំនោះសោត ដូចបុរសដែលត្រូវការដោយភ្លើង ស្វែងរកភ្លើង ត្រាច់ទៅកាន់ទីស្វែងរកភ្លើង ក៏កាន់យកនូវឈើពំនួតខាងលើទៅពួតនឹងឈើស្រស់ ដែលនៅមានជ័រ បើទុកជាធ្វើនូវបំណង ហើយកាន់យកនូវឈើពំនួតខាងលើ ទៅពួតនឹងឈើស្រស់ ដែលនៅមានជ័រ ក៏មិនគួរដើម្បីបាននូវភ្លើងឡើយ បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយកាន់យកនូវឈើពំនួតខាងលើ ទៅពួតនឹងឈើស្រស់ ដែលនៅមានជ័រ

ក៏មិនគួរដើម្បីបាននូវភ្លើងដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះគ្មានទំនងដែលនាំឲ្យបាននូវភ្លើង សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាងពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិខុស ។បេ។ មានសមាធិខុស សមណព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលឡើយ បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏មិនគួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះគ្មានទំនង ដែលនាំឲ្យត្រាស់ដឹងនូវផលឡើយ ។

[ ៨២ ] ម្នាលភូមិជៈ លុះតែពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិត្រូវ មានសេចក្តីត្រិះរិះត្រូវ មានវាចាត្រូវ មានការងារត្រូវ មានព្យាយាមត្រូវ មានសតិត្រូវ មានសមាធិត្រូវ សមណព្រាហ្មណ៍ទាំងនោះ បើធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផល បើទុកជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនង ដែលនាំឲ្យត្រាស់ដឹងនូវផលបាន ។

[ ៨៣ ] ម្នាលភូមិជៈ ដូចបុរសដែលត្រូវការដោយប្រេង ស្វែងរកប្រេង ត្រាច់ទៅកាន់ទីស្វែងរកប្រេង ក៏យកម្សៅល្ងមកចាក់ក្នុងស្នូក ហើយយកទឹកមកប្រោះព្រំ ប្របាច់រឿយៗ បើទុកជាធ្វើនូវបំណង ហើយយកម្សៅល្ងមកចាក់ក្នុងស្នូក ហើយយកទឹកមកប្រោះព្រំ ប្របាច់រឿយៗ ក៏គួរដើម្បីបាននូវប្រេង បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយយកម្សៅល្ងមកចាក់ក្នុងស្នូក ហើយយកទឹកមកប្រោះព្រំ ប្របាច់រឿយៗ ក៏គួរដើម្បីបាននូវប្រេងដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនងដែលនាំឲ្យបាននូវប្រេង សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាងពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិត្រូវ ។បេ។ មានសមាធិត្រូវ ពួកសមណព្រាហ្មណ៍នោះ បើធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ គួរដើម្បីត្រាស់ដឹងនូវផល បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនងដែលនាំឲ្យត្រាស់ដឹងនូវផល ។

[ ៨៤ ] ម្នាលភូមិជៈ ពុំនោះសោត ដូចបុរសដែលត្រូវការដោយទឹកដោះស្រស់ ស្វែងរកទឹកដោះស្រស់ ត្រាច់ទៅកាន់ទីស្វែងរកទឹកដោះស្រស់ ក៏ចាប់មួលដោះមេគោដែលមានកូនខ្ចី បើធ្វើនូវបំណងហើយ ចាប់មួលដោះ

មេគោមានកូនខ្ចី ក៏គួរដើម្បីបាននូវទឹកដោះស្រស់ បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយចាប់មួលដោះមេគោដែលមានកូនខ្ចី ក៏គួរដើម្បីបាននូវទឹកដោះស្រស់ដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនងដែលនាំឲ្យបាននូវទឹកដោះស្រស់ សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាងពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិត្រូវ ។បេ។ មានសមាធិត្រូវ សមណព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនងគួរឲ្យត្រាស់ដឹងនូវផលបាន ។

[ ៨៥ ] ម្នាលភូមិជៈ ពុំនោះសោត ដូចបុរសដែលត្រូវការដោយទឹកដោះខាប់ ស្វែងរកទឹកដោះខាប់ ត្រាច់ទៅកាន់ទីស្វែងរកទឹកដោះខាប់ ហើយយកទឹកដោះជូរមកស្រោចលើកក់ ហើយវិតដោយឈើសម្រាប់វិត បើទុកជាធ្វើនូវបំណង ហើយយកទឹកដោះជូរមកស្រោចលើកក់ រួចវិតដោយឈើសម្រាប់វិត ក៏គួរដើម្បីបាននូវទឹកដោះខាប់ បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយយកទឹកដោះជូរមកស្រោចលើកក់ ហើយវិតដោយឈើសម្រាប់វិត ក៏គួរដើម្បីបាននូវទឹកដោះខាប់ដែរ សេចក្តីនោះ ព្រោះ

ហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនងដែលនាំឲ្យបាននូវទឹកដោះខាប់ សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាង ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិត្រូវ ។បេ។ មានសមាធិត្រូវ សមណព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផល បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណង ខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវ បំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តី នោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនង ដែលនាំឲ្យត្រាស់ដឹង នូវផលបាន ។

[ ៨៦ ] ម្នាលភូមិជៈ ពុំនោះសោត ដូចបុរសដែលត្រូវការដោយភ្លើង ស្វែងរកភ្លើង ត្រាច់ទៅកាន់ទីស្វែងរកភ្លើង ហើយកាន់យកឈើពំនួតខាងលើ ទៅពួតនឹងឈើស្ងួតខ្សោះ ក៏គួរដើម្បីបាននូវភ្លើង បើទុកជាធ្វើនូវបំណង ... បើទុកជាមិនធ្វើនូវបំណង ... បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ... បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយយកឈើពំនួត ខាងលើ ទៅពួតនឹងឈើស្ងួតខ្សោះ ក៏គួរដើម្បីបាននូវភ្លើងដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនង ដែលនាំឲ្យបាននូវភ្លើង សេចក្តីនេះ មានឧបមាយ៉ាងណាមិញ ម្នាលភូមិជៈ មានឧបមេយ្យដូចយ៉ាង ពួកសមណៈ ឬព្រាហ្មណ៍ណាមួយ ដែលមានទិដ្ឋិត្រូវ មានសេចក្តីត្រិះរិះត្រូវ ។បេ។ មានសមាធិត្រូវ សមណព្រាហ្មណ៍ទាំងនោះ បើទុកជាធ្វើនូវបំណង

ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផល បើទុកជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាធ្វើនូវបំណងខ្លះ មិនធ្វើនូវបំណងខ្លះ ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ បើទុកជាមិនធ្វើនូវបំណង មិនមែនជាមិនធ្វើនូវបំណង ហើយប្រព្រឹត្តព្រហ្មចរិយៈ ក៏គួរដើម្បីត្រាស់ដឹងនូវផលដែរ សេចក្តីនោះ ព្រោះហេតុដូចម្តេច ម្នាលភូមិជៈ ព្រោះមានទំនងដែលនាំឲ្យត្រាស់ដឹងនូវផលបាន ។

[ ៨៧ ] ម្នាលភូមិជៈ បើអ្នកអាចសម្តែងនូវឧបមាទាំង ៤ នេះ ដល់ជយសេនរាជកុមារបាន សេចក្តីអស្ចារ្យរបស់អ្នក ក៏នឹងកើតមាន ឯជយសេនរាជកុមារក៏មុខជាជ្រះថ្លានឹងអ្នក លុះជ្រះថ្លាហើយ នឹងធ្វើនូវអាការជ្រះថ្លាដល់អ្នកទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះខ្ញុំព្រះអង្គអាចនឹងសម្តែងដល់ជយសេនរាជកុមារ នូវសេចក្តីឧបមាទាំង ៤ នេះ ដែលជាទីអស្ចារ្យ ខ្ញុំព្រះអង្គមិនធ្លាប់ស្តាប់មកក្នុងកាលមុនសោះ ដូចជាព្រះមានព្រះភាគ អំពីណាបាន ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សូត្រនេះចប់ហើយ ព្រះភូមិជៈមានអាយុ ក៏មានសេចក្តីត្រេកអរ រីករាយនឹងភាសិតនៃព្រះមានព្រះភាគ ។

## ភូមិជសូត្រទី ៦ ចប់

# អដ្ឋកថា

## ភូមិជសូត្រ

[ ៧៣ ] ភូមិជសូត្រ មានពាក្យផ្ដើមថា **ឃរម្ហេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ភូមិជោ** សេចក្ដីថា ព្រះថេរៈនេះជាម្ចាស់អ៊ំរបស់ព្រះរាជកុមារព្រះនាមជ័យសេន ។

[ ៧៤ ] បទថា **អាសញ្ច ឆាសញ្ច** សេចក្ដីថា ជួនកាលក៏បំណាន់ ជួនកាលក៏មិនបំណាន់ ។

[ ៧៥ ] បទថា **ឃកោនេវ ជាលិចាកេន** សេចក្ដីថា ទ្រង់អន្ធាសដោយកិច្ចាដែលប្រព្រឹត្តទៅហើយតាមប្រក្រតី គឺភត្តដែលគេត្រៀមទុកដើម្បីព្រះអង្គ ។ បទដ៏សេសក្នុងទីទាំងពួង ងាយល់ទាំងអស់ហើយ ដូច្នេះ ៕

**អដ្ឋកថា ភូមិជសូត្រ ចប់**

**សូត្រទី ៦ ចប់**

# សុត្តន្តបិដក

## អនុរុទ្ធសូត្រទី ៧

[ ៨៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចឥរិយាបថ ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង បញ្ចកង្គថបតិ បានហៅបុរសម្នាក់មកថា នែបុរសដ៏ចម្រើន អ្នកចូរមក ចូរអ្នកទៅឯព្រះអនុរុទ្ធមានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំបាទានៃព្រះអនុរុទ្ធមានអាយុ ដោយត្បូង តាមពាក្យរបស់យើងថា បពិត្រលោកដ៏ចម្រើន បញ្ចកង្គថបតិ សូមថ្វាយបង្គំបាទានៃព្រះអនុរុទ្ធមានអាយុ ដោយត្បូង រួចហើយ អ្នកចូរពោលយ៉ាងនេះទៀតថា បពិត្រលោកដ៏ចម្រើន សូមព្រះអនុរុទ្ធមានអាយុ មានខ្លួនជាគម្រប់ ៤ ទទួលភត្តរបស់បញ្ចកង្គថបតិ ដើម្បីឆាន់ក្នុងថ្ងៃស្អែក បពិត្រលោកដ៏ចម្រើន សូមព្រះអនុរុទ្ធមានអាយុ ប្រញាប់និមន្តមកអំពីព្រឹកឲ្យទាន បពិត្រលោកដ៏ចម្រើន ព្រោះថា បញ្ចកង្គថបតិ គាត់មានកិច្ចច្រើន មានការងារច្រើន ដោយព្រះរាជកិច្ច ។ បុរសនោះ ក៏ទទួលពាក្យបញ្ចកង្គថបតិថា បាទលោកនាយ ហើយក៏ចូលទៅរកព្រះអនុរុទ្ធមានអាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះអនុរុទ្ធមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះបុរសនោះអង្គុយក្នុងទីសមគួរហើយ ក៏ទូលព្រះអនុរុទ្ធមានអាយុ ដូច្នេះថា បពិត្រលោកដ៏ចម្រើន បញ្ចកង្គថបតិ សូមថ្វាយបង្គំបាទានៃព្រះអនុរុទ្ធមានអាយុដោយត្បូង រួចពោលយ៉ាងនេះទៀតថា បពិត្រលោកដ៏ចម្រើន សូមព្រះអនុរុទ្ធមានអាយុ មានខ្លួនជាគម្រប់ ៤ ទទួល

កត្តារបស់បញ្ចកង្គថបតិ ដើម្បីឆាន់ក្នុងថ្ងៃស្អែក បពិត្រលោកដ៏ចម្រើន សូម
ព្រះអនុរុទ្ធមានអាយុ ប្រញាប់និមន្តទៅអំពីព្រឹកឲ្យទាន បពិត្រលោកដ៏ចម្រើន
ព្រោះថា បញ្ចកង្គថបតិ គាត់មានកិច្ចច្រើន មានការងារច្រើន ដោយព្រះ
រាជកិច្ច ។ ឯព្រះអនុរុទ្ធមានអាយុ ក៏ទទួលនិមន្តន៍ដោយតុណ្ហីភាព ។

[ ៨៩ ] គ្រានោះ ព្រះអនុរុទ្ធមានអាយុ លុះកន្លងរាត្រីនោះទៅហើយ ក៏ស្លៀកស្បង់ប្រដាប់ដោយបាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅឯផ្ទះ បញ្ចកង្គថបតិ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលទុក ។ លំដាប់នោះ បញ្ចកង្គថបតិ ញុំាងព្រះអនុរុទ្ធមានអាយុ ឲ្យឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ឧត្តម ដោយដៃនៃខ្លួន ត្រាតែព្រះអនុរុទ្ធហាមឃាត់ ។ ឯបញ្ចកង្គថបតិ កំណត់ដឹងថា ព្រះអនុរុទ្ធមានអាយុឆាន់រួចហើយ លែងលូកព្រះហស្តទៅក្នុងបាត្រទៀតហើយ ក៏កាន់យកនូវអាសនៈមួយដ៏ទាប ហើយអង្គុយក្នុងទីសមគួរ ។ លុះបញ្ចកង្គថបតិ អង្គុយក្នុងទីសមគួរហើយ ក៏ទូលព្រះអនុរុទ្ធមានអាយុដូច្នេះថា បពិត្រលោកដ៏ចម្រើន ពួកភិក្ខុជាថេរៈក្នុងសាសនានេះ ចូលមករកខ្ញុំហើយពោលយ៉ាងនេះថា ម្នាលគហបតី អ្នកចូរចម្រើននូវអប្បមាណាចេតោវិមុត្តិទៅ ព្រះថេរៈពួកខ្លះពោលយ៉ាងនេះថា ម្នាលគហបតី អ្នកចូរចម្រើននូវមហគ្គតចេតោវិមុត្តិទៅ បពិត្រលោកដ៏ចម្រើន ចុះអប្បមាណាចេតោវិមុត្តិណាក្តី មហគ្គតចេតោវិមុត្តិណាក្តី ធម៌ទាំងពីរនេះ មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផងឬ ឬក៏មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈទេ ។ ម្នាលគហបតី បើដូច្នោះ អ្នកចូរបំភ្លឺនូវសេចក្តីនោះ ក្នុងប្រស្នា

នុះមកមើល បើអ្នក ( សម្តែង ) នឹងមិនមានសេចក្តីខុសក្នុងប្រស្នានេះឡើយ ។ បពិត្រលោកដ៏ចម្រើន ខ្ញុំមានសេចក្តីចូលចិត្តយ៉ាងនេះថា អប្បមាណាចេតោវិមុត្តិណាក្តី មហគ្គតចេតោវិមុត្តិណាក្តី ធម៌ទាំងពីរនេះ មានអត្ថដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈ ។

[ ៩០ ] ម្នាលគហបតី អប្បមាណាចេតោវិមុត្តិណាក្តី មហគ្គតចេតោវិមុត្តិណាក្តី ធម៌ទាំងពីរនេះ មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ម្នាលគហបតី សេចក្តីនោះ អ្នកគប្បីដឹងដោយបរិយាយនេះចុះថា តាមពិតធម៌ទាំងពីរនេះ មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ។ ម្នាលគហបតី អប្បមាណាចេតោវិមុត្តិ តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ មានចិត្តប្រកបដោយមេត្តា ផ្សាយទៅកាន់ទិសទី ១ ផ្សាយទៅកាន់ទិសទី ២ ទី ៣ ទី ៤ ដូចគ្នា សូម្បីក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ក៏ជាអ្នកមានចិត្តប្រកបដោយមេត្តា ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនឯង ទៅប្រៀបផ្ទឹមនឹងសត្វទាំងពួង ក្នុងទីទាំងពួង ។ មានចិត្តប្រកបដោយករុណា ... មានចិត្តប្រកបដោយមុទិតា ... មានចិត្តប្រកបដោយឧបេក្ខា ... ផ្សាយទៅកាន់ទិសទី ១ ផ្សាយទៅកាន់ទិសទី ២ ទី ៣ ទី ៤ ដូចគ្នា សូម្បីក្នុងទិសខាងលើ ទិសខាងក្រោម និងទិសទទឹង ក៏ជាអ្នកមានចិត្តប្រកបដោយឧបេក្ខា ជាចិត្តធំទូលាយ ប្រមាណមិនបាន មិនមានពៀរ មិនមានព្យាបាទ ផ្សាយទៅកាន់សត្វលោកទាំងពួង ដោយការយកខ្លួនឯងទៅប្រៀបផ្ទឹមនឹងសត្វ

ទាំងពួង ក្នុងទីទាំងពួង ម្នាលគហបតី នេះហៅថា អប្បមាណចេតោវិមុត្តិ ។

[ ៩១ ] ម្នាលគហបតី ចុះមហគ្គតចេតោវិមុត្តិ តើដូចម្តេច ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់រុក្ខមូល ១ ជាកំណត់ ថាជាមហគ្គតៈ គឺទីដែលត្រូវយកចិត្តទុកដាក់ ម្នាលគហបតី នេះលោកហៅថា មហគ្គតចេតោវិមុត្តិ ។ ម្នាលគហបតី មួយទៀត ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់រុក្ខមូល ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ ម្នាលគហបតី នេះលោកហៅថា មហគ្គតចេតោវិមុត្តិដែរ ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់គាមក្ខេត្ត ១ ជាកំណត់ ថាជាទីមហគ្គតៈ ម្នាលគហបតី នេះហៅថា មហគ្គតចេតោវិមុត្តិដែរ ។ ម្នាលគហបតី មួយទៀត ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្ត ទៅកាន់គាមក្ខេត្ត ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ ម្នាលគហបតី នេះហៅថា មហគ្គតចេតោវិមុត្តិដែរ ។ ម្នាលគហបតី ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់ដែនធំ ១ ម្នាលគហបតី នេះហៅថា មហគ្គតចេតោវិមុត្តិដែរ ។ ម្នាលគហបតី មួយទៀត ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់ដែនធំ ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ ម្នាលគហបតី នេះហៅថា មហគ្គតចេតោវិមុត្តិដែរ ។ ម្នាលគហបតី មួយទៀត ភិក្ខុក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់សមុទ្រជាទីបំផុត ជាកំណត់ ថាជាទីមហគ្គតៈ ម្នាលគហបតី នេះហៅថា មហគ្គតចេតោវិមុត្តិដែរ ។ ម្នាលគហបតី សេចក្តីនេះឯង ដែលអ្នកគប្បីដឹងដោយបរិយាយនេះថា ធម៌ទាំងពីរ

នេះឯង មានអត្ថផ្សេងគ្នាផង មានព្យញ្ជនៈផ្សេងគ្នាផង ។

[ ៩២ ] ម្នាលគហបតី កិរិយាកើតក្នុងភពនេះមាន ៤ យ៉ាង ។ ៤ យ៉ាង តើដូចម្តេច ។ ម្នាលគហបតី បុគ្គលខ្លះ ក្នុងលោកនេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់បរិត្តាភជ្ឈាន ។ បុគ្គលនោះ លុះមានរាងកាយបែកធ្លាយ ទៅខាងមុខបន្ទាប់អំពីមរណៈ ក៏ទៅកើតជាមួយនឹងពួកបរិត្តាភទេវតា ។ ម្នាល គហបតី មួយទៀត បុគ្គលខ្លះ ក្នុងលោកនេះ ផ្សាយចិត្ត បង្អោនចិត្តទៅ កាន់អប្បមាណាភជ្ឈាន ។ បុគ្គលនោះ លុះមានរាងកាយបែកធ្លាយទៅខាង មុខ បន្ទាប់អំពីមរណៈ ក៏ទៅកើតជាមួយនឹងពួកអប្បមាណាភទេវតា ។ ម្នាល គហបតី បុគ្គលខ្លះ ក្នុងលោកនេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់សង្កិលិដ្ឋា-ភជ្ឈាន ។ បុគ្គលនោះ លុះមានរាងកាយបែកធ្លាយទៅ ខាងមុខបន្ទាប់អំពី មរណៈ ក៏ទៅកើតជាមួយនឹងពួកសង្កិលិដ្ឋាភទេវតា ។ ម្នាលគហបតី មួយ ទៀត បុគ្គលពួកខ្លះ ក្នុងលោកនេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់បរិសុទ្ធា-ភជ្ឈាន ។ បុគ្គលនោះ លុះមានរាងកាយ បែកធ្លាយទៅ ខាងមុខបន្ទាប់អំពី មរណៈ ក៏ទៅកើតជាមួយនឹងពួកបរិសុទ្ធាភទេវតា ។ ម្នាលគហបតី កិរិយា កើតក្នុងភព មាន ៤ យ៉ាងនេះឯង ។

[ ៩៣ ] ម្នាលគហបតី មានសម័យដែលពួកទេវតាប្រជុំគ្នា ក្នុងទីមួយ ឯពួកទេវតាដែលប្រជុំគ្នា ក្នុងទីមួយនោះ ប្រាកដជាមានសម្បុរផ្សេងគ្នា តែ មិនមែនមានពន្លឺផ្សេងគ្នាទេ ។ ម្នាលគហបតី ដូចបុរសដែលញុាំងប្រទីបប្រេង ជាច្រើន ឲ្យចូលទៅកាន់ផ្ទះមួយ ឯប្រទីបប្រេងទាំងនោះ ដែលចូលទៅកាន់

ផ្ទះមួយ ប្រាកដជាមានអណ្តាតភ្លើងផ្សេងគ្នា តែមិនមែនមានពន្លឺផ្សេងគ្នាទេ មានឧបមាយ៉ាងណាមិញ ម្នាលគហបតី មានឧបមេយ្យដូចយ៉ាងសម័យដែលពួកទេវតាប្រជុំគ្នាក្នុងទីមួយ ឯពួកទេវតាដែលប្រជុំគ្នាក្នុងទីមួយនោះ ប្រាកដជាមានសម្បុរផ្សេងគ្នា តែមិនមែនមានពន្លឺផ្សេងគ្នាទេ ។

[ ៩៤ ] ម្នាលគហបតី សម័យដែលពួកទេវតាចេញទៅអំពីទីប្រជុំនោះ ឯពួកទេវតានោះ កាលដែលចេញទៅ អំពីទីប្រជុំនោះ ប្រាកដជាមានសម្បុរក៏ផ្សេងគ្នា មានពន្លឺក៏ផ្សេងគ្នា ។ ម្នាលគហបតី ដូចបុរសនាំយកនូវប្រទីបប្រេង ដ៏ច្រើនទាំងនោះ ចេញអំពីផ្ទះនោះ ឯប្រទីបប្រេងទាំងនោះ កាលដែលគេនាំចេញអំពីផ្ទះនោះ ប្រាកដជាមានអណ្តាតភ្លើងផ្សេងគ្នា មានពន្លឺក៏ផ្សេងគ្នា មានឧបមាយ៉ាងណាមិញ ម្នាលគហបតី មានឧបមេយ្យដូចយ៉ាងសម័យដែលពួកទេវតា ចេញទៅអំពីទីប្រជុំនោះ ឯពួកទេវតានោះ កាលដែលចេញទៅអំពីទីប្រជុំនោះ ប្រាកដជាមានសម្បុរផ្សេងគ្នា មានពន្លឺក៏ផ្សេងគ្នា ។

[ ៩៥ ] ម្នាលគហបតី ឯទេវតាទាំងនោះ មិនមានសេចក្តីត្រិះរិះយ៉ាងនេះថា ទីរបស់យើងនេះ ទៀងទាត់ ឋិតថេរមាំមួន ដូច្នេះឡើយ ។ មួយទៀតពួកទេវតាណា នៅអាស្រ័យក្នុងទីណាៗ ទេវតាទាំងនោះ រមែងត្រេកអរក្នុងទីនោះៗ ឯង ។ ម្នាលគហបតី ដូចហ្វូងរុយ ដែលគេនាំទៅដោយអម្រែកក្តីដោយកញ្ជើក្តី តែងមិនមានសេចក្តីត្រិះរិះយ៉ាងនេះថា ទីរបស់យើងនេះ ទៀងទាត់ ឋិតថេរមាំមួន ដូច្នេះឡើយ ។ មួយវិញទៀត រុយទាំងនោះ ទៅអាស្រ័យក្នុងទីណាៗ រុយទាំងនោះ រមែងត្រេកអរក្នុងទីនោះៗ ឯង មានឧបមាយ៉ាង

ណាមិញ ម្នាលគហបតី មានឧបមេយ្យដូចយ៉ាងទេវតាទាំងនោះ តែងមិនមានសេចក្តីត្រិះរិះយ៉ាងនេះថា ទីរបស់យើងនេះ ទៀងទាត់ ឋិតថេរមាំមួន ដូច្នេះឡើយ ។ មួយវិញទៀត ពួកទេវតាណា នៅអាស្រ័យក្នុងទីណាៗ ទេវតាទាំងនោះ រមែងត្រេកអរក្នុងទីនោះៗ ។

[ ៩៦ ] កាលបើព្រះអនុរុទ្ធ ពោលយ៉ាងនេះហើយ ព្រះអភិយកច្ចានៈមានអាយុ ក៏ពោលនឹងព្រះអនុរុទ្ធមានអាយុ ដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ពាក្យរបស់លោកម្ចាស់ប្រពៃហើយ តែខ្ញុំត្រូវការសួរក្នុងប្រស្នាទុំះតទៅទៀត បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ពួកទេវតាណា ដែលមានពន្លឺ ទេវតាទាំងនោះ មានពន្លឺតិចទាំងអស់ឬ ឬក៏មានពួកទេវតា ដែលមានពន្លឺប្រមាណមិនបាន ក្នុងទីទុំះខ្វះដែរ ។ ព្រះអនុរុទ្ធឆ្លើយថា ម្នាលអាវុសោកច្ចានៈ ដោយហេតុនោះៗ ទេវតាដែលមានពន្លឺតិច ក៏មានក្នុងទីទុំះខ្វះ ទេវតាដែលមានពន្លឺប្រមាណមិនបាន ក៏មានក្នុងទីទុំះខ្វះដែរ ។ បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យទេវតាទាំងនោះ ចូលទៅកើតក្នុងពួកនៃទេវតាដូចគ្នា តែទេវតាពួកខ្វះក្នុងទីទុំះ មានពន្លឺតិចក៏មាន ទេវតាពួកខ្វះក្នុងទីទុំះ មានពន្លឺប្រមាណមិនបានក៏មាន ។

[ ៩៧ ] ម្នាលអាវុសោកច្ចានៈ បើដូច្នោះ ខ្ញុំនឹងត្រឡប់សួរលោក ក្នុងប្រស្នាទុំះវិញ បើប្រស្នានោះ គាប់ចិត្តលោកយ៉ាងណា លោកគប្បីដោះស្រាយនូវប្រស្នានោះ យ៉ាងនោះចុះ ។ ម្នាលអាវុសោកច្ចានៈ លោកសម្គាល់នូវសេចក្តីនោះ ថាដូចម្តេច គឺត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់រុក្ខ-

មូល ១ ជាកំណត់ ថាជាទីមហគ្គតៈ ( ទីជាធំ គឺទីត្រូវយកចិត្តទុកដាក់ ) និងត្រង់ដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្តទៅកាន់រុក្ខមូល ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ បណ្តាចិត្តភាវនាទាំង ២ នេះ ចិត្តភាវនាណា ដែលចាត់ជាមហគ្គតៈ ខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចម្រើន បណ្តាចិត្តភាវនា ទាំង ២ នេះ ចិត្តភាវនា ដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្តទៅកាន់រុក្ខមូល ២ ឬ ៣ ជាកំណត់ថាជាទីមហគ្គតៈ នេះឯង ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។

[ ៩៨ ] ម្នាលអាវុសោកច្ចានៈ លោកសម្គាល់សេចក្តីនោះថាដូចម្តេច គឺត្រង់ដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្តទៅកាន់រុក្ខមូល ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ និងត្រង់ដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្តទៅកាន់គាមក្ខេត្ត ១ ជាកំណត់ ថាជាទីមហគ្គតៈ បណ្តាចិត្តភាវនាទាំង ២ នេះ តើចិត្តភាវនាណា ដែលចាត់ជាមហគ្គតៈ ខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចម្រើន បណ្តាចិត្ត-ភាវនាទាំង ២ នេះ ចិត្តភាវនាដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់គាមក្ខេត្ត ១ ជាកំណត់ ថាជាទីមហគ្គតៈ នេះឯង ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។

[ ៩៩ ] ម្នាលអាវុសោកច្ចានៈ លោកសម្គាល់នូវសេចក្តីនោះថាដូចម្តេច គឺត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់គាមក្ខេត្ត ១ ជាកំណត់ ថាជាទីមហគ្គតៈ និងត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់គាមក្ខេត្ត ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ បណ្តាចិត្តភាវនាទាំង ២ នេះ តើចិត្តភាវនាណា ដែលចាត់ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចម្រើន បណ្តាចិត្តភាវនាទាំង ២ នេះ ចិត្តភាវនាដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅ

កាន់គាមក្ខេត្ត ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ នេះឯង ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។

[ ១០០ ] ម្នាលអាវុសោកច្ចានៈ លោកសម្គាល់សេចក្តីនោះថាដូចម្តេច គឺត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់គាមក្ខេត្ត ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ និងត្រង់ដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្តទៅកាន់ដែនធំ ១ ជាកំណត់ ថាជាទីមហគ្គតៈ បណ្តាចិត្តភាវនាទាំងពីរនេះ តើចិត្តភាវនាណា ដែលចាត់ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចម្រើន បណ្តាចិត្តភាវនាទាំង ២ នេះ ចិត្តភាវនាដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់ដែនធំ ១ ជាកំណត់ ថាជាទីមហគ្គតៈ នេះឯង ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។

[ ១០១ ] ម្នាលអាវុសោកច្ចានៈ លោកសម្គាល់សេចក្តីនោះថាដូចម្តេច គឺត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់ដែនធំ ១ ជាកំណត់ ថាជាទីមហគ្គតៈ និងត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់ដែនធំ ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ បណ្តាចិត្តភាវនាទាំង ២ នេះ តើចិត្តភាវនាណា ដែលចាត់ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចម្រើន បណ្តាចិត្តភាវនាទាំង ២ នេះ ចិត្តភាវនាដែលភិក្ខុផ្សាយចិត្ត បង្អោនចិត្តទៅកាន់ដែនធំ ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ នេះឯង ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។

[ ១០២ ] ម្នាលអាវុសោកច្ចានៈ លោកសម្គាល់សេចក្តីនោះថាដូចម្តេច គឺត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់ដែនធំ ២ ឬ ៣ ជាកំណត់ ថាជាទីមហគ្គតៈ និងត្រង់ដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់

ផែនដីមានសមុទ្រជាទីបំផុត ជាកំណត់ ថាជាទីមហគ្គតៈ បណ្ដាចិត្តភាវនាទាំង ២ នេះ ចិត្តភាវនាណា ដែលចាត់ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។ បពិត្រលោកដ៏ចម្រើន បណ្ដាចិត្តភាវនាទាំង ២ នេះ ចិត្តភាវនាដែលភិក្ខុ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់ផែនដី មានសមុទ្រជាទីបំផុត ជាកំណត់ ថាជាទីមហគ្គតៈ នេះឯង ជាមហគ្គតៈខ្ពង់ខ្ពស់ជាង ។ ម្នាលអាវុសោកច្ចានៈ នេះឯង ជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យទេវតាទាំងនោះ ចូលទៅកើតក្នុងពួកទេវតាតែមួយពួក ប៉ុន្តែទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺតិច ក៏មាន ទេវតាខ្លះក្នុងទីនុ៎ះ មានពន្លឺប្រមាណមិនបាន ក៏មាន ។

[ ១០៣ ] បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ពាក្យរបស់លោកម្ចាស់ ប្រពៃហើយ តែខ្ញុំនៅតែត្រូវការសួរក្នុងប្រស្នានុ៎ះតទៅទៀត បពិត្រលោកដ៏ចម្រើន ទេវតាទាំងអម្បាលម៉ាន ដែលមានពន្លឺ តើទេវតាទាំងនោះ មានពន្លឺស្រអាប់ទាំងអស់ឬ ឬក៏មានទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺថ្លាដែរ ។ ម្នាលអាវុសោកច្ចានៈ ដោយហេតុដូចពោលមកហើយនោះឯង ទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺស្រអាប់ក៏មាន ទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺថ្លាក៏មាន ។ បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ចុះហេតុដូចម្ដេច បច្ច័យដូចម្ដេច ដែលនាំឲ្យទេវតាទាំងនោះ ចូលទៅកើតក្នុងពួកនៃទេវតាតែមួយពួកសោះទេ ប៉ុន្តែទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺស្រអាប់ ក៏មាន ទេវតាពួកខ្លះ ក្នុងទីនុ៎ះ មានពន្លឺថ្លា ក៏មាន ។

[ ១០៤ ] ម្នាលអាវុសោកច្ចានៈ បើដូច្នោះ ខ្ញុំនឹងធ្វើនូវសេចក្ដីឧបមាដល់លោក ព្រោះថា វិញ្ញូបុរសពួកខ្លះ ក្នុងលោកនេះ តែងដឹងច្បាស់នូវសេចក្ដី

នៃភាសិត ដោយសារពាក្យឧបមា ។ ម្នាលអាវុសោកច្ចានៈ ដូចប្រទីបប្រេង ដែលកំពុងឆេះ មានប្រេងមិនបរិសុទ្ធខ្លះ មានប្រឆេះមិនស្អាតខ្លះ ។ ប្រទីបប្រេងនោះឯង ព្រោះតែប្រេងមិនបរិសុទ្ធក៏មាន ព្រោះតែប្រឆេះមិនស្អាតក៏មាន ក៏ឆេះហាក់ដូចជាងងឹតស្រអាប់ មានឧបមាយ៉ាងណាមិញ ម្នាលអាវុសោកច្ចានៈ មានឧបមេយ្យដូចយ៉ាងភិក្ខុខ្លះក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់សង្កិលិដ្ឋាកជ្ឈាន ( ឈានមានពន្លឺស្រអាប់ ) ។ គឺភិក្ខុនោះ មានសេចក្តីក្តាំក្តងកាយ មិនបានស្ងប់រម្ងាប់ខ្លះ មានថីនមិទ្ធៈ មិនបានដកចោលខ្លះ មានឧទ្ធច្ចកុក្កុច្ចៈមិនបានកម្ចាត់ចោលខ្លះ ។ ភិក្ខុនោះ ព្រោះតែសេចក្តីក្តាំក្តងកាយ មិនបានស្ងប់រម្ងាប់ក៏មាន ព្រោះតែមានថីនមិទ្ធៈ មិនបានដកចោលក៏មាន ព្រោះតែមានឧទ្ធច្ចកុក្កុច្ចៈ មិនបានកម្ចាត់ចោលក៏មាន ក៏ចម្រើនឈាន ហាក់ដូចជាងងឹតស្រអាប់ ។ ភិក្ខុនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ខាងមុខបន្ទាប់អំពីមរណៈ តែងទៅកើតជាមួយនឹងពួកទេវតាដែលមានពន្លឺស្រអាប់ ។ ម្នាលអាវុសោកច្ចានៈ មួយទៀត ដូចប្រទីបប្រេងដែលកំពុងឆេះ មានប្រេងបរិសុទ្ធផង មានប្រឆេះស្អាតផង ។ ប្រទីបប្រេងនោះ ព្រោះតែប្រេងបរិសុទ្ធផង ព្រោះតែប្រឆេះស្អាតផង ក៏ឆេះហាក់ដូចជាមិនងងឹតស្រអាប់ មានឧបមាយ៉ាងណាមិញ ម្នាលអាវុសោកច្ចានៈ មានឧបមេយ្យដូចយ៉ាងភិក្ខុពួកខ្លះ ក្នុងសាសនានេះ ផ្សាយចិត្ត បង្អោនចិត្តទៅកាន់បរិសុទ្ធាកជ្ឈាន ( ឈានមានពន្លឺថ្លា ) ។ គឺភិក្ខុនោះ មានសេចក្តីក្តាំក្តងកាយស្ងប់រម្ងាប់ផង មានថីនមិទ្ធៈ ដកចោលហើយផង មានឧទ្ធច្ចកុក្កុច្ចៈកម្ចាត់ចោលហើយផង ។ ភិក្ខុនោះ ព្រោះ

តែមានសេចក្តីផ្គាំផ្គងកាយស្ងប់រម្ងាប់ហើយផង ព្រោះតែមានថីនមិទ្ធៈដកចោលហើយផង ព្រោះតែមានឧទ្ធច្ចកុក្កុច្ចៈកម្ចាត់ចោលហើយផង រមែងចម្រើនឈានហាក់ដូចជាមិនងងឹតស្រអាប់ ។ ភិក្ខុនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅខាងមុខបន្ទាប់អំពីមរណៈ តែងទៅកើតជាមួយនឹងពួកទេវតា មានពន្លឺថ្លា ។ ម្នាលអាវុសោកច្ចានៈ នេះឯងជាហេតុ នេះឯងជាបច្ច័យ ដែលនាំឲ្យទេវតាទាំងនោះ ទៅកើតក្នុងពួកនៃទេវតាតែមួយពួកទេ ប៉ុន្តែ ទេវតាខ្លះ ក្នុងទីនុ៎ះមានពន្លឺស្រអាប់ ក៏មាន ទេវតាខ្លះ ក្នុងទីនុ៎ះ មានពន្លឺថ្លា ក៏មាន ។

[ ១០៥ ] កាលបើព្រះអនុរុទ្ធមានអាយុពោលយ៉ាងនេះហើយ អភិយកច្ចានៈមានអាយុ ក៏ពោលទៅនឹងព្រះអនុរុទ្ធមានអាយុ ដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន ពាក្យរបស់លោកប្រពៃហើយ បពិត្រលោកដ៏ចម្រើន ព្រះអនុរុទ្ធមានអាយុ មិនបានពោលយ៉ាងនេះថា ខ្ញុំបានស្តាប់មកយ៉ាងនេះ ឬថាសេចក្តីយ៉ាងនេះគួរនឹងមានទេ បពិត្រលោកដ៏ចម្រើន តែថា ព្រះអនុរុទ្ធមានអាយុ សម្តែងអំពីទេវតានោះ យ៉ាងនេះខ្លះ សម្តែងអំពីទេវតានោះ ដូច្នេះខ្លះ បពិត្រលោកដ៏ចម្រើន ខ្ញុំមានសេចក្តីចូលចិត្តយ៉ាងនេះថា ព្រះអនុរុទ្ធមានអាយុធ្លាប់នៅផង ធ្លាប់និយាយផង ធ្លាប់សាកច្ឆាផង ធ្លាប់រួមគំនិតផង ជាមួយនឹងទេវតាទាំងនោះឯង ។ ម្នាលអាវុសោកច្ចានៈ វាចាស្មានេះ លោកបានពោលហើយ ដោយត្រឹមត្រូវពិត បើដូច្នោះ ខ្ញុំនឹងប្រាប់លោក ម្នាលអាវុសោកច្ចានៈខ្ញុំធ្លាប់នៅផង ធ្លាប់និយាយផង ធ្លាប់សាកច្ឆាផង ធ្លាប់រួមគំនិតផង ជាមួយនឹងទេវតាទាំងនោះឯង អស់កាលជាយូរអង្វែង ពិតមែន ។

[ ១០៦ ] កាលបើព្រះអនុរុទ្ធមានអាយុពោលយ៉ាងនេះហើយ អភិយ-កច្ចានៈមានអាយុ ក៏ពោលទៅនឹងបញ្ចកង្គថបតិ ដូច្នេះថា ម្នាលគហបតី អ្នកពេញជាមានលាភ ម្នាលគហបតី អត្តភាពជាមនុស្ស អ្នកពេញជាបានដោយល្អហើយ ព្រោះថា អ្នកបានលះបង់នូវធម៌កង្ខា ( សេចក្តីសង្ស័យ ) នោះ ព្រោះថា យើងទាំងឡាយ បានស្តាប់នូវធម្មបរិយាយនេះ ។

អនុរុទ្ធសូត្រទី ៧ ចប់

# អដ្ឋកថា

## អនុរុទ្ធសូត្រ

[ ៨៨ ] អនុរុទ្ធសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ៨៩ ] ក្នុងបទទាំងនោះ បទថា **ឯវមាហំសុ** សេចក្ដីថា ចូលទៅរកក្នុងវេលាដែលឧបាសកនោះមានជំងឺ ទើបពោលយ៉ាងនេះ ។ បទថា **អបណ្ណកំ** ប្រែថា មិនខុសភ្លាំងភ្លាត់ ។ បទថា **ឯកត្ថ** បានដល់ ចេតោវិមុត្តិដែលប្រមាណមិនបានផង ចេតោវិមុត្តិដែលជាមហគ្គតៈផង ។ លោកកាន់យកពាក្យនេះថា ឈាន ក៏ហៅយ៉ាងនោះ ព្រោះការដែលចិត្តនោះឯង មានអារម្មណ៍តែមួយ ។

[ ៩១ ] បទថា **យាវតា ឯកំ រុក្ខមូលំ មហាគតន្តិ ផរិត្វា អធិមុច្ចិត្វា វិហរតិ** សេចក្ដីថា បង្អោនចិត្តផ្សាយទៅកាន់មហគ្គតជ្ឈានក្នុងកសិណនិមិត្តនោះ គ្របដណ្ដប់គល់ឈើមួយកន្លែង ដែលល្មមប្រមាណដោយកសិណនិមិត្ត ។ បទថា **មហាគ្គតំ** សេចក្ដីថា ការចងចិត្តមិនមានដល់កិក្ខុនោះ ទើបលោកពោលបទនេះទុក ដោយអំណាចនៃការប្រព្រឹត្តទៅនៃមហគ្គតជ្ឈានតែម្យ៉ាង ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ បទថា **ឥមិនា ខោ ឯតំ គហបតិ បរិយាយេន** សេចក្ដីថា ដោយហេតុនេះ ។ ក្នុងសេចក្ដីនេះមានវិនិច្ឆ័យថា និមិត្តនៃព្រហ្មវិហារ ដែលលោកពោលថា ជាអប្បមាណានេះ រមែងមិនគួរ គឺមិនទាន់កើតការផ្សាយពង្រីកផង ឈានទាំងនោះក៏មិនទាន់ជាបាទនៃអភិញ្ញា ឬនិរោធផង ឈានដែលជាបាទនៃវិបស្សនា រមែងជាបាទនៃ

វឌ្ឍៈផង ជាការឈានចុះកាន់ភពផង ។ តែនិមិត្តនៃឈានដែលជាកសិណ ដែលលោកពោលថា ជាមហគ្គតៈ រមែងគួរ គឺរមែងកើតការផ្សាយពង្រីកចេញទៅ និងរមែងឈានចុះបាន ឈានដែលជាបាទនៃអភិញ្ញា រមែងជាបាទនៃនិរោធផង ជាបាទនៃវឌ្ឍៈផង ឈានចុះកាន់ភពផង ។ ធម៌ទាំងនេះមានអត្ថផ្សេងគ្នាយ៉ាងនេះ និងមានព្យញ្ជនៈផ្សេងគ្នាយ៉ាងនេះ គឺជាអប្បមាណា និងជាមហគ្គតៈ ។

[ ៩២ ] ឥឡូវនេះ កាលសម្ដែងហេតុនៃការចេញចាកមហគ្គតសមាបត្តិហើយចូលកាន់ភព ទើបលោកពោលថា **ចតស្សោ ខោ ឥមា** ដូច្នេះជាដើម ។ បទថា **បរិត្តាភា** សេចក្ដីថា ការបងចិត្តនេះរបស់ភិក្ខុដែលបង្អោនចិត្តផ្សាយទៅ ហើយដឹង មានតែភិក្ខុដែលត្រូវបម្រើនឈាន ជាហេតុនៃការកើតក្នុងទេវតាជាន់បរិត្តាភាទាំងឡាយ ទើបលោកពោលយ៉ាងនេះ ។ ក្នុងបទទាំងពួងក៏មានន័យនេះ ទេវតាជាន់បរិត្តាភា មានពន្លឺខ្សោយក៏មាន មានពន្លឺភ្លឺខ្លាំងក៏មាន ។ ទេវតាជាន់អប្បមាណាភា មានពន្លឺខ្សោយក៏មាន មានពន្លឺភ្លឺខ្លាំងក៏មាន ។

សួរថា សេចក្ដីនេះដូចម្ដេច ឆ្លើយថា ភិក្ខុធ្វើបរិកម្មក្នុងកសិណ មានប្រមាណប៉ុនចង្អេរ ឬមានប្រមាណប៉ុនថ្ពិល ធ្វើសមាបត្តិឲ្យកើតហើយ មានវសីដែលសន្សំទុកហើយ ដោយអាការទាំង ៥ ព្រោះធម៌ដែលជាសត្រូវមិនទាន់បរិសុទ្ធល្អ ។ លោកប្រើប្រាស់សមាបត្តិ ដែលមិនទាន់ជំនាញនោះឯង តាំងនៅក្នុងឈានដែលមិនទាន់ជំនាញ ធ្វើកាលកិរិយាហើយ រមែងកើត

ក្នុងពួកទេវតាជាន់បរិត្តាភាទាំងឡាយ ។ ពណ៌សម្បុររបស់លោកក៏តិច និង សៅហ្មង ។ ឯភិក្ខុដែលមានការជំនាញ គឺវសីសន្សំហើយ ដោយអាការ ទាំង ៥ ប្រើប្រាស់សមាបត្តិដែលបរិសុទ្ធល្អ តាំងនៅក្នុងឈានដែលជំនាញ ហើយ ធ្វើកាលកិរិយាហើយ រមែងទៅកើតក្នុងទេវតាជាន់បរិត្តាភា ព្រោះធម៌ ដែលជាសត្រូវបរិសុទ្ធល្អ ពណ៌សម្បុររបស់លោកមានតិចតួច និងបរិសុទ្ធ ។ ដោយប្រការដូចពោលមកនេះ ទើបទេវតាជាន់បរិត្តាភា មានទាំងពន្លឺខ្សោយ មានទាំងពន្លឺខ្លាំង ។ ការដែលភិក្ខុធ្វើបរិកម្មក្នុងកសិណដ៏បរិបូណ៌ ហើយ ញុំាងសមាបត្តិឲ្យកើត មានការស្ទាត់ជំនាញសន្សំហើយ ដោយអាការទាំង ៥ នេះ គប្បីជ្រាបដូចគ្នានឹងពោលហើយអំពីមុន ។ ដោយប្រការដូចពោលមក នេះ ទេវតាជាន់អប្បមាណាភា ក៏មានទាំងពន្លឺខ្សោយ មានទាំងពន្លឺខ្លាំង ។

[ ៩៣ ] បទថា **វណ្ណនានត្តំ** ប្រែថា មានកាយផ្សេងគ្នា ។ បទថា **នោ ច អាភានត្តំ** បានដល់ មិនប្រាកដថា មានពន្លឺផ្សេងគ្នា ។

[ ៩៤ ] បទថា **អច្ចិនានត្តំ** សេចក្តីថា មានអណ្តាតពន្លឺផ្សេងគ្នា គឺវែងខ្លះ ខ្លីខ្លះ តូចខ្លះ ធំខ្លះ ។

[ ៩៥ ] បទថា **យត្ថ យត្ថ** ប្រែថា នៅអាស្រ័យ គឺនៅប្រចាំក្នុងទីណា មួយ ដូចជាឧទ្យាន វិមាន ដើមកប្បព្រឹក្ស មាត់ទឹក និងស្រះបោក្ខរណី ។ បទថា **អភិរមន្តិ** ប្រែថា រមែងត្រេកអរ គឺមិនធុញទ្រាន់ ។ បទថា **កាជេន** បានដល់ រែករបស់ណាមួយ ដូចជារែកបបរ រែកកត្ត រែកប្រេង រែកទឹក អំពៅ រែកត្រី និងរែកសាច់ ។ បាឋៈថា **កាចេន** ដូច្នេះក៏មាន ។ សេចក្តី

ក៏យ៉ាងនោះដូចគ្នា ។ បទថា **ឋិដកេន** ប្រែថា ដោយល្អ ។ បទថា **តត្ថ តត្ថេវ** សេចក្ដីថា ពពួករុយដែលគេនាំចេញអំពីប្រកពដែលរកបានងាយ ដូចជាសប្បិ ទឹកឃ្មុំ ទឹកអំពៅជាដើម ហើយនាំទៅកាន់ទីដែលក្រាស់ទៅដោយអំបិល និងត្រីស្អុយជាដើម រមែងមិនកើតការគិតយ៉ាងនេះថា កាលមុន លំនៅរបស់អញសប្បាយ អញនៅជាសុខក្នុងទីនេះ អំបិលធ្វើឲ្យអញលំបាកក្នុងទីនេះ ឬថា ក្លិនត្រីស្អុយ ធ្វើឲ្យអញឈឺក្បាល រមែងត្រេកអរក្នុងទីនោះឯង ។

[ ៩៦ ] បទថា **អាភា** ប្រែថា សម្បុរដោយពន្លឺ ។ បទថា **តទង្គេន** បានដល់ អង្គនៃការចូលដល់កពនោះ អធិប្បាយថា បានដល់ ហេតុនៃការចូលដល់កព ។

ឥឡូវនេះ កាលនឹងសួរដល់ហេតុនោះ ទើបលោកពោលថា **កោ នុ ខោ ភន្តេ** ដូច្នេះជាដើម ។

[ ១០៤ ] បទថា **កាយទុដ្ឋុល្លំ** បានដល់ ការខ្ជិលច្រអូសតាមកាយ ។ បទថា **ឈាយតោ** ប្រែថា ភ្លើងឆេះរុងរឿង ។

[ ១០៥ ] បទថា **ទីឃរត្តំ ខោ មេ** សេចក្ដីថា បានឮថា ព្រះថេរៈបំពេញបារមី បួសជាឥសី ញុំាងសមាបត្តិឲ្យកើត បានកំណើតក្នុងព្រហ្មលោក ៣០០ ជន ជាប់តគ្នាទៅ ពាក្យនេះ លោកពោលសំដៅដល់ព្រះថេរៈរូបនោះឯង សមដូចលោកពោលជាប្រព័ន្ធគាថាដូច្នេះថា

*កាលមុន ខ្ញុំស្វែងរកអសង្ខតធម៌ ដែលជាតាទិ បួស*

*ជាឥសី ត្រាច់ទៅក្នុងព្រហ្មលោកអស់ ៣០០ ជន្ម ។*

*បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយដូច្នេះ ។៕*

**អដ្ឋកថាអនុរុទ្ធសូត្រ ចប់**

**សូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ឧបក្កិលេសសូត្រទី ៨

[ ១០៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង ពួកភិក្ខុក្នុងក្រុងកោសម្ពី កើតមានការបង្កហេតុ កើតមានជម្លោះ ដល់នូវការទាស់ទែងគ្នា ចាក់ដោតគ្នាដោយលំពែង គឺមាត់ ។

[ ១០៨ ] គ្រានោះ ភិក្ខុមួយរូប ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ ឯភិក្ខុនោះ លុះឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុ ក្នុងក្រុងកោសម្ពីនេះកើតមានការបង្កហេតុ កើតមានជម្លោះ ដល់នូវការទាស់ទែងគ្នា ចាក់ដោតគ្នានិងគ្នា ដោយលំពែង គឺមាត់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ស្តេចចូលទៅកាន់សម្នាក់ភិក្ខុទាំងនោះ ដោយសេចក្តីអនុគ្រោះ ។ ព្រះមានព្រះភាគក៏ទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះមានព្រះភាគស្តេចចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ ក៏ត្រាស់ឃាត់ភិក្ខុទាំងនោះ ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំងឡាយ កុំធ្វើនូវការបង្កហេតុ កុំធ្វើនូវជម្លោះ កុំធ្វើនូវសេចក្តីប្រកាន់ខុសគ្នា កុំធ្វើនូវការទាស់ទែងគ្នាឡើយ ។ កាលបើព្រះមានព្រះភាគទ្រង់ត្រាស់ឃាត់យ៉ាងនេះហើយ ភិក្ខុមួយរូប ក៏ក្រាបបង្គំទូលឃាត់ព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមាន

ព្រះភាគ ជាធម្មស្សាមី ទ្រង់ឈប់សិនចុះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់មានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបនូវកិរិយានៅជាសុខក្នុងបច្ចុប្បន្នចុះ យើងខ្ញុំទាំងឡាយ នឹងប្រាកដដោយការបង្កហេតុ ដោយជម្លោះ ដោយសេចក្តីប្រកាន់ខុសគ្នា ដោយការទាស់ទែងគ្នាទុំះ មិនលែងទេ ។

[ ១០៩ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ឃាត់នូវភិក្ខុទាំងនោះ ជាគម្រប់ពីរដង ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំងឡាយ កុំធ្វើនូវការបង្កហេតុ កុំធ្វើនូវជម្លោះ កុំធ្វើនូវសេចក្តីប្រកាន់ខុសគ្នា កុំធ្វើនូវការទាស់ទែងគ្នាឡើយ ។ ភិក្ខុនោះ ក៏ក្រាបបង្គំទូលឃាត់ព្រះមានព្រះភាគ ជាគម្រប់ពីរដង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ជាធម្មស្សាមី ទ្រង់ឈប់សិនចុះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់មានសេចក្តីខ្វល់ខ្វាយតិច ទ្រង់ប្រកបនូវកិរិយានៅជាសុខក្នុងបច្ចុប្បន្នចុះ យើងខ្ញុំទាំងឡាយនឹងប្រាកដ ដោយការបង្កហេតុ ដោយជម្លោះ ដោយសេចក្តីប្រកាន់ខុសគ្នា ដោយការទាស់ទែងគ្នាទុំះ មិនលែងឡើយ ។

[ ១១០ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ឃាត់នូវភិក្ខុទាំងនោះជាគម្រប់ ៣ ដង ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ កុំឡើយ អ្នកទាំងឡាយ កុំធ្វើនូវការបង្កហេតុ កុំធ្វើនូវជម្លោះ កុំធ្វើនូវសេចក្តីប្រកាន់ខុសគ្នា កុំធ្វើនូវការទាស់ទែងគ្នាឡើយ ។ ភិក្ខុនោះ ក៏ក្រាបបង្គំទូលឃាត់ព្រះមានព្រះភាគជាគម្រប់ ៣ ដង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ជាធម្មស្សាមី ទ្រង់ឈប់សិនចុះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់មានសេចក្តី

ខ្វល់ខ្វាយតិច ទ្រង់ប្រកបនូវកិរិយានៅជាសុខ ក្នុងបច្ចុប្បន្នចុះ យើងខ្ញុំទាំងឡាយ នឹងប្រាកដដោយការបន្ទូហេតុ ដោយជម្លោះ ដោយសេចក្តីប្រកាន់ខុសគ្នា ដោយការទាស់ទែងគ្នាទុំះ មិនលែងទេ ។

[ ១១១ ] លំដាប់នោះ ព្រះមានព្រះភាគទ្រង់ស្បង់ ប្រដាប់ដោយបាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់ក្រុងកោសម្ពី ដើម្បីបិណ្ឌបាត ។ លុះព្រះមានព្រះភាគ ទ្រង់ស្តេចទៅក្នុងក្រុងកោសម្ពី ដើម្បីបិណ្ឌបាត ត្រឡប់អំពីបិណ្ឌបាត ក្នុងបច្ឆាភត្តហើយ ទ្រង់ឲ្យរៀបចំសេនាសនៈ ហើយកាន់យកបាត្រ និងចីវរ ទ្រង់ព្រះស្ថិត ( ឈរ ) សម្តែងនូវព្រះគាថាទាំងនេះថា

ជនមានសំឡេងខ្លាំង ( ទៅរកគ្នា ) ផង ជនធ្វើនូវសេចក្តីបន្ទូហេតុប្រហែលគ្នាផង សូម្បីជនណាមួយដឹងខ្លួនថា អាត្មាអញជាបុគ្គលពាល ក៏គ្មានឡើយ កាលបើសង្ឃកំពុងតែបែកគ្នា ក៏មិនបានដឹង ហេតុដទៃឲ្យក្រៃលែងដែរ ពួកជនដែលភ្លេចស្មារតី ហើយធ្វើឫកពាខ្លួនដូចអ្នកប្រាជ្ញ មានសម្តីជាអារម្មណ៍ ពោលនូវពាក្យជាប្រក្រតី ចង់ហាមាត់និយាយប៉ុន្មាន ក៏និយាយប៉ុណ្ណោះទៅ កាលបើជម្លោះណា នាំទៅហើយ ក៏មិនដឹងច្បាស់នូវជម្លោះនោះឡើយ ពួកជនណាចងនូវសេចក្តីក្រោធនោះទុក ដោយគិតថា ជនឯណោះបានជេរអាត្មាអញ ជនឯណោះ បានវាយអាត្មាអញ ជនឯណោះ បានផ្ចាញ់អាត្មាអញ ជនឯណោះ បានលួចទ្រព្យ

របស់អាត្មាអញ ពៀររបស់ជនទាំងនោះ មិនរម្ងាប់ទេ លុះតែពួកជនណា មិនចងសេចក្តីក្រោធនោះទុក ដោយគិតថា ជនឯណោះ បានជេរអាត្មាអញ ជនឯណោះ បានវាយអាត្មាអញ ជនឯណោះ បានផ្ចាញ់អាត្មាអញ ជនឯណោះ បានលួចទ្រព្យរបស់អាត្មាអញ ដូច្នេះទេ ពៀររបស់ជនទាំងនោះ ទើបរម្ងាប់ទៅបាន ធម្មតា ពៀរក្នុងលោកនេះ មិនដែលរម្ងាប់ ដោយការចងពៀរម្តងណាឡើយ ការរម្ងាប់ពៀរទៅបាន តែដោយការមិនចងពៀរ ធម៌នុ៎ះជាប្រវេណី ពួកជនដទៃ តែងមិនដឹងច្បាស់ថា យើងនឹងវិនាស ក្នុងកណ្តាលជំនុំសង្ឃនេះឡើយ បណ្ឌិតទាំងឡាយណា ដឹងច្បាស់ក្នុងជំនុំសង្ឃនោះ ជម្លោះ តែងរម្ងាប់អំពីសម្នាក់បណ្ឌិតទាំងនោះ អម្បាលម្ល៉ឹងមាតាបិតា របស់ទីឃាវុកុមារ គេកាត់ចោលទាំងជីវិត គេក៏សម្លាប់ចោល ទាំងគោ សេះ និងធនធាន គេក៏នាំយកទៅ ទាំងដែន គេក៏រឹបជាន់ដណ្តើមយកអស់ ស្តេចទាំងនោះ ម្តេចគង់មានសេចក្តីព្រមព្រៀងគ្នាបាន ចុះអ្នកទាំងឡាយ ហេតុអ្វី ក៏គ្មានសេចក្តីព្រមព្រៀងគ្នាសោះ បើបុគ្គលបាននូវសម្លាញ់ មានប្រាជ្ញាជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នា បុគ្គលនោះ អាចគ្របសង្កត់នូវសេចក្តីអន្ត-

រាយទាំងពួងបាន គប្បីជាអ្នកមានសេចក្តីត្រេកអរ មានស្មារតី ត្រាច់ទៅជាមួយនឹងសម្លាញ់នោះចុះ បើបុគ្គលមិនបាននូវសម្លាញ់ ដែលមានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ មានធម៌ជាគ្រឿងនៅសប្បាយ ត្រាច់ទៅជាមួយគ្នាទេ បុគ្គលនោះ គួរត្រាច់ទៅតែម្នាក់ឯង ប្រៀបដូចជាព្រះរាជា លះបង់ដែន ដែលខ្លួនឈ្នះហើយ ( ត្រាច់ទៅម្នាក់ឯង ) ពុំនោះសោត ប្រៀបដូចដំរីដ៏ប្រសើរ ( ត្រាច់ទៅម្នាក់ឯង ) ក្នុងព្រៃ ការត្រាច់ទៅនៃបុគ្គលម្នាក់ឯង ហៅពេញជាប្រសើរ ព្រោះបុគ្គលពាលគ្មានសហាយតាគុណទេ មួយទៀត បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង តែថា មិនគួរធ្វើអំពើលាមកឡើយ ដូចដំរីដ៏ប្រសើរ មានសេចក្តីខ្វល់ខ្វាយតិច ( ត្រាច់ទៅតែម្នាក់ឯង ) ក្នុងព្រៃ ។

[ ១១២ ] លុះព្រះមានព្រះភាគទ្រង់ព្រះស្តិត ( ឈរ ) ពោលគាថាទាំងនេះរួចហើយ ក៏ទ្រង់ស្តេចទៅ ឯពាលកលោណការគ្រាម ។ សម័យនោះឯង ក៏ជួនជាព្រះភគុមានអាយុ គង់ក្នុងពាលកលោណការគ្រាមនោះដែរ ។ ឯព្រះភគុមានអាយុ បានឃើញព្រះមានព្រះភាគ ទ្រង់ស្តេចមកអំពីចម្ងាយ លុះឃើញហើយ ក៏រៀបក្រាលអាសនៈ រួចតម្កល់ទឹកសម្រាប់លាងព្រះបាទ ។ ព្រះមានព្រះភាគ ក៏ទ្រង់គង់លើអាសនៈ ដែលព្រះភគុមានអាយុក្រាលថ្វាយ លុះគង់ហើយ ទើបទ្រង់លាងព្រះបាទា ។ ចំណែកព្រះភគុមានអាយុ ក៏ក្រាប

ថ្វាយបង្គំព្រះមានព្រះភាគ រួចហើយ អង្គុយនៅក្នុងទីសមគួរ ។ លុះព្រះភគុមានអាយុអង្គុយក្នុងទីសមគួរហើយ ព្រះមានព្រះភាគក៏ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលភិក្ខុ អ្នកល្មមអត់ធន់បានទេឬ ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានទេឬ អ្នកមិនលំបាកដោយបិណ្ឌបាតទេឬ ។ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គល្មមអត់ធន់បាន បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស មួយទៀត ខ្ញុំព្រះអង្គមិនលំបាក ដោយបិណ្ឌបាតទេ ។ វេលានោះ ព្រះមានព្រះភាគទ្រង់ពន្យល់ព្រះភគុមានអាយុ ឲ្យឃើញច្បាស់ ឲ្យកាន់យកតាម ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ទ្រង់ក្រោកចាកអាសនៈ ស្តេចទៅឯប្រទេសព្រៃឈ្មោះបាចីនវំសៈ ។

[ ១១៣ ] សម័យនោះឯង ចួនជាព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិម្ពិលៈមានអាយុ គង់នៅក្នុងប្រទេសព្រៃ ឈ្មោះបាចីនវំសៈនោះ ។ ឯនាយទាយបាល ( បុរសជាអ្នករក្សាព្រៃ ) បានឃើញព្រះមានព្រះភាគ ទ្រង់ស្តេចមកអំពីចម្ងាយ លុះឃើញហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះសមណៈ ព្រះអង្គកុំស្តេចចូលទៅកាន់ព្រៃនេះឡើយ ដ្បិតមានពួកកុលបុត្រ ៣ រូប មានសភាពជាអ្នកស្រឡាញ់ខ្លួន នៅក្នុងព្រៃនេះ ព្រះអង្គកុំធ្វើឲ្យកុលបុត្រទាំងនោះ មានសេចក្តីមិនសប្បាយឡើយ ។ ឯព្រះអនុរុទ្ធមានអាយុ បានឮពាក្យនាយទាយបាល កំពុងនិយាយជាមួយនឹងព្រះមានព្រះភាគ លុះឮហើយ ក៏និយាយទៅនឹងនាយទាយបាល

ដូច្នេះថា ម្នាលនាយទាយបាលមានអាយុ អ្នកកុំឃាត់ព្រះមានព្រះភាគឡើយ ដ្បិតព្រះមានព្រះភាគជាគ្រូរបស់យើង ព្រះអង្គទ្រង់ស្តេចមកដល់ហើយ ។ លំដាប់នោះ ព្រះអនុរុទ្ធមានអាយុ ចូលទៅរកព្រះនន្ទិយៈមានអាយុ និងព្រះកិម្ពិលៈមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយនឹងព្រះនន្ទិយៈមានអាយុ និងព្រះកិម្ពិលៈមានអាយុ ដូច្នេះថា នែលោកមានអាយុទាំងឡាយ ចូរលោកទាំងឡាយនិមន្តទៅទទួល នែលោកមានអាយុទាំងឡាយ ចូរលោកទាំងឡាយនិមន្តទៅទទួល ដ្បិតព្រះមានព្រះភាគជាគ្រូរបស់យើង ព្រះអង្គទ្រង់ស្តេចមកដល់ហើយ ។ គ្រានោះ ព្រះអនុរុទ្ធមានអាយុ ព្រះនន្ទិយៈមានអាយុ និងព្រះកិម្ពិលៈមានអាយុ ក៏ក្រោកទៅទទួលព្រះមានព្រះភាគ មួយអង្គទទួលបាត្រនិងចីវរ នៃព្រះមានព្រះភាគ មួយអង្គរៀបក្រាលទីអាសនៈ មួយអង្គទៀតតម្កល់ទឹកសម្រាប់លាងព្រះបាទា ។ ព្រះមានព្រះភាគ ទ្រង់គង់លើអាសនៈដែលព្រះថេរៈនោះក្រាលថ្វាយ លុះគង់ហើយ ទ្រង់លាងព្រះបាទា ។ ចំណែកលោកមានអាយុទាំងនោះ ក៏នាំគ្នាក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចហើយអង្គុយក្នុងទីសមគួរ ។

[ ១១៤ ] លុះព្រះអនុរុទ្ធមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលអនុរុទ្ធទាំងឡាយ អ្នកល្មមអត់ធន់បានទេឬ ល្មមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានស្រួលទេឬ អ្នកទាំងឡាយមិនលំបាកដោយបិណ្ឌបាតទេឬ ។ ឯព្រះថេរៈទាំង ៣ អង្គ ក្រាបបង្គំទូលថា បពិត្រព្រះមានព្រះភាគ យើងខ្ញុំព្រះអង្គ ល្មមអត់ធន់បាន បពិត្រព្រះមានព្រះ

ភាគ យើងខ្ញុំព្រះអង្គល្មមញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅបានស្រួល សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំព្រះអង្គមិនលំបាកដោយបិណ្ឌបាតទេ ។ ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយ បានព្រមព្រៀងស្មោះសរនឹងគ្នា មិនវិវាទគ្នា ដូចជាទឹកដោះលាយនឹងទឹក សម្លឹងមើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់ដែរឬ ។ ព្រះករុណាព្រះអង្គ យើងខ្ញុំព្រះអង្គព្រមព្រៀងស្មោះសរនឹងគ្នា មិនវិវាទគ្នាទេ ដូចជាទឹកដោះលាយនឹងទឹក សម្លឹងមើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់បាន ។ ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំង-ឡាយ បានព្រមព្រៀង ស្មោះសរនឹងគ្នា មិនវិវាទគ្នា ដូចជាទឹកដោះលាយនឹងទឹក មើលគ្នាទៅវិញទៅមក ដោយភ្នែកជាទីស្រឡាញ់ តើដោយហេតុដូចម្តេចខ្លះ ។

[ ១១៥ ] សូមទ្រង់ព្រះមេត្តាប្រោស ក្នុងទីនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ ហៅពេញជាមានលាភ អត្តភាពជាមនុស្សហៅពេញជាអាត្មាអញបានដោយល្អ ព្រោះថា អាត្មាអញបាននៅជាមួយនឹងសព្រហ្មចារីបុគ្គល មានសភាពយ៉ាងនេះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានតម្កល់កាយកម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខ និងទីកំបាំងមុខ បានតម្កល់វចីកម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខ និងទីកំបាំងមុខ បានតម្កល់មនោកម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខ និងទីកំបាំងមុខ ចំពោះលោកមានអាយុអម្បាលនេះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្ត នៃលោកមានអាយុទាំងនេះវិញ សូមទ្រង់ព្រះមេត្តា

ប្រោស ខ្ញុំព្រះអង្គក៏បានដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្ត នៃលោកមានអាយុទាំងនេះទៅ សូមទ្រង់ព្រះមេត្តាប្រោស ទោះបីរាងកាយរបស់យើងខ្ញុំព្រះអង្គទាំងឡាយ ផ្សេងគ្នាក៏ពិតមែន ប៉ុន្តែ ចិត្តហាក់ដូចតែមួយ ។

[ ១១៦ ] ឯព្រះនន្ទិយៈមានអាយុ និងព្រះកិម្ពិលៈមានអាយុ ក៏បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ ហៅពេញជាមានលាភ អត្តភាពជាមនុស្ស ហៅពេញជាអាត្មាអញបានដោយល្អ ព្រោះថា អាត្មាអញបាននៅជាមួយនឹងសព្រហ្មចារីបុគ្គល មានសភាពយ៉ាងនេះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានតម្កល់កាយកម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខ និងទីកំបាំងមុខ បានតម្កល់វចីកម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខ និងទីកំបាំងមុខ បានតម្កល់មនោកម្មប្រកបដោយមេត្តា ក្នុងទីចំពោះមុខ និងទីកំបាំងមុខ ចំពោះលោកមានអាយុអម្បាលនេះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញ ដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្ត នៃលោកមានអាយុទាំងនេះវិញចុះ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គក៏បានដាក់ចិត្តរបស់ខ្លួនចេញ ហើយប្រព្រឹត្តតាមអំណាចចិត្ត នៃលោកមានអាយុទាំងនេះវិញទៅ សូមទ្រង់ព្រះមេត្តាប្រោស ទោះបីរាងកាយរបស់យើងខ្ញុំពល់គ្នា ផ្សេងគ្នាក៏ពិតមែន ប៉ុន្តែ ចិត្តហាក់ដូចតែមួយ ។ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំព្រះអង្គព្រមព្រៀងគ្នា រីករាយ

រកគ្នា មិនវិវាទគ្នា ដូចជាទឹកដោះលាយនឹងទឹក មើលគ្នាទៅវិញទៅមក ដោយចក្ខុជាទីស្រឡាញ់បាន ដោយហេតុយ៉ាងនេះឯង ។

[ ១១៧ ] ម្នាលអនុរុទ្ធទាំងឡាយ ប្រពៃហើយ ប្រពៃហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយ មិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ខ្លះដែរឬ ។ ព្រះករុណាព្រះអង្គ យើងខ្ញុំព្រះអង្គ មិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ម្នាលអនុរុទ្ធទាំងឡាយ ចុះអ្នកទាំងឡាយ ដែលមិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន តើដោយហេតុដូចម្តេច ។

[ ១១៨ ] សូមទ្រង់ព្រះមេត្តាប្រោស បណ្តាយើងខ្ញុំព្រះអង្គដែលនៅក្នុងទីនេះ បើលោកអង្គណា ត្រឡប់មកអំពីបិណ្ឌបាត ក្នុងស្រុកមុនគេ លោកអង្គនោះ រៀបចំក្រាលអាសនៈ តម្កល់ទឹកឆាន់ និងទឹកប្រើប្រាស់ តម្កល់កាជន៍សម្រាប់ផ្ទេរ លោកអង្គណាត្រឡប់មកអំពីបិណ្ឌបាតក្នុងស្រុក ក្រោយគេ បើមានរបស់ដែលសល់ពីឆាន់ បើលោកនោះចង់ឆាន់ក៏ឆាន់ទៅ បើមិនចង់ឆាន់ទេ ចាក់ចោលទៅក្នុងទីគ្មានស្មៅស្រស់ក៏បាន បាចសាចទៅក្នុងទឹក ដែលគ្មានសត្វតូចក៏បាន រួចលោកនោះរៀបចំទុកដាក់អាសនៈ រៀបចំទុកដាក់ទឹកសម្រាប់ឆាន់ និងទឹកសម្រាប់ប្រើប្រាស់ រៀបចំទុកដាក់កាជន៍សម្រាប់ផ្ទេរ ហើយបោសសម្អាតរោងភត្ត បើលោកណា ឃើញក្អមសម្រាប់ដាក់ទឹកឆាន់ក្តី ក្អមសម្រាប់ដាក់ទឹកលាងវច្ចៈក្តី នៅរលីងទទេ លោកនោះ ក៏តម្កល់ទុកឲ្យមានឡើង បើ

លោកនោះ មិនអាចនឹងលើកដោយដៃបានទេ យើងខ្ញុំក៏ហៅគ្នីគ្នាមកជួយលើកដោយដៃ ហើយតម្កល់ទុកក្អម សម្រាប់ដាក់ទឹកឆាន់ ឬក្អមសម្រាប់ដាក់ទឹកប្រើប្រាស់ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំព្រះអង្គ មិនដែលបញ្ចេញវាចាព្រោះហេតុប៉ុណ្ណោះឡើយ សូមទ្រង់ព្រះមេត្តាប្រោស មួយទៀត តែគ្រប់ប្រាំថ្ងៃហើយ យើងខ្ញុំតែងអង្គុយប្រជុំគ្នាដោយធម្មីកថា អស់រាត្រីទាំងមូល គឺអស់មួយយប់ សូមទ្រង់ព្រះមេត្តាប្រោស យើងខ្ញុំព្រះអង្គ មិនបានប្រហែសធ្វេស ខំព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ហើយប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះឯង ។

[ ១១៩ ] ម្នាលអនុរុទ្ធទាំងឡាយ ប្រពៃហើយ ប្រពៃហើយ ម្នាលអនុរុទ្ធទាំងឡាយ ចុះកាលដែលអ្នកទាំងឡាយ មិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ យ៉ាងនេះ តើអ្នកទាំងឡាយត្រាស់ដឹងនូវផាសុវិហារធម៌ដ៏វិសេស គឺញាណទស្សនៈដ៏ប្រសើរ ដែលអាចកម្ចាត់បង់នូវកិលេសដ៏ក្រៃលែងជាងមនុស្សធម៌ មានឬទេ ។ សូមទ្រង់ព្រះមេត្តាប្រោស ក្នុងទីនេះ យើងខ្ញុំព្រះអង្គមិនបានប្រហែសធ្វេស មានព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ក៏ស្គាល់ច្បាស់នូវពន្លឺផង នូវការឃើញរូបទាំងឡាយផង ប៉ុន្តែ ឯពន្លឺ និងការឃើញរូបទាំងឡាយនោះ របស់យើងខ្ញុំព្រះអង្គ មិននៅយូរប៉ុន្មាន ក៏បាត់ទៅវិញ ឯយើងខ្ញុំព្រះអង្គ ក៏មិនបានត្រាស់ដឹងនូវនិមិត្តនោះទេ ។

[ ១២០ ] ម្នាលអនុរុទ្ធទាំងឡាយ អ្នកទាំងឡាយ គប្បីត្រាស់ដឹងនូវនិមិត្តនោះជាប្រាកដ ម្នាលអនុរុទ្ធទាំងឡាយ ក្នុងកាលមុន អំពីការត្រាស់ដឹង តថាគតមិនទាន់បានត្រាស់ដឹង នៅជាពោធិសត្វនៅឡើយ ក៏ស្គាល់ច្បាស់នូវពន្លឺផង នូវការឃើញរូបទាំងឡាយផង ។ ប៉ុន្តែ ឯពន្លឺ និងការឃើញរូបទាំង-ឡាយនោះ របស់តថាគត មិននៅយូរប៉ុន្មាន ក៏បាត់ទៅវិញ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ចុះមានហេតុអ្វី បច្ច័យអ្វី ដែលនាំឲ្យពន្លឺ និងការឃើញរូបទាំងឡាយ របស់អាត្មាអញបាត់បង់ទៅ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះ ដូច្នេះថា វិចិកិច្ឆា ( សេចក្តីសង្ស័យ ) កើតឡើងដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញ ក៏ឃ្លាតទៅព្រោះតែមានវិចិកិច្ឆាជាហេតុ ( ជាទោស ) កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ វិចិកិច្ឆានឹងកើតឡើងមិនបានដល់អាត្មាអញទៀត យ៉ាងណា អាត្មាអញនឹងធ្វើយ៉ាងនោះ ។

[ ១២១ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគតមិនបានប្រហែសធ្វេស ខំព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ក៏ស្គាល់ច្បាស់នូវពន្លឺផង នូវការឃើញរូបទាំងឡាយផង ។ ឯពន្លឺ និងការឃើញរូបទាំងឡាយនោះ របស់តថាគត មិននៅយូរប៉ុន្មាន ក៏បាត់ទៅវិញ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ចុះមានហេតុអ្វី បច្ច័យអ្វី ដែលនាំឲ្យពន្លឺ និងការឃើញរូបទាំងឡាយ របស់អាត្មាអញបាត់បង់ទៅ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះ ដូច្នេះថា

អមនសិការ ( ការមិនធ្វើទុកក្នុងចិត្ត ) កើតឡើងហើយដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញក៏ឃ្លាតទៅ ព្រោះតែមានអមនសិការជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ វិចិកិច្ឆា និងអមនសិការកើតឡើងមិនបាន ដល់អាត្មាអញទៀត យ៉ាងណា អាត្មាអញនឹងធ្វើយ៉ាងនោះ ។

[ ១២២ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំង-ឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ថីនមិទ្ធៈ ( សេចក្តីងងុយ និងងោកងក់ ) កើតឡើងហើយដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញក៏ឃ្លាតទៅ ព្រោះតែមានថីនមិទ្ធៈជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ វិចិកិច្ឆា អមនសិការ និងថីនមិទ្ធៈ កើតឡើងមិនបាន ដល់អាត្មាអញទៀត យ៉ាងណា អាត្មាអញនឹងធ្វើយ៉ាងនោះ ។

[ ១២៣ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំង-ឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីរន្ធត់កាយកើតឡើងហើយដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញ ក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីរន្ធត់កាយជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំង-ឡាយ ក៏បាត់បង់ទៅដែរ ។ ម្នាលអនុរុទ្ធទាំងឡាយ ដូចបុរសដើរផ្លូវឆ្ងាយ ហើយមានពេជ្ឈឃាតនៅចាំផ្លូវទាំងពីរខាង នៃបុរសនោះ ឯសេចក្តីរន្ធត់កាយក៏កើតឡើងដល់បុរសនោះ ព្រោះតែនាយពេជ្ឈឃាតនោះជាហេតុ យ៉ាងណា

មិញ ម្នាលអនុរុទ្ធទាំងឡាយ សេចក្ដីរន្ធត់កាយ កើតឡើងហើយដល់តថាគត ឯសមាធិរបស់តថាគតក៏ឃ្លាតទៅ ព្រោះតែមានសេចក្ដីរន្ធត់កាយ ជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់ទៅដែរ ក៏យ៉ាងនោះឯង ។ វិចិកិច្ឆា អមនសិការ ថីនមិទ្ធៈ និងសេចក្ដីរន្ធត់កាយ កើតឡើងមិនបាន ដល់តថាគតទៀត យ៉ាងណា តថាគតនឹងធ្វើយ៉ាងនោះ ។

[ ១២៤ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំង-ឡាយ តថាគតមានសេចក្ដីត្រិះរិះដូច្នេះថា សេចក្ដីឆ្មើងឆ្មៃកើតឡើងហើយដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញ ក៏ឃ្លាតទៅ ព្រោះតែមានសេចក្ដីឆ្មើងឆ្មៃជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ ម្នាលអនុរុទ្ធទាំងឡាយ ដូចបុរសស្វែងរកកំណប់ទ្រព្យមួយ ស្រាប់តែបានកំណប់ទ្រព្យ ៥ តែម្ដង សេចក្ដីឆ្មើងឆ្មៃ គប្បីកើតឡើងដល់បុរសនោះ ព្រោះតែបានកំណប់ទ្រព្យនោះជាហេតុ យ៉ាងណាមិញ ម្នាលអនុរុទ្ធទាំងឡាយ សេចក្ដីឆ្មើងឆ្មៃកើតឡើងហើយដល់តថាគត ឯសមាធិរបស់តថាគតក៏ឃ្លាតទៅ ព្រោះតែមានសេចក្ដីឆ្មើងឆ្មៃជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ក៏យ៉ាងនោះឯង ។ វិចិកិច្ឆា អមនសិការ ថីនមិទ្ធៈ សេចក្ដីរន្ធត់កាយ និងសេចក្ដីឆ្មើងឆ្មៃ កើតឡើងមិនបាន ដល់តថាគតទៀត យ៉ាងណា តថាគតនឹងធ្វើយ៉ាងនោះ ។

[ ១២៥ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំង-ឡាយ តថាគតមានសេចក្ដីត្រិះរិះដូច្នេះថា សេចក្ដីក្រវល់ក្រវាយកាយ កើត

ឡើងហើយដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញ ក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីក្រវល់ក្រវាយកាយជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ វិចិកិច្ឆា អមនសិការ ថីនមិទ្ធៈ សេចក្តីរន្ធត់កាយ សេចក្តីឆ្មើងឆ្មៃ និងសេចក្តីក្រវល់ក្រវាយកាយ កើតឡើងមិនបាន ដល់តថាគតទៀត យ៉ាងណា តថាគតនឹងធ្វើយ៉ាងនោះ ។

[ ១២៦ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីព្យាយាមតឹងហួសពេករបស់អាត្មាអញកើតឡើងហើយ ឯសមាធិរបស់អាត្មាអញក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីព្យាយាមតឹងហួសពេកជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ ម្នាលអនុរុទ្ធទាំងឡាយ ដូចបុរសចាប់សត្វចាបខ្វាំងពេក ដោយដៃទាំងពីរ សត្វចាបនោះ គប្បីស្លាប់ក្នុងដៃនោះមិនខាន យ៉ាងណាមិញ ម្នាលអនុរុទ្ធទាំងឡាយ សេចក្តីព្យាយាមតឹងហួសពេក របស់តថាគតកើតឡើងហើយ ឯសមាធិរបស់តថាគត ក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីព្យាយាមតឹងហួសពេកជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយបាត់បង់ទៅដែរ ក៏យ៉ាងនោះឯង ។ វិចិកិច្ឆា អមនសិការ ថីនមិទ្ធៈ សេចក្តីរន្ធត់កាយ សេចក្តីឆ្មើងឆ្មៃ សេចក្តីក្រវល់ក្រវាយកាយ និងសេចក្តីព្យាយាមតឹងហួសពេក កើតឡើងមិនបាន ដល់តថាគតទៀត យ៉ាងណា តថាគតនឹងធ្វើយ៉ាងនោះ ។

[ ១២៧ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំង-

ឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីព្យាយាមធូរពេក របស់អាត្មាអញកើតឡើងហើយ ឯសមាធិរបស់អាត្មាអញ ក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីព្យាយាមធូរពេកជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់បង់ទៅដែរ ។ ម្នាលអនុរុទ្ធទាំងឡាយ ដូចបុរសចាប់សត្វចាបស្រាលពេក សត្វចាបនោះ គប្បីហើរទៅអំពីដៃ នៃបុរសនោះបាន យ៉ាងណាមិញ ម្នាលអនុរុទ្ធទាំងឡាយ សេចក្តីព្យាយាមធូរពេករបស់តថាគតកើតឡើងហើយ ឯសមាធិរបស់តថាគតក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីព្យាយាមធូរពេកជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយក៏បាត់ទៅដែរ យ៉ាងនោះឯង ។ វិចិកិច្ឆា អមនសិការ ថីនមិទ្ធៈ សេចក្តីរន្ធត់កាយ សេចក្តីធ្មេចធ្មៃ សេចក្តីក្រវល់ក្រវាយកាយ សេចក្តីព្យាយាមតឹងពេក និងសេចក្តីព្យាយាមធូរពេក កើតឡើងមិនបានដល់តថាគត យ៉ាងណា តថាគតនឹងធ្វើយ៉ាងនោះ ។

[ ១២៨ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំង-ឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សេចក្តីប្រាថ្នាហួសពេក ( តណ្ហា ) របស់អាត្មាអញ កើតឡើងហើយ ឯសមាធិរបស់អាត្មាអញ ក៏ឃ្លាតទៅ ព្រោះតែមានសេចក្តីប្រាថ្នាហួសពេកជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់ទៅដែរ ។ វិចិកិច្ឆា អមនសិការ ថីនមិទ្ធៈ សេចក្តីរន្ធត់កាយ សេចក្តីធ្មេចធ្មៃ សេចក្តីក្រវល់ក្រវាយកាយ សេចក្តីព្យាយាមតឹងពេក សេចក្តីព្យាយាមធូរពេក និងសេចក្តីប្រាថ្នាហួសពេក កើត

ឡើងមិនបានដល់អាត្មាអញទៀត យ៉ាងណា អាត្មាអញនឹងធ្វើយ៉ាងនោះ ។

[ ១២៩ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគត ។បេ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា នានត្តសញ្ញា ( សេចក្តីសម្គាល់ផ្សេងគ្នា ) កើតឡើងហើយដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញក៏ឃ្លាតទៅ ព្រោះតែមាននានត្តសញ្ញាជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺនិងការឃើញរូបទាំងឡាយ ក៏បាត់ទៅដែរ ។ វិចិកិច្ឆា អមនសិការ ថីនមិទ្ធៈ សេចក្តីរន្ធត់កាយ សេចក្តីធ្មេចធ្មៃ សេចក្តីក្រវល់ក្រវាយកាយ សេចក្តីព្យាយាមតឹងពេក សេចក្តីព្យាយាមធូរពេក សេចក្តីប្រាថ្នាហួសពេក និងនានត្តសញ្ញា កើតឡើងមិនបានទៀតដល់អាត្មាអញ យ៉ាងណា អាត្មាអញនឹងធ្វើយ៉ាងនោះ ។

[ ១៣០ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគត មិនបានប្រហែសធ្វេស ខំព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ក៏ស្គាល់ច្បាស់នូវពន្លឺផង នូវការឃើញរូបទាំងឡាយផង ។ ប៉ុន្តែពន្លឺ និងការឃើញរូបទាំងឡាយនោះ របស់តថាគតមិនទៅយូរប៉ុន្មាន ក៏បាត់ទៅវិញ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះ ដូច្នេះថា ចុះមានហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យពន្លឺ និងការឃើញរូបទាំងឡាយរបស់អាត្មាអញបាត់ទៅ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ការសម្លឹងមើលនូវរូបក្រៃពេក កើតឡើងហើយដល់អាត្មាអញ ឯសមាធិរបស់អាត្មាអញក៏ឃ្លាតទៅ ព្រោះតែមានការសម្លឹងមើលនូវរូបក្រៃពេក

ជាហេតុ កាលបើសមាធិឃ្លាតទៅហើយ ពន្លឺ និងការឃើញរូបទាំងឡាយ ក៏បាត់ទៅដែរ ។ វិចិកិច្ឆា អមនសិការ ថីនមិទ្ធៈ សេចក្តីរន្ធត់កាយ សេចក្តីឆ្មើងឆ្មៃ សេចក្តីក្រវល់ក្រវាយកាយ សេចក្តីព្យាយាមតឹងពេក សេចក្តីព្យាយាមធូរពេក សេចក្តីប្រាថ្នាហួសពេក នានត្តសញ្ញា និងការសម្លឹងមើលនូវរូបក្រៃពេក កើតឡើងមិនបានដល់អាត្មាអញ យ៉ាងណា អាត្មាអញនឹងធ្វើយ៉ាងនោះ ។

[ ១៣១ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគតដឹងច្បាស់ថា វិចិកិច្ឆា ជាឧបក្កិលេស ( គ្រឿងសៅហ្មង ) របស់ចិត្ត ហើយក៏បានលះបង់នូវវិចិកិច្ឆាជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា អមនសិការជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវអមនសិការ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ថីនមិទ្ធៈ ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់ថីនមិទ្ធៈជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីរន្ធត់កាយ ជាឧក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីរន្ធត់កាយ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីឆ្មើងឆ្មៃ ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីឆ្មើងឆ្មៃ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីក្រវល់ក្រវាយកាយ ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីក្រវល់ក្រវាយកាយ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវសេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមធូរពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវ

សេចក្តីព្យាយាមធូរពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវ សេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា នានត្តសញ្ញាជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវនានត្តសញ្ញាជា ឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ការសម្លឹងមើលនូវរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្ត ហើយក៏បានលះបង់នូវការសម្លឹងមើលនូវរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។

[ ១៣២ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគតមិនបានប្រហែសធ្វេស ខំព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ស្គាល់ច្បាស់នូវពន្លឺ តែមិនបានឃើញរូបទាំងឡាយទេ បានឃើញរូបទាំងឡាយ តែមិនបានស្គាល់ច្បាស់នូវពន្លឺទេ រហូតអស់មួយយប់ ក៏មាន រហូតអស់មួយថ្ងៃក៏មាន រហូតអស់មួយយប់ មួយថ្ងៃក៏មាន ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ចុះមានហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យអាត្មាអញ ស្គាល់ច្បាស់នូវពន្លឺ តែមិនបានឃើញរូបទាំង-ឡាយ បានឃើញនូវរូបទាំងឡាយ តែមិនបានស្គាល់ច្បាស់នូវពន្លឺ រហូតអស់មួយយប់ក៏មាន រហូតអស់មួយថ្ងៃក៏មាន រហូតអស់មួយយប់ មួយថ្ងៃក៏មាន ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សម័យណា អាត្មាអញមិនបានធ្វើទុកក្នុងចិត្ត នូវរូបនិមិត្ត តែបានធ្វើទុកក្នុងចិត្តនូវឱភាសនិមិត្ត ( ពន្លឺ ) ប៉ុណ្ណោះ សម័យនោះ អាត្មាអញស្គាល់ច្បាស់នូវពន្លឺ តែមិនបាន

ឃើញរូបទាំងឡាយ មួយទៀត សម័យណា អាត្មាអញ មិនបានធ្វើទុកក្នុងចិត្ត នូវឱភាសនិមិត្ត តែមិនបានធ្វើទុកក្នុងចិត្តនូវរូបនិមិត្ត ( ប៉ុណ្ណោះ ) សម័យនោះ អាត្មាអញបានឃើញរូបទាំងឡាយ តែមិនបានស្គាល់ច្បាស់នូវពន្លឺឡើយ រហូតអស់មួយយប់ ក៏មាន រហូតអស់មួយថ្ងៃ ក៏មាន រហូតអស់មួយយប់មួយថ្ងៃ ក៏មាន ។

[ ១៣៣ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគតមិនបានប្រហែសធ្វេស ខំព្យាយាមដុតកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ក៏ស្គាល់ច្បាស់ពន្លឺ មានប្រមាណតិចផង ឃើញរូបទាំងឡាយមានប្រមាណតិចផង ស្គាល់ច្បាស់ពន្លឺប្រមាណមិនបានផង ឃើញរូបទាំងឡាយប្រមាណមិនបានផង រហូតអស់មួយយប់ ក៏មាន រហូតអស់មួយថ្ងៃ ក៏មាន រហូតអស់មួយយប់ មួយថ្ងៃ ក៏មាន ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ចុះមានហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឲ្យអាត្មាអញស្គាល់ពន្លឺមានប្រមាណតិចផង ឃើញរូបទាំងឡាយមានប្រមាណតិចផង ស្គាល់ច្បាស់នូវពន្លឺ ប្រមាណមិនបានផង ឃើញរូបទាំងឡាយ ប្រមាណមិនបានផង រហូតអស់មួយយប់ក៏មាន រហូតអស់មួយថ្ងៃក៏មាន រហូតអស់មួយយប់ មួយថ្ងៃក៏មាន ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា សម័យណា សមាធិរបស់អាត្មាអញ មានប្រមាណតិច សម័យនោះ ចក្ខុរបស់អាត្មាអញ ក៏មានប្រមាណតិចដែរ ព្រោះតែចក្ខុមានប្រមាណតិច បានជាអាត្មាអញស្គាល់ច្បាស់ពន្លឺ មានប្រមាណតិចផង ឃើញរូបទាំង-

ឡាយ មានប្រមាណតិចផង មួយទៀត សម័យណា សមាធិរបស់អាត្មាអញ ប្រមាណមិនបាន សម័យនោះ ចក្ខុរបស់អាត្មាអញ ប្រមាណមិនបានដែរ ព្រោះតែចក្ខុប្រមាណមិនបាន បានជាអាត្មាអញ ស្គាល់ច្បាស់ពន្លឺប្រមាណមិនបានផង ឃើញរូបទាំងឡាយ ប្រមាណមិនបានផង រហូតអស់មួយយប់ក៏មាន រហូតអស់មួយថ្ងៃក៏មាន រហូតអស់មួយយប់ មួយថ្ងៃក៏មាន ។ ម្នាលអនុរុទ្ធទាំងឡាយ កាលណាបើតថាគតដឹងច្បាស់ថា វិចិកិច្ឆា ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់វិចិកិច្ឆា ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា អមនសិការជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់អមនសិការ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ថីនមិទ្ធៈ ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់ថីនមិទ្ធៈ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីរន្ធត់កាយ ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីរន្ធត់កាយ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីឆ្មើងឆ្មៃ ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីឆ្មើងឆ្មៃ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីក្រវល់ក្រវាយកាយ ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីក្រវល់ក្រវាយកាយ ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីព្យាយាមតឹងពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីព្យាយាមធូរពេកជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់សេចក្តីព្យាយាមធូរពេក ជាឧបក្កិលេសរបស់

ចិត្តចេញ ។ ដឹងច្បាស់ថា សេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្ត ហើយ ក៏បានលះបង់សេចក្តីប្រាថ្នាហួសពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា នានត្តសញ្ញា ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់ នានត្តសញ្ញា ជាឧបក្កិលេសរបស់ចិត្តចេញ ។ ដឹងច្បាស់ថា ការសម្លឹងមើល នូវរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្តហើយ ក៏បានលះបង់ការសម្លឹងមើល នូវរូបក្រៃពេក ជាឧបក្កិលេសរបស់ចិត្តចេញ ។ ម្នាលអនុរុទ្ធទាំងឡាយ តថាគតមានសេចក្តីត្រិះរិះដូច្នេះថា ឧបក្កិលេសណារបស់ចិត្តនៃអាត្មាអញ ឧបក្កិលេសទាំងនោះ អាត្មាអញបានលះបង់អស់ហើយ បើដូច្នោះ មានតែ អាត្មាអញ ចម្រើននូវសមាធិ ៣ ប្រការ ក្នុងកាលឥឡូវនេះ ។

[ ១៣៤ ] ម្នាលអនុរុទ្ធទាំងឡាយ តថាគតក៏បានចម្រើននូវសមាធិ ប្រកបដោយវិតក្ក ប្រកបដោយវិចារផង ។ បានចម្រើននូវសមាធិ មិនមាន វិតក្ក មានតែវិចារផង ។ បានចម្រើននូវសមាធិ មិនមានវិតក្កទាំងមិនមាន វិចារផង ។ បានចម្រើននូវសមាធិ ប្រកបដោយបីតិផង ។ បានចម្រើននូវ សមាធិ មិនមានបីតិផង ។ បានចម្រើននូវសមាធិ ប្រកបដោយសេចក្តី សប្បាយផង ។ បានចម្រើននូវសមាធិ ប្រកបដោយឧបេក្ខាផង ។ ម្នាល អនុរុទ្ធទាំងឡាយ កាលបើតថាគតបានចម្រើនសមាធិ ប្រកបដោយវិតក្ក ប្រកបដោយវិចាររួចហើយ ។ បានចម្រើនសមាធិ មិនមានវិតក្ក មានតែ វិចាររួចហើយ ។ បានចម្រើនសមាធិ មិនមានវិតក្ក ទាំងមិនមានវិចាររួច ហើយ ។ បានចម្រើនសមាធិ ប្រកបដោយបីតិរួចហើយ ។ បានចម្រើន

សមាធិ មិនមានបីតិរួចហើយ ។ បានចម្រើនសមាធិ ប្រកបដោយសេចក្តីសប្បាយរួចហើយ ។ បានចម្រើនសមាធិ ប្រកបដោយឧបេក្ខារួចហើយ ។ សេចក្តីដឹង និងសេចក្តីឃើញ ក៏កើតឡើងដល់តថាគតថា វិមុត្តិរបស់អាត្មាអញ ជាធម្មជាតមិនកម្រើក ជាតិរបស់អាត្មាអញនេះ មានក្នុងទីបំផុត ឥឡូវនេះ សេចក្តីកើតទៀតមិនមានឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអនុរុទ្ធមានអាយុ ក៏មានសេចក្តីត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## ឧបក្កិលេសសូត្រទី ៨ ចប់

# អដ្ឋកថា

## ឧបក្កិលេសសូត្រ

[ ១០៧ ] ឧបក្កិលេសសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ១០៨ ] ក្នុងបទទាំងនោះ បទថា **ឯតទវោច** សេចក្ដីថា មិនមែនក្រាបទូលដោយបំណងនឹងឲ្យបែកគ្នា និងមិនមែនដើម្បីបញ្ចើចបញ្ចើ ពិតហើយ ភិក្ខុនោះមានគំនិតយ៉ាងនេះថា ភិក្ខុទាំងនេះជឿស្ដាប់អញហើយ នឹងវៀរចាក ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់បំណងអនុគ្រោះដើម្បីប្រយោជន៍ក្នុងស្ថានមួយ ទ្រង់នឹងត្រាស់ប្រាប់ហេតុមួយដល់ភិក្ខុទាំងនេះដោយពិត ភិក្ខុទាំងនោះស្ដាប់ហេតុទាំងនោះហើយ នឹងវៀរចាក បន្ទាប់អំពីនោះ ភិក្ខុទាំងនោះនឹងនៅយ៉ាងផាសុក ។ ព្រោះហេតុនោះ ទើបភិក្ខុនោះក្រាបទូលថា **ឥធ ភន្តេ** ដូច្នេះជាដើម ។ ក្នុងបទថា **មា ភណ្ឌនំ** ជាដើម គប្បីបន្ថែមបាឋៈដ៏សេសថា **អកត្ថ** ជាដើមចូលទៅផងដែរ ហើយកាន់យកសេចក្ដីយ៉ាងនេះថា **មា ភណ្ឌនំ** គឺកុំធ្វើការទាស់ទែងគ្នា ។ បទថា **អញ្ញាតរោ** សេចក្ដីថា បានឮថា ភិក្ខុនោះប្រាថ្នាប្រយោជន៍ចំពោះព្រះមានព្រះភាគ គឺបានឮថា ភិក្ខុនោះមានបំណងយ៉ាងនេះថា ភិក្ខុទាំងនេះត្រូវសេចក្ដីក្រោធគ្របសង្កត់ហើយ នឹងមិនស្ដាប់ពាក្យប្រៀនប្រដៅនៃព្រះសាស្ដា សូមព្រះមានព្រះភាគ កាលពោលប្រៀនប្រដៅភិក្ខុទាំងនេះ សូមទ្រង់កុំលំបាកឡើយ ដូច្នេះ ។ ព្រោះដូច្នោះ ទើបក្រាបទូលយ៉ាងនេះ ។

[ ១១១ ] បទថា **បិណ្ឌាយ ចារិសិ** សេចក្តីថា មិនមែនយាងចូលទៅដើម្បីបិណ្ឌបាតតែម្យ៉ាងទេ តែទ្រង់បានអធិដ្ឋានក្នុងព្រះហឫទ័យថា អ្នកដែលឃើញតថាគតហើយ គប្បីចូលគាល់តថាគត ។ សួរថា ទ្រង់អធិដ្ឋានដើម្បីប្រយោជន៍អ្វី ឆ្លើយថា ដើម្បីទ្រង់ទូន្មានភិក្ខុទាំងនោះ ។ ព្រះមានព្រះភាគទ្រង់ត្រឡប់អំពីបិណ្ឌបាតដោយអាការយ៉ាងនោះហើយ ត្រាស់គាថាយ៉ាងនេះថា **បុថុសទ្ទោ សមជនោ** ដូច្នេះជាដើម ហើយទ្រង់ចេញអំពីក្រុងកោសម្ពី ឆ្ពោះទៅកាន់ពាលកលោណការគ្រាម ។ បន្ទាប់អំពីនោះ ទ្រង់យាងទៅកាន់បាចីនវង្សមិគទាយវ័ន បន្ទាប់អំពីនោះ ទ្រង់ចូលទៅកាន់ដងព្រៃឈ្មោះបាលិលេយ្យកៈ ដែលមានដីដ៏ប្រសើរ ឈ្មោះបាលិលេយ្យកៈ ទំនុកបម្រុងទ្រង់គង់អស់ត្រៃមាស ។ សូម្បីពួកអ្នកនគរគិតថា ព្រះសាស្តាស្តេចចូលទៅកាន់វិហារហើយ ពួកយើងនឹងទៅស្តាប់ធម៌ ហើយកាន់ផ្កាកម្រង និងគ្រឿងក្រអូប ឆ្ពោះទៅកាន់វិហារ សួរថា បពិត្រលោកម្ចាស់ ព្រះសាស្តាទ្រង់យាងទៅណា ភិក្ខុទាំងឡាយប្រាប់ថា ពួកអ្នកនឹងគាល់ព្រះសាស្តាបានអំពីណា ទ្រង់យាងមកដោយបំណងថា នឹងសម្រុះសម្រួលភិក្ខុទាំងនេះឲ្យសាមគ្គីគ្នា តែមិនអាចឲ្យព្រមព្រៀងគ្នាបាន ទើបស្តេចចេញទៅហើយ ។ ពួកអ្នកស្រុកទាំងអស់នាំគ្នាពោលទោសថា ពួកខ្ញុំអស់ប្រាក់ទាំងរយទាំងពាន់ ក៏មិនអាចនាំព្រះសាស្តាមកបាន សូម្បីពួកខ្ញុំមិនក្រាបទូលអារាធនា ព្រះអង្គក៏យាងមកឯង ព្រោះអាស្រ័យភិក្ខុទាំងនេះ ធ្វើឲ្យពួកខ្ញុំមិនបានស្តាប់ធម្មកថាចំពោះព្រះភក្ត្រព្រះអង្គ ភិក្ខុទាំងនេះ បួសឧទ្ទិសព្រះសាស្តា កាលទ្រង់ធ្វើឲ្យសាមគ្គី

គ្នា ក៏មិនព្រមស្រុះស្រួលសាមគ្គីគ្នា ដូច្នេះ តើនឹងស្តាប់អ្នកណាទៅវិញ ណ្ហើយចុះ ពួកយើងកុំឲ្យភិក្ខាដល់ភិក្ខុទាំងនេះ ។ ស្អែកឡើង ភិក្ខុទាំងនោះ ទៅបិណ្ឌបាតទូទាំងព្រះនគរ មិនបានភិក្ខាសូម្បីតែមួយវែក ត្រឡប់មកកាន់វិហារហើយ ។ ពួកឧបាសក ឧបាសិកាទាំងឡាយពោលនឹងភិក្ខុទាំងនោះទៀតថា ពួកខ្ញុំដាក់ទណ្ឌកម្មនេះឯងដល់លោកម្ចាស់ទាំងឡាយ ទម្រាំពួកលោកម្ចាស់ឲ្យព្រះសាស្តាទ្រង់អត់ទោស ។ ភិក្ខុទាំងនោះ គិតថា ពួកយើងនឹងឲ្យព្រះសាស្តាអត់ទោស កាលព្រះមានព្រះភាគ មិនទាន់យាងដល់នគរសាវត្ថី បានទៅរង់ចាំនៅក្រុងសាវត្ថីហើយ ព្រះសាស្តាទ្រង់សម្តែងភេទករវត្ថុ ១៨ ប្រការ ដល់ភិក្ខុទាំងនោះហើយ ក្នុងរឿងនេះ មានសេចក្តីដែលពោលក្នុងបាលីមុត្តកៈ មានប្រមាណប៉ុណ្ណោះ ។

ឥឡូវនេះ នឹងវិនិច្ឆ័យក្នុងគាថាជាដើមថា **បុថុសទ្ទោ** ដូចតទៅនេះ ឈ្មោះថា **បុថុសទ្ទោ** ព្រោះអត្ថថា មានសំឡេងខ្លាំង សំឡេងធំនោះឯង ។ បទថា **សមជនោ** បានដល់ បុគ្គលដែលដូចគ្នា គឺស្រដៀងៗ គ្នា អធិប្បាយថា បុគ្គលដែលធ្វើការបែកខ្ញែកគ្នាទាំងអស់នេះ មានសំឡេងខ្លាំងផង មានសំឡេងដូចគ្នាផង ដោយការបន្លឺសំឡេងខ្លាំង លាន់ទៅវិញ ទៅមក ។ បទថា **ន ពាលោ កោចិ មញ្ញថ** សេចក្តីថា មិនមានបុគ្គលណាសូម្បីតែម្នាក់ ដែលដឹងខ្លួនថា អញជាបុគ្គលពាល គ្រប់គ្នាយល់ថា ខ្លួនជាបណ្ឌិតទាំងអស់ ។ បទថា **នាញ្ញំ ភិយ្យោ អមញ្ញរុំ** បានដល់ មិនមានបុគ្គលណាសូម្បីតែម្នាក់ សម្គាល់ខ្លួនថា ជាបុគ្គលពាល អធិប្បាយថា កាលសង្ឃបែកគ្នា ម្នាក់ៗ ក៏

មិនបានសម្គាល់ហេតុដទៃណាមួយឲ្យក្រៃលែងឡើងទៅ គឺមិនសម្គាល់ដល់ហេតុនេះថា សង្ឃបែកគ្នា ព្រោះអាត្មាអញជាហេតុឡើយ ។ បទថា **បរិមុដ្ឋា** ប្រែថា មិនមានស្មារតី ។ បទថា **វាចាគោចរភាណិនោ** លោកផ្លាស់ **រា** អក្ខរៈ ឲ្យទៅជា **រ** អក្ខរៈ សេចក្តីថា និយាយតាមអារម្មណ៍ មិនមានសតិប្បដ្ឋានឃុំគ្រង បានដល់ និយាយតាមទឹកឃើញ ។ បទថា **យាវិច្ឆន្តិ មុខាយាមំ** បានដល់ និយាយទៅត្រឹមតែដើម្បីប្រាថ្នាថ្វីមាត់ អធិប្បាយថា ភិក្ខុមួយរូបក៏មិនព្រមស្ងាត់មាត់ដោយការគោរពក្នុងសង្ឃ ។ បទថា **យេន នីតា** សេចក្តីថា ដែលជម្លោះណានាំទៅកាន់ភាពជាបុគ្គលមុខក្រាស់ គឺមិនមានខ្មាស ។ បទថា **ន តំ វិទូ** សេចក្តីថា មិនដឹងដល់ហេតុនោះថា ការឈ្លោះនេះមានទោសយ៉ាងនេះ ។ បទថា **យេ ច តំ ឧបនយ្ហន្តិ** សេចក្តីថា មនុស្សពួកណាចូលទៅចងសេចក្តីក្រោធ មានអាការជាដើមថា បុគ្គលនេះបានជេរអញដូច្នេះ ។ បទថា **សនន្តនោ** ប្រែថា ជារបស់ចាស់ ។ បទថា **បរេ** សេចក្តីថា វៀរបណ្ឌិតទាំងឡាយហើយ បុគ្គលបន្តជម្លោះដទៃ ឈ្មោះថា ជាបុគ្គលដទៃអំពីបណ្ឌិតនោះ ។ មនុស្សទាំងនោះ កាលបន្តជម្លោះក្នុងកណ្តាលចំណោមសង្ឃ រមែងមិនដឹងថា ពួកយើងនឹងលំបាក គឺនឹងវិនាសជិតស្លាប់ចូលទៅគ្រប់ខណៈ មិនដាច់ ។ បទថា **យេ ច តត្ថ វិជានន្តិ** សេចក្តីថា បណ្តាមនុស្សទាំងនោះ ជនពួកណាជាបណ្ឌិត ដឹងខ្លួនថា ពួកយើងនៅជិតមច្ចុ ដូច្នេះ ។ បទថា **តតោ សម្មន្តិ មេធគា** សេចក្តីថា បណ្ឌិតទាំងនោះដឹងយ៉ាងនេះ កើតយោនិសោមនសិការ រមែងបដិបត្តិដើម្បី

ការចូលទៅស្ងប់រម្ងាប់វិវាទនិងជម្លោះ ។ គាថាថា **អដ្ឋិច្ឆិន្នា** ជាដើមនេះ មានមកក្នុងជាតក លោកពោលសំដៅដល់ព្រះបាទព្រហ្មទត្ត និងទីឃាវុកុមារ ។

ក្នុងព្រះគាថានេះ មានអត្ថដូចតទៅនេះ សូម្បីមនុស្សទាំងនោះ គឺមនុស្សដែលចងពៀរដល់គ្នាបែបនោះ គង់ធ្វើសេចក្តីល្អដល់គ្នាបាន ហេតុអ្វី ទើបពួកអ្នកមិនធ្វើដល់គ្នាបាន ។ ព្រោះពួកអ្នកមិនទាន់ដល់ការកាច់បំបាក់ឆ្អឹងគ្នានិងគ្នា មិនទាន់ដល់ការបំផ្លាញជីវិតគ្នានិងគ្នា មិនទាន់ដល់លួចគោ សេះ និងទ្រព្យគ្នា ។ ទ្រង់ត្រាស់ព្រះគាថាថា **សចេ លភេថ** ដូច្នេះជាដើម ក៏ដើម្បីទ្រង់សម្តែងគុណ និងទោសនៃសម្លាញ់ដែលជាបណ្ឌិត និងសម្លាញ់ដែលជាពាល ។ បទថា **អភិភុយ្យ សព្វានិ បរិស្សយានិ** សេចក្តីថា គប្បីសរសើរមានសតិត្រាច់ទៅជាមួយសម្លាញ់ដែលការពារអន្តរាយ ដែលប្រាកដ និងមិនប្រាកដបាននោះ ។ បទថា **រាជាវ រដ្ឋំ វិជិតំ** សេចក្តីថា គប្បីត្រាច់ទៅ ដូចព្រះមហាជនក និងព្រះបាទអរិន្ទមមហារាជដែលទ្រង់លះដែន ដែលព្រះអង្គឈ្នះហើយ យាងទៅតែម្នាក់ឯង ។ បទថា **មាតង្គរញ្ញេវ នាគោ** សេចក្តីថា ដូចដំរីមាតង្គៈដែលត្រាច់ទៅក្នុងព្រៃ ដូច្នោះ ។ ដំរីធម្មតាៗ លោកហៅថា មាតង្គៈ ។ បទថា **នាគោ** នេះ ជាឈ្មោះនៃដំរីធំ ។ ទើបលោកពោលដូច្នេះថា ត្រាច់ទៅតែម្នាក់ឯង មិនធ្វើនូវបាបទាំងឡាយ ដូចដំរីមាតង្គៈដែលចិញ្ចឹមម្តាយ ត្រាច់ទៅក្នុងព្រៃតែម្នាក់ឯង មិនធ្វើបាប និងដូចដំរីបាលិលេយ្យកៈ ដូច្នោះ ។

[ ១១២ ] បទថា **ពាលកលោណការគាមោ** បានដល់ ស្រុកសួយ

របស់ឧបាលិគហបតី ។ បទថា **តេនុបសង្កមិ** នេះ មានពាក្យសួរថា ទ្រង់យាងចូលទៅដើម្បីអ្វី ឆ្លើយថា បានឮថា ព្រះអង្គទ្រង់ឃើញទោសក្នុងការនៅជាក្រុមរបស់កគ្គភិក្ខុនោះ ទ្រង់ប្រាថ្នានឹងឃើញភិក្ខុដែលនៅម្នាក់ឯង ដូច្នោះទើបយាងចូលទៅក្នុងពាលកលោណការគ្រាម ដូចបុគ្គលត្រូវរងាជាដើមបៀតបៀនហើយ ប្រាថ្នាកម្តៅ ដូច្នោះ ។ បទថា **ធម្មិយា កថាយ** សេចក្តីថា បដិសំយុត្តដោយអានិសង្ស ក្នុងការនៅម្នាក់ឯង ។

[ ១១៣ ] សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគយាងចូលទៅក្នុងបាចីនវង្សទាយវ័ននោះ ឆ្លើយថា ព្រះមានព្រះភាគ ទ្រង់មានពុទ្ធបំណងនឹងជួបភិក្ខុទាំងឡាយ ដែលបន្ទុជម្លោះ ហើយត្រឡប់បាននូវការស្រុះស្រួលសាមគ្គីគ្នា ក្រោយអំពីឃើញទោសនៃជម្លោះនោះ ព្រោះដូច្នោះ ទើបយាងចូលទៅក្នុងបាចីនវង្សទាយវ័ននោះ ដូចបុគ្គលត្រូវរងាជាដើមបៀតបៀនហើយប្រាថ្នាកម្តៅ ដូច្នោះ ។ បទថា **អាយស្មា ច អនុរុទ្ធោ** ជាដើម មានន័យដូចពោលហើយនោះឯង ។

[ ១១៩ ] បទថា **អត្ថិ ខោ បន វោ** សេចក្តីថា គប្បីសួរលោកុត្តរធម៌ដោយសំណួរចុងក្រោយ ។ លោកុត្តរធម៌នោះ មិនមានដល់ព្រះថេរៈទាំង-ឡាយ ព្រោះដូច្នោះ ទើបការសួរដល់លោកុត្តរធម៌ មិនសមគួរឡើយ ហេតុនោះ ទើបទ្រង់សួរឱកាសនៃបរិកម្ម ។

បទថា **ឱភាសំយេវ សញ្ជានាម** បានដល់ ដឹងនូវពន្លឺនៃបរិកម្ម ។ បទថា **ទស្សនញ្ច រូបានំ** បានដល់ ដឹងច្បាស់នូវការឃើញរូបដោយទិព្វចក្ខុ ។

បទថា **តញ្ច និមិត្តំ ន បដិវិជ្ឈាម** សេចក្តីថា ឱភាស និងការឃើញរូបនៃខ្ញុំព្រះអង្គទាំងឡាយ រមែងបាត់ទៅដោយហេតុណា ខ្ញុំព្រះអង្គទាំងឡាយ មិនទាន់ដឹងនូវហេតុនោះ ។

[ ១២០ ] បទថា **តំ ខោ បន វោ អនុរុទ្ធា និមិត្តំ បដិវិជ្ឈិតព្វំ** សេចក្តីថា ពួកអ្នកគួរដឹងហេតុនោះ ។ ព្រះមានព្រះភាគ ទ្រង់ប្រារព្ធទេសនានេះ ដោយពាក្យថា **អហំបិ សុទំ** ដូច្នេះជាដើម ក៏ដើម្បីទ្រង់សម្តែងថា ម្នាលអនុរុទ្ធ ពួកអ្នកសៅហ្មងឬហ្ន៎ សូម្បីតថាគតក៏ធ្លាប់សៅហ្មងមកហើយដោយឧបក្កិលេសទាំង ១១ ប្រការនេះ ។ ក្នុងបទថា **វិចិកិច្ឆា ខោ មេ** ជាដើម សេចក្តីថា ព្រះមហាសត្វចម្រើនអាលោកកសិណ ហើយឃើញរូបផ្សេងៗ ដោយទិព្វចក្ខុ ទើបកើតការសង្ស័យថា នេះអ្វីហ្ន៎ នេះអ្វីហ្ន៎ ។ បទថា **សមាធិ ចវិ** សេចក្តីថា ទើបបរិកម្មសមាធិកម្រើក ។ បទថា **ឱភាសោ** សេចក្តីថា សូម្បីឱភាសនៃបរិកម្មក៏បាត់ទៅ គឺមិនឃើញរូបដោយទិព្វចក្ខុ ។

[ ១២១ ] បទថា **អមនសិការោ** សេចក្តីថា វិចិកិច្ឆារមែងកើតដល់បុគ្គលដែលឃើញរូប គឺកើតអមនសិការថា ឥឡូវនេះ អញមិនបានដាក់ចិត្តណាមួយ ។

[ ១២២ ] បទថា **ថីនមិទ្ធំ** សេចក្តីថា កាលមិនដាក់ចិត្តដល់អ្វីមួយ ថីនមិទ្ធៈក៏កើតឡើង ។

[ ១២៣ ] បទថា **ឆម្ភិតត្តំ** សេចក្តីថា កិក្ខុចម្រើនអាលោកកសិណបែរមុខទៅកាន់ហិមវន្តប្រទេស បានឃើញសត្វផ្សេងៗ ដូចជាយក្ខ អារក្ខទឹក

ពស់ថ្លាន់ជាដើម ពេលនោះ ការស្រៀវខ្លាចកើតឡើងហើយដល់លោក ។

[ ១២៤ ] បទថា **ឧព្ពិលំ** សេចក្តីថា កាលភិក្ខុគិតថា វត្ថុដែលអញឃើញថា គួរខ្លាចក្នុងពេលមើល តាមប្រក្រតីរមែងមិនមាន កាលមិនមានហេតុអ្វីចាំបាច់ខ្លាច ដូច្នេះ ការក្រោកផ្អើលក៏អស់ទៅ ។ បទថា **សកិំ ទេវ** សេចក្តីថា គប្បីជួបរណ្តៅទ្រព្យ ៥ រណ្តៅ ដោយការជីកត្រឹមតែម្តងប៉ុណ្ណោះ ។ បទថា **ទុដ្ឋុល្លំ** សេចក្តីថា សេចក្តីព្យាយាមដែលអញបានផ្គងយ៉ាងមាំទាំ ត្រូវសេចក្តីភ័យខ្លាចដែលកើតឡើងដល់អញនោះ ធ្វើឲ្យរាថយ ។ បន្ទាប់អំពីនោះ មានតែការក្រវល់ក្រវាយ ។ ពាក្យថា ក្រវល់ក្រវាយកាយ សេចក្តីថា ធ្វើនូវការក្រវល់ក្រវាយ គឺការៈដែលរាងកាយខ្ជិលច្រអូសកើតឡើង ។

[ ១២៦ ] បទថា **អច្ចារទ្ធវីរិយំ** សេចក្តីថា ការព្យាយាមដែលប្រារព្ធហួសពេកកើតហើយដល់ភិក្ខុ ដែលផ្តើមតាំងសេចក្តីព្យាយាមថ្មី ដោយគិតថា ការតក់ស្លុត ធ្វើសេចក្តីព្យាយាមរបស់អញឲ្យរាថយ ទើបការប្រទូស្តកើតឡើងបាន ។ បទថា **បតមេយ្យ** ប្រែថា គប្បីស្លាប់ ។

[ ១២៧ ] បទថា **អតិលីនវីរិយំ** សេចក្តីថា កាលអញផ្គងសេចក្តីព្យាយាមយ៉ាងនេះ ធ្វើការព្យាយាមធូរថយពេក ក៏កើតឡើងបានទៀត ។

[ ១២៨ ] បទថា **អភិជប្បា** សេចក្តីថា កាលអញចម្រើនអាលោក-កសិណ បែរមុខចំពោះទេវលោក ឃើញពួកទេវតា តណ្ហាក៏កើតឡើង ។

[ ១២៩ ] បទថា **នានត្តសញ្ញា** សេចក្តីថា កាលអញចម្រើនអាលោក-កសិណ បែរមុខចំពោះទេវលោកតាមកាល ហើយដាក់ចិត្តដល់រូប មានសភាព

ផ្សេងៗគ្នា ដោយគិតថា លុះអញដាក់ចិត្តដល់រូបដែលមានកំណើតតែមួយ តណ្ហាកើតឡើងហើយ អញនឹងដាក់ចិត្តដល់រូបមានសភាពផ្សេងៗ ដូច្នេះ ការសម្គាល់ភាវៈថា ការផ្សេងគ្នាក៏កើតឡើង ។

[ ១៣០ ] បទថា **អតិនិជ្ឈាយិតត្តំ** សេចក្តីថា កាលអញដាក់ចិត្តដល់រូបដែលមានបែបផ្សេងគ្នា ការសម្គាល់សភាវៈថាផ្សេងគ្នា ក៏កើតឡើង កាលអញតាំងចិត្តថា នឹងដាក់ចិត្តដល់រូបដែលមានកំណើតតែមួយ គួរប្រាថ្នា ឬមិនគួរប្រាថ្នា ហើយដាក់ចិត្តយ៉ាងនោះ រូបដែលមានការសម្លឹងពន់ពេកជាលក្ខណៈក៏កើត ។

[ ១៣២ ] បទថា **ឱភាសនិមិត្តំ មនសិករោមិ** សេចក្តីថា អញមានការដឹងដូច្នេះថា អញដាក់ចិត្តតែក្នុងពន្លឺនៃបរិកម្មតែម្យ៉ាង ។ បទថា **ន ច រូបានិ បស្សាមិ** សេចក្តីថា អញមិនឃើញរូបដោយទិព្វចក្ខុ ។ បទថា **រូបនិមិត្តំ មនសិករោមិ** សេចក្តីថា អញដាក់ចិត្តដល់រូបដែលជាអារម្មណ៍ប៉ុណ្ណោះ ដោយទិព្វចក្ខុ ។

[ ១៣៣ ] បទថា **បរិត្តញ្ចេវ ឱភាសំ** បានដល់ ពន្លឺក្នុងកម្មដ្ឋានតិចតួច ។ បទថា **បរិត្តានិ ច រូបានិ** បានដល់ រូបក្នុងព្រះកម្មដ្ឋានបន្តិចបន្តួច ។ បណ្ឌិតគប្បីជ្រាបទុតិយវារៈដោយបរិយាយផ្ទុយគ្នា ។ បទថា **បរិត្តោ សមាធិ** បានដល់ ឱភាសនៃបរិកម្មបន្តិចបន្តួច ។ តែក្នុងទីនេះ លោកពោលបរិកម្ម-សមាធិថា បន្តិចបន្តួច ដូច្នេះ សំដៅដល់ពន្លឺបន្តិចបន្តួច ។ បទថា **បរិត្តំ តស្មឹ សមយេ** សេចក្តីថា ក្នុងសម័យនោះ ទិព្វចក្ខុក៏មានបន្តិចបន្តួច ។

ក្នុងអប្បមាណវារៈ ក៏មានន័យនេះដូចគ្នា ។

[ ១៣៤ ] បទថា **អវិតក្កំបិ វិចារមត្តំ** បានដល់ សមាធិក្នុងទុតិ-យជ្ឈាន ក្នុងបញ្ចកន័យ ។ បទថា **អវិតក្កំបិ អវិចារំ** បានដល់ សមាធិក្នុងពួក ៣ នៃឈាន ទាំងក្នុងចតុក្កន័យ ទាំងក្នុងបញ្ចកន័យ ។ បទថា **សប្បីតិកំ** បានដល់ សមាធិក្នុងទុកជ្ឈាន និងតិកជ្ឈាន ។

បទថា **និប្បីតិកំ** បានដល់ សមាធិក្នុងទុកទុកជ្ឈាន ។ បទថា **សាត-សហគតំ** បានដល់ សមាធិក្នុងតិកចតុក្កជ្ឈាន ។ បទថា **ឧបេក្ខាសហគតំ** នេះ ក្នុងចតុក្កន័យ បានដល់ សមាធិក្នុងចតុក្កជ្ឈាន ក្នុងបញ្ចកន័យ បានដល់ សមាធិក្នុងបញ្ចមជ្ឈាន ។

សួរថា ព្រះមានព្រះភាគ ទ្រង់ចម្រើនសមាធិមាន ៣ យ៉ាងនេះ ក្នុងវេលាណា ឆ្លើយថា ព្រះមានព្រះភាគ ប្រថាប់គង់នាមណ្ឌលពោធិព្រឹក្ស ទ្រង់ចម្រើនសមាធិយ៉ាងនេះ ក្នុងបច្ឆិមយាម ។

ក្នុងបឋមមគ្គ បានជាអង្គប្រកបនៃបឋមជ្ឈានដល់ព្រះមានព្រះភាគ ។ ទុតិយមគ្គជាដើម ក៏បានជាអង្គប្រកបនៃទុតិយជ្ឈាន តតិយជ្ឈាន និងចតុ-ត្ថជ្ឈាន ។ ក្នុងបញ្ចកន័យ បញ្ចមជ្ឈានមិនមានមគ្គ ។ ពាក្យថា មគ្គនោះ ចាត់ជាលោកិយនេះ លោកពោលសំដៅដល់មគ្គដែលលាយដោយលោកិយ និងលោកុត្តរ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ។៚

**អដ្ឋកថា ឧបក្កិលេសសូត្រ ចប់**

**សូត្រទី ៨ ចប់**

# សុត្តន្តបិដក

## ពាលបណ្ឌិតសូត្រទី ៩

[ ១៣៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ កាល ព្រះមានព្រះភាគគង់នៅក្នុងវត្តនោះ បានត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំង-ឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ១៣៦ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល មានហេតុជាគ្រឿងចំណាំថាពាល មានហេតុជាគ្រឿងសម្គាល់ថាពាល មានចរិតជាពាល ៣ យ៉ាងនេះ ។ ហេតុ ៣ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលក្នុងលោកនេះ ជាអ្នកគិតគំនិតអាក្រក់ ១ និយាយសម្តីអាក្រក់ ១ ធ្វើអំពើអាក្រក់ ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលពាល ជាអ្នកមិនគិតគំនិតអាក្រក់ផង មិននិយាយសម្តីអាក្រក់ផង មិនធ្វើអំពើអាក្រក់ផងទេ ។ តើពួកបណ្ឌិតណា នឹងស្គាល់គេថា អ្នកដ៏ចម្រើននេះ ជាមនុស្សពាល ជាអសប្បុរស ដូច្នេះបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល តែងជាអ្នកគិតគំនិតអាក្រក់ផង និយាយសម្តីអាក្រក់ផង ធ្វើអំពើអាក្រក់ផង ព្រោះហេតុណា ហេតុនោះ បានជាបណ្ឌិតទាំងឡាយ ស្គាល់គេថា អ្នកដ៏ចម្រើននេះ ជាមនុស្សពាល ជាអសប្បុរសបាន ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង តែងទទួលទុក្ខ ទោមនស្ស ៣ យ៉ាង ក្នុងបច្ចុប្បន្ននេះ ។

[ ១៣៧ ] ម្នាលភិក្ខុទាំងឡាយ បើបុគ្គលពាល អង្គុយក្នុងសាលាក្តី អង្គុយក្នុងច្រកក្តី អង្គុយក្នុងផ្លូវបែកជា ៤ ក្តី ចំណែកអ្នកផងដែលអង្គុយក្នុងបរិស័ទនោះ តែងប្រឹក្សាពាក្យ ( ថ្លែងអំពីទោស ) ដែលកើតអំពីអំពើនោះ សមគួរដល់អំពើនោះ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើបុគ្គលពាល ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ និយាយកុហក ជាអ្នកតាំងនៅក្នុងសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល តែងគិតក្នុងពាក្យដែលអ្នកផងនិយាយនោះ យ៉ាងនេះថា អ្នកផងតែងប្រឹក្សាពាក្យណា ដែលកើតអំពីអំពើនោះ សមគួរដល់អំពើនោះ ធម៌ទាំងឡាយនោះ ក៏មាននៅក្នុងអញផង ខ្លួនអញសោត ក៏ប្រាកដក្នុងធម៌ទាំងនោះផង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល តែងទទួលទុក្ខ ទោមនស្សទី ១ នេះ ក្នុងបច្ចុប្បន្ន ។

[ ១៣៨ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពាលឃើញព្រះរាជាទាំងឡាយ កាលចាប់ចោរ ដែលប្រព្រឹត្តអាក្រក់បានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយផ្តៅខ្លះ ឲ្យវាយដោយដំបងខ្លីខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ឲ្យកាត់ទាំងដៃទាំងជើងខ្លះ ឲ្យកាត់ស្លឹកត្រចៀកខ្លះ ឲ្យកាត់ច្រមុះខ្លះ ឲ្យកាត់ទាំងស្លឹកត្រចៀកទាំងច្រមុះខ្លះ ឲ្យធ្វើពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ ឲ្យធ្វើនូវសង្ខមុណ្ឌិកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យរលីងដូចជាសម្បកស័ង្ខខ្លះ ឲ្យធ្វើរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហូខ្លះ ឲ្យធ្វើនូវជោតិ

មាលិកកម្ម គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ឲ្យធ្វើនូវហត្ថប្បជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ឲ្យធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើដូចជាគេពន្លាត់ស្បែកពពែខ្លះ ឲ្យធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សម្បកឈើខ្លះ ឲ្យធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាជើងសត្វទ្រាយខ្លះ ឲ្យធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេថ្ពក់មាត់ដោយកាង ឬសន្ទូចខ្លះ ឲ្យធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខូចសរីរៈប្រមាណប៉ុនកហាបណៈមួយៗ ខ្លះ ឲ្យធ្វើនូវខារាបតច្ឆិកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ឲ្យធ្វើនូវពលិឃបរិវត្តិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាបង្វិលជើងគុល ឬសសរគោលខ្លះ ឲ្យធ្វើនូវបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ ឲ្យស្រោចដោយប្រេងដ៏ក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ ឲ្យកាត់ក្បាលដោយដាវខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលតែងត្រិះរិះក្នុងអំពើទាំងនោះ យ៉ាងនេះថា ព្រះរាជាទាំងឡាយ ចាប់ចោរដែលប្រព្រឹត្តអាក្រក់បានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យវាយដោយរំពាត់ខ្លះ ។បេ។ ឲ្យកាត់ក្បាលដោយដាវខ្លះ ព្រោះហេតុតែបាបកម្ម មានសភាពយ៉ាងណាៗ ។ ធម៌ទាំងឡាយនោះ ក៏មាននៅក្នុងអញផង ខ្លួនអញសោត ក៏ប្រាកដក្នុងធម៌ទាំងនោះផង ។ បើព្រះរាជាទាំងឡាយ ជ្រាបនូវអញហើយ មុខជាព្រះរាជានឹងចាប់អញ ហើយត្រាស់បង្គាប់ ឲ្យធ្វើកម្មករណ៍ផ្សេងៗ មិនខាន គឺឲ្យវាយដោយរំពាត់ខ្លះ ។បេ។ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ ឲ្យកាត់ក្បាលដោយដាវខ្លះ ។ ម្នាល

ភិក្ខុទាំងឡាយ បុគ្គលពាលតែងទទួលទុក្ខ ទោមនស្សទី ២ នេះឯង ក្នុងបច្ចុប្បន្ន ។

[ ១៣៩ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត បុគ្គលពាល កាលឡើងកាន់តាំងក្តី ឡើងកាន់គ្រែក្តី ដេកលើផែនដីក្តី អំពើអាក្រក់ទាំងឡាយ គឺការប្រព្រឹត្តអាក្រក់ដោយកាយ ប្រព្រឹត្តអាក្រក់ដោយវាចា ប្រព្រឹត្តអាក្រក់ដោយចិត្តណា ដែលគេធ្វើទុកក្នុងកាលមុន អំពើអាក្រក់ទាំងនោះឯង តែងគ្របដណ្តប់ សង្កត់សង្កិន រួបរឹតគេ ក្នុងសម័យនោះ ។ ម្នាលភិក្ខុទាំងឡាយ ស្រមោលនៃកំពូលភ្នំដ៏ធំ តែងក្រាលរាលដាល គ្របលើផែនដី ក្នុងវេលាថ្ងៃរសៀល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចបុគ្គលពាល កាលឡើងកាន់តាំងក្តី ឡើងកាន់គ្រែក្តី ដេកលើផែនដីក្តី អំពើអាក្រក់ទាំងឡាយ គឺការប្រព្រឹត្តអាក្រក់ដោយកាយ ប្រព្រឹត្តអាក្រក់ដោយវាចា ប្រព្រឹត្តអាក្រក់ដោយចិត្តណា ដែលធ្វើទុកក្នុងកាលមុន អំពើអាក្រក់នោះឯង តែងគ្របដណ្តប់ សង្កត់សង្កិន រួបរឹតគេ ក្នុងសម័យនោះ ដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល តែងគិតក្នុងអារម្មណ៍ ដែលប្រាកដក្នុងចក្ខុទ្វារនោះ យ៉ាងនេះថា អើហ្ន៎ អាត្មាអញមិនបានធ្វើអំពើល្អ មិនបានធ្វើកុសល មិនបានធ្វើបុណ្យ សម្រាប់ការពារភ័យទុកសោះ អាត្មាអញធ្វើតែបាប ធ្វើតែអំពីអាក្រក់ ធ្វើតែអំពីក្តៅក្រហាយទុក ពួកជនដែលមិនបានធ្វើអំពើល្អ មិនបានធ្វើកុសល មិនបានធ្វើបុណ្យ សម្រាប់ការពារភ័យទុក ជាអ្នកបានធ្វើតែអំពើបាប ធ្វើតែអំពើអាក្រក់ ធ្វើតែអំពើក្តៅក្រហាយទុក រមែងមានគតិ

ណា អាត្មាអញនឹងទៅកាន់គតិនោះ ក្នុងបរលោក ។ បុគ្គលពាលនោះ តែង ក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្តីវង្វេង ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាល តែងទទួលទុក្ខ ទោមនស្សទី ៣ នេះឯង ក្នុងបច្ចុប្បន្ន ។

[ ១៤០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។ ម្នាលភិក្ខុទាំងឡាយ អ្នកផងដែលនិយាយតាមហេតុ តែងនិយាយចំពោះទីណាថា ជាទីមិនគួរប្រាថ្នាតែមួយយ៉ាង មិនគួរត្រេកអរតែមួយយ៉ាង មិនគួរពេញចិត្តតែមួយយ៉ាង ដូច្នេះ ទីនោះ គឺនរកនុ៎ះឯង ដែលអ្នកផងនិយាយតាមហេតុ តែងនិយាយថា ជាទីមិនគួរប្រាថ្នាតែមួយយ៉ាង មិនគួរត្រេកអរតែមួយយ៉ាង មិនគួរពេញចិត្តតែមួយយ៉ាង ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មិនងាយនឹងធ្វើឧបមា ឲ្យដល់កម្រិតនរកដែលមានទុក្ខបានឡើយ ។

[ ១៤១ ] កាលបើព្រះអង្គទ្រង់ត្រាស់យ៉ាងនេះហើយ មានភិក្ខុមួយរូប ក្រាបបង្គំទូលសួរសេចក្តីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើនចុះព្រះអង្គអាចនឹងធ្វើសេចក្តីឧបមាបានឬទេ ។ ព្រះមានព្រះភាគត្រាស់តបថា ម្នាលភិក្ខុ តថាគតអាចនឹងធ្វើបាន រួចទ្រង់សម្តែងថា ម្នាលភិក្ខុទាំង-ឡាយ ដូចពួករាជបុរស ចាប់ចោរប្រព្រឹត្តអាក្រក់បានហើយ នាំមកថ្វាយព្រះរាជាទូលថា បពិត្រព្រះសម្មតិទេព អ្នកនេះជាចោរ ប្រព្រឹត្តអាក្រក់នឹងព្រះ

អង្គ បើទ្រង់សព្វព្រះហឫទ័យនឹងដាក់អាជ្ញាណា ដល់ចោរនេះ សូមទ្រង់ដាក់អាជ្ញានោះចុះ ។ ព្រះរាជាមានព្រះឱង្ការ យ៉ាងនេះថា នែប្រស្ដែង ចូរអ្នករាល់គ្នា ទៅយកលំពែងមួយរយ ចាក់បុរសនេះ ក្នុងវេលាព្រឹកព្រហាមចុះ ។ ពួករាជបុរស ក៏យកលំពែងមួយរយ ចាក់បុរសនោះ ក្នុងវេលាព្រឹកព្រហាម ។ លុះវេលាថ្ងៃត្រង់ ព្រះរាជាមានព្រះឱង្ការសួរយ៉ាងនេះថា នែប្រស្ដែង ចុះបុរសនោះ តើដូចម្ដេចទៅ ។ ពួករាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិទេព បុរសនោះរស់នៅឡើយទេ ។ ព្រះរាជាត្រាស់បង្គាប់យ៉ាងនេះថា នែប្រស្ដែង ចូរអ្នករាល់គ្នា ទៅយកលំពែងមួយរយ ចាក់បុរសនោះ ក្នុងវេលាថ្ងៃត្រង់ចុះ ។ ពួករាជបុរស យកលំពែងមួយរយ ចាក់បុរសនោះ ក្នុងវេលាថ្ងៃត្រង់ ។ លុះវេលាថ្ងៃរសៀល ព្រះរាជាក៏មានព្រះឱង្ការសួរយ៉ាងនេះថា នែប្រស្ដែង ចុះបុរសនោះ តើដូចម្ដេចទៅ ។ ពួករាជបុរសក្រាបទូលថា បពិត្រព្រះសម្មតិ-ទេព បុរសនោះរស់នៅឡើយទេ ។ ព្រះរាជាមានព្រះឱង្ការបង្គាប់យ៉ាងនេះថា នែប្រស្ដែង ចូរអ្នករាល់គ្នា ទៅយកលំពែងមួយរយ ចាក់បុរសនោះ ក្នុងវេលាថ្ងៃរសៀលចុះ ។ លុះវេលាថ្ងៃរសៀល ពួករាជបុរស ក៏យកលំពែងមួយរយ ចាក់បុរសនោះទៀត ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនោះថាដូចម្ដេច បុរសនោះ កាលបើចាក់ ដោយលំពែងបីរយ តើនឹងទទួលទុក្ខ ទោមនស្ស ព្រោះលំពែងនោះជាហេតុ ដែរឬទេ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុរសនោះសូម្បីគេចាក់ដោយលំពែងតែមួយក៏ទទួលទុក្ខ ទោមនស្ស ព្រោះលំពែងនោះ ជាហេតុទៅហើយ ចាំបាច់និយាយ

ថ្វីដល់ទៅចាក់ ដោយលំពែងបីរយ ។

[ ១៤២ ] គ្រានោះឯង ព្រះមានព្រះភាគទ្រង់ចាប់ថ្មតូច ប្រមាណប៉ុនបាតដៃ ហើយត្រាស់សួរពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច ដុំថ្មប្រមាណប៉ុនបាតដៃ ដែលតថាគតកំពុងកាន់នេះ និងស្តេចភ្នំហិមពាន្ត តើណាធំជាង ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដុំថ្មតូចប្រមាណប៉ុនបាតដៃ ដែលព្រះអង្គកំពុងកាន់នេះ តូចពេកណាស់ ប្រៀបផ្ទឹមនឹងស្តេចភ្នំហិមពាន្តនោះ មិនដល់នូវការរាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីនេះ មានឧបមេយ្យដូចជាបុរសដែលគេចាក់ដោយលំពែងបីរយ រមែងរងទុក្ខ ទោមនស្សណា ព្រោះលំពែងនោះជាហេតុ ។ ទុក្ខនោះឯង ប្រៀបផ្ទឹមនឹងទុក្ខ របស់នរក ក៏មិនដល់នូវការរាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ។

[ ១៤៣ ] ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ធ្វើកម្មករណ៍ឈ្មោះបញ្ចវិធពន្ធន៍ ( ចំណង ៥ ប្រការ ) ចំពោះសត្វនរកនោះ គឺផ្តេក ( សត្វនរកនោះ ) ហើយបោះដែកគោលដ៏ក្តៅ ត្រង់ដៃ ( ខាងស្តាំ ) ១ បោះដែកគោលដ៏ក្តៅ ត្រង់ដៃខាងឆ្វេង ១ បោះដែកគោលដ៏ក្តៅត្រង់ជើង ( ខាងស្តាំ ) ១ បោះដែកគោលដ៏ក្តៅ ត្រង់ជើងខាងឆ្វេង ១ បោះដែកគោលដ៏ក្តៅចំកណ្តាលទ្រូង ១ ។ សត្វនោះរងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សា ក្នុងទីនោះ បើបាបកម្មនោះ មិនទាន់អស់ដរាបណា ក៏មិនធ្វើមរណកាល ដរាបនោះ ។ ម្នាលភិក្ខុ

ទាំងឡាយ លុះពួកនិរយបាល ផ្តេកសត្វនរកនោះរួចហើយ ទើបយកដឹងចាំង ។ សត្វនោះ ក៏រងទុក្ខវេទនា ក្លាខ្លាំង ក្នុងទីនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាលចាប់សត្វនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ហើយ ប្រាសដោយកាំបិតព្រា ។ សត្វនោះ ក៏រងទុក្ខវេទនា ក្លាខ្លាំង ក្នុងទីនោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ទឹមសត្វនោះនឹងរថ ហើយបរទៅបរមក លើប្រឹថពី ដែលភ្លើងកំពុងឆេះសព្វ ភ្លឺសន្ធោសន្ធៅ ប្រាលផ្សា ។ សត្វនោះ ក៏រងទុក្ខវេទនា ក្លាខ្លាំង ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ប្រើសត្វនោះឲ្យឡើងភ្នំ ឲ្យចុះអំពីភ្នំរងើកភ្លើងដ៏ធំ ដែលកំពុងឆេះក្តៅសព្វ ភ្លឺសន្ធោសន្ធៅ ប្រាលផ្សា ។ សត្វនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងទីនោះ បើបាបកម្មនោះ មិនទាន់អស់ដរាបណា ក៏មិនធ្វើមរណកាលដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់សត្វនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ទម្លាក់ទៅក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះក្តៅសព្វ ភ្លឺសន្ធោសន្ធៅ ប្រាលផ្សា ។ សត្វនោះ ឆេះនឹងកម្សួលពពុះ ក្នុងខ្ទះទង់ដែងនោះ ។ កាលសត្វនោះ ឆេះនឹងកម្សួលពពុះ ក្នុងខ្ទះទង់ដែងនោះ ចួនកាលអណ្តែតឡើងលើម្តង ចួនកាលអណ្តែតចុះក្រោមម្តង ចួនកាលអណ្តែតទទឹងម្តង ។ សត្វនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងខ្ទះទង់ដែងនោះ បើបាបកម្មនោះមិនទាន់អស់ ដរាបណា ក៏មិនធ្វើមរណកាលដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ក៏ចាប់បោះសត្វនោះ ទៅក្នុងមហានរក ។ ម្នាលភិក្ខុទាំងឡាយ មហានរកនោះសោត

មានជ្រុងបួន មានទ្វារបួន បែងចែកដោយចំណែកៗ
មានរបងដែកព័ទ្ធជុំវិញ គ្របដោយគម្របដែក ។
ផ្ទៃក្រោមនៃមហានរកនោះ សុទ្ធតែដែក មាន
ភ្លើងឆេះភ្លឺប្រាលរន្ទាលផ្សាយទៅ បានមួយរយ
យោជន៍ជុំវិញ តាំងនៅសព្វៗកាល ។

ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងរៀបរាប់ អំពីនរកដោយអនេក បរិយាយទៅក៏បាន ។ ម្នាលភិក្ខុទាំងឡាយ តែដំណើរដែលតថាគតពោលទៅ មិនងាយនឹងដល់កម្រិតនរក ដែលមានទុក្ខបានឡើយ ។

[ ១៨៤ ] ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន ( ខ្លះ ) មានស្មៅជាអាហារ ។ ពួកសត្វតិរច្ឆានទាំងនោះ រមែងស៊ីស្មៅស្រស់ ច្រឹបផ្តាច់ដោយធ្មេញ ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកសត្វតិរច្ឆាន ដែលមានស្មៅជាអាហារ តើអ្វីខ្លះ គឺសេះ គោ លា ពពែ ម្រឹគ ឬក៏សត្វតិរច្ឆានណាមួយ ដទៃទៀត ដែលមានស្មៅជាអាហារដូចគ្នា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង ជាអ្នកជាប់នឹងរសអាហារ ក្នុងកាលពីមុន ក្នុងលោកនេះ ហើយធ្វើកម្មដ៏លាមក ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកសត្វ ដែលមានស្មៅជាអាហារនោះ ។

[ ១៨៥ ] ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន ( ខ្លះ ) មានលាមកជាអាហារ ។ ពួកសត្វតិរច្ឆានទាំងនោះ គ្រាន់តែធុំក្លិនលាមកអំពីចម្ងាយ ក៏ស្ទុះទៅដោយគិតថា យើងនឹងស៊ី ក្នុងទីនុ៎ះ យើងនឹងស៊ី ក្នុងទីនុ៎ះ ។ ពួក

ព្រាហ្មណ៍ តែងស្ទុះទៅតាមក្លិននៃគ្រឿងបូជា ដោយគិតថា យើងនឹងបរិភោគ ក្នុងទីនុ៎ះ យើងនឹងបរិភោគ ក្នុងទីនុ៎ះ សេចក្ដីនេះមានឧបមាយ៉ាងណា ម្នាល ភិក្ខុទាំងឡាយ ពួកសត្វតិរច្ឆានដែលមានលាមកជាអាហារ ពួកសត្វតិរច្ឆាន នោះ គ្រាន់តែធុំក្លិនលាមកអំពីចម្ងាយ ក៏ស្ទុះទៅដោយគិតថា យើងនឹងស៊ីក្នុង ទីនុ៎ះ យើងនឹងស៊ីក្នុងទីនុ៎ះ ក៏មានឧបមេយ្យយ៉ាងនោះឯង ។ ម្នាលភិក្ខុទាំង- ឡាយ ពួកសត្វតិរច្ឆានដែលមានលាមកជាអាហារ តើអ្វីខ្លះ គឺមាន់ ជ្រូក ឆ្កែ ចចក ឬក៏សត្វតិរច្ឆានណាមួយក្រៅពីនេះទៀត ដែលមានលាមកជាអាហារ ដូចគ្នា ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង ជាអ្នកជាប់នឹងរសអាហារ ក្នុងកាលមុន ក្នុងលោកនេះ ហើយធ្វើនូវកម្មដ៏លាមកក្នុងលោកនេះ លុះបែក ធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកសត្វ ដែលមានលាមកជា អាហារនោះ ។

[ ១៤៦ ] ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន កើតក្នុងទីងងឹត ចាស់ក្នុងទីងងឹត ស្លាប់ក៏ក្នុងទីងងឹត ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកសត្វតិរច្ឆាន កើតក្នុងទីងងឹត ចាស់ក្នុងទីងងឹត ស្លាប់ក៏ក្នុងទីងងឹត តើអ្វីខ្លះ គឺកន្លាត ទាក ជន្លេន ឬក៏សត្វតិរច្ឆានណាមួយក្រៅពីនេះទៀត ដែលកើតក្នុងទីងងឹត ចាស់ ក្នុងទីងងឹត ស្លាប់ក៏ក្នុងទីងងឹតដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះ ឯង ជាអ្នកជាប់នឹងរសអាហារក្នុងកាលមុន ក្នុងលោកនេះ ហើយធ្វើកម្មដ៏ លាមក ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹង ពួកសត្វដែលកើតក្នុងទីងងឹត ចាស់ក្នុងទីងងឹត ស្លាប់ក៏ក្នុងទីងងឹតនោះ ។

[ ១៤៧ ] ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន កើតក្នុងទឹក ចាស់ក្នុងទឹក ស្លាប់ក៏ក្នុងទឹក ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកសត្វតិរច្ឆានកើតក្នុងទឹក ចាស់ក្នុងទឹក ស្លាប់ក៏ក្នុងទឹក តើអ្វីខ្លះ គឺត្រី អណ្ដើក ក្រពើ ឬក៏សត្វតិរច្ឆានណាមួយក្រៅពីនេះទៀត ដែលកើតក្នុងទឹក ចាស់ក្នុងទឹក ស្លាប់ក៏ក្នុងទឹកដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង ជាអ្នកជាប់នឹងរសអាហារក្នុងកាលមុន ក្នុងលោកនេះ ហើយធ្វើនូវកម្មដ៏លាមក ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកសត្វ ដែលកើតក្នុងទឹក ចាស់ក្នុងទឹក ស្លាប់ក៏ក្នុងទឹកនោះ ។

[ ១៤៨ ] ម្នាលភិក្ខុទាំងឡាយ មានពួកសត្វតិរច្ឆាន កើតក្នុងទីមិនស្អាត ចាស់ក្នុងទីមិនស្អាត ស្លាប់ក៏ក្នុងទីមិនស្អាត ។ ម្នាលភិក្ខុទាំងឡាយ ចុះពួកសត្វតិរច្ឆាន កើតក្នុងទីមិនស្អាត ចាស់ក្នុងទីមិនស្អាត ស្លាប់ក៏ក្នុងទីមិនស្អាត តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលកើតក្នុងត្រីស្អុយក៏មាន ចាស់ក្នុងត្រីស្អុយក៏មាន ស្លាប់ក្នុងត្រីស្អុយក៏មាន ក្នុងសាកសពស្អុយក៏មាន ... ក្នុងនំស្អុយក៏មាន ... ក្នុងរណ្ដៅជ្រាំក៏មាន ... កើតក្នុងប្រឡាយបង្ហូរជ្រាំក៏មាន ។បេ។ ឬក៏ពួកសត្វតិរច្ឆានណាមួយក្រៅពីនេះទៀត ដែលកើតក្នុងទីមិនស្អាត ចាស់ក្នុងទីមិនស្អាត ស្លាប់ក៏ក្នុងទីមិនស្អាតដែរ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង ជាអ្នកជាប់នឹងរសអាហារក្នុងកាលមុន ក្នុងលោកនេះ ហើយធ្វើនូវកម្មដ៏លាមក ក្នុងលោកនេះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតជាមួយនឹងពួកសត្វ ដែលកើតក្នុងទីមិនស្អាត ចាស់

ក្នុងទីមិនស្អាត ស្លាប់ក៏ក្នុងទីមិនស្អាតនោះ ។ ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងរៀបរាប់នូវកំណើតនៃសត្វតិរច្ឆាន ដោយអនេកបរិយាយទៅក៏បាន ។ ម្នាលភិក្ខុទាំងឡាយ តែដំណើរដែលតថាគតពោលទៅ ក៏មិនងាយនឹងដល់កម្រិតកំណើតសត្វតិរច្ឆាន ដែលមានទុក្ខបានឡើយ ។

[ ១៤៩ ] ម្នាលភិក្ខុទាំងឡាយ ដូចបុរសដាក់នឹម ដែលមានប្រឡោះតែមួយ ទៅក្នុងមហាសមុទ្រ ។ ខ្យល់ពីខាងកើតបក់បន្សាត់នឹមនោះទៅខាងលិច ខ្យល់ពីខាងលិចបក់បន្សាត់ទៅខាងកើត ខ្យល់ពីខាងជើងបក់បន្សាត់ទៅខាងត្បូង ខ្យល់ពីខាងត្បូងបក់បន្សាត់ទៅខាងជើង ។ ក្នុងមហាសមុទ្រនោះ មានអណ្តើកខ្វាក់មួយ អណ្តើកនោះ អំណឹះទៅមួយរយឆ្នាំ ទើបងើបឡើងម្តង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្តីនោះថាដូចម្តេច អណ្តើកខ្វាក់នោះ តើអាចនឹងប្រក-កឲ្យចូលទៅក្នុងនឹម ដែលមានប្រឡោះតែមួយនោះបានឬទេ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនបានទេ បពិត្រព្រះអង្គដ៏ចម្រើន បើក្រែងតែកន្លងកាលទៅម្តងៗ យូរអង្វែងណាស់ ( ទើបអណ្តើកនោះ ប្រក-កចូលទៅក្នុងប្រឡោះនឹមនោះបាន ) ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អណ្តើកខ្វាក់នោះ ប្រក-កឲ្យចូលទៅក្នុងនឹម ដែលមានប្រឡោះតែមួយនោះ ទុកជាឆាប់ណាស់ផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលពាលទៅកើតជាវិនិបាតម្តងហើយ កម្រនឹងបានអត្តភាពជាមនុស្សវិញ ជាងអណ្តើកខ្វាក់នោះទៅទៀត ដំណើរនោះ តើព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា ក្នុងវិនិបាតនោះ មិនមានការប្រព្រឹត្តធម៌ដ៏ស្មើ

មិនមានការធ្វើកុសល មិនមានការធ្វើបុណ្យទេ ម្នាលភិក្ខុទាំងឡាយ មានតែការខាំស៊ីទូទៅគ្នានិងគ្នា សម្លាប់គ្នាដែលមានកម្លាំងថយ តែងមានទៅក្នុងវិនិបាតនោះ ។

[ ១៥០ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលនោះឯង ប្រសិនបើអំណើះកាលយូរអង្វែងទៅម្តងៗ ទើបបានមកកាន់អត្តភាពជាមនុស្ស ក្នុងកាលជាខាងក្រោយ តែងកើតក្នុងត្រកូលថោកទាប គឺត្រកូលចណ្ឌាល ត្រកូលអ្នកនេសាទ ត្រកូលអ្នកត្បាញផែង ត្រកូលអ្នកធ្វើរថ ត្រកូលអ្នកកើបសំរាម ជាត្រកូលកម្សត់ ឥតមានបាយ ទឹក ភោជន ប្រព្រឹត្តរស់នៅដោយលំបាក ជាត្រកូលរកបាយស៊ី និងសំពត់ស្លៀកបានដោយត្រដាបត្រដួស ។ បុគ្គលនោះឯង ជាមនុស្សមានសម្បុរអាក្រក់ មិនគួរអ្នកផងមៀងមើល ជាមនុស្សតឿ មានជំងឺច្រើន ជាមនុស្សខ្វាក់ ក្ញែង ខ្ចក ខ្វិន ជាអ្នកមិនបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ទីដេក ទីនៅអាស្រ័យ គ្រឿងប្រទីបឡើយ ។ បុគ្គលនោះ ប្រព្រឹត្តទុច្ចរិត ដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្ត ។ បុគ្គលនោះ លុះប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ ដល់បែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ។

[ ១៥១ ] ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងអ្នកលេងល្បែងភ្នាល់ តែងធ្វើកូនឲ្យហិនហោចទៅផង ធ្វើប្រពន្ធឲ្យហិនហោចទៅផង ធ្វើសម្បត្តិទាំងពួង

ឲ្យហិនហោចទៅផង ដោយការចាញ់ជាដំបូង តទៅមុខ ក៏ដល់នូវការជាប់វណ្ឌខ្លួនឯងទៀត ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ហេតុដែលអ្នកលេងល្បែងភ្នាល់នោះ ធ្វើកូនឲ្យហិនហោចទៅផង ធ្វើប្រពន្ធឲ្យហិនហោចទៅផង ធ្វើសម្បត្តិទាំងពួងឲ្យហិនហោចទៅផង ដោយការចាញ់ជាដំបូង តទៅមុខ ក៏ដល់នូវការជាប់វណ្ឌខ្លួនឯងទៀតនោះ ឈ្មោះថា ចាញ់បន្តិចបន្តួចទេ ។ ចំណែកខាងបុគ្គលពាលនោះ ប្រព្រឹត្តទុច្ចរិតដោយកាយ ប្រព្រឹត្តទុច្ចរិតដោយវាចា ប្រព្រឹត្តទុច្ចរិតដោយចិត្តហើយ លុះដល់បែកធ្លាយរាងកាយ ស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតសត្វតិរច្ឆាន ប្រេត អសុរកាយ នរកនេះឯង ទើបឈ្មោះថា ការចាញ់យ៉ាងធំ ជាងនោះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះឯង ឈ្មោះថា ពាលភូមិ ដ៏បរិបូណ៌គ្រប់គ្រាន់ ។

[ ១៥២ ] ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិត មានហេតុជាគ្រឿងចំណាំថាជាបណ្ឌិត មានហេតុជាគ្រឿងសម្គាល់ថាជាបណ្ឌិត មានចរិតជាបណ្ឌិត ៣ យ៉ាងនេះ ។ ហេតុ ៣ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតក្នុងលោកនេះ ជាអ្នកគិតគំនិតល្អ ១ និយាយសម្តីល្អ ១ ធ្វើអំពើល្អ ១ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើជនជាបណ្ឌិតនោះ ជាអ្នកមិនគិតគំនិតល្អផង មិននិយាយសម្តីល្អផង មិនធ្វើអំពើល្អផងទេ ។ តើពួកអ្នកប្រាជ្ញណា នឹងស្គាល់ជនជាបណ្ឌិតនោះថា អ្នកដ៏ចម្រើននេះ ជាបណ្ឌិត ជាសប្បុរស ដូច្នេះបាន ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិត ជាអ្នកគិតគំនិតល្អផង និយាយសម្តីល្អផង ធ្វើអំពើល្អផង ព្រោះហេតុណា ហេតុនោះ បាន

ជាពួកអ្នកប្រាជ្ញ ស្គាល់ជនជាបណ្ឌិតនោះថា អ្នកនេះជាបណ្ឌិត ជាសប្បុរស ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតនោះសោត តែងទទួលនូវសេចក្តីសុខសោមនស្ស ៣ យ៉ាង ក្នុងបច្ចុប្បន្ននេះ ។

[ ១៥៣ ] ម្នាលភិក្ខុទាំងឡាយ ប្រសិនបើជនជាបណ្ឌិត អង្គុយក្នុងសាលាក្តី អង្គុយក្នុងច្រកក្តី អង្គុយក្នុងផ្លូវបែកជា ៤ ក្តី ចំណែកអ្នកផងដែលអង្គុយក្នុងបរិស័ទនោះ តែងប្រឹក្សាពាក្យ ( ថ្លែងអំពីទោស ) ដែលកើតអំពីអំពើនោះ ដ៏សមគួរដល់អំពើនោះ ។ ម្នាលភិក្ខុទាំងឡាយ បើជនជាបណ្ឌិតជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារវៀរចាកមុសាវាទ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវសុរា និងមេរ័យ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតនោះ តែងគិតក្នុងពាក្យដែលអ្នកផងនិយាយនោះថា អ្នកផង តែងប្រឹក្សាពាក្យណា ដែលកើតអំពីអំពើនោះដ៏សមគួរដល់អំពើនោះ ធម៌ទាំងឡាយនោះ មាននៅក្នុងអញផង ខ្លួនអញសោត ក៏ប្រាកដក្នុងធម៌ទាំងនោះផង ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតតែងទទួលនូវសេចក្តីសុខ សោមនស្សទី ១ នេះ ក្នុងបច្ចុប្បន្ន ។

[ ១៥៤ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ជនជាបណ្ឌិតឃើញនូវព្រះរាជាទាំងឡាយ កាលចាប់នូវចោរដែលប្រព្រឹត្តអាក្រក់បានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយផ្តៅខ្លះឲ្យវាយដោយដំបងខ្លីខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ឲ្យកាត់ទាំងដៃទាំងជើងខ្លះ ឲ្យកាត់ស្លឹកត្រចៀកខ្លះ ឲ្យកាត់ច្រមុះខ្លះ ឲ្យកាត់ទាំងស្លឹកត្រចៀក ទាំង

ប្រមុះខ្លះ ឲ្យធ្វើពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ ឲ្យធ្វើនូវសង្ខមុណ្ឌិកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យរលីងដូចជាសម្បកស័ង្ខខ្លះ ឲ្យធ្វើនូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហុខ្លះ ឲ្យធ្វើនូវជោតិមាលិកកម្ម គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ឲ្យធ្វើនូវហត្ថប្បជ្ជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ឲ្យធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើដូចជាពន្ទាត់ស្បែកពពែខ្លះ ឲ្យធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សម្បកឈើខ្លះ ឲ្យធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាជើងសត្វទ្រាយខ្លះ ឲ្យធ្វើនូវពលិមំសិកកម្ម គឺអំពើដែលគេថ្ពក់មាត់ ដោយកាង ឬសន្ទូចខ្លះ ឲ្យធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខ្ទូចសរីរៈប្រមាណប៉ុនកហាបណៈមួយៗខ្លះ ឲ្យធ្វើនូវខារាបតច្ឆិកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ឲ្យធ្វើបលិឃបរិវត្តិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាបង្វិលជើងគុល ឬសសរគោលខ្លះ ឲ្យធ្វើបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ ឲ្យស្រោចដោយប្រេងដ៏ក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ ឲ្យកាត់ក្បាលដោយដាវខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បណ្ឌិតតែងត្រិះរិះក្នុងអំពើទាំងនោះយ៉ាងនេះថា ព្រះរាជាទាំងឡាយ ចាប់ចោរដែលប្រព្រឹត្តអាក្រក់បានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយផ្តៅខ្លះ ឲ្យវាយដោយដំបងខ្លីខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ឲ្យកាត់ទាំងដៃទាំងជើងខ្លះ ឲ្យកាត់ស្លឹកត្រចៀកខ្លះ ឲ្យកាត់ប្រមុះខ្លះ ឲ្យកាត់ទាំងស្លឹកត្រចៀកទាំងប្រមុះខ្លះ ឲ្យធ្វើ

ពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ ឲ្យធ្វើនូវសង្ខមុណ្ឌិកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យរលីងដូចជាសម្បកស័ង្ខខ្លះ ឲ្យធ្វើនូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ឲ្យដូចជាមាត់រាហុខ្លះ ឲ្យធ្វើនូវជោតិ-មាលិកកម្ម គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ឲ្យធ្វើនូវហត្ថប្បជ្ជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ឲ្យធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាពន្ធាត់ស្បែកពពែខ្លះ ឲ្យធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សម្បកឈើខ្លះ ឲ្យធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាជើងទ្រាយខ្លះ ឲ្យធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេថ្កក់មាត់ដោយកាង ឬសន្ទូចខ្លះ ឲ្យធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខូចសរីរៈ ប្រមាណប៉ុនកហាបណៈមួយៗខ្លះ ឲ្យធ្វើនូវខារាបតច្ឆិកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ឲ្យធ្វើនូវបលិឃបរិវត្តិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាបង្វិលជើងគុល ឬសសរគោលខ្លះ ឲ្យធ្វើនូវបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ ឲ្យស្រោចដោយប្រេងដ៏ក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ ឲ្យកាត់ក្បាលដោយដាវខ្លះ ព្រោះហេតុ បាបកម្មមានសភាពយ៉ាងណាៗ ។ ធម៌ទាំងឡាយនោះ មិនមានក្នុងអាត្មាអញ ទាំងអាត្មាអញសោត ក៏មិនប្រាកដក្នុងធម៌ទាំងឡាយនោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិត រមែងទទួលសេចក្តីសុខសោមនស្សទី ២ នេះឯង ក្នុងបច្ចុប្បន្ន ។

[ ១៥៥ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ជនជាបណ្ឌិត កាលឡើងកាន់តាំងក្តី ឡើងកាន់គ្រែក្តី ដេកលើផែនដីក្តី អំពើល្អទាំងឡាយ គឺការប្រព្រឹត្តល្អដោយកាយ ការប្រព្រឹត្តល្អដោយវាចា ការប្រព្រឹត្តល្អដោយចិត្តណា ដែលជនជាបណ្ឌិតនោះ ធ្វើទុកក្នុងកាលមុន អំពើល្អទាំងនោះឯង តែងគ្របដណ្តប់ស្រោចស្រង់ ទំនុកបម្រុងនូវជនជាបណ្ឌិតនោះ ក្នុងសម័យនោះ ។ ម្នាលភិក្ខុទាំងឡាយ ស្រមោលនៃកំពូលភ្នំដ៏ធំ តែងក្រាលរាលដាល គ្របលើផែនដីក្នុងវេលាថ្ងៃរសៀល មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចជនជាបណ្ឌិត កាលឡើងកាន់តាំងក្តី ឡើងកាន់គ្រែក្តី ដេកលើផែនដីក្តី អំពើល្អទាំងឡាយ គឺការប្រព្រឹត្តល្អដោយកាយ ការប្រព្រឹត្តល្អដោយវាចា ការប្រព្រឹត្តល្អដោយចិត្តណា ដែលជនជាបណ្ឌិតនោះ ធ្វើទុកក្នុងកាលមុន អំពើល្អទាំងនោះឯង តែងគ្របដណ្តប់ ស្រោចស្រង់ ទំនុកបម្រុងនូវជនជាបណ្ឌិតនោះ ក្នុងសម័យនោះ ដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិត តែងគិតក្នុងអារម្មណ៍ ដែលប្រាកដក្នុងចក្ខុទ្វារនោះ យ៉ាងនេះថា អើហ្ន៎ អាត្មាអញ មិនបានធ្វើបាប មិនបានធ្វើអំពើអាក្រក់ មិនបានធ្វើអំពើក្តៅក្រហាយទុកទេ អាត្មាអញ ធ្វើតែអំពើល្អ ធ្វើតែអំពើកុសល ធ្វើតែបុណ្យសម្រាប់ការពារភ័យ ពួកជនដែលមិនបានធ្វើបាប មិនបានធ្វើអំពើអាក្រក់ មិនបានធ្វើអំពើក្តៅក្រហាយទុក ជាអ្នកធ្វើតែអំពើល្អ ធ្វើតែកុសល ធ្វើតែបុណ្យសម្រាប់ការពារភ័យ រមែងមានគតិយ៉ាងណា អាត្មាអញ នឹងទៅកាន់គតិនោះក្នុងបរលោក ។ ជនជាបណ្ឌិតនោះ តែងមិនក្រៀមក្រំចិត្ត មិនលំបាក មិន

ខ្សឹកខ្សួល មិនគក់ទ្រូងទ្រហោយំ មិនដល់នូវសេចក្ដីវង្វេង ។ ម្នាលភិក្ខុទាំង-ឡាយ ជនជាបណ្ឌិតតែងទទួលសេចក្ដីសុខសោមនស្សទី ៣ នេះឯង ក្នុងបច្ចុប្បន្ន ។

[ ១៥៦ ] ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតនោះសោត បានប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ម្នាលភិក្ខុទាំងឡាយ អ្នកផងដែលនិយាយតាមហេតុ តែងនិយាយចំពោះទីណា ថាជាទីគួរប្រាថ្នាតែមួយយ៉ាង គួរត្រេកអរតែមួយយ៉ាង គួរពេញចិត្តតែមួយយ៉ាងដូច្នេះ ទីនោះគឺឋានសួគ៌នោះឯង ដែលអ្នកផងនិយាយតាមហេតុ តែងនិយាយថា ជាទីគួរប្រាថ្នាតែមួយយ៉ាង គួរត្រេកអរតែមួយយ៉ាង គួរពេញចិត្តតែមួយយ៉ាង ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីនេះមិនងាយនឹងធ្វើឧបមា ឲ្យដល់កម្រិតឋានសួគ៌ដែលមានសេចក្ដីសុខបានឡើយ ។

[ ១៥៧ ] កាលបើព្រះអង្គត្រាស់យ៉ាងនេះហើយ មានភិក្ខុមួយរូបក្រាបបង្គំទូលសួរសេចក្ដីនុ៎ះ ចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ចុះព្រះអង្គអាចនឹងធ្វើឧបមាបាន ឬទេ ។ ព្រះមានព្រះភាគត្រាស់តបថា ម្នាលភិក្ខុ តថាគតអាចនឹងធ្វើបាន ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំង-ឡាយ ដូចស្ដេចចក្រពត្តិទ្រង់ប្រកបដោយរតនៈ ៧ ប្រការ និងដោយឫទ្ធិ ៤ យ៉ាង ហើយទ្រង់សោយសេចក្ដីសុខ សោមនស្ស ព្រោះរតនៈ និងឫទ្ធិនោះជាហេតុ ។ រតនៈទាំង ៧ ប្រការនោះ តើដូចម្ដេចខ្លះ ។

[ ១៥៨ ] ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ ក្សត្រិយ៍ជាព្រះរាជាបានមុទ្ធាភិសេកហើយ ទ្រង់កក់ព្រះសិរ្សក្នុងថ្ងៃ ១៥ ជាថ្ងៃឧបោសថ ហើយរក្សាឧបោសថ គង់នៅលើប្រាសាទដ៏ប្រសើរ ចក្ករ័តន៍ជាទិព្វ មានកាំមួយពាន់ ព្រមទាំងខ្នងកង់ និងដុំ បរិបូណ៌ដោយអាការសព្វគ្រប់ ក៏កើតប្រាកដឡើង ។ ក្សត្រិយ៍ជាព្រះរាជាបានមុទ្ធាភិសេក ទ្រង់ទតឃើញហើយ ទើបទ្រង់ព្រះតម្រិះដូច្នេះថា អើ អាត្មាអញក៏ធ្លាប់បានឮរឿងនេះមកហើយថា ក្សត្រិយ៍អង្គណាជាព្រះរាជាបានមុទ្ធាភិសេកហើយ ទ្រង់កក់ព្រះសិរ្សក្នុងថ្ងៃ ១៥ ជាថ្ងៃឧបោ-សថ ហើយរក្សាឧបោសថ គង់នៅលើប្រាសាទដ៏ប្រសើរ ចក្ករ័តន៍ជាទិព្វ មានកាំមួយពាន់ ព្រមទាំងខ្នងកង់ទាំងដុំ បរិបូណ៌ដោយអាការទាំងពួង ក៏កើតប្រាកដឡើង ព្រះរាជាអង្គនោះ នឹងបានជាស្តេចចក្រពត្តិ ឱហ្ន៎ អាត្មាអញបានជាស្តេចចក្រពត្តិហើយតើ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ក្សត្រិយ៍ជាព្រះរាជាបានមុទ្ធាភិសេកហើយ ទ្រង់ក្រោកចាកអាសនៈហើយ ទើបយកព្រះហស្តខាងឆ្វេងចាប់កុណ្ឌី យកព្រះហស្តខាងស្តាំ ស្រោះព្រំចក្ករ័តន៍ហើយត្រាស់ថា ចក្ករ័តន៍ដ៏ចម្រើន ចូរអណ្តែតទៅ ចក្ករ័តន៍ដ៏ចម្រើន ចូរមានជ័យជម្នះ ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ចក្ករ័តន៍នោះឯង ក៏អណ្តែតត្រសែតទៅកាន់ទិសខាងកើត ទើបព្រះបាទចក្រពត្តិ ទ្រង់ស្តេចទៅតាមក្រោយ ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ បើចក្ករ័តន៍ប្រតិស្ឋានក្នុងប្រទេសណា ព្រះបាទចក្រពត្តិ ព្រមទាំងចតុរង្គសេនា ក៏ចូលទៅតាំងព្រះរាជនិវេសន៍ក្នុងប្រទេសនោះ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកពួកស្តេចណាដែលជាសត្រូវ

គង់នៅក្នុងទិសខាងកើត ព្រះរាជាទាំងនោះ ក៏ស្តេចចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ស្តេចមកចុះ បពិត្រមហារាជ ទ្រង់ស្តេចមកល្អហើយ បពិត្រមហារាជ រាជសម្បត្តិរបស់ខ្ញុំព្រះអង្គ ជារបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ។ ព្រះបាទចក្រពត្តិ ក៏មានព្រះបន្ទូលយ៉ាងនេះថា អ្នកទាំងឡាយ មិនត្រូវសម្លាប់សត្វ មិនត្រូវកាន់យកទ្រព្យ ដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវពោលពាក្យមុសាវាទ មិនត្រូវផឹកទឹកស្រវឹងឡើយ អ្នកទាំងឡាយ ចូរបរិភោគតែរបស់ដែលគួរបរិភោគចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកស្តេចណា ដែលជាសត្រូវនៅក្នុងទិសខាងកើត ស្តេចទាំងនោះ ក៏ត្រឡប់ជាចុះចូលព្រះបាទចក្រពត្តិវិញ ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ចក្ករ័តន៍នោះ ក៏ចុះកាន់សមុទ្រទិសខាងកើត ហើយឆ្លងឡើងវិលទៅកាន់ទិសខាងត្បូង ។បេ។ ចុះកាន់សមុទ្រទិសខាងត្បូង ហើយឆ្លងឡើងវិលទៅកាន់ទិសខាងលិច ។បេ។ ចុះកាន់សមុទ្រទិសខាងលិច ហើយឆ្លងឡើងវិលទៅកាន់ទិសខាងជើង ព្រះបាទចក្រពត្តិ ក៏ស្តេចទៅតាមខាងក្រោយ ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ បើចក្ករ័តន៍ប្រតិស្ឋាននៅក្នុងប្រទេសណា ព្រះបាទចក្រពត្តិ ស្តេចក៏ទ្រង់ប្រថាប់នៅក្នុងប្រទេសនោះ ព្រមដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកស្តេចណា ជាសឹកសត្រូវនៅក្នុងទិសខាងជើង ស្តេចទាំងនោះ ក៏នាំគ្នាចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រ

មហារាជ សូមព្រះអង្គស្តេចមកចុះ បពិត្រមហារាជ ទ្រង់ស្តេចមកល្អហើយ បពិត្រមហារាជ រាជសម្បត្តិរបស់ខ្ញុំព្រះអង្គ ជាព្រះរាជទ្រព្យរបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ។ ព្រះបាទចក្រពត្តិទ្រង់ក៏មានព្រះរាជឱង្ការយ៉ាងនេះថា អ្នកទាំងឡាយ មិនត្រូវសម្លាប់សត្វ មិនត្រូវកាន់យកទ្រព្យដែលគេមិនបានឲ្យ មិនត្រូវប្រព្រឹត្តខុសក្នុងកាមទាំងឡាយ មិនត្រូវពោលពាក្យមុសាវាទ មិនត្រូវផឹកទឹកស្រវឹងឡើយ អ្នកទាំងឡាយ ចូរបរិភោគតែរបស់ដែលគួរបរិភោគចុះ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ពួកស្តេចណា ជាសឹកសត្រូវក្នុងទិសខាងជើង ស្តេចទាំងនោះ ក៏ត្រឡប់ជាចុះចូលព្រះបាទចក្រពត្តិវិញ ។ ម្នាលភិក្ខុទាំងឡាយ តពីនោះមក ចក្ករ័តន៍នោះបានបង្ក្រាបផែនដី ដែលមានសមុទ្រជាព្រំប្រទល់ រួចត្រឡប់មកកាន់រាជធានីនោះវិញ ហើយឋិតនៅ ( ក្នុងរបៀងនៃសាលាវិនិច្ឆ័យ ) ទៀបទ្វារនៃព្រះបរមរាជវាំង របស់ព្រះបាទចក្រពត្តិ ( នៅនឹងថ្កល់ ) ហាក់ដូចជាបាក់ភ្ជៅ ហើយបំភ្លឺទ្វារ ក្នុងព្រះបរមរាជវាំងនៃព្រះបាទចក្រពត្តិ ( ឲ្យភ្លឺព្រោងព្រាត ) ។ ម្នាលភិក្ខុទាំងឡាយ ចក្ករ័តន៍បែបនេះ តែងកើតឡើងប្រាកដដល់ស្តេចចក្រពត្តិ ។

[ ១៥៩ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ហត្ថិរ័តន៍ ( ដំរីកែវ ) ក៏កើតប្រាកដដល់ស្តេចចក្រពត្តិ ។ ( ដំរីកែវនោះ ) ជាស្តេចដំរី ឈ្មោះឧបោសថ មានសម្បុរសសុទ្ធ មានអវយវៈតូចធំសមរម្យទាំងអស់ ជាដំរីមានឫទ្ធិ អាចហោះទៅលើអាកាសបាន ។ លុះព្រះបាទចក្រពត្តិ ទ្រង់ទតឃើញហើយ ក៏មានព្រះហឫទ័យជ្រះថ្លាថា អើ យានដំរីល្អណាស់តើហ្ន៎ ប្រសិនបើ

ចូលទៅបង្ហាត់បាន ( ជាការប្រពៃ ) ។ ម្នាលភិក្ខុទាំងឡាយ ឯហត្ថិរ័តន៍នោះ ក៏ដល់នូវការបង្ហាត់បាន ដូចជាដំរីអាជានេយ្យដ៏ល្អ ដែលគេបង្ហាត់បានរបៀបល្អយូរអង្វែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ កាលទ្រង់នឹងល្បងមើលហត្ថិរ័តន៍នោះឯង មុនដំបូង ទ្រង់ឡើងគង់ ( លើហត្ថិរ័តន៍នោះ ) ក្នុងវេលាព្រឹកព្រហាម ហើយស្តេចទៅត្រួតត្រានូវផែនដី មានសមុទ្រជាព្រំប្រទល់ រួចហើយ ស្តេចត្រឡប់មកសោយព្រះក្រយាហារ ក្នុងវេលាព្រឹក ឯរាជធានីរបស់ព្រះអង្គនោះវិញទាន់ ។ ម្នាលភិក្ខុទាំងឡាយ ហត្ថិរ័តន៍មានសភាពយ៉ាងនេះ តែងកើតប្រាកដ ដល់ស្តេចចក្រពត្តិ ។

[ ១៦០ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត អស្សរ័តន៍ ( សេះកែវ ) ក៏កើតឡើងប្រាកដដល់ស្តេចចក្រពត្តិ ។ ( អស្សរ័តន៍នោះ ) ជាស្តេចសេះឈ្មោះវលាហកៈ មានសម្បុរសសុទ្ធ មានសម្បុរត្រង់ក្បាលខ្មៅ ( រលើប ) ដូចជាសម្បុរនៃកក្អែក មានសក់ ( សក្បុស ) ដូចជាបណ្តូលស្មៅយាប្លង់ ជាសេះមានឫទ្ធិ អាចហោះទៅលើអាកាសបាន ។ លុះស្តេចចក្រពត្តិទ្រង់ទតឃើញហើយ ក៏មានព្រះហឫទ័យជ្រះថ្លាថា អើ យានសេះ ល្អណាស់ហ្ន៎ ប្រសិនបើចូលទៅបង្ហាត់បាន ( ជាការប្រពៃ ) ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ អស្សរ័តន៍នោះ ក៏ដល់នូវការបង្ហាត់បាន ដូចជាសេះអាជានេយ្យដ៏ល្អ ដែលគេបង្ហាត់បានរបៀបល្អយូរអង្វែងហើយ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ កាលទ្រង់នឹងល្បងមើលអស្សរ័តន៍នោះឯង មុនដំបូង ទ្រង់ឡើងគង់ ( លើអស្សរ័តន៍ ) ក្នុងវេលាព្រឹកព្រហាម ហើយស្តេចទៅត្រួតត្រាផែនដី

ដែលមានសមុទ្រជាព្រំប្រទល់ រួចហើយ ស្តេចត្រឡប់មកសោយព្រះស្ងោយ ក្នុងវេលាព្រឹក ឯរាជធានីរបស់ព្រះអង្គនោះវិញទាន់ ។ ម្នាលភិក្ខុទាំងឡាយ អស្សរ័តន៍ មានសភាពយ៉ាងនេះ តែងកើតប្រាកដ ដល់ស្តេចចក្រពត្តិ ។

[ ១៦១ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត មណិរ័តន៍ ក៏កើតប្រាកដដល់ស្តេចចក្រពត្តិ ។ មណិរ័តន៍នោះជាកែវពៃទូរ្យ មានជាតិដ៏ល្អ មានជ្រុង ៨ ដែលជាងថ្នៃល្អហើយ ។ ម្នាលភិក្ខុទាំងឡាយ មណិរ័តន៍នោះឯង មានពន្លឺផ្សាយទៅបានមួយយោជន៍ជុំវិញ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិកាលទ្រង់នឹងល្បងមើលនូវមណិរ័តន៍នោះឯង មុនដំបូង ទ្រង់ប្រជុំអស់ចតុរង្គសេនាមកហើយទ្រង់ស្ទួយកែវមណីឡើងទៅកាន់ចុងដងទង់ ហើយទ្រង់គ្រវីទៅក្នុងទីងងឹតអ័ព្ទក្នុងរាត្រី ។ ម្នាលភិក្ខុទាំងឡាយ ចំណែកអ្នកស្រុកទាំងឡាយណា ដែលនៅជិតខាង អ្នកស្រុកទាំងនោះ សម្គាល់ថាជាវេលាថ្ងៃ ក៏នាំគ្នាប្រកបការងារដោយសារពន្លឺ ( កែវ ) នោះឯង ។ ម្នាលភិក្ខុទាំងឡាយ មណិរតន៍ មានសភាពយ៉ាងនេះ តែងកើតប្រាកដ ដល់ស្តេចចក្រពត្តិ ។

[ ១៦២ ] ម្នាលភិក្ខុទាំងឡាយ តទៅទៀត ឥត្ថីរ័តន៍ ( ស្រីកែវ ) ក៏កើតប្រាកដដល់ស្តេចចក្រពត្តិ ។ ស្រីកែវនោះ មានរូបឆោមដ៏ល្អ គួរឲ្យអ្នកផង ពិតពិលរមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង មិនខ្ពស់ពេក មិនទាបពេក មិនស្គមពេក មិនធាត់ពេក មិនខ្មៅពេក មិនសពេក លើសលែងកន្លងហួសសម្បុរស្ត្រីមនុស្ស តែមិនដល់សម្បុរទិព្វទេ ។ ម្នាលភិក្ខុទាំងឡាយ ឥត្ថីរ័តន៍នោះឯង មានកាយសម្ផស្ស ( ទន់ល្មូក ) ដូចជា

សំឡីគរ ឬសំឡីកប្បាស ។ ម្នាលភិក្ខុទាំងឡាយ ឯឥត្ថីរ័តន៍នោះឯង ក្នុងរដូវត្រជាក់ មានខ្លួនក្តៅ ក្នុងរដូវក្តៅ មានខ្លួនត្រជាក់ ។ ម្នាលភិក្ខុទាំងឡាយ មិនតែប៉ុណ្ណោះសោត ឥត្ថីរ័តន៍នោះឯង មានក្លិនខ្លឹមចន្ទន៍ផ្សាយចេញអំពីកាយ មានក្លិនផ្កាឧប្បលផ្សាយចេញអំពីមាត់ ។ ម្នាលភិក្ខុទាំងឡាយ ឥត្ថីរ័តន៍នោះឯង ជាស្ត្រីតែងក្រោកឡើងមុន តែងអង្គុយក្រោយ យកចិត្តទុកដាក់ធ្វើការអ្វីៗប្រព្រឹត្តតម្រូវព្រះហឫទ័យ ពោលតែពាក្យជាទីពេញព្រះហឫទ័យរបស់ស្តេចចក្រពត្តិ ។ ម្នាលភិក្ខុទាំងឡាយ ឥត្ថីរ័តន៍នោះឯង សូម្បីតែចិត្តក៏មិនប្រព្រឹត្តកន្លងស្តេចចក្រពត្តិទៅហើយ ម្តេចឡើយនឹងប្រព្រឹត្តកន្លងដោយកាយបាន ។ ម្នាលភិក្ខុទាំងឡាយ ឥត្ថីរ័តន៍មានសភាពយ៉ាងនេះឯង តែងកើតប្រាកដ ដល់ស្តេចចក្រពត្តិ ។

[ ១៦៣ ] ម្នាលភិក្ខុទាំងឡាយ តទៅទៀត គហបតិរ័តន៍ ( គហបតីកែវ ) ក៏កើតប្រាកដដល់ស្តេចចក្រពត្តិ ។ ឯគហបតិរ័តន៍នោះ មានទិព្វចក្ខុកើតអំពីផលនៃកុសលកម្ម អាចមើលឃើញកំណប់ទ្រព្យដែលមានម្ចាស់ និងមិនមានម្ចាស់បាន ។ គហបតិរ័តន៍នោះ ចូលទៅគាល់ស្តេចចក្រពត្តិ ក៏ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំមានសេចក្តីខ្វល់ខ្វាយឡើយ ខ្ញុំព្រះអង្គនឹងចាត់ចែងការ ដែលគួរធ្វើដោយទ្រព្យថ្វាយ ដោយព្រះរាជទ្រព្យព្រះអង្គ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិកាលទ្រង់នឹងល្បងមើលគហបតិរ័តន៍នោះឯង មុនដំបូង ទ្រង់ប្រថាប់លើព្រះទីនាំងនាវាសំដៅទៅកាន់ខ្សែទឹកក្នុងកណ្តាលទន្លេគង្គា ទើបទ្រង់ត្រាស់នឹងគហបតិរតន៍

នោះយ៉ាងនេះថា ម្នាលគហបតី យើងមានសេចក្តីត្រូវការ ដោយប្រាក់ និង មាស ។ គហបតិរ័តន៍នោះ ក្រាបបង្គំទូលតបថា បពិត្រមហារាជ បើដូច្នោះ សូមទ្រង់អែបនាវាទៅខាងត្រើយប្រាំងម្ខាង ។ ទ្រង់មានព្រះរាជឱង្ការថា ឱ គហបតី យើងមានសេចក្តីត្រូវការតែប្រាក់ និងមាសត្រង់ទីនេះឯង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង គហបតិរ័តន៍នោះលូកដៃទាំងពីរចុះទៅក្នុងទឹក ចាប់លើកយកឆ្នាំងដែលពេញដោយប្រាក់ និងមាស ហើយក្រាបទូលស្តេចចក្រពត្តិថា បពិត្រមហារាជ ល្មមហើយដោយប្រាក់ និងមាសប៉ុណ្ណេះ បពិត្រមហារាជ ប្រាក់ និងមាសប៉ុណ្ណេះ ល្មមធ្វើព្រះរាជកិច្ចបានហើយ បពិត្រមហារាជ ប្រាក់ និងមាសប៉ុណ្ណេះ ខ្ញុំព្រះអង្គថ្វាយហើយ ។ ស្តេចចក្រពត្តិ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលគហបតី ប្រាក់ និងមាសប៉ុណ្ណេះល្មមហើយ ម្នាលគហបតី ប្រាក់ និងមាសប៉ុណ្ណេះ ល្មមធ្វើកិច្ចបានហើយ ម្នាលគហបតី ប្រាក់ និងមាសប៉ុណ្ណេះ អ្នកឯងថ្វាយយើងហើយ ។ ម្នាលភិក្ខុទាំងឡាយ គហបតិរ័តន៍ មានសភាពយ៉ាងនេះ តែងកើតប្រាកដ ដល់ស្តេចចក្រពត្តិ ។

[ ១៦៤ ] ម្នាលភិក្ខុទាំងឡាយ តទៅទៀត បរិនាយករ័តន៍ ( បរិនាយកកែវ ) ក៏កើតប្រាកដដល់ស្តេចចក្រពត្តិ ។ ( បរិនាយកកែវនោះ ) ជាបណ្ឌិតវាងវៃ មានប្រាជ្ញា អង់អាច ដើម្បីញុំាងស្តេចចក្រពត្តិ ដែលខ្ជូនគួរឲ្យស្តេចចូលទៅ ឲ្យចូលទៅបាន ដើម្បីញុំាងស្តេចចក្រពត្តិ ដែលខ្ជូនគួរឲ្យស្តេចចេញទៅ ឲ្យចេញទៅបាន ដើម្បីញុំាងស្តេចចក្រពត្តិ ឲ្យតាំងងារបុគ្គលដែលគួរតាំងបាន ។ បរិនាយករ័តន៍នោះ ចូលទៅគាល់ស្តេចចក្រពត្តិហើយ ទើបក្រាប

បង្គំទូលយ៉ាងនេះថា បពិត្រព្រះសម្មតិទេព សូមព្រះអង្គ កុំមានសេចក្តីខ្វល់ខ្វាយឡើយ ខ្ញុំព្រះអង្គនឹងប្រៀនប្រដៅថ្វាយ ។ ម្នាលភិក្ខុទាំងឡាយ បរិនាយករ័តន៍មានសភាពយ៉ាងនេះ តែងកើតប្រាកដដល់ស្តេចចក្រពត្តិ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ ទ្រង់ប្រកបដោយរតនៈ ( ៧ ប្រការ ) នេះឯង ។ ស្តេចចក្រពត្តិ ទ្រង់ប្រកបដោយឫទ្ធិ ៤ យ៉ាង តើដូចម្តេចខ្លះ ។

[ ១៦៥ ] ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិមានព្រះរូបល្អ គួរឲ្យអ្នកផងពិតពិលរមិលមើល គួរឲ្យជ្រះថ្លា ទ្រង់ប្រកបដោយព្រះឆវិវណ្ណដ៏ល្អក្រៃលែង ជាងមនុស្សឯទៀត ក្នុងលោកនេះ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិទ្រង់ប្រកបដោយឫទ្ធិ នេះជាឫទ្ធិទី ១ ។

[ ១៦៦ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្តេចចក្រពត្តិ មានព្រះជន្មាយុវែង ទ្រង់ឋិតនៅអស់កាលយូរអង្វែង ក្រៃលែងជាងមនុស្សទាំងឡាយឯទៀត ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិទ្រង់ប្រកបដោយឫទ្ធិ នេះជាឫទ្ធិទី ២ ។

[ ១៦៧ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត ស្តេចចក្រពត្តិ ទ្រង់មិនមានអាពាធ មិនមានទុក្ខ ប្រកបដោយភ្លើងធាតុ ដែលកើតអំពីកម្ម មានវិបាកស្មើគ្នា គឺមិនត្រជាក់ពេក មិនក្តៅពេក លើសជាងមនុស្សដទៃ ។ ម្នាលភិក្ខុទាំងឡាយ ស្តេចចក្រពត្តិទ្រង់ប្រកបដោយឫទ្ធិ នេះជាឫទ្ធិទី ៣ ។

[ ១៦៨ ] ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ស្តេចចក្រពត្តិទ្រង់ជាទីស្រឡាញ់ ជាទីពេញចិត្តនៃព្រាហ្មណ៍ និងគហបតីទាំងឡាយ ។ ម្នាលភិក្ខុទាំង-

ឡាយ បិតាជាទីស្រឡាញ់ពេញចិត្តនៃកូនទាំងឡាយ យ៉ាងណាមិញ ម្នាល ភិក្ខុទាំងឡាយ ស្តេចចក្រពត្តិទ្រង់ជាទីស្រឡាញ់ពេញចិត្ត នៃព្រាហ្មណ៍ និង គហបតីទាំងឡាយ យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ចំណែកខាង ព្រាហ្មណ៍ និងគហបតីទាំងឡាយ ក៏ជាទីស្រឡាញ់ពេញព្រះហឫទ័យនៃស្តេច ចក្រពត្តិដែរ ។ ម្នាលភិក្ខុទាំងឡាយ កូនទាំងឡាយជាទីស្រឡាញ់ពេញចិត្តនៃ បិតា យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ព្រាហ្មណ៍ និងគហបតីទាំងឡាយ ក៏ជាទីស្រឡាញ់ពេញព្រះហឫទ័យនៃស្តេចចក្រពត្តិ យ៉ាងនោះដែរ ។ ម្នាល ភិក្ខុទាំងឡាយ ស្តេចចក្រពត្តិ កាលមុនដំបូង ទ្រង់ស្តេចទៅកាន់ទីឧទ្យាន ដោយចតុរង្គសេនា ។ ម្នាលភិក្ខុទាំងឡាយ លំដាប់នោះ ព្រាហ្មណ៍ និងគហបតី ទាំងឡាយ ចូលទៅគាល់ស្តេចចក្រពត្តិ ក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះ សម្មតិទេព សូមព្រះអង្គកុំស្តេចទៅ ដោយរួសរាន់ឡើយ សូមឲ្យយើងខ្ញុំព្រះ អង្គឃើញព្រះអង្គ អស់កាលយូរ ។ ម្នាលភិក្ខុទាំងឡាយ ឯស្តេចចក្រពត្តិ ទ្រង់ត្រាស់នឹងសារថីថា ម្នាលសារថី អ្នកកុំបរទៅ ដោយរួសរាន់ឡើយ ។ សុំឲ្យខ្ញុំឃើញព្រាហ្មណ៍ និងគហបតីទាំងឡាយ អស់កាលយូរ ។ ម្នាលភិក្ខុ ទាំងឡាយ ស្តេចចក្រពត្តិទ្រង់ប្រកបដោយឫទ្ធិ នេះជាឫទ្ធិទី ៤ ។ ម្នាលភិក្ខុ ទាំងឡាយ ស្តេចចក្រពត្តិទ្រង់ប្រកបដោយឫទ្ធិ ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុ ទាំងឡាយ អ្នកទាំងឡាយសម្គាល់នូវហេតុនោះ ថាដូចម្តេច ស្តេចចក្រពត្តិ ប្រកបដោយរតនៈទាំង ៧ ប្រការនេះផង ដោយឫទ្ធិ ៤ យ៉ាងនេះផង តើ ទ្រង់សោយនូវសេចក្តីសុខសោមនស្ស ព្រោះរតនៈ និងឫទ្ធិនោះ ជាហេតុដែរឬ

អ្វី ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ស្ដេចចក្រពត្តិសូម្បីប្រកបដោយរតនៈតែមួយៗ ក៏គង់សោយសេចក្ដីសុខសោមនស្ស ព្រោះរតនៈនោះ ជាហេតុទៅហើយ ចាំបាច់និយាយថ្វីដល់ទៅប្រកបដោយរតនៈទាំង ៧ ប្រការ និងឫទ្ធិ ៤ យ៉ាង ( នោះ ) ។

[ ១៦៩ ] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ចាប់នូវដុំថ្មតូចប្រមាណប៉ុនបាតដៃ ហើយត្រាស់សួរភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសម្គាល់សេចក្ដីនោះ ថាដូចម្ដេច ដុំថ្មតូចប្រមាណប៉ុនបាតដៃ ដែលតថាគតកំពុងកាន់នេះ និងស្ដេចភ្នំហិមពាន្ត តើណាធំជាង ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ដុំថ្មតូចប្រមាណប៉ុនបាតដៃ ដែលព្រះអង្គកាន់នេះតូចពេកណាស់ប្រៀបផ្ទឹមនឹងស្ដេចភ្នំហិមពាន្ត មិនដល់នូវការរាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចចក្រពត្តិប្រកបដោយរតនៈទាំង ៧ ប្រការ និងឫទ្ធិ ៤ យ៉ាង ទ្រង់សោយសេចក្ដីសុខ សោមនស្សណា ព្រោះរតនៈ និងឫទ្ធិនោះជាហេតុ ។ សេចក្ដីសុខនោះ ប្រៀបផ្ទឹមនឹងសេចក្ដីសុខទិព្វ មិនដល់នូវការរាប់ផង មិនដល់មួយចំណិតផង មិនដល់នូវការប្រៀបធៀបផង ក៏ដូច្នោះដែរ ។

[ ១៧០ ] ម្នាលភិក្ខុទាំងឡាយ ជនជាបណ្ឌិតនោះ បើអំណឹះកាលយូរអង្វែងទៅម្ដងៗ ក៏មកកាន់អត្តភាពជាមនុស្ស ក្នុងកាលជាខាងក្រោយ តែងកើតក្នុងត្រកូលខ្ពស់ គឺត្រកូលខត្តិយមហាសាលខ្ជះ ត្រកូលព្រាហ្មណ៍មហាសាលខ្ជះ ត្រកូលគហបតីមហាសាលខ្ជះ ជាត្រកូលស្ដុកស្ដម្ភមាំមួន មានទ្រព្យ

ច្រើន មានគ្រឿងប្រើប្រាស់ច្រើន មានប្រាក់មាសច្រើន មានគ្រឿងឧបករណ៍ច្រើន មានធញ្ញជាតិជាទ្រព្យច្រើន ។ មួយទៀត ជនជាបណ្ឌិតនោះមានរូបល្អគួរពិតពិលរមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អដ៏ក្រៃលែង ជាអ្នកបានបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ទីដេក ទីនៅអាស្រ័យ និងគ្រឿងប្រទីប ។ ជនជាបណ្ឌិតនោះ តែងប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ។ លុះជនជាបណ្ឌិតនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ហើយដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។

[ ១៧១ ] ម្នាលភិក្ខុទាំងឡាយ ដូចអ្នកលេងល្បែងភ្នាល់ បាននូវគំនរទ្រព្យសម្បត្តិច្រើន ដោយការឈ្នះជាដំបូងប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ ត្រង់ហេតុដែលអ្នកលេងល្បែងភ្នាល់នោះ បាននូវគំនរទ្រព្យសម្បត្តិច្រើន ដោយការឈ្នះជាដំបូងប៉ុណ្ណោះនោះ ឈ្មោះថាជាការឈ្នះតែបន្តិចបន្តួចទេ ។ ចំណែកខាងជនជាបណ្ឌិតនោះ ប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិសួគ៌ ទេវលោក នេះឯង ទើបឈ្មោះថាការឈ្នះធំជាងនោះទៅទៀត ។ ម្នាលភិក្ខុទាំងឡាយ នេះឈ្មោះថាបណ្ឌិតភូមិ ដ៏បរិបូណ៌គ្រប់គ្រាន់ ។ លុះព្រះមានព្រះភាគ ត្រាស់ព្រះសូត្រនេះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

ពាលបណ្ឌិតសូត្រទី ៩ ចប់

# អដ្ឋកថា

## ពាលបណ្ឌិតសូត្រ

[ ១៣៥ ] ពាលបណ្ឌិតសូត្រ មានបទផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ១៣៦ ] ក្នុងបទទាំងនោះ បទថា **ពាលលក្ខណានិ** សេចក្ដីថា ឈ្មោះថា **ពាលលក្ខណា** ព្រោះអត្ថថា ជាគ្រឿងកំណត់ គឺជាគ្រឿងសម្គាល់ឲ្យដឹងថា នេះជាបុគ្គលពាល ។ ពាលលក្ខណៈទាំងនោះ លោកហៅថា **ពាលនិមិត្ត** ព្រោះជាហេតុនៃការសម្គាល់ថា បុគ្គលនោះជាបុគ្គលពាល ។ហៅថា **ពាលាបទាន** ព្រោះបុគ្គលពាលប្រព្រឹត្តមិនដាច់ ។ បទថា **ទុច្ចិន្តិតចិន្តី** សេចក្ដីថា ធម្មតាបុគ្គលពាល កាលគិត រមែងគិតតែរឿងអាក្រក់ដោយអំណាចអភិជ្ឈា ព្យាបាទ និងមិច្ឆាទិដ្ឋិតែម្យ៉ាង ។ បទថា **ទុព្ភាសិតភាសី** សេចក្ដីថា កាលពោល ក៏ពោលតែពាក្យអាក្រក់ៗ ដោយវចីទុច្ចរិតមានមុសាវាទជាដើម ។ បទថា **ទុក្កដកម្មការី** សេចក្ដីថា សូម្បីធ្វើក៏ធ្វើចំពោះតែកម្មអាក្រក់ៗ ដោយអំណាចនៃកាយទុច្ចរិត មានបាណាតិបាតជាដើម ។

[ ១៣៧ ] បទថា **តត្រ** ចេ បានដល់ ក្នុងបរិស័ទដែលបុគ្គលពាលអង្គុយហើយនោះ ។ បទថា **តជ្ជំ តស្សារុប្បំ** សេចក្ដីថា ពោលដោយពាក្យដែលសមគួរដល់បុគ្គលនោះ គឺសមគួរដល់បុគ្គលនោះ អធិប្បាយថា បានដល់ ពាក្យដែលសម្បយុត្តដោយទោស ទាំងដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ននិងសម្បរាយភពនៃបញ្ចវេរ ។ បទថា **តត្រ** បានដល់ វាចាដែលពោល

*ដល់គ្នានិងគ្នានោះ ។ បទថា* **ពាលំ** *ជាដើម ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃឆដ្ឋីវិភត្តិ ។*

*[ ១៣៩ ] បទថា* **ឱលម្ពន្តិ** *សេចក្តីថា រមែងចូលទៅតាំងនៅ ។ ពីរបទដ៏សេស ជាវេវចនៈនៃបទថា* **ឱលម្ពន្តិ** *នោះ ។ លក្ខណៈបុគ្គលពាលទាំងនោះ រមែងប្រាកដដោយអាការដែលផ្សាយទៅជាដើម ព្រោះដូច្នោះ ទើបលោកពោលយ៉ាងនេះ ។ បទថា* **បថវិយា ឱលម្ពន្តិ** *បានដល់ ផ្សាយទៅលើបឋវី ពីរបទដ៏សេស ជាវេវចនៈនៃបទនោះឯង ។ សេចក្តីនោះជាអាការដែលផ្សាយទៅ ។ បទថា* **តត្រ ភិក្ខវេ ពាលស្ស** *សេចក្តីថា កាលប្រាកដការនោះមកដល់ បន្ទាប់អំពីនោះ បុគ្គលពាលរមែងមានការគិតយ៉ាងនេះ ។ បទថា* **ឯតទហោឆ** *សេចក្តីថា ភិក្ខុអ្នកឈ្លាសក្នុងអនុសន្ធិគិតថា បុគ្គលណាម្នាក់ មិនអាចធ្វើឧបមានៃនរកបាន ព្រះមានព្រះភាគក៏មិនបានត្រាស់ តែត្រាស់ថា មិនមែនរបស់ដែលធ្វើបានដោយងាយ ទោះបីធ្វើបានងាយ ក៏មិនមានអ្នកធ្វើបាន ឈ្មោយចុះ អញនឹងទូលអារាធនាឲ្យព្រះទសពល ទ្រង់ធ្វើឧបមា ដូច្នេះ រួចបានពោលពាក្យនេះថា* **ឯតំ សក្កា ភន្តេ** *ដូច្នេះ ។*

*[ ១៤១ ] បទថា* **ហនេយ្យុំ** *សេចក្តីថា គប្បីសម្លាប់បែបចាក់ទម្លុះ ២ ដងក្នុងទីតែមួយ មិនឲ្យដល់នូវការស្លាប់ ដោយវិធីចាក់ទម្លុះ ហើយក៏ទៅ ព្រោះដូច្នោះ ទើបចោរនោះមានមុខរបួសដល់ទៅ ២០០ កន្លែង សូម្បីបទដែលមានចំនួនក្រៃលែងទៅជាងនេះ ក៏ន័យនេះដូចគ្នា ។*

*[ ១៤២ ] បទថា* **ចាណិមត្តំ** *បានដល់ មានទំហំត្រឹមតែការតាំងនៅ*

ក្នុងបាតដៃ ។ បទថា **សង្ខម្បិ ន ឧបេតិ** ប្រែថា មិនដល់ចំនួនដែលល្មមរាប់បាន ។ បទថា **កលភាគម្បិ** ប្រែថា មិនដល់ថ្នាក់ដែលគួរនឹងពោលថាចូលដល់ចម្រៀកទី ១ រយ ចម្រៀកទី ១ ពាន់ ឬក៏ចម្រៀកទី ១ សែន ។ បទថា **ឧបនិធម្បិ** បានដល់ មិនដល់នូវការចូលទៅប្រៀបធៀប គឺមិនមានសូម្បីតែបុគ្គលដែលក្រឡេកមើល ។

[ ១៤៣ ] បណ្ដាបទទាំងនោះ បទថា **អយោខីលំ** សេចក្ដីថា ឲ្យសត្វនរកដែលមានអត្តភាព ៣ គាវុត ដេកផ្ងារលើបន្ទះដែកដែលក្រហមប្រាលភ្លៅ យកលំពែងដែកប្រមាណប៉ុនដើមត្នោតដោតត្រង់ដៃខាងស្ដាំ ដៃឆ្វេងជាដើមក៏ធ្វើយ៉ាងនោះ ហើយឲ្យដេកផ្កាប់ខ្លះ ដេកផ្អៀងស្ដាំខ្លះ ដេកផ្អៀងឆ្វេងខ្លះ ដោយដាក់ទោស ដូចដេកផ្ងារដែរ ហើយដាក់ទោសដូចគ្នា ។ បទថា **សំវេសិត្វា** សេចក្ដីថា នាយនិរយបាលចាប់សត្វនរកដែលមានអត្តភាព ៣ គាវុត ឲ្យដេកលើផែនដីដែកដែលឆេះប្រាលភ្លៅ ។ បទថា **កុឋារីហិ** សេចក្ដីថា ចាំងដោយដឹងធំ ទំហំប៉ុនដំបូលផ្ទះមួយចំហៀង ។ ឈាមហូរដូចទឹកឈាមខ្វាយឡើងអំពីផែនដី ឆេះជាអណ្ដាតភ្លើង ទៅទល់ទីដែលគេពន្លះហើយ ។ ទុក្ខដ៏ធំក្រៃលែងកើតឡើង និងកាលពន្លះ ក៏ពន្លះធ្វើឲ្យជាសរសៃបន្ទាត់ កាត់ចេញជា ៨ ចម្រៀកខ្លះ ៦ ចម្រៀកខ្លះ ដូចកាត់កំណាត់ឧស ។ បទថា **វាសីហិ** បានដល់ កាំបិតដែលមានប្រមាណប៉ុនចង្អេរខ្នាតធំ ។ កាលពុះដោយកាំបិតនោះ ក៏ពន្លះតាំងអំពីស្បែក រហូតទៅដល់ឆ្អឹង អវយវៈដែលពន្លះហើយ ក៏កើតឡើងវិញដូចប្រក្រតី ។ បទថា **រថេ យោជេត្វា** សេចក្ដីថា

ទីមដោយរថដែលឆេះសន្ធោសន្ធៅ ដោយប្រការទាំងពួង ព្រមទាំងខ្សែ កន់ទូក និងជន្ទួញ ។ បទថា **មហន្តំ** បានដល់ មានប្រមាណប៉ុនផ្ទះកំពូលខ្នាតធំ ។ បទថា **អារោបេន្តិ** សេចក្តីថា នាយនិរយបាលសំពងដោយដំបងដែកដែលឆេះដោយភ្លើង ហើយបញ្ជាឲ្យសត្វនរកប្រវាឡើង ។ បទថា **សកឹបិ ឧទ្ធំ** សេចក្តីថា សត្វនរកស្ទុះទៅខាងលើខ្លះ ខាងក្រោមខ្លះ ខាងទទឹងខ្លះ ដូចគ្រាប់អង្ករដែលគេដាក់ទៅក្នុងឆ្នាំងបាយដែលកំពុងពុះ ។

បទថា **ភាគសោ មិតោ** បានដល់ ចែកជាចំណែកស្មើៗគ្នា ។ បទថា **បរិយន្តោ** ប្រែថា ព័ទ្ធជុំវិញ ។ បទថា **អយសា** សេចក្តីថា ខាងលើគ្របដោយគម្របដែក ។ បទថា **សមន្តា យោជនសតំ ផរិត្វា តិដ្ឋតិ** សេចក្តីថា ផ្សាយទៅហើយយ៉ាងនេះ តាំងនៅ ដូចភ្នែកនៃបុគ្គលដែលឈរក្នុងទីប្រមាណ ១ រយយោជន៍ដោយជុំវិញ នឹងលៀនចេញមកទាំងគូ ។ បទថា **ន សុករំ អក្ខាតេន ចាបុណិតុំ** អធិប្បាយថា ទោះពោលពណ៌នាអស់ ១ រយឆ្នាំ ១ ពាន់ឆ្នាំ រហូតដល់ទីបំផុតថា ឈ្មោះថា នរកជាទុក្ខយ៉ាងនេះ មិនមែនជារបស់ដែលធ្វើបានងាយ ។

[ ១៤៤ ] បទថា **ឧន្តុល្លេហកំ** ប្រែថា ប្រើធ្មេញ និងក្រចក អធិប្បាយថា ដកឡើងដោយធ្មេញ ។ បទថា **រសាទោ** បានដល់ បរិភោគដោយជាប់ចិត្តក្នុងរស ដោយចំណង់ក្នុងរសអាហារ ។

[ ១៤៩ ] បទថា **អញ្ញមញ្ញខាទិកា** ប្រែថា មានតែការទំពាស៊ីគ្នាឯង ។

[ ១៥០ ] បទថា **ឧព្ពណ្ណោ** ប្រែថា មានរូបអាក្រក់ ។ បទថា **ឧទ្ទុ-**

**សិង្ឃោ** បានដល់ មានរូបគួរខ្ពើម ដូចយក្ខដែលគេស្អាប់ដើម្បីបន្ទាចឲ្យក្មេងខ្លាច ។ បទថា **ឱក្កោដិមកោ** បានដល់ មានរាងកាយតឿ កខ្វី ពោះកំប៉ោង ។ បទថា **កាណោ** បានដល់ ជាបុគ្គលខ្វាក់ម្ខាង ឬខ្វាក់សងខាង ។ បទថា **កុណី** បានដល់ បុគ្គលដែលមានដៃដាច់ម្ខាង ឬមានដៃកំបុតទាំងសងខាង ។ បទថា **បក្ខហតោ** ប្រែថា ជាបុគ្គលគមខ្វិន ។ បទថា **សោ កាយេន** ជាដើមនេះ លោកប្រារព្ធដើម្បីសម្តែងដល់ការចូលទៅពាក់ព័ន្ធនឹងសេចក្តីទុក្ខរបស់សត្វនរកនោះ ។

[ ១៥១ ] បទថា **កលិគ្គហេន** ប្រែថា ដោយការចាញ់ ។ បទថា **អធិពន្ធំ និគច្ឆេយ្យ** សេចក្តីថា ព្រោះសម្បត្តិគ្រប់យ៉ាងដ៏ច្រើនរបស់អ្នកចាញ់មិនគ្រប់គ្រាន់ឲ្យអ្នកឈ្នះ ដូច្នោះ ទើបគេត្រូវចងដោយចំណងទៀត ។ បទថា **កេវលា បរិបូរា ពាលភូមិ** សេចក្តីថា បុគ្គលពាលធ្វើទុច្ចរិត ៣ យ៉ាងបរិបូណ៌ហើយ រមែងកើតក្នុងនរក តែដោយសំណល់នៃកម្មដ៏សេសក្នុងនរកនោះ សូម្បីបុគ្គលនោះបានត្រឡប់មកកើតជាមនុស្ស ក៏ត្រូវកើតក្នុងត្រកូលទាបទាំង ៥ ហើយបើនៅតែធ្វើទុច្ចរិត ៣ ទៀត ក៏ត្រូវកើតក្នុងនរក ទាំងអស់នេះជាកម្មនៃបុគ្គលពាលយ៉ាងបរិបូណ៌ ។

[ ១៥២ ] បទថា **បណ្ឌិតលក្ខណានិ** ជាដើម គប្បីជ្រាបដោយទំនងដូចពាលហើយនោះឯង ។ បទទាំងឡាយ មានបទថា **សុចិន្តិតចិន្តី** ជាដើមក្នុងនិទ្ទេសនេះ គប្បីប្រកបចូលដោយអំណាចនៃមនោសុចរិតជាដើម ។

[ ១៥៨ ] បទថា **សីសន្ហាតស្ស** បានដល់ ស្រពស្រង់សីសៈដោយ

ទឹកក្រអូប ។ បទថា **ឧបោសថិកស្ស** បានដល់ ទ្រង់សមាទានអង្គឧបោសថហើយ ។ បទថា **ឧបរិបាសាទវរគតស្ស** ប្រែថា កាលប្រថាប់នៅក្នុងមហាប្រាសាទជាន់លើ គឺទ្រង់សោយសុធាភោជន យាងចូលបន្ទប់ដ៏មានសិរីលើផ្ទៃដ៏ធំទូលាយ លើផ្ទៃមហាប្រាសាទ ទ្រង់អាវជ្ជនៈដល់សីលទាំងឡាយ ។

បានឮថា គ្រានោះ ព្រះរាជាគ្រាន់តែព្រឹកឡើង ក៏លះព្រះរាជទ្រព្យ ១ សែន ថ្វាយមហាទាន ស្រពព្រះសិរសៈដោយគន្ធទក ម្តង ១៦ ក្អម សោយព្រះក្រយាហារព្រឹកហើយ ទ្រង់ទៀងស្មាដោយសំពត់សបរិសុទ្ធ អង្គុយពត់ភ្នែនលើទីបន្ទំដ៏មានសិរី នាប្រាសាទជាន់លើ ប្រថាប់ពិចារណាដល់គំនរបុណ្យ គឺទាន ការសង្កត់ចិត្ត និងការសង្រួមព្រះកាយ ។ នេះជាធម្មតារបស់ស្តេចចក្រពត្តិទាំងពួង ។

កាលស្តេចចក្រពត្តិទាំងនោះ កំពុងពិចារណាដល់គំនរបុណ្យនោះឯង ទិព្វចក្ករ័តន៍ មានបុញ្ញកម្មដូចពោលហើយជាបច្ច័យ មានឧតុជាសមុដ្ឋាន មានលក្ខណៈដូចគ្នានឹងដុំកែវមណីពណ៌ខៀវ ក៏ប្រាកដឡើង ហាក់ដូចជ្រែកផ្ទៃទឹកមហាសមុទ្រឡើងមកអំពីទិសបូព៌ ឧបមាដូចធ្វើអន្លង់នភាកាសឲ្យស្រស់ស្អាត ។ ចក្ករ័តន៍នោះ លោកហៅថា ជាទិព្វ ព្រោះប្រកបទៅដោយអានុភាពដែលជាទិព្វ ។ ឈ្មោះថា **សហស្សារ** ព្រោះមានកាំមួយពាន់ ឈ្មោះថា **សនេមិកំ សនាភិកំ** ព្រោះប្រកបដោយខ្នងកង់ និងដុំ ។ ឈ្មោះថា **សព្វាការបរិបូរំ** ព្រោះបរិបូណ៌ទៅដោយអាការគ្រប់យ៉ាង ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអាការទាំងនោះដូចតទៅនេះ ឈ្មោះថា **ចក្ករតន**

ព្រោះជាចក្រផង ជារតនៈផង ដោយអត្ថថា ញុំាំងនូវការត្រេកអរឲ្យកើត ។ ឯដុំរបស់ចក្ករ័តន៍ដែលលោកពោលថា មួយអន្ទើទៅដោយដុំ សម្រេចហើយដោយកែវឥន្ទនីល ។ ត្រង់កណ្ដាលដុំនោះមានប្រហោង សម្រេចដោយប្រាក់ស្អាតផូរផង់ ដូចការញញឹម ឬសើច មានជួរធ្មេញស្អាតស្និទ្ធល្អ ។ និងពាសទៅដោយបន្ទះប្រាក់ទាំងសងខាង ។ គឺទាំងខាងក្រៅ និងខាងក្នុង ដូចមណ្ឌលនៃព្រះចន្ទ មានប្រហោងត្រង់កណ្ដាល ដូច្នោះ ។ ក្នុងទីដែលបន្ទះប្រាក់ពាសទៅដោយដុំ និងប្រហោងទាំងនោះ ប្រាកដថា មានស្នាមគំនូស ដែលកំណត់ក្នុងឋានៈដែលសមគួរ បានរៀបចំហើយយ៉ាងល្អ នេះជាការបរិបូណ៌ដោយអាការគ្រប់យ៉ាងនៃដុំចក្ករ័តន៍នោះជាបឋម ។

ចក្ករ័តន៍ដែលលោកពោលថា មានកាំ ១០០០ ប្រកបដោយកាំឯណា កាំទាំងនោះសម្រេចដោយរតនៈ ៧ បរិបូណ៌ដោយរស្មី ដូចរស្មីនៃព្រះអាទិត្យ ។ សូម្បីកាំទាំងនោះ ក៏ប្រាកដថា បានចែកហើយយ៉ាងល្អដូចគ្នា ដូចធ្នូតគំនូសដែលគួរជាក្អមកែវមណីជាដើម ។ នេះជាការបរិបូណ៌ដោយអាការគ្រប់យ៉ាងនៃកាំទាំងឡាយនៃចក្ករ័តន៍នោះ ។

ឯចក្ករ័តន៍ដែលលោកពោលថា ដល់ព្រមដោយខ្នងកង់ ប្រកបទៅដោយខ្នងកង់ណា ខ្នងកង់នោះសម្រេចទៅដោយកែវប្រពាល មានពណ៌ក្រហមបរិសុទ្ធគួរស្រឡាញ់ ហាក់ដូចជាប្រកួតប្រជែងនៃរស្មីព្រះអាទិត្យកំពុងចែងចាំង ។

ឯទី-តនៃខ្នងកង់នោះ ជាបន្ទះមាសជម្ពូនទពណ៌ក្រហម មានឈ្មោះបោះសំឡេង គួរស្ងើចសរសើរ និងមានក្បូរក្បាច់ជារង្វង់មូលប្រាកដថា លោក

បានចាត់ចែងហើយយ៉ាងល្អ នេះជាការបរិបូណ៌ដោយអាការគ្រប់យ៉ាង នៃដុំ របស់ទិព្វចក្ករ័តន៍នោះ ។

ផ្នែកខាងខ្នងមណ្ឌលនៃដុំរបស់ទិព្វចក្ករ័តន៍ មានឈើសម្រេចដោយកែវ ប្រពាល ដូចបំពង់បបុសដែលមានប្រហោងខាងក្នុងប្រដាប់ជារង្វង់មូលនៅ ត្រង់កាំ ម្ខាងជប់ៗ ឈើសម្រេចដោយកែវប្រពាលណា វេលាខ្យល់បក់ មានសំឡេងពីរោះ នាំឲ្យកើតការសប្បាយចិត្តរីករាយចិត្ត ដូចសំឡេងនៃ តន្ត្រី ដែលមានអង្គ ៥ ដែលគេលេងដោយសិប្បៈដ៏ជំនាញ ដូច្នោះ ។ ឈើ ដែលសម្រេចដោយកែវប្រពាលនោះឯង មានស្វេតច្ឆត្រនៅខាងលើ មាន កម្រងផ្កាកោសុម ក្រងជារបៀបទាំងសងខាង ដោយប្រការដូចពណ៌នាមក នេះ ទើបមានសីហបញ្ជរ ២ ផ្នែក ខាងក្នុងកាំនៃដុំទាំង ២ របស់ទិព្វចក្ករ័តន៍ ដែលទ្រទ្រង់ដោយខ្នងកង់ ដែលចូលទៅបន្ថែមសម្រស់ដោយឈើសម្រេច ដោយកែវប្រពាល ១០០ សម្រាប់ទ្រទ្រង់នូវស្វេតច្ឆត្រ ១០០ មានកម្រងផ្កា កោសុមគ្រប់ដណ្តប់ជារបៀបដល់ទៅ ២០០ ជាបរិវារ មានក្រុមនៃកែវមុក្តា ទាំង ២ សំយុងចុះ មើលទៅល្អពន់ពេក តាមធម្មជាតិ ដូចអាកាសគង្គា មាន សិរីដោយក្រុមពន្លឺចន្ទពេញវង់ ដែលបាចសាចទៅប្រមាណមួយជួរដើមត្នោត ហាក់ដូចសំពត់កម្ពលពណ៌ក្រហម និងដូចពន្លឺព្រះអាទិត្យដ៏ស្រទន់ ចក្រទាំង ៣ ប្រាកដហាក់ដូចវិលទៅព្រមៗគ្នា ដោយការវិលទៅក្នុងអាកាស ព្រម ដោយចក្ករ័តន៍ ។ នេះជាការបរិបូណ៌ដោយអាការគ្រប់យ៉ាង ដោយប្រការ ទាំងពួងនៃចក្ករ័តន៍នោះ ។

កាលពួកមនុស្សបរិភោគអាហារល្ងាច តាមប្រក្រតីហើយ អង្គុយលើអាសនៈត្រង់មាត់ទ្វារដែលគេក្រាលទុករៀងៗខ្លួន សន្ទនាគ្នាដល់ហេតុការណ៍តាមដែលប្រព្រឹត្តទៅ កាលពួកទារកដែលមិនខ្ពស់ពេក មិនទាបពេក កំពុងលេងក្នុងថ្នល់ និងផ្លូវបែកជា ៤ ជាដើម ទិព្វចក្ករតន៍នោះឯង ក៏ធ្វើដំណើរឆ្ពោះមកកាន់រាជធានី ហាក់ដូចចូលទៅបន្តុតលម្អ មែកឈើ ចុងឈើបន្ថែមបរិយាកាស រហូតដល់បរិវេណក្នុងព្រៃស្រោង ដាស់ឲ្យពួកសត្វផ្សៀងត្រចៀកស្តាប់ដោយសំឡេងដ៏ពីរោះ ស្តាប់បានឆ្ងាយដល់ទៅ ១២ យោជន៍ ដឹកនាំឲ្យសម្លឹងមើល ដោយមានពន្លឺរុងរឿងជាហេតុ ឲ្យកើតរស្មីមានប្រការផ្សេងៗ អាចមើលឃើញបានក្នុងចម្ងាយមួយយោជន៍ ហាក់ដូចប្រកាសនូវបុញ្ញានុភាពនៃស្តេចចក្រពត្តិ ។

កាលចក្ករតន៍នោះបន្លឺសំឡេងទូទៅពេញព្រៃនោះឯង មនុស្សទាំងនោះគិតថា សំឡេងនេះមកអំពីណាហ្ន៎ ហើយក៏នាំគ្នាងើយមើលទៅទិសបូព៌ា ក៏នាំគ្នាពោលយ៉ាងនេះថា លោកដ៏ចម្រើនទាំងឡាយ ចូរមើលវត្ថុគួរអស្ចារ្យរៀងរាល់យប់ព្រះចន្ទពេញវង់តែមួយដួង តែថ្ងៃនេះ រះឡើងពីរដួង ឯដួងចន្ទទាំងគូនេះ អណ្តែតលឿនលយទៅកាន់នភាកាស តម្រង់ទៅទិសបូព៌ ឧបមាដូចគូនៃស្តេចហង្សបណ្តែតខ្លួនក្នុងអាកាសដូច្នោះ ។ ពួកខ្លះទៀត ពោលជំទាស់ថា នែសម្លាញ់ អ្នកនិយាយអ្វី ព្រះចន្ទពីរដួងរះព្រមគ្នា អ្នកធ្លាប់ឃើញពីអង្កាល់ណា ន៎ុះ គឺព្រះអាទិត្យដែលទ្រទ្រង់នូវរស្មីដ៏ខ្លាំងក្លា មានពណ៌ក្រហមលឿង ផុសឡើងមកហើយមិនមែនឬ មួយពួកទៀត ពោល

អះអាងបែបចំអកពួកមនុស្សទាំងនោះថា អ្នកទាំងឡាយឆ្កួតទៅហើយឬ ព្រះអាទិត្យទើបតែលិចទៅអម្បាញ់មិញមិនមែនឬ ព្រះអាទិត្យនោះនឹងរះតាមព្រះចន្ទពេញវង់នេះបានដូចម្ដេច តែនេះប្រហែលជាវិមានរបស់អ្នកមានបុណ្យណាម្នាក់ ទើបរុងរឿងទៅដោយពន្លឺនៃរតនៈមិនមែនតិច ។ មនុស្សទាំងអស់នោះនាំគ្នាយល់ឃើញមួយបែបម្នាក់ ទើបពួកក្រោយគេពោលយ៉ាងនេះថា ពួកអ្នកទាំងឡាយនិយាយផ្ដេសផ្ដាសឲ្យច្រើនរឿងធ្វើអ្វី នុ៎ះ មិនមែនព្រះចន្ទពេញវង់ មិនមែនព្រះអាទិត្យ មិនមែនវិមានរបស់ទេវតា តាមពិតសិរីសម្បត្តិបែបនេះមិនបានកើតឡើងដើម្បីវត្ថុទាំងនោះ តែពន្លឺនោះប្រហែលជាចក្ករ័តន៍ ។

កាលការចរចាជជែកវែកញែកប្រព្រឹត្តទៅយ៉ាងនេះ ចក្ករ័តន៍នោះ ក៏លះចន្ទមណ្ឌលតម្រង់មុខមក ។ បន្ទាប់អំពីនោះ មនុស្សទាំងនោះ ក៏ពោលថា ចក្ករ័តន៍នេះ កើតឡើងដើម្បីនរណាហ្ន៎ ក៏មានមនុស្សនិយាយឡើងថា ចក្ក-រ័តន៍នេះ មិនមែនកើតឡើងដល់អ្នកណាដទៃ អំពីមហារាជនៃពួកយើងទាំង-ឡាយ ទ្រង់បំពេញភាពជាស្ដេចចក្រពត្តិបរិបូណ៌ហើយ ចក្ករ័តន៍នេះ កើតឡើងជាគូនឹងបុណ្យបារមីរបស់ព្រះអង្គពិតប្រាកដ ។

លំដាប់នោះ ទាំងមហាជនក្រុមនោះ ទាំងមនុស្សដទៃៗ ដែលមើលឃើញគ្រប់ៗគ្នា ក៏ដើរតាមចក្ករ័តន៍ទៅរឿយៗ ។ សូម្បីចក្ករ័តន៍នោះ ក៏វិលជុំវិញព្រះនគរទៅ របូតផុតកំពែងនោះឯង ៧ ជុំ ហាក់ដូចប្រកាសឲ្យមនុស្សទូទៅដឹងនូវដំណើររបស់ខ្លួនមក ដើម្បីជាសម្បត្តិរបស់ព្រះរាជាមួយអន្លើធ្វើប្រទក្សិណខាងក្នុងព្រះរាជវាំងនៃព្រះរាជាហើយ ប្រតិស្ឋានទៅត្រង់សីហ-

បញ្ជរទិសឧត្តរនៃព្រះរាជវាំង ដូចត្រូវគន្លឹះខ្ចាស់ ដើម្បីឲ្យមហាជនបូជាដោយគ្រឿងសក្ការៈ មានគ្រឿងក្រអូប និងផ្កាជាដើមបានដោយស្រួល ។

កាលទិព្វចក្ករ័តន៍នោះ តាំងនៅដោយប្រការដូច្នេះហើយ ព្រះរាជាធិបតីទតឃើញគំនររស្មី មានព្រះហឫទ័យប្រាថ្នាដើម្បីទតចក្រកែវ ដែលចូលទៅតាមប្រហោងនៃសីហបញ្ជរ ធ្វើឲ្យខាងក្នុងប្រាសាទរុងរឿងដោយរស្មីកែវញុំាងឲ្យកើតសេចក្តីត្រេកអរ មានប្រការផ្សេងៗ ។ សូម្បីពួកជនដែលចោមរោម ក៏នាំគ្នាក្រាបទូលមូលហេតុនៃចក្ករ័តន៍នោះ ដោយពាក្យសម្តីគួរជាទីស្រឡាញ់ កាលនោះ ព្រះរាជាធិបតីមានព្រះវរកាយជោរជន់ទៅដោយបីតិបាមោជ្ជដ៏ខ្លាំងក្លា មានព្រះឧស្សាហ៍លះនូវបល្ល័ង្ក ទ្រង់ក្រោកចាកអាសនៈទៅកាន់ទីជិតសីហបញ្ជរ ទតឃើញចក្រកែវហើយ ទើបទ្រង់ព្រះចិន្តនាការថាឯអញបានឮពាក្យបុរាណលោកពោលមកថា ។បេ។ ដូច្នេះជាដើម ។ ព្រោះដូច្នោះ ទើបលោកពោលថា កាលទតឃើញហើយ ទើបទ្រង់មានព្រះតម្រិះថា ។បេ។ អញគប្បីបានជាស្តេចចក្រពត្តិពិតប្រាកដ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **សោ ហោតិ រាជា ចក្កវត្តិ** សេចក្តីថា សួរថា ព្រះរាជារមែងជាស្តេចចក្រពត្តិដោយហេតុមានប្រមាណប៉ុនណា ឆ្លើយថាដោយហេតុចក្ករ័តន៍ហោះឡើងកាន់អាកាសត្រឹម ១ អង្គុលីក៏បាន ២ អង្គុលីក៏បាន ។

ឥឡូវនេះ ដើម្បីសម្តែងដល់ការដែលព្រះរាជាគប្បីធ្វើក្នុងពិធីអភិសេកជាស្តេចចក្រពត្តិ ទើបត្រាស់ពាក្យថា **អថ ខោ ភិក្ខវេ** ដូច្នេះជាដើម ។ បណ្តា

បទទាំងនោះ បទថា **ឧដ្ឋាយាសនា** បានដល់ ទ្រង់ក្រោកអំពីអាសនៈដែលប្រថាប់គង់យាងទៅជិតចក្ករ័តន៍ ។ បទថា **សុវណ្ណភិង្ការំ គហេត្វា** សេចក្ដីថា ទ្រង់លើកសុវណ្ណភិង្គា គឺកុណ្ឌីមាស ដែលមានប្រហោងដូចប្រមោយដំរី ទ្រង់ចាប់កុណ្ឌីដោយព្រះហស្ដឆ្វេង ( ប្រោះលើចក្រកែវដោយព្រះហស្ដស្ដាំ ) ត្រាស់ថា ចក្ករ័តន៍ដ៏ចម្រើន ចូរអណ្ដែតទៅ ចក្ករ័តន៍ដ៏ចម្រើន ចូរមានជ័យជម្នះ ។ បទថា **អឆនេវ រាជា ចក្កវត្តិ ហោតិ ចតុរង្គិនិយា សេនាយ** សេចក្ដីថា ក្នុងខណៈដែលព្រះរាជាទ្រង់ប្រោះទឹកបំណាំងភាពជាស្ដេចចក្រពត្តិ ហើយទ្រង់បញ្ជាថា ចក្រកែវដ៏ចម្រើន ចូរមានមហាជ័យជម្នះចុះ ចក្រកែវក៏អណ្ដែតឡើងកាន់វេហាស៍ ត្រាច់ទៅ ។ ព្រះរាជានោះរមែងបានឈ្មោះថា ជាស្ដេចចក្រពត្តិអស់កាលដែលចក្រកែវអណ្ដែតទៅ ។ កាលចក្រកែវអណ្ដែតទៅហើយ ព្រះរាជាក៏ជាប់តាមចក្រកែវនោះទៅរឿយៗ ស្ដេចឡើងកាន់យានដ៏ប្រសើររបស់ស្ដេចចក្រពត្តិ ហោះឡើងកាន់វេហាស៍ ដោយប្រការដូច្នេះ ។

លំដាប់នោះ បរិវារ និងអ្នករាជការក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ក៏កាន់ឆត្រ និងផ្លិតជាដើម បន្ទាប់អំពីនោះ ក៏ដល់ក្រុមឥស្សរជន មានឧបរាជសេនាបតី ដល់ព្រមទៅដោយកម្លាំងទ័ពរបស់ព្រះអង្គ ដែលតាក់តែងគ្រឿងចម្បាំង មានអាវក្រោះ និងក្រោះ ៦ ប្រការជាដើម ប្រដាប់ដោយទង់ជ័យទង់ផ្កាលា លើកឡើង ដល់ព្រមទៅដោយគ្រឿងអលង្ការដែលនាំមកប្រដាប់ច្រើនប្រការ ក៏ហោះឡើងកាន់វេហាស៍ ជង្រៃព្រះរាជាមួយអង្គ ។ ដើម្បីសង្គ្រោះប្រជាជន ទើបពួកភ្នាក់ងាររបស់ព្រះរាជាស្រែកប្រកាសទៅគ្រប់ផ្លូវ

ថ្នល់ ក្នុងព្រះនគរថា ពុកម៉ែទាំងឡាយ ចក្រកែវកើតហើយដល់ព្រះរាជា របស់ពួកយើង ពួកអ្នកចូរប្រញាប់ចាត់ចែង សម្អិតសម្អាងខ្លួនប្រាណ តាមឋានានុរូបរៀងៗខ្លួន ប្រញាប់មកប្រជុំគ្នាចុះ ។ មហាជនឯណោះ ក៏នាំគ្នាលះការងារគ្រប់យ៉ាងដែលត្រូវធ្វើតាមប្រក្រតី កាន់គ្រឿងសក្ការៈ មានគ្រឿងក្រអូប និងផ្កាកម្រងជាដើម ប្រជុំគ្នាហើយ តាមសំឡេងចក្រកែវនោះឯង សូម្បីមហាជននោះៗ ក៏ហោះឡើងកាន់អាកាស ហែហមព្រះរាជាមួយអន្លើ គឺបុគ្គលណាបំណងនឹងធ្វើដំណើរជាមួយព្រះរាជា បុគ្គលនោះ ក៏ទៅតាមផ្លូវអាកាស ដោយប្រការដូច្នេះ ទើបមានបរិស័ទមកប្រជុំគ្នា ទាំងបណ្តោយ ទាំងទទឹងប្រមាណ ១២ យោជន៍ ក្នុងបរិស័ទនោះ មិនមានសូម្បីតែម្នាក់ដែលមានអវយវៈវិកលវិការ ឬស្លៀកពាក់សៅហ្មងឡើយ ទើបព្រះរាជាមានបរិវារដ៏ស្អាត ។ ធម្មតាបរិស័ទរបស់ស្តេចចក្រពត្តិធ្វើដំណើរទៅតាមអាកាស ដូចបរិស័ទវិទ្យាធរ ដូចគ្នានឹងរតនៈដែលដេរដាសនៅលើផ្ទៃកែវឥន្ទនីល ព្រោះដូច្នោះ ទើបលោកពោលថា ព្រះបាទចក្រពត្តិ ទ្រង់ស្តេចទៅតាមក្រោយ ព្រមដោយចតុរង្គសេនា ។

ចក្ករតន៍នោះ ក៏អណ្តែតលយល្បឿនទៅ ដោយអាកាសបទេស មិនខ្ពស់ពេក ប៉ប្រះៗចុងឈើ អាចឲ្យមនុស្សដឹងបានថា ទុំះព្រះរាជា ទុំះឧបរាជ ទុំះសេនាបតី ឧបមាដូចមនុស្សដែលត្រូវការផ្កា ផ្លែឈើ ឬស្លឹកឈើ ឈរនៅត្រង់ផែនដី ក៏អាចបេះយកវត្ថុទាំងនោះបានដោយស្រួល ។ បុគ្គលណាបំណងនឹងទៅក្នុងឥរិយាបថណា មានឈរជាដើម បុគ្គលនោះ ទៅបាន

ដោយឥរិយាបថនោះ ។ ឯបុគ្គលដែលដាក់ចិត្តក្នុងសិប្បៈ មានចិត្រកម្មជាដើម ក៏នាំគ្នាធ្វើធុរកិច្ចរៀងៗខ្លួន ទៅបានក្នុងអាកាសនោះ ។ លើផែនដីធ្លាប់ធ្វើធុរកិច្ចយ៉ាងណា ក្នុងអាកាសក៏អាចធ្វើធុរកិច្ចគ្រប់យ៉ាងបាន ដូច្នោះ ។ ចក្ក-រ័តន៍នោះ នាំបរិស័ទរបស់ស្តេចចក្រពត្តិវាងភ្នំសិនេរុរាជ ទៅខាងឆ្វេង ធ្លងផ្ទៃមហាសមុទ្រ រហូតដល់បុព្វវិទេហៈ ប្រមាណបាន ៨០០០ យោជន៍ ។ ចក្ក-រ័តន៍នោះប្រតិស្ឋានទៅលើអាកាស ដូចមានអ្វីទ្រ លើភូមិភាគដែលសមគួរដល់ការប្រជុំរបស់បរិស័ទ ទំហំ ១២ យោជន៍ វាស់ដោយជុំវិញ ៣៦ យោជន៍ រកឧបករណ៍ធ្វើអាហារបានស្រួល សម្បូរដោយម្ហូប និងទឹក ត្រង់ផ្ទៃដីដែលស្អាត រាបស្មើ គួរជាទីរីករាយ ។ កាលនោះ មហាជនចុះហើយដោយសញ្ញានោះ ធ្វើកិច្ចគ្រប់យ៉ាង ដូចជាងូតទឹក បរិភោគអាហារជាដើមតាមគាប់ចិត្ត ។ ព្រោះហេតុនោះ ទើបលោកពោលថា ចក្ករ័តន៍ប្រតិស្ឋានក្នុងប្រទេសណា ព្រះបាទចក្រពត្តិ ព្រមទាំងចតុរង្គសេនា ក៏ចូលទៅតាំងព្រះរាជនិវេសន៍ ក្នុងប្រទេសនោះ ។

កាលស្តេចចក្រពត្តិចូលទៅប្រថាប់យ៉ាងនេះ ព្រះរាជាក្នុងប្រទេសនោះៗគ្រាន់តែឮថា ចក្រមកហើយ ក៏ប្រជុំពលនិកាយ មិនត្រៀមច្បាំងក្នុងរវាងដែលចក្ករ័តន៍កើតឡើងហើយនោះឯង មិនមានបុគ្គលណាក្លាហានទាញអាវុធឡើងច្បាំងជាមួយព្រះរាជា ដោយបំណងជាសត្រូវ ។ នេះជាអានុភាពនៃចក្ករ័តន៍ ។

ដោយអានុភាពនៃចក្រ អរិរាជសត្រូវរបស់ព្រះរាជាអង្គនោះ រមែងដល់

នូវការស្ងប់ទៅដោយមិនមានសល់ ដោយហេតុនោះឯង ចក្ររបស់ព្រះរាជា-ធិបតីអង្គនោះ ទើបហៅថា អរិន្ទម ។

ព្រោះដូច្នោះ ព្រះរាជាទាំងនោះ គ្រប់ៗព្រះអង្គ ក៏កាន់យករាជសម្បត្តិដែលសមគួរដល់សិរីរាជសម្បត្តិរៀងៗខ្លួន បង្អោនសិរសាថ្វាយស្តេចចក្រពត្តិ ធ្វើការបូជាព្រះបាទរបស់ព្រះអង្គ ដោយវិធីអភិសេក ដោយពន្លឺនៃកែវមណីត្រង់ព្រះមោលីរបស់ខ្លួន ដល់នូវការចុះចាញ់ ដោយពោលពាក្យជាដើមថា សូមព្រះអង្គជាមហារាជចុះ ដូច្នេះ ។ ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចំណែកពួកស្តេចណា ដែលជាសត្រូវ គង់នៅក្នុងទិសខាងកើត ព្រះរាជាទាំងនោះ ក៏យាងចូលទៅគាល់ព្រះបាទចក្រពត្តិ ហើយក្រាបបង្គំទូលយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គទ្រង់យាងមកចុះ បពិត្រមហារាជ ទ្រង់យាងមកល្អហើយ បពិត្រមហារាជ រាជសម្បត្តិរបស់ខ្ញុំព្រះអង្គ ជារបស់ព្រះអង្គហើយ បពិត្រមហារាជ សូមព្រះអង្គទ្រង់ប្រៀនប្រដៅចុះ ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **ស្វាគតំ** ប្រែថា យាងមកល្អ ។ អធិប្បាយថា កាលព្រះរាជាមួយពួកយាងមក ប្រជានុរាស្ត្រសោកសៅ កាលព្រះរាជាយាងទៅ ប្រជារាស្ត្រត្រេកអរ កាលព្រះរាជាអង្គខ្លះយាងមក ប្រជារាស្ត្រត្រេកអរ កាលទ្រង់យាងទៅ ប្រជារាស្ត្រសោយសោក ស្តេចចក្រពត្តិដូចព្រះរាជាក្រោយនេះ គឺកាលយាងមកប្រជានុរាស្ត្រត្រេកអរ លុះយាងទៅ ប្រជានុរាស្ត្រសោយសោក ព្រោះដូច្នោះ ទើបការយាងមករបស់ព្រះអង្គ ឈ្មោះថា យាងមកល្អ ។ កាលពួកស្តេចបទេសរាជ ក្រាបទូល

ដូច្នេះហើយ ស្តេចចក្រពត្តិក៏មិនបានត្រាស់ថា ចូរព្រះអង្គបញ្ជូនបណ្ណាការដល់ខ្ញុំអស់កាលវេលាប៉ុណ្ណេះឆ្នាំផង ទ្រង់មិនរឹបជាន់ទ្រព្យសម្បត្តិរបស់អ្នកដទៃណាម្នាក់ផង តែទ្រង់ចូលទៅកំណត់អកុសលកម្មបថ មានបាណាតិបាតជាដើម ដោយវាចាដែលសមគួរដល់ការៈដែលព្រះអង្គជាធម្មរាជា ទ្រង់សម្តែងធម៌ដោយព្រះសូរសៀងដ៏គួរស្រឡាញ់ គួរពេញចិត្ត ដោយន័យជាដើមថា ដែលឈ្មោះថា បាណាតិបាតនេះ អ្នកណាសេព ចម្រើន ធ្វើឲ្យច្រើន រមែងទៅនរក ហើយប្រកាសឱវាទជាដើមថា មិនត្រូវសម្លាប់សត្វ ដូច្នេះ ដោយហេតុនោះ ទើបលោកពោលថា ស្តេចចក្រពត្តិត្រាស់បញ្ជាយ៉ាងនេះថា អ្នកទាំងឡាយមិនត្រូវសម្លាប់សត្វ ។បេ។ អ្នកទាំងឡាយ ចូរបរិភោគតែរបស់ដែលគួរបរិភោគចុះ ដូច្នេះ ។

សួរថា ព្រះរាជាគ្រប់អង្គ រមែងទទួលឱវាទនេះរបស់ព្រះរាជាធិបតីឬ ។ ឆ្លើយថា ព្រះរាជាគ្រប់អង្គមិនទទួលឱវាទនេះរបស់ព្រះពុទ្ធអង្គមកអំពីមុន នឹងទទួលឱវាទរបស់ព្រះរាជាបានដូចម្តេច ព្រោះដូច្នោះ ព្រះរាជាពួកណាជាអ្នកឈ្លាសប្រតិពល ព្រះរាជាទាំងនោះរមែងទទួល កាលព្រះរាជាគ្រប់អង្គប្រព្រឹត្តតាម រមែងចម្រើន ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា **យេ ខោ បន ភិក្ខវេ** ដូច្នេះជាដើម ។ កាលស្តេចចក្រពត្តិព្រះរាជទានព្រះឱវាទដល់អ្នកស្រុកបុព្វវិទេហៈយ៉ាងនេះ សោយព្រះក្រយាហារព្រឹកហើយ ចក្ករតន៍នោះ ក៏ហោះឡើងកាន់វេហាស៍ដោយកម្លាំងនៃស្តេចចក្រពត្តិ ចុះកាន់សមុទ្រទិសបូព៌ា ។ ចក្ករតន៍ឈានចុះដោយប្រការណាមួយ ចុះកាន់ផ្ទៃមហាសមុទ្រ

ប្រមាណមួយយោជន៍ ការខ្វាយរបស់រលក ក៏ថមថយចុះ ដូចស្តេចនាគប៉ះ ក្លិនថ្នាំហើយ បិទពពារ តាំងនៅដូចជញ្ជាំងកែវពៃទូរ្យក្នុងមហាសមុទ្រដោយ ប្រការនោះ ។ ខណៈនោះឯង រតនៈផ្សេងៗ ដែលដេរដាសនៅក្នុងផ្ទៃមហា សមុទ្រ ក៏មកអំពីមហាសមុទ្រនោះ ពាសពេញប្រទេសនោះ ហាក់ដូចជានាំ ឲ្យសរសើរនូវបុណ្យរបស់ព្រះរាជាធិបតីអង្គនោះ ។ កាលព្រះរាជា និងរាជ-បុរសឃើញផ្ទៃមហាសមុទ្រពេញទៅដោយរតនៈមានប្រការផ្សេងៗនោះ ទើប កាន់យក ដាក់ថ្នក់ ដាក់កញ្ចប់តាមពេញចិត្ត កាលបរិស័ទកាន់យករតនៈ តាមគាប់ចិត្ត ចក្ករ័តន៍នោះ ក៏វិលត្រឡប់ កាលចក្ករ័តន៍នោះវិលត្រឡប់ ទើបបរិស័ទនៅខាងមុខ ព្រះរាជានៅត្រង់កណ្តាល ចក្ករ័តន៍នៅក្នុងទីបំផុត សូម្បីទឹកសមុទ្រនោះ ហាក់ដូចត្រូវស្មានៃចក្ករ័តន៍ការពារ មិនអាចអត់ធន់ បាន ទើបបែកចេញអំពីចក្ករ័តន៍នោះ ហើយរសាត់ចូលមកបោកទីជុំវិញខ្នង កង់ចក្ករ័តន៍មិនដាច់ខ្សែ ។ ស្តេចចក្រពត្តិនោះ ទ្រង់មានជ័យជម្នះធំក្រៃលែង ចំពោះបុព្វវិទេហទ្វីប ដែលមានមហាសមុទ្រទិសខាងកើតជាព្រំដែន ទ្រង់ មានព្រះបំណងនឹងបានជ័យជម្នះក្នុងជម្ពូទ្វីប ដែលមានមហាសមុទ្រទិសខាង ត្បូងជាព្រំដែន ទើបបែរមុខទៅកាន់មហាសមុទ្រទិសទក្សិណ ដោយមាគ៌ា ដែលចក្ករ័តន៍បង្ហាញហើយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ចក្ករ័តន៍នោះបានអណ្តែតទៅទល់សមុទ្រ ទិសខាងកើត ហើយត្រឡប់អណ្តែតទៅទិសខាងត្បូង ។

វិធីវិលត្រឡប់របស់ចក្ករ័តន៍នោះ ដែលអណ្តែតទៅយ៉ាងនេះ ការប្រជុំ

របស់ពួកសេនា ការយាងទៅនៃស្តេចបទេសរាជ ការប្រគល់អនុសាសន៍ដល់ស្តេចបទេសរាជទាំងនោះ ការឈមចុះកាន់សមុទ្រទិសទក្សិណ ការកាន់យករតនៈដែលហូរតាមខ្សែទឹកនៃសមុទ្រទាំងអស់នេះ បណ្ឌិតគប្បីជ្រាបដោយន័យមុននោះឯង ។

ចក្ករ័តន៍នោះ កាលមានជ័យជម្នះហើយ ក៏អណ្តែតឆ្លងសមុទ្រទិសទក្សិណ ឆ្ពោះជម្ពូទ្វីប មានផ្ទៃប្រមាណ ១ ម៉ឺនយោជន៍ ហើយវិលទៅ ដោយន័យដូចពោលហើយពីមុននោះឯង ដើម្បីឈ្នះក្នុងអមរគោយានទ្វីប ដែលមានផ្ទៃប្រមាណ ៧ ពាន់យោជន៍ កាលមានជ័យជម្នះក្នុងអមរគោយានទ្វីប ដែលមានសមុទ្រជាព្រំដែននោះ ដោយទំនងនោះឯង ក៏អណ្តែតឆ្លងសមុទ្រទិសបស្ចិម ទៅដោយវិធីនោះឯង ដើម្បីឈ្នះឧត្តរកុរុទ្វីបដែលមានផ្ទៃប្រមាណ ៨ ពាន់យោជន៍ កាលមានជ័យជម្នះក្នុងឧត្តរកុរុទ្វីបនោះ ដែលមានសមុទ្រជាព្រំដែន ដោយវិធីដូចគ្នា ក៏អណ្តែតឆ្លងសមុទ្រទិសឧត្តរ ។ ស្តេចចក្រពត្តិទ្រង់សម្រេចភាពជាធំក្រៃលែងក្នុងផែនដី មានមហាសមុទ្រ ៤ ជាព្រំប្រទល់ ដោយប្រការដូចពណ៌នាមកនេះ ។

ស្តេចចក្រពត្តិនោះមានជ័យជម្នះដោយពិតយ៉ាងនេះហើយ កាលទ្រង់ទតសិរីរាជសម្បត្តិរបស់ព្រះអង្គ ទើបទ្រង់មួយអន្ទើដោយបរិស័ទ ហោះឡើងកាន់នភាកាសខាងលើ ពិនិត្យមើលទ្វីបធំទាំង ៤ ដែលមានទ្វីបតូចៗ ប្រាំរយៗ ជាបរិវារ ដូចជាតស្រះទាំង ៤ មានលម្អទៅដោយវត្ថុផ្សេងៗ ដូចជាបទុមឧប្បល និងបុណ្ឌរីក ដែលរីកស្គុសស្គាយ ដូច្នោះហើយ យាងត្រឡប់មក

រាជធានីដើមរបស់ព្រះអង្គតាមលំដាប់ ដោយមាគ៌ាដែលសម្ដែងហើយ ក្នុងចក្កទ្វីបនោះឯង ។

គ្រានោះ ចក្ករ័តន៍នោះប្រតិស្ឋាននៅដូចជាគ្រឿងបន្ថែមលម្អក្នុងទ្វារព្រះរាជវាំង កាលចក្ករ័តន៍នោះប្រតិស្ឋានដូច្នេះ កិច្ចដែលគប្បីធ្វើទាក់ទងនឹងគប់ភ្លើងក្ដី ការដុតប្រទីបក្ដី មិនចាំបាច់មានក្នុងព្រះរាជវាំង ពន្លឺនៃចក្ករ័តន៍នោះឯងកម្ចាត់ការងងឹតក្នុងរាត្រីបាន ឯជនណាត្រូវការងងឹត ជនទាំងនោះ ក៏បាននូវការងងឹត ដោយហេតុនោះ ទើបលោកពោលថា **ឧក្កិណ្ណំ ធិសំ សមុទ្ធំ អជ្ឈោគហេត្វា ។បេ។ ឯវរូបំ ចក្ករតនំ ចាតុភវតិ** ដូច្នេះ ។

ឯអមាត្យរបស់ស្ដេចចក្រពត្តិ ដែលមានចក្ករ័តន៍ប្រាកដហើយយ៉ាងនេះ បញ្ជាឲ្យធ្វើការសម្អាតភូមិភាគ ដែលជាលំនៅរបស់មង្គលហត្ថីដោយប្រក្រតី ឲ្យលាបស្រឡាបដោយគ្រឿងក្រអូប ដែលគួរដល់ការហិត មានខ្លឹមចន្ទន៍ក្រហមជាដើម ខាងក្រោមឲ្យដេរដាសទៅដោយផ្កាកោសុម ដែលនាំឲ្យមានពណ៌ដ៏វិចិត្រ ខាងលើតាក់តែងដោយផ្កាយមាស មានពិតានប្រដាប់ទៅដោយកម្រងផ្កាកោសុមគួរសរសើរ ចងជាក្រុមក្នុងចន្លោះផ្កាយមាស តុបតែងឲ្យស្អាតដូចទេវវិមាន ហើយក្រាបទូលថា បពិត្រសម្មតិទេព សូមទ្រង់ចិន្តនាការដល់ការមកនៃដំរីកែវឈ្មោះនេះ ។ ព្រះរាជាបំពេញមហាទាន សមាទានសីល ប្រថាប់គង់អាវជ្ជនៈដល់បុញ្ញសម្បត្តិនោះ ដោយន័យដូចពោលហើយខាងដើមនោះឯង ។

[ ១៥៩ ] លំដាប់នោះ ដំរីដ៏ប្រសើរដែលអានុភាពនៃបុណ្យរបស់ស្ដេច

ចក្រពត្តិជាស់តឿនហើយ បំណាច់នឹងសោយសក្ការៈដ៏វិសេសនោះ ក៏មកអំពីត្រកូលដំរីឆទ្ទន្ត ឬមកអំពីត្រកូលដំរីឧបោសថ មានសរីរៈសបរិសុទ្ធ ប្រដាប់ដោយសំពត់គជាករណៈសម្រាប់ដណ្តប់ក និងមុខ ពណ៌ក្រហមដូចព្រះអាទិត្យដែលទើបតែរះ មានអវយវៈទាំង ៧ ទល់ផែនដី ត្រូវលក្ខណៈ គឺមានអវយវៈតូច-ធំត្រូវខ្នាត មានចុងប្រមោយក្រហម ដូចផ្កាបទុមមាសពណ៌ក្រហម ដែលរីកស្គុសស្គាយ អាចហោះហើរលើអាកាសបាន ដូចព្រះយោគីដែលមានឫទ្ធិ ជាដំរីដ៏ប្រសើរបំផុត ដូចភ្នំប្រាក់ដែលមានកំពូលលាបដោយលម្អិតនៃមនោសិលា ប្រតិស្ឋាននៅក្នុងប្រទេសនោះ ដំរីដ៏ប្រសើរនោះ កាលមកពីត្រកូលដំរីឆទ្ទន្ត ក៏មកតែដំរីដែលតូចជាងដំរីទាំងពួង កាលមកអំពីត្រកូលដំរីឧបោសថ ក៏មកតែដំរីដែលធំជាងដំរីទាំងពួង តែក្នុងព្រះបាលីកំណត់ថា មកក្នុងលក្ខណៈស្តេចដំរីឈ្មោះឧបោសថ ។ កាលស្តេចចក្រពត្តិបំពេញវត្តនៃស្តេចចក្រពត្តិបរិបូណ៌ហើយ ទ្រង់ចិន្តនាការដោយន័យដូចពោលហើយក្នុងព្រះសូត្រនោះឯង ដំរីឧបោសថក៏ដើរមក មិនមែនមកដើម្បីមនុស្សដទៃឡើយ កាលមកដល់រោង ដំរីមង្គលហត្ថីធម្មតា ក៏នាំមង្គលហត្ថីចេញហើយចូលទៅឈរជំនួសក្នុងរោងដំរីនោះ ដោយខ្លួនឯងនោះឯង ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មួយទៀត ។បេ។ ជាស្តេចដំរី ឈ្មោះឧបោសថ ។

ហត្ថាចារ្យជាដើម ឃើញហត្ថិរ័តន៍នោះប្រាកដដូច្នោះហើយ ក៏សប្បាយរីករាយ រួតរះទៅក្រាបទូលឲ្យព្រះរាជាធិបតីទ្រង់ជ្រាបដោយប្រញាប់ ព្រះរាជា

យានមកដោយរហ័ស ទតឃើញហើយ មានព្រះរាជហឫទ័យប្រោសប្រាណ ទ្រង់ត្រិះរិះថា នេះជាហត្ថិយានដ៏ចម្រើនហ្ន៎ នែបា បើសម្រេចការទូន្មានហើយ ទ្រង់លាព្រះហស្តចេញ ។ គ្រានោះ ដំរីកែវសម្ងបត្រចៀក ដូចកូនគោដែលជៅជោះមេគោក្នុងផ្ទះ កាលសម្ដែងភាពដែលខ្លួនជាសត្វក្លាហាន ទើបចូលទៅគាល់ព្រះរាជា ព្រះអង្គមានបំណងនឹងប្រថាប់លើដំរីកែវនោះ គ្រានោះ បរិវារ-ជនជ្រាបបំណងរបស់ព្រះអង្គហើយ ទើបតាក់តែងហត្ថីរ័តន៍នោះ ដោយទង់មាស គ្រឿងអលង្ការមាស គ្របខ្លួនដោយសំណាញ់មាស ហើយនាំទៅថ្វាយ ។ ព្រះរាជាទ្រង់ធ្វើដំរីកែវឲ្យស្ងប់ ឡើងប្រថាប់ដោយជណ្ដើរ សម្រេចដោយរតនៈ ៧ ប្រការ មានព្រះហឫទ័យប្រាថ្នានឹងយាងទៅតាមអាកាស ព្រមគ្នានឹងព្រះរាជាធិបតីទ្រង់ព្រះតម្រិះនោះឯង ស្ដេចដំរីនោះ ក៏ហោះពួយឡើងកាន់នភាកាសពណ៌ខៀវ ចៀលច្នាត់ដោយសំណាញ់មាស ភ្លឺដោយពន្លឺកែវឥន្ទនីល និងកែវមណី ដូចស្ដេចហង្ស ។ បន្ទាប់អំពីនោះ បរិស័ទរបស់ព្រះរាជាទាំងអស់ក៏ជាប់តាមទៅ ដោយន័យដូចពោលហើយ ក្នុងការត្រាច់ទៅនៃចក្រ ព្រះរាជា មួយអន្លើដោយបរិស័ទ ស្ដេចត្រាច់ទៅពេញប្រឹថពីទាំងមូល ហើយត្រឡប់ដល់រាជធានី ទាន់ពេលព្រះស្ងោយព្រឹក ដំរីកែវរបស់ស្ដេចចក្រពត្តិមានឫទ្ធិច្រើនយ៉ាងនេះ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **ឧិស្វា ។បេ។ ធាតុរហោសិ** ដូច្នេះ ។

[ ១៦០ ] បរិស័ទរបស់ស្ដេចចក្រពត្តិ ដែលមានហត្ថីរ័តន៍ប្រាកដហើយដូច្នេះហើយ នាំគ្នាក្ការពេងសេះមង្គលឲ្យស្អាត មានផ្ទៃរាបស្មើ ប្រជាប់តាក់

តែងហើយ ក្រាបទូលជាស់តឿនព្រះរាជាឲ្យមានព្រះឧស្សាហ៍ ចិន្តនាការដល់ការមករបស់អស្សរ័តន៍នោះ ព្រះរាជាទ្រង់បំពេញទានសក្ការៈ សមាទានសីល ប្រថាប់គន់លើផ្ទៃប្រាសាទជាន់លើ ទ្រង់បង្អោនរឭកដល់បុញ្ញសម្បត្តិ ដោយន័យមុននោះឯង កាលនោះ ស្តេចសេះឈ្មោះវលាហក ដែលអានុភាពនៃបុណ្យរបស់ស្តេចចក្រពត្តិនោះជាស់តឿនហើយ មានកាយល្អ ពណ៌ដូចពពក ដូចដុំវលាហកស ក្នុងសរទកាល ដែលដើរជាសដោយផ្ទែកបន្ទោរ មានជើងក្រហម មាត់ក្រហម មានខ្លួនប្រកបដោយជង្ឃខ្លួនល្អឥតខ្ចោះ ដូចដុំនៃពន្លឺព្រះចន្ទ មានក្បាលស្រដៀងក្បាលក្អែក ព្រោះប្រកបដោយក្បាលពណ៌ខ្មៅដូចកក្អែក និងដូចកែវមណីឥន្ទនីល មានសរសៃសក់ល្អ ដូចស្មៅយាប្លង ព្រោះប្រកបទៅដោយសរសៃសក់ដែលល្អិត ត្រង់ ដូចគ្នានឹងស្មៅយាប្លងដែលគេក្រង ហោះទៅក្នុងអាកាសបាន មកអំពីត្រកូលសេះសិន្ធពប្រតិស្ឋានក្នុងទីនោះ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងហត្ថិរ័តន៍នោះឯង ។ ទ្រង់សំដៅយកអស្សរ័តន៍បែបនេះ ទើបព្រះមានព្រះភាគត្រាស់ថា **បុន ចបរំ** ដូច្នេះជាដើម ។

[ ១៦១ ] កាលស្តេចចក្រពត្តិមានរតនៈប្រាកដដូច្នេះ ក៏មានមណីរ័តន៍ចេញមកពី ភ្នំវេបុលបព៌ត បណ្តោយប្រមាណ ៤ ហត្ថ មានសណ្ឋានប្រមាណប៉ុនដុំរទេះ ទីបំផុតសងខាង ស្រោបទៅដោយកណិការ ប្រដាប់ទៅដោយបទុមមាសសងខាង មានចង្កោមមុក្តាស្អាតបរិសុទ្ធ ប្រាសចាកមន្ទិលដូចជាព្រះចន្ទពេញវង់ ហែហមទៅដោយហ្វូងផ្កាយតូចធំ ចោលរស្មីទៅ

ដូច្នោះ កាលកែវមណីនោះ អណ្តែតមកយ៉ាងនេះហើយ មហាជនក៏តប្ញស្សី តៗគ្នា លើកឡើងកាន់អាកាស កម្ពស់ប្រមាណ ៦០ ហត្ថ ដោយវៀរ សំណាញ់នៃកែវមុក្តា ក្នុងពេលយប់ មានពន្លឺផ្សាយទៅក្នុងទីប្រមាណមួយ យោជន៍ដោយជុំវិញ មណីរ័តន៍ដែលឲ្យកើតពន្លឺពេញបរិវេណទាំងអស់ ដូច ពន្លឺក្នុងវេលាព្រះអាទិត្យរះឡើង ធ្វើឲ្យអ្នកស្រែប្រកបកសិកម្មបាន ឈ្មួញ ពាណិជលក់ដូរបន្តបានក្នុងផ្សារ បុគ្គលដែលថ្មីកក្នុងអាជីពតែមួយសាខា សម្គាល់ថា ជាពេលថ្ងៃ ក៏ប្រកបការងាររបស់ខ្លួនបានតាមនាទី ដោយហេតុ នោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សេចក្តីដទៃនៅ មានទៀត ។បេ។ មណីរ័តន៍ រមែងប្រាកដ ដូច្នេះ ។

[ ១៦២ ] ឥត្ថីរ័តន៍ដែលជាហេតុឲ្យកើតសេចក្តីសុខពិសេស តាមភេទ វិស័យ រមែងកើតឡើងដល់ស្តេចចក្រពត្តិ ដែលមានមណីរ័តន៍ប្រាកដហើយ ដូច្នេះ ។ ប្រជានុរាស្ត្រ រមែងនាំអគ្គមហេសីមកអំពីត្រកូលមទ្ទរាជ ថ្វាយ ស្តេចចក្រពត្តិខ្លះ អគ្គមហេសីយាងមកឯងអំពីឧត្តរកុរុទ្វីប ដោយបុញ្ញានុភាព ខ្លះ ។ ឯគុណសម្បត្តិដ៏សេសនៃអគ្គមហេសីនោះ មានមកហើយ ក្នុងព្រះ បាលីទាំងអស់ ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ តទៅទៀត ឥត្ថីរ័តន៍ ក៏កើតប្រាកដដល់ស្តេចចក្រពត្តិ ។ ស្រីកែវនោះមានរូបឆោមដ៏ល្អ គួរឲ្យអ្នក ផងពិតពិលរមិលមើល ... ដូច្នេះ ។ ក្នុងបទដែលមកក្នុងព្រះបាលីទាំងនោះ មានវិនិច្ឆ័យដូច្នេះ ដែលឈ្មោះ **អភិរូបា** ព្រោះមានរូបស្អាត បរិបូណ៌ដោយ ទ្រង់ទ្រាយ ។ កាលសម្លឹងមើល ក៏ពេញភ្នែក ព្រោះដូច្នោះ ទើបឈ្មោះថា

**ឧស្សង្កនីយា** ព្រោះត្រូវផ្អាកកិច្ចដទៃ ហើយក្រឡេកមើល ។ ឈ្មោះថា **ចាសាទិកា** ព្រោះកាលមើល ក៏នាំឲ្យមានចិត្តសោមនស្ស ។ បទថា **បរមាយ** សេចក្តីថា ឈ្មោះថា ឧត្តម ព្រោះនាំនូវការជ្រះថ្លាមកឲ្យយ៉ាងនេះ ។ បទថា **វណ្ណាចោក្ខរតាយ** ប្រែថា មានពណ៌សម្បុរល្អ ។ បទថា **សមន្នាគតា** ប្រែថា ចូលដល់ មួយប្រការទៀត ឈ្មោះថា មានរូបស្អាត ព្រោះមិនខ្ពស់ពេក មិនទាបពេក ឈ្មោះថា គួរមើល ព្រោះមិនស្គមពេក មិនធាត់ពេក ឈ្មោះថា គួរជ្រះថ្លា ព្រោះមិនខ្មៅពេក មិនសពេញ ឈ្មោះថា ប្រកបដោយលម្អនៃសម្បុរស្បែកដ៏ក្រៃលែង ព្រោះកន្លងបង់នូវពណ៌សម្បុររបស់មនុស្ស តែមិនទាន់ដល់លំដាប់ជាទិព្វ សេចក្តីពិត ពណ៌សម្បុររបស់មនុស្សទាំងឡាយ មិនមានពន្លឺផ្សាយទៅខាងក្រៅ ចំណែកពណ៌សម្បុររបស់ទេវតា ផ្សាយទៅបានឆ្ងាយ ។ តែពន្លឺនៃសរីរៈរបស់ស្រីកែវនោះ ភ្លឺទៅក្នុងបរិវេណប្រមាណ ១២ ហត្ថ ក្នុងបណ្តាគុណសម្បត្តិ មានមិនខ្ពស់ពេកជាដើម លោកពោលអារោហសម្បត្តិដោយគុណសម្បត្តិគូទី ១ ពោលបរិ-ណាហសម្បត្តិដោយគុណសម្បត្តិគូទី ២ ពោលវណ្ណសម្បត្តិដោយគុណ-សម្បត្តិគូទី ៣ ។ ម្យ៉ាងទៀត គុណ ៦ ប្រការនេះ អគ្គមហេសីមិនមានការខ្វះខាតដោយកាយឡើយ ។

កាយសម្បត្តិ ត្រាស់ដោយបទនេះថា **អតិក្កន្តា មានុសំ វណ្ណំ** គឺកន្លងបង់នូវពណ៌សម្បុររបស់មនុស្ស ។ បទថា **តូលបិចុនោ វា កប្បាសបិចុនោ វា** សេចក្តីថា មានសម្ផស្សកាយប្រៀបដូចសម្ផស្សនៃគរ ឬសំឡីដែលគេ

ដាក់ក្នុងសប្បិ ហើយថ្លចអស់ ១០០ ដង ។

បទថា **សីតេ** បានដល់ ក្នុងពេលដែលព្រះរាជាធិបតីរងា ។ បទថា **ឧណ្ហេ** បានដល់ ក្នុងគ្រាដែលព្រះរាជាធិបតីក្តៅ ។ បទថា **ចន្ទនគន្ធា** សេចក្តីថា ក្លិនចន្ទន៍ដែលគេបុកសព្វកាលថ្មីថ្មោង នាំមកលាយជាមួយគន្ធ-ជាតិទាំង ៤ រមែងផ្សាយចេញអំពីកាយ ។ បទថា **ឧប្បលគន្ធោ** សេចក្តីថា ក្លិនដែលក្រអូបរបស់ឧប្បលខៀវដែលគេកាត់ផ្កាក្នុងខណៈនោះ រមែងក្រអូបចេញអំពីមាត់ ក្នុងវេលាញញឹម ឬចរចា ។ ដើម្បីសម្តែងដល់មារយាទដែលសមគួរដល់ស្ត្រីសម្បត្តិរបស់ស្រីកែវ ព្រោះប្រកបដោយគុណសម្បត្តិបែបនេះ ទើបត្រាស់ថា **តំ ខោ បន** ដូច្នេះជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទទាំងនោះដូច្នេះ ដែលឈ្មោះថា **បុព្វុដ្ឋាយិនី** គឺក្រោកមុន ព្រោះត្រូវក្រោកឡើងមុននោះឯង ដូចសង្ស័យថា ព្រះរាជាទ្រង់ឃើញហើយ នឹងពិរោធ ដូចភ្លើងឆេះ តាំងអំពីរាជអាសនៈ ។ ឈ្មោះថា **បច្ឆានិបាតិនី** ព្រោះកាលព្រះរាជាប្រថាប់គង់ ក៏ត្រូវបក់ផ្លិតថ្វាយព្រះរាជាធិបតីមុនហើយ ទើបដេក ឬសម្រាកបានក្នុងកាលជាខាងក្រោយ ។ ដែលឈ្មោះថា **កឹការបដិស្សាវិនី** ព្រោះនឹងត្រូវទទួលដោយវាចាថា បពិត្រព្រះអង្គ ខ្ញុំម្ចាស់ត្រូវធ្វើអ្វី ។ ដែលឈ្មោះថា **មនាបចារិនី** ព្រោះត្រូវប្រព្រឹត្ត គឺធ្វើឲ្យត្រូវចិត្តព្រះរាជា ។ ដែលឈ្មោះថា **បិយវាទិនី** ព្រោះព្រះរាជាប្រោសយ៉ាងណា ក៏ត្រូវទូលយ៉ាងនោះ ។ ឥឡូវនេះ ដើម្បីសម្តែងថា ស្រីកែវនោះ មានអាចារបរិសុទ្ធផូរផង់ ដោយចំណែកមួយ មិនមានមាយាសាថេយ្យ ទើបត្រាស់ថា **តំ ខោ បន** ដូច្នេះ

ជាដើម ។

បណ្តាបទទាំងនោះ បទថា **នោ អតិចរតិ** បានដល់ មិនប្រព្រឹត្តក្រៅចិត្ត អធិប្បាយថា មិនប្រាថ្នាប្រុសដទៃសូម្បីដោយចិត្ត ។ ក្នុងបណ្តាគុណសម្បត្តិទាំងនោះ គុណសម្បត្តិណាដែលត្រាស់ខាងដើមថា មានរូបស្អាតជាដើមក្តី ដែលត្រាស់ក្នុងខាងចុងថា ក្រោកឡើងមុនជាដើមក្តី គុណសម្បត្តិទាំងនោះ ជាគុណសម្បត្តិធម្មតាប៉ុណ្ណោះ ។ បទថា **អតិក្កន្តា មានុសំ វណ្ណំ** ជាដើម គប្បីជ្រាបថា ស្តេចចក្រពត្តិទាំងឡាយ រមែងកើតឡើង ដោយអានុភាពនៃបុរាណកម្ម រាប់អំពីចក្ករ័តន៍ប្រាកដ ព្រោះត្រូវអាស្រ័យបុណ្យបារមី ។ មួយប្រការទៀត ចាប់តាំងអំពីចក្ករ័តន៍ប្រាកដ ភាពជាអ្នកមានរូបស្អាតជាដើម កើតឡើងបរិបូណ៌គ្រប់អន្លើ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ឥត្ថីរ័តន៍មានសភាពយ៉ាងនេះឯង តែងកើតប្រាកដ ដល់ស្តេចចក្រពត្តិ ដូច្នេះ ។

[ ១៦៣ ] គហបតិរ័តន៍ រមែងប្រាកដដល់ស្តេចចក្រពត្តិដែលមានឥត្ថីរ័តន៍ប្រាកដហើយ ដើម្បីជួយឲ្យងាយស្រួល ទាក់ទងនឹងកិច្ចរក្សាឃ្លាំង តាមព្រះរាជអធ្យាស្រ័យ បុគ្គលដែលមានភោគៈច្រើនតាមប្រក្រតីក្តី បុគ្គលដែលកើតក្នុងត្រកូលមានភោគៈច្រើនក្តី មានចំណែកជួយឲ្យកិច្ចថែរក្សាឃ្លាំងរបស់ព្រះរាជាឲ្យចម្រើនរុងរឿង ទើបជាសេដ្ឋីគហបតីបាន ។ ចក្ខុប្រៀបដូចទិព្វកើតអំពីវិបាកកម្ម ក្នុងការជួយនូវប្រយោជន៍ រមែងប្រាកដដល់គហាតីកែវនោះឯង ជាហេតុឲ្យមើលឃើញទ្រព្យខាងក្នុងផែនដីបាន ក្នុងទីមួយយោជន៍ គាត់

ឃើញសម្បត្តិនោះហើយ ត្រេកអរ ចូលគាល់ស្តេចចក្រពត្តិ ជួយធ្វើកិច្ចរក្សាឃុំគ្រងឲ្យព្រះរាជា ចាត់ចែងការងារឃុំគ្រងគ្រប់យ៉ាងឲ្យបរិបូណ៌ ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ នៅមានតទៅទៀត ។បេ។ គហបតិរ័តន៍បែបនេះ រមែងប្រាកដដូច្នេះ ។

[ ១៦៤ ] បរិនាយករ័តន៍ អាចចាត់ចែងកិច្ចគ្រប់យ៉ាងឲ្យសម្រេច រមែងប្រាកដដល់ស្តេចចក្រពត្តិ ដែលមានគហបតីកែវប្រាកដហើយនោះ ដោយប្រការដូច្នេះ ។ បរិនាយកនោះ ជាព្រះរាជបុត្រច្បងរបស់ស្តេចចក្រពត្តិ ជាបណ្ឌិត ឈ្លាសប្រតិពល មានបញ្ញាដោយប្រក្រតីនោះឯង មានបរចិត្តញាណរមែងកើតដល់បរិនាយករ័តន៍នោះ ដោយអានុភាពនៃកម្មរបស់ខ្លួនឯង ព្រោះអាស្រ័យបុញ្ញានុភាពរបស់ស្តេចចក្រពត្តិ ជាហេតុអាចឲ្យដឹងវារៈចិត្តរបស់រាជបរិវារបានប្រមាណ ១២ យោជន៍ ហើយកំណត់វត្ថុដែលមិនជាប្រយោជន៍និងវត្ថុដែលជាប្រយោជន៍សម្រាប់ព្រះរាជាបាន ។ បរិនាយកនោះ ឃើញអានុភាពរបស់ខ្លួននោះហើយ ត្រេកអរ ទទួលយកអាសាព្រះរាជា ដោយបញ្ហាចាត់ការជំនួសក្នុងកិច្ចគ្រប់យ៉ាង ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តទៅទៀត បរិនាយករ័តន៍ ក៏កើតប្រាកដដល់ស្តេចចក្រពត្តិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឋបេតព្វំ ឋបេតុំ** បានដល់ ដើម្បីទ្រទ្រង់តែងតាំងបុគ្គលដែលគួរតែងតាំងក្នុងតំណែងនោះៗ ។ បទថា **សមវេចាកិណិយា** ជាដើម លោកពោលហើយខាងដើមនោះឯង ។ បទថា **កដគ្គាហោន** ប្រែថា

*ព្រោះជួយយកជ័យជម្នះបាន ។*

[ ១៧១ ] *បទថា* **មហន្តំ ភោគក្ខន្ធំ** *សេចក្តីថា គប្បីបានប្រាក់ ២ ឬ ៣ សែន ដោយការជួយយកជ័យជម្នះបានម្តងប៉ុណ្ណោះ ។ បទថា* **កេវលា បរិបូរា បណ្ឌិតភូមិ** *សេចក្តីថា បណ្ឌិតបំពេញសុចរិត ៣ រមែងកើតក្នុងស្ថានសួគ៌ ។ បន្ទាប់អំពីនោះ កាលមកកាន់មនុស្សលោក រមែងកើតក្នុងទីដែលបរិបូណ៌ដោយត្រកូល រូប និងភោគៈ ជននោះតាំងនៅក្នុងសម្បត្តិនោះហើយ បំពេញសុចរិត ៣ ឲ្យបរិបូណ៌ រមែងទៅកើតក្នុងស្ថានសួគ៌ទៀត ។ តាមដែលពណ៌នាមកនេះ ទើបចាត់ថា ជាភូមិរបស់បណ្ឌិត យ៉ាងគ្រប់គ្រាន់បរិបូណ៌ ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ហើយ ដូច្នេះ ។*

**អដ្ឋកថា ពាលបណ្ឌិតសូត្រ ចប់**

**សូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ទេវទូតសូត្រទី ១០

[ ១៧២ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ កាល ព្រះមានព្រះភាគ គង់នៅក្នុងវត្តនោះ បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាល ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះ ករុណាព្រះអង្គ ។

[ ១៧៣ ] ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មានផ្ទះពីរ ប្រកបដោយទ្វារ ក្នុងផ្ទះនោះ មានបុរសភ្នែកភ្លឺម្នាក់ ឈរចំកណ្តាល គប្បីមើលឃើញពួកមនុស្ស ដែលកំពុងចូលទៅកាន់ផ្ទះក្តី ចេញអំពីផ្ទះក្តី កំពុងសញ្ចរទៅមកក្តី កំពុងត្រាច់ទៅមកក្តី សេចក្តីនេះមានឧបមាយ៉ាងណា ម្នាលភិក្ខុទាំងឡាយ មានឧបមេយ្យដូចតថាគត មានចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ កន្លងលើសចក្ខុជារបស់នៃមនុស្សធម្មតា រមែងឃើញពួកសត្វលោកដែលច្យុត ដែលកើត ជាសត្វថោកទាប ឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មាន គតិល្អ មានគតិអាក្រក់ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្មរបស់ ខ្លួនថា អើហ្ន៎ សត្វទាំងឡាយនេះ ប្រកបដោយកាយសុចរិត ប្រកបដោយ វចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលព្រះអរិយបុគ្គល ទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើជាសម្មាទិដ្ឋិ លុះសត្វទាំងនោះ បែក ធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ចំណែកសត្វ

ទាំងឡាយនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់នូវអំពើជាសម្មាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងមនុស្សលោក អើហ្ន៎ សត្វទាំងនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះបែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតប្រេតវិស័យ ចំណែកសត្វទាំងឡាយនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ចំណែកពួកសត្វនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលព្រះអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់នូវអំពើជាមិច្ឆាទិដ្ឋិ លុះសត្វទាំងនោះ បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេត អសុរកាយ នរក ។

[ ១៧៤ ] ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុរសនោះ ត្រង់ដើមដៃផ្សេងៗ នាំយកទៅថ្វាយព្រះយមរាជ រួចក្រាបទូលថា បពិត្រព្រះឧបបត្តិទេព បុរសនេះ ជាអ្នកមិនគោរពមាតាបិតា មិនគោរពសមណៈ មិនគោរពព្រាហ្មណ៍ មិនកោតក្រែងក្នុងត្រកូលរៀមច្បងទេ សូមទ្រង់ដាក់អាជ្ញា

ដល់បុរសនេះចុះ ។

[ ១៧៥ ] ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជសាកសួរដេញដោល សួរឈ្មេចឈ្មី នូវទេវទូតទី ១ នឹងបុរសនោះថា នែបុរស អ្នកឯងមិនបាន ឃើញទេវទូតទី ១ ដែលកើតប្រាកដក្នុងមនុស្សលោក ទេឬ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរសនោះយ៉ាងនេះវិញថា ម្នាល បុរស អ្នកឯងមិនបានឃើញកូនខ្ចីកំពុងដេកផ្ងារ ដេកត្រាំក្នុងទឹកមូត្រ និងលាមក របស់ខ្លួន ក្នុងមនុស្សលោក ទេឬ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូម ទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយម-រាជសួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្តីឡើង រហូតដល់ចាស់ តើមានគំនិតថា អាត្មាអញឯង មានជាតិជាធម្មតា មិនកន្លង នូវជាតិទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញធ្វើអំពើល្អដោយកាយ ដោយ វាចា ដោយចិត្ត ដូច្នេះដែរឬទេ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូម ទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច ( នឹងគិតឃើញដូច្នោះ ) បានឡើយ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជមានព្រះឱង្ការពន្យល់បុរសនោះ យ៉ាងនេះថា ម្នាលបុរស ព្រោះ តែសេចក្តីប្រមាទ បានជាអ្នកឯង មិនបានធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯង មានសេចក្តីប្រមាទ យ៉ាងណា ពួកនិរយ-បាល នឹងធ្វើ ( អ្នកឯង ) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកឯងនោះ

មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាទាំងឡាយធ្វើឲ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាក នៃបាបកម្មនោះវិញ ។

[ ១៧៦ ] ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជ សាកសួរដេញដោលសួរឈ្ងេចឈ្ងី នូវទេវទូតទី ១ នឹងបុរសនោះរួចហើយ ទើបសាកសួរដេញដោល សួរឈ្ងេចឈ្ងី នូវទេវទូតទី ២ ទៀតថា ម្នាលបុរស អ្នកឯងមិនបានឃើញទេវទូតទី ២ ដែលកើតប្រាកដក្នុងមនុស្សលោកទេឬ ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរសនោះ យ៉ាងនេះវិញថា នែបុរស ចុះអ្នកឯងមិនបានឃើញស្ត្រី ឬបុរសដែលមានអាយុ ៨០ ឆ្នាំ ៩០ ឆ្នាំ ឬ ១០០ ឆ្នាំ ដែលចាស់គ្រាំគ្រាអំពីកំណើត មានឆ្អឹងជំនីរកោងដូចជាបង្កង់ផ្ទះ មានកាយកោង កាន់ឈើច្រត់ដើរទៅ ញ័ររន្ធត់ ក្ដៅអន្ទះសា មានវ័យជ្រុលហួសហើយ មានធ្មេញបាក់ មានសក់ស្កូវ មានក្បាលធក មានក្បាលតម្លែក មានស្បែកជ្រួញជ្រីវ មានខ្លួនសៅហ្មងដោយប្រជ្រុយ ក្នុងមនុស្សលោក ទេឬ ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្ដីឡើងរហូតដល់ចាស់ តើមាន

គំនិតថា អាត្មាអញឯង មានសេចក្តីគ្រាំគ្រាជាធម្មតា មិនកន្លងនូវសេចក្តីគ្រាំគ្រាទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬ ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច ( នឹងគិតឃើញ ) ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជក៏ត្រាស់ពន្យល់បុរសយ៉ាងនេះថា ម្នាលបុរស ព្រោះតែសេចក្តីប្រមាទបានជាអ្នកឯង មិនធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរសបើអ្នកឯង មានសេចក្តីប្រមាទយ៉ាងណា ពួកនិរយបាលនឹងធ្វើ ( អ្នកឯង ) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកនោះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាទាំងឡាយធ្វើឲ្យទេ ឯបាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាក នៃបាបកម្មនោះវិញ ។

[ ១៧៧ ] ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោលសួរឈ្លេចឈ្លី នូវទេវទូតទី ២ នឹងបុរសនោះរួចហើយ ទើបសាកសួរដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ៣ ទៀតថា ម្នាលបុរស អ្នកឯងមិនបានឃើញនូវទេវទូតទី ៣ ដែលកើតប្រាកដក្នុងមនុស្សលោកទេឬ ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរសនោះ យ៉ាងនេះវិញថា នៃ

បុរស អ្នកឯងមិនបានឃើញនូវស្ត្រី ឬបុរស ដែលមានជំងឺ ដល់នូវសេចក្តីលំបាក ឈឺធ្ងន់ កំពុងដេកត្រាំក្នុងទឹកមូត្រ និងលាមករបស់ខ្លួន លុះតែមានពួកជនដទៃគ្រាហ៍ទើបក្រោករួច មានពួកជនដទៃគ្រាហ៍ ទើបចូលមកបាន ក្នុងមនុស្សលោកទេឬ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្តីឡើង រហូតដល់ចាស់ តើមានគំនិតថា អាត្មាអញឯង មានជំងឺជាធម្មតា មិនកន្លងជំងឺទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញ ធ្វើអំពើល្អដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬទេ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច ( នឹងគិតឃើញ ) ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រាស់ពន្យល់បុរសនោះយ៉ាងនេះថា នែបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯងមិនបានធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯងមានសេចក្តីប្រមាទយ៉ាងណា ពួកនិរយបាលនឹងធ្វើ ( អ្នកឯង ) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកឯងនោះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាទាំងឡាយធ្វើឲ្យទេ បាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាក នៃបាបកម្មនោះវិញ ។

[ ១៧៨ ] ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ៣ នឹងបុរសរួចហើយ ទើបសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ៤ ទៀតថា នៃបុរស អ្នកឯងមិនបានឃើញនូវទេវទូតទី ៤ ដែលកើតប្រាកដ ក្នុងមនុស្សលោកទេឬ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ទើបព្រះយមរាជត្រឡប់សួរបុរសនោះ យ៉ាងនេះវិញថា នៃបុរស ចុះអ្នកឯងបានឃើញនូវព្រះរាជាទាំងឡាយ កាលចាប់ចោរ ដែលប្រព្រឹត្តអាក្រក់បានហើយ ត្រាស់បង្គាប់ឲ្យធ្វើកម្មករណ៍ផ្សេងៗ គឺឲ្យវាយដោយរំពាត់ខ្លះ ឲ្យវាយដោយផ្តៅខ្លះ ឲ្យវាយដោយដំបងខ្លីខ្លះ ឲ្យកាត់ដៃខ្លះ ឲ្យកាត់ជើងខ្លះ ឲ្យកាត់ទាំងដៃទាំងជើងខ្លះ ឲ្យកាត់ស្លឹកត្រចៀកខ្លះ ឲ្យកាត់ច្រមុះខ្លះ ឲ្យកាត់ទាំងស្លឹកត្រចៀក ទាំងច្រមុះខ្លះ ឲ្យធ្វើពិលង្គថាលិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាឆ្នាំងដាក់ទឹកជ្រក់ខ្លះ ឲ្យធ្វើនូវសង្ខមុណ្ឌិកកម្ម គឺអំពើដែលគេធ្វើក្បាលឲ្យរលីងដូចជាសម្បកស័ង្ខខ្លះ ឲ្យធ្វើនូវរាហុមុខកម្ម គឺអំពើដែលគេធ្វើមាត់ ឲ្យដូចជាមាត់រាហុខ្លះ ឲ្យធ្វើនូវជោតិមាលិកកម្ម គឺអំពើដែលគេធ្វើខ្លួនមនុស្សឲ្យដូចជាផ្កាភ្លើងខ្លះ ឲ្យធ្វើនូវហត្ថប្បជោតិកកម្ម គឺអំពើដែលគេដុតដៃខ្លះ ឲ្យធ្វើនូវឯរកវត្តិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាពន្ទាត់ស្បែកពពែខ្លះ ឲ្យធ្វើនូវចីរកវាសិកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាស្លៀកសំពត់សម្បកឈើខ្លះ ឲ្យធ្វើនូវឯណេយ្យកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាជើងសត្វទ្រាយខ្លះ ឲ្យធ្វើនូវពលិសមំសិកកម្ម គឺអំពើដែលគេថ្ពក់មាត់ដោយកាង ឬ

សន្ធបខ្លះ ឲ្យធ្វើនូវកហាបណកកម្ម គឺអំពើដែលគេធ្វើឲ្យខូចសរីរៈប្រមាណប៉ុនកហាបណៈមួយៗខ្លះ ឲ្យធ្វើនូវខារាបតច្ឆិកកម្ម គឺអំពើដែលគេយកទឹកផ្សាស្រោចខ្លះ ឲ្យធ្វើនូវបលិឃបរិវត្តិកកម្ម គឺអំពើដែលធ្វើឲ្យដូចជាបង្វិលជើងគុល ឬសសរគោលខ្លះ ឲ្យធ្វើនូវបលាលបីឋកកម្ម គឺអំពើដែលគេធ្វើឲ្យដូចជាកណ្តាប់ចំបើងខ្លះ ឲ្យស្រោចប្រេងដែលក្តៅខ្លះ ឲ្យឆ្កែខាំខ្លះ ឲ្យដេកផ្ងារលើឈើអណ្តោតទាំងរស់ខ្លះ ឲ្យកាត់ក្បាលដោយដាវខ្លះ ដូច្នេះដែរ ឬទេ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្តីឡើង រហូតដល់ចាស់ តើមានគំនិតថា បានឮថា អ្នកណា ធ្វើនូវបាបកម្មទាំងឡាយ អ្នកនោះ គេនឹងធ្វើកម្មករណ៍ផ្សេងៗយ៉ាងនេះវិញ ក្នុងបច្ចុប្បន្ននេះឯង នឹងបាច់និយាយថ្វីក្នុងបរលោក បើដូច្នោះគួរតែអាត្មាអញធ្វើអំពើល្អដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬទេ ។ បុរសនោះ ក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច ( នឹងគិតឃើញ ) ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជ ក៏ត្រាស់ពន្យល់បុរសនោះ យ៉ាងនេះថា នែបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯងមិនធ្វើអំពើល្អដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯង មានសេចក្តីប្រមាទ យ៉ាងណា ពួកនិរយបាលនឹងធ្វើ ( អ្នកឯង ) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកឯងនុ៎ះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យ

ទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាទាំងឡាយធ្វើឲ្យទេ បាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាក នៃបាបកម្មនោះវិញ ។

[ ១៧៩ ] ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជសាកសួរ ដេញដោលសួរឈ្ងេចឈ្ងី នូវទេវទូតទី ៤ នឹងបុរសនោះរួចហើយ ទើបសាកសួរ ដេញដោល សួរឈ្ងេចឈ្ងី នូវទេវទូតទី ៥ ទៀតថា នែបុរស អ្នកឯងមិនបានឃើញនូវទេវទូតទី ៥ ដែលកើតប្រាកដក្នុងមនុស្សលោកទេឬ ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គ មិនបានឃើញទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រឡប់សួរបុរសនោះ យ៉ាងនេះវិញថា នែបុរស អ្នកឯងមិនបានឃើញស្ត្រី ឬបុរសដែលស្លាប់អស់មួយថ្ងៃ ឬស្លាប់អស់ពីរថ្ងៃ ឬក៏ស្លាប់អស់បីថ្ងៃ កំពុងហើមប៉ោង មានសម្បុរខៀវដោយច្រើន មានខ្ទុះហូរចេញតាមទ្វារផ្សេងៗ ទេឬ ។ បុរសនោះក្រាបទូល យ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានឃើញ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជសួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស កាលអ្នកឯងនោះ ដឹងក្តីឡើងរហូតដល់ចាស់ តើមានគំនិតថា អាត្មាអញឯង មានសេចក្តីស្លាប់ ជាធម្មតា មិនកន្លងសេចក្តីស្លាប់ទៅបានឡើយ បើដូច្នោះ គួរតែអាត្មាអញ ធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត ដូច្នេះដែរឬទេ ។ បុរសនោះក្រាបទូលយ៉ាងនេះថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គមិនអាច ( នឹង

គិតឃើញ ) ទេ សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គជាមនុស្សប្រមាទ ។ ម្នាលភិក្ខុទាំងឡាយ ព្រះយមរាជត្រាស់ពន្យល់បុរសនោះ យ៉ាងនេះថា នែបុរស ព្រោះតែសេចក្តីប្រមាទ បានជាអ្នកឯងមិនធ្វើអំពើល្អ ដោយកាយ ដោយវាចា ដោយចិត្ត អើបុរស បើអ្នកឯង មានសេចក្តីប្រមាទ យ៉ាងណា ពួកនិរយបាលនឹងធ្វើ ( អ្នកឯង ) យ៉ាងនោះវិញ ដ្បិតបាបកម្មរបស់អ្នកឯងនោះ មិនមែនមាតាធ្វើឲ្យទេ មិនមែនបិតាធ្វើឲ្យទេ មិនមែនបងប្អូនប្រុសធ្វើឲ្យទេ មិនមែនបងប្អូនស្រីធ្វើឲ្យទេ មិនមែនពួកមិត្តអាមាត្យធ្វើឲ្យទេ មិនមែនពួកញាតិសាលោហិតធ្វើឲ្យទេ មិនមែនពួកសមណព្រាហ្មណ៍ធ្វើឲ្យទេ មិនមែនទេវតាទាំងឡាយធ្វើឲ្យទេ បាបកម្មនុ៎ះ គឺអ្នកឯងធ្វើខ្លួនឯង អ្នកឯងនឹងត្រូវទទួលវិបាកនៃបាបកម្មនោះវិញ ។ ម្នាលភិក្ខុទាំងឡាយ លុះព្រះយមរាជបានសាកសួរ ដេញដោល សួរឈ្លេចឈ្លី នូវទេវទូតទី ៥ នឹងបុរសនោះរួចហើយ ក៏ទ្រង់នៅស្ងៀម ។

[ ១៨០ ] ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ធ្វើនូវកម្មករណ៍ឈ្មោះបញ្ចពិធពន្ធន៍ ( ចំណងប្រាំប្រការ ) ចំពោះបុរសនោះ គឺផ្តេក ( បុរសនោះ ) ហើយបោះដែកគោលដ៏ក្តៅត្រង់ដៃ ( ខាងស្តាំ ) ១ បោះដែកគោលដ៏ក្តៅ ត្រង់ដៃខាងឆ្វេង ១ បោះដែកគោលដ៏ក្តៅ ត្រង់ជើង ( ខាងស្តាំ ) ១ បោះដែកគោលដ៏ក្តៅត្រង់ជើងខាងឆ្វេង ១ បោះដែកគោលដ៏ក្តៅចំកណ្តាលទ្រូង ១ ។ បុរសនោះ ក៏រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សា ក្នុងទីនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

[ ១៨១ ] ម្នាលភិក្ខុទាំងឡាយ លុះពួកនិរយបាល ចាប់ផ្តួកបុរសនោះរួចហើយ ទើបចាំងដោយដឹង ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុរសនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ហើយប្រាសដោយកាំបិតព្រា ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ទឹមបុរសនោះនឹងរថ ហើយបរទៅបរមក លើប្រឹថពីដែលភ្លើងកំពុងឆេះក្តៅសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ប្រើបុរសនោះឲ្យឡើងភ្នំ ឲ្យចុះអំពីភ្នំរងើកភ្លើងដ៏ធំ ដែលកំពុងក្តៅសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ចាប់បុរសនោះ យកជើងឡើងលើ យកក្បាលចុះក្រោម ហើយទម្លាក់ទៅក្នុងខ្ទះទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះក្តៅសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ។ បុរសនោះ ក៏ឆេះនឹងកម្ពុលពពុះ ក្នុងខ្ទះទង់ដែងនោះ ។ កាលបុរសនោះ ឆេះនឹងកម្ពុលពពុះ ក្នុងខ្ទះទង់ដែងនោះ ចួនកាលអណ្តែតឡើងលើម្តង ចួនកាលលិចចុះក្រោមម្តង ចួនកាលអណ្តែតទៅទទឹងម្តង ។ បុរសនោះរងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងខ្ទះទង់ដែងនោះ បើបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

[ ១៨២ ] ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ក៏បោះបុរសនោះ ទៅក្នុងមហានរក ។ ម្នាលភិក្ខុទាំងឡាយ មហានរកនោះសោត

មានជ្រុងបួន មានទ្វារបួន បែងចែកដោយចំណែកៗ
មានរបងដែកព័ទ្ធជុំវិញ គ្របដោយគម្របដែក ។ ផ្ទៃ
ផែនដីខាងក្រោមនៃមហានរកនោះ សុទ្ធតែដែក មាន

ភ្លើងឆេះប្រាលរន្ទាល ផ្សាយទៅបានមួយរយយោជន៍
ជុំវិញ តាំងនៅសព្វៗកាល ។

ម្នាលភិក្ខុទាំងឡាយ មហានរកនោះឯង មានអណ្តាតភ្លើងឆេះឡើងអំពីជញ្ជាំងខាងកើត ធាបដល់ជញ្ជាំងខាងលិច ។ អណ្តាតភ្លើង ឆេះឡើងអំពីជញ្ជាំងខាងលិច ធាបដល់ជញ្ជាំងខាងកើត ។ អណ្តាតភ្លើង ឆេះឡើងអំពីជញ្ជាំងខាងជើង ធាបដល់ជញ្ជាំងខាងត្បូង ។ អណ្តាតភ្លើង ឆេះឡើងអំពីជញ្ជាំងខាងត្បូង ធាបដល់ជញ្ជាំងខាងជើង ។ អណ្តាតភ្លើង ឆេះឡើងអំពីខាងក្រោម ធាបដល់ខាងលើ អណ្តាតភ្លើងឆេះឡើងអំពីខាងលើ ធាបដល់ខាងក្រោម ។ បុរសនោះ ក៏រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងមហានរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

[ ១៨៣ ] ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលវែងឆ្ងាយទៅម្តងៗ មានសម័យដែលពួកនិរយបាល បើកទ្វារខាងកើតនៃមហានរកនោះ ។ បុរសនោះក៏ស្ទុះដ៏រហ័សទៅត្រង់ទ្វារនោះ ។ កាលដែលបុរសនោះ ស្ទុះទៅ ដោយសម្ទុះដ៏រហ័ស ភ្លើងក៏ឆេះស្បែកក្រៅផង ឆេះស្បែកក្នុងផង ឆេះសាច់ផង ឆេះសរសៃផង ឆេះឆ្អឹងផង ហុយផ្សែងទ្រលោមឡើង កាលលើកជើងឡើងរត់ទៅ ភ្លើងក៏នៅតែឆេះដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបុរសនោះតាំងនៅ ( ក្នុងទីនោះ ) ជាច្រើនឆ្នាំ ទ្វារនោះក៏និរយបាលបិទទៅវិញ ។ បុរសនោះរងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងមហានរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

[ ១៨៤ ] ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលវែងឆ្ងាយទៅម្តងៗ មានសម័យដែលពួកនិរយបាល បើកទ្វារខាងលិចនៃអវីចិមហានរកនោះ ។បេ។ បើកទ្វារខាងជើង ។បេ។ បើកទ្វារខាងត្បូង ។ បុរសនោះ ក៏ស្ទុះដោយសម្ទុះដ៏រហ័ស ទៅត្រង់ទ្វារនោះ ។ កាលបុរសស្ទុះទៅដោយសម្ទុះដ៏រហ័ស ភ្លើងក៏ឆេះស្បែកក្រៅផង ឆេះស្បែកក្នុងផង ឆេះសាច់ផង ឆេះសរសៃផង ឆេះឆ្អឹងផង ហុយផ្សែងទ្រលោមឡើង កាលលើកជើងឡើងរត់ទៅ ភ្លើងក៏នៅតែឆេះប្រាកដដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាលបុរសនោះតាំងនៅ ( ក្នុងទីនោះ ) ជាច្រើនឆ្នាំ ទ្វារនោះក៏និរយបាលបិទទៅវិញ ។ បុរសនោះរងទុក្ខវេទនាក្លាខ្លាំង ខ្លោចផ្សាក្នុងមហានរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

[ ១៨៥ ] ម្នាលភិក្ខុទាំងឡាយ លុះកន្លងកាលវែងឆ្ងាយទៅម្តងៗ មានសម័យដែលពួកនិរយបាល បើកទ្វារខាងកើតនៃមហានរកនោះ ។ បុរសនោះក៏ស្ទុះទៅដោយសម្ទុះដ៏រហ័ស ទៅត្រង់ទ្វារនោះ ។ កាលបុរសនោះស្ទុះដោយសម្ទុះដ៏រហ័ស ភ្លើងក៏ឆេះស្បែកក្រៅផង ឆេះស្បែកក្នុងផង ឆេះសាច់ផង ឆេះសរសៃផង ឆេះឆ្អឹងផង ហុយផ្សែងទ្រលោមឡើង កាលលើកជើងឡើងរត់ទៅ ភ្លើងក៏នៅតែឆេះប្រាកដដូច្នោះឯង ។ បុរសនោះ ក៏ស្ទុះចេញទៅតាមទ្វារនោះ ។ ម្នាលភិក្ខុទាំងឡាយ មានគូថនរកដ៏ធំ តាំងនៅបន្ទាប់គ្នានឹងមហានរកនោះឯង ។ បុរសនោះ ធ្លាក់ទៅក្នុងគូថនរកនោះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងគូថនរកនោះសោត មានសត្វទាំងឡាយមាត់ស្រួចដូចម្ជុល កកេរស្បែកក្រៅ

លុះកកេរស្បែកក្រៅហើយ កកេរស្បែកក្នុង លុះកកេរស្បែកក្នុងហើយ កកេរសាច់ លុះកកេរសាច់ហើយ កកេរសរសៃ លុះកកេរសរសៃហើយ កកេរឆ្អឹង លុះកកេរឆ្អឹងហើយ ទើបខាំស៊ីខួរក្នុងឆ្អឹង ។ បុរសនោះ រងទុក្ខវេទនាក្លាខ្លាំង ខ្លោចផ្សាក្នុងគូថនរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

[ ១៨៦ ] ម្នាលភិក្ខុទាំងឡាយ មានកុក្កុលនរកដ៏ធំ តាំងនៅបន្ទាប់គ្នានឹងគូថនរកនោះឯង ។ បុរសនោះ ធ្លាក់ទៅក្នុងកុក្កុលនរកនោះ ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងកុក្កុលនរកនោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

[ ១៨៧ ] ម្នាលភិក្ខុទាំងឡាយ មានព្រៃរកាដ៏ធំ ខ្ពស់ត្រដួចឡើងមួយយោជន៍ មានបន្លា ១៦ ធ្នាប់ ភ្លើងឆេះក្តៅសព្វ ភ្លឺប្រាលឡោល សន្ធោសន្ធៅ តាំងនៅបន្ទាប់គ្នានឹងកុក្កុលនរកនោះឯង ។ ពួកនិរយបាល ក៏ប្រើបុរសនោះឲ្យឡើងឲ្យចុះអំពីព្រៃរកានោះ ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាលើដើមរកានោះ បើបាបកម្មមិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

[ ១៨៨ ] ម្នាលភិក្ខុទាំងឡាយ មានព្រៃស្លោសសិតធំ តាំងនៅបន្ទាប់គ្នានឹងព្រៃរកានោះឯង ។ បុរសនោះ ចូលទៅក្នុងព្រៃស្លោសសិតនោះ ។ ខ្យល់បក់ស្លឹកសសិតនោះ មកកាត់ដៃ កាត់ជើង កាត់ទាំងដៃទាំងជើង កាត់ស្លឹកត្រចៀក កាត់ច្រមុះ កាត់ទាំងស្លឹកត្រចៀកទាំងច្រមុះ ( របស់បុរសនោះ ) ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សា នៅក្នុងព្រៃសសិតនោះ បើបាប-

កម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

[ ១៨៩ ] ម្នាលភិក្ខុទាំងឡាយ មានស្ទឹងទឹកផ្សាដ៏ធំ តាំងនៅបន្ទាប់គ្នានឹងព្រៃសសិតនោះឯង ។ បុរសនោះ ក៏ធ្លាក់ទៅក្នុងស្ទឹងនោះ ។ បុរសនោះ ជួនកាលអណ្តែតបណ្តោយខ្សែទឹក ជួនកាលអណ្តែតច្រាសខ្សែទឹក ជួនកាលអណ្តែតទាំងបណ្តោយខ្សែទឹកទាំងច្រាសខ្សែទឹក ក្នុងស្ទឹងនោះ ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងស្ទឹងនោះ បើបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

[ ១៩០ ] ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល យកសន្ទូចស្ទូចបុរសនោះវិធឡើង ដាក់មកលើគោក ហើយសួរយ៉ាងនេះថា នែបុរស អ្នកឯងប្រាថ្នាអ្វី ។ បុរសនោះឆ្លើយយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំឃ្លានបាយ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល ក៏យកកន្សែវដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ មកបើកមាត់បុរសនោះ ហើយញាត់នូវដុំទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ទៅក្នុងមាត់ ។ ដុំទង់ដែងនោះ ក៏ឆេះបបូរមាត់ ឆេះមាត់ ឆេះបំពង់ក ឆេះពោះនាំយកទាំងពោះវៀនធំ ទាំងពោះវៀនតូច របស់បុរសនោះ ចេញមកខាងក្រោម ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងនរកនោះ បើបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។

[ ១៩១ ] ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល សួរបុរសនោះ យ៉ាងនេះទៀតថា នែបុរស អ្នកឯងប្រាថ្នាអ្វី ។ បុរសនោះឆ្លើយយ៉ាងនេះថា បពិត្រ

លោកដ៏ចម្រើន ខ្ញុំស្រេកទឹក ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល យកកន្ទ្រវដែកដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ មកបើកមាត់បុរសនោះ ហើយបង្អកទឹកទង់ដែងដ៏ក្តៅ ដែលភ្លើងកំពុងឆេះសព្វ ភ្លឺប្រាលរន្ទាល សន្ធោសន្ធៅ ទៅក្នុងមាត់ ។ ទឹកទង់ដែងនោះ ក៏ឆេះបបូរមាត់ ឆេះមាត់ ឆេះបំពង់ក ឆេះពោះ នាំយកទាំងពោះវៀនធំ ទាំងពោះវៀនតូច របស់បុរសនោះចេញ មកខាងក្រោម ។ បុរសនោះ រងទុក្ខវេទនា ក្លាខ្លាំង ខ្លោចផ្សាក្នុងនរកនោះ បើបាបកម្មនោះ មិនទាន់អស់ត្រឹមណា ក៏មិនទាន់ស្លាប់ត្រឹមនោះ ។ ម្នាលភិក្ខុទាំងឡាយ ពួកនិរយបាល បោះទម្លាក់បុរសនោះទៅក្នុងមហានរកវិញ ។

[ ១៩២ ] ម្នាលភិក្ខុទាំងឡាយ រឿងរ៉ាវធ្លាប់មានមកហើយថា ព្រះយមរាជ មានសេចក្តីត្រិះរិះដូច្នេះថា បានឮថា សត្វទាំងឡាយណា ធ្វើបាបកម្មក្នុងលោក សត្វនោះឯង រមែងត្រូវគេធ្វើកម្មករណ៍ផ្សេងៗ មានសភាពយ៉ាងនេះ ឱហ្ន៎ អាត្មាអញសូមឲ្យបានអត្តភាពជាមនុស្ស ឲ្យទាន់ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ត្រាស់ឡើងក្នុងលោក សូមឲ្យអាត្មាអញ ចូលទៅអង្គុយជិតព្រះមានព្រះភាគអង្គនោះ បើព្រះមានព្រះភាគអង្គនោះ ទ្រង់សំដែងធម៌ប្រោសអាត្មាអញ សូមឲ្យអាត្មាអញយល់ច្បាស់ នូវធម៌របស់ព្រះមានព្រះភាគអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ឯតថាគតមិនមែនបានស្តាប់រឿងនោះឯង អំពីសមណៈ ឬព្រាហ្មណ៍ដទៃណាមួយ ហើយ ( នាំមក ) សំដែងទេ តាមដែលពិតនោះ តថាគតសំដែងរឿងដែលតថាគតដឹងខ្លួនឯង ឃើញខ្លួនឯង យល់

ខ្លួនឯង តែមួយយ៉ាង ។

[ ១៩៣ ] លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះ ចប់ហើយ លុះព្រះសុគត ទ្រង់ត្រាស់ព្រះសូត្រនេះ ចប់ហើយ ទើបព្រះសាស្តា ទ្រង់ត្រាស់និពន្ធគាថានេះតទៅថា

មាណពទាំងឡាយណា ដែលយមរាជ ដាស់តឿន
ដោយទេវទូតទាំងឡាយហើយ ក៏នៅតែប្រមាទ មាណព
ទាំងនោះឯង ជាអ្នកបាននូវកាយ ដ៏ថោកទាប រមែង
សោកសៅ អស់កាលយូរអង្វែង ចំណែកមាណព
ណាក្នុងលោកនេះ ជាសប្បុរស មានសន្តានស្ងប់រម្ងាប់
ដែលយមរាជ ដាស់តឿន ដោយទេវទូតទាំងឡាយ
ហើយ តែងមិនប្រមាទក្នុងអរិយធម៌ ក្នុងកាលណា
ឡើយ រមែងឃើញនូវភ័យក្នុងឧបាទាន ជាហេតុកើត
ឡើងនៃជាតិ និងមរណៈ តែងចុះចិត្តស៊ប់ក្នុងព្រះនិព្វាន
ជាធម្មជាតអស់ទៅនៃជាតិ និងមរណៈ ព្រោះមិនប្រកាន់
មាំ មាណពនោះឯង ជាអ្នកដល់នូវទីដ៏ក្សេម មាន
សេចក្តីសុខ រលត់កិលេសក្នុងបច្ចុប្បន្ន ជាអ្នកកន្លងផុត
នូវពៀរ និងភ័យទាំងពួង បានធ្លងផុតនូវទុក្ខទាំងពួង ។

ទេវទូតសូត្រទី ១០ ចប់

សុញ្ញតវគ្គទី ៣ ចប់

## បញ្ជីឈ្មោះសូត្រ នៃសុញ្ញតវគ្គនោះ គឺ

ចូឡសុញ្ញតសូត្រ មហាសុញ្ញតសូត្រ អច្ឆរិយព្ភូត-
ធម្ម សូត្រដ៏ប្រសើរ ពក្កុលត្ថេរច្ឆរិយព្ភូតធម្មសូត្រ
ទន្តភូមិសូត្រ ភូមិជសូត្រ អនុរុទ្ធសូត្រ ឧប-
ក្កិលេសសូត្រ ពាលបណ្ឌិតសូត្រ ទេវទូតសូត្រ ។

# អដ្ឋកថា

## ទេវទូតសូត្រ

[ ១៧២ ] ទេវទូតសូត្រ មានពាក្យផ្ដើមថា **ឯវមេ្មសុតំ** ដូច្នេះជាដើម ។

[ ១៧៣-១៧៤ ] ក្នុងបទទាំងនោះ បទថា **ទ្វេ អគារា** ជាដើម ឲ្យពិស្ដារហើយក្នុងអស្សបុរសូត្រ ។ បទថា **និរយំ ឧបបន្នា** សេចក្ដីថា ក្នុងគ្រាខ្លះ ព្រះមានព្រះភាគ ទ្រង់ញុំាងទេសនាតាំងអំពីនរក បញ្ចប់ដោយទេវលោក ។ ជួនកាល ផ្ដើមអំពីទេវលោក បញ្ចប់ដោយនរក ។ បើព្រះអង្គត្រាស់សគ្គសម្បត្តិឲ្យពិស្ដារ ត្រាស់ដល់ទុក្ខក្នុងនរក ដោយឯកទេស ទុក្ខក្នុងកំណើតសត្វតិរច្ឆាន ទុក្ខក្នុងបេតវិស័យ ត្រាស់ដល់សម្បត្តិក្នុងមនុស្សលោកដោយឯកទេស ។ បើព្រះអង្គត្រាស់សេចក្ដីទុក្ខក្នុងនរកឲ្យពិស្ដារ រមែងត្រាស់ដល់សម្បត្តិក្នុងទេវលោក មនុស្សលោក និងទុក្ខក្នុងកំណើតតិរច្ឆាន និងបិត្តិវិស័យ ដោយឯកទេស ឈ្មោះថា ញុំាងទុក្ខក្នុងនរកឲ្យពិស្ដារក្នុងព្រះសូត្រនេះ ព្រះអង្គទ្រង់ញុំាងទុក្ខក្នុងនរកឲ្យពិស្ដារ ព្រោះដូច្នោះ ទ្រង់ញុំាងឯកទេសតាំងអំពីទេវលោក ឲ្យចប់ដោយនរក ដើម្បីត្រាស់ដល់សម្បត្តិក្នុងទេវលោក មនុស្សលោក និងទុក្ខក្នុងកំណើតតិរច្ឆាន និងក្នុងបិត្តិវិស័យដោយឯកទេស ហើយត្រាស់ដល់ទុក្ខក្នុងនរកដោយពិស្ដារ ទើបត្រាស់ពាក្យថា **តមេនំ ភិក្ខវេ និរយបាលា** ជាដើម ។ ក្នុងបទនោះ ព្រះថេរៈពួកខ្លះពោលថា នាយនិរយបាលមិនមាន កម្មប៉ុណ្ណោះរមែងញុំាងហេតុប្រៀបដូចមនុស្សយន្ត ។ កម្មនោះត្រូវបដិសេធក្នុងអភិធម្ម ដោយន័យជាដើមថា អើ

នាយនិរយបាលក្នុងនរកមានហើយ ជាអ្នកញុំាងហេតុក៏មាន ។ ប្រៀបដូច ក្នុងមនុស្សលោក មានអ្នកដាក់ទោសដោយកម្មករណ៍ យ៉ាងណា នាយនិរយបាលក៏មានក្នុងនរក ដូច្នោះ ។

បទថា **យមស្ស រញ្ញោ** បានដល់ ព្រះរាជាវេមានិកប្រេត ឈ្មោះថា ស្តេចយម ក្នុងវេលាខ្លះ មានដើមកប្បព្រឹក្ស ឧទ្យានទិព្វ អ្នករបាំទិព្វ សម្បត្តិទិព្វ ក្នុងវិមានទិព្វ ជួនកាល ជាព្រះរាជាទ្រទ្រង់ធម៌ សោយផលកម្ម តែមិនមែនខណៈតែមួយ ។ ត្រង់ទ្វារទាំង ៤ មានសិរីគុត្តមាត្យ ៤ នាក់ ។

[ ១៧៥-១៧៦ ] បទថា **ឆាទូសំ** សេចក្តីថា លោកសំដៅយកទេវទូតជាមនុស្សណាម្នាក់ ដែលត្រូវបញ្ជូនទៅក្នុងសម្នាក់របស់ខ្លួន ទើបពោលយ៉ាងនេះ ។ គ្រានោះ ស្តេចយមដឹងថា បុគ្គលនេះ មិនកំណត់អត្ថនៃភាសិត បំណងនឹងឲ្យសត្វនោះកំណត់ ទើបពោលពាក្យថា **អម្ភោ** ។ បទថា **ជាតិ-ធម្មោ** គឺមានការកើតជាធម្មតា មិនផុតអំពីការកើតទៅបានឡើយ ឈ្មោះថា ជាតិ រមែងប្រព្រឹត្តទៅក្នុងខាងក្នុងនៃយើង ។ ក្នុងបទថា **ជរាធម្មោ** ជាដើម ក៏មានន័យដូច្នេះដូចគ្នា ។ ក្នុងបទថា **បឋមំ ទេវទូតំ សមនុយុញ្ជិត្វា** សេចក្តីថា ទារក រមែងពោលយ៉ាងនេះ ដោយអត្ថថា អ្នកដ៏ចម្រើន ចូរមើលខ្ញុំ សូម្បីខ្ញុំក៏មានដៃ និងជើងដូចពួកអ្នក តែខ្ញុំបម្រះនទៀលក្នុងមូត្រលាមករបស់ខ្លួន មិនអាចក្រោកឡើង ងូតទឹកតាមធម្មតារបស់ខ្លួនបានទេ ខ្ញុំជាមនុស្សមានកាយស្មោកគ្រោកហើយ មិនអាចប្រាប់ថា ងូតទឹកឲ្យខ្ញុំ ខ្ញុំឈ្មោះថា មានសភាពដូច្នេះ ព្រោះមិនផុតចាកការកើត តែមិនមែនតែខ្ញុំទេ សូម្បី

អ្នកទាំងឡាយ ក៏មិនផុតពីការកើត ការកើតនឹងមកដល់អ្នកទាំងឡាយដូចខ្ញុំដែរ អ្នកទាំងឡាយចូរធ្វើសេចក្ដីល្អមុនការកើតនោះ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះឯង កូនង៉ែតនោះ ឈ្មោះថា ទេវទូត ។ តែអត្ថនៃពាក្យលោកបានពោលហើយ ក្នុងមយទេវសូត្រ ។

ក្នុងបទថា **ទុតិយំ ទេវទូតំ** នេះ សេចក្ដីថា មនុស្សចាស់ ឈ្មោះថាពោលយ៉ាងនេះ ដោយសេចក្ដីថា អ្នកដ៏ចម្រើន ពួកអ្នកចូរមើល ខ្ញុំធ្លាប់ជាកំលោះ បរិបូណ៌ដោយកម្លាំងស្មង កម្លាំងដើមដៃ និងរហ័សរហួន ដូចអ្នកដែរ ការដល់ព្រមដោយកម្លាំង និងការរហ័សរហួនទាំងនោះ របស់ខ្ញុំអស់ទៅហើយ សូម្បីដៃ និងជើងរបស់ខ្ញុំមាន ក៏ធ្វើកិច្ចដោយដៃ និងជើងមិនបាន ខ្ញុំឈ្មោះថា មានសភាពដូច្នេះ ព្រោះមិនផុតអំពីជរា តែមិនមែនតែខ្ញុំប៉ុណ្ណោះទេ សូម្បីអ្នកទាំងឡាយ ក៏មិនផុតអំពីជរា ជរានឹងមកដល់អ្នកទាំងឡាយ ដូចតែខ្ញុំដែរ អ្នកទាំងឡាយ ចូរធ្វើសេចក្ដីល្អឲ្យហើយ មុនពេលជរាមកដល់ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះឯង មនុស្សចាស់នោះ ឈ្មោះថា ជាទេវទូត ។

[ ១៧៧ ] ក្នុងបទថា **តតិយំ ទេវទូតំ** សេចក្ដីថា សត្វដែលមានជំងឺតម្កាត់ ហាក់ដូចជាពោលយ៉ាងនេះ ដោយសេចក្ដីថា អ្នកដ៏ចម្រើន ពួកអ្នកចូរមើល ពីមុន ខ្ញុំក៏ជាអ្នកមិនមានរោគដូចអ្នកដែរ តែខ្ញុំឥឡូវនេះ ត្រូវព្យាធិគ្របសង្កត់ ដេកនៅក្នុងមូត្រ និងលាមករបស់ខ្លួន មិនអាចដើម្បីនឹងក្រោកឡើង ទោះបីដៃ និងជើងរបស់ខ្ញុំមាន ក៏ធ្វើកិច្ចដោយដៃ និងជើងមិនបាន ខ្ញុំមានសភាពដូច្នេះ ព្រោះមិនផុតអំពីព្យាធិ តែមិនមែនតែខ្ញុំប៉ុណ្ណោះទេ សូម្បី

អ្នកទាំងឡាយ ក៏មិនផុតចាកព្យាធិ ព្យាធិនឹងមកដល់អ្នកទាំងឡាយដូចខ្ញុំដែរ អ្នកទាំងឡាយ ចូរធ្វើសេចក្តីល្អទុកឲ្យហើយ មុនព្យាធិមកដល់ ដោយប្រការដូច្នេះ ។ ព្រោះហេតុនោះ សត្វដែលមានជំងឺនោះ ឈ្មោះថា ទេវទូត ។

[ ១៧៨ ] ក្នុងបទថា **ចតុត្ថំ ទេវទូតំ** នេះ កម្មករណ៍ ឬអ្នកត្រូវដាក់ទោស ឈ្មោះថា ទេវទូត ។ ក្នុង ២ បទនោះ ក្នុងចំណែកកម្មករណ៍ កម្មករណ៍ ៣២ ជាបឋម រមែងពោលយ៉ាងនេះ ដោយអត្ថថា ពួកខ្ញុំកាលកើត មិនកើតត្រង់ដើមឈើ ឬដុំថ្ម រមែងកើតក្នុងសរីរៈរបស់មនុស្សដូចអ្នកដែរ ដោយប្រការដូច្នេះ ពួកអ្នកចូរធ្វើសេចក្តីល្អ មុនយើងកើត ព្រោះហេតុនោះ ទើបកម្មករណ៍ទាំងនោះ ឈ្មោះថា ទេវទូត ។ សូម្បីអ្នកធ្វើទារុណកម្ម ក៏ហាក់ដូចជាពោលយ៉ាងនេះ ដោយអត្ថថា ពួកខ្ញុំដាក់កម្មករណ៍ ៣២ យ៉ាង មិនមែនដាក់ត្រង់ដើមឈើជាដើមឡើយ រមែងដាក់ក្នុងសត្វដូចជាពួកអ្នកនោះឯង ដោយប្រការដូច្នេះ ពួកអ្នកធ្វើសេចក្តីល្អ មុនដែលខ្ញុំដាក់ទោស ព្រោះហេតុនោះ អ្នកទោសទាំងនោះ ឈ្មោះថា ទេវទូត ។

[ ១៧៩ ] បទថា **បញ្ចមំ ទេវទូតំ** នេះ សេចក្តីថា សត្វដែលស្លាប់ហើយ រមែងពោលយ៉ាងនេះ ដោយអត្ថថា អ្នកដ៏ចម្រើន ពួកអ្នកចូរមើលខ្ញុំដែលគេបោះបោលក្នុងព្រៃខ្មោច ដល់នូវភាពជាអ្នកហើមប៉ោងជាដើម ខ្ញុំមានសភាពដូច្នេះ ព្រោះមិនផុតអំពីការស្លាប់ តែមិនមែនតែខ្ញុំប៉ុណ្ណោះទេ សូម្បីពួកអ្នក ក៏មិនផុតអំពីសេចក្តីស្លាប់ដូចគ្នា ការស្លាប់នឹងមកដល់អ្នកទាំងឡាយដូចតែខ្ញុំដែរ ពួកអ្នកចូរធ្វើសេចក្តីល្អ មុនសេចក្តីស្លាប់នោះមកដល់ ព្រោះ

ដូច្នោះ សត្វដែលស្លាប់នោះ ឈ្មោះថា ទេវទូត ។

សួរថា បុគ្គលណាបានប្រយោជន៍ក្នុងទេវទូតនេះ បុគ្គលណាមិនបាន ។ ឆ្លើយថា បុគ្គលណាធ្វើបាបកម្មច្រើន បុគ្គលនោះទៅកើតក្នុងនរក ។ បុគ្គលណាធ្វើបាបកម្មតិចតួច បុគ្គលនោះ រមែងបាន ។ ជនទាំងឡាយចាប់ចោរមួយអន្ទើដោយកណ្ឌៈ រមែងធ្វើវត្ថុដែលគួរធ្វើ មិនវិនិច្ឆ័យ តែនាំចោរដែលត្រូវសាកសួរ ចាប់ទៅកាន់សាលា គេបានកាត់ក្តី យ៉ាងណា ការប្រៀបធៀបក៏ដូច្នោះ ។ បុគ្គលមានបាបកម្មតិចតួច រមែងរឭកបានតាមធម្មតារបស់ខ្លួន សូម្បីត្រូវគេឲ្យរឭក ក៏រឭកបាន ។ ក្នុងសេចក្តីនោះ មានទមិឡឈ្មោះទីឃទន្ត រឭកបានតាមធម្មតារបស់ខ្លួន ។ បានឮថា ទមិឡនោះយកសំពត់ពណ៌ក្រហម បូជាអាកាសចេតិយក្នុងសុមនគិរីវិហារ ។ គ្រានោះ បុរសនោះកើតក្បែរឧស្សទនរក បានឮសំឡេងអណ្តាតភ្លើង រឭកដល់សំពត់ដែលខ្លួនបូជា ទើបគាត់ចូលទៅកើតក្នុងស្ថានសួគ៌ ។ ជនម្នាក់ទៀត ប្រគេនសំពត់សាច់រឹងដល់ភិក្ខុកំលោះដែលជាកូន ត្រង់ទៀបព្រះបាទ ក្នុងវេលាជិតស្លាប់កាន់យកនិមិត្តក្នុងសំឡេងថា បដៈ បដៈ គាត់កើតក្បែរឧស្សទនរក ក៏រឭកដល់សំពត់នោះ ព្រោះសំឡេងអណ្តាតភ្លើង ទើបទៅកើតក្នុងស្ថានសួគ៌ ។ គាត់រឭកដល់កុសលកម្មតាមធម្មតារបស់ខ្លួនយ៉ាងនេះ ទើបកើតក្នុងស្ថានសួគ៌ តែបើរឭកតាមធម្មតារបស់ខ្លួនមិនបាន ទើបសួរទេវទូតទាំង ៥ ក្នុងទេវទូតទាំង ៥ នោះ បុគ្គលខ្លះរឭកបានដោយទេវទូតទី ១ បុគ្គលខ្លះរឭកបានដោយទេវទូតទី ២ ជាដើម ។ ឯបុគ្គលណារឭកមិនបានក្នុងទេវទូតទាំង ៥ ស្តេច

យមឲ្យបុគ្គលនោះ ពេ្រកបានឯង ។ បានឮអមាត្យម្នាក់ បូជាមហាចេតិយដោយក្អមផ្កាម្ទិះ បានឲ្យចំណែកបុណ្យដល់ស្តេចយម ។ និរយបាលនាំអមាត្យដែលកើតក្នុងនរកនោះ ព្រោះអកុសលកម្មទៅឲ្យស្តេចយម ។ កាលអមាត្យនោះពេ្រកមិនបានដោយទេវទូតទាំង ៥ ស្តេចយមពិចារណាឯង ឃើញហើយឲ្យពេ្រកថា អ្នកបូជាមហាចេតិយដោយក្អមផ្កាម្ទិះ ហើយឧទ្ទិសចំណែកបុណ្យឲ្យខ្ញុំមិនមែនឬ គាត់ពេ្រកបានក្នុងវេលានោះហើយ ទៅកាន់ទេវលោក តែបើស្តេចយមរំពឹងមើលឯង ក៏មិនឃើញ ត្រិះរិះថា ឱ សត្វនេះនឹងសោយទុក្ខធំទើបអង្គុយស្ងៀម ។

[ ១៨២ ] បទថា **មហានិរយេ** បានដល់ អវីចីមហានរក សួរថា អវីចីមហានរកនោះ ទំហំខាងក្នុងប៉ុនណា ឆ្លើយថា ផែនដីលោហៈ ដំបូលលោហៈដោយបណ្តោយ និងទទឹងប្រមាណ ៩ រយយោជន៍ ជញ្ជាំងម្ខាងៗ ប្រមាណ ៨១ យោជន៍ ។ អណ្តាតភ្លើងនោះតាំងឡើងក្នុងទិសខាងកើត បាញ់ទៅទល់នឹងជញ្ជាំងទិសខាងលិច ទម្លុះជញ្ជាំងនោះទៅខាងមុខ ១០០ យោជន៍ ។ សូម្បីក្នុងទិសខាងជើង ក៏ន័យនេះឯង ។ ដោយប្រការដូច្នេះ ដោយចំណែកបណ្តោយ និងចំណែកទទឹង ដោយទីបំផុតនៃអណ្តាតភ្លើង មានប្រមាណ ៣១៨ យោជន៍ តែដោយជុំវិញ មានប្រមាណ ៩៥៤ យោជន៍ ។ ចំណែកដោយជុំវិញមួយអន្លើដោយឧស្សទនរក ប្រមាណ ១ ម៉ឺនយោជន៍ ។

[ ១៨៣ ] ក្នុងបទថា **ឧព្ភតំ តាទិសមេវ ហោតិ** នេះ សេចក្តីថា មិនអាចនឹងលើកជើងដែលជាន់រហូតដល់ក្អឹងឲ្យមាំទាំបាន ។ ក្នុងបទនេះ មាន

អធិប្បាយដូច្នេះថា ត្រូវដុតឆេះទាំងខាងក្រោម ខាងលើ ។ ដោយប្រការដូច្នេះ ក្នុងវេលាជាន់ ប្រាកដត្រូវអណ្តាតភ្លើងដុតឆេះ ក្នុងវេលាលើកឡើងក៏ដូច្នោះ ។ ព្រោះដូច្នោះ ទើបលោកពោលយ៉ាងនេះ ។ បទថា **ពហុសម្បត្តោ** គឺដល់ទៅច្រើនសែនឆ្នាំ ។

សួរថា ព្រោះហេតុអ្វី ទើបនរកនេះឈ្មោះថា អវីចី ឆ្លើយថា ចន្លោះលោកហៅថា **វីចិ** ។ ក្នុងនរកនោះមិនមានចន្លោះនៃអណ្តាតភ្លើងរបស់សត្វ ឬរបស់ទុក្ខ ព្រោះដូច្នោះ ទើបនរកនោះឈ្មោះថា **អវីចិ** ។ អណ្តាតភ្លើងតាំងឡើង តាំងអំពីជញ្ជាំងទិសបូព៌ានៃនរកនោះ បាញ់ទៅ ១០០ យោជន៍ ទម្លុះជញ្ជាំងទៅ ខាងមុខ ១០០ យោជន៍ ។ សូម្បីក្នុងទិសដ៏សេស ក៏មានន័យនេះដូចគ្នា ។ ទេវទត្តកើតក្នុងកណ្តាលនៃអណ្តាតភ្លើងទាំង ៦ នេះ ។ ទេវទត្តមានអត្តភាពប្រមាណ ១០០ យោជន៍ ។ ជើងទាំង ២ ចូលទៅកាន់ផែនដីលោហៈ ស្មើកជើង ដៃទាំង ២ ចូលទៅកាន់ជញ្ជាំងលោហៈដល់កដៃ ក្បាលទល់នឹងដំបូលលោហៈ ដល់ត្រឹមចិញ្ចើម ។ លំពែងលោហៈមួយចូលទៅដោយចំណែកខាងក្រោម ទម្លុះកាយរហូតដល់ដំបូល ។ លំពែងចេញអំពីជញ្ជាំងទិសខាងកើត ទម្លុះបេះដូង ចូលទៅជញ្ជាំងទិសខាងលិច លំពែងចេញអំពីជញ្ជាំងទិសឧត្តរ ទម្លុះត្រឹមជំនីរ ទៅទល់ជញ្ជាំងទិសទក្សិណ ទេវទត្តមានសភាពដូច្នេះ ព្រោះកម្មដែលទេវទត្តធ្វើ ព្រោះខុសក្នុងព្រះតថាគតដែលជាតាទិបុគ្គល ។ ដោយប្រការដូច្នេះ នរកឈ្មោះថា **អវីចិ** ព្រោះអណ្តាតភ្លើងមិនឈប់ឈរ ។ ខាងក្នុងនរកនោះ ក្នុងទីប្រមាណ ១០០ យោជន៍

សត្វកកកុញគ្នា ដូចម្សៅដែលគេញាត់ក្នុងនាឡិ មិនគួរពោលថា ក្នុងទីនេះមានសត្វ ក្នុងទីនេះមិនមាន ។ សត្វដើរ ឈរ អង្គុយ និងដេកមិនមានទីបំផុត សត្វទាំងឡាយកាលដើរ ឈរ អង្គុយ ឬដេក រមែងមិនបៀតបៀនដល់គ្នានិងគ្នា ។ ឈ្មោះថា **អវីចិ** ព្រោះសត្វទាំងឡាយកកកុញគ្នាយ៉ាងនេះ ។ ឯក្នុងកាយទ្វារ ចិត្តសហគតៈដោយឧបេក្ខា ៦ ដួង រមែងកើតឡើង ១ ដួងសហគតៈដោយទុក្ខ ។ កាលបើយ៉ាងនេះ កាលបុគ្គលបន្តក់ទឹកឃ្មុំ ៦ តំណក់ត្រង់អណ្តាត ១ តំណក់ ដាក់ត្រង់នាឡិលោហៈ ព្រោះត្រូវជុតបំផ្លាញកម្លាំងតំណក់ទឹកនោះ រមែងប្រាកដ ក្រៅអំពីនេះ ជាអញ្ញោហារិក យ៉ាងណា ទុក្ខក្នុងនរកនេះមិនមានចន្លោះ ព្រោះមានការឆេះជាកម្លាំង ទុក្ខក្រៅអំពីនេះ ជាអញ្ញោហារិក ដូច្នោះ ។ ឈ្មោះថា **អវីចិ** ព្រោះពេញទៅដោយទុក្ខយ៉ាងនេះឯង ។

[ ១៨៥ ] បទថា **មហាន្តោ** គឺប្រមាណ ១០០ យោជន៍ ។ បទថា **សោ តត្ថ បតតិ** សេចក្តីថា ជើងម្ខាងនៅក្នុងមហានរក ។ ជើងម្ខាងធ្លាក់ទៅក្នុងគូថនរក ។ បទថា **សូចិមុខា** គឺមានមាត់ដូចម្ជុល ។ សត្វទាំងនោះ មានកប៉ុនដំរី និងប៉ុនទូកកម្រោល ១ ។

[ ១៨៦ ] បទថា **កុក្កុលនិរយោ** សេចក្តីថា នរកផេះក្តៅ ប្រាសចាកអណ្តាតភ្លើង ទំហំខាងក្នុងដូចផ្ទះកំពូលប្រមាណ ១០០ យោជន៍ ។ សត្វដែលធ្លាក់ទៅក្នុងនរកខាងក្រោម ដូចគ្រាប់ស្ពៃ ដូចគំនរគ្រាប់ស្ពៃដែលគេបោះទៅក្នុងរណ្តៅរងើកភ្លើង ។

[ ១៨៧ ] បទថា **អារោបេន្តិ** សេចក្តីថា យកដុំដែកស្ងួចលើកឡើង ។ ក្នុងវេលាលើកដុំដែកទាំងនោះឡើង បន្ទាដែកនៅខាងក្រោម វេលាលើកចុះ បន្ទាដែកនៅខាងលើ ។

[ ១៨៨ ] បទថា **វាតេរិតានិ** បានដល់ ត្រាច់ទៅដោយកម្ម ។ បទថា **ហត្ថម្បិ ឆិន្ទតិ** សេចក្តីថា បានដល់ ចិញ្ច្រាំ ដូចចិញ្ច្រាំសាច់លើជ្រញ់ ។ បើក្រោកឡើងគេចទៅបាន កំពែងដែកផុសឡើងមកឃាំង មុខកាំបិតកោរ ក៏តាំងឡើងខាងក្រោម ។

[ ១៨៩ ] បទថា **ខារោទកា នទី** បានដល់ ស្ទឹងទន់ដែងឈ្មោះវេត្តរណី ក្នុងបទនោះ ខ្សាច់គ្រោតគ្រាត សម្រេចដោយដែក ស្ទឹកឈូកខាងក្រោម មានមុខមុតដូចកាំបិតកោរ ត្រង់ច្រាំងទាំងសងខាង មានផ្តៅ និងស្បូវក្លាំង ។ បទថា **សោ តត្ថ ទុក្ខា តិព្វា ១រា** សេចក្តីថា សត្វនរកនោះអណ្តែតខាងលើ និងលិចចុះទៅខាងក្រោមក្នុងនរក ដាច់ជាចម្រៀកក្នុងស្ទឹកឈូក ។ ត្រូវបន្ទាខ្សាច់គ្រោតគ្រាត មានសណ្ឋានជាជើងក្អែក មុតដោយមានមុខដូចកាំបិតកោរ រមែងធូតដោយស្បូវក្លាំង ត្រង់ច្រាំងទាំងសងខាងថ្តក់មកដោយផ្តៅ ។ ត្រូវកាត់ដោយសស្រ្តាដ៏មុត ។

[ ១៩០ ] បទថា **តត្តេន អយោសង្កុនា** សេចក្តីថា កាលសត្វនរកពោលថា ខ្ញុំឃ្លាន និរយបាលទាំងនោះ យកដុំលោហៈដាក់ល្អីលោហៈធំចូលទៅឲ្យ ។ សត្វនរកដឹងថា ជាដុំលោហៈប៉ះត្រង់ធ្មេញ គ្រានោះ នាយនិរយ-បាលយកកន្ធ្វេរដែកក្តៅ ខ្វាស់មាត់សត្វនរក ។ យកទឹកទន់ដែងចាក់ចូលទៅ

ក្នុងថ្នាំងទង់ដែងធំ ហើយធ្វើយ៉ាងនោះឯង ។

[ ១៩១ ] បទថា **បុន មហានិរយេ** សេចក្តីថា នាយនិរយបាលឲ្យដាក់ទោសតាំងអំពីចំណង ៥ ប្រការ រហូតដល់បញ្ចុកទឹកទង់ដែងយ៉ាងនេះ តាំងអំពីឲ្យផឹកទឹកទង់ដែង ឲ្យចងដោយចំណង ៥ ប្រការជាដើមទៀត បោះទៅក្នុងមហានរក ។ ក្នុងមហានរកនោះ ខាងដើម ផុតចំណង ៥ ប្រការ ជួនកាល ផុតគ្រាទី ២ ជួនកាល ផុតគ្រាទី ៣ ជួនកាល ផុតដោយការផឹកទឹកទង់ដែង កាលមិនទាន់អស់កម្ម និរយបាលក៏បោះទៅក្នុងមហានរកទៀត ។ ភិក្ខុកំលោះមួយរូប កាលរៀនព្រះសូត្រនេះ ពោលថា លោកម្ចាស់ដ៏ចម្រើន កាលសត្វនរកសោយទុក្ខប៉ុណ្ណោះហើយ និរយបាលនៅតែបោះទៅក្នុងមហានរកទៀតឬ ។ ភិក្ខុពោលថា លោកដ៏ចម្រើន ឧទ្ទេសចូរស្ទះទុកសិន សូមលោកម្ចាស់ប្រាប់កម្មដ្ឋានដល់ខ្ញុំ ឲ្យព្រះថេរៈប្រាប់កម្មដ្ឋានហើយ បានជាព្រះសោតាបន្ន អាស្រ័យរៀនឧទ្ទេស សូម្បីជនដទៃរៀនឧទ្ទេសបទេសនេះ សម្រេចអរហត្តមិនមានចំនួន គឺរាប់មិនបាន ។ ព្រះសូត្រនេះ ព្រះពុទ្ធគ្រប់អង្គទ្រង់មិនវៀរឡើយ ។

[ ១៩៣ ] បទថា **ហីនកាយូបគា** បានដល់ ជាបុគ្គលចូលដល់ពួកអាក្រក់ ។ បទថា **ឧបាទានេ** គឺប្រកាន់ដោយតណ្ហា និងទិដ្ឋិ ។ បទថា **ជាតិមរណសម្ភវេ** បានដល់ ជាហេតុនៃការកើត និងការស្លាប់ ។ បទថា **អនុបាទា** បានដល់ មិនប្រកាន់ដោយឧបាទាន ៤ ។ បទថា **ជាតិមរណសង្ខយេ** គឺរមែងរួចផុត ព្រោះនិព្វាន ពោល គឺជាទីអស់ជាតិ និងមរណៈ ។

*បទថា* **ទិដ្ឋធម្មាភិនិព្វុតា** *សេចក្ដីថា រលត់ហើយដោយការរលត់កិលេសទាំងពួង ក្នុងទិដ្ឋធម្ម គឺក្នុងអត្តភាពនេះឯង ។ បទថា* **សព្វទុក្ខំ ឧបច្ចគុំ** *គឺឈ្មោះថា កន្លងបង់នូវទុក្ខទាំងពួងបាន ។៚*

**អដ្ឋកថាទេវទូតសូត្រ ចប់**

**សូត្រទី ១០ ចប់**

**វគ្គទី ៣ ចប់**

# សុត្តន្តបិដក

# មជ្ឈិមនិកាយ ឧបរិបណ្ណាសក

# នវមភាគ វិភង្គវគ្គ

## ភទ្ទេករត្តសូត្រទី ១

[ ១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវឧទ្ទេស គឺមាតិកាជាគ្រឿងសម្តែងឡើង និងវិភង្គ គឺបទជាគ្រឿងចែកដោយពិស្តាររបស់បុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវសូត្រនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះ ទទួលស្តាប់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ២ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា បុគ្គល
មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ដែលកន្លងទៅហើយ
មិនគប្បីប្រាថ្នាបញ្ចក្ខន្ធ ដែលមិនទាន់មកដល់ទេ ព្រោះ
បញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះកន្លងហួសទៅហើយ

*បញ្ចក្ខន្ធណាជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណា ឃើញច្បាស់ នូវធម៌ជាបច្ចុប្បន្ន ក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម និងមិនបានកម្រើក ( ដោយពួក កិលេស ) គប្បីចម្រើនឲ្យរឿយៗ នូវផលសមាបត្តិ ដែល មានព្រះនិព្វាននោះ ជាអារម្មណ៍ ឯការព្យាយាមជា គ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នក ណានឹងដឹងថា សេចក្តីស្លាប់ នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើង ចំពោះមច្ចុ ដែលមាន សេនាដ៏ច្រើននោះ មិនមានសោះឡើយ អ្នកប្រាជ្ញដែល ស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាង នេះ ជាអ្នកមានព្យាយាមដុតកិលេស ជាអ្នកមិនខ្ជិល ច្រអូសអស់យប់ និងថ្ងៃនោះឯង ថាជាអ្នកមានរាត្រី មួយដ៏ចម្រើន ។*

[ ៣ ] *ម្នាលភិក្ខុទាំងឡាយ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធដែលកន្លង ទៅហើយ តើដូចម្តេច ។ បុគ្គលរមែងប្រព្រឹត្តទៅតាមសេចក្តីត្រេកអរក្នុងរូប នោះថា អាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលដែលកន្លងទៅហើយ ប្រព្រឹត្ត ទៅតាមតណ្ហា ក្នុងវេទនានោះថា អាត្មាអញមានវេទនាយ៉ាងនេះ ក្នុងកាលជា អតីត ប្រព្រឹត្តទៅតាមសេចក្តីត្រេកអរក្នុងសញ្ញានោះថា អាត្មាអញមានសញ្ញា*

យ៉ាងនេះ ក្នុងកាលជាអតីត ប្រព្រឹត្តទៅតាមសេចក្ដីត្រេកអរ ក្នុងសង្ខារទាំង-ឡាយនោះថា អាត្មាអញមានសង្ខារយ៉ាងនេះ ក្នុងកាលជាអតីត ប្រព្រឹត្តទៅតាមសេចក្ដីត្រេកអរក្នុងវិញ្ញាណនោះថា អាត្មាអញមានវិញ្ញាណយ៉ាងនេះក្នុងកាលជាអតីត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលអាឡោះអាល័យបច្ចុប្បន្នដែលកន្លងទៅហើយយ៉ាងនេះឯង ។

[ ៤ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនអាឡោះអាល័យបច្ចុប្បន្នជាអតីតតើដូចម្ដេច ។ បុគ្គលមិនប្រព្រឹត្តទៅ តាមសេចក្ដីត្រេកអរក្នុងរូបនោះថា អាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាមសេចក្ដីត្រេកអរ ក្នុងវេទនានោះថា អាត្មាអញមានវេទនាយ៉ាងនេះ ក្នុងកាលជាអតីតមិនប្រព្រឹត្តទៅតាមសេចក្ដីត្រេកអរ ក្នុងសញ្ញានោះថា អាត្មាអញមានសញ្ញាយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាមសេចក្ដីត្រេកអរ ក្នុងសង្ខារទាំងឡាយនោះថា អាត្មាអញមានសង្ខារយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាមសេចក្ដីត្រេកអរ ក្នុងវិញ្ញាណនោះថា អាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអតីត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនអាឡោះអាល័យបច្ចុប្បន្នដែលកន្លងទៅហើយ យ៉ាងនេះឯង ។

[ ៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រាថ្នានូវបច្ចុប្បន្នក្នុងកាល ជាអនាគតតើដូចម្ដេច ។ បុគ្គលប្រព្រឹត្តទៅតាមសេចក្ដីត្រេកអរ ក្នុងរូបនោះថា សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត មានវេទនាយ៉ាងនេះ ។បេ។ មានសញ្ញាយ៉ាងនេះ ។បេ។ មានសង្ខារយ៉ាងនេះ ។បេ។ រមែងប្រព្រឹត្តទៅ

តាមសេចក្តីត្រេកអរ ក្នុងវិញ្ញាណនោះថា សូមឲ្យអាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធ ក្នុងកាលជាអនាគត យ៉ាងនេះឯង ។

[ ៦ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធ ក្នុងកាលជាអនាគតនោះ តើដូចម្តេច ។ បុគ្គលមិនប្រព្រឹត្តទៅតាមសេចក្តីត្រេកអរ ក្នុងរូបនោះថា សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត មានវេទនាយ៉ាងនេះ ។បេ។ មានសញ្ញាយ៉ាងនេះ ។បេ។ មានសង្ខារយ៉ាងនេះ ។បេ។ មិនប្រព្រឹត្តទៅតាមសេចក្តីត្រេកអរ ក្នុងវិញ្ញាណនោះថា សូមឲ្យអាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធ ក្នុងកាលជាអនាគត យ៉ាងនេះឯង ។

[ ៧ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលរសេមរសាម ( ដោយតណ្ហា និងទិដ្ឋិ ) ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់ មិនបានជួបប្រទះនឹងពួកព្រះអរិយៈ ជាអ្នកមិនឈ្លាសក្នុងធម៌របស់ព្រះអរិយៈ មិនបានហាត់ក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះនូវសប្បុរសទាំងឡាយ មិនឈ្លាសក្នុងធម៌របស់សប្បុរស មិនបានហាត់ក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញនូវរូបថាជាខ្លួន ពិចារណាឃើញនូវខ្លួនថាមានរូប នូវរូបថាមានក្នុងខ្លួន ឬនូវខ្លួនថាមានក្នុងរូប ពិចារណាឃើញនូវវេទនា ។បេ។ នូវសញ្ញា ។បេ។ នូវសង្ខារទាំងឡាយ ។បេ។ នូវវិញ្ញាណថាជាខ្លួន នូវខ្លួនថាមានវិញ្ញាណ នូវវិញ្ញាណថាមានក្នុងខ្លួន ឬនូវ

ខ្លួនថាមានក្នុងវិញ្ញាណ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[ ៨ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនរសេមរសាមក្នុងធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកបានស្តាប់ ជាអ្នកបានជួបប្រទះនឹងពួកព្រះអរិយៈ ជាអ្នកឈ្លាសវៃក្នុងធម៌របស់ព្រះអរិយៈ បានហាត់ល្អក្នុងធម៌របស់ព្រះអរិយៈ បានជួបប្រទះនឹងពួកសប្បុរស ឈ្លាសវៃក្នុងធម៌របស់សប្បុរស បានហាត់ក្នុងធម៌របស់សប្បុរស មិនពិចារណាឃើញរូបថាជាខ្លួន មិនពិចារណាឃើញខ្លួនថាមានរូប មិនពិចារណាឃើញរូបថាមានក្នុងខ្លួន មិនពិចារណាឃើញខ្លួនថាមានក្នុងរូប មិនពិចារណាឃើញវេទនា ។បេ។ មិនពិចារណាឃើញសញ្ញា ។បេ។ មិនពិចារណាឃើញសង្ខារទាំងឡាយ ។បេ។ មិនពិចារណាឃើញវិញ្ញាណថាជាខ្លួន មិនពិចារណាឃើញខ្លួនថាមានវិញ្ញាណ មិនពិចារណាឃើញវិញ្ញាណថាមានក្នុងខ្លួន មិនពិចារណាឃើញខ្លួនថាមានក្នុងវិញ្ញាណឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[ ៩ ] បុគ្គលមិនគប្បីអាឡោះអាល័យ នូវបញ្ចក្ខន្ធ
ជាអតីត មិនគប្បីប្រាថ្នានូវបញ្ចក្ខន្ធ ជាអនាគត
ឡើយ ព្រោះបញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះ
កន្លងហួសទៅហើយ បញ្ចក្ខន្ធណា ជាអនាគត
បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់មួយទៀត បុគ្គល

ណា ពិចារណាឃើញច្បាស់នូវធម៌ជាបច្ចុប្បន្ន ក្នុង
ទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន
ដែលមិនរសេមរសាម និងមិនកម្រើកហើយ គប្បី
ចម្រើននូវផលសមាបត្តិ ដែលមានព្រះនិព្វាននោះ
ជាអារម្មណ៍ឲ្យរឿយៗ ឯការព្យាយាមជាគ្រឿងដុត
កិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណា
អាចដឹងថា សេចក្ដីស្លាប់ នឹងមានក្នុងថ្ងៃស្អែបាន
ព្រោះថា ការតទល់របស់យើងចំពោះ មច្ចុដែល
មានសេនាដ៏ច្រើននោះ មិនមានសោះឡើយ អ្នក
ប្រាជ្ញដែលស្ងប់ទុក្ខហើយ តែងហៅបុគ្គលដែលមាន
វិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្ដៅកិលេស
ជាអ្នកមិនខ្ជិលច្រអូសអស់ថ្ងៃ និងយប់នោះឯង ថា
ជាអ្នកមានរាត្រីមួយ ដ៏ចម្រើន ។

ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវឧទ្ទេស គឺមាតិកា និងវិភង្គ គឺភាជនីយ របស់បុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន ដល់អ្នកទាំងឡាយ ។ ពាក្យណា ដែលតថាគតពោលហើយ ដោយប្រការដូច្នេះ ពាក្យនោះ តថាគតពោលសំដៅហេតុនេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ភាសិតនេះចប់ហើយ ពួកភិក្ខុទាំងនោះក៏មានចិត្តត្រេកអរ រីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ។

## ភទ្ទេករត្តសូត្រទី ១ ចប់

# អដ្ឋកថា

# វិភង្គវគ្គ

## ភទ្ទេករត្តសូត្រ

[ ១ ] ភទ្ទេករត្តសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងភទ្ទេករត្តសូត្រនោះ បទថា **ភទ្ទេករត្តស្ស** សេចក្ដីថា ឈ្មោះថា ជាអ្នកមានរាត្រីមួយដ៏ចម្រើន ព្រោះបុគ្គលនោះជាអ្នកដល់ព្រមដោយការតាមប្រកបវិបស្សនា ។ បទថា **ឧទ្ទេសំ** បានដល់ មាតិកា ។ បទថា **វិភង្គំ** បានដល់ បទដែលគប្បីចែកដោយវិត្ថារ ។

[ ២ ] បទថា **អតីតំ** បានដល់ ក្នុងខន្ធ ៥ ដែលកន្លងហើយ ។ បទថា **នាន្វាគមេយ្យ** សេចក្ដីថា មិនគួរនឹកដល់ដោយតណ្ហា និងទិដ្ឋិទាំងឡាយ ។ បទថា **នប្បដិកង្ខេ** សេចក្ដីថា មិនគប្បីប្រាថ្នា ដោយតណ្ហានិងទិដ្ឋិទាំងឡាយ ។ បទថា **យទតីតំ** នេះ ក្នុងគាថានេះ ជាការពោលដល់ហេតុ ព្រោះវត្ថុណាកន្លងទៅហើយ វត្ថុនោះក៏លះទៅហើយ រលត់ហើយដល់នូវការតាំងនៅមិនបានហើយ ព្រោះដូច្នោះ បុគ្គលមិនគួរគិតដល់វត្ថុដែលកន្លងទៅហើយនោះទេ ម្យ៉ាងទៀត វត្ថុណាមិនទាន់មកដល់ វត្ថុនោះ ក៏មិនទាន់មកដល់ មិនទាន់កើត មិនទាន់កើតឡើង ព្រោះដូច្នោះ បុគ្គលមិនគប្បីប្រាថ្នាវត្ថុដែលមិនទាន់មកដល់នោះ ។ បទថា **តត្ថ តត្ថ** សេចក្ដីថា បុគ្គលចូលដល់ធម៌ដែលជាបច្ចុប្បន្នក្នុងធម៌ណាមួយ ឃើញច្បាស់នូវធម៌នោះ

ដោយអនុបស្សនា ៧ យ៉ាង មានអនិច្ចានុបស្សនាជាដើមក្នុងធម៌នោះៗឯង ។ ម្យ៉ាងទៀត បុគ្គលឃើញច្បាស់ក្នុងធម៌នោះៗ ក្នុងទីទាំងឡាយ មានព្រៃជាដើម ។ បទថា **អសំហិរំ អសង្កុប្បំ** នេះ ព្រះមានព្រះភាគត្រាស់ដើម្បីសម្តែងវិបស្សនា និងបដិវិបស្សនា ។ ពិតហើយ វិបស្សនារមែងមិនរសេមរសាម មិនកម្រើកដោយកិលេសទាំងឡាយ មានរាគៈជាដើម ព្រោះដូច្នោះ វិបស្សនានោះ ឈ្មោះថា **អសំហិរំ** មិនរសេមរសាម ឈ្មោះថា **អសង្កុប្បំ** មិនកម្រើក ។ លោកអធិប្បាយថា បុគ្គលគប្បីកពូន គប្បីចម្រើន គប្បីឃើញច្បាស់ចំពោះវិបស្សនានោះ ។ ម្យ៉ាងទៀត និព្វាន មិនរសេមរសាម មិនកម្រើក ដោយកិលេសទាំងឡាយ មានរាគៈជាដើមឡើយ ព្រោះដូច្នោះ ទើបនិព្វាននោះឈ្មោះថា **អសំហិរំ អសង្កុប្បំ** ប្រែថា មិនរសេមរសាម មិនកម្រើក ។ អធិប្បាយថា ភិក្ខុដែលជាបណ្ឌិតដឹងច្បាស់ហើយ គប្បីចម្រើននិព្វាននោះ គឺកាលមិនទាន់សម្រេចផលសមាបត្តិ ដែលមាននិព្វាននោះជាអារម្មណ៍ ក៏គប្បីចម្រើនរឿយៗ ។ ដើម្បីប្រយោជន៍ដល់ភិក្ខុអ្នកចម្រើននោះ ។ បទថា **អជ្ជេវ កិច្ចមាតប្បំ** សេចក្តីថា សេចក្តីព្យាយាម ឈ្មោះថា អាតប្បៈ ព្រោះដុតកិលេសទាំងឡាយ ឬញុំាងកិលេសទាំងឡាយឲ្យក្តៅទូទៅ គប្បីធ្វើក្នុងថ្ងៃនេះឯង ។ បាទគាថាថា **កោ ជញ្ញា មរណំ សុវេ** សេចក្តីថា នរណានឹងដឹងការរស់នៅ ឬការស្លាប់ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគទ្រង់សម្តែងថា គប្បីធ្វើសេចក្តីព្យាយាមយ៉ាងនេះថា ការឃើតឃូររមែងមានក្នុងថ្ងៃនេះប៉ុណ្ណោះថា អញនឹងធ្វើទាន ឬនឹងរក្សាសីល ឬនឹងធ្វើកុសលណាមួយ ក្នុងថ្ងៃនេះឯង

អញ មិនញុំាងចិត្តឲ្យកើតឡើងថា អញនឹងដឹងក្នុងថ្ងៃស្អែក ឬក្នុងថ្ងៃខានស្អែក នឹងធ្វើក្នុងថ្ងៃនេះឯង ។ បទថា **មហាសេនេន** សេចក្តីថា ហេតុនៃសេចក្តីស្លាប់មានច្រើនយ៉ាង មានភ្លើង ថ្នាំពុល សស្ត្រាជាដើម គឺសេនារបស់មច្ចុរាជនោះ ការស្និទ្ធស្នាល ពោល គឺធ្វើសន្ធវមេត្រីយ៉ាងនេះថា សូមលោកបន្ធូរ ២-៣ ថ្ងៃសិន ទម្រាំខ្ញុំធ្វើកម្មដែលជាទីពឹងរបស់ខ្លួន មានការបូជាព្រះពុទ្ធជាដើម ឬពោល គឺការឲ្យសំណូកយ៉ាងនេះថា សូមលោកកាន់យក ១ រយ ឬ ១ សែននេះហើយ បន្ធូរ ២-៣ ថ្ងៃ ឬនឹងប្រើកងពលយ៉ាងនេះថា អញនឹងតតាំងដោយកងកម្លាំងនេះ ដូច្នេះ ជាមួយនឹងមច្ចុរាជបែបនេះ ដែលមានសេនា ដ៏ពន្លឹកនោះ ដោយអំណាចនៃសេនាដ៏ធំនោះ មិនមាន ។ បទថា **សង្គរោ** ការតទល់នោះ ជាឈ្មោះនៃការធ្វើសន្ធវមេត្រី ការស៊ីកប៉ាន់ និងកងពល ។ ព្រោះដូច្នោះ អត្ថនេះបានពោលហើយ ។ បទថា **អតន្ទិតំ** បានដល់ បុគ្គលមិនខ្ជិលច្រអូស គឺឧស្សាហ៍ ។ បុគ្គលនោះ ឈ្មោះថា ជាអ្នកមានរាត្រីមួយដ៏ចម្រើន ព្រោះបុគ្គលនោះ ជាអ្នកបដិបត្តិយ៉ាងនេះ ព្រោះដូច្នោះ បុគ្គលនោះ ឈ្មោះថា **ភទ្ទេករត្តោ** ជាអ្នកមានរាត្រីមួយដ៏ចម្រើន ។ ព្រះមុនីសម្ពុទ្ធ ឈ្មោះថា ទ្រង់ស្ងប់ហើយ ព្រោះកិលេសទាំងឡាយ មានរាគៈជាដើមស្ងប់ ហើយត្រាស់ហៅបុគ្គលដែលបដិបត្តិយ៉ាងនេះថា បុគ្គលនេះ ជាអ្នកមានរាត្រីមួយដ៏ចម្រើន ដោយប្រការដូច្នេះ ។

[ ៣ ] ក្នុងបទទាំងឡាយថា **ឃរំរូបោ** ជាដើម សេចក្តីថា មានពណ៌ដូចកែវមណីឥន្ទនីល ។ បទថា **អហោសិ** សេចក្តីថា អញមានរូបយ៉ាងនេះ

ដោយអំណាចនៃរូបដែលគប្បីពេញចិត្តយ៉ាងនេះឯង ។ អញមានវេទនាយ៉ាងនេះ ដោយអំណាចនៃសុខវេទនា និងសោមនស្សវេទនាដែលជាកុសល មានសញ្ញាយ៉ាងនេះ ដោយអំណាចនៃធម៌ទាំងឡាយ មានសញ្ញាជាដើម ដែលប្រកបព្រមដោយវេទនានោះឯង មានសង្ខារយ៉ាងនេះ មានវិញ្ញាណយ៉ាងនេះ ។ បទថា **អតីតមន្វាគំ** សេចក្ដីថា រំពឹងដល់ការត្រេកអរក្នុងរឿងនោះៗ បានដល់ ត្រិះរិះស្របតាមតណ្ហាក្នុងរូបជាដើមនោះ ។ រមែងមិនសម្គាល់ថា អញជាអ្នកមានរូបយ៉ាងនេះ ដោយអំណាចរូបអាក្រក់ជាដើម ។បេ។ មានវិញ្ញាណយ៉ាងនេះ ។

[ ៤ ] បទថា **នន្ទឹ ន សមន្វានេតិ** សេចក្ដីថា តណ្ហា ឬទិដ្ឋិដែលសម្បយុត្តដោយតណ្ហា ដែលបុគ្គលរមែងមិនឲ្យប្រព្រឹត្តទៅ ។ គប្បីជ្រាបការត្រិះរិះដល់ការត្រេកអរ ពោល គឺការប្រព្រឹត្តិទៅនៃតណ្ហា និងទិដ្ឋិ ដោយអំណាចនៃរូប ដែលប្រណីត និងគប្បីពេញចិត្តជាដើម ក្នុងបទថា **ឯវំរូបោ សិយំ** ជាដើម ។

[ ៧ ] បទថា **កថញ្ច ភិក្ខវេ បច្ចុប្បន្នេសុ ធម្មេសុ សំហិរតិ** នេះ ត្រាស់ដើម្បីសម្ដែងពង្រីកឧទ្ទេសថា បុគ្គលឃើញច្បាស់នូវធម៌បច្ចុប្បន្ន ក្នុងធម៌នោះៗ ដែលមិនរសេមរសាម មិនកម្រើក ។ បទថា **កថញ្ច ភិក្ខវេ បច្ចុប្បន្នំ ធម្មំ ន វិបស្សតិ** ជាដើម គប្បីត្រាស់ក្នុងព្រះសូត្រនេះក៏ពិតតែក៏នៅត្រាស់ដល់វិបស្សនាថា មិនរសេមរសាម និងមិនកម្រើក ព្រោះដូច្នោះ ដើម្បីសម្ដែងការមាន និងការមិនមាននៃវិបស្សនានោះ ទើបទ្រង់លើក

មាតិកាថា បុគ្គលរសេមរសាម មិនរសេមរសាម ដូច្នេះហើយ ត្រាស់សេចក្តីពិស្តារ ។ បណ្តាបទទាំងនោះ បទថា **សំហរតិ** សេចក្តីថា បុគ្គលឈ្មោះថា ត្រូវតណ្ហា និងទិដ្ឋិទាញទៅ ព្រោះមិនមានវិបស្សនា ។

[ ៨ ] បទថា **ន សំហរតិ** សេចក្តីថា ឈ្មោះថា មិនត្រូវតណ្ហានិងទិដ្ឋិទាញទៅ ព្រោះមានវិបស្សនា ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ៕

## អដ្ឋកថា ភទ្ទេករត្តសូត្រ ចប់

## សូត្រទី ១ ចប់

# សុត្តន្តបិដក

## អានន្ទភទ្ទេករត្តសូត្រទី ២

[ ១០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក៏សម័យនោះឯង ព្រះអានន្ទមានអាយុ បានពន្យល់ណែនាំពួកភិក្ខុ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ក្នុងឧបដ្ឋានសាលា ហើយសម្តែងនូវឧទ្ទេស គឺមាតិកា និងវិភង្គ គឺភាជនីយ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើន ។

[ ១១ ] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចេញចាកផលសមាបត្តិក្នុងសាយណ្ហសម័យ ចូលទៅឯឧបដ្ឋានសាលា លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លុះព្រះមានព្រះភាគគង់ស្រេចហើយ ទើបត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកណាហ្ន៎ ពន្យល់ណែនាំពួកភិក្ខុឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាក្នុងឧបដ្ឋា-នសាលា ហើយសម្តែងនូវឧទ្ទេស និងវិភង្គ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើន ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអានន្ទមានអាយុ លោកពន្យល់ណែនាំពួកភិក្ខុ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថា ក្នុងឧបដ្ឋានសាលា ហើយសម្តែងនូវឧទ្ទេស និងវិភង្គ របស់បុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុថា ម្នាលអានន្ទ ចុះអ្នកពន្យល់ណែនាំពួកភិក្ខុឲ្យកាន់

យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយសម្តែងនូវឧទ្ទេស និង វិភង្គ របស់បុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន ដូចម្តេចខ្លះ ។

[ ១២ ] ព្រះអានន្ទក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គពន្យល់ណែនាំពួកភិក្ខុឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយសម្តែងនូវឧទ្ទេស និងវិភង្គ របស់បុគ្គលអ្នកមានរាត្រីមួយ ដ៏ចម្រើន យ៉ាងនេះថា

បុគ្គលមិនត្រូវអាឡោះអាល័យ នូវបញ្ចក្ខន្ធដែលកន្លង
ទៅហើយទេ មិនគប្បីប្រាថ្នានូវបញ្ចក្ខន្ធដែលជាអនាគត
ឡើយ ព្រោះបញ្ចក្ខន្ធណាជាអតីត បញ្ចក្ខន្ធនោះ កន្លង
ហួសទៅហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះ
ក៏មិនទាន់មកដល់ បុគ្គលណា ពិចារណាឃើញច្បាស់
នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់
នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនបានកម្រើក
នោះហើយ គប្បីចម្រើននូវផលសមាបត្តិ ដែលមានព្រះ
និព្វាននោះ ជាអារម្មណ៍ឲ្យរឿយៗ ឯការព្យាយាមជា
គ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នក
ណាអាចដឹងថា សេចក្តីស្លាប់ នឹងមានក្នុងថ្ងៃស្អែកបាន
ព្រោះថា ការតទល់របស់យើងចំពោះមច្ចុ ដែលមាន
សេនាដ៏ច្រើននោះ មិនមានសោះឡើយ អ្នកប្រាជ្ញស្ងប់

ទុក្ខ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មាន
ព្យាយាមដុតកម្តៅកិលេស មិនខ្ជិលច្រអូសអស់ថ្ងៃ និង
យប់នោះឯង ថាជាអ្នកមានរាត្រីមួយ ដ៏ចម្រើន ។

[ ១៣ ] ម្នាលអាវុសោ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើ
ដូចម្តេច ។ បុគ្គលប្រព្រឹត្តទៅតាមនូវតណ្ហាក្នុងរូបនោះថា អាត្មាអញមានរូប
យ៉ាងនេះ ក្នុងកាលជាអតីត ប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងវេទនានោះថា
អាត្មាអញមានវេទនាយ៉ាងនេះ ក្នុងកាលជាអតីត ប្រព្រឹត្តទៅតាមនូវតណ្ហាក្នុង
សញ្ញានោះថា អាត្មាអញមានសញ្ញាយ៉ាងនេះ ក្នុងកាលជាអតីត ប្រព្រឹត្តទៅ
តាមនូវតណ្ហាក្នុងសង្ខារទាំងឡាយនោះថា អាត្មាអញមានសង្ខារយ៉ាងនេះ ក្នុង
កាលជាអតីត ប្រព្រឹត្តទៅតាមនូវតណ្ហាក្នុងវិញ្ញាណនោះថា អាត្មាអញមាន
វិញ្ញាណយ៉ាងនេះ ក្នុងកាលជាអតីត ។ ម្នាលអាវុសោ បុគ្គលអាឡោះ
អាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

[ ១៤ ] ម្នាលអាវុសោ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធ ដែលជា
អតីត តើដូចម្តេច ។ បុគ្គលមិនប្រព្រឹត្តទៅតាមនូវតណ្ហាក្នុងរូបនោះថា
អាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាមនូវតណ្ហា
ក្នុងវេទនានោះថា អាត្មាអញមានវេទនាយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រ-
ព្រឹត្តទៅតាមនូវតណ្ហា ក្នុងសញ្ញានោះថា អាត្មាអញមានសញ្ញាយ៉ាងនេះក្នុង
កាលជាអតីត មិនប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងសង្ខារទាំងឡាយនោះថា
អាត្មាអញមានសង្ខារយ៉ាងនេះ ក្នុងកាលជាអតីត មិនប្រព្រឹត្តទៅតាមនូវ

តណ្ហា ក្នុងវិញ្ញាណនោះថា អាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអតីត ។ ម្នាលអាវុសោ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

[ ១៥ ] ម្នាលអាវុសោ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។ បុគ្គលប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងរូបនោះថា សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត មានវេទនាយ៉ាងនេះ ។បេ។ មានសញ្ញាយ៉ាងនេះ ។បេ។ មានសង្ខារយ៉ាងនេះ ។បេ។ ប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងវិញ្ញាណនោះថា សូមឲ្យអាត្មាអញ មានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលអាវុសោ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធ ដែលជាអនាគត យ៉ាងនេះឯង ។

[ ១៦ ] ម្នាលអាវុសោ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។ បុគ្គលមិនប្រព្រឹត្តទៅតាមនូវតណ្ហាក្នុងរូបនោះថា សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត មានវេទនាយ៉ាងនេះ ។បេ។ មានសញ្ញាយ៉ាងនេះ ។បេ។ មានសង្ខារយ៉ាងនេះ ។បេ។ មិនប្រព្រឹត្តទៅតាមនូវតណ្ហា ក្នុងវិញ្ញាណនោះថា សូមឲ្យអាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលអាវុសោ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធ ជាអនាគតយ៉ាងនេះឯង ។

[ ១៧ ] ម្នាលអាវុសោ បុគ្គលរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលអាវុសោ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់ មិន

បានជួបប្រទះនឹងពួកអរិយៈ ជាអ្នកមិនយល់ធម៌របស់ព្រះអរិយៈ មិនបាន ហាត់ក្នុងធម៌របស់ព្រះអរិយៈ មិនបានជួបប្រទះនឹងពួកសប្បុរស មិនយល់ ធម៌របស់សប្បុរស មិនបានហាត់ក្នុងធម៌របស់សប្បុរស រមែងពិចារណា ឃើញនូវរូបថាជាខ្លួន នូវខ្លួនថាមានរូប នូវរូបថាមានក្នុងខ្លួន នូវខ្លួនថាមាន ក្នុងរូប នូវវេទនា ។បេ។ នូវសញ្ញា ។បេ។ នូវសង្ខារទាំងឡាយ ។បេ។ រមែងពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន នូវខ្លួនថាមានវិញ្ញាណ នូវវិញ្ញាណ ថាមានក្នុងខ្លួន នូវខ្លួនថាមានក្នុងវិញ្ញាណ ។ ម្នាលអាវុសោ បុគ្គលរសេម-រសាមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[ ១៨ ] ម្នាលអាវុសោ បុគ្គលមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលអាវុសោ អរិយសាវកក្នុងលោកនេះ ជាអ្នកបានស្តាប់ បានជួបប្រទះនឹងពួកព្រះអរិយៈ យល់ធម៌របស់ព្រះអរិយៈ បានហាត់ល្អក្នុង ធម៌របស់ព្រះអរិយៈ ជាអ្នកបានឃើញពួកសប្បុរស យល់ធម៌របស់សប្បុរស បានហាត់ល្អក្នុងធម៌របស់សប្បុរស មិនពិចារណាឃើញនូវរូបថាខ្លួន មិនពិចា-រណាឃើញនូវខ្លួនថាមានរូប មិនពិចារណាឃើញនូវរូបថាមានក្នុងខ្លួន មិន ពិចារណានូវខ្លួនថាមានក្នុងរូប មិនពិចារណាឃើញនូវវេទនា ។បេ។ មិនពិចា-រណាឃើញនូវសញ្ញា ។បេ។ មិនពិចារណាឃើញនូវសង្ខារទាំងឡាយ ។បេ។ មិនពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន មិនពិចារណាឃើញនូវខ្លួនថាមាន វិញ្ញាណ មិនពិចារណាឃើញនូវវិញ្ញាណថាមានក្នុងខ្លួន មិនពិចារណាឃើញ នូវខ្លួនថាមានក្នុងវិញ្ញាណឡើយ ។ ម្នាលអាវុសោ បុគ្គលមិនរសេមរសាម

ក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[ ១៩ ] បុគ្គល មិនគប្បីអាឡោះអាល័យ បញ្ចក្ខន្ធជាអតីត មិនគប្បីប្រាថ្នានូវបញ្ចក្ខន្ធ ជាអនាគតទេ ព្រោះថា បញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណាឃើញច្បាស់នូវធម៌ជាបច្ចុប្បន្នក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកម្រើក ហើយគប្បីចម្រើនឲ្យរឿយៗ នូវផលសមាបត្តិ ដែលមានព្រះនិព្វាននោះជាអារម្មណ៍ ឯការព្យាយាមជាគ្រឿងដុតកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុដែលមានសេនាច្រើននោះ មិនមានសោះឡើយ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្តៅកិលេស ជាអ្នកមិនខ្ជិលច្រអូសអស់ថ្ងៃ និងយប់នោះឯង ថាជាអ្នកមានរាត្រីមួយ ដ៏ចម្រើន ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានពន្យល់ពួកភិក្ខុឲ្យកាន់យក ឲ្យ

អាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយសម្តែងនូវឧទ្ទេសនិងវិភង្គ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើន យ៉ាងនេះឯង ។

[ ២០ ] ម្នាលអានន្ទ ប្រពៃហើយ ប្រពៃហើយ ម្នាលអានន្ទ អ្នកបានពន្យល់ណែនាំពួកភិក្ខុ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយសម្តែងនូវឧទ្ទេស និងវិភង្គ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើនថា

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ដែលជា
អតីត ។បេ។ មុនីជាអ្នកស្ងប់ទុក្ខ រមែងហៅបុគ្គល
នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ដូច្នេះនោះ
ត្រឹមត្រូវហើយ ។

[ ២១ ] ម្នាលអានន្ទ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត តើដូចម្តេច ។បេ។ ម្នាលអានន្ទ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត យ៉ាងនេះឯង ។ ម្នាលអានន្ទ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត តើដូចម្តេច ។បេ។ ម្នាលអានន្ទ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។ ម្នាលអានន្ទ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។បេ។ ម្នាលអានន្ទ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធ ជាអនាគត យ៉ាងនេះឯង ។ ម្នាលអានន្ទ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។បេ។ ម្នាលអានន្ទ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត យ៉ាងនេះឯង ។ ម្នាលអានន្ទ បុគ្គលរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។បេ។ ម្នាលអានន្ទ បុគ្គលរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។ ម្នាលអានន្ទ បុគ្គលមិន

រសេម-រសោមក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។បេ។ ម្នាលអានន្ទ បុគ្គល មិនរសេមរសោមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[ ២២ ] បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជា
អតីត ។បេ។ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលនោះ
ឯង ថាជាអ្នកមានរាត្រីមួយ ដ៏ចម្រើន ។

លុះព្រះមានព្រះភាគ ត្រាស់ភាសិតនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិត របស់ព្រះមានព្រះភាគ ។

## អានន្ទភទ្ទេករត្តសូត្រទី ២ ចប់

# អដ្ឋកថា

## អានន្ទភទ្ទេករត្តសូត្រ

[ ១០ ] *អានន្ទភទ្ទេករត្តសូត្រ មានពាក្យផ្តើមថា* **ឯវម្មេ សុតំ** *ដូច្នេះជាដើម ។*

[ ១១ ] *បណ្តាបទទាំងនោះ បទថា* **បដិសល្លានា វុដ្ឋិតោ** *សេចក្តីថា ទ្រង់ចេញចាកផលសមាបត្តិ ។ បទថា* **កោ នុខោ ភិក្ខវេ** *សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ដឹងនោះឯង តែត្រាស់សួរដើម្បីផ្តើមរឿងឡើង ។*

[ ២០ ] *បទថា* **សាធុ សាធុ** *សេចក្តីថា ទ្រង់ប្រទានសាធុការដល់ព្រះថេរៈ ។ បទថា* **សាធុ ខោ ត្វំ** *សេចក្តីថា ទ្រង់សរសើរទេសនា ហើយត្រាស់ ព្រោះទេសនាដែលព្រះថេរៈសម្តែងដោយបទ និងព្យញ្ជនៈទាំងឡាយពីរោះរណ្តំ បរិសុទ្ធល្អ ។ បទដ៏សេស ក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ៕៚*

អដ្ឋកថា អានន្ទភទ្ទេករត្តសូត្រ ចប់

សូត្រទី ២ ចប់

# សុត្តន្តបិដក

## មហាកច្ចានភទ្ទេករត្តសូត្រទី ៣

[ ២៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះឥរិយាបថ ក្នុងតបោទារាម ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះសមិទ្ធិមានអាយុ ក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយចូលទៅរកស្ទឹងឈ្មោះតបោទា ដើម្បីនឹងស្រឡាបខ្លួន ។ លុះចុះទៅស្រឡាបខ្លួនក្នុងស្ទឹងឈ្មោះតបោទាស្រេចហើយ លោកក៏ឡើងមកវិញ មានតែចីវរមួយឈរហាលខ្លួនឲ្យស្ងួត ។ គ្រានោះឯង កាលរាត្រីបឋមយាមកន្លងទៅហើយ មានទេវតាមួយអង្គ មានរស្មីដ៏រុងរឿង ញុំាងស្ទឹងឈ្មោះ តបោទា ទាំងមូលឲ្យភ្លឺស្វាង ហើយចូលទៅរកព្រះសមិទ្ធិមានអាយុ លុះចូលទៅដល់ហើយ ទើបឈរក្នុងទីសមគួរ ។

[ ២៤ ] លុះទេវតានោះ ឈរក្នុងទីសមគួរហើយ បាននិយាយនឹងព្រះសមិទ្ធិមានអាយុ យ៉ាងនេះថា បពិត្រភិក្ខុ លោកចាំនូវឧទ្ទេស និងវិភង្គរបស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើនឬទេ ។ ម្នាលអាវុសោ អាត្មាមិនចាំនូវឧទ្ទេស និងវិភង្គរបស់បុគ្គលដែលមានរាត្រីមួយ ដ៏ចម្រើនទេ ម្នាលអាវុសោ ចុះអ្នកចាំនូវឧទ្ទេស និងវិភង្គ របស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើនឬទេ ។ បពិត្រភិក្ខុ ខ្ញុំព្រះករុណា ក៏មិនចាំនូវឧទ្ទេស និងវិភង្គរបស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើនដែរ បពិត្រភិក្ខុ ចុះលោកចាំគាថា មានរាត្រីមួយដ៏ចម្រើនឬទេ ។ ម្នាលអាវុសោ អាត្មាមិនចាំគាថាមានរាត្រីមួយដ៏ចម្រើនទេ ម្នាល

អាវុសោ ចុះអ្នកចាំគាថាមានរាត្រីមួយដ៏ចម្រើនឬទេ ។ បពិត្រភិក្ខុ ខ្ញុំព្រះករុណា ក៏មិនចាំគាថាមានរាត្រីមួយដ៏ចម្រើនដែរ បពិត្រភិក្ខុ ចូរលោករៀននូវឧទ្ទេស និងវិភង្គរបស់បុគ្គលអ្នកមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ចូរលោកទន្ទេញនូវឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ចូរលោកចាំទុកនូវឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ព្រោះឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន ជាធម៌ប្រកបដោយប្រយោជន៍ ហើយជាខាងដើមនៃមគ្គព្រហ្មចារ្យ ។ ទេវតានោះបានពោលពាក្យនេះ លុះពោលពាក្យនេះហើយ ក៏បាត់ក្នុងទីនោះទៅ ។

[ ២៥ ] គ្រានោះឯង ព្រះសមិទ្ធិមានអាយុ លុះកន្លងរាត្រីនោះហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំចំពោះព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះសមិទ្ធិមានអាយុអង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រីក្នុងទីនេះ បានចូលទៅឯស្ទឹងតបោទា ដើម្បីនឹងស្រឡាបខ្លួន ។ លុះបានស្រឡាបខ្លួនក្នុងស្ទឹងតបោទាស្រេចហើយ ខ្ញុំព្រះអង្គក៏ឡើងមកវិញ មានតែចីវរមួយឈរហាលខ្លួនឲ្យស្ងួត ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងគ្រារាត្រីបឋមយាមកន្លងហើយ មានទេវតាមួយអង្គ មានរស្មីដ៏រុងរឿង ញុំាងស្ទឹងតបោទាឲ្យភ្លឺស្វាង ហើយចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ហើយក៏ឈរក្នុងទីសមគួរ លុះទេវតានោះឈរក្នុងទីសមគួរហើយ បាននិយាយនឹងខ្ញុំព្រះអង្គ

ដូច្នេះថា បពិត្រភិក្ខុ លោកចាំនូវឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើនឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន កាលទេវតាពោលយ៉ាងនេះហើយ ខ្ញុំព្រះអង្គបានពោលនឹងទេវតានោះដូច្នេះថា ម្នាលអាវុសោ អាត្មាមិនចាំនូវឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើនទេ ម្នាលអាវុសោ ចុះអ្នកចាំនូវឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើនឬទេ ។ ទេវតានោះតបថា បពិត្រភិក្ខុ ខ្ញុំករុណាក៏មិនចាំនូវឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើនដែរ បពិត្រភិក្ខុ ចុះលោកចាំនូវគាថា មានរាត្រីមួយដ៏ចម្រើនឬទេ ។ ខ្ញុំព្រះអង្គតបថា ម្នាលអាវុសោ អាត្មាមិនចាំនូវគាថា មានរាត្រីមួយដ៏ចម្រើនទេ ម្នាលអាវុសោ ចុះអ្នកចាំនូវគាថា មានរាត្រីមួយដ៏ចម្រើនឬទេ ។ ទេវតាតបថា បពិត្រភិក្ខុ ខ្ញុំករុណាក៏មិនចាំនូវគាថា មានរាត្រីមួយដ៏ចម្រើនដែរ បពិត្រភិក្ខុ ចូរលោករៀនយកនូវឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ចូរលោកទន្ទេញនូវឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ចូរលោកចាំទុកនូវឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន បពិត្រភិក្ខុ ព្រោះថាឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយ ដ៏ចម្រើន ជាធម៌ប្រកបដោយប្រយោជន៍ ជាខាងដើមនៃព្រហ្មចារ្យ ។ បពិត្រព្រះអង្គដ៏ចម្រើន ទេវតានោះបានពោលពាក្យនេះ លុះពោលពាក្យនេះហើយ ក៏បាត់ក្នុងទីនោះទៅ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស សូមព្រះអង្គទ្រង់សំដែងនូវឧទ្ទេស និងវិភង្គរបស់បុគ្គលមានរាត្រីមួយដ៏ចម្រើន ដល់ខ្ញុំព្រះអង្គ ។ ព្រះអង្គ

ក៏ទ្រង់ត្រាស់ថា ម្នាលភិក្ខុ បើដូច្នោះ អ្នកចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃ ចុះ តថាគតនឹងសម្តែងប្រាប់ ។ ព្រះសមិទ្ធិមានអាយុ បានទទួលព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ២៦ ] ព្រះមានព្រះភាគ ទ្រង់បានត្រាស់គាថានេះថា បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត មិនគប្បីប្រាថ្នាបញ្ចក្ខន្ធ ជាអនាគត ព្រោះបញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណា ឃើញច្បាស់នូវធម៌ជាបច្ចុប្បន្ន ក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វានដែលមិនរសេមរសាម មិនកម្រើកហើយ គប្បីចម្រើនឲ្យរឿយៗ នូវផលសមាបត្តិ ដែលមានព្រះនិព្វាននោះជាអារម្មណ៍ ឯការព្យាយាមជាគ្រឿងដុតនូវកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើង ចំពោះមច្ចុដែលមានសេនាច្រើននោះ មិនមានសោះឡើយ មុនីជាអ្នកស្ងប់ទុក្ខតែងហៅបុគ្គល ដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្តៅកិលេស មិនខ្ជិលច្រអូសអស់ថ្ងៃ

និងយប់នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

ព្រះមានព្រះភាគ បានត្រាស់ភាសិតនេះ លុះព្រះសុគតត្រាស់ភាសិតនេះចប់ហើយ ទ្រង់ក្រោកអំពីអាសនៈ ហើយចូលទៅកាន់វិហារ ។

[ ២៧ ] គ្រានោះឯង កាលព្រះមានព្រះភាគចៀសចេញទៅមិនយូរប៉ុន្មាន ពួកភិក្ខុទាំងនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ម្នាលអាវុសោទាំង-ឡាយ ព្រះមានព្រះភាគបានសម្តែងឧទ្ទេសនេះឯង ដោយសេចក្តីបង្រួញមិនទាន់ចែកសេចក្តីដោយពិស្តារដល់យើងទាំងឡាយនៅឡើយ ទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ ( ឧទ្ទេសនោះ គឺ )

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត មិន
គប្បីប្រាថ្នាបញ្ចក្ខន្ធ ជាអនាគត ព្រោះបញ្ចក្ខន្ធណា ជា
អតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណា
ជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត
បុគ្គលណាពិចារណាឃើញច្បាស់នូវធម៌ ជាបច្ចុប្បន្នក្នុង
ទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែល
មិនរសេមរសាម មិនកម្រើកហើយ គប្បីចម្រើនឲ្យ
រឿយៗ នូវផលសមាបត្តិ ដែលមានព្រះនិព្វាននោះ
ជាអារម្មណ៍ ឯការព្យាយាមជាគ្រឿងដុតនូវកិលេស
បុគ្គលគួរធ្វើក្នុងថ្ងៃនេះឯង អ្នកណានឹងដឹងថា សេចក្តី
ស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថាការតទល់របស់

យើងចំពោះមច្ចុ ដែលមានសេនាច្រើននោះ មិនមាន
សោះឡើយ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលដែល
មានវិហារធម៌យ៉ាងនេះ មានព្យាយាមដុតកម្តៅកិលេស
ជាអ្នកមិនខ្ជិលច្រអូសអស់ថ្ងៃ និងយប់នោះឯង ថាជា
អ្នកមានរាត្រីមួយចម្រើន ។

កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងនូវឧទ្ទេសនេះដោយសេចក្តីបង្រួញ មិនចែកសេចក្តីដោយពិស្តារហើយ អ្នកណាគប្បីចែកសេចក្តីដោយពិស្តារបាន ។ គ្រានោះឯង ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះមហាកច្ចានៈមានអាយុនេះ ព្រះសាស្តាទ្រង់សរសើរផង ពួកសព្រហ្មចារីជាអ្នកចេះដឹងបានលើកតម្កើងផង ព្រះមហាកច្ចានៈមានអាយុអាចចែករំលែកនូវសេចក្តីនៃឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប មិនបានចែករំលែកសេចក្តីដោយពិស្តារនេះ ឲ្យពិស្តារបានផង បើដូច្នោះ គួរពួកយើងនាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយយើងត្រូវសួរសេចក្តីនុ៎ះនឹងព្រះមហាកច្ចានៈមានអាយុ ។

[ ២៨ ] គ្រានោះឯង ភិក្ខុទាំងនោះក៏នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ក៏រាក់ទាក់សំណេះសំណាលជាមួយនឹងព្រះមហាកច្ចានៈមានអាយុ លុះបញ្ចប់ពាក្យរាក់ទាក់សំណេះសំណាល និងពាក្យគួរឲ្យរឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក៏បាននិយាយនឹងព្រះមហាកច្ចានៈមានអាយុ យ៉ាងនេះថា

ម្នាលអាវុសោកច្ចានៈ ព្រះមានព្រះភាគទ្រង់សម្តែងនូវឧទ្ទេសនេះឯង ដោយសេចក្តីសង្ខេប មិនចែករំលែកសេចក្តីដោយពិស្តារ ដល់យើងទាំងឡាយនៅឡើយ ហើយទ្រង់ក្រោកអំពីអាសនៈចូលទៅកាន់វិហារទៅ ( ឧទ្ទេសនោះគឺ )

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត

។បេ។ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលនោះឯង

ថាជាអ្នកមានរាត្រីមួយ ដ៏ចម្រើន ។

ម្នាលអាវុសោកច្ចានៈ កាលព្រះមានបុណ្យស្តេចចេញទៅមិនយូរប៉ុន្មាន ពួកយើងខ្ញុំទាំងនោះក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគទ្រង់សម្តែងនូវឧទ្ទេសនេះឯង ដោយសេចក្តីសង្ខេប មិនបានចែកសេចក្តីដោយពិស្តារដល់យើងទាំងឡាយនៅឡើយ ហើយទ្រង់ក្រោកអំពីអាសនៈចូលទៅកាន់វិហារទៅ ( ឧទ្ទេសនោះ គឺ )

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត

។បេ។ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលនោះឯង

ថាជាអ្នកមានរាត្រីមួយ ដ៏ចម្រើន ។

ឧទ្ទេសនេះបើព្រះមានបុណ្យទ្រង់សម្តែងដោយសេចក្តីសង្ខេប មិនបានចែកសេចក្តីដោយពិស្តារ អ្នកណាហ្ន៎ គប្បីចែកសេចក្តីដោយពិស្តារបាន ម្នាលអាវុសោកច្ចានៈ ពួកយើងខ្ញុំទាំងនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះមហាកច្ចានៈមានអាយុនេះឯង ព្រះសាស្តាតែងសរសើរផង ពួកសព្រហ្មចារីជាអ្នកចេះដឹងបានលើកតម្កើងផង ព្រះមហាកច្ចានៈមានអាយុ អាចចែករំលែកសេចក្តី

នៃឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេបនេះឲ្យពិស្តារបាន ផង បើដូច្នោះគួរតែយើងនាំគ្នា ចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូល ទៅដល់ហើយ ត្រូវសួរសេចក្តីនេះនឹងព្រះមហាកច្ចានៈមានអាយុ សូមឲ្យព្រះ មហាកច្ចានៈមានអាយុ ចែកសេចក្តីឲ្យទាន ។

[ ២៩ ] ព្រះមហាកច្ចានៈពោលថា ម្នាលអាវុសោ បុរសអ្នកត្រូវការ ដោយខ្លឹមឈើ ស្វែងរកខ្លឹមឈើ ត្រាច់ស្វែងរកខ្លឹមឈើ កាលឈើមានខ្លឹម ដុះ ( នៅមុខ ) ក៏រំលងគល់រំលងដើម ហើយសម្គាល់រកខ្លឹមឯមែក និងសន្លឹក វិញ មានឧបមាយ៉ាងណាមិញ សេចក្តីនេះក៏មានឧបមេយ្យយ៉ាងនោះដែរ ព្រះ សាស្តានៅក្នុងទីចំពោះមុខរបស់លោកមានអាយុទាំងឡាយ ពួកលោករំលង ព្រះមានព្រះភាគនោះហើយ សម្គាល់សេចក្តីដែលត្រូវសួរនោះចំពោះខ្ញុំវិញ ម្នាលអាវុសោ ព្រោះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ជ្រាបនូវធម៌ដែលគួរ ជ្រាបបាន ឃើញនូវធម៌ដែលគួរឃើញបាន ទ្រង់មានបញ្ញាចក្ខុ មានញាណ ទ្រង់មានធម៌ មានគុណដ៏ប្រសើរ ទ្រង់កាន់ធម៌ ប្រព្រឹត្តធម៌ ពន្យល់សេចក្តី ទ្រង់ប្រទាននូវអមតៈ ( និព្វាន ) ជាម្ចាស់ធម៌ ជាព្រះតថាគត ឯកាលដ៏សម គួរដល់ប្រស្នានុ៎ះ គឺកាលវេលាដែលអ្នកទាំងឡាយគួរតែសួរសេចក្តីនុ៎ះនឹងព្រះ មានព្រះភាគ បើព្រះមានព្រះភាគទ្រង់ដោះស្រាយដល់អ្នកទាំងឡាយយ៉ាង ណា ចូរអ្នកទាំងឡាយ ចាំទុកសេចក្តីនោះ យ៉ាងនោះចុះ ។ ម្នាលអាវុសោ កច្ចានៈ ព្រះមានព្រះភាគ ព្រះអង្គជ្រាបនូវធម៌ដែលគួរជ្រាប ឃើញនូវធម៌ដែល គួរឃើញ មានបញ្ញាចក្ខុ មានញាណ មានធម៌ មានគុណដ៏ប្រសើរ ទ្រង់

កាន់ធម៌ ប្រព្រឹត្តធម៌ ពន្យល់សេចក្តី ប្រទានទូវអមតៈ ( និព្វាន ) ជាម្ចាស់ធម៌ ជាព្រះតថាគត ឯកាលដ៏សមគួរដល់ប្រស្នានុ៎ះ គឺកាលវេលាដែលយើងទាំងឡាយគួរតែសួរសេចក្តីនុ៎ះនឹងព្រះមានព្រះភាគ បើព្រះមានព្រះភាគទ្រង់ដោះស្រាយដល់យើងទាំងឡាយ យ៉ាងណា យើងទាំងឡាយគប្បីចាំទុកសេចក្តីនោះយ៉ាងនោះក៏ពិតមែនហើយ តែថាព្រះមហាកច្ចានៈមានអាយុ ព្រះសាស្តាតែងសរសើរផង ពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹងតែងលើកតម្កើងផង មួយទៀត ព្រះមហាកច្ចានៈមានអាយុ លោកអាចចែកសេចក្តីនៃឧទ្ទេសដែលព្រះមានព្រះភាគសម្តែងហើយដោយសេចក្តីសង្ខេប មិនទាន់ចែករំលែកសេចក្តីដោយពិស្តារនេះ ឲ្យពិស្តារបានផង សូមព្រះមហាកច្ចានៈមានអាយុកុំធ្វើឲ្យយឺតយូរឡើយ សូមចែកឲ្យទាន ។ ព្រះមហាកច្ចានៈតបថា ម្នាលអាវុសោ បើដូច្នោះ លោកទាំងឡាយចូរស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ ខ្ញុំនឹងសម្តែងប្រាប់ ។ ពួកភិក្ខុទាំងនោះក៏ទទួលពាក្យរបស់ព្រះមហាកច្ចានៈមានអាយុថា ករុណា អាវុសោ ។

[ ៣០ ] ព្រះមហាកច្ចានៈមានអាយុ បានពោលពាក្យនេះថា ម្នាលអាវុសោ ព្រះមានព្រះភាគទ្រង់សម្តែងនូវឧទ្ទេសណាដល់អ្នកទាំងឡាយដោយសេចក្តីសង្ខេប មិនទាន់ចែកសេចក្តីដោយពិស្តារនៅឡើយ ស្រាប់តែទ្រង់ក្រោកអំពីអាសនៈចូលទៅកាន់វិហារ ( ឧទ្ទេសនោះ គឺ )

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត ។បេ។
មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលនោះឯង ថាជាអ្នក

មានរាត្រីមួយ ដ៏ចម្រើន ។

ម្នាលអាវុសោ កាលព្រះមានព្រះភាគ ទ្រង់សម្ដែងនូវឧទ្ទេសនេះដោយសង្ខេប មិនបានចែកសេចក្ដីឲ្យពិស្ដារ ខ្ញុំយល់សេចក្ដីពិស្ដារដូចតទៅនេះ ។

[ ៣១ ] ម្នាលអាវុសោ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើដូចម្ដេច ។ វិញ្ញាណរមែងជាប់ជំពាក់នឹងឆន្ទរាគក្នុងចក្ខុ និងរូបនោះថា អាត្មាអញ មានចក្ខុក្នុងកាលជាអតីតដូច្នេះ មានរូបដូច្នេះ បុគ្គល តែងត្រេកអរចំពោះចក្ខុ និងរូបនោះ ព្រោះវិញ្ញាណជាប់ជំពាក់ដោយឆន្ទរាគ កាលបុគ្គលត្រេកអរចំពោះចក្ខុ និងរូបនោះ ឈ្មោះថា អាឡោះអាល័យចក្ខុ និងរូបជាអតីត ។ អាត្មាអញមានសោតៈក្នុងកាលជាអតីតដូច្នេះ មានសំឡេងដូច្នេះ ... អាត្មាអញមានឃានៈក្នុងកាលជាអតីតដូច្នេះ មានក្លិនដូច្នេះ ... អាត្មាអញមានជិវ្ហាក្នុងកាលជាអតីតដូច្នេះ មានរសដូច្នេះ ... អាត្មាអញមានកាយក្នុងកាលជាអតីតដូច្នេះ មានផោដ្ឋព្វៈដូច្នេះ ... អាត្មាអញមានចិត្តក្នុងកាលជាអតីតដូច្នេះ មានធម្មារម្មណ៍ដូច្នេះ វិញ្ញាណរមែងជាប់ជំពាក់នឹងឆន្ទរាគ ក្នុងចិត្ត និងធម្មារម្មណ៍នោះដូច្នេះ បុគ្គលរមែងត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ព្រោះវិញ្ញាណជាប់ជំពាក់នឹងឆន្ទរាគ កាលបុគ្គលត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថា នៅអាឡោះអាល័យចិត្ត និងធម្មារម្មណ៍ជាអតីត ។ ម្នាលអាវុសោ បុគ្គលនៅអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

[ ៣២ ] ម្នាលអាវុសោ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើដូចម្ដេច ។ វិញ្ញាណរមែងមិនជាប់ជំពាក់នឹងឆន្ទរាគក្នុងចក្ខុ និងរូបនោះថា

អាត្មាអញមានចក្ខុក្នុងកាលជាអតីតដូច្នេះ មានរូបដូច្នេះ បុគ្គលរមែងមិនត្រេកអរចំពោះចក្ខុ និងរូបនោះ ព្រោះវិញ្ញាណមិនបានជាប់ជំពាក់នឹងឆន្ទរាគ កាលបុគ្គលមិនត្រេកអរចំពោះចក្ខុ និងរូបនោះ ឈ្មោះថា មិនបានអាឡោះអាល័យចក្ខុ និងរូបជាអតីត ។ អាត្មាអញមានសោតៈក្នុងកាលជាអតីតដូច្នេះ មានសំឡេងដូច្នេះ ... អាត្មាអញមានឃានៈក្នុងកាលជាអតីតដូច្នេះ មានក្លិនដូច្នេះ ... អាត្មាអញមានជិវ្ហាក្នុងកាលជាអតីតដូច្នេះ មានរសដូច្នេះ ... អាត្មាអញមានកាយក្នុងកាលជាអតីតដូច្នេះ មានផោដ្ឋព្វៈដូច្នេះ ... វិញ្ញាណរមែងមិនជាប់ជំពាក់ដោយឆន្ទរាគក្នុងចិត្ត និងធម្មារម្មណ៍នោះថា អាត្មាអញមានចិត្តក្នុងកាលជាអតីតដូច្នេះ មានធម្មារម្មណ៍ដូច្នេះ បុគ្គលមិនត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ព្រោះវិញ្ញាណមិនជាប់ជំពាក់ដោយឆន្ទរាគ កាលបុគ្គលមិនត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថា មិនអាឡោះអាល័យចិត្ត និងធម្មារម្មណ៍ជាអតីត ។ ម្នាលអាវុសោ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីតយ៉ាងនេះឯង ។

[ ៣៣ ] ម្នាលអាវុសោ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។ បុគ្គលតម្កល់ចិត្ត ដើម្បីការបាននូវរបស់ដែលមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានចក្ខុដូច្នេះ មានរូបដូច្នេះ ព្រោះការតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលត្រេកអរចំពោះចក្ខុ និងរូបនោះ កាលបុគ្គលត្រេកអរចំពោះចក្ខុ និងរូបនោះ ឈ្មោះថា ប្រាថ្នានូវចក្ខុ និងរូបជាអនាគត ។ ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានសោតៈដូច្នេះ មានសំឡេងដូច្នេះ ...

ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានឃានៈដូច្នេះ មានក្លិនដូច្នេះ ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានជិវ្ហាដូច្នេះ មានរសដូច្នេះ ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានកាយដូច្នេះ មានផោដ្ឋព្វៈដូច្នេះ ... បុគ្គលតម្កល់ចិត្ត ដើម្បីការបាននូវចិត្ត និងធម្មារម្មណ៍ដែលមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានចិត្តដូច្នេះ មានធម្មារម្មណ៍ដូច្នេះ ព្រោះការតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលនោះត្រេកអរចំពោះចិត្ត និងធម្មា-រម្មណ៍នោះ កាលបុគ្គលត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថា ប្រាថ្នានូវចិត្ត និងធម្មារម្មណ៍ជាអនាគត ។ ម្នាលអាវុសោ បុគ្គលប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត យ៉ាងនេះឯង ។

[ ៣៤ ] ម្នាលអាវុសោ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។ បុគ្គលមិនបានតម្កល់ចិត្តដើម្បីការបាននូវរបស់ដែលខ្លួនមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានចក្ខុដូច្នេះ មានរូបដូច្នេះ ព្រោះការមិនបានតម្កល់ចិត្តជាបច្ច័យ នាំឲ្យបុគ្គលលែងត្រេកអរចំពោះចក្ខុ និងរូបនោះ កាលបុគ្គលលែងត្រេកអរ ចំពោះចក្ខុ និងរូបនោះ ឈ្មោះថា មិនប្រាថ្នានូវចក្ខុ និងរូបជាអនាគត ។ ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានសោតៈដូច្នេះ មានសំឡេងដូច្នេះ ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានឃានៈដូច្នេះ មានក្លិនដូច្នេះ ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានជិវ្ហាដូច្នេះ មានរសដូច្នេះ ... ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានកាយដូច្នេះ មានផោដ្ឋព្វៈដូច្នេះ ... បុគ្គល មិនបានតម្កល់ចិត្តទុក

ដើម្បីការបាននូវចិត្ត និងធម្មារម្មណ៍ដែលមិនទាន់បានថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានចិត្តដូច្នេះ មានធម្មារម្មណ៍ដូច្នេះ ព្រោះការមិនបានតម្កល់ចិត្តទុកជាបច្ច័យ នាំឲ្យបុគ្គលលែងត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ កាលបុគ្គលលែងត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថា មិនប្រាថ្នានូវចិត្ត និងធម្មារម្មណ៍ជាអនាគត ។ ម្នាលអាវុសោ បុគ្គលមិនប្រាថ្នានូវបញ្ចក្ខន្ធជាអនាគត យ៉ាងនេះឯង ។

[ ៣៥ ] ម្នាលអាវុសោ បុគ្គលរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្ដេច ។ ម្នាលអាវុសោ ចក្ខុ និងរូបទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងជាប់ជំពាក់នឹងឆន្ទរាគ ក្នុងចក្ខុ និងរូបជាបច្ចុប្បន្ននោះឯង បុគ្គលត្រេកអរចំពោះចក្ខុ និងរូបនោះ ព្រោះវិញ្ញាណជាប់ជំពាក់នឹងឆន្ទរាគ កាលបុគ្គលត្រេកអរចំពោះចក្ខុ និងរូបនោះ ឈ្មោះថា រសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ ត្រចៀក និងសំឡេង ... ម្នាលអាវុសោ ច្រមុះ និងក្លិន ... ម្នាលអាវុសោ អណ្ដាត និងរស ... ម្នាលអាវុសោ កាយ និងផោដ្ឋព្វៈ ... ម្នាលអាវុសោ ចិត្ត និងធម្មារម្មណ៍ទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងជាប់ជំពាក់នឹងឆន្ទរាគ ក្នុងចិត្ត និងធម្មារម្មណ៍ជាបច្ចុប្បន្ននោះឯង បុគ្គលរមែងត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍នោះ ព្រោះវិញ្ញាណជាប់ជំពាក់នឹងឆន្ទរាគ កាលបុគ្គលត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍ ជាបច្ចុប្បន្ននោះ ឈ្មោះថា រសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ បុគ្គលរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[ ៣៦ ] ម្នាលអាវុសោ បុគ្គលមិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលអាវុសោ ចក្ខុ និងរូបទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណមិនជាប់ជំពាក់នឹងឆន្ទរាគ ក្នុងចក្ខុ និងរូបជាបច្ចុប្បន្ននោះឯង បុគ្គលមិនត្រេកអរចំពោះចក្ខុ និងរូបនោះ ព្រោះវិញ្ញាណមិនជាប់ជំពាក់នឹងឆន្ទរាគ កាលបុគ្គលមិនត្រេកអរចំពោះចក្ខុ និងរូបនោះ ឈ្មោះថា មិនរសេមរសាម ក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ ត្រចៀក និងសំឡេង ... ម្នាលអាវុសោ ច្រមុះ និងក្លិន ... ម្នាលអាវុសោ អណ្តាត និងរស ... ម្នាលអាវុសោ កាយ និងផោដ្ឋព្វៈ ... ម្នាលអាវុសោ ចិត្ត និងធម្មារម្មណ៍ទាំង ២ នេះ ជាបច្ចុប្បន្ន វិញ្ញាណរមែងមិនជាប់ជំពាក់នឹងឆន្ទរាគ ក្នុងចិត្ត និងធម្មារម្មណ៍ជាបច្ចុប្បន្ននោះឯង បុគ្គលមិនត្រេកអរចំពោះចិត្ត និងធម្មារម្មណ៍ ជាបច្ចុប្បន្ននោះ ព្រោះវិញ្ញាណមិនជាប់ជំពាក់នឹងឆន្ទរាគ កាលបុគ្គលមិនត្រេកអរ ចំពោះចិត្ត និងធម្មារម្មណ៍នោះ ឈ្មោះថា មិនរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន ។ ម្នាលអាវុសោ បុគ្គលមិនរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[ ៣៧ ] ម្នាលអាវុសោ ត្រង់ដែលព្រះមានព្រះភាគ ត្រាស់សម្តែងនូវឧទ្ទេសដោយសេចក្តីសង្ខេប មិនបានចែករំលែកសេចក្តីដោយពិស្តារ ដល់អ្នកទាំងឡាយ ហើយទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ ( ឧទ្ទេសនោះគឺ )

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត
។បេ។ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលនោះឯង

ថាជាអ្នកមានរាត្រីមួយ ដ៏ចម្រើន ។

ម្នាលអាវុសោ ឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប មិនបានចែកសេចក្តីដោយពិស្តារនេះឯង ខ្ញុំយល់សេចក្តីដោយពិស្តារយ៉ាងនេះ តែប្រសិនបើលោកមានអាយុប្រាថ្នា ត្រូវចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរបញ្ជាក់សេចក្តីនុ៎ះ ហើយត្រូវចាំទុកសេចក្តីនោះ តាមទំនងដែលព្រះមានព្រះភាគ ទ្រង់ដោះស្រាយយ៉ាងនោះចុះ ។

[ ៣៨ ] គ្រានោះឯង ពួកភិក្ខុទាំងនោះ ក៏ត្រេកអរអនុមោទនានឹងភាសិតរបស់ព្រះមហាកច្ចាយនៈមានអាយុ ហើយក្រោកអំពីអាសនៈ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយ អង្គុយក្នុងទីសមគួរ ។ លុះពួកភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួរ ហើយ បានក្រាបទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងនូវឧទ្ទេសណា ដោយសេចក្តីសង្ខេប មិនទាន់បានចែករំលែកសេចក្តីដោយពិស្តារនៅឡើយ ហើយទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារទៅ ( ឧទ្ទេសនោះ គឺ )

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត
។បេ។ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលនោះឯង
ថាជាអ្នកមានរាត្រីមួយ ដ៏ចម្រើន ។

បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះមានព្រះភាគ ស្តេចចេញទៅមិនយូរប៉ុន្មាន យើងខ្ញុំទាំងនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោ ព្រះមាន

ព្រះភាគ ទ្រង់ត្រាស់សម្តែងនូវឧទ្ទេសនេះឯង ដោយសេចក្តីសង្ខេប មិនទាន់ចែកសេចក្តីដោយពិស្តារនៅឡើយ ហើយទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ ( ឧទ្ទេសនោះ គឺ )

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីតទេ
មិនគប្បីប្រាថ្នាបញ្ចក្ខន្ធ ជាអនាគតទេ ព្រោះថា
បញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅ
ហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះមិន
ទាន់មកដល់ មួយទៀត បុគ្គលណាឃើញច្បាស់ នូវ
ធម៌ជាបច្ចុប្បន្នក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់
នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកម្រើក
ហើយ ត្រូវចម្រើនឲ្យរឿយៗ នូវផលសមាបត្តិដែល
មានព្រះនិព្វាននោះ ជាអារម្មណ៍ ឯការព្យាយាមដុត
កម្តៅកិលេស បុគ្គលគួរតែធ្វើក្នុងថ្ងៃនេះឯង នរណា
នឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះ
ថា ការតទល់របស់យើងចំពោះមច្ចុ ដែលមានសេនា
ច្រើននោះ មិនមានឡើយ មុនីជាអ្នកស្ងប់ទុក្ខ តែង
ហៅបុគ្គលដែលមានវិហារធម៌យ៉ាងនេះ មានព្យាយាម
ដុតកម្តៅកិលេស ជាអ្នកមិនខ្ជិលច្រអូសអស់ថ្ងៃ និង
យប់នោះឯង ថាជាអ្នកមានរាត្រីមួយ ដ៏ចម្រើន ។

នរណាហ្ន៎ គប្បីចែករំលែកសេចក្តីនៃឧទ្ទេស ដែលព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងដោយសង្ខេប ទ្រង់មិនទាន់ចែកសេចក្តីដោយពិស្តារនេះ ឲ្យពិស្តារបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ព្រះមហាកច្ចានៈមានអាយុនេះឯង ព្រះសាស្តាតែងសរសើរផង ពួកសព្រហ្មចារីបុគ្គលជាអ្នកចេះដឹង តែងលើកតម្កើងផង ព្រះមហាកច្ចានៈមានអាយុ អាចចែកសេចក្តីនៃឧទ្ទេស ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់សម្តែងដោយសង្ខេប មិនទាន់ចែកសេចក្តីដោយពិស្តារនេះ ឲ្យពិស្តារបានផង បើដូច្នោះ គួរពួកយើងចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ពួកយើងគប្បីសួរបញ្ហាក់សេចក្តីនុ៎ះ នឹងព្រះមហាកច្ចានៈមានអាយុចុះ បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះ ពួកខ្ញុំព្រះអង្គ ក៏នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះទៅដល់ហើយ បានសួរបញ្ជាក់សេចក្តីនុ៎ះនឹងព្រះមហាកច្ចានៈមានអាយុ បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាកច្ចានៈមានអាយុ ក៏បានចែកសេចក្តីដោយអាការទាំងឡាយនេះ ដោយបទទាំងឡាយនេះ ដោយព្យញ្ជនៈទាំងឡាយនេះ ដល់ពួកខ្ញុំព្រះអង្គទាំងនោះ ។

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈមានប្រាជ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ ប្រសិនបើអ្នកទាំងឡាយ សួរបញ្ជាក់សេចក្តីនុ៎ះនឹងតថាគត តថាគតក៏នឹងដោះស្រាយសេចក្តីនោះតាមទំនងដែលមហាកច្ចានៈដោះស្រាយយ៉ាងនោះដែរ សេចក្តីនៃភាសិតនោះដូច្នោះមែនហើយ ចូរអ្នកទាំងឡាយ ចាំទុកយ៉ាងនេះចុះ ។ លុះព្រះមាន

ព្រះភាគ ត្រាស់ភាសិតនោះចប់ហើយ ពួកភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

## មហាកច្ចានភទ្ទេករត្តសូត្រទី ៣ ចប់

# អដ្ឋកថា

## មហាកច្ចានភទ្ទេករត្តសូត្រ

[ ២៣ ] មហាកច្ចានភទ្ទេករត្តសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **តបោទារាមេ** សេចក្តីថា ក្នុងអារាមមានឈ្មោះយ៉ាងនេះ ដោយអំណាចនៃស្រះឈ្មោះតបោទៈ គឺមានទឹកក្តៅ ។ បានឮថា ខាងក្រោមវេភារបព៌ត មានពិភពនាគប្រមាណ ៥០០ យោជន៍របស់នាគ ដែលនៅក្នុងផែនដីទាំងឡាយ ដូចគ្នានឹងស្ថានទេវលោកដែរ ដល់ព្រមដោយផ្ទៃដែលសម្រេចដោយកែវមណី និងឧទ្យាន ដែលជាទីមនោរម្យទាំងឡាយ ។ ក្នុងទីលេងរបស់របស់នាគទាំងឡាយ ក្នុងពិភពនាគនោះ មានស្រះទឹកធំ ក៏ឈ្មោះតបោទា មានទឹកក្តៅហូរចេញអំពីស្រះនោះ ។ ព្រោះហេតុអ្វី ទើបទឹកនោះទៅជាដូច្នេះ ។ បានឮថា លោកនៃមហាប្រេតព័ទ្ធជុំវិញក្រុងរាជគ្រឹះ ។ ស្ទឹងតបោទានេះមកក្នុងចន្លោះលោហកុម្ភីនរកទាំង ២ ក្នុងមហាបេតលោកនោះ ព្រោះដូច្នោះ ទើបស្ទឹងតបោទានោះក្តៅហូរមក សមដូចព្រះតម្រាស់ ដែលព្រះមានព្រះភាគត្រាស់ក្នុងវិនយបិដក មហាវិភង្គ ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ស្ទឹងតបោទានេះ ហូរមកអំពីអន្លង់ទឹកណា អន្លង់នោះ មានទឹកថ្លា ទឹកត្រជាក់ ទឹកឆ្ងាញ់ ទឹកស្អាត មានកំពង់ដ៏ល្អ គួរជាទីរីករាយ មានត្រី និងអណ្តើកដ៏ច្រើន មានទាំងផ្កាឈូកប៉ុនៗកង់ ( នៃរថ ) រីកស្គុសស្គាយ ម្នាលភិក្ខុទាំងឡាយ ប៉ុន្តែស្ទឹងតបោទានេះ មកតាមចន្លោះនៃមហានរកទាំងពីរ ព្រោះហេតុនោះ បានជាស្ទឹងតបោទានេះ មានទឹកក្តៅហូរ

មក ដូច្នេះ ។ ស្រះធំកើតខាងមុខអារាមនេះ ។ ដោយអំណាចនៃឈ្មោះស្រះទឹកធំនោះ ទើបវិហារនេះ ហៅថា តបោទារាម ។

[ ២៤ ] បទថា **សមិទ្ធិ** សេចក្តីថា អត្តភាពរបស់ព្រះថេរៈនោះល្អិតល្អន់ មានរូបស្អាត គួរជ្រះថ្លា ព្រោះដូច្នោះ ទើបដល់នូវការរាប់ថា សមិទ្ធិ ។ បទថា **អាទិព្រហ្មចរិយកោ** បានដល់ ជាខាងដើមនៃមគ្គព្រហ្មចរិយៈ គឺបដិបទាក្នុងចំណែកខាងដើម ។

[ ២៦ ] បទថា **ឥធំ វត្វា សុគតោ វុដ្ឋាយាសនា** ជាដើម គប្បីឲ្យពិស្តារដោយន័យដែលពោលហើយ ក្នុងមធុបិណ្ឌកសូត្រ ។

[ ៣១ ] បទថា **ឥតិ មេ ចក្ខុំ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់តាំងមាតិកាដោយអំណាចនៃអាយតនៈ ១២ ក្នុងសូត្រនេះ ព្រះមានព្រះភាគទ្រង់ធ្វើមាតិកា និងវិភង្គ ដោយអំណាចនៃខន្ធ ៥ ក្នុង ៣ សូត្រនេះ គឺក្នុងសូត្រ ២ ដំបូង និង ១ សូត្រខាងចុង ដែលជាសូត្រទី ៤ តែក្នុងសូត្រនេះ ឯព្រះថេរៈបានន័យថា **មាតិកាវ ឋបិតា** ទើបពោលយ៉ាងនេះ ដើម្បីចែកអាយតនៈ ១២ ។ ព្រះថេរៈ កាលបានន័យនេះ បានធ្វើការៈធ្ងន់ គឺសម្តែងស្នាមជើងក្នុងទីដែលមិនមានស្នាមជើង ធ្វើស្នាមជើងក្នុងអាកាស ដោយហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សំដៅដល់ព្រះសូត្រនេះឯង ទ្រង់តាំងព្រះថេរៈក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈ ជាកំពូលនៃភិក្ខុទាំងឡាយ ដែលជាសាវ័ករបស់តថាគត ដែលចែកអត្ថនៃភាសិតដោយសង្ខេប ឲ្យពិស្តារបាន ។

ក្នុងសូត្រនេះ បទថា **ចក្ខុំ** បានដល់ ចក្ខុបសាទ ។ បទថា **រូបា** បានដល់ រូបទាំងឡាយ ដែលមានសមុដ្ឋាន ៤ គប្បីជ្រាបអាយតនៈដ៏សេស ដោយន័យនេះ ។ បទថា **វិញ្ញាណំ** បានដល់ វិញ្ញាណដែលទៀង ។

[ ៣២ ] បទថា **តទភិនន្ទតិ** សេចក្តីថា ត្រេកអរក្នុងចក្ខុ និងរូបនោះ ដោយអំណាចនៃតណ្ហា និងទិដ្ឋិ ។ បទថា **អន្វាគមេតិ** សេចក្តីថា ទៅតាមដោយតណ្ហា និងទិដ្ឋិទាំងឡាយ ។ ក្នុងបទថា **ឥតិ មេ មនោ អតីតមទ្ធានំ អហោសិ ឥតិ ធម្មា** នោះ បទថា **មនោ** បានដល់ ភវង្គចិត្ត ។ បទថា **ធម្មា** បានដល់ ធម្មារម្មណ៍ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

[ ៣៣ ] បទថា **បណិទហតិ** គឺតាំងទុកដោយអំណាចនៃការប្រាថ្នា ។ បទថា **បណិធានប្បច្ចយា** បានដល់ ព្រោះតាំងសេចក្តីប្រាថ្នា គឺព្រោះហេតុ ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ។

**អដ្ឋកថា មហាកច្ចានភទ្ទេករត្តសូត្រ ចប់**

**សូត្រទី ៣ ចប់**

# សុត្តន្តបិដក

## លោមសកង្គិយសូត្រទី ៤

[ ៤០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះលោមសកង្គិយៈមានអាយុ នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។

គ្រានោះឯង ទេវបុត្រឈ្មោះចន្ទនៈ នាកាលរាត្រីបឋមយាមកន្លងហើយ មានរស្មីដ៏រុងរឿង ញុំាងនិគ្រោធារាមទាំងមូលឲ្យរុងរឿង បានចូលទៅរកព្រះលោមសកង្គិយៈមានអាយុ លុះចូលទៅដល់ហើយ បានឋិតនៅក្នុងទីសមគួរ ។

[ ៤១ ] លុះចន្ទនទេវបុត្រ ឋិតនៅក្នុងទីសមគួរហើយ បានពោលពាក្យនេះនឹងព្រះលោមសកង្គិយៈមានអាយុថា បពិត្រភិក្ខុ លោកចាំនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តៈ ដែរឬទេ ។ ព្រះលោមសកង្គិយៈតបថា ម្នាលអាវុសោ យើងមិនបានចាំនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តៈទេ ម្នាលអាវុសោ ចុះអ្នកចាំនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តៈឬ ។ បពិត្រភិក្ខុ ខ្ញុំក៏មិនចាំនូវឧទ្ទេសនិងវិភង្គនៃភទ្ទេករត្តៈដែរ បពិត្រភិក្ខុ ចុះលោកចាំនូវភទ្ទេករត្តិគាថាទាំងឡាយឬ ។ ម្នាលអាវុសោ យើងមិនចាំនូវភទ្ទេករត្តិគាថាទាំងឡាយទេ ម្នាលអាវុសោ ចុះអ្នកចាំនូវភទ្ទេករត្តិគាថាទាំងឡាយឬ ។ បពិត្រភិក្ខុ ខ្ញុំចាំភទ្ទេករត្តិគាថាទាំងឡាយ ។ ម្នាលអាវុសោ ចុះអ្នកចាំភទ្ទេករត្តិគាថាទាំងឡាយ ដោយប្រការដូចម្តេច ។

[ ៤២ ] បពិត្រភិក្ខុ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅលើបណ្ឌុកម្ពលសិលា ទៀបដើមបារិច្ឆត្តកព្រឹក្ស ក្នុងឋានតាវត្តិង្សទេវលោក ។ គ្រានោះ ព្រះមានព្រះភាគ បានទ្រង់ភាសិតនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តៈ ដល់ពួកទេវតា នាឋានតាវត្តិង្សថា

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត មិនគប្បីប្រាថ្នាបញ្ចក្ខន្ធ ជាអនាគត ព្រោះថា បញ្ចក្ខន្ធណា ជាអតីត បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណា ជាអនាគត បញ្ចក្ខន្ធនោះ ក៏មិនទាន់មកដល់ មួយទៀត បុគ្គលណាឃើញច្បាស់នូវធម៌ កើតឡើងចំពោះមុខ ក្នុងទីនោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិនរសេមរសាម មិនកម្រើកហើយ គួរចម្រើនឲ្យរឿយៗ នូវផលសមាបត្តិ ដែលមានព្រះនិព្វាននោះជាអារម្មណ៍ ឯសេចក្តីព្យាយាម បុគ្គលគួរធ្វើក្នុងថ្ងៃនេះ នរណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើង ចំពោះមច្ចុដែលមានសេនាច្រើន មិនមានឡើយ មុនីជាអ្នកស្ងប់ទុក្ខ តែងហៅបុគ្គលអ្នកមានព្យាយាម មិនខ្ជិលច្រអូសទាំងថ្ងៃទាំងយប់ នៅដោយសេចក្តីមិនប្រមាទយ៉ាងនេះ ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

[ ៤៣ ] បពិត្រភិក្ខុ ខ្ញុំចាំនូវភទ្ទេករត្តិគាថាទាំងឡាយ ដោយប្រការយ៉ាងនេះឯង បពិត្រភិក្ខុ ចូរលោករៀននូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តិគាថាចុះ បពិត្រភិក្ខុ ចូរលោកទន្ទេញនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តិគាថាចុះ បពិត្រភិក្ខុ ចូរលោកចាំទុកនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តិគាថាចុះ បពិត្រភិក្ខុ ព្រោះថា ឧទ្ទេស និងវិភង្គនៃភទ្ទេករត្តិគាថា ដែលប្រកបដោយប្រយោជន៍ ចាត់ទុកថា ជាអាទិព្រហ្មចរិយៈ ( ព្រហ្មចរិយៈខាងដើម ) ។ ចន្ទនទេវបុត្របានពោលពាក្យនេះ លុះពោលពាក្យនេះចប់ហើយ ក៏បាត់ក្នុងទីនោះទៅ ។

[ ៤៤ ] គ្រានោះ ព្រះលោមសកង្គិយៈមានអាយុ កាលកន្លងរាត្រីនោះហើយ រៀបចំសេនាសនៈ កាន់បាត្រ និងចីវរ ហើយចៀសចេញទៅកាន់ចារិកក្នុងក្រុងសាវត្ថី ។ កាលលោកត្រាច់ទៅកាន់ចារិកដោយលំដាប់ ក៏ចូលទៅគាល់ព្រះមានព្រះភាគ ក្នុងវត្តជេតពនរបស់អនាថបិណ្ឌិក ទៀបក្រុងសាវត្ថី លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះលោមសកង្គិយៈមានអាយុ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សម័យមួយ ខ្ញុំព្រះអង្គនៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងដែនសក្កៈ បពិត្រព្រះអង្គដ៏ចម្រើន គ្រានោះឯង នាកាលរាត្រីបឋមយាមកន្លងហើយ មានទេវបុត្រមួយអង្គ មានរស្មីដ៏រុងរឿង ញុំាងនិគ្រោធារាមទាំងមូលឲ្យភ្លឺច្បាស់ ហើយចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ហើយ ទើបឋិតនៅក្នុងទីសមគួរ បពិត្រព្រះអង្គ លុះទេវបុត្រនោះ ឋិតនៅក្នុងទីសមគួរហើយ ទើបបានពោល

ពាក្យនេះនឹងខ្ញុំព្រះអង្គ យ៉ាងនេះថា បពិត្រភិក្ខុ លោកចាំនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តៈឬទេ កាលទេវបុត្រនោះសួរយ៉ាងនេះហើយ បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបានពោលនឹងទេវបុត្រនោះ យ៉ាងនេះថា ម្នាលអាវុសោ យើងមិនចាំនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តៈទេ ម្នាលអាវុសោ ចុះអ្នកចាំនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តៈឬ បពិត្រភិក្ខុ ខ្ញុំមិនចាំនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តៈទេ បពិត្រភិក្ខុ ចុះលោកចាំនូវភទ្ទេករត្តិគាថាទាំងឡាយឬ ម្នាលអាវុសោ យើងមិនចាំនូវភទ្ទេករត្តិគាថាទាំងឡាយទេ ម្នាលអាវុសោ ចុះអ្នកចាំនូវភទ្ទេករត្តិ-គាថាទាំងឡាយឬ បពិត្រភិក្ខុ ខ្ញុំចាំនូវភទ្ទេករត្តិគាថាទាំងឡាយ ម្នាលអាវុសោ ចុះអ្នកចាំនូវភទ្ទេករត្តិគាថាទាំងឡាយ ដោយប្រការដូចម្តេច បពិត្រភិក្ខុ សម័យមួយ ព្រះមានព្រះភាគ ស្តេចគង់នៅលើបណ្ឌុកម្ពលសិលា ទៀបដើមបារិច្ឆត្តកព្រឹក្ស ក្នុងឋានតាវត្តិង្សទេវលោក គ្រានោះ ព្រះមានព្រះភាគបានភាសិតនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តៈ ដល់ពួកទេវតាឋានតាវត្តិង្សថា

បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត
។បេ។ មុនីដែលជាអ្នកស្ងប់រម្ងាប់ តែងហៅបុគ្គល
នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

បពិត្រភិក្ខុ ខ្ញុំចាំនូវភទ្ទេករត្តិគាថាទាំងឡាយ ដោយប្រការយ៉ាងនេះ បពិត្រភិក្ខុ ចូរលោករៀននូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តិគាថា បពិត្រភិក្ខុ ចូរលោកទន្ទេញនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តិគាថា បពិត្រភិក្ខុ ចូរលោកចាំទុកនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តិគាថា បពិត្រភិក្ខុ ព្រោះថា ឧទ្ទេស និងវិភង្គ

នៃភទ្ទេករត្តិគាថា ប្រកបដោយប្រយោជន៍ ចាត់ថាជាអាទិព្រហ្មចរិយៈ ។ បពិត្រព្រះអង្គដ៏ចម្រើន ទេវបុត្រនោះ បានពោលពាក្យនេះ លុះពោលពាក្យនេះចប់ហើយ ក៏បាត់ក្នុងទីនោះទៅ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សម្តែងនូវឧទ្ទេស និងវិភង្គនៃភទ្ទេករត្តិគាថា ដល់ខ្ញុំព្រះអង្គឲ្យទាន ។

[ ៤៥ ] ព្រះអង្គទ្រង់សួរថា ម្នាលភិក្ខុ ចុះលោកស្គាល់ទេវបុត្រនោះឬទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានស្គាល់ទេវបុត្រនោះទេ ។ ម្នាលភិក្ខុ ទេវបុត្រនោះឈ្មោះចន្ទនៈ ម្នាលភិក្ខុ ចន្ទនទេវបុត្របានធ្វើឲ្យជាក់ច្បាស់ យកចិត្តទុកដាក់ ប្រមូលមកនូវធម៌ទាំងអស់ដោយចិត្ត ហើយផ្ទៀងសោតប្រសាទ ប្រុងស្តាប់ធម៌ ម្នាលភិក្ខុ បើដូច្នោះ ចូរអ្នកយកចិត្តទុកដាក់ស្តាប់ចុះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុនោះទទួលព្រះពុទ្ធដីកា របស់ព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ៤៦ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា បុគ្គល
មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីត មិនគប្បីប្រាថ្នា
បញ្ចក្ខន្ធ ជាអនាគត ព្រោះថា បញ្ចក្ខន្ធណាដែលជាអតីត
បញ្ចក្ខន្ធនោះ កន្លងហួសទៅហើយ បញ្ចក្ខន្ធណាដែលជា
អនាគត បញ្ចក្ខន្ធនោះ ក៏នៅមិនទាន់មកដល់ មួយទៀត
បុគ្គលណាឃើញច្បាស់ នូវធម៌កើតឡើងចំពោះមុខ ក្នុងទី
នោះៗ បុគ្គលនោះ លុះដឹងច្បាស់នូវព្រះនិព្វាន ដែលមិន
រសេមរសោម មិនកម្រើកហើយ ចម្រើនឲ្យរឿយៗ នូវផល

សមាបត្តិដែលមានព្រះនិព្វាននោះ ជាអារម្មណ៍ ឯសេចក្តីព្យាយាម គួរធ្វើក្នុងថ្ងៃនេះ នរណានឹងដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែកបាន ព្រោះថា ការតទល់របស់យើងចំពោះមច្ចុដែលមានសេនាច្រើន មិនមានឡើយ មុនីដែលជាអ្នកស្ងប់រម្ងាប់ តែងហៅបុគ្គល អ្នកមានព្យាយាមមិនខ្ជិលច្រអូសទាំងថ្ងៃទាំងយប់ នៅដោយសេចក្តីមិនប្រមាទយ៉ាងនេះ ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

[ ៤៧ ] ម្នាលភិក្ខុ ចុះបុគ្គលអាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើដូចម្តេច ។ បុគ្គលអាឡោះអាល័យនូវតម្រេក ក្នុងទីនោះៗថា អាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអតីត អាត្មាអញមានវេទនាយ៉ាងនេះ ។បេ។ អាត្មាអញមានសញ្ញាយ៉ាងនេះ ។បេ។ អាត្មាអញមានសង្ខារយ៉ាងនេះ ។បេ។ បុគ្គលអាឡោះអាល័យនូវតម្រេកក្នុងទីនោះៗថា អាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអតីត ។ ម្នាលភិក្ខុ បុគ្គលអាឡោះអាល័យបញ្ចក្ខន្ធ ជាអតីតយ៉ាងនេះឯង ។

[ ៤៨ ] ម្នាលភិក្ខុ ចុះបុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត តើដូចម្តេច ។ បុគ្គលមិនអាឡោះអាល័យនូវតម្រេកក្នុងទីនោះៗថា អាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអតីត អាត្មាអញមានវេទនាយ៉ាងនេះ ។បេ។ អាត្មាអញមានសញ្ញាយ៉ាងនេះ ។បេ។ អាត្មាអញមានសង្ខារយ៉ាងនេះ ។បេ។ បុគ្គលមិនអាឡោះអាល័យនូវតម្រេក ក្នុងទីនោះៗថា អាត្មាអញមានវិញ្ញាណ

យ៉ាងនេះ ក្នុងកាលជាអតីត ។ ម្នាលភិក្ខុ បុគ្គលមិនអាឡោះអាល័យបញ្ចក្ខន្ធជាអតីត យ៉ាងនេះឯង ។

[ ៤៩ ] ម្នាលភិក្ខុ ចុះបុគ្គលប្រាថ្នាបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។ បុគ្គលអាឡោះអាល័យនូវតម្រេក ក្នុងទីនោះៗថា សូមឲ្យអាត្មាអញមានរូបយ៉ាងនេះ ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានវេទនាយ៉ាងនេះ ។បេ។ សូមឲ្យអាត្មាអញមានសញ្ញាយ៉ាងនេះ ។បេ។ សូមឲ្យអាត្មាអញមានសង្ខារយ៉ាងនេះ ។បេ។ បុគ្គលអាឡោះអាល័យនូវតម្រេក ក្នុងទីនោះៗថា សូមឲ្យអាត្មាអញមានវិញ្ញាណយ៉ាងនេះ ក្នុងកាលជាអនាគត ។ ម្នាលភិក្ខុ បុគ្គលប្រាថ្នាបញ្ចក្ខន្ធ ជាអនាគត យ៉ាងនេះឯង ។

[ ៥០ ] ម្នាលភិក្ខុ ចុះបុគ្គលមិនប្រាថ្នាបញ្ចក្ខន្ធជាអនាគត តើដូចម្តេច ។ បុគ្គលមិនអាឡោះអាល័យនូវតម្រេក ក្នុងទីនោះៗថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញ មានរូបយ៉ាងនេះ សូមឲ្យអាត្មាអញ មានវេទនាយ៉ាងនេះ ។បេ។ សូមឲ្យអាត្មាអញមានសញ្ញាយ៉ាងនេះ ។បេ។ សូមឲ្យអាត្មាអញមានសង្ខារយ៉ាងនេះ ។បេ។ បុគ្គលមិនអាឡោះអាល័យនូវតម្រេក ក្នុងទីនោះៗថា ក្នុងកាលជាអនាគត សូមឲ្យអាត្មាអញមានវិញ្ញាណយ៉ាងនេះ ។ ម្នាលភិក្ខុ បុគ្គលមិនប្រាថ្នាបញ្ចក្ខន្ធ ជាអនាគត យ៉ាងនេះឯង ។

[ ៥១ ] ម្នាលភិក្ខុ ចុះបុគ្គលរសេមរសាមក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុ បុថុជ្ជនក្នុងលោកនេះ ជាអ្នកមិនបានស្តាប់ មិនបានឃើញពួកព្រះអរិយៈ មិនឈ្លាសក្នុងធម៌របស់ព្រះអរិយៈ មិនបានទទួលណែនាំ

ក្នុងធម៌របស់ព្រះអរិយៈ មិនបានឃើញពួកសប្បុរស មិនឈ្លាសក្នុងធម៌របស់សប្បុរស មិនបានទទួលណែនាំក្នុងធម៌របស់សប្បុរស រមែងពិចារណាឃើញរូបថាជាខ្លួន ឃើញខ្លួនថាមានរូប ឃើញរូបថាមានក្នុងខ្លួន ឬឃើញខ្លួនថាមានក្នុងរូប នូវវេទនា ។បេ។ នូវសញ្ញា ។បេ។ នូវសង្ខារទាំងឡាយ ។បេ។ ពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន ឃើញខ្លួនថាមានវិញ្ញាណ ឃើញវិញ្ញាណថាមានក្នុងខ្លួន ឬឃើញខ្លួនថាមានក្នុងវិញ្ញាណ ។ ម្នាលភិក្ខុ បុគ្គលរសេមរសោមក្នុងពួកធម៌ ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[ ៥២ ] ម្នាលភិក្ខុ ចុះបុគ្គលមិនរសេមរសោមក្នុងពួកធម៌ជាបច្ចុប្បន្ន តើដូចម្តេច ។ ម្នាលភិក្ខុ អរិយសាវកក្នុងសាសនានេះ ជាអ្នកបានស្តាប់ បានឃើញពួកព្រះអរិយៈ ជាអ្នកឈ្លាសក្នុងធម៌របស់ព្រះអរិយៈ ជាអ្នកទទួលណែនាំដោយប្រពៃក្នុងធម៌របស់ព្រះអរិយៈ ជាអ្នកឃើញពួកសប្បុរស ជាអ្នកឈ្លាសក្នុងធម៌របស់សប្បុរស ជាអ្នកទទួលណែនាំដោយប្រពៃ ក្នុងធម៌របស់សប្បុរស មិនពិចារណាឃើញនូវរូបថាជាខ្លួន មិនឃើញខ្លួនថាមានរូប មិនឃើញរូបថាមានក្នុងខ្លួន ឬមិនឃើញខ្លួនថាមានក្នុងរូប មិនឃើញវេទនា ។បេ។ មិនឃើញសញ្ញា ។បេ។ មិនឃើញសង្ខារទាំងឡាយ ។បេ។ មិនពិចារណាឃើញវិញ្ញាណថាជាខ្លួន មិនឃើញខ្លួនថាមានវិញ្ញាណ មិនឃើញវិញ្ញាណថាមានក្នុងខ្លួន ឬមិនឃើញខ្លួនថាមានក្នុងវិញ្ញាណ ។ ម្នាលភិក្ខុ ទើបបុគ្គលមិនរសេមរសោមក្នុងពួកធម៌ជាបច្ចុប្បន្ន យ៉ាងនេះឯង ។

[ ៥៣ ] បុគ្គល មិនគប្បីអាឡោះអាល័យបញ្ចក្ខន្ធ ជា

អតីត ។បេ។ មុនីជាអ្នកស្ងប់រម្ងាប់ តែងហៅបុគ្គល
នោះឯង ថាជាអ្នកមានរាត្រីមួយដ៏ចម្រើន ។

លុះព្រះមានព្រះភាគ បានត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះលោម-សកង្គិយៈមានអាយុ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

## លោមសកង្គិយភទ្ទេករត្តសូត្រទី ៤ ចប់

# អដ្ឋកថា

## លោមសកង្គិយភទ្ទេករត្តសូត្រ

[ ៤០ ] *លោមសកង្គិយភទ្ទេករត្តសូត្រ មានពាក្យផ្តើមថា* **ឯវម្មេ សុតំ** *ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា* **លោមសកង្គិយោ** *គឺ បានឮថា លោមសកង្គិយៈនោះ ជាឈ្មោះអង្គត្ថេរ ។ ព្រះថេរៈនោះ ប្រាកដឈ្មោះថា* **លោមសកង្គិយ** *ព្រោះកាយរបស់លោកមានរោមតិចតួច ។ បទថា* **ចន្ទនោ ទេវបុត្តោ** *សេចក្តីថា បានឮថា ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមជាកស្សប ឧបាសកឈ្មោះថា* **ចន្ទនៈ** *ជាអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន បូជាព្រះរតនត្រ័យដោយបច្ច័យ ៤ ស្លាប់ទៅកើតក្នុងទេវលោក ដែលឈ្មោះថា* **ចន្ទនទេវបុត្រ** *ដោយឈ្មោះដែលមានក្នុងជាតិមុន ។*

[ ៤២ ] *បទថា* **បណ្ឌុកម្ពលសិលាយំ** *បានដល់ ក្នុងកម្ពលសិលាអាសនៈពណ៌ក្រហម ។ បានឮថា ពណ៌នៃថ្ម កម្ពលអាសនៈពណ៌ក្រហមនោះ មានពណ៌ដូចគំនរផ្កាច្បា ព្រោះដូច្នោះ ទើបហៅថា បណ្ឌុកម្ពលសិលាអាសនៈ ។ សួរថា ព្រះមានព្រះភាគ ទ្រង់ប្រថាប់ក្នុងបណ្ឌុកម្ពលសិលា-អាសនៈនោះក្នុងកាលណា ។ ឆ្លើយថា ក្នុងឆ្នាំទី ៧ បន្ទាប់អំពីការត្រាស់ដឹង ទ្រង់ធ្វើយមកប្បាដិហារ្យក្នុងកណ្តាលបរិស័ទ ប្រមាណ ១២ យោជន៍ ក្នុងថ្ងៃពេញបូណ៌មី ខែអាសាឍ ជិតក្រុងសាវត្ថី ទ្រង់ប្រថាប់គង់លើពុទ្ធាសនៈ ដែលក្រាលទុកហើយ ជិតគល់គណ្ឌាម្ពព្រឹក្ស ( ដើមស្វាយ ) ទ្រង់ដកមហាជនឲ្យចេញអំពីទុក្ខធំ ដោយព្រះធម្មទេសនា ព្រោះធម្មតាព្រះពុទ្ធទាំង-*

ឡាយ ធ្វើបាដិហារ្យហើយ មិនប្រថាប់នៅក្នុងទីកដីមនុស្ស ព្រោះដូច្នោះ ទើប ទ្រង់ធ្វើឲ្យផុតចាកជនមកគាល់ ទ្រង់ទៅចាំវស្សាក្នុងបណ្ឌុកម្ពលសិលាសនៈ ជិតដើមបារិច្ឆត្ត ក្នុងតាវត្តិង្សពិភព ប្រថាប់នៅក្នុងសម័យនោះ ។

បទថា **តត្រ ខោ ភគវា** សេចក្ដីថា ព្រះមានព្រះភាគ កាលប្រថាប់នៅ ក្នុងតាវត្តិង្សពិភពនោះ ដែលទេវតា ១ ម៉ឺនចក្រវាលដោយច្រើន មកប្រជុំ ហែហមហើយ ទ្រង់សម្ដែងអភិធម្មបិដកដល់ព្រះមាតា ឲ្យបានជាកាយសក្ខី បានត្រាស់ឧទ្ទេស និងវិភង្គរបស់បុគ្គលដែលមានរាត្រីមួយដ៏ចម្រើន តាម លំដាប់ ដើម្បីទ្រង់ឲ្យកើតសេចក្ដីសង្វេគដល់ពួកទេវតា ដែលមិនអាចចាក់ ធ្លុះនូវកថា ដែលកំណត់រូប និងអរូប ដែលជ្រាលជ្រៅល្អិត ប្រកបដោយ ត្រៃលក្ខណ៍ ។ ក្នុងទីនោះ ទេវបុត្រនេះកាលរៀន បានរៀនគាថាទាំងនេះ និងវិភង្គ តែព្រោះទេវបុត្រនោះតាំងនៅក្នុងសេចក្ដីប្រមាទ ត្រូវអារម្មណ៍ដែល ជាទិព្វទាំងឡាយគ្របសង្កត់ ទើបភ្លេចព្រះសូត្រដោយលំដាប់ ចាំបានត្រឹម តែគាថាប៉ុណ្ណោះ ដោយហេតុនោះ ទើបទេវបុត្រពោលថា បពិត្រភិក្ខុ ខ្ញុំចាំ នូវភទ្ទេករត្តិគាថាទាំងឡាយ ដោយប្រការយ៉ាងនេះឯង ។

[ ៤៣ ] ក្នុងបទថា **ឧគ្គណ្ហា ហិ ត្វំ** ជាដើម ជាអ្នកស្ដៀម អង្គុយ ស្ដាប់ ឈ្មោះថា រៀន ។ កាលធ្វើការស្វាធ្យាយដោយវាចា ឈ្មោះថា ទន្ទេញ ។ កាលប្រាប់ដល់បុគ្គលដទៃ ឈ្មោះថា ចងចាំ ។ បទដ៏សេស ក្នុងព្រះសូត្រនេះ ងាយយល់ទាំងអស់ហើយ ។

**អដ្ឋកថា លោមសកង្គិយភទ្ទេករត្តសូត្រ ចប់**

# សុត្តន្តបិដក

## ចូឡកម្មវិភង្គសូត្រទី ៥

[ ៥៤ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះ ឯង សុភមាណព ជាបុត្ររបស់តោទេយ្យព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យសំណេះសំណាល នឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យសំណេះសំណាល និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។

[ ៥៥ ] លុះសុភមាណពតោទេយ្យបុត្រ អង្គុយក្នុងទីសមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន អ្វីហ្ន៎ជាហេតុ អ្វីហ្ន៎ជាបច្ច័យ ដែលនាំឲ្យពួកមនុស្ស កាលកើតមកជាមនុស្ស មានសេចក្តីថោកទាប និងខ្ពង់ខ្ពស់ប្រាកដឡើង បពិត្រព្រះគោតមដ៏ចម្រើន ព្រោះថា មនុស្សទាំងឡាយ មានអាយុខ្លី មានអាយុវែង មានអាពាធច្រើន មានអាពាធតិច មានសម្បុរអាក្រក់ មានសម្បុរល្អ មានសក្តិតូច មានសក្តិធំ មានភោគសម្បត្តិតិច មានភោគសម្បត្តិច្រើន មានត្រកូលទាប មានត្រកូលខ្ពស់ មានប្រាជ្ញាតិច មានប្រាជ្ញាច្រើន បពិត្រព្រះគោតមដ៏ចម្រើន អ្វីហ្ន៎ជាហេតុ អ្វីហ្ន៎ជាបច្ច័យ ដែលនាំឲ្យពួកមនុស្ស កាលកើតមកជាមនុស្ស មានសេចក្តីថោកទាប និងខ្ពង់ខ្ពស់ប្រាកដឡើង ។

[ ៥៦ ] ម្នាលមាណព សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្ម

ជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរឭក កម្មតែងចែកសត្វទាំងឡាយ ដើម្បីឲ្យថោកទាប និងខ្ពង់ខ្ពស់ ។ ខ្ញុំព្រះអង្គមិនយល់សេចក្តីពិស្តារ របស់ភាសិតសង្ខេបនេះ ដែលព្រះគោតមដ៏ចម្រើន មិនទាន់ចែកសេចក្តីដោយពិស្តារបានឡើយ សូមព្រះគោតមជាម្ចាស់ ទ្រង់សម្តែងធម៌ តាមទំនងដែលខ្ញុំព្រះអង្គ នឹងយល់សេចក្តីពិស្តារ របស់ភាសិតសង្ខេបនេះ ដែលព្រះគោតមដ៏ចម្រើន មិនទាន់ចែកសេចក្តីដោយពិស្តារឲ្យទាន ។ ម្នាលមាណព បើដូច្នោះ ចូរអ្នកយកចិត្តទុកដាក់ស្តាប់ឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ សុភមាណពតោទេយ្យបុត្រ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ៥៧ ] ព្រះមានព្រះភាគ បានត្រាស់យ៉ាងនេះថា ម្នាលមាណព ស្ត្រីឬបុរសពួកខ្លះក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ ប្រព្រឹត្តអាក្រក់ មានដៃប្រឡាក់ឈាម តាំងនៅក្នុងការបៀតបៀន និងការសម្លាប់ មិនដល់នូវសេចក្តីអាណិតក្នុងពួកសត្វ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានសមាទានយ៉ាងនេះ បុគ្គលនោះ លុះរំលាយកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ប្រសិនបើរំលាយកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស ក្នុងទីណាៗ រមែងជាអ្នកមានអាយុខ្លី ។ ម្នាលមាណព បុគ្គលសម្លាប់សត្វ ជាអ្នកប្រព្រឹត្តអាក្រក់ មានដៃប្រឡាក់ដោយឈាម តាំងនៅក្នុងការបៀតបៀន និងការ

សម្លាប់ មិនដល់នូវសេចក្តីអាណិតក្នុងពួកសត្វ នេះឈ្មោះថាបដិបទាប្រព្រឹត្តទៅ ដើម្បីឲ្យមានអាយុខ្លី ។

[ ៥៨ ] ម្នាលមាណព មួយទៀត ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ លះបង់បាណាតិបាត វៀរស្រឡះចាកបាណាតិបាត មានដំបងដាក់ចុះហើយ មានសស្ត្រាដាក់ចុះហើយ ជាអ្នកមានសេចក្តីអៀនខ្មាស មានសេចក្តីអាណិតអាសូរ អនុគ្រោះដោយប្រយោជន៍ ក្នុងពួកសត្វទាំងអស់ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះរំលាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ប្រសិនបើបុគ្គលនោះ រំលាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងសុគតិ សួគ៌ ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងមានអាយុវែង ។ ម្នាលមាណព បុគ្គលដែលលះបង់បាណា-តិបាត វៀរចាកបាណាតិបាត មានដំបងដាក់ចុះហើយ មានសស្ត្រាដាក់ចុះហើយ មានសេចក្តីអៀនខ្មាស មានសេចក្តីអាណិតអាសូរ ជាអ្នកមានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ក្នុងពួកសត្វទាំងអស់ នេះឈ្មោះថាបដិបទាប្រព្រឹត្តទៅ ដើម្បីឲ្យមានអាយុវែង ។

[ ៥៩ ] ម្នាលមាណព ស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ ជាអ្នកបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែង

ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ប្រសិនបើបុគ្គល នោះ ទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើត តិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជា មនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមានអាពាធច្រើន ។ ម្នាលមាណព បុគ្គលដែលជាអ្នកបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ នេះឈ្មោះថាបដិបទាប្រព្រឹត្តទៅ ដើម្បីមាន អាពាធច្រើន ។

[ ៦០ ] ម្នាលមាណពមួយទៀត ស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ ជា អ្នកមិនបៀតបៀនសត្វទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបង ខ្លះ ដោយសស្ត្រាខ្លះ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បាន កាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ប្រសិនបើបុគ្គលនោះ ទម្លាយ រាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនបានទៅកើតក្នុងសុគតិ សួគ៌ ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជា អ្នកមានអាពាធតិច ។ ម្នាលមាណព បុគ្គលដែលជាអ្នកមិនបៀតបៀនសត្វ ទាំងឡាយ ដោយបាតដៃខ្លះ ដោយដុំដីខ្លះ ដោយដំបងខ្លះ ដោយសស្ត្រាខ្លះ នេះ ឈ្មោះថាបដិបទា ប្រព្រឹត្តទៅដើម្បីមានអាពាធតិច ។

[ ៦១ ] ម្នាលមាណព ស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ ជាអ្នកមាន សេចក្តីក្រោធ ច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត គ្រាន់តែគេស្តីថាបន្តិច

បន្ទូច ក៏ថ្នាំងថ្នាក់ ខឹង ព្យាបាទ តប-ត សម្តែងសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីមិនត្រេកអរ ឲ្យប្រាកដឡើង ។ ព្រោះអំពើនោះ ដែលខ្លួនបាន បំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបាន ត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមានសម្បុរ អាក្រក់ ។ ម្នាលមាណព បុគ្គលដែលមានសេចក្តីក្រោធ ច្រើនដោយសេចក្តី ចង្អៀតចង្អល់ចិត្ត គ្រាន់តែគេស្តីថាបន្តិចបន្តួចក៏ថ្នាំងថ្នាក់ ក្រោធ ព្យាបាទ តប-ត សម្តែងសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីមិនត្រេកអរ ឲ្យ ប្រាកដឡើង នេះឈ្មោះថាបដិបទាប្រព្រឹត្តទៅ ដើម្បីមានសម្បុរអាក្រក់ ។

[ ៦២ ] ម្នាលមាណពមួយទៀត ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេស្តីថាច្រើន ក៏មិនថ្នាំងថ្នាក់ មិនក្រោធ មិនព្យាបាទ មិនតប-ត មិនសម្តែងសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីមិនត្រេកអរឲ្យប្រាកដឡើង ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយ រាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ប្រសិនបើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនបានទៅ កើតក្នុងសុគតិ សួគ៌ ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើត

ក្នុងទីណាៗ រមែងជាអ្នកប្រកបដោយសម្បុរជ្រះថ្លា ។ ម្នាលមាណព បុគ្គល ដែលមិនមានសេចក្តីក្រោធ មិនច្រើនដោយសេចក្តីចង្អៀតចង្អល់ចិត្ត ទុកជាគេស្តីថាច្រើន ក៏មិនថ្នាំងថ្នាក់ មិនក្រោធ មិនព្យាបាទ មិនតប-ត មិនសម្តែងសេចក្តីក្រោធ សេចក្តីប្រទូស្ត និងសេចក្តីមិនត្រេកអរឲ្យប្រាកដឡើង នេះឈ្មោះថាបដិបទាប្រព្រឹត្តទៅ ដើម្បីជាអ្នកមានសម្បុរជ្រះថ្លា ។

[ ៦៣ ] ម្នាលមាណព ស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ ជាអ្នកច្រណែន តែងច្រណែន ប្រទូស្ត ចងទុកនូវសេចក្តីច្រណែន ក្នុងលាភសក្ការៈ សេចក្តីគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជារបស់បុគ្គលដទៃ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះលុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមានសក្តិតូច ។ ម្នាលមាណព បុគ្គលជាអ្នកច្រណែន តែងច្រណែន ប្រទូស្ត ចងទុកនូវសេចក្តីច្រណែន ក្នុងលាភសក្ការៈ សេចក្តីគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជារបស់បុគ្គលដទៃ នេះឈ្មោះថា បដិបទាប្រព្រឹត្តទៅ ដើម្បីមានសក្តិតូច ។

[ ៦៤ ] ម្នាលមាណព មួយទៀត ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកមិនច្រណែន រមែងមិនច្រណែន មិនប្រទូស្ត មិនចងទុកនូវសេចក្តី

ប្រណែន ក្នុងលាភសក្ការៈ សេចក្តីគោរព ការរាប់អាន ការថ្វាយបង្គំ និង ការបូជា របស់បុគ្គលដទៃ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក បើបុគ្គលនោះ ទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនបានទៅកើត ក្នុងសុគតិ សួគ៌ ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមានសក្តិធំ ។ ម្នាលមាណព បុគ្គលដែលមិនប្រណែន តែងមិនប្រណែន មិនប្រទូស្ត មិនចងទុកនូវសេចក្តីប្រណែន ក្នុងលាភៈសក្ការៈ សេចក្តីគោរព ការរាប់អាន ការថ្វាយបង្គំ និងការបូជារបស់បុគ្គលដទៃ នេះឈ្មោះថាបដិបទាប្រព្រឹត្តទៅ ដើម្បីមានសក្តិធំ ។

[ ៦៥ ] ម្នាលមាណព ស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ ជាអ្នកមិនបានឲ្យបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ទីដេក ទីអាស្រ័យ ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ប្រសិនបើបុគ្គលនោះ ទម្លាយរាងកាយស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមានភោគ-សម្បត្តិតិច ។ ម្នាលមាណព បុគ្គលដែលមិនបានឲ្យបាយ ទឹក សំពត់ យាន

ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ទីដេក ទីអាស្រ័យ ប្រទីបដល់សមណៈ ឬព្រាហ្មណ៍ នេះឯងឈ្មោះថាបដិបទាប្រព្រឹត្តទៅ ដើម្បីមានភោគសម្បត្តិតិច ។

[ ៦៦ ] ម្នាលមាណព មួយទៀត ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ជាអ្នកឲ្យបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿលាបផ្សេងៗ ទីដេក ទីអាស្រ័យ ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានសមាទានយ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក បើបុគ្គលនោះ ទម្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ មិនទៅកើតក្នុងសុគតិ សួគ៌ ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមានភោគសម្បត្តិច្រើន ។ ម្នាលមាណព បុគ្គលដែលឲ្យបាយ ទឹក សំពត់ យាន ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ទីដេក ទីអាស្រ័យ ប្រទីប ដល់សមណៈ ឬព្រាហ្មណ៍ នេះឈ្មោះថាបដិបទាប្រព្រឹត្តទៅ ដើម្បីមានភោគសម្បត្តិច្រើន ។

[ ៦៧ ] ម្នាលមាណព ស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះ ជាអ្នករឹងត្អឹងមើលងាយ មិនសំពះបុគ្គលដែលគួរសំពះ មិនក្រោកទទួលបុគ្គល ដែលគួរក្រោកទទួល មិនឲ្យអាសនៈដល់បុគ្គលដែលគួរដល់អាសនៈ មិនឲ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ មិនធ្វើសក្ការៈដល់បុគ្គលដែលគួរដល់សក្ការៈ មិនធ្វើសេចក្ដីគោរព ដល់បុគ្គលដែលគួរធ្វើសេចក្ដីគោរព មិនរាប់អានដល់បុគ្គល

ដែលគួររាប់អាន មិនបូជាដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមានត្រកូលថោកទាប ។ ម្នាលមាណព បុគ្គលដែលរឹងត្អឹង មើលងាយ មិនសំពះបុគ្គលដែលគួរសំពះ មិនក្រោកទទួលបុគ្គលដែលគួរក្រោកទទួល មិនឲ្យអាសនៈដល់បុគ្គលដែលគួរដល់អាសនៈ មិនឲ្យផ្លូវដល់បុគ្គល ដែលគួរដល់ផ្លូវ មិនធ្វើសក្ការៈ ដល់បុគ្គលដែលគួរធ្វើសក្ការៈ មិនធ្វើសេចក្តីគោរព ដល់បុគ្គលដែលគួរធ្វើសេចក្តីគោរព មិនរាប់អានបុគ្គល ដែលគួររាប់អាន មិនបូជាបុគ្គលដែលគួរបូជា នេះឈ្មោះថាបដិបទាប្រព្រឹត្តទៅ ដើម្បីមានត្រកូលថោកទាប ។

[ ៦៨ ] ម្នាលមាណព មួយទៀត ស្ត្រី ឬបុរសពួកខ្លះក្នុងលោកនេះជាអ្នកមិនរឹងត្អឹង មិនមើលងាយ សំពះបុគ្គលដែលគួរសំពះ ក្រោកទទួលបុគ្គលដែលគួរក្រោកទទួល ឲ្យអាសនៈដល់បុគ្គលដែលគួរដល់អាសនៈ ឲ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ ធ្វើសក្ការៈដល់បុគ្គលដែលគួរធ្វើសក្ការៈ ធ្វើសេចក្តីគោរព ដល់បុគ្គលដែលគួរគោរព រាប់អានបុគ្គលដែលគួររាប់អាន បូជាដល់បុគ្គលដែលគួរបូជា ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ

រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើបុគ្គលនោះ ទម្លាយរាងកាយបន្ទាប់អំពីមរណៈទៅ មិនទៅកើតក្នុងសុគតិ សួគ៌ទេវលោកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមានត្រកូលខ្ពង់ខ្ពស់ ។ ម្នាលមាណព បុគ្គលដែលមិនរឹងត្អឹង មិនមើលងាយគេ សំពះបុគ្គលដែលគួរសំពះ ក្រោកទទួលបុគ្គលដែលគួរក្រោកទទួល ឲ្យអាសនៈដល់បុគ្គលដែលគួរដល់អាសនៈ ឲ្យផ្លូវដល់បុគ្គលដែលគួរដល់ផ្លូវ ធ្វើសក្ការៈដល់បុគ្គលដែលគួរធ្វើសក្ការៈ ធ្វើសេចក្ដីគោរពដល់បុគ្គលដែលគួរធ្វើសេចក្ដីគោរព រាប់អានបុគ្គលដែលគួររាប់អាន បូជាបុគ្គលដែលគួរបូជា នេះឈ្មោះថា បដិបទា ប្រព្រឹត្តទៅដើម្បីមានត្រកូលខ្ពង់ខ្ពស់ ។

[ ៦៩ ] ម្នាលមាណព ស្រ្តី ឬបុរសពួកខ្លះក្នុងលោកនេះ ចូលទៅរកសមណៈ ឬព្រាហ្មណ៍ ហើយមិនបានសួរថា បពិត្រលោកម្ចាស់ដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើខ្ញុំធ្វើប្រព្រឹត្តទៅដើម្បីទោស ដើម្បីទុក្ខអស់កាលដ៏យូរ មួយទៀត អ្វីកាលបើខ្ញុំធ្វើប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលដ៏យូរ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានកាន់ខ្ជាប់យ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បើបុគ្គលនោះទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ មិនទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរកទេ បើបានត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ

រមែងជាអ្នកគ្មានប្រាជ្ញា ។ ម្នាលមាណព បុគ្គលដែលចូលទៅរកសមណៈ ឬព្រាហ្មណ៍ ហើយមិនបានសួរថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើខ្ញុំធ្វើប្រព្រឹត្តទៅដើម្បីទោស ដើម្បីទុក្ខអស់កាលដ៏យូរ មួយទៀត អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលដ៏យូរ នេះឈ្មោះថា បដិបទា ប្រព្រឹត្តទៅ ដើម្បីមិនមានប្រាជ្ញា ។

[ ៧០ ] ម្នាលមាណព មួយទៀត ស្ត្រី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចូលទៅជិតសមណៈ ឬព្រាហ្មណ៍ ហើយសួរថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅដើម្បីទោស ដើម្បីទុក្ខអស់កាលដ៏យូរ មួយទៀត អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខអស់កាលដ៏យូរ ។ ព្រោះអំពើនោះ ដែលខ្លួនបានបំពេញយ៉ាងនេះ បានសមាទានយ៉ាងនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក បើបុគ្គលនោះ ទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ មិនទៅកើតក្នុងសុគតិសួគ៌ទេវលោកទេ បើត្រឡប់មកកាន់ភាពជាមនុស្ស កើតក្នុងទីណាៗ រមែងជាអ្នកមានប្រាជ្ញាច្រើន ។ ម្នាលមាណព បុគ្គលដែលចូលទៅរកសមណៈ ឬព្រាហ្មណ៍ ហើយបានសួរថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល អ្វីជាអកុសល អ្វីមានទោស អ្វីឥតទោស អ្វីគួរសេព អ្វីមិនគួរសេព អ្វីកាលបើខ្ញុំធ្វើប្រព្រឹត្តទៅដើម្បីទោស ដើម្បី

សេចក្ដីទុក្ខអស់កាលដ៏យូរ មួយទៀត អ្វីកាលបើខ្ញុំធ្វើ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខអស់កាលដ៏យូរ នេះឈ្មោះបដិបទាប្រព្រឹត្តទៅដើម្បីមានប្រាជ្ញាច្រើន ។

[ ៧១ ] ម្នាលមាណព ព្រោះហេតុថា សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅឲ្យមានអាយុខ្លី រមែងនាំឲ្យមានអាយុខ្លី សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីឲ្យមានអាយុវែង រមែងនាំឲ្យមានអាយុវែង សេចក្ដីប្រតិបត្តិប្រព្រឹត្តទៅដើម្បីឲ្យមានអាពាធច្រើន រមែងនាំឲ្យមានអាពាធច្រើន សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីអាពាធតិច រមែងនាំឲ្យមានអាពាធតិច សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីឲ្យមានសម្បុរអាក្រក់ រមែងនាំឲ្យមានសម្បុរអាក្រក់ សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីជាអ្នកមានសម្បុរជ្រះថ្លា រមែងនាំឲ្យជាអ្នកមានសម្បុរជ្រះថ្លា សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីឲ្យមានសក្តិតូច រមែងនាំឲ្យមានសក្តិតូច សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីឲ្យមានសក្តិធំ រមែងនាំឲ្យមានសក្តិធំ សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីឲ្យមានភោគសម្បត្តិតិច រមែងនាំឲ្យមានភោគសម្បត្តិតិច សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីឲ្យមានភោគសម្បត្តិច្រើន រមែងនាំឲ្យមានភោគសម្បត្តិច្រើន សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីឲ្យមានត្រកូលថោកទាប រមែងនាំឲ្យមានត្រកូលថោកទាប សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីឲ្យមានត្រកូលខ្ពង់ខ្ពស់ រមែងនាំឲ្យមានត្រកូលខ្ពង់ខ្ពស់ សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីមិនមានប្រាជ្ញា រមែងនាំឲ្យមិនមានប្រាជ្ញា សេចក្ដីប្រតិបត្តិដែលប្រព្រឹត្តទៅដើម្បីឲ្យមានប្រាជ្ញាច្រើន

រមែងនាំឲ្យមានប្រាជ្ញាច្រើន ។ ម្នាលមាណព សត្វទាំងឡាយមានកម្មជារបស់ខ្លួន មានកម្មជាទាយាទ មានកម្មជាកំណើត មានកម្មជាផៅពង្ស មានកម្មជាគ្រឿងរឭក កម្មតែងចែកពួកសត្វដើម្បីឲ្យថោកទាប និងខ្ពង់ខ្ពស់ ។

[ ៧២ ] កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សុកមាណពតោទេយ្យបុត្រ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះអង្គសម្តែងហើយដោយអនេកបរិយាយយ៉ាងនេះ ( ភ្លឺច្បាស់ណាស់ ) ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬបើកបង្ហាញរបស់ដែលកំបាំង ឬក៏ប្រាប់ផ្លូវដល់មនុស្សវង្វេង ពុំនោះសោត ដូចជាគេទ្រោលប្រទីបបំភ្លឺក្នុងទីងងឹតដោយគិតថា ឲ្យពួកមនុស្សដែលមានភ្នែកភ្លឺមើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់នូវព្រះគោតមដ៏ចម្រើនផងព្រះធម៌ផង ព្រះសង្ឃផងជាទីពឹងទីរឭក សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណៈស្មើដោយជីវិត ចាប់ដើមតាំងពីថ្ងៃនេះ តរៀងទៅ ។

ចូឡកម្មវិភង្គសូត្រទី ៥ ចប់

# អដ្ឋកថា

## ចូឡកម្មវិភង្គសូត្រ

[ ៥៤ ] ចូឡកម្មវិភង្គសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងសូត្រនោះ បទថា **សុភោ** សេចក្ដីថា បានឮថា គាត់ជាបុគ្គលគួរមើល គួរជ្រះថ្លា ។ ដោយហេតុនោះ ទើបញាតិទាំងឡាយតាំងឈ្មោះគាត់ថា **សុភ:** ព្រោះគាត់មានអវយវៈស្អាត តែបានហៅគាត់ថា មាណព ក្នុងកាលដែលនៅជាកំលោះ ។ គាត់ត្រូវហៅដោយវោហារនោះឯង ទោះបីក្នុងកាលគាត់ចាស់ ។ បទថា **តោទេយ្យបុត្តោ** បានដល់ កូនរបស់ព្រាហ្មណ៍បុរោហិត របស់ព្រះបាទបសេនទិកោសល ឈ្មោះថា តោទេយ្យ ។ បានឮថា គាត់ចូលដល់នូវការរាប់ថា **តោទេយ្យ** ព្រោះជាធំនៃស្រុកឈ្មោះថា **តុទិគាម** ដែលនៅជិតក្រុងសាវត្ថី ។ គាត់មានទ្រព្យច្រើន មានសម្បត្តិដល់ទៅ ៨៧ កោដិ តែមានសេចក្ដីកំណាញ់ស្វិតស្វាញ ។ កាលនឹងឲ្យក៏គិតថា ឈ្មោះថា ការមិនអស់នៃភោគៈទាំងឡាយមិនមាន ទើបមិនឲ្យដល់បុគ្គលណាឡើយ ។ សមដូចពាក្យដែលលោកពោលថា

**អញ្ជនានំ ខយំ ទិស្វា វម្មិកានញ្ច សញ្ចយំ**
**មធូនញ្ច សមាហារំ បណ្ឌិតោ ឃរមាវសេតិ ។**

បណ្ឌិតឃើញការអស់ទៅ នៃថ្នាំបន្តក់ភ្នែកទាំងឡាយ
ការសន្សំ របស់ពួកកណ្ដៀរទាំងឡាយ និងការសាមគ្គី
នៃឃ្មុំទាំងឡាយហើយ គប្បីនៅគ្រប់គ្រងផ្ទះ ។

គាត់ឲ្យសញ្ញាយ៉ាងនេះអស់កាលយូរនោះឯង គាត់មិនឲ្យវត្ថុ សូម្បីបបរមួយត្រឡោក ឬបាយមួយវែកដល់ព្រះសម្មាសម្ពុទ្ធ ដែលប្រថាប់នៅក្នុងវិហារជិតធ្វើកាលកិរិយាដោយការលោភក្នុងទ្រព្យ ទៅកើតជាឆ្កែក្នុងផ្ទះនោះឯង ។ សុភមាណពស្រឡាញ់ឆ្កែនោះពន់ពេក ឲ្យស៊ីបាយដែលខ្លួនបរិភោគនោះឯង លើកឡើងឲ្យដេកក្នុងដំណេកដ៏ប្រសើរ ។

ថ្ងៃមួយ ព្រះមានព្រះភាគ ទ្រង់ប្រមើលមើលលោក ក្នុងសម័យទៀបភ្លឺទ្រង់ឃើញឆ្កែនោះហើយ ទ្រង់ព្រះតម្រិះថា តោទេយ្យព្រាហ្មណ៍ស្លាប់ទៅ កើតជាឆ្កែក្នុងផ្ទះខ្លួនឯង ព្រោះការជាប់ជំពាក់ក្នុងទ្រព្យ ថ្ងៃនេះ កាលតថាគតទៅកាន់ផ្ទះរបស់សុភៈ ឆ្កែឃើញតថាគតហើយ នឹងធ្វើនូវការព្រុស លំដាប់នោះតថាគតនឹងពោលពាក្យមួយដល់ឆ្កែនោះ ឆ្កែនោះនឹងដឹងថា តថាគតជាសមណគោតម ហើយទៅដេកក្នុងចង្ក្រាន ព្រោះសេចក្តីនោះជាហេតុ សុភៈនឹងមានការសន្ទនាមួយជាមួយនឹងតថាគត សុភៈស្តាប់ធម៌ហើយ នឹងតាំងនៅក្នុងសរណៈទាំងឡាយ ឯឆ្កែស្លាប់ទៅហើយ នឹងកើតក្នុងនរក ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់ដឹងមាណពតាំងនៅក្នុងសរណៈទាំងឡាយនេះហើយ ថ្ងៃនោះទ្រង់បដិបត្តិព្រះសរីរៈ យាងទៅកាន់ផ្ទះនោះ ដើម្បីបិណ្ឌបាត ដោយខណៈនោះ មាណពចេញទៅកាន់ស្រុក ។ ឆ្កែឃើញព្រះមានព្រះភាគហើយ ធ្វើការព្រុស ទៅក្បែរព្រះមានព្រះភាគ ។ ពេលនោះ ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះនឹងឆ្កែនោះថា នែតោទេយ្យ អ្នកធ្លាប់ពោលជាមួយនឹងតថាគតថា **ភោ ភោ** ទៅកើតជាឆ្កែ ឥឡូវនេះ ធ្វើការព្រុស ហើយនឹងទៅកាន់អវីចី

ដូច្នេះ ។ ឆ្កែស្តាប់ព្រះតម្រាស់នោះហើយ ដឹងថាជាសមណគោតម មានការក្តៅក្រហាយ មានកន្ទិនចុះ ទៅដេកក្នុងផេះ ក្នុងចន្លោះចង្ក្រាន ។ មនុស្សមិនអាចលើកឡើងឲ្យដេកត្រង់ដំណេកដ៏ប្រសើរបាន សុភមាណពមកហើយពោលថា អ្នកណាលើកឆ្កែនេះចុះពីដំណេក ។ មនុស្សពោលថា មិនមានអ្នកណាលើកទេ ហើយប្រាប់រឿងរ៉ាវដែលកើតមកនោះ ។ មាណពស្តាប់ហើយ ក្រោធថា ឪពុករបស់អញទៅកើតក្នុងព្រហ្មលោក មិនមានឆ្កែឈ្មោះតោទេយ្យ តែព្រះសមណគោតម ធ្វើឪពុកអញឲ្យជាសុនខ ព្រះសមណគោតមនោះ និយាយផ្តេសផ្តាស ដូច្នេះ បំណងនឹងសង្កត់សង្កិនព្រះមានព្រះភាគដោយពាក្យមិនពិត ទើបទៅកាន់វិហារ ទូលសួរប្រវត្តិនោះ ។

ព្រះមានព្រះភាគត្រាស់យ៉ាងនោះឯង ដល់សុភមាណពនោះ ដើម្បីមិនឲ្យប្រកែកគ្នា ទើបត្រាស់ថា ម្នាលមាណព ទ្រព្យដែលបិតារបស់អ្នកមិនបានប្រាប់មានឬ ។ សុភមាណពទូលថា បពិត្រព្រះគោតមដ៏ចម្រើន មានម្កុដមាសតម្លៃមួយសែន ស្បែកជើងមាសតម្លៃមួយសែន និងកហាបណៈមួយសែន ។ ព្រះមានព្រះភាគត្រាស់ថា អ្នកចូរទៅសួរសុនខនោះក្នុងវេលាឲ្យស៊ីបាយាសដែលមានទឹកតិច ហើយលើកឡើងក្នុងទីដេក ឲ្យលក់បន្តិច ឆ្កែនោះនឹងប្រាប់ទ្រព្យទាំងអស់ដល់អ្នក លំដាប់នោះ អ្នកគប្បីដឹងឆ្កែនោះថា ជាឪពុករបស់អ្នក ។ មាណពសប្បាយចិត្តដោយហេតុ ២ ប្រការ គឺបើជាការពិត អញនឹងបានទ្រព្យ បើមិនពិត អញនឹងសង្កត់សង្កិនព្រះសមណគោតមដោយពាក្យមិនពិត ដូច្នេះហើយ ទៅធ្វើយ៉ាងនោះ ។ ឆ្កែដឹងថា អញត្រូវ

មាណពនេះដឹងហើយ ធ្វើសំឡេង ហុំ ហុំ ទៅកាន់ទីដែលកប់ទ្រព្យ កាយដី ដោយជើង ហើយឲ្យសញ្ញា ។ មាណពកាន់យកទ្រព្យហើយ មានចិត្តជ្រះថ្លា ក្នុងព្រះមានព្រះភាគថា ធម្មតាទីដែលបិទបាំងទ្រព្យ ប្រាកដជារបស់ល្អិតនៅ ក្នុងរវាងបដិសន្ធិយ៉ាងនេះ នុ៎ះជាសព្វញ្ញូរបស់ព្រះសមណគោតមពិត ទើប ចងប្រស្នា ១៤ ប្រស្នា ។ បានឮថា មាណពនោះជាអ្នកបាឋកៈ ក្នុងវិជ្ជាអង្គ កាយ ដោយហេតុនោះ ទើបមាណពនោះមានការគិតថា អញមានបណ្ណាការ នេះហើយ នឹងទូលសួរបញ្ហា ជាមួយព្រះសមណគោតម ដោយការទៅលើក ទី ២ ទើបចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ ។ តែព្រះមានព្រះភាគ ទ្រង់ឆ្លើយប្រស្នាទាំងឡាយ ដែលមាណពនោះទូលសួរត្រឹមតែមួងប៉ុណ្ណោះ ទើបត្រាស់ថា **កម្មស្សកា** ជាដើម ។

[ ៥៦ ] ក្នុងពាក្យនោះ កម្មជារបស់សត្វទាំងនោះ គឺជាកណ្ឌៈរបស់ខ្លួន ព្រោះដូច្នោះ សត្វទាំងនោះ ឈ្មោះថា **កម្មស្សកា** ។ សត្វទាំងឡាយជា ទាយាទនៃកម្ម ព្រោះដូច្នោះ សត្វទាំងនោះ ឈ្មោះថា **កម្មទាយាទា** អធិប្បាយថា មានកម្មជាមត៌ក គឺជាកណ្ឌៈនៃសត្វទាំងនោះ ។ កម្មជា កំណើត គឺជាហេតុនៃសត្វទាំងនោះ ព្រោះដូច្នោះ សត្វទាំងនោះ ឈ្មោះថា **កម្មយោនិ** ។ កម្មជាផៅពង្សរបស់សត្វទាំងនោះ ព្រោះដូច្នោះ សត្វទាំងនោះ ឈ្មោះថា **កម្មពន្ធុ** អធិប្បាយថា មានកម្មជាញាតិ ។ កម្មដែលជាទីពឹង អាស្រ័យ គឺជាទីតាំងរបស់សត្វទាំងនោះ ព្រោះដូច្នោះ សត្វទាំងនោះ ឈ្មោះថា **កម្មប្បដិសរណា** ។ បទថា **យទិទំ ហីនប្បណីតតាយ** សេចក្តីថា កម្មនេះ

បែកឲ្យអាក្រក់ និងប្រណីតយ៉ាងនេះថា អ្នកអាក្រក់ អ្នកប្រណីត អ្នកមានអាយុតិច អ្នកមានអាយុវែង អ្នកមានបញ្ញាអន់ថយ អ្នកមានបញ្ញា ដូច្នេះ បុគ្គលដទៃមិនធ្វើកម្មនោះ កម្មនោះឯង រមែងបែកសត្វទាំងឡាយ ដូច្នេះ ។ មាណពមិនដឹងអត្ថនៃឧទ្ទេស ដែលទ្រង់សម្តែងខុទ្ទ ដូចគ្នានឹងចងមាត់របស់មាណណនោះ ដោយផ្ទាំងសំពត់ត្រង់មុខ ហើយដាក់របស់ផ្អែមខាងមុខ បានឮថា មាណពនោះអាស្រ័យមានះ ប្រកាន់ខ្លួនថា ជាបណ្ឌិត រមែងពិចារណាឃើញខ្លួន ។

លំដាប់នោះ ព្រះមានព្រះភាគ ដើម្បីទ្រង់កាច់បំបាក់មានះរបស់មាណពនោះ ដែលគិតថា ព្រះសមណគោតមត្រាស់អ្វី អញរមែងដឹងដល់វត្ថុដែលត្រាស់នោះឯង កុំឲ្យមានដូច្នេះ ទើបត្រាស់ធ្វើឲ្យចាក់ធ្លុះបានដោយលំបាកថា តថាគតនឹងសម្តែងធ្វើឲ្យចាក់ធ្លុះបានលំបាកតាំងអំពីខាងដើមនោះឯង បន្ទាប់ពីនោះ មាណពនឹងអារាធនាតថាគតថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមិនដឹង សូមព្រះអង្គទ្រង់សម្តែងធ្វើឲ្យប្រាកដដល់ខ្ញុំព្រះអង្គដោយពិស្តារ គ្រានោះ តថាគតនឹងសម្តែងដល់សុភមាណពក្នុងវេលាអារាធនា កាលបើដូច្នេះ ក៏នឹងជាប្រយោជន៍ដល់មាណពនោះ ដូច្នេះ ។ ឥឡូវនេះ មាណពនោះកាលនឹងប្រកាសភាពដែលខ្លួនជាអ្នកមិនចាក់ធ្លុះ ទើបទូលថា **ន ខោ អហំ** ដូច្នេះជាដើម ។

[ ៥៧ ] បទថា **សមត្តេន** បានដល់ បរិបូណ៌ ។ បទថា **សមាទិន្នេន** បានដល់ កាន់យកហើយ គឺស្ទាបអង្អែលហើយ ។ បទថា **អប្បាយុក-**

**សំវត្តនិកា ឯសា មាណវ បដិបទា យទិទំ ទាណាតិបាតី** សេចក្ដីថា កម្មក្នុងការញ៉ាំងជីវិតសត្វឲ្យធ្លាក់ចុះនេះ នុ៎ះជាបដិបទាប្រព្រឹត្តទៅដើម្បីមានអាយុខ្លី ។

បដិបទានោះ រមែងធ្វើឲ្យមានអាយុខ្លីដូចម្ដេច ។ កម្មមាន ៤ ប្រភេទ គឺឧបបីឡកកម្ម ឧបច្ឆេទកកម្ម ជនកកម្ម ឧត្ថម្ភកកម្ម ។ ឧបបីឡកកម្មក្នុងបវត្តិដែលកើតដោយកម្មដ៏មានកម្លាំង ហាក់ដូចពោលដោយអត្ថយ៉ាងនេះថា បើអញដឹងមុន មិនគប្បីឲ្យកម្មនោះកើតក្នុងទីនេះ គប្បីឲ្យឯងកើតក្នុងអបាយទាំង ៤ តែលើកទុកសិនចុះ ឯងកើតក្នុងទីណាមួយ អញនឹងបៀតបៀន កម្មដែលឈ្មោះថា ឧបបីឡកកម្មនោះ និងធ្វើឲ្យប្រាសចាករស ប្រាសចាកពូជឲ្យគ្មានតម្លៃ ចាប់ផ្ដើមអំពីនោះ នឹងធ្វើវាឲ្យមានសភាពដូច្នោះ ។ កម្មនោះបៀតបៀនដូចម្ដេច គឺនាំអន្តរាយចូលមក ញ៉ាំងភោគៈឲ្យវិនាស ។ ព្រោះកម្មនោះ ចាប់តាំងអំពីកាលដែលទារកកើតក្នុងផ្ទៃមាតា មាតារមែងមិនមានការស្រាកស្រាន្តចិត្ត ឬមិនមានសេចក្ដីសុខ និងការបៀតបៀន រមែងកើតដល់មាតា បិតា រមែងនាំអន្តរាយចូលមកយ៉ាងនេះ ។ ចាប់តាំងអំពីការដែលទារកកើតក្នុងផ្ទៃមាតា ភោគៈទាំងឡាយក្នុងផ្ទះ រមែងវិនាសដោយអំណាចនៃស្ដេចជាដើម ដូចអំបិលត្រូវទឹក ។ មេគោទាំងឡាយដែលរីតទឹកដោះដាក់ក្នុងភាជនៈ ក៏មិនមានទឹកដោះ ហ្វូងគោក៏ទៅជាកាចប្រទូស្តគ្នា ខ្វាក់ភ្នែក ពាក់ជើង រោគរាតត្បាតក្នុងក្រោលគោ បរិវារជន មានទាសៈជាដើមមិនស្ដាប់បង្គាប់ សំណាបដែលព្រោះមិនកើត សម្បូងដែលនៅក្នុងស្រុក រមែងវិនាសក្នុង

ស្រុក ដែលនៅក្នុងព្រៃក៏វិនាសក្នុងព្រៃ វត្ថុដោយគ្រាន់តែបំបាត់ការស្រេក ឃ្លាន ក៏រកបានលំបាកដោយលំដាប់ ។ គ្រឿងបរិហារគភ៌ក៏មិនមាន ។ វេលា ប្រសូតហើយ ទឹកដោះមាតាក៏រីងស្ងួត ។ ទារកកាលមិនបានបរិហារ ក៏ត្រូវ បៀតបៀន ប្រាសចាករស ស្គាំងស្គម មិនមានតម្លៃ នេះឈ្មោះថា ឧប- បីឡកកម្ម ។ ឯកាលបុគ្គលកើតហើយ ដោយកម្មដែលឲ្យមានអាយុវែង ឧបច្ឆេទកកម្មក៏ចូលកាត់ផ្តាច់អាយុ ។ ដូចបុរសធ្វើការប្បាំងនឹងគោ ៨ ក្បាល បាញ់ព្រួញ មនុស្សម្នាក់ទៀតក៏វាយព្រួញនោះ ឲ្យរបូតពីបន្ទោះធ្នូដោយដំបង ឲ្យធ្លាក់ចុះក្នុងទីនោះ យ៉ាងណា ឧបច្ឆេទកកម្មរមែងកាត់អាយុរបស់ខ្លួនដែល កើតហើយដោយកម្ម ដែលនាំឲ្យមានអាយុវែង ដូច្នោះ សេចក្តីនេះដូចម្តេច ចោរឲ្យបុគ្គលនោះចូលទៅកាន់ព្រៃ ឲ្យដើរកាត់ទឹកដែលមានត្រីកាច ឬនាំចូល ទៅកាន់ទីអន្តរាយដទៃ នេះឈ្មោះថា ឧបច្ឆេទកកម្ម ។ ឧបច្ឆេទកកម្មនោះឯង ឈ្មោះថា ឧបឃាតកកម្មដូច្នេះក៏មាន ។ ឯកម្មដែលឲ្យបដិសន្ធិ ឈ្មោះថា ជនកកម្ម កម្មដែលឧបការៈដោយការធ្វើឲ្យដល់ព្រមដោយភោគៈជាដើម ដល់ បុគ្គលដែលកើតក្នុងត្រកូលទាំងឡាយ មានត្រកូលដែលមានភោគៈតិច ជាដើម ឈ្មោះថា ឧបត្ថម្ភកកម្ម ។

កម្ម ៤ ប្រភេទនេះ កម្ម ២ ប្រភេទខាងដើម ជាអកុសលតែម្យ៉ាង ។ កម្មទាំងនោះ បាណាតិបាត រមែងប្រព្រឹត្តទៅដើម្បីមានអាយុខ្លី ដោយភាពជា ឧបច្ឆេទកកម្ម ។ ឬកុសលកម្មដែលបុគ្គលមានប្រក្រតី ញ៉ាំងជីវិតឲ្យធ្លាក់ចុះ រមែងមិនឱឡារ ។ រមែងមិនអាចញ៉ាំងបដិសន្ធិ ដែលមានអាយុវែងឲ្យកើត

ឡើងបានឡើយ ។ បាណាតិបាត រមែងប្រព្រឹត្តទៅដើម្បីឲ្យអាយុខ្លី ដោយប្រការដូច្នេះ ។ ឬកំណត់បដិសន្ធិប៉ុណ្ណោះ ធ្វើឲ្យមានអាយុខ្លី ។ ឬរមែងកើតក្នុងនរកដោយសន្និដ្ឋានចេតនា ។ ជាហេតុឲ្យមានអាយុខ្លី ដោយន័យពោលហើយ ដោយបុព្វចេតនា និងអបរចេតនា ។

[ ៥៨ ] ក្នុងបទថា **ទីឃាយុកសំវត្តនិកា ឯសា មាណវ បដិបទា** នេះ កម្មដែលវៀរចាកបាណាតិបាតយ៉ាងនេះ ក្នុងបវត្តិដែលកើតដោយកម្មបន្តិចបន្តួច ហាក់ដូចជាពោលយ៉ាងនេះ ដោយសេចក្តីថា បើអញដឹងមុន មិនគប្បីឲ្យឯងកើតក្នុងទីនេះឡើយ គប្បីឲ្យឯងកើតក្នុងទេវលោកប៉ុណ្ណោះ ណ្ហើយចុះ ឯងកើតក្នុងទីណាក៏ដោយ អញនឹងជួយឧបត្ថម្ភ ឧបត្ថម្ភដូចម្តេច គឺញុំាងអន្តរាយឲ្យវិនាស ញុំាងភោគៈឲ្យកើតឡើង ព្រោះឧបត្ថម្ភកកម្មនោះ ឪពុកម្តាយតែងមានសេចក្តីសុខតែម្យ៉ាង រមែងស្រោកស្រាន្តចិត្តតែម្យ៉ាង ចាប់តាំងអំពីកាលដែលទារកកើតក្នុងផ្ទៃមាតា អន្តរាយអំពីមនុស្ស និងអមនុស្សដោយប្រក្រតីពួកណា អន្តរាយទាំងអស់នោះ រមែងទៅប្រាស ។ រមែងញុំាងអន្តរាយឲ្យវិនាសយ៉ាងនេះ ។ ប្រមាណនៃភោគៈទាំងឡាយក្នុងផ្ទះ រមែងមិនមាន ( គឺរាប់មិនបាន ) ចាប់តាំងអំពីកាលដែលទារកកើតក្នុងផ្ទៃមាតា ។ កំណប់ទ្រព្យទាំងឡាយ រមែងមករួបរួមនៅក្នុងផ្ទះ ទាំងខាងមុខ ទាំងខាងក្រោយ ។ មាតា បិតា រមែងទៅកាន់ភាពបរិបូណ៌ដោយទ្រព្យ ដែលបុគ្គលទាំងនោះនាំមក ។ មេគោទឹកដោះទាំងឡាយ រមែងមានទឹកដោះច្រើន ។ ហ្វូងគោរមែងនៅជាសុខ ។ សំណាបទាំងឡាយក្នុងទីដែលព្រោះរមែងបរិបូណ៌ ។

បុគ្គលទាំងឡាយ ដែលមិនមានអ្នកណាដាស់តឿន រមែងនាំទ្រព្យដែលប្រកប សេចក្ដីចម្រើន ឬទ្រព្យដែលគេឲ្យម្ដងម្កាលមកឲ្យឯង ។ បរិវារជនទាំងឡាយ មានទាសៈជាដើម ក៏នឹងជាអ្នកប្រដៅងាយ ការងារទាំងឡាយក៏មិនវិនាស ។ ទារករមែងបានបរិហារចាប់តាំងអំពីនៅក្នុងគភ៌ ។ ពេទ្យដែលទាក់ទងនឹងទារក ទាំងឡាយ ក៏មកឲ្យយោបល់ ។ ទារកដែលកើតក្នុងត្រកូលគហបតី នឹងបាន ជាសេដ្ឋី កើតក្នុងត្រកូលទាំងឡាយ មានត្រកូលអមាត្យជាដើម ក៏បានតំណែង ទាំងឡាយ មានតំណែងសេនាបតីជាដើម ។ រមែងឲ្យភោគៈទាំងឡាយ កើត ឡើងដោយប្រការដូច្នេះ ។ បុគ្គលនោះមិនមានអន្តរាយ មានភោគៈ មានអាយុ យឺនយូរ ។ កម្ម គឺការមិនសម្លាប់សត្វ រមែងប្រព្រឹត្តទៅដើម្បីឲ្យមានអាយុ វែងយ៉ាងនេះ ។ កុសលដទៃដែលបុគ្គលមិនសម្លាប់សត្វធ្វើទុករមែងឱឡារ ។ រមែងអាចដើម្បីញ៉ាំងបដិសន្ធិឲ្យមានអាយុវែងកើតឡើង ។ រមែងប្រព្រឹត្តទៅ ដើម្បីមានអាយុវែងយ៉ាងនេះ ឬកំណត់បដិសន្ធិប៉ុណ្ណោះធ្វើឲ្យមានអាយុវែង ។ ឬរមែងកើតក្នុងទេវលោក ដោយសន្និដ្ឋានចេតនា ។ រមែងមានអាយុវែង ដោយន័យពោលហើយដោយបុព្វចេតនា ។ គប្បីជ្រាបអត្ថក្នុងការស្រាយ ប្រស្នាទាំងពួងដោយន័យនេះ ។

កម្មទាំងឡាយ មានការបៀតបៀនជាដើម មកក្នុងបវត្តិកាលហើយ ដូច ជាពោលយ៉ាងនេះដោយអត្ថ រមែងធ្វើកិច្ចទាំងឡាយ មានអាពាធច្រើនជាដើម ដោយហេតុទាំងឡាយ មានញ៉ាំងរោគឲ្យកើតជាដើម ដល់បុគ្គលដែលប្រាស ចាកភោគៈ ដោយការបៀតបៀន មិនបានធ្វើកិច្ចបដិបត្តិ ឬដោយកុសលដែល

បុគ្គលមានប្រក្រតីបៀតបៀនជាដើមធ្វើហើយ ជាធម្មជាតិមិនឱឡារ ឬដោយការកំណត់បដិសន្ធិតាំងអំពីខាងដើម ឬដោយអំណាចនៃបុព្វចេតនា និងអបរាបរចេតនាដោយន័យពោលហើយនោះឯង កម្មទាំងឡាយ មានការមិនបៀតបៀនជាដើម រមែងធ្វើនូវភាពជាបុគ្គលមានអាពាធតិចទាំងឡាយ មានការមិនសម្លាប់សត្វ ដូច្នោះ ។

[ ៦៣ ] ក្នុងបទទាំងនោះ បទថា **ឥស្សាមនកោ** បានដល់ មានចិត្តប្រកបដោយសេចក្ដីច្រណែន ។ បទថា **ឧបទុស្សតិ** សេចក្ដីថា ជេរដោយអំណាចសេចក្ដីច្រណែននោះ ហើយប្រទូស្ត ។ បទថា **ឥស្សំ ពន្ធតិ** សេចក្ដីថា ចងសេចក្ដីច្រណែន ដូចចងកណ្ដាប់ស្រូវ ដូចចងដោយមិនឲ្យរបូត ។ បទថា **អប្បេសក្ខោ** សេចក្ដីថា មានបរិវារតិច គឺមិនប្រាកដ ដូចព្រួញដែលបាញ់ក្នុងរាត្រី ។ មានដៃស្មោកគ្រោកអន្ទុយហើយ រមែងមិនបាននូវអ្នកឲ្យទឹក ។

[ ៦៥ ] បទថា **ន ទាតា ហោតិ** សេចក្ដីថា ជាអ្នកមិនឲ្យដោយអំណាចនៃការកំណាញ់ ។ បទថា **តេន កម្មេន** បានដល់ កម្ម គឺការកំណាញ់នោះ ។

[ ៦៧-៦៨ ] បទថា **អភិវាទេតព្វំ** គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ឬព្រះអរិយសាវក ជាអ្នកគួរដល់ការអភិវាទ ។ ក្នុងបទទាំងឡាយ សូម្បីមានបុគ្គលគួរក្រោកឡើងទទួលជាដើម ក៏ន័យនេះដូចគ្នា ។ មិនគួរកាន់យកឧបបីឡកកម្ម និងឧបឃាតកកម្មក្នុងការស្រាយប្រស្នានេះ ។ ព្រោះមិនអាចធ្វើដល់បុគ្គលមានត្រកូលទាប បុគ្គលមានត្រកូលខ្ពស់ក្នុងបវត្តិកាល ។ តែកម្ម

របស់អ្នកកើតក្នុងត្រកូលទាប កំណត់បដិសន្ធិនោះឯង ឲ្យកើតក្នុងត្រកូលទាប កម្មដែលនាំឲ្យកើតក្នុងត្រកូលខ្ពស់ រមែងឲ្យកើតក្នុងត្រកូលខ្ពស់ ។

[ ៦៩ ] រមែងកើតក្នុងនរក ដោយការមិនបានសាកសួរក្នុងបទនេះថា **ន បរិបុច្ឆិតា ហោតិ** ។ បុគ្គលមិនសាកសួរ រមែងមិនដឹងថា នេះគួរធ្វើ នេះមិនគួរធ្វើ ។ កាលមិនដឹង រមែងមិនធ្វើវត្ថុដែលគួរធ្វើ រមែងធ្វើវត្ថុដែលមិនគួរធ្វើ រមែងកើតក្នុងនរកដោយកម្មនោះ ។ បុគ្គលក្រៅអំពីនេះ រមែងកើតក្នុងស្ថានសួគ៌ ។

បទថា **ឥតិ ខោ មាណវ ។បេ។ យទិទំ ហីនប្បណីតតាយ** សេចក្ដីថា ព្រះសាស្ដាទ្រង់ញ៉ាំងទេសនាឲ្យចប់តាមអនុសន្ធិ ។ បទដ៏សេស ក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ។៚

## អដ្ឋកថា ចូឡកម្មវិភង្គសូត្រ ចប់
## សូត្រទី ៥ ចប់

# សុត្តន្តបិដក

## មហាកម្មវិភង្គសូត្រទី ៦

[ ៧៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះសមិទ្ធិមានអាយុ គង់នៅក្នុងកុដិដែលតាំងនៅក្នុងព្រៃ ។ គ្រានោះឯង បរិព្វាជកឈ្មោះបោតលិបុត្រ ដើរចង្ក្រមត្រាច់ទៅមកដើម្បីសម្រួលស្ងួន ហើយចូលទៅរកព្រះសមិទ្ធិមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់នឹងព្រះសមិទ្ធិមានអាយុ លុះបញ្ចប់ពាក្យរាក់ទាក់ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[ ៧៤ ] លុះបោតលិបុត្តបរិព្វាជក អង្គុយក្នុងទីសមគួរហើយ ទើបពោលពាក្យនេះនឹងព្រះសមិទ្ធិមានអាយុថា ម្នាលអាវុសោសមិទ្ធិ ពាក្យនេះ ខ្ញុំបានស្តាប់មកក្នុងទីចំពោះព្រះភក្ត្រ បានទទួលមកក្នុងទីចំពោះព្រះភក្ត្រនៃព្រះសមណគោតមថា កាយកម្មជាកម្មឥតអំពើ វចីកម្មជាកម្មឥតអំពើ មនោកម្មទើបជាកម្មពិត មួយទៀត បុគ្គលចូលកាន់សមាបត្តិណាហើយ មិនទទួលអារម្មណ៍អ្វីមួយ សមាបត្តិនោះក៏មានដែរ ។ ព្រះសមិទ្ធិពោលតបថា ម្នាលអាវុសោបោតលិបុត្ត អ្នកកុំពោលយ៉ាងនេះឡើយ អ្នកកុំពោលបង្កាច់ព្រះមានព្រះភាគ ព្រោះថា ការពោលបង្កាច់ព្រះមានព្រះភាគមិនល្អទេ ដ្បិតថា ព្រះមានព្រះភាគមិនបានត្រាស់ថា កាយកម្មជាកម្មឥតអំពើ វចីកម្មជាកម្មឥតអំពើ មនោកម្មទើបជាកម្មពិតយ៉ាងនេះទេ ម្នាលអាវុសោ តែចំណែកខាងបុគ្គលចូល

កាន់សមាបត្តិណា មិនទទួលអារម្មណ៍អ្វីមួយ សមាបត្តិនោះក៏មានមែន ។ ម្នាលអាវុសោសមិទ្ធិ លោកបួសបានយូរប៉ុន្មានវស្សាហើយ ។ ម្នាលអាវុសោ មិនយូរប៉ុន្មានទេ ទើបតែនឹងបាន ៣ វស្សា ។ ឥឡូវនេះ យើងទាំងឡាយចាំនិយាយថ្វីចំពោះពួកភិក្ខុជាថេរៈក្នុងរឿងនេះ ព្រោះសូម្បីភិក្ខុថ្មី ក៏គង់សម្គាល់នូវសាស្តាដែលខ្លួនគួរការពារយ៉ាងនេះបានដែរ ម្នាលអាវុសោសមិទ្ធិ បុគ្គលធ្វើកម្មប្រកបដោយចេតនា ដោយកាយវាចាចិត្តហើយ តើរងវេទនាដូចម្តេច ។ ម្នាលអាវុសោបោតលិបុត្ត បុគ្គលធ្វើកម្មប្រកបដោយចេតនា ដោយកាយវាចាចិត្តហើយ រមែងរងទុក្ខវេទនា ។ គ្រានោះ បោតលិបុត្តបរិព្វាជក មិនត្រេកអរ មិនខាំងឃាត់ភាសិតរបស់ព្រះសមិទ្ធិមានអាយុ លុះមិនត្រេកអរ មិនខាំងឃាត់ហើយ ក៏ក្រោកអំពីអាសនៈចៀសចេញទៅ ។

[ ៧៥ ] គ្រានោះឯង ព្រះសមិទ្ធិមានអាយុ កាលបោតលិបុត្តបរិព្វាជកចៀសចេញទៅមិនយូរប៉ុន្មាន ក៏ចូលទៅរកព្រះអានន្ទមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់នឹងព្រះអានន្ទមានអាយុ លុះបញ្ចប់ពាក្យដែលគួររាក់ទាក់ និងពាក្យគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសមិទ្ធិមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបផ្តៀងពាក្យចរចាទាំងអស់ ដែលខ្លួននិយាយនឹងបោតលិបរិព្វាជកទាំងប៉ុន្មាន ដល់ព្រះអានន្ទមានអាយុ ។ កាលព្រះសមិទ្ធិមានអាយុពោលយ៉ាងនេះហើយ ព្រះអានន្ទមានអាយុក៏ពោលនឹងព្រះសមិទ្ធិមានអាយុយ៉ាងនេះថា ម្នាលអាវុសោសមិទ្ធិ ពាក្យនេះជាពាក្យមានមូលហេតុហើយ ម្នាលអាវុសោសមិទ្ធិ គួរយើងនាំគ្នាមក

ដើម្បីគាល់ព្រះមានព្រះភាគ គួរនាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ គួរក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះមានព្រះភាគ ព្រះមានព្រះភាគ នឹងព្យាករដល់យើងយ៉ាងណា យើងគប្បីចងចាំសេចក្តីនោះយ៉ាងនោះ ។ ព្រះសមិទ្ធិមានអាយុ ទទួលពាក្យព្រះអានន្ទមានអាយុថា ករុណា អាវុសោ ។ គ្រានោះ ព្រះសមិទ្ធិមានអាយុ និងព្រះអានន្ទមានអាយុ ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអានន្ទមានអាយុអង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលពាក្យចរចាទាំងប៉ុន្មានរបស់ព្រះសមិទ្ធិមានអាយុជាមួយនឹងបោតលិបុត្តបរិព្វាជកទាំងអស់ ចំពោះព្រះមានព្រះភាគ ។

[ ៧៦ ] លុះព្រះអានន្ទក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគទ្រង់ត្រាស់នឹងព្រះអានន្ទមានអាយុយ៉ាងនេះថា ម្នាលអានន្ទ តថាគតមិនទាំងធ្លាប់ឃើញនូវបោតលិបុត្តបរិព្វាជកសោះ តើនឹងមានការចរចាជាមួយបែបនេះមកពីណា ម្នាលអានន្ទ ប្រស្នាដែលគួរចែក គួរដោះស្រាយដល់បោតលិបុត្តបរិព្វាជក លោកសមិទ្ធិជាមោឃបុរសនេះឯង ដោះស្រាយហើយតែមួយចំណែក ។ កាលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ព្រះឧទាយិមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្រែងសមិទ្ធិមានអាយុពោលដូច្នោះព្រោះអាងហេតុនេះថា វេទនាណានីមួយ វេទនានោះ សុទ្ធតែជាទុក្ខ ដូច្នេះទេដឹង ។

[ ៧៧ ] កាលព្រះឧទាយិក្រាបទូលយ៉ាងនេះហើយ ព្រះមានព្រះភាគ

ទ្រង់ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ ចូរអ្នកមើលនូវសេចក្តីល្ងង់របស់ឧទាយិ ជាមោឃបុរសនេះ ម្នាលអានន្ទ តថាគតបានដឹងច្បាស់ហើយថា ឥឡូវនេះ ឧទាយិនេះជាមោឃបុរស កាលងើបឡើង តែងងើបឡើងដោយឧបាយមិនមែនជាប្រាជ្ញា ម្នាលអានន្ទ បោតលិបុត្តបរិព្វាជកបានសួរវេទនា ៣ ខាងដើម ម្នាលអានន្ទ ប្រសិនបើសមិទ្ធិជាមោឃបុរសនេះ ត្រូវបោតលិបុត្ត បរិព្វាជកសួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះថា ម្នាលអាវុសោបោតលិបុត្ត បុគ្គលធ្វើអំពើប្រកបដោយចេតនា ដោយកាយវាចាចិត្ត ជាហេតុនៃសុខវេទនា បុគ្គលនោះក៏រងសុខវេទនា ម្នាលអាវុសោបោតលិបុត្ត បុគ្គលធ្វើកម្មប្រកបដោយចេតនា ដោយកាយវាចាចិត្ត ជាហេតុនៃទុក្ខវេទនា បុគ្គលនោះ តែងរងទុក្ខវេទនា ម្នាលអាវុសោបោតលិបុត្ត បុគ្គលធ្វើអំពើប្រកបដោយចេតនា ដោយកាយវាចាចិត្ត ជាហេតុនៃអទុក្ខមសុខវេទនា បុគ្គលនោះតែងរងអទុក្ខមសុខវេទនា ម្នាលអានន្ទ សមិទ្ធិជាមោឃបុរស កាលព្យាករយ៉ាងនេះ ឈ្មោះថា គួរព្យាករដោយប្រពៃដល់បោតលិបុត្តបរិព្វាជក ម្នាលអានន្ទ មួយទៀត ពួកតិត្ថិយបរិព្វាជកដទៃទាំងនោះ ជាមនុស្សល្ងង់ មិនឈ្លាសប្រតិពល ម្តេចឡើយនឹងដឹងមហាកម្មវិភង្គរបស់តថាគតបាន ម្នាលអានន្ទ បើដូច្នោះកាលបើតថាគត ចែកមហាកម្មវិភង្គ អ្នកទាំងឡាយគប្បីស្តាប់ចុះ ។ បពិត្រព្រះមានព្រះភាគ កាលនេះ ជាកាលគួរព្រះមានព្រះភាគគួរចែកនូវមហាកម្មវិភង្គ បពិត្រព្រះសុគត កាលនេះ ជាកាលគួរព្រះមានព្រះភាគ គួរចែកមហាកម្មវិភង្គ ពួកភិក្ខុបានស្តាប់

ព្រះពុទ្ធដីការបស់ព្រះមានព្រះភាគ នឹងបានចងចាំទុក ។ ម្នាលអានន្ទ បើដូច្នោះ ចូរអ្នកយកចិត្តទុកដាក់ស្តាប់ដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ព្រះអានន្ទមានអាយុ ក៏ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ៧៨ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះថា ម្នាលអានន្ទ បុគ្គលក្នុងលោកនេះមាន ៤ ពួក ។ បុគ្គល ៤ ពួកតើដូចម្តេចខ្លះ ។ ម្នាលអានន្ទ បុគ្គលពួកមួយក្នុងលោកនេះជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ សម្លឹងរំពៃចំពោះទ្រព្យរបស់គេ មានចិត្តព្យាបាទ មានគំនិតយល់ខុសក្នុងលោកនេះ បុគ្គលនោះលុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ ម្នាលអានន្ទ មួយទៀត បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ ជាអ្នកសម្លឹងរំពៃចំពោះទ្រព្យរបស់គេ មានចិត្តព្យាបាទ មានគំនិតយល់ខុសក្នុងលោកនេះ បុគ្គលនោះលុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវ-លោក ។ ម្នាលអានន្ទ បុគ្គលពួកមួយក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេសុមិច្ឆាចារ

វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណវាចា វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកមានចិត្តមិនបានសម្លឹងរំពៃចំពោះទ្រព្យរបស់គេ មានចិត្តមិនបានព្យាបាទ ជាអ្នកមានគំនិតយល់ត្រូវក្នុងលោកនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ ម្នាលអានន្ទ មួយទៀត បុគ្គលពួកមួយក្នុងលោកនេះ វៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេសុមិច្ឆាចារ វៀរស្រឡះចាកមុសាវាទ វៀរស្រឡះចាកបិសុណវាចា វៀរស្រឡះចាកផរុសវាចា វៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកមានចិត្តមិនបានរំពៃចំពោះទ្រព្យរបស់គេ មានចិត្តមិនព្យាបាទ ជាអ្នកមានគំនិតយល់ត្រូវក្នុងលោកនេះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។

[ ៧៩ ] ម្នាលអានន្ទ សមណៈ ឬព្រាហ្មណ៍ពួកមួយក្នុងលោកនេះ អាស្រ័យសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស អាស្រ័យសេចក្តីព្យា-យាម ជាគ្រឿងតម្កល់ចិត្តទុក អាស្រ័យសេចក្តីប្រឹងប្រែង អាស្រ័យសេចក្តីមិនប្រមាទ អាស្រ័យសេចក្តីយកចិត្តទុកដាក់ដោយប្រពៃ រមែងបាននូវចេតោ-សមាធិ មានសភាពដូច្នោះ ។ កាលបើតម្កល់ចិត្តនឹងហើយ សមណៈ ឬព្រាហ្មណ៍នោះ រមែងឃើញដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា នូវបុគ្គលឯណោះដែលសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ

ប្រព្រឹត្តខុសកាមទាំងឡាយ ពោលពាក្យកុហក ពោលពាក្យញុះញង់ ពោលពាក្យអាក្រក់ ពោលពាក្យឥតប្រយោជន៍ មានចិត្តសម្លឹងរំពៃចំពោះទ្រព្យរបស់គេ មានចិត្តព្យាបាទ មានគំនិតយល់ខុសក្នុងលោកនេះ រមែងឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ សមណៈ ឬព្រាហ្មណ៍នោះពោលយ៉ាងនេះថា អើហ្ន៎ អំពើអាក្រក់ក៏មាន ផលរបស់ទុច្ចរិតក៏មាន អាត្មាអញបានឃើញបុគ្គលឯណោះដែលសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។បេ។ មានគំនិតយល់ខុសក្នុងលោកនេះ បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ សមណៈ ឬព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា អើហ្ន៎ បានឮថា បុគ្គលណាជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុស បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះ ឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង ( អំពីនេះ ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស ។ សមណព្រាហ្មណ៍នោះ រមែងក្តួចកាន់ព្រោះស្ទាបអង្អែលនូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្តីយល់នេះឯងជារបស់ពិត សេចក្តីយល់ដទៃជាមោឃៈ ។

[ ៨០ ] ម្នាលអានន្ទ មួយទៀត សមណៈ ឬព្រាហ្មណ៍ពួកមួយក្នុងលោកនេះ អាស្រ័យនូវសេចក្ដីព្យាយាមជាគ្រឿងដុតកម្ដៅកិលេស អាស្រ័យនូវសេចក្ដីព្យាយាមតម្កល់ចិត្តទុក អាស្រ័យនូវសេចក្ដីប្រឹងប្រែង អាស្រ័យនូវសេចក្ដីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ រមែងបាននូវចេតោសមាធិ មានសភាពដូច្នោះ ។ កាលបើបានតម្កល់ចិត្តនឹងហើយ សមណៈ ឬព្រាហ្មណ៍នោះ រមែងឃើញដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា នូវបុគ្គលឯណោះដែលសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុសក្នុងលោកនេះ រមែងឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ សមណៈ ឬព្រាហ្មណ៍នោះពោលយ៉ាងនេះថា អើហ្ន៎ កម្មដ៏លាមកមិនមាន ផលរបស់ទុច្ចរិតក៏មិនមាន ខ្ញុំបានឃើញបុគ្គលឯណោះជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុសក្នុងលោកនេះ បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ សមណៈ ឬព្រាហ្មណ៍នោះ ពោលយ៉ាងនេះទៀតថា អើហ្ន៎ បុគ្គលណាជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុស បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង ( អំពីនេះ ) ការដឹងរបស់បុគ្គលនោះ ឈ្មោះ

ថាដឹងខុស ។ សមណព្រាហ្មណ៍នោះ ក្តួចកាន់ ព្រោះស្ទាបអង្អែលនូវហេតុ ដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថាសេចក្តីយល់នេះឯងជារបស់ពិត សេចក្តីយល់ដទៃជាមោឃៈ ។

[ ៨១ ] ម្នាលអានន្ទ សមណៈ ឬព្រាហ្មណ៍ពួកមួយ ក្នុងលោកនេះ អាស្រ័យនូវសេចក្តីព្យាយាម ជាគ្រឿងដុតកម្តៅកិលេស អាស្រ័យនូវសេចក្តី ព្យាយាមតម្កល់ចិត្តទុក អាស្រ័យនូវសេចក្តីប្រឹងប្រែង អាស្រ័យនូវសេចក្តី មិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ រមែងបាននូវចេតោ-សមាធិ មានសភាពដូច្នោះ ។ កាលបើតម្កល់ចិត្តមាំហើយ សមណៈ ឬ ព្រាហ្មណ៍នោះ រមែងឃើញដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់ មនុស្សធម្មតា នូវបុគ្គលឯណោះដែលវៀរស្រឡះចាកបាណាតិបាត វៀរ ស្រឡះចាកអទិន្នាទាន វៀរស្រឡះចាកកាមេសុមិច្ឆាចារ វៀរស្រឡះចាក មុសាវាទ វៀរស្រឡះចាកបិសុណវាចា វៀរស្រឡះចាកផរុសវាចា វៀរ ស្រឡះចាកសម្ផប្បលាបៈ ជាអ្នកមានចិត្តមិនបានសម្លឹងរំពៃចំពោះទ្រព្យរបស់ គេ មានចិត្តមិនព្យាបាទ មានគំនិតយល់ត្រូវក្នុងលោកនេះ រមែងឃើញបុគ្គល នោះដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ ទេវលោក ។ សមណៈ ឬព្រាហ្មណ៍នោះ ពោលយ៉ាងនេះថា អើហ្ន៎ អំពើជា កុសលក៏មាន ផលរបស់សុចរិតក៏មាន ខ្ញុំបានឃើញបុគ្គលឯណោះដែលជា អ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិត យល់ត្រូវក្នុងលោកនេះ បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់

អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ សមណៈ ឬព្រាហ្មណ៍នោះ ក៏ពោលយ៉ាងនេះថា អើហ្ន៎ បុគ្គលណាវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវ បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក ។ បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះ ឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង ( អំពីនេះ ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស ។ សមណព្រាហ្មណ៍នោះ រមែងក្តួចកាន់ ព្រោះស្ទាបអង្អែលនូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិហើយពោលថាសេចក្តីយល់នេះឯងជារបស់ពិត សេចក្តីយល់ដទៃជាមោឃៈ ។

[ ៨២ ] ម្នាលអានន្ទ មួយទៀត សមណៈ ឬព្រាហ្មណ៍ពួកមួយ ក្នុងលោកនេះ អាស្រ័យនូវសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស អាស្រ័យនូវសេចក្តីព្យាយាមតម្កល់ចិត្តទុក អាស្រ័យនូវសេចក្តីប្រឹងប្រែង អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ រមែងបាននូវចេតោសមាធិ មានសភាពដូច្នោះ ។ កាលបើបានតម្កល់ចិត្តនឹងហើយ សមណៈ ឬព្រាហ្មណ៍នោះ រមែងឃើញដោយទិព្វចក្ខុដ៏បរិសុទ្ធ កន្លងបង់ចក្ខុរបស់មនុស្សធម្មតា នូវបុគ្គលឯណោះដែលវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវ រមែងឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ សមណៈ ឬព្រាហ្មណ៍នោះពោលយ៉ាងនេះថា អើហ្ន៎

អំពើជាកុសលក៏មិនមាន ផលរបស់សុចរិតក៏មិនមាន ខ្ញុំបានឃើញបុគ្គលឯណោះដែលវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវក្នុងលោកនេះ បានឃើញបុគ្គលនោះដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ សមណៈ ឬព្រាហ្មណ៍នោះពោលយ៉ាងនេះថា អើហ្ន៎ បុគ្គលណាវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវ បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះ ឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង ( អំពីនេះ ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថា ដឹងខុស ។ សមណព្រាហ្មណ៍នោះ រមែងស្ទាបអង្អែលប្រកាន់នូវហេតុ ដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្តីយល់នេះឯង ជារបស់ពិត សេចក្តីយល់ដទៃ ជាមោឃៈ ។

[ ៨៣ ] ម្នាលអានន្ទ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណៈ ឬព្រាហ្មណ៍ណា ពោលយ៉ាងនេះថា អើហ្ន៎ អំពើដ៏លាមកក៏មាន ផលរបស់ទុច្ចរិតក៏មាន ដូច្នេះ តថាគតយល់ស្របតាមពាក្យរបស់ពួកសមណព្រាហ្មណ៍នោះដែរ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា ខ្ញុំបានឃើញបុគ្គលឯណោះ ដែលជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុស ក្នុងលោកនេះ បានឃើញបុគ្គលនោះ ដែល

ទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក តថាគតក៏យល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះដែរ ។ តែត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា អើហ្ន៎ បុគ្គលណា ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុស បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក តថាគតមិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង ( អំពីនេះ ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស តថាគតក៏មិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះដែរ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ស្ទាបអង្អែលប្រកាន់នូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្តីយល់នេះឯង ជារបស់ពិត សេចក្តីយល់ដទៃជាមោឃៈ តថាគតក៏មិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ដំណើរនោះព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះសត្វតែងមានសេចក្តីយល់ក្នុងមហាកម្មវិភង្គផ្សេងគ្នា ។

[ ៨៤ ] ម្នាលអានន្ទ បណ្តាសមណព្រាហ្មណ៍ទាំងនោះ សមណៈ ឬព្រាហ្មណ៍ណា ពោលយ៉ាងនេះថា អើហ្ន៎កម្មដ៏លាមកមិនមានទេ ទាំងផលរបស់ទុច្ចរិតក៏មិនមានដែរ តថាគតមិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍

នោះទេ ។ តែត្រង់សមណព្រាហ្មណ៍នោះពោលយ៉ាងនេះថា យើងបានឃើញបុគ្គលឯណោះ ដែលជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុសក្នុងលោកនេះ បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក តថាគតយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះ ។ ឯត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា អើហ្ន៎ បុគ្គលណាជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុស បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក តថាគតមិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង ( អំពីនេះ ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស តថាគតក៏មិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ។ តែត្រង់សមណព្រាហ្មណ៍នោះស្ទាបអង្អែល ប្រកាន់នូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្ដីយល់នេះឯងជារបស់ពិត សេចក្ដីយល់ដទៃជាមោឃៈ តថាគតមិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះសត្វតែងមានសេចក្ដីយល់ក្នុងមហាកម្មវិភង្គផ្សេងគ្នា ។

[ ៨៥ ] ម្នាលអានន្ទ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ សមណៈ

ឬព្រាហ្មណ៍ណា ពោលយ៉ាងនេះថា អើហ្ន៎ អំពើជាកុសលក៏មាន ផលរបស់សុចរិតក៏មាន តថាគតយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា ខ្ញុំឃើញបុគ្គលឯណោះជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវក្នុងលោកនេះ បានឃើញបុគ្គលនោះ ដែលទម្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ទៅកើតក្នុងសុគតិសួគ៌ទេវលោក តថាគតក៏យល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះ ។ ទាំងត្រង់សមណ-ព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា អើហ្ន៎ បុគ្គលណាវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវ បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក តថាគតក៏យល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះដែរ ។ ឯត្រង់សមណព្រាហ្មណ៍នោះពោលពាក្យយ៉ាងនេះថា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង ( អំពីនេះ ) ការដឹងរបស់បុគ្គលនោះ ឈ្មោះថាដឹងខុស តថាគតមិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ។ ទាំងត្រង់បុគ្គលនោះស្ទាបអង្អែលប្រកាន់ នូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ ដោយកម្លាំងទិដ្ឋិ ហើយពោលថា សេចក្ដីយល់នេះឯង ជារបស់ពិត សេចក្ដីយល់ដទៃជាមោឃៈ តថាគតមិនយល់ស្របតាមពាក្យរបស់សមណ-ព្រាហ្មណ៍នោះទេ ដំណើរនោះព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះសត្វតែងមាន

សេចក្តីយល់ក្នុងមហាកម្មវិភង្គផ្សេងគ្នា ។

[ ៨៦ ] ម្នាលអានន្ទ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ សមណៈ ឬព្រាហ្មណ៍ណាពោលពាក្យយ៉ាងនេះថា អើហ្ន៎ អំពើជាកុសលមិនមាន ផល របស់សុចរិតក៏មិនមាន តថាគតមិនយល់ស្របតាមពាក្យ របស់សមណ-ព្រាហ្មណ៍នោះទេ ។ តែត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា ខ្ញុំឃើញបុគ្គលឯណោះ ក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវ រមែងឃើញបុគ្គលនោះ ដែលទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ ទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក តថាគតយល់ស្របតាមពាក្យរបស់សមណ-ព្រាហ្មណ៍នោះ ។ ឯត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា អើហ្ន៎ បុគ្គលណាជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវ បុគ្គលទាំងអស់នោះ លុះទម្លាយរាងកាយបន្ទាប់ អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរ-កាយ នរក តថាគតមិនយល់ស្របតាមពាក្យរបស់សមណព្រាហ្មណ៍នោះទេ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ពោលពាក្យយ៉ាងនេះថា បុគ្គលណាដឹងយ៉ាងនេះ បុគ្គលនោះឈ្មោះថាដឹងត្រូវ បុគ្គលណាដឹងផ្សេង ( អំពីនេះ ) ការដឹង របស់បុគ្គលនោះ ឈ្មោះថាដឹងខុស តថាគតក៏មិនយល់ស្របតាមពាក្យរបស់ សមណព្រាហ្មណ៍នោះទេ ។ ទាំងត្រង់សមណព្រាហ្មណ៍នោះ ស្ទាបអង្អែល ប្រកាន់នូវហេតុដែលយល់ខ្លួនឯង ឃើញខ្លួនឯង ដឹងច្បាស់ខ្លួនឯងនោះ តាម

កម្លាំងទិដ្ឋិ ហើយពោលថា សេចក្តីយល់នេះឯងជារបស់ពិត សេចក្តីយល់ដទៃជាមោឃៈ តថាគតមិនយល់ស្របតាមពាក្យរបស់បុគ្គលនោះទេ ដំណើរនោះព្រោះហេតុអ្វី ម្នាលអានន្ទ ព្រោះសត្វតែងមានសេចក្តីយល់ក្នុងមហាកម្មវិភង្គផ្សេងគ្នា ។

[ ៨៧ ] ម្នាលអានន្ទ បណ្តាពួកបុគ្គលទាំងនោះ បុគ្គលណាក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុស លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បាបកម្មនោះ ដែលបុគ្គលនោះបានធ្វើក្នុងកាលមុន ក៏ជាហេតុនៃទុក្ខវេទនា បាបកម្មនោះ ដែលបុគ្គលនោះបានធ្វើក្នុងខាងក្រោយ ក៏ជាហេតុនៃទុក្ខវេទនាដែរ មិច្ឆាទិដ្ឋិដែលបុគ្គលនោះបានធ្វើឲ្យបរិបូណ៌ បានសមាទានហើយ ក្នុងពេលជិតស្លាប់ ដោយអំពើនោះ បុគ្គលនោះលុះទម្លាយរាងកាយ បន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ បុគ្គលនោះសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុស ក្នុងលោកនេះ ដោយហេតុណា ។ បុគ្គលនោះរមែងទទួលវិបាក របស់ហេតុនោះក្នុងបច្ចុប្បន្ននេះ ឬក្នុងជាតិជាលំដាប់ ឬក្នុងអត្តភាពជាខាងក្រោយៗ មក ។

[ ៨៨ ] ម្នាលអានន្ទ បណ្តាបុគ្គលទាំងនោះ បុគ្គលណាក្នុងលោកនេះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុស លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ

សួគ៌ ទេវលោក អំពើជាកុសលនោះ ដែលបុគ្គលនោះធ្វើក្នុងកាលមុន ក៏ជាហេតុនៃសុខវេទនា អំពើជាកុសលនោះ ដែលបុគ្គលនោះធ្វើខាងក្រោយ ក៏ជាហេតុនៃសុខវេទនាដែរ សម្មាទិដ្ឋិដែលបុគ្គលធ្វើឲ្យបរិបូណ៌ហើយ បានសមាទានហើយ ក្នុងកាលជិតស្លាប់ ព្រោះអំពើនោះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ព្រោះហេតុតែបុគ្គលនោះ ជាអ្នកសម្លាប់សត្វ កាន់យកទ្រព្យដែលគេមិនបានឲ្យ ។បេ។ មានគំនិតយល់ខុស ក្នុងលោកនេះ ។ បានជាបុគ្គលនោះ ទទួលវិបាករបស់កម្មនោះ ក្នុងបច្ចុប្បន្ន ឬក្នុងជាតិជាលំដាប់ ឬក៏ក្នុងអត្តភាពជាខាងក្រោយៗ មក ។

[ ៨៩ ] ម្នាលអានន្ទ បណ្តាបុគ្គលទាំងនោះ បុគ្គលណាក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក អំពើជាកុសលនោះ ដែលបុគ្គលនោះធ្វើក្នុងកាលមុន ក៏ជាហេតុនៃសុខវេទនា អំពើជាកុសលនោះ ដែលបុគ្គលនោះធ្វើក្នុងខាងក្រោយ ក៏ជាហេតុនៃសុខវេទនាដែរ សម្មាទិដ្ឋិដែលបុគ្គលនោះបានធ្វើឲ្យបរិបូណ៌ហើយ បានសមាទានហើយ ក្នុងកាលជិតស្លាប់ ព្រោះអំពើនោះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។ ព្រោះហេតុតែបុគ្គលនោះ វៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវ ក្នុងលោកនេះ ។ បាន

ជាបុគ្គលនោះ ទទួលនូវវិបាករបស់កម្មនោះ ក្នុងបច្ចុប្បន្ន ឬក្នុងជាតិជាលំដាប់ ឬក៏ក្នុងអត្តភាពខាងក្រោយៗ មក ។

[ ៩០ ] ម្នាលអានន្ទ បណ្ដាបុគ្គលទាំងនោះ បុគ្គលណាក្នុងលោកនេះ ជាអ្នកវៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក បាបកម្មនោះ ដែលបុគ្គលនោះបានធ្វើក្នុងកាលមុន ក៏ជាហេតុនៃទុក្ខវេទនា បាបកម្មនោះ ដែលបុគ្គលនោះធ្វើខាងក្រោយ ក៏ជាហេតុនៃទុក្ខវេទនាដែរ មិច្ឆាទិដ្ឋិដែលបុគ្គលនោះបានធ្វើឲ្យបរិបូណ៌ហើយ បានសមាទានហើយ ក្នុងកាលជិតស្លាប់ ព្រោះអំពើនោះ បុគ្គលនោះ លុះទម្លាយរាងកាយបន្ទាប់អំពីសេចក្ដីស្លាប់ទៅ រមែងទៅកើតក្នុងកំណើតតិរច្ឆាន ប្រេតវិស័យ អសុរកាយ នរក ។ ព្រោះហេតុតែបុគ្គលនោះ វៀរស្រឡះចាកបាណាតិបាត វៀរស្រឡះចាកអទិន្នាទាន ។បេ។ មានគំនិតយល់ត្រូវ ក្នុងលោកនេះ ។ បានជាបុគ្គលនោះ ទទួលនូវវិបាករបស់កម្មនោះ ក្នុងបច្ចុប្បន្ន ឬក្នុងជាតិជាលំដាប់ ឬក៏ក្នុងអត្តភាពជាខាងក្រោយៗ មក ។

[ ៩១ ] ម្នាលអានន្ទ ព្រោះហេតុនេះ កម្មមិនគួរឃាត់កម្មមិនគួរក៏មាន កម្មមិនគួរឃាត់កម្មគួរក៏មាន កម្មគួរឃាត់កម្មគួរក៏មាន កម្មគួរឃាត់កម្មមិនគួរក៏មាន ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

មហាកម្មវិភង្គសូត្រទី ៦ ចប់

# អដ្ឋកថា

## មហាកម្មវិភង្គសូត្រ

[ ៧៣ ] មហាកម្មវិភង្គសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ៧៤ ] ក្នុងសូត្រនោះ បទថា **មោឃំ** បានដល់ ទទេ មិនមានផល ។ បទថា **សច្ចំ** បានដល់ ពិត មានពិត ។ ក្នុងសេចក្ដីនេះ បរិព្វាជកបោត្តលិបុត្រនោះ មិនបានស្ដាប់មកចំពោះព្រះភក្ត្រ ។ តែមនោកម្មដែលមានទោសច្រើនជាង បានបញ្ញត្តហើយ ក្នុងឧបាលិសូត្រ ។ ពាក្យថា កាយកម្មក៏មិនដូច្នោះ វចីកម្មក៏មិនដូច្នោះ នៃការធ្វើកម្មអាក្រក់ នៃការប្រព្រឹត្តិទៅរបស់កម្មអាក្រក់ ដែលព្រះមានព្រះភាគត្រាស់ហើយ មាន ។ កថានោះកើតប្រាកដក្នុងរវាងតិរ្ថិយទាំងឡាយ ។ បរិព្វាជកបោត្តលិបុត្រ កាន់យកកថានោះពោល ។ ពោលពាក្យនេះថា សមាបត្តិនោះមាន ដូច្នេះ សំដៅដល់អភិសញ្ញានិរោធកថាដែលកើតហើយ ក្នុងបោដ្ឋបាទសូត្រថា អ្នកដ៏ចម្រើន អភិសញ្ញានិរោធតើដូម្ដេច ។ បទថា **ន កិញ្ចិ វេទិយតិ** សេចក្ដីថា មិនសោយវេទនា ១ ។ បទថា **អត្ថិ ច ខោ** សេចក្ដីថា ព្រះថេរៈរមែងទទួលដឹង សំដៅដល់និរោធសមាបត្តិ ។ បទថា **បរិរក្ខិតព្វំ** សេចក្ដីថា គប្បីរក្សាការដោះចាកពាក្យនិន្ទា ។ ការចង់ចិត្តនៃកម្មនោះមាន ។ ព្រោះដូច្នោះ កម្មនោះ ឈ្មោះថា **សញ្ចេតនិកំ** ប្រែថា ប្រកបដោយការចង់ចិត្តដែលមានបំណង ។ បទថា **ទុក្ខំ** សេចក្ដីថា ព្រះថេរៈសំដៅដល់អកុសលប៉ុណ្ណោះ ទើបពោលយ៉ាងនេះ ដោយសម្គាល់ថា បរិព្វាជកនឹងសួរ ។

[ ៧៦ ] បទថា **ឧស្សន្នម្បិ ខោ អហំ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ឃើញសន្ធារសូម្បីប៉ុនគ្រាប់ល្ង ក្នុងទីប្រមាណមួយយោជន៍ដោយជុំវិញក្នុងទីងងឹតដែលប្រកបដោយអង្គ ៤ ដោយមំសចក្ខុនោះឯង ។ បរិព្វាជកនេះនៅក្នុងទីមិនឆ្ងាយ ខាងក្នុងប្រមាណមួយគាវុត ។ សួរថា ព្រោះហេតុអ្វី ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ។ ឆ្លើយថា ព្រោះត្រាស់សំដៅដល់ការឃើញសមាគមប៉ុណ្ណោះ ។ បទថា **ឧទាយិ** គឺលោឡុទាយីភិក្ខុ ។ បទថា **តំ ទុក្ខស្មឹ** បានដល់ ទុក្ខទាំងអស់នោះឯង ។ ពាក្យថា បើព្រះមានព្រះភាគមានកាសិតសោត ដូច្នេះ សំដៅដល់វដ្តទុក្ខ កិលេសទុក្ខ និងសង្ខារទុក្ខដោយប្រការដូច្នេះ ។

[ ៧៧ ] បទថា **ឧម្មង្គំ** បានដល់ ការប្រាកដចេញមកនៃបញ្ញា ។ បទថា **ឧម្មុជ្ជមានោ** បានដល់ ងើបក្បាល ។ បទថា **អយោនិសោ ឧម្មុជ្ជិស្សតិ** បានដល់ ងើបក្បាលដោយមិនមានឧបាយ ។

ឯព្រះមានព្រះភាគ ទ្រង់ដឹងរឿងនេះ មិនមែនទ្រង់ដឹងដោយទិព្វចក្ខុ ចេតោបរិយញ្ញាណ ឬសព្វញ្ញុតញ្ញាណឡើយ ទ្រង់ដឹងដោយអធិប្បាយប៉ុណ្ណោះ ។ កាលពោលធម្មតា អធិប្បាយក៏ដឹងបានងាយ អ្នកបំណងនឹងពោលរមែងអើតក ញ៉របង្កា មាត់របស់បុគ្គលនោះក៏កម្រើក មិនអាចស្ងប់ស្ងៀមបាន ។ ព្រះមានព្រះភាគទ្រង់ឃើញអាការនោះ របស់ឧទាយិភិក្ខុនោះហើយ ទ្រង់មើលហើយថា ឧទាយីនេះ មិនអាចស្ងប់ស្ងៀមបាន នឹងពោលពាក្យដែលមិនពិតនោះឯង ទ្រង់បានដឹងហើយ ។ បទថា **អាទិំយេវ** គឺក្នុងខាងដើមនោះឯង ។

បទថា **តិស្សោ វេទនា** សេចក្តីថា បរិញ្វជកបោតលិបុត្ត កាលសួរថា បុគ្គលនោះសោយអ្វី ក៏កំណត់យ៉ាងនេះថា អញនឹងសួរវេទនា ៣ ដូច្នេះហើយ ទើបសួរវេទនា ៣ ។ បទថា **សុខវេទនីយំ** បានដល់ ជាបច្ច័យនៃសុខវេទនា ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ក្នុងទីនេះ ឈ្មោះថា កម្មដែលឲ្យផលជាសុខ ព្រោះកើតសុខវេទនាក្នុងបដិសន្ធិ និងបវត្តិកាល យ៉ាងនេះ គឺចេតនា ៤ ដែលសម្បយុត្តដោយចិត្ត សហគតៈដោយសោមនស្ស ដោយកាមាវចរកុសលចេតនាក្នុងឈានពួក ៣ ខាងក្រោម ។ ក្នុងទីនេះ កាមាវចររមែងញុំាងសុខដោយចំណែកមួយ ឲ្យកើតក្នុងបដិសន្ធិនោះឯង រមែងញុំាងអទុក្ខមសុខឲ្យកើតឡើង ក្នុងឥដ្ឋមជ្ឈត្តារម្មណ៍ ដែលប្រព្រឹត្តទៅហើយ ។ អកុសលចេតនា ឈ្មោះថា ឲ្យផលជាទុក្ខ ព្រោះកើតទុក្ខប៉ុណ្ណោះ ក្នុងបដិសន្ធិកាល និងបវត្តិកាល ។ កាលកាយទ្វារប្រព្រឹត្តទៅហើយ ក៏ញុំាងទុក្ខដោយចំណែកមួយនោះ ឲ្យកើតឡើង ។ រមែងញុំាងអទុក្ខមសុខឲ្យកើតឡើងក្នុងភារៈដទៃ ។ វេទនានោះដល់នូវការរាប់ថា ទុក្ខនោះឯង ព្រោះកើតឡើងក្នុងអនិដ្ឋានិដ្ឋមជ្ឈត្តារម្មណ៍ទាំងឡាយ ។ ឈ្មោះថា កម្មឲ្យផលជាអទុក្ខមសុខ ព្រោះកើតវេទនាទី ៣ ក្នុងបដិសន្ធិកាល និងបវត្តិកាល យ៉ាងនេះ គឺវេទនា ៤ ដែលសម្បយុត្តដោយចិត្តដែលប្រកបដោយឧបេក្ខា ក្នុងកាមាវចរកុសល វេទនាក្នុងចតុត្ថជ្ឈានក្នុងរូបាវចរកុសល ក៏ញុំាងអទុក្ខមសុខដោយចំណែកមួយឲ្យកើតក្នុងកាមាវចរបដិសន្ធិនោះឯង ញុំាងសុខឲ្យកើតក្នុងឥដ្ឋារម្មណ៍ដែលប្រព្រឹត្តទៅហើយ ។ មយ៉ាងទៀត កម្មដែលឲ្យផលជាសុខ

រមែងប្រព្រឹត្តទៅដោយអំណាចនៃការប្រព្រឹត្តិទៅរបស់បដិសន្ធិ ។ កម្មដែលឲ្យផលជាអទុក្ខមសុខ រមែងប្រព្រឹត្តទៅដូចគ្នា កម្មដែលឲ្យផលជាទុក្ខ រមែងប្រព្រឹត្តទៅដោយអំណាចនៃការប្រព្រឹត្តិទៅដូចគ្នា ។ ដោយអំណាចនៃទុក្ខ-វេទនីយកម្មនោះ កម្មទាំងអស់ រមែងប្រព្រឹត្តទៅដោយអំណាចនៃការប្រព្រឹត្តិទៅនោះឯង ។

បទថា **ឯតស្ស ភគវា** សេចក្តីថា ព្រះតថាគត ទ្រង់សម្តែងអាល័យដើម្បីទ្រង់សម្តែងមហាកម្មវិភង្គ ព្រះថេរៈទូលអារាធនាព្រះតថាគតហើយ នឹងធ្វើមហាវិភង្គញ្ញាណឲ្យប្រាកដដល់ភិក្ខុសង្ឃ ដូច្នេះហើយ ពោលយ៉ាងនេះ ព្រោះភាពដែលខ្លួនជាអ្នកឈ្លាសក្នុងការក្តាប់សេចក្តី ។ បណ្តាបទទាំងនោះ បទថា **មហាកម្មវិភង្គំ** បានដល់ ការចែកមហាកម្ម ។ ពាក្យថា បុគ្គល ៤ ពួកដូចម្តេច ម្នាលអានន្ទ បុគ្គលពួកខ្លះក្នុងលោកនេះ ។បេ។ រមែងចូលដល់នរក នេះជាមហាកម្មវិភង្គញ្ញាណភាជនៈ តែក៏ជាមាតិកាឋបនៈ ដើម្បីប្រ-យោជន៍ដល់មហាកម្មវិភង្គញ្ញាណភាជនៈ ។ ពាក្យថា ម្នាលអានន្ទ សមណៈពួកខ្លះក្នុងលោកនេះ តែមួយពាក្យជាអនុសន្ធិ ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ប្រារព្ធដល់អនុសន្ធិនោះ ដើម្បីទ្រង់ប្រកាសថា សមណៈ ឬព្រាហ្មណ៍ទាំងឡាយ ដែលមានចក្ខុប្រៀបដូចទិព្វ ធ្វើអនុសន្ធិនេះជាអារម្មណ៍បាន បច្ច័យនេះកាន់យកទស្សនៈនេះ ។

[ ៧៩ ] បណ្តាបទទាំងនោះ បទថា **អាតប្បំ** ជាដើម ជាឈ្មោះនៃការព្យាយាម ៥ ប្រការនោះឯង ។ បទថា **ចេតោ សមាធឹ** បានដល់ ទិព្វចក្ខុ-

សមាធិ ។ បទថា **បស្សតិ** សេចក្តីថា រមែងសម្លឹងឃើញថា សត្វនោះកើតហើយក្នុងទីណា ។ បទថា **យេ អញ្ញថា** សេចក្តីថា រមែងពោលថា ជនពួកណារមែងដឹងថា បុគ្គលនោះចូលដល់នរក ព្រោះកុសលកម្មបថ ១០ ដែលខ្លួនប្រព្រឹត្តទៅហើយ ការដឹងរបស់ជនទាំងនោះខុស ។ គប្បីជ្រាបអត្ថក្នុងវារៈទាំងពួងដោយន័យនេះ ។ បទថា **វិទិតំ** បានដល់ ប្រាកដ ។ បទថា **ថាមសា** បានដល់ ដោយកម្លាំងទិដ្ឋិ ។ បទថា **បរាមាសា** បានដល់ ស្ទាបអង្អែលដោយទិដ្ឋិ ។ បទថា **អភិនិវិស្ស វោហរតិ** សេចក្តីថា និយាយដោតចុះទៅកាន់ការប្រកាន់ ។

[ ៨៣ ] បទថា **តត្រានន្ទ** នេះ ជាបទចែកមហាកម្មវិភង្គញ្ញាណ សូម្បីយ៉ាងនោះ ក៏នៅជាបទតាំងមាតិកាដែរ ។ ក្នុងទីនេះ ព្រះមានព្រះភាគទ្រង់សម្តែងបទនេះថា វាទៈមានប្រមាណប៉ុណ្ណេះ តថាគតអនុមតិវាទមានប្រមាណប៉ុណ្ណេះ តថាគតមិនអនុមតិតាមពាក្យរបស់សមណៈ ឬព្រាហ្មណ៍ទាំងនោះដែលមានទិព្វចក្ខុ ។ បទថា **តត្រ** គឺក្នុងសមណៈ ឬព្រាហ្មណ៍ ៤ ពួកនេះ ។

[ ៨៤ ] បទថា **ឥទមស្ស** កាត់បទជា **ឥទំ វចនំ អស្ស** ប្រែថា ពាក្យនេះគប្បីមាន ។ បទថា **អញ្ញថា** គឺដោយអាការដទៃ ។ គប្បីជ្រាបវាទៈដែលទ្រង់អនុមតិ ទ្រង់មិនអនុមតិក្នុងបទទាំងពួងយ៉ាងនេះថា ទ្រង់អនុមតិក្នុងឋានៈ ២ យ៉ាង ទ្រង់មិនអនុមតិក្នុងឋានៈ ៣ យ៉ាង ក្នុងវាទៈនៃសមណៈ ឬព្រាហ្មណ៍ទាំងនេះ ដោយប្រការដូច្នេះ ។

[ ៨៨ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងអនុមតិ និងមិនអនុមតិ តាមពាក្យនៃសមណៈ ឬព្រាហ្មណ៍ទាំងឡាយ ដែលមានទិព្វចក្ខុយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់ចែកញាណក្នុងមហាកម្មវិភង្គ ទើបត្រាស់ថា **តត្រានន្ទ យ្វាយំ បុគ្គលោ** ដូច្នេះជាដើម ។

[ ៨៩ ] បទថា **បុព្វេ វាស្ស តំ កតំ ហោតិ** សេចក្តីថា បុគ្គលដែលធ្វើកម្មណា សមណៈ ឬព្រាហ្មណ៍នេះ ដែលមានទិព្វចក្ខុឃើញហើយ ។ កម្មដែលបុគ្គលធ្វើហើយក្នុងកាលមុនអំពីនោះ បុគ្គលរមែងកើតក្នុងនរកដោយកម្មដែលខ្លួនធ្វើហើយ ក្នុងកាលមុនក៏មាន រមែងកើតដោយកម្មដែលខ្លួនធ្វើក្នុងកាលក្រោយក៏មាន ។ ក្នុងមរណកាល ក៏រមែងកើតដូចគ្នា សូម្បីដោយការឃើញខុសជាដើមថា ព្រះខន្ទប្រសើរបំផុត ព្រះសិវៈប្រសើរបំផុត ព្រះព្រហ្មប្រសើរបំផុត ឬលោកប្រសើរវិសេសដោយឥស្សរៈជាដើម ។ បទថា **ទិដ្ឋេវ ធម្មេ** សេចក្តីថា កម្មណាគប្បីឲ្យផលក្នុងបច្ចុប្បន្ននោះ បុគ្គលរមែងបានសោយផលនៃកម្មនោះ ក្នុងបច្ចុប្បន្ននោះឯង កម្មណាឲ្យផលក្នុងកាលកើតឡើង បុគ្គលកើតឡើងហើយ រមែងបានសោយផលកម្មនោះ កម្មណាឲ្យផលក្នុងលំដាប់បន្ទាប់ទៅ រមែងបានសោយផលនៃកម្មនោះ ក្នុងលំដាប់បន្ទាប់ទៅ ។ សមណៈ ឬព្រាហ្មណ៍នេះបានឃើញគំនរនៃកម្ម ១ គំនរនៃវិបាក ១ ដោយប្រការដូច្នេះ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ឃើញគំនរនៃកម្ម ៣ យ៉ាង និងគំនរនៃវិបាក ២ យ៉ាង ដែលសមណៈ ឬព្រាហ្មណ៍នេះមិនឃើញហើយ តែទ្រង់ឃើញគំនរនៃកម្ម ៤ យ៉ាង និងគំនរនៃវិបាក ៣ យ៉ាង ដែល

សមណៈ ឬព្រាហ្មណ៍នេះឃើញហើយ ។ ញាណក្នុងការដឹងឋានៈទាំង ៧ យ៉ាងនេះ ឈ្មោះថា ញាណក្នុងមហាកម្មវិភង្គនៃព្រះតថាគត ។ សមណៈ ឬព្រាហ្មណ៍ដែលមានទិព្វចក្ខុ មិនឃើញវត្ថុអ្វីមួយក្នុងវារៈទី ២ ។ ឯញាណក្នុងការដឹងឋានៈ ៥ យ៉ាងនេះ គឺគំនរនៃកម្ម ៣ យ៉ាង គំនរនៃវិបាក ២ យ៉ាង ដែលព្រះតថាគតទ្រង់ឃើញហើយ ដូច្នេះ ឈ្មោះថា ញាណក្នុងមហាកម្មវិភង្គនៃព្រះតថាគត ។ ក្នុងវារៈ ២ យ៉ាងដ៏សេសក៏មានន័យនេះដូចគ្នា ។

[ ៩១ ] បទថា **អភព្វំ** បានដល់ វៀរចាកការពិត គឺជាអកុសល ។ បទថា **អភព្វាភាសំ** សេចក្តីថា កម្មមិនគួរ រមែងសឲ្យឃើញ គឺរមែងគ្របសង្កត់ អធិប្បាយថា រមែងហាម ។ កាលអកុសលកម្មមានច្រើន ដែលបុគ្គលធ្វើហើយ កម្មដែលមានកម្លាំងហាមវិបាកនៃកម្មដែលមិនមានកម្លាំង រមែងធ្វើឱកាសឲ្យដល់វិបាករបស់ខ្លួន កម្មនេះ ឈ្មោះថា កម្មមិនគួរ សឲ្យឃើញថា មិនគួរ ។ ឯបុគ្គលធ្វើកុសលកម្មហើយ ធ្វើអកុសលកម្មក្នុងវេលាជិតស្លាប់ អកុសលកម្មនោះហាមវិបាករបស់កុសលកម្ម ធ្វើឱកាសឲ្យដល់វិបាករបស់ខ្លួន កម្មនេះឈ្មោះថា កម្មមិនគួរ ធ្លុះបញ្ចាំងឲ្យឃើញថា គួរ ។ កាលកុសលច្រើនដែលបុគ្គលធ្វើហើយ ជាកម្មមានកម្លាំង ហាមវិបាករបស់កម្មដែលមិនមានកម្លាំង រមែងធ្វើឱកាសដល់វិបាករបស់ខ្លួន កម្មនេះ ឈ្មោះថា កម្មគួរ ធ្លុះបញ្ចាំងឲ្យឃើញថា គួរ ។ ឯបុគ្គលធ្វើអកុសល ហើយធ្វើកុសលក្នុងវេលាជិតស្លាប់ កុសលកម្មនោះ ហាមវិបាករបស់អកុសលកម្ម ធ្វើឱកាសឲ្យដល់វិបាករបស់ខ្លួន កម្មនេះ ឈ្មោះថា កម្មគួរ និងធ្លុះបញ្ចាំងឲ្យ

ឃើញថា មិនគួរ ។

ម្យ៉ាងទៀត គប្បីជ្រាបអត្ថក្នុងទីនេះ ដោយអាការដែលប្រាកដ ។ មានអធិប្បាយដូច្នេះ កម្មណារមែងធ្លុះបញ្ចាំងឲ្យឃើញ គឺរមែងប្រាកដដោយមិនគួរ ព្រោះដូច្នោះ កម្មនោះ ឈ្មោះថា ធ្លុះបញ្ចាំងឲ្យឃើញថា មិនគួរ ។ ព្រះមានព្រះភាគត្រាស់បុគ្គល ៤ ពួក ដោយន័យជាដើមថា ក្នុងបុគ្គល ៤ ពួកនោះ បុគ្គលណាក្នុងលោកនេះ ជាអ្នកច្រើនដោយការធ្វើជីវិតសត្វឲ្យធ្លាក់ចុះកន្ទង ដូច្នេះ ។ ក្នុងបុគ្គល ៤ ពួកនោះ កម្មរបស់បុគ្គលពួកទី ១ ឈ្មោះថា កម្មមិនគួរ ធ្លុះបញ្ចាំងឲ្យឃើញថា មិនគួរ ។ កម្មនេះ ឈ្មោះថា មិនគួរ ព្រោះជាអកុសល ។ កម្មដែលជាហេតុឲ្យកើតក្នុងនរកនោះ ឈ្មោះថា ជាអកុសលប្រាកដ ព្រោះបុគ្គលពួកទី ១ នោះកើតក្នុងនរក កម្មរបស់ពួកបុគ្គលពួកទី ២ ឈ្មោះថា កម្មមិនគួរ ធ្លុះបញ្ចាំងឲ្យឃើញថា គួរ ។ កម្មនោះ ឈ្មោះថា មិនគួរ ព្រោះជាអកុសល ។ កម្មដែលជាហេតុឲ្យកើតក្នុងស្ថានសួគ៌របស់អន្យតិរ្ថិយទាំងឡាយ ឈ្មោះថា ជាកុសលប្រាកដ ព្រោះបុគ្គលពួកទី ២ កើតក្នុងស្ថានសួគ៌ កម្ម ២ យ៉ាងក្រៅអំពីនេះ ក៏មានន័យដូចគ្នា ។ បទដ៏សេសក្នុងទីពួង ងាយយល់ទាំងអស់ហើយ ។

## អដ្ឋកថា មហាកម្មវិភង្គសូត្រ ចប់

## សូត្រទី ៦ ចប់

# សុត្តន្តបិដក

## សឡាយតនវិភង្គសូត្រទី ៧

[ ៩២ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះឯងថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងសឡាយតនវិភង្គ ( ចំណែកអាយតនៈទាំង ៦ ) ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយប្រុងស្តាប់ នូវសឡាយតនវិភង្គនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ក៏ទទួលស្តាប់ព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ៩៣ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា បុគ្គលគប្បីដឹងអាយតនៈខាងក្នុង ៦ គប្បីដឹងអាយតនៈខាងក្រៅ ៦ គប្បីដឹងកងនៃវិញ្ញាណ ៦ គប្បីដឹងកងនៃផស្សៈ ៦ គប្បីដឹងមនោបវិចារ ( សេចក្តីពិចារណានៃចិត្ត ) ១៨ គប្បីដឹងសត្តបទ ( ចំណែកនៃសត្វដែលអាស្រ័យនូវវដ្តៈ និងវិវដ្តៈ ) ៣៦ បណ្តាធម៌ទាំងនោះ អ្នកទាំងឡាយចូរអាស្រ័យនូវធម៌នេះ ហើយលះបង់ធម៌នេះចេញ ឯសតិប្បដ្ឋានមាន ៣ ប្រការ ជាធម៌ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរប្រៀនប្រដៅនូវគណៈបានសាស្តានោះ តថាគតពោលថា ជាសារថីអ្នកទូន្មាននូវបុរស ជាអាចារ្យដ៏

ប្រសើរជាងអាចារ្យអ្នកបង្ហាត់នូវហ្វឹកហាត់ មានជំរីជាដើម នេះជាឧទ្ទេសរបស់សឡាយតនវិភង្គ ។

[ ៩៤ ] ពាក្យថា បុគ្គលគប្បីដឹងអាយតនៈខាងក្នុង ៦ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ អាយតនៈ ( អណ្តូងជាទីកើតនៃអារម្មណ៍ ) គឺភ្នែក ១ អាយតនៈ គឺត្រចៀក ១ អាយតនៈ គឺច្រមុះ ១ អាយតនៈ គឺអណ្តាត ១ អាយតនៈ គឺកាយ ១ អាយតនៈ គឺចិត្ត ១ ។ ពាក្យណាដែលតថាគតពោលហើយថា បុគ្គលគប្បីដឹងអាយតនៈខាងក្នុង ៦ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យនូវហេតុនេះឯង ។

[ ៩៥ ] ពាក្យថា បុគ្គលគប្បីដឹងអាយតនៈខាងក្រៅ ៦ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ អាយតនៈ គឺរូប ១ អាយតនៈ គឺសំឡេង ១ អាយតនៈ គឺក្លិន ១ អាយតនៈ គឺរស ១ អាយតនៈ គឺផោដ្ឋព្វៈ ១ អាយតនៈ គឺធម៌ ១ ។ ពាក្យណាដែលតថាគតពោលហើយថា បុគ្គលគប្បីដឹងអាយតនៈខាងក្រៅ ៦ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យនូវហេតុនេះឯង ។

[ ៩៦ ] ពាក្យថា បុគ្គលគប្បីដឹងកងនៃវិញ្ញាណ ៦ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ ចក្ខុវិញ្ញាណ ( សេចក្តីដឹងតាមទ្វារភ្នែក ) ១ សោតវិញ្ញាណ ១ ឃានវិញ្ញាណ ១ ជិវ្ហាវិញ្ញាណ ១ កាយវិញ្ញាណ ១ មនោវិញ្ញាណ ១ ។ ពាក្យណា ដែល

តថាគតពោលហើយថា បុគ្គលគប្បីដឹងកងនៃវិញ្ញាណ ៦ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យនូវហេតុនេះឯង ។

[ ៩៧ ] ពាក្យថា បុគ្គលគប្បីដឹងកងនៃផស្សៈ ៦ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ ចក្ខុសម្ផស្ស ( អារម្មណ៍ដែលប៉ះពាល់ដោយភ្នែក ) ១ សោតសម្ផស្ស ១ ឃានសម្ផស្ស ១ ជិវ្ហាសម្ផស្ស ១ កាយសម្ផស្ស ១ មនោសម្ផស្ស ១ ។ ពាក្យណា ដែលតថាគតពោលហើយថា បុគ្គលគប្បីដឹងកងនៃផស្សៈ ៦ ដូច្នេះ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យនូវហេតុនេះឯង ។

[ ៩៨ ] ពាក្យថា បុគ្គលគប្បីដឹងមនោបវិចារទាំង ១៨ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ បុគ្គលឃើញរូបដោយភ្នែកហើយ ក៏ពិចារណានូវរូបជាទីតាំងនៃសោមនស្ស ពិចារណានូវរូបជាទីតាំងនៃទោមនស្ស ពិចារណានូវរូបជាទីតាំងនៃឧបេក្ខា ។ ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ប៉ះពាល់ផោដ្ឋព្វៈដោយកាយ ... ដឹងនូវធម៌ដោយចិត្តហើយ ក៏ពិចារណានូវធម៌ជាទីតាំងនៃសោមនស្ស ពិចារណានូវធម៌ជាទីតាំងនៃទោមនស្ស ពិចារណានូវធម៌ជាទីតាំងនៃឧបេក្ខា ។ សោមនស្សុបវិចារ ( សេចក្តីពិចារណាដោយសោមនស្ស ) មាន ៦ ទោមនស្សុបវិចារមាន ៦ ឧបេក្ខុបវិចារមាន ៦ ( រួមគ្នាត្រូវជា ១៨ ) ដោយប្រការដូច្នេះ ។ ពាក្យណា ដែលតថាគតបានពោលហើយថា បុគ្គលគប្បីដឹងមនោបវិចារទាំង ១៨ ដូច្នេះ ពាក្យនុ៎ះ តថាគត

ពោលព្រោះអាស្រ័យនូវហេតុនេះឯង ។

[ ៩៩ ] ពាក្យថា បណ្ឌិតគប្បីដឹងសត្តបទ ( ចំណែកនៃសត្វ ) ៣៦ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ គេហសិតសោមនស្ស ( សោមនស្សអាស្រ័យកាមគុណ ) មាន ៦ នេក្ខម្មសិតសោមនស្ស ( សោមនស្សអាស្រ័យនេក្ខម្មៈ គឺវិបស្សនា ) មាន ៦ គេហសិតទោមនស្សមាន ៦ នេក្ខម្មសិតទោមនស្សមាន ៦ គេហសិតឧបេក្ខាមាន ៦ នេក្ខម្មសិតឧបេក្ខាមាន ៦ ( ត្រូវជា ៣៦ ) ។

[ ១០០ ] បណ្តាធម៌ទាំងនោះ គេហសិតសោមនស្សមាន ៦ យ៉ាងតើដូចម្តេច ។ បុគ្គលកាលឃើញច្បាស់នូវការបានរូប ដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយលោកាមិសៈ គឺតណ្ហាថាជាការបានក្តី កាលរឭកឃើញ ( នូវរូប ) ដែលខ្លួនធ្លាប់បានហើយក្នុងកាលមុន ដែលកន្លងហើយ ដែលរលត់ហើយ ដែលប្រែប្រួលហើយក្តី ហើយក៏កើតសេចក្តីសោមនស្សឡើង សោមនស្សណា មានសភាពដូច្នេះ សោមនស្សនេះ តថាគតហៅថា គេហសិតសោមនស្ស ។ បុគ្គលកាលឃើញច្បាស់ នូវការបានសំឡេង ដែលគប្បីដឹងដោយត្រចៀក ... ក្លិនដែលគប្បីដឹងដោយច្រមុះ ... រសដែលគប្បីដឹងដោយអណ្តាត ... ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ... ធម៌ដែលគប្បីដឹងដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយលោកាមិសៈថាជាការបានក្តី កាលរឭកឃើញនូវធម៌ ដែលខ្លួនធ្លាប់បានហើយ ក្នុងកាលមុន ដែល

កន្លងហើយ ដែលរលត់ហើយ ដែលប្រែប្រួលហើយក្តី ហើយក៏កើតសេចក្តីសោមនស្សឡើង សោមនស្សណាមានសភាពដូច្នេះ សោមនស្សនេះ តថាគតហៅថា គេហសិតសោមនស្ស ។ នេះគេហសិតសោមនស្ស ៦ យ៉ាង ។

[ ១០១ ] បណ្តាធម៌ទាំងនោះ នេក្ខម្មសិតសោមនស្សមាន ៦ យ៉ាង តើដូចម្តេច ។ បុគ្គលកាលដឹងច្បាស់ថា រូបមានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការរលត់ ហើយឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះថា រូបក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏កើតសោមនស្សឡើង សោមនស្សណាមានសភាពដូច្នេះ សោមនស្សនេះ តថាគតហៅថា នេក្ខម្មសិតសោមនស្ស ។ បុគ្គលកាលដឹងច្បាស់ថា សំឡេង ... ដឹងច្បាស់ថា ក្លិន ... ដឹងច្បាស់ថា រស ... ដឹងច្បាស់ថា ផោដ្ឋព្វៈ ... ដឹងច្បាស់ថា ធម៌មានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការរលត់ ហើយឃើញច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះ ដូច្នេះថា ធម៌ទាំងឡាយក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី ធម៌ទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏កើតសោមនស្សឡើង សោមនស្សណាមានសភាពដូច្នេះ សោមនស្សនេះ តថាគតហៅថា នេក្ខម្មសិតសោមនស្ស ។ នេះនេក្ខម្មសិតសោមនស្ស ៦ យ៉ាង ។

[ ១០២ ] បណ្តាធម៌ទាំងនោះ គេហសិតទោមនស្សមាន ៦ យ៉ាង តើដូចម្តេច ។ បុគ្គលកាលឃើញច្បាស់ នូវការមិនបានរូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយ

លោកាមិសៈថាជាការមិនបានក្តី កាលរឮកឃើញនូវរូបដែលខ្លួនមិនធ្លាប់បាន ក្នុងកាលមុនក្តី ដែលកន្លងហើយ ដែលរលត់ហើយ ដែលប្រែប្រួលហើយក្តី ហើយក៏កើតទោមនស្សឡើង ទោមនស្សណាមានសភាពដូច្នេះ ទោមនស្សនេះ តថាគតហៅថា គេហសិតទោមនស្ស ។ បុគ្គលកាលឃើញច្បាស់នូវការ មិនបានសំឡេង ដែលគប្បីដឹងដោយត្រចៀក ... ក្លិនដែលគប្បីដឹងដោយ ច្រមុះ ... រសដែលគប្បីដឹងដោយអណ្តាត ... ផោដ្ឋព្វៈដែលគប្បីដឹងដោយ កាយ ... ធម៌ដែលគប្បីដឹងដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ ចិត្ត ជាតម្រេកនៃចិត្ត ប្រកបដោយលោកាមិសៈថាជាការមិនបានក្តី កាល រឮកឃើញនូវធម៌ ដែលខ្លួនមិនធ្លាប់បានក្នុងកាលមុន ដែលកន្លងហើយ ដែល រលត់ហើយ ដែលប្រែប្រួលហើយក្តី ហើយក៏កើតទោមនស្សឡើង ទោម-នស្សណាមានសភាពដូច្នេះ ទោមនស្សនេះ តថាគតហៅថា គេហសិត-ទោមនស្ស ។ នេះគេហសិតទោមនស្ស ៦ យ៉ាង ។

[ ១០៣ ] បណ្តាធម៌ទាំងនោះ នេក្ខម្មសិតទោមនស្សមាន ៦ យ៉ាង តើ ដូចម្តេច ។ បុគ្គលដឹងច្បាស់ថា រូបមានការមិនទៀងមានការប្រែប្រួល មាន ការវិនាស មានការរលត់ ឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាង នេះដូច្នេះថា រូបក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់នោះ សុទ្ធ តែមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏ញុំាងសេចក្តី ស្រឡាញ់ឲ្យតាំងឡើង ក្នុងអនុត្តរវិមោក្ខ គឺព្រះអរហត្តថា កាលណាហ្ន៎ អាត្មាអញនឹងបានដល់នូវអាយតនៈ គឺព្រះអរហត្ត ជាអាយតនៈដែលព្រះ

អរិយៈទាំងឡាយ តែងបានដល់ក្នុងកាលឥឡូវនេះ កាលញុំាងសេចក្តីស្រឡាញ់ឲ្យតាំងឡើង ក្នុងអនុត្តរវិមោក្ខដូច្នេះហើយ ក៏កើតទោមនស្សឡើង ព្រោះតែសេចក្តីស្រឡាញ់ជាបច្ច័យ ទោមនស្សណាមានសភាពដូច្នេះ ទោមនស្សនេះ តថាគតហៅថា នេក្ខម្មសិតទោមនស្ស ។ បុគ្គលកាលដឹងច្បាស់ថា សំឡេង ... ដឹងច្បាស់ថា ក្លិន ... ដឹងច្បាស់ថា រស ... ដឹងច្បាស់ថា ផោដ្ឋព្វៈ ... ដឹងច្បាស់ថា ធម៌ មានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការរលត់ ឃើញច្បាស់តាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះដូច្នេះថា ធម៌ក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី ធម៌ទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏ញុំាងសេចក្តីស្រឡាញ់ឲ្យតាំងឡើងក្នុងអនុត្តរវិមោក្ខថា កាលណាហ្ន៎ អាត្មាអញនឹងបានដល់នូវអាយតនៈជាអាយតនៈដែលព្រះអរិយៈទាំងឡាយ តែងបានដល់ក្នុងកាលឥឡូវនេះ កាលញុំាងសេចក្តីស្រឡាញ់ឲ្យតាំងឡើង ក្នុងអនុត្តរវិមោក្ខ ដូច្នេះហើយ ក៏កើតទោមនស្សឡើង ព្រោះតែសេចក្តីស្រឡាញ់ជាបច្ច័យ ទោមនស្សណាមាន សភាពដូច្នេះ ទោមនស្សនេះ តថាគតហៅថា នេក្ខម្មសិតទោមនស្ស ។ នេះនេក្ខម្មសិតទោមនស្ស ៦ យ៉ាង ។

[ ១០៤ ] បណ្តាធម៌ទាំងនោះ គេហសិតឧបេក្ខា ៦ យ៉ាង តើដូចម្តេច ។ បុថុជ្ជនជាបុគ្គលល្ងង់ វង្វេង ឬបុថុជ្ជនដែលមិនទាន់ផ្ចាញ់កិលេសបាន មិនទាន់ផ្ចាញ់វិបាកបាន ជាអ្នកឃើញថាមិនមានទោស ជាអ្នកមិនចេះដឹងពុទ្ធវចនៈ ឃើញរូបដោយភ្នែក ហើយក៏កើតឧបេក្ខាឡើង ឧបេក្ខាណា

មានសភាពដូច្នេះ ឧបេក្ខានោះ មិនប្រព្រឹត្តកន្លងនូវរូបឡើយ ព្រោះហេតុនោះ ឧបេក្ខានោះ តថាគតហៅថា គេហសិតឧបេក្ខា ។ ឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្តាត ... ពាល់ត្រូវផោដ្ឋព្វៈដោយកាយ ... បុថុជ្ជនល្ងង់ វង្វេង ឬបុថុជ្ជនដែលមិនទាន់ផ្ចាញ់កិលេសបាន មិនទាន់ផ្ចាញ់វិបាកបាន ជាអ្នកឃើញថាមិនមានទោស ជាអ្នកមិនចេះដឹងពុទ្ធវចនៈ ដឹងនូវធម៌ដោយចិត្ត ហើយក៏កើតឧបេក្ខាឡើង ឧបេក្ខាណា មានសភាពដូច្នេះ ឧបេក្ខានោះ មិនប្រព្រឹត្តកន្លងនូវធម៌ឡើយ ព្រោះហេតុនោះ ឧបេក្ខានោះ តថាគតហៅថា គេហសិតឧបេក្ខា ។ នេះគេហសិតឧបេក្ខា ៦ យ៉ាង ។

[ ១០៥ ] បណ្តាធម៌ទាំងនោះ នេក្ខម្មសិតឧបេក្ខា ៦ យ៉ាង តើដូចម្តេច ។ បុគ្គលកាលដឹងច្បាស់ថា រូបមានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការរលត់ ឃើញច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះដូច្នេះថា រូបក្នុងកាលមុនក្តី ក្នុងកាលឥឡូវនេះក្តី រូបទាំងអស់នោះសុទ្ធតែមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា ហើយក៏កើតឧបេក្ខាឡើង ឧបេក្ខាណាមានសភាពដូច្នេះ ឧបេក្ខានោះ មិនប្រព្រឹត្តកន្លងនូវរូបឡើយ ព្រោះហេតុនោះ ឧបេក្ខានោះ តថាគតហៅថា នេក្ខម្មសិតឧបេក្ខា ។ បុគ្គលកាលដឹងច្បាស់ថាសំឡេង ...ថាក្លិន ... ថារស ... ថាផោដ្ឋព្វៈ ... ដឹងច្បាស់ថាធម៌ មានការមិនទៀង មានការប្រែប្រួល មានការវិនាស មានការរលត់ ឃើញច្បាស់តាមពិត ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនេះដូច្នេះថា ធម៌ក្នុងកាល

មុនក្តី ក្នុងកាលឥឡូវនេះក្តី ធម៌ទាំងអស់នោះ សុទ្ធតែមិនទៀង ជាទុក្ខ មាន សេចក្តីប្រែប្រួលជាធម្មតា ហើយក៏កើតឧបេក្ខាឡើង ឧបេក្ខាណាមានសភាព ដូច្នេះ ឧបេក្ខានោះមិនប្រព្រឹត្តកន្លងនូវធម៌ឡើយ ព្រោះហេតុនោះ ឧបេក្ខានោះ តថាគតហៅថា នេក្ខម្មសិតឧបេក្ខា ។ នេះនេក្ខម្មសិតឧបេក្ខាមាន ៦ យ៉ាង ។ ពាក្យណាដែលតថាគតពោលហើយថា បណ្ឌិតគប្បីដឹងសត្តបទ ៣៦ ដូច្នេះ ពាក្យនុ៎ះ តថាគតពោល ព្រោះអាស្រ័យនូវហេតុនេះឯង ។

[ ១០៦ ] ពាក្យថា បណ្តាធម៌ទាំងនោះ អ្នកទាំងឡាយចូរអាស្រ័យនឹង ធម៌នេះ ហើយលះបង់នូវធម៌នេះចេញ ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ បណ្តា ធម៌ទាំងនោះ អ្នកទាំងឡាយចូរអាស្រ័យ ពឹងផ្អែកនូវនេក្ខម្មសិតសោមនស្ស ទាំង ៦ ហើយលះបង់ កន្លងឲ្យផុតនូវគេហសិតសោមនស្សទាំង ៦ ចេញ ការលះបង់នូវសោមនស្សទាំងនោះ យ៉ាងនេះឯង ការកន្លងឲ្យផុតនូវសោម-នស្សទាំងនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ អ្នក ទាំងឡាយ ចូរអាស្រ័យពឹងផ្អែកនូវនេក្ខម្មសិតទោមនស្សទាំង ៦ ហើយ លះបង់ កន្លងឲ្យផុតនូវគេហសិតទោមនស្សទាំង ៦ ចេញ ការលះបង់នូវ ទោមនស្សទាំងនោះ យ៉ាងនេះឯង ការកន្លងឲ្យផុតនូវទោមនស្សទាំងនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ អ្នកទាំងឡាយ ចូរ អាស្រ័យពឹងផ្អែកនឹងនេក្ខម្មសិតឧបេក្ខាទាំង ៦ ហើយលះបង់ កន្លងឲ្យផុត នូវគេហសិតឧបេក្ខាទាំង ៦ ចេញ ការលះបង់ឧបេក្ខាទាំងនោះ យ៉ាងនេះឯង

ការកន្លងឲ្យផុតនូវឧបេក្ខាទាំងនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ អ្នកទាំងឡាយ ចូរអាស្រ័យពឹងផ្អែក នឹងនេក្ខម្មសិតសោមនស្សទាំង ៦ ហើយលះបង់ កន្លងឲ្យផុតនូវនេក្ខម្មសិតទោមនស្សទាំង ៦ ចេញ ការលះបង់នូវទោមនស្សទាំងនោះ យ៉ាងនេះឯង ការកន្លងឲ្យផុតនូវទោមនស្សទាំងនោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ អ្នកទាំងឡាយ ចូរអាស្រ័យពឹងផ្អែកនឹងនេក្ខម្មសិតឧបេក្ខាទាំង ៦ ហើយលះបង់ កន្លងឲ្យផុតនូវនេក្ខម្មសិតសោមនស្សទាំង ៦ ចេញ ការលះបង់នូវសោមនស្សទាំងនោះ យ៉ាងនេះឯង ការកន្លងឲ្យផុតនូវសោមនស្សទាំងនោះ យ៉ាងនេះឯង ។

[ ១០៧ ] ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាផ្សេងគ្នា អាស្រ័យនូវអារម្មណ៍ផ្សេងគ្នាក៏មាន ឧបេក្ខាជាមួយគ្នា អាស្រ័យនូវអារម្មណ៍ជាមួយគ្នាក៏មាន ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាផ្សេងគ្នា អាស្រ័យនូវអារម្មណ៍ផ្សេងគ្នា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាក្នុងរូបក៏មាន ក្នុងសំឡេងក៏មាន ក្នុងក្លិនក៏មាន ក្នុងរសក៏មាន ក្នុងផោដ្ឋព្វៈក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះឧបេក្ខាផ្សេងគ្នា អាស្រ័យនូវអារម្មណ៍ផ្សេងគ្នា ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាជាមួយគ្នា អាស្រ័យនូវអារម្មណ៍ជាមួយគ្នា តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ឧបេក្ខាអាស្រ័យនូវអាកាសានញ្ចាយតនជ្ឈានក៏មាន អាស្រ័យនូវវិញ្ញាណញ្ចាយតនជ្ឈានក៏មាន អាស្រ័យនូវអាកិញ្ចញ្ញាយតនជ្ឈានក៏មាន អាស្រ័យនូវនេវសញ្ញានាសញ្ញាយតនជ្ឈានក៏មាន ។ ម្នាលភិក្ខុទាំងឡាយ នេះ

ជាឧបេក្ខាជាមួយគ្នា អាស្រ័យនូវអារម្មណ៍ជាមួយគ្នា ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាឧបេក្ខាទាំងពីរនោះ អ្នកទាំងឡាយ ចូរអាស្រ័យពឹងផ្អែកនឹងឧបេក្ខាជាមួយគ្នា មានអារម្មណ៍ជាមួយគ្នា ហើយលះបង់ កន្លងឲ្យផុតនូវឧបេក្ខាផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នាចេញ ការលះបង់នូវឧបេក្ខានុ៎ះ យ៉ាងនេះឯង ការកន្លងឲ្យផុតនូវឧបេក្ខានុ៎ះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ ចូរអាស្រ័យនឹងតណ្ហា ពឹងផ្អែកនឹងតណ្ហា ហើយលះបង់ កន្លងឲ្យផុតនូវឧបេក្ខាជាមួយគ្នា មានអារម្មណ៍ជាមួយគ្នាចេញ ការលះបង់ឧបេក្ខានុ៎ះ យ៉ាងនេះឯង ការកន្លងឲ្យផុតនូវឧបេក្ខានុ៎ះ យ៉ាងនេះឯង ។ ពាក្យណា ដែលតថាគតពោលហើយថា បណ្ដាធម៌ទាំងនោះ អ្នកទាំងឡាយ ចូរអាស្រ័យនឹងធម៌នេះ ហើយលះបង់នូវធម៌នេះចេញ ដូច្នេះនេះ ពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យហេតុនេះឯង ។

[ ១០៨ ] ពាក្យថា សតិប្បដ្ឋានមាន ៣ ប្រការ ដែលសាស្ដាដ៏ប្រសើរតែងសេព កាលសាស្ដាដ៏ប្រសើរសេពហើយ ទើបគួរនឹងប្រៀនប្រដៅគណៈបាន ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោលព្រោះអាស្រ័យអ្វី ។

[ ១០៩ ] ម្នាលភិក្ខុទាំងឡាយ សាស្ដាជាអ្នកអនុគ្រោះ ជាអ្នកស្វែងរកប្រយោជន៍ តែងសម្ដែងធម៌ដល់ពួកសាវក ព្រោះអាស្រ័យនូវសេចក្ដីអនុគ្រោះដូច្នេះថា ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីសេចក្ដីសុខដល់អ្នកទាំងឡាយ ។ តែពួកសាវក

របស់សាស្ដានោះមិនចង់ស្ដាប់ មិនផ្ចង់ត្រចៀក មិនតាំងចិត្តដើម្បីឲ្យដឹងសេចក្ដី ក៏ប្រព្រឹត្តកន្លងពាក្យប្រៀនប្រដៅរបស់សាស្ដាទៅវិញ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដំណើរនោះ ព្រះតថាគតមិនមានចិត្តរីករាយ មិនទទួលនូវសេចក្ដីរីករាយ មានចិត្តមិនប្រឡាក់ដោយរាគៈ មានតែសតិសម្បជញ្ញៈ ប្រព្រឹត្តទៅគ្រប់ឥរិយាបថ ម្នាលភិក្ខុទាំងឡាយ នេះហៅសតិប្បដ្ឋានទី ១ ដែលសាស្ដាដ៏ប្រសើរតែងសេព កាលសាស្ដាដ៏ប្រសើរសេពហើយ ទើបគួរនឹងប្រៀនប្រដៅគណៈបាន ។

[ ១១០ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត សាស្ដាជាអ្នកអនុគ្រោះ ស្វែងរកប្រយោជន៍ តែងសម្ដែងធម៌ដល់ពួកសាវ័ក ព្រោះអាស្រ័យនូវសេចក្ដីអនុគ្រោះថា ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីសេចក្ដីសុខដល់អ្នកទាំងឡាយ ។ សាវ័កពួកខ្លះ របស់សាស្ដានោះមិនចង់ស្ដាប់ មិនផ្ចង់ត្រចៀក មិនតាំងចិត្តដើម្បីឲ្យដឹងសេចក្ដី ក៏ប្រព្រឹត្តកន្លងពាក្យប្រៀនប្រដៅរបស់សាស្ដា ។ សាវ័កពួកខ្លះ ចង់ស្ដាប់ ផ្ចង់ត្រចៀក តាំងចិត្តដើម្បីឲ្យដឹងសេចក្ដី មិនហ៊ានប្រព្រឹត្តកន្លងនូវពាក្យប្រៀនប្រដៅរបស់សាស្ដាឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដំណើរនោះព្រះតថាគត ក៏មិនមានចិត្តរីករាយ មិនទទួលនូវសេចក្ដីរីករាយ មិនមានតូចចិត្ត មិនទទួលនូវសេចក្ដីតូចចិត្ត វៀរបង់នូវសេចក្ដីរីករាយ និងសេចក្ដីតូចចិត្តទាំងពីរនោះ ជាអ្នកព្រងើយ ប្រកបដោយសតិសម្បជញ្ញៈ ប្រព្រឹត្តនៅគ្រប់ឥរិយាបថ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សតិប្បដ្ឋានទី ២ ដែលសាស្ដាដ៏

ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរនឹងប្រៀនប្រដៅនូវគណៈបាន ។

[ ១១១ ] ម្នាលភិក្ខុទាំងឡាយ មួយទៀត សាស្តាជាអ្នកអនុគ្រោះស្វែងរកប្រយោជន៍ រមែងសម្តែងធម៌ដល់ពួកសាវក ព្រោះអាស្រ័យនូវសេចក្តីអនុគ្រោះថា ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់អ្នកទាំងឡាយ ធម្មជាតនេះ ប្រព្រឹត្តទៅដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយ ។ តែពួកសាវករបស់សាស្តានោះ ចង់ស្តាប់ ផ្ទង់ត្រចៀក តាំងចិត្តដើម្បីឲ្យដឹងសេចក្តី ទាំងមិនបានប្រព្រឹត្តកន្លងពាក្យប្រៀនប្រដៅរបស់សាស្តា ។ ម្នាលភិក្ខុទាំងឡាយ ក្នុងដំណើរនោះ ព្រះតថាគតរមែងមានចិត្តរីករាយ ទទួលនូវសេចក្តីរីករាយ តែថា មានចិត្តមិនប្រឡាក់ដោយរាគៈ ជាអ្នកមានសតិសម្បជញ្ញៈ ប្រព្រឹត្តទៅគ្រប់ឥរិយាបថ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សតិប្បដ្ឋានទី ៣ ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរនឹងប្រៀនប្រដៅនូវគណៈបាន ។ ពាក្យថា សតិប្បដ្ឋានមាន ៣ ប្រការ ដែលសាស្តាដ៏ប្រសើរតែងសេព កាលសាស្តាដ៏ប្រសើរសេពហើយ ទើបគួរប្រៀនប្រដៅនូវគណៈបាន ដូច្នេះ តថាគតពោលហើយ ពាក្យនេះ ដែលតថាគតពោល ព្រោះអាស្រ័យនូវហេតុនេះឯង ។

[ ១១២ ] ពាក្យថា បុគ្គលនោះ តថាគតហៅថា ជាសារថីទូន្មាននូវបុរស ជាអាចារ្យប្រសើរជាងអាចារ្យអ្នកទូន្មាននូវវាហនៈ មានដំរីជាដើម ដូច្នេះនេះ តថាគតបានពោលហើយ ។ ចុះពាក្យនុ៎ះ តថាគតពោល ព្រោះ

អាស្រ័យអ្វី ។ ម្នាលភិក្ខុទាំងឡាយ ដំរីគួរទូន្មានដែលទមក់ដំរីបានទូន្មានហើយ រមែងស្ទុះទៅ កាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ សេះគួរទូន្មានដែលទម័កសេះបានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ គោគួរទូន្មានដែលទម័កគោបានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសតែមួយៗ គឺទិសខាងកើតក្តី ខាងលិចក្តី ខាងជើងក្តី ខាងត្បូងក្តី ។ ម្នាលភិក្ខុទាំងឡាយ ឯបុរសគួរទូន្មានដែលព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធបានទូន្មានហើយ រមែងស្ទុះទៅកាន់ទិសទាំង ៨ បាន គឺបុគ្គលបាននូវរូបជ្ឈាន តែងមើលឃើញនូវរូបទាំងឡាយ នេះជាទិសទី ១ ។ បុគ្គលមិនបានសម្គាល់នូវរូបខាងក្នុង តែងឃើញនូវរូបខាងក្រៅទាំង-ឡាយ នេះជាទិសទី ២ ។ បុគ្គលបង្អោនចិត្តទៅកាន់អារម្មណ៍ថា ( នេះ ) ល្អដូច្នេះ នេះជាទិសទី ៣ ។ បុគ្គលព្រោះកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង ព្រោះអស់បដិឃសញ្ញា ព្រោះលែងធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ នេះជាទិសទី ៤ ។ បុគ្គលព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ នេះជាទិសទី ៥ ។ បុគ្គលព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវ

អាកិញ្ចញ្ញាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ដូច្នេះ ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ នេះជាទិសទី ៦ ។ បុគ្គលព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ប្រព្រឹត្តនៅគ្រប់ឥរិយាបថទាំង ៤ នេះជាទិសទី ៧ ។ បុគ្គលព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏បានដល់នូវសញ្ញាវេទយិតនិរោធ ប្រព្រឹត្តនៅគ្រប់ឥរិយាទាំង ៤ នេះជាទិសទី ៨ ។ ម្នាលភិក្ខុទាំងឡាយ បុរសគួរទូន្មានដែលព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធទូន្មានហើយ រមែងស្ទុះទៅកាន់ទិសទាំង ៨ នេះឯង ។ ពាក្យណាថា បុគ្គលនោះតថាគតហៅថាជាសារថីអ្នកទូន្មាននូវបុរស ជាអាចារ្យប្រសើរជាងអាចារ្យអ្នកទូន្មាននូវវាហនៈ មានដំរីជាដើម ដូច្នេះ តថាគតបានពោលហើយ ពាក្យនុ៎ះតថាគតពោលព្រោះអាស្រ័យនូវហេតុនេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់សម្តែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានចិត្តត្រេកអររីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

សឡាយតនវិភង្គសូត្រទី ៧ ចប់

# អដ្ឋកថា

## សឡាយតនវិភង្គសូត្រ

[ ៩២ ] សឡាយតនវិភង្គសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះ ជាដើម ។

[ ៩៣ ] បណ្តាបទទាំងនោះ បទថា **វេទិតព្វានិ** សេចក្តីថា គប្បីដឹង ដោយមគ្គ ដែលមានវិបស្សនា ។ បទថា **មនោបវិចារា** បានដល់ វិតក្ក និងវិចារ ។ ពិតហើយ មនៈដែលញ៉ាំងវិតក្កឲ្យកើតឡើង លោកបំណងយក ថា **មន** ក្នុងទីនោះ ។ ឈ្មោះថា **មនោបវិចារា** ព្រោះអត្ថថា ជាការនឹក ត្រិះរិះរបស់ចិត្ត ។ បទថា **សត្តបទា** បានដល់ ផ្លូវធ្វើដំណើររបស់សត្វ ទាំងឡាយដែលអាស្រ័យវដ្តៈ និងវិវដ្តៈ ។ ក្នុងទីនេះ ផ្លូវទៅកាន់វដ្តៈមាន ១៨ ប្រការ ផ្លូវទៅកាន់វិវដ្តៈក៏មាន ១៨ ប្រការដែរ ។ ផ្លូវទាំងនោះ គប្បី ជ្រាបដោយមគ្គដែលមានវិបស្សនានោះឯង ។ បទថា **យោគ្គាចរិយានំ** សេចក្តីថា អ្នកឲ្យសិក្សាអាចារ មានហត្ថិយោគជាដើម បានដល់ បុគ្គល ទូន្មានបុគ្គលដែលគួរទូន្មាន ។ បទដ៏សេសជាក់ច្បាស់ក្នុងវិភង្គនោះឯង ។ បទ ថា **អយមុទ្ទេសោ** នេះ ជាបទតាំងមាតិកា ។ អាយតនៈទាំងឡាយ មាន ចក្ខាយតនៈជាដើម មានពិស្តារហើយ ក្នុងវិសុទ្ធិមគ្គ ។

[ ៩៦ ] បទថា **ចក្ខុវិញ្ញាណំ** បានដល់ ចក្ខុវិញ្ញាណទាំង ២ ដោយ វិបាករបស់កម្មដែលជាកុសល និងអកុសល ។ ក្នុងបសាទវិញ្ញាណដ៏សេស ទាំងឡាយ ក៏មានន័យនេះដូចគ្នា ។ វិញ្ញាណដ៏សេស វៀរវិញ្ញាណ ៥

ប្រការនេះ ឈ្មោះថា មាននៅវិញ្ញាណក្នុងទីនេះ ។

[ ៩៧ ] បទថា **ចក្ខុសម្ផស្សោ** បានដល់ ផស្សៈក្នុងចក្ខុ ។ នុ៎ះជាឈ្មោះរបស់ផស្សៈ ដែលប្រកបដោយចក្ខុវិញ្ញាណ ។ ក្នុងសម្ផស្សដ៏សេសទាំងឡាយ ក៏ន័យនេះដូចគ្នា ។

[ ៩៨ ] បទថា **ចក្ខុនា រូបំ ទិស្វា** សេចក្តីថា ព្រោះឃើញរូបដោយចក្ខុវិញ្ញាណ ។ ក្នុងបទទាំងពួង ក៏ន័យនេះដូចគ្នា ។ បទថា **សោមនស្សដ្ឋានិយំ** បានដល់ ជាហេតុដោយអំណាចនៃអារម្មណ៍របស់សោមនស្ស ។ បទថា **ឧបវិចរតិ** សេចក្តីថា ចិត្តរមែងនឹកពាវរក ដោយការប្រព្រឹត្តិទៅរបស់វិតក្ក ក្នុងការនឹកពាវរករបស់ចិត្តនោះ ។ គប្បីជ្រាបការនឹកពាវរករបស់ចិត្ត ពោល គឺវិតក្ក វិចារ ១៨ ប្រការ ដោយន័យជាដើមថា **វិតក្កោ តំសម្បយុត្តោ ច** ឈ្មោះថា សោមនស្សូបវិចារ ព្រោះអត្ថថា នឹកពាវរកព្រមជាមួយសោមនស្ស ក្នុងបទថា **ឆ សោមនស្សូបវិចារា** នេះ ក្នុងបទទាំង ២ ដ៏សេស ក៏ន័យនេះដូចគ្នា ។

[ ៩៩ ] បទថា **គេហសិតានិ** បានដល់ អាស្រ័យកាមគុណ ។ បទថា **នេក្ខម្មសិតានិ** បានដល់ អាស្រ័យវិបស្សនា ។

[ ១០០ ] បទថា **ឥដ្ឋានំ** បានដល់ ស្វែងរកហើយ ។ បទថា **កន្តានំ** បានដល់ ឲ្យនូវការស្រឡាញ់ ។ បទថា **មនោរមានំ** សេចក្តីថា ចិត្តរមែងត្រេកអរក្នុងធម្មារម្មណ៍ទាំងនោះ ព្រោះដូច្នោះ ទើបធម្មារម្មណ៍ទាំងនោះឈ្មោះថា ជាទីមកត្រេកអរនៃចិត្ត ធម្មារម្មណ៍ទាំងនោះ ជាទីត្រេកអរនៃចិត្ត ។

បទថា **លោកាមិសប្បដិសំយុត្តានំ** គឺប្រកបដោយតណ្ហា ។ បទថា **អតីតំ** គឺដែលបានចំពោះហើយ ។ សួរថា សោមនស្សប្រារព្ធបច្ចុប្បន្នកើតឡើងមុន និងកើតឡើងក្នុងអតីតដូចម្តេច ។ ឆ្លើយថា សោមនស្សដែលមានកម្លាំង រមែងកើតដល់បុគ្គលដែលរឭកទៅក្រោយ ក្នុងអតីតថា អញសោយឥដ្ឋារម្មណ៍ក្នុងឥឡូវនេះ យ៉ាងណា អញសោយហើយ ក្នុងកាលមុនក៏ដូច្នោះ ។

[ ១០១ ] បទថា **អនិច្ចតំ** បានដល់ អាការដែលមិនទៀង ។ បទថា **វិបរិណាមវិរាគនិរោធំ** សេចក្តីថា ឈ្មោះថា ការប្រែប្រួល ព្រោះលះប្រក្រតី ឈ្មោះថា ការលះទៅ ព្រោះទៅប្រាស ឈ្មោះថា ការរលត់ ព្រោះរលត់ទៅ ។ បទថា **សម្មប្បញ្ញាយ** បានដល់ វិបស្សនាបញ្ញា ។ បទថា **ឥទំ វុច្ចតិ នេក្ខម្មសិតសោមនស្សំ** សេចក្តីថា សោមនស្សនេះកើតឡើងហើយ ដល់បុគ្គលដែលអង្គុយចម្រើនវិបស្សនា ឃើញការបែកធ្លាយនៃសង្ខារទាំងឡាយ ដូចព្រះរាជាឃើញសិរីសម្បត្តិរបស់ព្រះអង្គ ដូច្នោះ ក្នុងកាលវិបស្សនាញាណចាស់ក្លា សូម្បីសង្ខារនាំទៅ យើងក៏ហៅថា សោមនស្សអាស្រ័យនេក្ខម្មៈ ។ សមដូចគាថាព័ន្ធ ដែលលោកត្រាស់ក្នុងធម្មបទដូច្នេះថា

សេចក្តីត្រេកអរ ដែលមិនមែនជារបស់មនុស្ស រមែង
មានដល់ភិក្ខុ អ្នកចូលទៅកាន់ផ្ទះស្ងាត់ អ្នកមានចិត្ត
រម្ងាប់ អ្នកឃើញធម៌ដោយប្រពៃ ។ ភិក្ខុពិចារណា
ការកើតឡើង និងការវិនាសខន្ធទាំងឡាយ ក្នុងកាល
ណា ក្នុងកាលនោះ ភិក្ខុនោះ រមែងបានបីតិ និង

បាមោជ្ជ បីតិ និងបាមោជ្ជនោះ ឈ្មោះថា ជាអមតធម៌
របស់បណ្ឌិតអ្នកដឹងធម៌ទាំងឡាយ ។

បទថា **ឥមានិ** សេចក្តីថា ទាំងនេះ សោមនស្សអាស្រ័យនេក្ខម្មៈ ៦ យ៉ាងកើតហើយ ដល់បុគ្គលដែលអន្ទ្រយចម្រើនវិបស្សនា ដោយអំណាចនៃការមិនទៀងជាដើម កាលឥដ្ឋារម្មណ៍ទៅកាន់គន្លងក្នុងទ្វារ ៦ ។

[ ១០២ ] បទថា **អតីតំ** សេចក្តីថា ទោមនស្ស ចូរកើតដល់បុគ្គលដែលប្រាថ្នាមិនបានឥដ្ឋារម្មណ៍បច្ចុប្បន្ន និងកើតក្នុងអតីតដូចម្តេច ។ ទោមនស្សដែលមានកម្លាំង រមែងកើតដល់បុគ្គលដែលរឭកទៅក្រោយ ក្នុងអតីតថា អញប្រាថ្នាហើយ មិនបានឥដ្ឋារម្មណ៍ក្នុងឥឡូវនេះ យ៉ាងណា អញប្រាថ្នាហើយ មិនបានក្នុងកាលមុន ក៏ដូច្នោះ ។ បទថា **អនុត្តរេសុ វិមោក្ខេសុ** គឺអរហត្ត ឈ្មោះថា អនុត្តរវិមោក្ខ ។ អធិប្បាយថា តាំងសេចក្តីប្រាថ្នាក្នុងអរហត្ត ។ បទថា **អាយតនំ** បានដល់ អាយតនៈ គឺអរហត្ត ។ បទថា **បិហំ ឧបដ្ឋាបយតោ** សេចក្តីថា តាំងសេចក្តីប្រាថ្នា ។ អាយតនៈនោះ រមែងកើតដល់បុគ្គលដែលតាំងសេចក្តីប្រាថ្នានោះ ។ អធិប្បាយថា បុគ្គលចូលទៅតាំងសេចក្តីប្រាថ្នា ព្រោះអាយតនៈជាឫសគល់នៃការប្រាថ្នា ដោយប្រការដូច្នេះ ។ បទថា **ឥមានិ ឆ នេក្ខម្មសិតានិ ទោមនស្សានិ** សេចក្តីថា ទោមនស្សដែលកើតដល់បុគ្គលដែលតាំងសេចក្តីប្រាថ្នាក្នុងអរហត្ត ក្នុងកាលឥដ្ឋារម្មណ៍ទៅកាន់គន្លងក្នុងទ្វារ ៦ យ៉ាងនេះ មិនអាចដើម្បីតាំងវិបស្សនាឲ្យចម្រើនឡើង ដោយអំណាចនៃការមិនទៀងជាដើម ។ ដើម្បីសម្រេចអរហត្ត

នោះ ដូចព្រះមហាសិវត្ថេរនៅក្នុងញកភ្នំ ក្បែរស្រុក សោយសោកថា អាត្មាអញមិនអាចសម្រេចអរហត្ត អស់បក្ខនេះខ្លះ អស់ខែនេះខ្លះ អស់ឆ្នាំនេះខ្លះ ដោយអំណាចការប្រព្រឹត្តិទៅនៃទឹកភ្នែក ដូច្នេះ គប្បីជ្រាបថា ទោមនស្សអាស្រ័យនេក្ខម្ម: ៦ ឯរឿងរ៉ាវក៏បានឲ្យពិស្តារហើយ ក្នុងសក្កបញ្ហវណ្ណនា ក្នុងអដ្ឋកថាទីឃនិកាយ ឈ្មោះសុមង្គលវិលាសិនី ។ បុគ្គលត្រូវការ គប្បីកាន់យកអំពីអដ្ឋកថានោះចុះ ។

[ ១០៤ ] ឧបេក្ខាក្នុងអញ្ញាណ ឈ្មោះថា ឧបេក្ខា ក្នុងបទថា **ឧបេក្ខា** ។ បទថា **អនោធិជិនស្ស** សេចក្តីថា ព្រះខីណាស្រព ឈ្មោះថា **ឱធិជិន** ព្រោះព្រះខីណាស្រពឈ្នះសត្រូវ គឺកិលេស ហើយស្ថិតនៅ ។ ព្រោះដូច្នេះ បទនេះ បានដល់បុថុជ្ជនដែលមិនទាន់អស់អាសវៈ ។ ព្រះខីណាស្រព ឈ្មោះថា **វិបាកជិន** ព្រោះព្រះខីណាស្រពឈ្នះវិបាកតទៅ ស្ថិតនៅ សូម្បីក្នុងបទថា **អវិបាកជិនស្ស** បានដល់ បុគ្គលអ្នកមិនអស់អាសវៈនោះឯង ។ បទថា **អនាទីនវទស្សាវិនោ** បានដល់ បុគ្គលមិនឃើញដោយភាពជាទោស ។ បទថា **ឥមា ច គេហសិតា ឧបេក្ខា** សេចក្តីថា ឧបេក្ខាដែលមិនត្រឡប់កាន់រូបជាដើម ដូចរុយដែលទំត្រង់ដុំស្ករអំពៅ កាលឥដ្ឋារម្មណ៍ទៅកាន់គន្លងក្នុងទ្វារ ៦ យ៉ាងនេះ ជាប់នៅក្នុងរូបជាដើមនោះ កើតឡើងនេះ គប្បីជ្រាបថា ឧបេក្ខាអាស្រ័យផ្ទះ ៦ ។ បទថា **រូបំ សា នាតិវត្តតិ** សេចក្តីថា ឧបេក្ខានោះ មិនកន្លងរូប ។ មិនតាំងនៅដោយអំណាចការនឿយណាយក្នុងរូបនោះ ។

[ ១០៥ ] បទថា **ឥមា ច នេក្ខម្មសិតា ឧបេក្ខា** សេចក្តីថា ឧបេក្ខា

កើតឡើងដល់បុគ្គលមិនត្រេកអរក្នុងឥដ្ឋារម្មណ៍ មិនប្រទូស្តក្នុងអនិដ្ឋារម្មណ៍ កាលអារម្មណ៍ដែលគួរប្រាថ្នាជាដើម ទៅកាន់គន្លងក្នុងទ្វារ ៦ យ៉ាងនេះ មិនវង្វេងដោយការពិចារណាមិនល្អ ប្រកបដោយឧបេក្ខាញាណទាំងនេះ គប្បីជ្រាបថា ជាឧបេក្ខាអាស្រ័យនេក្ខម្មៈ ៦ ។

[ ១០៦ ] បទថា **តត្រ ឥទំ និស្សាយ ឥទំ បជហថ** សេចក្តីថា ក្នុងផ្លូវរបស់សត្វ ៣៦ ប្រការនោះ ពួកអ្នកចូរអាស្រ័យផ្លូវ ១៨ ប្រការ លះផ្លូវ ១៨ ប្រការ ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា **តត្រ ភិក្ខវេ យានិ ឆ នេក្ខម្មសិតានិ** ដូច្នេះជាដើម ។ បទថា **និស្សាយ អាគម្ម** បានដល់ អាស្រ័យ និងពឹងផ្អែក ដោយអំណាចការប្រព្រឹត្តិទៅ ។ បទថា **ឯវមេតេសំ សមតិក្កមោ ហោតិ** សេចក្តីថា ឈ្មោះថា កន្លងឧបេក្ខាអាស្រ័យផ្ទះ ព្រោះការប្រព្រឹត្តិទៅនៃឧបេក្ខាអាស្រ័យនេក្ខម្មៈយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់ឲ្យលះធម៌ដែលដូចគ្នា ដោយធម៌ដែលដូចគ្នាយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់ឲ្យលះធម៌ដែលមិនមានកម្លាំង ដោយធម៌ដែលមានកម្លាំង ទើបត្រាស់ទៀតថា **តត្រ ភិក្ខវេ យានិ ឆ នេក្ខម្មសិតានិ សោមនស្សានិ** ដូច្នេះជាដើម ។ ព្រះមានព្រះភាគ ទ្រង់ឲ្យលះទោមនស្សអាស្រ័យនេក្ខម្មៈ ដោយសោមនស្សអាស្រ័យនេក្ខម្មៈ និងសោមនស្សអាស្រ័យនេក្ខម្មៈ ដោយឧបេក្ខាអាស្រ័យនេក្ខម្មៈយ៉ាងនេះ ទើបត្រាស់ការលះធម៌ដែលមិនមានកម្លាំង ដោយធម៌ដែលមានកម្លាំង ។ បណ្ឌិតតាំងនៅក្នុងការលះនោះ គប្បីពោលឧបេក្ខា ។ ឯបុព្វភាគវិបស្សនានៃភិក្ខុ ៤ រូប ដែលប្រារព្ធវិបស្សនា ធ្វើ

ឈាន ៣ មានបឋមជ្ឈានជាដើម ក្នុងសមាបត្តិ ៨ និងសង្ខារបរិសុទ្ធទាំងឡាយ ឲ្យជាបាទ រមែងសហគតៈដោយសោមនស្ស ឬសហគតៈដោយឧបេក្ខា ។ ចំណែកវុដ្ឋានគាមិនី សហគតៈដោយសោមនស្សនោះឯង ។ បុព្វភាគវិបស្សនារបស់ភិក្ខុ ៥ រូប ដែលប្រារព្ធវិបស្សនា ធ្វើឈានទាំងឡាយ មានចតុត្ថជ្ឈានជាដើមឲ្យជាបាទ ក៏ដូចគ្នានឹងន័យមុន ។ ឯវុដ្ឋានគាមិនី ជាការសហគតៈដោយឧបេក្ខា ។ ទ្រង់សំដៅដល់បទនេះ ទើបត្រាស់ថា ឧបេក្ខាអាស្រ័យនេក្ខម្មៈ ៦ ណា ពួកអ្នកអាស្រ័យឧបេក្ខាទាំងនោះ ពឹងផ្អែកឧបេក្ខាទាំងនោះ ចូរលះសោមនស្ស អាស្រ័យនេក្ខម្មៈ ៦ ដូច្នេះ ។ ភិក្ខុបដិបត្តិយ៉ាងនេះ រមែងមានគុណវិសេស ដោយអំណាចនៃវេទនា មិនមែនដោយវិបស្សនានេះតែម្យ៉ាងឡើយ ។ គុណវិសេសនៃអង្គរបស់ឈាន ពោជ្ឈង្គ និងអង្គនៃមគ្គ រមែងមានក្នុងអរិយមគ្គ ។ អ្វីកំណត់គុណវិសេសនោះ ។ ព្រះថេរៈពួកខ្លះពោលជាបឋមថា ឈានដែលមានវិបស្សនាជាបាទ រមែងកំណត់ ។ ព្រះថេរៈពួកខ្លះពោលថា ខន្ធទាំងឡាយដែលជាអារម្មណ៍របស់វិបស្សនា រមែងកំណត់ ។ ពួកខ្លះពោលថា អជ្ឈាស្រ័យរបស់បុគ្គល រមែងកំណត់ ។ ក្នុងវាទៈនៃព្រះថេរៈទាំងនោះ វិបស្សនាដែលជាវុដ្ឋានគាមិនីក្នុងបុព្វភាគនេះឯង គប្បីជ្រាបថា រមែងកំណត់ ។ ឯវិនិច្ឆ័យកថាក្នុងសេចក្តីនេះ បានពោលហើយ ក្នុងសង្ខារុបេក្ខានិទ្ទេស ក្នុងវិសុទ្ធិមគ្គនោះឯង ។

[ ១០៧ ] បទថា **នានត្តា** បានដល់ ផ្សេងៗ ច្រើន មានប្រមាណមិនមែនតែមួយ បទថា **នានត្តសិតា** បានដល់ អាស្រ័យអារម្មណ៍ផ្សេងៗ ។

បទថា **ឯកត្តា** បានដល់ ១ ។ បទថា **ឯកត្តសិតា** បានដល់ អាស្រ័យអារម្មណ៍ ១ ។ សួរថា ឧបេក្ខានេះដូចម្តេច ។ ឆ្លើយថា បានត្រាស់អញ្ញាណុបេក្ខាទុកមុន ។ ត្រាស់ឆឡង្គុបេក្ខាទុកក្រោយ ។ ទ្រង់កាន់យកឧបេក្ខា ២ យ៉ាង គឺសមថឧបេក្ខា និងវិបស្សនូបេក្ខាក្នុងទីនេះ ។ ឧបេក្ខា ២ យ៉ាងនេះ ព្រោះឧបេក្ខាក្នុងរូប ១ ឧបេក្ខាក្នុងសំឡេងជាដើម ១ ។ ឧបេក្ខាក្នុងរូបរមែងមិនមានក្នុងសំឡេងជាដើម ។ ឧបេក្ខាក្នុងរូបប៉ុណ្ណោះ ធ្វើរូបប៉ុណ្ណោះឲ្យជាអារម្មណ៍ ។ សំឡេងជាដើម រមែងមិនធ្វើរូប និងភាពជាឧបេក្ខាឲ្យជាអារម្មណ៍ ។ សមថឧបេក្ខាដទៃៗ គឺឧបេក្ខាដែលធ្វើបឋវីកសិណ ឲ្យជាអារម្មណ៍កើតឡើង ។ ឧបេក្ខាដទៃៗ គឺឧបេក្ខាដែលកើតឡើង ព្រោះធ្វើអបោកសិណជាដើមឲ្យជាអារម្មណ៍ ព្រោះដូច្នោះ កាលទ្រង់ចែកសេចក្តីផ្សេងៗ និងអាស្រ័យអារម្មណ៍ផ្សេងៗ ទើបត្រាស់ថា **អត្ថិ ភិក្ខវេ ឧបេក្ខា រូបេ** ជាដើម ព្រោះអាកាសានញ្ចាយតនៈ ឬវិញ្ញាណញ្ចាយតនៈជាដើម មិនមាន ២ ឬ ៣ ។ ព្រោះដូច្នោះ កាលទ្រង់ចែកអាស្រ័យអារម្មណ៍ ១ ទើបត្រាស់ថា **អត្ថិ ភិក្ខវេ ឧបេក្ខា អាកាសានញ្ចាយតននិស្សិតា** ដូច្នេះជាដើម ។ បណ្តាឧបេក្ខាទាំងនោះ អាកាសានញ្ចាយតនូបេក្ខា អាស្រ័យអាកាសានញ្ចាយតនៈ ដោយអំណាចដែលជាសម្បយុត្ត ។ វិបស្សនូបេក្ខារបស់ភិក្ខុដែលឃើញច្បាស់នូវអាកាសានញ្ចាយតនក្ខន្ធ អាស្រ័យអាកាសានញ្ចាយតនៈ ដោយអំណាចនៃអារម្មណ៍ ។ ក្នុងឧបេក្ខាដ៏សេស ក៏ន័យនេះដូចគ្នា ។ ទ្រង់ឲ្យលះរូបាវចរកុសលសមាបត្តិឧបេក្ខា ដោយអរូបាវចរសមាបត្តិឧបេក្ខា ទ្រង់

ឲ្យលះរូបាវចរ វិបស្សនូបេក្ខា ដោយអរូបាវចរវិបស្សនូបេក្ខា ក្នុងបទថា **តំ បជហាថ** ដូច្នេះ តណ្ហា ឈ្មោះថា **តម្មយតា** ក្នុងបទនេះថា **អតម្មយតំ** ។ វិបស្សនា ដែលឲ្យដល់នូវការចេញចាកការរួបរឹតនៃតណ្ហានោះ ហៅថា **អតម្មយតា** ។ តែងលះអរូបាវចរសមាបត្តិឧបេក្ខា និងវិបស្សនូបេក្ខា ដោយវុដ្ឋានគាមិនីវិបស្សនា ក្នុងបទនេះថា **តំ បជហាថ** ។

[ ១០៨ ] បទថា **យទរិយោ** សេចក្តីថា ព្រះសម្មាសម្ពុទ្ធ ជាអរិយៈ ទ្រង់រមែងសេពសតិប្បដ្ឋានពួកណា ទ្រង់តាំងព្រះសតិក្នុងឋានៈ ៣ យ៉ាងនោះ គប្បីជ្រាបថា ទ្រង់សេពសតិប្បដ្ឋាន ។

[ ១០៩ ] បទថា **ន សុស្សូសន្តិ** សេចក្តីថា មិនប្រាថ្នាដើម្បីស្តាប់ ។ បទថា **ន អញ្ញា** សេចក្តីថា មិនតាំងចិត្តដើម្បីប្រយោជន៍ដល់ការដឹង ។ បទថា **ឋាកម្ម** បានដល់ ឈានកន្ទង ។ បទថា **សត្ថុ សាសនំ** សេចក្តីថា មិនសម្គាល់នូវឱវាទរបស់ព្រះសាស្តាដែលគួរកាន់យក គួរឲ្យពេញ ។ បទថា **ន ច អត្តមនោ** គឺមិនមានចិត្តជារបស់ខ្លួន ។ តែក្នុងទីនេះ មិនគួរឃើញអត្ថយ៉ាងនេះថា មិនអាក់អន់ដោយអំណាចទោមនស្សអាស្រ័យផ្ទះ ។ តែត្រាស់បទនោះ ដោយមិនមានហេតុនៃការសរសើរ ក្នុងពួកសាវ័កដែលមិនបដិបត្តិ ។ បទថា **អនវស្សុតោ** គឺមិនខ្វល់ខ្វាយដោយអំណាចការខ្វល់ខ្វាយ គឺការអាក់អន់ ។ បទថា **សតោ សម្បជានោ** សេចក្តីថា ដល់ព្រមដោយសតិ និងញាណ ។

[ ១១០ ] បទថា **ឧបេក្ខកោ** សេចក្តីថា ព្រងើយដោយធម្មជាតិឧបេក្ខា ។ មិនគប្បីជ្រាបអត្ថយ៉ាងនេះថា មានការត្រេកអរដោយអំណាចសោមនស្ស អាស្រ័យផ្ទះ ក្នុងបទនេះថា **អត្តមនោ ។** បទនោះត្រាស់ហើយដោយការមានហេតុនៃការសរសើរ ក្នុងពួកសាវកដែលបដិបត្តិ ។

[ ១១១ ] បទថា **អនវស្សុតោ** បានដល់ មិនខ្វល់ខ្វាយ ដោយអំណាចការខ្វល់ខ្វាយដោយរាគៈ ។

[ ១១២ ] បទថា **សារិតោ** បានដល់ ទូន្មានហើយ ។ បទថា **ឯកំយេវ ទិសំ ធាវតិ** សេចក្តីថា កាលមិនឲ្យស្ទុះត្រឡប់ទៅ ឈ្មោះថា ស្ទុះត្រឡប់ទៅកាន់ទិសមួយប៉ុណ្ណោះ ។ តែអាចឲ្យស្ទុះត្រឡប់ទៅកាន់ទិសដទៃ ។ បទថា **អដ្ឋទិសា វិធាវតិ** សេចក្តីថា អង្គុយដោយភ្នែនមួយ មិនត្រឡប់ដោយកាយ ស្ទុះទៅក្នុងទិសទាំង ៨ ម្តងប៉ុណ្ណោះ ដោយអំណាចនៃវិមោក្ខ ។ អធិប្បាយថា ទ្រង់បែរព្រះភក្រ្តទៅទិសខាងកើត ឬទិសខាងត្បូងជាដើម ទិសណាមួយ ប្រថាប់គង់ចូលសមាបត្តិទាំង ៨ នោះឯង ។ បទដ៏សេសក្នុងទាំងពួង ងាយយល់ទាំងអស់ហើយ ដូច្នេះ ៕

**អដ្ឋកថា សឡាយតនវិភង្គសូត្រ ចប់**

**សូត្រទី ៧ ចប់**

# សុត្តន្តបិដក

## ឧទ្ទេសវិភង្គសូត្រទី ៨

[ ១១៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងទីនោះថា ម្នាលភិក្ខុទាំង-ឡាយ ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ តថាគតនឹងសម្តែងនូវឧទ្ទេសវិភង្គ ( ចំណែកឧទ្ទេស គឺមាតិកា ) ប្រាប់អ្នកទាំងឡាយ អ្នកទាំងឡាយចូរប្រុងស្តាប់នូវឧទ្ទេស និងវិភង្គនោះ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះទទួលស្តាប់ព្រះពុទ្ធ-ដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ១១៤ ] ព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាដូច្នេះថា កាលបើភិក្ខុនោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះមានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុតព្រោះមិនប្រកាន់មាំហើយ សេចក្តីកើតឡើងព្រម មានព្រមនៃជាតិ ជរា មរណៈដ៏សេសសល់ រមែងមិនមានតទៅទៀតដោយប្រការយ៉ាងណាៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីពិចារណាដោយប្រការយ៉ាងនោះៗ ចុះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះ លុះព្រះសុគត

ទ្រង់មានព្រះពុទ្ធដីកាដូច្នេះហើយ ក៏ទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ ។

[ ១១៥ ] គ្រាកាលដែលព្រះមានព្រះភាគ ទ្រង់ស្តេចចេញទៅមិនយូរប៉ុន្មាន ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សម្តែងនូវឧទ្ទេសនេះដល់យើងទាំងឡាយដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា កាលបើភិក្ខុនោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុតព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះមានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំហើយ សេចក្តីកើតឡើងព្រម មានព្រមនៃជាតិ ជរា មរណៈ និងទុក្ខរមែងមិនមានតទៅទៀតដោយប្រការយ៉ាងណាៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីពិចារណាដោយប្រការយ៉ាងនោះៗ ចុះ តើឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សម្តែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារនេះ នរណាហ្ន៎ នឹងអាចចែកអត្ថដោយពិស្តារបាន ។ គ្រានោះ ភិក្ខុទាំងនោះ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមហាកច្ចានៈមានអាយុនេះ ព្រះសាស្តាទ្រង់សរសើរផង សព្រហ្មចារីទាំងឡាយ ជាអ្នកប្រាជ្ញលើកតម្កើងផង ឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារនេះ មានតែព្រះមហាកច្ចានៈមានអាយុ ទើបអាចចែកអត្ថដោយពិស្តារបាន បើដូច្នោះ គួរ

តែយើងទាំងឡាយ នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ យើងទាំងឡាយ គប្បីសួរនូវសេចក្តីនេះនឹងព្រះមហាកច្ចានៈមានអាយុ ។

[ ១១៦ ] លំដាប់នោះ ភិក្ខុទាំងនោះក៏នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាលនឹងព្រះមហាកច្ចានៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក៏ពោលនឹងព្រះមហាកច្ចានៈមានអាយុដូច្នេះថា បពិត្រព្រះកច្ចានៈមានអាយុ ព្រះមានព្រះភាគ ទ្រង់សម្តែងឧទ្ទេសនេះដល់យើងទាំងឡាយដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា កាលបើភិក្ខុនោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុង ហើយមិនបានតក់ស្លុតព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុង មិនតក់ស្លុតព្រោះមិនបានប្រកាន់មាំហើយ សេចក្តីកើតឡើងព្រម មានព្រមនៃជាតិ ជរា មរណៈ និងទុក្ខរមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណាៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីពិចារណាដោយប្រការយ៉ាងនោះៗ ចុះបពិត្រព្រះកច្ចានៈមានអាយុ កាលដែលព្រះមានព្រះភាគ ទ្រង់ស្តេចចេញទៅមិនយូរប៉ុន្មាន យើងទាំងឡាយនោះ ក៏មានសេចក្តីត្រិះរិះ ដូច្នេះថា ម្នាល

អាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សម្តែងឧទ្ទេសនេះដល់យើងទាំង-ឡាយដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារឡើយ ក៏ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា កាលបើភិក្ខុនោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុង ហើយមិនតក់ស្លុតព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះមានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុង មិនតក់ស្លុតព្រោះមិនប្រកាន់មាំហើយ សេចក្តីកើតឡើងព្រម មានព្រមនៃជាតិ ជរា មរណៈ និងទុក្ខរមែងមិនមានតទៅទៀតដោយប្រការយ៉ាងណាៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីពិចារណាដោយប្រការយ៉ាងនោះៗ ចុះ តើឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារនេះ នរណាហ្ន៎នឹងអាចចែកអត្ថដោយពិស្តារបាន បពិត្រព្រះកច្ចានៈមានអាយុ យើងទាំងឡាយនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមហាកច្ចានៈមានអាយុនេះឯង ព្រះសាស្តាទ្រង់សរសើរផង សព្រហ្មចារីទាំងឡាយ ជាអ្នកប្រាជ្ញលើកតម្កើងផង ឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារនេះ មានតែព្រះមហាកច្ចានៈមានអាយុ ទើបអាចចែកអត្ថដោយពិស្តារបាន បើដូច្នោះ គួរតែយើងទាំងឡាយ នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ យើងទាំងឡាយ គប្បីសួរនូវសេចក្តីនេះនឹងព្រះមហាកច្ចានៈមានអាយុ ដូច្នេះ សូមព្រះមហាកច្ចានៈមានអាយុចែក ( អត្ថនោះដោយពិស្តារឲ្យទាន )។

[ ១១៧ ] ព្រះមហាកច្ចានៈមានអាយុពោលថា ម្នាលអាវុសោទាំងឡាយ បុរសអ្នកត្រូវការដោយឈើខ្លឹម ជាអ្នកស្វែងរកឈើខ្លឹម បានដើរទៅស្វែងរកឈើខ្លឹម កាលបើដើមឈើធំដុះនៅ ( ចំពោះមុខ ) ក៏ដើររម្លងឫសរម្លងដើម សម្គាល់នូវមែក និងស្លឹកថាជាខ្លឹមដែលខ្លួនត្រូវស្វែងរកវិញ មានឧបមាដូចម្ដេចមិញ សេចក្ដីនេះ ក៏មានឧបមេយ្យដូចកាលដែលព្រះសាស្ដាឋិតនៅចំពោះមុខ នៃលោកមានអាយុទាំងឡាយ លោកទាំងឡាយ ក៏រម្លងព្រះមានព្រះភាគនោះ ហើយសម្គាល់នូវយើងថា ជាបុគ្គលគួរសួរនូវសេចក្ដីនេះវិញ ម្នាលអាវុសោទាំងឡាយ ព្រោះថា ព្រះមានព្រះភាគនោះ ព្រះអង្គជ្រាបនូវហេតុដែលគួរជ្រាប ឃើញនូវហេតុដែលគួរឃើញបាន ជាអ្នកមានបញ្ញាចក្ខុកើតហើយ មានញាណកើតហើយ មានធម៌កើតហើយ មានសេចក្ដីប្រសើរកើតហើយ ជាអ្នកពោលធម៌ ជាអ្នកញុំាងធម៌ឲ្យប្រព្រឹត្តទៅ ជាអ្នកពន្យល់សេចក្ដី ជាអ្នកឲ្យនូវអមតៈ ( និព្វាន ) ព្រះតថាគតជាម្ចាស់នៃធម៌ កាលនោះជាកាលគួរ អ្នកទាំងឡាយសួរសេចក្ដីនេះ នឹងព្រះមានព្រះភាគបាន ព្រះមានព្រះភាគ ព្យាករដល់អ្នកទាំងឡាយយ៉ាងណា អ្នកទាំងឡាយគប្បីចាំទុកនូវសេចក្ដីនោះ យ៉ាងនោះ ។ ភិក្ខុទាំងឡាយពោលថា ម្នាលព្រះកច្ចានៈមានអាយុ ព្រះមានព្រះភាគ ព្រះអង្គជ្រាបនូវហេតុដែលគួរជ្រាប ឃើញនូវហេតុដែលគួរឃើញ ព្រះអង្គមានចក្ខុកើតហើយ មានញាណកើតហើយ មានធម៌កើតហើយ មានសេចក្ដីប្រសើរកើតហើយ ជាអ្នកពោលធម៌ ជាអ្នកញុំាងធម៌ឲ្យប្រព្រឹត្តទៅ ជាអ្នកពន្យល់សេចក្ដី ជាអ្នកឲ្យនូវអមតៈ ( និព្វាន ) ព្រះ

តថាគតជាម្ចាស់នៃធម៌ កាលនោះជាកាលគួរយើងទាំងឡាយ សួរសេចក្ដីនេះនឹងព្រះមានព្រះភាគហើយ បើព្រះមានព្រះភាគព្យាករដល់យើងទាំងឡាយយ៉ាងណា យើងទាំងឡាយគប្បីចាំទុកនូវសេចក្ដីនោះ យ៉ាងនោះដោយពិតមែនហើយ តែថាព្រះមហាកច្ចានៈមានអាយុ ព្រះសាស្ដាសរសើរផង សព្រហ្មចារីទាំងឡាយ ជាអ្នកប្រាជ្ញលើកតម្កើងផង ឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្ដែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្ដារនេះ មានតែព្រះមហាកច្ចានៈ ទើបអាចចែកនូវអត្ថដោយពិស្ដារបាន សូមព្រះមហាកច្ចានៈមានអាយុកុំធ្វើនូវសេចក្ដីចង្អៀតចង្អល់ឡើយ សូមចែក ( អត្ថនេះដោយពិស្ដារ ) ។ ព្រះកច្ចានៈពោលថា ម្នាលអាវុសោទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរស្ដាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អចុះ ខ្ញុំនឹងសម្ដែងឲ្យស្ដាប់ ។ ភិក្ខុទាំងនោះទទួលស្ដាប់ពាក្យព្រះមហាកច្ចានៈមានអាយុថា ករុណា អាវុសោ ។

[ ១១៨ ] ព្រះមហាកច្ចានៈមានអាយុពោល ដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគទ្រង់សម្ដែងឧទ្ទេសណា ដល់យើងទាំងឡាយដោយសង្ខេប មិនបានចែកអត្ថដោយពិស្ដារស្រាប់តែទ្រង់ក្រោកអំពីអាសនៈចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថាកាលបើភិក្ខុនោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុងហើយមិនតក់ស្លុតព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះមានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ទាំងមិនឋិតនៅខាងក្នុងមិនតក់ស្លុតព្រោះមិនប្រកាន់មាំហើយ ការកើតឡើងព្រម មានព្រមនៃជាតិ

ជរា មរណៈ និងទុក្ខរមែងមិនមានតទៅទៀតដោយប្រការយ៉ាងណាៗ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុគប្បីពិចារណាដោយប្រការយ៉ាងនោះៗ ចុះ ម្នាលអាវុសោ ទាំងឡាយ ឧទ្ទេសនេះឯង ដែលព្រះមានព្រះភាគទ្រង់សម្តែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ខ្ញុំក៏ដឹងច្បាស់នូវអត្ថដោយពិស្តារ ដូចនឹង ពោលតទៅនេះឯង ។

[ ១១៩ ] ម្នាលអាវុសោទាំងឡាយ ដូចម្តេចហៅថា វិញ្ញាណរាត់រាយ ខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ឃើញរូបដោយចក្ខុហើយ ក៏មានវិញ្ញាណរឭកទៅតាមរូបនិមិត្ត ប្រាថ្នាដោយ សេចក្តីត្រេកអរក្នុងរូបនិមិត្ត ជាប់ជំពាក់ដោយសេចក្តីត្រេកអរក្នុងរូបនិមិត្ត ប្រកបព្រមដោយសេចក្តីត្រេកអរក្នុងរូបនិមិត្ត ( នេះ ) ហៅថា វិញ្ញាណរាត់ រាយខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ភិក្ខុឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយ ច្រមុះ ... ទទួលរសដោយអណ្តាត ... ប៉ះពាល់ផោដ្ឋព្វៈដោយកាយ ... ដឹង នូវធម៌ដោយចិត្តហើយ ក៏មានវិញ្ញាណរឭកទៅតាមធម្មនិមិត្ត ប្រាថ្នាដោយ សេចក្តីត្រេកអរក្នុងធម្មនិមិត្ត ជាប់ជំពាក់ដោយសេចក្តីត្រេកអរក្នុងធម្មនិមិត្ត ប្រកបព្រមដោយសេចក្តីត្រេកអរក្នុងធម្មនិមិត្ត ( នេះ ) ហៅថា វិញ្ញាណរាត់ រាយ ខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ម្នាលអាវុសោទាំងឡាយ ដែលហៅថា វិញ្ញាណរាត់រាយ ខ្ចាត់ខ្ចាយទៅខាងក្រៅ យ៉ាងនេះឯង ។

[ ១២០ ] ម្នាលអាវុសោទាំងឡាយ ដូចម្តេចហៅថា វិញ្ញាណមិនរាត់ រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនា

នេះ ឃើញរូបដោយចក្ខុហើយ តែវិញ្ញាណមិនបានរឭកទៅតាមរូបនិមិត្ត មិនបានប្រាថ្នាដោយសេចក្ដីត្រេកអរក្នុងរូបនិមិត្ត មិនជាប់ជំពាក់ដោយសេចក្ដីត្រេកអរក្នុងរូបនិមិត្ត មិនប្រកបព្រមដោយសេចក្ដីត្រេកអរក្នុងរូបនិមិត្ត (នេះ) ហៅថា វិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ភិក្ខុឮសំឡេងដោយត្រចៀក ... ធុំក្លិនដោយច្រមុះ ... ទទួលរសដោយអណ្ដាត ... ប៉ះពាល់នូវផោដ្ឋព្វៈដោយកាយ ... ដឹងនូវធម៌ដោយចិត្តហើយ វិញ្ញាណក៏មិនបានរឭកទៅតាមធម្មនិមិត្ត មិនប្រាថ្នាដោយសេចក្ដីត្រេកអរក្នុងធម្មនិមិត្ត មិនជាប់ជំពាក់ដោយសេចក្ដីត្រេកអរក្នុងធម្មនិមិត្ត មិនប្រកបព្រមដោយសេចក្ដីត្រេកអរក្នុងធម្មនិមិត្ត ( នេះ ) ហៅថា វិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ ។ ម្នាលអាវុសោទាំងឡាយ ដែលហៅថាវិញ្ញាណមិនរាត់រាយមិនខ្ចាត់ខ្ចាយទៅខាងក្រៅ យ៉ាងនេះឯង ។

[ ១២១ ] ម្នាលអាវុសោទាំងឡាយ ដូចម្ដេចហៅថា ចិត្តឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំង-ឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក វិចារ មានតែបីតិ និងសុខ ដែលកើតអំពីវិវេក ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះរមែងមានវិញ្ញាណ រឭកទៅតាមបីតិ និងសុខ ដែលកើតអំពីវិវេក ប្រាថ្នាដោយសេចក្ដីត្រេកអរក្នុងបីតិនិងសុខដែលកើតអំពីវិវេក ជាប់ជំពាក់ដោយសេចក្ដីត្រេកអរក្នុងបីតិ និងសុខដែលកើតអំពីវិវេក ប្រកបព្រមដោយសេចក្ដីត្រេកអរ ក្នុងបីតិ និងសុខ

ដែលកើតអំពីវិវេក ( នេះ ) ហៅថា ចិត្តឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត ភិក្ខុព្រោះរម្ងាប់នូវវិតក្ក និងវិចារ រួចហើយបានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានចិត្ត ប្រកបដោយសេចក្ដីជ្រះថ្លា គឺសទ្ធា មានភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ និងសុខកើតអំពីសមាធិ គឺបឋមជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះរមែងមានវិញ្ញាណ វេ្យកទៅតាមនូវបីតិ និងសុខ ដែលកើតអំពីសមាធិ ប្រាថ្នាដោយសេចក្ដីត្រេកអរក្នុងបីតិ និងសុខដែលកើតអំពីសមាធិ ជាប់ជំពាក់ដោយសេចក្ដីត្រេកអរក្នុងបីតិ និងសុខដែលកើតអំពីសមាធិ ប្រកបព្រមដោយសេចក្ដីត្រេកអរក្នុងបីតិ និងសុខដែលកើតអំពីសមាធិ ( នេះ ) ហៅថា ចិត្តឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ មួយទៀត ភិក្ខុព្រោះនឿយណាយចាកបីតិហើយ ប្រកបដោយឧបេក្ខា មានស្មារតី និងមានសេចក្ដីដឹងខ្លួន ទទួលសេចក្ដីសុខដោយនាមកាយ ព្រះអរិយៈទាំងឡាយ តែងសរសើរបុគ្គលដែលបានតតិយជ្ឈាន ថាៈ បើបុគ្គលដែលបានតតិយជ្ឈាន តែងមានចិត្តប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខ ដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាននោះហើយ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះ រមែងមានវិញ្ញាណវេ្យកទៅតាមនូវឧបេក្ខា ប្រាថ្នាដោយសេចក្ដីត្រេកអរក្នុងសុខប្រកបដោយឧបេក្ខា ជាប់ជំពាក់ដោយសេចក្ដីត្រេកអរ ក្នុងសុខប្រកបដោយឧបេក្ខា ប្រកបព្រមដោយសេចក្ដីត្រេកអរ ក្នុងឧបេក្ខា និងសុខ

( នេះ ) ហៅថា ចិត្តឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត ភិក្ខុព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្ស និងទោមនស្សអស់ហើយ ក្នុងកាលមុនផង ក៏បានដល់នូវចតុត្ថជ្ឈាន ដែលមិនមានទុក្ខមិនមានសុខ មានតែសតិដ៏បរិសុទ្ធដោយឧបេក្ខា ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះរមែងមានវិញ្ញាណ វេញកទៅតាមអទុក្ខមសុខ គឺឧបេក្ខា ប្រាថ្នាដោយសេចក្តីត្រេកអរក្នុងអទុក្ខមសុខ ជាប់ជំពាក់ដោយសេចក្តីត្រេកអរក្នុងអទុក្ខមសុខ ប្រកបព្រមដោយសេចក្តីត្រេកអរក្នុងអទុក្ខមសុខ ( នេះ ) ហៅថា ចិត្តឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំង-ឡាយ យ៉ាងនេះឯង ដែលហៅថា ចិត្តឋិតនៅខាងក្នុង ។

[ ១២២ ] ម្នាលអាវុសោទាំងឡាយ ចុះដូចម្តេច ហៅថា ចិត្តមិនឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ។បេ។ បានដល់នូវបឋមជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះរមែងមានវិញ្ញាណ មិនបានវេញកទៅតាមបីតិនិងសុខ ដែលកើតអំពីវិវេក មិនបានប្រាថ្នាដោយសេចក្តីត្រេកអរក្នុងបីតិ និងសុខដែលកើតអំពីវិវេក មិនបានជាប់ជំពាក់ដោយសេចក្តីត្រេកអរក្នុងបីតិ និងសុខ ដែលកើតអំពីវិវេក មិនប្រកបព្រមដោយសេចក្តីត្រេកអរក្នុងបីតិ និងសុខដែលកើតអំពីវិវេក ( នេះ ) ហៅថា ចិត្តមិនឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ មួយវិញទៀត ភិក្ខុព្រោះរម្ងាប់នូវវិតក្ក និងវិចារ ។បេ។ បានដល់នូវទុតិយជ្ឈាន ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។

ភិក្ខុនោះរមែងមានវិញ្ញាណ មិនបានរពូកទៅតាមបីតិ និងសុខ ដែលកើតអំពីសមាធិ មិនបានប្រាថ្នាដោយសេចក្តីត្រេកអរក្នុងបីតិ និងសុខ ដែលកើតអំពីសមាធិ មិនជាប់ជំពាក់ដោយសេចក្តីត្រេកអរក្នុងបីតិ និងសុខ ដែលកើតអំពីសមាធិ មិនប្រកបព្រមដោយសេចក្តីត្រេកអរក្នុងបីតិ និងសុខ ដែលកើតអំពីសមាធិ ( នេះ ) ហៅថា ចិត្តមិនឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយមួយទៀត ភិក្ខុព្រោះនឿយណាយចាកបីតិ ។បេ។ បានដល់នូវតតិយជ្ឈានហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះ រមែងមានវិញ្ញាណ មិនបានរពូកទៅតាមឧបេក្ខា មិនបានប្រាថ្នាដោយសេចក្តីត្រេកអរក្នុងសុខ ប្រកបដោយឧបេក្ខា មិនជាប់ជំពាក់ដោយសេចក្តីត្រេកអរ ក្នុងឧបេក្ខា និងសុខ មិនប្រកបព្រមដោយសេចក្តីត្រេកអរក្នុងសុខ ប្រកបដោយឧបេក្ខា ( នេះ ) ហៅថា ចិត្តមិនឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយមួយវិញទៀត ភិក្ខុព្រោះលះបង់នូវសុខផង ។បេ។ បានដល់នូវចតុត្ថជ្ឈានហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ភិក្ខុនោះ រមែងមានវិញ្ញាណមិនបានរពូកទៅតាមអទុក្ខមសុខ មិនប្រាថ្នាដោយសេចក្តីត្រេកអរក្នុងអទុក្ខមសុខ មិនជាប់ជំពាក់ដោយសេចក្តីត្រេកអរ ក្នុងអទុក្ខមសុខ មិនប្រកបព្រមដោយសេចក្តីត្រេកអរ ក្នុងអទុក្ខមសុខ ( នេះ ) ហៅថា ចិត្តមិនឋិតនៅខាងក្នុង ។ ម្នាលអាវុសោទាំងឡាយ យ៉ាងនេះឯង ហៅថា ចិត្តមិនឋិតនៅខាងក្នុង ។

[ ១២៣ ] ម្នាលអាវុសោទាំងឡាយ ចុះសេចក្តីតក់ស្លុត ព្រោះប្រកាន់

មាំនោះ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ បុថុជ្ជនក្នុងលោកនេះ មិនចេះដឹងពុទ្ធវចនៈ មិនបានឃើញព្រះអរិយៈ មិនឈ្លាសវៃក្នុងអរិយធម៌ មិនបានទូន្មានខ្លួនក្នុងអរិយធម៌ មិនឃើញសប្បុរស មិនឈ្លាសវៃក្នុងសប្បុរិស-ធម៌ មិនទូន្មានខ្លួន ក្នុងសប្បុរិសធម៌ រមែងពិចារណាឃើញនូវរូបថាជាខ្លួន ឬឃើញនូវខ្លួនថាមានរូប ឃើញនូវរូបថាមានក្នុងខ្លួន ឃើញនូវខ្លួនថាមានក្នុងរូប ។ រូបនោះរបស់បុគ្គលនោះ រមែងប្រែប្រួលទៅជាដទៃ ។ បុគ្គលនោះ រមែងមានវិញ្ញាណ ត្រឡប់ទៅតាមសេចក្តីប្រែប្រួលនៃរូប ព្រោះភាវៈនៃរូបប្រែប្រួលទៅជាដទៃ ។ ឯសេចក្តីតក់ស្លុត និងហេតុជាទីកើតឡើងនៃអកុ-សលធម៌ ដែលកើតអំពីការត្រឡប់ទៅតាមសេចក្តីប្រែប្រួលនៃរូប រមែងគ្របសង្កត់ចិត្តរបស់បុគ្គលនោះ ។ បុគ្គលនោះ ព្រោះតែសេចក្តីគ្របសង្កត់ចិត្ត ក៏ប្រកបដោយសេចក្តីខ្វាចផង ប្រកបដោយសេចក្តីចង្អៀតចង្អល់ផង ប្រកបដោយសេចក្តីអាឡោះអាល័យផង រមែងតក់ស្លុត ព្រោះប្រកាន់មាំ ។ បុគ្គលពិចារណាឃើញនូវវេទនា ... សញ្ញា ... សង្ខារ ... បុគ្គលពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន ឬឃើញនូវខ្លួនថាមានវិញ្ញាណ ឃើញវិញ្ញាណថាមានក្នុងខ្លួន ឬឃើញខ្លួនថាមានក្នុងវិញ្ញាណ ។ វិញ្ញាណនោះរបស់បុគ្គលនោះ ក៏ប្រែប្រួលទៅជាដទៃ ។ បុគ្គលនោះ រមែងមានវិញ្ញាណត្រឡប់ទៅតាមសេចក្តីប្រែប្រួលនៃវិញ្ញាណ ព្រោះភាវៈនៃវិញ្ញាណប្រែប្រួលទៅជាដទៃ ។ ឯសេចក្តីតក់ស្លុត និងហេតុជាទីកើតឡើងនៃអកុសលធម៌ ដែលកើតអំពីការត្រឡប់ទៅតាមនូវសេចក្តីប្រែប្រួលនៃវិញ្ញាណ រមែងគ្របសង្កត់ចិត្តរបស់

បុគ្គលនោះ ។ បុគ្គលនោះ ព្រោះតែសេចក្តីគ្របសង្កត់ចិត្ត ក៏ប្រកបដោយសេចក្តីខ្វាចផង ប្រកបដោយសេចក្តីចង្អៀតចង្អល់ផង ប្រកបដោយសេចក្តីអាឡោះអាល័យផង រមែងតក់ស្លុត ព្រោះប្រកាន់មាំ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីតក់ស្លុត ព្រោះប្រកាន់មាំ យ៉ាងនេះឯង ។

[ ១២៤ ] ម្នាលអាវុសោទាំងឡាយ ចុះសេចក្តីមិនតក់ស្លុតព្រោះមិនប្រកាន់មាំ តើដូចម្តេច ។ ម្នាលអាវុសោទាំងឡាយ អរិយសាវកក្នុងសាសនានេះ ជាអ្នកចេះដឹងពុទ្ធវចនៈ បានឃើញព្រះអរិយៈ ឈ្លាសវៃក្នុងអរិយធម៌ ទូន្មានខ្លួនក្នុងអរិយធម៌ បានឃើញសប្បុរស ឈ្លាសវៃក្នុងសប្បុរសធម៌ បានទូន្មានខ្លួនក្នុងសប្បុរិសធម៌ រមែងមិនពិចារណាឃើញនូវរូបថាជាខ្លួន មិនឃើញនូវខ្លួនថាមានរូប មិនឃើញរូបថាមានក្នុងខ្លួន មិនឃើញខ្លួនថាមានក្នុងរូប ។ រូបនោះរបស់បុគ្គលនោះ ក៏ប្រែប្រួលទៅជាដទៃ ។ បុគ្គលនោះ ក៏រមែងមានវិញ្ញាណ មិនបានត្រឡប់ទៅតាមនូវសេចក្តីប្រែប្រួលនៃរូប ព្រោះតែភាវៈនៃរូប ប្រែប្រួលទៅជាដទៃឡើយ ។ ឯសេចក្តីតក់ស្លុត និងហេតុជាទីកើតឡើងនៃអកុសលធម៌ ដែលកើតអំពីការត្រឡប់ទៅតាម នូវសេចក្តីប្រែប្រួលនៃរូប រមែងមិនគ្របសង្កត់ចិត្តរបស់បុគ្គលនោះទេ ។ បុគ្គលនោះ ព្រោះតែសេចក្តីមិនគ្របសង្កត់ចិត្ត ក៏មិនបានប្រកបដោយសេចក្តីខ្វាចផង មិនប្រកបដោយសេចក្តីចង្អៀតចង្អល់ផង មិនប្រកបដោយសេចក្តីអាឡោះអាល័យផង រមែងមិនតក់ស្លុតព្រោះមិនប្រកាន់មាំ ។ បុគ្គលមិនបានពិចារណាឃើញនូវវេទនា ... សញ្ញា ... សង្ខារ ... បុគ្គលមិនបានពិចារណាឃើញនូវវិញ្ញាណថាជាខ្លួន មិន

ឃើញខ្លួនថាមានវិញ្ញាណ មិនឃើញវិញ្ញាណថាមានក្នុងខ្លួន មិនឃើញខ្លួនថាមានក្នុងវិញ្ញាណ ។ វិញ្ញាណនោះរបស់បុគ្គលនោះ ប្រែប្រួលទៅជាដទៃ ។ បុគ្គលនោះរមែងមានវិញ្ញាណ មិនបានត្រឡប់ទៅតាម សេចក្តីប្រែប្រួលនៃវិញ្ញាណ ព្រោះភាវៈនៃវិញ្ញាណ ប្រែប្រួលទៅជាដទៃទេ ។ ឯសេចក្តីតក់ស្លុត និងហេតុជាទីកើតឡើងនៃអកុសលធម៌ ដែលកើតឡើងអំពីការត្រឡប់ទៅតាមនូវសេចក្តីប្រែប្រួលនៃវិញ្ញាណ រមែងមិនគ្របសង្កត់ចិត្ត របស់បុគ្គលនោះឡើយ ។ បុគ្គលនោះ ព្រោះតែសេចក្តីមិនគ្របសង្កត់ចិត្ត ក៏មិនបានប្រកបដោយសេចក្តីខ្វាចផង មិនប្រកបដោយសេចក្តីចង្អៀតចង្អល់ផង មិនប្រកបដោយសេចក្តីអាឡោះអាល័យផង រមែងមិនតក់ស្លុតព្រោះមិនប្រកាន់មាំ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីមិនតក់ស្លុតព្រោះមិនប្រកាន់មាំ យ៉ាងនេះឯង ។

[ ១២៥ ] ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគ ទ្រង់សំដែងនូវឧទ្ទេសណា ដល់យើងទាំងឡាយដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ ពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះ មិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុតព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុនោះ មានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុតព្រោះមិនប្រកាន់មាំហើយ ឯការកើតឡើងព្រម មានព្រមនៃជាតិ ជរា មរណៈ និង

ទុក្ខ រមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណាៗ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីពិចារណា ដោយប្រការយ៉ាងនោះៗ ចុះ ម្នាលអាវុសោទាំងឡាយ នេះឯងឧទ្ទេស ដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ខ្ញុំយល់ច្បាស់នូវអត្ថដោយពិស្តារយ៉ាងនេះឯង បើលោកមានអាយុទាំងឡាយ ប្រាថ្នា ( ចង់ដឹង ) គប្បីចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរសេចក្តីនេះថែមទៀតចុះ បើព្រះមានព្រះភាគ ទ្រង់ព្យាករដល់យើងទាំងឡាយយ៉ាងណា អ្នកទាំងឡាយគប្បីចាំទុកនូវសេចក្តីនោះ យ៉ាងនោះចុះ ។

[ ១២៦ ] លំដាប់នោះ ភិក្ខុទាំងនោះត្រេកអរអនុមោទនា នឹងភាសិតរបស់ព្រះមហាកច្ចានៈមានអាយុ ហើយក៏ក្រោកអំពីអាសនៈ នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីសមគួររួចហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់សម្តែងឧទ្ទេសណា ដល់យើងខ្ញុំព្រះអង្គទាំងឡាយដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះ មិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង ហើយមិនតក់ស្លុត ព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុតព្រោះមិនប្រកាន់មាំហើយ ឯការកើតឡើងព្រម

មានព្រមនៃជាតិ ជរា មរណៈ និងទុក្ខ រមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណាៗ ភិក្ខុគប្បីពិចារណាដោយប្រការយ៉ាងនោះៗ ចុះ បពិត្រព្រះអង្គដ៏ចម្រើន កាលដែលព្រះមានព្រះភាគ ស្តេចចេញទៅមិនយូរប៉ុន្មាន ខ្ញុំព្រះអង្គទាំងនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ម្នាលអាវុសោទាំងឡាយ ព្រះមានព្រះភាគទ្រង់សម្តែងឧទ្ទេសនេះ ដល់យើងទាំងឡាយដោយសង្ខេប មិនបានចែកអត្ថដោយពិស្តារ ស្រាប់តែទ្រង់ក្រោកអំពីអាសនៈ ស្តេចចូលទៅកាន់វិហារ គឺទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះពិចារណាហើយ វិញ្ញាណរបស់ភិក្ខុនោះ មិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុតព្រោះមិនប្រកាន់មាំ ម្នាលភិក្ខុទាំងឡាយ កាលបើភិក្ខុនោះ មានវិញ្ញាណមិនរាត់រាយ មិនខ្ចាត់ខ្ចាយទៅខាងក្រៅ មិនឋិតនៅខាងក្នុង មិនតក់ស្លុតព្រោះមិនប្រកាន់មាំហើយ ឯការកើតព្រម មានព្រមនៃជាតិ ជរា មរណៈ និងទុក្ខ រមែងមិនមានតទៅទៀត ដោយប្រការយ៉ាងណាៗ ភិក្ខុគប្បីពិចារណាដោយប្រការយ៉ាងនោះៗ ចុះ ឧទ្ទេសដែលព្រះមានព្រះភាគទ្រង់សម្តែងដោយសង្ខេប មិនចែកអត្ថដោយពិស្តារនេះ តើនរណាហ្ន៎នឹងចែកអត្ថដោយពិស្តារបាន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងនោះ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ព្រះមហាកច្ចានៈមានអាយុនេះឯង ព្រះសាស្តាសរសើរផង សព្រហ្មចារីទាំងឡាយ ជាអ្នកប្រាជ្ញលើកតម្កើងផង ឯឧទ្ទេសដែលព្រះមានព្រះភាគ ទ្រង់សម្តែងដោយសង្ខេប មិនចែកអត្ថដោយពិស្តារនេះ មានតែព្រះមហាកច្ចានៈមានអាយុ ទើបអាចចែកអត្ថដោយពិស្តារបាន បើដូច្នោះ

គួរតែយើងទាំងឡាយ នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ គប្បីសួរសេចក្ដីនេះ នឹងព្រះមហាកច្ចានៈមានអាយុ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះអង្គទាំងឡាយ ក៏នាំគ្នាចូលទៅរកព្រះមហាកច្ចានៈមានអាយុ លុះចូលទៅដល់ហើយ ក៏បានសួរសេចក្ដីនេះ នឹងព្រះមហាកច្ចានៈមានអាយុ បពិត្រព្រះអង្គដ៏ចម្រើន ឯព្រះមហាកច្ចានៈមានអាយុ ក៏បានចែកអត្ថ ដោយអាការទាំងនេះ ដោយបទទាំងនេះ ដោយព្យញ្ជនៈទាំងនេះ ដល់ខ្ញុំព្រះអង្គទាំងឡាយ ។

[ ១២៧ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈជាបណ្ឌិត ម្នាលភិក្ខុទាំងឡាយ មហាកច្ចានៈមានបញ្ញាច្រើន ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយសួរសេចក្ដីនេះ នឹងតថាគតទៀត តថាគតក៏គប្បីព្យាករ ដូចជាសេចក្ដីដែលមហាកច្ចានៈ បានព្យាកររួចហើយ យ៉ាងនុ៎ះដែរ នេះហើយជាសេចក្ដីរបស់ឧទ្ទេសនោះ អ្នកទាំងឡាយគប្បីចាំទុកនូវសេចក្ដីនោះ យ៉ាងនេះចុះ ។ លុះព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាដូច្នេះ ចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

ឧទ្ទេសវិភង្គសូត្រទី ៨ ចប់

# អដ្ឋកថា

## ឧទ្ទេសវិភង្គសូត្រ

[ ១១៣ ] ឧទ្ទេសវិភង្គសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **ឧទ្ទេសវិភង្គំ** បានដល់ ឧទ្ទេស និងវិភង្គ អធិប្បាយថា មាតិកា និងការចែក ។

[ ១១៤ ] បទថា **ឧបបរិក្ខេយ្យ** សេចក្ដីថា គប្បីប្រៀបធៀប គប្បីពិចារណា គប្បីកាន់យក គប្បីកំណត់ ។ បទថា **ពហិទ្ធា** បានដល់ ក្នុងអារម្មណ៍ទាំងឡាយខាងក្រៅ ។ បទថា **អវិក្ខិត្តំ អវិសដំ** សេចក្ដីថា ការតាំងមាំក្នុងអារម្មណ៍ ដោយអំណាចសេចក្ដីប្រាថ្នាផ្សាយទៅ ឈ្មោះថា បន្សាត់ទៅ ។ កាលទ្រង់បដិសេធការដឹងដែលផ្សាយទៅនោះ ទើបត្រាស់យ៉ាងនេះ ។ បទថា **អជ្ឈត្តំ អសណ្ឋិតំ** សេចក្ដីថា មិនតាំងនៅស្ងប់ដោយអំណាចនៃការប្រាថ្នាក្នុងអារម្មណ៍ខាងក្នុង ។ បទថា **អនុបាទាយ ន បរិតស្សេយ្យ** អធិប្បាយថា ការដឹងនោះ មិនតក់ស្លុត ព្រោះមិនប្រកាន់មាំ គឺមិនកាន់យកការដឹង មិនផ្សាយទៅ មិនបន្សាត់ទៅខាងក្រៅ មិនស្ងប់នៅខាងក្នុង មិនតក់ស្លុត ព្រោះមិនប្រកាន់មាំយ៉ាងណា ភិក្ខុគប្បីពិចារណាយ៉ាងនោះ ។ បទថា **ជាតិជរា មរណទុក្ខសមុទយសម្ភវោ** សេចក្ដីថា រមែងមិនមានការកើតនៃជាតិ ជរា មរណៈ និងទុក្ខដ៏សេស ។

[ ១១៥ ] បទថា **រូបនិមិត្តានុសារី** បានដល់ ឈ្មោះថា ស្ទុះទៅតាមនិមិត្ត គឺរូប ព្រោះអត្ថថា ស្ទុះទៅ រត់ទៅតាមនិមិត្ត គឺរូប ។

[ ១២១ ] បទថា **ឯវំ ខោ អាវុសោ អជ្ឈត្តំ ចិត្តំ អសណ្ឋិតំ** សេចក្ដីថា មិនស្ងប់ដោយអំណាចនៃការប្រាថ្នា ។ ចិត្តមិនតាំងមាំដោយអំណាចនៃការប្រាថ្នា រមែងមិនជាចំណែកក្នុងការលះ តែជាចំណែកក្នុងគុណវិសេសតែម្យ៉ាង ។

[ ១២៣ ] បទថា **អនុបាទា បរិតស្សនា** សេចក្ដីថា ព្រះសាស្ដាទ្រង់សម្ដែងការតក់ស្លុតព្រោះប្រកាន់មាំ និងការមិនតក់ស្លុត ព្រោះមិនប្រកាន់ក្នុងខន្ធិយវគ្គ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងការតក់ស្លុតព្រោះការប្រកាន់មាំ និងការមិនតក់ស្លុត ព្រោះការមិនប្រកាន់មាំ ។ ព្រះមហាថេរៈ កាលសម្ដែងការតក់ស្លុតនោះ ធ្វើការតក់ស្លុត ព្រោះការប្រកាន់មាំ ឲ្យជាការតក់ស្លុត ព្រោះប្រកាន់មាំមិនបាន ទើបពោលយ៉ាងនេះថា នែអាវុសោទាំងឡាយ ការតក់ស្លុត ព្រោះការប្រកាន់មាំ ដូចម្ដេច ព្រោះមិនមានសង្ខារដែលគប្បីប្រកាន់មាំ បើសង្ខារណាមួយជារបស់ទៀង ឬមាំទាំសោត ក៏នឹងជារបស់គួរប្រកាន់ថា ជាខ្លួន ឬអាស្រ័យខ្លួន ការតក់ស្លុតនេះ ជាការតក់ស្លុតព្រោះការប្រកាន់មាំ ។ ព្រោះធម្មតាសង្ខារ ដែលគួរប្រកាន់មាំយ៉ាងនេះ មិនមាន ព្រោះដូច្នោះ សង្ខារទាំងឡាយ សូម្បីមានចិត្តគ្រប់គ្រង មានរូបជាដើម ដោយន័យជាដើមថា រូប អត្តា នេះ ជារបស់មិនគួរប្រកាន់មាំពិត ។ ការតក់ស្លុតនោះ ទោះជាការតក់ស្លុត ព្រោះប្រកាន់មាំយ៉ាងនេះ ដោយអត្ថ គប្បីជ្រាបថា ជាការតក់ស្លុត ព្រោះប្រកាន់មាំមិនបាន ។

បទថា **អញ្ញថា ហោតិ** សេចក្ដីថា រូបប្រែប្រួលទៅ តែក៏វិនាសទៅ

ព្រោះការលះប្រក្រតី ។ បទថា **រូបវិបរិណាមានុបរិវត្តិ** សេចក្តីថា កម្ម-វិញ្ញាណរមែងប្រែប្រួលទៅតាមការបែកធ្លាយរបស់រូប ដោយន័យជាដើមថា រូបរបស់អញប្រែប្រួលទៅហើយ ឬរូបណាមាន រូបនោះឯងរបស់អញមិនមាន ដូច្នេះ ។ បទថា **វិបរិណាមានុបរិវត្តជា** សេចក្តីថា ដែលកើតដល់ការប្រែប្រួលទៅ តាមការប្រែប្រួល គឺអំពីចិត្តដែលមានអារម្មណ៍មានការប្រែប្រួល ។ បទថា **បរិតស្សនា ធម្មសមុប្បាទា** បានដល់ ការតក់ស្លុតព្រោះតណ្ហា និងការកើតឡើងនៃអកុសលធម៌ ។ បទថា **ចិត្តំ បរិយាទាយ តិដ្ឋន្តិ** សេចក្តីថា រមែងតាំងនៅគ្របសង្កត់ គឺប្រកាន់ បោះទៅនូវអកុសលចិត្ត ។ បទថា **ឧត្តាសវា** សេចក្តីថា មានការស្រៀវខ្លាចព្រោះការតក់ស្លុតអំពីភ័យខ្លះ មានការស្រៀវខ្លាចព្រោះការតក់ស្លុតអំពីតណ្ហាខ្លះ ។ បទថា **វិឃាតវា** បានដល់ មានការចង្អៀតចង្អល់ មានទុក្ខ ។ បទថា **អបេក្ខវា** បានដល់ មានអាល័យ មានការជាប់ជំពាក់ ។ បទថា **ឯវំ ខោ អាវុសោ អនុបាទាបរិតស្សនា ហោតិ** សេចក្តីថា ការតក់ស្លុតព្រោះប្រកាន់មាំមិនបាន រមែងមានដល់បុគ្គលដូចកាន់ប្រអប់ទទេ ដោយសម្គាល់ថា ប្រអប់កែវមណីយ៉ាងនេះ កាលបើប្រអប់នោះវិនាសហើយ ក៏ដល់នូវការចង្អៀតចង្អល់ក្នុងកាលក្រោយ ដូច្នោះ ។

[ ១២៤ ] *បទថា* **ន រូបវិបរិណាមានុបរិវត្តិ** *សេចក្តីថា កម្មវិញ្ញាណនៃព្រះខីណាស្រពនោះឯង រមែងមិនមាន ។ ព្រោះដូច្នោះ ទើបសមគួរដើម្បីពោលថា ការប្រែប្រួលទៅតាមការបែកធ្លាយរបស់រូបមិនមាន ដូច្នេះ ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ។*

**អដ្ឋកថា ឧទ្ទេសវិភង្គសូត្រ ចប់**

**សូត្រទី ៨ ចប់**

# សុត្តន្តបិដក

## អរណវិភង្គសូត្រទី ៩

[ ១២៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវអរណវិភង្គ ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់នូវអរណវិភង្គនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។

[ ១២៩ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា បុគ្គលមិនគប្បីប្រកបរឿយៗ នូវសេចក្តីសុខក្នុងកាម ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ឡើយ មួយទៀត មិនគប្បីប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជារបស់នាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់ព្រះអរិយ-បុគ្គល មិនប្រកបដោយប្រយោជន៍ឡើយ ឯមជ្ឈិមប្បដិបទា គឺសេចក្តីប្រតិ-បត្តិយ៉ាងកណ្តាល មិនប៉ះពាល់នូវធម៌អមខាងទាំង ២ នោះ ដែលតថាគតបានត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីចេះដឹង តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ដើម្បីស្គាល់នូវ

អរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីព្រះនិព្វាន ។ បុគ្គលគប្បីដឹងនូវការលើកតម្កើងផង គប្បីដឹងនូវការបន្ទុះបង្អាប់ផង លុះដឹងនូវការលើកតម្កើង ទាំងដឹងនូវការបន្ទុះបង្អាប់ហើយ មិនគប្បីលើកតម្កើង មិនគប្បីបន្ទុះបង្អាប់ ត្រូវសម្តែងធម៌ដោយត្រង់ គប្បីដឹងនូវសេចក្តីសុខដែលថោកថយ លុះដឹងនូវសេចក្តីសុខដែលថោកថយហើយ គប្បីប្រកបរឿយៗ នូវសេចក្តីសុខក្នុងសន្តាន មិនគប្បីពោលពាក្យក្នុងទីកំបាំងមុខ ( ពាក្យញុះញង់ ) មិនគប្បីពោលពាក្យសៅហ្មង ក្នុងទីចំពោះមុខ គប្បីពោលកុំឲ្យរួសរាន់ពេក មិនគប្បីពោលរួសរាន់ពេក មិនគប្បីប្រកាន់ភាសាក្នុងជនបទ មិនគប្បីប្រព្រឹត្តកន្លងនូវឈ្មោះ នេះជាឧទ្ទេសនៃអរណវិភង្គ ។

[ ១៣០ ] ឯពាក្យថា បុគ្គលមិនគប្បីប្រកបរឿយៗ នូវសេចក្តីសុខក្នុងកាម ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ មួយទៀត មិនគប្បីប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជារបស់នាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ដូច្នេះនុ៎ះតថាគតបានពោលហើយ ។ ពាក្យនុ៎ះ តថាគតបានពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ធម៌ណា គឺការប្រកបរឿយៗ នូវសេចក្តីសោមនស្សរបស់បុគ្គលដែលមានសេចក្តីសុខ ដោយកាមប្បដិសន្ធិ ដែលជាធម៌ថោកទាប ជាធម៌របស់អ្នកស្រុក ជាធម៌របស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយ-បុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នេះ ជាធម៌ប្រកបដោយសេចក្តីទុក្ខ

ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ។ ធម៌ណា គឺការមិនប្រកបរឿយៗ នូវសេចក្តីព្យាយាមដោយសោមនស្ស របស់បុគ្គលដែលមានសេចក្តីសុខដោយកាមប្បដិសន្ធិ ជាសេចក្តីព្យាយាមថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នេះ ជាធម៌មិននាំមកនូវសេចក្តីទុក្ខ មិនលំបាក មិនចង្អៀតចង្អល់ មិនក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ។ ធម៌ណា គឺសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជារបស់នាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នេះរមែងប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ។ ធម៌ណា គឺការមិនប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជាសេចក្តីព្យាយាមនាំមកនូវទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ មិននាំមកនូវសេចក្តីទុក្ខ មិនលំបាក មិនចង្អៀតចង្អល់ មិនក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ។ ពាក្យណាដែលតថាគតពោលហើយថា បុគ្គលមិនគប្បីប្រកបរឿយៗ នូវសេចក្តីសុខក្នុងកាម ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ មួយទៀត មិនគប្បីប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក នាំមកនូវទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ដូច្នេះ

ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[ ១៣១ ] ឯពាក្យថា មជ្ឈិមប្បដិបទា គឺសេចក្តីប្រតិបត្តិយ៉ាងកណ្តាល មិនប៉ះពាល់នូវធម៌អមខាងទាំង ២ នុ៎ះ ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីចេះដឹងតែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីព្រះនិព្វាន ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះឯង គឺសេចក្តីយល់ត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ សេចក្តីព្យាយាមត្រូវ ១ ការរឭកត្រូវ ១ ការតម្កល់ចិត្តនឹងត្រូវ ១ ។ ពាក្យណាដែលតថាគតពោលហើយថា មជ្ឈិមប្បដិបទា គឺសេចក្តីប្រតិបត្តិជាកណ្តាល មិនបានប៉ះពាល់នូវធម៌អមខាងទាំង ២ នុ៎ះ ដែលតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីចេះដឹង តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ដើម្បីស្គាល់អរិយសច្ច ដើម្បីត្រាស់ដឹងអរិយសច្ច ដើម្បីព្រះនិព្វាន ដូច្នេះ ពាក្យនុ៎ះ ដែលតថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[ ១៣២ ] ឯពាក្យថា បុគ្គលគប្បីដឹងនូវការលើកតម្កើងផង គប្បីដឹងនូវការបន្ទុះបន្អាប់ផង លុះដឹងនូវការលើកតម្កើង ទាំងដឹងនូវការបន្ទុះបន្អាប់ហើយ មិនគប្បីលើកតម្កើង មិនគប្បីបន្ទុះបន្អាប់ គប្បីសម្តែងធម៌ដោយត្រង់ ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ពាក្យនុ៎ះតថាគតបានពោលហើយ ព្រោះ

អាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ការលើកតម្កើង និងការបន្ទុះបន្ទាប់ មិនមែនជាការសម្តែងធម៌ តើដូចម្តេច ។ កាលដែលបុគ្គលអ្នកសម្តែងធម៌ពោលថា ជនទាំងឡាយណា មានសេចក្តីសុខដោយកាមប្បដិសន្ធិ រមែងប្រកបរឿយៗ នូវសេចក្តីព្យាយាមដោយសោមនស្ស ដែលជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយ-បុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ ឈ្មោះថា ប្រកបដោយទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិខុស ដូច្នេះ ឈ្មោះថា បន្ទុះបន្ទាប់បុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ កាលដែលបុគ្គលសម្តែងធម៌ពោលថា ជនទាំងឡាយណា មានសេចក្តីសុខដោយកាមប្បដិសន្ធិ មិនប្រកបរឿយៗ នូវសេចក្តីព្យាយាមដោយសោមនស្ស ដែលជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ មិនមានសេចក្តីទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវ ដូច្នេះឈ្មោះថា លើកតម្កើងបុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ កាលដែលបុគ្គលអ្នកសម្តែងធម៌ពោលថា ជនទាំងឡាយណា ប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក នាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់

ប្រកបដោយសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិខុស ដូច្នេះឈ្មោះថា បន្ទះ-បន្ទាប់បុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ កាលដែលបុគ្គលអ្នកសម្តែងធម៌ពោលថា ជនទាំងឡាយណាមិនប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជារបស់នាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ មិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវ ដូច្នេះឈ្មោះថា លើកតម្កើងបុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ កាលដែលបុគ្គលអ្នកសម្តែងធម៌ពោលថា ជនទាំងឡាយណាមួយ មិនបានលះបង់នូវសំយោជនៈក្នុងភព ( តណ្ហា ) ជនទាំងអស់នោះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិខុស ដូច្នេះឈ្មោះថា បន្ទះបន្ទាប់បុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ កាលដែលបុគ្គលអ្នកសម្តែងធម៌ពោលថា បុគ្គលណាមួយលះបង់សំយោជនៈ ក្នុងភពបានហើយ ជនទាំងអស់នោះ មិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវ ដូច្នេះឈ្មោះថា លើកតម្កើងបុគ្គលពួកខ្លះ ដោយប្រការដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ការលើកតម្កើង និងការបន្ទះបន្ទាប់ មិនមែនជាការសម្តែងធម៌ យ៉ាងនេះឯង ។

[ ១៣៣ ] ម្នាលភិក្ខុទាំងឡាយ ចុះការមិនលើកតម្កើង ការមិនបន្ទះ-បន្ទាប់ ជាការសម្តែងធម៌ដោយត្រង់ តើដូចម្តេច ។ បុគ្គលអ្នកសម្តែងធម៌

មិនបានពោលយ៉ាងនេះថា ជនទាំងឡាយណា ដែលជាអ្នកមានសេចក្តីសុខ ដោយកាមប្បដិសន្ធិ ប្រកបរឿយៗ នូវសេចក្តីព្យាយាមដោយសោមនស្ស ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ ឈ្មោះថា ប្រកបដោយទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិខុសដូច្នេះ ។ កាលដែលបុគ្គលអ្នកសម្តែងធម៌ ពោលថា អនុយោគធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ដូច្នេះឈ្មោះថា សម្តែងធម៌ដោយត្រង់ ។ បុគ្គលអ្នកសម្តែងធម៌ មិនបានពោលយ៉ាងនេះថា ជនទាំង-ឡាយណា ជាអ្នកមានសេចក្តីសុខ ដោយកាមប្បដិសន្ធិ មិនប្រកបរឿយៗ នូវសេចក្តីព្យាយាមដោយសោមនស្ស ដែលជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះមិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនក្តៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវ ដូច្នេះ ។ កាលដែលបុគ្គលអ្នកសម្តែងធម៌ពោលថា អននុយោគធម៌នុ៎ះ មិនមានសេចក្តីទុក្ខ មិនមានសេចក្តីលំបាក មិនមានការចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ដូច្នេះ ឈ្មោះថា សម្តែងធម៌ដោយត្រង់ ។ បុគ្គលអ្នកសម្តែងធម៌ មិនបានពោលយ៉ាងនេះថា ជនទាំងឡាយណា ជាអ្នកប្រកប

រឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក នាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិខុស ដូច្នេះ ។ កាលដែលបុគ្គលអ្នកសម្តែងធម៌ពោលថា អនុយោគធម៌នេះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ដូច្នេះ ឈ្មោះថា សម្តែងធម៌ដោយត្រង់ ។ បុគ្គលអ្នកសម្តែងធម៌ មិនបានពោលយ៉ាងនេះថា ជនទាំងឡាយណា ដែលមិនប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក នាំមកនូវទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ជនទាំងអស់នោះ មិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវ ដូច្នេះ ។ កាលដែលបុគ្គលអ្នកសម្តែងធម៌ ពោលថា អននុយោគធម៌នុ៎ះ មិនមានទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ដូច្នេះ ឈ្មោះថា សម្តែងធម៌ដោយត្រង់ ។ បុគ្គលអ្នកសម្តែងធម៌មិនបានពោលយ៉ាងនេះថា ជនទាំងឡាយណាមួយ មិនបានលះបង់នូវភវសំយោជនៈ ជនទាំងអស់នោះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិខុស ដូច្នេះ ។ កាលដែលបុគ្គលអ្នក

សម្តែងធម៌ពោលថា កាលបើកវសំយោជនៈ មិនទាន់លះបង់នៅឡើយ ភព ក៏មិនបានលះបង់ទៅដែរ ដូច្នេះឈ្មោះថា សម្តែងធម៌ដោយត្រង់ ។ បុគ្គលអ្នក សម្តែងធម៌មិនបានពោលយ៉ាងនេះថា ជនទាំងឡាយណាមួយ បានលះបង់នូវ កវសំយោជនៈ ជនទាំងអស់នោះ មិនមានទុក្ខ មិនមានសេចក្តីលំបាក មិន មានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាអ្នកប្រតិបត្តិត្រូវ ដូច្នេះ ។ កាលដែលបុគ្គលអ្នកសម្តែងធម៌ពោលថា កាលបើកវសំយោជនៈ លះបង់ទៅហើយ ភពក៏លះបង់ទៅដែរ ដូច្នេះឈ្មោះថាសម្តែងធម៌ដោយត្រង់ ។ ម្នាលភិក្ខុទាំងឡាយ ការមិនលើកតម្កើង ការមិនបន្តុះបង្អាប់ ជាការសម្តែង ធម៌ដោយត្រង់ យ៉ាងនេះឯង ។ ពាក្យណា ដែលតថាគតពោលហើយថា បុគ្គលគប្បីដឹងនូវការលើកតម្កើងផង គប្បីដឹងនូវការបន្តុះបង្អាប់ផង លុះដឹង នូវការលើកតម្កើង និងដឹងនូវការបន្តុះបង្អាប់ហើយ មិនគប្បីលើកតម្កើង មិន គប្បីបន្តុះបង្អាប់ គប្បីសម្តែងធម៌ដោយត្រង់ ដូច្នេះ ពាក្យនុ៎ះ តថាគតពោល ហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[ ១៣៤ ] ពាក្យថា បុគ្គលគប្បីដឹងនូវសេចក្តីសុខដែលថោកថយ លុះ ដឹងនូវសេចក្តីសុខដែលថោកថយហើយ គប្បីប្រកបរឿយៗ នូវសេចក្តីសុខ ក្នុងសន្តាន ដូច្នេះ ពាក្យនុ៎ះ តថាគតបានពោលហើយ ។ ពាក្យនុ៎ះ តថាគត ពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កាម- គុណនេះមាន ៥ ប្រការ កាមគុណ ៥ ប្រការ តើអ្វីខ្លះ រូបដែលគប្បីដឹង ដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់

ប្រកបដោយកាម ជាទីតាំងនៃសេចក្តីត្រេកអរ សំឡេងដែលគប្បីដឹងដោយត្រចៀក ...ក្លិនដែលគប្បីដឹងដោយច្រមុះ ...រសដែលគប្បីដឹងដោយអណ្តាត ... ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពជាទីស្រឡាញ់ ប្រកបដោយកាម ជាទីតាំងនៃសេចក្តីត្រេកអរ ម្នាលភិក្ខុទាំងឡាយ នេះឯងកាមគុណ ៥ ប្រការ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខ និងសោមនស្សណា តែងកើតឡើងព្រោះអាស្រ័យនូវកាមគុណទាំង ៥ នេះ សេចក្តីសុខ និងសោមនស្សនេះ តថាគតហៅថា ជាសេចក្តីសុខក្នុងកាម ជាសេចក្តីសុខរបស់បុថុជ្ជន ជាសេចក្តីសុខដ៏លាមក មិនមែនជាសេចក្តីសុខរបស់ព្រះអរិយបុគ្គលទេ ។ តថាគតពោលថា បុគ្គលមិនគប្បីសេព មិនគប្បីចម្រើន មិនគប្បីធ្វើឲ្យច្រើន គប្បីខ្លាចសេចក្តីសុខនេះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ហើយបានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក និងវិចារ មានបីតិ និងសុខដែលកើតអំពីសេចក្តីស្ងាត់ ហើយសម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ព្រោះរម្ងាប់វិតក្ក និងវិចារ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្ក មិនមានវិចារ មានតែបីតិ និងសុខ ដែលកើតអំពីសមាធិ គឺបឋមជ្ឈាន ... បានដល់នូវតតិយជ្ឈាន ... បានដល់នូវចតុត្ថជ្ឈាន ហើយសម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ នេះ តថាគតហៅថា នេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធិសុខ ។

តថាគតពោលថា បុគ្គលគួរសេព គួរចម្រើន គួរធ្វើឲ្យច្រើន មិនគួរខ្ពាច សេចក្តីសុខនេះឡើយ ។ ពាក្យណា ដែលតថាគតពោលហើយថា បុគ្គល គប្បីដឹងនូវសេចក្តីសុខ ដែលថោកថយ លុះដឹងនូវសេចក្តីសុខដែលថោក ថយហើយ គប្បីប្រកបរឿយៗ នូវសេចក្តីសុខក្នុងសន្តាន ដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[ ១៣៥ ] ពាក្យថា បុគ្គលមិនគប្បីពោលពាក្យក្នុងទីកំបាំងមុខ មិនគប្បី ពោលពាក្យនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុ ទាំងឡាយ បណ្តាពាក្យទាំងនោះ បុគ្គលដឹងនូវពាក្យស្ងាត់កំបាំងណា ជាពាក្យ មិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ដោយពិត មិនគប្បីពោលពាក្យ ស្ងាត់កំបាំងឡើយ មួយទៀត បុគ្គលដឹងនូវពាក្យស្ងាត់កំបាំងណា ជាពាក្យ ពិត ពាក្យទៀង តែមិនប្រកបដោយប្រយោជន៍ បុគ្គលគប្បីរៀនដើម្បីមិន និយាយនូវពាក្យនោះ មួយទៀត បុគ្គលដឹងនូវពាក្យស្ងាត់កំបាំងណា ជាពាក្យ ពិត ពាក្យទៀង ហើយប្រកបដោយប្រយោជន៍ បុគ្គលគួរជាអ្នកដឹងនូវកាល គួរក្នុងពាក្យនោះ ដើម្បីនិយាយនូវពាក្យស្ងាត់កំបាំងនោះ ។ ម្នាលភិក្ខុទាំង-ឡាយ បណ្តាពាក្យទាំងនោះ បុគ្គលដឹងនូវពាក្យណាដែលនាំឲ្យសៅហ្មងក្នុង ទីចំពោះមុខ ជាពាក្យមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ដោយពិត មិនគប្បីពោលពាក្យដែលនាំឲ្យសៅហ្មង ក្នុងទីចំពោះមុខនោះទេ មួយទៀត បុគ្គលដឹងនូវពាក្យណាដែលនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ជាពាក្យពិត ពាក្យ

ទៀង តែមិនប្រកបដោយប្រយោជន៍ បុគ្គលគប្បីរៀនដើម្បីមិនពោលនូវពាក្យនោះ មួយទៀត បុគ្គលដឹងនូវពាក្យណាដែលនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ជាពាក្យពិត ពាក្យទៀង ហើយប្រកបដោយប្រយោជន៍ បុគ្គលគួរជាអ្នកដឹងនូវកាលគួរក្នុងពាក្យនោះ ដើម្បីនិយាយនូវពាក្យដែលនាំឲ្យសៅហ្មងក្នុងទីចំពោះមុខនោះ ។ ពាក្យណាដែលតថាគតបានពោលហើយថា បុគ្គលមិនគប្បីពោលពាក្យក្នុងទីកំបាំងមុខ មិនគប្បីពោលពាក្យដែលនាំឲ្យសៅហ្មងក្នុងទីចំពោះមុខ ដូច្នេះ ពាក្យនោះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[ ១៣៦ ] ពាក្យថា បុគ្គលគប្បីពោលកុំឲ្យរួសរាន់ពេក មិនគប្បីពោលរួសរាន់ពេកទុំះ តថាគតបានពោលហើយ ។ ពាក្យនោះ តថាគតពោលហើយព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលដែលពោលរហ័ស កាយក៏រមែងលំបាក ចិត្តក៏រមែងព្រួយ សំឡេងក៏ស្អក កក៏ឈឺចាប់ សម្តីរបស់បុគ្គលដែលពោលញាប់ ជាសម្តីមិនស្រឡះផងស្តាប់មិនជាក់ផង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាបុគ្គលទាំងនោះ បុគ្គលដែលពោលមិនរហ័សពេក កាយក៏មិនលំបាក ចិត្តក៏មិនព្រួយ សំឡេងក៏មិនស្អក កក៏មិនឈឺចាប់ សម្តីរបស់បុគ្គលដែលពោលមិនញាប់ ជាសម្តីស្រឡះផង ដឹងសេចក្តីច្បាស់ផង ។ ពាក្យណា ដែលតថាគតពោលហើយថា បុគ្គលគប្បីពោលកុំឲ្យរួសរាន់ពេក មិនគប្បីពោលរួសរាន់ពេក ដូច្នេះ ពាក្យនោះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

[ ១៣៧ ] ពាក្យថា បុគ្គលមិនគប្បីប្រកាន់ភាសាក្នុងជនបទ មិនគប្បី

ប្រព្រឹត្តកន្លងនូវឈ្មោះដូច្នេះទុំ តថាគតបានពោលហើយ ។ ពាក្យទុំ តថាគត ពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចុះការប្រកាន់នូវភាសាក្នុងជនបទ និងការប្រព្រឹត្តកន្លងនូវឈ្មោះតើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ជនបទខ្លះក្នុងលោកនេះ ភាជនៈតែមួយបែបនោះសោះ តែជនទាំងឡាយរមែងស្គាល់ថា បាតិខ្លះ រមែងស្គាល់ថា បត្តៈខ្លះ រមែងស្គាល់ថា បិដ្ឋៈខ្លះ រមែងស្គាល់ថា សរាវៈខ្លះ រមែងស្គាល់ថា ហរោសៈខ្លះ រមែងស្គាល់ថា បោណៈខ្លះ រមែងស្គាល់ថា ហនៈខ្លះ រមែងស្គាល់ថា បិបិលៈខ្លះ ។ ព្រោះហេតុនោះ ពួកជនស្គាល់នូវរបស់នោះ ក្នុងជនបទនោះៗ យ៉ាងណាៗ បុគ្គលខ្លះ ក៏ប្រកាន់មាំមួនយ៉ាងនោះៗ ហើយពោលថា ពាក្យនេះ ជាពាក្យពិត ពាក្យដទៃ ជាមោឃៈ ។ ម្នាលភិក្ខុទាំងឡាយ ការប្រកាន់នូវភាសាក្នុងជនបទ និងការប្រព្រឹត្តកន្លងនូវឈ្មោះ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះការដែលមិនប្រកាន់នូវភាសាក្នុងជនបទ និងការមិនប្រព្រឹត្តកន្លងនូវឈ្មោះ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ក្នុងជនបទខ្លះ ក្នុងលោកនេះ ភាជនៈតែមួយបែបនោះសោះ តែជនទាំងឡាយរមែងស្គាល់ថា បាតិខ្លះ រមែងស្គាល់ថា បត្តៈខ្លះ រមែងស្គាល់ថា បិដ្ឋៈខ្លះ រមែងស្គាល់ថា សរាវៈខ្លះ រមែងស្គាល់ថា ហរោសៈខ្លះ រមែងស្គាល់ថា បោណៈខ្លះ រមែងស្គាល់ថា ហនៈខ្លះ រមែងស្គាល់ថា បិបិលៈខ្លះ ។ ព្រោះហេតុនោះ ពួកជនតែងស្គាល់នូវភាជនៈនោះ ក្នុងជនបទនោះៗ ថា លោកមានអាយុទាំងនេះ ពោលសំដៅរបស់នេះ ដូច្នេះ យ៉ាងណាៗ បុគ្គលខ្លះមិនប្រកាន់មាំ តែងពោលយ៉ាងនោះៗ ម្នាលភិក្ខុទាំង-

ឡាយ ការមិនប្រកាន់នូវភាសាក្នុងជនបទ និងការមិនប្រព្រឹត្តកន្លងនូវឈ្មោះ យ៉ាងនេះឯង ។ ពាក្យណា ដែលតថាគតបានពោលហើយថា បុគ្គលមិនគប្បីប្រកាន់នូវភាសាក្នុងជនបទ មិនគប្បីប្រព្រឹត្តកន្លងនូវឈ្មោះ ដូច្នេះ ពាក្យនុ៎ះ តថាគតបានពោលហើយ ព្រោះអាស្រ័យសេចក្ដីនេះឯង ។

[ ១៣៨ ] ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ធម៌ណា គឺសេចក្ដីព្យាយាមដោយសោមនស្ស របស់បុគ្គលដែលមានសេចក្ដីសុខដោយកាមប្បដិសន្ធិ ជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកបដោយសេចក្ដីទុក្ខ ប្រកបដោយសេចក្ដីលំបាក ប្រកបដោយសេចក្ដីចង្អៀតចង្អល់ ប្រកបដោយសេចក្ដីក្ដៅក្រហាយ ជាសេចក្ដីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយសេចក្ដីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ធម៌ណា គឺការមិនប្រកបរឿយៗ នូវសេចក្ដីព្យាយាមដោយសោមនស្សរបស់បុគ្គលដែលមានសេចក្ដីសុខដោយកាមប្បដិសន្ធិ ជាធម៌ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះមិនមានទុក្ខ មិនមានសេចក្ដីលំបាក មិនមានសេចក្ដីចង្អៀតចង្អល់ មិនមានសេចក្ដីក្ដៅក្រហាយ ជាសេចក្ដីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្ដីសៅហ្មង ។

[ ១៣៩ ] ម្នាលភិក្ខុទាំងឡាយ បណ្ដាធម៌ទាំងនោះ ធម៌ណា គឺសេចក្ដីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជាធម៌នាំមកនូវសេចក្ដីទុក្ខ មិនមែនជារបស់

ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺការមិនប្រកបរឿយៗ នូវសេចក្តីព្យាយាមធ្វើខ្លួនឯងឲ្យលំបាក ជាសេចក្តីព្យាយាមនាំមកនូវសេចក្តីទុក្ខ មិនមែនជារបស់ព្រះអរិយបុគ្គល មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ មិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្តីសៅហ្មង ។

[ ១៤០ ] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ សេចក្តីប្រតិបត្តិយ៉ាងកណ្តាលណា ដែលព្រះតថាគតត្រាស់ដឹងហើយ ជាសេចក្តីប្រតិបត្តិធ្វើឲ្យកើតបញ្ញាចក្ខុ ធ្វើឲ្យកើតសេចក្តីចេះដឹង ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់រម្ងាប់កិលេស ដើម្បីស្គាល់នូវអរិយសច្ច ដើម្បីត្រាស់ដឹងនូវអរិយសច្ច ដើម្បីព្រះនិព្វាន ធម៌នុ៎ះ ឈ្មោះថា មិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្តីសៅហ្មង ។

[ ១៤១ ] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ការលើកតម្កើង និងការបន្តុះបង្អាប់ ទាំងមិនមែនជាការសម្តែងធម៌ណា ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់

ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ការដែលមិនលើកតម្កើង និងការមិនបន្តុះបង្អាប់ ទាំងការសម្តែងធម៌ដោយត្រង់ណា ធម៌នេះ មិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្តីសៅហ្មង ។

[ ១៤២ ] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ សេចក្តីសុខណា ជាសេចក្តីសុខក្នុងកាម ជាសេចក្តីសុខរបស់បុថុជ្ជន ជាសេចក្តីសុខដ៏លាមក មិនមែនជាសេចក្តីសុខរបស់ព្រះអរិយបុគ្គល ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ សេចក្តីសុខណា ដែលជាសេចក្តីសុខ ក្នុងការចេញចាកកាម ជាសេចក្តីសុខក្នុងការស្ងាត់ ជាសេចក្តីសុខ ក្នុងការរម្ងាប់កិលេស ជាសេចក្តីសុខ ក្នុងការត្រាស់ដឹងមគ្គផល ធម៌នុ៎ះ មិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្តីសៅហ្មង ។

[ ១៤៣ ] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ពាក្យស្ងាត់កំបាំងណា ជាពាក្យមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកប

ដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ពាក្យស្វាត់កំបាំងណា ជាពាក្យពិត ទៀង តែមិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ពាក្យស្វាត់កំបាំងណា ជាពាក្យពិត ទៀង ប្រកបដោយប្រយោជន៍ ធម៌នុ៎ះ មិននាំមកនូវសេចក្តីទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្តីសៅហ្មង ។

[ ១៨៤ ] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ពាក្យនាំឲ្យសៅហ្មងក្នុងទីចំពោះមុខណា ជាពាក្យមិនពិត មិនទៀង មិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ពាក្យនាំឲ្យសៅហ្មងក្នុងទីចំពោះមុខណា ជាពាក្យពិត ទៀង តែមិនប្រកបដោយប្រយោជន៍ ធម៌នុ៎ះ ប្រកបដោយ

សេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ពាក្យនាំឲ្យសៅហ្មងក្នុងទីចំពោះមុខណា ជាពាក្យពិតទៀង ទាំងប្រកបដោយប្រយោជន៍ ធម៌នុ៎ះ មិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្តីសៅហ្មង ។

[ ១៤៥ ] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺពាក្យរបស់បុគ្គលអ្នកពោលរហ័សពេក ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀតចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺពាក្យរបស់បុគ្គលអ្នកពោលមិនរហ័សពេក ធម៌នុ៎ះ មិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្តីសៅហ្មង ។

[ ១៤៦ ] ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺការប្រកាន់មាំនូវភាសាក្នុងជនបទ និងការប្រព្រឹត្តិកន្លងនូវឈ្មោះ ធម៌នុ៎ះ ប្រកបដោយសេចក្តីទុក្ខ ប្រកបដោយសេចក្តីលំបាក ប្រកបដោយសេចក្តីចង្អៀត

ចង្អល់ ប្រកបដោយសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិខុស ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា ប្រកបដោយសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ បណ្តាធម៌ទាំងនោះ ធម៌ណា គឺការមិនប្រកាន់នូវភាសាក្នុងជនបទ និងការមិនប្រព្រឹត្តកន្លងនូវឈ្មោះ ធម៌នុ៎ះ មិននាំមកនូវទុក្ខ មិនមានសេចក្តីលំបាក មិនមានសេចក្តីចង្អៀតចង្អល់ មិនមានសេចក្តីក្តៅក្រហាយ ជាសេចក្តីប្រតិបត្តិត្រូវ ព្រោះហេតុនោះ ធម៌នុ៎ះ ឈ្មោះថា មិនមានសេចក្តីសៅហ្មង ។

[ ១៤៧ ] ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ អ្នកទាំងឡាយគប្បីសិក្សាក្នុងសាសនានេះថា យើងទាំងឡាយ នឹងដឹងនូវធម៌ដែលប្រកបដោយសេចក្តីសៅហ្មងផង នឹងដឹងនូវធម៌ដែលមិនមានសេចក្តីសៅហ្មងផង លុះដឹងនូវធម៌ដែលប្រកបដោយសេចក្តីសៅហ្មង នឹងដឹងនូវធម៌ដែលមិនមានសេចក្តីសៅហ្មងហើយ ក៏នឹងដើរទៅកាន់ផ្លូវប្រតិបត្តិដែលមិនមានសេចក្តីសៅហ្មង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចំណែកសុភូតិកុលបុត្ត បានដើរទៅកាន់ផ្លូវប្រតិបត្តិដែលមិនមានសេចក្តីសៅហ្មង ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

**អរណាវិភង្គសូត្រទី ៩ ចប់**

# អដ្ឋកថា

## អរណាវិភង្គសូត្រ

[ ១២៨ ] អរណវិភង្គសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ១២៩ ] បណ្តាបទទាំងនោះ បទថា **នេវុស្សាទេយ្យ ន អប្ប–សាទេយ្យ** សេចក្តីថា មិនលើកតម្កើង មិនតិះដៀលបុគ្គលណាដោយអំណាចអាស្រ័យផ្ទះ ។ បទថា **ធម្មមេវ ទេសេយ្យ** គឺគប្បីពោលតែពាក្យពិតប៉ុណ្ណោះ ។ បទថា **សុខវិនិច្ឆយំ** បានដល់ សុខដែលវិនិច្ឆ័យហើយ ។ បទថា **រហោ វាទំ** បានដល់ ពោលទោសក្នុងទីកំបាំង អធិប្បាយថា ពោលពាក្យញុះញង់ ។ បទថា **សម្មុខា ណាតិខីណំ** សេចក្តីថា មិនគប្បីពោលពាក្យហួសព្រំដែន ពាក្យទ្រគោះបោះបោក ពាក្យស្មោកគ្រោកចំពោះមុខ ។ បទថា **ណាភិនិវេសេយ្យ** សេចក្តីថា មិនគប្បីពោលប្រញាប់ប្រញាល់ឲ្យតែបាន ។ បទថា **សមញ្ញំ** បានដល់ លោកសន្មត គឺលោកប្បញ្ញត្តិ ។ បទថា **ណាតិធាវេយ្យំ** គឺមិនគប្បីកន្លងល្មើស ។

[ ១៣០ ] បទថា **កាមប្បដិសន្ធិសុខិនោ** សេចក្តីថា អ្នកមានសេចក្តីសុខ ដោយសេចក្តីសុខក្នុងកាមប្បដិសន្ធិ គឺប្រកបដោយកាម ។ បទថា **សទុក្ខោ** បានដល់ មានទុក្ខ ដោយវិបាកទុក្ខខ្លះ កិលេសទុក្ខខ្លះ ។ បទថា **សឧបឃាតោ** បានដល់ មានការបង្អៀតបង្អល់ចិត្ត ដោយការបង្អៀតបង្អល់ក្នុងវិបាក និងការបង្អៀតបង្អល់ដោយកិលេសនោះឯង មានការក្តៅក្រហាយ

យ៉ាងនោះ ។ បទថា **មិច្ឆាបដិបទា** បានដល់ កិច្ចបដិបត្តិមិនជាសេចក្ដីពិត គឺបដិបត្តិដែលជាអកុសល ។

[ ១៣២ ] បទថា **ឥត្ថេកេ អបសាទេតិ** សេចក្ដីថា តិះដៀលបុគ្គលពួកខ្លះ ដោយអំណាចអាស្រ័យផ្ទះយ៉ាងនេះ ។ សូម្បីក្នុងការសរសើរ ក៏មានន័យនេះដូចគ្នា ។ បទថា **ភវសំយោជនំ** បានដល់ ចំណងក្នុងភព ។ នុះជាឈ្មោះនៃតណ្ហា ។ បានឮថា ព្រះសុភូតិត្ថេរ អាស្រ័យចតុក្កៈនេះ តាំងនៅក្នុងតំណែងឯតទគ្គៈ ។ ពិតហើយ កាលព្រះមានព្រះភាគទ្រង់សម្ដែងធម៌ ការសរសើរ និងការនិន្ទា រមែងប្រាកដដល់ជនទាំងឡាយ ។ កាលព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រជាដើមសម្ដែងធម៌ ការសរសើរ និងការនិន្ទា ក៏ប្រាកដយ៉ាងនោះ ។ តែធម្មទេសនារបស់ព្រះសុភូតិ មិនមានថា បុគ្គលនេះមិនបដិបត្តិ បដិបត្តិខុស ឬបុគ្គលនេះមានសីល មានគុណ មានហិរិ មានសីលជាទីស្រឡាញ់ ដល់ព្រមដោយមារយាទ ដូច្នេះ ។ ធម្មទេសនានៃព្រះសុភូតិនោះរមែងប្រាកដថា នេះជាការបដិបត្តិខុស នេះជាការបដិបត្តិត្រូវប៉ុណ្ណោះ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សុភូតិជាកំពូលនៃភិក្ខុទាំងឡាយ ក្នុងសាវ័ករបស់តថាគត ដែលមានប្រក្រតីនៅដោយសេចក្ដីស្ងប់ ។

[ ១៣៥ ] បទថា **កាលញ្ញូ អស្ស** សេចក្ដីថា មិនពោលក្នុងកាលដែលមិនទាន់មកដល់ និងដែលកន្លងទៅហើយ ពោលដល់កាលដែលគួរប្រកបសេចក្ដីព្យាយាម ដែលគួរពោលក្នុងឥឡូវនេះថា មហាជននឹងកាន់យក

មិនគប្បីពោលពាក្យកំបាំង ។ សូម្បីទីណាវាទក៏មានន័យដូចគ្នា ។

[ ១៣៦ ] បទថា **ឧបហញ្ញតិ** បានដល់ ត្រូវគោះបោះបោក ។ បទថា **សរោបិ ឧបហញ្ញតិ** គឺសូម្បីសំឡេង រមែងស្អក ។ បទថា **អាតុរិយតិ** បានដល់ ជាអ្នកក្តៅក្រហាយ ។ ដល់នូវជំងឺតម្កាត់ គឺបាននូវអាពាធ ។ បទថា **អវិសដ្ឋំ** បានដល់ ពាក្យមិនពីរោះ គឺមិនរណ្តំ ។

[ ១៣៧ ] បទថា **តទេវ** បានដល់ ភាជនៈនោះឯង ។ បទថា **អភិ-និវិស្ស វោហរតិ** សេចក្តីថា បុថុជ្ជនល្ងង់ខ្លៅ ទៅកាន់ជនបទដែលស្គាល់ថា **បត្តំ** បានឮថា ពួកអ្នកចូរនាំមក ចូរលាងបត្តៈ ប្រញាប់ពោលថា នេះមិនមែនបត្តៈ នេះឈ្មោះថា **បាតី** អ្នកចូរនិយាយយ៉ាងនេះ ។ គប្បីប្រកបដោយបទទាំងឡាយក្នុងទីទាំងពួងយ៉ាងនេះ ។ បទថា **អតិសារោ** បានដល់ **អតិ-ធាវនៈ** ។ បទថា **តថា តថា វោហរតិ អបរាមសំ** សេចក្តីថា ភាជនៈក្នុងជនបទរបស់ពួកយើង ហៅថា **បាតី** ។ ឯជនទាំងនេះ ហៅភាជនៈនោះថា **បត្តំ** ។ ចាប់អំពីពេលនោះ កែពាក្យពោលរបស់ជនបទ ពោលរឿយៗ ថា **បត្តំ បត្តំ** ដូច្នេះនោះត្រាច់ទៅ ។ ក្នុងបទដ៏សេសក៏មានន័យដូចគ្នា ។

[ ១៣៨ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ធ្វើបទ **មរិយាទ-ភាជនិយ** ទើបត្រាស់ថា **តត្រ ភិក្ខវេ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **សរណោ** បានដល់ មានធូលី មានកិលេស ។ បទថា **អរណោ** បានដល់ មិនមានធូលី ប្រាសចាកកិលេស ។

[ ១៣៧ ] *បទថា* **សុភូតិ ច បន ភិក្ខវេ** *សេចក្តីថា ព្រះថេរៈនេះ ឡើងកាន់តំណែងឯតទគ្គៈ ២ យ៉ាង គឺសុភូតិជាកំពូលក្នុងអរណវិហារី និង កំពូលក្នុងទក្ខិណេយ្យ ។ បានឮថា ព្រះធម្មសេនាបតីញ៉ាំងវត្ថុឲ្យបរិសុទ្ធ ។ សុភូតិញ៉ាំងទក្ខិណាឲ្យបរិសុទ្ធ ។ ពិតហើយ ព្រះធម្មសេនាបតីត្រាច់បិណ្ឌបាត ឈរនៅត្រង់ទ្វារ កំណត់ក្នុងបុព្វភាគហើយ ចូលនិរោធ ទម្រាំបុគ្គលនាំភិក្ខា មកប្រគេន ។ ចេញអំពីនិរោធហើយ ទទួលទេយ្យធម៌ ។ ព្រះសុភូតិចូល មេត្តាឈានយ៉ាងនោះដែរ ។ ចេញអំពីមេត្តាឈានហើយ ទទួលទេយ្យធម៌ ។ សួរថា ព្រះថេរៈអាចធ្វើយ៉ាងនេះបានឬ ឆ្លើយថា អើ អាច ។ ការដែលព្រះ សាវកទាំងឡាយ ដែលដល់នូវមហាភិញ្ញាគប្បីធ្វើយ៉ាងនេះ មិនគួរអស្ចារ្យទេ ពិតហើយ ក្នុងកាលន័យបុរាណរាជ ក្នុងតម្ពបណ្ណិទ្វីបនោះ ព្រះថេរៈឈ្មោះ បិង្គលពុទ្ធរក្ខិតៈ អាស្រ័យនៅឧត្តរគ្រាម ។ ក្នុងឧត្តរគ្រាមនោះ មានត្រកូល ៧ រយ ។ ព្រះថេរៈមិនធ្លាប់ចូលសមាបត្តិត្រង់ទ្វារត្រកូលណាមួយមិនមាន ឡើយ ។ បទដ៏សេសក្នុងទីទាំងពួង ងាយយល់ទាំងអស់ហើយ ដូច្នេះ ៕*

**អរណវិភង្គសូត្រ ចប់**

**សូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ធាតុវិភង្គសូត្រទី ១០

[ ១៤៨ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ស្តេចទៅកាន់ចារិកក្នុងដែនរបស់ពួកអ្នកមគធៈ បានដល់ទៅក្រុងរាជគ្រឹះ ចូលទៅរកស្មូនឆ្នាំងឈ្មោះភគ្គវៈ លុះចូលទៅដល់ហើយ ទើបត្រាស់នឹងស្មូនឆ្នាំងឈ្មោះភគ្គវៈយ៉ាងនេះថា ម្នាលភគ្គវៈ បើអ្នកមិនមានសេចក្តីចង្អៀតចង្អល់ទេ តថាគតសុំនៅក្នុងផ្ទះបានមួយរាត្រី ។ ស្មូនឆ្នាំងក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឥតមានសេចក្តីចង្អៀតចង្អល់អ្វីទេ ប៉ុន្តែ មានអ្នកបួសចូលទៅនៅក្នុងផ្ទះនេះមុនរួចហើយ បពិត្រព្រះអង្គដ៏ចម្រើន បើអ្នកបួសនោះយល់ព្រម សូមព្រះអង្គគង់នៅតាមសេចក្តីសប្បាយចុះ ។

[ ១៤៩ ] សម័យនោះឯង កុលបុត្រឈ្មោះបុក្កុសាតិ ចេញចាកផ្ទះហើយចូលទៅកាន់ផ្នួសព្រោះសទ្ធាចំពោះព្រះមានព្រះភាគ ។ បុក្កុសាតិកុល-បុត្រនោះឯង ជាអ្នកចូលមកនៅមុនក្នុងផ្ទះស្មូនឆ្នាំងនោះ ។ ព្រះមានព្រះភាគទ្រង់ចូលទៅរកបុក្កុសាតិមានអាយុ លុះចូលទៅដល់ហើយ ទើបត្រាស់នឹងបុក្កុសាតិមានអាយុថា ម្នាលភិក្ខុ បើអ្នកមិនមានសេចក្តីចង្អៀតចង្អល់ទេ តថាគតសុំនៅក្នុងផ្ទះបានមួយរាត្រី ។ បុក្កុសាតិតបថា ម្នាលអាវុសោ នេះកុម្ភការនិវេសន៍ ឈ្មោះឧរុន្ទៈ សូមលោកមានអាយុ នៅតាមសេចក្តីសប្បាយចុះ ។

[ ១៥០ ] ទើបព្រះមានព្រះភាគ ទ្រង់ចូលទៅកាន់កុម្ភការនិវេសន៍ ទ្រង់

ក្រាលកម្រាលស្មៅក្នុងទីសមគួរហើយ គង់ផ្គត់ព្រះភ្លៅ តាំងព្រះកាយត្រង់ ផ្ចង់ព្រះសតិឲ្យមានមុខឆ្ពោះទៅរកកម្មដ្ឋាន ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់គង់ដល់យប់ជ្រៅ ។ ឯបុក្កុសាតិមានអាយុ ក៏អង្គុយនៅដល់យប់ជ្រៅដែរ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា កុលបុត្រនេះ ប្រតិបត្តិវត្តគួរ ជ្រះថ្លាដែរឬហ្ន៎ បើដូច្នោះគួរតែតថាគតសួរមើល ។ ទើបព្រះមានព្រះភាគ ទ្រង់សួរបុក្កុសាតិមានអាយុយ៉ាងនេះថា ម្នាលភិក្ខុ លោកបួសចំពោះអ្នកណា អ្នកណាជាគ្រូលោក មួយទៀត លោកពេញចិត្តនឹងធម៌របស់អ្នកណា ។

[ ១៥១ ] បុក្កុសាតិតបថា ម្នាលអាវុសោ ព្រះសមណគោតមជាសក្យបុត្រ ចេញចាកសក្យត្រកូលទៅបួស ក៏កិត្តិសព្ទសរសើរព្រះគោតមដ៏ចម្រើននោះ ពីរោះល្បីឮខ្ចរខ្ចាយទៅយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកកិលេស ត្រាស់ដឹងដោយព្រះអង្គឯងដោយប្រពៃ ទ្រង់បរិបូណ៌ដោយវិជ្ជា និងចរណៈ ទ្រង់មានព្រះដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរដោយសីលាទិគុណ ជាអ្នកទូន្មាននូវបុរសដែលគួរទូន្មាន ព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងត្រឡប់មកកាន់កពថ្មីទៀត ដោយហេតុនេះៗ ខ្ញុំបួសចំពោះព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គនោះឯង ជាគ្រូរបស់ខ្ញុំ ខ្ញុំពេញចិត្តនឹងធម៌របស់ព្រះមានព្រះភាគអង្គនោះ ។ ម្នាលភិក្ខុ ចុះឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ លោកគង់នៅក្នុងទីណា ។ ម្នាលអាវុសោ ឥឡូវនេះ ព្រះមានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធអង្គនោះ ព្រះអង្គគង់នៅក្រុង

សាវត្ថី ដែលមាននៅក្នុងជនបទប៉ែកខាងជើង ម្នាលភិក្ខុ ចុះព្រះមានព្រះភាគ អង្គនោះ អ្នកដែលបានឃើញឬទេ ប្រសិនបើឃើញអាចស្គាល់ឬទេ ។ ម្នាល អាវុសោ ព្រះមានព្រះភាគអង្គនោះ ខ្ញុំមិនដែលបានឃើញទេ ទុកជាខ្ញុំឃើញ ក៏គង់មិនស្គាល់ដែរ ។

[ ១៥២ ] ទើបព្រះមានព្រះភាគ ទ្រង់ត្រិះរិះយ៉ាងនេះថា កុលបុត្រនេះ បួសចំពោះតថាគត បើដូច្នោះ គួរតថាគតសម្តែងធម៌ដល់កុលបុត្រនេះ ។ ទើបព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងបុក្កុសាតិមានអាយុថា ម្នាល ភិក្ខុ យើងនឹងសម្តែងធម៌ដល់អ្នក ចូរអ្នកយកចិត្តទុកដាក់ស្តាប់ធម៌នោះ ដោយប្រពៃចុះ យើងនឹងសម្តែង ។ បុក្កុសាតិមានអាយុទទួលព្រះពុទ្ធដីកានៃ ព្រះមានព្រះភាគថា អើ អាវុសោ ។

[ ១៥៣ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុ បុរសនេះ មានធាតុ ៦ មានផស្សាយតនៈ ៦ មានមនោបវិចារ ១៨ មានអធិដ្ឋាន ៤ សេចក្តីសម្គាល់ និងសេចក្តីវិលវល់ តែងមិនប្រព្រឹត្តទៅកាន់បុគ្គលដែលឋិត នៅក្នុងអធិដ្ឋានទាំងឡាយណា កាលបើសេចក្តីសម្គាល់ និងសេចក្តីវិលវល់ មិនប្រព្រឹត្តទៅហើយ បុគ្គលនោះ យើងហៅថា អ្នកប្រាជ្ញមានចិត្តស្ងប់រម្ងាប់ បុគ្គលមិនគួរបណ្តែតបណ្តោយបញ្ញា គួររក្សារឿយៗ នូវសច្ចៈ គួរបម្រើន រឿយៗ នូវចាគៈ គួរសិក្សានូវសន្តិ នេះជាឧទ្ទេសនៃធាតុវិភង្គ ។

[ ១៥៤ ] ពាក្យថា ម្នាលភិក្ខុ បុរសនេះមានធាតុ ៦ ដូច្នេះនុ៎ះ យើង បានពោលហើយ ។ ពាក្យនុ៎ះ យើងពោលហើយ ព្រោះអាស្រ័យសេចក្តីដូច

ម្ដេច ។ ម្នាលភិក្ខុ ឯធាតុនេះមាន ៦ ប្រការ គឺបឋវីធាតុ ( ធាតុដី ) ១ អាបោធាតុ ( ធាតុទឹក ) ១ តេជោធាតុ ( ធាតុភ្លើង ) ១ វាយោធាតុ ( ធាតុខ្យល់ ) ១ អាកាសធាតុ ( ធាតុអាកាស ) ១ វិញ្ញាណធាតុ ( ធាតុវិញ្ញាណ ឬចិត្ត ) ១ ពាក្យណា ដែលយើងបានពោលហើយថា ម្នាលភិក្ខុ បុរសនេះមានធាតុ ៦ ដូច្នេះ ពាក្យនុ៎ះយើងបានពោលហើយ ព្រោះអាស្រ័យសេចក្ដីនេះឯង ។

[ ១៥៥ ] ពាក្យថា ម្នាលភិក្ខុ បុរសនេះមានផស្សាយតនៈ ៦ ដូច្នេះនុ៎ះយើងបានពោលហើយ ។ ពាក្យនុ៎ះយើងពោលហើយ ព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ ចក្ខុជាផស្សាយតនៈ ១ សោតៈជាផស្សាយតនៈ ១ ឃានៈជាផស្សាយតនៈ ១ ជិវ្ហាជាផស្សាយតនៈ ១ កាយជាផស្សាយតនៈ ១ មនោជាផស្សាយតនៈ ១ ។ ពាក្យណា ដែលយើងបានពោលហើយថា ម្នាលភិក្ខុ បុរសនេះមានផស្សាយតនៈ ៦ ដូច្នេះ ពាក្យនុ៎ះ យើងបានពោលហើយ ព្រោះអាស្រ័យសេចក្ដីនេះឯង ។

[ ១៥៦ ] ពាក្យថា ម្នាលភិក្ខុ បុរសនេះមានមនោបវិចារ ១៨ ដូច្នេះនុ៎ះយើងបានពោលហើយ ។ ពាក្យនុ៎ះ យើងពោលហើយ ព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ បុគ្គលបានឃើញរូបដោយភ្នែក ហើយពិចារណារូបដែលជាទីតាំងនៃសោមនស្សវេទនា ពិចារណារូបដែលជាទីតាំងនៃទោមនស្សវេទនា ពិចារណារូបដែលជាទីតាំងនៃឧបេក្ខាវេទនា ស្ដាប់សំឡេងដោយត្រចៀក ។បេ។ ហិតក្លិនដោយច្រមុះ ... ទទួលរសដោយអណ្ដាត ... ពាល់

ត្រូវផោដ្ឋព្វៈដោយកាយ ... ដឹងច្បាស់នូវធម៌ដោយចិត្ត ហើយពិចារណាធម៌ដែលជាទីតាំងនៃសោមនស្សវេទនា ពិចារណាធម៌ដែលជាទីតាំងនៃទោមនស្សវេទនា ពិចារណាធម៌ដែលជាទីតាំងនៃឧបេក្ខាវេទនា ត្រូវជាសោមនស្សុបវិចារ ៦ ទោមនស្សុបវិចារ ៦ ឧបេក្ខុបវិចារ ៦ ដោយប្រការដូច្នេះ ។ ពាក្យណា ដែលយើងបានពោលហើយថា ម្នាលភិក្ខុ បុរសនេះ មានមនោបវិចារ ១៨ ដូច្នេះ ពាក្យនុ៎ះ យើងបានពោលហើយ ព្រោះអាស្រ័យសេចក្ដីនេះឯង ។

[ ១៥៧ ] ពាក្យថា ម្នាលភិក្ខុ បុរសនេះ មានអធិដ្ឋាន ៤ ដូច្នេះនុ៎ះ យើងបានពោលហើយ ។ ពាក្យនុ៎ះ យើងពោលហើយ ព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ បុរសមានអធិដ្ឋានក្នុងបញ្ញា ១ មានអធិដ្ឋានក្នុងសច្ចៈ ១ មានអធិដ្ឋានក្នុងចាគៈ ១ មានអធិដ្ឋានក្នុងឧបសមៈ ១ ។ ពាក្យណា ដែលយើងបានពោលហើយថា ម្នាលភិក្ខុ បុរសនេះមានអធិដ្ឋាន ៤ ដូច្នេះ ពាក្យនោះ យើងពោលហើយ ព្រោះអាស្រ័យសេចក្ដីនេះឯង ។

[ ១៥៨ ] ពាក្យថា បុគ្គលនោះ មិនគួរបណ្ដែតបណ្ដោយបញ្ញា គួររក្សារឿយៗ នូវសច្ចៈ គួរចម្រើនរឿយៗ នូវចាគៈ គួរសិក្សានូវសន្តិ ដូច្នេះនុ៎ះ យើងបានពោលហើយ ។ ពាក្យនុ៎ះ យើងពោលហើយព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ ម្នាលភិក្ខុ ចុះបុគ្គលមិនបណ្ដែតបណ្ដោយបញ្ញា តើដូចម្ដេច ។ ម្នាលភិក្ខុ ធាតុនេះមាន ៦ ប្រការ គឺបឋវីធាតុ ១ អាបោធាតុ ១ តេជោធាតុ ១ វាយោធាតុ ១ អាកាសធាតុ ១ វិញ្ញាណធាតុ ១ ។

[ ១៥៩ ] ម្នាលភិក្ខុ ចុះបឋវីធាតុ តើដូចម្តេច ។ ឯបឋវីធាតុខាងក្នុង ក៏មាន ខាងក្រៅក៏មាន ។ ម្នាលភិក្ខុ ចុះបឋវីធាតុជាខាងក្នុង តើដូចម្តេច ។ ធម្មជាតណាដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់កក ជារបស់រឹង មានវិញ្ញាណចូលទៅអាស្រ័យនៅ គឺសក់ រោម ក្រចក ធ្មេញ ស្បែក សាច់ សរសៃ ឆ្អឹង ខួរក្នុងឆ្អឹង ទាច បេះដូង ថ្លើម វាវ ក្រពះ សួត ពោះវៀនធំ ពោះវៀនតូច អាហារថ្មី អាហារចាស់ ឬរបស់ដទៃណាមួយ ជាធម្មជាត កើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់កក ជារបស់រឹង មានវិញ្ញាណចូលទៅអាស្រ័យនៅដែរ ម្នាលភិក្ខុ នេះយើងហៅថា បឋវីធាតុខាងក្នុង ។ មួយទៀត បឋវីធាតុខាងក្នុងណាក្តី បឋវីធាតុខាងក្រៅណាក្តី ទាំងពីរនេះជាបឋវី-ធាតុដូចគ្នា ។ បុគ្គលគួរឃើញតាមពិត នូវបឋវីធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អាត្មាអញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អាត្មាអញ ។ លុះឃើញតាមពិត នូវបឋវីធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងនឿយណាយក្នុងបឋវីធាតុ រមែងញុំាងចិត្តឲ្យគ្រាកចេញអំពីបឋវីធាតុ ។

[ ១៦០ ] ម្នាលភិក្ខុ ចុះអាបោធាតុ តើដូចម្តេច ។ អាបោធាតុខាងក្នុង ក៏មាន ខាងក្រៅក៏មាន ។ ម្នាលភិក្ខុ អាបោធាតុខាងក្នុង តើដូចម្តេច ។ ធម្ម-ជាតណាដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់ជ្រាយ ជារបស់រលាយ មានវិញ្ញាណចូលទៅអាស្រ័យនៅ គឺប្រមាត់ ស្លេស្ម ខ្ទុះ ឈាម ញើស ខ្លាញ់ខាប់ ទឹកភ្នែក ខ្លាញ់រាវ ទឹកមាត់ ទឹកសម្បោរ ទឹករំអិល មូត្រ ឬរបស់

ដទៃណាមួយ ដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់ជ្រាយ ជារបស់រលាយ មានវិញ្ញាណចូលទៅអាស្រ័យនៅ ម្នាលភិក្ខុ នេះយើងហៅថា អាបោធាតុខាងក្នុង ។ អាបោធាតុខាងក្នុងណាក្តី អាបោធាតុខាងក្រៅណាក្តី ទាំងពីរនេះ ជាអាបោធាតុដូចគ្នា ។ បុគ្គលគួរឃើញតាមពិត នូវអាបោធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ លុះឃើញតាមពិតនូវអាបោធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងនឿយណាយក្នុងអាបោធាតុ រមែងញុំាងចិត្តឲ្យគ្រាកចេញអំពីអាបោធាតុ ។

[ ១៦១ ] ម្នាលភិក្ខុ ចុះតេជោធាតុ តើដូចម្តេច ។ តេជោធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលភិក្ខុ ចុះតេជោធាតុខាងក្នុង តើដូចម្តេច ។ ធម្មជាតណាដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់មានចំហាយ ជារបស់មានកម្តៅ មានវិញ្ញាណចូលទៅអាស្រ័យនៅ គឺភ្លើងធាតុដែលធ្វើកាយឲ្យក្តៅស្រួល ១ ភ្លើងធាតុដែលធ្វើកាយឲ្យទ្រុឌទ្រោម ឬគ្រាំគ្រាទៅ ១ ភ្លើងធាតុដែលធ្វើកាយឲ្យក្តៅរោលរាល ១ ភ្លើងធាតុដែលធ្វើអាហារដែលបុគ្គលស៊ី ផឹក ទំពាស៊ី ក្រេប ជញ្ជាប់ឲ្យដល់នូវការរលាយទៅដោយស្រួល ១ ឬធម្មជាតដទៃណាមួយ ដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់មានចំហាយ ជារបស់មានកម្តៅមានវិញ្ញាណចូលទៅអាស្រ័យនៅ ម្នាលភិក្ខុ នេះយើងហៅថា តេជោធាតុខាងក្នុង ។ មួយទៀត តេជោធាតុខាងក្នុងណាក្តី តេជោធាតុខាងក្រៅណាក្តី ទាំងពីរនេះ ហៅថាតេជោធាតុដូចគ្នា ។ បុគ្គលគួរឃើញតាមពិត

នូវតេជោធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ លុះឃើញតាមពិតនូវតេជោធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងនឿយណាយក្នុងតេជោធាតុ រមែងញុំាងចិត្តឲ្យគ្រាកចេញអំពីតេជោធាតុ ។

[ ១៦២ ] ម្នាលភិក្ខុ ចុះវាយោធាតុតើដូចម្ដេច ។ វាយោធាតុខាងក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលភិក្ខុ ចុះវាយោធាតុខាងក្នុង តើដូចម្ដេច ។ ធម្មជាតណាដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់បក់ទៅមក ជារបស់ផ្សព្វផ្សាយទៅមក មានវិញ្ញាណចូលទៅអាស្រ័យនៅ គឺខ្យល់ដែលបក់ឡើងលើ ខ្យល់ដែលបក់ចុះក្រោម ខ្យល់ដែលខាំងនៅក្នុងផ្ទៃ ខ្យល់ដែលខាំងនៅក្នុងក្រពះ ខ្យល់ដែលរត់តាមអវយវៈតូចធំ ខ្យល់ដកដង្ហើមចេញ ខ្យល់ដកដង្ហើមចូល ឬធម្មជាតដទៃណាមួយដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់បក់ទៅមក ជារបស់ផ្សព្វផ្សាយទៅមក មានវិញ្ញាណចូលទៅអាស្រ័យនៅ ម្នាលភិក្ខុ នេះហៅថា វាយោធាតុខាងក្នុង ។ មួយទៀត វាយោធាតុខាងក្នុងណាក្ដី វាយោធាតុខាងក្រៅណាក្ដី ទាំងពីរនេះ ហៅថា វាយោធាតុដូចគ្នា ។ បុគ្គលគួរឃើញតាមពិត នូវវាយោធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ លុះឃើញតាមពិតនូវវាយោធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងនឿយណាយក្នុងវាយោធាតុ រមែងញុំាងចិត្តឲ្យគ្រាកចេញអំពីវាយោធាតុ ។

[ ១៦៣ ] ម្នាលភិក្ខុ ចុះអាកាសធាតុ តើដូចម្ដេច ។ អាកាសធាតុខាង

ក្នុងក៏មាន ខាងក្រៅក៏មាន ។ ម្នាលភិក្ខុ ចុះអាកាសធាតុខាងក្នុង តើដូចម្តេច ។ ធម្មជាតណាដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់សូន្យ ជារបស់ទទេ មានវិញ្ញាណចូលទៅអាស្រ័យនៅ គឺរន្ធត្រចៀក រន្ធច្រមុះ ទ្វារមាត់ និងប្រទេសសម្រាប់លេបអាហារដែលស៊ី ផឹក ទំពា ក្រេប ជញ្ជាប់ និងកន្លែងជាទីឋិតនៃអាហារដែលស៊ី ផឹក ទំពា ក្រេប ជញ្ជាប់ និងប្រទេសជាទីហូរចេញតាមចំណែកខាងក្រោម នៃអាហារដែលស៊ី ផឹក ទំពា ក្រេប ជញ្ជាប់ ឬធម្មជាតដទៃណាមួយដែលកើតក្នុងខ្លួន អាស្រ័យនូវខ្លួន ជារបស់សូន្យ ជារបស់ទទេ មានវិញ្ញាណចូលទៅអាស្រ័យនៅ ម្នាលភិក្ខុ នេះហៅថាអាកាសធាតុខាងក្នុង ។ មួយទៀត អាកាសធាតុខាងក្នុងណាក្តី អាកាសធាតុខាងក្រៅណាក្តី ទាំងពីរនេះ ហៅថាអាកាសធាតុដូចគ្នា ។ បុគ្គលគួរឃើញតាមពិតនូវអាកាសធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញ ។ លុះឃើញតាមពិត នូវអាកាសធាតុនោះ ដោយបញ្ញាដ៏ប្រពៃយ៉ាងនេះហើយ រមែងនឿយណាយក្នុងអាកាសធាតុ រមែងញុំាងចិត្តឲ្យគ្រាកចេញអំពីអាកាសធាតុ ។ ចំណែកខាងក្រោយ នៅសល់តែវិញ្ញាណដ៏បរិសុទ្ធផូរផង់ បុគ្គលតែងដឹងអ្វីមួយ គឺដឹងថា សុខខ្លះ ដឹងថា ទុក្ខខ្លះ ដឹងថា មិនមែនទុក្ខមិនមែនសុខខ្លះ ដោយវិញ្ញាណនោះឯង ។

[ ១៦៤ ] ម្នាលភិក្ខុ សុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈជាហេតុនៃសុខវេទនា ។ បុគ្គលនោះ កាលដែលទទួលនូវសុខវេទនា រមែងដឹងច្បាស់ថា អាត្មាអញទទួលនូវសុខវេទនា រមែងដឹងច្បាស់ថា វេទនាណា

ដែលកើតអំពីផស្សៈនោះ គឺសុខវេទនាដែលកើតឡើង ព្រោះអាស្រ័យនូវផស្សៈ ដែលជាហេតុនៃសុខវេទនា វេទនានោះក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈ ដែលជាហេតុនៃសុខវេទនានោះឯង ។ ម្នាលភិក្ខុ ទុក្ខវេទនាតែងកើតឡើង ព្រោះអាស្រ័យផស្សៈ ជាហេតុនៃទុក្ខវេទនា ។ បុគ្គលនោះ កាលទទួលនូវទុក្ខវេទនា រមែងដឹងច្បាស់ថា អាត្មាអញទទួលទុក្ខ-វេទនា រមែងដឹងច្បាស់ថា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺទុក្ខវេទនាដែលកើតឡើង ព្រោះអាស្រ័យនូវផស្សៈ ដែលជាហេតុនៃទុក្ខវេទនា វេទនានោះក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈ ដែលជាហេតុនៃទុក្ខវេទនានោះឯង ។ ម្នាលភិក្ខុ អទុក្ខមសុខវេទនាតែងកើតឡើង ព្រោះអាស្រ័យផស្សៈ ជាហេតុនៃអទុក្ខមសុខវេទនា ។ បុគ្គលនោះ កាលទទួលអទុក្ខមសុខវេទនា រមែងដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខ-វេទនា រមែងដឹងច្បាស់ថា វេទនាណាដែលកើតអំពីផស្សៈនោះ គឺអទុក្ខម-សុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈ ដែលជាហេតុនៃអទុក្ខម-សុខវេទនា វេទនានោះក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈ ដែលជាហេតុនៃអទុក្ខមសុខវេទនានោះឯង ។

[ ១៦៥ ] ម្នាលភិក្ខុ ដូចកម្តៅតែងកើតមាន ភ្លើងតែងកើតមាន ព្រោះកិរិយាខ្ទប់គ្នា ព្រោះកិរិយាប្រជុំគ្នានៃកំណាត់ឈើទាំងពីរ កម្តៅណាដែលកើតអំពីកិរិយាខ្ទប់គ្នានោះ កម្តៅនោះក៏រលត់ទៅ កម្តៅនោះក៏ស្ងប់រម្ងាប់ ព្រោះកិរិយាញែកគ្នា ព្រោះកិរិយាបែកគ្នានៃកំណាត់ឈើទាំងពីរនោះឯង មានឧបមា

យ៉ាងណាមិញ ម្នាលភិក្ខុ មានឧបមេយ្យដូចសុខវេទនាតែងកើតឡើង ព្រោះអាស្រ័យផស្សៈ ជាហេតុនៃសុខវេទនា បុគ្គលនោះ កាលទទួលសុខវេទនា រមែងដឹងច្បាស់ថា អាត្មាអញទទួលសុខវេទនា រមែងដឹងច្បាស់ថា វេទនាណាដែលកើតអំពីផស្សៈនោះ គឺសុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈ ដែលជាហេតុនៃសុខវេទនា វេទនានោះក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈ ជាហេតុនៃសុខវេទនានោះឯង ។ ម្នាលភិក្ខុ ទុក្ខវេទនាតែងកើតឡើង ព្រោះអាស្រ័យផស្សៈ ជាហេតុនៃទុក្ខវេទនា ។ បុគ្គលនោះ កាលទទួលទុក្ខវេទនា រមែងដឹងច្បាស់ថា អាត្មាអញទទួលទុក្ខ-វេទនា រមែងដឹងច្បាស់ថា វេទនាណាដែលកើតអំពីផស្សៈនោះ គឺទុក្ខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈ ដែលជាហេតុនៃទុក្ខវេទនា វេទនានោះក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈ ដែលជាហេតុនៃទុក្ខវេទនានោះឯង ។ ម្នាលភិក្ខុ អទុក្ខមសុខវេទនាតែងកើតឡើង ព្រោះអា-ស្រ័យផស្សៈជាហេតុនៃអទុក្ខមសុខវេទនា ។ បុគ្គលនោះ កាលទទួលអទុក្ខ-មសុខវេទនា រមែងដឹងច្បាស់ថា អាត្មាអញទទួលអទុក្ខមសុខវេទនា រមែងដឹងច្បាស់ថា វេទនាណា ដែលកើតអំពីផស្សៈនោះ គឺអទុក្ខមសុខវេទនាដែលកើតឡើង ព្រោះអាស្រ័យផស្សៈ ដែលជាហេតុនៃអទុក្ខមសុខវេទនា វេទនានោះក៏រលត់ទៅ វេទនានោះក៏ស្ងប់រម្ងាប់ ព្រោះការរលត់នៃផស្សៈ ដែលជាហេតុនៃអទុក្ខមសុខវេទនានោះឯង ក៏យ៉ាងនោះដែរ ។ ចំណែកខាងក្រោយនៅសល់តែឧបេក្ខាដ៏បរិសុទ្ធ ផូរផង់ ជាធម្មជាតទន់ផង គួរដល់ការងារផង

ក្តីថ្លាផង ។

[ ១៦៦ ] ម្នាលភិក្ខុ ដូចជាងមាសក្តី កូនសិស្សរបស់ជាងមាសក្តី ដែលប្រសប់ គប្បីរៀបចំនូវចង្ក្រានស្នប់ លុះរៀបចំនូវចង្ក្រានស្នប់រួចហើយ គប្បីដុតនូវមាត់នៃចង្ក្រានស្នប់ លុះដុតនូវមាត់នៃចង្ក្រានស្នប់រួចហើយ គប្បីយកដង្កាប់ចាប់មាសដាក់ទៅក្នុងមាត់នៃចង្ក្រានស្នប់ ។ គប្បីផ្លុំមាត់នៃចង្ក្រានស្នប់នោះសព្វៗ កាល យកទឹកប្រោះព្រំសព្វៗ កាល សម្លឹងមើលសព្វៗ កាល ។ មាសនោះប្រាសចាកទោស ប្រាសចាកមន្ទិល ជាមាសទន់ផង គួរដល់ការងារផង ភ្លឺថ្លាផង ទោះបីប្រាថ្នានឹងធ្វើគ្រឿងប្រដាប់ដ៏ផ្សេកណាៗ គឺខ្សែខ្ទនក្តី ការក្តី កងកក្តី ផ្កាមាសក្តី មាសនោះនឹងសម្រេចប្រយោជន៍ដល់បុគ្គលនោះបាន មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុ មានឧបមេយ្យដូចចំណែកខាងក្រោយ នៅសល់តែឧបេក្ខា ដ៏បរិសុទ្ធ ផូរផង់ ជាធម្មជាតទន់ផង គួរដល់ការងារផង ភ្លឺថ្លាផង យ៉ាងនោះឯង ។ បុគ្គលនោះ តែងដឹងច្បាស់យ៉ាងនេះថា បើអាត្មាអញបង្អោនទូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់អាកាសានញ្ចាយតនជ្ឈាន ហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់អាកាសានញ្ចាយតនជ្ឈាននោះ ឧបេក្ខារបស់អាត្មាអញនេះ អាស្រ័យនូវអាកាសនញ្ចាយតនជ្ឈាននោះ អែបនែបនឹងអាកាសានញ្ចាយតនជ្ឈាននោះយ៉ាងនេះ គប្បីឋិតនៅអស់កាលជាយូរអង្វែង ប្រសិនបើអាត្មាអញ បង្អោននូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់វិញ្ញាណញ្ចា-យតនជ្ឈាន ហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់វិញ្ញាណញ្ចាយតនជ្ឈាន

នោះ ឧបេក្ខារបស់អាត្មាអញនេះ ដែលអាស្រ័យនូវវិញ្ញាណញ្ចាយតនជ្ឈាន នោះ ដែលអែបនែបនឹងវិញ្ញាណញ្ចាយតនជ្ឈាននោះ យ៉ាងនេះ ក៏គប្បីឋិត នៅអស់កាលជាយូរអង្វែង ប្រសិនបើអាត្មាអញបង្អោននូវឧបេក្ខានេះ ដែល បរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន ហើយ ចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់អាកិញ្ចញ្ញាយតនជ្ឈាននោះ ឧបេក្ខារបស់ អាត្មាអញនេះ ដែលអាស្រ័យនូវអាកិញ្ចញ្ញាយតនជ្ឈាននោះ ដែលអែបនែប នឹងអាកិញ្ចញ្ញាយតនជ្ឈាននោះ យ៉ាងនេះ ក៏គប្បីឋិតនៅអស់កាលជាយូរ អង្វែង ប្រសិនបើអាត្មាអញបង្អោននូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ហើយចម្រើនចិត្ត ជា ធម៌ដ៏សមគួរដល់នេវសញ្ញានាសញ្ញាយតនជ្ឈាននោះ ឧបេក្ខារបស់អាត្មាអញ នេះ ដែលអាស្រ័យនូវនេវសញ្ញានាសញ្ញាយតនជ្ឈាននោះ ដែលអែបនែប នឹងនេវសញ្ញានាសញ្ញាយតនជ្ឈាននោះ យ៉ាងនេះ ក៏គប្បីឋិតនៅអស់កាលជា យូរអង្វែង ។ បុគ្គលនោះ តែងដឹងច្បាស់យ៉ាងនេះថា ប្រសិនបើអាត្មាអញ បង្អោននូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់អាកា-សានញ្ចាយតនជ្ឈាន ហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់អាកាសានញ្ចា-យតនជ្ឈាននោះ ឈានទុំះ នៅជាសង្ខតជ្ឈាន ប្រសិនបើអាត្មាអញបង្អោន នូវឧបេក្ខានេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់វិញ្ញាណញ្ចា-យតនជ្ឈាន ហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់វិញ្ញាណញ្ចាយតនជ្ឈាន នោះ ឈានទុំះ ក៏នៅជាសង្ខតជ្ឈាន ប្រសិនបើអាត្មាអញ បង្អោននូវឧបេក្ខា

នេះ ដែលបរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់អាកិញ្ចញ្ញាយតនជ្ឈាន ហើយចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់អាកិញ្ចញ្ញាយតនជ្ឈាននោះ ឈានទុំ: ក៏នៅជាសន្ធតជ្ឈាន ប្រសិនបើអាត្មាអញបង្អោនទូវឧបេក្ខានេះ ដែលបរិសុទ្ធ យ៉ាងនេះ ផូរផង់យ៉ាងនេះ ទៅកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ហើយ ចម្រើនចិត្ត ជាធម៌ដ៏សមគួរដល់នេវសញ្ញានាសញ្ញាយតនជ្ឈាននោះ ឈានទុំ: ក៏នៅជាសន្ធតជ្ឈាន ។ បុគ្គលនោះ ក៏លែងតាក់តែង លែងត្រិះរិះគិត ដើម្បី សេចក្តីចម្រើន ឬសេចក្តីវិនាស ។ បុគ្គលនោះ កាលលែងតាក់តែង លែង ត្រិះរិះគិត ដើម្បីសេចក្តីចម្រើន ឬសេចក្តីវិនាស ក៏លែងប្រកាន់របស់ទីមួយ ក្នុងលោក កាលបើលែងប្រកាន់ហើយ ក៏មិនតក់ស្លុត កាលមិនតក់ស្លុត រមែងរម្ងត់កិលេសដោយពិតប្រាកដ រមែងដឹងច្បាស់ថា ជាតិ ( របស់អាត្មា អញ ) អស់ហើយ ព្រហ្មចរិយធម៌ អាត្មាអញបាននៅគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បើបុគ្គលនោះ ទទួលសុខ- វេទនា ក៏ដឹងច្បាស់ថា សុខវេទនានោះមិនទៀង ដឹងច្បាស់ថា សុខវេទនា នោះ អាត្មាអញមិនគួរនឹងជ្រប់ជាប់ឡើយ ដឹងច្បាស់ថា សុខវេទនានោះ អាត្មាអញមិនគួរនឹងត្រេកអរឡើយ ។ ប្រសិនបើបុគ្គលនោះ ទទួលទុក្ខវេទនា ក៏ដឹងច្បាស់ថា ទុក្ខវេទនានោះ មិនទៀង ដឹងច្បាស់ថា ទុក្ខវេទនានោះ អាត្មា អញមិនគួរនឹងជ្រប់ជាប់ឡើយ ដឹងច្បាស់ថា ទុក្ខវេទនានោះ អាត្មាអញមិន គួរនឹងត្រេកអរឡើយ ។ ប្រសិនបើបុគ្គលនោះ ទទួលអទុក្ខមសុខវេទនា

ក៏ដឹងច្បាស់ថា អទុក្ខមសុខវេទនានោះមិនទៀង ដឹងច្បាស់ថា អទុក្ខមសុខ-វេទនានោះ អាត្មាអញមិនគួរនឹងជ្រប់ជាប់ឡើយ ដឹងច្បាស់ថា អទុក្ខមសុខ-វេទនានោះ អាត្មាអញមិនគួរនឹងត្រេកអរឡើយ ។ បើបុគ្គលនោះ ទទួលសុខវេទនា រមែងមានចិត្តនឿយណាយ ហើយទទួលសុខវេទនានោះ ។ បើបុគ្គលនោះ ទទួលទុក្ខវេទនា រមែងមានចិត្តនឿយណាយ ហើយទទួលទុក្ខ-វេទនានោះ ។ បើបុគ្គលនោះ ទទួលអទុក្ខមសុខវេទនា រមែងមានចិត្តនឿយណាយ ហើយទទួលអទុក្ខមសុខវេទនានោះ ។ កាលបុគ្គលនោះ ទទួលវេទនាដែលមានកាយជាទីបំផុត ក៏រមែងដឹងច្បាស់ថា អាត្មាអញទទួលវេទនាមានកាយជាទីបំផុត ។ កាលទទួលវេទនា ដែលមានជីវិតជាទីបំផុត ក៏រមែងដឹងច្បាស់ថា អាត្មាអញទទួលវេទនាមានជីវិតជាទីបំផុត ។ ដឹងច្បាស់ថា កាលបើមានរាងកាយបែកធ្លាយទៅហើយ ខាងនាយអំពីការអស់ជីវិតទៅ វេទនាទាំងពួង ដែលអាត្មាអញមិនគួរត្រេកអរ ក្នុងលោកនេះ នឹងរលត់អស់ទៅមិនមានសល់ ។

[ ១៦៧ ] ម្នាលភិក្ខុ ដូចជាប្រទីបប្រេង តែងឆេះរុងរឿង ព្រោះអាស្រ័យប្រេងផង ព្រោះអាស្រ័យប្រឆេះផង ។ អណ្តាតប្រទីបមិនមានអាហារ តែងរលត់ទៅ ព្រោះអស់ប្រេង និងប្រឆេះមុននោះផង ព្រោះមិនបានបន្ថែមប្រេង និងប្រឆេះដទៃទៀតផង យ៉ាងណាមិញ ម្នាលភិក្ខុ កាលបុគ្គលនោះ ទទួលវេទនាមានកាយជាទីបំផុត ក៏ដឹងច្បាស់ថា អាត្មាអញទទួលវេទនាមានកាយជាទីបំផុត ។ កាលទទួលវេទនាមានជីវិតជាទីបំផុត ក៏ដឹងច្បាស់ថា អាត្មា

អញទទួលវេទនាមានជីវិតជាទីបំផុត ។ ដឹងច្បាស់ថា កាលបើមានរាងកាយបែកធ្លាយទៅហើយ ខាងនាយអំពីការអស់ជីវិតទៅ វេទនាទាំងពួង ដែលអាត្មាអញមិនគួរត្រេកអរ ក្នុងលោកនេះ នឹងរលត់អស់ទៅមិនមានសល់ ក៏យ៉ាងនោះឯង ។ ម្នាលភិក្ខុ ព្រោះហេតុនោះ បុគ្គលដែលប្រកបដោយគុណធម៌យ៉ាងនេះ ទើបឈ្មោះថា ប្រកបដោយបញ្ញាធិដ្ឋានដ៏ឧត្តមនេះ ។ ម្នាលភិក្ខុ ព្រោះថា សេចក្តីដឹងក្នុងធម៌ ជាទីអស់ទៅនៃទុក្ខទាំងពួងណា សេចក្តីដឹងនុ៎ះ ហៅថា បញ្ញាដ៏ប្រសើរក្រៃលែង ។ វិមុត្តិនោះរបស់បុគ្គលនោះ ឋិតនៅក្នុងសច្ចៈ ជាវិមុត្តិមិនកម្រើក ។ ម្នាលភិក្ខុ ព្រោះថា របស់ណាដែលមានសេចក្តីវិនាសជាធម្មតា របស់នោះជារបស់មុសា ព្រះនិព្វានណាដែលមានសេចក្តីមិនវិនាសជាធម្មតា ព្រះនិព្វាននោះ ជារបស់សច្ចៈ ម្នាលភិក្ខុ ព្រោះហេតុនោះ បុគ្គលដែលប្រកបដោយគុណធម៌យ៉ាងនេះ ទើបឈ្មោះថា ប្រកបដោយសច្ចាធិដ្ឋានដ៏ឧត្តមនេះ ។ ម្នាលភិក្ខុ ព្រោះថា ព្រះនិព្វានណា ដែលមានសេចក្តីមិនវិនាសជាធម្មតា ព្រះនិព្វាននុ៎ះ ឈ្មោះថា ជាអរិយសច្ចដ៏ឧត្តម ។ ក៏កាលពីដើម បុគ្គលនោះ មិនទាន់ដឹងច្បាស់ តែងបំពេញ តែងកាន់យក នូវឧបធិទាំងឡាយ ។ ឧបធិទាំងនោះ បុគ្គលនោះ បានលះបង់ហើយ បានគាស់រំលើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការមិនមាន មានសភាពមិនកើតទៀតជាធម្មតាទៅ ម្នាលភិក្ខុ ព្រោះហេតុនោះ បុគ្គលដែលប្រកបដោយគុណធម៌យ៉ាងនេះ ទើបឈ្មោះថា ប្រកបដោយចាគាធិដ្ឋានដ៏ឧត្តមនេះ ។ ម្នាលភិក្ខុ ព្រោះថា ការ

លះបង់នូវឧបធិទាំងពួងណា ការលះបង់នុ៎ះ ហៅថា ចាគៈដ៏ប្រសើរក្រៃលែង ។ កាលពីដើម បុគ្គលនោះមិនទាន់ដឹងច្បាស់ អភិជ្ឈា ឆន្ទៈ និងសារាគៈ ក៏មាននៅ កិលេសនោះ បុគ្គលនោះបានលះបង់ចោលហើយ បានគាស់រម្លើងឫសគល់អស់ហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការមិនមាន មានសភាពមិនកើតតទៅទៀតជាធម្មតា ។ មួយទៀត កាលពីដើមបុគ្គលនោះមិនទាន់ដឹងច្បាស់ អាឃាត ព្យាបាទ និងសម្បទោសៈ ក៏មាននៅ កិលេសនោះ បុគ្គលនោះបានលះបង់ហើយ បានគាស់រម្លើងឫសគល់ចោលហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការមិនមាន មានសភាពមិនកើតតទៅទៀតជាធម្មតា ។ កាលពីដើមបុគ្គលនោះមិនទាន់ដឹងច្បាស់ អវិជ្ជា សម្មោហៈ និងសម្បមោហៈ ក៏មាននៅ កិលេសនោះ បុគ្គលនោះបានលះបង់ហើយ បានគាស់រម្លើងឫសគល់ចោលហើយ បានធ្វើឲ្យនៅសល់តែទីនៅ ដូចជាទីនៅនៃដើមត្នោត ជាសភាវៈដល់នូវការមិនមាន មានសភាពមិនកើតតទៅទៀតជាធម្មតា ម្នាលភិក្ខុ ព្រោះហេតុនោះ បុគ្គលដែលប្រកបដោយគុណធម៌យ៉ាងនេះ ទើបឈ្មោះថាប្រកប ដោយឧបសមាធិដ្ឋានដ៏ឧត្តមនេះ ។ ម្នាលភិក្ខុ ព្រោះថា ការរម្ងាប់នូវរាគៈ ទោសៈ និងមោហៈទាំងឡាយណា ការរម្ងាប់នុ៎ះ ឈ្មោះថាឧបសមៈដ៏ប្រសើរក្រៃលែង ។ ពាក្យណា ដែលយើងពោលហើយថា បុគ្គលនោះមិនគួរបណ្តែតបណ្តោយបញ្ញា គួររក្សារឿយៗនូវសច្ចៈ គួរចម្រើនរឿយៗនូវចាគៈ គួរសិក្សានូវសន្តិ ដូច្នេះ ពាក្យនុ៎ះ យើងពោលហើយ ព្រោះអាស្រ័យ

សេចក្តីនេះឯង ។

[ ១៦៨ ] ពាក្យថា សេចក្តីសម្គាល់ និងសេចក្តីវិលវល់ តែងមិនប្រព្រឹត្តទៅកាន់បុគ្គលដែលឋិតនៅក្នុងអធិដ្ឋានទាំងឡាយណា កាលបើសេចក្តីសម្គាល់ និងសេចក្តីវិលវល់មិនប្រព្រឹត្តទៅហើយ បុគ្គលនោះ យើងហៅថាជាអ្នកប្រាជ្ញ មានចិត្តស្ងប់រម្ងាប់ដូច្នេះនុ៎ះ យើងបានពោលហើយ ។ ពាក្យនុ៎ះ យើងពោលហើយ ព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ម្នាលភិក្ខុ សេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញកើតមានឥឡូវនេះ សេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញមិនកើតមានឥឡូវនេះ សេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញនឹងកើតមាន សេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញនឹងមិនកើតមាន សេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញនឹងមានរូប សេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញនឹងមិនមានរូប សេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញនឹងមានសញ្ញា សេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញនឹងមិនមានសញ្ញា សេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។ ម្នាលភិក្ខុ សេចក្តីសម្គាល់ឈ្មោះថាជារោគ សេចក្តីសម្គាល់ឈ្មោះថាជាបូស សេចក្តីសម្គាល់ឈ្មោះថាជាសរ ។ ម្នាលភិក្ខុ បុគ្គលនោះ យើងហៅថាជាអ្នកប្រាជ្ញមានចិត្តស្ងប់រម្ងាប់ ព្រោះតែការប្រព្រឹត្តកន្លងនូវសេចក្តីសម្គាល់ទាំងពួងបាន ។ ម្នាលភិក្ខុ ឯអ្នកប្រាជ្ញ ដែលមានចិត្តស្ងប់រម្ងាប់ រមែងលែងកើត លែងចាស់ លែងស្លាប់ លែងស្អប់ លែងស្រឡាញ់ ។ ម្នាលភិក្ខុ សត្វគប្បីកើតដោយហេតុណា ហេតុនោះរបស់បុគ្គលនោះមិនមានឡើយ កាលបុគ្គល

នោះមិនកើត នឹងចាស់មកពីណា កាលបើមិនចាស់ហើយនឹងស្លាប់មកពីណា កាលបើមិនស្លាប់ហើយ នឹងស្អប់មកពីណា កាលបើមិនស្អប់ហើយ នឹងស្រឡាញ់មកពីណា ។ ពាក្យណាដែលយើងពោលហើយថា សេចក្តីសម្គាល់ និងសេចក្តីវិលវល់ តែងមិនប្រព្រឹត្តទៅកាន់បុគ្គលដែលឋិតនៅក្នុងអធិដ្ឋានទាំងឡាយណា កាលបើសេចក្តីសម្គាល់ និងសេចក្តីវិលវល់ មិនប្រព្រឹត្តទៅហើយ បុគ្គលនោះយើងហៅថាជាអ្នកប្រាជ្ញ មានចិត្តស្ងប់រម្ងាប់ដូច្នេះ ពាក្យនុ៎ះយើងពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។ ម្នាលភិក្ខុ ចូរអ្នកចាំទុកនូវចំណែកនៃធាតុទាំង ៦ ដោយសេចក្តីសង្ខេបរបស់យើងនេះចុះ ។

[ ១៦៩ ] គ្រានោះឯង បុក្កុសាតិមានអាយុ ក៏ភ្ញាក់ស្មារតីដឹងថា ព្រះសាស្តារបស់អញ ស្តេចមកដល់ហើយតើ ព្រះសុគតរបស់អញ ស្តេចមកដល់ហើយតើ ព្រះសម្មាសម្ពុទ្ធរបស់អញ ស្តេចមកដល់ហើយតើ ដូច្នេះ ក៏ក្រោកអំពីអាសនៈ ធ្វើចីវរឆៀងស្មាម្ខាង ក្រាបទៀបបាទា របស់ព្រះមានព្រះភាគដោយត្បូងហើយ ទើបសូមខមាទោស ចំពោះព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីល្មើសហើយ ដោយហេតុថាខ្ញុំព្រះអង្គជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ព្រោះខ្ញុំព្រះអង្គបានសម្គាល់នូវព្រះមានព្រះភាគ ថាជាបុគ្គលដែលគេគប្បីហៅរក ដោយពាក្យថាអាវុសោដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់អត់ទោសតាមទោស របស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅមុខទៀត ។

[ ១៧០ ] ព្រះអង្គទ្រង់ត្រាស់ថា អើភិក្ខុ អ្នកមានសេចក្តីល្មើសហើយ

ដោយហេតុថាអ្នក ជាមនុស្សល្ងង់ខ្លៅ ជាមនុស្សវង្វេង ជាមនុស្សមិនឈ្លាស ព្រោះអ្នកបានសម្គាល់នូវតថាគត ថាជាបុគ្គលដែលគេគប្បីហៅរក ដោយពាក្យថាអាវុសោដូច្នេះ ម្នាលភិក្ខុ កាលណាបើអ្នកបានឃើញទោស តាមទោសហើយ សម្តែងដោយសមគួរតាមធម៌ហើយ យើងនឹងអត់ទោសនោះដល់អ្នក ម្នាលភិក្ខុ បុគ្គលណាឃើញនូវទោសតាមទោសហើយ សម្តែងដោយសមគួរតាមធម៌ហើយ ដល់នូវការសង្រួមតទៅ នេះជាសេចក្តីចម្រើន របស់បុគ្គលនោះ ក្នុងអរិយវិន័យ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរបាននូវឧបសម្បទា ក្នុងសម្នាក់ព្រះមានព្រះភាគ ។ ម្នាលភិក្ខុ ចុះបាត្រ និងចីវររបស់អ្នក មានគ្រប់គ្រាន់ហើយឬ ។ បពិត្រព្រះអង្គដ៏ចម្រើន បាត្រ និងចីវររបស់ខ្ញុំព្រះអង្គ មិនទាន់មានគ្រប់គ្រាន់ទេ ។ ម្នាលភិក្ខុ ព្រះតថាគតទាំងឡាយ មិនដែលឲ្យឧបសម្បទាដល់កុលបុត្រ ដែលមានបាត្រ និងចីវរមិនគ្រប់គ្រាន់ទេ ។

[ ១៧១ ] គ្រានោះឯង បុក្កុសាតិមានអាយុ ត្រេកអររីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ហើយធ្វើប្រទក្សិណាចៀសចេញទៅកាន់ទីស្វែងរកបាត្រ និងចីវរ ។ គ្រាកាលដែលបុក្កុសាតិមានអាយុ កំពុងត្រាច់ទៅកាន់ទីស្វែងរកបាត្រ និងចីវរ មេគោក៏មកបុះផ្តាច់ជីវិតទៅ ។ គ្រានោះឯង ភិក្ខុច្រើនរូប នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ទើបក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុទាំងនោះអង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលសួរព្រះមានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កុលបុត្រ

ឈ្មោះបុក្កុសាតិណា ដែលព្រះមានព្រះភាគ ទ្រង់ប្រដៅដោយឱវាទសង្ខេប បុក្កុសាតិកុលបុត្រនោះ ធ្វើមរណកាលទៅហើយ ចុះគតិ និងបរលោករបស់បុក្កុសាតិកុលបុត្រនោះ តើដូចម្តេច ។

[ ១៧២ ] ម្នាលភិក្ខុទាំងឡាយ បុក្កុសាតិកុលបុត្រ ជាបណ្ឌិតបានដល់នូវធម៌ដ៏សមគួរដល់ធម៌ មិនបាច់ញ៉ាំងតថាគតឲ្យនឿយព្រួយ ព្រោះធម៌ជាហេតុ ម្នាលភិក្ខុទាំងឡាយ បុក្កុសាតិកុលបុត្រជាឱបបាតិកៈ ព្រោះអស់ទៅនៃឱរម្ភាគិយសំយោជនៈទាំង ៥ ហើយបរិនិព្វានក្នុងលោកនោះតែម្តង មានសភាពមិនបានត្រឡប់ចាកលោកនោះមកវិញឡើយ ។ លុះព្រះមានព្រះភាគទ្រង់ត្រាស់សូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

ធាតុវិតក្កសូត្រជាគម្រប់ ១០ ចប់

# អដ្ឋកថា

## ធាតុវិភង្គសូត្រ

[ ១៤៨ ] ធាតុវិភង្គសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **ចារិកំ** បានដល់ ចារិកទៅដោយរួសរាន់ ។ បទថា **សចេ តេ ភគ្គវ អគរុ** សេចក្ដីថា បើមិនជាការបង្អៀតបង្អល់ចិត្ត គឺមិនផាសុកណានីមួយដល់អ្នក ។ បទថា **សចេ សោ អនុជានាតិ** សេចក្ដីថា បានឮថា ភគ្គវៈមានការគិតយ៉ាងនេះថា ធម្មតាបព្វជិតទាំងឡាយ រមែងមានអធ្យាស្រ័យផ្សេងគ្នា ខ្លះមានគណៈជាទីត្រេកអរ ខ្លះត្រេកអរតែម្នាក់ឯង បើបុគ្គលនោះត្រេកអរតែម្នាក់ឯង នឹងពោលថា អ្នកមានអាយុ អ្នកកុំចូលមក ខ្ញុំបានសាលាហើយ បើបុគ្គលនេះត្រេកអរក្នុងការនៅម្នាក់ឯង ក៏នឹងពោលថា អាវុសោ អ្នកចូរចេញទៅ ខ្ញុំបានសាលាហើយ បើយ៉ាងនេះ អញនឹងជាហេតុ ឲ្យអ្នកទាំង ២ ធ្វើការឈ្លោះគ្នា ធម្មតាវត្ថុដែលឲ្យហើយ ក៏គួរឲ្យហើយនោះឯង វត្ថុដែលធ្វើហើយ ក៏គួរធ្វើហើយដែរ ។ ព្រោះដូច្នោះទើបពោលយ៉ាងនេះ ។

[ ១៤៨ ] បទថា **កុលបុត្តោ** បានដល់ កុលបុត្រដោយជាតិខ្លះ កុលបុត្រដោយមារយាទខ្លះ ។ បទថា **វាសូបគតោ** បានដល់ ចូលទៅហើយ ។ សួរថា កុលបុត្រនោះមកពីណា ឆ្លើយថា មកអំពីនគរតក្កសិលា ។ ក្នុងរឿងនោះ មានតំណាលដោយលំដាប់ ដូច្នេះ ។

បានឮថា កាលព្រះបាទពិម្ពិសារសោយរាជសម្បត្តិក្នុងនគររាជគ្រឹះ ក្នុង

មជ្ឈិមប្រទេស ព្រះបាទបុក្កុសាតិសោយរាជសម្បត្តិក្នុងនគរតក្កសិលា ក្នុងបច្ចន្តប្រទេស ។ កាលនោះ ឈ្មួញទាំងឡាយ ក៏នាំទំនិញអំពីនគរតក្កសិលាមកកាន់នគររាជគ្រឹះ នាំបណ្ណាការទៅថ្វាយដល់ព្រះរាជា ។ ព្រះរាជាត្រាស់សួរឈ្មួញទាំងនោះ ដែលឈរថ្វាយបង្គំថា ពួកអ្នកនៅឯណា ។ ពួកឈ្មួញឆ្លើយថា ករុណាថ្លៃវិសេស នៅក្នុងនគរតក្កសិលា ។ លំដាប់នោះ ព្រះរាជាត្រាស់សួរដល់ការក្សេម និងការដែលរកកិក្ខាបានងាយជាដើមរបស់ជនបទ និងប្រវត្តិនៃព្រះនគរជាមួយឈ្មួញទាំងនោះ ហើយត្រាស់សួរថា ព្រះរាជារបស់ពួកអ្នកឈ្មោះអ្វី ពួកឈ្មួញឆ្លើយថា ព្រះនាមបុក្កុសាតិ ព្រះអង្គ ។ ព្រះរាជារបស់អ្នកតាំងនៅក្នុងធម៌ដែរឬ ឈ្មួញឆ្លើយថា យ៉ាងនោះឯងព្រះអង្គ ទ្រង់តាំងនៅក្នុងធម៌ ទ្រង់សង្គ្រោះជនដោយសង្គហវត្ថុ៤ ទ្រង់តាំងនៅក្នុងឋានៈមាតាបិតារបស់លោក ទ្រង់ញ៉ាំងជនឲ្យដូចជាទារកដេកលើភ្លៅ ឲ្យត្រេកអរ ។ ព្រះរាជាត្រាស់សួរថា ព្រះរាជារបស់អ្នកមានវ័យប៉ុនណា ។ លំដាប់នោះ ពួកឈ្មួញទូលប្រាប់វ័យដល់ព្រះរាជានោះ ។ ទ្រង់មានវ័យប៉ុននឹងព្រះបាទពិម្ពិសារគ្រានោះ ព្រះរាជាត្រាស់នឹងឈ្មួញទាំងនោះថា អើ បាទាំងឡាយ ព្រះរាជារបស់ពួកអ្នកតាំងនៅក្នុងធម៌ ទ្រង់មានវ័យស្មើជាមួយខ្ញុំ ពួកអ្នកអាចធ្វើព្រះរាជារបស់ពួកអ្នក ឲ្យជាសម្លាញ់ជាមួយខ្ញុំបានដែរឬ ។ ពួកឈ្មួញឆ្លើយថា អាច ក្រាបទូល ។ ព្រះរាជាទ្រង់លះការស៊ីដល់ឈ្មួញទាំងនោះ ទ្រង់ព្រះរាជទានផ្ទះ ហើយត្រាស់ថា ពួកអ្នកបំណងក្នុងពេលលក់ដូរត្រឡប់ ពួកអ្នកគប្បីជួបខ្ញុំ ហើយសឹមត្រឡប់ទៅដូច្នេះ ។ ឈ្មួញទាំងនោះធ្វើយ៉ាងនោះ ហើយចូល

ទៅគាល់ព្រះរាជាក្នុងវេលាត្រឡប់ទៅវិញ ។ ព្រះរាជាត្រាស់ថា ពួកអ្នកចូរត្រឡប់ ពួកអ្នកចូរទូលសួរដល់ការមិនមានរោគរឿយៗ តាមពាក្យរបស់ខ្ញុំ ហើយទូលថា ព្រះរាជាទ្រង់ព្រះបំណងធ្វើជាមិត្តភាពជាមួយព្រះអង្គ ។ ឈ្មួញទាំងនោះទទួលព្រះរាជឱង្ការ ហើយទៅប្រមូលទំនិញ បរិភោគអាហារព្រឹកហើយ ចូលទៅថ្វាយបង្គំព្រះរាជា ។ ព្រះរាជាត្រាស់សួរថា នែបា ពួកអ្នកទៅណា មិនឃើញច្រើនថ្ងៃហើយ ។ ពួកឈ្មួញទូលរឿងរ៉ាវទាំងអស់ ដល់ព្រះរាជា ។ ព្រះរាជាទ្រង់មានព្រះហឫទ័យត្រេកអរ ត្រាស់ថា នែបាទាំង-ឡាយ ជាការល្អសម្រាប់ខ្ញុំ ដែលព្រះរាជាក្នុងមជ្ឈិមប្រទេស បានសម្លាញ់ហើយ ព្រោះអាស្រ័យពួកអ្នក ។

ក្នុងវេលាតមក ឈ្មួញទាំងឡាយ នៅក្នុងនគររាជគ្រឹះ ក៏ទៅនគរតក្កសិលា ។ ព្រះបាទបុក្កុសាតិត្រាស់សួរឈ្មួញទាំងនោះ ដែលកាន់យកបណ្ណាការមកថា ពួកអ្នកមកអំពីណា ។ ព្រះរាជាទ្រង់ស្តាប់ថា មកអំពីនគររាជគ្រឹះទើបត្រាស់ថា ពួកអ្នកមកអំពីនគររបស់សម្លាញ់ខ្ញុំ ។ ពួកឈ្មួញឆ្លើយថា យ៉ាងនោះឯងព្រះអង្គ ព្រះរាជាត្រាស់សួរដល់ការមិនមានរោគថា សម្លាញ់របស់ខ្ញុំមិនមានរោគទេឬ ។ ហើយទ្រង់ឲ្យវាយស្គរប្រកាសថា ចាប់អំពីថ្ងៃនេះ ពួកឈ្មួញថ្មើរជើង ឬឈ្មួញរទេះណាមកអំពីនគររបស់សម្លាញ់ខ្ញុំ ចាប់តាំងអំពីកាលដែលឈ្មួញទាំងពួងចូលមកកាន់ព្រំដែនរបស់ខ្ញុំ ចូរឲ្យផ្ទះជាទីស្នាក់អាស្រ័យ និងស្បៀងអំពីព្រះឃ្លាំង ចូរកុំយកកាសុី កុំធ្វើអន្តរាយណាមួយដល់ឈ្មួញទាំងនោះ ដូច្នេះ ។ ព្រះបាទពិម្ពិសារក៏ទ្រង់ឲ្យវាយស្គរប្រកាស

ដូច្នេះដូចគ្នា ក្នុងនគររបស់ព្រះអង្គ ។ គ្រានោះ ព្រះបាទពិម្ពិសារ ទ្រង់បាន បញ្ជូនបណ្ណាការដល់ព្រះបាទបុក្កុសាតិថា រតនៈទាំងឡាយ មានកែវមណី និង កែវមុក្តាជាដើម រមែងកើតក្នុងបច្ចន្តប្រទេស រតនៈណាដែលគួរឃើញ ឬគួរ ស្តាប់កើតឡើងក្នុងរាជសម្បត្តិរបស់សម្លាញ់នៃខ្ញុំ សូម្បីសម្លាញ់របស់ខ្ញុំ ទ្រង់ កុំកំណាញ់ក្នុងរតនៈនោះ ។ ឯព្រះបាទបុក្កុសាតិ ទ្រង់បញ្ជូនព្រះរាជបណ្ណាការ តបទៅថា ធម្មតាមជ្ឈិមប្រទេស ជាមហាជនបទ រតនៈបែបនេះ រមែងកើត ក្នុងមហាជនបទនោះ សូមសម្លាញ់របស់ខ្ញុំ ទ្រង់កុំកំណាញ់ក្នុងរតនៈនោះ កាល កន្លងទៅយ៉ាងនេះ ព្រះរាជាទាំងនោះសូម្បីមិនឃើញគ្នា ក៏ជាមិត្រជិតស្និទ្ធ ។ កាលព្រះរាជាទាំង ២ អង្គនោះទ្រង់ត្រាស់យ៉ាងនេះ បណ្ណាការរមែងកើតដល់ ព្រះបាទបក្កុសាតិមុន ។ បានឮថា ព្រះរាជាទ្រង់បានសំពត់កម្ពល ៨ ផ្ទាំង ដែលកាត់ថ្លៃមិនបានមាន ៥ ពណ៌ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា សំពត់កម្ពល ទាំងនេះល្អក្រៃលែង អញនឹងផ្ញើឲ្យសម្លាញ់របស់អញ ទ្រង់បញ្ជូនអមាត្យ ទាំងឡាយ ដោយព្រះតម្រាស់ថា ពួកអ្នកចូរធ្វើប្រអប់រឹង ៨ ប្រអប់ ប៉ុនដុំ ល័ក្ត ដាក់សំពត់កម្ពលទាំងនោះ ក្នុងប្រអប់ទាំងនោះ ឲ្យប្រថាប់សំពត់ស មួយពាន់ ដាក់ក្នុងហិបមួយពាន់ ប្រថាប់ដោយត្រាព្រះរាជលញ្ចករ ថ្វាយ ដល់សម្លាញ់របស់ខ្ញុំ និងបានព្រះរាជទានព្រះរាជសាសន៍ថា បណ្ណាការនេះ ខ្ញុំដែលអមាត្យជាដើមចោមរោមហើយ ឃើញក្នុងកណ្តាលព្រះនគរ ។ អមាត្យ ទាំងនោះ ទៅទូលដល់ព្រះបាទពិម្ពិសារ ។

ព្រះបាទពិម្ពិសារទ្រង់ស្តាប់ព្រះរាជសាសន៍ ទ្រង់ឲ្យវាយស្គរប្រកាសថា

ជនទាំងឡាយ មានអមាត្យជាដើម ចូរប្រជុំ ដូច្នេះ អមាត្យជាដើមហែហម ហើយ ក្នុងកណ្តាលព្រះនគរ ទ្រង់មានស្វេតច្ឆត្រ ប្រថាប់គង់លើរាជបល្ល័ង្ក ដ៏ប្រសើរ ទ្រង់ទម្លាយស្នាមប្រថាប់ បើកសំពត់ចេញ បើកប្រអប់ ស្រាយគ្រឿងខាងក្នុង ទ្រង់ឃើញដុំល័ក្ត ទ្រង់មានព្រះតម្រិះថា ព្រះបាទបុក្កុសាតិ សម្លាញ់របស់អញ គង់សម្គាល់ថា អញមានព្រះរាជហឫទ័យរុងរឿង ទើបទ្រង់បញ្ជូនព្រះរាជបណ្ណាការនេះមក ដូច្នេះ ។ ទ្រង់ចាប់ដុំមួយ ហើយវាយដោយព្រះហស្ត ពិចារណាមើល ក៏មិនដឹងថា ខាងក្នុងមានគ្រឿងសំពត់ ។ លំដាប់នោះ ទ្រង់វាយដុំល័ក្តនោះត្រង់ជើងព្រះរាជបល្ល័ង្ក ។ លំដាប់នោះ ល័ក្តក៏បែកចេញ ។ ព្រះអង្គទ្រង់បើកដោយព្រះនខា ទ្រង់ឃើញកម្ពលរតនៈនៅខាងក្នុង ទ្រង់ឲ្យបើកប្រអប់ទាំងឡាយក្រៅអំពីនេះ ក៏ឃើញសំពត់កម្ពលទាំងអស់ ។ លំដាប់នោះ ទ្រង់ឲ្យលាសំពត់ទាំងនោះ សំពត់កម្ពលទាំងនោះ ដល់ព្រមដោយពណ៌ ដល់ព្រមដោយសម្ផស្ស បណ្តោយ ១៦ ហត្ថ ទទឹង ៨ ហត្ថ ។ មហាជនទាំងឡាយឃើញហើយ ផ្ទាត់ម្រាមដៃ ធ្វើការលើកសំពត់តូចៗ ឡើង នាំគ្នាត្រេកអរថា ព្រះបាទបុក្កុសាតិ សម្លាញ់កំបាំងមុខនៃព្រះរាជារបស់ពួកយើង ទ្រង់មិនធ្លាប់ឃើញគ្នាសោះ គង់បញ្ជូនព្រះរាជបណ្ណាការបែបនេះ សមគួរពិតហ្ន៎ ដើម្បីធ្វើព្រះរាជាបែបនេះឲ្យជាមិត្រ ។ ព្រះរាជាទ្រង់ឲ្យវាយតម្លៃសំពត់កម្ពលតែមួយផ្ទាំង ។ សំពត់កម្ពលគ្រប់ផ្ទាំង មានតម្លៃកាត់ថ្លៃមិនបាន ។ ក្នុងសំពត់កម្ពល ៨ ផ្ទាំងនោះ ទ្រង់ថ្វាយ ៤ ផ្ទាំងដល់ព្រះសម្មាសម្ពុទ្ធ ។ ទ្រង់ទុក ៤ ផ្ទាំងក្នុងព្រះរាជវាំងរបស់ព្រះអង្គ ។ បន្ទាប់អំពី

នោះ ទ្រង់ព្រះរាជតម្រិះថា ការដែលអញបញ្ជូនទៅឯក្រោយ ក៏គួរបញ្ជូនបណ្ណាការល្អជាងបណ្ណាការដែលបញ្ជូនមកមុន ឯសម្លាញ់អញ បានបញ្ជូនបណ្ណាការដែលមានតម្លៃកាត់ថ្លៃមិនបានដល់អញ អញនឹងបញ្ជូនអ្វីល្អហ្ន៎ ។ ក្នុងក្រុងរាជគ្រឹះ មិនមានវត្ថុដែលល្អជាងនោះឬ ។ មិនមែនទេ ព្រះរាជាទ្រង់មានបុណ្យច្រើន មួយប្រការទៀត ចាប់តាំងអំពីកាលដែលព្រះអង្គទ្រង់ជាព្រះសោតាបន្នហើយ វៀរចាកព្រះរតនត្រ័យចេញ មិនមានវត្ថុណាដទៃដែលឈ្មោះថា អាចដើម្បីញុំាងព្រះសោមនស្សឲ្យកើតឡើងបាន ទើបព្រះអង្គទ្រង់ប្រារព្ធដើម្បីជ្រើសរើសរតនៈ ។

ធម្មតារតនៈមាន ២ យ៉ាង គឺមានវិញ្ញាណ និងមិនមានវិញ្ញាណ ក្នុងរតនៈ ២ យ៉ាងនោះ រតនៈដែលមិនមានវិញ្ញាណ បានដល់ មាស និងប្រាក់ជាដើម ដែលមានវិញ្ញាណ បានដល់ វត្ថុដែលទាក់ទងនឹងឥន្ទ្រិយ ។ រតនៈដែលមិនមានវិញ្ញាណ ជាគ្រឿងប្រើប្រាស់ ដោយអំណាចនៃគ្រឿងប្រដាប់ជាដើមនៃរតនៈដែលមានវិញ្ញាណនោះឯង ។ ក្នុងរតនៈ ២ យ៉ាងនេះ រតនៈមានវិញ្ញាណប្រសើរបំផុត ។ រតនៈមានវិញ្ញាណមាន ២ យ៉ាង គឺតិរច្ឆានរតនៈ និងមនុស្សរតនៈ ។ ក្នុងរតនៈ ២ យ៉ាងនោះ តិរច្ឆានរតនៈ បានដល់ដំរីកែវ និងសេះកែវ ។ តិរច្ឆានរតនៈនោះ កើតឡើងដើម្បីជាគ្រឿងប្រើប្រាស់របស់មនុស្សទាំងឡាយនោះឯង ។ ក្នុងរតនៈ ២ យ៉ាងនោះ មនុស្សរតនៈប្រសើរបំផុត ដោយប្រការដូច្នេះ ។ មនុស្សរតនៈមាន ២ យ៉ាង គឺឥត្ថីរតនៈ និងបុរិសរតនៈ ។ ក្នុងរតនៈ ២ យ៉ាងនោះ ឥត្ថីរតនៈដែលកើតដល់ស្ដេច

ចក្រពត្តិ រមែងជាឧបភោគរបស់បុរសនោះឯង ។ ក្នុងរតនៈ ២ យ៉ាងនេះ បុរិសរតនៈ ប្រសើរបំផុត ដោយប្រការដូច្នេះ ។ សូម្បីបុរិសរតនៈមាន ២ យ៉ាង គឺអាគារិករតនៈ ១ អនាគារិករតនៈ ១ ។ ក្នុងអាគារិករតនៈនោះ ស្តេចចក្រពត្តិទ្រង់រមែងនមស្ការសាមណេរដែលបួសក្នុងថ្ងៃនេះ ដោយបញ្ចង្គ-ប្រតិស្ឋាន ក្នុងរតនៈ ២ យ៉ាងនេះ អនាគារិករតនៈប៉ុណ្ណោះ ប្រសើរបំផុត ។ សូម្បីអនាគារិករតនៈក៏មាន ២ យ៉ាង គឺសេក្ខរតនៈ ១ អសេក្ខរតនៈ ១ ។ ក្នុងអនាគារិករតនៈ ២ យ៉ាងនោះ ព្រះសេក្ខៈរាប់សែន រមែងមិនដល់ចំណែកមួយនៃព្រះអសេក្ខៈ ។ ក្នុងរតនៈ ២ យ៉ាងនេះ អសេក្ខរតនៈប៉ុណ្ណោះប្រសើរបំផុត ។ អសេក្ខរតនៈនោះក៏មាន ២ យ៉ាង គឺពុទ្ធរតនៈ ១ សាវករតនៈ ១ ។ ក្នុងអសេក្ខរតនៈនោះ សាវករតនៈរាប់សែន ក៏មិនដល់ចំណែកមួយនៃព្រះ-ពុទ្ធរតនៈ ។ ក្នុងរតនៈ ២ យ៉ាងនេះ ពុទ្ធរតនៈប៉ុណ្ណោះប្រសើរបំផុត ដោយប្រការដូច្នេះ ។ សូម្បីពុទ្ធរតនៈក៏មាន ២ យ៉ាង គឺបច្ចេកពុទ្ធរតនៈ ១ សព្វញ្ញុពុទ្ធរតនៈ ១ ។ ក្នុងពុទ្ធរតនៈនោះ បច្ចេកពុទ្ធរតនៈរាប់សែន ក៏មិនដល់ចំណែកមួយនៃសព្វញ្ញុពុទ្ធរតនៈ ។ ក្នុងរតនៈ ២ យ៉ាងនេះ សព្វញ្ញុ-ពុទ្ធរតនៈប៉ុណ្ណោះប្រសើរបំផុត ។ ឈ្មោះថា រតនៈ ដែលស្មើដោយពុទ្ធរតនៈ រមែងមិនមានក្នុងលោក ព្រមទាំងទេវលោក ។ ព្រោះដូច្នោះ ទើបទ្រង់ព្រះរាជតម្រិះថា អញនឹងបញ្ជូនរតនៈ ដែលមិនមានវត្ថុណាមួយស្មើប៉ុណ្ណោះដល់សម្លាញ់របស់អញ ទើបត្រាស់សួរពួកឈ្មួញអ្នកនគរតក្កសិលាថា នែបាទាំង-ឡាយ រតនៈ ៣ យ៉ាង គឺពុទ្ធរតនៈ ធម្មរតនៈ សង្ឃរតនៈ ប្រាកដក្នុងជនបទ

របស់ពួកអ្នកដែរឬទេ ។ ពួកឈ្មួញឆ្លើយថា បពិត្រមហារាជ សូម្បីតែសំឡេង ក៏មិនមានក្នុងជនបទនោះ ការឃើញនឹងមានអំពីណា ព្រះអង្គ ។ ព្រះរាជា ទ្រង់ត្រេកអរ ទ្រង់ព្រះរាជតម្រិះថា អញអាចបញ្ជូនព្រះសម្មាសម្ពុទ្ធទៅកាន់ទី លំនៅរបស់សម្លាញ់អញ ដើម្បីប្រយោជន៍ការសង្គ្រោះជន តែព្រះពុទ្ធទាំង- ឡាយ ទ្រង់មិនទទួលអរុណក្នុងបច្ចន្តជនបទទាំងឡាយឡើយ ព្រោះដូច្នោះ ព្រះសាស្តាទ្រង់មិនអាចទៅ គប្បីបញ្ជូនព្រះមហាសាវក មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម តែអញបានដំណឹងថា ព្រះថេរៈទាំងឡាយនៅក្នុង បច្ចន្តជនបទ សមគួរដើម្បីបញ្ជូនមនុស្សទាំងឡាយ ទៅនាំព្រះថេរៈទាំងនោះ មកកាន់ទីជិតខ្លួន ហើយទំនុកបម្រុង ព្រោះដូច្នោះ ព្រះថេរៈទាំងឡាយក៏មិន អាចទៅ កាលបញ្ជូនរាជសាសន៍ទៅហើយ ដោយបណ្ណាការណា ព្រះសាស្តា និងសាវកទាំងឡាយ ក៏ឈ្មោះថា ទៅហើយដូចគ្នា អញនឹងបញ្ជូនរាជសាសន៍ ដោយបណ្ណាការនោះ ដូច្នេះ ទ្រង់ព្រះរាជតម្រិះទៀតថា អញនឹងឲ្យគេធ្វើបន្ទះ មាស បណ្តោយប្រមាណ ៤ ហត្ថ ទទឹងប្រមាណ ១ ចំអាម ក្រាស់ល្មម សមគួរ មិនស្រាលពេក មិនធ្ងន់ពេក មិនក្រាស់ពេក ហើយនឹងចារអក្ខរៈ ចុះក្នុងបន្ទះមាសនោះក្នុងថ្ងៃនេះ ទ្រង់ស្រពព្រះកក្ត្រតាំងអំពីព្រលឹម ទ្រង់ អធិដ្ឋានអង្គឧបោសថ ទ្រង់សោយព្រះក្រយាហារព្រឹក ដោះគ្រឿងព្រះសុគន្ធ- មាលា និងអាភរណៈចេញ ទ្រង់កាន់យកជាតិហិង្គុលដោយផ្តិលមាស ទ្រង់ បើកទ្វារទាំងឡាយ តាំងអំពីជាន់ក្រោម ស្តេចឡើងលើប្រាសាទ ទ្រង់បើក បង្អួចទិសខាងកើត ប្រថាប់លើផ្ទៃអាកាស ទ្រង់ចារព្រះអក្ខរៈចុះក្នុងបន្ទះមាស

ទ្រង់ចារព្រះពុទ្ធគុណ ដោយឯកទេសថា **ឥធ តថាគតោ លោកេ ឧប្បន្នោ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ** ព្រះពុទ្ធកើតឡើងហើយក្នុងលោក ទ្រង់ព្រះនាមថា **អរហំ** ទ្រង់ដល់ព្រមដោយវិជ្ជា និងចរណៈ ទ្រង់យាងទៅល្អ ទ្រង់ដឹងច្បាស់នូវលោក ទ្រង់ជាសារថី ទូន្មានមនុស្សដ៏កំពូល ជាព្រះសាស្តានៃទេវតា និងមនុស្សទាំងឡាយ ទ្រង់ភ្ញាក់ហើយ ទ្រង់ចែកនូវធម៌ ដូច្នេះ ។

បន្ទាប់អំពីនោះ ទ្រង់ចារថា ព្រះពុទ្ធទ្រង់បំពេញបារមី ១០ យ៉ាងនេះ ទ្រង់ចុតិចាកតុសិត ទ្រង់បដិសន្ធិក្នុងគភ៌មាតា ការបើកលោកមានហើយយ៉ាងនេះ កាលទ្រង់នៅក្នុងគភ៌ព្រះមាតា នេះបានមានហើយ កាលទ្រង់ប្រសូតគ្រប់គ្រងផ្ទះ នេះបានមានហើយ កាលទ្រង់ចេញមហាភិនេស្រ្កមណ៍យ៉ាងនេះ ទ្រង់ផ្តើមតាំងមហាបធានយ៉ាងនេះ ទ្រង់បំពេញទុក្ករកិរិយាយ៉ាងនេះ ទ្រង់ឡើងកាន់មណ្ឌលពោធិព្រឹក្ស ប្រថាប់គង់លើអបរាជិតបល្ល័ង្កហើយ ទ្រង់ចាក់ធ្លុះសព្វញ្ញុតញ្ញាណ កាលទ្រង់ចាក់ធ្លុះសព្វញ្ញុតញ្ញាណ មានការបើកលោកយ៉ាងនេះ រតនៈដទៃបែបនេះ មិនមានក្នុងលោក ព្រមទាំងទេវលោក ដូច្នេះ ។

ទ្រង់ចារព្រះពុទ្ធគុណទាំងឡាយ ដោយឯកទេសយ៉ាងនេះថា ទ្រព្យជាទីគាប់ចិត្តណាមួយក្នុងលោកនេះ ឬក្នុងលោកដទៃ រតនវត្ថុដ៏ឧត្តមណា ក្នុងស្ថានសួគ៌ក្តី ( ទ្រព្យ និងរតនវត្ថុទាំងនោះ ) ស្មើដោយព្រះតថាគតមិនមានឡើយ រតនៈ គឺព្រះពុទ្ធនេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ

សូមសួស្តីកើតមាន ដូច្នេះ ។

កាលទ្រង់សរសើរព្រះធម្មរតនៈទី ២ ថា **ស្វាក្ខាតោ ភគវតា ធម្មោ ។បេ។ បច្ចត្តំ វេទិតព្វោ វិញ្ញូហីតិ** ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ ។បេ។ ដែលវិញ្ញូជនទាំងឡាយគប្បីដឹងចំពោះខ្លួន ដូច្នេះហើយ ទ្រង់ចារឹកពោធិបក្ខិយធម៌ ៣៧ ប្រការដោយឯកទេសថា សតិប្បដ្ឋាន ៤ ។បេ។ មគ្គមានអង្គ ៨ ដ៏ប្រសើរ ឈ្មោះថា ព្រះធម៌ដែលព្រះសាស្តា ទ្រង់សម្តែងហើយ បែបនេះឯង យ៉ាងនេះឯង ដូច្នេះហើយ ទ្រង់ចារឹកធម្មគុណទាំងឡាយដោយឯកទេសថា

ព្រះពុទ្ធដ៏ប្រសើរ ទ្រង់សរសើរនូវសមាធិណា ជាសមាធិស្អាត បណ្ឌិតទាំងឡាយ ពោលនូវសមាធិណា ថាជាធម៌ឲ្យនូវផលដោយលំដាប់ សមាធិដទៃ ស្មើដោយសមាធិនោះ មិនមានឡើយ រតនៈ គឺព្រះធម៌នេះឯង ជារតនៈដ៏ឧត្តម ។ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ដូច្នេះ ។

បន្ទាប់អំពីនោះ កាលទ្រង់សរសើរព្រះសង្ឃរតនៈទី ៣ ថា **សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ ។បេ។ បុញ្ញក្ខេត្តំ លោកស្សាតិ** ព្រះសង្ឃជាសាវ័ករបស់ព្រះមានព្រះភាគ ជាអ្នកបដិបត្តិល្អ ។បេ។ ជាស្រែបុណ្យនៃលោក ដូច្នេះ ទ្រង់ចារឹកចូឡសីល មជ្ឈិមសីល និងមហាសីល ដោយឯកទេសថា ធម្មតាកុលបុត្រទាំងឡាយ ស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ ចេញបួសយ៉ាងនេះ ពួកខ្លះលះស្វេតច្ឆត្របួស ពួកខ្លះលះភាពជាឧបរាជបួស ពួកខ្លះលះតំណែងទាំងឡាយ មានតំណែងសេនាបតីជាដើមបួស កាលបួស

ហើយ បំពេញបដិបត្តិនេះ ទ្រង់ចារឹកការសង្រួមក្នុងទ្វារ ៦ សតិសម្បជញ្ញៈ ការត្រេកអរក្នុងការចម្រើនចតុប្បច្ចយសន្តោសៈ ការលះនីវរណៈ បរិកម្មជ្ឈាន និងអភិញ្ញា កម្មដ្ឋាន ៣៨ ប្រការ រហូតដល់ការអស់ទៅនូវអាសវៈ ដោយឯកទេស ទ្រង់ចារឹកអានាបានស្សតិកម្មដ្ឋាន ១៦ ប្រការដោយពិស្តារ ហើយទ្រង់ចារឹកព្រះសង្ឃគុណទាំងឡាយដោយឯកទេសថា ឈ្មោះថា ព្រះសង្ឃ-សាវកនៃព្រះសាស្តា ដល់ព្រមដោយគុណទាំងឡាយ បែបនេះផង បែបនេះផង ៗ

បុគ្គលទាំងឡាយ ៨ ពួកដែលសប្បុរសទាំងឡាយសរសើរហើយ បើរាប់ជាគូបាន ៤ គូ បុគ្គលទាំងឡាយនោះ ជាសាវករបស់ព្រះសុគត លោកគួរដល់ទក្ខិណាទាន ទានទាំងឡាយ ដែលបុគ្គលឲ្យហើយ ចំពោះបុគ្គលទាំង-ឡាយនោះ ជាទានមានផលច្រើន រតនៈ គឺព្រះសង្ឃនេះឯង ជារតនៈដ៏ឧត្តម ៗ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ដូច្នេះ ៗ

ទ្រង់ចារឹកថា សាសនារបស់ព្រះមានព្រះភាគត្រាស់ល្អហើយ ជាសាសនានាំសត្វចេញចាកទុក្ខ បើសម្លាញ់របស់ខ្ញុំអាចសោត សូមចេញព្រះផ្នួសចុះដូច្នេះ ៗ ទ្រង់រុំជុំមាសដោយសំពត់កម្ពលសាច់ម៉ដ្ឋ ទ្រង់ដាក់ក្នុងហិបដ៏រឹងទ្រង់ដាក់ហិបនោះក្នុងហិបមាស ទ្រង់ដាក់ហិបមាសក្នុងហិបប្រាក់ ទ្រង់ដាក់ហិបប្រាក់ក្នុងហិបកែវមណី ទ្រង់ដាក់ហិបកែវមណីក្នុងហិបកែវប្រពាល ទ្រង់ដាក់ហិបកែវប្រពាលក្នុងហិបកែវទទឹម ទ្រង់ដាក់ហិបកែវទទឹមក្នុងហិបកែវមក៌ត ទ្រង់ដាក់ហិបកែវមក៌តក្នុងហិបកែវផលិក ទ្រង់ដាក់ហិបកែវផលិកក្នុង

ហិបក្តុក ទ្រង់ដាក់ហិបក្តុកក្នុងហិបរតនៈគ្រប់យ៉ាង ទ្រង់ដាក់ហិបរតនៈគ្រប់យ៉ាងក្នុងហិបកន្ទេលផែន ទ្រង់ដាក់ហិបកន្ទេលផែនក្នុងប្រអប់រឹង ។

ទ្រង់ដាក់ប្រអប់រឹងក្នុងប្រអប់មាសទៀត ទ្រង់នាំទៅដោយន័យមុននោះឯង ទ្រង់ដាក់ប្រអប់ដែលធ្វើដោយរតនៈគ្រប់យ៉ាង ក្នុងប្រអប់ដែលធ្វើដោយកន្ទេលផែន ។ បន្ទាប់អំពីនោះ ទ្រង់ដាក់ប្រអប់ដែលធ្វើដោយកន្ទេលផែនក្នុងហិបដែលធ្វើដោយឈើខ្លឹម ទ្រង់នាំទៅដោយន័យមុននោះឯងទៀត ទ្រង់ដាក់ហិបដែលធ្វើដោយរតនៈគ្រប់យ៉ាង ក្នុងហិបដែលធ្វើកន្ទេលផែន ខាងក្រៅទ្រង់រុំដោយសំពត់ ប្រថាប់ត្រាព្រះរាជលញ្ចករ ត្រាស់បញ្ជាអមាត្យទាំងឡាយថា អ្នកទាំងឡាយ ចូរធ្វើផ្លូវក្នុងស្ថានទីដែលជាអាណាចក្ររបស់ខ្ញុំ ធ្វើឲ្យធំទូលាយ ៨ ឧសភៈ ស្ថានទី ៤ ឧសភៈត្រូវឲ្យស្អាតជានិច្ច អ្នកទាំងឡាយចូរតាក់តែងក្នុងទី ៤ ឧសភៈត្រង់កណ្តាល ដោយអានុភាពរបស់ព្រះរាជា ។ បន្ទាប់អំពីនោះ ទ្រង់បញ្ជូនទូតដោយរួសរាន់ដល់អ្នករាជការខាងក្នុងថា ចូរប្រដាប់ដំរីមង្គល រៀបចំបល្ល័ង្កលើដំរីនោះ លើកស្វេតច្ឆត្រ ធ្វើផ្លូវក្នុងព្រះនគរឲ្យស្អាត ប្រដាប់ឲ្យល្អ ដោយទង់ជ្វាលាដ៏ស្រស់ស្អាត លើកដើមចេក តាំងក្អមទឹកដែលពេញ គ្រឿងក្រអូប ធូបក្រអូប និងផ្កាជាដើម ចូរធ្វើការបូជាបែបនេះ ក្នុងស្ថានទីគ្រប់គ្រងរៀងៗ ខ្លួន ដូច្នេះ ។ ឯព្រះអង្គទ្រង់តាក់តែងគ្រឿងអលង្ការគ្រប់យ៉ាង មានកងកម្លាំង មួយអន្ទើនឹងតូរ្យតន្ត្រីគ្រប់ប្រភេទ ទ្រង់ព្រះរាជតម្រិះថា អញនឹងជូនបណ្ណាការទៅ ដូច្នេះ យាងទៅរហូតផុតព្រះរាជអាណាខេត្តរបស់ព្រះអង្គហើយ បានប្រទានព្រះរាជសាសន៍

ជាគ្រឿងសម្គាល់ដល់អមាត្យ ហើយត្រាស់ថា នែបា ព្រះបាទបុក្កុសាតិ ជាសម្លាញ់របស់ខ្ញុំ កាលទ្រង់ទទួលបណ្ណាការនេះ កុំទទួលត្រង់កណ្តាលជំណាក់ពួកស្រីស្នំ ចូរយាងឡើងប្រាសាទ ហើយទទួលចុះ ។ កាលព្រះរាជទានព្រះរាជសាសន៍នេះហើយ ទ្រង់ព្រះតម្រិះថា ព្រះសាស្តាទ្រង់យាងទៅបច្ចន្តប្រទេស ហើយព្រះរាជានមស្ការដោយបញ្ចង្គប្រតិដ្ឋាន ហើយយាងត្រឡប់ ។ ឯអ្នករាជការខាងក្នុងទាំងឡាយ តាក់តែងផ្លូវដោយទំនងនោះឯង នាំទៅនូវព្រះបណ្ណាការ ។

ចំណែកព្រះបាទបុក្កុសាតិ ទ្រង់តាក់តែងផ្លូវដោយទំនងនោះ តាំងអំពីរដ្ឋសីមារបស់ព្រះអង្គមក ទ្រង់ឲ្យប្រដាប់តាក់តែងព្រះនគរ ទ្រង់បានធ្វើការទទួលព្រះរាជបណ្ណាការ ។ ព្រះរាជបណ្ណាការកាលដល់នគរតក្កសិលា បានដល់ក្នុងថ្ងៃឧបោសថ ។ ឯអមាត្យដែលទទួលព្រះរាជបណ្ណាការ ទៅទូលប្រាប់ព្រះរាជសាសន៍ដែលពោលដល់ព្រះរាជា ។ ព្រះរាជាទ្រង់សណ្តាប់ព្រះរាជសាសន៍នោះហើយ ទ្រង់ពិចារណាកិច្ចដែលគួរធ្វើដល់អមាត្យទាំងឡាយដែលមកជាមួយព្រះរាជបណ្ណាការ យាងឡើងកាន់ប្រាសាទ ហើយត្រាស់ថា បុគ្គលណាម្នាក់ កុំចូលមកក្នុងទីនេះ ទ្រង់ឲ្យធ្វើការរក្សាត្រង់ទ្វារ ទ្រង់បើកព្រះសីហបញ្ជរ ទ្រង់ដាក់ព្រះរាជបណ្ណាការលើទីបន្ទំខ្ពស់ ចំណែកព្រះអង្គប្រថាប់គង់លើអាសនៈទាប ទ្រង់ទម្លាយស្នាមប្រថាប់ ទ្រង់ដោះគ្រឿងខ្ចប់ ទ្រង់បើកដោយលំដាប់ ចាប់តាំងអំពីហិបកន្ទេលផែង ទ្រង់ឃើញហិបដែលធ្វើដោយខ្លឹមចន្ទន៍ ទ្រង់ព្រះរាជតម្រិះថា ឈ្មោះថា មហាបរិវារនេះ នឹងមិន

មានដល់រតនៈដទៃ រតនៈដែលគួរស្តាប់បានកើតឡើងហើយក្នុងមជ្ឈិមប្រទេសពិត ។ លំដាប់នោះ ទ្រង់បើកហិបនោះហើយ ទ្រង់ទម្លាយស្នាមប្រថាប់ព្រះរាជលញ្ចនៈ ទ្រង់បើកសំពត់កម្ពលសាច់ម៉ដ្ឋទាំងសងខាង ទ្រង់ឃើញបន្ទះមាស ។ ព្រះអង្គទ្រង់លើកបន្ទះមាសនោះចេញ ទ្រង់ព្រះរាជតម្រិះថា អក្ខរៈទាំងឡាយគួរពេញចិត្តពិតហ្ន៎ មានក្បាលស្មើគ្នា មានរបៀបរៀបរយ មានជ្រុង ៤ ដូច្នេះ ទ្រង់ប្រារព្ធដើម្បីអានចាប់អំពីដើម ។ ព្រះសោមនស្សដ៏មានកម្លាំង បានកើតដល់ព្រះអង្គ ទ្រង់អានហើយអានទៀត នូវព្រះពុទ្ធគុណទាំងឡាយថា ព្រះតថាគតទ្រង់កើតឡើងហើយក្នុងលោក ។ ព្រះលោមា ៩ ម៉ឺន ៩ ពាន់រណ្តៅ ក៏មានចុងបះឡើង ។ ព្រះអង្គទ្រង់មិនជ្រាបដល់ភាពដែលព្រះអង្គប្រថាប់ឈរ ឬប្រថាប់អង្គុយ ។ លំដាប់នោះ ព្រះបីតិដ៏មានកម្លាំងក្រៃលែងបានកើតដល់ព្រះអង្គថា អញបានស្តាប់ព្រះសាសនាដែលរកបានដោយលំបាកនេះ ដោយសែនកោដិកប្ប ព្រោះអាស្រ័យសម្លាញ់ ។ ព្រះអង្គមិនអានតទៅទៀត ក៏ប្រថាប់គង់ ទម្រាំបីតិស្ងប់រម្ងាប់ ហើយទ្រង់ប្រារព្ធព្រះធម្មគុណទាំងឡាយតទៅថា ព្រះធម៌ ដែលព្រះមានព្រះភាគត្រាស់ល្អហើយ ដូច្នេះ ។ ព្រះអង្គក៏ទ្រង់មានព្រះបីតិយ៉ាងនោះ ក្នុងព្រះធម្មគុណនោះឯង ។ ព្រះអង្គប្រថាប់គង់ទៀត ទម្រាំស្ងប់កម្លាំងនៃបីតិ ទ្រង់ប្រារព្ធសង្ឃគុណទាំងឡាយតទៅថា ព្រះសង្ឃសាវកជាអ្នកបដិបត្តិល្អ ។ ក្នុងព្រះសង្ឃគុណនោះ ព្រះអង្គក៏ទ្រង់មានព្រះបីតិយ៉ាងនោះដូចគ្នា ។ លំដាប់នោះ ទ្រង់អានអានាបានស្សតិកម្មដ្ឋាន ក្នុងលំដាប់ចុងក្រោយ ទ្រង់ញុំាងចតុត្ថជ្ឈាន និង

បញ្ចមជ្ឈានឲ្យកើតឡើង ។ ព្រះអង្គទ្រង់ញុំាងវេលាឲ្យកន្លងទៅដោយឈាន-សុខនោះឯង ។ បុគ្គលដទៃមិនបានដើម្បីឃើញព្រះអង្គ ។ មហាតលិកប្រចាំព្រះអង្គម្នាក់ប៉ុណ្ណោះ ចូលទៅបាន ។ ទ្រង់ញុំាងកាលប្រមាណកន្លះខែឲ្យកន្លងទៅ ដោយប្រការដូច្នេះ ។

អ្នកនគរទាំងឡាយ ប្រជុំគ្នាក្នុងលានរាជវាំង បានធ្វើការស្រែកឡើងថា ចាប់តាំងពីថ្ងៃដែលព្រះរាជា ទ្រង់ទទួលព្រះរាជបណ្ណាការហើយ មិនមានការទតព្រះនគរ ឬទតស្រីរបាំ មិនមានការព្រះរាជទានវិនិច្ឆ័យ ព្រះរាជាសូមទ្រង់រាជទានព្រះរាជបណ្ណាការដែលសម្លាញ់បញ្ជូនមកឲ្យ ដល់អ្នកទទួលទៅចុះ ធម្មតាព្រះរាជាទាំងឡាយ ទ្រង់រមែងព្យាយាមដើម្បីបោកបញ្ឆោតដោយគ្រឿងបណ្ណាការ ដណ្តើមយករាជសម្បត្តិរបស់ព្រះរាជាអង្គខ្លះដល់ខ្លួន ព្រះរាជារបស់ពួកយើងធ្វើអ្វីហ្ន៎ ដូច្នេះ ។ ព្រះរាជាទ្រង់ស្តាប់សំឡេងស្រែកហើយ ទ្រង់ព្រះតម្រិះថា អញតាំងទុកនូវរាជសម្បត្តិ ឬព្រះសាស្តាហ្ន៎ លំដាប់នោះព្រះអង្គទ្រង់មានព្រះរាជតម្រិះថា ប្រធាន និងមហាមាត្យរបស់ប្រធាន រមែងមិនអាចរាប់ការដែលអញសោយរាជសម្បត្តិបាន អញនឹងទ្រទ្រង់ទុកនូវព្រះសាសនារបស់ព្រះសាស្តា ។ ទ្រង់ចាប់ដាវដែលទ្រង់ទុកលើទីបន្ទំ កាត់ព្រះកេសា ហើយទ្រង់បើកបង្អួច ទ្រង់ញុំាងព្រះកេសា មួយអន្លើនឹងព្រះចូឡាមណីឲ្យធ្លាក់ចុះក្នុងកណ្តាលបរិស័ទថា អ្នកទាំងឡាយកាន់យកបាច់សក់នេះ គ្រងរាជសម្បត្តិចុះ មហាជនលើកបាច់ព្រះកេសានោះឡើងហើយ ទ្រហោយំសំឡេងតែមួយថា បពិត្រព្រះសម្មតិទេព ព្រះរាជាទាំងឡាយ បានព្រះរាជ-

បណ្ណាការអំពីសម្មាក់សម្ងាញ់ហើយ រមែងដូចគ្នានឹងព្រះអង្គឬ ។ ព្រះកេសា និងព្រះមស្សុប្រមាណ ២ អង្គុលីរបស់ព្រះរាជាបានមានហើយ ។ បានឮថា ព្រះកេសា និងព្រះមស្សុ កើតដូចជាមួយនឹងបព្វជ្ជារបស់ព្រះពោធិសត្វនោះឯង ។ លំដាប់នោះ ទ្រង់បញ្ជូនមហាតលិកប្រចាំព្រះអង្គ ទៅនាំយកសំពត់កាសាវពស្ត្រ ២ ផ្ទាំង និងបាត្រដីអំពីទីផ្សារ ទ្រង់ឧទ្ទិសចំពោះព្រះសាស្តាថា ព្រះអរហន្តពួកណាក្នុងលោក អាត្មាអញបួសឧទ្ទិសព្រះអរហន្តទាំងនោះ ដូច្នេះហើយ ទ្រង់ស្លៀកសំពត់កាសាវៈមួយផ្ទាំង ទ្រង់ដណ្តប់សំពត់កាសាវៈមួយផ្ទាំង ទ្រង់ស្ពាយបាត្រ កាន់ធារព្រះករ ទ្រង់ចង្ក្រមទៅមកៗ ២-៣ ដង ក្នុងផែនដីធំ ដោយព្រះតម្រិះថា បព្វជ្ជារបស់អាត្មាអញស្អាតឬហ្ន៎ ដូច្នេះ ទ្រង់ជ្រាបថា បព្វជ្ជារបស់ព្រះអង្គស្អាត ដូច្នេះហើយ ទ្រង់បើកទ្វារ ហើយយាងចុះអំពីប្រាសាទ ។ ប្រជាជនទាំងឡាយ មានស្រីរបាំដែលឈរត្រង់ទ្វារទាំង ៣ ជាដើម តែចាំព្រះរាជាដែលយាងចុះមកនោះមិនបាន ។ បានឮថា នាំគ្នាគិតថា ជាព្រះបច្ចេកពុទ្ធមួយអង្គ មកដើម្បីសម្តែងធម្មកថាដល់ព្រះរាជារបស់ពួកយើង តែកាលឡើងលើប្រាសាទហើយ ឃើញតែទីប្រថាប់ឈរ ទីប្រថាប់អង្គុយជាដើមរបស់ព្រះរាជា ដឹងថា ព្រះរាជាយាងទៅហើយ ទើបនាំគ្នាស្រែកព្រមគ្នានោះឯង ដូចជនក្នុងទូកកំពុងលិចទឹក ក្នុងកណ្តាលសមុទ្រ ដូច្នោះ ។ សេនាទាំង ១៨ អ្នកនគរទាំងអស់ និងពលនិកាយទាំងឡាយ នាំគ្នាហែហមកុលបុត្រដែលគ្រាន់តែយាងចុះកាន់ផែនដី ហើយស្រែកដោយសំឡេងខ្លាំង ។ ឯអមាត្យទាំងឡាយ ក្រាបទូលដល់កុលបុត្រនោះថា បពិត្រ

ទេវៈ ធម្មតាស្តេចទាំងឡាយ ក្នុងមជ្ឈិមប្រទេស ជាអ្នកមានមាយាច្រើន សូមព្រះអង្គបញ្ជូនព្រះរាជសាសន៍ទៅថា ពុទ្ធរតនៈបានកើតឡើងក្នុងលោកហើយឬ ទ្រង់ជ្រាបហើយ សឹមទៅ សូមព្រះអង្គយាងត្រឡប់ចុះ ។ ព្រះរាជាត្រាស់ថា ខ្ញុំជឿសម្លាញ់របស់ខ្ញុំ ខ្ញុំ និងសម្លាញ់នោះ មិនមានការខុសគ្នា ពួកអ្នកចូរឈប់ចុះ ។ អមាត្យទាំងនោះ ក៏ជាប់តាមព្រះរាជាទៅ ។ កុលបុត្រទ្រង់យកដាវព្រះករ ( ឈើប្រត់ ) គូសជាតួអក្សរ ត្រាស់ថា រាជសម្បត្តិនេះជារបស់អ្នកណា អមាត្យទាំងឡាយពោលថា ជារបស់ព្រះអង្គ ។ ព្រះរាជាត្រាស់ថា បុគ្គលណា ធ្វើតួអក្សរនេះក្នុងចន្លោះ បុគ្គលនោះ គប្បីឲ្យសោយរាជអំណាច ។ ព្រះទេវីឈ្មោះសីវលី កាលទ្រង់មិនអាចធ្វើអក្សរដែលព្រះពោធិសត្វធ្វើហើយ ក្នុងមហាជនកជាតកឲ្យមានចន្លោះ ក៏យាងត្រឡប់ទៅ មហាជនក៏បានទៅតាមផ្លូវដែលព្រះទេវីយាងទៅ ។ មហាជនក៏មិនអាចធ្វើអក្សរនោះ ឲ្យមានចន្លោះ ។ ពួកអ្នកនគរធ្វើព្រះអក្សរនេះទុកលើក្បាល ហើយត្រឡប់ទៅទ្រហោយំ ។ មហាជនគិតថា កុលបុត្រនេះ នឹងឲ្យឈើសួន់ ឬទឹកក្តុរមាត់ក្នុងទីដែលអញទៅហើយ ដូច្នេះ កាលមិនបានអ្វីដោយហោចសូម្បីតែចម្រៀកសំពត់ ក៏ចៀសចេញទៅ ។ បានឮថា កុលបុត្រមានការគិតយ៉ាងនេះថា ព្រះសាស្តារបស់អាត្មាអញ យាងចេញមហាភិនេស្រ្កមណ៍ ទ្រង់បព្វជ្ជាមួយព្រះអង្គឯង ទៅមួយព្រះអង្គឯង អញខ្មាសចំពោះព្រះសាស្តា បានឮថា ព្រះសាស្តារបស់អញ ទ្រង់បព្វជ្ជាហើយ មិនឡើងកាន់យាន មិនពាក់ស្បែកព្រះបាទ ដោយហោចសូម្បីតែមួយជាន់ ទ្រង់មិន

បាំងឆត្រ ។ មហាជនឡើងដើមឈើ ឡើងកំពែង និងប៉មជាដើម សម្លឹងមើលថា ព្រះរាជារបស់យើងយាងទៅ ដូច្នេះ ។ កុលបុត្រគិតថា អញដើរផ្លូវឆ្ងាយ មិនអាចដើម្បីទៅផ្លូវមួយបាន ទើបយាងជាប់តាមឈ្មួញរទេះមួយពួក ។ កាលកុលបុត្រដែលមានជាតិសុខុមាល ដើរលើផែនដីដែលក្តៅ ផ្ទៃព្រះបាទទាំងពីរ ក៏ពុរពងបែកជាដំបៅ ទុក្ខវេទនាក៏កើតឡើង ។

កាលពួកឈ្មួញបោះជំរំ នាំគ្នាអង្គុយហើយ កុលបុត្រក៏ចេញអំពីផ្លូវអង្គុយត្រង់គល់ឈើមួយ ។ ឈ្មោះថា អ្នកធ្វើបរិកម្មជើង ឬគក់ខ្នងក្នុងទីអង្គុយមិនមាន ។ កុលបុត្រចូលអានាបានចតុត្ថជ្ឈាន សង្កត់នូវការលំបាកតាមផ្លូវ និងការហត់នឿយ ការក្តៅ ញុំាងវេលាឲ្យកន្លងទៅ ដោយការត្រេកអរក្នុងឈាន ។ ក្នុងថ្ងៃស្អែកឡើង កាលអរុណរះ ធ្វើកិច្ចបដិបត្តិសរីរៈ ធ្វើដំណើរតាមពួកឈ្មួញទៀត ។ ក្នុងវេលាអាហារព្រឹក ពួកឈ្មួញទទួលបាត្ររបស់កុលបុត្រ ហើយដាក់ខាទនីយ និងភោជនីយ ក្នុងបាត្រប្រគេន ។ ខាទនីយ និងភោជនីយនោះ ឆៅខ្លះ សៅហ្មងខ្លះ ។ រីឯដូចដុំក្រួសខ្លះ សាបខ្លះ ប្រៃខ្លះ ។ កុលបុត្រពិចារណាទីសម្រាក បរិភោគខាទនីយ និងភោជនីយដូចអម្រឹតដោយទំនងនោះ ដើរទៅអស់ចម្ងាយ ១៩២ យោជន៍ ដើរទៅជិតខ្លោងទ្វារវត្តជេតពន ក៏មិនសួរថា ព្រះសាស្តាប្រថាប់ក្នុងទីណា ។ ព្រោះហេតុអ្វី ព្រោះគោរពក្នុងព្រះសាស្តា និងព្រោះអំណាចនៃព្រះរាជសាសន៍ដែលព្រះរាជាទ្រង់បញ្ជូនទៅ ។ ឯព្រះរាជាទ្រង់បញ្ជូនព្រះរាជសាសន៍ ទ្រង់ធ្វើហាក់ដូចព្រះសាស្តាទ្រង់កើតឡើងក្នុងក្រុងរាជគ្រឹះថា ព្រះតថាគតទ្រង់កើត

ឡើងក្នុងលោក ។ ព្រោះដូច្នោះ ទើបមិនសួរ ដើរទៅអស់ចម្ងាយ ៤៥ យោជន៍ ។ ក្នុងវេលាព្រះអាទិត្យអស្ដង្គត កុលបុត្រនោះទៅដល់ក្រុងរាជគ្រឹះ ទើបសួរថា ព្រះសាស្ដាទ្រង់ប្រថាប់ក្នុងទីណា ។ អ្នកស្រុកពោលថា លោកម្ចាស់មកអំពីទីណា ។ កុលបុត្រឆ្លើយថា ខ្ញុំមកអំពីឧត្តរប្រទេស អ្នកស្រុកប្រាប់ថា នគរឈ្មោះសាវត្ថី មាននៅក្នុងផ្លូវដែលលោកម្ចាស់មក ចម្ងាយអំពីរាជគ្រឹះនេះប្រមាណ ៤៥ យោជន៍ ព្រះសាស្ដាប្រថាប់នៅក្នុងក្រុងសាវត្ថីនោះ ។ កុលបុត្រនោះគិតថា ឥឡូវនេះ មិនមែនជាកាល អញមិនអាចត្រឡប់ថ្ងៃនេះ អញសម្រាកក្នុងទីនេះសិន ស្អែកនេះ សឹមទៅកាន់សម្នាក់ព្រះសាស្ដា ។ ពេលនោះ ទើបសួរថា ពួកបព្វជិតដែលមកដល់ក្នុងវេលាវិកាល សម្រាកក្នុងទីណា ។ អ្នកស្រុកប្រាប់ថា សម្រាកក្នុងសាលាស្មូនឆ្នាំងនេះ ។ លំដាប់នោះ កុលបុត្រនោះ សូមសម្រាកជាមួយនាយស្មូនឆ្នាំងនោះហើយ ចូលទៅអង្គុយដើម្បីប្រយោជន៍ដល់ការស្នាក់អាស្រ័យ ក្នុងសាលារបស់ស្មូនឆ្នាំងនោះ ។

ក្នុងវេលាជិតភ្លឺថ្ងៃនោះ ព្រះមានព្រះភាគទ្រង់ប្រមើលមើលសត្វលោក ទ្រង់ឃើញកុលបុត្រឈ្មោះបុក្កុសាតិ ទ្រង់ព្រះតម្រិះថា កុលបុត្រនេះអានត្រឹមតែសាសន៍ ដែលសម្លាញ់បញ្ជូនទៅ លះរាជសម្បត្តិធំ ធ្វើដំណើរជាង ១០០ យោជន៍ បួសឧទ្ទិសតថាគត ធ្វើដំណើរ ១៩២ យោជន៍ ដល់ក្រុងរាជគ្រឹះ កាលតថាគតមិនទៅ នឹងមិនសម្រេចសាមញ្ញផល ៣ នឹងធ្វើកាលកិរិយាឥតទីពឹង ដោយការសម្រាកត្រឹមមួយយប់ តែបើតថាគតទៅហើយ នឹងបាក់ដុះ

សាមញ្ញផល ៣ ឯតថាគត បំពេញបារមីទាំងឡាយអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប ដើម្បីសង្គ្រោះជនប៉ុណ្ណោះ តថាគតនឹងធ្វើការសង្គ្រោះដល់កុល-បុត្របុក្កុសាតិ ដូច្នេះ ។ ទ្រង់ធ្វើកិច្ចបដិបត្តិព្រះសរីរៈអំពីព្រហាម មានព្រះភិក្ខុសង្ឃចោមរោម យាងបិណ្ឌបាតក្នុងក្រុងសាវត្ថី ខាងក្រោយភត្ត យាងត្រឡប់អំពីបិណ្ឌបាត យាងចូលព្រះគន្ធកុដិ ទ្រង់រម្ងាប់សេចក្ដីលំបាកក្នុងការធ្វើដំណើរមួយសន្ទុះ ទ្រង់ព្រះតម្រិះថា កុលបុត្របានធ្វើកិច្ច ដែលគេបានលំបាក ព្រោះសេចក្ដីគោរពក្នុងតថាគត លះរាជសម្បត្តិ ធ្វើដំណើរជាង ១០០ យោជន៍ មិនកាន់យកសេសសំពត់ ដោយហោចសូម្បីអ្នកឲ្យទឹកខ្ពុរមាត់ ចេញទៅតែម្នាក់ឯង ដូច្នេះ មិនត្រាស់អ្វី ជាមួយព្រះថេរៈទាំងឡាយ មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម ទ្រង់កាន់យកបាត្រ និងចីវររបស់ព្រះអង្គ ចេញទៅមួយព្រះអង្គឯង កាលយាងទៅ ទ្រង់ក៏មិនហោះ ទ្រង់មិនបង្រួញផែនដី ។ ទ្រង់ព្រះតម្រិះទៀតថា កុលបុត្រនេះខ្មាសចំពោះតថាគត មិនអង្គុយក្នុងយាន មានដំរី សេះ រថ និងវិមានជាដើម ដោយហោច មិនពាក់ស្បែកជើងមួយជាន់ មិនបាំងឆត្រ ចេញទៅ សូម្បីតថាគតក៏គួរទៅដោយជើងប៉ុណ្ណោះ ដូច្នេះ ទើបទ្រង់យាងទៅដោយព្រះបាទ ព្រះអង្គទ្រង់បិទបាំងព្រះពុទ្ធសិរី គឺអនុព្យញ្ជនៈ ៨០ រស្មីមួយព្យាម មហាបុរិស-លក្ខណៈ ៣២ យាងទៅ ដោយភេទជាភិក្ខុមួយរូប ដូចព្រះចន្ទពេញវង់ដែលពពកបិទ ដូច្នោះ ដោយបច្ឆាភត្តមួយប៉ុណ្ណោះ ក៏យាងទៅបាន ៤៥ យោជន៍ ក្នុងវេលាព្រះអាទិត្យលិច ទ្រង់យាងដល់សាលារបស់នាយស្មូនឆ្នាំង

នោះ ក្នុងខណៈដែលកុលបុត្រចូលទៅហើយនោះឯង ។ លោកសំដៅដល់សាលារបស់នាយស្មូនឆ្នាំងនោះ ទើបពោលថា សម័យនោះឯង កុលបុត្រឈ្មោះបុក្កុសាតិ ចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស ព្រោះសទ្ធាចំពោះព្រះមានព្រះភាគ ។ បុក្កុសាតិកុលបុត្រនោះឯង ជាអ្នកចូលមកនៅមុន ក្នុងផ្ទះស្មូនឆ្នាំងនោះ ដូច្នេះ ។

ព្រះមានព្រះភាគ កាលយាងទៅយ៉ាងនេះហើយ ក៏ទ្រង់មិនអួតអាងថា តថាគតជាព្រះសម្មាសម្ពុទ្ធ យាងទៅកាន់សាលារបស់នាយស្មូនឆ្នាំង ប្រថាប់ឈរត្រង់ទ្វារនោះឯង កាលឲ្យកុលបុត្រធ្វើឱកាស ទើបត្រាស់ថា **សចេ តេ ភិក្ខុ** ដូច្នេះជាដើម ។ បទថា **ឧរុន្ធំ** បានដល់ ស្ងាត់មិនចង្អៀត ។ បទថា **វិហរតាយស្មា យថាសុខំ** សេចក្តីថា កុលបុត្រធ្វើឱកាសថា សូមព្រះមានព្រះភាគនៅជាសុខ តាមឥរិយាបថដែលមានផាសុកចុះ ។ ឯកុលបុត្រលះរាជសម្បត្តិ ធ្វើដំណើរជាង ១០០ យោជន៍ ហើយបួស នឹងកំណាញ់សាលានាយស្មូនឆ្នាំង ដែលអ្នកដទៃបោះបង់ចោល ដើម្បីព្រហ្មចារីដទៃឬ ។ ចំណែកមោឃបុរសពួកខ្លះ បួសក្នុងសាសនាហើយ ត្រូវសេចក្តីកំណាញ់ក្នុងអាវាសគ្របសង្កត់ រមែងស្រវាស្រទេញ ព្រោះអាវាសរបស់បុគ្គលដទៃថា ជាទីលំនៅរបស់ខ្លួន ជាកុដិរបស់អញ ជាបរិវេណរបស់អញ ដូច្នេះ ។

[ ១៥០ ] បទថា **និសីទិ** សេចក្តីថា ព្រះលោកនាថទ្រង់សុខុមាលជាតិដ៏ក្រៃលែង ទ្រង់លះព្រះគន្ធកុដិ ដូចគ្នានឹងទេពវិមាន ទ្រង់ក្រាលសន្ថត គឺស្មៅក្នុងសាលារបស់ស្មូនឆ្នាំង ដែលមានផេះរាយរាយទូទៅ ស្មោកគ្រោក

ដោយកាជនៈបែក ស្មៅស្លួត អាចម៍មាន់ និងអាចម៍ជ្រូកជាដើម ដែលដូចគ្នានឹងទីចាក់សំរាម ទ្រង់ក្រាលបង្សុកូលចីវរប្រថាប់គង់ ដូចយានចូលព្រះគន្ធកុដិដែលមានក្លិនទិព្វ ដូចគ្នានឹងទេវវិមាន ហើយប្រថាប់គង់ ដូច្នោះ ។ ដោយប្រការដូច្នេះ ព្រះមានព្រះភាគ ទ្រង់កើតក្នុងព្រះមហាសម្មតិវង្សដែលមិនលាយឡំ សូម្បីកុលបុត្រក៏ចម្រើនហើយក្នុងខត្តិយគត្រ ព្រះមានព្រះភាគក៏ទ្រង់ដល់ព្រមដោយព្រះអភិនីហារ សូម្បីកុលបុត្រក៏ដល់ព្រមដោយអភិ-នីហារ ព្រះមានព្រះភាគក្តី កុលបុត្រក្តី សុទ្ធតែលះរាជសម្បត្តិ ទ្រង់ផ្នួស ។ ព្រះមានព្រះភាគ ទ្រង់មានពណ៌សម្បុរដូចមាស សូម្បីកុលបុត្រក៏មានពណ៌សម្បុរដូចមាស ព្រះមានព្រះភាគក្តី កុលបុត្រក្តី ទ្រង់មានលាភ គឺសមាបត្តិទាំង ២ ព្រះអង្គទ្រង់ជាក្សត្រទាំង ២ ព្រះអង្គ ទ្រង់ដល់ព្រមដោយអភិ-នីហារទាំង ២ ព្រះអង្គក៏ទ្រង់ផ្នួសអំពីរាជត្រកូលទាំង ២ ព្រះអង្គទ្រង់មានវណ្ណៈដូចមាស ទាំង ២ ព្រះអង្គទ្រង់មានលាភ គឺសមាបត្តិ ស្តេចចូលកាន់សាលារបស់ស្មូនឆ្នាំង ហើយប្រថាប់គង់ ដោយប្រការដូច្នេះ ។ ដោយហេតុនោះ ទើបសាលាស្មូនឆ្នាំងល្អយ៉ាងក្រៃលែង គប្បីនាំស្ថានទីទាំងឡាយជាដើមថា គុហាដែលស្តេចសត្វទាំង ២ មានសីហៈជាដើម ចូលទៅសម្តែងប្រៀបធៀបចុះ ។

ក្នុងបុគ្គលទាំង ២ នោះ ព្រះមានព្រះភាគទ្រង់មិនញ៉ាំងព្រះហឫទ័យឲ្យកើតឡើងថា តថាគតជាសុខមាលជាតិ ធ្វើដំណើរមកអស់ ៤៥ យោជន៍ ដោយវេលាក្រោយភត្តមួយ គួរសម្រេចសីហសេយ្យាមួយសន្ទុះសិន ឲ្យបាត់

នឿយហត់អំពីការដើរផ្លូវ ដូច្នេះ ប្រថាប់គង់ចូលផលសមាបត្តិនោះឯង ។ ឯកុលបុត្រក៏មិនញុំាងចិត្តឲ្យកើតឡើងថា អញដើរមកអស់ ១៩២ យោជន៍ គួរដេកសម្រាកបន្ទោបង់ការនឿយហត់ ក្នុងការធ្វើដំណើរ ក៏គង់ចូលអានាបានចតុត្ថជ្ឈានានោះឯង ។ លោកសំដៅដល់ការចូលសមាបត្តិនោះ ទើបពោលថា **អថខោ ភគវា ពហុទេវ រត្តឹ** ជាដើម ។ សួរថា ព្រះមានព្រះភាគយាងមកដោយព្រះតម្រិះថា តថាគតនឹងសម្ដែងធម៌ដល់កុលបុត្រមិនមែនឬ ព្រោះហេតុអ្វី ទើបមិនសម្ដែង ។ ឆ្លើយថា ទ្រង់មិនសម្ដែង ព្រោះថា កុលបុត្រមានការហត់នឿយ ក្នុងការធ្វើដំណើរមិនទាន់ស្ងប់រម្ងាប់ មិនអាចទទួលព្រះធម្មទេសនាបានឡើយ សូមការហត់នឿយក្នុងការធ្វើដំណើររបស់កុលបុត្រនោះ ស្ងប់រម្ងាប់សិន ។ អាចារ្យពួកខ្លះពោលថា ធម្មតានគររាជគ្រឹះដេរដាសដោយមនុស្ស មិនស្ងាត់ចាកសំឡេង ១០ យ៉ាង សំឡេងនោះស្ងប់ដោយប្រមាណ ២ យាមកន្លះ ព្រះមានព្រះភាគទ្រង់រង់ចាំការស្ងប់សំឡេងនោះទើបទ្រង់មិនសម្ដែង ។ តែនោះមិនមែនជាហេតុ ។ ព្រោះព្រះមានព្រះភាគទ្រង់អាចញុំាងសំឡេងសូម្បីប៉ុនព្រហ្មលោកឲ្យស្ងប់រម្ងាប់បាន ដោយអានុភាពរបស់ព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់រង់ចាំការស្ងប់រម្ងាប់អំពីការនឿយហត់ ក្នុងការធ្វើដំណើរសិន ទើបទ្រង់មិនសម្ដែង ។ បណ្ដាបទទាំងនោះ បទថា **ពហុទេវ រត្តឹ** បានដល់ ប្រមាណ ២ យាមកន្លះ ។ បទថា **ឯតទវោច** សេចក្ដីថា ព្រះមានព្រះភាគ ចេញអំពីផលសមាបត្តិហើយ ទ្រង់បើកព្រះនេត្រ ដែលល្អដោយបសាទ ៥ យ៉ាង ទ្រង់ឆ្មៀងមើល ដូចបើកសីហបញ្ជរ

កែវមណី ក្នុងវិមានមាស ដូច្នោះ ។

លំដាប់នោះ ទ្រង់ឃើញកុលបុត្រប្រាសចាកការរពិសដៃ ការរពិសជើង និងការគ្រវីក្បាល អង្គុយដូចសសរខឿន ដែលកប់យ៉ាងល្អហើយ ដូចបដិមាមាស មិនកម្រើកជានិច្ច ទើបត្រាស់ថា **ចាសាទិកំ ខោ** ជាដើម ។ បណ្ដាបទទាំងនោះ បទថា **ចាសាទិកោ** គឺនាំមកនូវការជ្រះថ្លា ។ ពាក្យនោះ ជាភាវនបុំសកលិង្គ ។ ក្នុងពាក្យនោះ មានអត្ថដូច្នេះថា កុលបុត្រ រមែងប្រព្រឹត្តទៅដោយឥរិយាបថគួរជ្រះថ្លា ព្រោះដូច្នោះ ឥរិយាបថ ជាកិរិយាដែលគួរជ្រះថ្លា ដោយប្រការណា ក៏រមែងប្រព្រឹត្តទៅ ដោយប្រការនោះ ។ ក្នុងឥរិយាបថទាំង ៤ ឥរិយាបថ ៣ រមែងមិនស្អាត ។ ពិតហើយ ភិក្ខុដើរទៅ ដៃទាំងឡាយរមែងបង់បោយ ជើងទាំងឡាយរមែងកម្រើកទៅ ក្បាលរមែងរង្គើ ។ កាយរបស់ភិក្ខុឈរ រមែងរឹង ។ ឥរិយាបថរបស់ភិក្ខុដេករមែងមិនគួរជ្រះថ្លា ។ តែកាលភិក្ខុបោសទីសម្រាកពេលថ្ងៃ ក្នុងបច្ឆាភត្តក្រាលបន្ទះស្បែក មានដៃ និងជើងលាងល្អហើយ អង្គុយពត់ភ្នែន ប្រកបដោយសន្ធិ ៤ នោះឯង ឥរិយាបថរមែងស្អាត ។ កុលបុត្រនេះ អង្គុយពត់ភ្នែន ចូលអានាបានចតុត្ថជ្ឈាន ។ កុលបុត្រប្រកបដោយឥរិយាបថ ដោយប្រការដូច្នេះឯង ។ ព្រះមានព្រះភាគទ្រង់បរិវិតក្កថា កុលបុត្រគួរជ្រះថ្លាហ្ន៎ ។ សួរថា ព្រះមានព្រះភាគ ទ្រង់បរិវិតក្កថា ណ្ហើយចុះ តថាគតគួរសួរមើលខ្លះ ហើយត្រាស់សួរ ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទ្រង់មិនដឹងការដែលកុល-បុត្រនោះជាអ្នកបួសឧទ្ទិសចំពោះព្រះអង្គឬ ។ ឆ្លើយថា ទ្រង់មិនដឹងក៏មិនមែន

តែកាលមិនត្រាស់សួរ វាចាក៏មិនតាំងឡើង កាលវាចាមិនតាំងឡើងហើយ ការសម្តែងរមែងមិនកើតឡើង ព្រោះដូច្នោះ ទើបត្រាស់សួរ ដើម្បីផ្តើមតាំងវាចាឡើង ។

[ ១៥១ ] បទថា **ជិវ្ហាទាហំ ច ជានេយ្យំ** សេចក្តីថា ជនទាំងអស់រមែងដឹងព្រះតថាគតដែលជាអ្នករុងរឿង ដោយពុទ្ធសិរីថា នេះជាព្រះពុទ្ធ ។ ការដឹងនោះមិនគួរអស្ចារ្យ តែព្រះមានព្រះភាគ ទ្រង់បិទបាំងព្រះពុទ្ធស្មីយាងចូលទៅដោយអំណាចរបស់ភិក្ខុដែលបិណ្ឌបាតមួយរូប ទើបដឹងបានលំបាក ។ បុក្កុសាតិពោលសភាពតាមពិតថា ខ្ញុំមិនដឹងដោយប្រការដូច្នេះ ។ សេចក្តីពិតយ៉ាងនោះ បុក្កុសាតិមិនដឹងថាជាព្រះមានព្រះភាគ សូម្បីប្រថាប់គង់ក្នុងរោងស្មូនឆ្នាំងជាមួយគ្នា ។

[ ១៥២ ] បទថា **ឯតទហោសិ** សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ដឹងនូវការបាត់នឿយ ក្នុងការធ្វើដំណើរស្ងប់រម្ងាប់ហើយ ទ្រង់មានព្រះតម្រិះ ។ បទថា **ឯវមាវុសោ** សេចក្តីថា កុលបុត្របានអានត្រឹមតែរាជសាសន៍ដែលសម្លាញ់បញ្ជូនទៅ លះរាជសម្បត្តិចេញបួស ដោយគិតថា អញនឹងបានស្តាប់ព្រះធម្មទេសនាដ៏ពីរោះរបស់ព្រះទសពល កាលបព្វជ្ជាហើយ ក៏ធ្វើដំណើរផ្លូវឆ្ងាយប្រមាណប៉ុណ្ណោះ ក៏មិនបានព្រះសាស្តាដែលត្រាស់ត្រឹមតែមួយបទថា ម្នាលភិក្ខុ តថាគតនឹងសម្តែងធម៌ដល់អ្នក កុលបុត្រនោះ នឹងមិនស្តាប់ពាក្យដែលត្រាស់ថា ម្នាលភិក្ខុ តថាគតនឹងសម្តែងធម៌ដល់អ្នកដោយគោរពឬ កុលបុត្រនេះ ដូចជាអ្នកលេងសុរាដែលស្រេក និងដូចដំរីដែលចុះប្រេង

ដូច្នោះ ។ ព្រោះដូច្នោះ កាលកុលបុត្រប្តេជ្ញាដល់ការស្តាប់ដោយសេចក្តីគោរព ទើបសួរថា **ឯវមាវុសោ** ដូច្នេះ ។

[ ១៥៣ ] បទថា **ឆធាតុរោ អយំ** សេចក្តីថា ព្រះមានព្រះភាគមិនត្រាស់បដិបទាចំណែកខាងដើមដល់កុលបុត្រ តែទ្រង់ប្រារព្ធដើម្បីត្រាស់ប្រាប់វិបស្សនាលក្ខណៈប៉ុណ្ណោះ ដែលមានការសោះសូន្យទទេក្រៃលែង ដែលជាបទដ្ឋាននៃអរហត្តអំពីខាងដើម ។ ពិតហើយ បុព្វភាគបដិបទានៃបុគ្គលណាមិនទាន់បរិសុទ្ធ ព្រះមានព្រះភាគក៏ត្រាស់បុព្វភាពបដិបទានេះ គឺសីលសំវរៈ ការគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ការប្រកបរឿយៗ នូវសេចក្តីព្យាយាមជាគ្រឿងភ្ញាក់រឭក សទ្ធម្ម ៧ ឈាន ៤ ដល់បុគ្គលនោះមុន តែបុព្វភាគបដិបទានោះនៃបុគ្គលណា បរិសុទ្ធ ព្រះមានព្រះភាគទ្រង់មិនត្រាស់បដិបទានោះ តែត្រាស់ប្រាប់វិបស្សនានោះឯង ដែលជាបទដ្ឋាននៃអរហត្តដល់បុគ្គលនោះ ។ ឯបុព្វភាគរបស់កុលបុត្របរិសុទ្ធហើយ ។ ពិតហើយ កុលបុត្រនោះអានសាសន៍ហើយ ឡើងប្រាសាទដ៏ប្រសើរនោះឯង ញុំាងអានាបានចតុត្ថជ្ឈានឲ្យកើតឡើងហើយ ទើបធ្វើដំណើរទៅអស់ ១៩២ យោជន៍ ញុំាងកិច្ចក្នុងយានឲ្យសម្រេច ។ សូម្បីសាមណេរសីលរបស់កុលបុត្រនោះក៏បរិបូណ៌ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ មិនត្រាស់បុព្វភាពបដិបទា តែទ្រង់ប្រារព្ធដើម្បីត្រាស់ប្រាប់វិបស្សនាលក្ខណៈដែលមានការសោះសូន្យយ៉ាងក្រៃលែង ដែលជាបទដ្ឋាននៃអរហត្តប៉ុណ្ណោះដល់កុលបុត្រនោះ ។

[ ១៥៣ ] បទថា **ឆធាតុរោ** បានដល់ ធាតុ ៦ មាន បុរសមិនមាន ។ ព្រះមានព្រះភាគ ទ្រង់សម្តែងនូវវត្ថុដែលមិនមានដោយវត្ថុមិនមានក្នុងទីណា ទ្រង់សម្តែងវត្ថុដែលមានដោយវត្ថុដែលមិនមានក្នុងទីណា ទ្រង់សម្តែងវត្ថុដែលមានដោយវត្ថុដែលមានក្នុងទីណា ទ្រង់សម្តែងវត្ថុដែលមិនមានដោយវត្ថុដែលមិនមានក្នុងទីណា ពាក្យដូចពោលមកនេះ គប្បីឲ្យពិស្តារដោយន័យដែលពោលហើយ ក្នុងសព្វាសវសំវរសូត្រនោះឯង ។ តែក្នុងធាតុវិភង្គសូត្រនេះ ព្រះមានព្រះភាគ កាលទ្រង់សម្តែងវត្ថុដែលមានដោយវត្ថុដែលមិនមាន ទើបត្រាស់យ៉ាងនោះ ។ បើព្រះមានព្រះភាគទ្រង់លះបញ្ញត្តិថា បុរស ត្រាស់ថា ធាតុប៉ុណ្ណោះ ហើយទ្រង់ដាក់ព្រះហឫទ័យ កុលបុត្រគប្បីធ្វើនូវការងឿងឆ្ងល់ ដល់នូវការសង្ស័យ មិនអាចដើម្បីទទួលទេសនាបាន ។ ព្រោះដូច្នោះ ទើបព្រះតថាគតទ្រង់លះបញ្ញត្តិថា បុរសដោយលំដាប់ ត្រាស់ត្រឹមតែបញ្ញត្តិថា សត្វ ឬបុរស ឬបុគ្គលប៉ុណ្ណោះ ដោយបរមត្ថ ឈ្មោះថា សត្វមិនមាន ការដាក់ព្រះហឫទ័យក្នុងធម៌ថា ត្រឹមតែជាធាតុប៉ុណ្ណោះ ត្រាស់ទុកនៅក្នុងអនង្គណសូត្រថា តថាគតនឹងឲ្យបាក់ធ្លុះនូវផល ៣ ដូច្នេះ ។ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដូចអាចារ្យឲ្យរៀនសិប្បៈដោយភាសាដទៃ ព្រោះជាអ្នកឈ្លាសក្នុងភាសាដទៃ ។

ក្នុងធាតុវិភង្គសូត្រនោះ ធាតុ ៦ នៃបុគ្គលនោះ ព្រោះដូច្នោះ ទើបបុគ្គលនោះ ឈ្មោះថា មានធាតុ ៦ អធិប្បាយថា លោករមែងចាំបុគ្គលបានថា បុរសបុគ្គលនោះមានធាតុ ៦ ក្នុងទីនេះដោយបរមត្ថ ក៏ត្រឹមតែធាតុ

ប៉ុណ្ណោះ ។ បទថា **ឋុរិសោ** គឺត្រឹមតែបញ្ញត្តិ ។ បទក្នុងទីដ៏សេស ក៏មានន័យនេះដូចគ្នា ។

សតិប្បដ្ឋាន ហៅថា អធិដ្ឋានក្នុងបទនេះថា **ចតុរាធិដ្ឋានោ** សេចក្តីថា មានអធិដ្ឋាន ៤ អធិប្បាយថា ម្នាលភិក្ខុ បុរសនេះមានធាតុ ៦ មានផស្សាយតនៈ ៦ មានមនោបវិចារ ១៨ ដូច្នេះ ។ កុលបុត្រនោះវិលត្រឡប់អំពីធាតុនោះឯង កាន់យកអរហត្តដែលជាសិទ្ធដ៏ឧត្តម តាំងនៅក្នុងឋានៈ ៤ នេះ កាន់យកអរហត្ត ព្រោះដូច្នោះ ទើបឈ្មោះថា មានអធិដ្ឋាន ៤ ។ បទថា **យត្ថ ឋិតំ** បានដល់ តាំងនៅក្នុងអធិដ្ឋានឯណា ។ បទថា **មញ្ញស្សវា ឆប្បវត្តន្តិ** បានដល់ មិនមានកិលេសជាគ្រឿងសម្គាល់ខ្លួនប្រព្រឹត្តទៅ ។ បទថា **មុនិ សន្តោតិ វុច្ចតិ** បានដល់ មុនីខីណាសវៈ លោកហៅថា ស្ងប់ហើយ រម្ងត់ហើយ ។ បទថា **បញ្ញំ ឆប្បមជ្ជេយ្យ** សេចក្តីថា មិនគប្បីប្រមាទ សមាធិ បញ្ញា និងវិបស្សនាបញ្ញាតាំងអំពីដើមនោះឯង ដើម្បីចាក់ធ្លុះអរហត្តផលបញ្ញា ។ បទថា **សច្ចមនុរក្ខេយ្យ** សេចក្តីថា គប្បីរក្សាវចីសច្ចៈ តាំងអំពីដើម ដើម្បីធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ច គឺនិព្វាន ។ បទថា **ចាគមនុព្រូហេយ្យ** សេចក្តីថា គប្បីបន្ថែមនូវការលះកិលេសអំពីខាងដើម ដើម្បីការលះកិលេសទាំងពួង ដោយអរហត្តមគ្គ ។ បទថា **សន្តិមេវ សោ សិក្ខេយ្យ** សេចក្តីថា គប្បីសិក្សាការស្ងប់រម្ងាប់កិលេស តាំងអំពីដើមនោះឯង ដើម្បីស្ងប់រម្ងាប់កិលេសទាំងអស់ ដោយអរហត្តមគ្គ ។ ព្រះមានព្រះភាគត្រាស់បុព្វភាគាធិដ្ឋានទាំងឡាយ មានសមថវិបស្សនាបញ្ញាជាដើម

នេះ ដើម្បីប្រយោជន៍ដល់ការសម្រេចអធិដ្ឋានទាំងឡាយ មានបញ្ញាធិដ្ឋានជាដើម ដោយប្រការដូច្នេះ ។

[ ១៥៥ ] បទថា **ឆស្សាយតនំ** សេចក្តីថា អាយតនៈ គឺអាការនៃផស្សៈ ។

[ ១៥៧ ] បទថា **បញ្ញាធិដ្ឋានោ** ជាដើម គប្បីជ្រាបដោយអំណាចនៃបញ្ញាទាំងឡាយ មានអរហត្តផលបញ្ញាជាដើម ដែលបានពោលហើយក្នុងបទមុន ។ ឥឡូវនេះ ជាការពោលដល់បទថា ជាធម៌ដែលបុគ្គលតាំងនៅហើយ មិនមានកិលេសជាគ្រឿងសម្គាល់ខ្លួន លះកិលេសជាគ្រឿងត្រាំប្រព្រឹត្តទៅដោយអំណាចនៃមាតិកា ដែលតាំងទុកហើយ ។ តែកាលបើសម្រេចអរហត្តហើយ កិច្ចដោយពាក្យថា មិនគប្បីប្រមាទនូវបញ្ញាជាដើមរមែងមិនមានទៀត ។ ព្រះមានព្រះភាគទ្រង់ដាក់មាតិកាដែលមានធាតុបញ្ចាស់គ្នាហើយ កាលទ្រង់ចែកវិភង្គ ដោយអំណាចតាមធម៌ប៉ុណ្ណោះ ទើបត្រាស់ថា បុគ្គលមិនគួរបណ្តែតបណ្តោយបញ្ញា ដូច្នេះ ។

សួរថា ក្នុងបាទគាថានោះ បុគ្គលណាបណ្តែតបណ្តោយក្នុងបញ្ញា បុគ្គលណាមិនបណ្តែតបណ្តោយ ។ បុគ្គលណាបួសក្នុងសាសនានេះមុនហើយ សម្រេចជីវិតដោយអនេសនា ២១ ដោយអំណាចកម្ម មានវេជ្ជកម្មជាដើម មិនអាចដើម្បីតាំងចិត្តុប្បាទដោយសមគួរដល់បព្វជ្ជា បុគ្គលនេះឈ្មោះថា បណ្តែតបណ្តោយបញ្ញា ។ ឯបុគ្គលណាបួសក្នុងសាសនាហើយតាំងនៅក្នុងសីល រៀនព្រះពុទ្ធវចនៈ សមាទានធុតង្គ ដែលជាសប្បាយ កាន់

យកកម្មដ្ឋានដែលគាប់ចិត្ត អាស្រ័យសេនាសនៈស្ងាត់ ធ្វើកសិណបរិកម្ម ញុំាងសមាបត្តិឲ្យកើតឡើង ចម្រើនវិបស្សនាថា ក្នុងថ្ងៃនេះឯង អរហត្ត ដូច្នេះ ត្រាច់ទៅ បុគ្គលនេះ ឈ្មោះថា មិនបណ្តែតបណ្តោយបញ្ញា ។ តែក្នុងសូត្រនេះ បានត្រាស់ដល់ការមិនបណ្តែតបណ្តោយបញ្ញានោះ ដោយអំណាចនៃធាតុកម្មដ្ឋាន ។ ឯពាក្យណា គប្បីពោលក្នុងធាតុកម្មដ្ឋាននោះ ពាក្យនោះបានពោលហើយ ក្នុងសូត្រទាំងឡាយ មានហត្ថិបទោបមសូត្រជាដើមខាងដើមនោះឯង ។ ក្នុងសូត្រនេះ មានអនុសន្ធិដោយចំពោះថា បន្ទាប់អំពីនោះ វត្ថុដ៏សេសនៅមានទៀត គឺវិញ្ញាណដូច្នេះ ។ ព្រោះបានត្រាស់រូបកម្មដ្ឋានខាងដើមហើយ ។

[ ១៦៣-១៦៥ ] ឥឡូវនេះ ព្រះមានព្រះភាគ ដើម្បីទ្រង់ផ្លាស់នូវការសម្តែងអរូបកម្មដ្ឋាន ដោយអំណាចវេទនា ទើបទ្រង់ប្រារព្ធទេសនានេះ ។ ឬអរូបកម្មដ្ឋាននេះ ដែលជាវិញ្ញាណ អ្នកធ្វើកម្មដោយអំណាចវិបស្សនា ដែលភិក្ខុនេះគប្បីដល់ក្នុងធាតុទាំងឡាយ មានបឋវីធាតុជាដើម ព្រះមានព្រះភាគកាលទ្រង់សម្តែងចែកអរូបកម្មដ្ឋាននោះ ដោយអំណាចវិញ្ញាណធាតុ ទើបទ្រង់ប្រារព្ធទេសនានេះ ។ បណ្តាបទទាំងនោះ បទថា **អវសិស្សតិ** សេចក្តីថា សល់ដើម្បីប្រយោជន៍អ្វី ។ សល់ដើម្បីប្រយោជន៍ដល់ការសម្តែងនៃព្រះសាស្តា និងដើម្បីប្រយោជន៍ដល់ការចាក់ធ្លុះរបស់កុលបុត្រ ។ បទថា **បរិសុទ្ធំ** បានដល់ ប្រាសចាកឧបក្កិលេស ។ បទថា **បរិយោទាតំ** បានដល់ ផូរផង់ ។ បទថា **សុខន្តិបិ បជានាតិ** សេចក្តីថា រមែងដឹងច្បាស់ថា កាលអញសោយ

សុខ ឈ្មោះថា សោយសុខវេទនា ។ ក្នុងបទទាំង ២ ដ៏សេស ក៏ន័យនេះដូចគ្នា ។ បើវេទនាកថានេះមិនបានត្រាស់ខាងដើមសោត ក៏គួរប្រព្រឹត្តទៅដើម្បីត្រាស់ក្នុងសូត្រនេះ ។ វេទនាកថានោះ បានត្រាស់ហើយក្នុងសតិប្បដ្ឋាននោះឯង ព្រោះដូច្នោះ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងសតិប្បដ្ឋាននោះឯង ។ បទជាដើមយ៉ាងនេះ **សុខវេទនីយំ** បានពោលហើយ ដើម្បីសម្តែងការកើតឡើង និងការរលត់ដោយអំណាចបច្ច័យ ។ បណ្តាបទទាំងនោះ បទថា **សុខវេទនីយំ** គឺជាបច្ច័យនៃសុខវេទនា ។ ក្នុងបទដ៏សេសទាំងឡាយ ក៏មានន័យនេះដូចគ្នា ។

[ ១៦៦ ] បទថា **ឧបេក្ខាយេវ អវសិស្សតិ** សេចក្តីថា កូនសិស្សធ្វើកែវមុក្តា ដែលអាចារ្យកែវមណីដ៏ឈ្លាស ដោតពេជ្រដោយម្ជុលយកមកហើយ ទុកទៀតក្នុងបន្ទះស្បែក កាលធ្វើការដោតដោយអំបោះ ឈ្មោះថាធ្វើគ្រឿងប្រដាប់ មានកុណ្ឌលកែវមុក្តា និងសំណាញ់កែវមុក្តាជាដើម យ៉ាងណា កុលបុត្រនេះ កាលមនសិការនូវកម្មដ្ឋានដែលព្រះមានព្រះភាគត្រាស់ឲ្យហើយ ឈ្មោះថា បានធ្វើឲ្យស្ទាត់ជំនាញដូច្នោះដូចគ្នា ព្រោះដូច្នោះ រូបកម្មដ្ឋានក្តី អរូបកម្មដ្ឋានក្តី បានកើតស្ទាត់ជំនាញ ដោយប្រការមានប្រមាណប៉ុណ្ណោះ ។

លំដាប់នោះ ទើបព្រះមានព្រះភាគត្រាស់ថា បន្ទាប់អំពីនោះ សល់ត្រឹមតែឧបេក្ខា ដូច្នេះ ។ សួរថា សល់ដើម្បីអ្វី ឆ្លើយថា ដើម្បីការសម្តែងរបស់ព្រះសាស្តា ។ អាចារ្យពួកខ្លះពោលថា ដើម្បីចាក់ធ្លុះនៃកុលបុត្រដូច្នេះក៏មាន ។

ពាក្យនោះ មិនគួរកាន់យក ។ កុលបុត្របានអានសាសន៍របស់សម្លាញ់ បាន ឈរនៅលើផ្ទៃប្រាសាទ ញុាំងអានាបានចតុត្ថជ្ឈានឲ្យកើតហើយ អានាបាន-ចតុត្ថជ្ឈាននោះ រមែងញុាំងយានកិច្ចរបស់កុលបុត្រនោះ ដែលធ្វើដំណើរមក មានប្រមាណប៉ុណ្ណោះឲ្យសម្រេច ព្រោះដូច្នោះ ទើបសល់ដើម្បីការត្រាស់ របស់ព្រះសាស្តាប៉ុណ្ណោះ ។ ក្នុងឋានៈនេះ ព្រះសាស្តាត្រាស់គុណក្នុងរូបា-វចរជ្ឈានដល់កុលបុត្រ ។ ព្រោះបានត្រាស់ថា **ភិក្ខុ បគុណំ តាវ ឥទំ រូបាវចរចតុត្ថជ្ឈានំ** ម្នាលភិក្ខុ រូបាវចរចតុត្ថជ្ឈាននេះស្ទាត់ជំនាញ ដូច្នេះ ។ បទថា **បរិសុទ្ធា** ជាដើម ជាការសម្តែងគុណនៃឧបេក្ខានោះឯង ។ បទថា **ឧក្កំ ពន្ធេយ្យ** គឺត្រៀមស្នប់ ។ បទថា **អាលិម្បេយ្យ** សេចក្តីថា ដាក់រងើក ភ្លើងក្នុងស្នប់នោះ ហើយដុត សប់ដោយស្នប់ឲ្យឆេះឡើង ។ បទថា **ឧក្កា-មុខេ បក្ខិបេយ្យ** សេចក្តីថា ថ្មៀបរងើកភ្លើងដាក់លើស្នប់ ឬដាក់រងើកភ្លើង លើស្នប់នោះ ។ បទថា **នីហដំ** គឺមានមន្ទិលដែលនាំចេញទៅហើយ ។ បទ ថា **និន្និតកសាវំ** បានដល់ មានទឹកចត់ចេញហើយ ។ បទថា **ឯវមេវ ខោ** សេចក្តីថា ទ្រង់សម្តែងនូវគុណមុនថា ចតុត្ថជ្ឈានុបេក្ខានេះ រមែងមានដើម្បី ប្រយោជន៍ដល់ធម៌ដែលអ្នកប្រាថ្នា ក្នុងបណ្តាធម៌ទាំងនេះ គឺវិបស្សនា អភិញ្ញា និរោធ ភវោក្កន្តិ ដូចមាស តែងប្រព្រឹត្តទៅជាគ្រឿងប្រដាប់ ជាទី ប្រាថ្នា និងត្រូវការហើយ ដូច្នោះ ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមាន ព្រះភាគមិនត្រាស់ទោសដើម្បីការផ្សរផង់ចាកការប្រាថ្នា ក្នុងរូបាវចរចតុត្ថជ្ឈាន នេះ តែត្រាស់គុណទៅវិញ ឆ្លើយថា ព្រោះការប្រកាន់មាំ ការស្រឡាញ់ក្នុង

ចតុត្ថជ្ឈានរបស់កុលបុត្រមានកម្លាំង ។ បើគប្បីត្រាស់ទោសសោត កុល-បុត្រក៏គប្បីដល់នូវការសង្ស័យ គិតមិនយល់ថា កាលអញបួសហើយ ដើរអស់ផ្លូវ ១៩២ យោជន៍ ចតុត្ថជ្ឈាននេះញុំាងយានកិច្ចឲ្យសម្រេចបាន អញមកអស់ផ្លូវប្រមាណប៉ុណ្ណេះ ក៏មកហើយដើម្បីការត្រេកអរក្នុងឈានសុខដោយឈានសុខ ព្រះមានព្រះភាគ ត្រាស់ទោសនៃធម៌ដ៏ប្រណីតបែបនេះទ្រង់ដឹង ឬមិនដឹងហ្ន៎ ទើបត្រាស់ដូច្នេះ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់គុណ ។ ក្នុងបទនេះថា **តទនុធម្មំ** នេះ អរូបាវចរជ្ឈាន ឈ្មោះថា ធម៌ ។ រូបាវចរជ្ឈាន ហៅថា អនុធម៌ ព្រោះជាធម៌អនុលោមតាមអរូបា-វចរជ្ឈាននោះ ។ មួយប្រការទៀត វិបាកជ្ឈាន ឈ្មោះថា ធម៌ កុសលជ្ឈានឈ្មោះថា អនុធម៌ ។ បទថា **តទុបាទានា** គឺការកាន់យកធម៌នោះ ។ បទថា **ចិរំ ទីឃមទ្ធានំ** បានដល់ អស់កាល ២ ម៉ឺនកប្ប ។ ពាក្យនោះត្រាស់ដោយអំណាចនៃវិបាក ។ សូម្បីបទក្រៅអំពីនេះ ក៏មានន័យដូចគ្នា ។

ព្រះមានព្រះភាគ កាលត្រាស់គុណរបស់អរូបាវចរជ្ឈានដោយ ៤ វារៈយ៉ាងនេះហើយ ឥឡូវនេះ កាលទ្រង់សម្តែងទោសនៃអរូបាវចរជ្ឈាននោះទើបត្រាស់ថា អ្នកដឹងច្បាស់យ៉ាងនេះជាដើម ។ បណ្តាបទទាំងនោះ បទថា **សង្ខតមេតំ** សេចក្តីថា ក្នុងបឋមព្រហ្មលោកនោះ មានអាយុ ២ ម៉ឺនកប្បក៏ពិត តែព្រះមានព្រះភាគ កាលទ្រង់ធ្វើចិត្តនោះឲ្យជាការប្រែងប្រៀប គឺការសម្រេច ការកពូន ក៏ទ្រង់រមែងធ្វើ ។ អាយុនោះមិនទៀង មិនស្ថិតស្ថេរ មិនពិតប្រាកដ ម្តងម្កាល មានការឃ្លាតទៅ បែកធ្លាយ និងខ្ចាត់ខ្ចាយជាធម្មតា

ស្របតាមការកើត ត្រូវជរាគ្របសង្កត់ តាំងនៅក្នុងទុក្ខ មិនមានអ្វីតតាំង មិនជាទីពួន មិនជាទីពឹង មិនជាទីអាស្រ័យ ។ ក្នុងវិញ្ញាណាយតនៈជាដើម ក៏ន័យនេះដូចគ្នា ។

ឥឡូវនេះ កាលទ្រង់កាន់យកកំពូលនៃទេសនា គឺអរហត្ត ទើបត្រាស់ថា បុគ្គលនោះ មិនគប្បីគិត ដូច្នេះជាដើម ។ ដូចគ្រូពេទ្យអ្នកឈ្លាស ឃើញការប្រែប្រួលនៃពិសហើយ ធ្វើចិត្តឲ្យពិសឃ្លាតចាកស្ថាន ឲ្យឡើងខាងលើ មិនឲ្យនៅត្រង់ក ឬត្រង់ក្បាល ឲ្យពិសធ្លាក់ចុះទៅក្នុងផែនដី យ៉ាងណា ព្រះមានព្រះភាគ ទ្រង់សម្តែងគុណក្នុងរូបាវចរជ្ឈាន ដល់កុលបុត្រដូច្នោះ ដូចគ្នា ។ កុលបុត្រនោះ ស្តាប់អរូបាវចរជ្ឈាននោះហើយ គ្របសង្កត់ដោយសេចក្តីប្រាថ្នាក្នុងរូបាវចរជ្ឈាន តាំងសេចក្តីប្រាថ្នាក្នុងអរូបាវចរជ្ឈាន ។ ព្រះមានព្រះភាគទ្រង់ដឹងការដែលកុលបុត្រនោះ គ្របសង្កត់សេចក្តីប្រាថ្នាក្នុងរូបាវចរជ្ឈាននោះហើយ ទើបទ្រង់សម្តែងទោសទាំងអស់នោះមួយបទប៉ុណ្ណោះថា **សង្ខតមេតំ** ដូច្នេះ ដល់ភិក្ខុដែលមិនទាន់សម្រេច ដែលមិនទាន់បានអរូបាវចរជ្ឈាននោះថា ឈ្មោះថា សម្បត្តិក្នុងអាកាសានញ្ចាយតនៈជាដើមនោះមានអាយុរបស់អ្នកបានអាកាសានញ្ចាយតនៈជាដើមនោះ ក្នុងព្រហ្មលោកទី ១ មាន ២ ម៉ឺនកប្ប ក្នុងព្រហ្មលោកទី ២ មាន ៤ ម៉ឺនកប្ប ក្នុងព្រហ្មលោកទី ៣ មាន ៦ ម៉ឺនកប្ប ក្នុងព្រហ្មលោកទី ៤ មាន ៨ ម៉ឺន ៤ ពាន់កប្ប តែអាយុនោះ មិនទៀង មិនស្ថិតស្ថេរ មិនពិតប្រាកដ ប្រព្រឹត្តទៅមួយរយៈមានការឃ្លាតទៅ បែកធ្លាយ និងខ្ចាត់ខ្ចាយជាធម្មតា អនុលោមតាមការកើត

ត្រូវជាពុកកាន មរណៈគ្របសង្កត់ តាំងនៅក្នុងទុក្ខ មិនមានអ្វីតតាំង មិនជាទីពួន មិនជាទីពឹង មិនជាទីអាស្រ័យ សូម្បីសោយសម្បត្តិក្នុងព្រហ្មលោកនោះ អស់កាលមានប្រមាណប៉ុណ្ណោះ ធ្វើកាលកិរិយាទាំងជាបុថុជ្ជន ហើយគប្បីធ្លាក់ទៅក្នុងអបាយ ៤ ទៀត ។ កុលបុត្របានស្តាប់ព្រះពុទ្ធវចនៈនោះហើយ ក្តួចចិត្តមាំ ប្រាថ្នាក្នុងអរូបាចរជ្ឈាន ។

ព្រះមានព្រះភាគ កាលទ្រង់ជ្រាបថា កុលបុត្រនោះ មានចិត្តក្តួចមាំ ប្រាថ្នាក្នុងរូបាវចរ និងអរូបាវចរហើយ កាលទ្រង់កាន់យកកំពូល គឺអរហត្ត ទើបត្រាស់ថា **សោ នេវាភិសង្ខរោតិ ...** បុគ្គលនោះ ក៏លែងតាក់តែង ... ដូច្នេះជាដើម ។ មហាយោធ គឺអ្នកចម្បាំងធំម្នាក់ ញុំាងព្រះរាជាមួយអង្គឲ្យពេញព្រះរាជហឫទ័យហើយ ទើបបានស្រុកសួយ ដែលមានតម្លៃមួយសែន ។ ព្រះរាជាទ្រង់រឭកដល់អានុភាព នៃមហាយោធនោះថា យោធមានអានុភាពច្រើន គេបានទ្រព្យតិច ដូច្នេះ ទើបព្រះរាជទានទៀតថា នែបា ស្រុកនេះមិនសមគួរដល់អ្នក អ្នកចូរទទួលយកស្រុកដទៃ ដែលមានតម្លៃ ៤ សែន ។ គាត់ទទួលព្រះបរមរាជឱង្ការថា សាធុ ព្រះអង្គ លះស្រុកនោះហើយ ទទួលយកស្រុកនេះ ។ ព្រះរាជាត្រាស់ឲ្យហៅមហាយោធនោះ ដែលមិនទាន់បានស្រុកនោះឯង ទ្រង់បញ្ជូនទៅថា អ្នកមានប្រយោជន៍អ្វីដោយស្រុកនោះ អហិវាតករោគ កំពុងកើតក្នុងស្រុកនោះ តែក្នុងទីឯណោះ មាននគរធំ អ្នកគប្បីលើកឆត្រសោយរាជ្យក្នុងនគរនោះចុះ ដូច្នេះ មហាយោធនោះគប្បីសោយរាជ្យយ៉ាងនោះ ។ ក្នុងសេចក្តីនោះ គប្បីឃើញព្រះសម្មាសម្ពុទ្ធដូច

ព្រះរាជា ។ បុក្កុសាតិកុលបុត្រ ដូចជាមហាយោធ អានាបានចតុត្ថជ្ឈាន ដូចស្រុកដែលបានដំបូង ។ ការឲ្យធ្វើការកួចចិត្ត ស្រឡាញ់ក្នុងអានាបា-នជ្ឈាន ហើយត្រាស់អរូប ដូចកាលឲ្យមហាយោធលះស្រុកនោះ ហើយត្រាស់ថា អ្នកចូរកាន់យកស្រុកនេះ ។ ការដែលកុលបុត្រដោះនូវការប្រាថ្នាក្នុងសមាបត្តិទាំងនោះ ទាំងដែលមិនទាន់បានដល់ ដោយការសម្តែងទោសក្នុងអរូបថា **សង្ខតមេតំ** ហើយទ្រង់កាន់យកទេសនាដោយកំពូល គឺអរហត្តក្នុងខាងលើ ដូចកាលដែលត្រាស់ឲ្យហៅមហាយោធដែលមិនទាន់ដល់ស្រុកនោះ ហើយត្រាស់ថា អ្នកមានប្រយោជន៍អ្វីដោយស្រុកនោះ អហិវាតករោគកំពុងកើតក្នុងស្រុកនោះ ក្នុងទីនោះ មាននគរ អ្នកចូរលើកឆត្រ សោយរាជ្យក្នុងនគរនោះចុះ ។

បណ្តាបទទាំងនោះ បទថា **នេវ អភិសង្ខរោតិ** គឺមិនសន្សំ បានដល់មិនធ្វើឲ្យជាគំនរ ។ បទថា **ន អភិសញ្ចេតយតិ** គឺមិនឲ្យសម្រេច ។ បទថា **ភវាយ វា វិភវាយ វា** បានដល់ ដើម្បីការចម្រើន ឬដើម្បីការវិនាស ។ គប្បីប្រកបដោយអំណាចនៃសស្សតៈ និងឧច្ឆេទ ។ បទថា **ន កិញ្ចិ លោកេ ឧបាទិយតិ** សេចក្តីថា មិនប្រកាន់ គឺស្ទាបអង្អែលនូវធម៌ណាមួយ ក្នុងធម៌ទាំងឡាយ មានរូបជាដើមក្នុងលោកដោយតណ្ហា ។ បទថា **នាបរំ ឥត្ថត្តា-យាតិ បជានាតិ** សេចក្តីថា ព្រះមានព្រះភាគទ្រង់តាំងនៅក្នុងពុទ្ធវិស័យនៃព្រះអង្គ ទ្រង់កាន់យកកំពូល គឺអរហត្តដោយទេសនា ។ ឯកុលបុត្រចាក់ធ្លុះសាមញ្ញផល ៣ តាមឧបនិស្ស័យរបស់ខ្លួន ។ ព្រះធម្មរាជាសោយភោជន

មានរសផ្សេងៗ ដោយភាជនៈមាស ទ្រង់ពូតដុំបាយដោយប្រមាណរបស់ព្រះអង្គ កាលព្រះរាជកុមារប្រថាប់គង់លើផ្លូវ សម្តែងសេចក្តីអាល័យក្នុងដុំបាយ ទ្រង់គប្បីបង្អោនដុំបាយនោះ ។ កុមារទ្រង់ធ្វើដុំបាយដោយប្រមាណព្រះឱស្ឋរបស់ព្រះអង្គ ព្រះរាជាទ្រង់សោយពំនូតបាយដ៏សេសដោយព្រះអង្គឯង ឬទ្រង់ដាក់ក្នុងចាន យ៉ាងណា ព្រះតថាគតជាធម្មរាជាក៏ដូច្នោះ កាលទ្រង់កាន់យកកំពូល គឺអរហត្ត ដោយប្រមាណព្រះអង្គទ្រង់សម្តែងទេសនា ។ កុលបុត្រចាក់ធ្លុះសាមញ្ញផល ៣ តាមឧបនិស្ស័យរបស់ខ្លួន ។ ក្នុងកាលមុនអំពីនេះ កុលបុត្រនោះសម្តែងកថា ដែលប្រកបដោយត្រៃលក្ខណ៍ ដែលមានការទទេក្រៃលែងបែបនេះថា ខន្ធ ធាតុ អាយតនៈទាំងឡាយ រមែងមិនកន្ទារមែងមិនសង្ស័យថា បានឮថា មិនមែនជាយ៉ាងនោះ សេចក្តីនោះ អាចារ្យរបស់អញពោលហើយយ៉ាងនេះ ជ្រាបថា ភាពជាបុគ្គលល្ងង់ខ្លៅ ភាពជាបុគ្គលខុស មិនមានដោយប្រការដូច្នេះ ។ បានឮថា ក្នុងឋានៈខ្លះ ព្រះពុទ្ធទាំងឡាយទ្រង់ទៅដោយភេទ ដែលបុគ្គលមិនអាចដឹងបាន ។ មានសេចក្តីសង្ស័យ មានការងឿងឆ្ងល់ថា នុ៎ះជាព្រះសម្មាសម្ពុទ្ធ ឬមិនមែនហ្ន៎ ។ ព្រោះកុលបុត្រនេះចាក់ធ្លុះអនាគាមិផលហើយក្នុងកាលនោះ ទើបសម្រេចចិត្តថា បុគ្គលនេះ គឺព្រះសាស្តារបស់អញ ។ សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វីទើបកុលបុត្រមិនសម្តែងទោស ដែលប្រព្រឹត្តកន្លង ឆ្លើយថា ព្រោះមិនមានឱកាស ។ ព្រះមានព្រះភាគទ្រង់ធ្វើភារៈមិនដាច់ហើយ ដោយមាតិកា តាមដែលទ្រង់លើកឡើងហើយ ទើបទ្រង់សម្តែងទេសនា ដូចទ្រង់ឲ្យឈានចុះ

អាកាសអត្ថា ដូច្នោះឯង ។ បទថា **សោ** គឺអរហន្តនោះ ។ បទថា **អនជ្ឈោ-សិតា** សេចក្ដីថា ដឹងច្បាស់ថា មិនគួរហើយ ដើម្បីលេបជាប់ចិត្ត កាន់យក ។ បទថា **អនភិនន្ទិតា** គឺដឹងច្បាស់ថា មិនគួរហើយ ដើម្បីត្រេកអរដោយអំណាចនៃតណ្ហា និងទិដ្ឋិ ។ បទថា **វិសំយុត្តោ ន វេទិយតិ** សេចក្ដីថា បើរាគានុស័យ ព្រោះប្រារព្ធសុខវេទនា បដិឃានុស័យ ព្រោះប្រារព្ធទុក្ខវេទនា អវិជ្ជានុស័យ ព្រោះប្រារព្ធវេទនាក្រៅអំពីនេះ គប្បីកើតដល់បុគ្គលនោះសោត បុគ្គលនោះ ក៏ឈ្មោះថា ប្រកបព្រមហើយសោយ ។

តែព្រោះមិនកើត ទើបមិនឈ្មោះថា មិនប្រកបព្រមហើយសោយ គឺរលាស់ចេញហើយ ផុតវិសេសហើយ ។ បទថា **កាយបរិយន្តិកំ** សេចក្ដីថា វេទនាដែលកើតឡើងមានកាយជាទីបំផុត រហូតដល់ការប្រព្រឹត្តិទៅនៃកាយ បន្ទាប់ពីនោះក៏មិនកើត ។ សូម្បីក្នុងបទទី ២ ក៏មានន័យនេះដូចគ្នា ។ បទថា **អភិនន្ទិតានិ សីតិភវិស្សន្តិ** សេចក្ដីថា ការសោយអារម្មណ៍ទាំងអស់ ឈ្មោះថា មិនត្រេកអរហើយ ព្រោះកិលេសទាំងឡាយមិនមានពិសេសក្នុងអាយតនៈ ១២ ទើបរលត់ក្នុងអាយតនៈ ១២ នោះឯង ។ កិលេសទាំង-ឡាយ សូម្បីរលត់ហើយ ព្រោះមកដល់និព្វាន រមែងមិនមានក្នុងទីណា ហៅថា រលត់ហើយក្នុងទីនោះ ។ អត្ថនេះ គប្បីសម្ដែងដោយសមុទយប្បញ្ញាថា តណ្ហានោះ កាលរលត់ រមែងរលត់ក្នុងទីនោះ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់ថា ការសោយអារម្មណ៍ទាំងអស់ ជាធម្មជាតស្ងប់ហើយ ព្រោះអាស្រ័យនិព្វាន និងជារបស់ស្ងប់ក្នុងលោកនេះឯង ។ សួរថា ព្រះមាន

ព្រះភាគត្រាស់ការសោយអារម្មណ៍ទាំងឡាយ ក្នុងទីនេះមិនមែនឬ ហេតុអ្វីទើបមិនត្រាស់កិលេសទាំងឡាយ ឆ្លើយថា ព្រោះការសោយអារម្មណ៍ទាំង-ឡាយ នឹងជារបស់ស្ងប់ ព្រោះមិនមានកិលេសនោះឯង ។ ធម្មតាការសោយអារម្មណ៍ទាំងឡាយជារបស់ស្ងប់ មិនមានក្នុងឋានៈក្រៅអំពីនោះ ព្រោះដូច្នោះពាក្យនោះ លោកពោលល្អហើយ ។ នេះជាការប្រៀបធៀបឧបមា ក្នុងបទនេះថា **ឯវមេវ ខោ** ។ ដូចបុរសម្នាក់ កាលប្រទីបប្រេងកំពុងឆេះ កាលប្រេងអស់ហើយ ក៏បន្ថែមប្រេងទាំងនោះ កាលប្រឆេះអស់ ក៏ដាក់ប្រឆេះកាលបើដូច្នោះ អណ្តាតប្រទីបក៏មិនរលត់ យ៉ាងណា បុថុជ្ជនក៏ដូច្នោះដូចគ្នាតាំងនៅក្នុងភពមួយ រមែងធ្វើកុសល និងអកុសល បុគ្គលនោះក៏នឹងកើតក្នុងសុគតិ និងអបាយទាំងឡាយ ព្រោះកុសល និងអកុសលនោះ កាលបើដូច្នោះ វេទនាទាំងឡាយក៏មិនដាច់សូន្យនោះឯង ។ មួយវិញទៀត បុគ្គលម្នាក់អផ្សុកក្នុងអណ្តាតប្រទីប ដោយគិតថា ព្រោះអាស្រ័យបុរសនេះ ទើបអណ្តាតប្រទីបនេះមិនរលត់ ដូច្នេះ គប្បីកាត់ក្បាលរបស់បុរសនោះ ។ ព្រោះមិនដាក់ប្រឆេះ និងមិនបន្ថែមប្រេងយ៉ាងនោះ អណ្តាតប្រទីបដែលអស់ពូជ ក៏រមែងរលត់ យ៉ាងណា ព្រះយោគាវចរអផ្សុកក្នុងបវត្តិកាលក៏ដូច្នោះដូចគ្នា រមែងកាត់ផ្តាច់នូវកុសល និងអកុសលដោយអរហត្តមគ្គ ។ ព្រោះកុសលនោះត្រូវកាត់ផ្តាច់ហើយ ការសោយអារម្មណ៍ទាំងឡាយ រមែងមិនកើតឡើងទៀតដល់ភិក្ខុដែលជាខីណាស្រព ព្រោះការបែកធ្លាយនៃកាយ ដូច្នេះ ។

[ ១៦៧ ] បទថា **តស្មា** សេចក្តីថា ព្រោះអរហត្តផលប្បញ្ញាក្រៃលែង

ជាងសមាធិប្បញ្ញា និងវិបស្សនាបញ្ញាខាងដើម ។ បទថា **ឯវំ សមន្នាគតោ** សេចក្តីថា បុគ្គលប្រកបព្រមដោយអរហត្តផលប្បញ្ញា ដែលជាធម៌គួរតាំងទុកក្នុងចិត្តដ៏ឧត្តមនេះ ។ ញាណក្នុងអរហត្តមគ្គ ឈ្មោះថា ញាណក្នុងការអស់ទៅនូវទុក្ខទាំងពួង ។ តែក្នុងសូត្រនេះ ទ្រង់បំណងយកញាណក្នុងអរហត្តផល ។ ព្រោះហេតុនោះឯង ទើបត្រាស់ថា ការរួចផុតរបស់បុគ្គលនោះ ចាត់ថា តាំងនៅក្នុងសច្ចៈ ជាគុណមិនកម្រើក ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **វិមុត្តិ** បានដល់ អហរត្តផលវិមុត្តិ ។ បទថា **សច្ចំ** បានដល់ បរមត្ថសច្ច គឺនិព្វាន ។ ការរួចផុតនោះ ត្រាស់ថា មិនកម្រើក ព្រោះធ្វើអារម្មណ៍ដែលមិនកម្រើក ដោយប្រការដូច្នេះ ។ បទថា **មុសា** បានដល់ មិនពិត ។ បទថា **មោសធម្មំ** បានដល់ សភាពដែលវិនាស ។ បទថា **តំ សច្ចំ** សេចក្តីថា សច្ចៈនោះជារបស់ពិត មានសភាវៈ ។ បទថា **អមោសធម្មំ** បានដល់ មានសភាពមិនវិនាស ។ បទថា **តស្មា** សេចក្តីថា ព្រោះបរមត្ថ-សច្ច គឺនិព្វាននោះឯង ខ្ពស់ជាងវចីសច្ចៈ ទុក្ខសច្ច និងសមុទយសច្ចៈ ដោយអំណាចនៃសមថៈ និងវិបស្សនាជាដើម ។ បទថា **ឯវំ សមន្នាគតោ** សេចក្តីថា ប្រកបព្រមដោយបរមត្ថសច្ចាធិដ្ឋានដ៏ខ្ពស់ ។ បទថា **បុព្វេ** គឺក្នុងកាលជាបុថុជ្ជន ។ បទថា **ឧបធីហោន្តិ** បានដល់ ឧបធិទាំងនេះ គឺកិលេសូបធិ អភិសង្ខារូបធិ បញ្ចកាមគុណូបធិ ។ បទថា **សមត្តា សមាទិន្នា** សេចក្តីថា បរិបូណ៌ គឺកាន់យកហើយ បានដល់ បពោសអង្អែលហើយ ។ បទថា **តស្មា**

សេចក្តីថា ព្រោះការលះបង់កិលេស ដោយអរហត្តមគ្គនោះឯង ល្អជាងការលះកិលេសដោយអំណាចនៃសមថៈ និងវិបស្សនាជាដើម និងល្អជាងការលះកិលេសដោយសោតាបត្តិមគ្គជាដើម ។ បទថា **ឯវំ សមន្នាគតោ** គឺប្រកបព្រមហើយដោយចាគាធិដ្ឋានដ៏ឧត្តមនេះ ។ ឈ្មោះថា **អាឃាត** ក្នុងបទថា **អាឃាតោ** នេះ ព្រោះធ្វើនូវការបំផ្លាញ ។ ឈ្មោះថា **ព្យាបាទ** ព្រោះការប្រទូស្ត ។ ឈ្មោះថា **សម្បទោស** ព្រោះប្រទូស្តគ្រប់យ៉ាង ។ លោកពោលអកុសលមូលប៉ុណ្ណោះដោយបទទាំង ៣ ។ បទថា **តស្មា** សេចក្តីថា ព្រោះការស្ងប់រម្ងាប់កិលេស ដោយអរហត្តមគ្គនោះឯង ខ្ពស់ជាងការស្ងប់រម្ងាប់កិលេស ដោយអំណាចនៃសមថៈ និងវិបស្សនាអំពីខាងដើម និងការស្ងប់រម្ងាប់កិលេស ដោយសោតាបត្តិមគ្គជាដើម ។ បទថា **ឯវំ សមន្នាគតោ** សេចក្តីថា បុគ្គលប្រកបដោយឧបសមាធិដ្ឋានដ៏ឧត្តមនេះ ។

[ ១៦៨ ] បទថា **មញ្ញិតមេតំ** សេចក្តីថា ការសម្គាល់ ៣ យ៉ាង គឺតណ្ហាមញ្ញិត មានមញ្ញិត ទិដ្ឋិមញ្ញិត រមែងប្រព្រឹត្តទៅ ។ បទថា **អស្មី-មហំ** ក្នុងបទថា **អហាមស្មិ** គឺការសម្គាល់តណ្ហានោះឯង រមែងប្រព្រឹត្តទៅ ឈ្មោះថា **រោគ** ព្រោះអត្ថថា បៀតបៀន ក្នុងបទថា **រោគោ** ជាដើម ។ ឈ្មោះថា **គណ្ឌ** ព្រោះអត្ថថា ប្រទូស្តខាងក្នុង ។ ឈ្មោះថា **សល្ល** ព្រោះអត្ថថា ចាក់ដោតរឿយៗ ។ បទថា **មុនិ សន្តោតិ វុច្ចតិ** សេចក្តីថា បុគ្គលនោះហៅថា មុនី ជាព្រះខីណាស្រពស្ងប់ហើយ គឺស្ងប់រម្ងាប់ហើយ រម្ងត់ទុក្ខ

ហើយ ។ បទថា **យត្ថ ឋិតំ** គឺតាំងនៅក្នុងឋានៈណា ។ បទថា **សង្ខិត្តេន** សេចក្ដីថា ព្រះធម្មទេសនាទាំងអស់របស់ព្រះពុទ្ធទាំងឡាយ ក៏សង្ខេបហើយនោះឯង ។ ឈ្មោះថា ទេសនាដោយពិស្ដារមិនមាន ។ សូម្បីសមន្តប្បដ្ឋានកថាក៏សង្ខេបហើយដូចគ្នា ព្រះមានព្រះភាគ ទ្រង់ញ៉ាំងទេសនាឲ្យដល់តាមអនុសន្ធិ ដោយប្រការដូច្នេះ ។ ក្នុងបុគ្គល ៤ ពួក មានឧគ្ឃដិតញ្ញូជាដើម បុក្កុសាតិកុលបុត្រជាវិបចិតញ្ញូ ។ ព្រះមានព្រះភាគ ទ្រង់សំដែងធាតុវិភង្គសូត្រនេះ ដោយអំណាចនៃវិបចិតញ្ញូ ដោយប្រការដូច្នេះ ។ ក្នុងពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន បាត្រ និងចីវររបស់ខ្ញុំព្រះអង្គ មិនទាន់មានគ្រប់គ្រាន់ទេ ។ មានពាក្យសួរថា ព្រោះហេតុអ្វី បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិមិនកើតឡើងដល់កុលបុត្រ ឆ្លើយថា ព្រោះបរិក្ខារ ៨ យ៉ាង កុលបុត្រមិនធ្លាប់ឲ្យទានហើយក្នុងកាលមុន ។ កុលបុត្រមានទានធ្លាប់ថ្វាយហើយ មានអភិនីហារបានធ្វើហើយ ទើបមិនគួរពោលថា ព្រោះទានមិនធ្លាប់ឲ្យហើយ ។ បាត្រ និងចីវរសម្រេចអំពីឫទ្ធិរមែងកើតដល់សាវកទាំងឡាយដែលមានភពចុងក្រោយប៉ុណ្ណោះ ឯកុលបុត្រនេះ នៅមានបដិសន្ធិទៀត ។ ព្រោះដូច្នោះ ទើបបាត្រ និងចីវរ ដែលសម្រេចដោយឫទ្ធិមិនកើតឡើង ។ សួរថា បើដូច្នោះ ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់មិនស្វែងរកដោយព្រះអង្គឯងឲ្យដល់ព្រម ឆ្លើយថា ព្រោះព្រះអង្គមិនមានឱកាស ។ អាយុរបស់កុលបុត្រក៏អស់ហើយ ។ មហាព្រហ្មដែលជាអនាគាមីជាន់សុទ្ធាវាសក៏ហាក់បីដូចមកកាន់សាលានាយស្មូនឆ្នាំង ហើយអង្គុយ ។ ព្រោះដូច្នោះ ទើប

ទ្រង់មិនស្វែងរកដោយព្រះអង្គឯង ។

[ ១៧១ ] បទថា **បត្តចីវរំ បរិយេសនំ បក្កាមិ** សេចក្ដីថា បុក្កុសាតិ ចៀសទៅក្នុងវេលា កាលអរុណរះឡើងហើយ ។

បានឮថា ការចប់ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ ការរះឡើងនៃអរុណ និងការបញ្ចេញព្រះរស្មីមានក្នុងខណៈជាមួយគ្នា ។ បានឮថា ព្រះមានព្រះភាគ ទ្រង់បញ្ចប់ព្រះទេសនាហើយ ទ្រង់បញ្ចេញព្រះរស្មី មានពណ៌ ៦ ប្រការ ។ និវេសន៍នៃជាងឆ្នាំងទាំងមូលនោះក៏ក្លាយមានពណ៌ដូចគ្នាតែមួយ ។ ព្រះឆព្វណ្ណរង្សីផ្ទៀលធ្វាត់ផ្សាយទៅជាក្រុមៗ ធ្វើទិសទាំងពួងឲ្យដូចគ្របដណ្ដប់ដោយបន្ទះមាស និងរុងរឿងដូចផ្កាជកគាំ និងរតនៈដ៏ប្រសើរ មានពណ៌ផ្សេងៗ ។ ព្រោះព្រះមានព្រះភាគទ្រង់អធិដ្ឋានថា សូមឲ្យអ្នកនគរទាំងឡាយឃើញតថាគត ដូច្នេះ ។ អ្នកនគរទាំងឡាយឃើញព្រះមានព្រះភាគ ក៏ប្រាប់តៗ គ្នាថា បានឮថា ព្រះសាស្ដាយាងមកហើយ បានឮថា ប្រថាប់គង់ក្នុងសាលានាយស្មូនឆ្នាំង ហើយក្រាបទូលដល់ព្រះរាជា ព្រះរាជាយាងទៅថ្វាយបង្គំព្រះសាស្ដា ហើយត្រាស់សួរថា ព្រះអង្គយាងមកហើយពីអង្កាល់ណា ។ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ កាលព្រះអាទិត្យអស្ដង្គតម្សិលមិញនេះ ។ ព្រះរាជាត្រាស់ថា ព្រះមានព្រះភាគយាងមកដោយកម្មអ្វី ព្រះមានព្រះភាគត្រាស់ថា បុក្កុសាតិសម្លាញ់របស់មហាបពិត្រ ស្ដាប់ព្រះរាជសាសន៍ដែលមហាបពិត្របញ្ជូនទៅ ហើយស្ដេចចេញបួស ទ្រង់យាងមកចំពោះតថាគតហួសក្រុងសាវត្ថីអស់ ៤៥ យោជន៍ ចូលកាន់សាលាស្មូនឆ្នាំង

នេះ ហើយប្រថាប់គង់ ទើបតថាគតមកដើម្បីសង្គ្រោះសម្លាញ់របស់មហាបពិត្រ បានសម្តែងធម្មកថា កុលបុត្រនោះសម្រេចផល ៣ ។ ព្រះរាជាពោលថា បពិត្រព្រះអង្គដ៏ចម្រើន ពេលនេះ ព្រះបាទបុក្កុសាតិនៅទីណា ។ ព្រះមានព្រះភាគត្រាស់ថា ស្តេចបុក្កុសាតិកុលបុត្រសូមឧបសម្បទាហើយ ចេញទៅដើម្បីស្វែងរកបាត្រ និងចីវរ ព្រោះបាត្រ និងចីវរមិនគ្រប់បរិបូណ៌ ។ ព្រះរាជាយាងទៅទិសដែលកុលបុត្រយាងទៅ ។ ឯព្រះមានព្រះភាគទ្រង់ហោះទៅប្រាកដក្នុងព្រះគន្ធកុដិ ក្នុងវត្តជេតពននោះឯង ។ សូម្បីកុលបុត្រ កាលស្វែងរកបាត្រ និងចីវរ ក៏មិនទៅកាន់សម្នាក់របស់ព្រះបាទពិម្ពិសារ និងរបស់ពួកឈ្មួញថ្មើរជើងអ្នកក្រុងតក្កសិលា ។ បានឮថា កុលបុត្រនោះគិតយ៉ាងនេះថា ការដែលជ្រើសរើសយកបាត្រ និងចីវរដែលពេញចិត្ត និងមិនពេញចិត្តក្នុងសម្នាក់នោះៗឯង មិនសមគួរដល់អញ ដូចមានព្រះនគរធំ ចាំអញនឹងស្វែងរកត្រង់កំពង់ទឹក ទីប៉ាធា គំនរសំរាម និងតាមច្រក ដូច្នេះ ។ កុលបុត្រប្រារព្ធដើម្បីស្វែងរកសេសសំពត់ត្រង់គំនរសំរាម ក្នុងច្រកមុន ។

បទថា **ជីវិតា វោរោបេសិ** សេចក្តីថា មេគោកូនខ្ចីរត់បុះកុលបុត្រនោះដែលកំពុងសម្លឹងមើលសេសសំពត់ ក្នុងគំនរសំរាមមួយកន្លែង ឲ្យប៉ើងឡើងលើ ដល់នូវការស្លាប់ កុលបុត្រត្រូវសេចក្តីឃ្លានគ្របសង្កត់ ដល់នូវការអស់អាយុក្នុងអាកាសនោះឯង ធ្លាក់ចុះមក ដេកផ្កាប់មុខ ក្នុងគំនរសំរាម ដូចបដិមាសដូច្នោះ ។ កាលធ្វើកាលកិរិយាហើយ ទៅកើតព្រហ្មលោកជាន់អវិហា ។ លុះកើតហើយក៏សម្រេចអរហត្ត បានឮថា ជនដែលគ្រាន់តែកើតហើយក្នុង

អវិហាព្រហ្មលោក មាន ៧ នាក់ បានសម្រេចអរហត្ត សមដូចពាក្យដែលលោកពោលថា

ភិក្ខុ ៧ រូប ចូលដល់អវិហាព្រហ្មលោក ហើយរួចផុត មានរាគៈ និងទោសៈអស់ហើយ ឆ្លងតណ្ហាក្នុងលោក ហើយលោកទាំងនោះ ឆ្លងភក់ដែលជាអន្ទាក់មច្ចុរាជ ដែលគេឆ្លងបានដោយក្រ លោកទាំងនោះ លះបង់យោគរបស់មនុស្ស ហើយ ចូលដល់យោគដែលជាទិព្វ ។

លោកទាំងនោះ គឺឧបកៈ ១ បលគណ្ឌៈ ១ បុក្កុសាតិ ១ រួមជា ៣ ភទ្ទិយៈ ១ ខណ្ឌទេវៈ ១ ពាហុទត្តិ ១ បិង្គិយៈ ១ លោកទាំងនោះ លះយោគរបស់មនុស្ស ហើយចូលដល់យោគដែលជាទិព្វ ដូច្នេះ ។

ចំណែកព្រះបាទពិម្ពិសារ ទ្រង់ព្រះរាជតម្រិះថា សម្លាញ់អញបានអានត្រឹមតែរាជសាសន៍ដែលអញផ្ញើទៅ ទ្រង់លះរាជសម្បត្តិដែលនៅក្នុងកណ្ដាប់ដៃ ធ្វើដំណើរមកអស់ចម្ងាយប្រមាណប៉ុណ្ណេះ កិច្ចដែលធ្វើបានលំបាក កុលបុត្របានធ្វើហើយ អញនឹងធ្វើសក្ការៈដល់ទ្រង់ ដោយគ្រឿងសក្ការៈរបស់បព្វជិត ដូច្នេះហើយ ទើបត្រាស់ថា ពួកអ្នកទាំងឡាយ ចូរតាមរកសម្លាញ់របស់ខ្ញុំ ដូច្នេះ ។ រាជបរិវារទាំងឡាយដែលត្រូវបញ្ជូនទៅក្នុងទីនោះៗ បានឃើញកុលបុត្រនោះ ។ ឃើញលោកដួលចុះត្រង់គំនរសំរាម ត្រឡប់មកទូលដល់ព្រះរាជា ។ ព្រះរាជាយាងទៅឃើញកុលបុត្រហើយ ទ្រង់ព្រះកន្សែងថា ឱ អ្នកទាំងឡាយ ពួកយើងមិនបានធ្វើសក្ការៈដល់សម្លាញ់ហ្ន៎

សម្លាញ់របស់ខ្ញុំ មិនមានទីពឹងហើយ ត្រាស់ឲ្យនាំកុលបុត្រដោយគ្រែ តម្កល់ទុកក្នុងឱកាសដ៏សមគួរ ត្រាស់ហៅអ្នកងូតទឹក ឲ្យងូតទឹកឲ្យ និងខ្វាន់ព្រះកេសជាដើម ដោយឲ្យដឹងដល់ការធ្វើសក្ការៈដល់កុលបុត្រ ដែលមិនទាន់បានឧបសម្បទា ទ្រង់ឲ្យងូតព្រះសីសៈរបស់កុលបុត្រ ទ្រង់ឲ្យស្លៀកសំពត់បរិសុទ្ធជាដើម ទ្រង់ឲ្យតាក់តែងដោយភេទជាព្រះរាជា ទ្រង់លើកឡើងកាន់វិមាស ទ្រង់ឲ្យធ្វើការបូជាដោយវត្ថុទាំងឡាយ មានតន្ត្រី គ្រឿងក្រអូប និងមាលាគ្រប់យ៉ាងជាដើម ទ្រង់នាំចេញចាកព្រះនគរ ទ្រង់ឲ្យធ្វើមហាចិត្រកាធារ ដោយឈើក្រអូបដ៏ច្រើន កាលទ្រង់ធ្វើសរីរកិច្ចរបស់កុលបុត្រហើយ ទ្រង់នាំយកព្រះធាតុមកប្រតិស្ឋានក្នុងព្រះចេតិយ ។ ពាក្យដ៏សេស ក្នុងបទទាំងពួង ងាយយល់ ទាំងអស់ហើយ ៕០៚

## អដ្ឋកថា ធាតុវិភង្គសូត្រ ចប់

## សូត្រទី ១០ ចប់

# សុត្តន្តបិដក

## សច្ចវិភង្គសូត្រទី ១១

[ ១៧៣ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ។ ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ១៧៤ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ធម្មចក្កដ៏ប្រសើរ ដែលតថាគតជាអរហន្តសម្មាសម្ពុទ្ធ ឲ្យប្រព្រឹត្តទៅក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ជាធម្មចក្កដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី នរណាមួយក្តីក្នុងលោក មិនអាចធ្វើបដិវត្តិបាន គឺការប្រាប់ ការសម្តែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយនូវអរិយសច្ចទាំង ៤ អរិយសច្ចទាំង ៤ តើដូចម្តេច គឺការប្រាប់ ការសម្តែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយ នូវទុក្ខអរិយសច្ច ១ ការប្រាប់ ការសម្តែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយ នូវទុក្ខ-សមុទយអរិយសច្ច ១ ការប្រាប់ ការសម្តែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយ នូវទុក្ខនិរោធអរិយសច្ច ១ ការប្រាប់ ការសម្តែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ម្នាលភិក្ខុទាំងឡាយ ធម្ម-

ចក្រដ៏ប្រសើរ ដែលតថាគតជាអរហន្តសម្មាសម្ពុទ្ធ ឲ្យប្រព្រឹត្តទៅក្នុងឥសិ-បតនមិគទាយវ័ន ជិតក្រុងពារាណសី ជាធម្មចក្រដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី នរណាមួយក្តីក្នុងលោក មិនអាចធ្វើបដិវត្តិបាន គឺការប្រាប់ ការសំដែង ការបញ្ញត្ត ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយ នូវអរិយសច្ចទាំង ៤ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរសេពនូវសារីបុត្រ និងមោគ្គល្លានចុះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរគប់រកសារីបុត្រ និងមោគ្គល្លានចុះ ព្រោះសារីបុត្រ និងមោគ្គ-ល្លាន ជាបណ្ឌិតភិក្ខុ ជាអ្នកអនុគ្រោះសព្រហ្មចារីទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្រ ប្រៀបដូចជាម្តាយបង្កើតកូន ។ មោគ្គល្លានប្រៀបដូចជាអ្នកចិញ្ចឹមកូនដែលកើតហើយ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្រទូន្មានបុគ្គល ក្នុងសោតាបត្តិផល មោគ្គល្លានទូន្មានបុគ្គលក្នុងប្រយោជន៍ដ៏ខ្ពង់ខ្ពស់ ម្នាលភិក្ខុទាំងឡាយ សារីបុត្រអាចប្រាប់ សំដែង បញ្ញត្ត តែងតាំង បើក វែកញែក ធ្វើឲ្យងាយនូវអរិយសច្ចទាំង ៤ ដោយពិស្តារបាន ។ ព្រះមានព្រះភាគ បានសំដែងពាក្យនេះរួចហើយ លុះព្រះសុគត ទ្រង់សំដែងសេចក្តីនេះរួចហើយ ក៏ក្រោកអំពីអាសនៈ ហើយស្តេចចូលទៅកាន់វិហារ ។

[ ១៧៥ ] កាលដែលព្រះមានព្រះភាគ ស្តេចចៀសចេញទៅមិនយូរប៉ុន្មាន ព្រះសារីបុត្រមានអាយុ ក៏ហៅភិក្ខុទាំងឡាយក្នុងទីនោះថា នែអាវុសោទាំងឡាយ ។ ភិក្ខុទាំងនោះ ក៏ទទួលពាក្យព្រះសារីបុត្រមានអាយុថា អើអាវុសោ ។ ព្រះសារីបុត្រមានអាយុពោលដូច្នេះថា នែអាវុសោទាំងឡាយ

ធម្មចក្រដ៏ប្រសើរ ដែលព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បានឲ្យប្រព្រឹត្តទៅ ក្នុងឥសិបតនមិគទាយវ័ន ជិតក្រុងពារាណសី ជាធម្មចក្រដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី នរណាមួយក្តីក្នុងលោក មិនអាចធ្វើបដិវត្តិបាន គឺការប្រាប់ ការសំដែង ការបញ្ញត្តិ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយនូវអរិយសច្ចទាំង ៤ អរិយសច្ចទាំង ៤ តើដូចម្តេច គឺការប្រាប់ ការសំដែង ការបញ្ញត្តិ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយនូវទុក្ខអរិយសច្ច ១ ការប្រាប់ ការសំដែង ការបញ្ញត្តិ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយនូវទុក្ខសមុទយអរិយសច្ច ១ ការប្រាប់ ការសំដែង ការបញ្ញត្តិ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយនូវទុក្ខនិរោធអរិយសច្ច ១ ការប្រាប់ ការសំដែង ការបញ្ញត្តិ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយនូវទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ ។

[ ១៧៦ ] ម្នាលអាវុសោទាំងឡាយ ទុក្ខអរិយសច្ច តើដូចម្តេច ។ ជាតិទុក្ខ ១ ជរាទុក្ខ ១ មរណទុក្ខ ១ សោកទុក្ខ ១ បរិទេវទុក្ខ ១ ទុក្ខទុក្ខ ១ ទោមនស្សទុក្ខ ១ ឧបាយាសទុក្ខ ១ យម្បិច្ឆំ ន លភតិ តម្បិទុក្ខំ ១ ដោយបង្រួមបញ្ចុបាទានក្ខន្ធ ឈ្មោះថា ទុក្ខ ។ ម្នាលអាវុសោទាំងឡាយ ជាតិ តើដូចម្តេច ការកើត ការកើតព្រម ការចុះកាន់គភ៌ ការប្រព្រឹត្តទៅមិនដាច់ ការវិលត្រឡប់ ការកើតប្រាកដនៃខន្ធ និងការបានចំពោះនូវអាយតនៈណារបស់ពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ម្នាលអាវុសោទាំងឡាយ នេះ

ហៅថា ជាតិ ។ ម្នាលអាវុសោទាំងឡាយ ជរា តើដូចម្ដេច សេចក្ដីចាស់ កាពគ្រាំគ្រា ធ្មេញបាក់ សក់ស្កូវ ស្បែកជ្រួញជ្រីវយុរយារ ការថយអាយុ ការចាស់ជរា នៃឥន្ទ្រិយណារបស់ពួកសត្វនោះៗ ក្នុងសត្តនិកាយនោះៗ ម្នាលអាវុសោទាំងឡាយ នេះហៅថា ជរា ។ ម្នាលអាវុសោទាំងឡាយ មរណៈ តើដូចម្ដេច ការច្យុត ការឃ្លាតចាកសត្តនិកាយនោះៗ ការបែកធ្លាយ ការបាត់បង់ សេចក្ដីស្លាប់ មរណៈ កាលកិរិយា ការបែកធ្លាយខន្ធ ការដាក់ចុះនូវសាកសព ការផ្ដាច់បង់នូវជីវិតិន្ទ្រិយណារបស់ពួកសត្វនោះៗ ម្នាលអាវុសោទាំងឡាយ នេះហៅថា មរណៈ ។ ម្នាលអាវុសោទាំងឡាយ សោក តើដូចម្ដេច ម្នាលអាវុសោទាំងឡាយ សេចក្ដីស្ងួតស្ងប់ ការស្រពោនស្រពាប់ ការស្រណោះស្រណោក ការក្រៀមក្រំខាងក្នុង ការសង្រេងសង្រែខាងក្នុងណារបស់សត្វដែលប្រកបដោយសេចក្ដីវិនាសណាមួយ ឬត្រូវសេចក្ដីទុក្ខណាមួយប៉ះពាល់ហើយ ម្នាលអាវុសោទាំងឡាយ នេះហៅថា សោក ។ ម្នាលអាវុសោទាំងឡាយ បរិទេវៈ តើដូចម្ដេច ម្នាលអាវុសោទាំងឡាយ ទំនួញ ការទួញរៀបរាប់ ការត្អូញត្អែរ ការយំយែក ការអណ្ដឺតអណ្ដក ការយំរៀបរាប់ណារបស់សត្វ ដែលប្រកបដោយសេចក្ដីវិនាសណាមួយ ឬត្រូវសេចក្ដីទុក្ខណាមួយប៉ះពាល់ហើយ ម្នាលអាវុសោទាំងឡាយ នេះហៅថា បរិទេវៈ ។ ម្នាលអាវុសោទាំងឡាយ ទុក្ខ តើដូចម្ដេច ម្នាលអាវុសោទាំង-ឡាយ សេចក្ដីលំបាកកាយ ការមិនសប្បាយកាយ សេចក្ដីទុក្ខកើតអំពីកាយ-សម្ផស្ស ការទទួលអារម្មណ៍មិនជាទីសប្បាយណា ម្នាលអាវុសោទាំងឡាយ

នេះហៅថា ទុក្ខ ។ ម្នាលអាវុសោទាំងឡាយ ទោមនស្ស តើដូចម្តេច ម្នាលអាវុសោទាំងឡាយ សេចក្តីលំបាកក្នុងចិត្ត ការមិនសប្បាយចិត្ត សេចក្តីទុក្ខកើតអំពីមនោសម្ផស្ស ការទទួលអារម្មណ៍មិនជាទីសប្បាយណា ម្នាលអាវុសោទាំងឡាយ នេះហៅថា ទោមនស្ស ។ ម្នាលអាវុសោទាំងឡាយ ឧបាយាស តើដូចម្តេច ម្នាលអាវុសោទាំងឡាយ សេចក្តីតានតឹង ការចង្អៀតចិត្ត ការខ្វាំងខ្វាស់ ការតឹងចិត្តណា របស់សត្វដែលប្រកបដោយសេចក្តីវិនាសណាមួយ ឬត្រូវសេចក្តីទុក្ខណាមួយប៉ះពាល់ហើយ ម្នាលអាវុសោទាំងឡាយ នេះហៅថា ឧបាយាស ។ ម្នាលអាវុសោទាំងឡាយ យម្បិច្ឆំ ន លភតិ តម្បិទុក្ខំ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលមានជាតិជាធម្មតា រមែងមានសេចក្តីប្រាថ្នាយ៉ាងនេះថា ឱហ្ន៎ សូមឲ្យយើងទាំងឡាយ កុំគប្បីជាអ្នកមានជាតិជាធម្មតាឡើយ ពុំនោះសោត ជាតិកុំគប្បីមកដល់យើងទាំងឡាយឡើយ អំពើនុ៎ះឯង ក៏សត្វទាំងឡាយមិនគប្បីដល់តាមសេចក្តីប្រាថ្នាឡើយ នេះហៅថា យម្បិច្ឆំ ន លភតិ តម្បិទុក្ខំដែរ ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលមានជរាជាធម្មតា ... ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលមានព្យាធិជាធម្មតា ... ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលមានសេចក្តីស្លាប់ជាធម្មតា ... ម្នាលអាវុសោទាំងឡាយ ពួកសត្វដែលមានសេចក្តីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីចង្អៀតចង្អល់ជាធម្មតា រមែងមានសេចក្តីប្រាថ្នាកើតឡើងយ៉ាងនេះថា ឱហ្ន៎ សូមឲ្យយើងទាំងឡាយ កុំគប្បីជាអ្នកមានសេចក្តីសោក ខ្សឹកខ្សួល ទុក្ខ ទោមនស្ស និង

សេចក្តីបង្អៀតបង្អល់ចិត្តជាធម្មតាឡើយ ពុំនោះសោត សេចក្តីសោកខ្សឹកខ្សួល ទុក្ខ ទោមនស្ស និងសេចក្តីបង្អៀតបង្អល់ កុំគប្បីមកដល់យើងទាំង-ឡាយឡើយ អំពើនុ៎ះឯង ក៏សត្វទាំងឡាយ មិនគប្បីដល់តាមសេចក្តីប្រាថ្នាឡើយ នេះហៅថា យម្បិច្ឆំ ន លភតិ តម្បិទុក្ខំដែរ ។ ម្នាលអាវុសោទាំង-ឡាយ ដោយបង្រួញ បញ្ចុបាទានក្ខន្ធ ឈ្មោះថា ទុក្ខ តើដូចម្តេច រូបជាឧបាទានក្ខន្ធ ១ វេទនាជាឧបាទានក្ខន្ធ ១ សញ្ញាជាឧបាទានក្ខន្ធ ១ សង្ខារជាឧបាទានក្ខន្ធ ១ វិញ្ញាណជាឧបាទានក្ខន្ធ ១ ម្នាលអាវុសោទាំងឡាយ ទាំងនេះ ហៅថា បញ្ចុបាទានក្ខន្ធដោយបង្រួញ ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ទុក្ខអរិយសច្ច ។

[ ១៧៧ ] ម្នាលអាវុសោទាំងឡាយ ទុក្ខសមុទយអរិយសច្ច តើដូចម្តេច ។ តណ្ហាណាដែលនាំសត្វទៅកើតទៀត ប្រកបព្រមដោយសេចក្តីត្រេក-ត្រអាល មានសេចក្តីត្រេកអរក្នុងភពនោះៗ គឺកាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ម្នាលអាវុសោទាំងឡាយ នេះហៅថាទុក្ខសមុទយអរិយសច្ច ។

[ ១៧៨ ] ម្នាលអាវុសោទាំងឡាយ ទុក្ខនិរោធអរិយសច្ច តើដូចម្តេច ។ សេចក្តីវិនាស និងការរលត់មិនមានសល់នៃតណ្ហានោះឯង កិរិយាលះបង់ ការរលាស់ចោល ការជម្រុះចោលនូវតណ្ហានោះឯង ការមិនអាល័យក្នុងតណ្ហានោះឯងណា ម្នាលអាវុសោទាំងឡាយ នេះហៅថា ទុក្ខនិរោធអរិយសច្ច ។

[ ១៧៩ ] ម្នាលអាវុសោទាំងឡាយ ទុក្ខនិរោធគាមិនីបដិបទាអរិយ-សច្ច តើដូចម្តេច ។ អរិយមគ្គប្រកបដោយអង្គ ៨ ប្រការនេះឯង គឺសេចក្តី

យល់ឃើញត្រូវ ១ សេចក្តីត្រិះរិះត្រូវ ១ វាចាត្រូវ ១ ការងារត្រូវ ១ ការចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ សេចក្តីរឭកត្រូវ ១ ការតម្កល់ចិត្តត្រូវ ១ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីយល់ឃើញត្រូវ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ សេចក្តីដឹងក្នុងកងទុក្ខ សេចក្តីដឹងក្នុងហេតុឲ្យកើតទុក្ខ សេចក្តីដឹងក្នុងធម៌រលត់ទុក្ខ សេចក្តីដឹងក្នុងសេចក្តីប្រតិបត្តិដើម្បីរលត់ទុក្ខ ម្នាលអាវុសោទាំងឡាយ នេះហៅថា សេចក្តីយល់ឃើញត្រូវ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីត្រិះរិះត្រូវ តើដូចម្តេច សេចក្តីត្រិះរិះដើម្បីចេញចាកកាម ១ សេចក្តីត្រិះរិះដើម្បីមិនព្យាបាទ ១ សេចក្តីត្រិះរិះដើម្បីមិនបៀតបៀន ១ ម្នាលអាវុសោទាំងឡាយ នេះហៅថា សេចក្តីត្រិះរិះត្រូវ ។ ម្នាលអាវុសោទាំងឡាយ វាចាត្រូវ តើដូចម្តេច ការវៀរចាកសម្តីកុហក ១ ការវៀរចាកសម្តីញុះញង់ ១ ការវៀរចាកសម្តីទ្រគោះ ១ ការវៀរចាកពាក្យរោយរាយឥតប្រយោជន៍ ១ ម្នាលអាវុសោទាំងឡាយ នេះហៅថា វាចាត្រូវ ។ ម្នាលអាវុសោទាំងឡាយ ការងារត្រូវតើដូចម្តេច ការវៀរចាកបាណាតិបាត ១ ការវៀរចាកអទិន្នាទាន ១ ការវៀរចាកកាមេសុមិច្ឆាចារ ១ ម្នាលអាវុសោទាំងឡាយ នេះហៅថា ការងារត្រូវ ។ ម្នាលអាវុសោទាំងឡាយ ការចិញ្ចឹមជីវិតត្រូវ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ អរិយសាវកក្នុងសាសនានេះ លះបង់នូវការចិញ្ចឹមជីវិតខុស ហើយសម្រេចជីវិតដោយការចិញ្ចឹមជីវិតត្រូវ ម្នាលអាវុសោទាំងឡាយ នេះហៅថា ការចិញ្ចឹមជីវិតត្រូវ ។ ម្នាលអាវុសោទាំងឡាយ ព្យាយាមត្រូវ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុង

សាសនានេះ ញ៉ាំងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែងប្រារព្ធព្យាយាម ផ្គងចិត្តទុកតម្កល់ចិត្ត ដើម្បីញ៉ាំងអកុសលធម៌ដ៏លាមកទាំងឡាយ ដែលមិនទាន់កើតមិនឲ្យកើតឡើងបាន ញ៉ាំងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែងប្រារព្ធព្យាយាម ផ្គងចិត្តទុក តម្កល់ចិត្ត ដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកទាំងឡាយ ដែលកើតឡើងហើយ ញ៉ាំងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុក តម្កល់ចិត្តដើម្បីញ៉ាំងកុលសធម៌ទាំងឡាយដែលមិនទាន់កើតឡើង ឲ្យកើតឡើង ញ៉ាំងឆន្ទៈឲ្យកើតឡើង ប្រឹងប្រែង ប្រារព្ធព្យាយាម ផ្គងចិត្តទុកតម្កល់ចិត្ត ដើម្បីញ៉ាំងកុសលធម៌ទាំងឡាយដែលកើតឡើងហើយឲ្យបានឋិតថេរនៅ មិនឲ្យវិនាសទៅវិញ ឲ្យបានចម្រើនជំទូលាយ ឲ្យកើតបរិបូណ៌ ម្នាលអាវុសោទាំងឡាយ នេះហៅថា ព្យាយាមត្រូវ ។ ម្នាលអាវុសោទាំងឡាយ សេចក្តីរឭកត្រូវ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញរឿយៗ នូវកាយក្នុងកាយ មានព្យាយាមដុតកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី បន្ទោបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ពិចារណាឃើញរឿយៗ នូវវេទនាក្នុងវេទនាទាំងឡាយ ។បេ។ ពិចារណាឃើញរឿយៗ នូវចិត្តក្នុងចិត្ត ។បេ។ ពិចារណារឿយៗ នូវធម៌ក្នុងធម៌ទាំង-ឡាយ មានព្យាយាមដុតកិលេស មានសេចក្តីដឹងខ្លួន មានស្មារតី បន្ទោបង់នូវអភិជ្ឈា និងទោមនស្សក្នុងលោក ម្នាលអាវុសោទាំងឡាយ នេះហៅថា សេចក្តីរឭកត្រូវ ។ ម្នាលអាវុសោទាំងឡាយ ការតម្កល់ចិត្តត្រូវ តើដូចម្តេច ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងាត់ចាកកាមទាំងឡាយ ស្ងាត់

ចាកអកុសលធម៌ទាំងឡាយ បានដល់នូវបឋមជ្ឈាន ប្រកបដោយវិតក្ក ប្រកបដោយវិចារ មានបីតិ និងសុខដែលកើតអំពីសេចក្តីស្ងាត់ ក៏សម្រេចសម្រាន្តនៅគ្រប់ឥរិយាបថ ភិក្ខុបានដល់នូវទុតិយជ្ឈានជាធម្មជាតកើតមានក្នុងសន្តានចិត្ត ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កមិនមានវិចារ មានតែបីតិនិងសុខកើតអំពីសមាធិ គឺទុតិយជ្ឈាន ព្រោះរម្ងាប់វិតក្ក និងវិចារ ... ( បានដល់ ) នូវតតិយជ្ឈាន ... បានដល់នូវចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅគ្រប់ឥរិយាបថ ម្នាលអាវុសោទាំងឡាយ នេះហៅថា ការតម្កល់ចិត្តត្រូវ ។ ម្នាលអាវុសោទាំងឡាយ នេះហៅថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។

[ ១៨០ ] ម្នាលអាវុសោទាំងឡាយ ធម្មចក្រដ៏ប្រសើរ ដែលព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធឲ្យប្រព្រឹត្តទៅក្នុងឥសិបតនមិគទាយវ័ន ទៀបក្រុងពារាសី ជាធម្មចក្រដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី នរណាមួយក្តី ក្នុងលោកមិនអាចធ្វើបដិវត្តិបាន គឺការប្រាប់ ការសំដែង ការបញ្ញាក់ ការតែងតាំង ការបើក ការវែកញែក និងការធ្វើឲ្យងាយនូវអរិយសច្ចទាំង ៤ នេះឯង ។ លុះព្រះសារីបុត្តមានអាយុ សំដែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានចិត្តត្រេកអររីករាយនឹងភាសិតរបស់ព្រះសារីបុត្តមានអាយុ ។

សច្ចវិភង្គសូត្រទី ១១ ចប់

# អដ្ឋកថា

## សច្ចវិភង្គសូត្រ

[ ១៧៣ ] សច្ចវិភង្គសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ១៧៤ ] បណ្តាបទទាំងនោះ បទថា **អាចិក្ខនា** សេចក្តីថា នេះឈ្មោះថា ទុក្ខអរិយសច្ច ។បេ។ នេះឈ្មោះថា ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ។ ក្នុងបទដ៏សេសក៏មានន័យនេះដូចគ្នា ។ ម្យ៉ាងទៀត ក្នុងទីនេះ ការតាំងសច្ចៈមានទុក្ខសច្ចជាដើម ឈ្មោះថា ការបញ្ញត្តិ ។ បុគ្គលតាំងអាសនៈ ហៅថា បញ្ញត្តអាសនៈ ។ បទថា **បដ្ឋបនា** គឺការបញ្ញត្តិ ។ បទថា **វិវរណា** គឺការធ្វើនូវការបើកផ្សារ ។ បទថា **វិភជនា** គឺធ្វើការចែក ។ បទថា **ឧត្តានីកម្មំ** បានដល់ ធ្វើឲ្យប្រាកដ ។ បទថា **អនុគ្គាហកា** សេចក្តីថា អនុគ្រោះដោយការសង្គ្រោះ ២ យ៉ាង គឺអាមិសសង្គហៈ ១ ធម្មសង្គហៈ ១ ។ បទថា **ជនេតា** គឺមាតាអ្នកឲ្យកើត ។ បទថា **អបាទេតា** គឺអ្នកចិញ្ចឹម ។ ទ្រង់សម្តែងថា មោគ្គល្លានដូចមាតាចិញ្ចឹម ។ បណ្តាអ្នកឲ្យកើត វៀរបស់ប្រៃនិងរបស់ជូរជាដើម អស់ ៩ ខែ ឬ ១០ ខែ ទ្រទ្រង់ទារកក្នុងផ្ទៃ ឲ្យមាតាចិញ្ចឹម គឺមេដោះ ទទួលទារកដែលចេញអំពីផ្ទៃ ។ មាតានោះ ចិញ្ចឹមទារកដោយទឹកដោះ និងនវនីតជាដើមឲ្យចម្រើន ។ ទារកនោះអាស្រ័យសេចក្តីចម្រើនគ្រាប់ទៅតាមសប្បាយ ។ ព្រះសារីបុត្តេរក៏ដូច្នោះ សង្គ្រោះបព្វជិតទាំងឡាយរបស់ខ្លួន ឬរបស់ភិក្ខុដទៃ ដោយការសង្គ្រោះ ២ យ៉ាង បដិបត្តិបព្វជិតអ្នកជំងឺ ដឹកនាំក្នុងកម្មដ្ឋាន ដឹងនូវភាពជាព្រះសោតាបន្ន ហើយចាប់

ផ្តើមអំពីកាលបព្វជិតទាំងនោះ ចេញចាកភ័យក្នុងអបាយទាំងឡាយ ឥឡូវនេះ ក៏ជាអ្នកមិនដាក់ចិត្តក្នុងបព្វជិតទាំងនោះថា ពួកបព្វជិតទាំងនោះ នឹងញុំាងមគ្គខាងលើឲ្យកើតឡើង ដោយការធ្វើរបស់បុរសចំពោះខ្លួនហើយ ហើយបង្រៀនបព្វជិតថ្មីៗ ដទៃ ។ ឯព្រះមហាមោគ្គល្លានសង្គ្រោះបព្វជិតទាំង-ឡាយក្នុងសម្នាក់របស់ខ្លួន ឬរបស់ភិក្ខុដទៃដូច្នោះដូចគ្នា ដឹកនាំក្នុងកម្មដ្ឋាន រមែងមិនដល់នូវភាពជាអ្នកមិនដាក់ចិត្តក្នុងបព្វជិតទាំងឡាយ សម្រេចហើយនូវផល ៣ ខាងក្រោម ។ ព្រោះហេតុអ្វី ទើបព្រះមហាមោគ្គល្លាននោះមានការគិតយ៉ាងនេះ ។ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដូចលាមក សូម្បីបន្តិចបន្តួច រមែងមានក្លិនស្អុយ ។បេ។ ម្នាលភិក្ខុទាំងឡាយ ដូចទឹកមូត្រ សូម្បីបន្តិចបន្តួច រមែងមានក្លិនស្អុយ ... ទឹកមាត់ សូម្បីបន្តិចបន្តួច រមែងមានក្លិនស្អុយ ... ខ្ទុះ សូម្បីបន្តិចបន្តួច រមែងមានក្លិនស្អុយ ... ឈាម សូម្បីបន្តិចបន្តួច រមែងមានក្លិនស្អុយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ តថាគតមិនដែលសរសើរនូវការបដិសន្ធិ ក្នុងភពសូម្បីបន្តិចបន្តួច ដោយហោចទៅ សូម្បីអស់កាលត្រឹមតែផ្ទាត់ម្រាមដៃម្តងឡើយ ក៏យ៉ាងនោះឯង ដូច្នេះ ។ ព្រោះដូច្នោះ ទើបព្រះមហាមោគ្គល្លានមិនដល់នូវភាពជាអ្នកមិនដាក់ចិត្តក្នុងបព្វជិតទាំងនោះ ដរាបណា បព្វជិតទាំងនោះមិនទាន់សម្រេចអរហត្ត រមែងដល់នូវភាពជាអ្នកមិនដាក់ចិត្តក្នុងបព្វជិតទាំងឡាយ ដែលជាអ្នកសម្រេចអរហត្តហើយ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រ ដូចមាតាដែលបង្កើត

មោគ្គល្លាន ដូចមាតាចិញ្ចឹមទារកដែលកើតហើយ ម្នាលភិក្ខុទាំងឡាយ សារីបុត្រ រមែងដឹកនាំក្នុងសោតាបត្តិផល មោគ្គល្លាន រមែងដឹកនាំក្នុងផលដែលខ្ពស់ឡើងទៅ ដូច្នេះ ។

បទថា **បហោតិ** បានដល់ រមែងអាច ។

[ ១៧៩ ] បទថា **ទុក្ខេ ញាណំ** បានដល់ ញាណក្នុងការចាក់ធ្លុះដោយការស្តាប់ និងការពិចារណា ។ ក្នុងទុក្ខសមុទយៈក៏យ៉ាងនោះ ។ បដិវេធញ្ញាណក្នុងការស្តាប់ រមែងគួរក្នុងទុក្ខនិរោធ ។ រមែងគួរក្នុងទុក្ខនិរោធគាមិនីបដិបទាដូចគ្នា ។ ក្នុងសង្កប្បទាំងឡាយ មាននេក្ខម្មសង្កប្បជាដើម ការត្រិះរិះថា សង្កប្បកើតឡើងហើយដល់អ្នកពិចារណាកាម ដោយអត្ថថា កាមជាសត្រូវ ឬដោយការរលាស់ចេញចាកកាមក្តី សង្កប្បធ្វើការកម្ចាត់កាម គឺការចូលទៅស្ងប់រម្ងាប់កាមកើតឡើងហើយក្តី សង្កប្បកើតឡើងក្នុងទីបំផុតនៃការស្ងប់ចាកកាមក្តី ឈ្មោះថា នេក្ខម្មសង្កប្ប ។ សូម្បីក្នុងបទទាំង ២ ដ៏សេសក៏មានន័យនេះដូចគ្នា ។ ឯសង្កប្បទាំងអស់នោះ ក្នុងបុព្វភាគបានក្នុងចិត្តផ្សេងៗ ក្នុងខណៈនៃមគ្គ រមែងបានក្នុងចិត្ត ១ ។ ពិតហើយ រមែងបានសង្កប្ប ១ ប៉ុណ្ណោះ ដែលទម្លាយមិច្ឆាសង្កប្បចេតនា ក្នុងឯកចិត្តនោះ រមែងមិនបានទូវសង្កប្បផ្សេងៗ ។ សូម្បីសម្មាវាចាជាដើម ក៏រមែងបានក្នុងចិត្ត ១

*ក្នុងខណៈនៃមគ្គ ដោយន័យដែលពោលហើយ ក្នុងបណ្ដាចិត្តផ្សេងៗ ក្នុងបុព្វភាគ ។ ក្នុងទីនេះ មានសេចក្ដីសង្ខេបប្រមាណប៉ុណ្ណោះ ។ ឯសេចក្ដីពិស្ដារ បានពោលហើយ ក្នុងសច្ចកថាវិសុទ្ធិមគ្គ និងក្នុងសម្មាទិដ្ឋិសូត្រនោះឯង ។*

**អដ្ឋកថា សច្ចវិភង្គសូត្រ ចប់**

**សូត្រទី ១១ ចប់**

# សុត្តន្តបិដក

## ទក្ខិណាវិភង្គសូត្រទី ១២

[ ១៨១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះព្រះនាងមហាបជាបតិគោតមី នាំយកសំពត់ថ្មី ១ គូ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មី ១ គូនេះ ខ្ញុំម្ចាស់វៃខ្លួនឯង ត្បាញខ្លួនឯង ផ្តងចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ អាស្រ័យនូវសេចក្តីអនុគ្រោះចំពោះខ្ញុំម្ចាស់ ទទួលយកនូវសំពត់នោះ ។

[ ១៨២ ] កាលបើព្រះនាងមហាបជាបតិគោតមី ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគក៏មានព្រះបន្ទូលនឹងព្រះនាងមហាបជាបតិគោតមីដូច្នេះថា បពិត្រព្រះនាងគោតមី សូមព្រះនាងប្រគេន ( សំពត់នេះ ) ចំពោះសង្ឃវិញចុះ កាលបើព្រះនាងប្រគេនសំពត់នេះចំពោះសង្ឃហើយ តថាគតឈ្មោះថា ព្រះនាងបានបូជាហើយផង ទាំងសង្ឃក៏ឈ្មោះថា ព្រះនាងបានបូជាហើយដែរ ។ ព្រះនាងមហាបជាបតិគោតមី ក្រាបបង្គំទូលអង្វរព្រះមានព្រះភាគអស់វារៈ ២ ដងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មី ១ គូនេះ ខ្ញុំម្ចាស់វៃខ្លួនឯង ត្បាញខ្លួនឯង ឧទ្ទិសចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏

ចម្រើន សូមព្រះមានព្រះភាគ អាស្រ័យនូវសេចក្ដីអនុគ្រោះចំពោះខ្ញុំម្ចាស់ ទទួលយកនូវសំពត់នោះ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងព្រះនាងមហាបជាបតិគោតមីអស់វារៈ ២ ដងដូច្នេះថា បពិត្រព្រះនាងគោតមី សូមព្រះនាងប្រគេនសង្ឃវិញចុះ កាលបើព្រះនាងប្រគេនសង្ឃហើយ តថាគតក៏ឈ្មោះថា ព្រះនាងបានបូជាហើយផង ទាំងសង្ឃក៏ឈ្មោះថា ព្រះនាងបានបូជាហើយដែរ ។ ព្រះនាងមហាបជាបតិគោតមី ក្រាបបង្គំទូលព្រះមានព្រះភាគអស់វារៈ ៣ ដងដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មី ១ គូនេះ ខ្ញុំម្ចាស់រវៃខ្លួនឯង ត្បាញខ្លួនឯង ឧទ្ទិសចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ អាស្រ័យនូវសេចក្ដីអនុគ្រោះចំពោះខ្ញុំម្ចាស់ហើយ ទទួលយកនូវសំពត់នោះ ។ ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងព្រះនាងមហាបជាបតិគោតមីអស់វារៈ ៣ ដងដូច្នេះថា បពិត្រព្រះនាងគោតមី សូមព្រះនាងប្រគេនសង្ឃវិញចុះ កាលបើព្រះនាងប្រគេនសង្ឃហើយ តថាគតក៏ឈ្មោះថា ព្រះនាងបានបូជាហើយផង ទាំងសង្ឃក៏ឈ្មោះថា ព្រះនាងបានបូជាហើយដែរ ។

[ ១៨៣ ] កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលអង្វរព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ទទួលសំពត់ថ្មី ១ គូរបស់ព្រះនាងមហាបជាបតិគោតមី បពិត្រព្រះអង្គចម្រើន ព្រះនាងមហាបជាបតិ-គោតមីជាអ្នកមានឧបការៈច្រើន ជាព្រះមាតុច្ឆារបស់ព្រះមានព្រះភាគ ជាអ្នក

ថែរក្សា អ្នកចិញ្ចឹម អ្នកថ្វាយទឹកក្សីរ កាលព្រះមាតាបង្កើតព្រះមានព្រះភាគ ទ្រង់ទិវង្គតទៅ នាងបានបំបៅទឹកដោះ បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគក៏មានឧបការៈច្រើនដល់ព្រះនាងមហាបជាបតិគោតមីដែរ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះនាងមហាបជាបតិគោតមី អាស្រ័យព្រះមានព្រះភាគ ទើបបានដល់នូវព្រះពុទ្ធជាទីពឹង បានដល់នូវព្រះធម៌ជាទីពឹង បានដល់នូវព្រះសង្ឃជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី អាស្រ័យព្រះមានព្រះភាគ ទើបជាអ្នកបានវៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តិខុសក្នុងកាមទាំង-ឡាយ វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី អាស្រ័យនូវព្រះមានព្រះភាគ ទើបប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយដែលជាទីត្រេកអរនៃព្រះអរិយបុគ្គល បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី អាស្រ័យនូវព្រះមានព្រះភាគ ទើបជាអ្នកអស់សង្ស័យក្នុងទុក្ខ អស់សង្ស័យក្នុងហេតុឲ្យកើតទុក្ខ អស់សង្ស័យក្នុងធម៌រម្ងត់ទុក្ខ អស់សង្ស័យក្នុងសេចក្តីប្រតិបត្តិទៅកាន់ទីរម្ងត់ទុក្ខ បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគ ក៏មានឧបការៈច្រើនដល់ព្រះនាងមហាបជា-បតិគោតមីដែរ ។

[ ១៨៤ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា អើ យ៉ាងហ្នឹងហើយអានន្ទ អើយ៉ាងហ្នឹងហើយអានន្ទ ម្នាលអានន្ទ បុគ្គលអាស្រ័យបុគ្គលណា ទើបបានដល់ព្រះពុទ្ធជាទីពឹង បានដល់ព្រះធម៌ជាទីពឹង បានដល់ព្រះសង្ឃជាទីពឹង ម្នាលអានន្ទ តថាគតមិនសម្តែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិ-កម្ម សាមីចិកម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ ជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនោះតបស្នងដល់បុគ្គលនេះ បានដោយល្អឡើយ ។ ម្នាលអានន្ទ មួយទៀត បុគ្គលអាស្រ័យនូវបុគ្គលណាហើយ បានវៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តិខុសក្នុងកាមទាំងឡាយ វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង គឺសុរា និងមេរ័យ ម្នាលអានន្ទ តថាគតមិនសម្តែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជ-បរិក្ខារ ជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនេះតបស្នងដល់បុគ្គលនេះ បានដោយល្អឡើយ ។ ម្នាលអានន្ទ មួយទៀត បុគ្គលអាស្រ័យនូវបុគ្គលណាហើយ បានក្របកដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លា មិនកម្រើកក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ជាទីត្រេកអរនៃព្រះអរិយបុគ្គល ម្នាលអានន្ទ តថាគតមិនសម្តែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិ-កម្ម សាមីចិកម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារ

ជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនេះតបស្នងដល់បុគ្គលនេះ បាន ដោយល្អឡើយ ។ ម្នាលអានន្ទ មួយទៀត បុគ្គលអាស្រ័យនូវបុគ្គលណា ហើយ ជាអ្នកអស់សង្ស័យក្នុងទុក្ខ អស់សង្ស័យក្នុងហេតុឲ្យកើតទុក្ខ អស់ សង្ស័យក្នុងធម៌រលត់ទុក្ខ អស់សង្ស័យក្នុងសេចក្តីប្រតិបត្តិទៅកាន់ធម៌រលត់ ទុក្ខ ម្នាលអានន្ទ តថាគតមិនសំដែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជ-លិកម្ម សាមីចិកម្ម និងការឲ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជ-បរិក្ខារ ជាបច្ច័យដល់អ្នកជំងឺ ថាជាកម្មដែលបុគ្គលនេះ តបស្នងដល់បុគ្គល នេះ បានដោយល្អឡើយ ។

[ ១៨៥ ] ម្នាលអានន្ទ បាដិបុគ្គលិកាទក្ខិណា ( ទានដែលឲ្យចំពោះ បុគ្គល ) នេះមាន ១៤ យ៉ាង ។ បុគ្គលឲ្យទានចំពោះព្រះតថាគតជាអរហន្ត សម្មាសម្ពុទ្ធ នេះជាបាដិបុគ្គលិកាទក្ខិណាទី ១ ។ ឲ្យទានចំពោះព្រះបច្ចេកពុទ្ធ នេះជាបាដិបុគ្គលិកាទក្ខិណាទី ២ ។ ឲ្យទានចំពោះព្រះអរហន្តជាសាវ័ករបស់ ព្រះតថាគត នេះជាបាដិបុគ្គលិកាទក្ខិណាទី ៣ ។ ឲ្យទានចំពោះបុគ្គលអ្នក ប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល នេះជាបាដិបុគ្គលិកាទក្ខិណាទី ៤ ។ ឲ្យទានចំពោះអនាគាមិបុគ្គល នេះជាបាដិបុគ្គលិកាទក្ខិណាទី ៥ ។ ឲ្យ ទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល នេះជា បាដិបុគ្គលិកាទក្ខិណាទី ៦ ។ ឲ្យទានចំពោះសកទាគាមិបុគ្គល នេះជាបាដិ-បុគ្គលិកាទក្ខិណាទី ៧ ។ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ ច្បាស់នូវសកទាគាមិផល នេះជាបាដិបុគ្គលិកាទក្ខិណាទី ៨ ។ ឲ្យទានចំពោះ

សោតាបន្នបុគ្គល នេះជាបាដិបុគ្គលិកាទក្ខិណាទី ៩ ។ ឲ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល នេះជាបាដិបុគ្គលិកាទក្ខិណាទី ១០ ។ ឲ្យទានចំពោះអ្នកបួសជាខាងក្រៅ ( ពុទ្ធសាសនា ) ដែលប្រាសចាកតម្រេកក្នុងកាមទាំងឡាយ នេះជាបាដិបុគ្គលិកាទក្ខិណាទី ១១ ។ ឲ្យទានចំពោះបុថុជ្ជនមានសីល នេះជាបាដិបុគ្គលិកាទក្ខិណាទី ១២ ។ ឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល នេះជាបាដិបុគ្គលិកាទក្ខិណាទី ១៣ ។ ឲ្យទានចំពោះសត្វតិរច្ឆាន នេះជាបាដិបុគ្គលិកាទក្ខិណាទី ១៤ ។

[ ១៨៦ ] ម្នាលអានន្ទ បណ្តាបុគ្គលអ្នកទទួលទានទាំងនោះ ទក្ខិណាមានគុណមួយរយ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះសត្វតិរច្ឆាន ។ ទក្ខិណាមានគុណមួយពាន់ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុថុជ្ជនទ្រុស្តសីល ។ ទក្ខិណាមានគុណមួយសែន ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុថុជ្ជនមានសីល ។ ទក្ខិណាមានគុណមួយសែនកោដិ ដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះអ្នកបួសខាងក្រៅ ដែលប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។ ទក្ខិណាមានគុណរាប់មិនបាន ប្រមាណមិនកើតដែលបុគ្គលត្រូវបាន ព្រោះឲ្យទានចំពោះបុគ្គល ដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ នឹងបាច់និយាយទៅថ្វី ( ដល់ទក្ខិណាដែលបុគ្គលឲ្យ ) ចំពោះសោតាបន្នបុគ្គល នឹងនិយាយទៅថ្វីចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល នឹងនិយាយទៅថ្វីចំពោះសកទាគាមិបុគ្គល នឹងនិយាយទៅថ្វីចំពោះបុគ្គល ដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគា-

មិផល នឹងនិយាយទៅថ្វីចំពោះអនាគាមិបុគ្គល នឹងនិយាយទៅថ្វីចំពោះបុគ្គល ដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល នឹងនិយាយទៅថ្វីចំពោះព្រះអរហន្តជាសាវ័ករបស់តថាគត នឹងនិយាយទៅថ្វីចំពោះព្រះបច្ចេកសម្ពុទ្ធ នឹងនិយាយទៅថ្វីចំពោះព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។

[ ១៨៧ ] ម្នាលអានន្ទ សង្ឃគតាទក្ខិណា ( ទានដែលតម្កល់ក្នុងសង្ឃ ) នេះមាន ៧ យ៉ាង ។ បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន នេះជាសង្ឃគតាទក្ខិណាទី ១ ។ កាលបើព្រះតថាគតបរិនិព្វានទៅ បុគ្គលឲ្យទានចំពោះសង្ឃទាំងពីរចំណែក នេះជាសង្ឃគតាទក្ខិណាទី ២ ។ ឲ្យទានចំពោះតែភិក្ខុសង្ឃ នេះជាសង្ឃគតាទក្ខិណាទី ៣ ។ ឲ្យទានចំពោះតែភិក្ខុនីសង្ឃ នេះជាសង្ឃគតាទក្ខិណាទី ៤ ។ បុគ្គល ( ទៅនិមន្តអំពីសម្មាក់សង្ឃ ) ថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណេះ ពួកភិក្ខុនីប៉ុណ្ណេះ អំពីសង្ឃដើម្បីខ្ញុំហើយ ទើបឲ្យទាន នេះជាសង្ឃគតាទក្ខិណាទី ៥ ។ បុគ្គល ( ទៅនិមន្តអំពីសម្មាក់សង្ឃ ) ថា សូមលោកទាំងឡាយចាត់ពួកភិក្ខុប៉ុណ្ណេះ អំពីសង្ឃដើម្បីខ្ញុំហើយ ទើបឲ្យទាន នេះជាសង្ឃគតាទក្ខិណាទី ៦ ។ បុគ្គល ( ទៅនិមន្តអំពីសម្មាក់សង្ឃ ) ថា សូមលោកទាំងឡាយចាត់ពួកភិក្ខុនីប៉ុណ្ណេះ អំពីសង្ឃដើម្បីខ្ញុំហើយ ទើបឲ្យទាន នេះជាសង្ឃគតាទក្ខិណាទី ៧ ។

[ ១៨៨ ] ម្នាលអានន្ទ ក្នុងកាលជាអនាគត នឹងមានគោត្រភូសង្ឃ ( សង្ឃមានតែឈ្មោះ ) មានតែសំពត់កាសាវៈចងក ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ជនទាំងនោះ ឧទ្ទិសចំពោះសង្ឃ ហើយនឹងឲ្យទានដល់បុគ្គល

ទ្រុស្តសីលទាំងនោះ ម្នាលអានន្ទ សូម្បីក្នុងកាលនោះ ក៏តថាគតពោលថា សង្ឃគតាទក្ខិណាទាន មានអានិសង្សរាប់មិនបាន ប្រមាណមិនកើតដែរ ម្នាលអានន្ទ តថាគតមិនដែលពោលនូវបាដិបុគ្គលិកទាន ថាមានផលច្រើន ជាងសង្ឃគតាទក្ខិណាទាន ដោយបរិយាយណាមួយឡើយ ។

[ ១៨៩ ] ម្នាលអានន្ទ ទក្ខិណាវិសុទ្ធិ ( ការបរិសុទ្ធិ និងមិនបរិសុទ្ធ របស់ទាន ) នេះមាន ៤ យ៉ាង ។ ឯទក្ខិណាវិសុទ្ធិទាំង ៤ តើដូចម្តេច ។ ម្នាលអានន្ទ ទក្ខិណាបរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល ១ ម្នាលអានន្ទ ទក្ខិណាបរិសុទ្ធខាងអ្នកទទួល មិនបរិសុទ្ធខាងអ្នកឲ្យ ១ ម្នាលអានន្ទ ទក្ខិណាមិនបរិសុទ្ធខាងអ្នកឲ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង ១ ម្នាលអានន្ទ ទក្ខិណាបរិសុទ្ធខាងអ្នកឲ្យផង បរិសុទ្ធខាងអ្នកទទួលផង ១ ។

[ ១៩០ ] ម្នាលអានន្ទ ទក្ខិណាបរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាបុគ្គលមានសីល មានធម៌ល្អ ឯពួកអ្នកទទួលជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ម្នាលអានន្ទ យ៉ាងនេះឯងឈ្មោះថាទក្ខិណាបរិសុទ្ធខាងអ្នកឲ្យ មិនបរិសុទ្ធខាងអ្នកទទួល ។

[ ១៩១ ] ម្នាលអានន្ទ ទក្ខិណាបរិសុទ្ធខាងអ្នកទទួល តែមិនបរិសុទ្ធខាងអ្នកឲ្យ តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាបុគ្គលទ្រុស្តសីល មានធម៌ដ៏លាមក ឯពួកអ្នកទទួលជាបុគ្គលមានសីល មានធម៌ល្អ ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា ទក្ខិណាបរិសុទ្ធខាងអ្នកទទួល មិនបរិសុទ្ធខាងអ្នកឲ្យ ។

[ ១៩២ ] ម្នាលអានន្ទ ទក្ខិណាមិនបរិសុទ្ធខាងអ្នកឲ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ទាំងពួកអ្នកទទួលក៏ជាបុគ្គលទ្រុស្តសីល មានធម៌ដ៏លាមកដូចគ្នា ម្នាលអានន្ទ យ៉ាងនេះឯងឈ្មោះថា ទក្ខិណាមិនបរិសុទ្ធខាងអ្នកឲ្យផង មិនបរិសុទ្ធខាងអ្នកទទួលផង ។

[ ១៩៣ ] ម្នាលអានន្ទ ទក្ខិណាបរិសុទ្ធខាងអ្នកឲ្យផង បរិសុទ្ធខាងអ្នកទទួលផង តើដូចម្តេច ។ ម្នាលអានន្ទ អ្នកឲ្យក្នុងលោកនេះ ជាបុគ្គលមានសីល មានធម៌ល្អ ទាំងពួកអ្នកទទួលក៏ជាបុគ្គលមានសីល មានធម៌ល្អដូចគ្នា ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា ទក្ខិណាបរិសុទ្ធខាងអ្នកឲ្យផង បរិសុទ្ធខាងអ្នកទទួលផង ។ ម្នាលអានន្ទ នេះឯងជាទក្ខិណាវិសុទ្ធិ ៤ យ៉ាង ។

[ ១៩៤ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់នូវព្រះសូត្រនេះ លុះព្រះសុគតជាសាស្តា ទ្រង់ត្រាស់នូវព្រះសូត្រនេះរួចហើយ ទើបទ្រង់ត្រាស់នូវព្រះគាថាតទៅទៀតដូច្នេះថា

បុគ្គលណា ជាអ្នកមានសីល មានចិត្តជ្រះថ្លាដោយប្រពៃ
ជឿស៊ប់នូវកម្ម និងផលរបស់កម្មដ៏លើសលុប ឲ្យទាន
ដែលខ្លួនបានមកដោយធម៌ ចំពោះពួកបុគ្គលទ្រុស្តសីល
ទក្ខិណានោះ បរិសុទ្ធខាងអ្នកឲ្យ បុគ្គលណា ជាអ្នក
ទ្រុស្តសីល មានចិត្តមិនបានជ្រះថ្លា មិនជឿស៊ប់នូវកម្ម
និងផលរបស់កម្មដ៏លើសលុប ឲ្យទានដែលខ្លួនបានមក

មិនដោយធម៌ ចំពោះពួកបុគ្គលអ្នកមានសីល ទក្ខិណា នោះ បរិសុទ្ធខាងអ្នកទទួល បុគ្គលណា ជាអ្នកទ្រុស្ត-សីល មានចិត្តមិនបានជ្រះថ្លា មិនជឿស៊ប់នូវកម្ម និង ផលរបស់កម្មដ៏លើសលុប ឲ្យទានដែលខ្លួនបានមកមិន ដោយធម៌ ចំពោះពួកបុគ្គលទ្រុស្តសីល តថាគតមិន ពោលថា ទាននោះ មានផលដ៏បរិបូណ៌ទេ បុគ្គលណា ជាអ្នកមានសីល មានចិត្តជ្រះថ្លាដោយប្រពៃ ជឿស៊ប់ នូវកម្ម និងផលរបស់កម្មដ៏លើសលុប ឲ្យទានដែលខ្លួន បានមកដោយធម៌ ចំពោះពួកបុគ្គលមានសីល តថាគត ពោលថា ទាននោះឯង ទើបបានផលដ៏បរិបូណ៌ បុគ្គល ណា ជាអ្នកប្រាសចាករាគៈ មានចិត្តជ្រះថ្លាដោយប្រពៃ ជឿស៊ប់នូវកម្ម និងផលរបស់កម្មដ៏លើសលុប ឲ្យទាន ដែលខ្លួនបានមកដោយធម៌ ចំពោះពួកបុគ្គលប្រាសចាក រាគៈ ទាននោះឯង ប្រសើរជាងពួកអាមិសទាន ( ទាំង អស់ ) ។

ទក្ខិណាវិភង្គសូត្រទី ១២ ចប់

វិភង្គវគ្គទី ៤ ចប់

## ឧទ្ទាននៃវិភង្គវគ្គនោះគឺ

កម្មទេករត្តសូត្រ ១ រឿងព្រះអានន្ទសម្ដែង ( កម្មទេករត្ត-សូត្រ ) ក្នុងឧបដ្ឋានសាលា ១ រឿងព្រះសមិទ្ធិ ( ក្នុងមហាកច្ចានភទ្ទេករត្តសូត្រ ) ១ រឿងចន្ទនទេវបុត្រ ( ក្នុងលោមសកង្គិយសូត្រ ) ១ រឿងមាណពអគ្គិវេសនគោត្រ ( ក្នុងចូឡកម្មវិភង្គសូត្រ ) ១ រឿងបុគ្គលឈ្មោះថាមានញាណដ៏ប្រសើរ ( ក្នុងមហាកម្មវិភង្គសូត្រ ) ១ រឿងព្រះសម្ពុទ្ធព្រះនាមបរិសទម្មសារថិ ( ក្នុងសឡាយតនវិភង្គសូត្រ ) ១ ឧទ្ទេសវិភង្គសូត្រ ១ អរណវិភង្គសូត្រ ១ រឿងបុក្កុសកុលបុត្រ ( ក្នុងធាតុវិភង្គ-សូត្រ ) ១ រឿងសច្ចៈដ៏ប្រសើរ ( ក្នុងសច្ចវិភង្គសូត្រ ) ១ រឿងទាន ( ក្នុងទក្ខិណាវិភង្គសូត្រ ) ១ ។

# អដ្ឋកថា

## ទក្ខិណាវិភង្គសូត្រ

[ ១៨១ ] ទក្ខិណាវិភង្គសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងទក្ខិណាវិភង្គសូត្រនោះ បទថា **មហាបជាបតី គោតមី** បានដល់ ព្រះគោត្រថា **គោតមី** ។ ក្នុងថ្ងៃថ្វាយព្រះនាម ព្រាហ្មណ៍ទាំងឡាយបានទទួលសក្ការៈហើយ ឃើញព្រះលក្ខណសម្បត្តិរបស់ព្រះនាងហើយ បានព្យាករថា បើស្ត្រីនោះបានព្រះធីតា ព្រះធីតានឹងបានជាអគ្គមហេសីរបស់ស្ដេចចក្រពត្តិ បើបានព្រះឱរស ព្រះឱរសនឹងបានជាស្ដេចចក្រពត្តិ ព្រះបជារបស់ព្រះនាង ជាបុគ្គលធំក្រៃលែង ដោយប្រការទាំង ២ នោះឯង ដូច្នេះ ។ ទើបញាតិទាំងឡាយថ្វាយព្រះនាមថា **បជាបតី** ដោយប្រការដូច្នេះ ។ តែក្នុងសូត្រនេះ លោកសង្គ្រោះយកគោត្រផង ទើបត្រាស់ថា **មហាបជាបតី-គោតមី** ។ បទ ថា **នវំ** បានដល់ ថ្មី ។ បទថា **សាមំ វាយិតំ** គឺទ្រង់ត្បាញឯងដោយព្រះហស្ត ។ ក្នុងថ្ងៃនោះ ព្រះនាងមហាបជាបតិគោតមីដែលពួកកីលៀង នាងស្នំ ហោមរោមហើយ យាងមកកាន់រោងការងារត្បាញនូវសំពត់របស់សិប្បៈទាំងឡាយ ព្រះនាងចាប់ចុងត្រល់ ធ្វើអាការនៃការត្បាញ ។ ពាក្យនោះ លោកពោលសំដៅដល់ការត្បាញសំពត់នោះ ។ សួរថា ព្រះនាងគោតមី ទ្រង់កើតព្រះហឫទ័យដើម្បីថ្វាយសំពត់មួយគូដល់ព្រះមានព្រះភាគក្នុងកាលណា ឆ្លើយថា ក្នុងកាលដែលព្រះមានព្រះភាគទ្រង់សម្រេចអភិសម្ពោធិញ្ញាណ ហើយស្ដេចមកកាន់ក្រុងកបិលពស្តុដោយ

ការយាងលើកទី ១ ពិតហើយ ព្រះបាទសុទ្ធោទនមហារាជទ្រង់នាំព្រះសាស្តា ដែលយាងបិណ្ឌបាត ឲ្យត្រឡប់ទៅកាន់ព្រះរាជនិវេសន៍របស់ព្រះអង្គ ។ គ្រា នោះ ព្រះនាងមហាបជាបតិគោតមី ឃើញព្រះរូបសោភានៃព្រះមានព្រះភាគ ហើយ ទ្រង់ព្រះតម្រិះថា អត្តភាពកូនរបស់អញស្អាតហ្ន៎ ដូច្នេះ ។ លំដាប់នោះ ព្រះនាងក៏កើតសោមនស្សជាកម្លាំង ។ បន្ទាប់អំពីនោះ ព្រះនាងព្រះតម្រិះថា កាលកូនរបស់អញនៅក្នុងវាំងអស់ ២៩ ឆ្នាំ វត្ថុដែលអញឲ្យហើយ ដោយ ហោចសូម្បីត្រឹមតែផ្លែបេកនោះឯង មិនមានឡើយ ឥឡូវនេះ អញនឹងថ្វាយ សំពត់ចីវរដល់កូននោះ ។ ព្រះនាងញ៉ាំងព្រះហឫទ័យឲ្យកើតឡើងថា ក្នុងក្រុង រាជគ្រឹះនេះ មានសំពត់តម្លៃថ្លៃច្រើន សំពត់ទាំងនោះ រមែងមិនញ៉ាំងអញ ឲ្យត្រេកអរ សំពត់ដែលអញធ្វើឯងនោះឯង រមែងញ៉ាំងអញឲ្យត្រេកអរបាន អញចាំបាច់ធ្វើឯងថ្វាយ ដូច្នេះ ។

គ្រានោះ ព្រះនាងឲ្យនាំសំឡីមកអំពីផ្សារ អង្រួន ញី ដោយព្រះហស្ត រវៃអំបោះយ៉ាងល្អិត ឲ្យសាងរោងតម្បាញខាងក្នុងព្រះរាជវាំងនោះឯង ឲ្យ ហៅជាងសិប្បៈទាំងឡាយ ព្រះរាជទានគ្រឿងបរិភោគ ខាទនីយ និងភោជនីយ របស់ព្រះនាងនោះឯង ឲ្យដល់ជាងសិប្បៈទាំងឡាយ ហើយទ្រង់ឲ្យត្បាញ សំពត់ ។ ព្រះនាងដែលគណៈកីលៀងចោមរោមហែហមហើយ ព្រះនាង ចូលទៅចាប់ចុងត្រល់តាមសមគួរដល់កាលវេលា ។ ក្នុងកាលសំពត់នោះ ត្បាញស្រេចហើយ ព្រះនាងធ្វើសក្ការៈធំដល់ជាងសិប្បៈទាំងឡាយ ហើយ ដាក់គូសំពត់មួយក្នុងហិបដែលមានក្លិនក្រអូប ឲ្យកាន់យកសំពត់ ទូលដល់

ព្រះរាជាថា ខ្ញុំម្ចាស់នឹងកាន់សំពត់ចីវរទៅថ្វាយដល់បុត្ររបស់យើង ។ ព្រះរាជាត្រាស់បញ្ជាឲ្យត្រៀមផ្លូវយានទៅ ។ ព្រះរាជបរិវារទាំងឡាយបោសសម្អាតថ្នល់ តាំងក្អមទឹកពេញ លើកទង់សំពត់ទាំងឡាយ តាក់តែងផ្លូវតាំងអំពីទ្វារព្រះរាជវាំងរហូតដល់ព្រះវិហារនិគ្រោធារាម ធ្វើផ្លូវឲ្យជេរជាសដោយផ្កា ។ ឯព្រះនាងមហាបជាបតី ទ្រង់ប្រដាប់គ្រឿងអលង្ការគ្រប់យ៉ាង ដែលគណៈភីលៀង នាងស្នំហែហមហើយ ព្រះនាងទូលហិបសំពត់ យានទៅកាន់សម្នាក់របស់ព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មី ១ គូនេះ ខ្ញុំម្ចាស់រវៃខ្លួនឯង ត្បាញខ្លួនឯង ដូច្នេះជាដើម ។

[ ១៨២ ] បទថា **ឧតិយម្បិ ខោ** សេចក្តីថា កាលព្រះមានព្រះភាគត្រាស់ថា ម្នាលនាងគោតមី ចូរព្រះនាងប្រគេនសង្ឃចុះ ព្រះនាងមហាបជា-បតិគោតមី ក្រាបទូលអង្វរថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់អាចថ្វាយសំពត់ចីវរទាំងឡាយអំពីឃ្លាំងសំពត់ ដល់ភិក្ខុ ១០០ រូបខ្លះ ១០០០ រូបខ្លះ ឯសំពត់ថ្មីគូនេះ ខ្ញុំម្ចាស់ការឯង ត្បាញឯង តាំងចិត្តឧទ្ទិសចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគមេត្តាទទួលសំពត់ថ្មីគូនោះរបស់ខ្ញុំម្ចាស់ចុះ ។ ព្រះនាងក្រាបទូលយ៉ាងនេះអស់វារៈ ៣ ដង ។ ព្រះមានព្រះភាគ ទ្រង់ហាមយ៉ាងនោះឯង ។ សួរថា ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ឲ្យថ្វាយគូសំពត់ថ្មី ដែលព្រះនាងថ្វាយដល់ព្រះអង្គ ដល់ព្រះភិក្ខុសង្ឃទៅវិញ ឆ្លើយថា ព្រោះដើម្បីទ្រង់អនុគ្រោះព្រះមាតា ។ បានឮថា ព្រះមានព្រះភាគអង្គនោះ ទ្រង់មានព្រះតម្រិះថា ចេតនា ៣ យ៉ាង គឺ-

បុព្វចេតនា មុញ្ចនចេតនា អបរាបរចេតនារបស់ព្រះនាងមហាបជាបតីនោះ កើតឡើងប្រារព្ធតថាគតហើយ ចូរកើតឡើងប្រារព្ធភិក្ខុសង្ឃខ្លះ កាលបើដូច្នេះ ចេតនាទាំង ៦ យ៉ាង ក៏រួមតែមួយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ អនុគ្រោះ ដើម្បីសេចក្ដីសុខអស់កាលដ៏យូរ ដល់ព្រះនាងមហាបជាបតិគោតមីនោះ ដូច្នេះ ។ ឯវិតណ្ឌវាទី គឺអ្នកពោលឲ្យជាក់ចិត្តជឿ ពោលថា ទានដែលថ្វាយសង្ឃមានផលច្រើន ។ គប្បីសួរវិតណ្ឌវាទីនោះថា ព្រោះហេតុអ្វីទើបពោលយ៉ាងនោះ លោករមែងពោលថា ទានដែលថ្វាយសង្ឃ មានផលច្រើនជាងទានដែលថ្វាយដល់ព្រះសាស្តាឬ ។ អើ ខ្ញុំពោល ។ ដូច្នោះ ចូរអានព្រះសូត្រមកមើល ។ វិតណ្ឌវាទីអានព្រះសូត្រថា ម្នាលគោតមី នាងចូរថ្វាយសង្ឃចុះ កាលថ្វាយសង្ឃហើយ ឈ្មោះថា ព្រះនាងបានបូជាទាំងតថាគត និងសង្ឃ ។ ព្រះសូត្រនេះមានអត្ថត្រឹមតែប៉ុណ្ណេះឬ ។ អើ មានប៉ុណ្ណេះ ។ ឧបមាថា បើយ៉ាងនោះ ទានដែលឲ្យដល់អ្នកស៊ីដែលទាំងឡាយក៏គប្បីមានផលច្រើន តាមព្រះតម្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរឲ្យនំដល់ពួកមនុស្សអ្នកស៊ីដែលចុះ និងព្រះសូត្រថា ម្នាលកច្ចាន: បើដូច្នោះ អ្នកឯងចូរឲ្យពួកមនុស្សអ្នកស៊ីដែលឆ្អែតស្កប់ស្កល់ ដោយស្ករអំពៅទាំង-ឡាយចុះ ដូច្នេះ ។ កាលបើដូច្នោះ ទើបព្រះសាស្តា ទ្រង់ញ៉ាំងសំពត់ដែលគេថ្វាយព្រះអង្គឲ្យដល់សង្ឃហើយ ដូច្នេះ ។ ជនទាំងឡាយ មានព្រះរាជា និងមហាមាត្យរបស់ព្រះរាជាជាដើម រមែងបញ្ជាឲ្យបណ្ណាការដែលនាំមកដើម្បីខ្លួន ឲ្យដល់ជនទាំងឡាយ មានអ្នកចិញ្ចឹមដំរីជាដើម ជនទាំងនោះក៏

គប្បីធំជាងព្រះរាជាជាដើម ។ ពិតហើយ ទក្ខិណេយ្យបុគ្គលដ៏កំពូលជាងព្រះតថាគតមិនមាន តាមព្រះបាលីថា ព្រោះដូច្នោះ អ្នកកុំប្រកាន់យ៉ាងនោះ ទក្ខិណេយ្យបុគ្គល ដែលដល់នូវភាពជាអគ្គនៃអាហុនេយ្យបុគ្គលទាំងឡាយ បុគ្គលត្រូវការបុណ្យ ស្វែងផលបរិបូណ៌ដ៏ប្រសើរបំផុត ដូចគ្នានឹងព្រះពុទ្ធមិនមាន ក្នុងលោកនេះ ឬលោកដទៃ ។ ចេតនា ៦ ប្រការ របស់ព្រះនាងមហាបជាបតិគោតមីនោះ រួមចូលគ្នាហើយ នឹងមានដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ អស់កាលដ៏យូរយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់ឃាត់ដល់ទៅ ៣ ដង ហើយទ្រង់ឲ្យថ្វាយដល់សង្ឃ ទ្រង់បំណងដូចម្ដេច ត្រាស់យ៉ាងនោះ ដើម្បីជនឯក្រោយ និងដើម្បីទ្រង់ឲ្យកើតសេចក្ដីកោតក្រែងក្នុងសង្ឃផង បានឮថា ព្រះមានព្រះភាគ ទ្រង់មានព្រះតម្រិះយ៉ាងនេះថា តថាគតមិនតាំងនៅយូរឡើយ តែសាសនារបស់តថាគតតាំងនៅក្នុងភិក្ខុសង្ឃ ជនឯក្រោយ ចូរញ៉ាំងសេចក្ដីក្រែងក្នុងសង្ឃឲ្យកើតឡើង ដូច្នេះ ទើបទ្រង់ឃាត់ដល់ទៅ ៣ ដង ហើយទ្រង់ឲ្យថ្វាយសង្ឃ ។ កាលបើដូច្នោះ ទើបព្រះសាស្ដាទ្រង់ឲ្យថ្វាយគូសំពត់ថ្មីដែលព្រះនាងថ្វាយព្រះអង្គឲ្យដល់សង្ឃ ទក្ខិណេយ្យបុគ្គល ឈ្មោះថា ព្រោះដូច្នោះ ជនឯក្រោយនឹងញ៉ាំងសេចក្ដីកោតក្រែងឲ្យកើតឡើងក្នុងសង្ឃ និងសម្គាល់បច្ច័យ ៤ ជាវត្ថុគប្បីថ្វាយ សង្ឃកាលមិនលំបាកដោយបច្ច័យ ៤ នឹងរៀនព្រះពុទ្ធវចនៈ ធ្វើសមណធម៌ កាលបើដូច្នោះ សាសនារបស់តថាគត នឹងតាំងនៅដល់ ៥០០០ ឆ្នាំ ដូច្នេះ ។ ពាក្យថា ធម្មតាអគ្គទក្ខិណេយ្យបុគ្គលដ៏កំពូលជាងព្រះ

សាស្តាមិនមាននោះ គួរពោលដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទទួលចុះ ដូច្នេះ ។ ព្រះអានន្ទមិនមានសេចក្តីអាឃាត ឬពៀរក្នុងព្រះនាងមហាបជាបតី ទាំងព្រះថេរៈមិនត្រូវការថា ទក្ខិណារបស់ព្រះនាង កុំបីមានផលច្រើន ។ ពិតហើយ ព្រះថេរៈជាបណ្ឌិត ជាពហូសូតសម្រេចសេក្ខប្បដិបទា ។ ព្រះថេរៈនោះ កាលឃើញសំពត់ថ្មីមួយគូ ដែលព្រះនាងថ្វាយព្រះសាស្តានោះមានផលច្រើន ទើបក្រាបទូលសូមដើម្បីទ្រង់ទទួលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគមេត្តាទទួលចុះ ដូច្នេះ ។ វិតណ្ឌវាទីពោលទៀតថា ព្រះសាស្តាទ្រង់ទាក់ទងជាមួយសង្ឃ ព្រោះព្រះតម្រាស់ថា កាលថ្វាយសង្ឃហើយ ក៏ឈ្មោះថា ព្រះនាងបានបូជាតថាគតផង សង្ឃផង ដូច្នេះ ។ វិតណ្ឌវាទីនោះគួរត្រូវចោទសួរថា លោកដឹងឬថាសរណៈមានប៉ុន្មាន ការជ្រះថ្លាពិតប្រាកដមានប៉ុន្មាន ។ វិតណ្ឌវាទីកាលដឹងក៏នឹងពោលថា សរណៈមាន ៣ ការជ្រះថ្លាពិតប្រាកដមាន ៣ ។ បន្ទាប់អំពីនោះ ក៏គួរត្រូវពោលថា តាមលទ្ធិរបស់អ្នក សរណៈក៏គង់មាន ២ យ៉ាងប៉ុណ្ណោះ ព្រោះព្រះសាស្តាទាក់ទងជាមួយសង្ឃ ។ កាលបើដូច្នោះ បព្វជ្ជាដែលទ្រង់អនុញ្ញាតយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបព្វជ្ជាឧបសម្បទាដោយត្រៃសរណគមន៍ ដូច្នេះ សូម្បីឧបសម្បទាក៏មិនចម្រើនឡើង ។ បន្ទាប់អំពីនោះ លោកក៏មិនមែនជាបព្វជិត គង់ជាគ្រហស្ថ ។ កាលព្រះសម្មាសម្ពុទ្ធ គង់ក្នុងព្រះគន្ធកុដិ ភិក្ខុទាំងឡាយធ្វើឧបោសថខ្លះ បវារណាខ្លះ សង្ឃកម្មទាំងឡាយខ្លះ កម្មទាំងនោះ ក៏គប្បីកម្រើក ព្រោះភាពដែលព្រះ

សាស្តា ទ្រង់ទាក់ទងជាមួយសង្ឃផង និងមិនមានផង ។ ព្រោះដូច្នោះ ទើប មិនគួរពោលពាក្យនេះថា ព្រះសាស្តាទ្រង់ជាប់ទាក់ទងជាមួយសង្ឃឡើយ ។

[ ១៨៣ ] បទថា **អាបាទិកា** បានដល់ ទ្រង់ឲ្យបម្រើនព្រមហើយ អធិប្បាយថា កាលព្រះហស្ត និងព្រះបាទរបស់ព្រះអង្គមិនទាន់ញុំាងកិច្ចដោយព្រះហស្ត និងព្រះបាទឲ្យសម្រេច ព្រះនាងក៏ទ្រង់ឲ្យព្រះហស្ត និងព្រះបាទឲ្យបម្រើនដោយប្រណិប័តន៍ ។ បទថា **ពោសិកា** សេចក្តីថា ព្រះនាងចិញ្ចឹមព្រះអង្គដោយឲ្យផ្ទួតទឹក ឲ្យសោយ ឲ្យផឹកមួយថ្ងៃ ២-៣ ដង ។ បទថា **ថញ្ញំ បាយេសិ** សេចក្តីថា បានឮថា នន្ទកុមារ និងព្រះពោធិសត្វ កើតមុនក្រោយគ្នា ត្រឹមតែ ២-៣ ថ្ងៃប៉ុណ្ណោះ កាលនន្ទកុមារប្រសូតហើយ ព្រះនាងមហាបជាបតិគោតមី ទ្រង់ឲ្យព្រះឱរសរបស់ព្រះនាងដល់គីលៀងនាងស្នំ ព្រះនាងឯងឲ្យនាទីនាងស្នំឲ្យសម្រេច ប្រទានព្រះខីរសេដល់ព្រះពោធិសត្វ ព្រះថេរៈសំដៅដល់ការប្រទានព្រះខីរសេនោះ ទើបក្រាបទូលយ៉ាងនេះ ។ ព្រះថេរៈកាលសម្តែងភាពដែលព្រះនាងមហាបជាបតិ មានឧបការៈច្រើន ដោយប្រការដូច្នេះហើយ ឥឡូវនេះ ដើម្បីសម្តែងភាពដែលព្រះតថាគតទ្រង់មានព្រះឧបការៈច្រើន ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគក៏មានឧបការៈច្រើន ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **ភគវន្តំ ភន្តេ អាគម្ម** គឺទ្រង់អាស្រ័យ គឺទ្រង់ពឹងពាក់ ទ្រង់សំដៅយកព្រះមានព្រះភាគ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលទ្រង់អនុមោទនាដល់ឧបការៈក្រៃលែងឡើងៗ ទៅ ក្នុងឧបការៈទាំង ២ ទើប

ត្រាស់ថា សេចក្តីនុ៎ះ យ៉ាងនោះជាដើម ។

[ ១៨៤ ] បណ្តាបទទាំងនោះ បទថា **យំ ហានន្ទ បុគ្គលោ បុគ្គលំ អាគម្ម** សេចក្តីថា បុគ្គលដែលជាអន្តេវាសិកអាស្រ័យ បុគ្គលដែលជាអាចារ្យណា ។ បទថា **ឥមស្សានន្ទ បុគ្គលស្ស ឥមិនា បុគ្គលេន** សេចក្តីថា បុគ្គលដែលជាអន្តេវាសិកនេះ តបស្នងដល់បុគ្គលដែលជាអាចារ្យនេះ ។ បទថា **ន សុប្បដិការំ វទាមិ** សេចក្តីថា តថាគតមិនពោលការតបស្នងឧបការៈ ជាការធ្វើដោយល្អ ។ ក្នុងកម្មទាំងឡាយ មានការអភិវាទនៈជាដើម គប្បីឃើញអាចារ្យ ហើយធ្វើនូវការថ្វាយបង្គំ ឈ្មោះថា អភិវាទនៈ បានដល់ កាលនឹងសម្រេចឥរិយាបថទាំងឡាយ បែរមុខទៅកាន់ទិសាភាគដែលអាចារ្យនៅ ថ្វាយបង្គំហើយ ដើរ ថ្វាយបង្គំហើយ ឈរ ថ្វាយបង្គំហើយ អង្គុយ ថ្វាយបង្គំហើយ ដេក ។ ឯការឃើញអាចារ្យអំពីចម្ងាយក្រោកឡើងធ្វើការទទួល ឈ្មោះថា បច្ចុដ្ឋាន ។ ឯកម្មនេះ គឺឃើញអាចារ្យហើយ ផ្គងអញ្ជលីដាក់លើសិរសា នមស្ការអាចារ្យ ឬបែរមុខទៅទិសាភាគដែលអាចារ្យនោះនៅ នមស្ការយ៉ាងនោះឯង ដើរទៅក្តី ឈរក្តី អង្គុយក្តី ដេកក្តី ផ្គងអញ្ជលី ហើយនមស្ការនោះឯង ឈ្មោះថា អញ្ជលិកម្ម ការធ្វើកម្មដ៏សមគួរ ឈ្មោះថា សាមីចិកម្ម ។ ក្នុងវត្ថុទាំងឡាយ មានចីវរជាដើម កាលនឹងប្រគេនចីវរ មិនប្រគេនតាមមានតាមបាន ប្រគេនចីវរ ដែលមានតម្លៃច្រើន មានតម្លៃ ១០០ខ្ទះ ៥០០ខ្ទះ ១០០០ខ្ទះ ។ ក្នុងវត្ថុទាំងឡាយ មានបិណ្ឌបាតជាដើម មានន័យដូចគ្នា ។ ដោយបច្ច័យច្រើនប៉ុណណា កាល

ញុំាងចក្រវាលឲ្យពេញដោយបច្ច័យដ៏ប្រណីតៗ ៤ កាន់យកកំពូលស្មើភ្នំសិនេរុបពិតប្រគេន រមែងមិនអាចដើម្បីធ្វើកិរិយាដែលសមគួរដល់អាចារ្យឡើយ ។

[ ១៨៥ ] ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគប្រារព្ធថា ឯទក្ខិណា ១៤ នេះឯង ។ សូត្រនេះ កើតឡើងប្រារព្ធទក្ខិណាជាបាដិបុគ្គលិក ។ ឯព្រះអានន្ទកាន់យកទក្ខិណាជាបាដិបុគ្គលិកតែម្យ៉ាងថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគមេត្តាទទួល ដូច្នេះ ។ តែព្រះមានព្រះភាគទ្រង់ប្រារព្ធទេសនានេះ ដើម្បីទ្រង់សម្តែងថា ទានដែលបុគ្គលឲ្យហើយ ក្នុងឋានៈ ១៤ ឈ្មោះថា ជាបាដិបុគ្គលិក ។ បទថា **អយំ បឋមា** សេចក្តីថា ទក្ខិណានេះជាប្រការទី ១ ដោយអំណាចគុណខ្លះ ដោយអំណាចជាទក្ខិណាចម្រើនបំផុតខ្លះ ពិតហើយ ទក្ខិណានេះទី ១ គឺប្រសើរ បានដល់ ចម្រើនបំផុត ឈ្មោះថា ប្រមាណនៃទក្ខិណានេះមិនមាន ។ ទក្ខិណាប្រការទី ២-៣ ជាទក្ខិណាក្រៃលែងដូចគ្នា ។ ទក្ខិណាទាំងឡាយដ៏សេស រមែងមិនដល់នូវភាពជាទក្ខិណាដ៏ក្រៃលែងបាន ។ បទថា **ពាហិរកេ កាមេសុ វីតរាគេ** បានដល់កម្មវាទីបុគ្គល កិរិយវាទីបុគ្គល បុគ្គលដែលមានអភិញ្ញា ៥ ដែលជាលោកិយ ។ បទថា **បុថុជ្ជនសីលវា** សេចក្តីថា បុថុជ្ជនអ្នកមានសីលដោយឈ្មោះ ជាអ្នកមានសីលជាបាទ មិនអួតអាង មិនមានមាយា មិនបៀតបៀនអ្នកដទៃ សម្រេចជីវិតដោយកសិកម្ម ឬពាណិជកម្ម ដោយធម៌ដ៏ប្រពៃ ។ បទថា **បុថុជ្ជនទុស្សីលេ** សេចក្តីថា បុគ្គលទាំងឡាយ មាននាយគេវដ្ដៈ និង

អ្នកចាប់ត្រីជាដើម ឈ្មោះថា បុថុជ្ជនទុស្សីល ចិញ្ចឹមជីវិតដោយការបៀតបៀនសត្វដទៃ ។

[ ១៨៦ ] ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់កំណត់វិបាកនៃទក្ខិណា ជាបាដិបុគ្គលិក ទើបត្រាស់ថា **តត្រានន្ទ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **តិរច្ឆានគតេ** សេចក្ដីថា ទានណាដែលបុគ្គលឲ្យហើយ ដើម្បីចិញ្ចឹម ដោយអំណាចនៃគុណ ដោយអំណាចនៃឧបការៈ ទាននេះមិនកាន់យក ។ ទានណាគ្រាន់តែបាយមួយពំនូត ឬកន្ទះពំនូត បុគ្គលឲ្យហើយ ទាននោះមិនកាន់យកហើយ ។ ឯទានណាដែលបុគ្គលសង្ឃឹមផល ហើយឲ្យតាមសេចក្ដីត្រូវការដល់សត្វទាំងឡាយ មានឆ្កែ ជ្រូក មាន់ និងក្អែកជាដើមណាមួយដែលមកដល់ ទ្រង់សំដៅទាននេះ ទើបត្រាស់ថា ឲ្យទានក្នុងសត្វតិរច្ឆានដូច្នេះ ។ បទថា **សតគុណា** បានដល់ មានអានិសង្ស ១០០ ដង ។ បទថា **ចាដិកង្ខិតព្វា** គឺគប្បីប្រាថ្នា អធិប្បាយថា ទក្ខិណានេះរមែងឲ្យអានិសង្ស ៥០០ ដង គឺអាយុ ១០០ ដង ពណ៌សម្បុរ ១០០ ដង សេចក្ដីសុខ ១០០ ដង កម្លាំង ១០០ ដង បដិភាណ ១០០ ដង ។ ទក្ខិណាឲ្យអាយុក្នុង ១០០ អត្តភាព ឈ្មោះថា អាយុ ១០០ ដង ឲ្យវណ្ណៈ ១០០ អត្តភាព ឈ្មោះថា វណ្ណៈ ១០០ ដង ឲ្យសុខ ១០០ អត្តភាព ឈ្មោះថា សុខ ១០០ ដង ឲ្យពលក្នុង ១០០ អត្តភាព ឈ្មោះថា ពល ១០០ ដង ឲ្យបដិភាណ ធ្វើនូវការមិនតក់ស្លុតក្នុង ១០០ អត្តភាព ឈ្មោះថា បដិភាណ ១០០ ដង ។ ក្នុងកត ១០០ ដង ដែលលោកពោលហើយ ក៏មានន័យយ៉ាងនេះឯង គប្បី

ជ្រាបន័យគ្រប់បទ ដោយទំនងយ៉ាងនេះ ។ ក្នុងពាក្យនេះថា បុគ្គលដែលប្រតិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល សូម្បីឧបាសកដែលដល់នូវត្រៃសរណៈ ដោយហោចយ៉ាងទាប ឈ្មោះថា បដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ ទានដែលឲ្យហើយក្នុងឧបាសក អ្នកបដិបត្តិដើម្បីឲ្យជាក់ច្បាស់នូវសោតាបត្តិផលនោះ រាប់មិនបាន ប្រមាណមិនបាន ។ ឯទានដែលឲ្យដល់បុគ្គលដែលតាំងនៅក្នុងសីល ៥ មានផលច្រើនជាងនោះ ។ ទានដែលឲ្យដល់បុគ្គលដែលតាំងនៅក្នុងសីល ១០ មានផលច្រើនជាងនោះទៀត ។ ទានដែលឲ្យដល់សាមណេរដែលបួសក្នុងថ្ងៃនោះ មានផលច្រើនជាងនោះ ទានដែលឲ្យដល់ភិក្ខុ ដែលឧបសម្បទាមានផលច្រើនជាងនោះ ទានដែលឲ្យដល់ភិក្ខុដែលឧបសម្បទានោះឯង ដែលដល់ព្រមដល់វត្តមានផលច្រើនជាងនោះ ទានដែលឲ្យដល់អ្នកប្រារព្ធវិបស្សនា មានផលច្រើនជាងនោះ ។ សម្រាប់បុគ្គលដែលជាមគ្គសមង្គី ដោយហោចត្រឹមបុគ្គលដែលបដិបត្តិដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ឈ្មោះថា បដិបត្តិហើយ ។ ទានដែលឲ្យដល់បុគ្គលនោះ មានផលច្រើនជាងនោះទៅទៀត ។ សួរថា អាចដើម្បីឲ្យទាន ដល់ភិក្ខុដែលជាមគ្គសមង្គីឬ ឆ្លើយថា អើ អាចដើម្បីឲ្យ ។ ភិក្ខុអ្នកប្រារព្ធវិបស្សនា កាន់បាត្រ និងចីវរចូលស្រុក ដើម្បីបិណ្ឌបាត ។ កាលភិក្ខុដែលជាមគ្គសមង្គីនោះ ឈរត្រង់ទ្វារស្រុក ជនទាំងឡាយទទួលបាត្រអំពីដៃ ក៏ដាក់ខាទនីយ និងភោជនីយ ។ ការចេញចាកមគ្គរបស់ភិក្ខុរមែងមានក្នុងខណៈនោះ។ ទាននេះ ឈ្មោះថា ឲ្យហើយដល់ភិក្ខុដែលជាមគ្គ-

សមង្គី ។ មួយប្រការទៀត ភិក្ខុនោះ អង្គុយក្នុងរោងឆាន់ មនុស្សទាំងឡាយ ទៅហើយ ដាក់ខាទនីយ ភោជនីយក្នុងបាត្រ ការចេញចាកមគ្គរបស់ភិក្ខុនោះ រមែងមានក្នុងខណៈនោះ ។ ទាននេះ ឈ្មោះថា ឲ្យហើយដល់ភិក្ខុដែលជាមគ្គសមង្គី ។ម្យ៉ាងទៀត កាលភិក្ខុនោះអង្គុយក្នុងវិហារ ឬរោងឆាន់ ឧបាសកទាំងឡាយកាន់បាត្រទៅកាន់ផ្ទះនៃខ្លួន ហើយដាក់ខាទនីយ និងភោជនីយ ។ ការចេញចាកមគ្គនៃភិក្ខុនោះ តែងមានក្នុងខណៈនោះ ។ ទាននេះ ឈ្មោះថា ឲ្យហើយដល់ភិក្ខុដែលជាមគ្គសមង្គី គប្បីជ្រាបទានដែលបុគ្គលឲ្យហើយដល់អ្នកបដិបត្តិដើម្បីធ្វើឲ្យជាក់នូវសោតាបត្តិផលនោះ ដូចទឹកក្នុងត្រពាំង មិនអាចរាប់បាន ដូច្នោះ ។ គប្បីជ្រាបទាន ដែលបុគ្គលឲ្យហើយ ក្នុងបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម ដូចទឹកក្នុងមហាសមុទ្រនោះឯង ក្នុងបណ្តាមហាទានទីនោះៗ ជាការរាប់មិនបាន ។ គប្បីសម្តែងអត្ថនេះ ដោយការដែលធ្វើធូលីក្នុងទីលានស្រូវនៃផែនដីជាដើម រហូតដល់ធូលីពេញផែនដីដែលប្រមាណមិនបាន ។

ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគទ្រង់ប្រារព្ធថា ទក្ខិណា ៧ យ៉ាងនេះ ទ្រង់ប្រារព្ធទេសនានេះ ដែលត្រាស់ថា ម្នាលគោតមី សូមព្រះនាងថ្វាយសង្ឃចុះ កាលថ្វាយសង្ឃហើយ ឈ្មោះថា ព្រះនាងបានបូជាតថាគតផង សង្ឃផង ដើម្បីទ្រង់សម្តែងថា ទានដែលឲ្យក្នុងឋានៈ ៧ នោះ ឈ្មោះថា ថ្វាយសង្ឃហើយ ។

[ ១៨៧ ] បណ្តាបទទាំងនោះ បទថា **ពុទ្ធប្បមុខេ ឧភតោសង្ឃេ** សេចក្តី

ថា សង្ឃនេះ គឺភិក្ខុសង្ឃចំណែកមួយ ភិក្ខុនីសង្ឃចំណែកមួយ ព្រះសាស្តាប្រថាប់គង់ក្នុងកណ្តាល ឈ្មោះថា សង្ឃ ២ ចំណែកមានព្រះពុទ្ធជាប្រធាន ។ បទថា **អយំ បឋមា** សេចក្តីថា ឈ្មោះថា ទក្ខិណាមានប្រមាណស្មើដោយទក្ខិណានេះមិនមាន ។ ទក្ខិណាទាំងឡាយ មានទក្ខិណាទី ២ ជាដើម រមែងមិនដល់ទក្ខិណានោះ ។ សួរថា កាលព្រះសាស្តាបរិនិព្វានហើយ អាចថ្វាយទានដល់សង្ឃ ២ ចំណែក មានព្រះពុទ្ធជាប្រធានបានដែរឬ ។ ឆ្លើយថា អាច ។ អាចដូចម្តេច ។ គប្បីតាំងព្រះពុទ្ធរូប ដែលមានព្រះធាតុ ក្នុងឋានៈជាប្រធានរបស់សង្ឃ ២ ចំណែក ក្នុងអាសនៈដាក់តាំងថ្វាយវត្ថុទាំងឡាយ មានទក្ខិណោទកជាដើមដល់ព្រះសាស្តាមុន ហើយថ្វាយដល់សង្ឃ ២ ចំណែក ។ ទានដែលឈ្មោះថា ថ្វាយសង្ឃ ២ ចំណែក មានព្រះពុទ្ធជាប្រធាន ដោយប្រការដូច្នេះ ។ សួរថា ក្នុងព្រះសង្ឃ ២ ចំណែកនោះ ទានណាថ្វាយព្រះសាស្តា ទាននោះគប្បីធ្វើដូចម្តេច ។ ឆ្លើយថា គប្បីប្រគេនដល់ភិក្ខុដែលដល់ព្រមដោយវត្ត ដែលបដិបត្តិព្រះសាស្តា ព្រោះថា ទ្រព្យដែលជារបស់បិតា រមែងគួរដល់បុត្រ ។ សូម្បីការថ្វាយទានដល់ភិក្ខុសង្ឃក៏គួរ ។ ឯសប្បិ និងប្រេង គប្បីអុជធ្វើជាប្រទីប សំពត់សាដក គប្បីលើកជាទង់ ។ បទថា **ភិក្ខុសង្ឃេ** បានដល់ ភិក្ខុសង្ឃចំណែកច្រើនមិនទាន់ដាច់ខ្សែ ។ ក្នុងភិក្ខុនីសង្ឃនោះ ក៏មានន័យដូចគ្នា ។

[ ១៨៨ ] បទថា **គោត្រភុនោ** បានដល់ សោយត្រឹមតែគោត្រប៉ុណ្ណោះ អធិប្បាយថា ជាសមណៈតែឈ្មោះ ។ បទថា **កាសាវកណ្ឋា** គឺដែលមាន

ឈ្មោះថា មានកាសាវៈរុំក បានឮថា ភិក្ខុទាំងនោះយកសំពត់សាកាវៈមួយផ្ចាំងចងត្រង់ដៃ ឬត្រង់កត្រាច់ទៅ ។ ឯទ្វារស្រុក សូម្បីកម្ម មានបុត្រកិរិយាកសិកម្ម និងពាណិជកម្មជាដើមរបស់ភិក្ខុទ្រុស្តសីលទាំងនោះ ក៏នៅជាប្រក្រតីនោះឯង ។ មិនបានត្រាស់ថា សង្ឃទ្រុស្តសីល ក្នុងបទនេះថា មនុស្សទាំងឡាយ នឹងថ្វាយទានចំពោះសង្ឃបាន ក្នុងពួកភិក្ខុទ្រុស្តសីលនោះ ពិតហើយសង្ឃឈ្មោះថា ទ្រុស្តសីលមិនមាន តែឧបាសកទាំងឡាយឈ្មោះថា ទ្រុស្តសីល នឹងថ្វាយទានដោយគិតថា អញនឹងថ្វាយសំពោះសង្ឃក្នុងពួកភិក្ខុទ្រុស្តសីលនោះ ។

ទក្ខិណាដែលថ្វាយសង្ឃ មានព្រះពុទ្ធជាប្រធាន ដែលព្រះមានព្រះភាគត្រាស់ថា មានផលរាប់មិនបាន ដោយការរាប់គុណ ដោយប្រការដូច្នេះ ។ សូម្បីទក្ខិណា ដែលឲ្យក្នុងសង្ឃ ដែលមានភិក្ខុមានសំពត់កាសាវៈរុំកត្រាស់ថា មានផលរាប់មិនបាន ដោយការរាប់គុណដូចគ្នា ឯទក្ខិណាដែលដល់សង្ឃ រមែងមានដល់បុគ្គលដែលអាចធ្វើសេចក្តីកោតក្រែងក្នុងសង្ឃ ។ តែការកោតក្រែងក្នុងសង្ឃធ្វើបានលំបាក ។ បុគ្គលណាត្រៀមទេយ្យធម៌ដោយគិតថា អញនឹងឲ្យទក្ខិណាដល់សង្ឃ ទៅវិហារហើយ សួរថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យព្រះថេរៈមួយរូបឧទ្ទិសចំពោះសង្ឃចុះ ។ លំដាប់នោះ បានសាមណេរអំពីសង្ឃ រមែងដល់នូវភាពជាប្រការដទៃថា អញបានសាមណេរហើយ ដូច្នេះ ។ ទក្ខិណានៃបុគ្គលនោះ រមែងមិនដល់សង្ឃ ។ កាលបានព្រះមហាថេរៈ ក៏កើតសោមនស្សថា អញបានមហាថេរៈ

ហើយ ដូច្នេះ ទក្ខិណាក៏មិនដល់សង្ឃដូចគ្នា ឯបុគ្គលណាបានសាមណេរក្តី ឧបសម្បន្នក្តី ភិក្ខុកំលោះក្តី ព្រះថេរៈក្តី ពាលក្តី បណ្ឌិតក្តី ណាមួយ អំពីសម្នាក់សង្ឃ ហើយមិនសង្ស័យ រមែងធ្វើសេចក្តីកោតក្រែងក្នុងសង្ឃថា អញនឹងថ្វាយសង្ឃ ទក្ខិណានៃបុគ្គលនោះ ឈ្មោះថា ដល់សង្ឃហើយ ។ បានឮថា ពួកឧបាសកអ្នកដែនសមុទ្រខាងនាយធ្វើយ៉ាងនេះ ។ ក្នុងឧបាសកទាំងនោះ ម្នាក់ជាម្ចាស់របស់វត្ត ជាកុដុម្ពិកៈឧទ្ទិសចំពោះសង្ឃថា ខ្ញុំនឹងថ្វាយទក្ខិណាដល់សង្ឃ ទើបនិមន្តថា សូមលោកម្ចាស់ឲ្យភិក្ខុមួយរូប ។ ឧបាសកនោះ បានភិក្ខុទ្រុស្តសីលមួយរូប នាំទៅកាន់ទីអង្គុយ ក្រាលអាសនៈ ចងពិតានខាងលើ បូជាដោយគ្រឿងក្រអូប ផ្សែងក្រអូប និងផ្កា លាងជើងលាបដោយប្រេង បានថ្វាយទេយ្យធម៌ ដោយការកោតក្រែងក្នុងសង្ឃ ។ ដូចធ្វើការគោរពកោតក្រែងដល់ព្រះសម្មាសម្ពុទ្ធ ។ ភិក្ខុរូបនោះមកកាន់ទ្វារផ្ទះគិតថា អ្នកចូរឲ្យចបដើម្បីប្រយោជន៍ ដល់កិច្ចបដិបត្តិវត្តក្នុងកាលខាងក្រោយកត្ត ។ ឧបាសកនោះគ្ពុះចបដោយជើង ហើយឲ្យថា ចូរទទួលទៅ ។ មនុស្សទាំងឡាយបានពោលនឹងគាត់ថា អ្នកបានធ្វើសក្ការៈដល់ភិក្ខុនេះអំពីព្រឹក មិនអាចនឹងពោល ឥឡូវនេះ គ្រាន់តែឧបចារៈ គឺមារយាទក៏មិនមាន តើសេចក្តីនេះដូចម្តេច ។ ឧបាសកពោលថា នៃអ្នក ការកោតក្រែងនោះមានចំពោះសង្ឃ មិនមានដល់ភិក្ខុនោះ សួរថា បុគ្គលណារមែងញ៉ាំងទក្ខិណាដែលថ្វាយសង្ឃ ដែលមានភិក្ខុមានសំពត់កាសាវៈរុំកឲ្យបរិសុទ្ធ ។ ឆ្លើយថា ព្រះមហាថេរៈ ៨០ រូប មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាដើម រមែងឲ្យ

បរិសុទ្ធបាន ។ម្យ៉ាងទៀត ព្រះថេរៈទាំងឡាយបរិនិព្វានយូរហើយ ព្រះទីណាស្រេពទាំងឡាយនៅមានជីវិត តាំងអំពីព្រះថេរៈជាដើម រហូតដល់សព្វថ្ងៃនេះ រមែងឲ្យបរិសុទ្ធដូចគ្នា ។

ក្នុងបទនេះថា ម្នាលអានន្ទ តថាគតមិនដែលពោលនូវបាដិបុគ្គលិក-ទានថា មានផលច្រើនជាងសង្ឃគតាទក្ខិណាទាន ដោយបរិយាយណាមួយឡើយ ។ សង្ឃមានព្រះពុទ្ធជាប្រធាន មាន សង្ឃបច្ចុប្បន្ននេះ មាន សង្ឃដែលភិក្ខុមានសំពត់កាសាវៈរុំកក្នុងអនាគត ក៏មាន សង្ឃដែលមានព្រះពុទ្ធជាប្រធាន មិនគប្បីនាំចូលទៅជាមួយសង្ឃក្នុងបច្ចុប្បន្ននេះ សង្ឃក្នុងបច្ចុប្បន្ននេះក៏មិនគប្បីនាំចូលទៅជាមួយសង្ឃ ដែលមានសំពត់កាសាវៈរុំកក្នុងអនាគត ។ គប្បីពោលតាមសម័យប៉ុណ្ណោះ ។ ឯសមណបុថុជ្ជន ដែលនាំទៅចំពោះចាកសង្ឃ ជាបាដិបុគ្គលិកសោតាបន្ន កាលបុគ្គលអាចធ្វើការកោតក្រែងក្នុងសង្ឃទានដែលឲ្យក្នុងសមណបុថុជ្ជន មានផលច្រើនជាង ។ ក្នុងពាក្យជាដើមថា សោតាបន្នដែលទាយកឧទ្ទិសចំពោះ ជាបាដិបុគ្គលិកសកទាគាមី ក៏មានន័យនេះដូចគ្នា ។ ពិតហើយ កាលបុគ្គលអាចធ្វើសេចក្ដីកោតក្រែងក្នុងសង្ឃ ឲ្យទានក្នុងភិក្ខុទ្រុស្តសីល មានផលច្រើនជាងទានដែលបុគ្គលថ្វាយឧទ្ទិសក្នុងព្រះទីណាស្រេពនោះឯង ។ ពាក្យណា ដែលពោលថា បពិត្រមហារាជ ទានដែលឲ្យដល់បុគ្គលមានសីលនោះឯងមានផលច្រើន ទានដែលឲ្យក្នុងបុគ្គលទ្រុស្តសីល មិនមានផលច្រើនឡើយ ពាក្យនោះ គប្បីលះន័យនេះ ហើយគប្បីឃើញក្នុងចតុក្កៈនេះថា ម្នាលអានន្ទ សេចក្តីបរិសុទ្ធនៃទក្ខិណានេះ មាន

*៤ យ៉ាង ។*

*[ ១៨៩-១៩៣ ] បទថា* **ទាយកតោ វិសុជ្ឈតិ** *សេចក្តីថា ទក្ខិណាខ្លះ បរិសុទ្ធដោយការមានផលច្រើន អធិប្បាយថា ជាទានមានផលច្រើន ។ បទថា* **កល្យាណធម្មោ** *បានដល់ មានសុចិធម៌ ។ បទថា* **ចាបធម្មោ** *គឺមានធម៌ដ៏លាមក ។ គប្បីសម្តែងព្រះវេស្សន្តរមហារាជ ក្នុងបទនេះថា ទក្ខិណាខ្លះបរិសុទ្ធខាងទាយក ។ ព្រះវេស្សន្តរមហារាជ ទ្រង់ឲ្យព្រះឱរស ព្រះធីតាដល់ជូជកព្រាហ្មណ៍ហើយ ញ៉ាំងផែនដីឲ្យកម្រើក គប្បីសម្តែងនាយកេវដ្ដៈដែលអាស្រ័យនៅត្រង់ទ្វារទឹក កល្យាណនទី ក្នុងពាក្យនេះថា ទក្ខិណាណាមួយបរិសុទ្ធខាងបដិគ្គាហកៈ ។ បានឮថា កេវដ្ដៈនោះបានថ្វាយបិណ្ឌបាតដល់ព្រះទីឃសោមត្ថេរដល់ទៅ ៣ ដង ដេកលើគ្រែសម្រាប់ស្លាប់ បានពោលថា បិណ្ឌបាតដែលថ្វាយដល់លោកម្ចាស់ទីឃសោមត្ថេរ រមែងលើកខ្ញុំឡើង ។ គប្បីសម្តែងដល់ព្រានដែលនៅត្រង់ភ្នំវឡ្លមានជាដើម ។ ក្នុងបទថា* **នេវ ទាយកតោ** *នេះ បានឮថា នាយព្រាននោះ កាលឲ្យទក្ខិណាឧទ្ទិសដល់អ្នកស្លាប់ បានឲ្យដល់អ្នកទ្រុស្តសីលមួយរូប អស់ ៣ ដង ។ ក្នុងកាលទី ៣ អមនុស្សស្រែកឡើងថា អ្នកទ្រុស្តសីលប្លន់ខ្ញុំ ដូច្នោះ ។ ក្នុងវេលាដែលព្រាននោះ ឲ្យដល់ភិក្ខុអ្នកមានសីលមួយរូបដែលមកដល់ ផលរបស់ទក្ខិណាក៏ដល់អមនុស្សនោះ ។ គប្បីសម្តែងអសទិសទាន ក្នុងពាក្យនេះថា ទក្ខិណាខ្លះបរិសុទ្ធខាងទាយកប៉ុណ្ណោះ ។*

*ក្នុងពាក្យថា ទក្ខិណានោះបរិសុទ្ធខាងទាយកនេះ គប្បីជ្រាបការបរិសុទ្ធិ*

នៃទានក្នុងបទទាំងពួង ដោយទំនងនេះថា អ្នកស្រែដ៏ឈ្លាស បានស្រែមិនល្អ ក្តួរក្នុងសម័យកម្ចាត់ធូលី ដាំពូជដែលមានសារៈ មើលថែអស់យប់ និងថ្ងៃ កាលមិនដល់នូវសេចក្តីប្រមាទ រមែងបានស្រូវល្អជាងស្រែដែលមិនមើលថែ របស់អ្នកដទៃ យ៉ាងណា អ្នកមានសីល សូម្បីឲ្យទានដល់អ្នកទ្រុស្តសីល រមែងបានផលច្រើន ដូច្នោះ ។

[ ១៩៤ ] ក្នុងបទថា **វីតរាគោ វីតរាគេសុ** នេះ ព្រះអនាគាមី ឈ្មោះថា ប្រាសចាករាគៈ ឯព្រះអរហន្ត ជាអ្នកប្រាសចាករាគៈដោយឥត សេសសល់នោះឯង ព្រោះដូច្នោះ ទានដែលព្រះអរហន្តឲ្យដល់ព្រះអរហន្ត នោះឯង ជាអគ្គទាន ។ ព្រោះហេតុអ្វី ព្រោះមិនមានការប្រាថ្នាភពរបស់អ្នក អាល័យក្នុងភព ។ សួរថា ព្រះខីណាស្រពរមែងមិនជឿផលទានមិនមែនឬ ។ ឆ្លើយថា បុគ្គលទាំងឡាយជឿផលទានស្មើដូចព្រះខីណាស្រពមិនមាន កម្ម ដែលព្រះខីណាស្រពធ្វើហើយ មិនជាកុសល ឬអកុសល ព្រោះជាអ្នកប្រាស ចាកឆន្ទរាគៈហើយ រមែងតាំងនៅក្នុងឋានៈជាកិរិយា ដោយហេតុនោះ ទើប បណ្ឌិតទាំងឡាយពោលថា ទានរបស់ព្រះខីណាស្រពនោះ មានផលដ៏លើស ដូច្នេះ ។ សួរថា ទានដែលព្រះសម្មាសម្ពុទ្ធឲ្យដល់ព្រះសារីបុត្រ មានផល ច្រើន ឬទានដែលព្រះសារីបុត្រថ្វាយដល់ព្រះសម្មាសម្ពុទ្ធមានផលច្រើន ។ ឆ្លើយថា បណ្ឌិតទាំងឡាយពោលថា ទានដែលព្រះសម្មាសម្ពុទ្ធឲ្យដល់ព្រះ សារីបុត្រមានផលច្រើន ព្រោះហេតុអ្វី ព្រោះបុគ្គលដទៃ វៀរព្រះសម្មាសម្ពុទ្ធ ឈ្មោះថា អាចឲ្យផលទានកើតឡើងមិនមាន ។ ពិតហើយ ទានរមែងឲ្យផល

ដល់អ្នកអាចដើម្បីធ្វើដោយសម្បទា ៤ ក្នុងអត្តភាពនោះឯង ។ សម្បទាក្នុងសូត្រនេះមានដូច្នេះ គឺទេយ្យធម៌មិនបៀតបៀនអ្នកដទៃ កើតឡើងដោយធម៌ដ៏ប្រពៃ ។ ចេតនា មានបុព្វចេតនាជាដើម ជាធម៌ធំ ។ ភាពជាអ្នកមានគុណដ៏ក្រៃលែង ដោយភាពជាព្រះខីណាស្រព ។ ការដល់ព្រមដោយវត្ថុ ដោយភាពជាអ្នកចេញហើយអំពីនិរោធក្នុងថ្ងៃនោះ ដូច្នេះ ។

អដ្ឋកថា ទក្ខិណាវិភង្គសូត្រ ចប់

សូត្រទី ១២ ចប់

វគ្គទី ៤ ចប់

# សុត្តន្តបិដក

## សឡាយតនវគ្គ

### អនាថបិណ្ឌិកោវាទសូត្រទី ១

[ ១៩៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកគហបតី ជិតក្រុងសាវត្ថី ។ សម័យនោះឯង អនាថបិណ្ឌិកគហបតី មានអាពាធដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ ។ គ្រានោះ អនាថបិណ្ឌិកគហបតី ហៅបុរសម្នាក់មកថា នែបុរសដ៏ចម្រើន អ្នកឯងចូរមកអាយ ចូរអ្នកទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ចូរអ្នកថ្វាយបង្គំព្រះបាទា ព្រះមានព្រះភាគដោយសិរ្សៈ តាមពាក្យរបស់យើងរួចហើយចូរក្រាបបង្គំទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន អនាថបិណ្ឌិក-គហបតីមានអាពាធ ដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់ក្រាបថ្វាយបង្គំព្រះបាទា ព្រះមានព្រះភាគដោយសិរ្សៈ រួចហើយ ចូរអ្នកទៅគាល់ព្រះសារីបុត្រមានអាយុ លុះចូលទៅដល់ហើយ ចូរអ្នកថ្វាយបង្គំព្រះបាទា ព្រះសារីបុត្រមានអាយុ តាមពាក្យរបស់យើង រួចហើយ ចូរអ្នកទូលយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន អនាថបិណ្ឌិកគហបតី មានអាពាធដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់ថ្វាយបង្គំព្រះបាទា ព្រះសារីបុត្រមានអាយុ ដោយសិរ្សៈ ដូច្នេះផង ចូរអ្នកទូលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណាសូមអង្វរ សូមព្រះសារីបុត្រមានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះ ចូលទៅកាន់លំនៅរបស់អនាថបិណ្ឌិកគហបតី ដូច្នេះផង ។ បុរសនោះ ទទួលពាក្យ

អនាថបិណ្ឌិកគហបតីថា បាទ លោកដ៏ចម្រើន ហើយក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគរួចហើយ អង្គុយក្នុងទីដ៏សមគួរ ។

[ ១៩៦ ] លុះបុរសនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន អនាថបិណ្ឌិកគហបតីមានអាពាធដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់ក្រាបថ្វាយបង្គំ ព្រះបាទាព្រះមានព្រះភាគដោយសិរ្បៈ ហើយបុរសនោះ ក៏ចូលទៅរកព្រះសារីបុត្រមានអាយុ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះសារីបុត្រមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។ លុះបុរសនោះអង្គុយក្នុងទីសមគួរហើយ ក៏ទូលព្រះសារីបុត្រមានអាយុដូច្នេះថា បពិត្រលោកដ៏ចម្រើន អនាថបិណ្ឌិកគហបតីមានអាពាធដល់នូវសេចក្តីទុក្ខ មានជំងឺធ្ងន់ គាត់ថ្វាយបង្គំព្រះបាទា ព្រះសារីបុត្រមានអាយុដោយសិរ្បៈ ហើយបុរសនោះក៏ទូលយ៉ាងនេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំព្រះករុណាសូមអង្វរ សូមព្រះសារីបុត្រមានអាយុ អាស្រ័យនូវសេចក្តីអនុគ្រោះចូលទៅកាន់ផ្ទះរបស់អនាថបិណ្ឌិកគហបតី ( ឲ្យទាន ) ។ ព្រះសារីបុត្រមានអាយុ ក៏ទទួលនិមន្តន៍ដោយតុណ្ហីភាព ។ លំដាប់នោះ ព្រះសារីបុត្រមានអាយុស្លៀកស្បង់ ប្រដាប់ដោយបាត្រ និងចីវរ មានព្រះអានន្ទមានអាយុជាបច្ឆាសមណៈ ក៏ចូលទៅកាន់ផ្ទះរបស់អនាថបិណ្ឌិកគហបតី លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈដែលគេក្រាលប្រគេន ។

[ ១៩៧ ] លុះព្រះសារីបុត្រមានអាយុ គង់រួចហើយ ក៏មានថេរវាចា

នឹងអនាថបិណ្ឌិកគហបតីដូច្នេះថា ម្នាលគហបតី សរីរយន្តអ្នកល្មមអត់ធន់បានដែរឬ ល្មមឲ្យប្រព្រឹត្តទៅបានដែរឬ ទុក្ខវេទនាបានស្រាកស្រាន្ត មិនចម្រើនឡើងទេឬ ការធូរថយរមែងប្រាកដ ឯការចម្រើនឡើងរមែងមិនប្រាកដទេឬ ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ទុក្ខវេទនាដ៏ក្លារបស់ខ្ញុំ ចេះតែចម្រើនឡើង មិនស្រាកស្រាន្តទេ ការចម្រើនចេះតែប្រាកដ ការធូរថយមិនប្រាកដទេ ។

[ ១៩៨ ] បពិត្រព្រះសារីបុត្រដ៏ចម្រើន បុរសមានកម្លាំង ចាក់អំបែងក្បាល ដោយដែកស្រួចមុត យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្យល់ដ៏ខ្លាំង ចាក់ដោយអំបែងក្បាលខ្ញុំ ក៏យ៉ាងនោះដែរ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាដ៏ក្លារបស់ខ្ញុំ រមែងចម្រើនឡើង មិនស្រាកស្រាន្តទេ មានតែរឹតឡើង ឥតធូរថយសោះ ។

[ ១៩៩ ] បពិត្រព្រះសារីបុត្រដ៏ចម្រើន បុរសមានកម្លាំងយកចន្លាយព្រ័ត្រដ៏មាំ មកត្របែងក្បាល យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្យល់ដ៏ខ្លាំង ធ្មៀលក្បាលខ្ញុំ ក៏យ៉ាងនោះដែរ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាដ៏ក្លារបស់ខ្ញុំ តែងចម្រើនឡើង មិនស្រាកស្រាន្តទេ មានតែរឹតឡើង ឥតធូរថយសោះ ។

[ ២០០ ] បពិត្រព្រះសារីបុត្រដ៏ចម្រើន អ្នកសម្លាប់គោក្តី កូនសិស្សរបស់អ្នកសម្លាប់គោ ដ៏ឈ្លាសក្តី វះពោះដោយកាំបិត សម្រាប់វះគោដ៏មុត

យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្យល់ដែលខ្លាំងរមែងអាវពោះរបស់ខ្ញុំ ក៏យ៉ាងនោះឯង បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនាដ៏ក្លារបស់ខ្ញុំ តែងចម្រើនឡើង មិនស្រាកស្រាន្ត មានតែរឹតតែឡើង ឥតធូរថយសោះ ។

[ ២០១ ] បពិត្រព្រះសារីបុត្រដ៏ចម្រើន បុរស ២ នាក់ មានកម្លាំង ចាប់បុរសម្នាក់ដែលខ្សោយជាង ត្រង់ដើមដៃទាំងពីរ រោលកម្តៅលើរណ្តៅរងើកភ្លើង យ៉ាងណាមិញ បពិត្រព្រះសារីបុត្រដ៏ចម្រើន ឯសេចក្តីក្តៅក្រហាយដ៏ខ្លាំងក្នុងកាយរបស់ខ្ញុំ ក៏យ៉ាងនោះឯង បពិត្រព្រះសារីបុត្រដ៏ចម្រើន ខ្ញុំអត់ធន់មិនបានទេ ឲ្យប្រព្រឹត្តទៅមិនបានទេ ព្រោះទុក្ខវេទនា ដ៏ក្លារបស់ខ្ញុំ តែងចម្រើនឡើង មិនស្រាកស្រាន្តទេ មានតែរឹតតែឡើង ឥតធូរថយសោះ ។

[ ២០២ ] ព្រះសារីបុត្រតបថា ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចក្ខុ ទាំងវិញ្ញាណដែលអាស្រ័យចក្ខុ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវត្រចៀក ទាំងវិញ្ញាណដែលអាស្រ័យត្រចៀក របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវច្រមុះ ទាំងវិញ្ញាណដែលអាស្រ័យច្រមុះរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាល

គហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវអណ្តាត ទាំងវិញ្ញាណដែលអាស្រ័យអណ្តាត របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវកាយ ទាំងវិញ្ញាណដែលអាស្រ័យកាយរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចិត្ត ទាំងវិញ្ញាណដែលអាស្រ័យចិត្តរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ២០៣ ] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវរូប ទាំងវិញ្ញាណដែលអាស្រ័យរូបរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវសំឡេង ... នឹងមិនប្រកាន់នូវក្លិន ... នឹងមិនប្រកាន់នូវរស ... នឹងមិនប្រកាន់នូវផ្សព្វ ... នឹងមិនប្រកាន់នូវធម្មារម្មណ៍ ទាំងវិញ្ញាណដែលអាស្រ័យធម្មារម្មណ៍ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ២០៤ ] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវ

សិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចក្ខុវិញ្ញាណ ទាំងវិញ្ញាណដែលអាស្រ័យចក្ខុវិញ្ញាណ របស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវសោតវិញ្ញាណ ... នឹងមិនប្រកាន់នូវឃានវិញ្ញាណ ... នឹងមិនប្រកាន់នូវជិវ្ហាវិញ្ញាណ ... នឹងមិនប្រកាន់នូវកាយវិញ្ញាណ ... នឹងមិនប្រកាន់នូវមនោវិញ្ញាណ ទាំងវិញ្ញាណដែលអាស្រ័យមនោវិញ្ញាណ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ២០៥ ] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវចក្ខុសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យចក្ខុសម្ផស្ស របស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវសោតសម្ផស្ស ... នឹងមិនប្រកាន់នូវឃានសម្ផស្ស ... នឹងមិនប្រកាន់នូវជិវ្ហាសម្ផស្ស ... នឹងមិនប្រកាន់នូវកាយសម្ផស្ស ... នឹងមិនប្រកាន់នូវមនោសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យមនោសម្ផស្ស របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ២០៦ ] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវេទនា ដែលកើតអំពីចក្ខុ-

សម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យវេទនា ដែលកើតអំពីចក្ខុសម្ផស្សរបស់អាត្មាអញនឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវេទនា ដែលកើតអំពីសោតសម្ផស្ស ... នឹងមិនប្រកាន់នូវវេទនា ដែលកើតអំពីឃានសម្ផស្ស ... នឹងមិនប្រកាន់នូវវេទនា ដែលកើតអំពីជិវ្ហាសម្ផស្ស ... នឹងមិនប្រកាន់នូវវេទនា ដែលកើតអំពីកាយ-សម្ផស្ស ... នឹងមិនប្រកាន់នូវវេទនាដែលកើតអំពីមនោសម្ផស្ស ទាំងវិញ្ញាណដែលអាស្រ័យវេទនា ដែលកើតអំពីមនោសម្ផស្ស របស់អាត្មាអញ នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ២០៧ ] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញមិនប្រកាន់នូវបឋវីធាតុ ទាំងវិញ្ញាណដែលអា-ស្រ័យបឋវីធាតុរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវអាបោធាតុ ... នឹងមិនប្រកាន់នូវតេជោធាតុ ... នឹងមិនប្រកាន់នូវវាយោធាតុ ... នឹងមិនប្រកាន់នូវអាកាសធាតុ ... នឹងមិនប្រកាន់នូវវិញ្ញាណធាតុ ទាំងវិញ្ញាណដែលអាស្រ័យវិញ្ញាណធាតុ របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ២០៨ ] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវ

សិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវរូប ទាំងវិញ្ញាណដែលអាស្រ័យរូបរបស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវេទនា ... នឹងមិនប្រកាន់នូវសញ្ញា ... នឹងមិនប្រកាន់នូវសង្ខារទាំងឡាយ ... នឹងមិនប្រកាន់នូវវិញ្ញាណ ទាំងវិញ្ញាណដែលអាស្រ័យវិញ្ញាណ របស់អាត្មាអញ ក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ២០៩ ] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវអាកាសានញ្ចាយតនៈ ទាំងវិញ្ញាណដែលអាស្រ័យអាកាសានញ្ចាយតនៈ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវវិញ្ញាណញ្ចាយតនៈ ... នឹងមិនប្រកាន់នូវអាកិញ្ចញ្ញាយតនៈ ... នឹងមិនប្រកាន់នូវនេវសញ្ញានាសញ្ញាយតនៈ ទាំងវិញ្ញាណដែលអាស្រ័យនេវ-សញ្ញានាសញ្ញាយតនៈ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ២១០ ] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវលោកនេះ ទាំងវិញ្ញាណដែលអាស្រ័យលោកនេះ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នក

ត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា អាត្មាអញនឹងមិនប្រកាន់នូវលោកខាងមុខ ទាំងវិញ្ញាណ ដែលអាស្រ័យលោកខាងមុខ របស់អាត្មាអញ នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ២១១ ] ម្នាលគហបតី ព្រោះហេតុនោះ ក្នុងសាសនានេះ អ្នកត្រូវសិក្សាយ៉ាងនេះថា ធម្មជាតណាដែលអាត្មាអញបានឃើញហើយ ឮហើយ ប៉ះពាល់ហើយ ដឹងច្បាស់ហើយ ស្វែងរកហើយ ស្ទាបស្ទង់ដោយចិត្តហើយ អាត្មាអញនឹងមិនប្រកាន់នូវធម្មជាតនោះ ទាំងវិញ្ញាណដែលអាស្រ័យធម្មជាតនោះ របស់អាត្មាអញក៏នឹងមិនមានឡើយ ម្នាលគហបតី អ្នកត្រូវសិក្សាយ៉ាងនេះចុះ ។

[ ២១២ ] កាលដែលព្រះសារីបុត្រ មានថេរវាចាយ៉ាងនេះហើយ អនាថបិណ្ឌិកសេដ្ឋី យំសម្រក់ទឹកភ្នែក ។ គ្រានោះ ព្រះអានន្ទមានអាយុ មានថេរវាចានឹងអនាថបិណ្ឌិកគហបតី ដូច្នេះថា ម្នាលគហបតី អ្នកជាប់នៅក្នុងទ្រព្យសម្បត្តិឬ ម្នាលគហបតី អ្នកលិចនៅក្នុងទ្រព្យសម្បត្តិឬ ។ អនាថ-បិណ្ឌិកគហបតីឆ្លើយថា បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំមិនជាប់ មិនលិចនៅក្នុងទ្រព្យសម្បត្តិទេ តែថា ខ្ញុំព្រះករុណា ដែលចូលទៅអង្គុយជិតព្រះសាស្តាអស់កាលយូរហើយផង ចូលទៅអង្គុយជិតពួកភិក្ខុ ជាអ្នកចម្រើនចិត្តអស់កាលយូរហើយផង ក៏ខ្ញុំព្រះករុណាមិនដែលបានស្តាប់ ធម្មីកថាមានសភាពដូច្នេះឡើយ ។ ម្នាលគហបតី ធម្មីកថាមានសភាពដូច្នេះ តែងមិនច្បាស់ប្រាកដ

ដល់ពួកគ្រហស្ថអ្នកស្លៀកសទេ ម្នាលគហបតី ឯធម្មីកថាមានសភាពដូច្នេះ រមែងច្បាស់ប្រាកដដល់ពួកបព្វជិត ( តែប៉ុណ្ណោះ ) ។ បពិត្រព្រះសារីបុត្រដ៏ចម្រើន បើដូច្នោះ ធម្មីកថាមានសភាពដូច្នេះ សូមឲ្យបានច្បាស់ប្រាកដដល់ពួកគ្រហស្ថអ្នកស្លៀកសផង បពិត្រលោកដ៏ចម្រើន ព្រោះថា មានពួកកុលបុត្រ ដែលប្រកបដោយជាតិ ជាអ្នកមានធូលីតិចក្នុងភ្នែក ជាអ្នកដឹងច្បាស់នូវធម៌ ព្រោះតែមិនបានស្តាប់ធម៌ មុខជានឹងសាបសូន្យចាកធម៌មិនខាន ។ លុះព្រះសារីបុត្រមានអាយុ និងព្រះអានន្ទមានអាយុ ទូន្មានអនាថបិណ្ឌិកគហបតី ដោយឱវាទនេះរួចហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។

[ ២១៣ ] កាលបើព្រះសារីបុត្រមានអាយុ និងព្រះអានន្ទមានអាយុ ចៀសចេញទៅ អស់កាលមិនយូរប៉ុន្មាន អនាថបិណ្ឌិកគហបតី ក៏ធ្វើមរណកាល ទៅកើតក្នុងពួកទេវតាឋានតុសិត ។ លំដាប់នោះ អនាថបិណ្ឌិកទេវបុត្រ លុះរាត្រីបឋមយាមកន្លងទៅហើយ មានពន្លឺដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ ឲ្យភ្លឺស្វាងហើយ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកទេវបុត្រ ឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគ ដោយគាថាទាំងឡាយថា

> វត្តជេតពននេះ សុទ្ធតែពួកអ្នកស្វែងរកគុណដ៏ល្អ នៅ
> អាស្រ័យជានិច្ច ដែលព្រះពុទ្ធជាធម្មរាជ គង់អាស្រ័យ
> នៅ ជាទីញុំាងបីតិ ឲ្យកើតព្រមដល់ខ្ញុំព្រះអង្គ កម្ម គឺ

មគ្គចេតនា ១ វិជ្ជា គឺមគ្គប្បញ្ញា ១ ធម៌ទាំងឡាយ ជាបក្ខពួកខាងសមាធិ ១ សីល ឈ្មោះថា ជីវិតខ្ពស់បំផុត ១ សត្វទាំងឡាយ រមែងស្អាតដោយធម៌នេះ មិនមែនដោយគោត្រ ឬមិនមែនដោយទ្រព្យឡើយ ព្រោះហេតុនោះ បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ត្រូវពិចារណាធម៌ ដោយឧបាយនៃប្រាជ្ញា ទើបស្អាតក្នុងធម៌នោះ យ៉ាងនេះបាន មានតែព្រះសារីបុត្រមួយ ទើបប្រសើរដោយបញ្ញាផង ដោយសីលផង ដោយកិរិយារម្ងាប់នូវកិលេសផង ទុកជាភិក្ខុណាដល់នូវត្រើយ គឺព្រះនិព្វាន ( ភិក្ខុនោះ ) ក៏មានគុណអស់ត្រឹមប៉ុណ្ណោះឯង ។

លុះអនាថបិណ្ឌិកទេវបុត្រ ពោលនូវគាថានេះចប់ ព្រះសាស្ដាក៏មានព្រះហឫទ័យត្រេកអរ ។ លំដាប់នោះ អនាថបិណ្ឌិកទេវបុត្រដឹងថា ព្រះសាស្ដារបស់អាត្មាអញ មានព្រះហឫទ័យត្រេកអរហើយ ក៏ក្រាបថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណ រួចក៏បាត់ក្នុងទីនោះទៅ ។

[ ២១៤ ] លុះកន្លងរាត្រីនោះទៅហើយ ព្រះមានព្រះភាគក៏ត្រាស់ហៅពួកភិក្ខុមកថា ម្នាលភិក្ខុទាំងឡាយ កាលដែលរាត្រីបឋមយាមកន្លងទៅហើយក្នុងយប់នេះឯង មានទេវបុត្រមួយអង្គ មានរស្មីដ៏រុងរឿង ញុំាងវត្តជេតពនទាំងអស់ឲ្យភ្លឺស្វាង ហើយក៏ចូលមករកតថាគត លុះចូលមកដល់ ថ្វាយបង្គំ

តថាគត ហើយឋិតនៅក្នុងទីសមគួរ ។ លុះទេវបុត្រនោះ ឋិតនៅក្នុងទីសមគួរហើយ ពោលគាថាទាំងនេះ ចំពោះតថាគតថា

វត្តជេតពននេះ សុទ្ធតែពួកអ្នកស្វែងរកគុណដ៏ល្អ នៅអាស្រ័យជានិច្ច ដែលព្រះពុទ្ធជាធម្មរាជ គង់អាស្រ័យនៅ ជាទីញុំាងបីតិ ឲ្យកើតព្រមដល់ខ្ញុំព្រះអង្គ កម្ម គឺមគ្គចេតនា ១ វិជ្ជា គឺមគ្គបញ្ញា ១ ធម៌ទាំងឡាយ ជាបក្ខពួកខាងសមាធិ ១ សីល ឈ្មោះថា ជីវិតខ្ពស់បំផុត ១ សត្វទាំងឡាយ រមែងស្អាតដោយធម៌នេះ មិនមែនដោយគោត្រ ឬមិនមែនដោយទ្រព្យឡើយ ព្រោះហេតុនោះ បុរសជាបណ្ឌិត កាលបើឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន ត្រូវពិចារណាធម៌ ដោយឧបាយនៃប្រាជ្ញា ទើបស្អាតក្នុងធម៌នោះ យ៉ាងនេះបាន មានតែព្រះសារីបុត្រមួយ ទើបប្រសើរដោយបញ្ញាផង ដោយសីលផង ដោយកិរិយារម្ងាប់នូវកិលេសផង ទុកជាភិក្ខុណាដល់នូវត្រើយ គឺព្រះនិព្វាន ( ភិក្ខុនោះ ) ក៏មានគុណអស់ត្រឹមប៉ុណ្ណោះឯង ។

ម្នាលភិក្ខុទាំងឡាយ លុះទេវបុត្រនោះ ពោលនូវគាថានេះចប់ហើយ ដឹងថា ព្រះសាស្តារបស់អាត្មាអញ មានព្រះហឫទ័យត្រេកអរហើយ ក៏ក្រាបថ្វាយបង្គំតថាគត ធ្វើប្រទក្សិណ រួចក៏បាត់ក្នុងទីនោះទៅ ។

[ ២១៥ ] កាលបើព្រះមានព្រះភាគ មានព្រះពុទ្ធដីកាយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ទេវបុត្រនោះឯង ប្រាកដជាអនាថបិណ្ឌិកគហបតីនោះ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះអនាថបិណ្ឌិកគហបតី បានជ្រះថ្លាក្រៃពេកក្នុងព្រះសារីបុត្រមានអាយុ ។ ម្នាលអានន្ទ ត្រូវហើយៗ ម្នាលអានន្ទ ហេតុដែលអ្នកបានត្រិះរិះនោះត្រូវហើយ ទេវបុត្រនោះ គឺអនាថបិណ្ឌិកហ្នឹងឯង មិនមែនអ្នកដទៃទេ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់នូវពាក្យនេះចប់ហើយ ព្រះអានន្ទមានអាយុ មានសេចក្ដីត្រេកអរ រីករាយនឹងភាសិត ព្រះមានព្រះភាគ ។

អនាថបិណ្ឌិកោវាទសូត្រទី ១ ចប់

# អដ្ឋកថា

## អនាថបិណ្ឌិកោវាទសូត្រ

[ ១៩៥ ] *អនាថបិណ្ឌិកោវាទសូត្រ មានពាក្យផ្ដើមថា* **ឯវម្មេ សុតំ** *ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា* **ពាឡ្ហគិលានោ** *គឺមានជំងឺជាទម្ងន់ដល់នូវការដេករង់ចាំសេចក្ដីស្លាប់ ។ បទថា* **អាមន្តេសិ** *សេចក្ដីថា គឺបានឮមកថា ដរាបណាដែលជើងរបស់គហបតីនៅនាំទៅបាន ដរាបនោះ គហបតីក៏បានធ្វើការទំនុកបម្រុងព្រះពុទ្ធមួយថ្ងៃ ២-៣ ដង មិនដាច់ លោកទំនុកបម្រុងព្រះសាស្ដាប៉ុនណា ក៏ទំនុកបម្រុងព្រះមហាថេរៈប៉ុណ្ណោះដូចគ្នា ថ្ងៃនេះលោកចូលដល់ការដេក តាមបែបដែលមិនមានការក្រោកឡើងទៀត ព្រោះជើងដើរទៅមិនបានហើយ ចង់បញ្ជូនដំណឹងទៅ ទើបហៅរកបុរសណាម្នាក់មក ។ បទថា* **តេនុបសង្កមិ** *គឺកាលទូលលាព្រះមានព្រះភាគហើយ ក៏ចូលទៅរកក្នុងវេលាព្រះអាទិត្យលិច ។*

[ ១៩៧-២០១ ] *បទថា* **បដិក្កមន្តិ** *គឺមិនស្រាកស្រាន្តចុះ ។ បទថា* **អភិក្កមន្តិ** *គឺចម្រើនក្រៃលែង បានដល់ កើនឡើង គឺកើតទុក្ខវេទនាដ៏មានកម្លាំង ។ បទថា* **អភិក្កមោសានំ បញ្ញាយតិ នោ បដិក្កមោ** *គឺក្នុងសម័យដែលកើតទុក្ខវេទនាស្មើរស្លាប់កើតឡើងនោះ ប្រៀបដូចខ្យល់ក្នុងស្នប់ដែលសប់ អស់កាលដែលកម្ដៅមិនទាន់រលត់ ទោះបីមានការព្យាយាមធំយ៉ាងណា តែមិនអាចធ្វើវេទនានោះឲ្យរម្ងាប់ទៅបាន តែរម្ងាប់ទៅបាន លុះណាកម្ដៅរលត់ទៅហើយ ។ ពេលនោះ ព្រះសារីបុត្រគិតថា វេទនារបស់មហាសេដ្ឋី*

ជាវេទនាទៀបនឹងស្លាប់ មិនមាននរណាអាចហាមបាន ពាក្យដ៏សេស ប្រើប្រយោជន៍មិនបាន អញនឹងពោលធម្មកថាដល់មហាសេដ្ឋីនោះ ។

[ ២០២ ] កាលពោលធម្មកថាជាមួយគហបតីនោះ ទើបផ្ដើមថា **តស្មាតិហ** ។ ក្នុងបទទាំងនោះ បទថា **តស្មា** គឺព្រោះកាន់យកចក្ខុ ដោយការកាន់យកទាំង ៣ អាចការពារវេទនា ដែលមានការស្លាប់ជាទីបំផុតកើតឡើងហើយមិនមាន ។ បទថា **ន ចក្ខុំ ឧបាទិយិស្សាមិ** គឺមិនប្រកាន់ចក្ខុដោយការប្រកាន់ទាំង ៣ យ៉ាង ។ បទថា **ន ច មេ ចក្ខុនិស្សិតំ** គឺការដឹងច្បាស់ដែលអាស្រ័យចក្ខុរបស់អញមិនមានផង ។ រូបក្នុងអាយតនៈ លោកបានសម្ដែងខាងដើមថា **ន រូបំ** ហើយ ។ ក្នុងទីនេះ នឹងសម្ដែងរូបក្នុងកាមទាំងអស់ ទើបលោកពោលយ៉ាងនេះ ។

[ ២១០ ] បទថា **ន ឥធលោកំ** សេចក្ដីថា មិនថាទីអាស្រ័យ អាហារបរិភោគ គ្រឿងស្លៀកដណ្ដប់ ខ្ញុំមិនជាប់ជំពាក់ទាំងអស់ ។ ឯពាក្យនេះលោកសម្ដែង ដើម្បីការមិនមានការតក់ស្លុតក្នុងបច្ច័យទាំងឡាយ ។ ឯក្នុងបទថា **ន បរលោកំ** នេះ សេចក្ដីថា លើកមនុស្សលោកចេញហើយ លោកដទៃ ឈ្មោះថា បរលោក ឬលោកខាងមុខ ពាក្យនេះ លោកពោលដើម្បីការលះនូវការតក់ស្លុតនេះថា អញកាលកើតក្នុងទេវលោកនោះហើយ នឹងកើតក្នុងឋានៈឈ្មោះនោះ អញនឹងទំពា នឹងស៊ី នឹងស្លៀក នឹងដណ្ដប់វត្ថុឈ្មោះនេះ ។ ព្រះថេរៈដោះអំពីការប្រកាន់ទាំង ៣ យ៉ាង យ៉ាងនេះថា សូម្បីវត្ថុនោះ ខ្ញុំក៏មិនជាប់ជំពាក់ ឯការដឹងច្បាស់ដែលអាស្រ័យការប្រកាន់នោះ ក៏

មិនមានដល់ខ្ញុំដែរ ហើយទើបបញ្ចប់ទេសនាដោយកំពូល គឺអរហត្ត ។

[ ២១២ ] បទថា **ឱលីយសិ** គឺលោកបានឃើញសម្បត្តិរបស់ខ្លួន ហើយរមែងកើត រមែងទទឹកក្នុងអារម្មណ៍ទាំងឡាយ ។ កាលព្រះអានន្ទពោល ដូចពោលមកនេះហើយ ក៏សម្គាល់ថា ប្រហែលគហបតីនេះ ដែលមានការ ជ្រះថ្លាយ៉ាងនេះ គង់ខ្វាចស្លាប់ ហើយអម្បាលអ្នកដទៃ មុចថាមិនខ្វាចនោះ ហើយឲ្យឱវាទដល់គហបតីនោះ ទើបបានពោលយ៉ាងនេះ ។ បទថា **ឆ ចមេ ឃវូបី ធម្មីកថា សុតបុព្វា** គឺឧបាសកនោះពោលថា ធម្មីកថាបែបនេះ ខ្ញុំមិន ធ្លាប់បានស្តាប់អំពីសម្នាក់ព្រះសាស្តាឡើយ ។ សួរថា ព្រះសាស្តាទ្រង់មិន សម្តែងវាចាដ៏ល្អិតជ្រាលជ្រៅបែបនេះឬ ។ ឆ្លើយថា មិនមែនទ្រង់មិនសម្តែង ទេ ។ តែពាក្យដែលទ្រង់សម្តែងដល់អាយតនៈខាងក្នុង ៦ អាយតនៈខាង ក្រៅ ៦ ពួកវិញ្ញាណ ៦ ពួកផស្សៈ ៦ ពួកវេទនា ៦ ធាតុ ៦ ខន្ធ ៥ អរូប ៤ លោកនេះ និងលោក ខាងមុខ ហើយត្រាស់ទុកក្នុងភាពជាព្រះអរហន្ត ដោយអំណាចរូបដែលភ្នែកបានឃើញហើយ សំឡេងដែលត្រចៀកបានឮ ហើយ ក្លិន រស ផោដ្ឋព្វៈ ដែលច្រមុះ អណ្តាត កាយបានដឹងហើយ និង ធម្មារម្មណ៍ដែលចិត្តដឹងច្បាស់ហើយ គហបតីនេះមិនទាន់ធ្លាប់ស្តាប់ ព្រោះ ដូច្នោះ ទើបពោលយ៉ាងនោះ ។

ម្យ៉ាងទៀត ឧបាសកនេះ ត្រេកអរក្រៃលែងក្នុងទាន កាលនឹងទៅកាន់ សម្នាក់ព្រះពុទ្ធ ទើបមិនធ្លាប់ទៅដៃទទេ កាលនឹងទៅក្នុងពេលមុនឆាន់ ក៏ឲ្យ មនុស្សកាន់យកបបរ និងខាទនីយជាដើម ហើយទើបទៅ កាលទៅក្នុងពេល

ក្រោយភត្ត ក៏ឲ្យយកសប្បិ ទឹកឃ្មុំ និងទឹកអំពៅជាដើម ហើយទើបទៅ កាលមិនមានវត្ថុទាំងនោះ ក៏ឲ្យយកសង្រែកវែកខ្សាច់យកទៅរោយក្នុងបរិវេណព្រះគន្ធកុដិ កាលឲ្យទាន រក្សាសីលស្រេចហើយ ទើបត្រឡប់ទៅកាន់ផ្ទះ បានឮថា ឧបាសកនេះ មានគតិដូចពោធិសត្វដូច្នោះ អស់កាល ២៤ ឆ្នាំដោយច្រើន ព្រះមានព្រះភាគត្រាស់តែទានកថាប៉ុណ្ណោះ ដល់ឧបាសកថា ឧបាសក ធម្មតាទាននេះ ជាផ្លូវដើររបស់ពួកពោធិសត្វ ជាផ្លូវដើររបស់តថាគតផងដែរ តថាគតបានឲ្យទានមកអស់ ៤ អសង្ខេយ្យ និង ១ សែនកប្ប អ្នកក៏ឈ្មោះថា ដើរតាមផ្លូវដែលតថាគតបានដើរមកហើយដោយពិត ។ សូម្បីព្រះមហាសាវក មានព្រះធម្មសេនាបតីជាដើម ក្នុងវេលាដែលឧបាសកមកកាន់សម្នាក់របស់ខ្លួន ក៏សម្តែងតែទានកថាដល់គាត់ដូចគ្នា ។ ព្រោះហេតុនោះ ទើបលោកពោលថា ម្នាលគហបតី ធម្មីកថាមានសភាពដូច្នេះ តែងមិនច្បាស់ប្រាកដដល់ពួកគ្រហស្ថអ្នកស្លៀកសទេ ។ មានពាក្យដែលលោកអធិប្បាយយ៉ាងនេះថា នែគហបតី សម្រាប់ពួកគ្រហស្ថ មានការជាប់ជំពាក់តែក្នុងស្រែចម្ការ ប្រាក់ មាស ទាសី ទាសា បុត្រ និងភរិយាជាដើម គិតតែពីការពេញចិត្ត និងការរួបរឹតយ៉ាងខ្លាំង ទើបពាក្យថា កុំធ្វើសេចក្តីអាល័យក្នុងវត្ថុទាំងនោះ កុំធ្វើការពេញចិត្ត ដូច្នេះ មិនប្រាកដ គឺរមែងមិនពេញចិត្តដល់គ្រហស្ថទាំងនោះ ដោយប្រការដូច្នេះ ។

[ ២១៣ ] បទថា **យេន ភគវា តេនុបសង្កមិ** សេចក្តីថា ហេតុអ្វីទើបចូលទៅគាល់ ។ បានឮមកថា គហបតីនោះ កើតក្នុងជាន់តុសិត

*ប៉ុណ្ណោះ ក៏ឃើញអត្តភាពទំហំ ៣ គាវុត ភ្លឺព្រោងព្រាយដូចដុំមាស និង សម្បត្តិ មានឧទ្យាន និងវិមានជាដើម ទើបរំពឹងមើលថា សម្បត្តិរបស់អញ នេះ ធំក្រៃលែង អញបានធ្វើអ្វីក្នុងទឹកដីមនុស្សហ្ន៎ ឃើញការធ្វើក្រៃលែងក្នុង ព្រះរតនត្រ័យ ក៏គិតថា ភាពជាទេវតានេះ ជាទីតាំងនៃសេចក្តីប្រមាទ ព្រោះ ថា កាលអញស្រវឹងក្នុងសម្បត្តិនេះ នឹងត្រូវមានការភ្លេចស្មារតីក៏បាន ណ្ហើយ ចុះ អញនឹងទៅពោលសរសើរវត្តជេតពនរបស់អញ ព្រះភិក្ខុសង្ឃ ព្រះ តថាគត អរិយមគ្គ និងព្រះសារីបុត្តត្ថេរ ចាំមកពីទីនោះហើយ ចាំសោយ សម្បត្តិ ។ ទើបទេវបុត្រនោះបានធ្វើយ៉ាងនោះ ។ ដើម្បីសម្តែងសេចក្តីនោះ ទើបលោកពោលថា* **អយំហិ តំ ជេតវនំ** *ជាដើម ។ ក្នុងបទទាំងនោះ បទថា* **ឥសិសង្ឃនិសេវិតំ** *បានដល់ ពួកឥសី គឺភិក្ខុសេពហើយ ។*

*កាលពោលសរសើរវត្តជេតពនដោយគាថាជំបូងយ៉ាងនេះហើយ ឥឡូវ នេះ កាលនឹងពោលសរសើរអរិយមគ្គ ទើបបានពោលថា* **កម្មំ វិជ្ជា ច** *ជាដើម ។ ក្នុងបទទាំងនោះ បទថា* **កម្មំ** *សំដៅដល់មគ្គចេតនា ។ បទថា* **វិជ្ជា** *សំដៅដល់មគ្គប្បញ្ញា ។ បទថា* **ធម្មោ** *សំដៅដល់ធម៌ដែលជា ចំណែកនៃសមាធិ ។ លោកសម្តែងថា ជីវិតនៃបុគ្គលតាំងនៅក្នុងសីលថា ជាជីវិតដ៏ឧត្តម ដោយពាក្យថា* **សីលំ ជីវិតមុត្តមំ ។**

*ម្យ៉ាងទៀត ការឃើញ និងការត្រិះរិះ ឈ្មោះថា* **វិជ្ជា ។** *សេចក្តីព្យាយាម ការរឭក និងការតាំងចិត្តមាំ ឈ្មោះថា* **ធម្មោ ។** *ការពោល ការងារ និងការ ចិញ្ចឹមជីវិត ឈ្មោះថា* **សីលំ ។** *ជីវិតនៃបុគ្គលតាំងនៅក្នុងសីលនេះ ជាជីវិត*

ដ៏ឧត្តម ឈ្មោះថា **ជីវិតមុត្តមំ** ។ បទថា **ឯតេន មច្ចា សុជ្ឈន្តិ** គឺពួកសត្វរមែងបរិសុទ្ធដោយមគ្គដែលប្រកបដោយអង្គ ៨ នេះ ។

បទថា **តស្មា** គឺព្រោះហេតុដែលបរិសុទ្ធដោយមគ្គ មិនមែនដោយគោត្រ ឬទ្រព្យ ។ បាទគាថាថា **យោនិសោ វិចិនេ ធម្មំ** គឺគប្បីជ្រើសរើសធម៌ដែលជាចំណែកនៃសមាធិយ៉ាងនឹងធឹង ។ បាទគាថាថា **ឯវំ តត្ថ វិសុជ្ឈតិ** គឺដោយលក្ខណៈដូច្នេះ ទើបបរិសុទ្ធក្នុងអរិយមគ្គនោះ ។ម្យ៉ាងទៀត បាទគាថាថា **យោនិសោ វិចិនេ ធម្មំ** គឺជ្រើសរើសធម៌ គឺខន្ធ ៥ យ៉ាងពិតប្រាកដ ។ បាទគាថាថា **ឯវំ តត្ថ សុជ្ឈតិ** គឺយ៉ាងនេះ ទើបបរិសុទ្ធក្នុងសច្ចៈទាំង ៤ នោះ ។

ឥឡូវនេះ អនាថបិណ្ឌិកទេវបុត្រ កាលពោលសរសើរព្រះសារីបុត្តត្ថេរ ទើបពោលថា **សារីបុត្តោ វ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **សារីបុត្តោ វ** ជាអវធារណៈ គឺហាមសេចក្ដីដទៃ អនាថបិណ្ឌិកទេវបុត្ររមែងពោលថា ព្រះសារីបុត្រប៉ុណ្ណោះជាកំពូលដោយបញ្ញាជាដើមទាំងនេះ ។ បទថា **ឧបសមេន** គឺដោយការចូលទៅស្ងប់កិលេស ។ បទថា **បារគតោ** គឺដល់ព្រះនិព្វាន ។ អនាថនិណ្ឌិកទេវបុត្ររមែងពោលថា ភិក្ខុរូបណាមួយសម្រេចព្រះនិព្វាន ភិក្ខុរូបនោះយ៉ាងច្រើនក៏ប៉ុណ្ណោះ មិនមានអ្នកណាលើសព្រះថេរៈទៅបានឡើយ ។ ពាក្យដ៏សេសក្នុងទីទាំងពួងងាយយល់ទាំងអស់ហើយ ។

**អដ្ឋកថា អនាថបិណ្ឌិកោវាទសូត្រ ចប់**

**សូត្រទី ១ ចប់**

# សុត្តន្តបិដក

## ឆន្នោវាទសូត្រទី ២

[ ២១៦ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ ក៏ក្នុងសម័យនោះ ព្រះសារីបុត្រមានអាយុ ព្រះមហាចុន្ទៈមានអាយុ និងព្រះឆន្នៈមានអាយុ កំពុងគង់នៅនាភ្នំគិជ្ឈកូដ ។ សម័យនោះឯង ព្រះឆន្នៈមានអាយុ មានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺចាប់ជាទម្ងន់ ។

[ ២១៧ ] គ្រានោះ ព្រះសារីបុត្រមានអាយុ ចេញចាកផលសមាបត្តិ ក្នុងសាយណ្ហសម័យ ហើយចូលទៅរកព្រះមហាចុន្ទៈមានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះមហាចុន្ទៈមានអាយុ យ៉ាងនេះថា ម្នាលចុន្ទៈមានអាយុ មក យើងចូលទៅរកព្រះឆន្នៈមានអាយុ នឹងបានសួរជំងឺ ។ ព្រះមហាចុន្ទៈមានអាយុ ទទួលពាក្យព្រះសារីបុត្រមានអាយុថា ករុណាលោកមានអាយុ ។ លំដាប់នោះ ព្រះសារីបុត្រមានអាយុ និងព្រះមហាចុន្ទៈមានអាយុ ចូលទៅរកព្រះឆន្នៈមានអាយុ លុះចូលទៅដល់ហើយ ក៏និយាយរាក់ទាក់សំណេះសំណាល ជាមួយនឹងព្រះឆន្នៈមានអាយុ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យគួររឭកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្រមានអាយុ អង្គុយនៅក្នុងទីដ៏សមគួរហើយ បានសួរព្រះឆន្នៈមានអាយុ យ៉ាងនេះថា ម្នាលអាវុសោឆន្នៈ លោកអាចអត់ធន់បានឬទេ លោកអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ ទុក្ខវេទនាបានស្រាកស្រាន្ត មិន

បម្រើនឡើងទេឬ ការធូរថយប្រាកដ ការបម្រើនមិនប្រាកដទេឬ ។ ព្រះឆន្នត្ថេរនិយាយថា ម្នាលអាវុសោសារីបុត្រ ខ្ញុំមិនអាចអត់ធន់បានទេ ខ្ញុំមិនអាចញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំខ្លាំងណាស់ ចេះតែបម្រើនឡើង មិនស្រាកស្រាន្តទេ ការបម្រើនឡើងនៃទុក្ខវេទនា ចេះតែប្រាកដ ការធូរថយមិនប្រាកដទេ ។

[ ២១៨ ] ម្នាលអាវុសោសារីបុត្រ បុរសមានកម្លាំងគប្បីចាក់ក្បាលដោយដែកស្រួចដ៏មុត យ៉ាងណា ម្នាលអាវុសោសារីបុត្រ ខ្យល់ដ៏ក្រៃលែងចាក់នូវក្បាលខ្ញុំ យ៉ាងនោះដែរ ម្នាលអាវុសោសារីបុត្រ ខ្ញុំមិនអាចអត់ធន់បានទេ ខ្ញុំមិនអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនានៃខ្ញុំខ្លាំងណាស់ ចេះតែបម្រើនឡើង មិនស្រាកស្រាន្តទេ ការបម្រើនឡើងនៃទុក្ខវេទនាចេះតែប្រាកដ ការធូរថយមិនប្រាកដឡើយ ។

[ ២១៩ ] ម្នាលអាវុសោសារីបុត្រ បុរសមានកម្លាំង រុំត្របែងក្បាលដោយកំណាត់ព្រ័ត្រដ៏មាំ យ៉ាងណា ម្នាលអាវុសោសារីបុត្រ ខ្យល់ដ៏ក្រៃលែងចាក់ដោតក្បាលខ្ញុំ យ៉ាងនោះដែរ ម្នាលអាវុសោសារីបុត្រ ខ្ញុំមិនអាចអត់ធន់បានទេ ខ្ញុំមិនអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំខ្លាំងណាស់ ចេះតែបម្រើនទៅមុខ មិនស្រាកស្រាន្តទេ ការបម្រើនឡើងនៃទុក្ខវេទនាចេះតែប្រាកដ ការធូរថយមិនប្រាកដឡើយ ។

[ ២២០ ] ម្នាលអាវុសោសារីបុត្រ អ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោ ដែលប៉ិនប្រសប់ គប្បីវះពោះគោដោយកាំបិតសម្រាប់អារគោដ៏

មុត យ៉ាងណា ម្នាលអាវុសោសារីបុត្រ ខ្យល់ដ៏ក្រៃលែងរះអាវពោះខ្ញុំ យ៉ាងនោះដែរ ម្នាលអាវុសោសារីបុត្រ ខ្ញុំមិនអាចអត់ធន់បានទេ ខ្ញុំមិនអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនានៃខ្ញុំខ្លាំងណាស់ ចេះតែចម្រើនទៅមុខ មិនស្រាកស្រាន្តទេ ការចម្រើនឡើងនៃទុក្ខវេទនាចេះតែប្រាកដ ការធូរថយមិនប្រាកដឡើយ ។

[ ២២១ ] ម្នាលអាវុសោសារីបុត្រ បុរសមានកម្លាំងពីរនាក់ ចាប់នូវបុរសមានកម្លាំងថយ ត្រង់ដើមដៃម្ខាងៗ ម្នាក់ នាំយកទៅរោលកម្ដៅ លើរណ្ដៅរងើកភ្លើង យ៉ាងណា ម្នាលអាវុសោសារីបុត្រ សេចក្ដីក្ដៅក្រហាយក្នុងរាងកាយរបស់ខ្ញុំដ៏ក្រៃលែង យ៉ាងនោះដែរ ម្នាលអាវុសោសារីបុត្រ ខ្ញុំមិនអាចអត់ធន់បានទេ ខ្ញុំមិនអាចញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានទេ ទុក្ខវេទនារបស់ខ្ញុំខ្លាំងណាស់ ចេះតែចម្រើនទៅមុខ មិនស្រាកស្រាន្តទេ ការចម្រើនឡើងនៃទុក្ខវេទនាចេះតែប្រាកដ ការធូរថយមិនប្រាកដឡើយ ម្នាលអាវុសោសារីបុត្រ ខ្ញុំនឹងនាំយកនូវកាំបិត ខ្ញុំមិនអាល័យជីវិតទេ ។

[ ២២២ ] ព្រះសារីបុត្រនិយាយថា ឆន្នៈមានអាយុ កុំកាន់យកកាំបិតឡើយ ឆន្នៈមានអាយុ ចូរញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅចុះ ពួកយើងចង់ឲ្យឆន្នៈមានអាយុ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ប្រសិនបើមិនមានភោជនជាទីសប្បាយ សម្រាប់ឆន្នៈមានអាយុទេ ខ្ញុំនឹងស្វែងរកភោជនជាទីសប្បាយឲ្យឆន្នៈមានអាយុ ប្រសិនបើមិនមានភេសជ្ជៈ ជាទីសប្បាយសម្រាប់ឆន្នៈមានអាយុទេ ខ្ញុំនឹងស្វែងរកភេសជ្ជៈជាទីសប្បាយឲ្យឆន្នៈមានអាយុ ប្រសិនបើ

មិនមានមនុស្សជាឧបដ្ឋាកដ៏សមគួរសម្រាប់ឆន្នៈមានអាយុទេ ខ្លួនខ្ញុំនឹងបម្រើឆន្នៈមានអាយុ ឆន្នៈមានអាយុកុំកាន់យកកាំបិតឡើយ ឆន្នៈមានអាយុ ចូរញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ យើងប្រាថ្នាឲ្យឆន្នៈមានអាយុ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅណាស់ ។

[ ២២៣ ] ឆន្នភិក្ខុឆ្លើយថា ម្នាលអាវុសោសារីបុត្រ ភោជនជាទីសប្បាយសម្រាប់ខ្ញុំមិនមែនគ្មានទេ ភេសជ្ជៈជាទីសប្បាយសម្រាប់ខ្ញុំ មិនមែនគ្មានទេ មនុស្សជាឧបដ្ឋាកដ៏សមគួរសម្រាប់ខ្ញុំ មិនមែនគ្មានទេ ម្នាលអាវុសោសារីបុត្រ តែថា ខ្ញុំធ្លាប់បម្រើព្រះសាស្តា យូរអង្វែងមកហើយ ដោយសេចក្តីពេញចិត្តពិតៗ មិនមែនបម្រើដោយសេចក្តីមិនពេញចិត្តទេ ម្នាលអាវុសោសារីបុត្រ ព្រោះថា អំពើដែលសមគួរដល់សាវ័ក គឺត្រូវបម្រើព្រះសាស្តា ដោយសេចក្តីពេញចិត្តពិតៗ មិនមែនបម្រើដោយសេចក្តីមិនពេញចិត្តនោះទេ ម្នាលអាវុសោសារីបុត្រ អ្នកចូរចាំទុកសេចក្តីនុ៎ះ យ៉ាងនេះថា ឆន្នភិក្ខុនឹងកាន់យកកាំបិតឥតទោសពៃរ៍អ្វីទេ ។ ព្រះសារីបុត្រសួរថា បើឆន្នៈមានអាយុបើកឱកាសដើម្បីឆ្លើយប្រស្នាបាន យើងនឹងសួរនូវហេតុបន្តិច នឹងឆន្នៈមានអាយុ ។ ឆន្នភិក្ខុឆ្លើយថា ម្នាលអាវុសោសារីបុត្រ អ្នកសួរមកចុះ ខ្ញុំស្តាប់ហើយគង់នឹងដឹង ។

[ ២២៤ ] ម្នាលអាវុសោឆន្នៈ អ្នកពិចារណាឃើញនូវចក្ខុ នូវចក្ខុវិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយចក្ខុវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ម្នាលអាវុសោឆន្នៈ អ្នកពិចារណាឃើញនូវ

សោតៈ នូវសោតវិញ្ញាណ ។បេ។ ម្នាលអាវុសោឆន្នៈ អ្នកពិចារណាឃើញនូវឃានៈ នូវឃានវិញ្ញាណ ... ម្នាលអាវុសោឆន្នៈ អ្នកពិចារណាឃើញនូវជិវ្ហា នូវជិវ្ហាវិញ្ញាណ ... ម្នាលអាវុសោឆន្នៈ អ្នកពិចារណាឃើញនូវកាយ នូវកាយវិញ្ញាណ ... ម្នាលអាវុសោឆន្នៈ អ្នកពិចារណាឃើញនូវមនោ នូវមនោវិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយមនោវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ ម្នាលអាវុសោសារីបុត្រ ខ្ញុំពិចារណាឃើញនូវចក្ខុ នូវចក្ខុវិញ្ញាណ និងពួកធម៌ដែលគប្បីដឹង ដោយចក្ខុវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនខ្លួនអញទេ ម្នាលអាវុសោសារីបុត្រ ខ្ញុំពិចារណាឃើញនូវសោតៈ នូវសោតវិញ្ញាណ ... ម្នាលអាវុសោសារីបុត្រ ខ្ញុំពិចារណាឃើញនូវឃានៈ នូវឃានវិញ្ញាណ ... ម្នាលអាវុសោសារីបុត្រ ខ្ញុំពិចារណាឃើញនូវជិវ្ហា នូវជិវ្ហាវិញ្ញាណ ... ម្នាលអាវុសោសារីបុត្រ ខ្ញុំពិចារណាឃើញនូវកាយ នូវកាយវិញ្ញាណ ... ម្នាលអាវុសោសារីបុត្រ ខ្ញុំពិចារណាឃើញនូវមនោ នូវមនោវិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយមនោវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។

[ ២២៥ ] ព្រះសារីបុត្រសួរថា ម្នាលអាវុសោឆន្នៈ អ្នកឃើញដូចម្តេច ដឹងដូចម្តេច ក្នុងចក្ខុ ក្នុងចក្ខុវិញ្ញាណ និងក្នុងពួកធម៌ដែលគប្បីដឹងដោយចក្ខុ-វិញ្ញាណ ទើបពិចារណាឃើញនូវចក្ខុ នូវចក្ខុវិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយចក្ខុវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែន

ជាខ្លួនអញទេ ម្នាលអាវុសោឆន្នៈ ក្នុងសោតៈ ក្នុងសោតវិញ្ញាណ ... ម្នាលអាវុសោឆន្នៈ ក្នុងឃានៈ ក្នុងឃានវិញ្ញាណ ... ម្នាលអាវុសោឆន្នៈ ក្នុងជិវ្ហា ក្នុងជិវ្ហាវិញ្ញាណ ... ម្នាលអាវុសោឆន្នៈ ក្នុងកាយ ក្នុងកាយវិញ្ញាណ ... ម្នាលអាវុសោឆន្នៈ អ្នកឃើញដូចម្តេច ដឹងដូចម្តេច ក្នុងមនោ ក្នុងមនោវិញ្ញាណ និងក្នុងពួកធម៌ដែលគប្បីដឹងដោយមនោវិញ្ញាណ ទើបពិចារណានូវមនោ នូវមនោវិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយមនោវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។ ម្នាលអាវុសោសារីបុត្រ ខ្ញុំឃើញនូវសេចក្តីរលត់ ដឹងនូវសេចក្តីរលត់ ក្នុងចក្ខុ ក្នុងចក្ខុវិញ្ញាណ និងក្នុងពួកធម៌ដែលគប្បីដឹងដោយចក្ខុវិញ្ញាណ បើពិចារណាឃើញនូវចក្ខុ នូវចក្ខុវិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយចក្ខុវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញទេ ម្នាលអាវុសោសារីបុត្រ ក្នុងសោតៈ ក្នុងសោតវិញ្ញាណ ... ម្នាលអាវុសោសារីបុត្រ ក្នុងឃានៈ ក្នុងឃានវិញ្ញាណ ... ម្នាលអាវុសោសារីបុត្រ ក្នុងជិវ្ហា ក្នុងជិវ្ហាវិញ្ញាណ ... ម្នាលអាវុសោសារីបុត្រ ក្នុងកាយ ក្នុងកាយវិញ្ញាណ ... ម្នាលអាវុសោសារីបុត្រ ខ្ញុំឃើញនូវសេចក្តីរលត់ ដឹងនូវសេចក្តីរលត់ក្នុងមនោ ក្នុងមនោវិញ្ញាណ និងក្នុងពួកធម៌ដែលគប្បីដឹងដោយមនោវិញ្ញាណ ទើបពិចារណាឃើញនូវមនោ នូវមនោវិញ្ញាណ និងពួកធម៌ដែលគប្បីដឹងដោយមនោវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនរបស់អញទេ ។

[ ២២៦ ] កាលបើឆន្នភិក្ខុនិយាយយ៉ាងនេះហើយ ព្រះមហាចុន្ទៈមានអាយុ និយាយនឹងឆន្នៈមានអាយុយ៉ាងនេះថា ម្នាលអាវុសោឆន្នៈ ព្រោះហេតុនោះ សាសនានេះរបស់ព្រះមានព្រះភាគនោះ បុគ្គលគួរធ្វើទុកក្នុងចិត្តអស់កាលជានិច្ច បុគ្គលដែលមានតណ្ហា និងទិដ្ឋិអាស្រ័យនៅហើយ រមែងមានសេចក្តីញាប់ញ័រ បុគ្គលដែលមិនមានតណ្ហា និងទិដ្ឋិអាស្រ័យនៅហើយ មិនមានសេចក្តីញាប់ញ័រទេ កាលបើសេចក្តីញាប់ញ័រមិនមានហើយ សេចក្តីស្ងប់រម្ងាប់នៃកាយ និងចិត្តរមែងមាន កាលបើសេចក្តីស្ងប់រម្ងាប់មានហើយ តណ្ហាក៏មិនមាន កាលបើតណ្ហាមិនមានហើយ អាគតិ និងគតិ ក៏មិនមាន កាលបើអាគតិ និងគតិមិនមានហើយ ចុតិ និងបដិសន្ធិក៏មិនមាន កាលបើចុតិ និងបដិសន្ធិមិនមានហើយ លោកនេះក៏មិនមាន លោកខាងមុខក៏មិនមាន លោកទាំងពីរក៏មិនមាន នេះហៅថា ទីបំផុតនៃទុក្ខ ។ គ្រានោះឯង ព្រះសារីបុត្រមានអាយុ និងព្រះមហាចុន្ទៈមានអាយុ បាននិយាយទូន្មានឆន្នៈមានអាយុ ដោយឱវាទនេះហើយ ក៏ក្រោកអំពីអាសនៈចេញទៅ ។

[ ២២៧ ] គ្រាកាលដែលព្រះសារីបុត្រមានអាយុ និងព្រះមហាចុន្ទៈមានអាយុ ចេញទៅមិនយូរប៉ុន្មាន ព្រះឆន្នៈមានអាយុក៏នាំយកនូវកាំបិត ។ គ្រានោះព្រះសារីបុត្រមានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគហើយ អង្គុយនៅក្នុងទីសមគួរ ។ លុះព្រះសារីបុត្រមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ឆន្នៈមានអាយុនាំយកនូវកាំបិតហើយ គតិ

របស់លោកដូចម្តេចទៅ បរលោកដូចម្តេចទៅ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ ការមិនមានទោស ( នោះ ) ឆន្នភិក្ខុបានព្យាករចំពោះមុខអ្នកឯងហើយតើ ។ បពិត្រព្រះអង្គដ៏ចម្រើន មានស្រុកវជ្ជីឈ្មោះបុព្វជិរៈ ត្រកូលជាមិត្ត ត្រកូលជាសម្លាញ់ ត្រកូលដែលគួរចូលទៅរករបស់ឆន្នៈមានអាយុ មាននៅក្នុងស្រុកនោះ ។

[ ២២៨ ] ព្រះមានព្រះភាគត្រាស់ថា ម្នាលសារីបុត្រ ត្រកូលទាំងនោះ គឺត្រកូលជាមិត្ត ត្រកូលជាសម្លាញ់ ត្រកូលដែលគួរចូលទៅរករបស់ឆន្នភិក្ខុ មានមែនហើយ ម្នាលសារីបុត្រ តែថា តថាគតមិនហៅថា ជាបុគ្គលគួរតិះដៀល ដោយហេតុមានប្រមាណប៉ុណ្ណេះទេ ម្នាលសារីបុត្រ អ្នកណាដាក់ចុះនូវកាយនេះផង ប្រកាន់នូវកាយឯទៀតផង តថាគតហៅអ្នកនោះថា គួរគេតិះដៀល ដំណើរនោះមិនមានដល់ឆន្នភិក្ខុទេ ឆន្នភិក្ខុនាំយកនូវកាំបិត ឥតមានទោសឡើយ ។ លុះព្រះមានព្រះភាគពោលពាក្យនេះហើយ ព្រះសារីបុត្រមានអាយុ ក៏មានសេចក្តីត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

**ឆន្នោវាទសូត្រទី ២ ចប់**

# អដ្ឋកថា

## ឆន្នោវាទសុត្ត

[ ២១៦ ] ឆន្នោវាទសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **ឆន្នោ** បានដល់ ព្រះថេរៈមានឈ្មោះយ៉ាងនោះ មិនមែនជាព្រះថេរៈដែលចេញទៅជាមួយព្រះពោធិសត្វ កាលចេញទៅអភិនេស្រ្កមណ៍ឡើយ ។

[ ២១៧-២២៨ ] បទថា **បដិសល្លានា** គឺចាកផលសមាបត្តិ ។ បទថា **គិលានបុច្ឆកា** បានដល់ ការទំនុកបម្រុងភិក្ខុឈឺដែលព្រះពុទ្ធទ្រង់សរសើរ ទ្រង់បានពណ៌នា ព្រោះដូច្នោះ ទើបលោកពោលយ៉ាងនោះ ។ បទថា **សត្ថំ** បានដល់សស្រ្តាដែលផ្តាច់ជីវិត ។ បទថា **នាវកង្ខាមិ** គឺមិនចង់បាន ។ បទថា **អនុបវជ្ជំ** គឺមិនកើត មិនមានបដិសន្ធិ ។ បទថា **ឯតំ មម** ជាដើម លោកពោលដោយអំណាចការប្រកាន់មាំដោយតណ្ហា មានះ និងទិដ្ឋិ ។ បទថា **និរោធំ ទិស្វា** គឺជ្រាបការអស់ និងការសូន្យទៅ ។ បទថា **នេតំ មម នេសោហមស្មិ ន មេសោ សមនុបស្សាមិ** គឺខ្ញុំពិចារណាឃើញថា មិនទៀង ជាទុក្ខ មិនមែនជាតួខ្លួន ។ បទថា **តស្មា** គឺព្រោះហេតុដែលព្រះថេរៈពោលថា កាលខ្ញុំអត់សង្កត់នូវវេទនាដែលមានការស្លាប់ជាទីបំផុតមិនបាន ទើបនាំយកសស្រ្តាមកនោះ លោកជាបុថុជ្ជន ទើបចង្អុលបង្ហាញថា ព្រោះដូច្នោះ សូមលោកដាក់ចិត្តក្នុងសេចក្តីនេះ ។ បទថា **និច្ចកប្បំ** គឺជានិច្ចកាល ។ បទថា **និស្សិតស្ស** គឺតណ្ហា និងទិដ្ឋិអាស្រ័យហើយ ។ បទថា **ចលិតំ** បាន

ដល់ ជារបស់កម្រើក គឺញាប់ញ័រ ។ បទថា **បស្សទ្ធិ** គឺការស្ងប់កាយស្ងប់ចិត្ត អធិប្បាយថា ដល់នូវការស្ងប់កិលេស ក៏រមែងមាន ។ បទថា **នតិ** បានដល់ តណ្ហា ។ បទថា **នតិយា អសតិ** គឺកាលមិនមានការវួបរឹត ព្រោះសេចក្ដីអាល័យដើម្បីប្រយោជន៍ដល់ភព ។ បទថា **អាគតិគតិ ន ហោតិ** គឺឈ្មោះថា ការមកដោយអំណាចបដិសន្ធិ រមែងមិនមាន ឈ្មោះថា ការទៅដោយអំណាចចុតិ ក៏រមែងមិនមាន ។ បទថា **ចុតូបបាតោ** គឺឈ្មោះថា ចុតិដោយអំណាចការឃ្លាត ឈ្មោះថា ឧប្បត្តិ ដោយអំណាចការកើតឡើង ។ បទថា **នេវិធ ន ហុរំ ន ឧភយមន្តរេន** គឺក្នុងលោកនេះក៏មិនមាន ក្នុងលោកខាងមុខក៏មិនមាន ក្នុងលោកទាំង ២ ក៏មិនមាន ។ បទថា **ឯសេវន្តោ ទុក្ខស្ស** គឺនេះប៉ុណ្ណោះជាទីបំផុតនៃវដ្ដទុក្ខ និងកិលេសទុក្ខ នេះជាកំណត់ដោយជុំវិញជាផ្លូវដោយជុំវិញ ។ ព្រោះនេះប៉ុណ្ណោះ ជាបំណងក្នុងសេចក្ដីនេះ ។ សម្រាប់បុគ្គលណាកាន់យកពាក្យថា មិនមានដោយចន្លោះលោកទាំង ២ ហើយត្រូវការចន្លោះភព ពាក្យដែលក្រៃលែងទៅសម្រាប់លោកទាំងនោះ ក៏ពោលខាងដើមស្រេចហើយ ។ បទថា **សត្ថំ អាហារេសិ** គឺយកសស្ត្រាសម្រាប់ផ្ដាច់ជីវិតមកហើយ កាត់បំពង់កហើយ ។

ខណៈនោះ ការខ្លាចស្លាប់របស់លោកក៏ឈានចុះ គតិនិមិត្តប្រាកដឡើង លោកដឹងថា ខ្លួនទៅជាបុថុជ្ជន កើតនូវសេចក្ដីសង្វេគ តាំងវិបស្សនា ពិចា-រណាសង្ខារ សម្រេចជាព្រះអរហន្ត ជាសមសីសី ហើយក៏បរិនិព្វាន ។ បទថា **សម្មុខាយេវ អនុបវជ្ជតា ព្យាកតា** គឺសូម្បីការព្យាករណ៍នេះ មានក្នុង

*វេលាដែលព្រះថេរៈនៅជាបុថុជ្ជនក៏ពិត សូម្បីយ៉ាងនោះ បរិនិព្វានដែលមិនមានអ្វីមកជ្រែកបានរបស់លោក ក៏មានតាមពាក្យព្យាករណ៍នេះ ហេតុនោះទើបព្រះមានព្រះភាគ ទ្រង់កាន់យកព្យាករនោះឯងមកត្រាស់ ។ បទថា* **ឧបវជ្ជកុលានិ** *គឺត្រកូលដែលគួរចូលទៅ ដោយពាក្យថា ត្រកូលគប្បីចូលទៅនេះ ព្រះថេរៈរមែងទូលសួរថា ខ្ញុំព្រះអង្គកាលនៅមានពួកឧបដ្ឋាក និងពួកឧបដ្ឋាយិកាយ៉ាងនេះ ភិក្ខុនោះ នឹងបរិនិព្វានក្នុងសាសនារបស់ព្រះអង្គឬ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់សម្តែងភាពដែលភិក្ខុនោះ មិនមានការប្រឡូកប្រឡំក្នុងត្រកូលទាំងឡាយ ទើបត្រាស់ថា* **ហោន្តិ ហេតេ សារីបុត្ត** *ដូច្នេះជាដើម ។ បានឮមកថា ក្នុងឋានៈនេះ ការមិនជាប់ជំពាក់ក្នុងត្រកូលទាំងឡាយ នៃព្រះថេរៈ បានជាទីប្រាកដហើយ ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើងាយយល់ទាំងអស់ហើយ ។*

**អដ្ឋកថា ឆន្នោវាទសូត្រ ចប់**

**សូត្រទី ២ ចប់**

# សុត្តន្តបិដក

## បុណ្ណោវាទសូត្រទី ៣

[ ២២៩ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះបុណ្ណៈមានអាយុ ចេញចាកទីសម្ងំក្នុងវេលាសៀល ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះបុណ្ណៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មេត្តាប្រោសទូន្មានខ្ញុំព្រះអង្គដោយព្រះឱវាទយ៉ាងសង្ខេប លុះខ្ញុំព្រះអង្គស្តាប់នូវធម៌របស់ព្រះមានព្រះភាគហើយ នឹងចេញទៅតែម្នាក់ឯង មិនប្រមាទ មានព្យាយាមជាគ្រឿងដុតបំផ្លាញកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន សម្រេចសម្រាន្តឥរិយាបថទាំង ៤ ។ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលបុណ្ណៈ បើដូច្នោះ អ្នកចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តឲ្យល្អ តថាគតនឹងសម្តែង ។ ព្រះបុណ្ណៈមានអាយុនោះ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ២៣០ ] ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលបុណ្ណៈ រូបដែលគប្បីដឹងដោយភ្នែក ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេកក៏មាន បើភិក្ខុរីករាយពោលសរសើរ ប្រកាន់ខ្ជាប់នូវរូបនោះ កាលដែលភិក្ខុនោះរីករាយ ពោលសរសើរ

ប្រកាន់ខ្ជាប់នូវរូបនោះហើយ សេចក្តីរីករាយក៏កើតឡើង ម្នាលបុណ្ណៈ តថាគតពោលថា ការកើតឡើងនៃសេចក្តីទុក្ខ ព្រោះការកើតឡើងនៃសេចក្តីរីករាយ ។ ម្នាលបុណ្ណៈ សំឡេងដែលគប្បីដឹងដោយត្រចៀក ... ក្លិនដែលគប្បីដឹងដោយច្រមុះ ... រសដែលគប្បីដឹងដោយអណ្តាត ... ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ... ធម៌ដែលគប្បីដឹងដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេកក៏មាន បើភិក្ខុរីករាយពោលសរសើរ ប្រកាន់ខ្ជាប់នូវធម៌នោះ កាលដែលភិក្ខុនោះរីករាយ ពោលសរសើរ ប្រកាន់ខ្ជាប់នូវធម៌នោះហើយ សេចក្តីរីករាយក៏កើតឡើង ម្នាលបុណ្ណៈ តថាគតពោលថា ការកើតឡើងនៃសេចក្តីទុក្ខ ព្រោះការកើតឡើងនៃសេចក្តីរីករាយ ។

[ ២៣១ ] ម្នាលបុណ្ណៈ រូបដែលគប្បីដឹងដោយចក្ខុ ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរស្រឡាញ់ ប្រកបដោយកាមគួរឲ្យកើតតម្រេកក៏មាន បើភិក្ខុមិនរីករាយ មិនពោលសរសើរ មិនប្រកាន់ខ្ជាប់នូវរូបនោះ កាលដែលភិក្ខុនោះមិនរីករាយ មិនពោលសរសើរ មិនប្រកាន់ខ្ជាប់នូវរូបនោះហើយ សេចក្តីរីករាយក៏រលត់ទៅ ម្នាលបុណ្ណៈ តថាគតពោលថា ការរលត់សេចក្តីទុក្ខ ព្រោះការរលត់សេចក្តីរីករាយ ។ ម្នាលបុណ្ណៈ សំឡេងដែលគប្បីដឹងដោយត្រចៀក ... ក្លិនដែលគប្បីដឹងដោយច្រមុះ ... រសដែលគប្បីដឹងដោយអណ្តាត ... ផោដ្ឋព្វៈដែលគប្បីដឹងដោយកាយ ... ធម៌ដែលគប្បីដឹងដោយចិត្ត ជាទីប្រាថ្នា ជាទីត្រេកអរ ជាទីគាប់ចិត្ត មានសភាពគួរ

ស្រឡាញ់ ប្រកបដោយកាម គួរឲ្យកើតតម្រេកក៏មាន បើភិក្ខុមិនរីករាយ មិនពោលសរសើរ មិនប្រកាន់ខ្ជាប់នូវធម៌នោះ កាលដែលភិក្ខុនោះមិនរីករាយ មិនពោលសរសើរ មិនប្រកាន់ខ្ជាប់នូវធម៌នោះហើយ សេចក្តីរីករាយក៏រលត់ទៅ ម្នាលបុណ្ណៈ តថាគតពោលថា ការរលត់សេចក្តីទុក្ខ ព្រោះការរលត់សេចក្តីរីករាយ ម្នាលបុណ្ណៈ តថាគតទូន្មានអ្នកដោយឱវាទយ៉ាងសង្ខេបនេះឯងហើយ តើអ្នកនឹងនៅក្នុងជនបទណា ។ ព្រះបុណ្ណៈក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទូន្មានខ្ញុំព្រះអង្គដោយឱវាទសង្ខេបនេះហើយ ខ្ញុំព្រះអង្គនឹងនៅក្នុងជនបទឈ្មោះសុនាបរន្តៈ ។

[ ២៣២ ] ព្រះមានព្រះភាគត្រាស់ថា ម្នាលបុណ្ណៈ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទសុទ្ធតែកាចៗ ម្នាលបុណ្ណៈ ពួកមនុស្សអ្នកនៅក្នុងសុនា-បរន្តជនបទ សុទ្ធតែរឹងរូស ម្នាលបុណ្ណៈ ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ ជេរគំរាមអ្នក ម្នាលបុណ្ណៈ អ្នកនឹងប្រព្រឹត្តក្នុងហេតុនោះដូចម្តេចទៅ ។ ព្រះបុណ្ណៈក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងជេរគំរាមខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះមិនប្រហារអាត្មាអញដោយបាតដៃ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ ។

[ ២៣៣ ] ព្រះមានព្រះភាគសួរថា ម្នាលបុណ្ណៈ ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នកដោយបាតដៃ ម្នាលបុណ្ណៈ តើអ្នកនឹងប្រព្រឹត្តក្នុងហេតុនុ៎ះដូចម្តេច ។ ព្រះបុណ្ណៈក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គដោយបាតដៃ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនប្រហារអាត្មាអញដោយដុំដី បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះ យ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះ យ៉ាងនេះ ។

[ ២៣៤ ] ម្នាលបុណ្ណៈ ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នកដោយដុំដី ម្នាលបុណ្ណៈ អ្នកនឹងប្រព្រឹត្តក្នុងហេតុនោះដូចម្តេចទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គដោយដុំដី ខ្ញុំព្រះអង្គប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនប្រហារអាត្មាអញដោយដំបង បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះ យ៉ាងនេះ ។

[ ២៣៥ ] ម្នាលបុណ្ណៈ ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្ត-

ជនបទ នឹងប្រហារអ្នកដោយដំបង ម្នាលបុណ្ណៈ តើអ្នកនឹងប្រព្រឹត្តក្នុងហេតុនោះដូចម្តេចទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គដោយដំបង ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះ ជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនប្រហារអាត្មាអញដោយកាំបិត បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះ យ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះ យ៉ាងនេះ ។

[ ២៣៦ ] ម្នាលបុណ្ណៈ ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារអ្នកដោយកាំបិត ម្នាលបុណ្ណៈ តើអ្នកនឹងប្រព្រឹត្តក្នុងហេតុនោះដូចម្តេចទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងប្រហារខ្ញុំព្រះអង្គដោយកាំបិត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះជាមនុស្សល្អ ពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទនេះល្អណាស់ហ្ន៎ ដោយហេតុមនុស្សទាំងនេះ មិនផ្តាច់ជីវិតខ្ញុំព្រះអង្គ ដោយកាំបិតដ៏មុតឡើយ បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ ។

[ ២៣៧ ] ម្នាលបុណ្ណៈ ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងផ្តាច់ជីវិតអ្នកដោយកាំបិតដ៏មុត ម្នាលបុណ្ណៈ តើអ្នកនឹងប្រព្រឹត្តក្នុង

ហេតុនោះដូចម្ដេចទៀត ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកមនុស្សអ្នកនៅក្នុងសុនាបរន្តជនបទ នឹងផ្ដាច់ជីវិតខ្ញុំព្រះអង្គដោយកាំបិតដ៏មុតមែន ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនោះយ៉ាងនេះថា ពួកសាវ័ករបស់ព្រះមានព្រះភាគ ជាទុក្ខធុញទ្រាន់ខ្ពើមកាយ និងជីវិត តែងស្វែងរកនូវគ្រឿងសស្ត្រាជាគ្រឿងនាំបង់នូវជីវិត អាត្មាអញមិនបាច់ស្វែងរកនូវគ្រឿងសស្ត្រា ជាគ្រឿងនាំបង់នូវជីវិតនោះទេ ស្រាប់តែបានមក បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ បពិត្រព្រះសុគត ខ្ញុំព្រះអង្គនឹងប្រព្រឹត្តក្នុងហេតុនុ៎ះយ៉ាងនេះ ។

[ ២៣៨ ] ម្នាលបុណ្ណៈ ប្រពៃណាស់ហើយ ម្នាលបុណ្ណៈ អ្នកឯងប្រកបដោយការទូន្មានចិត្ត និងការរម្ងាប់ចិត្តនេះហើយ ទើបគួរនឹងនៅក្នុងសុនាបរន្តជនបទបាន ម្នាលបុណ្ណៈ ចូរអ្នកសម្គាល់នូវកាលគួរនឹងទៅឥឡូវនេះចុះ ។ គ្រានោះឯង ព្រះបុណ្ណៈមានអាយុ ត្រេកអរអនុមោទនាចំពោះភាសិតនៃព្រះមានព្រះភាគ ហើយក្រោកចាកអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ រៀបចំសេនាសនៈ រួចចាប់យកបាត្រ និងចីវរនិមន្តទៅកាន់ចារិក ក្នុងសុនាបរន្តជនបទ ។ លុះនិមន្តទៅកាន់ចារិកតាមលំដាប់ ក៏បានដល់សុនាបរន្តជនបទនោះ ។

[ ២៣៩ ] ឮថា ព្រះបុណ្ណៈមានអាយុ គង់នៅក្នុងសុនាបរន្តជនបទនោះ ។ គ្រានោះឯង ព្រះបុណ្ណៈមានអាយុ បានទូន្មានពួកឧបាសកប្រមាណ ៥០០ នាក់ក្នុងវស្សានោះ បានទូន្មានពួកឧបាសិកាប្រមាណ ៥០០ នាក់ក្នុងវស្សា

នោះ ហើយលោកបានធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា ៣ ខាងក្នុងវស្សានោះដែរ ។ លំដាប់នោះ ព្រះបុណ្ណៈមានអាយុ ក៏បរិនិព្វានទៅក្នុងសម័យខាងក្រោយ ។ គ្រានោះឯង ភិក្ខុជាច្រើនរូបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះភិក្ខុទាំងនោះ អង្គុយក្នុងទីដ៏សមគួរហើយ ទើបក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន កុលបុត្រឈ្មោះបុណ្ណៈដែលព្រះមានព្រះភាគទូន្មាន ដោយឱវាទសង្ខេប លោកធ្វើមរណកាលទៅហើយ គតិរបស់លោកដូចម្ដេច បរលោកដូចម្ដេចទៅ ។

[ ២៨០ ] ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ កុលបុត្រឈ្មោះបុណ្ណៈជាបណ្ឌិត បានប្រព្រឹត្តធម៌ដ៏សមគួរដល់នវលោកុត្តរធម៌ ទាំងមិនបានញុំាងតថាគតឲ្យលំបាកព្រោះធម៌ជាហេតុ ម្នាលភិក្ខុទាំងឡាយ កុលបុត្រឈ្មោះបុណ្ណៈបរិនិព្វានហើយ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះហើយ ភិក្ខុទាំងនោះក៏មានសេចក្ដីត្រេកអររីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## បុណ្ណោវាទសូត្រទី ៣ ចប់

# អដ្ឋកថា

## បុណ្ណោវាទសូត្រ

[ ២២៩ ] បុណ្ណោវាទសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងព្រះសូត្រនោះ ការនៅម្នាក់ឯង ឈ្មោះថា **បដិសល្លាន** ។

[ ២៣០-២៣១ ] បទថា **តញ្ចេ** បានដល់ ភ្នែក និងរូបនោះ ។ បទថា **នន្ទិសមុទយា ទុក្ខសមុទយោ** គឺការសង្រ្គោះយកទុក្ខក្នុងខន្ធ ៥ រមែងមានដោយការរួមយកការត្រេកអរ ដែលបានដល់តណ្ហាមកជាមួយគ្នា ។ ដោយប្រការដូច្នេះ ក៏ឈ្មោះថា ទ្រង់ធ្វើឲ្យវដ្ដៈដល់ទីបំផុត ។ ដោយអំណាចនៃសច្ចៈទាំង ២ គឺទុក្ខ និងហេតុឲ្យកើតទុក្ខ ក្នុងទ្វារទាំង ៦ ហើយទើបទ្រង់សម្ដែង ។ ក្នុងន័យទី ២ ទ្រង់ធ្វើវដ្ដៈឲ្យដល់ទីបំផុត ដោយអំណាចសច្ចៈ ២ គឺនិរោធ ១ មគ្គ ១ ហើយទើបទ្រង់សម្ដែង ។ អនុសន្ធិដែលចែកទុកដោយបំពោះ គឺពាក្យថា **ឥមិនា ច ត្វំ បុណ្ណ** ។ កាលទ្រង់ដាក់ទេសនាដោយអំណាចវដ្ដៈ និងវិវដ្ដៈ ក្នុងអរហត្តយ៉ាងនេះមុនហើយ ឥឡូវនេះ ដើម្បីទ្រង់ឲ្យព្រះបុណ្ណត្ថេរបន្លឺសីហនាទ ក្នុងស្ថានទាំង ៧ ទើបបានត្រាស់ពាក្យថា **ឥមិនា ច ត្វំ** ដូច្នេះជាដើម ។

[ ២៣២ ] បទថា **ចណ្ឌា** គឺកាចឃោរឃៅ ។ បទថា **ផរុសា** គឺគ្រោតគ្រាត ។ បទថា **អក្កោសិស្សន្តិ** គឺរមែងជេរដោយអក្កោសវត្ថុ ១០ យ៉ាង ។ បទថា **បរិភាសិស្សន្តិ** គឺរមែងគំហកថា គាត់នេះជាសមណៈបានដូចម្ដេច អញនឹងលេងនក្ខត្តឫក្សយ៉ាងនេះ និងយ៉ាងនេះ ។ បទថា **ឯវមេត្ថ** គឺវត្ថុ

យ៉ាងនេះ ក្នុងករណីនេះមានដល់ខ្ញុំព្រះអង្គ ។

[ ២៣៤ ] បទថា **ឧណ្ឌេន** គឺដោយដំបងប្រវែង ៤ ហត្ថ ឬដោយអង្កត់ខុស និងញញួរ ។

[ ២៣៥ ] បទថា **សត្ថេន** គឺដោយអាវុធ មានកាំបិតមុខម្ខាងជាដើម ។

[ ២៣៧ ] បទថា **សត្ថហារកំ បរិយេសេន្តិ** គឺស្វែងរកសស្ត្រា គ្រឿងប្រហារជីវិត ។ សេចក្តីនេះ ព្រះថេរៈពោលសំដៅដល់ភិក្ខុដែលស្លាប់រឿងមិនស្អាត ក្នុងវត្ថុនៃបារាជិកសិក្ខាបទទី ៣ កើតការនឿយណាយក្នុងរាងកាយ ហើយស្វែងរកគ្រឿងផ្តាច់ជីវិត គឺសស្ត្រា ។

[ ២៣៨ ] បទថា **ឧមោ** ក្នុងបទថា **ឧមូបសមេន** នេះ ជាឈ្មោះនៃការសង្រួមឥន្ទ្រិយជាដើម ។ ពិតហើយ ការសង្រួមឥន្ទ្រិយលោកពោលថា ជា **ឧម** ដូចក្នុងប្រយោគជាដើមថា **សច្ចេន ឧន្តោ ឧមសា ឧបេតោ វេទន្តគូ វុសិតព្រហ្មចរិយោ** បុគ្គលណា បានទូន្មានខ្លួនដោយបរមត្ថសច្ច ប្រកបដោយការទូន្មានឥន្ទ្រិយ ជាអ្នកដល់នូវមគ្គញាណទី ៤ ជាទីបំផុតនៃវេទ បានប្រព្រឹត្តមគ្គព្រហ្មចរិយចប់ហើយ ។ បញ្ញា លោកហៅថា **ឧម** ដូចក្នុងប្រយោគជាដើមថា **យទិ សច្ចា ឧមា ចាគា ខន្ត្យា ភិយ្យោធ វិជ្ជតិ** ( បើមានធម៌ដទៃទៀតក្នុងលោកនេះ ) ឲ្យក្រៃលែងជាង សច្ចៈ ទមៈ ចាគៈ ខន្តិ តទៅទៀត ។ ឧបោសថកម្ម លោកហៅថា **ឧម** ដូចក្នុងប្រយោគជាដើមថា **ទានេន ឧមេន សំយមេន សច្ចវជ្ជេន** បុគ្គលធ្វើកុសលដោយឲ្យទាន ដោយទូន្មាននូវឥន្ទ្រិយ ដោយសង្រួមកាយវាចា ដោយពោលពាក្យសច្ចៈ ។ តែក្នុង

ព្រះសូត្រនេះ គប្បីជ្រាបថា ការអត់ធន់ គឺការទូន្មានចិត្ត ។ បទថា **ឧប-សមោ** ជាវេវចនៈនឹងបទថា **ឧមោ** នោះឯង ។ បទថា **អថ ខោ អាយស្មា បុណ្ណោ** សេចក្តីថា ចង់ដឹងថា បុណ្ណៈនេះជានរណា ហេតុអ្វី ទើបចង់ទៅក្នុងទីនោះ ។ ព្រះថេរៈរូបនេះ ជាអ្នកស្រុកសុនាបរន្តៈនោះឯង ។ លោកកំណត់ថា ក្នុងក្រុងសាវត្ថីនៅមិនសប្បាយ ទើបចង់ទៅក្រុងសុនាបរន្តៈនោះ ។

តទៅនេះ ជាលំដាប់ពាក្យក្នុងរឿងនោះ

បានឮមកថា ក្នុងដែនសុនាបរន្តជនបទ មានបងប្អូន ២ នាក់ នៅក្នុងភូមិឈ្មួញមួយកន្លែង ក្នុងបងប្អូន ២ នាក់នោះ ជួនកាលបងក៏នាំរទេះ ៥០០ ទៅជនបទ ហើយក៏ផ្ទុកទំនិញមក ។ ជួនកាលក៏ប្អូនប្រុស ។ ឯក្នុងពេលនេះ បងប្រុសឲ្យប្អូនប្រុសនៅចាំផ្ទះ ហើយខ្លួនឯងក៏នាំយករទេះ ៥០០ គ្រឿង ត្រាច់ទៅតាមជនបទ មកដល់ក្រុងសាវត្ថីដោយលំដាប់ ដាក់រទេះត្រង់ទីជិតវត្តជេតពន បរិភោគអាហារព្រឹកហើយ មានជនហែហមហើយ អង្គុយសម្រាកតាមសប្បាយ ។

សម័យនោះ អ្នកក្រុងសាវត្ថីបរិភោគអាហារព្រឹកហើយ អធិដ្ឋានអង្គឧបោសថ មានសំលៀកបំពាក់ស្អាត កាន់គ្រឿងក្រអូប មានផ្កាជាដើម បង្អោនទៅកាន់ទីដែលមានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃគង់នៅ ហើយនាំគ្នាចេញទៅតាមទ្វារទិសខាងត្បូង ឆ្ពោះទៅកាន់វត្តជេតពន ។ កាលឈ្មួញនោះឃើញជនទាំងនោះ ទើបសួរបុរសម្នាក់ថា មនុស្សទាំងនេះទៅណា បុរសនោះឆ្លើយថា នេះលោកមិនដឹងសោះឬ រតនៈ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ

កើតឡើងហើយក្នុងលោក ព្រោះហេតុនេះ ទើបមហាជននេះ នាំគ្នាទៅស្តាប់ធម្មកថាក្នុងសម្នាក់ព្រះសាស្តា ។ ពាក្យថា **ពុទ្ធ** របស់បុរសនោះ ទម្លាយស្បែកជាដើមចូលទៅដល់ខួរក្នុងឆ្អឹង តាំងនៅ ។ បន្ទាប់មក គាត់មានបរិវាររបស់ខ្លួនហែហម បានទៅកាន់វិហារជាមួយនឹងបរិស័ទនោះ ឈរនៅក្នុងទីបំផុតរបស់បរិស័ទ ស្តាប់ធម៌របស់ព្រះសាស្តាដ៏មានកម្លាំង សម្តែងធម៌ដោយព្រះសូរសៀងដ៏ពីរោះ ហើយកើតការគិតចង់បួស ។ កាលព្រះតថាគតជ្រាបវេលា បញ្ជូនបរិស័ទទៅហើយ ក៏ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយទូលអារាធនាសោយព្រះក្រយាហារ ក្នុងថ្ងៃស្អែក ក្នុងថ្ងៃទី ២ ឲ្យសង់បារាំរៀបចំអាសនៈ ថ្វាយមហាទានដល់ព្រះសង្ឃ មានអង្គព្រះសម្ពុទ្ធជាប្រធាន ក្នុងទីបំផុតកត្តកិច្ច ព្រះមានព្រះភាគ ទ្រង់អនុមោទនា ហើយយាងត្រឡប់ ។ គាត់ទទួលទានអាហារព្រឹកហើយ អធិដ្ឋានអង្គឧបោសថ ហើយហៅមេការដែលគ្រប់គ្រងទ្រព្យមកប្រាប់សព្វយ៉ាងថា របស់មានប្រមាណប៉ុណ្ណេះ បានចំណាយទៅហើយ បានប្រគល់វត្ថុគ្រប់យ៉ាងថា ចូរឲ្យសម្បត្តិនេះដល់ប្អូនប្រុសខ្ញុំ ហើយក៏បួសក្នុងសម្នាក់ព្រះសាស្តា ផ្តើមប្រារព្ធកម្មដ្ឋាន ។ កាលនោះ លោកដាក់ចិត្តក្នុងកម្មដ្ឋានៗ ក៏មិនប្រាកដ បន្ទាប់មក ទើបគិតថា ជនបទនេះ មិនស្រួលដល់អញសោះ អញនឹងទទួលកម្មដ្ឋាន ក្នុងសម្នាក់ព្រះសាស្តា ហើយទៅមាតុភូមិរបស់អញ ទើបកាលលោកត្រាច់បិណ្ឌបាតក្នុងពេលព្រឹកហើយ ចេញចាកការសម្ងំក្នុងពេលរសៀល ក៏ចូលគាល់ព្រះមានព្រះភាគ អារាធនាឲ្យទ្រង់ប្រាប់កម្មដ្ឋាន បានបន្លឺសីហនាទ ៧ យ៉ាង ហើយ

ទើបចៀសចេញទៅ ។ ព្រោះហេតុនោះ ទើបលោកពោលថា **អថ ខោ អាយស្មា បុណ្ណោ ។បេ។** ដូច្នេះ ។

ព្រះបុណ្ណៈនេះ នៅទីណា ។ លោកនៅក្នុងទី ៤ កន្លែង ។ ដំបូងលោកចូលកាន់សុនាបរន្តជនបទ ហើយចូលទៅអម្ពហដ្ឋបព៌ត ចូលកាន់ស្រុកឈ្នួញដើម្បីបិណ្ឌបាត ។ ពេលនោះឯង ប្អូនប្រុសចាំលោកបាន ទើបប្រគេនអាហារ ហើយហៅលោកថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនបាច់ទៅទីដទៃទេ និមន្តនៅក្នុងទីនេះចុះ ឲ្យលោកទទួលពាក្យហើយ និមន្តឲ្យនៅក្នុងទីនោះ ។

បន្ទាន់អំពីនោះ លោកបានទៅកាន់វត្តសមុទ្ទគិរី ។ ក្នុងទីនោះ មានទីសម្រាប់ដើរចង្ក្រម ដែលគេកាត់យកបន្ទះថ្ម ដោតដែកត្រង់ចុង មកតម្រៀបធ្វើ ។ មិនមានអ្នកណាដើរជាន់បន្ទះថ្មនោះបាន ។ ក្នុងទីនោះ រលកសមុទ្របានមកបោកផែនថ្មដែលដោតដែកត្រង់ខាងចុង លាន់សំឡេងដ៏ខ្លាំង ។ ព្រះថេរៈគិតថា ចូរជាទីនៅជាផាសុកសម្រាប់អ្នកយកចិត្តទុកដាក់ធ្វើកម្មដ្ឋានចុះ រួចក៏អធិដ្ឋានធ្វើឲ្យសមុទ្រស្ងប់សំឡេង ។

បន្ទាប់អំពីនោះ លោកបានទៅកាន់មាតុលគិរី ។ ក្នុងទីនោះ មានពួកបក្សីប្រជុំគ្នា សំឡេងខ្ទៀវខ្ទារទាំងយប់ទាំងថ្ងៃ ព្រះថេរៈគិតថា ទីនេះមិនមានផាសុក បន្ទាប់អំពីនោះ ក៏ទៅកាន់វត្តមកុឡការាម ។ វត្តនោះនៅមិនជិតមិនឆ្ងាយអំពីភូមិឈ្នួញពេក ទៅមកងាយស្រួល មិនមានសំឡេង ។ ព្រះថេរៈគិតថា ទីនេះមានផាសុក ទើបឲ្យសាងទីសម្រាកពេលយប់ និងពេលថ្ងៃ

មួយអន្ទើដោយទឹចង្រ្កមជាដើមហើយ ក៏ចូលចាំវស្សាក្នុងទីនោះ លោកនៅក្នុងទី ៤ កន្លែង ដូចពោលមកនេះ ។

បន្ទាប់មកទៀត ថ្ងៃមួយ ខាងក្នុងវស្សានោះឯង មានឈ្មួញ ៥០០ នាក់ តាំងចិត្តថា ពួកយើងនឹងទៅកាន់សមុទ្រដទៃ ទើបជញ្ជូនទំនិញដាក់ទូក ។ ក្នុងថ្ងៃចុះទូក ប្អូនប្រុសរបស់ព្រះថេរៈ អង្គាសព្រះថេរៈហើយ ទទួលសិក្ខាបទក្នុងសម្នាក់ព្រះថេរៈ ថ្វាយបង្គំស្រេចហើយ កាលនឹងទៅ បានប្រាប់លោកថា លោកម្ចាស់ ធម្មតាសមុទ្រមានអន្តរាយច្រើនហួសប្រមាណ សូមលោកម្ចាស់ជួយស្រោចស្រង់ពួកខ្ញុំផង ហើយក៏ចុះទូកទៅ ។ ទូកក៏រសាត់ទៅដោយសម្ទុះលឿន រហូតដល់កោះមួយ ពួកមនុស្សគិតថា ពួកយើងនឹងបរិភោគអាហារព្រឹក ហើយក៏នាំគ្នាឡើងកោះ ។ កោះមិនមានអ្វីដទៃ មានតែព្រៃចន្ទន៍ គ្រានោះ មនុស្សម្នាក់យកកាំបិតកាប់ដើមឈើ ក៏ដឹងថា ចន្ទន៍ក្រហម ទើបពោលថា នែវ៉ើយ ពួកយើងទៅកាន់សមុទ្រដទៃ ដើម្បីប្រយោជន៍ដល់លាភឈ្មោះថា លាភដ៏ក្រៃលែងជាងនេះមិនមាន ដុំឈើបណ្តាយ ៤ ធ្នាប់ក៏មានតម្លៃរាប់សែន យើងយកតែរបស់ដែលគួរយកទៅ ហើយក៏យកខ្លឹមចន្ទន៍ផ្ទុកឲ្យពេញ ។ ពួកជនទាំងនោះក៏ធ្វើយ៉ាងនោះ ។

ពួកអមនុស្សដែលអាស្រ័យនៅក្នុងព្រៃចន្ទន៍ មានការខឹងក្រោធ នាំគ្នាគិតថា មនុស្សទាំងនេះ ធ្វើព្រៃចន្ទន៍របស់ពួកយើងឲ្យវិនាសហើយ ពួកយើងនឹងសម្លាប់មនុស្សទាំងនេះ ហើយពោលថា បើមនុស្សទាំងនេះត្រូវសម្លាប់ក្នុងទីនេះ ព្រៃទាំងអស់ ក៏ក្លាយជាសាកសពពេញព្រៃនោះឯង ពួក

យើងនឹងឲ្យទូករបស់ជនទាំងនេះ លិចត្រង់កណ្តាលសមុទ្រ ។ បន្ទាប់មក ក្នុងវេលាដែលមនុស្សទាំងនោះឡើងទូក ហើយចេញដំណើរទៅបានមួយសន្ទុះ ប៉ុណ្ណោះ ក៏ធ្វើឲ្យកើតខ្យល់ព្យុះដ៏ខ្លាំងក្លា ហើយពួកអមនុស្សទាំងនោះ ក៏នាំគ្នាបង្ហាញរូប ដែលគួរខ្លាចផ្សេងៗ ច្រើនប្រការ ។ ពួកមនុស្សក៏ខ្លាច នាំគ្នាសំពះព្រះជាម្ចាស់រៀងៗ ខ្លួន ចូឡបុណ្ណកុដុម្ពិកៈប្អូនប្រុសរបស់ព្រះថេរៈគិតថា សូមឲ្យបងប្រុសរបស់អញជាទីពឹងផងចុះ ហើយក៏ឈរព្វកដល់ព្រះថេរៈ ។

បានឮថា ខណៈនោះឯង ព្រះថេរៈពិចារណាមើល ក៏បានដឹងថា ពួកមនុស្សទាំងនោះ កំពុងធ្លាក់នៅក្នុងសេចក្តីវិនាស ទើបហោះឡើងកាន់អាកាសមកឈរត្រង់ចំពោះមុខ ។ ពួកអមនុស្សឃើញព្រះថេរៈពោលថា លោកម្ចាស់បុណ្ណត្ថេរមកហើយ ក៏នាំគ្នាគេចទៅ ព្យុះកំណាចក៏ស្ងប់មួយរំពេច ព្រះថេរៈលួងលោមមនុស្សទាំងនោះថា មិនចាំបាច់ខ្លាចឡើយ ហើយសួរថា តើពួកអ្នកចង់ទៅណា ។ ពួកមនុស្សឆ្លើយថា ខ្ញុំទៅមាតុភូមិខ្លួនឯងនោះឯងលោកម្ចាស់ ។ ព្រះថេរៈជាន់លើទូក ហើយអធិដ្ឋានថា ចូរទូកនេះទៅកាន់ទីដែលពួកមនុស្សត្រូវការ ពួកឈ្មួញកាលទៅដល់ទីដែលខ្លួនប្រាថ្នាហើយ ក៏តំណាលរឿងនោះឲ្យកូនប្រពន្ធស្តាប់ ហើយបបួលគ្នាថា មកវ៉ឺយពួកយើង ចូរដល់ព្រះថេរៈជាពឹងចុះ ទាំង ៥០០ នាក់ មួយអន្លើដោយមេផ្ទះរបស់ខ្លួន ៥០០ នាក់ទៀត តាំងនៅក្នុងសរណៈ ៣ ប្រកាសខ្លួនជាឧបាសក ។ បន្ទាប់អំពីនោះ ក៏ឲ្យជញ្ជូនទ្រព្យឡើងអំពីទូក ប្រគេនព្រះថេរៈមួយចំណែក ប្រាប់ថា

បពិត្រលោកម្ចាស់ នេះជាចំណែករបស់លោកម្ចាស់ ។ ព្រះថេរៈឆ្លើយថា អាត្មាមិនមានកិច្ចដោយចំណែកមួយឡើយ តែពួកអ្នកធ្លាប់ឃើញព្រះសាស្តាហើយឬ ។ ពួកមនុស្សឆ្លើយថា មិនធ្លាប់ឃើញទេ លោកម្ចាស់ ។ ព្រះថេរៈពោលថា កាលបើដូច្នោះ ពួកអ្នកចូរយកចំណែកនេះទៅសង់រោងបាយថ្វាយព្រះសាស្តាចុះ ហើយពួកអ្នកនឹងបានឃើញព្រះសាស្តាដោយអាការយ៉ាងនេះ ។ មនុស្សពួកនោះក៏ទទួលថា សាធុ លោកម្ចាស់ ហើយក៏ផ្តើមសាងបាយដោយចំណែកនោះ និងដោយចំណែករបស់ខ្លួនដទៃទៀតជាច្រើន ។

បានឮថា សូម្បីព្រះសាស្តាក៏ទ្រង់ធ្វើការបរិកោគ តាំងអំពីផ្តើមកសាង ។ ពួកមនុស្សអ្នកយាមបានឃើញពន្លឺក្នុងពេលយប់ ក៏យល់ថា មានទេវតាដ៏ជាធំ ។ ពួកឧបាសកនាំគ្នាសាងបាយ និងសេនាសនៈសម្រាប់ព្រះភិក្ខុសង្ឃ រហូតស្រេចហើយ ត្រៀមទេយ្យទាន ហើយប្រាប់ព្រះថេរៈថា បពិត្រលោកម្ចាស់ ពួកខ្ញុំបានធ្វើកិច្ចស្រេចហើយ សូមលោកម្ចាស់មេត្តាទូលព្រះសាស្តាចុះ ។ ពេលរសៀល ព្រះថេរៈទៅកាន់ក្រុងសាវត្ថីដោយឫទ្ធិ ហើយក្រាបទូលអារាធនាព្រះមានព្រះភាគថា អ្នកភូមិឈ្មួញចង់គាល់ព្រះអង្គ សូមព្រះអង្គមេត្តាធ្វើនូវសេចក្តីអនុគ្រោះដល់ជនទាំងនោះចុះ ។ ព្រះមានព្រះភាគទទួលហើយ ។ ព្រះថេរៈជ្រាបថា ព្រះមានព្រះភាគទទួលហើយ ក៏ត្រឡប់ទៅកាន់ទឹកដីរបស់ខ្លួនវិញ ។

ព្រះមានព្រះភាគ ក៏ត្រាស់ហៅព្រះអានន្ទមកប្រាប់ថា អានន្ទ ស្អែកនេះពួកយើងនឹងត្រាច់បិណ្ឌបាតត្រង់ភូមិពួកឈ្មួញ ក្នុងដែនសុនាបរន្តៈ អ្នកចូរ

ឲ្យស្ងាកដល់ភិក្ខុ ៤៩៩ រូប ។ ព្រះថេរៈទទួលព្រះពុទ្ធដីកាថា សាធុ ព្រះអង្គ ហើយប្រាប់រឿងនោះដល់ភិក្ខុសង្ឃ ដោយពោលថា សូមពួកលោកម្ចាស់ ត្រាច់ទៅបិណ្ឌបាត ចូរកុំចាប់ស្ងាក ។ ក្នុងថ្ងៃនោះ ព្រះកុណ្ឌធានត្ថេរបាន ចាប់ស្ងាកដំបូង ។ ឯពួកអ្នកភូមិឈ្មួញជ្រាបថា បានឮថា ស្អែកនេះ ព្រះ សាស្ដាយាងមកដល់ ទើបសាងបារាំកណ្ដាលស្រុក ត្រៀមទេយ្យធម៌ដ៏ ប្រសើរ ថ្វាយទាន ព្រះមានព្រះភាគទ្រង់ធ្វើកិច្ចបដិបត្តិព្រះសរីរៈ តាំងអំពី ព្រលឹម យាងចូលព្រះគន្ធកុដិ ប្រថាប់គង់ចូលផលសមាបត្តិ ។ បណ្ឌុល- កម្ពលសិលាសនៈរបស់សក្កទេវរាជ ក៏ក្ដៅឡើង ។ សក្កទេវរាជនោះទ្រង់ ពិចារណាថា នេះរឿងអ្វីហ្ន៎ ទ្រង់ឃើញថា ព្រះសាស្ដាយាងទៅដែនសុណា- បរន្តៈ ទើបត្រាស់ហៅវិស្សកម្មទេវបុត្រមកប្រាប់ថា នែបា ថ្ងៃនេះ ព្រះមាន ព្រះភាគយាងបិណ្ឌបាត រយៈផ្លូវឆ្ងាយប្រមាណ ៣០០ យោជន៍ បាចូរនិម្មិត ផ្ទះកំពូល ៥០០ ខ្នង ធ្វើការត្រៀមរយៈផ្លូវដែលព្រះមានព្រះភាគយាងក្នុងទី បំផុត តាំងអំពីខ្លោងទ្វារវត្តជេតពនទៅ តាំងទុកឲ្យដល់ព្រម ។ វិស្សកម្ម នោះបានធ្វើយ៉ាងនោះហើយ ។ ផ្ទះកំពូលសម្រាប់ព្រះមានព្រះភាគមានមុខ ៤ របស់អគ្គសាវកទាំង ២ មានមុខ ២ សម្រាប់ភិក្ខុដ៏សេសមានមុខ ១ ។ ព្រះ សាស្ដាស្ដេចចេញអំពីព្រះគន្ធកុដិ ទ្រង់ចូលកាន់ផ្ទះកំពូលដ៏ប្រសើរ ក្នុងបណ្ដា ផ្ទះកំពូលដែលតាំងទុកតាមលំដាប់ ពួកភិក្ខុ ៤៩៩ រូប ផ្ដើមអំពីព្រះអគ្គ- សាវកទាំង ២ ក៏ទៅកាន់ផ្ទះកំពូល ៤៩៩ ខ្នង មានផ្ទះកំពូលទទេមួយខ្នង ។ ផ្ទះកំពូលទាំង ៥០០ អណ្ដែតទៅតាមអាកាស ។

ព្រះសាស្តាយាងឡើងភ្នំឈ្មោះសច្ចពន្ធ ហើយទ្រង់បញ្ឈប់ផ្ទះកំពូលទុកលើអាកាស ។ ត្រង់ភ្នំនោះ មានតាបសមិច្ឆាទិដ្ឋិ ឈ្មោះសច្ចពន្ធ ធ្វើឲ្យមហាជនកាន់យកនូវការយល់ខុស ជាអ្នកមានលាភ និងយសដ៏ក្រៃលែង ។ ឯខាងក្នុងខ្លួនរបស់តាបសនោះ មាននិស្ស័យនៃអរហត្ត ក៏សន្ធោសន្ធៅ ដូចប្រទីបនៅក្នុងឆ្នាំង ។ កាលទ្រង់ឃើញតាបសនោះហើយ ទ្រង់ព្រះតម្រិះថា តថាគតនឹងសម្តែងធម៌ដល់តាបសនេះ ទើបយាងទៅសម្តែងធម៌ ។ កាលទ្រង់សម្តែងធម៌ចប់ តាបសក៏សម្រេចអរហត្ត ។ អភិញ្ញារបស់លោកក៏មកជាមួយមគ្គនោះឯង ។ លោកជាឯហិភិក្ខុ ទ្រទ្រង់បាត្រចីវរ ដែលសម្រេចព្រោះឫទ្ធិ ហើយចូលកាន់ផ្ទះកំពូល ។

ព្រះមានព្រះភាគយាងទៅដល់ភូមិឈ្មួញ មួយអន្លើដោយភិក្ខុ ៥០០ រូប នៅក្នុងផ្ទះកំពូល ទ្រង់ធ្វើមិនឲ្យបុគ្គលណាមួយឃើញផ្ទះកំពូល ហើយយាងទៅកាន់ស្រុកឈ្មួញ ។ ពួកឈ្មួញបានថ្វាយមហាទានដល់ពួកភិក្ខុ ដែលមានព្រះពុទ្ធជាប្រធាន ហើយទូលអារាធនាព្រះសាស្តាយាងទៅកាន់មកុឡការាម ។ ព្រះសាស្តាទ្រង់ចូលកាន់រោងបារាំ ។ មហាជនរង់ចាំវេលារហូតព្រះសាស្តារម្ងាត់សេចក្តីក្រវល់ក្រវាយ ព្រោះព្រះក្រយាហារឲ្យស្ងប់ នាំគ្នាបរិភោគអាហារព្រឹកស្រេចហើយ សមាទានអដ្ឋង្គឧបោសថ កាន់គ្រឿងក្រអូប និងផ្កាដ៏ច្រើន ត្រឡប់មកវត្ត ដើម្បីស្តាប់ធម៌ ។ ព្រះសាស្តាទ្រង់សម្តែងធម៌ ។ ការរួចផុតចាកកិលេសដែលជាចំណង កើតដល់មហាជនហើយ ។ ការកោលាហលដ៏ធំទាក់ទងនឹងព្រះពុទ្ធ មានហើយ ។

ដើម្បីសង្គ្រោះមហាជន ព្រះសាស្តាប្រថាប់ ២-៣ ថ្ងៃ ក្នុងទីនោះឯង ទ្រង់ញ៉ាំងអរុណឲ្យតាំងឡើងក្នុងព្រះមហាគន្ធកុដិនោះឯង ។ កាលប្រថាប់ក្នុងទីនោះ ២-៣ ថ្ងៃហើយ ស្តេចក៏ត្រាច់បិណ្ឌបាតក្នុងភូមិឈ្មួញ ហើយត្រាស់ឲ្យព្រះបុណ្ណត្ថេរត្រឡប់ថា អ្នកចូរនៅក្នុងទីនេះឯង ។ ក្នុងរវាងផ្លូវមានស្ទឹងឈ្មោះនិម្មទា ( នម្មទា ) ទ្រង់បានទៅដល់ស្ទឹងនោះ និម្មទានាគរាជធ្វើនូវបដិសណ្ឋារៈដល់ព្រះសាស្តា អារាធនាទៅកាន់ពិភពនាគ បានធ្វើសក្ការៈព្រះរតនត្រ័យហើយ ។ ព្រះសាស្តា ទ្រង់សម្តែងធម៌ដល់នាគរាជនោះហើយ យាងចេញចាកភពនាគ នាគរាជក្រាបទូលអារាធនាថា សូមទ្រង់ព្រះរាជទានវត្ថុដែលគប្បីបម្រើដល់ខ្ញុំព្រះអង្គផងចុះ ។ ទើបព្រះមានព្រះភាគទ្រង់សម្តែងបទចេតិយ គឺស្នាមព្រះបាទត្រង់ច្រាំងស្ទឹងនិម្មទានោះ ។ ស្នាមព្រះបាទនោះកាលរលកបក់មក ក៏បិទ កាលរលកទៅវិញ ក៏បើក ក្លាយជាស្នាមព្រះបាទដែលដល់នូវសក្ការៈដ៏ធំ ។ កាលព្រះសាស្តាទ្រង់ចេញអំពីទីនោះហើយ យាងដល់ភ្នំសច្ចពន្ធត្រាស់ប្រាប់សច្ចពន្ធថា មហាជនត្រូវអ្នកធ្វើឲ្យលិចចុះក្នុងអបាយ អ្នកត្រូវនៅក្នុងទីនេះហើយ ស្រាយលទ្ធិរបស់មនុស្សទាំងនោះចេញ ហើយឲ្យពួកជនទាំងនោះ តាំងនៅក្នុងផ្លូវនៃព្រះនិព្វាន ។ សច្ចពន្ធត្ថេរក៏ទូលសូមវត្ថុដែលត្រូវបម្រើ ។ ព្រះសាស្តា ទ្រង់សម្តែងស្នាមព្រះបាទទុកលើផែនថ្ម ដូចប្រថាប់ត្រាទុកលើដុំដីស្អិតស្រស់ ដូច្នោះ ។ បន្ទាប់អំពីនោះ ទ្រង់យាងទៅដល់វត្តជេតពននោះឯង ។ លោកសំដៅយកសេចក្តីនេះ ទើបពោលពាក្យជាដើមថា ខាងក្នុងវស្សានោះឯង ដូច្នេះ ។

*[ ២៣៩ ] បទថា* **បរិនិព្វាយិ** *គឺបរិនិព្វានហើយ ដោយអនុបាទិសេស-និព្វានធាតុ ។ មហាជនធ្វើការបូជាព្រះសរីរៈរបស់ព្រះថេរៈអស់ ៧ ថ្ងៃ ហើយយកឈើក្រអូបដ៏ច្រើនមកតរដុតព្រះសរីរៈ រក្សាធាតុ ហើយសាង ចេតិយបញ្ចុះ ។ បទថា* **សម្ពហុលា ភិក្ខូ** *គឺពួកភិក្ខុដែលនៅក្នុងទីឈាបនកិច្ចសពរបស់ព្រះថេរៈ ។ ពាក្យដ៏សេស ក្នុងទីគ្រប់អន្លើ ងាយយល់ទាំងអស់ហើយ ។*

## អដ្ឋកថា បុណ្ណោវាទសូត្រ ចប់
## សូត្រទី ៣ ចប់

# សុត្តន្តបិដក

## ឆក្កនិបាតសូត្រទី ៨

[ ២៤១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ លំដាប់នោះ ព្រះនាងមហាបជាបតិគោតមី ព្រមទាំងភិក្ខុនីប្រមាណប្រាំរយរូប នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី ឋិតនៅក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ទូន្មានពួកភិក្ខុនី បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ប្រៀនប្រដៅពួកភិក្ខុនី បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ធ្វើនូវធម្មីកថាដល់ពួកភិក្ខុនី ។

[ ២៤២ ] ក្នុងសម័យនោះឯង ពួកភិក្ខុជាថេរៈតែងទូន្មានពួកភិក្ខុនីតាមវេនៗ ។ ចំណែកនន្ទកៈមានអាយុ មិនចង់ទូន្មានពួកភិក្ខុនីតាមវេនឡើយ ។ ទើបព្រះមានព្រះភាគ ត្រាស់ហៅព្រះអានន្ទមានអាយុមកថា ម្នាលអានន្ទ ថ្ងៃនេះជាវេនភិក្ខុណាហ្ន៎ ដែលត្រូវឲ្យឱវាទពួកភិក្ខុនីតាមវេន ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងអស់បានធ្វើវេនដើម្បីទូន្មានពួកភិក្ខុនីតាមវេនៗ ហើយ បពិត្រព្រះអង្គដ៏ចម្រើន នន្ទកៈមានអាយុនេះមិនចង់ទូន្មានពួកភិក្ខុនីតាមវេនទេ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់ហៅនន្ទកៈមានអាយុមកថា ម្នាលនន្ទកៈ អ្នកចូរទូន្មានពួកភិក្ខុនី ម្នាលនន្ទកៈ អ្នកចូរប្រៀន

ប្រដៅពួកភិក្ខុនី ម្នាលព្រាហ្មណ៍ អ្នកចូរធ្វើនូវធម្មីកថាដល់ពួកភិក្ខុនី ។ នន្ទកៈមានអាយុទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ លុះត្រាច់ទៅបិណ្ឌបាតក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកពីបិណ្ឌបាតវិញក្នុងវេលាក្រោយភត្ត មានខ្លួនជាគម្រប់ពីរ គឺមានគ្នាពីរនាក់ចូលទៅកាន់រាជការាម ។ ពួកភិក្ខុនីទាំងនោះ បានឃើញនន្ទកៈមានអាយុមកអំពីចម្ងាយ លុះឃើញហើយក៏ក្រាលអាសនៈ តម្កល់ទឹកសម្រាប់លាងព្រះបាទ ។ នន្ទកៈមានអាយុអង្គុយលើអាសនៈ ដែលគេក្រាលទុកហើយ លុះអង្គុយស៊ប់ទើបលាងជើង ។ ភិក្ខុនីទាំងនោះថ្វាយបង្គំនន្ទកៈមានអាយុ ហើយអង្គុយក្នុងទីសមគួរ ។

[ ២៤៣ ] លុះភិក្ខុនីទាំងនោះ អង្គុយក្នុងទីសមគួរហើយ នន្ទកៈមានអាយុបាននិយាយយ៉ាងនេះថា ម្នាលនាងទាំងឡាយ តទៅមុខបើមានពាក្យគេសាកសួរ បើពួកភិក្ខុនីដឹងច្បាស់ក្នុងប្រស្នានោះ គប្បីឆ្លើយថា ពួកយើងដឹង បើមិនដឹងទេ គប្បីឆ្លើយថា ពួកយើងមិនដឹងទេ មួយទៀត ភិក្ខុនីណាមានសេចក្តីសង្ស័យ ឬងឿងឆ្ងល់ ភិក្ខុនីនោះគប្បីសួរយើងក្នុងប្រស្នានោះចុះថា បពិត្រលោកដ៏ចម្រើន ពាក្យនេះដូចម្តេច សេចក្តីអធិប្បាយរបស់ពាក្យនេះដូចម្តេច ។ ពួកភិក្ខុនីតបថា បពិត្រលោកដ៏ចម្រើន លោកម្ចាស់នន្ទកៈបវារណាយើងដោយពាក្យណា ពួកយើងមានចិត្តត្រេកអររីករាយចំពោះលោកម្ចាស់នន្ទកៈដោយពាក្យមានប្រមាណប៉ុណ្ណោះ ។

[ ២៤៤ ] នន្ទកភិក្ខុសួរថា ម្នាលនាងទាំងឡាយ ពួកនាងសម្គាល់នូវសេចក្តីនោះដូចម្តេច ចក្ខុ ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ របស់ណាមិនទៀង របស់នោះ ជាទុក្ខ ឬជាសុខ ។ របស់នោះជាទុក្ខលោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខមានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេលោកម្ចាស់ ។ ម្នាលនាងទាំងឡាយ ពួកនាងសម្គាល់សេចក្តីនោះដូចម្តេច ត្រចៀក ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។បេ។ ច្រមុះ ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។បេ។ អណ្តាត ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។បេ។ កាយ ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។បេ។ ចិត្ត ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ ចុះរបស់ណាដែលមិនទៀង របស់នោះ ជាទុក្ខ ឬជាសុខ ។ របស់នោះជាទុក្ខ លោកម្ចាស់ ។ របស់ណាដែលមិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេលោកម្ចាស់ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិតនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃថា អាយតនៈខាងក្នុងទាំង ៦ នេះ មិនទៀងទេ ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះ អរិយសាវកក៏ឃើញដោយប្រាជ្ញាដ៏ប្រពៃ តាមពិតយ៉ាងនោះដែរ ។

[ ២៤៥ ] ម្នាលនាងទាំងឡាយ ពួកនាងសម្គាល់សេចក្ដីនោះដូចម្ដេច រូប ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។ ចុះរបស់ណាមិនទៀង របស់នោះ ជាទុក្ខ ឬជាសុខ ។ របស់នោះ ជាទុក្ខលោកម្ចាស់ ។ របស់ណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេលោកម្ចាស់ ។ ម្នាលនាងទាំងឡាយ ពួកនាងសម្គាល់សេចក្ដីនោះដូចម្ដេច ។ សំឡេង ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ ក្លិន ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ រស ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។បេ។ ផោដ្ឋព្វៈ ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។បេ។ ធម្មារម្មណ៍ ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ របស់ណាមិនទៀង របស់នោះ ជាទុក្ខ ឬជាសុខ ។ របស់នោះ ជាទុក្ខ លោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេលោកម្ចាស់ ។ សេចក្ដីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិតនូវសេចក្ដីនុ៎ះដោយប្រាជ្ញាដ៏ប្រពៃថា អាយតនៈខាងក្រៅទាំង ៦ នេះ មិនទៀងទេ ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ហើយ ម្នាលនាងទាំងឡាយ សេចក្ដីនុ៎ះ អរិយសាវកក៏ឃើញដោយប្រាជ្ញាដ៏ប្រពៃ តាមពិតយ៉ាងនោះដែរ ។

[ ២៤៦ ] ម្នាលនាងទាំងឡាយ ពួកនាងសម្គាល់សេចក្តីនោះដូចម្តេច ចក្ខុវិញ្ញាណ ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។ របស់ណាដែលមិនទៀង របស់នោះ ជាទុក្ខ ឬជាសុខ ។ របស់នោះជាទុក្ខលោកម្ចាស់ ។ របស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេលោកម្ចាស់ ។ ម្នាលនាងទាំងឡាយ ពួកនាងសម្គាល់សេចក្តីនោះដូចម្តេច សោតវិញ្ញាណ ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។បេ។ ឃានវិញ្ញាណ ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ ជិវ្ហាវិញ្ញាណ ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។បេ។ កាយវិញ្ញាណ ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។បេ។ មនោវិញ្ញាណ ទៀង ឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។ របស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ របស់នោះ ជាទុក្ខលោកម្ចាស់ ។ របស់ណាដែលមិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនុ៎ះទេ លោកម្ចាស់ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបាន ឃើញតាមពិតនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃថា វិញ្ញាណកាយទាំង ៦ នេះ មិនទៀងទេ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះ អរិយសាវកក៏ឃើញដោយប្រាជ្ញាដ៏ប្រពៃ តាមពិតយ៉ាងនោះដែរ ។

[ ២៤៧ ] ម្នាលនាងទាំងឡាយ សេចក្តីប្រៀបថា ប្រទីបពេញដោយប្រេងកំពុងឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ពន្លឺក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។ ម្នាលនាងទាំងឡាយ ជនណានិយាយយ៉ាងនេះថា ប្រទីបពេញដោយប្រេងឯណោះកំពុងឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ពន្លឺណារបស់ប្រទីបនោះ ពន្លឺនោះទើបទៀងទាត់ ឋិតថេរ មិនមានសេចក្តីប្រែប្រួលជាធម្មតា ម្នាលនាងទាំងឡាយ ជននោះ ឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ ការនិយាយនុ៎ះ មិនត្រូវទេលោកម្ចាស់ ។ ពាក្យនោះមិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថាប្រទីបពេញដោយប្រេងឯណោះកំពុងតែឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ចាំបាច់និយាយទៅថ្វីដល់ទៅពន្លឺរបស់ប្រទីបនោះដែលជារបស់មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។

[ ២៤៨ ] ម្នាលនាងទាំងឡាយ សេចក្តីនេះក៏ដូច្នេះដែរ ជនណានិយាយយ៉ាងនេះថា អាយតនៈខាងក្នុង ៦ នេះ មិនទៀង អាត្មាអញទទួលដឹងអារម្មណ៍ណាជាសុខ ឬជាទុក្ខ ឬមិនទុក្ខមិនសុខ ព្រោះអាស្រ័យអាយតនៈខាងក្នុង អារម្មណ៍នោះ ទៀងទាត់ ឋិតថេរ មិនមានសេចក្តីប្រែប្រួលជា

ធម្មតា ម្នាលនាងទាំងឡាយ ជននោះ ឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ ការនិយាយនុ៎ះ មិនត្រឹមត្រូវទេលោកម្ចាស់ ។ ពាក្យនោះ មិនត្រឹមត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា វេទនាដែលកើតអំពីអាយតនៈខាងក្នុងនោះៗ តែងកើតឡើង ព្រោះអាស្រ័យបច្ច័យដែលកើតអំពីអាយតនៈខាងក្នុងនោះៗ វេទនាដែលកើតអំពីអាយតនៈខាងក្នុងនោះៗ តែងរលត់ទៅ ព្រោះរលត់នៃបច្ច័យ ដែលកើតអំពីអាយតនៈខាងក្នុងនោះៗ ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ហើយ ម្នាលនាងទាំងឡាយ សេចក្តីនោះ អរិយសាវកក៏ឃើញតាមពិត ដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះដែរ ។

[ ២៤៩ ] ម្នាលនាងទាំងឡាយ ប្រៀបដូចជាឈើធំ មានខ្លឹមកំពុងឈរនៅ ឫសក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ដើមក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា មែក និងសន្លឹកក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ស្រមោលក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។ ម្នាលនាងទាំងឡាយ ជនណានិយាយយ៉ាងនេះថា ឈើធំឯណោះ មានខ្លឹមកំពុងឈរនៅ ឫសក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ដើមក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា មែក និងសន្លឹកក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ស្រមោលណារបស់ឈើនោះ ស្រមោលនោះ ទៀងទាត់ ឋិតថេរ មិនមានសេចក្តីប្រែប្រួលជាធម្មតា អ្នកនោះឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ ការនិយាយនុ៎ះ មិនត្រូវទេលោកម្ចាស់ ។ ការនិយាយនោះ មិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះថា ឈើធំឯណោះ មានខ្លឹម

កំពុងឈរនៅ ឫសក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ដើមក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា មែក និងសន្លឹកក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ចាំបាច់និយាយទៅថ្វីដល់ស្រមោលរបស់ឈើនោះ ដែលជារបស់មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។

[ ២៥០ ] ម្នាលនាងទាំងឡាយ សេចក្តីនេះ ក៏យ៉ាងនោះដែរ ជនណានិយាយយ៉ាងនេះថា អាយតនៈខាងក្រៅ ៦ នេះ មិនទៀង អាត្មាអញអាស្រ័យអាយតនៈខាងក្រៅហើយ ទទួលដឹងអារម្មណ៍ណា ជាសុខ ឬជាទុក្ខ ឬមិនមែនទុក្ខមិនមែនសុខ អារម្មណ៍នោះ ទៀងទាត់ ឋិតថេរ មិនមានសេចក្តីប្រែប្រួលជាធម្មតា ម្នាលនាងទាំងឡាយ ជននោះ ឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ការនិយាយនុ៎ះ មិនត្រូវទេ ។ ការនិយាយនោះ មិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថាវេទនាដែលកើតអំពីអាយតនៈខាងក្រៅនោះៗ តែងកើតឡើង ព្រោះអាស្រ័យបច្ច័យដែលកើតអំពីអាយតនៈខាងក្រៅនោះៗ វេទនាដែលកើតអំពីអាយតនៈខាងក្រៅនោះៗ រលត់ទៅវិញ ព្រោះរលត់បច្ច័យដែលកើតអំពីអាយតនៈខាងក្រៅនោះៗ ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះ អរិយសាវកក៏ឃើញតាមពិតដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។

[ ២៥១ ] ម្នាលនាងទាំងឡាយ ប្រៀបដូចជាបុរសអ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោដែលប្រសប់ សម្លាប់នូវមេគោ ហើយពន្លះនូវមេគោដោយកាំបិតសម្រាប់អារគោដ៏មុត មិនឲ្យខូចសាច់ខាងក្នុង មិនឲ្យខូចស្បែក

ខាងក្រៅ បណ្តាវត្ថុទាំងនោះ វត្ថុណាៗ គឺសាច់វាវខាងក្នុងក្តី សរសៃខាងក្នុងក្តី ចំណងខាងក្នុងក្តី ក៏អារពន្ធះកាត់យកវត្ថុនោះៗ ដោយកាំបិតសម្រាប់អារគោដ៏មុត លុះអារពន្ធះកាត់រួចហើយ ក៏បកយកស្បែកខាងក្រៅមកគ្របមេគោដោយស្បែកនោះវិញដដែល ហើយនិយាយយ៉ាងនេះថា មេគោនេះនៅមានស្បែកដូចមុនដដែល ម្នាលនាងទាំងឡាយ ជននោះឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកម្ចាស់ ការនិយាយនុ៎ះមិនត្រូវទេ ។ ការនិយាយនោះមិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះថា បុរសអ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោឯណោះដែលប្រសប់ បានសម្លាប់នូវមេគោ ហើយអារនូវមេគោដោយកាំបិត សម្រាប់អារគោដ៏មុត មិនឲ្យខូចសាច់ខាងក្នុង មិនឲ្យខូចស្បែកខាងក្រៅ បណ្តាវត្ថុទាំងនោះ វត្ថុណាៗ គឺសាច់វាវខាងក្នុងក្តី សរសៃខាងក្នុងក្តី ចំណងខាងក្នុងក្តី ក៏អារពន្ធះកាត់យកវត្ថុនោះៗ ដោយកាំបិតសម្រាប់អារគោដ៏មុត លុះអារពន្ធះកាត់រួចហើយ ក៏បកយកស្បែកខាងក្រៅមកគ្របមេគោនោះ ដោយស្បែកនោះវិញដដែល ជននោះនិយាយយ៉ាងនេះថា មេគោនេះនៅមានស្បែកដូចមុនដដែល ដូច្នេះក៏ពិតមែនហើយ ប៉ុន្តែ មេគោនោះ ប្រាសចាកស្បែកនោះហើយដោយប្រាកដ ។

[ ២៥២ ] ម្នាលនាងទាំងឡាយ ពាក្យឧបមា ដែលយើងធ្វើហើយនេះ ដើម្បីឲ្យពួកនាងដឹងច្បាស់នូវសេចក្តីអធិប្បាយ ។ ឯសេចក្តីអធិប្បាយ ក្នុងអាយតនៈនុ៎ះ ដូចតទៅនេះ ។ ម្នាលនាងទាំងឡាយ ពាក្យថា សាច់ខាងក្នុងនុ៎ះ ជាឈ្មោះនៃអាយតនៈខាងក្នុង ៦ ។ ម្នាលនាងទាំងឡាយ ពាក្យថា

ស្បែកខាងក្រៅនោះ ជាឈ្មោះនៃអាយតនៈខាងក្រៅ ៦ ។ ម្នាលនាងទាំង-ឡាយ ពាក្យថា សាច់វាវខាងក្នុងក្តី សរសៃខាងក្នុងក្តី ចំណងខាងក្នុងក្តី នុ៎ះ ជាឈ្មោះនៃនន្ទិរាគ ។ ម្នាលនាងទាំងឡាយ ពាក្យថា កាំបិតសម្រាប់អារគោ ដ៏មុតនុ៎ះ ជាឈ្មោះនៃប្រាជ្ញាដ៏ប្រសើរ ។ ប្រាជ្ញាដ៏ប្រសើរនេះ តែងអារពន្ធះ កាត់កិលេសខាងក្នុង សំយោជនៈខាងក្នុង ចំណងខាងក្នុង ។

[ ២៥៣ ] ម្នាលនាងទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ ភិក្ខុណាចម្រើន ហើយ ធ្វើឲ្យរឿយៗ ហើយ ភិក្ខុនោះរមែងអស់អាសវៈទាំងឡាយ ហើយ ត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ បានដល់ដោយខ្លួនឯង ក្នុងបច្ចុប្បន្នទូវចេតោ-វិមុត្តិ បញ្ញាវិមុត្តិដែលមិនមានអាសវៈ សម្រេចសម្រាន្តនៅដោយឥរិយាបថ ទាំង ៤ ។ ពោជ្ឈង្គទាំង ៧ ដូចម្តេចខ្លះ ។ ម្នាលនាងទាំងឡាយ ភិក្ខុក្នុង សាសនានេះ ចម្រើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តីស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ ឈមមុខទៅកាន់ សេចក្តីលះបង់ ចម្រើននូវធម្មវិចយសម្ពោជ្ឈង្គ ... ចម្រើននូវវីរិយសម្ពោជ្ឈង្គ ... ចម្រើននូវបីតិសម្ពោជ្ឈង្គ ... ចម្រើននូវបស្សទ្ធិសម្ពោជ្ឈង្គ ... ចម្រើននូវ សមាធិសម្ពោជ្ឈង្គ ... ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យសេចក្តី ស្ងប់ស្ងាត់ អាស្រ័យសេចក្តីប្រាសចាកតម្រេក អាស្រ័យសេចក្តីរលត់ ឈម មុខទៅកាន់សេចក្តីលះបង់ ។ ម្នាលនាងទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ដែលភិក្ខុណាបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ ភិក្ខុនោះ រមែងអស់ អាសវៈទាំងឡាយ ហើយត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ បានដល់ដោយខ្លួន

ឯងក្នុងបច្ចុប្បន្ន នូវចេតោវិមុត្តិ បញ្ញាវិមុត្តិដែលមិនមានអាសវៈ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។

[ ២៥៤ ] លំដាប់នោះឯង ព្រះនន្ទកៈមានអាយុ ទូន្មានពួកភិក្ខុនីនោះ ដោយឱវាទនេះហើយ ទើបបញ្ជូនទៅថា ម្នាលនាងទាំងឡាយ ចូរពួកនាងទៅចុះ ព្រោះកាលគួរហើយ ។ ទើបភិក្ខុនីទាំងនោះ ត្រេកអរអនុមោទនានូវភាសិត របស់ព្រះនន្ទកៈមានអាយុ ហើយក៏ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះនន្ទកៈមានអាយុ ធ្វើប្រទក្សិណហើយ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះភិក្ខុនីទាំងនោះ ឋិតនៅក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុនីទាំងឡាយ ចូរពួកនាងទៅចុះ ព្រោះកាលគួរហើយ ។ ទើបភិក្ខុនីទាំងនោះ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយចេញទៅ ។

[ ២៥៥ ] កាលដែលភិក្ខុនីទាំងនោះ ចេញទៅមិនយូរប៉ុន្មាន ទើបព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថទី ១៤ ជនជាច្រើន រមែងមិនមានសេចក្តីសង្ស័យ ឬងឿងឆ្ងល់ថា ព្រះចន្ទខ្វះ ឬព្រះចន្ទពេញដូច្នេះឡើយ រមែងចូលចិត្តថា ព្រះចន្ទខ្វះដោយពិត សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ក៏ពួកភិក្ខុនីនោះ គ្រាន់តែមានសេចក្តីត្រេកអរ នឹងធម្មទេសនារបស់នន្ទកភិក្ខុមែន ប៉ុន្តែ មានបំណងមិនបានពេញលេញឡើយ មានឧបមេយ្យយ៉ាងនោះឯង ។ គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់ហៅព្រះនន្ទកៈមានអាយុថា ម្នាលនន្ទកៈ បើ

ដូច្នោះ ក្នុងថ្ងៃស្អែក អ្នកគប្បីទូន្មានពួកភិក្ខុនីនោះ ដោយឱវាទនោះទៀត ។ ព្រះនន្ទកៈមានអាយុ ទទួលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ២៥៦ ] លំដាប់នោះឯង ព្រះនន្ទកៈមានអាយុ កាលរាត្រីនោះកន្លងទៅ ក៏ស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត មានខ្លួនជាគម្រប់ពីរ ចូលទៅកាន់រាជការាម ។ ភិក្ខុនីទាំងនោះ បានឃើញព្រះនន្ទកៈមានអាយុ និមន្តមកអំពីចម្ងាយ ។ លុះឃើញហើយ ក៏នាំគ្នាក្រាលអាសនៈផង តម្កល់ទឹកសម្រាប់លាងជើងផង ។ ព្រះនន្ទកៈមានអាយុ គង់លើអាសនៈដែលពួកភិក្ខុនីក្រាលហើយ ។ លុះគង់រួចហើយ ទើបលាងនូវជើងទាំងឡាយ ។ ឯពួកភិក្ខុនីនោះ ថ្វាយបង្គំព្រះនន្ទកៈមានអាយុ ហើយអង្គុយនៅក្នុងទីសមគួរ ។

[ ២៥៧ ] លុះពួកភិក្ខុនីនោះ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះនន្ទកៈមានអាយុ បានសួរយ៉ាងនេះថា ម្នាលនាងទាំងឡាយ បើមានពាក្យសាកសួរពួកភិក្ខុនីអាចដឹងក្នុងប្រស្នានោះ គប្បីឆ្លើយថា ពួកយើងដឹង ( បើ ) មិនដឹងទេ គប្បីឆ្លើយថា ពួកយើងមិនដឹងទេ បើសេចក្តីសង្ស័យ ឬងឿងឆ្ងល់មានដល់ភិក្ខុនីណា ភិក្ខុនីនោះគប្បីសួរយើងក្នុងប្រស្នានោះថា បពិត្រលោកដ៏ចម្រើន ពាក្យនេះដូចម្តេច សេចក្តីអធិប្បាយរបស់ពាក្យនេះដូចម្តេច ។ បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់នន្ទកៈបវារណាយើងដោយពាក្យណា យើងមាន

សេចក្តីត្រេកអរ រីករាយចំពោះលោកម្ចាស់នន្ទកៈ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ។

[ ២៥៨ ] ម្នាលនាងទាំងឡាយ ពួកនាងសម្គាល់សេចក្តីនោះ ដូចម្តេច ចក្ខុ ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខលោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញរបស់នោះថា នុ៎ះរបស់ អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះ ទេ លោកម្ចាស់ ។ ម្នាលនាងទាំងឡាយ ពួកនាងសម្គាល់សេចក្តីនោះ ដូច ម្តេច ត្រចៀក ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ ច្រមុះ ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ អណ្តាត ទៀង ឬ មិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ កាយ ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ ចិត្ត ទៀង ឬមិនទៀង ។ មិនទៀងទេលោក ម្ចាស់ ។ របស់ណាដែលមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ ជាទុក្ខ លោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជា ធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួន អញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ សេចក្តី នោះ ព្រោះហេតុអ្វី ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិតនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃថា អាយតនៈ ខាងក្នុង ៦ នេះ មិនទៀងទេ ។ ម្នាលនាងទាំងឡាយ ប្រពៃណាស់ហើយ

ម្នាលនាងទាំងឡាយ រឿងនុ៎ះ អរិយសាវ័ក ក៏ឃើញពិតប្រាកដដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។

[ ២៥៩ ] ម្នាលនាងទាំងឡាយ ពួកនាងសម្គាល់សេចក្ដីនោះ ដូចម្ដេច រូប ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។ ចុះរបស់ណាដែលមិនទៀង របស់នោះ ជាទុក្ខ ឬជាសុខ ។ ជាទុក្ខលោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ ម្នាលនាងទាំងឡាយ ពួកនាងសម្គាល់សេចក្ដីនោះ ដូចម្ដេច សំឡេង ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ ក្លិន ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ រសទៀងឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ ផោដ្ឋព្វៈ ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ ធម្មារម្មណ៍ ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។ ចុះរបស់ណាដែលមិនទៀង របស់នោះ ជាទុក្ខ ឬជាសុខ ។ ជាទុក្ខលោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ សេចក្ដីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិតនូវសេចក្ដីនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃថា អាយតនៈខាងក្រៅទាំង ៦នេះ មិនទៀងទេ ។ ម្នាលនាងទាំងឡាយ ប្រពៃ

ពេកហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះ អរិយសាវកក៏ឃើញពិតប្រាកដដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។

[ ២៦០ ] ម្នាលនាងទាំងឡាយ ពួកនាងសម្គាល់នូវសេចក្តីនោះ ដូចម្តេច ចក្ខុវិញ្ញាណ ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។ ចុះរបស់ណាដែលមិនទៀង របស់នោះ ជាទុក្ខ ឬជាសុខ ។ ជាទុក្ខលោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខមានសេចក្តីប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនុ៎ះទេ លោកម្ចាស់ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិតនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃថា វិញ្ញាណកាយទាំង ៦ នេះមិនទៀង ។ ម្នាលនាងទាំងឡាយ ប្រពៃពេកហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះ អរិយសាវកក៏ឃើញពិតប្រាកដដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។ សោតវិញ្ញាណ ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ ឃានវិញ្ញាណទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ ជិវ្ហាវិញ្ញាណ ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។បេ។ កាយវិញ្ញាណទៀងឬមិនទៀង ។ មិនទៀងទេ លោកម្ចាស់ ។បេ។ មនោវិញ្ញាណ ទៀង ឬមិនទៀង ។ មិនទៀងទេលោកម្ចាស់ ។ ចុះរបស់ណាដែលមិនទៀង របស់នោះ ជាទុក្ខ ឬជាសុខ ។ ជាទុក្ខលោកម្ចាស់ ។ របស់ណាដែលមិនទៀង ជាទុក្ខ ប្រែប្រួលជាធម្មតា គួរយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួន

អញដូច្នេះដែរឬ ។ មិនគួរយល់ឃើញយ៉ាងនោះទេ លោកម្ចាស់ ។ សេចក្តីនោះ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ក្នុងកាលមុន ពួកយើងបានឃើញតាមពិតនូវសេចក្តីនុ៎ះ ដោយប្រាជ្ញាដ៏ប្រពៃថា វិញ្ញាណកាយទាំង ៦ នេះ មិនទៀងទេ ។ ម្នាលនាងទាំងឡាយ ប្រពៃពេកហើយ ម្នាលនាងទាំងឡាយ រឿងនុ៎ះ អរិយសាវកក៏ឃើញពិតប្រាកដដោយប្រាជ្ញាដ៏ប្រពៃយ៉ាងនេះដែរ ។

[ ២៦១ ] ម្នាលនាងទាំងឡាយ ប្រៀបដូចជាប្រទីបពេញដោយប្រេងកំពុងឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ពន្លឺក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។ ម្នាលនាងទាំងឡាយ ជនណានិយាយយ៉ាងនេះថា ប្រទីបពេញដោយប្រេងឯណោះ កំពុងឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា តែពន្លឺណារបស់ប្រទីបនោះ ពន្លឺនោះទៀងទាត់ឋិតថេរ មិនមានសេចក្តីប្រែប្រួលជាធម្មតា ម្នាលនាងទាំងឡាយ ជននោះ ឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកដ៏ចម្រើន ការនិយាយនោះមិនត្រូវទេ ។ ការនិយាយនោះមិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា ប្រទីបពេញដោយប្រេងឯណោះកំពុងឆេះ ប្រេងក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ប្រឆេះ ក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា អណ្តាតភ្លើង ក៏មិន

ទៀង មានសេចក្តីប្រែប្រួលជាធម្មតា ចាំបាច់និយាយទៅថ្វី ដល់ពន្លឺរបស់ប្រទីបនោះ ដែលជារបស់មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។

[ ២៦២ ] ម្នាលនាងទាំងឡាយ ដំណើរនេះក៏ដូច្នោះដែរ ជនណានិយាយយ៉ាងនេះថា អាយតនៈខាងក្នុងទាំង ៦ នេះ មិនទៀង អាត្មាអញអាស្រ័យអាយតនៈខាងក្នុងទាំង ៦ ហើយ ទទួលដឹងវេទនាណាជាសុខ ឬជាទុក្ខ ឬក៏មិនមែនទុក្ខមិនមែនសុខ វេទនានោះទៀងទាត់ ឋិតថេរ មិនមានសេចក្តីប្រែប្រួលជាធម្មតា ម្នាលនាងទាំងឡាយ ជននោះឈ្មោះថា និយាយត្រូវដែរឬ ។ បពិត្រលោកដ៏ចម្រើន ការនិយាយនោះមិនត្រូវទេ ។ ការនិយាយនោះមិនត្រូវព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា វេទនាដែលកើតអំពីអាយ-តនៈខាងក្នុងនោះៗ តែងកើតឡើង ព្រោះអាស្រ័យបច្ច័យ ដែលកើតអំពីអាយតនៈខាងក្នុងនោះៗ វេទនាដែលកើតអំពីអាយតនៈខាងក្នុងនោះៗ រលត់ទៅ ព្រោះរលត់នៃបច្ច័យ ដែលកើតអំពីអាយតនៈខាងក្នុងនោះៗ ។ ម្នាលនាងទាំងឡាយ ប្រពៃពេកហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះ អរិយ-សាវក ក៏ឃើញពិតប្រាកដដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។

[ ២៦៣ ] ម្នាលនាងទាំងឡាយ ប្រៀបដូចជាឈើធំមានខ្លឹមកំពុងឈរនៅ ឫសក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ដើមក៏មិនទៀងមានសេចក្តីប្រែប្រួលជាធម្មតា មែក និងសន្លឹកក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ស្រមោលក៏មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា ។ ម្នាលនាងទាំងឡាយ ជនណានិយាយយ៉ាងនេះថា ឈើធំឯណោះមានខ្លឹម កំពុងឈរនៅ ឫសក៏មិន

ទៀង មានសេចក្ដីប្រែប្រួលជាធម្មតា ដើមក៏មិនទៀង មានសេចក្ដីប្រែប្រួលជាធម្មតា មែក និងសន្ទឹកក៏មិនទៀង មានសេចក្ដីប្រែប្រួលជាធម្មតា តែស្រមោលណារបស់ឈើនោះ ស្រមោលនោះ ទៀងទាត់ ឋិតថេរ មិនមានសេចក្ដីប្រែប្រួលជាធម្មតាឡើយ ម្នាលនាងទាំងឡាយ ជននោះ ឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកដ៏ចម្រើន ការនិយាយនុ៎ះមិនត្រូវទេ ។ ការនិយាយនោះ មិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថាឈើធំឯណោះ មានខ្លឹមកំពុងឈរនៅ ឫសក៏មិនទៀង មានសេចក្ដីប្រែប្រួលជាធម្មតា ដើមក៏មិនទៀង មានសេចក្ដីប្រែប្រួលជាធម្មតា មែក និងសន្ទឹកក៏មិនទៀង មានសេចក្ដីប្រែប្រួលជាធម្មតា ចាំបាច់និយាយទៅថ្វី ដល់ទៅស្រមោលរបស់ឈើនោះ ដែលជារបស់មិនទៀង មានសេចក្ដីប្រែប្រួលជាធម្មតា ។

[ ២៦៤ ] ម្នាលនាងទាំងឡាយ សេចក្ដីនេះក៏ដូច្នោះដែរ ជនណានិយាយយ៉ាងនេះថា អាយតនៈខាងក្រៅទាំង ៦ នេះ មិនទៀង អាត្មាអញអាស្រ័យអាយតនៈខាងក្រៅហើយ ទទួលដឹងវេទនាណា ជាសុខ ឬជាទុក្ខ ឬក៏មិនមែនទុក្ខមិនមែនសុខ អារម្មណ៍នោះទៀងទាត់ ឋិតថេរ មិនមានសេចក្ដីប្រែប្រួលជាធម្មតាឡើយ ម្នាលនាងទាំងឡាយ ជននោះ ឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកដ៏ចម្រើន ការនិយាយនុ៎ះ មិនត្រូវទេ ។ ការនិយាយនោះ មិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថាវេទនាដែលកើតអំពីអាយតនៈខាងក្រៅនោះៗ តែងកើតឡើង ព្រោះអាស្រ័យ

បច្ច័យដែលកើតអំពីអាយតនៈខាងក្រៅនោះៗ វេទនាដែលកើតអំពីអាយតនៈខាងក្រៅនោះៗ រលត់ទៅ ព្រោះរលត់នៃបច្ច័យដែលកើតអំពីអាយតនៈខាងក្រៅនោះៗ ។ ម្នាលនាងទាំងឡាយ ប្រពៃពេកហើយ ម្នាលនាងទាំងឡាយ សេចក្តីនុ៎ះ អរិយសាវក ក៏ឃើញពិតប្រាកដ ដោយប្រាជ្ញាដ៏ប្រពៃ យ៉ាងនោះដែរ ។

[ ២៦៥ ] ម្នាលនាងទាំងឡាយ ប្រៀបដូចជាបុរសអ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោ ដែលប្រសប់ សម្លាប់មេគោហើយ ពន្លះនូវមេគោ ដោយកាំបិតសម្រាប់អារគោដ៏មុត មិនឲ្យខូចសាច់ខាងក្នុង មិនឲ្យខូចស្បែកខាងក្រៅ បណ្តាវត្ថុទាំងនោះ វត្ថុណាៗ គឺសាច់វាវខាងក្នុងក្តី សរសៃខាងក្នុងក្តី ចំណងខាងក្នុង ក៏អារពន្លះកាត់ វត្ថុនោះៗ ដោយកាំបិតសម្រាប់អារគោដ៏មុត លុះអារពន្លះកាត់រួចហើយ ក៏បកយកស្បែកខាងក្រៅ មកគ្របមេគោនោះ ដោយស្បែកនោះវិញដដែល ហើយនិយាយយ៉ាងនេះថា មេគោនេះនៅមានស្បែកដូចមុនដដែល ម្នាលនាងទាំងឡាយ ជននោះ ឈ្មោះថានិយាយត្រឹមត្រូវដែរឬ ។ បពិត្រលោកដ៏ចម្រើន ការនិយាយនោះមិនត្រូវទេ ។ ការនិយាយនោះ មិនត្រូវ ព្រោះហេតុអ្វី ។ បពិត្រលោកដ៏ចម្រើន ព្រោះថា បុរសអ្នកសម្លាប់គោ ឬកូនសិស្សអ្នកសម្លាប់គោឯណោះដែលប្រសប់ បានសម្លាប់មេគោ ហើយពន្លះនូវមេគោ ដោយកាំបិតសម្រាប់អារគោដ៏មុត មិនឲ្យខូចសាច់ខាងក្នុង មិនឲ្យខូចស្បែកខាងក្រៅ បណ្តាវត្ថុទាំងនោះ វត្ថុណាៗ គឺសាច់វាវខាងក្នុងក្តី សរសៃខាងក្នុងក្តី ចំណងខាងក្នុងក្តី ក៏អារពន្លះកាត់វត្ថុ

នោះៗ ដោយកាំបិតសម្រាប់អារគោដ៏មុត លុះអារពន្ទះកាត់រួចហើយ ក៏បកយកស្បែកខាងក្រៅ មកគ្របមេគោនោះដោយស្បែកនោះដដែល អ្នកនោះនិយាយយ៉ាងនេះថា មេគោនេះនៅមានស្បែកដូចមុនដដែល ក៏ពិតមែនហើយ ប៉ុន្តែ មេគោនោះ ប្រាសចាកស្បែកនោះទៅហើយ ។

[ ២៦៦ ] ម្នាលនាងទាំងឡាយ ពាក្យឧបមាដែលយើងធ្វើហើយនេះ ដើម្បីឲ្យពួកនាងដឹងច្បាស់ នូវសេចក្តីអធិប្បាយ ។ ឯសេចក្តីអធិប្បាយក្នុងអាយតនៈនុ៎ះ ដូចតទៅនេះ ។ ម្នាលនាងទាំងឡាយ ពាក្យថា សាច់ខាងក្នុងដូច្នេះនុ៎ះ ជាឈ្មោះនៃអាយតនៈខាងក្នុង ៦ ។ ម្នាលនាងទាំងឡាយ ពាក្យថា ស្បែកខាងក្រៅដូច្នេះនោះ ជាឈ្មោះនៃអាយតនៈខាងក្រៅ ៦ ។ ម្នាលនាងទាំងឡាយ ពាក្យថា សាច់វាវខាងក្នុងក្តី សរសៃខាងក្នុងក្តី ចំណងខាងក្នុងក្តីដូច្នេះនុ៎ះ ជាឈ្មោះនៃនន្ទិរាគ ។ ម្នាលនាងទាំងឡាយ ពាក្យថា កាំបិតសម្រាប់អារគោដ៏មុតដូច្នេះនុ៎ះ ជាឈ្មោះនៃប្រាជ្ញាដ៏ប្រសើរ ។ ប្រាជ្ញាដ៏ប្រសើរនេះ តែងអារពន្ទះកាត់នូវកិលេសខាងក្នុង សំយោជនៈខាងក្នុង និងចំណងខាងក្នុង ។

[ ២៦៧ ] ម្នាលនាងទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះ ភិក្ខុណាចម្រើនហើយ ធ្វើឲ្យរឿយៗ ហើយ ភិក្ខុនោះ រមែងអស់អាសវៈទាំងឡាយហើយត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់បានដោយខ្លួនឯង ក្នុងបច្ចុប្បន្ននូវចេតោ-វិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។ ពោជ្ឈង្គទាំង ៧ ដូចម្តេចខ្លះ ។ ម្នាលនាងទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចម្រើននូវសតិសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់

អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ ឈមមុខទៅកាន់សេចក្តីលះបង់ ចម្រើននូវធម្មវិចយសម្ពោជ្ឈង្គ ... ចម្រើននូវវិរិយសម្ពោជ្ឈង្គ ... ចម្រើននូវបីតិសម្ពោជ្ឈង្គ ... ចម្រើននូវបស្សទ្ធិសម្ពោជ្ឈង្គ ... ចម្រើននូវសមាធិសម្ពោជ្ឈង្គ ... ចម្រើននូវឧបេក្ខាសម្ពោជ្ឈង្គ ដែលអាស្រ័យនូវសេចក្តីស្ងប់ស្ងាត់ អាស្រ័យនូវសេចក្តីប្រាសចាកតម្រេក អាស្រ័យនូវសេចក្តីរលត់ ឈមមុខទៅកាន់សេចក្តីលះបង់ ។ ម្នាលនាងទាំងឡាយ ពោជ្ឈង្គទាំង ៧ នេះឯង ដែលភិក្ខុណាបានចម្រើន បានធ្វើឲ្យរឿយៗ ហើយ ភិក្ខុនោះ រមែងអស់អាសវៈទាំងឡាយ ហើយត្រាស់ដឹង ធ្វើឲ្យជាក់ច្បាស់ បានដល់ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននូវចេតោវិមុត្តិ បញ្ញាវិមុត្តិ ដែលមិនមានអាសវៈ សម្រេចសម្រាន្តនៅ ដោយឥរិយាបថទាំង ៤ ។

[ ២៦៨ ] លំដាប់នោះឯង លុះព្រះនន្ទកៈមានអាយុ បានទូន្មានភិក្ខុនីទាំងនោះ ដោយឱវាទនេះហើយ ទើបបញ្ជូនទៅថា ម្នាលនាងទាំងឡាយ ពេលល្មមហើយ ចូរនាំគ្នាទៅចុះ ។ គ្រានោះឯង ពួកភិក្ខុនីនោះ ត្រេកអរអនុមោទនានូវភាសិត របស់ព្រះនន្ទកៈមានអាយុហើយ ក៏ក្រោកអំពីអាសនៈថ្វាយបង្គំព្រះនន្ទកៈមានអាយុ ធ្វើប្រទក្សិណហើយ ទើបចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគហើយឋិតនៅក្នុងទីដ៏សមគួរ ។ លុះពួកភិក្ខុនីនោះ ឋិតនៅក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាលនាងទាំងឡាយ ពេលល្មមហើយ ចូរទៅចុះ ។ លំដាប់នោះ ពួកភិក្ខុនីនោះ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយ

ទើបចេញទៅ ។

[ ២៦៩ ] កាលដែលពួកភិក្ខុនីនោះ ចេញទៅមិនយូរប៉ុន្មាន ទើបព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ ក្នុងថ្ងៃឧបោសថទី ១៥ ជនជាច្រើនតែងមិនមានសេចក្តីសង្ស័យ ឬងឿងឆ្ងល់ថា ព្រះចន្ទខ្វះ ឬព្រះចន្ទពេញដូច្នេះឡើយ គឺចូលចិត្តថា ព្រះចន្ទពេញដោយពិត សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុនីនោះ មានសេចក្តីត្រេកអរ ក្នុងធម្មទេសនារបស់នន្ទកភិក្ខុផង មានបំណងពេញលេញផង ក៏មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុនីទាំង-ឡាយប្រាំរយនោះ ភិក្ខុនីដែលក្រោយគេបំផុត ភិក្ខុនីនោះជាសោតាបន្នា មានសភាពមិនធ្លាក់ទៅក្នុងអបាយភូមិ ជាអ្នកទៀង តទៅកពខាងមុខ នឹងបានត្រាស់ដឹង ( នូវសច្ចធម៌ ) ។ លុះព្រះមានព្រះភាគ ត្រាស់ពាក្យនេះចប់ហើយ ភិក្ខុទាំងនោះ ក៏មានសេចក្តីត្រេកអរ រីករាយចំពោះភាសិត របស់ព្រះមានព្រះភាគ ។

**នន្ទកោវាទសូត្រទី ៤ ចប់**

# អដ្ឋកថា

## នន្ទកោវាទសូត្រ

[ ២៤១-២៤២ ] នន្ទកោវាទសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងព្រះសូត្រនោះបទថា **តេន ខោ បន សមយេន** សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់ទទួលការអារាធនាអំពីព្រះនាងមហាបជាបតិគោតមីហើយ ទ្រង់បញ្ជូនភិក្ខុសង្ឃទៅហើយ ទ្រង់ឲ្យភិក្ខុសង្ឃមកប្រជុំ ទ្រង់ធ្វើការៈដល់សង្ឃថា ភិក្ខុទាំងឡាយដែលជាថេរៈ ចូរប្ដូរវេនគ្នាទូន្មានភិក្ខុនី ព្រះអានន្ទពោលសំដៅយកសេចក្ដីនោះ ទើបពោលពាក្យនេះ ។ ក្នុងសូត្រនេះ បទថា **បរិយាយេន** សំដៅដល់ដោយវារៈ ។ បទថា **ន ឥច្ឆតិ** គឺកាលដល់វេនរបស់ខ្លួនហើយ អ្នកទូន្មានភិក្ខុនីនឹងទៅស្រុកឆ្ងាយ ឬយកម្ជុលមកដេរសំពត់ជាដើម ហើយប្រាប់ឲ្យពោលជំនួសថា នេះគង់ជាការយឺតយូររបស់ភិក្ខុនោះតែការប្ដូរវេនគ្នាទូន្មាននេះ ព្រះមានព្រះភាគទ្រង់បានធ្វើការៈ ព្រោះហេតុនៃព្រះនន្ទកត្ថេរប៉ុណ្ណោះ ។ ព្រោះហេតុអ្វី ព្រោះកាលពួកភិក្ខុនីទាំងនេះបានឃើញព្រះថេរៈហើយ ចិត្តក៏នឹងជ្រះថ្លាពិតប្រាកដ ។ ព្រោះហេតុនោះ ទើបភិក្ខុនីទាំងនោះចង់ទទួលពាក្យទូន្មានរបស់លោក បំណងនឹងស្ដាប់ធម្មកថា ដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើឱវាទដោយវារៈថា កាលដល់វេនរបស់ខ្លួនហើយ នន្ទកៈនឹងសម្ដែងឱវាទ នឹងពោលធម្មកថា ឯព្រះថេរៈមិនព្រមធ្វើវេនរបស់ខ្លួន ។ បើមានពាក្យសួរថា ព្រោះហេតុអ្វី ក៏ឆ្លើយថា បានឮថា ភិក្ខុនីទាំងនោះ កាលព្រះថេរៈសោយរាជសម្បត្តិក្នុងជម្ពូទ្វីបកាលពីជាតិមុន ធ្លាប់ជាស្រីស្នំ ។ ព្រះ

ថេរៈបានជ្រាបហេតុការណ៍នោះ ដោយបុព្វេនិវាសញ្ញាណ ទើបគិតថា ភិក្ខុ ដទៃដែលបានបុព្វេនិវាសញ្ញាណ កាលបានឃើញអាត្មាអញ អង្គុយកណ្ដាល ភិក្ខុនីសង្ឃនេះ ទាញយកការប្រៀបធៀបនឹងហេតុការណ៍ផ្សេងៗ ជាធម្មតាថា ក៏នឹងសម្គឹងហេតុការណ៍នោះ ហើយសម្គាល់ពាក្យដែលគប្បីពោលថា នន្ទកៈ មិនព្រមលះបង់ពួកស្រីស្នំ រហូតមកដល់ថ្ងៃនេះ ព្រះនន្ទកៈមានស្រីស្នំចោម រោមនេះ ល្អពិតហ្ន៎ ។ កាលពិចារណាឃើញសេចក្ដីនេះ ទើបព្រះថេរៈមិន ព្រមធ្វើវេនរបស់ខ្លួន ។ បានឮមកថា ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ធម្ម-ទេសនារបស់ព្រះថេរៈប៉ុណ្ណោះ ទើបជាទីសប្បាយដល់ភិក្ខុនីទាំងនេះ ទើប ត្រាស់ឲ្យហៅព្រះនន្ទកៈមកក្នុងគ្រានោះឯង ។ ដើម្បីដឹងថា ភិក្ខុនីទាំងនោះ កាលពីជាតិមុនជាស្រីស្នំរបស់ព្រះថេរៈ ទើបមានរឿងដូចតទៅនេះ

បានឮមកថា ក្នុងកាលមុន ក្នុងក្រុងពារាណសី មានពួកអ្នកធ្វើការដោយ កម្លាំងស្មូង ១០០០ នាក់ គឺទាសៈ ៥០០ នាក់ ទាសី ៥០០ នាក់ ធ្វើការ ជាមួយគ្នា ស្នាក់នៅជាមួយគ្នា ។ ព្រះនន្ទកត្ថេរនេះ ជាប្រធានក្នុងទាសៈទាំង នោះ ព្រះនាងគោតមីជាប្រធានពួកទាសី នាងជាកិរិយាដែលឈ្លាសប្រតិពល របស់ប្រធានទាសៈ ។ សូម្បីពួកអ្នកធ្វើការដោយកម្លាំងទាំង ១០០០ នាក់ កាលធ្វើបុញ្ញកម្ម ក៏ធ្វើជាមួយគ្នា បន្ទាប់មក ក្នុងពេលចូលវស្សា មានព្រះ បច្ចេកពុទ្ធ ៥ អង្គ មកអំពីញកក្នុំនន្ទមូលកៈ ចុះត្រង់ឥសិបតនៈ ត្រាច់បិណ្ឌ-បាតក្នុងក្រុង ហើយក៏ទៅកាន់ឥសិបតនៈនោះឯង គិតថា ពួកយើងនឹងសូម ហត្ថកម្មដើម្បីប្រយោជន៍ដល់កុដិនៅចាំវស្សា ដណ្ដប់ចីវរចូលទៅកាន់ក្រុងក្នុង

ពេលល្ងាច ឈរត្រង់ទ្វារផ្ទះសេដ្ឋី នាងប្រធានទាសីកណ្តៀតក្អមទៅកាន់កំពង់ទឹក បានឃើញព្រះបច្ចេកពុទ្ធទាំងឡាយ កំពុងចូលកាន់ក្រុង ។ សេដ្ឋីបានស្តាប់ហេតុការណ៍ដែលព្រះបច្ចេកពុទ្ធទាំងនោះមក ក៏ពោលថា ពួកយើងមិនមានពេលទំនេរ សូមនិមន្តទៅចុះ ។ គ្រានោះ ប្រធានទាសីកំពុងទូលក្អមទឹក ចូលទៅ ឃើញព្រះបច្ចេកពុទ្ធទាំងឡាយនោះ កំពុងចេញមកអំពីក្រុង ទើបលើកក្អមទឹកចុះ ថ្វាយបង្គំ បិទមុខហើយទូលសួរថា លោកម្ចាស់ទាំង-ឡាយគ្រាន់តែចូលកាន់ក្រុងហើយ ក៏ចេញមក លោកម្ចាស់មានការអ្វីឬ ។ ព្រះបច្ចេកពុទ្ធ ក៏ពោលថា ពួកអាត្មាមកដើម្បីសូមហត្ថកម្មនៃកុដិចាំវស្សា ។ ទាសីពោលថា តើលោកម្ចាស់បានដែរឬទេ ព្រះបច្ចេកពុទ្ធពោលថា មិនបានទេ ឧបាសិកា ។ ទាសីពោលថា ឯកុដិនោះ ពួកអ្នកមានស្តុកស្តម្ភ ទើបធ្វើបាន ឬពួកអ្នកក្រីក្រ ក៏ធ្វើបានដែរ ព្រះបច្ចេកពុទ្ធពោលថា អ្នកណាមួយក៏អាចធ្វើបានដែរ ។ ទាសីពោលថា សាធុ លោកម្ចាស់ ពួកខ្ញុំនឹងធ្វើប្រគេនស្អែកនេះ សូមនិមន្តលោកម្ចាស់ ទទួលភិក្ខានាងខ្ញុំ ។ និមន្តទុកហើយ ក៏យកទឹកទៅ ហើយកណ្តៀតក្អមមកវិញ ឈរត្រង់កំពង់ទឹកទៀត និយាយនឹងពួកទាសីដ៏សេស ដែលនាំគ្នាមកហើយថា ពួកនាងចូរនៅទីនេះឯង ក្នុងវេលាដែលគ្រប់គ្នាមកហើយ ក៏ពោលថា ពួកនាងនឹងធ្វើការងារនេះដាច់ថ្លៃឲ្យអ្នកដទៃ រហូតទៅឬ ឬចង់ផុតចាកភាពដាច់ថ្លៃនេះ ពួកទាសីឆ្លើយថា ចង់ផុតថ្ងៃនេះឯង នាងម្ចាស់ ។ ទើបនាងពោលថា បើដូច្នោះ ស្អែកនេះ ខ្ញុំនិមន្តព្រះបច្ចេកពុទ្ធទាំង ៥ អង្គ ដែលមិនបានហត្ថកម្មមកឆាន់ ចូរពួកនាងឲ្យស្វាមី

របស់ពួកនាង ធ្វើហត្ថកម្មត្រឹមមួយថ្ងៃចុះ ។ ពួកនាងទាំងនោះក៏ទទួលថា បាន ហើយក៏ប្រាប់ដល់ស្វាមី ក្នុងវេលាដែលមកអំពីព្រៃក្នុងវេលាល្ងាច ។

ពួកគេក៏ទទួលយល់ព្រម ហើយនាំគ្នាទៅប្រជុំត្រង់ទ្វារផ្ទះរបស់ប្រធានទាសៈ ។ លំដាប់នោះ នាងប្រធានទាសីពោលនឹងពួកជនទាំងនោះថា បាទាំងឡាយ ស្អែកនេះ សូមឲ្យពួកបាឲ្យនូវហត្ថកម្មដល់ព្រះបច្ចេកពុទ្ធទាំងឡាយចុះ ហើយក៏ប្រាប់អានិសង្ស ទូន្មានហើយ លើកទឹកចិត្តអ្នកដែលមិនចង់ធ្វើ ដោយឱវាទដ៏ធ្ងន់ ។ ស្អែកឡើង នាងបានថ្វាយអាហារដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ហើយឲ្យសញ្ញាដល់ពួកកូនទាសៈគ្រប់គ្នា ។ រំពេចនោះ ពួកកូនទាសៈទាំងនោះក៏ចូលព្រៃ ប្រមូលទព្វសម្ភារៈរាប់រយ សាងកុដិម្នាក់មួយខ្នងៗ មានបរិវារ គឺទីចង្ក្រមជាដើម មួយខ្នងមួយកន្លែងៗ ដាក់គ្រែ តាំង ទឹកផឹក និងភាជនៈសម្រាប់ដាក់របស់ដែលត្រូវឆាន់ជាដើម អារាធនាសូមឲ្យព្រះបច្ចេកពុទ្ធធ្វើបដិញ្ញាដើម្បីប្រយោជន៍នៅក្នុងកុដិនោះអស់កាល ៣ ខែ ហើយដាក់វេនប្រគេនចង្ហាន់ ។ ក្នុងវេនអ្នកដែលក្រជាងគេ ប្រធានទាសីក៏បញ្ជូនយកអំពីផ្ទះខ្លួនឯង មកប្រគេនជំនួសបុគ្គលនោះ ។ កាលនាងប្រធានទាសីប្រណិប័តន៍អស់កាល ៣ ខែយ៉ាងនេះហើយ ក៏ឲ្យទាសៈម្នាក់លះសំពត់ មួយផ្ទាំងៗ បានសំពត់សាច់គ្រោតគ្រាត ៥០០ ផ្ទាំង ឲ្យធ្វើសំពត់ទាំងនោះជាត្រៃចីវរថ្វាយព្រះបច្ចេកពុទ្ធទាំង ៥ អង្គ ។ ព្រះបច្ចេកពុទ្ធទាំងឡាយចៀសចេញទៅតាមសប្បាយ ។ អ្នកធ្វើការដោយកម្លាំងស្មូងទាំង ១០០០ នាក់នោះ បានធ្វើកុសលមកជាមួយគ្នា ស្លាប់ហើយ កើតក្នុងទេវលោក ។ មេផ្ទះទាំង ៥០០

នាក់នោះ ជួនកាលក៏ជាកិរិយារបស់បុរសទាំង ៥០០ នាក់នោះ ជួនកាលអ្នកទាំងអស់នោះ ក៏ជាកិរិយារបស់កូនទាសៈដែលជាប្រធានប៉ុណ្ណោះ ។ តមកក្នុងគ្រាមួយ កូនប្រធានទាសៈចុតិអំពីទេវលោក មកកើតក្នុងរាជត្រកូលសូម្បីទេវកញ្ញាទាំង ៥០០ នោះ ក៏មកកើតក្នុងត្រកូលអ្នកមានសម្បត្តិច្រើនកាលព្រះរាជបុត្រនោះបានសោយរាជ្យ ក៏ទៅកាន់ព្រះរាជវាំងជាស្រីស្នំ ។ ពួកនាងអន្ទោលទៅដោយទំនងនេះ ក្នុងកាលនៃព្រះមានព្រះភាគមកកើតក្នុងត្រកូលក្សត្រកោលិយនគរខ្លះ ក្នុងទេវទហនគរខ្លះ ។

ព្រះនន្ទកៈសោត កាលបួសហើយ ក៏បានសម្រេចជាព្រះអរហន្ត ។ កូនក្រមុំប្រធានទាសីចម្រើនវ័យហើយ ក៏តាំងនៅក្នុងតំណែងអគ្គមហេសីរបស់ព្រះបាទសុទ្ធោទនមហារាជ ។ សូម្បីស្រីក្រៅអំពីនេះ ក៏ទៅកាន់វាំងរបស់ព្រះរាជបុត្រទាំងនោះ ។ ព្រះរាជា ៥០០ អង្គ ដែលជាព្រះស្វាមីរបស់ព្រះនាងទាំងនោះ បានស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ព្រោះការឈ្លោះដណ្តើមទឹក ហើយក៏ព្រះផ្នួស ។ ពួកអគ្គមហេសីក៏ទ្រង់បញ្ជូនសាសន៍ ដើម្បីឲ្យព្រះស្វាមីទាំងនោះអផ្សុក ។ ព្រះមានព្រះភាគ ទ្រង់នាំពួកភិក្ខុចង់សឹកទាំងនោះទៅកាន់ស្រះតាវោ ហើយទ្រង់ឲ្យតាំងនៅក្នុងសោតាបត្តិផល ក្នុងថ្ងៃប្រជុំធំ ( ថ្ងៃសម្តែងមហាសមយសូត្រ ) ក៏ទ្រង់ឲ្យតាំងនៅក្នុងភាពជាព្រះអរហន្ត ។ សូម្បីស្រីទាំង ៥០០ អង្គនោះ ក៏នាំគ្នាចេញទៅបួសក្នុងសម្នាក់ព្រះនាងមហាបជាបតិ ។

គប្បីសម្តែងរឿងនេះយ៉ាងនេះថា ប្រធានទាសៈ គឺព្រះនន្ទកៈ ទាសីទាំង

នេះឯង គឺកិក្ខុនីទាំងនោះដូច្នេះ ។ បទថា **រាជការាមោ** បានដល់ អារាម ដែលព្រះបាទបសេនទិកោសល ទ្រង់សាងទុកក្នុងទីកន្លែងដូចគ្នានឹងថូបារាម ក្នុងចំណែកទិសខាងត្បូងនៃព្រះនគរ ។

[ ២៤៥ ] បទថា **សម្មប្បញ្ញាយ សុទិដ្ឋំ** គឺដែលឃើញតាមហេតុ តាមការណ៍ដោយវិបស្សនាបញ្ញា គឺតាមការពិត ។

[ ២៤៨ ] បទថា **តជ្ជំ តជ្ជំ** គឺមានបច្ច័យនោះជាខ្លួនពិត មានបច្ច័យ នោះជាសភាវៈ ។ មានពាក្យអធិប្បាយថា ឯវេទនានោះៗ ព្រោះអាស្រ័យ បច្ច័យនោះៗ ទើបកើតឡើង ។

[ ២៤៩ ] បទថា **បគេវស្ស ឆាយា** សេចក្តីថា ការកើតឡើងព្រោះ អាស្រ័យឫសគល់ជាដើមក៏មិនទៀង តាំងអំពីដំបូងនោះឯង ។

[ ២៥១ ] បទថា **អនុបហច្ច** គឺមិនចូលទៅប្រហារ បុគ្គលធ្វើសាច់ឲ្យ ឃើញដុំៗ ហើយបកស្បែកសំយុងចុះមក ឈ្មោះថា រមែងចូលទៅកម្ចាត់ កាយ គឺសាច់ ក្នុងពាក្យថា មិនចូលទៅកម្ចាត់នោះ បុគ្គលធ្វើឲ្យស្បែកជាប់ គ្នាជាផ្ទាំង ហើយពន្ធះឲ្យសាច់ទាំងឡាយសំយុងចុះមក ឈ្មោះថា រមែងចូល ទៅកម្ចាត់កាយ គឺស្បែក មិនធ្វើយ៉ាងនោះ ។ បទថា **វិលិមំសនហារុ ពន្ធនំ** បានដល់ សាច់យាវ ដែលជាប់ត្រង់ស្បែកទាំងអស់នោះឯង លោកសំដៅ យកកិលេសក្នុងចន្លោះគ្រប់យ៉ាងនោះឯងថា មានគ្រឿងចង គឺកិលេស សំយោជនៈក្នុងចន្លោះ ដូច្នេះ ។

សួរថា ហេតុអ្វី ទើបលោកពោលពាក្យថា ទាំង ៧ យ៉ាងនេះឯង ។

ឆ្លើយថា ព្រោះបញ្ញាណាដែលលោកពោលថា បញ្ញានេះ រមែងកាត់កិលេសទាំងឡាយបាន បញ្ញានោះ ជាបញ្ញាធម្មតាៗ មិនអាចកាត់បានឡើយ ។ ឧបមាដូចពូថៅ ដោយធម្មតារបស់ខ្លួន មិនអាចកាត់បានឡើយ លុះណាអាស្រ័យសេចក្តីព្យាយាម ដែលកើតអំពីខ្លួនរបស់បុរសនោះហើយ ទើបនឹងកាត់បានយ៉ាងណា វៀរចាកពោជ្ឈង្គ ៦ ទៀតហើយ បញ្ញាមិនអាចកាត់កិលេសទាំង-ឡាយបានដូច្នោះដូចគ្នា ។ ព្រោះដូច្នោះ ទើបលោកពោលយ៉ាងនោះ ។ ពាក្យថា **តេន ហិ** សេចក្តីថា លោកសម្តែងអាយតនៈខាងក្នុង ៦ អាយតនៈខាងក្រៅ ៦ គំនរវិញ្ញាណ ៦ ការប្រៀបធៀបប្រទីប ប្រៀបធៀបដើមឈើ និងប្រៀបធៀបគោ ហើយបញ្ចប់ទេសនា ដោយការអស់ទៅនៃអាសវៈដោយពោជ្ឈង្គ ៧ យ៉ាង ព្រោះហេតុណា ព្រោះហេតុនោះ សូម្បីស្អែកនេះ លោកក៏គប្បីទូន្មានពួកភិក្ខុនីទាំងនោះ ដោយឱវាទនោះឯង ។

[ ២៦៩ ] បទថា **សា សោតាបន្នា** សេចក្តីថា ភិក្ខុនីដែលទាបជាងគេទាំងអស់ដោយគុណ ក៏ជាសោតាបន្ន ដ៏សេសក៏ជាសកទាគាមី អនាគាមី និងព្រះខីណាស្រព ។ សួរថា បើដូច្នោះ នឹងមានការត្រិះរិះបរិបូណ៌បានដូចម្តេច ។ ឆ្លើយថា នឹងមានការត្រិះរិះបរិបូណ៌បាន ដោយការបរិបូណ៌នៃអធ្យាស្រ័យ ។ ពិតហើយ ភិក្ខុនីរូបណាមានការគិតយ៉ាងនេះថា អន្កាលណាហ្ន៎ អញកំពុងស្តាប់ធម្មទេសនារបស់លោកម្ចាស់នន្ទកៈ គប្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលក្នុងអាសនៈនោះឯង ។ ភិក្ខុនីទាំងនោះ ក៏បានធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ ភិក្ខុនីរូបណាមានការគិតថា សកទាគាមិផល

*អនាគាមិផល អរហត្តផល ភិក្ខុនីរូបនោះ ក៏ធ្វើភាពជាព្រះអរហន្តឲ្យជាក់ច្បាស់ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ជាអ្នកត្រេកអរ និងមានតម្រិះបរិបូណ៌ហើយ ដូច្នេះ ៕៚*

**អដ្ឋកថា ឆន្នោវាទសូត្រ ចប់**

**សូត្រទី ៤ ចប់**

# សុត្តន្តបិដក

## ចូឡរាហុលោវាទសូត្រទី ៩

[ ២៧០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងទីស្ងាត់ ពួនសម្ងំ ( ក្នុងផលសមាបត្តិ ) ក៏មានព្រះតម្រិះក្នុងព្រះហឫទ័យកើតឡើងយ៉ាងនេះថា ធម៌ទាំងឡាយសម្រាប់ធ្វើវិមុត្តិឲ្យចាស់ក្លារបស់រាហុល ចាស់ក្លាហើយ បើដូច្នោះ គួរតែតថាគតទូន្មានរាហុល ក្នុងការអស់ទៅនៃអាសវៈទាំងឡាយតទៅទៀត ។

[ ២៧១ ] គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរ ក្នុងវេលាព្រឹកព្រហាម ស្តេចចូលទៅកាន់ក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ។ លុះព្រះអង្គស្តេចទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថីហើយ ត្រឡប់មកអំពីបិណ្ឌបាត ក្នុងកាលជាខាងក្រោយនៃភត្តវិញ ទ្រង់ត្រាស់ហៅព្រះរាហុលមានអាយុថា ម្នាលរាហុល ចូរអ្នកកាន់យកសំពត់និសីទនៈ យើងនឹងចូលទៅឯអន្ធវ័ន ( ព្រៃជាទីនៅនៃចោរខ្វាក់ ) ដើម្បីសម្រាកក្នុងវេលាថ្ងៃ ។ ព្រះរាហុលមានអាយុ ទទួលតបព្រះពុទ្ធដីកា នៃព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ហើយក៏កាន់យកសំពត់និសីទនៈ ដើរតាមក្រោយៗ ព្រះមានព្រះភាគទៅ ។ សម័យនោះឯង ទេវតាច្រើនពាន់ទៅតាមព្រះមានព្រះភាគ ដោយគិតថា ថ្ងៃនេះ ព្រះមានព្រះភាគនឹងទូន្មានព្រះរាហុលមានអាយុ ក្នុងការអស់ទៅនៃអាសវៈទាំងឡាយតទៅទៀត ។ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅ

ដល់អន្ធវ័ន ហើយគង់លើអាសនៈ ដែលគេក្រាលថ្វាយ ទៀបគល់ឈើមួយដើម ។ ចំណែកព្រះរាហុលមានអាយុ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់ក្នុងទីសមគួរ ។

[ ២៧២ ] លុះព្រះរាហុលមានអាយុ គង់នៅក្នុងទីសមគួរហើយ ទើបព្រះមានព្រះភាគត្រាស់សួរដូច្នេះថា ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច ចក្ខុ ទៀង ឬមិនទៀង ។ ព្រះរាហុលមានអាយុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[ ២៧៣ ] ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច រូបទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[ ២៧៤ ] ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច ចក្ខុវិញ្ញាណទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិន

ទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[ ២៧៥ ] ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច ចក្ខុសម្ផស្ស ទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះ ជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[ ២៧៦ ] ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច ធម្មជាតណា គឺវេទនា សញ្ញា សង្ខារ វិញ្ញាណ កើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ធម្មជាតនោះ តើទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[ ២៧៧ ] ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច ត្រចៀក

ទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។បេ។ ប្រមុះទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។បេ។ អណ្តាត ទៀង ឬ មិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។បេ។ កាយ ទៀង ឬ មិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។បេ។

[ ២៧៨ ] ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច ចិត្ត ទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណា មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញរបស់ នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះ អង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[ ២៧៩ ] ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច ធម្មា-រម្មណ៍ ទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះ របស់ណាមិនទៀង របស់នោះ ជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរ នឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[ ២៨០ ] ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច មនោ-វិញ្ញាណ ទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះ របស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជា

ទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[ ២៨១ ] ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច មនោសម្ផស្ស ទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[ ២៨២ ] ម្នាលរាហុល អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច ធម្មជាតណា គឺវេទនា សញ្ញា សង្ខារ វិញ្ញាណ តែងកើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ ធម្មជាតនោះ តើទៀង ឬមិនទៀង ។ បពិត្រព្រះអង្គដ៏ចម្រើន មិនទៀងទេ ។ ចុះរបស់ណាមិនទៀង របស់នោះជាទុក្ខ ឬជាសុខ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាទុក្ខ ។ ចុះរបស់ណាមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា តើគួរនឹងយល់ឃើញនូវរបស់នោះថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ដូច្នេះដែរឬ ។ បពិត្រព្រះអង្គដ៏ចម្រើន មិនគួរនឹងយល់ឃើញយ៉ាងនោះទេ ។

[ ២៨៣ ] ម្នាលរាហុល អរិយសាវកដែលមានសេចក្តីចេះដឹង យល់ឃើញយ៉ាងនេះ ក៏នឿយណាយក្នុងចក្ខុផង នឿយណាយក្នុងរូបផង នឿយ

ណាយក្នុងចក្ខុវិញ្ញាណផង នឿយណាយក្នុងចក្ខុសម្ផស្សផង នឿយណាយក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យផង ។ នឿយណាយក្នុងត្រចៀកផង នឿយណាយក្នុងសំឡេងផង ... នឿយណាយក្នុងច្រមុះផង នឿយណាយក្នុងក្លិនផង ... នឿយណាយក្នុងអណ្ដាតផង នឿយណាយក្នុងរសផង ... នឿយណាយក្នុងកាយផង ... នឿយណាយក្នុងផោដ្ឋព្វៈផង ... នឿយណាយក្នុងចិត្តផង នឿយណាយក្នុងធម្មារម្មណ៍ផង នឿយណាយក្នុងមនោវិញ្ញាណផង នឿយណាយក្នុងមនោ-សម្ផស្សផង នឿយណាយក្នុងវេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលកើតឡើងព្រោះមនោសម្ផស្សជាបច្ច័យផង ។ កាលអរិយសាវក នឿយណាយ ( យ៉ាងនេះ ) ហើយ ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ ( ចាកអាសវៈ ) ព្រោះប្រាសចាកតម្រេក កាលបើចិត្តផុតស្រឡះហើយ ប្រាជ្ញាក៏កើតឡើងថា ចិត្តផុតស្រឡះហើយ អរិយសាវកនោះ ក៏ដឹងច្បាស់ដូច្នេះថា ជាតិ ( របស់អាត្មាអញ ) អស់ហើយ ព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ កិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។

[ ២៨៤ ] លុះព្រះមានព្រះភាគ ទ្រង់សម្ដែងនូវព្រះសូត្រនេះចប់ហើយ ព្រះរាហុលមានអាយុ ក៏មានសេចក្ដីត្រេកអរនឹងភាសិតនៃព្រះមានព្រះភាគ ។ កាលដែលព្រះមានព្រះភាគ ទ្រង់សម្ដែងនូវវេយ្យាករណ៍នេះចប់ហើយ ចិត្តរបស់រាហុលមានអាយុ ក៏បានរួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិន

ប្រកាន់មាំ ( ថាអញ ថាយើង ) ទៀតឡើយ ។ ធម្មចក្ខុ ( ភ្នែកឃើញធម៌ ) ដ៏ប្រាសចាកធូលី គឺរាគាទិក្កិលេស ប្រាសចាកមន្ទិល គឺអកុសល បានកើតឡើងហើយ ដល់ពួកទេវតាច្រើនពាន់ទាំងនោះថា ធម្មជាតណាមួយ មានកិរិយាកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ មានកិរិយារលត់ទៅវិញជាធម្មតា ។

## ចូឡរាហុលោវាទសូត្រទី ៥ ចប់

# អដ្ឋកថា

## ពាហុលោវាទសូត្រ

[ ២៧០ ] ពាហុលោវាទសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងព្រះសូត្រនោះ បទថា **វិមុត្តិបរិបាចនីយា** មានវិគ្គហៈថា ឈ្មោះថា បទវិមុត្តិ ក៏ព្រោះធ្វើវិមុត្តិឲ្យទុំ ។ បទថា **ធម្មា** បានដល់ ធម៌ ១៥ យ៉ាង ។ ធម៌ទាំងនោះ គប្បីជ្រាបដោយអំណាចនៃការបរិសុទ្ធិនៃឥន្ទ្រិយមានសទ្ធាជាដើម ។ សមដូចលោកពោលនៅក្នុងបដិសម្ភិទាមគ្គថា

សទ្ធិន្ទ្រិយបរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលឥតសទ្ធា ១ សេពគប់ គប់រក ចូលទៅអង្គុយជិត បុគ្គលដែលមានសទ្ធា ១ ពិចារណាព្រះសូត្រដែលជាទីជ្រះថ្លា១ ។

វីរិយិន្ទ្រិយបរិសុទ្ធិដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលខ្ជិលច្រអូស ១ សេពគប់ គប់រក ចូលទៅអង្គុយជិត បុគ្គលដែលមានសេចក្តីព្យាយាម ១ ពិចារណាសម្មប្បធាន ១ ។

សតិន្ទ្រិយបរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលភ្លេចស្មារតី ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គល ដែលមានស្មារតីតម្កល់មាំ ១ ពិចារណាសតិប្បដ្ឋាន ១ ។

សមាធិន្ទ្រិយបរិសុទ្ធដោយអាការ ៣ នេះ គឺបុគ្គលវៀរបុគ្គល ដែលមានចិត្តមិននឹងធឹង ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គល ដែលមានចិត្តនឹងធឹង ១ ពិចារណាឈាន និងវិមោក្ខ ១ បញ្ញិន្ទ្រិយបរិសុទ្ធ ដោយ

អាការ ៣ នេះ គឺបុគ្គលវៀរបុគ្គលដែលអាប់ឥតបញ្ញា ១ សេពគប់ គប់រក ចូលទៅអង្គុយជិតបុគ្គល ដែលមានបញ្ញា ១ ពិចារណានូវញាណចរិយាដ៏ជ្រៅ ១ ។

កាលវៀរបុគ្គល ៥ ពួក សេពគប់ ចូលទៅអង្គុយជិតបុគ្គល ៥ ពួក ពិចារណាសូត្រទាំង ៥ នេះ ដូចពោលមកនេះ ដោយអាការ ១៥ យ៉ាងនេះ ឥន្ទ្រិយទាំង ៥ ក៏រមែងបរិសុទ្ធ ។ នៅមានធម៌សម្រាប់បន្ទុំវិមុត្តិ ១៥ យ៉ាង គឺឥន្ទ្រិយ៥ មានសទ្ធិន្ទ្រិយជាដើម និព្វេធភាគិយសញ្ញា គឺការសម្គាល់ដែលជាចំណែកនៃការចាក់ធ្លុះ ៥ យ៉ាង គឺការសម្គាល់ថាមិនទៀង ការសម្គាល់ជាទុក្ខ ក្នុងវត្ថុដែលមិនទៀង ការសម្គាល់ថា មិនមែនតួខ្លួន ក្នុងវត្ថុដែលជាទុក្ខ ការសម្គាល់ក្នុងការលះ ការសម្គាល់ក្នុងវិរាគៈ និងធម៌ ៥ យ៉ាងទៀត មានកល្យាណមិត្តជាដើម ដែលត្រាស់ដល់ព្រះមេឃិយត្ថេរ ។

សួរថា ព្រះមានព្រះភាគទ្រង់មានព្រះតម្រិះយ៉ាងនេះ ក្នុងពេលណា ។ ឆ្លើយថា កាលព្រះអង្គទ្រង់ប្រមើលមើលលោកក្នុងសម័យជិតភ្លឺ ទ្រង់ក៏មានព្រះតម្រិះយ៉ាងនេះ ។

[ ២៧១ ] បទថា **អនេកានំ ទេវតាសហស្សានំ** សេចក្តីថា ព្រះរាហុលតាំងនូវសេចក្តីប្រាថ្នា ទៀបបាទមូលរបស់ព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ ក្នុងកាលនៅជាស្តេចនាគ ឈ្មោះបាលិត មួយអន្លើនឹងទេវតាដែលតាំងទុកនូវសេចក្តីប្រាថ្នាដូចគ្នា ។ បណ្តាទេវតាទាំងនោះ ពួកខ្លះជាទេវតានៅលើផែនដី ពួកខ្លះ នៅលើអាកាស ។ ពួកខ្លះ ក៏នៅក្នុងចាតុម្មហារាជិកា ។

ពួកខ្លះ ក៏នៅក្នុងទេវលោក ពួកខ្លះ ក៏កើតក្នុងព្រហ្មលោក ។ តែក្នុងថ្ងៃនេះ ទេវតាទាំងអស់មកប្រជុំគ្នា ក្នុងព្រៃអន្ធវ័ននោះឯង ក្នុងទីតែមួយ ។

[ ២៨៤ ] បទថា **ធម្មចក្ខុំ** សេចក្ដីថា បឋមមគ្គ គឺសោតា លោកហៅថា **ធម្មចក្ខុ** ក្នុងឧបាលិវាទសូត្រ និងទីឃនខសូត្រ ។ ផលទាំង ៣ លោកហៅថា **ធម្មចក្ខុ** ក្នុងព្រហ្មាយុសូត្រ តែក្នុងសូត្រនេះ មគ្គ ៤ ផល ៤ គប្បីជ្រាបថាជា **ធម្មចក្ខុ** ។ បណ្ដាទេវតាទាំងនោះ ទេវតាពួកខ្លះបានជាព្រះសោតាបន្ន ពួកខ្លះបានជាព្រះសកទាគាមី ពួកខ្លះក៏ជាព្រះអនាគាមី ពួកខ្លះក៏ជាព្រះខីណាស្រព ឯការកំណត់ដោយការរាប់ចំនួនទេវតាទាំងនោះថាប៉ុណ្ណេះ ប៉ុណ្ណោះមិនមាន ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ ងាយយល់ហើយ ៕

## អដ្ឋកថា រាហុលោវាទសូត្រ ចប់

## សូត្រទី ៥ ចប់

# សុត្តន្តបិដក

## ឆឆក្កសូត្រទី ៦

[ ២៨៥ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ កាល ព្រះមានព្រះភាគ គង់នៅក្នុងវត្តនោះ បានត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាល ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំង-ឡាយ តថាគតនឹងសម្តែងធម៌ មានលម្អបទដើម មានលម្អបទកណ្តាល មាន លម្អបទចុង ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏ បរិសុទ្ធ បរិបូណ៌ទាំងអស់ ចំពោះអ្នកទាំងឡាយ ចូរអ្នកទាំងឡាយ ស្តាប់នូវ ធម៌ដែលមានចំនួន ៦ ឆក្កៈ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹង សម្តែង ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ២៨៦ ] ព្រះមានព្រះភាគ បានត្រាស់ដូច្នេះថា អាយតនៈខាងក្នុង ៦ ក៏គួរដឹង អាយតនៈខាងក្រៅ ៦ ក៏គួរដឹង វិញ្ញាណកាយ ( ពួកវិញ្ញាណ ) ៦ ក៏គួរដឹង ផស្សកាយ ( ពួកផស្សៈ ) ៦ ក៏គួរដឹង វេទនាកាយ ( ពួក វេទនា ) ៦ ក៏គួរដឹង តណ្ហាកាយ ( ពួកតណ្ហា ) ៦ ក៏គួរដឹង ។

[ ២៨៧ ] ឯពាក្យថា អាយតនៈខាងក្នុង ៦ ក៏គួរដឹងដូច្នេះនុ៎ះ តថាគត បានពោលហើយ ។ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យ

សេចក្តីដូចម្តេច ។ ចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ មនាយតនៈ ១ ។ ពាក្យណាដែលតថាគតពោលហើយថា អាយតនៈខាងក្នុង ៦ ក៏គួរដឹងដូច្នេះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។ នេះឆក្កៈទី ១ ។

[ ២៨៨ ] ពាក្យថា អាយតនៈខាងក្រៅ ៦ ក៏គួរដឹងដូច្នេះនុ៎ះ តថាគតបានពោលហើយ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្តីដូចម្តេច ។ រូបាយតនៈ ១ សទ្ទាយតនៈ ១ គន្ធាយតនៈ ១ រសាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ ធម្មាយតនៈ ១ ។ ពាក្យណាដែលតថាគតពោលហើយថា អាយតនៈខាងក្រៅ ៦ ក៏គួរដឹងដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។ នេះឆក្កៈទី ២ ។

[ ២៨៩ ] ពាក្យថា វិញ្ញាណកាយ ៦ ក៏គួរដឹងដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យភ្នែក និងរូប ១ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀក និងសំឡេង ១ ឃានវិញ្ញាណកើតឡើង ព្រោះអាស្រ័យច្រមុះ និងក្លិន ១ ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាត និងរស ១ កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយ និងផោដ្ឋព្វៈ ១ មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្ត និងធម្មារម្មណ៍ ។ ពាក្យណាដែលតថាគតពោលហើយថា វិញ្ញាណកាយ ៦ ក៏គួរដឹងដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

នេះឆក្កៈទី ៣ ។

[ ២៩០ ] ពាក្យថា ផស្សកាយ ៦ ក៏គួរដឹងដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ ចក្ខុវិញ្ញាណកើតឡើងព្រោះអាស្រ័យភ្នែក និងរូប ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ១ ។ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀក និងសំឡេង ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ១ ។ ឃានវិញ្ញាណកើតឡើង ព្រោះអាស្រ័យច្រមុះ និងក្លិន ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ១ ។ ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្ដាត និងរស ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ១ ។ កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយ និងផោដ្ឋព្វៈ ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ១ ។ មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្ត និងធម្មារម្មណ៍ ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ១ ពាក្យណាដែលតថាគតពោលហើយថា ផស្សកាយ ៦ ក៏គួរដឹងដូច្នេះ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យសេចក្ដីនេះឯង ។ នេះឆក្កៈទី ៤ ។

[ ២៩១ ] ពាក្យថា វេទនាកាយ ៦ ក៏គួរដឹងដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្ដីដូចម្ដេច ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យភ្នែក និងរូប ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ១ ។ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀក និងសំឡេង ...

ឃានវិញ្ញាណកើតឡើង ព្រោះអាស្រ័យច្រមុះ និងក្លិន ... ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាត និងរស ... កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយ និងផោដ្ឋព្វៈ ... មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្ត និងធម្មារម្មណ៍ ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ១ ។ ពាក្យណាដែលតថាគតពោលហើយថា វេទនាកាយ ៦ ក៏គួរដឹងដូច្នេះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។ នេះឆក្កៈទី ៥ ។

[ ២៩២ ] ពាក្យថា តណ្ហាកាយ ៦ ក៏គួរដឹងដូច្នេះនុ៎ះ តថាគតបានពោលហើយ ។ ចុះពាក្យដែលតថាគតពោលហើយនុ៎ះ តើព្រោះអាស្រ័យសេចក្តីដូចម្តេច ។ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យភ្នែក និងរូប ការជួបជុំនៃរបស់ទាំង៣ ហៅថា ផស្សៈ ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហា ១ ។ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀក និងសំឡេង ... ឃានវិញ្ញាណកើតឡើង ព្រោះអាស្រ័យច្រមុះ និងក្លិន ... ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាត និងរស ... កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយ និងផោដ្ឋព្វៈ ... មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្ត និងធម្មារម្មណ៍ ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ ព្រោះផស្សៈជាបច្ច័យ ទើបមានវេទនា ព្រោះវេទនាជាបច្ច័យ ទើបមានតណ្ហា ១ ។ ពាក្យណាដែលតថាគតពោលហើយថា តណ្ហាកាយ ៦ ក៏គួរដឹងដូច្នេះ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យសេចក្តីនេះឯង ។

នេះឆក្កៈទី ៦ ។

[ ២៩៣ ] បុគ្គលណានិយាយយ៉ាងនេះថា ភ្នែកជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ( ព្រោះថា ) ភ្នែកគេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណានិយាយថា ភ្នែកជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួនឡើយ ។ បុគ្គលណានិយាយថារូបជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។ ( ព្រោះថា ) រូបគេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណានិយាយថារូបជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួន រូបក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណានិយាយថា ចក្ខុវិញ្ញាណជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ( ព្រោះថា ) ចក្ខុវិញ្ញាណគេតែដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ឃើញត្រូវ ហេតុនោះ បានជាថា បុគ្គលណានិយាយថា ចក្ខុ

វិញ្ញាណជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួន រូបមិនមែនជាខ្លួន ចក្ខុវិញ្ញាណក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណានិយាយថា ចក្ខុសម្ផស្សជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ( ព្រោះថា ) ចក្ខុសម្ផស្ស គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯងទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណានិយាយថា ចក្ខុសម្ផស្សជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួន រូបមិនមែនជាខ្លួន ចក្ខុវិញ្ញាណមិនមែនជាខ្លួន ចក្ខុសម្ផស្សក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណានិយាយថា វេទនាជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។ ( ព្រោះថា ) វេទនាគេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណា ដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯងទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះបានជាថា បុគ្គលណានិយាយថា វេទនាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួន រូបមិនមែនជាខ្លួន ចក្ខុវិញ្ញាណមិនមែនជាខ្លួន ចក្ខុសម្ផស្សមិនមែនជាខ្លួនវេទនាក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណានិយាយថាតណ្ហាជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។ ( ព្រោះថា ) តណ្ហា គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។

លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ឃើញត្រូវ ហេតុនោះ បានជាថា បុគ្គលណានិយាយថា តណ្ហាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ភ្នែកមិនមែនជាខ្លួន រូបមិនមែនជាខ្លួន ចក្ខុវិញ្ញាណមិនមែនជាខ្លួន ចក្ខុសម្ផស្សមិនមែនជាខ្លួន វេទនាមិនមែនជាខ្លួន តណ្ហាក៏មិនមែនជាខ្លួនឡើយ ។

[ ២៩៤ ] បុគ្គលណានិយាយថា ត្រចៀកជាខ្លួន ... បុគ្គលណានិយាយថា ច្រមុះជាខ្លួន ... បុគ្គលណានិយាយថា អណ្តាតជាខ្លួន ... បុគ្គលណានិយាយថា កាយជាខ្លួន ... បុគ្គលណានិយាយថា ចិត្តជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។ ( ព្រោះថា ) ចិត្ត គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ត្រូវ ហេតុនោះ បានជាថា បុគ្គលណានិយាយថា ចិត្តជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្តមិនមែនជាខ្លួនឡើយ ។ បុគ្គលណានិយាយថា ធម្មារម្មណ៍ជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ( ព្រោះថា ) ធម្មារម្មណ៍គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញ កើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់

ឃើញត្រូវ ហេតុនោះ បានជាថា បុគ្គលណានិយាយថា ធម្មារម្មណ៍ជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្តមិនមែនជាខ្លួន ធម្មារម្មណ៍ក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណា និយាយថា មនោវិញ្ញាណជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ( ព្រោះថា ) មនោវិញ្ញាណ គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថាយល់ឃើញត្រូវ ហេតុនោះ បានជាថា បុគ្គលណានិយាយថា មនោវិញ្ញាណជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្តមិនមែនជាខ្លួន ធម្មារម្មណ៍មិនមែនជាខ្លួន មនោវិញ្ញាណក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណា និយាយថាមនោសម្ផស្សជាខ្លួន ពាក្យរបស់បុគ្គលនោះមិនកើតការទេ ។ ( ព្រោះថា ) មនោសម្ផស្ស គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់ នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ឃើញត្រូវ ហេតុនោះ បានជាថាបុគ្គលណានិយាយថា មនោសម្ផស្សជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្តមិនមែនជាខ្លួន ធម្មារម្មណ៍មិនមែនជាខ្លួន មនោវិញ្ញាណមិនមែនជាខ្លួន មនោសម្ផស្សក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណានិយាយថា វេទនាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ( ព្រោះថា )

វេទនាគេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ឃើញត្រូវ ហេតុនោះ បានជាថា បុគ្គលណានិយាយថា វេទនាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្តមិនមែនជាខ្លួន ធម្មារម្មណ៍មិនមែនជាខ្លួន មនោវិញ្ញាណមិនមែនជាខ្លួន មនោសម្ផស្សមិនមែនជាខ្លួន វេទនាក៏មិនមែនជាខ្លួនឡើយ ។ បុគ្គលណានិយាយថា តណ្ហាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ( ព្រោះថា ) តណ្ហា គេតែងដឹងច្បាស់ថា មានការកើតឡើងផង ការវិនាសទៅវិញផង ។ លុះតែបុគ្គលណាដឹងច្បាស់នូវការកើតឡើង និងការវិនាសទៅវិញថា ខ្លួនរបស់អញកើតឡើងផង វិនាសទៅវិញផង បុគ្គលនោះឯង ទើបឈ្មោះថា យល់ឃើញត្រូវ ហេតុនោះ បានជាថា បុគ្គលណានិយាយថា តណ្ហាជាខ្លួន ពាក្យរបស់បុគ្គលនោះ មិនកើតការទេ ។ ព្រោះហេតុនោះ ចិត្តមិនមែនជាខ្លួន ធម្មារម្មណ៍មិនមែនជាខ្លួន មនោវិញ្ញាណមិនមែនជាខ្លួន មនោសម្ផស្សមិនមែនជាខ្លួន វេទនាមិនមែនជាខ្លួន តណ្ហាក៏មិនមែនជាខ្លួនឡើយ ។

[ ២៩៥ ] ម្នាលភិក្ខុទាំងឡាយ នេះបដិបទាជាដំណើរកើតនៃសក្កាយ ។ បុគ្គលពិចារណាឃើញចក្ខុថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញរូបថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញចក្ខុវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណា

ឃើញចក្ខុសម្ផស្សថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញវេទនាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញតណ្ហាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញត្រចៀកថា នុ៎ះរបស់អញ ... ពិចារណាឃើញច្រមុះថា នុ៎ះរបស់អញ ... ពិចារណាឃើញអណ្តាតថា នុ៎ះរបស់អញ ... ពិចារណាឃើញកាយថា នុ៎ះរបស់អញ ... ពិចារណាឃើញចិត្តថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញធម្មារម្មណ៍ថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញមនោវិញ្ញាណថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។ ពិចារណាឃើញតណ្ហាថា នុ៎ះរបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនអញ ។

[ ២៩៦ ] ម្នាលភិក្ខុទាំងឡាយ នេះបដិបទាជាដំណើរលត់ទៅនៃសក្កាយ ។ បុគ្គលពិចារណាឃើញចក្ខុថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញរូបថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញចក្ខុវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញចក្ខុសម្ផស្សថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញវេទនាថា នុ៎ះមិនមែនជារបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញតណ្ហាថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញ

ត្រចៀកថា នុ៎ះមិនមែនរបស់អញ ... ពិចារណាឃើញច្រមុះថា នុ៎ះមិនមែនរបស់អញ ... ពិចារណាឃើញអណ្តាតថា នុ៎ះមិនមែនរបស់អញ ... ពិចារណាឃើញកាយថា នុ៎ះមិនមែនរបស់អញ ... ពិចារណាឃើញចិត្តថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញធម្មារម្មណ៍ថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញមនោវិញ្ញាណថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញមនោសម្ផស្សថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញវេទនាថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។ ពិចារណាឃើញតណ្ហាថា នុ៎ះមិនមែនរបស់អញ នុ៎ះមិនមែនជាអញ នុ៎ះមិនមែនជាខ្លួនអញ ។

[ ២៩៧ ] ម្នាលភិក្ខុទាំងឡាយ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យភ្នែក និងរូប ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ វេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី កើតឡើងព្រោះផស្សៈជាបច្ច័យ ។ បុគ្គលនោះកាលបើសុខវេទនាពាល់ត្រូវ រមែងរីករាយក្អាកក្អាយ តាំងនៅក្នុងសេចក្តីពេញចិត្ត រាគានុស័យនៃបុគ្គលនោះ ក៏ដេកសម្ងំនៅ ។ កាលបើទុក្ខវេទនាពាល់ត្រូវ រមែងក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំ ដល់នូវសេចក្តីវង្វេង បដិឃានុស័យនៃបុគ្គលនោះក៏ដេកសម្ងំនៅ ។ កាលបើអទុក្ខមសុខវេទនាពាល់ត្រូវ រមែងមិនដឹងច្បាស់តាមពិត នូវការកើតឡើង

ផង នូវសេចក្តីវិនាសទៅផង នូវអានិសង្សផង នូវទោសផង នៃវេទនានោះ និងការរលាស់ចេញនូវវេទនានោះ អវិជ្ជានុស័យនៃបុគ្គលនោះ ក៏ដេកសម្ងំនៅ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះឯង បើទុកជាមិនបាច់លះបង់នូវរាគានុស័យក្នុងសុខវេទនា មិនបាច់បន្ទោបង់នូវបដិឃានុស័យក្នុងទុក្ខវេទនា មិនបាច់គាស់រំលើង នូវអវិជ្ជានុស័យក្នុងអទុក្ខមសុខវេទនា មិនបាច់លះបង់នូវអវិជ្ជា មិនបាច់ញុំាងវិជ្ជាឲ្យកើតឡើងក៏ដោយ ក៏គង់ជាអ្នកធ្វើនូវទីបំផុតនៃទុក្ខ ក្នុងបច្ចុប្បន្ននេះបាន ពាក្យដូច្នេះនុ៎ះ មិនសមហេតុឡើយ ។ ម្នាលភិក្ខុទាំងឡាយ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀក និងសំឡេង ... ឃានវិញ្ញាណកើតឡើង ព្រោះអាស្រ័យច្រមុះ និងក្លិន ... ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាត និងរស ... កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយ និងផោដ្ឋព្វៈ ... មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្ត និងធម្មារម្មណ៍ ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ វេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី រមែងកើតឡើងព្រោះផស្សៈជាបច្ច័យ ។ បុគ្គលនោះកាលបើសុខវេទនាពាល់ត្រូវ រមែងរីករាយក្អាកក្អាយ តាំងនៅក្នុងសេចក្តីពេញចិត្ត រាគានុស័យនៃបុគ្គលនោះ ក៏ដេកសម្ងំនៅ ។ កាលទុក្ខវេទនាពាល់ត្រូវ រមែងក្រៀមក្រំចិត្ត លំបាក ខ្សឹកខ្សួល គក់ទ្រូង ទ្រហោយំដល់នូវសេចក្តីវង្វេង បដិឃានុស័យនៃបុគ្គលនោះ ក៏ដេកសម្ងំនៅ ។ កាលអទុក្ខមសុខវេទនាពាល់ត្រូវ រមែងមិនដឹងច្បាស់តាមពិត នូវការកើតឡើងផង នូវសេចក្តីវិនាសទៅផង នូវអានិសង្សផង នូវទោសផង នៃវេទនានោះ

និងការរលាស់ចេញនូវវេទនានោះ អវិជ្ជានុស័យនៃបុគ្គលនោះ ក៏ដេកសម្ងំនៅ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះឯង បើទុកជាមិនបាច់លះបង់នូវរាគានុស័យក្នុងសុខវេទនា មិនបាច់បន្ទោបង់នូវបដិឃានុស័យក្នុងទុក្ខវេទនា មិនបាច់គាស់រម្លើងនូវអវិជ្ជានុស័យក្នុងអទុក្ខមសុខវេទនា មិនបាច់លះបង់នូវអវិជ្ជា មិនបាច់ញុំាងវិជ្ជាឲ្យកើតឡើងក៏ដោយ ក៏គង់ជាអ្នកធ្វើទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ននេះបាន ពាក្យដូច្នេះនុ៎ះ មិនសមហេតុឡើយ ។

[ ២៩៨ ] ម្នាលភិក្ខុទាំងឡាយ ចក្ខុវិញ្ញាណកើតឡើង ព្រោះអាស្រ័យភ្នែក និងរូប ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ វេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី រមែងកើតឡើង ព្រោះផស្សៈជាបច្ច័យ ។ បុគ្គលនោះកាលបើសុខវេទនាពាល់ត្រូវ រមែងមិនរីករាយ មិនក្អាកក្អាយ មិនតាំងនៅក្នុងសេចក្តីពេញចិត្តទេ រាគានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។ កាលទុក្ខវេទនាពាល់ត្រូវ រមែងមិនក្រៀមក្រំចិត្ត មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងទ្រហោយំ មិនដល់នូវសេចក្តីវង្វេងទេ បដិឃានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។ កាលអទុក្ខមសុខវេទនាពាល់ត្រូវ រមែងដឹងច្បាស់តាមពិត នូវការកើតឡើងផង នូវសេចក្តីវិនាសទៅផង នូវអានិសង្សផង នូវទោសផងនៃវេទនានោះ និងការរលាស់ចេញនូវវេទនានោះ អវិជ្ជានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះឯង លះបង់នូវរាគានុស័យក្នុងសុខវេទនា បន្ទោបង់នូវបដិឃានុ-ស័យក្នុងទុក្ខវេទនា គាស់រម្លើងនូវអវិជ្ជានុស័យក្នុងអទុក្ខមសុខវេទនា លះបង់

នូវអវិជ្ជា ញ៉ាំងវិជ្ជាឲ្យកើតឡើងហើយ និងជាអ្នកធ្វើទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ន នេះបាន ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ។ ម្នាលភិក្ខុទាំងឡាយ សោតវិញ្ញាណកើតឡើង ព្រោះអាស្រ័យត្រចៀក និងសំឡេង ... ម្នាលភិក្ខុទាំងឡាយ ឃានវិញ្ញាណកើតឡើង ព្រោះអាស្រ័យច្រមុះ និងក្លិន ... ម្នាលភិក្ខុទាំងឡាយ ជិវ្ហាវិញ្ញាណកើតឡើង ព្រោះអាស្រ័យអណ្តាត និងរស ... ម្នាលភិក្ខុទាំងឡាយ កាយវិញ្ញាណកើតឡើង ព្រោះអាស្រ័យកាយ និងផោដ្ឋព្វៈ ... ម្នាលភិក្ខុទាំងឡាយ មនោវិញ្ញាណកើតឡើង ព្រោះអាស្រ័យចិត្ត និងធម្មារម្មណ៍ ការជួបជុំនៃរបស់ទាំង ៣ ហៅថា ផស្សៈ វេទនាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី រមែងកើតឡើងព្រោះផស្សៈជាបច្ច័យ ។ បុគ្គលនោះ កាលសុខវេទនាពាល់ត្រូវ រមែងមិនរីករាយ មិនក្អាកក្អាយ មិនតាំងនៅក្នុងសេចក្តីពេញចិត្តទេ រាគានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។ កាលទុក្ខវេទនាពាល់ត្រូវរមែងមិនក្រៀមក្រំចិត្ត មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងទ្រហោយំ មិនដល់នូវសេចក្តីវង្វេងទេ បដិឃានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។ កាលអទុក្ខមសុខវេទនាពាល់ត្រូវ តែងដឹងច្បាស់តាមពិត នូវការកើតឡើងផង នូវសេចក្តីវិនាសទៅផង នូវអានិសង្សផង នូវទោសផង នៃវេទនានោះ និងការរលាស់ចេញនូវវេទនានោះ អវិជ្ជានុស័យនៃបុគ្គលនោះ ក៏មិនដេកសម្ងំនៅឡើយ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលនោះឯងលះបង់នូវរាគានុស័យ ក្នុងសុខវេទនា បន្ទោបង់នូវបដិឃានុស័យក្នុងទុក្ខវេទនា គាស់រម្លើងនូវអវិជ្ជានុស័យ ក្នុងអទុក្ខមសុខ-

វេទនា លះបង់នូវអវិជ្ជា ញ៉ាំងវិជ្ជាឲ្យកើតឡើងហើយ និងជាអ្នកធ្វើទីបំផុតនៃទុក្ខក្នុងបច្ចុប្បន្ននេះបាន ពាក្យដូច្នេះនុ៎ះ ទើបសមហេតុ ។

[ ២៩៩ ] ម្នាលភិក្ខុទាំងឡាយ អរិយសាវកដែលមានសេចក្តីចេះដឹងកាលយល់ឃើញយ៉ាងនេះ ក៏នឿយណាយក្នុងភ្នែកផង នឿយណាយក្នុងរូបផង នឿយណាយក្នុងចក្ខុវិញ្ញាណផង នឿយណាយក្នុងចក្ខុសម្ផស្សផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងតណ្ហាផង នឿយណាយក្នុងត្រចៀកផង នឿយណាយក្នុងសំឡេងផង ... នឿយណាយក្នុងច្រមុះផង នឿយណាយក្នុងក្លិនផង ... នឿយណាយក្នុងអណ្តាតផង នឿយណាយក្នុងរសផង ... នឿយណាយក្នុងកាយផង នឿយណាយក្នុងផោដ្ឋព្វៈផង ... នឿយណាយក្នុងចិត្តផង នឿយណាយក្នុងធម្មារម្មណ៍ផង នឿយណាយក្នុងមនោវិញ្ញាណផង នឿយណាយក្នុងមនោសម្ផស្សផង នឿយណាយក្នុងវេទនាផង នឿយណាយក្នុងតណ្ហាផង ។ កាលបើនឿយណាយហើយ ក៏ប្រាសចាកតម្រេក ចិត្តក៏ផុតស្រឡះ ( ចាកអាសវៈ ) ព្រោះការប្រាសចាកតម្រេក កាលចិត្តផុតស្រឡះហើយ ញាណក៏កើតឡើងថា ចិត្តផុតស្រឡះហើយ អរិយសាវកនោះ រមែងដឹងច្បាស់ថា ជាតិអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអាត្មាអញបានធ្វើរួចហើយ កិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ លុះព្រះមានព្រះភាគ សម្តែងព្រះសូត្រនេះចប់ហើយ ភិក្ខុទាំងនោះក៏មានសេចក្តីត្រេកអរ រីករាយ នឹងភាសិតនៃព្រះមានព្រះភាគ ។ ក៏កាល

ដែលព្រះមានព្រះភាគ សម្តែងវេយ្យាករណ៍នេះចប់ហើយ ចិត្តរបស់ភិក្ខុទាំងឡាយ ប្រមាណ ៦០ រូប ក៏រួចស្រឡះចាកអាសវៈទាំងឡាយ ព្រោះមិនបានប្រកាន់មាំទៀតឡើយ ។

## ឆឆក្កសូត្រទី ៦ ចប់

# អដ្ឋកថា

## ឆឆក្កសូត្រ

[ ២៨៥ ] ឆឆក្កសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា **អាទិកល្យាណំ** សេចក្តីថា តថាគតធ្វើឲ្យពីរោះ គឺឲ្យប្រាសចាកទោស ឲ្យល្អក្នុងខាងដើម ហើយសម្តែង ។ សូម្បីការពីរោះក្នុងកណ្តាល និងពីរោះខាងចុង ក៏មានទំនងដូចគ្នានេះ ។ ព្រះមានព្រះភាគទ្រង់សរសើរអរិយវង្សសូត្រ ៩ បទ មហាសតិប្បដ្ឋានសូត្រ ៧ បទ មហាអស្សបុរសូត្រ ៧ បទដូចគ្នា ដោយប្រការដូច្នេះ ។ សម្រាប់សូត្រនេះ ទ្រង់សរសើរដោយបទ ៩ បទ ។

[ ២៨៦ ] បទថា **វេទិតព្វានិ** គឺគប្បីជ្រាបដោយមគ្គ ព្រមទាំងវិបស្សនា ។ ចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ប៉ុណ្ណោះ ទ្រង់សម្តែងដោយមនាយតនៈ ។ ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ខាងក្រៅ ទ្រង់សម្តែងដោយធម្មាយតនៈ ។ វៀរទ្វិបញ្ចញ្ញាណ លោកិយវិបាកចិត្ត ២០ ដួងដ៏សេសទ្រង់សម្តែងដោយមនោវិញ្ញាណ ។ ផស្សៈ និងវេទនា ជាធម៌ដែលសម្បយុត្តដោយវិបាកវិញ្ញាណតាមដែលបានពោលហើយ ។ បទថា **តណ្ហា** បានដល់តណ្ហាដែលកើតក្នុងខណៈនៃជវន ដែលមានវិបាកវេទនាជាបច្ច័យ ។

[ ២៩៣ ] បទថា **ចក្ខុ អត្តា** ជាអនុសន្ធិមួយដោយចំពោះ ។ ដើម្បីសម្តែងភាពដែលសច្ចៈ ២ ដែលត្រាស់ខាងដើមថា មិនមែនជាតួខ្លួន ទើបទ្រង់ផ្តើមទេសនានេះ ។ ក្នុងបទទាំងនោះ បទថា **ន ឧបបជ្ជតិ** សំដៅដល់

មិនសមគួរ ។ បទថា **វេតិ** គឺប្រាសទៅ រលត់ទៅ ។

[ ២៩៥ ] បទថា **អយំ ខោ បន ភិក្ខវេ** គឺនេះជាអនុសន្ធិមួយដោយចំពោះ ។ ពិតហើយ ដើម្បីទ្រង់សម្តែងវដ្តៈដោយអំណាចការប្រកាន់មាំ ៣ យ៉ាង ព្រះមានព្រះភាគ ទ្រង់ផ្តើមទេសនានេះ ។ អាចារ្យខ្លះពោលថា ដើម្បីសម្តែងវដ្តៈដោយសច្ចៈ ២ គឺទុក្ខ សមុទយៈ ដូច្នេះក៏មានដូចគ្នា ។ ក្នុងបទថា **ឯតំ មម** ជាដើម គប្បីជ្រាបការប្រកាន់មាំដោយតណ្ហា មានះ និងទិដ្ឋិនោះឯង ។ បទថា **សមនុបស្សតិ** គឺរមែងឃើញដោយអំណាចការប្រកាន់មាំទាំង ៣ យ៉ាង ។

[ ២៩៦ ] កាលទ្រង់សម្តែងវដ្តៈ ៣ យ៉ាងនេះហើយ គ្រានេះ ដើម្បីទ្រង់សម្តែងវិវដ្តៈដោយអំណាចបដិបក្ខចំពោះការប្រកាន់មាំទាំង ៣ យ៉ាង ឬដើម្បីទ្រង់សម្តែងវិវដ្តៈដោយអំណាចសច្ចៈ ២ គឺនិរោធ និងមគ្គទាំងនេះ ទើបត្រាស់ថា **អយំ ខោ បន** ដូច្នេះជាដើម ។ បទថា **នេតំ មម** ជាដើម ជាពាក្យបដិសេធតណ្ហាជាដើម ។ បទថា **សមនុបស្សតិ** គឺរមែងឃើញថាជាវត្ថុមិនទៀង ជាទុក្ខ និងជាអនត្តា ។

[ ២៩៧ ] កាលទ្រង់សម្តែងវិវដ្តៈយ៉ាងនេះហើយ គ្រានេះ កាលទ្រង់សម្តែងវដ្តៈ ដោយអំណាចអនុស័យទាំង ៣ យ៉ាងទៀត ទើបត្រាស់ថា **ចក្ខុញ្ច ភិក្ខវេ** ជាដើម ។ ក្នុងបទទាំងនោះ បទថា **អភិនន្ទតិ** ជាដើម ព្រះមានព្រះភាគត្រាស់ដោយអំណាចតណ្ហា និងទិដ្ឋិប៉ុណ្ណោះ ។ បទថា **អជ្ឈោសេតិ** គឺមិនទាន់លះបាន ។ បទថា **ទុក្ខស្ស** បានដល់ នៃវដ្តទុក្ខ និងកិលេសទុក្ខ ។

[ ២៩៨ ] ទ្រង់សម្តែងវដ្ដៈដោយអំណាចអនុស័យ ៣ យ៉ាង យ៉ាងនេះហើយ គ្រានេះ កាលទ្រង់សម្តែងវិវដ្ដៈដោយអំណាចន័យដែលផ្ទុយគ្នារបស់អនុស័យទាំង ៣ យ៉ាងនោះ ទើបត្រាស់ពាក្យជាដើមថា **ចក្ខុញ្ច** ម្តងទៀត ។ បទថា **អវិជ្ជំ បហាយ** គឺលះនូវការមិនដឹង ដែលជាឫសគល់នៃវដ្ដៈបានហើយ ។ បទថា **វិជ្ជំ** គឺញុំាងវិជ្ជា គឺអរហត្តមគ្គឲ្យកើតឡើងហើយ ។

បទថា **ឋានមេតំ វិជ្ជតិ** គឺដោយកថាមគ្គមានប្រមាណប៉ុណ្ណោះឯង ក៏ទ្រង់ទេសនាដោយអំណាចវដ្ដៈ និងវិវដ្ដៈ ឲ្យដល់កំពូលបានហើយ កាលទ្រង់សង្គ្រោះព្រះធម្មទេសនានោះឯង ក៏បានត្រាស់ពាក្យជាដើមថា **ឯវំ បស្សំ ភិក្ខវេ** ម្តងទៀត ។

[ ២៩៩ ] ក្នុងបទថា **សដ្ឋិមត្តានំ ភិក្ខូនំ** គឺភិក្ខុប្រមាណ ៦០ រូបនេះមិនជាការអស្ចារ្យឡើយ កាលព្រះសាស្ដាទ្រង់សម្តែងឯងពិតៗ ភិក្ខុ ៦០ រូបបានសម្រេចជាព្រះអរហន្ត ។ ព្រោះថា កាលព្រះធម្មសេនាបតី សម្តែងសូត្រនេះ ក៏មានភិក្ខុ ៦០ រូប សម្រេចជាព្រះអរហន្ត សូម្បីព្រះមហាមោគ្គល្លានសម្តែងក្តី ព្រះមហាថេរៈ ៨០ រូបសម្តែងក្តី ក៏មានភិក្ខុ ៦០ បានសម្រេចដូចគ្នា សេចក្តីនេះក៏មិនគួរអស្ចារ្យ ។ ព្រោះសាវកទាំងនោះ ជាអ្នកសម្រេចមហាភិញ្ញាទាំងអស់ ។ សូម្បីក្នុងកាលឯក្រោយ ព្រះមាលេយ្យទេវត្ថេរក្នុងកោះលង្កា ក៏បានសម្តែងព្រះសូត្រនេះ ខាងក្រោមលោហប្រាសាទ សូម្បីកាលនោះ ក៏មានភិក្ខុ ៦០ រូបសម្រេចជាព្រះអរហន្តដែរ ។ ហើយព្រះថេរៈក៏សម្តែងព្រះសូត្រនេះ ក្នុងមហាបារាំ ដូចព្រះមាលេយ្យទេវត្ថេរសម្តែង ក្នុង

លោហប្រាសាទដូចគ្នា ។ ព្រះថេរៈកាលចេញអំពីមហាវិហារហើយ ក៏ទៅចេតិយបព៌ត ក្នុងទីនោះ លោកក៏សម្តែងដូចគ្នា ។ បន្ទាប់អំពីនោះ លោកទៅសម្តែងឯវត្តសាកិយវង្ស ត្រង់វត្តកូដាសី ត្រង់វាងបឹង ត្រង់លានមុក្កា ត្រង់ភ្នំបាតកា ត្រង់ព្រៃចីនយរកៈ ត្រង់ទីយវាបី ត្រង់ញកភ្នំលោកន្ទរ និងទីចិញ្ចឹមពព៌ៃ ។ ក្នុងទីទាំងនោះ ក៏មានភិក្ខុ ៦០ រូបៗ សម្រេចជាព្រះអរហន្តដូចគ្នា ។ កាលចេញចាកទីនោះហើយ ព្រះថេរៈក៏ទៅកាន់ចិត្តលបព៌ត ។ គ្រានោះ ត្រង់វត្តចិត្តលបព៌ត មានព្រះមហាថេរៈមានវស្សាជាង ៦០ ។ ក្បែរស្រះឈូកធំ ត្រង់កំពង់ជ្រៅ ឈ្មោះថា កំពង់កុរុវកៈ ។ ត្រង់កំពង់នោះ ព្រះថេរៈគិតថា អញនឹងងូតទឹក ទើបចុះទៅ ។ ព្រះទេវត្ថេរចូលទៅរកលោកហើយប្រាប់ថា ខ្ញុំនឹងជងទឹកស្រង់ប្រគេន លោកម្ចាស់ ។ ដោយការបដិ-សណ្ឋារៈនោះឯង ព្រះថេរៈក៏ជ្រាបបានថា ពួកមនុស្សពោលថា មានព្រះមហាថេរៈ ឈ្មោះមាលយទេវៈ ពិតជាលោកម្ចាស់អង្គនេះ ទើបសួរថា លោកម្ចាស់ឈ្មោះទេវៈឬ ។ ព្រះថេរៈពោលថា ករុណាលោកម្ចាស់ ។ មិនមានអ្នកណាយកដៃដុសរាងកាយរបស់ខ្ញុំអស់ ៦០ ឆ្នាំមកហើយ តែលោកម្ចាស់ បែរជាមកងូតទឹកឲ្យខ្ញុំ ហើយក៏ឡើងទៅអង្គុយត្រង់មាត់ច្រាំង ។

ព្រះថេរៈធ្វើបរិកម្មដៃ និងជើង រហូតពេញរាងកាយហើយ ក៏ស្រង់ទឹកប្រគេនព្រះថេរៈ ។ ថ្ងៃនោះ ជាថ្ងៃស្តាប់ធម៌ ។ ពេលនោះ ទើបព្រះមហាថេរៈពោលថា លោកម្ចាស់ទេវៈ លោកគួរឲ្យធម្មទានដល់យើងទាំងឡាយ ព្រះថេរៈទទួលថា សាធុ លោកម្ចាស់ ។ កាលព្រះអាទិត្យលិចហើយ ពួក

មនុស្សក៏ប្រកាសកាលស្តាប់ធម៌ ។ ព្រះថេរៈ ៦០ រូប សុទ្ធតែមានវស្សាលើស ៦០ បាននាំគ្នាស្តាប់ធម៌ ។ ព្រះទេវត្ថេរក៏ផ្តើមសូត្រនេះ កាលបញ្ចប់ទំនងសូត្រហើយ ។ កាលបញ្ចប់សូត្រ ព្រះថេរៈ ៦០ រូប ក៏បានសម្រេចជាព្រះអរហន្ត បន្ទាប់អំពីនោះ លោកក៏ទៅសម្តែងឯតិស្សមហាវិហារ ។ សូម្បីក្នុងវត្តនោះក៏មានព្រះថេរៈ ៦០ រូបបានជាព្រះអរហន្ត ។ បន្ទាប់អំពីនោះ ក៏សម្តែងត្រង់នាគមហាវិហារ ជិតស្រុកកលកច្ឆៈ ។ សូម្បីក្នុងទីនោះក៏មានព្រះថេរៈ ៦០ រូបបានជាព្រះអរហន្ត ។ បន្ទាប់អំពីនោះ ក៏ទៅវត្តកល្យាណី ក្នុងវត្តនោះ លោកក៏សម្តែងខាងក្រោមប្រាសាទ ក្នុងថ្ងៃទី ១៤ សូម្បីក្នុងទីនោះ ក៏មានព្រះថេរៈ ៦០ រូបជាព្រះអរហន្ត ។ ក្នុងថ្ងៃឧបោសថក៏សម្តែងលើប្រាសាទ ។ លើប្រាសាទនោះ ក៏មានព្រះថេរៈ ៦០ រូបសម្រេចជាព្រះអរហន្តដូចគ្នា ។ កាលព្រះទេវត្ថេរនោះសម្តែងសូត្រនេះយ៉ាងនេះ ក្នុងទី ៦០ កន្លែង ក៏មានអ្នកសម្រេចជាព្រះអរហន្ត មួយកន្លែង ៦០ រូបដោយប្រការដូច្នេះ ។

កាលព្រះចុល្លនាគត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដកសម្តែងព្រះសូត្រនេះក្នុងវត្តអម្ពិលកឡកវិហារ មានមនុស្សបរិស័ទ ៣ គាវុត ។ ទេវតាបរិស័ទ ១ យោជន៍ ។ កាលចប់ព្រះសូត្រ ភិក្ខុ ១០០០ រូបបានជាព្រះអរហន្ត ។ ឯក្នុងពួកទេវតាក្នុងចំនួននោះៗ តែមួយចំនួន មានបុថុជ្ជនត្រឹមចំនួនមួយអង្គប៉ុណ្ណោះឯង ៕ល៚

## អដ្ឋកថា ឆក្កសូត្រទី ៦ ចប់

# សុត្តន្តបិដក

## សឡាយតនវិភង្គសូត្រទី ៧

[ ៣០០ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ព្រះមានព្រះភាគ បានត្រាស់ហៅភិក្ខុទាំងឡាយ ក្នុងទីនោះថា ម្នាលភិក្ខុទាំង-ឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវធម្មបរិយាយ ជាគ្រឿងបំភ្លឺនូវអាយតនៈធំៗ ៦ ដល់អ្នកទាំងឡាយ ចូរអ្នកទាំងឡាយស្តាប់ពាក្យនោះ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធដីកា ព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ៣០១ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹង មិនឃើញនូវចក្ខុតាមពិត មិនដឹងមិនឃើញនូវរូបតាមពិត មិនដឹងមិនឃើញនូវចក្ខុវិញ្ញាណតាមពិត មិនដឹងមិនឃើញនូវចក្ខុសម្ផស្សតាមពិតទេ វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខមិនមែនជាសុខក្តី តែងកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏មិនដឹងមិនឃើញតាមពិត នូវវេទនានោះផង រមែងត្រេកអរក្នុងចក្ខុ ត្រេកអរក្នុងរូប ត្រេកអរក្នុងចក្ខុវិញ្ញាណ ត្រេកអរក្នុងចក្ខុសម្ផស្ស វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខមិនមែនជាសុខក្តី តែងកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏ត្រេកអរក្នុងវេទនានោះ

ផង ។ កាលបុគ្គលនោះមានចិត្តត្រេកអរ ជ្រុលជ្រប់ រំភើងភ្លុំលង់ ជាអ្នកពិចារណាឃើញនូវសេចក្ដីត្រេកអរហើយ ឧបាទានក្ខន្ធទាំង ៥ ក៏ដល់នូវសេចក្ដីចម្រើនតទៅ ។ ឯតណ្ហាដែលតាក់តែងនូវភពថ្មី ប្រកបដោយតម្រេកដោយអំណាចនៃសេចក្ដីត្រេកត្រអាល មានកិរិយារីករាយក្នុងអារម្មណ៍នោះៗ ជាប្រក្រតីរបស់បុគ្គលនោះ តណ្ហានោះរបស់បុគ្គលនោះ រមែងចម្រើនឡើង ។ បុគ្គលនោះរមែងមានសេចក្ដីក្រវល់ក្រវាយ ប្រព្រឹត្តទៅក្នុងកាយចម្រើនឡើងផង មានសេចក្ដីក្រវល់ក្រវាយ ប្រព្រឹត្តទៅក្នុងចិត្ត ចម្រើនឡើងផង មានសេចក្ដីក្ដៅក្រហាយ ប្រព្រឹត្តទៅក្នុងកាយ ចម្រើនឡើងផង មានសេចក្ដីក្ដៅក្រហាយ ប្រព្រឹត្តទៅក្នុងចិត្ត ចម្រើនឡើងផង មានសេចក្ដីអន្ទះអន្ទែង ប្រព្រឹត្តទៅក្នុងកាយ ចម្រើនឡើងផង មានសេចក្ដីអន្ទះអន្ទែង ប្រព្រឹត្តទៅក្នុងចិត្ត ក៏ចម្រើនឡើងផង ។ បុគ្គលនោះរមែងរងទុក្ខ ប្រព្រឹត្តទៅក្នុងកាយផង រងទុក្ខប្រព្រឹត្តទៅក្នុងចិត្តផង ។

[ ៣០២ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងមិនឃើញ នូវត្រចៀកតាមពិត ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងមិនឃើញនូវច្រមុះតាមពិត ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងមិនឃើញនូវអណ្ដាតតាមពិត ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងមិនឃើញនូវកាយតាមពិត ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលមិនដឹងមិនឃើញ នូវចិត្តតាមពិត មិនដឹងមិនឃើញនូវធម្មារម្មណ៍តាមពិត មិនដឹងមិនឃើញនូវមនោវិញ្ញាណតាមពិត មិនដឹងមិនឃើញនូវមនោសម្ផស្សតាមពិត វេទនាណាជាសុខក្ដី ជាទុក្ខក្ដី មិន

មែនទុក្ខមិនមែនសុខក្តី តែងកើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ ក៏មិនដឹង មិនឃើញតាមពិត នូវវេទនានោះផង តែងត្រេកអរក្នុងចិត្ត ត្រេកអរក្នុងធម្មារម្មណ៍ ត្រេកអរក្នុងមនោវិញ្ញាណ ត្រេកអរក្នុងមនោសម្ផស្ស វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី តែងកើតឡើងព្រោះមនោសម្ផស្សជាបច្ច័យ ក៏ត្រេកអរក្នុងវេទនានោះផង ។ កាលបុគ្គលនោះមានចិត្តត្រេកអរជ្រុលជ្រប់ វង្វេងវង្វាន់ ជាអ្នកពិចារណាឃើញនូវសេចក្តីត្រេកអរហើយ ឧបាទានក្ខន្ធទាំង ៥ ក៏ដល់នូវសេចក្តីចម្រើនតទៅ ។ ឯតណ្ហាដែលតាក់តែងភពថ្មី ប្រកបដោយតម្រេក ដោយអំណាចនៃសេចក្តីត្រេកត្រអាល មានការរីករាយក្នុងអារម្មណ៍នោះៗ ជាប្រក្រតី របស់បុគ្គលនោះ តណ្ហានោះរបស់បុគ្គលនោះ រមែងចម្រើនឡើង បុគ្គលនោះរមែងមានសេចក្តីក្រវល់ក្រវាយប្រព្រឹត្តទៅក្នុងកាយ ចម្រើនឡើងផង មានសេចក្តីក្រវល់ក្រវាយប្រព្រឹត្តទៅក្នុងចិត្ត ចម្រើនឡើងផង មានសេចក្តីក្តៅក្រហាយប្រព្រឹត្តទៅក្នុងកាយ ចម្រើនឡើងផង មានសេចក្តីក្តៅក្រហាយប្រព្រឹត្តទៅក្នុងចិត្តចម្រើនឡើងផង មានសេចក្តីអន្ទះអន្ទែង ប្រព្រឹត្តទៅក្នុងកាយ ចម្រើនឡើងផង មានសេចក្តីអន្ទះអន្ទែង ប្រព្រឹត្តទៅក្នុងចិត្ត ចម្រើនឡើងផង ។ បុគ្គលនោះរមែងរងទុក្ខប្រព្រឹត្តទៅក្នុងកាយផង រងទុក្ខប្រព្រឹត្តទៅក្នុងចិត្តផង ។

[ ៣០៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវចក្ខុតាមពិត កាលដឹង ឃើញនូវរូបតាមពិត កាលដឹង ឃើញនូវចក្ខុវិញ្ញាណតាមពិត កាលដឹង ឃើញនូវចក្ខុសម្ផស្សតាមពិត វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខ

មិនមែនសុខក្តី តែងកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏ដឹង ឃើញនូវវេទនានោះតាមពិតផង តែមិនត្រេកអរក្នុងចក្ខុ មិនត្រេកអរក្នុងរូប មិនត្រេកអរក្នុងចក្ខុវិញ្ញាណ មិនត្រេកអរក្នុងចក្ខុសម្ផស្សទេ វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី តែងកើតឡើងព្រោះចក្ខុសម្ផស្សជាបច្ច័យ ក៏មិនត្រេកអរក្នុងវេទនានោះផង ។ កាលបុគ្គលនោះមានចិត្តមិនត្រេកអរ មិនជ្រុលជ្រប់ មិនវង្វេងវង្វាន់ ជាអ្នកពិចារណាឃើញនូវទោសហើយ ឧបាទានក្ខន្ធទាំង ៥ ក៏ដល់នូវសេចក្តីមិនចម្រើនតទៅ ។ ឯតណ្ហាដែលតាក់តែងភពថ្មី ប្រកបដោយតម្រេក ដោយអំណាចនៃសេចក្តីត្រេកត្រអាល មានសេចក្តីរីករាយក្នុងអារម្មណ៍នោះៗ ជាប្រក្រតី របស់បុគ្គលនោះ តណ្ហានោះបុគ្គលនោះឯងលះបង់ចេញបាន ។ សេចក្តីក្រវល់ក្រវាយប្រព្រឹត្តទៅក្នុងកាយបុគ្គលនោះរមែងលះបង់បានផង សេចក្តីក្រវល់ក្រវាយប្រព្រឹត្តទៅក្នុងចិត្ត ក៏រមែងលះបង់បានផង សេចក្តីក្តៅក្រហាយប្រព្រឹត្តទៅក្នុងកាយ ក៏រមែងលះបង់បានផង សេចក្តីក្តៅក្រហាយប្រព្រឹត្តទៅក្នុងចិត្ត ក៏រមែងលះបង់បានផង សេចក្តីអន្ទះអន្ទែងប្រព្រឹត្តក្នុងកាយ ក៏រមែងលះបង់បានផង សេចក្តីអន្ទះអន្ទែងប្រព្រឹត្តទៅក្នុងចិត្ត ក៏រមែងលះបង់បានផង ។ បុគ្គលនោះ តែងរងនូវសេចក្តីសុខប្រព្រឹត្តទៅក្នុងកាយ និងសេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ។ សេចក្តីយល់ឃើញណា របស់បុគ្គលមានសភាពដូច្នោះ សេចក្តីយល់ឃើញនោះ របស់បុគ្គលនោះ ឈ្មោះថាសេចក្តីយល់ឃើញត្រូវ សេចក្តីត្រិះរិះណា របស់បុគ្គលមានសភាពដូច្នោះ សេចក្តីត្រិះរិះនោះ របស់បុគ្គលនោះ ឈ្មោះថា សេចក្តី

ត្រិះរិះត្រូវ សេចក្តីព្យាយាមណា របស់បុគ្គលមានសភាពដូច្នោះ សេចក្តីព្យាយាមនោះ របស់បុគ្គលនោះ ឈ្មោះថា សេចក្តីព្យាយាមត្រូវ ការរឭកណារបស់បុគ្គលមានសភាពដូច្នោះ ការរឭកនោះ របស់បុគ្គលនោះ ឈ្មោះថា ការរឭកត្រូវ ការតាំងចិត្តនឹងណា របស់បុគ្គលមានសភាពដូច្នោះ ការតាំងចិត្តនឹងនោះ របស់បុគ្គលនោះ ឈ្មោះថា ការតាំងចិត្តនឹងត្រូវ ។ បុគ្គលនោះឯង ឈ្មោះថា មានកាយកម្ម វចីកម្ម និងអាជីវៈដ៏បរិសុទ្ធល្អ ក្នុងកាលមុនពិត ។ អដ្ឋង្គិក-មគ្គដ៏ប្រសើរនេះ របស់បុគ្គលនោះ រមែងដល់នូវការពេញបរិបូណ៌ ដោយភាវនាយ៉ាងនេះឯង ។

[ ៣០៤ ] កាលបុគ្គលនោះ ចម្រើននូវអដ្ឋង្គិកមគ្គដ៏ប្រសើរនេះ យ៉ាងនេះហើយ សតិប្បដ្ឋាន ៤ ក្តី តែងដល់នូវការបរិបូណ៌ដោយភាវនា សម្ម-ប្បធាន ៤ ក្តី តែងដល់នូវការបរិបូណ៌ដោយភាវនា ឥទ្ធិបាទ ៤ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ឥន្ទ្រិយ ៥ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ពល ៥ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ពោជ្ឈង្គ ៧ ក៏ដល់នូវការបរិបូណ៌ដោយភាវនា ។ ធម៌ ២ យ៉ាងនេះ គឺសមថៈ ១ វិបស្សនា ១ ជាធម៌ទាក់ទងគូនឹងគ្នា តែងប្រព្រឹត្តទៅដល់បុគ្គលនោះ ។ ធម៌ទាំងឡាយណា ដែលគប្បីកំណត់ដឹង ដោយប្រាជ្ញាដ៏ឧត្តម បុគ្គលនោះ ក៏កំណត់ដឹងនូវធម៌ទាំងនោះ ដោយប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីលះបង់ដោយប្រាជ្ញាដ៏ឧត្តម ក៏លះបង់នូវធម៌ទាំងនោះ ដោយប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីចម្រើនដោយប្រាជ្ញាដ៏ឧត្តម ក៏ចម្រើននូវធម៌ទាំងនោះ ដោយ

ប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះ ដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច ត្រូវឆ្លើយថា បានដល់ឧបាទានក្ខន្ធ ( គំនរជាគ្រឿងប្រកាន់មាំ ) ទាំង ៥ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទា-នក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ នេះឯងដែលជាធម៌គប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីលះបង់ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច អវិជ្ជា និងភវតណ្ហានេះឯង ជាធម៌ត្រូវលះបង់ដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីចម្រើនដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច សមថៈ និងវិបស្សនានេះឯង ជាធម៌ត្រូវចម្រើនដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច វិជ្ជា និងវិមុត្តិនេះឯង ជាធម៌ត្រូវធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម ។

[ ៣០៥ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវត្រចៀកតាមពិត ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវច្រមុះតាមពិត ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវអណ្តាតតាមពិត ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវកាយតាមពិត ... ម្នាលភិក្ខុទាំងឡាយ បុគ្គលកាលដឹង ឃើញនូវចិត្តតាមពិត កាលដឹង ឃើញនូវធម្មារម្មណ៍តាមពិត កាលដឹង ឃើញនូវមនោវិញ្ញាណតាមពិត កាលដឹង ឃើញនូវមនោ-

សម្ផស្សតាមពិត វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនមែនជាទុក្ខ មិនមែនជាសុខក្តី រមែងកើតឡើង ព្រោះមនោសម្ផស្សជាបច្ច័យ ក៏ដឹង ឃើញនូវវេទនានោះតាមពិតផង តែមិនត្រេកអរក្នុងចិត្ត មិនត្រេកអរក្នុងធម្មារម្មណ៍ មិនត្រេកអរក្នុងមនោវិញ្ញាណ មិនត្រេកអរក្នុងមនោសម្ផស្សទេ វេទនាណាជាសុខក្តី ជាទុក្ខក្តី មិនមែនទុក្ខមិនមែនសុខក្តី តែងកើតឡើងព្រោះមនោ-សម្ផស្សជាបច្ច័យ ក៏មិនត្រេកអរក្នុងវេទនានោះផង ។ កាលបុគ្គលនោះមិនត្រេកអរ មិនជ្រុលជ្រប់ មិនវង្វេងងុលងប់ ជាអ្នកពិចារណាឃើញទោសរឿយៗ ឧបាទានក្ខន្ធទាំង ៥ ក៏ដល់នូវសេចក្តីមិនចម្រើនតទៅ ។ ឯតណ្ហាដែលតាក់តែងភពថ្មី ប្រកបដោយតម្រេក ដោយអំណាចនៃសេចក្តីត្រេកត្រអាល មានសេចក្តីរីករាយក្នុងអារម្មណ៍នោះៗ ជាប្រក្រតី របស់បុគ្គលនោះ តណ្ហានោះ ក៏បុគ្គលនោះឯងលះបង់បាន ។ សេចក្តីក្រវល់ក្រវាយប្រព្រឹត្តទៅក្នុងកាយ ក៏បុគ្គលនោះលះបង់បាន សេចក្តីក្រវល់ក្រវាយប្រព្រឹត្តទៅក្នុងចិត្ត ក៏លះបង់បាន សេចក្តីក្តៅក្រហាយប្រព្រឹត្តទៅក្នុងកាយ ក៏លះបង់បាន សេចក្តីក្តៅក្រហាយប្រព្រឹត្តទៅក្នុងចិត្ត ក៏លះបង់បាន សេចក្តីអន្ទះអន្ទែងប្រព្រឹត្តទៅក្នុងកាយ ក៏លះបង់បាន សេចក្តីអន្ទះអន្ទែងប្រព្រឹត្តទៅក្នុងចិត្ត ក៏លះបង់បាន ។ បុគ្គលនោះតែងទទួលនូវសេចក្តីសុខ ប្រព្រឹត្តទៅក្នុងកាយ និងសេចក្តីសុខប្រព្រឹត្តទៅក្នុងចិត្ត ។ សេចក្តីយល់ឃើញណា របស់បុគ្គលមានសភាពដូច្នោះ សេចក្តីយល់ឃើញនោះ របស់បុគ្គលនោះ ឈ្មោះថា សេចក្តីយល់ឃើញត្រូវ សេចក្តីត្រិះរិះណា របស់បុគ្គលមានសភាពដូច្នោះ

សេចក្តីត្រិះរិះនោះ របស់បុគ្គលនោះ ឈ្មោះថា សេចក្តីត្រិះរិះត្រូវ សេចក្តីព្យាយាមណារបស់បុគ្គល មានសភាពដូច្នោះ សេចក្តីព្យាយាមនោះ របស់បុគ្គលនោះ ឈ្មោះថា សេចក្តីព្យាយាមត្រូវ ការរឭកណារបស់បុគ្គល មានសភាពដូច្នោះ ការរឭកនោះ របស់បុគ្គលនោះ ឈ្មោះថា ការរឭកត្រូវ ការតាំងចិត្តនឹងណា របស់បុគ្គលមានសភាពដូច្នោះ ការតាំងចិត្តនឹងនោះ របស់បុគ្គលនោះ ឈ្មោះថា ការតាំងចិត្តនឹងត្រូវ ។ បុគ្គលនោះឯង ឈ្មោះថា មានកាយកម្ម វចីកម្ម និងអាជីវៈបរិសុទ្ធល្អ ក្នុងកាលមុនពិត ។ អដ្ឋង្គិកមគ្គដ៏ប្រសើរនេះ របស់បុគ្គលនោះ រមែងដល់នូវការបរិបូណ៌ ដោយភាវនាយ៉ាងនេះ ។

[ ៣០៦ ] កាលបុគ្គលនោះ ចម្រើនអដ្ឋង្គិកមគ្គដ៏ប្រសើរយ៉ាងនេះហើយ សតិប្បដ្ឋាន ៤ ក្តី តែងដល់នូវការបរិបូណ៌ដោយភាវនា សម្មប្បធាន ៤ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ឥទ្ធិបាទ ៤ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ឥន្ទ្រិយ ៥ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ពល ៥ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ពោជ្ឈង្គ ៧ ក្តី ក៏ដល់នូវការបរិបូណ៌ដោយភាវនា ។ បុគ្គលនោះតែងមានធម៌ពីរយ៉ាងនេះ គឺសមថៈ ១ វិបស្សនា ១ ប្រព្រឹត្តទាក់ទងគូនឹងគ្នា ។ ធម៌ទាំងឡាយណា ដែលគប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម បុគ្គលនោះ ក៏កំណត់ដឹងនូវធម៌ទាំងនោះ ដោយប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីលះបង់ដោយប្រាជ្ញាដ៏ឧត្តម ក៏លះបង់នូវធម៌ទាំងនោះ ដោយប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីចម្រើនដោយ

ប្រាជ្ញាដ៏ឧត្តម ក៏ចម្រើននូវធម៌ទាំងនោះ ដោយប្រាជ្ញាដ៏ឧត្តម ធម៌ទាំងឡាយណា ដែលគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ក៏ធ្វើឲ្យជាក់ច្បាស់នូវធម៌ទាំងនោះ ដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលគប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច គប្បីឆ្លើយថា បានដល់ឧបាទានក្ខន្ធទាំង ៥ គឺរូបូបាទានក្ខន្ធ ១ វេទនូបាទានក្ខន្ធ ១ សញ្ញូបាទានក្ខន្ធ ១ សង្ខារូបាទានក្ខន្ធ ១ វិញ្ញាណូបាទានក្ខន្ធ ១ នេះឯង ជាធម៌ដែលគប្បីកំណត់ដឹងដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយដែលគប្បីលះបង់ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច អវិជ្ជា និងភវតណ្ហានេះឯងជាធម៌ដែលគប្បីលះបង់ដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីចម្រើនដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច សមថៈ និងវិបស្សនានេះឯង ជាធម៌ដែលគប្បីចម្រើនដោយប្រាជ្ញាដ៏ឧត្តម ។ ម្នាលភិក្ខុទាំងឡាយ ចុះធម៌ទាំងឡាយ ដែលគប្បីធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ឧត្តម តើដូចម្តេច វិជ្ជា និងវិមុត្តិនេះឯង ជាធម៌ដែលគប្បីធ្វើឲ្យជាក់ច្បាស់ដោយប្រាជ្ញាដ៏ឧត្តម ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះ ចប់ហើយ ភិក្ខុទាំងនោះ ជាអ្នកមានសេចក្តីត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

*សឡាយតនវិភង្គសូត្រទី ៧ ចប់*

# អដ្ឋកថា

## សឡាយតនិកសូត្រ

[ ៣០០ ] មហាសឡាយតនិកសូត្រ មានពាក្យផ្តើមថា **ឯវំមេ្ម សុតំ** ដូច្នេះជាដើម ។ ក្នុងព្រះសូត្រនោះ បទថា **មហាសឡាយតនិកំ** គឺជាធម្មបរិយាយ ចុះបញ្ចាំងដល់អាយតនៈដែលសំខាន់ ៦ យ៉ាង ។

[ ៣០១ ] បទថា **អជានំ** គឺមិនដឹងដោយមគ្គ ដែលព្រមនឹងវិបស្សនា ។ បទថា **ឧបចយំ គច្ឆន្តិ** គឺរមែងដល់នូវការចម្រើន ដោយអត្ថថា ដល់នូវការស្ទាត់ជំនាញ ។ បទថា **កាយិក** បានដល់ ការរសាប់រសល់តាមទ្វារទាំង ៥ ។ បទថា **ចេតសិក** បានដល់ ការរសាប់រសល់តាមមនោទ្វារ ។ ក្នុងបទថា **សន្តាបា** ជាដើម ក៏ទំនងដូចគ្នានេះឯង ។

[ ៣០៣ ] បទថា **កាយិកសុខំ** បានដល់ សុខតាមទ្វារ ៥ ។ បទថា **ចេតោសុខំ** បានដល់ សុខតាមមនោទ្វារ ។ ក្នុងពាក្យថា សុខផ្លូវចិត្តនេះ មិនមានការចូល ឬការចេញ ដោយជវនតាមទ្វារ ៥ ។ គឺសេចក្តីសុខផ្លូវចិត្តនេះ គ្រាន់តែកើតឡើងប៉ុណ្ណោះឯង ។ គ្រប់យ៉ាងរមែងមានតាមមនោទ្វារ ។ ឯវិបស្សនាដែលមានកម្លាំងនេះ រមែងជាបច្ច័យដល់មគ្គវុដ្ឋាន ។ វិបស្សនាដែលមានកម្លាំងនោះ ទើបមានតាមមនោទ្វារដូចគ្នា ។

បទថា **តថាភូតស្ស** គឺជាអ្នកដល់ព្រមដោយសេចក្តីសុខផ្លូវចិត្ត ដែលប្រកបព្រមដោយកុសលចិត្ត ។ បទថា **បុព្វេវ ខោ បនស្ស** គឺវាចា ការងារ និងអាជីវៈនៃភិក្ខុនោះ ឈ្មោះថា ស្អាតក្នុងកាលមុន គឺរមែងជារបស់បរិសុទ្ធ

តាំងអំពីខាងដើម ចំណែក ៥ អង្គទៀត គឺការឃើញ ការត្រិះរិះ ការព្យាយាម ការរឭក ការតាំងមាំ ឈ្មោះថា ជាអង្គដែលឧបការៈគ្រប់ករណី ។ ដោយប្រការដូច្នេះ ទើបលោកុត្តរមគ្គមានអង្គ ៨ ឬអង្គ ៧ ក៏បាន ។ ឯបុគ្គលដែលចូលចិត្តពោលខោកគោះ ចាប់យកអត្ថព្រះសូត្រនេះឯងថា ការឃើញរបស់ភិក្ខុយ៉ាងនោះ ហើយពោលថា លោកុត្តរមគ្គមានអង្គ ៥ ក៏មិនមាន ។ គប្បីជំទាស់អ្នកពោលខោកគោះនោះ ដោយវាចាភ្លាមៗ នេះថា អរិយមគ្គប្រកបដោយអង្គ ៨ របស់អ្នកនេះ រមែងដល់នូវការបរិបូណ៌នៃការអប់រំ ដោយអាការយ៉ាងនេះ ។ ហើយក៏គប្បីឲ្យយល់ព្រមក្រៃលែងឡើងៗទៅយ៉ាងនេះ ។ ឈ្មោះថា លោកុត្តរមគ្គនោះ មានអង្គ ៥ មិនមានទេ ឯអង្គដែលឧបការៈក្នុងករណីទាំងអស់នេះ រមែងឲ្យពេញដោយអំណាចវិរតិចេតសិក ក្នុងខណៈនៃមគ្គ ។ ព្រោះថា វិរតិចេតសិក ក្នុងវិរតិចេតសិកដែលពោលយ៉ាងនេះថា ការវៀរចាកវចីទុច្ចរិតទាំង ៤ ឯណា រមែងលះការពោលខុស ធ្វើការពោលប្រពៃឲ្យចម្រើន ។ កាលអប់រំវាចាប្រពៃយ៉ាងនេះ អង្គទាំង ៥ ក៏មិនខ្វះខាត រមែងបរិបូណ៌ព្រមនឹងការវៀរនោះឯង ។ ក្នុងការងារត្រូវ និងការចិញ្ចឹមជីវិតត្រូវ ក៏ទំនងនេះឯង ។ ដោយប្រការដូច្នេះ វចីកម្មជាដើម ក៏ជារបស់បរិសុទ្ធតាំងអំពីដំបូងនោះឯង ។

ឯអង្គដែលឧបការៈក្នុងគ្រប់ករណីទាំង ៥ នេះ រមែងបរិបូណ៌ ដោយអំណាចវិរតិចេតសិក ទើបឈ្មោះថា មគ្គមានអង្គ ៥ មិនមាន ។ ក្នុងសុភទ្ទសូត្រ ( មហាបរិនិព្វានសូត្រ ) ព្រះមានព្រះភាគត្រាស់យ៉ាងនេះថា ម្នាល

*សុភទ្ទ ក្នុងធម្មវិន័យនេះឯង មានអរិយមគ្គប្រកបដោយអង្គ ៨ ។ ព្រះសូត្រទាំងឡាយដទៃច្រើនរយសូត្រ ក៏មកហើយអំពីមគ្គដែលមានអង្គ ៨ ប៉ុណ្ណោះ ។*

*[ ៣០៥ ] បទថា* **ចត្តារោបិ សតិបដ្ឋានា** *គឺសតិប្បដ្ឋានដែលប្រកបព្រមដោយមគ្គនោះឯង ។ សូម្បីក្នុងសម្មាវាយាមៈជាដើម ក៏មានទំនងដូចគ្នានេះឯង ។ បទថា* **យុគនទ្ធា** *គឺគូប្រកបដោយគណៈជាមួយគ្នា ធម៌ទាំងនេះ សូម្បីមានប្រមាណផ្សេងគ្នាយ៉ាងនេះ គឺក្នុងខណៈមួយជាសមាបត្តិ ក្នុងខណៈដទៃជាវិបស្សនា ។ តែក្នុងអរិយមគ្គ ធម៌ទាំងនោះប្រកបក្នុងខណៈជាមួយគ្នា ។*

*[ ៣០៦ ] បទថា* **វិជ្ជា ច វិមុត្តិ ច** *បានដល់ វិជ្ជាក្នុងអរហត្តមគ្គ និងផលវិមុត្តិ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ ងាយយល់ហើយ ។៚*

**អដ្ឋកថា សឡាយតនវិភង្គសូត្រ ចប់**

**សូត្រទី ៧ ចប់**

# សុត្តន្តបិដក

## នគរវិន្ទេយ្យសូត្រទី ៨

[ ៣០៧ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ត្រាច់ទៅកាន់ចារិក ក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃច្រើនរូប ក៏បានស្តេចទៅដល់ព្រាហ្មណគ្រាម ឈ្មោះនគរវិន្ទៈ របស់ពួកអ្នកកោសល ។ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកនគរវិន្ទៈ បានឮដំណឹងថា ព្រះសមណគោតម ជាសក្យបុត្រ ចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវនេះ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងដែនកោសល ព្រមដោយភិក្ខុសង្ឃច្រើនរូប ក៏បានស្តេចមកដល់ស្រុកនគរវិន្ទៈហើយ កិត្តិសព្ទដ៏ពីរោះ របស់ព្រះគោតមដ៏ចម្រើននោះ ក៏ឮខ្ចរខ្ចាយ សុសសាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់ឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជា និងចរណៈ ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ ព្រះអង្គជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបាន ព្រះអង្គជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងមកកាន់ភពថ្មីទៀត ព្រះអង្គទ្រង់ធ្វើឲ្យជាក់ច្បាស់ ដោយប្រាជ្ញាដ៏ប្រសើរ របស់ព្រះអង្គ នូវលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក នូវពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ហើយអាចប្រកាសបាន ទ្រង់សំដែងធម៌មានលម្អ

បទដើម មានលម្អបទកណ្តាល មានលម្អបទចុង ព្រះអង្គប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថ និងព្យញ្ជនៈដ៏បរិសុទ្ធ បរិបូណ៌ទាំងអស់ ក៏ដំណើរដែលបានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនោះ ជាការប្រពៃពេក ។ គ្រានោះឯង ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកនគរវិន្ទៈ ក៏នាំគ្នាចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ពួកខ្លះថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះប្រកាសនាម និងគោត្រក្នុងសម្នាក់ព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះអង្គុយនៅស្ងៀមក្នុងទីដ៏សមគួរ ។

[ ៣០៨ ] លុះពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកនគរវិន្ទៈ អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះមានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលគហបតីទាំងឡាយ បើបរិព្វាជកជាអន្យតិរ្ថិយ ( មានលទ្ធិផ្សេង ) សួរអ្នកទាំងឡាយយ៉ាងនេះថា ម្នាលគហបតីទាំងឡាយ ពួកសមណព្រាហ្មណ៍បែបណា ដែលគេមិនគួរធ្វើសក្ការៈ មិនគួរគោរព មិនគួររាប់អាន មិនគួរបូជា ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះហើយ គប្បីដោះស្រាយយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ណា មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងរូបដែលគប្បីដឹងបានដោយភ្នែក ជាអ្នកមានចិត្តមិនស្ងប់រម្ងាប់ ខាងក្នុងសន្តាន ប្រព្រឹត្តត្រូវខ្លះ ខុសខ្លះ ដោយកាយវាចាចិត្ត ពួកសមណព្រាហ្មណ៍

បែបនេះឯង គេមិនគួរធ្វើសក្ការៈ មិនគួរគោរព មិនគួររាប់អាន មិនគួរបូជាឡើយ ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះថា សូម្បីពួកយើងក៏មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងរូបដែលគប្បីដឹងបានដោយភ្នែក ជាអ្នកមានចិត្តមិនស្ងប់រម្ងាប់ ខាងក្នុងសន្តាន នៅប្រព្រឹត្តត្រូវខ្លះខុសខ្លះ ដោយកាយវាចាចិត្តដែរ នេះឯងជាសេចក្តីប្រព្រឹត្តត្រឹមត្រូវរបស់យើងទាំងនោះ ដែលមិនឃើញនូវធម៌ខ្ពង់ខ្ពស់ ព្រោះហេតុនោះ ពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ គេមិនគួរធ្វើសក្ការៈ មិនគួរគោរព មិនគួររាប់អាន មិនគួរបូជាឡើយ ។ ពួកសមណព្រាហ្មណ៍ណា មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងសំឡេងដែលគប្បីដឹងបានដោយត្រចៀក ... ក្នុងក្លិនដែលគប្បីដឹងបានដោយច្រមុះ ... ក្នុងឱជារសដែលគប្បីដឹងបានដោយអណ្តាត ... ក្នុងផោដ្ឋព្វៈដែលគប្បីដឹងបានដោយកាយ ... មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងធម្មារម្មណ៍ ដែលគប្បីដឹងបានដោយចិត្ត ជាអ្នកមានចិត្តមិនស្ងប់រម្ងាប់ខាងក្នុងសន្តាន ប្រព្រឹត្តត្រូវខ្លះខុសខ្លះ ដោយកាយវាចាចិត្ត ពួកសមណព្រាហ្មណ៍បែបនេះឯង គេមិនគួរធ្វើសក្ការៈ មិនគួរគោរព មិនគួររាប់អាន មិនគួរបូជាឡើយ ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះថា សូម្បីពួកយើង ក៏មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងធម្មារម្មណ៍ ដែលគប្បីដឹងបានដោយចិត្ត ជាអ្នកមានចិត្តមិនស្ងប់រម្ងាប់ខាងក្នុងសន្តាន នៅប្រព្រឹត្តត្រូវខ្លះខុសខ្លះ ដោយកាយវាចាចិត្តដែរ

នេះឯង ជាសេចក្ដីប្រព្រឹត្តត្រឹមត្រូវ របស់យើងទាំងនោះ ដែលមិនឃើញនូវធម៌ខ្ពង់ខ្ពស់ ព្រោះហេតុនោះ សមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ គេមិនគួរធ្វើសក្ការៈ មិនគួរគោរព មិនគួររាប់អាន មិនគួរបូជាឡើយ ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជក ជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះឯង ។

[ ៣០៩ ] ម្នាលគហបតីទាំងឡាយ មួយទៀត បើបរិព្វាជកជាអន្យតិរ្ថិយ សួរអ្នកទាំងឡាយ យ៉ាងនេះថា ម្នាលគហបតីទាំងឡាយ ចុះពួកសមណព្រាហ្មណ៍បែបណា ដែលគេគួរធ្វើសក្ការៈ គួរគោរព គួររាប់អាន គួរបូជា ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះថា ពួកសមណព្រាហ្មណ៍ណា ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ក្នុងរូបដែលគប្បីដឹងបានដោយភ្នែក ជាអ្នកមានចិត្តស្ងប់រម្ងាប់ ខាងក្នុងសន្ដាន ប្រព្រឹត្តត្រឹមត្រូវដោយកាយវាចាចិត្ត ពួកសមណព្រាហ្មណ៍បែបនេះឯង ទើបគេគួរធ្វើសក្ការៈ គួរគោរព គួររាប់អាន គួរបូជា ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះថា សូម្បីពួកយើង មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងរូបដែលគប្បីដឹងបានដោយភ្នែក មានចិត្តមិនទាន់ស្ងប់រម្ងាប់ខាងក្នុងសន្ដានទេ នៅប្រព្រឹត្តត្រូវខ្លះខុសខ្លះ ដោយកាយវាចាចិត្ត នេះឯងជាសេចក្ដីប្រព្រឹត្តត្រឹមត្រូវ របស់យើងទាំងនោះ ដែលឃើញនូវធម៌ខ្ពង់ខ្ពស់ ព្រោះហេតុនោះ ពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ ទើបគេគួរធ្វើសក្ការៈ

គួរគោរព គួររាប់អាន គួរបូជា ។ ពួកសមណព្រាហ្មណ៍ណា ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ក្នុងសំឡេងដែលគប្បីដឹងបានដោយត្រចៀក ... ក្នុងក្លិនដែលគប្បីដឹងបានដោយច្រមុះ ... ក្នុងឱជារសដែលគប្បីដឹងបានដោយអណ្តាត ... ក្នុងផោដ្ឋព្វៈដែលគប្បីដឹងបានដោយកាយ ... ប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ ក្នុងធម្មារម្មណ៍ ដែលគប្បីដឹងបានដោយចិត្ត ជាអ្នកមានចិត្តស្ងប់រម្ងាប់ខាងក្នុងសន្តាន ប្រព្រឹត្តត្រឹមត្រូវដោយកាយវាចាចិត្ត ពួកសមណព្រាហ្មណ៍បែបនេះ ទើបគេគួរធ្វើសក្ការៈ គួរគោរព គួររាប់អាន គួរបូជា ដំណើរនោះ តើព្រោះហេតុអ្វី ព្រោះថា សូម្បីពួកយើង មិនទាន់ប្រាសចាករាគៈ មិនទាន់ប្រាសចាកទោសៈ មិនទាន់ប្រាសចាកមោហៈ ក្នុងធម្មារម្មណ៍ ដែលគប្បីដឹងបានដោយចិត្ត ជាអ្នកមានចិត្តមិនទាន់ស្ងប់រម្ងាប់ខាងក្នុងសន្តាន នៅប្រព្រឹត្តត្រូវខ្លះខុសខ្លះ ដោយកាយវាចាចិត្ត នេះឯងជាសេចក្តីប្រព្រឹត្តត្រឹមត្រូវ របស់យើងទាំងនោះ ដែលឃើញនូវធម៌ខ្ពង់ខ្ពស់ ព្រោះហេតុនោះ បានជាពួកសមណព្រាហ្មណ៍ដ៏ចម្រើនទាំងនោះ គេគួរធ្វើសក្ការៈ គួរគោរព គួររាប់អាន គួរបូជា ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះឯង ។

[ ៣១០ ] ម្នាលគហបតីទាំងឡាយ បើបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះថា ម្នាលអ្នកមានអាយុទាំងឡាយ ចុះលោកមានអាយុទាំងឡាយ មានហេតុដូចម្តេច មានប្រាជ្ញាយោបល់ដូចម្តេច ដែលនាំឲ្យអ្នកទាំងឡាយ

និយាយយ៉ាងនេះថា អ្នកមានអាយុទាំងនោះ ប្រាសចាករាគៈ ឬកំពុងប្រតិបត្តិដើម្បីបន្ទោបង់នូវរាគៈ ប្រាសចាកទោសៈ ឬកំពុងប្រតិបត្តិដើម្បីបន្ទោបង់នូវទោសៈ ប្រាសចាកមោហៈ ឬកំពុងប្រតិបត្តិដើម្បីបន្ទោបង់នូវមោហៈដោយពិត ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ សួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះថា ពិតដូច្នោះមែន ព្រោះលោកមានអាយុទាំងនោះ តែងគប់រកសេនាសនៈដ៏ស្ងាត់ គឺព្រៃតូច និងព្រៃធំ ដ្បិតរូបគប្បីដឹងបានដោយភ្នែក ដែលគេឃើញញយៗ ហើយ គួរត្រេកអរបាន មិនមានក្នុងព្រៃនោះឡើយ សំឡេងគប្បីដឹងបានដោយត្រចៀក ដែលគេឮញយៗ ហើយ គួរត្រេកអរបាន មិនមានក្នុងព្រៃនោះឡើយ ក្លិនគប្បីដឹងបានដោយច្រមុះ ដែលគេហិតញយៗ ហើយ គួរត្រេកអរបាន មិនមានក្នុងព្រៃនោះឡើយ រសគប្បីដឹងបានដោយអណ្តាត ដែលគេទទួលរសញយៗ ហើយ គួរត្រេកអរបាន មិនមានក្នុងព្រៃនោះឡើយ ផោដ្ឋព្វៈគប្បីដឹងបានដោយកាយ ដែលគេប៉ះពាល់ញយៗ ហើយ គួរត្រេកអរបាន មិនមានក្នុងព្រៃនោះឡើយ ម្នាលអាវុសោទាំងឡាយ យើងទាំងឡាយមានហេតុនេះឯង មានប្រាជ្ញាយោបល់នេះឯងហើយ ដែលនាំឲ្យពួកយើងនិយាយយ៉ាងនេះ ចំពោះអ្នកមានអាយុទាំងឡាយថា លោកមានអាយុទាំងនោះ ប្រាសចាករាគៈ ឬកំពុងប្រតិបត្តិដើម្បីបន្ទោបង់រាគៈ ប្រាសចាកទោសៈ ឬកំពុងប្រតិបត្តិដើម្បីបន្ទោបង់ទោសៈ ប្រាសចាកមោហៈ ឬកំពុងប្រតិបត្តិដើម្បីបន្ទោបង់មោហៈដោយពិត ។ ម្នាលគហបតីទាំងឡាយ អ្នកទាំងឡាយ កាលបើបរិព្វាជកជាអន្យតិរ្ថិយទាំងនោះ

សួរយ៉ាងនេះ គប្បីដោះស្រាយយ៉ាងនេះឯង ។

[ ៣១១ ] កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ពួកព្រាហ្មណ៍ និងគហបតី អ្នកស្រុកនគរវិន្ទៈ បានក្រាបទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើន ទ្រង់សំដែងហើយដោយអនេកបរិយាយយ៉ាងនេះ ដូចជាគេផ្ងាររបស់ដែលផ្កាប់ ឬដូចគេបើកបង្ហាញរបស់ដែលកំបាំង ពុំនោះដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចជាគេទ្រោលប្រទីបក្នុងទីងងឹត ដោយគិតថាមនុស្សដែលមានភ្នែកនឹងមើលឃើញរូបបាន ខ្ញុំព្រះអង្គទាំងឡាយនេះ សូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ថាជាទីពឹង សូមព្រះគោតមដ៏ចម្រើន ទ្រង់ជ្រាបទុកនូវខ្ញុំព្រះអង្គទាំងឡាយ ថាជាឧបាសកដល់នូវសរណគមន៍ ស្មើដោយជីវិត ចាប់ដើមពីថ្ងៃនេះតទៅ ។

## នគរវិន្ទេយ្យសូត្រទី ៨ ចប់

# អដ្ឋកថា

## នគរវិន្ទេយ្យសូត្រ

[ ៣០៧ ] នគរវិន្ទេយ្យសូត្រ មានពាក្យផ្ដើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។

[ ៣០៨ ] ក្នុងព្រះសូត្រនោះ បទថា **សមវិសមំ ចរន្តិ** បានដល់ ជួនកាល ក៏ប្រព្រឹត្តស្មើ ជួនកាល ក៏ប្រព្រឹត្តមិនស្មើ ។

[ ៣០៩ ] បទថា **សមចរិយំបិ ហោតំ** កាត់បទជា **សមចរិយំបិ ហិ ឯតំ** ប្រែថា នេះក៏ជាការប្រព្រឹត្តិស្មើ ។

[ ៣១០ ] បទថា **កេ អាការា** គឺហេតុពួកណា ។ បទថា **កេ អន្វយា** ប្រែថា អ្វីដែលគប្បីតាមដឹង ។ ហេតុអ្វី ទើបលោកពោលថា ឯក្នុងព្រៃជ្រៅនោះមិនមានឡើយ កាមគុណ ៥ មានរូបជាដើម ដែលគួរពេញចិត្តយ៉ាងក្រៃលែង ដោយអំណាចស្មៅខៀវ និងព្រៃចម្បាជាដើម ដែលមាននៅក្នុងព្រៃមិនមែនឬ ។ ឆ្លើយថា មិនមែនមិនមានទេ ។ តែពាក្យនេះ លោកមិនសម្ដែងដោយព្រៃជ្រៅ ។ តែលោកសំដៅយករូបមនុស្សស្រីជាដើម ទើបពោលពាក្យនេះ ។ ឯរូបនៃមនុស្សស្រីជាដើមនោះ ទាញចិត្តរបស់មនុស្សប្រុស ហើយតាំងនៅ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញរូបដទៃ សូម្បីតែរូប ១ ដែលគ្របសង្កត់ចិត្តបុរស ហើយឋិតនៅ ដូចរូបស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ រូបស្ត្រី ទើបអាចគ្របសង្កត់ចិត្តបុរស ហើយឋិតនៅ ។ គប្បីពង្រីកឲ្យពិស្ដារ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ ងាយយល់ទាំងអស់ហើយ ៕

# សុត្តន្តបិដក

## បិណ្ឌបាតបារិសុទ្ធិសូត្រទី ៩

[ ៣១២ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះសារីបុត្តមានអាយុ ចេញអំពីផលសមាបត្តិ ក្នុងវេលាសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តមានអាយុគង់នៅក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគ ក៏ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលសារីបុត្ត ឥន្ទ្រិយរបស់អ្នកជ្រះថ្លា សម្បុរស្បែករបស់អ្នកស្អាតផូរផង់ ម្នាលសារីបុត្ត ក្នុងកាលឥឡូវនេះ តើលោកច្រើនប្រព្រឹត្តទៅ ដោយវិហារធម៌ដូចម្តេច ។ ព្រះសារីបុត្តក្រាបបង្គំទូលថា បពិត្រព្រះអង្គ ក្នុងកាលឥឡូវនេះ ខ្ញុំព្រះអង្គ ច្រើនប្រព្រឹត្តទៅដោយសុញ្ញតាវិហារធម៌ ។

[ ៣១៣ ] ម្នាលសារីបុត្ត ប្រពៃណាស់ហើយៗ ម្នាលសារីបុត្រ បានឮថា ក្នុងកាលឥឡូវនេះ លោកច្រើនប្រព្រឹត្តទៅដោយវិហារធម៌ របស់មហាបុរស ម្នាលសារីបុត្រ ឯវិហារធម៌របស់មហាបុរស ក៏គឺសុញ្ញតាវិហារធម៌នេះឯង ។ ម្នាលសារីបុត្ត ព្រោះហេតុនោះ បើភិក្ខុក្នុងសាសនានេះ ប្រាថ្នាថា អាត្មាអញគួរតែប្រព្រឹត្តទៅ ច្រើនដោយសុញ្ញតាវិហារធម៌ ម្នាលសារីបុត្ត ភិក្ខុនោះគប្បីពិចារណាដូច្នេះថា អាត្មាអញបានចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត តាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងប្រទេសណាក្តី បាន

ត្រឡប់អំពីបិណ្ឌបាត ចេញអំពីស្រុកតាមផ្លូវណាក្តី តើក្នុងផ្លូវទាំងនោះ អាត្មាអញមានឆន្ទៈ គឺសេចក្តីពេញចិត្ត ឬរាគៈ គឺសេចក្តីត្រេក ទោសៈ គឺសេចក្តីប្រទូស្ត ឬមោហៈ គឺសេចក្តីវង្វេង ឬក៏បដិឃៈ គឺសេចក្តីថ្នាំងថ្នាក់នៃចិត្តក្នុងរូបដែលគប្បីដឹងបានដោយភ្នែកដែរឬទេ ។ ម្នាលសារីបុត្ត កាលបើភិក្ខុពិចារណាដឹងយ៉ាងនេះថា អាត្មាអញបានចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតតាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងប្រទេសណាក្តី បានត្រឡប់អំពីបិណ្ឌបាត ចេញអំពីស្រុកតាមផ្លូវណាក្តី ក្នុងផ្លូវទាំងនោះ អាត្មាអញមានឆន្ទៈ ឬរាគៈ ទោសៈ ឬមោហៈ ឬក៏បដិឃៈនៃចិត្ត ក្នុងរូបដែលគប្បីដឹងបានដោយភ្នែកដែរ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីលះបង់នូវអកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា អាត្មាអញបានចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត តាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងប្រទេសណាក្តី បានត្រឡប់អំពីបិណ្ឌបាត ចេញអំពីស្រុកតាមផ្លូវណាក្តី ក្នុងផ្លូវទាំងនោះ អាត្មាអញមិនមានឆន្ទៈ ឬរាគៈ ទោសៈ ឬមោហៈ ឬក៏បដិឃៈនៃចិត្ត ក្នុងរូបដែលគប្បីដឹងបានដោយភ្នែកទេ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃទាំងយប់ នៅដោយបីតិ និងបាមោជ្ជនោះឯង ។

[ ៣១៤ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា អាត្មាអញបានចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតតាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងប្រទេសណាក្តី បានត្រឡប់អំពីបិណ្ឌបាត ចេញអំពីស្រុកតាម

ផ្លូវណាក្តី តើផ្លូវទាំងនោះ អាត្មាអញមានឆន្ទៈ ឬរាគៈ ទោសៈ ឬមោហៈ ឬក៏បដិឃៈនៃចិត្ត ក្នុងសំឡេងដែលគប្បីដឹងបានដោយត្រចៀក ... ក្នុងក្លិនដែលគប្បីដឹងបានដោយច្រមុះ ... ក្នុងឱជារសដែលគប្បីដឹងបានដោយអណ្តាត ... ក្នុងផោដ្ឋព្វៈដែលគប្បីដឹងបានដោយកាយ ... ក្នុងធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្តដែរឬទេ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណាដឹងយ៉ាងនេះថា អាត្មាអញបានចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត តាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាត ក្នុងប្រទេសណាក្តី បានត្រឡប់អំពីបិណ្ឌបាត ចេញអំពីស្រុកតាមផ្លូវណាក្តី ក្នុងផ្លូវទាំងនោះ អាត្មាអញមានឆន្ទៈ ឬរាគៈ ទោសៈ ឬមោហៈ ឬក៏បដិឃៈនៃចិត្ត ក្នុងធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្តដែរ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីលះបង់អកុសលធម៌ដ៏លាមកទាំងនោះចេញ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា អាត្មាអញបានចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត តាមផ្លូវណាក្តី បានត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងប្រទេសណាក្តី បានត្រឡប់អំពីបិណ្ឌបាត ចេញអំពីស្រុកតាមផ្លូវណាក្តី ក្នុងផ្លូវទាំងនោះ អាត្មាអញ មិនមានឆន្ទៈ ឬរាគៈ ទោសៈ ឬមោហៈ ឬក៏បដិឃៈនៃចិត្តក្នុងធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្តទេ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ទាំងថ្ងៃទាំងយប់ ហើយនៅដោយបីតិ និងបាមោជ្ជនោះឯង ។

[ ៣១៥ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា កាមគុណ ៥ ប្រការ អាត្មាអញបានលះបង់ហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុ

ពិចារណា ដឹងយ៉ាងនេះថា កាមគុណ ៥ ប្រការ អាត្មាអញមិនទាន់បាន លះបង់ទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីលះបង់នូវកាមគុណ ទាំង ៥ ប្រការចេញ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញ ថា កាមគុណទាំង ៥ ប្រការ អាត្មាអញលះបង់ហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃ ទាំងយប់ នៅដោយបីតិ និង បាមោជ្ជនោះឯង ។

[ ៣១៦ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា នីវរណៈទាំង ៥ ប្រការ អាត្មាអញបានលះបង់ហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណាដឹងយ៉ាងនេះថា នីវរណៈទាំង ៥ ប្រការ អាត្មាអញមិន ទាន់បានលះបង់ទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីលះបង់នូវ នីវរណៈទាំង ៥ ប្រការចេញ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណា ដឹង យ៉ាងនេះវិញថា នីវរណៈទាំង ៥ ប្រការ អាត្មាអញបានលះបង់ហើយ ម្នាល សារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃ ទាំងយប់ នៅដោយ បីតិ និងបាមោជ្ជនោះឯង ។

[ ៣១៧ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា ឧបា-ទានក្ខន្ធទាំង ៥ ប្រការ អាត្មាអញកំណត់ដឹងហើយឬ ។ ម្នាលសារីបុត្ត បើ ភិក្ខុពិចារណាដឹងយ៉ាងនេះថា ឧបាទានក្ខន្ធទាំង ៥ ប្រការ អាត្មាអញមិន ទាន់កំណត់ដឹងទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីកំណត់ដឹងនូវ ឧបាទានក្ខន្ធទាំង ៥ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាង

នេះវិញថា ឧបាទានក្ខន្ធទាំង ៥ ប្រការ អាត្មាអញបានកំណត់ដឹងហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃ ទាំងយប់ នៅដោយបីតិ និងបាមោជ្ជនោះឯង ។

[ ៣១៨ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា សតិប្បដ្ឋានទាំង ៤ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណាដឹងយ៉ាងនេះថា សតិប្បដ្ឋានទាំង ៤ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាម ដើម្បីចម្រើននូវសតិប្បដ្ឋាន ៤ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា សតិប្បដ្ឋានទាំង ៤ ប្រការ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃ ទាំងយប់ នៅដោយបីតិ និងបាមោជ្ជនោះឯង ។

[ ៣១៩ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា សម្មប្បធានទាំង ៤ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណាដឹងយ៉ាងនេះថា សម្មប្បធានទាំង ៤ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីចម្រើននូវសម្មប្បធានទាំង ៤ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា សម្មប្បធានទាំង ៤ ប្រការ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃ ទាំងយប់ នៅដោយបីតិ និងបាមោជ្ជនោះឯង ។

[ ៣២០ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា ឥទ្ធិបាទទាំង ៤ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណាដឹងយ៉ាងនេះថា ឥទ្ធិបាទទាំង ៤ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីចម្រើននូវឥទ្ធិបាទទាំង ៤ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា ឥទ្ធិ-បាទទាំង ៤ ប្រការ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ទាំងថ្ងៃ ទាំងយប់ នៅដោយបីតិ និងបាមោជ្ជៈនោះឯង ។

[ ៣២១ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា ឥន្ទ្រិយទាំង ៥ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា ដឹងយ៉ាងនេះថា ឥន្ទ្រិយទាំង ៥ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះ គប្បីព្យាយាមដើម្បីចម្រើននូវឥន្ទ្រិយទាំង ៥ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា ឥន្ទ្រិយទាំង ៥ ប្រការ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះ ត្រូវសិក្សាក្នុងកុសលធម៌ទាំងថ្ងៃទាំងយប់ នៅដោយបីតិ និងបាមោជ្ជនោះឯង ។

[ ៣២២ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា ពលទាំង ៥ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណាដឹងយ៉ាងនេះថា ពលទាំង ៥ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះគប្បីព្យាយាមដើម្បីចម្រើននូវពលទាំង ៥ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា ពលទាំង ៥ ប្រការ

អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃ ទាំងយប់ នៅដោយបីតិ និងបាមោជ្ជនោះឯង ។

[ ៣២៣ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា ពោជ្ឈង្គទាំង ៧ ប្រការ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណាដឹងយ៉ាងនេះថា ពោជ្ឈង្គទាំង ៧ ប្រការ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះគប្បីព្យាយាមដើម្បីចម្រើននូវពោជ្ឈង្គទាំង ៧ ប្រការ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា ពោជ្ឈង្គទាំង ៧ ប្រការ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃ ទាំងយប់ នៅដោយបីតិ និងបាមោជ្ជនោះឯង ។

[ ៣២៤ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា អដ្ឋង្គិកមគ្គដ៏ប្រសើរ អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណាដឹងយ៉ាងនេះថា អដ្ឋង្គិកមគ្គដ៏ប្រសើរ អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះគប្បីព្យាយាមដើម្បីចម្រើននូវអដ្ឋង្គិកមគ្គដ៏ប្រសើរ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា អដ្ឋង្គិក-មគ្គដ៏ប្រសើរ អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃ ទាំងយប់ នៅដោយបីតិ និងបាមោជ្ជនោះឯង ។

[ ៣២៥ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា សមថៈ និងវិបស្សនា អាត្មាអញបានចម្រើនហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណា

*ដឹងយ៉ាងនេះថា សមថៈ និងវិបស្សនា អាត្មាអញមិនទាន់បានចម្រើនទេ ម្នាលសារីបុត្ត ភិក្ខុនោះគប្បីព្យាយាមដើម្បីចម្រើននូវសមថៈ និងវិបស្សនា ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា សមថៈ និងវិបស្សនា អាត្មាអញបានចម្រើនហើយ ម្នាលសារីបុត្ត ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃ ទាំងយប់ នៅដោយបីតិ និងបាមោជ្ជនោះឯង ។*

*[ ៣២៦ ] ម្នាលសារីបុត្ត មួយទៀត ភិក្ខុគប្បីពិចារណាដូច្នេះថា វិជ្ជា និងវិមុត្តិ អាត្មាអញបានធ្វើឲ្យជាក់ច្បាស់ហើយឬ ។ ម្នាលសារីបុត្ត បើភិក្ខុពិចារណាដឹងយ៉ាងនេះថា វិជ្ជា និងវិមុត្តិ អាត្មាអញមិនទាន់បានធ្វើឲ្យជាក់ច្បាស់ទេ ម្នាលសារីបុត្ត ភិក្ខុនោះគប្បីព្យាយាមដើម្បីធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា និងវិមុត្តិ ។ ម្នាលសារីបុត្ត តែបើភិក្ខុពិចារណាដឹងយ៉ាងនេះវិញថា វិជ្ជា និងវិមុត្តិ អាត្មាអញបានធ្វើជាក់ច្បាស់ហើយ ម្នាលសារីបុត្ត ភិក្ខុនោះត្រូវសិក្សាក្នុងកុសលធម៌ ទាំងថ្ងៃ ទាំងយប់ នៅដោយបីតិ និងបាមោជ្ជនោះឯង ។*

*[ ៣២៧ ] ម្នាលសារីបុត្ត បុគ្គលណាមួយ ជាសមណៈ ឬព្រាហ្មណ៍ក្នុងអតីតកាល កាលនឹងធ្វើបិណ្ឌបាតឲ្យបរិសុទ្ធ បុគ្គលទាំងអស់នោះ សុទ្ធតែបានពិចារណារឿយៗ ហើយធ្វើបិណ្ឌបាតឲ្យបរិសុទ្ធយ៉ាងនេះឯង ។ ម្នាលសារីបុត្ត បុគ្គលណាមួយ ជាសមណៈ ឬព្រាហ្មណ៍ ក្នុងអនាគតកាល កាលនឹងធ្វើបិណ្ឌបាតឲ្យបរិសុទ្ធ បុគ្គលទាំងអស់នោះ នឹងពិចារណារឿយៗ ហើយធ្វើបិណ្ឌបាតឲ្យបរិសុទ្ធយ៉ាងនេះឯង ។ ម្នាលសារីបុត្ត បុគ្គលណាមួយ ជាសមណៈ ឬព្រាហ្មណ៍ក្នុងកាលឥឡូវនេះ កាលនឹងធ្វើបិណ្ឌបាតឲ្យបរិសុទ្ធ*

បុគ្គលទាំងអស់នោះ តែងពិចារណារឿយៗ ហើយធ្វើបិណ្ឌបាតឲ្យបរិសុទ្ធ យ៉ាងនេះឯង ។ ម្នាលសារីបុត្ត ព្រោះហេតុនោះ អ្នកទាំងឡាយត្រូវសិក្សា ក្នុងសាសនានេះថា យើងទាំងឡាយនឹងពិចារណារឿយៗ ហើយធ្វើបិណ្ឌបាត ឲ្យបរិសុទ្ធដូច្នេះ ម្នាលសារីបុត្ត អ្នកទាំងឡាយត្រូវតែសិក្សាយ៉ាងនេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះសារីបុត្តមាន អាយុ មានសេចក្តីត្រេកអរ រីករាយចំពោះភាសិតរបស់ព្រះមានព្រះភាគ ។

## បិណ្ឌបាតបារិសុទ្ធិសូត្រទី ៩ ចប់

# អដ្ឋកថា

## បិណ្ឌបាតបារិសុទ្ធិសូត្រ

[ ៣១២ ] បិណ្ឌបាតបារិសុទ្ធិសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ បទថា **បដិសល្លានា** គឺចេញអំពីផលសមាបត្តិ ។ បទថា **វិប្បសន្នានិ** លោកពោលដោយអំណាចឱកាស ពិតហើយ ភិក្ខុដែលចេញអំពីផលសមាបត្តិ មានឱកាសដែលបសាទទាំង ៥ តាំងនៅផូរផង់ ពណ៌សម្បុរក៏បរិសុទ្ធ ព្រោះដូច្នោះ ទើបលោកពោលយ៉ាងនោះ ។ បទថា **សុញ្ញតវិហារេន** គឺដោយធម៌ជាគ្រឿងនៅ គឺផលសមាបត្តិដែលមានសុញ្ញតៈជាអារម្មណ៍ ។

[ ៣១៣ ] បទថា **មហាបុរិសវិហារោ** បានដល់ វិហារធម៌របស់ព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ និងព្រះមហាសាវករបស់ព្រះតថាគត ដែលជាមហាបុរស ។ ក្នុងបទជាដើមថា **យេនចាហំ មគ្គេន** បានដល់ ជួនកាលផ្តើមតាំងអំពីសសរវត្ត ទៅរហូតដល់សសរខឿននៃស្រុក នេះឈ្មោះថា ផ្លូវចូល ។ បទេសដែលគេចូលទៅខាងក្នុងស្រុក ត្រាច់ទៅតាមលំដាប់ផ្ទះ រហូតដល់ផ្លូវចេញពីក្រុង នេះឈ្មោះថា បទេសដែលគប្បីត្រាច់ទៅ ។ តាំងអំពីក្រៅសសរខឿនរហូតមកដល់វត្ត នេះឈ្មោះថា ផ្លូវមក ។ បទថា **បដិឃំ វាបិ ចេតសោ** សេចក្តីថា អ្វីមួយដែលកើតអំពីកិលេសដែលជាហេតុឲ្យថ្នាំងថ្នាក់ចិត្ត មាន ឬមិនមាន ។ បទថា **អហោរត្តានុសិក្ខិនា** គឺបុគ្គលតាមសិក្សាអស់ថ្ងៃ និងយប់ ។

[ ៣១៥ ] ក្នុងបទជាដើមថា **បហីនា នុ ខោ មេ បញ្ច កាមគុណា** សេចក្តីថា ការពិចារណានៃភិក្ខុមួយរូប ក៏បែកចេញពីគ្នាទៅ ។ ការពិចារណារបស់ភិក្ខុដទៃៗ ក៏មិនដូចគ្នា ។ សេចក្តីនេះដូចម្តេច ។ ពិតហើយ ភិក្ខុមួយរូប ត្រឡប់មកអំពីបិណ្ឌបាតក្នុងបច្ឆាភត្ត ទុកដាក់បាត្រ ចីវរ មកអង្គុយក្នុងឱកាសដ៏ស្ងាត់ ហើយពិចារណាថា អញបានលះកាមគុណ ៥ ហើយឬហ្ន៎ ។ គប្បីជ្រាបថា មិនទាន់លះបាន ទើបផ្គងសេចក្តីព្យាយាមដករាគៈ ដែលទាក់ទងនឹងកាមគុណ ៥ ដោយអនាគាមិមគ្គ ចេញអំពីនោះហើយ ក៏ពិចារណាផលបន្ទាប់អំពីមគ្គ ពិចារណាមគ្គបន្ទាប់អំពីផល ដឹងល្អថា លះបានហើយ ។ សូម្បីក្នុងនីវរណៈជាដើម ក៏ន័យដូចគ្នានេះឯង ។ តែការលះនីវរណៈទាំងនេះជាដើម រមែងមានដោយអរហត្តមគ្គ ។ ការពិចារណាផ្សេងៗ នៃភិក្ខុមួយរូបរមែងមានដោយវិធីនេះ ។ សម្រាប់ក្នុងការពិចារណាទាំងនេះ ភិក្ខុរូបដទៃរមែងពិចារណាគោលសម្រាប់ពិចារណាម្យ៉ាង ភិក្ខុរូបដទៃទៀត ក៏ពិចារណាម្យ៉ាង ដូចពោលមកនេះ ។ ការពិចារណាផ្សេងៗ របស់ភិក្ខុច្រើនរូប រមែងមានដោយប្រការដូច្នេះ ។ ពាក្យដ៏សេសក្នុងទីគ្រប់អន្លើ ងាយយល់ទាំងអស់ហើយ ។៚

**អដ្ឋកថា បិណ្ឌបាតបារិសុទ្ធិសូត្រ ចប់**

**សូត្រទី ៩ ចប់**

# សុត្តន្តបិដក

## ឥន្ទ្រិយភាវនាសូត្រទី ១០

[ ៣២៨ ] ខ្ញុំបានស្តាប់យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងព្រៃឫស្សី ជិតកជង្គលនិគម ។ គ្រានោះឯង ឧត្តរមាណព ជាកូនសិស្សរបស់បារាសិរិយព្រាហ្មណ៍ បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏រីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររឭកហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។

[ ៣២៩ ] លុះឧត្តរមាណពជាកូនសិស្ស របស់បារាសិរិយព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគត្រាស់សួរដូច្នេះថា ម្នាលឧត្តរៈ បារាសិរិយព្រាហ្មណ៍ តែងសម្តែងវិធីចម្រើនឥន្ទ្រិយរបស់សាវកទាំងឡាយមែនឬ ។ ឧត្តរមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន បារាសិរិយព្រាហ្មណ៍ តែងសម្តែងវិធីចម្រើនឥន្ទ្រិយរបស់សាវកទាំងឡាយមែន ។ ព្រះអង្គត្រាស់សួរថា ម្នាលឧត្តរៈ ចុះបារាសិរិយព្រាហ្មណ៍តែងសម្តែងវិធីចម្រើនឥន្ទ្រិយរបស់សាវកទាំងឡាយ តើដូចម្តេច ។ បពិត្រព្រះគោតមដ៏ចម្រើន បារាសិរិយព្រាហ្មណ៍សម្តែងថា បុគ្គលក្នុងលោកនេះ កុំមើលរូបដោយភ្នែក កុំស្តាប់សំឡេងដោយត្រចៀក បពិត្រព្រះគោតមដ៏ចម្រើន ឯបារាសិរិយព្រាហ្មណ៍ តែងសម្តែងនូវវិធីចម្រើនឥន្ទ្រិយរបស់សាវកទាំងឡាយយ៉ាងនេះឯង ។ ឱឧត្តរៈ កាលបើយ៉ាងនេះ បុគ្គលខ្វាក់នឹងបាននាមថា ជាអ្នកចម្រើនឥន្ទ្រិយហើយ បុគ្គលថ្លង់នឹងបាននាមថា ជាអ្នកចម្រើនឥន្ទ្រិយហើយ ទើប

សមនឹងពាក្យរបស់បារាសិរិយព្រាហ្មណ៍ ម្នាលឧត្តរៈ ព្រោះថា បុគ្គលខ្វាក់ មិនឃើញរូបដោយភ្នែកទេ បុគ្គលថ្លង់មិនឮសំឡេងដោយត្រចៀកទេ ។ កាល ព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ឧត្តរមាណពជាកូនសិស្សបារា- សិរិយព្រាហ្មណ៍ ក៏អង្គុយនៅស្ងៀម អៀនអន់ ឱន-ក ដាក់មុខជ្រប់ មិន និយាយ ។

[ ៣៣០ ] គ្រានោះឯង ព្រះមានព្រះភាគទ្រង់ជ្រាបថា ឧត្តរមាណពជា សិស្សរបស់បារាសិរិយព្រាហ្មណ៍ អង្គុយនៅស្ងៀម អៀនអន់ ឱន-ក ដាក់ មុខជ្រប់ មិននិយាយហើយ ទើបត្រាស់ហៅព្រះអានន្ទមានអាយុថា ម្នាល អានន្ទ បារាសិរិយព្រាហ្មណ៍ តែងសម្ដែងនូវវិធីចម្រើនឥន្ទ្រិយរបស់សាវក ទាំងឡាយផ្សេង ចំណែកការចម្រើនឥន្ទ្រិយដ៏ប្រសើរ ក្នុងវិន័យរបស់ព្រះ អរិយៈផ្សេង ។ ព្រះអានន្ទក្រាបបង្គំទូលថា ព្រះមានព្រះភាគគប្បីសម្ដែង នូវវិធីចម្រើនឥន្ទ្រិយដ៏ប្រសើរណា ក្នុងវិន័យរបស់ព្រះអរិយៈ បពិត្រព្រះ មានព្រះភាគ កាលនេះ ជាកាលគួរនឹងសម្ដែងនូវវិធីចម្រើនឥន្ទ្រិយនុ៎ះ បពិត្រ ព្រះសុគត កាលនេះ ជាកាលគួរនឹងសម្ដែងនូវវិធីចម្រើនឥន្ទ្រិយនុ៎ះ ភិក្ខុទាំង- ឡាយ បានស្ដាប់ព្រះពុទ្ធដីការបស់ព្រះអង្គហើយ នឹងចងចាំបាន ។ ព្រះអង្គ ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរស្ដាប់ ចូរធ្វើទុកក្នុងចិត្តឲ្យប្រពៃចុះ តថាគតនឹងសម្ដែង ។ ព្រះអានន្ទមានអាយុ ក៏ទទួលព្រះបន្ទូលនៃព្រះមាន ព្រះភាគថា ព្រះករុណា ព្រះអង្គ ។

[ ៣៣១ ] ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរដូច្នេះថា ម្នាលអានន្ទ ចុះការ

បម្រើនឥន្ទ្រិយដ៏ប្រសើរក្នុងវិន័យរបស់ព្រះអរិយៈ តើដូចម្តេច ។ ទ្រង់ឆ្លើយដោយព្រះអង្គឯងថា ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះ កើតឡើងព្រោះឃើញរូបដោយភ្នែក ។ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា អាត្មាអញមានសេចក្តីគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះនេះកើតឡើងហើយ ឯវិបស្សនូបេក្ខាដ៏ល្អិត ដ៏ឧត្តមក៏កើតឡើង ព្រោះអាស្រ័យសេចក្តីគាប់ចិត្តជាដើម ដែលជារបស់មានបច្ច័យតាក់តែង ជារបស់គ្រោតគ្រាតនោះឯង ។ លុះភិក្ខុនោះ មានសេចក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះនោះកើតឡើងហើយ រលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើង ។ ម្នាលអានន្ទ បុរសមានភ្នែកភ្លឺបើកហើយបិទវិញ ឬបិទហើយបើកវិញ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ បុគ្គលណាមួយមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើងហើយរលត់ទៅវិញ ឯវិបស្សនូបេក្ខាក៏តាំងឡើងដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមានសេចក្តីលំបាកយ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង ម្នាលអានន្ទ នេះឯងតថាគតហៅថាការបម្រើននូវឥន្ទ្រិយដ៏ប្រសើរ ក្នុងរូបដែលគប្បីដឹងបានដោយភ្នែក ក្នុងវិន័យរបស់ព្រះអរិយៈ ។

[ ៣៣២ ] ម្នាលអានន្ទ មួយទៀត ភិក្ខុមានសេចក្តីគាប់ចិត្តកើតឡើង

មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើង ព្រោះស្តាប់សំឡេងដោយត្រចៀក ។ ភិក្ខុនោះ ដឹងច្បាស់យ៉ាងនេះថា អាត្មាអញមានសេចក្តីគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើងហើយ ឯវិបស្សនូបេក្ខាដ៏ល្អិត ដ៏ឧត្តមក៏កើតឡើង ព្រោះអាស្រ័យសេចក្តីគាប់ចិត្តជាដើម ដែលជារបស់មានបច្ច័យតាក់តែង ជារបស់គ្រោតគ្រាតនោះឯង ។ លុះភិក្ខុនោះមានសេចក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះនោះកើតឡើងហើយ រលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើង ។ ម្នាលអានន្ទ បុរសមានកម្លាំង ទះម្រាមដៃដោយមិនលំបាក យ៉ាងណាមិញ ម្នាលអានន្ទ បុគ្គលណាមួយមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើងហើយ រលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើង ដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមានសេចក្តីលំបាកយ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង ម្នាលអានន្ទ នេះឯង តថាគតហៅថា ការចម្រើនឥន្ទ្រិយដ៏ប្រសើរក្នុងសំឡេង ដែលគប្បីដឹងបានដោយត្រចៀក ក្នុងវិន័យរបស់ព្រះអរិយៈ ។

[ ៣៣៣ ] ម្នាលអានន្ទ មួយទៀត ភិក្ខុមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើង ព្រោះធុំក្លិនដោយច្រមុះ ។ ភិក្ខុនោះ រមែងដឹងច្បាស់យ៉ាងនេះថា អាត្មា

អញមានសេចក្តីគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះនេះកើតឡើងហើយ ឯវិបស្សនូបេក្ខាដ៏ល្អិត ដ៏ឧត្តមក៏កើតឡើង ព្រោះអាស្រ័យសេចក្តីគាប់ចិត្ត ជាដើម ដែលជារបស់មានបច្ច័យតាក់តែង ជារបស់គ្រោតគ្រាតនោះឯង ។ លុះភិក្ខុនោះមានសេចក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះនោះកើតឡើងហើយ រលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើង ។ ម្នាលអានន្ទ តំណក់ទឹករមៀលលើស្លឹកឈូកដែលផ្អៀងបន្តិច រមែងមិនជក់នៅ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ បុគ្គលណាមួយ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើងហើយ រលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើងដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមានសេចក្តីលំបាកយ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង ម្នាលអានន្ទ នេះឯង តថាគតហៅថា ការចម្រើនឥន្ទ្រិយដ៏ប្រសើរ ក្នុងក្ខិនដែលគប្បីដឹងបានដោយប្រមុះ ក្នុងវិន័យរបស់ព្រះអរិយៈ ។

[ ៣៣៤ ] ម្នាលអានន្ទ មួយទៀត ភិក្ខុមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ សេចក្តីមិនគាប់ចិត្តខ្លះកើតឡើង ព្រោះទទួលរសដោយអណ្តាត ។ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា អាត្មាអញមានសេចក្តីគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះនេះកើត

ឡើងហើយ ឯវិបស្សនូបេក្ខាដ៏ល្អិត ដ៏ឧត្តមក៏កើតឡើង ព្រោះអាស្រ័យសេចក្តីគាប់ចិត្តជាដើម ដែលជារបស់មានបច្ច័យតាក់តែង ជារបស់គ្រោតគ្រាតនោះឯង ។ លុះភិក្ខុនោះមានសេចក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មានសេចក្តីគាប់ចិត្តខ្វះ មិនគាប់ចិត្តខ្វះនោះកើតឡើងហើយ រលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើង ។ ម្នាលអានន្ទ បុរសមានកម្លាំងប្រមូលដុំទឹកមាត់មកលើចុងអណ្តាត ហើយស្តោះដោយមិនលំបាក មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ បុគ្គលណាមួយមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្វះ មិនគាប់ចិត្តខ្វះកើតឡើងហើយ រលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើងដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមានលំបាកយ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង ម្នាលអានន្ទ នេះឯង តថាគតហៅថា ការចម្រើនឥន្ទ្រិយដ៏ប្រសើរក្នុងរសដែលគប្បីដឹងបានដោយអណ្តាត ក្នុងវិន័យរបស់ព្រះអរិយៈ ។

[ ៣៣៥ ] ម្នាលអានន្ទ មួយទៀត ភិក្ខុមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្វះ មិនគាប់ចិត្តខ្វះកើតឡើង ព្រោះពាល់ត្រូវនូវផោដ្ឋព្វៈដោយកាយ ។ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា អាត្មាអញមានសេចក្តីគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្តខ្វះ មិនគាប់ចិត្តខ្វះនេះកើតឡើងហើយ ឯវិបស្សនូបេក្ខាដ៏ល្អិត ដ៏ឧត្តមក៏កើតឡើង ព្រោះអាស្រ័យសេចក្តីគាប់ចិត្តជាដើម ដែលជារបស់មានបច្ច័យតាក់តែង ជារបស់គ្រោតគ្រាតនោះ

ឯង ។ លុះភិក្ខុនោះមានសេចក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះនោះកើតឡើងហើយ រលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើង ។ ម្នាលអានន្ទ បុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ចូលដៃដែលលាចេញ មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ បុគ្គលណាមួយមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើងហើយ រលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើងដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមានសេចក្តីលំបាកយ៉ាងនេះ ក៏មានឧបមេយ្យយ៉ាងនោះឯង ម្នាលអានន្ទ នេះឯង តថាគតហៅថា ការចម្រើនឥន្ទ្រិយដ៏ប្រសើរ ក្នុងផោដ្ឋព្វៈ ដែលគប្បីដឹងបានដោយកាយ ក្នុងវិន័យរបស់ព្រះអរិយៈ ។

[ ៣៣៦ ] ម្នាលអានន្ទ មួយវិញទៀត ភិក្ខុមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើង ព្រោះដឹងធម្មារម្មណ៍ដោយចិត្ត ។ ភិក្ខុនោះដឹងច្បាស់យ៉ាងនេះថា អាត្មាអញមានសេចក្តីគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីមិនគាប់ចិត្តនេះកើតឡើងហើយ មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះនេះកើតឡើងហើយ ឯវិបស្សនូបេក្ខាដ៏ល្អិត ដ៏ឧត្តមក៏កើតឡើង ព្រោះអាស្រ័យសេចក្តីគាប់ចិត្តជាដើម ដែលជារបស់មានបច្ច័យតាក់តែង ជារបស់គ្រោតគ្រាតនោះឯង ។ លុះភិក្ខុនោះមានសេចក្តីគាប់ចិត្តនោះកើតឡើង មានសេចក្តីមិនគាប់ចិត្តនោះកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះនោះកើតឡើងហើយ រលត់ទៅ

វិញ វិបស្សនូបេក្ខាក៏តាំងឡើង ។ ម្នាលអានន្ទ បុរសមានកម្លាំង សម្រក់នូវតំណក់ទឹក ២ តំណក់ ឬ ៣ តំណក់ទៅក្នុងខ្ទះដែកដ៏ក្តៅអស់ ១ ថ្ងៃ ម្នាលអានន្ទ ការសម្រក់នូវតំណក់ទឹកទាំងឡាយយឺតយូរ ឯទឹកនោះក៏ដល់នូវការអស់ទៅ ស្ងួតទៅដោយឆាប់រហ័ស មានឧបមាយ៉ាងណាមិញ ម្នាលអានន្ទ បុគ្គលណាមួយ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះនោះកើតឡើងហើយ រលត់ទៅវិញ វិបស្សនូបេក្ខាក៏តាំងឡើងដោយឆាប់យ៉ាងនេះ រហ័សយ៉ាងនេះ មិនមានសេចក្តីលំបាកយ៉ាងនេះ ក៏មានឧមេយ្យយ៉ាងនោះឯង ម្នាលអានន្ទ នេះឯងតថាគតហៅថា ការចម្រើនឥន្ទ្រិយ ក្នុងធម្មារម្មណ៍ដែលគប្បីដឹងបានដោយចិត្ត ក្នុងវិន័យរបស់ព្រះអរិយៈ ។ ម្នាលអានន្ទ ការចម្រើនឥន្ទ្រិយដ៏ប្រសើរក្នុងវិន័យ របស់ព្រះអរិយៈយ៉ាងនេះឯង ។

[ ៣៣៧ ] ម្នាលអានន្ទ បុគ្គលដែលឈ្មោះថា សេក្ខៈ ជាអ្នកមានបដិបទាតើដូចម្តេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើង ព្រោះឃើញរូបដោយភ្នែក ។ ភិក្ខុនោះក៏នឿយណាយធុញទ្រាន់ខ្ពើមរអើមដោយសេចក្តីគាប់ចិត្តដែលកើតឡើង ដោយសេចក្តីមិនគាប់ចិត្តដែលកើតឡើង ដោយសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះដែលកើតឡើងនោះ ។ ភិក្ខុមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើង ព្រោះឮសំឡេងដោយត្រចៀក ...

ព្រោះធុំក្លិនដោយច្រមុះ ... ព្រោះទទួលរសដោយអណ្ដាត ... ព្រោះពាល់ត្រូវផោដ្ឋព្វៈដោយកាយ ... ព្រោះដឹងធម្មារម្មណ៍ដោយចិត្ត ។ ភិក្ខុនោះ ក៏នឿយណាយធុញទ្រាន់ ខ្ពើមរអើមដោយសេចក្ដីគាប់ចិត្ត ដែលកើតដោយសេចក្ដីមិនគាប់ចិត្ត ដែលកើតឡើង ដោយសេចក្ដីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះ ដែលកើតឡើងនោះ ។ ម្នាលអានន្ទ បុគ្គលដែលឈ្មោះថា សេក្ខៈ ជាអ្នកមានបដិបទា យ៉ាងនេះឯង ។

[ ៣៣៨ ] ម្នាលអានន្ទ បុគ្គលដែលឈ្មោះថា អរិយៈ មានឥន្ទ្រិយចម្រើនហើយ តើដូចម្ដេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ មានសេចក្ដីគាប់ចិត្តកើតឡើង មានសេចក្ដីមិនគាប់ចិត្តកើតឡើង មានសេចក្ដីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើង ព្រោះឃើញរូបដោយភ្នែក ។ បើភិក្ខុនោះប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសម្គាល់ក្នុងរបស់គួរខ្ពើម ថាជារបស់មិនគួរខ្ពើមដូច្នេះហើយក៏សម្គាល់ថាជារបស់មិនគួរខ្ពើម ក្នុងរបស់ដែលគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញជាអ្នកសម្គាល់ក្នុងរបស់មិនគួរខ្ពើម ថាជារបស់គួរខ្ពើមដូច្នេះហើយ ក៏សម្គាល់ថាជារបស់គួរខ្ពើម ក្នុងរបស់ដែលមិនគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញជាអ្នកសម្គាល់ក្នុងរបស់គួរខ្ពើមផង មិនគួរខ្ពើមផង ថាជារបស់មិនគួរខ្ពើម ដូច្នេះហើយ ក៏សម្គាល់ថាជារបស់មិនគួរខ្ពើម ក្នុងរបស់ដែលគួរខ្ពើម និងមិនគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសម្គាល់ក្នុងរបស់មិនគួរខ្ពើមផង គួរខ្ពើមផង ថាជារបស់គួរខ្ពើម ដូច្នេះហើយ ក៏សម្គាល់ថាជារបស់គួរខ្ពើម ក្នុងរបស់ដែលមិនគួរខ្ពើម និងគួរខ្ពើមនោះ ។

បើប្រាថ្នាថា អាត្មាអញគួរវៀរចេញនូវរបស់ទាំងពីរ គឺរបស់គួរខ្ពើម និងមិនគួរខ្ពើម ជាអ្នកព្រងើយកន្តើយ មានស្មារតីដឹងសព្វ ដូច្នេះហើយ ក៏ជាអ្នកព្រងើយកន្តើយ មានស្មារតីដឹងសព្វ ក្នុងរបស់ទាំងពីរនោះ ។

[ ៣៣៩ ] ម្នាលអានន្ទ មួយវិញទៀត ភិក្ខុមានសេចក្តីគាប់ចិត្តកើតឡើង មានសេចក្តីមិនគាប់ចិត្តកើតឡើង មានសេចក្តីគាប់ចិត្តខ្លះ មិនគាប់ចិត្តខ្លះកើតឡើង ព្រោះឮសំឡេងដោយត្រចៀក ... ព្រោះធុំក្លិនដោយច្រមុះ ... ព្រោះទទួលរសដោយអណ្តាត ... ព្រោះពាល់ត្រូវផោដ្ឋព្វៈដោយកាយ ... ព្រោះដឹងធម្មារម្មណ៍ដោយចិត្ត ។ បើភិក្ខុនោះប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសម្គាល់ក្នុងរបស់គួរខ្ពើម ថាជារបស់មិនគួរខ្ពើម ដូច្នេះហើយ ក៏សម្គាល់ថាជារបស់មិនគួរខ្ពើម ក្នុងរបស់ដែលមិនគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញជាអ្នកសម្គាល់ក្នុងរបស់មិនគួរខ្ពើម ថាជារបស់គួរខ្ពើម ដូច្នេះហើយ ក៏សម្គាល់ថាជារបស់គួរខ្ពើម ក្នុងរបស់ដែលមិនគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញជាអ្នកសម្គាល់ក្នុងរបស់គួរខ្ពើមផង មិនគួរខ្ពើមផង ថាជារបស់មិនគួរខ្ពើម ដូច្នេះហើយ ក៏សម្គាល់ថាជារបស់មិនគួរខ្ពើម ក្នុងរបស់ដែលគួរខ្ពើម និងមិនគួរខ្ពើមនោះ។ បើប្រាថ្នាថា អាត្មាអញគប្បីជាអ្នកសម្គាល់ក្នុងរបស់មិនគួរខ្ពើមផង គួរខ្ពើមផង ថាជារបស់គួរខ្ពើម ដូច្នេះហើយ ក៏សម្គាល់ថាជារបស់គួរខ្ពើម ក្នុងរបស់ដែលមិនគួរខ្ពើម និងគួរខ្ពើមនោះ ។ បើប្រាថ្នាថា អាត្មាអញគួរជាអ្នកវៀរស្រឡះនូវរបស់ទាំងពីរ គឺរបស់គួរខ្ពើម និងរបស់មិនគួរខ្ពើម ជាអ្នកព្រងើយកន្តើយ មានស្មារតីដឹងសព្វ ដូច្នេះហើយ ក៏ជាអ្នកព្រងើយ

កន្ទើយ មានស្មារតីដឹងសព្វ ក្នុងរបស់ទាំងពីរនោះ ។ ម្នាលអានន្ទ បុគ្គលដែលឈ្មោះថា អរិយៈ មានឥន្ទ្រិយចម្រើនហើយ យ៉ាងនេះឯង ។

[ ៣៨០ ] ម្នាលអានន្ទ ការចម្រើននូវឥន្ទ្រិយដ៏ប្រសើរក្នុងវិន័យរបស់ព្រះអរិយៈ តថាគតបានសម្តែងហើយ បុគ្គលដែលឈ្មោះថា សេក្ខៈ ប្រកបដោយបដិបទា តថាគតបានសម្តែងហើយ បុគ្គលដែលឈ្មោះថា អរិយៈ មានឥន្ទ្រិយចម្រើនហើយ តថាគតក៏បានសម្តែងហើយ ដោយប្រការដូច្នេះឯង ម្នាលអានន្ទ កិច្ចណាដែលព្រះសាស្តា ជាអ្នកស្វែងរកនូវប្រយោជន៍ ជាអ្នកអនុគ្រោះដល់សាវកទាំងឡាយ គប្បីធ្វើព្រោះអាស្រ័យសេចក្តីអនុគ្រោះ កិច្ចនោះ តថាគតបានធ្វើហើយ ដល់អ្នកទាំងឡាយ ម្នាលអានន្ទ ទុំរុក្ខមូល ទុំសុញ្ញាគារ ម្នាលអានន្ទ អ្នកទាំងឡាយចូរពិនិត្យមើលចុះ ចូរកុំប្រមាទ កុំមានសេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ នេះហើយ ជាពាក្យប្រៀនប្រដៅរបស់តថាគតចំពោះអ្នកទាំងឡាយ ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះសូត្រនេះចប់ហើយ ព្រះអានន្ទមានអាយុ មានសេចក្តីត្រេកអររីករាយចំពោះភាសិតព្រះមានព្រះភាគ ។

ឥន្ទ្រិយភាវនាសូត្រទី ១០ ចប់

សឡាយតនវគ្គទី ៥ ចប់

## ឧទ្ទាននៃសឡាយតនវគ្គនោះ គឺ

អនាថបិណ្ឌិកោវាទសូត្រ ១ ឆន្នោវាទសូត្រ ១ បុណ្ណោវាទសូត្រ ១ នន្ទកោវាទសូត្រ ១ ចូឡរាហុលោវាទសូត្រ ១ ឆឆក្កសូត្រ ១ សឡាយតនវិភង្គសូត្រ ១ នគរវិន្ទេយ្យសូត្រ ១ បិណ្ឌបាតបារិសុទ្ធិសូត្រ ១ ឥន្ទ្រិយភាវនាសូត្រ ១ ( នេះ ) ជាវគ្គទី ៥ ខាងចុងបំផុត ។

## ឧបរិបណ្ណាសក ចប់

# អដ្ឋកថា

## ឥន្ទ្រិយភាវនាសូត្រ

[ ៣២៨ ] ឥន្ទ្រិយភាវនាសូត្រ មានពាក្យផ្តើមថា **ឯវម្មេ សុតំ** ដូច្នេះជាដើម ។ ក្នុងព្រះសូត្រនោះ បទថា **គជង្គលាយំ** គឺក្នុងខេត្តមានឈ្មោះយ៉ាងនោះ ។ បទថា **សុវេឡុវនេ** បានដល់ ដើមឈើមួយប្រភេទ ឈ្មោះវេឡុ គឺដើមឫស្សី ។ មានព្រៃធំដែលដើមឫស្សីទាំងនោះគ្របដណ្តប់ហើយ ព្រះមានព្រះភាគគង់នៅក្នុងដងព្រៃនោះ ។

[ ៣២៩ ] បទថា **ចក្ខុនា រូបំ ន បស្សតិ សោតេន សទ្ទំ ន សុណាតិ** លោកអធិប្បាយថា ព្រះមានព្រះភាគទ្រង់សម្តែងយ៉ាងនេះថា មិនគប្បីមើលរូបដោយភ្នែក មិនគប្បីស្តាប់សំឡេងដោយត្រចៀក ។

[ ៣៣០ ] ព្រះមានព្រះភាគ កាលទ្រង់សម្តែងការអប់រំឥន្ទ្រិយ ដែលមិនដូចក្នុងសាសនារបស់ព្រះអង្គ ទើបទ្រង់បានធ្វើសេចក្តីអាល័យ ដោយបទនេះថា **អញ្ញថា ច អរិយស្ស វិនយេ** ។ ព្រះអានន្ទគិតថា ព្រះសាស្តាទ្រង់សម្តែងអាល័យ ណ្ហើយចុះ អញនឹងអារាធនាធ្វើពាក្យដែលទាក់ទងនឹងការអប់រំឥន្ទ្រិយដល់ពួកភិក្ខុក្នុងបរិស័ទនេះហើយ កាលនឹងទូលអារាធនាព្រះសាស្តា ទើបបានពោលពាក្យជាថា **ឯតស្ស ភគវា** ជាដើម ។ លំដាប់នោះ កាលព្រះមានព្រះភាគ ទ្រង់សម្តែងការអប់រំឥន្ទ្រិយដល់លោក ទើបត្រាស់ពាក្យជាដើមថា **តេនហានន្ទ** ។

[ ៣៣១-៣៣៣ ] ក្នុងព្រះសូត្រនោះ បទថា **យទិទំ ឧបេក្ខា** គឺឈ្មោះ

ថា វិបស្សនូបេក្ខាណា វិបស្សនូបេក្ខានោះស្ងប់រម្ងាប់ វិបស្សនូបេក្ខានេះ ប្រណីត អធិប្បាយថា មិនធ្វើឲ្យក្តៅក្រហាយ ។ ភិក្ខុនេះមិនឲ្យចិត្តពេញចិត្ត ក្នុងអារម្មណ៍ដែលគួរប្រាថ្នា ក្នុងរូបារម្មណ៍ ក្នុងចក្ខុទ្វារ មិនពេញចិត្តក្នុង អារម្មណ៍ដែលមិនគួរប្រាថ្នា និងពេញចិត្ត មិនពេញចិត្តក្នុងអារម្មណ៍ជា កណ្តាល កាលមិនឲ្យតម្រេក មិនឲ្យប្រទូស្ត មិនឲ្យវង្វេងដល់ចិត្តនោះ កំណត់យកហើយ តាំងវិបស្សនាក្នុងភាពជាកណ្តាល ។ បទថា **ចក្ខុមា** គឺមានចក្ខុបរិបូណ៌ មានចក្ខុបរិសុទ្ធ ។ ពិតហើយ អ្នកឈឺភ្នែក ទោះបើក ឬបិទភ្នែកទៅខាងលើមិនបាន ។ ព្រោះដូច្នោះ ទើបមិនកាន់យកបុគ្គលនោះ ។ បទថា **ឡៀសកាំចោណោ** គឺអើតឡើង តាំងនៅ ដូចចន្ទោលរថ ។

[ ៣៣៨ ] ក្នុងបទថា **បដិក្កូលេ អប្បដិក្កូលសញ្ញី** ជាដើម ដោយ ការផ្សាយមេត្តា ឬដោយការយកធាតុមកប្រៀបធៀបគ្នា ក្នុងវត្ថុដែលគួរខ្ពើម ឈ្មោះថា មានការសម្គាល់ថា មិនគួរខ្ពើមបាន ។ ដោយការផ្សាយនូវការ មិនស្អាត ឬដោយការបង្អោនចូលទៅ ដោយភាពជារបស់មិនទៀង ក្នុងវត្ថុ ដែលមិនគួរខ្ពើម ក៏ជាអ្នកមានសេចក្តីសម្គាល់ថា គួរខ្ពើមបាន ។ សូម្បីក្នុង បទដ៏សេសក៏ន័យនេះឯង ។ កាលវៀរវត្ថុទាំង ២ ចំណែកនោះបានជា សមុច្ឆេទហើយ ជាអ្នកដាក់ខ្លួនជាកណ្តាល ប្រាថ្នាដើម្បីនឹងនៅធ្វើអ្វី ។ កាល វត្ថុគួរប្រាថ្នា និងវត្ថុមិនគួរប្រាថ្នាមកកាន់គន្លង ក៏នឹងក្លាយជាអ្នកមិនត្រេកអរ មិនប្រទូស្ត ។ សមដូចព្រះពុទ្ធតម្រាស់ដែលត្រាស់ថា

ភិក្ខុដែលមានសេចក្តីសម្គាល់ក្នុងវត្ថុដែលគួរខ្ពើម ថាមិនគួរខ្ពើមដូចម្តេច

គឺភិក្ខុរមែងផ្សាយមេត្តា ឬបង្អោនចូលទៅ ថាជាធាតុ ក្នុងវត្ថុដែលមិនគួរប្រាថ្នា ភិក្ខុរមែងជាអ្នកមានសេចក្តីសម្គាល់ក្នុងវត្ថុដែលគួរខ្ពើមថា មិនគួរខ្ពើម យ៉ាងនេះ ។ ភិក្ខុមានសេចក្តីសម្គាល់ក្នុងវត្ថុដែលមិនគួរខ្ពើមថា គួរខ្ពើមដូចម្តេច គឺភិក្ខុផ្សាយទៅដោយអសុភ ឬនាំទៅដោយការមិនទៀងក្នុងវត្ថុដែលគួរប្រាថ្នា ភិក្ខុរមែងមានការសម្គាល់ក្នុងវត្ថុដែលមិនគួរខ្ពើមថា គួរខ្ពើមយ៉ាងនេះ ។ ភិក្ខុជាអ្នកមានសេចក្តីសម្គាល់ក្នុងវត្ថុដែលគួរខ្ពើមផង និងមិនគួរខ្ពើមផងថា មិនគួរខ្ពើមដូចម្តេច គឺភិក្ខុរមែងផ្សាយមេត្តាទៅ ឬបង្អោនចូលទៅដោយភាពជាធាតុ ក្នុងវត្ថុដែលមិនគួរប្រាថ្នាផង និងគួរប្រាថ្នាផង យ៉ាងនេះ ឈ្មោះថា ជាអ្នកមានសេចក្តីសម្គាល់ក្នុងវត្ថុដែលគួរខ្ពើម និងមិនគួរខ្ពើម ថាមិនគួរខ្ពើម ។ ភិក្ខុ ឈ្មោះថា ជាអ្នកមានសេចក្តីសម្គាល់ក្នុងវត្ថុដែលមិនគួរខ្ពើម និងគួរខ្ពើម ថា គួរខ្ពើមដូចម្តេច គឺភិក្ខុផ្សាយអសុភទៅ ឬបង្អោនទៅជារបស់មិនទៀង ក្នុងវត្ថុដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាយ៉ាងនេះថា ជាអ្នកមានសេចក្តីសម្គាល់ក្នុងវត្ថុមិនគួរខ្ពើម និងគួរខ្ពើម ថាគួរខ្ពើម ។ ភិក្ខុជាអ្នកព្រងើយ មានសតិសម្បជញ្ញៈ វៀរវត្ថុដែលគួរខ្ពើម មិនគួរខ្ពើម និងវត្ថុទាំង ២ យ៉ាងនោះបានជាសមុច្ឆេទដូចម្តេច គឺភិក្ខុក្នុងធម្មវិន័យនេះ ឃើញរូបដោយភ្នែក មិនត្រេកអរ មិនអាក់អន់ ជាអ្នកព្រងើយៗ មានសតិសម្បជញ្ញៈ ។បេ។ ដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្ត មិនត្រេកអរ មិនអាក់អន់ ជាអ្នកព្រងើយៗ មានសតិសម្បជញ្ញៈ យ៉ាងនេះ ឈ្មោះថា ជាអ្នកវៀរវត្ថុដែលគួរខ្ពើម មិនគួរខ្ពើម និងវត្ថុទាំង ២ យ៉ាងនោះបានជាសមុច្ឆេទ ជាអ្នកព្រងើយៗ មានសតិ-

*សម្បជញ្ញៈ ។*

*ឯសេចក្តីសៅហ្មង គឺការពេញចិត្តផង មិនពេញចិត្តផង ពេញចិត្ត និង មិនពេញចិត្តផង រមែងប្រើបានក្នុងន័យដំបូង ក្នុងបណ្តាន័យទាំង ៣ នេះ ។ ការមិនសៅហ្មងក៏រមែងប្រើបាន ។ ក្នុងន័យទី ២ សង្កិលេសរមែងប្រើបាន ។ ក្នុងន័យទី ៣ ការសៅហ្មងរមែងប្រើបាន ។ ពាក្យដែលលោកពោលទៀតថា ការសៅហ្មងទី ១ រមែងប្រើបាន ការសៅហ្មង និងការមិនសៅហ្មងទី ២ ក៏ ប្រើបាន ការមិនសៅហ្មងទី ៣ ប៉ុណ្ណោះ ទើបប្រើបាន ។ ពាក្យដ៏សេសក្នុង ទីទាំងពួង ងាយយល់ទាំងអស់ហើយ ។*

**អដ្ឋកថា ឥន្ទ្រិយភាវនាសូត្រ ចប់**

**សូត្រទី ១០ ចប់**

**វគ្គទី ៥ ចប់**

**អដ្ឋកថា ឧបរិបណ្ណាសកសូត្រ ក្នុងមជ្ឈិមនិកាយ**

**ឈ្មោះ បបញ្ចសូទនី ចប់**

**ទុតិយបញ្ញាសក សុត្តន្តសង្គហដ្ឋកថា ដែលប្រដាប់ដោយ ៥ វគ្គ ចប់**

មជ្ឈិមនិកាយ ដែលហៅថា មហាវិបស្សនានេះ មានលម្អ ៣ យ៉ាង គឺ លម្អខាងដើម ព្រោះទ្រង់ផ្ដើមថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងធម្មមូលបរិយាយទាំងពួងដល់អ្នកទាំងឡាយ ក្នុងកណ្ដាល ឈ្មោះថា មានលម្អ ព្រោះពាក្យថា **សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតក អព្ភូតធម្ម វេទល្ល** ឈ្មោះថា លម្អខាងចុង ព្រោះពាក្យថា ព្រះអរិយៈ មានឥន្ទ្រិយអប់រំហើយ ដែលព្រះមានព្រះភាគទ្រង់សម្ដែងហើយ មជ្ឈិមនិកាយនោះ ចប់បរិបូណ៌ដោយអំណាចការពង្រីកសេចក្ដីហើយ ។

# និគមគាថា

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ខ្ញុំដែលលោកម្ចាស់ពុទ្ធមិត្តត្ថេរ ជាអ្នកមានការជីងល្អ ធ្លាប់នៅជាមួយគ្នាមក ត្រង់កំពង់មយូរសូត្រ អារាធនាហើយ បានផ្ដើមធ្វើអដ្ឋកថា ឈ្មោះ បបញ្ចសូទនីនៃមជ្ឈិមនិកាយដ៏ប្រសើរ សម្រាប់កម្ចាត់វាទៈរបស់អ្នកដទៃ បបញ្ចសូទនីនោះ កាន់យកសារៈអំពីមហាអដ្ឋកថាចប់ហើយ ។

អដ្ឋកថាឈ្មោះ បបញ្ចសូទនីនោះ ចប់ហើយដោយភាណវារទាំងឡាយនៃបាលីប្រមាណ ១០៧ ភាណវារ សូម្បីវិសុទ្ធិមគ្គដែលមានប្រមាណ ៥៩ ភាណវារ ដែលខ្ញុំបានរចនា ក៏ដើម្បីប្រយោជន៍ដល់ការប្រកាសអត្ថ ដោយភាណវារទាំងឡាយ ព្រោះហេតុនោះ អដ្ឋកថានេះក្ដី វិសុទ្ធិមគ្គនោះក្ដី ដោយន័យនៃការរាប់គាថា គប្បីដឹងថា មាន ១៦៦ គាថា ដោយភាណវារ មាន ១៦៦ ភាណវារ ដោយប្រការដូច្នេះ ។ ទើបខ្ញុំកាន់យកសារៈក្នុងមូលអដ្ឋកថា

ដែលប្រកាសលទ្ធិនៃព្រះថេរៈក្នុងមហាវិហារ រចនាអដ្ឋកថានេះ បានចូលទៅក្នុងគំនរបុណ្យណា ដោយបុណ្យនោះ សូមសត្វលោក មានសុខគ្រប់កាលចុះ ។

អដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី ដែលព្រះថេរៈប្រដាប់ដោយឈ្មោះ វិជ្ជា និងសេចក្ដីព្យាយាមបរិសុទ្ធក្រៃលែង ដែលជាហេតុឲ្យកើតឡើងព្រមនៃគុណ មានសីល អាចារ ការទៀងត្រង់ និងការទន់ភ្លន់ជាដើម ឲ្យកើតឡើងព្រមហើយ ជាអ្នកអាចឈានចុះក្នុងព្រៃស្ដុក គឺលទ្ធិរបស់ខ្លួន និងលទ្ធិរបស់អ្នកដទៃ ដែលប្រកបដោយការដឹងច្បាស់ និងការឈ្លាស ជាអ្នកមានបដិភាណ ដែលមិនមានអ្វីមួយ ឬ បុគ្គលណាម្នាក់មករារាំងបាន ក្នុងសាសនារបស់ព្រះសាស្ដា ព្រមទាំងអដ្ឋកថា ដែលផ្សេងដោយការរៀនបិដក ៣ ជាអ្នកវេយ្យាករណ៍ធំ ជាអ្នកប្រកបដោយវាចា ដែលបន្លឺចេញមកផ្អែមពីរោះ នាំឲ្យកើតសេចក្ដីសុខ ដោយការដល់ព្រមនៃការធ្វើ ជាអ្នកមានវាទៈបន្លឺយ៉ាងត្រឹមត្រូវ ប្រសើរជាងពួកវាគ្មិន ជាមហាកវី ជាគ្រឿងប្រដាប់វង្សនៃពួកថេរៈមហាវិហារ ជាប្រទីបនៃថេរវង្ស ជាអ្នកមានប្រាជ្ញាតាំងមាំល្អហើយ ក្នុងឧត្តរិមនុស្សធម្ម ដែលប្រដាប់ដោយគុណ មានអភិញ្ញា ៦ ជាដើម មានបដិសម្ភិទាជាបរិវារ ជាអ្នកមានសេចក្ដីបរិសុទ្ធិដ៏វិសាល មានឈ្មោះដើមថា ធេយ្យៈ ពួកគ្រូកាន់យកហើយថា ពុទ្ធឃោស បានធ្វើការរចនាហើយ ។

សូម្បីឈ្មោះថា ពុទ្ធៈ របស់ព្រះពុទ្ធ ជាអ្នកមានហឫទ័យស្អាត ជាតាទិ-បុគ្គល ជាអ្នកចម្រើនបំផុតក្នុងលោក ជាអ្នកស្វែងរកគុណធំ នៅប្រព្រឹត្តទៅក្នុងលោកដរាបណា សូមបបញ្ចសូទនីនេះ សម្ដែងន័យនៃការបរិសុទ្ធិ នៃការ

*ឃើញរបស់ពួកកុលបុត្រដែលស្វែងរកគុណ ជាគ្រឿងវេីខ្ទចេញចាកលោក ចូរតាំងនៅក្នុងលោកជរាបនោះ ។*

*អដ្ឋកថា ឈ្មោះបបញ្ចសូទនី ខ្ញុំដល់ស្ថានដ៏បរិសុទ្ធ ប្រាសចាកអន្តរាយ យ៉ាងណា មនោរថទាំងឡាយដែលអាស្រ័យធម៌របស់ពួកសត្វ សម្រេច យ៉ាងនោះហោង ។៚*

## អដ្ឋកថា មជ្ឈិមនិកាយ
## ឈ្មោះ បបញ្ចសូទនី ចប់

# ក្បាលទី ១៨

# សុត្តន្តបិដក បាលីប្រែ -២៧

## សន្ទឹកបង្អួលប្រាប់មាតិកា

មាតិកា លេខទំព័រ

### សុញ្ញតវគ្គ


| មាតិកា | | លេខទំព័រ |
|---|---|---|
| ចូឡសុញ្ញតសូត្រទី ១ | ...... ...... ...... ...... ...... ...... ...... | ២ |
| អដ្ឋកថាចូឡសុញ្ញតាសូត្រ | ...... ...... ...... ...... ...... ...... ...... | ១៤ |
| មហាសុញ្ញតសូត្រទី ២ | ...... ...... ...... ...... ...... ...... ...... | ២១ |
| អដ្ឋកថាមហាសុញ្ញតាសូត្រ | ...... ...... ...... ...... ...... ...... .... | ៣៨ |
| អច្ឆរិយព្ភូតធម្មសូត្រទី ៣ | ...... ...... ...... ...... ...... ...... ...... | ៥៤ |
| អដ្ឋកថាអច្ឆរិយព្ភូតធម្មសូត្រ | ...... ...... ...... ...... ...... ...... ....... | ៦៧ |
| ពក្កុលត្ថេរច្ឆរិយព្ភូតសូត្រទី ៤ | ... ...... ...... ...... ...... ...... ...... | ១០០ |
| អដ្ឋកថាពក្កុលត្ថេរច្ឆរិយព្ភូតសូត្រ | ...... ...... ...... ...... ...... ...... ..... | ១០៥ |
| ទន្តភូមិសូត្រទី ៥ | ...... ...... ...... ...... ...... ...... ...... | ១១៤ |
| អដ្ឋកថាទន្តភូមិសូត្រ | ...... ...... ...... ...... ...... ...... ...... | ១៣១ |
| ភូមិជសូត្រទី ៦ | ...... ...... ...... ...... ...... ...... ..... | ១៣៥ |
| អដ្ឋកថាភូមិជសូត្រ | ...... ...... ...... ...... ...... ...... ...... | ១៤៩ |
| អនុរុទ្ធសូត្រទី ៧ | ...... ...... ...... ...... ...... ...... ...... | ១៥០ |
| អដ្ឋកថាអនុរុទ្ធសូត្រ | ...... ...... ...... ...... ...... ...... ...... | ១៦៣ |
| ឧបក្កិលេសសូត្រទី ៨ | ...... ...... ...... ...... ...... ...... ...... | ១៦៨ |
| អដ្ឋកថាឧបក្កិលេសសូត្រ | ...... ...... ...... ...... ...... ...... ...... | ១៩១ |
| ពាលបណ្ឌិតសូត្រទី ៩ | ...... ...... ...... ...... ...... ...... ...... | ២០១ |
| អដ្ឋកថាពាលបណ្ឌិតសូត្រ | ...... ...... ...... ...... ...... ...... ..... | ២៣១ |

ទេវទូតសូត្រទី ១០ ...... ...... ...... ...... ...... ...... ....... ២៥៩
អដ្ឋកថាទេវទូតសូត្រ ...... ...... ...... ...... ...... ...... ....... ២៧៧

# សុត្តន្តបិដក ចាលីប្រែ -២៨

ភទ្ទេករត្តសូត្រទី ១ ...... ...... ...... ...... ...... ...... ....... ២៨៨
អដ្ឋកថាភទ្ទេករត្តសូត្រ ...... ...... ...... ...... ...... ...... ........ ២៩៤
អានន្ទភទ្ទេករត្តសូត្រទី ២ ...... ...... ...... ...... ...... ...... ........ ២៩៩
អដ្ឋកថាអានន្ទភទ្ទេករត្តសូត្រ ...... ...... ...... ...... ...... ...... ........ ៣០៧
មហាកច្ចានភទ្ទេករត្តសូត្រទី ៣ ...... ...... ...... ...... ...... ......... ៣០៨
អដ្ឋកថាមហាកច្ចានភទ្ទេករត្តសូត្រ ...... ...... ...... ...... ...... ......... ៣២៦
លោមសកង្គិយសូត្រទី ៤ ...... ...... ...... ...... ...... ......... ៣២៩
អដ្ឋកថាលោមសកង្គិយភទ្ទេករត្តសូត្រ ..... ...... ...... ...... .......... ៣៣៨
ចូឡកម្មវិភង្គសូត្រទី ៥ ...... ...... ...... ...... ...... ......... ៣៤០
អដ្ឋកថាចូឡកម្មវិភង្គសូត្រ ...... ...... ...... ...... ...... ......... ៣៥៣
មហាកម្មវិភង្គសូត្រទី ៦ ...... ...... ...... ...... ...... ......... ៣៦៤
អដ្ឋកថាមហាកម្មវិភង្គសូត្រ ...... ...... ...... ...... ...... ......... ៣៨២
សឡាយតនវិភង្គសូត្រទី ៧ ...... ...... ...... ...... ...... ......... ៣៩០
អដ្ឋកថាសឡាយតនវិភង្គសូត្រ ...... ...... ...... ...... ...... ......... ៤០៥
ឧទ្ទេសវិភង្គសូត្រទី ៨ ...... ...... ...... ...... ...... ...... ........ ៤១៥
អដ្ឋកថាឧទ្ទេសវិភង្គសូត្រ ...... ...... ...... ...... ...... ...... ........ ៤៣២
អរណវិភង្គសូត្រទី ៩ ...... ...... ...... ...... ...... ...... .......... ៤៣៦
អដ្ឋកថាអរណវិភង្គសូត្រ ...... ...... ...... ...... ...... ...... ......... ៤៥៥
ធាតុវិភង្គសូត្រទី ១០ ...... ...... ...... ...... ...... ...... .......... ៤៥៩
អដ្ឋកថាធាតុវិភង្គសូត្រ ...... ...... ...... ...... ...... ...... .......... ៤៨០

សច្ចវិភង្គសូត្រទី ១១ ...... ...... ...... ...... ...... ...... .......... ៥២៦
អដ្ឋកថាសច្ចវិភង្គសូត្រ ...... ...... ...... ...... ...... ...... .......... ៥៣៥
ទក្ខិណាវិភង្គសូត្រទី ១២ ...... ...... ...... ...... ...... ...... .......... ៥៣៩
អដ្ឋកថាទក្ខិណាវិភង្គសូត្រ ...... ...... ...... ...... ...... ...... .......... ៥៥០

## សឡាយតនវគ្គ

អនាថបិណ្ឌិកោវាទសូត្រទី ១ ...... ...... ...... ...... ...... ............ ៥៦៩
អដ្ឋកថាអនាថបិណ្ឌិកោវាទសូត្រ ...... ...... ...... ...... ...... ............ ៥៨២
ឆន្នោវាទសូត្រទី ២ ...... ...... ...... ...... ...... ...... ............ ៥៨៨
អដ្ឋកថាឆន្នោវាទសូត្រ ...... ...... ...... ...... ...... ...... ............ ៥៩៦
បុណ្ណោវាទសូត្រទី ៣ ...... ...... ...... ...... ...... ...... ............ ៥៩៩
អដ្ឋកថាបុណ្ណោវាទសូត្រ ...... ...... ...... ...... ...... ...... ............ ៦០៦
អត្ថរបស់ ទម សព្វ ...... ...... ...... ...... ...... ...... ............ ៦០៧
នន្ទកោវាទសូត្រទី ៤ ...... ...... ...... ...... ...... ...... ............ ៦១៨
អដ្ឋកថានន្ទកោវាទសូត្រ ...... ...... ...... ...... ...... ...... ............ ៦៤០
ចូឡរាហុលោវាទសូត្រទី ៥ ...... ...... ...... ...... ...... ........... ៦៤៨
អដ្ឋកថារាហុលោវាទសូត្រ ...... ...... ...... ...... ...... ............ ៦៥៥
ឆឆក្កសូត្រទី ៦ ...... ...... ...... ...... ...... ........... ៦៥៨
អដ្ឋកថាឆឆក្កសូត្រ ...... ...... ...... ...... ...... ........... ៦៧៤
សឡាយតនវិភង្គសូត្រទី ៧ ...... ...... ...... ...... ...... ........... ៦៧៩
អដ្ឋកថា សឡាយតវិភង្គសូត្រ ..... ...... ...... ...... ...... ........... ៦៨៨
នគរវិន្ទេយ្យសូត្រទី ៨ ...... ...... ...... ...... ...... ......... ៦៩១
អដ្ឋកថានគរវិន្ទេយ្យសូត្រ ...... ...... ...... ...... ...... ......... ៦៩៨
បិណ្ឌបាតបារិសុទ្ធិសូត្រទី ៩ ...... ...... ...... ...... ...... ......... ៦៩៩

អដ្ឋកថាបិណ្ឌបាតបារិសុទ្ធិសូត្រ ...... ...... ...... ...... ...... ......... ៧០៨
ឥន្ទ្រិយភាវនាសូត្រទី ១០ ...... ...... ...... ...... ...... ......... ៧១០
អដ្ឋកថាឥន្ទ្រិយភាវនាសូត្រ ...... ...... ...... ...... ...... ....... ៧២២